មេរៀន ភាគ ២

# ក្រមរដ្ឋប្បវេណី
# និង
# ក្រមនីតិវិធីរដ្ឋប្បវេណី

សមិទ្ធផលរបស់
គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ

## ក្រសួងយុត្តិធម៌

# មេរៀនស្តីពី
# ក្រមរដ្ឋប្បវេណី
# និង
# ក្រមនីតិវិធីរដ្ឋប្បវេណី

## ភាគ ២

រៀបរៀងដោយ
គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
ក្រសួងយុត្តិធម៌
រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

បោះពុម្ពលើកទី ១
នៅ **ភ្នំពេញ** ខែ វិច្ឆិកា ឆ្នាំ ២០១៦

# មេរៀនស្តីពី
# " ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី"
# ភាគ ២

**បោះពុម្ពនៅរាជធានីភ្នំពេញ ឆ្នាំ២០១៦**

**ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី ៤**

**របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា**

**និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន** (JICA)

**រក្សាសិទ្ធិនិពន្ធ និងថតចម្លងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធ ច្បាប់ និងតុលាការ**

**ដំណាក់កាលទី ៤ របស់ក្រសួងយុត្តិធម៌**

**និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន** (JICA)

ISBN-13: 978-99963-26-10-3

# បុព្វកថា

សៀវភៅនេះ គឺជាសមិទ្ធផលដ៏មានសារសំខាន់មួយដែលត្រូវបានចងក្រងរៀបចំឡើង តាមរយៈគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និង ទីភ្នាក់ងារសហប្រតិបត្តិការណ៍អន្តរជាតិនៃប្រទេសជប៉ុន (ហៅកាត់ថា JICA)។ ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារ JICA បានសហការគ្នាដើម្បីអភិវឌ្ឍប្រព័ន្ធច្បាប់លើវិស័យរដ្ឋប្បវេណីចាប់តាំងពីដើមឆ្នាំ១៩៩៩ តាមរយៈគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងតុលាការ ដំណាក់កាលទី១ ដល់ទី៣។ នៅក្នុងដំណាក់កាលទី១ ដល់ទី៣ គម្រោងបានសម្រេចនូវសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី រួមទាំងច្បាប់ និងបទដ្ឋានគតិយុត្តដទៃទៀតដែលចាំបាច់ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី។ ក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានដាក់ឲ្យអនុវត្តទូទាំងប្រទេសនៅខែកក្កដា ឆ្នាំ២០០៧ ចំណែកឯក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យប្រើនៅក្នុងឆ្នាំ២០០៧ ព្រមទាំងត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងខែធ្នូ ឆ្នាំ ២០១១។

ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី គឺមានសារសំខាន់នៅក្នុងនីតិរដ្ឋប្បវេណី ដូច្នេះ អ្នកអនុវត្តច្បាប់ត្រូវតែពង្រីកនូវការយល់ដឹងរបស់ខ្លួនឲ្យបានស៊ីជម្រៅ និងទូលំទូលាយទាក់ទងនឹងក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី។

គម្រោងនៅក្នុងដំណាក់កាលទី៤នេះ ត្រូវបានចាប់ផ្តើមនៅក្នុងខែមេសា ឆ្នាំ២០១២ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ដែលជាប្រធានគម្រោង និង លោកជំទាវ **ចាន់ សុន្ទរាវី** រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ និង ឯកឧត្តម **ឈន ព្រលឹង** ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដែលអ្នកគ្រប់គ្រងគម្រោង រួមទាំងមានការជួយសម្របសម្រួលពីឯកឧត្តម **ម៉ុន ហុន** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ គម្រោងនេះអាចដំណើរទៅបានដោយមានការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពីទីភ្នាក់ងារ JICA តាមរយៈជំនាញការជាច្រើន។ នៅក្នុងគម្រោងដំណាក់កាលទី៤នេះ មានកញ្ញា Nishimura Emiko និងលោក Matsubara Sadao (អតីតជំនាញការ និងប្រធានទីប្រឹក្សាច្បាប់) និង លោក Tsuji Yasuhiko ដែលជាជំនាញការ និងជាប្រធានទីប្រឹក្សាច្បាប់។ គម្រោងក្នុងដំណាក់កាលទី៤នេះ មានគោលដៅក្នុងការពង្រឹងសមត្ថភាពដល់អ្នកអនុវត្តច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីឲ្យមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត

ស្ថាប័នសំខាន់ៗនៅក្នុងវិស័យច្បាប់ដែលបានចូលរួមនៅក្នុងគម្រោងនេះ មានដូចជា ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ ស្ថាប័ននីមួយៗ បានបង្កើតនូវក្រុមការងារដើម្បីពិភាក្សានូវបញ្ហាដែលទាក់ទងនឹងទ្រឹស្តី ក៏ដូចជាបញ្ហាដែលទាក់ទងនឹងការអនុវត្តជាក់ស្តែងដែលកើតមានឡើងទាក់ទងនឹងក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ជាមួយនឹងជំនាញការជនជាតិជប៉ុន។ ជាគោលការណ៍ ក្រុមការងារនីមួយៗ ត្រូវជួបប្រជុំ ១ដងក្នុងមួយសប្តាហ៍។ បន្ថែមពីលើក្រុមការងារប្រចាំសប្តាហ៍ កិច្ចប្រជុំក្រុមការងារចម្រុះត្រូវបានធ្វើឡើងជារៀងរាល់ ៣ ឬ ៤ខែម្តង ដោយមានការចូលរួមពីក្រុមការងារទាំងបួនស្ថាប័ន ដើម្បីពិភាក្សាលើបញ្ហាច្បាប់សំខាន់ៗ។

សៀវភៅនេះ គឺជាកម្រងឯកសារដែលបានបង្កើតឡើងដោយក្រុមការងារទាំងបួនស្ថាប័ន ដែលមានដូចជា របាយការណ៍នៃការពិភាក្សា សំណួរចម្លើយ រួមទាំងឯកសារមេរៀន។ ខ្លឹមសារនៃឯកសារទាំងនេះ គឺជាប្រធានបទសំខាន់ៗ ដែលទាក់ទងនឹងក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងរាប់បញ្ចូលនូវករណីជាក់ស្តែង និង ករណីជាលក្ខណៈទ្រឹស្តីផងដែរ។ ដូច្នេះ សៀវភៅនេះមានអត្ថប្រយោជន៍ និង ប្រមូលផ្តុំនូវព័ត៌មានសំខាន់សម្រាប់អនុវត្តច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះអាចនឹងជួយដល់អ្នកអនុវត្តច្បាប់ក្នុងការពង្រីកនូវការយល់ដឹងរបស់ខ្លួនឲ្យកាន់តែស៊ីជម្រៅទាក់ទងនឹងក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី។

<u>កំណត់សម្គាល់៖</u>

សៀវភៅមេរៀនស្តីពី "ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី" ភាគ១ ត្រូវបានចងក្រងឡើងជាលើកទី១ ដោយយកសមិទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំ២០១២ និង ឆ្នាំ២០១៣ ព្រមទាំងត្រូវបានបោះពុម្ពលើកទី១ នៅក្នុងខែធ្នូ ឆ្នាំ២០១៥។

ចំពោះសៀវភៅនេះវិញ គឺជាសៀវភៅ ភាគ២ ដែលបន្តខ្លឹមសារពីសៀវភៅ ភាគ១ ហើយត្រូវបានចងក្រងឡើងជាលើកទី២ ដោយយកសមិទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំ២០១៤ ២០១៥ និង ដើមឆ្នាំ២០១៦ ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈជាផ្លូវការរបស់អាជ្ញាធរពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

ឯកសារនេះត្រូវបានបោះពុម្ពលើកទី១ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦។

# ក្រុមការងារ
# ក្រសួងយុត្តិធម៌

# មាតិកា

**ទំព័រ**


**៣.មោឃភាព និងការលុបចោល** ........ 1

៣.១.មោឃភាព ........ 1

៣.១.១. អានុភាព ........ 2

៣.១.២.បុគ្គលដែលអាចអះអាងនូវមោឃភាព( មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី ) ........ 2

៣.២.ការលុបចោល ........ 3

៣.២.១.អានុភាពនៃការលុបចោល ........ 4

៣.២.២. វិធីនៃការលុបចោល ........ 5

៣.២.៣.អ្នកដែលមានសិទ្ធិលុបចោល ........ 6

៣.២.៤.សច្ចានុមតិ ........ 10

ក. វិធីធ្វើសច្ចានុមតិ និង អានុភាព ........ 10

ខ. អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ ........ 10

គ.ពេលដែលអ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន(មាត្រា៣៦១នៃក្រមរដ្ឋប្បវេណី ).....12

ឃ.សច្ចានុមតិដែលច្បាប់កំណត់ ........ 13

៣.២.៥. អាជ្ញាយុកាល ........ 15

**៤.ការតំណាង** ........ 20

៤.១.និយមន័យ ........ 20

៤.២.ប្រភេទ និងអត្ថប្រយោជន៍ ........ 21

៤.៣.មូលហេតុនៃការកកើតសិទ្ធិតំណាង ........ 21

៤.៤.ទំហំនៃសិទ្ធិតំណាង ........ 24

៤.៥.លក្ខខណ្ឌ និងអានុភាពនៃសិទ្ធិតំណាង ........ 26

៤.៦.ការកម្រិតសិទ្ធិតំណាង ........ 27

៤.៧.ការរលត់សិទ្ធិតំណាង ........ 30

៤.៨. ការតំណាងដោយគ្មានសិទ្ធិ ........ 32

៤.៨.១. អត្ថន័យ ........ 32

៤.៨.២. អានុភាពនៃអំពើតំណាងដោយគ្មានសិទ្ធិ ........ 32

៤.៨.៣. សច្ចានុមតិដោយម្ចាស់សិទ្ធិ( មាត្រា ៣៧០ នៃក្រមរដ្ឋប្បវេណី ) ........ 33

៤.៨.៤.សិទ្ធិដាស់តឿន និង សិទ្ធិលុបចោលរបស់ភាគីម្ខាងទៀត ........ 34

៤.៨.៥.ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ ........ 36

៤.៩.ការតំណាងដែលមានលក្ខណៈជារូបភាព ........ 38

៤.៩.១.លក្ខខណ្ឌនៃការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសទំហំនៃសិទ្ធិ ........ 39

៤.៩.២.លក្ខខណ្ឌនៃការតំណាងដែលមានលក្ខណៈជារូបភាពក្រោយសិទ្ធិតំណាងបានរលត់........ 39

៤.៩.៣.លក្ខខណ្ឌនៃការតំណាងដែលមានលក្ខណៈជារូបភាពតាមរយៈការបង្ហាញថាបានប្រគល់

សិទ្ធិតំណាង ........................................ 40
៤.១០.វិការៈនៃអំពើតំណាង ........................................ 41
៤.១១.សមត្ថភាពនៃអ្នកតំណាង ........................................ 42
៤.១២.អនុតំណាង ........................................ 43
៤.១២.១. លក្ខខណ្ឌ ........................................ 44
៤.១២.២. ការទទួលខុសត្រូវរបស់អ្នកតំណាងក្នុងករណីដែលបានជ្រើសតាំងអនុតំណាង ........................................ 44
៤.១២.៣. ឋានៈនៃអានុតំណាង ........................................ 47
**៥.កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន** ........................................ 48
៥.១.និយមន័យ ........................................ 48
៥.២.ពាក្យបច្ចេកទេស ........................................ 48
៥.៣.តួនាទីនៃកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ........................................ 49
៥.៤.លក្ខខណ្ឌ ........................................ 51
៥.៥. ទំនាក់ទំនងរវាងគូភាគី ........................................ 52
៥.៥.១. ទំនាក់ទំនងរវាងអ្នកទទួលផលប្រយោជន៍ និង អ្នកព្រមផ្តល់ ........................................ 52
៥.៥.២.ទំនាក់ទំនងរវាងអ្នកទទួលផលប្រយោជន៍ និងអ្នកទាមទារការផ្តល់ ........................................ 52
៥.៥.៣. ទំនាក់ទំនងរវាងអ្នកទាមទារការផ្តល់ និងអ្នកព្រមផ្តល់ ........................................ 53
៥.៦.មោឃភាព ការលុបចោល និង ការរំលាយកិច្ចសន្យា ........................................ 53

## ៣.មោឃភាព និងការលុបចោល

ទោះបីកិច្ចសន្យាត្រូវបានបង្កើតឡើងក៏ដោយ ក៏កិច្ចសន្យាទាំងនោះមិនប្រាកដថាអាចអនុវត្តបាននោះទេ។ កិច្ចសន្យាមួយចំនួនត្រូវបានច្បាប់ចាត់ទុកជាមោឃៈហើយកិច្ចសន្យាមួយចំនួនទៀតអាចត្រូវភាគីសុំលុបចោល ដោយសារមានវិការៈ ឬ ដោយសារការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។

ក្រៅពីកិច្ចសន្យា សកម្មភាពឯកតោភាគីក៏ត្រូវបានចាត់ទុកជាមោឃៈ ឬ ត្រូវបានលុបចោលតាមរយៈការបង្ហាញឆន្ទៈមានវិការៈ ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពជាដើម ដូចករណីកិច្ចសន្យាផងដែរ (មាត្រា ៣១២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

### ៣.១.មោឃភាព

ទោះបីជាកិច្ចសន្យា ឬ សកម្មភាពឯកតោភាគីត្រូវបានបង្កើតឡើងក៏ដោយ ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនោះកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ (មាត្រា ៣៥៧ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ទី ១ (ករណីកិច្ចសន្យាដែលមានខ្លឹមសារផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ)៖

- កិច្ចសន្យាខ្ចីបរិភោគដោយយកអត្រាការប្រាក់លើសពីច្បាប់កំណត់
- កិច្ចសន្យាលក់ទិញគ្រឿងញៀនខុសច្បាប់
- កិច្ចសន្យាឲ្យប្តីប្រពន្ធលែងលះគ្នា។

ឧទាហរណ៍ទី ២ (ករណីសកម្មភាពឯកតោភាគីដែលមានខ្លឹមសារផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ)៖

កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ A បានបង្កើតនីតិបុគ្គលមូលនិធិមួយក្នុងគោលបំណងប្រព្រឹត្តបទល្មើស (មាត្រា១១០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ➡ សកម្មភាពបង្កើតនីតិបុគ្គលមូលនិធិនេះត្រូវចាត់ទុកជាមោឃៈ។

ទោះបីអត្ថន័យនៃកិច្ចសន្យា ឬ សកម្មភាពឯកតោភាគីមិនផ្ទុយទៅនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អក៏ដោយ តែបើសកម្មភាពនោះផ្ទុយទៅនឹងទម្រង់ដែលច្បាប់កំណត់ក៏ត្រូវចាត់ទុកជាមោឃៈផងដែរ (មាត្រា ៣៥៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ទី៣ (កិច្ចសន្យាដែលមានទម្រង់ខុសច្បាប់)៖ កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ A និង B បានព្រមព្រៀងគ្នាលក់ទិញអចលនវត្ថុ ប៉ុន្តែ មិនបានធ្វើឡើងដោយលិខិតយថាភូតទេ ➡ កិច្ចសន្យានេះត្រូវចាត់ទុកជាមោឃៈ (មាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ទី៤ (សកម្មភាពឯកតោភាគីដែលមានទម្រង់ខុសច្បាប់)៖

កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ A បានបង្កើតមតកសាសន៍ដោយលិខិតឯកជន ប៉ុន្តែ មិនបានចុះហត្ថលេខាទេ ➡ មតកសាសន៍បែបនេះត្រូវចាត់ទុកជាមោឃៈ (មាត្រា ១១៧៤ កថាខណ្ឌទី១ និង មាត្រា ១១៧០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

**៣.១.១. អានុភាព**

នៅពេលដែលសកម្មភាពមួយត្រូវបានចាត់ទុកជាមោឃៈ មានន័យថាសកម្មភាពនោះមិននាំឲ្យបង្កើតអានុភាពតាំងពីដំបូង។ ការណ៍ដែលនរណាម្នាក់អះអាងអំពីមោឃភាពនៃសកម្មភាពនោះគឺជា ការបញ្ជាក់ថាសកម្មភាពនោះមិនមានសុពលភាពតាំងពីដំបូង ហើយមិនធ្លាប់មានអានុភាពអ្វីទាល់តែសោះ ។ និយាយរួមសកម្មភាពដែលត្រូវបានចាត់ទុកជាមោឃៈ ទោះបីជាមិនមាននរណាម្នាក់អះអាងអំពីមោឃភាពនៃកិច្ចសន្យាក៏ដោយ ក៏មិនមានអានុភាពដែរ។ ត្រង់ចំណុចនេះ គឺខុសពីការលុបចោល មានន័យថា ក្នុងករណីការលុបចោលកិច្ចសន្យាមានអានុភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល ប្រើប្រាស់សិទ្ធិលុបចោល ដោយអះអាងអំពីការលុបចោល (មាត្រា ៣៥៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ហើយនៅពេលដែលសិទ្ធិលុបចោលត្រូវបានអនុវត្តនោះសកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង (មាត្រា ៣៥៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ នៅក្នុងករណីឧទាហរណ៍ទី៣ ទោះបីជា កិច្ចសន្យានេះត្រូវបានភាគីអះអាងអំពី មោឃភាពនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ ក៏ដោយ ក៏មោឃភាពនេះបានកើតមានឡើងតាំងពីដំបូងគឺ ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ មានន័យថា ចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ មកម្ល៉េះ ដែលកិច្ចសន្យាមិនមានសុពលភាព។ ប៉ុន្តែ មិនមែនមានន័យថាកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ តាមអានុភាពប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ នោះទេ។ កិច្ចសន្យានេះ មោឃភាពតាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ ប៉ុន្តែ ការបញ្ជាក់អំពីមោឃភាពគឺនៅ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣។ ដូចនេះ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ កិច្ចសន្យានេះមិនមានអត្ថិភាព និង មិនមានអានុភាពឡើយ ទោះបី រូបភាពជាក់ស្តែងកន្លងមកមើលទៅហាក់ដូចជាកិច្ចសន្យានេះមានអត្ថិភាពក៏ដោយ។

**៣.១.២. បុគ្គលដែលអាចអះអាងនូវមោឃភាព(មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី)**

ក្នុងករណីដែលសកម្មភាពមួយផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ មិនត្រឹមតែភាគីប៉ុណ្ណោះទេ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យាបានដែរ។ ទោះបីជា

ក្នុងករណីមោឃភាពដោយសារទម្រង់នៃសកម្មភាពនោះផ្ទុយច្បាប់ក៏ដោយ ជនដែលអាចអះអាងអំពីមោឃភាព មិនមែនមានតែភាគីប៉ុណ្ណោះទេ ជនណាក៏ដោយ ក៏អាចអះអាងបានដែរ។ ក៏ប៉ុន្តែ ច្បាប់បានកំណត់អំពីជនដែល អាចអះអាងមោឃភាពបាន លុះត្រាតែជននោះមានប្រយោជន៍ក្នុងការប្តឹង (មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។




ឧទាហរណ៍៖ A បានចុះកិច្ចសន្យាលក់ទិញដីជាមួយ B ក្នុងតម្លៃ ១០០០០$ ប៉ុន្តែ ដោយសារតែ ការចុះកិច្ចសន្យានោះមិនបានធ្វើឡើងជាលិខិតយថាភូត ដូចនេះកិច្ចសន្យាត្រូវបាន មោឃភាព។ ហេតុដូច្នេះ A អាចដាក់ពាក្យបណ្តឹងបញ្ជាក់អំពីមោឃភាពនៃកិច្ចសន្យា និង ដាក់ពាក្យបណ្តឹងសុំបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចរបស់ A ចំពោះ B បាន។ តើ C ដែលជាមិត្តភក្តិរបស់ A អាចប្តឹងសុំឲ្យបញ្ជាក់ពីមោឃភាពនៃកិច្ចសន្យា និង អាចដាក់ពាក្យបណ្តឹងសុំបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចរបស់ A យោងទៅតាមកិច្ចសន្យា នោះបានដែរ ឬទេ? C មិនអាចដាក់ពាក្យបណ្តឹងសុំឲ្យបញ្ជាក់មោឃភាពកិច្ចសន្យារវាង A និង B ឬសុំឲ្យបញ្ជាក់អំពីនត្ថិភាពកាតព្វកិច្ចរបស់ A បានទេ ដោយហេតុថា C មិនមែនជាភាគីនៃវិវាទ និង មិនមានផលប្រយោជន៍នៃបណ្តឹងនោះទេ។

លើសពីនេះ តើ D ដែលជាអ្នកជួលដីអាចដាក់ពាក្យបណ្តឹងសុំបញ្ជាក់ពីមោឃភាពនៃកិច្ចសន្យារវាង A និង B បានដែរឬទេ? តើ D អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យារវាង A និង B ហើយ អាចដាក់ពាក្យបណ្តឹងសុំបញ្ជាក់ពីនត្ថិភាពនៃកាតព្វកិច្ចបង់ថ្លៃរបស់ D ចំពោះ B បានដែរ ឬ ទេ? (អាច ឬ មិនអាច អាស្រ័យទៅលើការបកស្រាយថា តើ D មានផលប្រយោជន៍ ឬ គ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងដែរ ឬអត់?)។

**៣.២.ការលុបចោល**

ទោះបីជាកិច្ចសន្យា ឬ សកម្មភាពឯកតោភាគីត្រូវបានបង្កើតឡើងក៏ដោយ ប្រសិនបើមានមូលហេតុនៃការលុបចោលសកម្មភាពនោះ អ្នកមានសិទ្ធិលុបចោលអាចលុបចោលសកម្មភាពនោះបាន (មាត្រា៣៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ មូលហេតុនៃការលុបចោលមានដូចជា ការបង្ហាញឆន្ទៈដែលមានវិការៈ (មាត្រា ៣៤៦ ដល់ មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី) កង្វះសមត្ថភាពខាងឆន្ទៈ (មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី) និងការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព(មាត្រា១៨ មាត្រា២៦ និង មាត្រា៣០ នៃក្រមរដ្ឋប្បវេណី )។

ឧទាហរណ៍ទី៥ (ករណីលុបចោលកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈមានវិការៈ)៖

A (អ្នកលក់)ចង់លក់ម៉ូតូរបស់ខ្លួនដែលកំពុងប្រើប្រាស់ឲ្យទៅ B (អ្នកទិញ)។ ម៉ូតូរបស់ A ពណ៌ខ្មៅ រីឯ B ចង់បានម៉ូតូពណ៌ខៀវ ប៉ុន្តែ ដោយសារ A ចង់លក់ម៉ូតូរបស់ខ្លួនឲ្យទៅ B A ក៏បានកុហក B ថាម៉ូតូខ្លួនពណ៌ខៀវ។ នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៣ A និង B បានព្រមព្រៀង គ្នាបង្កើតកិច្ចសន្យាលក់ទិញម៉ូតូ ហើយ B បានប្រគល់ប្រាក់គ្រប់ចំនួនទៅឲ្យ A រួចរាល់។ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៣ A បែរជាប្រគល់ម៉ូតូ ១ គ្រឿងពណ៌ខ្មៅទៅឲ្យ B ទៅវិញ។ នៅក្នុងករណីនេះ B អាចលុបចោលកិច្ចសន្យាជាមួយ A បានដោយផ្អែកលើការឆបោក (មាត្រា ៣៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ទី៦ (ករណីលុបចោលសកម្មភាពឯកតោភាគីដោយសារការបង្ហាញឆន្ទៈមានវិការៈ) ៖ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ B បានគម្រាម A ថាបើមិនចុះហត្ថលេខាលើលិខិតលើកលែងកាតព្វកិច្ចចំនួន ១០០០ ដុល្លារ ដែល B មានចំពោះ A ទេ នោះ B នឹងវាយ A ។ A ក៏បានចុះហត្ថលេខា លើលិខិតលើកលែងកាតព្វកិច្ចនោះដោយសារការភ័យខ្លាច។ ក្នុងករណីនេះ A អាចលុបចោលការលើកលែងកាតព្វកិច្ចចំពោះ B ដោយ ផ្អែកលើការគម្រាមកំហែង (មាត្រា ៣៥០ និង មាត្រា ៣១២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ទី៧ (ករណីលុបចោលសកម្មភាពឯកតោភាគីដោយសារការកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈ) ៖ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ A និង B បានផឹកស្រាជាមួយគ្នា។ B ផឹកច្រើនពេកក៏ស្រវឹងខ្លាំងហើយក្រោយពីបាត់បង់សមត្ថភាពក្នុងការវិនិច្ឆ័យគាត់បាននិយាយទៅកាន់ A ថាប្រាក់១០០០ ដុល្លារ ដែល A បានខ្ចីនោះ មិនបាច់សងក៏បានដែរ។ ពាក្យដែល B បាននិយាយជាការបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ច (មាត្រា ៤៧៣ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីនេះ B អាចលុបចោលការលើកលែងកាតព្វកិច្ចបាន (មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ទី៨ (ករណីលុបចោលកិច្ចសន្យាដោយសារការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព) ៖ កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ A(អ្នកលក់) មានអាយុ២០ឆ្នាំនិង B(អ្នកទិញ) មានអាយុ១៥ឆ្នាំ បានបង្កើតកិច្ចសន្យាលក់ទិញម៉ូតូ។ ឪពុកម្ដាយរបស់ B គឺជាអ្នកមានអំណាចមេបាចំពោះ B ប៉ុន្តែ B មិនស្ដាប់បង្គាប់របស់ឪពុកម្ដាយទេ ហើយក៏បានលាក់រឿងលក់ទិញម៉ូតូនេះមិនឲ្យឪពុកម្ដាយដឹង។ ក្នុងករណី នេះ B ឬ ឪពុក ម្ដាយរបស់ B អាចលុបចោលកិច្ចសន្យាដែល B បានធ្វើឡើងជាមួយ A បាន (មាត្រា១៨ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

### ៣.២.១.អានុភាពនៃការលុបចោល

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោលលុបចោលសកម្មភាពនោះ (មាត្រា ៣៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ក្នុងករណីដែលអ្នកដែលមាន

សិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន ហើយសកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង (មាត្រា ៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ មានន័យថាការលុបចោលកិច្ចសន្យាមានអានុភាពប្រតិសកម្ម។

ឧទាហរណ៍៖ សាកល្បងពិចារណាក្នុងករណីដែល A (អ្នកលក់) បានឆបោក B (អ្នកទិញ) ធ្វើកិច្ចសន្យាទិញលក់រថយន្ត។ ក្នុងករណីដែល B បានលុបចោលកិច្ចសន្យា ដោយយោងតាមការឆបោកនៅមុនពេល A និង B អនុវត្តកិច្ចសន្យានោះ កាតព្វកិច្ចរបស់អ្នកទាំងពីរត្រូវបានរលត់ ដូច្នេះ ការអនុវត្តកាតព្វកិច្ចរបស់ A និង B ពុំមានភាពចាំបាច់ទេ។

បន្ទាប់ពី A បានប្រគល់រថយន្តទៅឲ្យ B ហើយ B ក៏បានបង់ប្រាក់ទៅឲ្យ A ហើយដែរ ប្រសិនបើ B បានលុបចោលកិច្ចសន្យាយោងតាមការឆបោក តើករណីនេះនឹងទៅជាយ៉ាងណា? នៅក្នុងករណីនេះ A មានកាតព្វកិច្ចប្រគល់ប្រាក់ទៅ B វិញ ហើយ B ក៏មានកាតព្វកិច្ចប្រគល់រថយន្តទៅឲ្យ A វិញដែរ (កាតព្វកិច្ចប្រគល់យោងតាមសេចក្តីចម្រើនដោយឥតហេតុ)។ ដោយសារតែ B ជាអ្នកដែលទទួលបាននូវផលប្រយោជន៍ដោយសុចរិត ដូច្នេះ ត្រូវសងត្រឹមកម្រិតនៃផលប្រយោជន៍ដែលមាន (មាត្រា៧៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ដោយសារតែ A ជាអ្នកដែលទទួល បាននូវផលប្រយោជន៍ដោយគំនិតទុច្ចរិត ដូច្នេះ ត្រូវសងផលប្រយោជន៍ដែលទទួលបានព្រមទាំងការប្រាក់(មាត្រា ៧៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

### ៣.២.២. វិធីនៃការលុបចោល

ការលុបចោលធ្វើឡើងតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀត ហើយអានុភាពនៃការលុបចោលកិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងបានទៅដល់ភាគីម្ខាងទៀត (មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណី)។ ការលុបចោលអាចធ្វើឡើងនៅក្រៅតុលាការក៏បាន។ ភាគច្រើនការលុបចោលធ្វើឡើងដោយការផ្ញើលិខិតជូនដំណឹងអំពីការបង្ហាញឆន្ទៈលុបចោលទៅភាគីម្ខាងទៀត ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងភាគីអាចធ្វើតាមវិធីណា ក៏បាន (ការផ្ញើសារអេឡិចត្រូនិច ការបង្ហាញឆន្ទៈតាមទូរស័ព្ទ ជាអាទិ៍) ឲ្យតែការបង្ហាញឆន្ទៈលុបចោលនោះបានទៅដល់ភាគីម្ខាងទៀត។

ក្នុងករណីមានវិវាទនៅតុលាការ ភាគីត្រូវបង្ហាញអំពីការទទួលបានការជូនដំណឹងរបស់ភាគីម្ខាងទៀត ហេតុនេះ ភាគីគួរតែប្រើប្រាស់វិធីណាដែលងាយស្រួលបង្ហាញអំពីការទទួលបានការជូនដំណឹងរបស់ភាគីម្ខាងទៀត។ ជាឧទាហរណ៍ការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ(មាត្រា៧នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី) ឬ ភាគីអាចឲ្យភាគីម្ខាងទៀតចុះហត្ថលេខា ឬ ផ្តិតមេដៃ លើលិខិតជូនដំណឹងដើម្បីទុកជាភស្តុតាង។

ដូចនៅក្នុងឧទាហរណ៍ទី៨ ខាងលើ B (អ្នកទិញ)បានបង្ហាញឆន្ទៈក្នុងការលុបចោលកិច្ចសន្យាទៅ A (អ្នកលក់) នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣។ A បានទទួលដំណឹង អំពីការលុបចោលកិច្ចសន្យានោះ នៅថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៣។ ករណីនេះ អានុភាពនៃការលុបចោលកិច្ចសន្យាត្រូវកើតឡើងនៅថ្ងៃទី១២ ខែមករា

ឆ្នាំ២០១៣។ ដោយសារអានុភាពប្រតិសកម្មនៃការលុបចោលនេះនាំឲ្យសកម្មភាពនេះ ត្រូវចាត់ទុកជា មោឃៈ តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។ ហេតុនេះ កិច្ចសន្យាលក់ទិញម៉ូតូរវាង A និង B ត្រូវចាត់ទុកជា មោឃៈ មានន័យថាមិនមានកិច្ចសន្យាកើតឡើងនោះទេ។ ដោយផ្អែកទៅលើករណីដែលមិនមានកិច្ចសន្យាលក់ ទិញ ប្រាក់ដែល A បានទទួលពី B គឺគ្មានមូលហេតុលើផ្លូវច្បាប់នោះទេ ហើយ B អាចទាមទារប្រាក់នោះពី A វិញបាន ដោយផ្អែកទៅលើសេចក្តីចម្រើនដោយឥតហេតុ រួមទាំងសំណងនៃការខូចខាតថែមទៀតផង (មាត្រា ៧៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

| |
|---|
| ＊ A បានលក់រថយន្តទៅ B ហើយ B ក៏បានលក់រថយន្តនោះបន្តទៅឲ្យ C ។ កិច្ចសន្យារវាង A និង B មានវិការៈហើយ C ក៏បានដឹងពីអង្គហេតុនោះដែរ។ A ចង់យករថយន្តពី C មកវិញដោយលុបចោលនូវ កិច្ចសន្យាទិញលក់ជាមួយនឹង B ។ តើ A ត្រូវជូនដំណឹងអំពីការលុបចោលទៅអ្នកណា? គឺជូនដំណឹងទៅ B ។ បន្ទាប់ពី A បានជូនដំណឹងអំពីការលុបចោលទៅ B ហើយក៏បានទាមទារឲ្យ C ប្រគល់រថយន្ត។ ប្រសិនបើក្នុង ករណីដែល C បដិសេធក្នុងការប្រគល់រថយន្ត A អាចដាក់ពាក្យបណ្តឹងទាមទារឲ្យ C ប្រគល់រថយន្តដោយផ្អែក លើកម្មសិទ្ធិ។ នៅក្នុងតុលាការ B មិនមែនជាចុងចម្លើយទេ។ |




1. A លក់រថយន្តទៅឲ្យ B
2. B លក់រថយន្តបន្តទៅឲ្យ C
3. A ជូនដំណឹងអំពីការលុបចោលកិច្ចសន្យាទៅ B
4. A ដាក់ពាក្យបណ្តឹងទៅតុលាការយក C ជាចុងចម្លើយ

### ៣.២.៣.អ្នកដែលមានសិទ្ធិលុបចោល

**អ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈមានវិការៈរួមមាន (មាត្រា ៣៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)៖**

- អ្នកបង្ហាញឆន្ទៈដោយមានវិការៈ ឬ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ
- សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ
- អ្នកទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ
- អច្ច័យលាភីសកលពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ (មាត្រា១២១២ នៃក្រមរដ្ឋប្បវេណី)

❖ បទបញ្ញត្តិនៃមាត្រា ៣៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី មិនបានកំណត់អំពីអច្ច័យលាភីសកលពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈទេ ប៉ុន្តែ ប្រសិនបើមើលពីគោលគំនិតក្នុងមាត្រា ១២១២ នៃ ក្រមរដ្ឋប្បវេណី អច្ច័យលាភីសកលក៏អាចអនុវត្តនូវសិទ្ធិលុបចោលបានដែរ។

❖ អ្នកតំណាងដែលច្បាប់បានកំណត់គឺផ្តោតសំខាន់ទៅលើ អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ។ ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ពោលគឺ ហិតូបត្ថម្ភកៈមានតួនាទីគ្រាន់តែផ្តល់ការយល់ព្រមទៅលើសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភតែប៉ុណ្ណោះ (មាត្រា៣០ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ទី៩៖ A (អ្នកលក់)បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តជាមួយ B (អ្នកទិញ)។ A មានរថយន្តរាង Sedan ប៉ុន្តែ B គិតថានេះជារថយន្តរាង Van។ នៅក្នុងករណីនេះ B បានបង្កើតកិច្ចសន្យាដោយមានការភាន់ច្រឡំ (មាត្រា ៣៤៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ហេតុនេះ B អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាបាន ប្រសិនបើ A បានដឹងអំពីការភាន់ច្រឡំនោះ។

បន្ទាប់ពី B បានចុះកិច្ចសន្យាជាមួយ A ហើយ B ត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើ សកម្មភាព និង អ្នកអាណាព្យាបាលទូទៅត្រូវបានជ្រើសតាំងសម្រាប់ B នោះ។ ក្នុងករណីនេះ អ្នកអាណាព្យាបាលទូទៅដែលជាអ្នកតំណាងដែលច្បាប់បានកំណត់អាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យានោះបាន។

នៅក្នុងករណីដែល B ទទួលមរណភាពវិញ C ដែលជាសន្តតិជនតែម្នាក់របស់ B អាចអនុវត្ត សិទ្ធិលុបចោលកិច្ចសន្យានេះបាន។ ក្នុងករណីដែល B បានធ្វើអច្ច័យទានសកលនូវទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅ D នោះ D ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ (មាត្រា ១២១២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

បើ B បានធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យា (មាត្រា ៥១២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ឲ្យទៅ E នោះ E ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ដោយមូលហេតុការភាន់ច្រឡំរបស់ B ។

**អ្នកដែលមានសិទ្ធិលុបចោលចំពោះការលុបចោលដោយមូលហេតុគ្មាន*សមត្ថភាពក្នុងការបង្ហាញឆន្ទៈ* (ពាក្យសមត្ថភាពក្នុងការបង្ហាញឆន្ទៈដែលមានចែងក្នុង មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នេះ មានន័យដូចគ្នានឹងពាក្យ*សមត្ថភាពខាងឆន្ទៈ* ដែលមានចែងក្នុង មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី) ឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពមានដូចខាងក្រោម (មាត្រា ៣៥៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី) ៖**

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកបង្ហាញឆន្ទៈ
- ហិតូបត្ថម្ភកៈនៃអ្នកបង្ហាញឆន្ទៈ
- សន្តតិជនរបស់អ្នកបង្ហាញឆន្ទៈ

- អច្ច័យលាភីសកលរបស់អ្នកបង្ហាញឆន្ទៈ
- អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ (មាត្រា ៥១៤ នៃក្រមរដ្ឋប្បវេណី)

❖ បញ្ញត្តិនៃមាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី មិនបានកំណត់អំពីអ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈទេ ប៉ុន្តែ បើតាមគោលគំនិតរបស់មាត្រា ៥១៤ នៃក្រមរដ្ឋប្បវេណី អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។

❖ ជនដែលត្រូវបានកម្រិតសមត្ថភាពអាចអនុវត្តនូវសិទ្ធិលុបចោលដោយឯករាជ្យបាន ប៉ុន្តែ ក្រោយពីបានអនុវត្តសិទ្ធិលុបចោលហើយ ជននោះមិនអាចលុបចោលនូវការអនុវត្តសិទ្ធិលុបចោលនោះបានឡើយ។




① A បង្កើតកិច្ចសន្យាជាមួយ B

② A អនុវត្តសិទ្ធិលុបចោលកិច្ចសន្យា

③ A មិនអាចលុបចោលនូវការអនុវត្តសិទ្ធិលុបចោល ② បានទេ

ឧទាហរណ៍៖ A (អ្នកលក់) និង B (អ្នកទិញ) បានបង្កើតកិច្ចសន្យាលក់ទិញរថយន្ត។ ក្នុងករណីដែល B គឺជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ B និង អ្នកតំណាងដែលច្បាប់បានកំណត់របស់ B (អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកអាណាព្យាបាលទូទៅ) អាចអនុវត្តសិទ្ធិលុបចោលបាន។

ក្នុងករណី B គឺជាជនស្ថិតនៅក្រោមរបបហិតូបត្ថម្ភនោះ B ឬ ហិតូបត្ថម្ភកៈរបស់ B អាចអនុវត្តសិទ្ធិលុបចោលបាន។

ក្នុងករណី B បានទទួលមរណភាព C ដែលជាសន្តតិជនរបស់ B អាចអនុវត្តសិទ្ធិលុបចោលបាន។ ប្រសិនបើ B បានធ្វើអច្ច័យទានសកលឲ្យទៅ D នោះ D អាចអនុវត្តសិទ្ធិលុបចោលបាន។

ប្រសិនបើក្នុងករណីដែល B ធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាទៅ D (មាត្រា ៥១២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)នោះ D អាចអនុវត្តសិទ្ធិលុបចោលដោយយកមូលហេតុនៃការកម្រិតសមត្ថភាពរបស់ B បាន (មាត្រា ៥១៤ នៃក្រមរដ្ឋប្បវេណី)។

A (អ្នកឲ្យខ្ចី) និង B (អ្នកខ្ចី) បានធ្វើកិច្ចសន្យាខ្ចីបរិភោគប្រាក់ហើយ C បានជានាកាតព្វកិច្ចរបស់ B។ ក្នុងករណីដែល B គឺជាអ្នកដែលត្រូវបានកម្រិតនូវសមត្ថភាព ហើយបានបង្ហាញឆន្ទៈដែលមានវិការៈ ប្រសិនបើ B លុបចោលកិច្ចសន្យាខ្ចីបរិភោគប្រាក់នោះ កាតព្វកិច្ចធានារបស់ C ក៏ត្រូវរលត់ដែរ (មាត្រា ៩០៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើ B មិនអនុវត្តនូវសិទ្ធិលុបចោល តើ C អាចអនុវត្តនូវសិទ្ធិលុបចោល ក្នុងនាមជាអ្នកធានាបានដែរឬទេ? គឺមិនអាចទេ។ ដោយសារមាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណី មិនបានកំណត់ថា អ្នកធានាគឺជា អ្នកដែលមានសិទ្ធិលុបចោល។ ទោះបីជា C មិនមានសិទ្ធិលុបចោលក៏ដោយ ក៏ C អាចបដិសេធ នូវការអនុវត្តកាតព្វកិច្ចធានារបស់ខ្លួនបាន ដោយសំអាងលើការបង្ហាញឆន្ទៈរបស់ B មានវិការៈ (មាត្រា៩០៥ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី)។

អ្នកទទួលបន្តនូវឋានៈក្នុងកិច្ចសន្យាអាចអនុវត្តនូវសិទ្ធិលុបចោលបាន ប៉ុន្តែ អនុប្បទានិកនៃកម្មវត្ថុនៃកិច្ចសន្យាមិនអាចអនុវត្តសិទ្ធិលុបចោលបានទេ។

ឧទាហរណ៍៖ A (អ្នកលក់)បានឆបោក B (អ្នកទិញ)ធ្វើកិច្ចសន្យាទិញលក់រថយន្ត។ ក្នុងករណីដែល B បានធ្វើអនុប្បទានឋានៈទៅអ្នកទិញ C មុនពេលអនុវត្តកិច្ចសន្យា នោះ C អាចលុបចោលកិច្ចសន្យាទិញលក់បានដោយសារមូលហេតុនៃការឆបោករបស់ A។




ផ្ទុយទៅវិញ ប្រសិនបើ B បានលក់បន្តរថយន្តនោះទៅ C នោះ C មិនអាចលុបចោលកិច្ចសន្យា ទិញលក់បានទេ (C គឺជាអនុប្បទានិកកម្មវត្ថុនៃកិច្ចសន្យា)។ ក្នុងករណីនេះ អ្នកដែលអាចអនុវត្តនូវសិទ្ធិលុបចោលគឺ B ។




* ដើម្បីដឹងថា C ជាអនុប្បទានិកឋានៈក្នុងកិច្ចសន្យា ឬ ជាអនុប្បទានិកកម្មវត្ថុនៃកិច្ចសន្យា គឺយើងត្រូវមើលនៅក្នុងខ្លឹមសារនៃកិច្ចសន្យា បើសិនជា ក្នុងកិច្ចសន្យារវាង B និង C ចែងអំពីការធ្វើអនុប្បទាន ឋានៈ នោះ C ជាអនុប្បទានិកនៃឋានៈ តែបើកិច្ចសន្យាចែងអំពីការលក់ឡានពី B ទៅ C នោះ C ជា អនុប្បទានិកកម្មវត្ថុនៃកិច្ចសន្យា។

### ៣.២.៤.សច្ចានុមតិ

សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គលមានសិទ្ធិលុបចោល បង្ហាញជាស្ថាពរថាខ្លួនមិនអនុវត្តសិទ្ធិលុបចោលដោយផ្អែកលើបុរេល័ក្ខខ័ណ្ឌដែលបានដឹងថាសកម្មភាពរបស់ខ្លួនអាចលុបចោលបាន។

#### ក. វិធីធ្វើសច្ចានុមតិ និង អានុភាព៖

ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន នោះសិទ្ធិលុបចោលនឹងត្រូវរលត់ ហើយក្រោយពីបានផ្តល់សច្ចានុមតិហើយនោះ សកម្មភាពដែលអាចលុបចោលបាននោះនឹងមិនអាចលុបចោលបានទេ។ សច្ចានុមតិត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀត ហើយអានុភាពត្រូវកើតឡើងនៅពេលដែល ដំណឹង នោះបានដល់ភាគីម្ខាងទៀតនោះ (មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណី)។ ការផ្តល់សច្ចានុមតិក៏ដូចជា ការលុបចោលដែរ គឺអាចធ្វើឡើងនៅក្រៅតុលាការបាន។

#### ខ. អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ

ការផ្តល់សច្ចានុមតិ អាចធ្វើឡើងបានដោយអ្នកមានសិទ្ធិលុបចោល (មាត្រា ៣៦១ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ អ្វីដែលមិនច្បាស់លាស់នោះ គឺការផ្តល់សច្ចានុមតិ ដោយអ្នកដែលត្រូវបានកម្រិតសមត្ថភាព (អនីតិជន ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ)។ ជនដែលត្រូវបានកម្រិតសមត្ថភាព អាចអនុវត្តសិទ្ធិលុបចោលនៅមុនពេលដែលជននោះត្រឡប់មកភាពដើមវិញ(មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ មិនអាចផ្តល់សច្ចានុមតិបានទេ (មាត្រា ៣៦១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ អ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ) និង ហិតូបត្ថមកៈរបស់អ្នកដែលត្រូវបានកម្រិតសមត្ថភាពអាចផ្តល់សច្ចានុមតិបាននៅមុនពេលដែលជននោះក្លាយជាជនដែលមានសមត្ថភាពឡើងវិញ ឬ មុនពេលជននោះដល់នីតិភាព (មាត្រា ៣៦១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

នៅពេលដែលបានទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ តើសាមីខ្លួន (អ្នកដែលត្រូវបានកម្រិតសមត្ថភាព) អាចធ្វើសច្ចានុមតិបានដែរ ឬទេ? នេះគឺជាបញ្ហា។ នៅក្នុងក្រមរដ្ឋប្បវេណី មិនបានសរសេរឲ្យបានច្បាស់លាស់ទេ ប៉ុន្តែ បើយោងតាមការបកស្រាយក្នុងមាត្រា ១៨ មាត្រា ២៦ និងមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី អាចត្រូវបានពិចារណាថា អនីតិជន និង ជននៅក្រោមហិតូបត្ថម្ភ បើបានទទួលការយល់ព្រមនោះគឺ អាចធ្វើសច្ចានុមតិបាន។ ប៉ុន្តែ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ទោះបីជា បានទទួលការយល់ព្រមក៏ដោយ ក៏មិនអាចធ្វើសច្ចានុមតិបានដែរ។ មាត្រា ១៨ និង មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា អនីតិជន ឬ ជននៅក្រោមហិតូបត្ថម្ភ អាចលុបចោលបាន តែសកម្មភាព ដែលមិនបានទទួលការយល់ព្រមប៉ុណ្ណោះ។ ចំណែកឯ មាត្រា ២៦ នៃក្រមរដ្ឋប្បវេណី កំណត់ត្រឹមតែពាក្យ "សកម្មភាព" ប៉ុណ្ណោះ ហេតុនេះ គេអាចធ្វើការបកស្រាយថា ជនដែលនៅក្រោមអាណាព្យាបាលទូទៅអាចលុប

ចោលសកម្មភាពទាំងឡាយ ទោះបីជាសកម្មភាពនោះទទួលបានការយល់ព្រម ឬ មិនទទួលបានការយល់ព្រមក៏ដោយ។

ខាងក្រោមនេះគឺជាតារាងសង្ខេប៖

| ការលុបចោលដោយជនដែលត្រូវបានកម្រិតសមត្ថភាព | សកម្មភាពទទួលការយល់ព្រម | សកម្មភាពដែលមិនបានទទួលការយល់ព្រម |
|---|---|---|
| អនីតិជន(មាត្រា ១៨ កថាខណ្ឌទី១) | មិនអាចលុបចោល | អាចលុបចោល |
| ជននៅក្រោមអាណាព្យាបាលទូទៅ (មាត្រា ២៦ កថាខណ្ឌទី១) | អាចលុបចោល | អាចលុបចោល |
| ជននៅក្រោមហិតូបត្ថម្ភ (មាត្រា ៣០ កថាខណ្ឌទី១) | មិនអាចលុបចោល | អាចលុបចោល |

| ការផ្តល់សច្ចានុមតិដោយជនដែលត្រូវបានកម្រិតសមត្ថភាព | ការផ្តល់សច្ចានុមតិដែលបានទទួលការយល់ព្រម | ការផ្តល់សច្ចានុមតិដែលមិនបានទទួលការយល់ព្រម |
|---|---|---|
| អនីតិជន(មាត្រា១៨ កថាខណ្ឌទី១) | អាច | មិនអាច |
| ជននៅក្រោមអាណាព្យាបាលទូទៅ(មាត្រា ២៦ កថាខណ្ឌទី១) | មិនអាច | មិនអាច |
| ជននៅក្រោមហិតូបត្ថម្ភ (មាត្រា ៣០កថាខណ្ឌទី១) | អាច | មិនអាច |

**គ. ពេលដែលអ្នកមានសិទ្ធិលុបចោលអាចផ្ដល់សច្ចានុមតិបាន (មាត្រា ៣៦១ នៃក្រមរដ្ឋប្បវេណី)៖**

• ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោល បានដឹងអំពីមូលហេតុនៃការលុបចោល (ការភាន់ច្រឡំ ការឆបោក ជាដើម) ក្នុងករណីដែលការលុបចោលសកម្មភាពដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ (ចំពោះការគម្រាមកំហែង តើការផ្ដល់សច្ចានុមតិត្រូវចាប់រាប់ពីពេលណា? គិតចាប់ពីពេលដឹងអំពីការគម្រាមកំហែង ឬ គិតពីស្ថានភាពនៃការគម្រាម កំហែងត្រូវបានបញ្ចប់? បើពិនិត្យមើល មាត្រា ៩៦៣ កថាខណ្ឌទី២ នៃក្រមរប្បវេណី សិទ្ធិលុបចោលត្រូវបាន រាប់ក្រោយពីបានរួចខ្លួនផុតពីការគម្រាម ហេតុនេះ ការគំរាមដែលមានចែងនៅក្នុងមាត្រា ៣៥០ គួរតែបកស្រាយ ឲ្យដូចនឹង មាត្រា៩៦៣ នៃក្រមរដ្ឋប្បវេណី)។

• នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោល(ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព)បានរលត់សម្រាប់ ករណីជនដែលត្រូវបានកម្រិតសមត្ថភាព (អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមរបបហិតូបត្ថម្ភ) ដូចជាពេលដែលអនីតិជនក្លាយជានីតិជន ឬ ពេលដែលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ ត្រូវបានលុបចោល។ ប៉ុន្តែ អ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ) ឬ ហិតូបត្ថម្ភកៈ អាចផ្ដល់សច្ចានុមតិបាន ទោះបីជានៅមុនពេលដែលស្ថានភាពនៃមូលហេតុនៃការលុបចោលរលត់ក៏ដោយ(មាត្រា ៣៦១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ម្យ៉ាងទៀត អនីតិជន ឬ ជននៅក្រោមរបបហិតូបត្ថម្ភ អាចផ្ដល់សច្ចានុមតិបានដោយមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ឬហិតូបត្ថម្ភកៈ (មាត្រា ១៨, មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ជននៅក្រោមអាណាព្យាបាលទូទៅមិនអាចផ្ដល់សច្ចានុមតិបានឡើយ ទោះបីជា មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ (មាត្រា ២៦ នៃក្រមរដ្ឋប្បវេណី)។

> ការផ្ដល់សច្ចានុមតិទៅលើសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាព
>
> ដើម្បីអាចធ្វើសច្ចានុមតិចំពោះសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពមានមធ្យោបាយ ៣ ៖
>
> ទី១/ "ក្រោយពីពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់" មធ្យោបាយដែលធ្វើសច្ចានុមតិ ដោយខ្លួនឯង(មាត្រា ៣៦១ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។
>
> ទី២/ មធ្យោបាយធ្វើសច្ចានុមតិដោយអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលទូទៅ) ឬ ហិតូបត្ថម្ភកៈរបស់ជនដែលត្រូវបានកម្រិតសមត្ថភាព (មាត្រា ៣៦១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ។
>
> ទី៣/ មធ្យោបាយធ្វើសច្ចានុមតិដោយជនត្រូវបានកម្រិតសមត្ថភាពដែលទទួលបានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈ។ មធ្យោបាយទី៣នេះ អនីតិជន ឬ ជននៅក្រោមរបបហិតូបត្ថម្ភក៏អាចផ្ដល់សច្ចានុមតិបានដែរ ឲ្យតែមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈ

ប៉ុន្តែចំពោះជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅវិញ ទោះបីជា ក្នុងករណីមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏មិនអាចផ្តល់សច្ចានុមតិបានឡើយ។

### ឃ. សច្ចានុមតិដែលច្បាប់កំណត់

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិបាន សកម្មភាពដែលអាចលុបចោលបានត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិរួចហើយ ហៅថាសច្ចានុមតិដែលច្បាប់បានកំណត់ (មាត្រា ៣៦២ នៃក្រមរដ្ឋប្បវេណី) ក្នុងករណីមានហេតុដូចខាងក្រោមនេះ ៖

១. ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែកចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ (មាត្រា ៣៦២ ចំណុច ក នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ A (អ្នកលក់) បានឆបោក B (អ្នកទិញ) ឲ្យចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយខ្លួន។ ទោះបីជា B បានបង់ប្រាក់ទៅឲ្យ A មុនពេលបានដឹងអំពីការឆបោកក៏ដោយ ក៏មិនមែនជាសច្ចានុមតិដែលច្បាប់បានកំណត់ដែរ ហេតុនេះ B អាចអនុវត្តសិទ្ធិលុបចោលហើយទាមទារឲ្យប្រគល់ប្រាក់មកវិញបាន។ ប៉ុន្តែ ប្រសិនបើ B បានបង់ប្រាក់ឲ្យទៅ A នៅក្រោយពេលដែលបានដឹងអំពីការឆបោកហើយនោះនឹងក្លាយជាសច្ចានុមតិដែលច្បាប់បានកំណត់ ហេតុនេះ B មិនអាចអនុវត្តសិទ្ធិលុបចោលបានទេ។

ឧទាហរណ៍៖ A (អ្នកលក់) បានចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយ B (អ្នកទិញ)។ នៅពេលចុះកិច្ចសន្យា B គឺជាអនីតិជន។ នៅមុនពេល B ក្លាយជានីតិជន ទោះបីជា B បានបង់ប្រាក់រួចហើយ ក៏ដោយ មិនត្រូវបានចាត់ទុកថាជាសច្ចានុមតិដោយច្បាប់កំណត់នោះទេ ដូចនេះ B អាចអនុវត្តសិទ្ធិលុបចោល ហើយទាមទារឲ្យប្រគល់ប្រាក់មកវិញបាន។ ប៉ុន្តែ ប្រសិនបើ B បានផ្តល់សច្ចានុមតិនៅក្រោយពេលដែលខ្លួនបានដល់នីតិភាពនោះ ត្រូវចាត់ទុកជាការផ្តល់សច្ចានុមតិតាមច្បាប់កំណត់ ហើយមិនអាចអនុវត្ត សិទ្ធិលុបចោល បានទេ។ នៅមុនពេល B បានដល់នីតិភាព ប្រសិនបើ អ្នកមានអំណាចមេបារបស់ B បានបង់ប្រាក់ ក្នុងនាមជាអ្នកតំណាងរបស់ B នោះត្រូវចាត់ទុកជាការផ្តល់សច្ចានុមតិតាមច្បាប់កំណត់ ហើយទាំងអ្នកមានអំណាចមេបារបស់ B និង B ផ្ទាល់នឹងមិនអាចអនុវត្តសិទ្ធិលុបចោលបានទេ។

២. ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាមទារឲ្យភាគីម្ខាងទៀតអនុវត្ត (មាត្រា ៣៦២ ចំណុច ខ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ A (អ្នកលក់) បានឆបោក B (អ្នកទិញ) ឲ្យចុះកិច្ចសន្យាលក់ទិញជាមួយខ្លួន។ នៅមុនពេល B បានដឹងអំពីការឆបោក ទោះបីជា B បានទាមទារឲ្យ A ប្រគល់រថយន្ត ឬ បានទៅយករថយន្ត នៅហាងរបស់ A ក៏ដោយ មិនត្រូវបានចាត់ទុកថាជាការផ្តល់សច្ចានុមតិដែលច្បាប់បានកំណត់នោះទេ ដូចនេះ B អាចលុបចោលកិច្ចសន្យា ហើយបដិសេធការទាមទារឲ្យប្រគល់ប្រាក់បាន។ ប៉ុន្តែ ប្រសិនបើ B បានទាមទារឲ្យ A

ប្រគល់រថយន្ត ឬ បានទៅយករថយន្តនៅហាងរបស់ A នៅក្រោយពេលដឹងអំពីការឆបោក នោះនឹងត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិដែលច្បាប់បានកំណត់ ដូចនេះ B មិនអាចលុបចោលកិច្ចសន្យាបានទេ។

ឧទាហរណ៍៖ A (អ្នកលក់)បានចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយ B (អ្នកទិញ)។ នៅពេល ចុះកិច្ចសន្យា B គឺជាជនស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ។ ទោះបីជា ជននៅក្រោមរបបអាណាព្យាបាលទូទៅ B បានទាមទារឲ្យ A ប្រគល់រថយន្តក៏ដោយ មិនត្រូវបានចាត់ទុកថាជា ការផ្តល់សច្ចានុមតិតាមច្បាប់កំណត់នោះទេ ដូចនេះ B អាចលុបចោលកិច្ចសន្យា ហើយអាចបដិសេធការទាមទារឲ្យប្រគល់ប្រាក់បាន។ ប៉ុន្តែក្រោយពេលដែលការប្រកាសអំពីរបបអាណាព្យាបាលទូទៅចំពោះ B ត្រូវបានលុបចោល (មាត្រា ២៧ នៃក្រមរដ្ឋប្បវេណី) ហើយ B បានទាមទារឲ្យ A ប្រគល់រថយន្តនោះចាត់ទុកថាជា ការផ្តល់សច្ចានុមតិតាមច្បាប់កំណត់ ហើយ B មិនអាចប្រើសិទ្ធិលុបចោលបានទេ។ ទោះបីជា នៅមុនពេលការប្រកាស អំពីរបបអាណាព្យាបាលទូទៅត្រូវបានលុបចោលក៏ដោយ ប្រសិនបើ អ្នកអាណាព្យាបាលទូទៅរបស់ B បានទាមទារឲ្យ A ប្រគល់រថយន្តនោះចាត់ទុកថាជាការផ្តល់សច្ចានុមតិតាមច្បាប់កំណត់ ហើយទាំង B និង អ្នកអាណាព្យាបាលទូទៅរបស់ B នឹងមិនអាចលុបចោលកិច្ចសន្យាបានឡើយ។

៣. អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែកចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន (មាត្រា ៣៦២ ចំណុច គ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ B (អ្នកលក់) បានភាន់ច្រឡំបង្កើតកិច្ចសន្យាលក់ទិញរថយន្តជាមួយ A (អ្នកទិញ) ។ នៅមុនពេល B បានដឹងអំពីការភាន់ច្រឡំរបស់ខ្លួន ទោះបីជាបានអនុប្បទានសិទ្ធិលើបំណុលជាប្រាក់ទៅឲ្យ C រួចហើយក៏ដោយ មិនត្រូវចាត់ទុកថាជាការផ្តល់សច្ចានុមតិតាមច្បាប់កំណត់នោះទេ ដូចនេះ B អាចលុបចោលកិច្ចសន្យា ហើយអាចបដិសេធការប្រគល់រថយន្តបាន។ ប៉ុន្តែ ប្រសិនបើ B បានធ្វើអនុប្បទានសិទ្ធិលើបំណុលជាប្រាក់នេះ នៅក្រោយពេលដែលខ្លួនបានដឹងអំពីការភាន់ច្រឡំរបស់ខ្លួន នោះត្រូវចាត់ទុកថាជាការផ្តល់សច្ចានុមតិតាមច្បាប់កំណត់ ហើយ B មិនអាចលុបចោលកិច្ចសន្យាបានទេ។

ឧទាហរណ៍៖ A (អ្នកទិញ) បានបង្កើតកិច្ចសន្យាលក់ទិញជាមួយ B (អ្នកលក់)។ នៅពេលបង្កើតកិច្ចសន្យា B គឺជាអនីតិជន។ នៅមុនពេល B បានដល់នីតិភាព ទោះបីជាបានអនុប្បទាន សិទ្ធិលើបំណុលជាប្រាក់ទៅឲ្យ C ហើយក៏ដោយ មិនត្រូវចាត់ទុកថាជាការផ្តល់សច្ចានុមតិ តាមច្បាប់កំណត់ នោះទេ ហេតុនេះ B ឬ អ្នកមានអំណាចមេបារបស់ B អាចលុបចោលកិច្ចសន្យា ហើយអាចបដិសេធការទាមទារ ឲ្យប្រគល់រថយន្តបាន។ ប៉ុន្តែប្រសិនបើ B បានធ្វើអនុប្បទានសិទ្ធិលើបំណុលឲ្យទៅ C នៅក្រោយពេលបានដល់នីតិភាពនោះ គឺជាការផ្តល់សច្ចានុមតិតាមច្បាប់កំណត់ហើយ B និង អ្នកមានអំណាចមេបារបស់ B មិនអាចលុបចោលកិច្ចសន្យាបានទេ។ ម្យ៉ាងទៀត ទោះបីជា នៅមុនពេល B បានដល់នីតិភាពក៏ដោយ ប្រសិនបើ អ្នកមានអំណាចមេបារបស់ B បានធ្វើអនុប្បទានសិទ្ធិលើបំណុលជាប្រាក់ ក្នុងនាមជាអ្នកតំណាងរបស់ B នោះគឺជាការផ្តល់សច្ចានុមតិ ដូចនេះ B និង អ្នកតំណាងដែលច្បាប់បានកំណត់របស់ B មិនអាច លុបចោលកិច្ចសន្យាបានទេ។

ប៉ុន្តែ បើមានបបនីយថាខ្លួនមិនបានផ្តល់សច្ចានុមតិនៅពេលធ្វើសកម្មភាពដូចខាងលើ នោះអានុភាព នៃសច្ចានុមតិនឹងមិនកើតឡើងទេ (មាត្រា ៣៦២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ពាក្យថា "បបនីយថា ខ្លួន មិនបានផ្តល់សច្ចានុមតិ" មានន័យថា បុគ្គលដែលបានធ្វើសកម្មភាពត្រូវបង្ហាញចេញមកក្រៅថាខ្លួនមិនបាន ផ្តល់សច្ចានុមតិទេ ទោះជាតាមការសរសេរ ឬ ការនិយាយក៏ដោយ។ ឧទាហរណ៍៖ កិច្ចសន្យាមួយធ្វើឡើងរវាង A ជាអ្នកលក់ និង B ជាអ្នកទិញ ដោយមានការឆបោករបស់អ្នកលក់ A ។ ក្រោយមក B មានបញ្ហាស្មារតី ហើយ អាណាព្យាបាលទូទៅរបស់ B ត្រូវបានជ្រើសតាំង។ អាណាព្យាបាលទូទៅរបស់ B បានអនុវត្តកាតព្វកិច្ច ជំនួស B ដោយសារតែមានការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុរបស់ B ប៉ុន្តែ នៅពេលអនុវត្តកាតព្វកិច្ច អាណាព្យាបាលទូទៅបានបញ្ជាក់ថា ការណ៍ដែលខ្លួនសងនេះ មិនមែនជាការផ្តល់សច្ចានុមតិនោះទេ។ ដូចនេះ ការអនុវត្តកាតព្វកិច្ចរបស់អាណាព្យាបាលទូទៅ មិនមែនជាសច្ចានុមតិដែលច្បាប់បានកំណត់នោះទេ។

នៅមុនពេលដែលអាចផ្តល់សច្ចានុមតិបាន សច្ចានុមតិដែលច្បាប់បានកំណត់មិនកើតឡើងទេ។ បន្ទាប់ពីបង្កើតកិច្ចសន្យាលក់ទិញ ទោះបីជា អ្នកទិញដែលត្រូវបានឆបោកបានបង់ប្រាក់មុនពេលដែលបានដឹង អំពីការឆបោកក៏ដោយ ក៏មិនមែនជាសច្ចានុមតិដែលច្បាប់បានកំណត់ដែរ។




ប្រសិនបើអ្នកទិញបានបង់ប្រាក់បន្ទាប់ពីបានដឹងអំពីការឆបោក គឺជាសច្ចានុមតិដែលច្បាប់បានកំណត់។




ក្នុងករណីដែលជនដែលត្រូវបានកម្រិតសមត្ថភាព (អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជន នៅក្រោមហិតូបត្ថម្ភ) បានធ្វើសកម្មភាពទាំងនេះ នោះអានុភាពមិនកើតឡើងទេ ប៉ុន្តែ ប្រសិនបើ អ្នកតំណាង ដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាល ទូទៅ) បានធ្វើសកម្មភាពទាំងនេះ នោះអានុភាពនឹងកើតមានឡើង។ ប្រសិនបើ អនីតិជន ឬ ជននៅក្រោម ហិតូបត្ថម្ភបានទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈ នោះអានុភាពនៃការ ផ្តល់សច្ចានុមតិនឹងកើតមានឡើង។ ប៉ុន្តែ ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ ទោះបីជា ទទួលបាន ការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏មិនកើតមាននូវអានុភាពនៃការផ្តល់សច្ចានុមតិនោះដែរ។

### ៣.២.៥. អាជ្ញាយុកាល

សិទ្ធិលុបចោល និង សិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើងដោយសារ ការលុបចោលនឹងត្រូវរលត់ បើមិនប្រើសិទ្ធិនេះក្នុងរយៈពេល ៣ ឆ្នាំ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុ

មតិបាន (មាត្រា ៣៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ពេលដែលអាចផ្ដល់សច្ចានុមតិបាន គឺពេលដែលអ្នកមានសិទ្ធិលុបចោលដឹងអំពីមូលហេតុនៃការលុបចោល ឬ ពេលដែលសមត្ថភាពដែលបានកម្រិតបានត្រឡប់មកភាពដើមវិញ។ នៅមុនពេលលុបចោល ប្រសិនបើមានការប្រគល់វត្ថុ ដោយផ្អែកលើកិច្ចសន្យា អ្នកមានសិទ្ធិលុបចោលអាចលុបចោលកិច្ចសន្យាបាន ហើយលើសពីនេះ ចាំបាច់ត្រូវទាមទារឲ្យប្រគល់សេចក្ដីចម្រើនដោយឥតហេតុមកវិញ។ ក្នុងអំឡុងពេល ៣ ឆ្នាំ ដែលអាចផ្ដល់សច្ចានុមតិបាន អ្នកមានសិទ្ធិលុបចោលត្រូវអនុវត្តសិទ្ធិលុបចោល ហើយលើសពីនេះ ត្រូវទាមទារឲ្យសងសេចក្ដីចម្រើនដោយឥតហេតុមកវិញ។




១. A បានបង្កើតកិច្ចសន្យាលក់ទិញដោយមានការឆបោក

២. A បានដឹងអំពីការឆបោក (ពេលដែលអាចផ្ដល់សច្ចានុមតិបាន)

៣. រលត់សិទ្ធិលុបចោលនិងសិទ្ធិទាមទារឲ្យសងសេចក្ដីចម្រើនដោយឥតហេតុមកវិញ




១. A បានបង្កើតកិច្ចសន្យាលក់ទិញដោយមានការឆបោក

២. A បានដឹងអំពីការឆបោក (ពេលដែលអាចផ្ដល់សច្ចានុមតិបាន)

៣. A អនុវត្តសិទ្ធិលុបចោល

៤. រលត់សិទ្ធិទាមទារឲ្យសងសេចក្ដីចម្រើនដោយឥតហេតុ(មាត្រា ៣៦៣ កថាខណ្ឌទី១)

ប្រសិនបើហួសអំឡុងពេល ១០ ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះ សិទ្ធិលុបចោលក៏ត្រូវរលត់ដែរ (មាត្រា ៣៦៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ នេះគឺជាការរលត់សិទ្ធិលុបចោល ដូចនេះ ប្រសិនបើ អនុវត្តសិទ្ធិលុបចោលក្នុងអំឡុងពេល ១០ ឆ្នាំ នោះ ទោះបីជាហួសអំឡុងពេល ១០ ឆ្នាំក៏ដោយ ក៏សិទ្ធិទាមទារឲ្យសងសេចក្ដីចម្រើនដោយឥតហេតុមិនរលត់ដែរ។ សិទ្ធិទាមទារឲ្យសងសេចក្ដីចម្រើនដោយឥតហេតុនឹងត្រូវរលត់ផ្អែកតាម មាត្រា ៣៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។




១. A បានបង្កើតកិច្ចសន្យាលក់ទិញដោយមានការឆបោក

២. ទោះបីជា A មិនបានដឹងអំពីការឆបោកក៏ដោយ ក៏សិទ្ធិលុបចោលត្រូវរលត់




១. A បានបង្កើតកិច្ចសន្យាលក់ទិញដោយមានការឆបោក

២. A បានដឹងអំពីការឆបោក (ពេលដែលអាចផ្តល់សច្ចានុមតិបាន) ហើយក៏អនុវត្តសិទ្ធិលុបចោល

៣·៤·៥. តើសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុត្រូវរលត់នៅ ចំណុចលេខ ៣ ឬ លេខ ៤ ឬ លេខ ៥?

មាត្រា ៣៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានកំណត់ថាសិទ្ធិលុបចោល និង សិទ្ធិទាមទារឲ្យសង សេចក្តីចម្រើនដោយឥតហេតុត្រូវរលត់ក្នុងអំឡុងពេល៣ឆ្នាំ។ ប៉ុន្តែ មាត្រា ៣៦៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានកំណត់ត្រឹមតែសិទ្ធិលុបចោលប៉ុណ្ណោះ (១០ឆ្នាំ) តែមិនបានកំណត់អំពីសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុទេ។ ហេតុនេះ ចំពោះសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុនៃកថាខណ្ឌទី២ មិនត្រូវយកមកអនុវត្តទេ ត្រូវយកកថាខណ្ឌទី១ មកអនុវត្ត ពោលគឺ រលត់នៅចំណុចលេខ៤ (មាត្រា ៣៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។




១. A បានបង្កើតកិច្ចសន្យាលក់ទិញដោយមានការឆបោក

២. A បានដឹងអំពីការឆបោក(ពេលដែលអាចផ្តល់សច្ចានុមតិបាន)

៣. ទោះបីជា A បានដឹងអំពីការឆបោកនៅចំណុចលេខ ២(ឆ្នាំទី៩) ក៏ដោយ ក៏សិទ្ធិលុបចោលរបស់ A ត្រូវរលត់នៅចំនុចលេខ ៣ (ឆ្នាំទី១០) មិនមែនរលត់នៅចំណុចលេខ ៤ ទេ។

## មោឃភាព និង ការលុបចោល

| | មោឃភាព | ការលុបចោល |
|---|---|---|
| មូលហេតុ | • អត្ថន័យផ្ទុយនិងបញ្ញត្តិអនុវត្តដោយបង្ខំឬសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ (មាត្រា ៣៥៧ វាក្យខណ្ឌទី១ និងមាត្រា ៣៥៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)<br>• ទម្រង់ផ្ទុយច្បាប់ (មាត្រា ៣៥៧ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) | •វិការៈនៃការបង្ហាញឆន្ទៈ(មាត្រា៣៤៦ ដល់ មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី)<br>• ខ្វះសមត្ថភាពខាងឆន្ទៈឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (មាត្រា ១៤ មាត្រា ១៨ មាត្រា ២៦ មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី) |
| អានុភាពនៃសកម្មភាព | អានុភាពមិនកើតឡើងតាំងពីដំបូង | អានុភាពកើតមានឡើងពីដំបូង ប៉ុន្តែពេលសិទ្ធិលុបចោលត្រូវបានអនុវត្តនោះ អានុភាព នោះនឹងបាត់បង់ដោយអានុភាពប្រតិសកម្ម (មាត្រា ៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) |
| អ្នកមានសិទ្ធិអះអាង | ជនណាក៏ដោយ (មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី) | អ្នកមានសិទ្ធិលុបចោល (មាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណី) |

| | | |
|---|---|---|
| ពេលដែលអាចអះអាង | មិនមានកម្រិតអំឡុងពេល | ៣ឆ្នាំចាប់ពីពេលដែលអាចផ្ដល់សច្ចានុមតិបាន ឬ១០ឆ្នាំ ចាប់ពីពេលដែលបានធ្វើសកម្មភាព (មាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណី) |
| ការផ្ដល់សច្ចានុមតិ | មិនបាន | បាន |

**ការលុបចោល និង ការផ្ដល់សច្ចានុមតិដោយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព អ្នកតំណាងដែលច្បាប់បានកំណត់ និង ហិតូបត្ថម្ភកៈ**

| | ការលុបចោល | ការផ្ដល់សច្ចានុមតិ |
|---|---|---|
| អនីតិជន | • ទោះបីជានៅមុនពេលបានដល់នីតិភាពក៏ដោយអនីតិជននោះអាចលុបចោលសកម្មភាពនោះបាន (មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។<br>• អ្នកតំណាងដែលច្បាប់បានកំណត់(អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន) ក៏អាចលុបចោលសកម្មភាពនោះបានដែរ (មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ | • នៅមុនពេលបានដល់នីតិភាព អនីតិជននោះ មិនអាចផ្ដល់សច្ចានុមតិបានទេ(មាត្រា ៣៦១ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ទោះបី នៅមុនពេលបានដល់នីតិភាពក៏ដោយ ប្រសិនបើមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បាន កំណត់ (អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន) នោះ អាចផ្ដល់សច្ចានុមតិចំពោះសកម្មភាពនោះបាន។<br>• អ្នកតំណាងដែលច្បាប់បានកំណត់(អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន) អាចផ្ដល់សច្ចានុមតិចំពោះសកម្មភាពនោះបាន ទោះបីជានៅមុនពេលអនីតិជននោះបានដល់នីតិភាពក៏ដោយ(មាត្រា៣៦១ កថាខណ្ឌ ទី២ នៃក្រមរដ្ឋប្បវេណី ) |
| ជននៅក្រោមអាណាព្យាបាលទូទៅ | • ទោះបីជានៅមុនពេលដែលការប្រកាសអំពីការចាប់ផ្ដើមអាណាព្យាបាលទូទៅត្រូវបានលុបចោលក៏ដោយ ជននៅក្រោមអាណាព្យាបាលទូទៅអាចលុប | • នៅមុនពេលការប្រកាសអំពីរបបអាណាព្យាបាលទូទៅត្រូវបានលុបចោលជននៅក្រោមអាណាព្យាបាលទូទៅមិនអាចផ្ដល់សច្ចានុមតិលើសកម្មភាពនោះបានឡើយ(មាត្រា ៣៦១ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ |

| | | |
|---|---|---|
| | ចោលសកម្មភាពនោះបាន (មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)<br>• អ្នកអាណាព្យាបាលទូទៅអាចលុបចោលសកម្មភាពនោះបាន (មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) | ទោះបីជា បាន ទទួលការយល់ព្រមពីអ្នកអាណាព្យាបាល ទូទៅក៏ដោយ ក៏នៅមុនពេលការប្រកាសអំពីរបប អាណាព្យាបាលទូទៅត្រូវបានលុបចោល សាមីខ្លួនមិនអាចផ្តល់សច្ចានុមតិលើសកម្មភាពនោះបានឡើយ។<br>• ទោះបីជានៅមុនពេលដែលការប្រកាសអំពីរបបអាណាព្យាបាលទូទៅត្រូវបានលុបចោលក៏ដោយ អ្នកអាណាព្យាបាលទូទៅអាចផ្តល់សច្ចានុមតិចំពោះសកម្មភាពនោះបាន(មាត្រា ៣៦១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) |
| ជននៅក្រោមរបបហិតូបត្ថម្ភ | • ទោះបីជានៅមុនពេលដែលការប្រកាសអំពីហិតូបត្ថម្ភត្រូវបានលុបចោលក៏ដោយ ជននៅក្រោមរបបហិតូបត្ថម្ភអាចលុបចោលសកម្មភាពនោះបាន (មាត្រា ៣៥៩ កថាខណ្ឌទី២)<br>• ហិតូបត្ថម្ភកៈក៏អាចលុបចោលសកម្មភាពនោះបានដែរ(មាត្រា ៣៥៩ កថាខណ្ឌទី២) | • នៅមុនពេលប្រកាសអំពីហិតូបត្ថម្ភត្រូវបានលុបចោលជននៅក្រោមហិតូបត្ថម្ភមិនអាចផ្តល់សច្ចានុមតិលើសកម្មភាពនោះបានទេ (មាត្រា ៣៦១ កថាខណ្ឌទី១ វាក្យខណ្ឌទី២នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ ប្រសិនបើមានការយល់ព្រមពីហិតូបត្ថម្ភកៈ ទោះបីជាមុនពេលការប្រកាសអំពីហិតូបត្ថម្ភត្រូវបានលុបចោលក៏ដោយ ក៏សាមីខ្លួនអាចផ្តល់សច្ចានុមតិបានដែរ (មាត្រា ៣៦១ កថាខណ្ឌ ទី២)។<br>• ទោះបីជានៅមុនការលុបចោលហិតូបត្ថម្ភក៏ដោយ ក៏ហិតូបត្ថម្ភកៈអាចផ្តល់សច្ចានុមតិបានដែរ។ |

## ៤.ការតំណាង

### ៤.១.និយមន័យ

ការតំណាង សំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀតដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង (មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណី)។ ការតំណាងក៏អាចអនុវត្តចំពោះសកម្មភាពឯកតោភាគីបានដែរ (មាត្រា ៣១២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។



### ៤.២.ប្រភេទ និងអត្ថប្រយោជន៍

ការតំណាងអាចបែងចែកជា៖

- **ការតំណាងដោយឆន្ទៈ**ជាការតំណាងដែលម្ចាស់សិទ្ធិជ្រើសតាំងអ្នកតំណាងហើយផ្ដល់សិទ្ធិតំណាង
- **ការតំណាងដែលច្បាប់បានកំណត់**ជាការតំណាងដែលកើតឡើងដោយសារបញ្ញត្តិច្បាប់។

ប្រសិនបើអ្នកតំណាងចុះហត្ថលេខាលើកិច្ចសន្យា កិច្ចសន្យានោះនឹងមានអានុភាព ទោះបីជាម្ចាស់សិទ្ធិមិនបានឃើញកិច្ចសន្យានោះក៏ដោយ ហើយកិច្ចសន្យាដែលម្ចាស់សិទ្ធិមិនបានឃើញនោះនឹងមានអានុភាពចងចំពោះម្ចាស់សិទ្ធិ។ ហេតុនេះ ការបង្កើតកិច្ចសន្យាតាមរយៈអ្នកតំណាងមានគ្រោះថ្នាក់ចំពោះម្ចាស់សិទ្ធិ។ ដូចនេះ នៅពេលម្ចាស់សិទ្ធិធ្វើការជ្រើសរើសអ្នកតំណាង ការកំណត់អំពីទំហំនៃសិទ្ធិតំណាងឲ្យបានច្បាស់លាស់ និងការជ្រើសរើសយកអ្នកតំណាងដែលអាចជឿទុកចិត្តបានមានសារៈសំខាន់ណាស់។ ទោះបីជា វាមានគ្រោះថ្នាក់បែបនេះក៏ដោយ ការណ៍ដែលម្ចាស់សិទ្ធិជ្រើសរើសអ្នកតំណាង ក៏មានភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធតំណាងដូចខាងក្រោម៖

តាមរយៈការប្រើប្រាស់ប្រព័ន្ធតំណាង អ្នកធ្វើជំនួញអាចធ្វើជំនួញបានច្រើននៅតាមតំបន់ផ្សេងៗ។ ម្យ៉ាងទៀត បុគ្គលដែលមិនអាចធ្វើជំនួញដោយខ្លួនឯងបាន ដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជនចាស់ជរាដែលមានសមត្ថភាពក្នុងការវិនិច្ឆ័យចុះខ្សោយ អាចធ្វើជំនួញបានតាមរយៈការប្រើប្រាស់ប្រព័ន្ធតំណាង។ ម្យ៉ាងទៀត ក្រុមហ៊ុនមិនអាចធ្វើសកម្មភាពដោយខ្លួនឯងបានទេ ហេតុនេះ អ្នកតំណាងក្រុមហ៊ុនចាំបាច់ត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកតំណាង។

### ៤.៣.មូលហេតុនៃការកកើតសិទ្ធិតំណាង

សិទ្ធិតំណាងកើតមានឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ឬ ដោយបញ្ញត្តិនៃច្បាប់ (មាត្រា ៣៦៥ នៃក្រមរដ្ឋប្បវេណី)។

មូលហេតុនៃការកកើតសិទ្ធិតំណាងដែលច្បាប់កំណត់មានដូចជា៖

- ករណីអ្នកដែលមានឋានៈជាក់លាក់ណាមួយចំពោះម្ចាស់សិទ្ធិក្លាយជាអ្នកតំណាងដោយស្វ័យប្រវត្តិ (អ្នកមានអំណាចមេបា)
- ករណីក្លាយជាអ្នកតំណាងតាមរយៈការពិភាក្សារបស់បុគ្គលក្រៅពីម្ចាស់សិទ្ធិ (ករណីកំណត់អ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្ដាយ (មាត្រា១០៣៧ មាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណី) ជាដើម)

- ករណីតុលាការជ្រើសតាំងអ្នកតំណាង(អ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន (មាត្រា ៣៧ នៃក្រមរដ្ឋប្បវេណី) អ្នកអាណាព្យាបាលរបស់អនីតិជន(មាត្រា ១០៦៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) អ្នកអាណាព្យាបាលទូទៅ (មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី) ជាដើម។

មូលហេតុនៃការកកើតសិទ្ធិតំណាងដោយឆន្ទៈ គឺកិច្ចសន្យាប្រគល់សិទ្ធិតំណាងរបស់ម្ចាស់សិទ្ធិ និង អ្នកតំណាង។ នៅពេលបង្កើតកិច្ចសន្យាអាណត្តិ កិច្ចសន្យាការងារ ឬ កិច្ចសន្យាម៉ៅការ ជាដើម ភាគច្រើនគឺគេបង្កើតកិច្ចសន្យាប្រគល់សិទ្ធិតំណាងនេះរួមគ្នាតែម្តង។ ប៉ុន្តែ កិច្ចសន្យាអាណត្តិ កិច្ចសន្យាការងារ កិច្ចសន្យាម៉ៅការ ជាដើម ជាកិច្ចសន្យាផ្សេងដោយឡែកពីកិច្ចសន្យាប្រគល់សិទ្ធិតំណាង ដូចនេះ មានករណីខ្លះ គេបង្កើតកិច្ចសន្យាអាណត្តិ កិច្ចសន្យាការងារ កិច្ចសន្យាម៉ៅការ ប៉ុន្តែ មិនបង្កើតកិច្ចសន្យាប្រគល់សិទ្ធិតំណាងទេ។

- **ទំនាក់ទំនងកិច្ចសន្យាអាណត្តិ និង កិច្ចសន្យាប្រគល់សិទ្ធិតំណាង**

កិច្ចសន្យាអាណត្តិ និង កិច្ចសន្យាប្រគល់សិទ្ធិតំណាងសុទ្ធតែជាកិច្ចសន្យាដែលភាគីម្ខាងផ្តល់អំណាចក្នុងការធ្វើសកម្មភាពជាកំណត់មួយឲ្យទៅភាគីម្ខាងទៀត ហេតុនេះកិច្ចសន្យាអាណត្តិ និង កិច្ចសន្យាប្រគល់សិទ្ធិតំណាងនេះមានលក្ខណៈស្រដៀងគ្នា។ មានប្រព័ន្ធច្បាប់ខ្លះមិនធ្វើការបែងចែករវាងកិច្ចសន្យាអាណត្តិនិងកិច្ចសន្យាប្រគល់សិទ្ធិតំណាងទេ ប៉ុន្តែ ក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្នបានធ្វើការបែងចែកដាច់ពីគ្នា។

កិច្ចសន្យាអាណត្តិកើតឡើងក្នុងករណីដែល A (អាណត្តិទាយក) ប្រគល់សិទ្ធិអំណាចឲ្យទៅ B (អាណត្តិគាហក) ធ្វើការចាត់ចែងកិច្ចការដើម្បី A (មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងការចាត់ចែងកិច្ចការមិនកំណត់ត្រឹមតែសកម្មភាពគតិយុត្ត (កិច្ចសន្យា និង សកម្មភាពឯកតោភាគី) ប៉ុណ្ណោះទេ សកម្មភាពទូទៅដែលមិនបង្កើតអានុភាពគតិយុត្តក៏រាប់បញ្ចូលដែរ។ សកម្មភាពទូទៅដែលមិនបង្កើតអានុភាពគតិយុត្តមានដូចជាសកម្មភាពនៃការបើកបររថយន្ត ការជីករណ្តៅដី ការធ្វើម្ហូប ជាដើម។ កិច្ចសន្យាប្រគល់សិទ្ធិតំណាងកើតឡើងក្នុងករណីដែល A (ម្ចាស់សិទ្ធិ) ប្រគល់សិទ្ធិអំណាចក្នុងការធ្វើ **សកម្មភាពភាពគតិយុត្ត** ឲ្យទៅ B (អ្នកតំណាង) **ក្នុងនាម** A ។

| | ខ្លឹមសារដែល A បានប្រគល់ឲ្យ B | កិច្ចសន្យាដែលកើតឡើង |
|---|---|---|
| ១ | សកម្មភាពទូទៅ | កិច្ចសន្យាអាណត្តិ |
| ២ | សកម្មភាពទូទៅ + ការធ្វើសកម្មភាពគតិយុត្តក្នុងនាម B | កិច្ចសន្យាអាណត្តិ |
| ៣ | សកម្មភាពទូទៅ + ការធ្វើសកម្មភាពគតិយុត្តក្នុងនាម A | កិច្ចសន្យាអាណត្តិ + កិច្ចសន្យាប្រគល់សិទ្ធិតំណាង |

ករណីទី១៖ ឧ. A បង់ប្រាក់ ១០០ ដុល្លារ/ខែឲ្យ B ដើម្បីឲ្យ B មកផ្ទះ A ធ្វើម្ហូបឲ្យ A រៀងរាល់ថ្ងៃ (ការធ្វើម្ហូបគឺជាសកម្មភាពទូទៅ)។ មានការសន្យាថា នឹងប្រើប្រាស់គ្រឿងផ្សំសម្រាប់ធ្វើម្ហូបដែលមាននៅផ្ទះរបស់ A ។

ករណីទី២៖ ឧ. A បង់ប្រាក់ ១០០ ដុល្លារ/ខែឲ្យ B ដើម្បីឲ្យ B មកផ្ទះ A ធ្វើម្ហូបឲ្យ A រៀងរាល់ថ្ងៃ។ គ្រឿងផ្សំធ្វើម្ហូបគឺ B ត្រូវទៅទិញនៅផ្សារដោយចំណាយប្រាក់ខ្លួនឯង ហើយប្រគល់វិក័យបត្រឲ្យទៅ A ទើប A បង់ប្រាក់ថ្លៃគ្រឿងផ្សំតាមក្រោយ (ការទិញគ្រឿងផ្សំ គឺជាការបង្កើតកិច្ចសន្យាលក់ទិញ ហេតុនេះ វាជាសកម្មភាពគតិយុត្ត)។

ករណីទី៣៖ ឧ. A បង់ប្រាក់ ១០០ ដុល្លារ/ខែឲ្យ B ដើម្បីឲ្យ B មកផ្ទះ A ធ្វើម្ហូបឲ្យ A រៀងរាល់ថ្ងៃ។ គ្រឿងផ្សំធ្វើម្ហូបគឺ B ទៅទិញនៅផ្សារក្នុងនាមជាអ្នកតំណាងឲ្យ A ហើយអ្នកលក់នៅក្នុងផ្សារនឹងផ្ញើលិខិតទារប្រាក់ទៅ A ហើយ A បង់ប្រាក់ឲ្យទៅអ្នកលក់ផ្ទាល់។

ឧទាហរណ៍នៃកិច្ចសន្យាប្រគល់សិទ្ធិតំណាង៖ A (អាណត្តិទាយក) ចង់បើកហាងលក់ស្រានៅភ្នំពេញ ដូចនេះ A បានស្វែងរកទីតាំងដែលល្អ ដើម្បីបើកហាងលក់ស្រា។ A កំពុងរស់នៅខេត្តសៀមរាប ដូចនេះ គាត់មិនអាចមកស្វែងរកដីនៅភ្នំពេញដោយខ្លួនឯងបានទេ ហេតុនេះ គាត់បានបង្កើតកិច្ចសន្យាអាណត្តិ ជាមួយ B (អាណត្តិគាហក) ដើម្បីឲ្យ B ស្វែងរកដីដែលមានទីតាំងល្អឲ្យខ្លួន។ B បានរកឃើញដីល្អមួយកន្លែងដែលជាកម្មសិទ្ធិរបស់ C ។

- ក្នុងករណីដែល A និង B បានបង្កើតកិច្ចសន្យាប្រគល់សិទ្ធិតំណាងនោះ B អាចបង្កើតកិច្ចសន្យាលក់ទិញជាមួយ C ក្នុងនាមជាអ្នកតំណាងរបស់ A បាន។ នៅពេលដែល B បង្កើតកិច្ចសន្យាលក់ទិញជាមួយ C នោះ A នឹងក្លាយជាអ្នកទិញ ដូចនេះការចុះបញ្ជីផ្ទេរកម្មសិទ្ធិគឺផ្ទេរពី C ទៅ A ។

- ក្នុងករណីដែល A និង B មិនបានបង្កើតកិច្ចសន្យាប្រគល់សិទ្ធិតំណាងទេនោះ B មិនអាចបង្កើតកិច្ចសន្យាលក់ទិញជាមួយ C ក្នុងនាមជាអ្នកតំណាងរបស់ A បានទេ។ ហេតុនេះ ដើម្បីបង្កើតកិច្ចសន្យាលក់ទិញ A ត្រូវមកភ្នំពេញដោយខ្លួនឯង ហើយចុះកិច្ចសន្យាលក់ទិញដោយផ្ទាល់ជាមួយ C ។ នេះមកពីកិច្ចសន្យាអាណត្តិ និង កិច្ចសន្យាប្រគល់សិទ្ធិតំណាង ជាកិច្ចសន្យាពីរដាច់ដោយឡែកពីគ្នា ហេតុនេះ ក្រោយពេលដែល B រកបាន ដីដែលមានទីតាំងល្អហើយនោះ A អាចបង្កើតកិច្ចសន្យាប្រគល់សិទ្ធិតំណាងជាមួយ B ដើម្បីឲ្យ B ចុះកិច្ចសន្យាលក់ទិញដីសម្រាប់ខ្លួនបាន។

សិទ្ធិតំណាងដោយឆន្ទៈ៖ កើតឡើងដោយការបង្កើតកិច្ចសន្យាប្រគល់សិទ្ធិតំណាងរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង។ មានករណីជាច្រើនដែលកិច្ចសន្យាប្រគល់សិទ្ធិតំណាងត្រូវបានបង្កើតឡើងស្របពេលជាមួយនឹងកិច្ចសន្យាអាណត្តិ ហេតុនេះ នៅក្នុងលិខិតដែលមានចំណងជើងថា លិខិតកិច្ចសន្យាអាណត្តិបានសរសេរចំណុចទាក់ទងនឹងការប្រគល់សិទ្ធិតំណាង ហើយម្ចាស់សិទ្ធិ (អាណត្តិទាយក) និង អ្នកតំណាង (អាណត្តិគា

ហាក) ចុះហត្ថលេខាលើលិខិតនោះ។ ករណីខ្លះទៀត ម្ចាស់សិទ្ធិបានបង្កើតលិខិតដែលមានចំណងជើងថា លិខិតប្រគល់សិទ្ធិ ហើយបានសរសេរចំណុចទាក់ទងនឹងការប្រគល់សិទ្ធិតំណាង ហើយម្ចាស់សិទ្ធិ (អាណត្តិទាយក) ចុះហត្ថលេខា និង ប្រគល់សិទ្ធិឲ្យអ្នកតំណាង (អាណត្តិគាហក)។ ប្រសិនបើមានលិខិតកិច្ចសន្យាអាណត្តិ ឬ លិខិតប្រគល់សិទ្ធិ នោះនឹងមានភាពច្បាស់លាស់ថា បានបង្កើតកិច្ចសន្យាអាណត្តិផង និង កិច្ចសន្យាប្រគល់សិទ្ធិតំណាងផង ហេតុនេះ គ្មានបញ្ហាទេ។

ប៉ុន្តែ ជាក់ស្តែងមានករណីខ្លះ ការតំណាងមិនបានបង្កើតជាលិខិតលាយលក្ខណ៍អក្សរទេ។ ឧ. A រស់នៅទីក្រុងភ្នំពេញមានចំការស្វាយនៅខេត្តកណ្តាល។ A បានជួល B ឲ្យថែទាំចំការស្វាយ ប៉ុន្តែ មិនបានធ្វើជាលាយលក្ខណ៍អក្សរទេ។ ករណីនេះ A និង B បានបង្កើតកិច្ចសន្យាអាណត្តិដោយផ្ទាល់មាត់។ តើ A និង B បានបង្កើតកិច្ចសន្យាប្រគល់សិទ្ធិតំណាងដែរ ឬ អត់ គឺមិនច្បាស់លាស់នោះទេ។ ឧ. ដោយសារ របងចំការស្វាយបានបាក់បែក B បានបង្កើតកិច្ចសន្យាជាមួយនឹងជាងជួសជុលក្នុងនាមជាអ្នកតំណាងឲ្យ A ។ ប្រសិនបើមានកិច្ចសន្យាប្រគល់សិទ្ធិតំណាង ជាងជួសជុលអាចទាមទារប្រាក់ពី A បាន។ ប៉ុន្តែ ប្រសិនបើ គ្មានកិច្ចសន្យាប្រគល់សិទ្ធិតំណាងទេនោះសកម្មភាពរបស់ B នឹងទៅជាការតំណាងដោយគ្មានសិទ្ធិ ហេតុនេះ ជាគោលការណ៍អ្នកជួសជុលមិនអាចទាមទារប្រាក់ពី A បានទេ។ ករណីនេះ ជាងជួសជុលអាចទាមទារប្រាក់ពី B បានដោយផ្អែកលើការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ (មាត្រា ៣៧១ នៃក្រមរដ្ឋប្បវេណី) ឬ ទាមទារពី A ប្រសិនបើបានបំពេញលក្ខខណ្ឌនៃការតំណាងដែលមានលក្ខណៈជារូបភាព(មាត្រា ៣៧២ នៃក្រមរដ្ឋប្បវេណី)។

ដូចករណីខាងលើនេះ តើមានកិច្ចសន្យាប្រគល់សិទ្ធិតំណាង ឬ អត់ ត្រូវសម្រេចតាមខ្លឹមសារនៃការព្រមព្រៀងរវាង A និង B ប៉ុន្តែ ក្នុងករណីដែលខ្លឹមសារនៃការព្រមព្រៀងមិនច្បាស់លាស់ទេគេនឹងធ្វើការបកស្រាយដោយផ្អែកលើទំនាក់ទំនងរវាង A និង B និង តាមទំនៀមទម្លាប់តាមតំបន់ ជាដើម។

### ៤.៤.ទំហំនៃសិទ្ធិតំណាង

ទំហំនៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ មានចែងនៅក្នុងច្បាប់ ចំណែកឯ ទំហំនៃសិទ្ធិតំណាងដោយឆន្ទៈ គឺមានកំណត់នៅក្នុងកិច្ចសន្យា (មាត្រា ៣៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ករណីសិទ្ធិតំណាងដោយឆន្ទៈ ជាទូទៅ ទំហំនៃសិទ្ធិតំណាងត្រូវបានកំណត់នៅក្នុងលិខិតកិច្ចសន្យាអាណត្តិ ឬ លិខិតប្រគល់សិទ្ធិ។ ប៉ុន្តែ ក៏មានករណីខ្លះ កិច្ចសន្យាប្រគល់សិទ្ធិតំណាង ក៏អាចកើតឡើងដោយផ្ទាល់មាត់ផងដែរ។ ទោះបីជា គ្មានលិខិតលាយលក្ខណ៍អក្សរក៏ដោយ ប្រសិនបើបានកំណត់អំពីទំហំនៃសិទ្ធិតំណាងដោយផ្ទាល់មាត់ នោះពុំមានបញ្ហាអ្វីនោះទេ ប៉ុន្តែ អាចមានករណីខ្លះទាំងនៅក្នុងលិខិតទាំងផ្ទាល់មាត់ ពុំបានកំណត់អំពីទំហំនៃសិទ្ធិតំណាងទេ។

ខ. នៅពេលម្ចាស់សិទ្ធិត្រូវចាកចេញពីផ្ទះមួយរយៈ ម្ចាស់សិទ្ធិបានពឹងពាក់សាច់ញាតិ ឬ មិត្តភក្តិ ឲ្យជួយគ្រប់គ្រងទ្រព្យសម្បត្តិផង។ ករណីនេះ ទោះបីជាបកស្រាយថា ម្ចាស់សិទ្ធិ បានប្រគល់សិទ្ធិតំណាងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិឲ្យទៅសាច់ញាតិ ឬ មិត្តភក្តិក៏ដោយ ក៏ទំហំនៃសិទ្ធិតំណាងពុំបានកំណត់ច្បាស់លាស់ដែរ។ ប្រសិនបើមិនដឹងអំពីទំហំនៃសិទ្ធិតំណាងទេ អ្នកតំណាងក៏ពិបាកនឹងដឹងថា តើត្រូវធ្វើសកម្មភាពណាខ្លះ ហើយ ភាគីម្ខាងទៀតនៃកិច្ចសន្យាក៏ពិបាកនឹងដឹងថាតើកិច្ចសន្យាដែលធ្វើស្ថិតនៅក្នុងទំហំនៃសិទ្ធិតំណាងដែរ ឬទេ។ ដើម្បីដោះស្រាយបញ្ហានេះ មាត្រា ៣៦៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ត្រូវបានបញ្ញត្តិឡើង។ មានន័យថា ក្នុងករណីដែលបានប្រគល់សិទ្ធិតំណាងហើយ តែមិនបានកំណត់អំពីទំហំនៃសិទ្ធិតំណាងទេនោះ អ្នកតំណាងត្រូវមានសិទ្ធិចំពោះអំពើថែរក្សា និង អំពើកែលំអ។ ប៉ុន្តែ ករណីនេះ មិនអនុវត្តឡើយចំពោះអំពើកែលំអដែលផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការតំណាង (មាត្រា ៣៦៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ មាត្រានេះក៏ត្រូវយកមកអនុវត្តផងដែរចំពោះអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមានដែលជាអ្នកតំណាងដែលច្បាប់បានកំណត់។

ក្នុងករណីអ្នកតំណាងដែលមិនបានកំណត់អំពីទំហំនៃសិទ្ធិតំណាងបានបង្កើតកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះជាអំពើថែរក្សា ឬ អំពើកែលំអ (អំពើដែលមិនផ្លាស់ប្តូរលក្ខណៈនៃកម្មវត្ថុ ឬ សិទ្ធិ) នោះ កិច្ចសន្យា ដែលត្រូវបានបង្កើតឡើងនោះគឺធ្វើឡើងក្នុងទំហំនៃសិទ្ធិតំណាង ហើយមានអានុភាព។ ប៉ុន្តែ ប្រសិនបើកិច្ចសន្យានោះជា អំពើកែលំអដែលផ្លាស់ប្តូរលក្ខណៈនៃកម្មវត្ថុ ឬ សិទ្ធិ ឬ ជាសកម្មភាពចាត់ចែង នោះ កិច្ចសន្យាដែលត្រូវបានបង្កើតឡើង គឺនៅក្រៅទំហំនៃសិទ្ធិតំណាង ហើយជាសកម្មភាពតំណាងដោយគ្មានសិទ្ធិ។ ហេតុនេះការវិនិច្ឆ័យថា អំពើណាមួយ ជាអំពើថែរក្សា ឬ អំពើកែលំអ (អំពើដែលមិនផ្លាស់ប្តូរលក្ខណៈនៃកម្មវត្ថុ ឬ សិទ្ធិ) ឬ ជាអំពើផ្សេងពីនេះ មានសារៈសំខាន់ណាស់។ ការវិនិច្ឆ័យថា អំពើណាមួយជាអំពើថែរក្សា ឬអំពើកែលំអនោះ មានភាពពិបាកហេតុនេះ ចាំបាច់ត្រូវធ្វើការសិក្សាស្រាវជ្រាវទៅលើសាលក្រម ឬ សាលដីកា (ប្រសិនបើមាន)ដើម្បីឲ្យមានភាពច្បាស់លាស់។

| |
|---|
| សកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិតំណាង = សកម្មភាពតំណាងដែលមានសុពលភាពក្នុងករណីធ្វើឡើងដោយអ្នកតំណាងដែលមិនបានកំណត់អំពីទំហំនៃសិទ្ធិតំណាង |

- អំពើថែរក្សា៖ គឺជា អំពើរក្សាស្ថានភាពនៃទ្រព្យសម្បត្តិ។ ឧទាហរណ៍៖ ប្រសិនបើ រថយន្តដែលជាទ្រព្យសម្បត្តិមួយក្នុងចំណោមទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិត្រូវបានធ្វើឲ្យខូចខាត នោះការថែរក្សា គឺជា ការបង្កើតកិច្ចសន្យាជួសជុលរថយន្តជាមួយនឹងជាងជួសជុលរថយន្ត។ តើសកម្មភាពខាងក្រោមនេះ ជាអំពើថែរក្សាដែរ ឬទេ?ឧទាហរណ៍៖ ដើម្បីផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជាប្រាក់ដែលជា ទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិ នោះអ្នកតំណាងត្រូវធ្វើសកម្មភាពណាដែលចាំបាច់។ ឧទាហរណ៍ ម្ចាស់ចំការបានពឹងពាក់អ្នកជិតខាងឲ្យ

មើលចំការរបស់ខ្លួន។ នៅពេលដែលម្ចាស់ចំការមិននៅ ដំណាំដល់ពេលត្រូវប្រមូលផល ហើយមិនអាចរង់ចាំបាន ហេតុនេះ អ្នកជិតខាងក៏បានប្រមូលផលយកទៅលក់ ហើយរក្សាប្រាក់សម្រាប់ ម្ចាស់ចំការ។

-អំពើកែលំអៈ គឺជាសកម្មភាពដែលបង្កើនតម្លៃនៃវត្ថុ ឬ សិទ្ធិ។ ប៉ុន្តែ អំពើកែលំអ ដែលស្ថិតក្នុងទំហំនៃសិទ្ធិតំណាង មានតែអំពើកែលំអដែលមិនផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិតែប៉ុណ្ណោះ។ ឧទាហរណ៍ ការបង្កើតកិច្ចសន្យាជាមួយជាងកញ្ចក់ ឲ្យផ្លាស់ប្តូរកញ្ចក់បង្អួចចាស់ជាក់កញ្ចក់ដែលមានគុណភាពល្អមិនងាយបែកដោយសារបង្អួចនៃអាគារដែលជាទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិ ចាស់ទ្រុឌទ្រោមងាយនឹងបែក។

| |
|---|
| សកម្មភាពដែលមិនស្ថិតនៅក្នុងទំហំនៃសិទ្ធិតំណាង = សកម្មភាពតំណាងដោយគ្មានសិទ្ធិក្នុងករណី ធ្វើឡើងដោយអ្នកតំណាងដែលមិនបានកំណត់អំពីទំហំនៃសិទ្ធិតំណាង |

-អំពើកែលំអដោយផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិៈ ជាអំពើដែលធ្វើឲ្យផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការតំណាង ហើយធ្វើឲ្យតម្លៃនៃទ្រព្យសម្បត្តិឡើងថ្លៃ។ "វត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃ ការតំណាង"សំដៅទៅលើទ្រព្យសម្បត្តិដែលម្ចាស់សិទ្ធិបានប្រគល់ឲ្យអ្នកតំណាងគ្រប់គ្រង ជាអាទិ៍។ ឧ. ករណីដែលម្ចាស់សិទ្ធិ A បានប្រគល់សិទ្ធិតំណាងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់ខ្លួនឲ្យទៅអ្នកតំណាង B នោះផ្ទះ រថយន្ត សិទ្ធិលើបំណុល ជាអាទិ៍ដែលជាទ្រព្យសម្បត្តិរបស់ A គឺជា "វត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃ ការតំណាង"។ ឧទាហរណ៍ ការបង្កើតកិច្ចសន្យាជាមួយជាងជួសជុលផ្ទះ ឲ្យផ្លាស់ប្តូរដំបូលប្រក់ស័ង្កសីទៅជា ដំបូលប្រក់ក្បឿង។ ឧទាហរណ៍ ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់ ឲ្យសាងសង់អាគារនៅលើដីទំនេរ ដែលជាទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិ។

- សកម្មភាពចាត់ចែងវត្ថុ ឬ សិទ្ធិៈ ឧទាហរណ៍ ការលក់រថយន្តដែលជាទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិ។

## ៤.៥. លក្ខខណ្ឌ និងអានុភាពនៃសិទ្ធិតំណាង

អានុភាពនៃកិច្ចសន្យាដែលអ្នកតំណាងបានបង្កើតកើតមានចំពោះម្ចាស់សិទ្ធិតាមរយៈអានុភាពនៃសិទ្ធិតំណាង។ ដើម្បីបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម (មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណី)៖

១. អត្ថិភាពនៃសិទ្ធិតំណាងនៅពេលធ្វើសកម្មភាពតំណាង (ការកើតមាននូវសិទ្ធិតំណាងតាមច្បាប់ ឬ តាមកិច្ចសន្យា)

២. អត្ថិភាពនៃសកម្មភាពតំណាង (ការបង្កើតកិច្ចសន្យាដោយអ្នកតំណាង ជាមួយ ភាគីម្ខាងទៀត)

៣. នៅពេលធ្វើសកម្មភាពតំណាង អ្នកតំណាងបានបង្ហាញថា ខ្លួនធ្វើដើម្បីម្ចាស់សិទ្ធិ (អង្គហេតុច្បាស់)

**ការបង្ហាញច្បាស់លាស់ (អង្គហេតុច្បាស់)**

ក្នុងករណីអ្នកតំណាង B បានបង្កើតកិច្ចសន្យាដើម្បីម្ចាស់សិទ្ធិ A នៅក្នុងលិខិតកិច្ចសន្យា អ្នកតំណាង B នឹងចុះហត្ថលេខាដោយប្រើឈ្មោះ B ។ ប៉ុន្តែ ក្រៅពីចុះហត្ថលេខា ត្រូវសរសេរបញ្ជាក់នៅក្នុងលិខិតកិច្ចសន្យាដើម្បីឲ្យដឹងថា B ចុះកិច្ចសន្យាដើម្បី A ដូចជា" B ជាអ្នកតំណាងរបស់ A " ឬ " B ជាអ្នកតំណាងឲ្យក្រុមហ៊ុន A " ជាដើម។ នេះគឺជា "ការបង្ហាញថាខ្លួនធ្វើសកម្មភាពដើម្បីម្ចាស់សិទ្ធិ" មានន័យថាជាអង្គហេតុច្បាស់។ បើគ្មានអង្គហេតុច្បាស់ទេ នោះ ប្រសិនបើអ្នកតំណាង B បានបង្កើត កិច្ចសន្យាដោយចុះឈ្មោះថា "B" នោះភាគីម្ខាងទៀតនៃកិច្ចសន្យា C នឹងយល់ថាខ្លួនបានបង្កើតកិច្ចសន្យា ជាមួយ B មិនមែនបង្កើតកិច្ចសន្យាជាមួយ A ទេ។ ហេតុនេះ ករណីគ្មានអង្គហេតុច្បាស់ទេ C អាចអះអាងថា បានបង្កើតកិច្ចសន្យាជាមួយ B បាន (មាត្រា ៣៧៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី )។ ម៉្យាងទៀត ប្រសិនបើក្រោយពេលបង្កើតកិច្ចសន្យា C ដឹងថា A គឺជាម្ចាស់សិទ្ធិនោះ C អាចអះអាងថា កិច្ចសន្យានោះ ជាកិច្ចសន្យាជាមួយ B ឬ ជាកិច្ចសន្យាជាមួយ A (មាត្រា ៣៧៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ និង កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ នៅពេលបង្កើតកិច្ចសន្យា ទោះបីជា គ្មានអង្គហេតុច្បាស់ ក៏ដោយ ប្រសិនបើ C បានដឹងថា B កំពុងចុះកិច្ចសន្យាក្នុងនាមជាអ្នកតំណាងឲ្យ A នោះ C មិនអាចអះអាងថា បានបង្កើតកិច្ចសន្យាជាមួយ B នោះទេ ហើយត្រូវទទួលស្គាល់ថា បានបង្កើតកិច្ចសន្យាជាមួយ A (មាត្រា ៣៧៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

### ៤.៦. ការកម្រិតសិទ្ធិតំណាង

អំពើដែលផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និង ផលប្រយោជន៍របស់អ្នកតំណាងមានភាពផ្ទុយគ្នា (អំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា) ទោះបីជា អំពើនោះស្ថិតនៅក្នុងទំហំនៃសិទ្ធិតំណាងក៏ដោយ ក៏ អ្នកតំណាងនោះគ្មានសិទ្ធិតំណាងទេ (មាត្រា ៣៦៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ អំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា បើនិយាយឲ្យងាយយល់ គឺករណីដែលអ្នកតំណាងទទួលបានផលប្រយោជន៍ពីការខាតបង់របស់ម្ចាស់សិទ្ធិ។ ករណីនេះ ដោយសារកម្រិតគ្រោះថ្នាក់ដែលអ្នកតំណាងបំពានផលប្រយោជន៍របស់ម្ចាស់សិទ្ធិមានកម្រិតខ្ពស់ទើបសិទ្ធិតំណាងត្រូវបានគេកម្រិត។ បញ្ហាថា តើអំពើមួយណាជាអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា ឬ អត់នោះ គឺចាំបាច់ត្រូវពិចារណាទៅតាមអំពើនីមួយៗ ប៉ុន្តែ ជំនួញដោយខ្លួនឯង ច្រើនតែជាអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា ហេតុនេះត្រូវបានគេសន្មតថា ជាអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា (មាត្រា ៣៦៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ការតំណាងឲ្យភាគីទាំងសងខាង មិនមែនជាករណីផលប្រយោជន៍រវាងម្ចាស់សិទ្ធិ និង អ្នកតំណាង មានភាពផ្ទុយគ្នានោះទេ ប៉ុន្តែ លទ្ធភាពនៃការបង្កើតកិច្ចសន្យាដែលនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់សិទ្ធិក៏មានកម្រិតខ្ពស់ ដូចករណីអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នាដែរ ហេតុនេះ ទើបគេកម្រិតសិទ្ធិរបស់អ្នកតំណាង ដូចករណីអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នាផងដែរ។

នៅពេលអានមាត្រា ៣៦៧ នៃក្រមរដ្ឋប្បវេណី មានចំណុច ២ ដែលចាំបាច់ត្រូវធ្វើការប្រុងប្រយ័ត្ន។ ចំណុចទីមួយគឺ ទោះបីជាជំនួញដោយខ្លួនឯង ឬ ជំនួញដោយការតំណាងភាគីទាំងសងខាងក៏ដោយ មិនមែនសុទ្ធតែសិទ្ធិតំណាងត្រូវបានកម្រិតនោះទេ។ ប្រសិនបើភាគីម្ខាងទៀតនៃកិច្ចសន្យាបង្ហាញថា មិនមែនជាជំនួញដោយខ្លួនឯង ឬ អំពើដែលនាំឲ្យមានផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និង របស់អ្នកតំណាងផ្ទុយគ្នាទេ នោះការសន្មតថាជាអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នានឹងមិនកើតឡើងទេ ដូចនេះ សិទ្ធិតំណាងនឹងមានសុពលភាព។ ចំណុចទីពីរគឺ ទោះបីជាជំនួញដែលមិនមែនជាជំនួញដោយខ្លួនឯង ឬ ជំនួញតំណាងឲ្យភាគី ទាំងសងខាង ឬ ជំនួញទម្រង់ផ្សេងទៀតក៏ដោយ ប្រសិនបើផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និង ផលប្រយោជន៍របស់អ្នកតំណាងផ្ទុយគ្នានោះ ជំនួញនោះនឹងក្លាយជាជំនួញដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា ហើយសិទ្ធិតំណាងក៏ត្រូវបានកម្រិតដែរ។

ក្នុងករណីដែលបានបង្កើតកិច្ចសន្យាតាមរយៈអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា ប្រសិនបើអត្ថន័យនៃកិច្ចសន្យា បំពានផលប្រយោជន៍របស់ម្ចាស់សិទ្ធិ ឬ មិនបំពានផលប្រយោជន៍របស់ម្ចាស់សិទ្ធិក៏ដោយ កិច្ចសន្យានោះត្រូវក្លាយជាអំពើតំណាងដោយគ្មានសិទ្ធិ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់សិទ្ធិផ្តល់ការយល់ព្រមចំពោះអំពើដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា នោះកិច្ចសន្យានោះនឹងក្លាយជាអំពើតំណាងដែលមានសុពលភាពហើយមានអានុភាពចំពោះម្ចាស់សិទ្ធិ(មាត្រា៣៦៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ទោះបីជាករណីបង្កើតកិច្ចសន្យាដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិក៏ដោយ ប្រសិនបើក្រោយមកម្ចាស់សិទ្ធិផ្តល់សច្ចានុមតិនោះ កិច្ចសន្យានោះនឹងក្លាយជាអំពើតំណាងដែលមានសុពលភាព ហើយមានអានុភាពចំពោះម្ចាស់សិទ្ធិ (មាត្រា ៣៦៩ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

១). ជំនួញដោយខ្លួនឯង (មាត្រា ៣៦៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ជាជំនួញរវាង អ្នកតំណាង និង ម្ចាស់សិទ្ធិ។

ឧទាហរណ៍៖ A បានប្រគល់សិទ្ធិតំណាងឲ្យទៅ B ក្នុងការលក់ដីរបស់ A ។ B បានបង្កើត កិច្ចសន្យា លក់ទិញរវាង A និង B ដោយយក A ជាអ្នកលក់ហើយ B ជាអ្នកទិញ។ កិច្ចសន្យានេះគឺជា ជំនួញដោយខ្លួនឯង។ B បានប្រើប្រាស់ឋានៈពីរ ដែលមួយគឺជា អ្នកតំណាងរបស់ A ហើយមួយទៀតគឺ B ខ្លួនឯងផ្ទាល់ ជាភាគីម្ខាងទៀតនៃកិច្ចសន្យា ក្នុងការបង្កើតលិខិតកិច្ចសន្យាតែម្នាក់ឯង។ មានការបារម្ភថា B នឹងធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ A ក្នុងការបង្កើតលិខិតកិច្ចសន្យាលក់ដីក្នុងតម្លៃថោកដើម្បីខ្លួនអាចទិញដីបានក្នុងតម្លៃថោក។ ហេតុនេះ B មិនមានសិទ្ធិតំណាងក្នុងការបង្កើតកិច្ចសន្យាបែបនេះទេ ហើយកិច្ចសន្យាលក់ទិញនេះ ជាអំពើតំណាងដោយគ្មានសិទ្ធិ។




២). ការតំណាងចំពោះភាគីទាំងសងខាង (មាត្រា ៣៦៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី) ចំពោះករណីអ្នកតំណាងធ្វើជាអ្នកតំណាងឲ្យម្ចាស់សិទ្ធិផង តតិយជនផង នោះផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និងរបស់តតិយជនមានភាពផ្ទុយគ្នា។

ឧទាហរណ៍៖ A បានប្រគល់សិទ្ធិតំណាងឲ្យទៅ B ក្នុងការលក់ដីរបស់ A ។ C បានប្រគល់សិទ្ធិតំណាងឲ្យ B ក្នុងការទិញដីសម្រាប់ C ។ C បានបង្កើតលិខិតកិច្ចសន្យាដែលមាន A ជាអ្នកលក់ និង C ជាអ្នកទិញ។ A ចង់លក់ដីឲ្យបានថ្លៃ ចំណែកឯ C ចង់ទិញដីក្នុងតម្លៃថោក ហេតុនេះ ផលប្រយោជន៍រវាង A និង C មានភាពផ្ទុយគ្នា។ ដូចនេះ កិច្ចសន្យានេះ គឺជាការតំណាងចំពោះភាគីទាំងសងខាង។ B បានប្រើប្រាស់ឋានៈពីរដែលមួយ គឺជាអ្នកតំណាងរបស់ A ហើយមួយទៀតគឺជា អ្នកតំណាងរបស់ C ក្នុងការបង្កើតលិខិតកិច្ចសន្យាតែម្នាក់ឯង។ មានការបារម្ភថា B អាចនឹងធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ A ក្នុងការបង្កើតលិខិតកិច្ចសន្យាលក់ដី ក្នុងតម្លៃថោក ដើម្បីឆ្លើយតបទៅនឹងការពឹងពាក់របស់ C ។ ហេតុនេះ B មិនមានសិទ្ធិតំណាង ក្នុងការបង្កើតកិច្ចសន្យាបែបនេះទេ ហើយកិច្ចសន្យាលក់ទិញនេះ គឺជាអំពើតំណាងដោយគ្មានសិទ្ធិ។




៣). អំពើផ្ទុយនឹងផលប្រយោជន៍ផ្សេងទៀត (មាត្រា ៣៦៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ទោះបីជាមិនមែនជំនួញដោយខ្លួនឯង ឬ ជំនួញតំណាងឲ្យភាគីទាំងសងខាងក៏ដោយ ជំនួញដែលនាំឲ្យមានការបាត់បង់ផលប្រយោជន៍របស់ម្ចាស់សិទ្ធិ ហើយក្លាយទៅជាផលប្រយោជន៍របស់អ្នកតំណាងនឹងទៅជាជំនួញដែលនាំឲ្យមានផលប្រយោជន៍ផ្ទុយគ្នា ហើយសិទ្ធិតំណាងនឹងត្រូវបានកម្រិត។

ឧទាហរណ៍ទី១៖ A ជាប្ដីបានប្រគល់សិទ្ធិតំណាងឲ្យទៅ B ជាប្រពន្ធ ក្នុងការចាត់ចែង ទ្រព្យដោយឡែករបស់ខ្លួន តែដោយ B មានបំណុលខ្ចីប្រាក់ពីធនាគារ C B ក៏ប្រើសិទ្ធិតំណាងនោះ ដោយយកទ្រព្យសម្បត្តិ

របស់ A ទៅបង្កើតហ៊ីប៉ូតែកដើម្បីធានាកាតព្វកិច្ចរបស់ខ្លួនទៅវិញ។ ផលប្រយោជន៍របស់ A និង ផលប្រយោជន៍របស់ B មានភាពផ្ទុយគ្នា ហេតុដូច្នេះហើយ សិទ្ធិតំណាងត្រូវបានកម្រិត។

ឧទាហរណ៍ទី២ ៖ A បានប្រគល់សិទ្ធិតំណាងឲ្យទៅ B ក្នុងការលក់ដីរបស់ A ។ B បានបង្កើតកិច្ចសន្យាលក់ទិញរវាង A និង C ដោយមាន A ជាអ្នកលក់ និង C ជាអ្នកទិញ។ តាមពិត B និង C បានសន្យាគ្នា ដោយចែកផលប្រយោជន៍ពីការលក់ ដែលមានន័យថា ប្រសិនបើ B លក់ដីឲ្យ C បានក្នុងតម្លៃថោកជាងតម្លៃ ទីផ្សារនោះ C ត្រូវចែកចំណែក ៥០% ពីប្រាក់ដែលចំណេញពីតម្លៃទីផ្សារឲ្យទៅ B ។ ប្រសិនបើ B លក់បានក្នុងតម្លៃថោកនោះ B នឹងទទួលបានប្រាក់កម្រៃពី C ដូច្នេះហើយ ផលប្រយោជន៍របស់ A និងរបស់ B មានភាពផ្ទុយគ្នា។ ករណីនេះ B មិនមានសិទ្ធិតំណាងក្នុងការបង្កើតកិច្ចសន្យាបែបនេះទេ ហើយកិច្ចសន្យា លក់ទិញបែបនេះ គឺជាអំពើតំណាងដោយគ្មានសិទ្ធិ។

ឧទាហរណ៍ទី៣ ៖ A បានប្រគល់សិទ្ធិតំណាងឲ្យទៅ B ក្នុងការលក់ដីរបស់ A ។ B បានបង្កើតកិច្ចសន្យាលក់ទិញរវាង A និង C ដោយមាន C ជាប្រពន្ធរបស់ B ។

តើក្នុងករណីនេះ ផលប្រយោជន៍របស់អ្នកតំណាង និង ម្ចាស់សិទ្ធិមានភាពផ្ទុយគ្នាដែរឬទេ?

## ៤.៧.ការរលត់សិទ្ធិតំណាង

- **សិទ្ធិតំណាងដែលបានទទួលពីម្ចាស់សិទ្ធិដោយកិច្ចសន្យាត្រូវរលត់ដោយសារមូលហេតុដូចខាងក្រោម** (មាត្រា ៣៦៨ នៃក្រមរដ្ឋប្បវេណី) ៖
  - មរណភាព ធនក្ស័យ ឬ ការរំលាយរបស់ម្ចាស់សិទ្ធិ
  - មរណភាព ធនក្ស័យ ឬ ការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង
  - ការបញ្ចប់អាណត្តិ កិច្ចសន្យាការងារ ឬ ទំនាក់ទំនងគតិយុត្តផ្សេងទៀត ដែលបានប្រគល់សិទ្ធិតំណាង
  - **មរណភាព៖**

ម្ចាស់សិទ្ធិបានជឿជាក់ និង បានជ្រើសតាំងបុគ្គលណាមួយឲ្យធ្វើជាអ្នកតំណាង។ ទោះបីជាម្ចាស់សិទ្ធិទទួលមរណភាពក៏ដោយ ឬ អ្នកតំណាងទទួលមរណភាពក៏ដោយ វានឹងក្លាយជាមូលហេតុនៃការរលត់សិទ្ធិតំណាង។ ប៉ុន្តែក្នុងករណីដែលម្ចាស់សិទ្ធិ ឬ អ្នកតំណាងទទួលមរណភាព សន្តតិជនរបស់អ្នកនោះ អាចធ្វើការព្រមព្រៀងចំពោះការបន្តទំនាក់ទំនងនៃការតំណាងបាន។ម្យ៉ាងទៀត ទោះបីជា គ្មានការព្រមព្រៀងបែបនេះក៏ដោយសន្តតិជនរបស់ម្ចាស់សិទ្ធិអាចធ្វើការជ្រើសតាំងអ្នកតំណាងផ្សេងទៀត ឬ ម្ចាស់សិទ្ធិអាចជ្រើសតាំងសន្តតិជនរបស់អ្នកតំណាងឲ្យធ្វើជាអ្នកតំណាងថ្មីក៏បាន។

➢ **ធនក្ស័យ៖**

ក្នុងករណីដែលម្ចាស់សិទ្ធិបានធនក្ស័យ ទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិ នឹងត្រូវគ្រប់គ្រងដោយអភិបាលបណ្ដោះអាសន្ន ដូចនេះ សិទ្ធិតំណាងរបស់អ្នកតំណាងនឹងត្រូវរលត់។

ក្នុងករណី អ្នកតំណាងបានធនក្ស័យ អាចនិយាយបានថា សមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់អ្នកតំណាងមិនគ្រប់គ្រាន់ ហើយគាត់អាចនឹងធ្វើអំពើដែលនាំឲ្យខូចដល់ផលប្រយោជន៍របស់ម្ចាស់សិទ្ធិ ហេតុនេះ សិទ្ធិតំណាងត្រូវរលត់។ ប៉ុន្តែ ម្ចាស់សិទ្ធិក៏អាចធ្វើការជ្រើសតាំងអ្នកតំណាងដែលធនក្ស័យនោះ ឲ្យធ្វើជាអ្នកតំណាងជាថ្មីម្ដងទៀតបានដែរ។

➢ **ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព៖**

ទោះបីជា ម្ចាស់សិទ្ធិត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ មិនមែនមានន័យថា សមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកតំណាងមានបញ្ហានោះទេ ហើយក៏មិនធ្វើឲ្យប៉ះពាល់ទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិដែរ ដូច្នេះ សិទ្ធិតំណាងមិនរលត់ទេ។

ប្រសិនបើ អ្នកតំណាងត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព មានន័យថាសមត្ថភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកតំណាងមានបញ្ហា ហើយអាចនឹងធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍របស់ម្ចាស់សិទ្ធិនៅពេលធ្វើសកម្មភាពតំណាង ដូច្នេះ សិទ្ធិតំណាងត្រូវរលត់។ ម្ចាស់សិទ្ធិក៏អាចផ្ដល់សិទ្ធិតំណាងចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបានដែរ ក្នុងករណីនេះ ជននោះអាចធ្វើសកម្មភាពតំណាងសម្រាប់ម្ចាស់សិទ្ធិបាន (មាត្រា ៣៧៥ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពត្រូវបានម្ចាស់សិទ្ធិប្រគល់សិទ្ធិតំណាងឲ្យធ្វើសកម្មភាពតំណាងសម្រាប់ខ្លួននោះ ជនដែលត្រូវបានកម្រិតសមត្ថភាព អាចធ្វើសកម្មភាពតំណាងដែលមានសុពលភាពដោយឯករាជ្យដោយពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបាអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ឬ ហិតូបត្ថមកៈឡើយ (មាត្រា ៣៧៥ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ A មានអាយុ ២០ឆ្នាំ បានប្រគល់សិទ្ធិតំណាងឲ្យ B មានអាយុ ១៥ឆ្នាំ ក្នុងការទិញម៉ូតូឲ្យខ្លួន។ ក្នុងករណីដែល B បានបង្កើតកិច្ចសន្យាលក់ទិញម៉ូតូក្នុងនាមជាអ្នកតំណាងឲ្យ A នោះ B និង A មិនអាចលុបចោលកិច្ចសន្យាលក់ទិញ ដោយយកមូលហេតុថា B គឺជាអនីតិជនបានទេ ទោះបីជា មានការយល់ព្រម ឬគ្មានការយល់ព្រមពីអ្នកអាណាព្យាបាលរបស់ B ក៏ដោយ។ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺជាប្រព័ន្ធមួយដែលត្រូវបានបង្កើតឡើងដើម្បីការពារ B ដែលជាជនត្រូវបានកម្រិតសមត្ថភាព។ ប្រសិនបើ B បានធ្វើសកម្មភាពក្នុងនាមជាអ្នកតំណាង ទោះបីជាបានបង្កើតកិច្ចសន្យា ខាតផលប្រយោជន៍ដោយសារសមត្ថភាពក្នុងការវិនិច្ឆ័យរបស់ B មិនគ្រប់គ្រាន់ក៏ដោយ អានុភាពនៃកិច្ចសន្យាមិនធ្លាក់មកលើ B ដែលជាអ្នកតំណាងទេ គឺ

ត្រូវមានអានុភាពចំពោះ A ដែលជាម្ចាស់សិទ្ធិ ដូច្នេះ មិនមានភាពចាំបាច់ក្នុងការលុបចោលកិច្ចសន្យាដើម្បីការពារ B នោះទេ។

ស្ថានភាពដែលត្រូវការពារ B នោះគឺករណី B បានបង្កើតកិច្ចសន្យាសម្រាប់ B ខ្លួនឯងផ្ទាល់។ និយាយរួម គឺករណី B បានបង្កើតកិច្ចសន្យាលក់ទិញម៉ូតូសម្រាប់ B ខ្លួនឯងផ្ទាល់។ ករណីនេះ B ឬ អ្នកអាណាព្យាបាលរបស់ B អាចលុបចោលកិច្ចសន្យាបាន។

- **សិទ្ធិតំណាងដែលច្បាប់បានកំណត់៖** មូលហេតុដែលកំណត់ក្នុងច្បាប់។

## ៤.៨. ការតំណាងដោយគ្មានសិទ្ធិ

### ៤.៨.១. អត្ថន័យ

សកម្មភាពតំណាងដោយគ្មានសិទ្ធិ គឺជាសកម្មភាពដែលបុគ្គលគ្មានសិទ្ធិតំណាងធ្វើសកម្មភាពតំណាងឲ្យម្ចាស់សិទ្ធិ (មាត្រា ៣៦៩ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

អ្នកតំណាងដោយគ្មានសិទ្ធិ គឺ៖

- បុគ្គលដែលមិនត្រូវបានប្រគល់សិទ្ធិតំណាង
- បុគ្គលដែលបានធ្វើសកម្មភាពលើសទំហំនៃសិទ្ធិតំណាងដែលត្រូវបានប្រគល់ឲ្យ
- បុគ្គលដែលបានធ្វើសកម្មភាពក្នុងនាមជាអ្នកតំណាងនៅក្រោយពេលដែលសិទ្ធិតំណាងដែលបានប្រគល់ឲ្យហើយបានរលត់។

### ៤.៨.២. អានុភាពនៃអំពើតំណាងដោយគ្មានសិទ្ធិ

អំពើរបស់អ្នកតំណាងដោយគ្មានសិទ្ធិ មិនមានអានុភាពចំពោះម្ចាស់សិទ្ធិទេ (មាត្រា ៣៦៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ហើយអ្នកតំណាងក៏មិនមែនជាភាគីនៃកិច្ចសន្យាដែរ ដូចនេះ មិនមានអានុភាពចំពោះអ្នកតំណាងទេ (មាត្រា ៣៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

ប៉ុន្តែ អំពើតំណាងដោយគ្មានសិទ្ធិ ត្រូវមានសុពលភាពប្រតិសកម្មដោយសច្ចានុមតិតាំងពីពេលដែលអំពើនោះ ត្រូវបានធ្វើឡើង (មាត្រា ៣៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិអាចទាមទារឲ្យអនុវត្តកិច្ចសន្យា ឬ ទាមទារសំណងការខូចខាតចំពោះអ្នកតំណាងដោយគ្មានសិទ្ធិតាមមាត្រា ៣៧១ ឬ ទាមទារឲ្យម្ចាស់សិទ្ធិអនុវត្តកិច្ចសន្យាតាមមាត្រា ៣៧២ នៃក្រមរដ្ឋប្បវេណីបាន។

### ៤.៨.៣.សច្ចានុមតិដោយម្ចាស់សិទ្ធិ (មាត្រា ៣៧០ នៃក្រមរដ្ឋប្បវេណី)

**វិធីផ្តល់សច្ចានុមតិ៖** ប្រសិនបើម្ចាស់សិទ្ធិមិនបានបង្ហាញឆន្ទៈផ្តល់សច្ចានុមតិចំពោះភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិទេ នោះម្ចាស់សិទ្ធិមិនអាចអះអាងអំពីអានុភាពនៃការផ្តល់សច្ចានុមតិចំពោះភាគីម្ខាងទៀតបានឡើយ (មាត្រា ៣៧០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ទោះបីជាម្ចាស់សិទ្ធិបានបង្ហាញឆន្ទៈផ្តល់សច្ចានុមតិចំពោះអំពើរបស់អ្នកតំណាងដោយគ្មានសិទ្ធិក៏ដោយ ក៏ម្ចាស់សិទ្ធិមិនអាចអះអាងអំពីអានុភាពនៃការផ្តល់សច្ចានុមតិចំពោះភាគីម្ខាងទៀតបានទេ។ ប្រសិនបើភាគីម្ខាងទៀតបានដឹងថាមានការផ្តល់សច្ចានុមតិហើយ ម្ចាស់សិទ្ធិក៏បានជូនដំណឹងទៅភាគីម្ខាងទៀតនូវការផ្តល់សច្ចានុមតិ នោះអានុភាពនៃការផ្តល់សច្ចានុមតិនឹងកើតឡើងចំពោះភាគីម្ខាងទៀត។

**អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ៖** មានតែម្ចាស់សិទ្ធិទេដែលជាអ្នកមានសិទ្ធិផ្តល់សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិចំពោះភាគីម្ខាងទៀត។


<u>លិខិតផ្តល់សច្ចានុម័ត</u>

ខ្ញុំសូមផ្តល់សច្ចានុម័តទៅលើកិច្ចសន្យា
ដែល B បានធ្វើជាមួយនឹង C ដូចខាងក្រោម៖
កាលបរិច្ឆេទកិច្ចសន្យា៖ ថ្ងៃទី.....ខែ.....ឆ្នាំ.....
អ្នកលក់៖ C
អ្នកទិញ៖ A
កម្មវត្ថុ៖ Lexus សេរី ២០១៥ ពណ៌ខ្មៅ
ថ្លៃលក់ទិញ៖ ២០០០០ដុល្លារ

ថ្ងៃទី..... ខែ..... ឆ្នាំ.....

A

**អានុភាពនៃការផ្តល់សច្ចានុមតិ៖** អំពើតំណាងដោយគ្មានសិទ្ធិត្រូវមានសុពលភាពប្រតិសកម្មដោយសច្ចានុមតិតាំងពីពេលដែលអំពើនោះត្រូវបានធ្វើឡើង។ ប៉ុន្តែ សច្ចានុមតិនោះមិនអាចធ្វើឲ្យខូចផលប្រយោជន៍តតិយជនដែលបានកើតឡើង ក្នុងអំឡុងពេល ចាប់តាំងពីពេលដែលអំពើតំណាងដោយគ្មានសិទ្ធិនោះត្រូវបានធ្វើឡើងរហូតដល់ពេលផ្តល់សច្ចានុមតិ។

ឧទាហរណ៍៖




B ដែលជាអ្នកតំណាងដោយគ្មានសិទ្ធិរបស់ A បានធ្វើអនុប្បទានសិទ្ធិលើបំណុលដែល A មានចំពោះ X ឲ្យទៅ C នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ X បានទទួលលិខិតជូនដំណឹង ដែលមានភ្ជាប់កាលបរិច្ឆេទស្លាពរ ថ្ងៃទី៥ ខែមករាឆ្នាំ២០១៣។ នៅថ្ងៃទី ៦ ខែមករា A បានធ្វើអនុប្បទានសិទ្ធិលើបំណុលដដែលនោះឲ្យទៅ D។ X បានទទួលលិខិតជូនដំណឹងដែលមានភ្ជាប់កាលបរិច្ឆេទស្លាពរថ្ងៃទី១០ ខែមករា។ ត្រង់ចំណុចនេះ ដោយសារ D បានបំពេញលក្ខខណ្ឌតតាំងចំពោះតតិយជន C ព្រោះ C ជាអនុប្បទានិក ផ្អែកតាម អំពើតំណាងដោយគ្មានសិទ្ធិរបស់ B នោះ D បានធ្វើលទ្ធកម្មឋានៈជាអនុប្បទានិកនៃសិទ្ធិលើបំណុលជាស្ថាពរ។ នៅថ្ងៃទី១១ ខែមករា A បានផ្តល់សច្ចានុមតិចំពោះ C អំពីការធ្វើអនុប្បទានសិទ្ធិលើបំណុល ។ ក្នុងករណីនេះ D គឺជាតតិយជនដែលទទួលបាននូវការការពារ ព្រោះថាប្រសិនបើអនុប្បទានសិទ្ធិលើបំណុលចំពោះ C មាន អានុភាពប្រតិសកម្មនោះនឹងមានអនុប្បទានត្រួតគ្នារវាងពី A ទៅ C និងពី A ទៅ D ហើយដោយសារតែ C បានទទួលលិខិតជូនដំណឹងដែលមានភ្ជាប់កាលបរិច្ឆេទស្លាពរមុន D នោះ C នឹងធ្វើលទ្ធកម្មសិទ្ធិលើបំណុល ចំណែកឯ D នឹងមិនអាចធ្វើលទ្ធកម្មសិទ្ធិលើបំណុលនោះបានឡើយ។ ប្រសិនបើដកឋានៈពី D ដែលជា អ្នកធ្វើលទ្ធកម្ម ដោយបានបំពេញលក្ខខណ្ឌតតាំងចំពោះតតិយជន C ម្តងរួចមកហើយនោះ D ហាក់ដូចជា ត្រូវបានទទួលការបំពានដោយមិនសមហេតុផល ហេតុនេះហើយ D ត្រូវបានការពារ ក្នុងនាម តតិយជន។ និយាយរួម ទោះបីជា A បានផ្តល់សច្ចានុមតិចំពោះអនុប្បទានសិទ្ធិ លើបំណុល ក៏ដោយ ក៏ C មិនអាចក្លាយជា អនុប្បទានិកនៃសិទ្ធិលើបំណុលនោះបានដែរ។

### ៤.៨.៤.សិទ្ធិដាស់តឿន និង សិទ្ធិលុបចោលរបស់ភាគីម្ខាងទៀត

បើម្ចាស់សិទ្ធិផ្តល់សច្ចានុមតិទៅលើអំពើដែលអ្នកតំណាងដោយគ្មានសិទ្ធិធ្វើក្នុងនាមជាអ្នកតំណាងឲ្យខ្លួននោះសកម្មភាពនោះនឹងមានអានុភាព។ ផ្ទុយទៅវិញ បើម្ចាស់សិទ្ធិមិនផ្តល់សច្ចានុមតិទេ នោះសកម្មភាពដែល អ្នកតំណាងដែលគ្មានសិទ្ធិធ្វើពុំមានអានុភាពចំពោះម្ចាស់សិទ្ធិទេ ហើយនេះជាស្ថានភាពដែលបង្កើតបញ្ហាចំពោះភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិ។ ឧទាហរណ៍៖ ចំពោះភាគីម្ខាងទៀតដែលបានបង្កើតកិច្ចសន្យាលក់ទិញជាមួយអ្នកតំណាងដោយគ្មានសិទ្ធិនោះ កិច្ចសន្យាពុំមានអានុភាពចំពោះម្ចាស់សិទ្ធិទេ។ ហេតុដូច្នេះ គាត់

ប្រាកដជាចង់ស្វែងរកអ្នកទិញផ្សេងទៀត ដើម្បីលក់ឲ្យបានឆាប់ ប៉ុន្តែម្ចាស់សិទ្ធិក៏ប្រហែលជាអាចផ្តល់សច្ចានុមតិផងដែរ ដូចនេះហើយគាត់មិនអាចលក់ទៅឲ្យអ្នកទិញ ផ្សេងទៀតបានទេ។ ហេតុនេះដើម្បីការពារភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិ ទើបមានបញ្ញត្តិអំពី សិទ្ធិដាស់តឿន និង សិទ្ធិលុបចោល។

**សិទ្ធិដាស់តឿន៖** ភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិ អាចកំណត់អំឡុងពេលសមរម្យដើម្បីឲ្យម្ចាស់សិទ្ធិឆ្លើយអំពីការផ្តល់ ឬ មិនផ្តល់សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិបាន។ ប្រសិនបើ ម្ចាស់សិទ្ធិមិនឆ្លើយបញ្ជាក់នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាម្ចាស់សិទ្ធិបដិសេធការផ្តល់សច្ចានុមតិ(មាត្រា ៣៧០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ប្រសិនបើម្ចាស់សិទ្ធិមិនឆ្លើយបញ្ជាក់ទេនោះ អំពើតំណាងដោយគ្មានសិទ្ធិនឹងពុំមានអានុភាពទេ ហើយក៏មិនអាចផ្តល់សច្ចានុមតិបានដែរ។

**សិទ្ធិលុបចោល៖** ភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិ អាចលុបចោលកិច្ចសន្យាដែលបុគ្គលគ្មានសិទ្ធិតំណាងបានបង្កើតមុនពេលម្ចាស់សិទ្ធិផ្តល់សច្ចានុមតិបាន។ ក្រោយពេលមានការលុបចោលដោយភាគីម្ខាងទៀត ម្ចាស់សិទ្ធិមិនអាចផ្តល់សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិបានទេ (មាត្រា ៣៧០ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ប្រសិនបើភាគីម្ខាងទៀតបានលុបចោលកិច្ចសន្យាហើយនោះ អំពើតំណាងដោយគ្មានសិទ្ធិនឹងពុំមានអានុភាពទេ ហើយក៏មិនអាចផ្តល់សច្ចានុមតិបានដែរ។

បន្ទាប់ពីភាគីម្ខាងទៀតបានអនុវត្តសិទ្ធិដាស់តឿនដោយកំណត់កាលបរិច្ឆេទរួចរាល់ហើយ តើភាគីម្ខាងទៀតអាចអនុវត្តសិទ្ធិលុបចោលកិច្ចសន្យាក្នុងអំឡុងពេលដាស់តឿនបានដែរ ឬ ទេ?




ឧទាហរណ៍៖ ភាគីម្ខាងទៀត C បានធ្វើការដាស់តឿនដោយកំណត់អំឡុងពេល ២ សប្តាហ៍ទៅ ម្ចាស់សិទ្ធិ A ប៉ុន្តែ ទើបតែបាន ១សប្តាហ៍ C បានជូនដំណឹងទៅ A អំពីការលុបចោលកិច្ចសន្យា។ យ៉ាងណាមិញ A មិនទាន់បានធ្វើសច្ចានុមតិនៅឡើយទេ។

ចំពោះបញ្ហានេះ គឺអាចមានមតិដែលថាអាចលុបចោលបាន និង អាចមានមតិដែលថាមិនអាចលុបចោលបាន។

ដំបូង គំនិតទី១ ដែលទទួលស្គាល់ការលុបចោល គឺផ្អែកតាមមូលហេតុ ជាលក្ខណៈទម្រង់ដែលត្រូវបានលើកឡើង ① ក្រមរដ្ឋប្បវេណី មាត្រា ៣៧០ កថាខណ្ឌទី៣ និង ទី៤ ដោយកថាខណ្ឌនេះ មិនបានកម្រិតអំពីការ

លុបចោលក្នុងអំឡុងពេលដាស់តឿននោះទេ។ ម្យ៉ាងទៀត ② ទាំងសិទ្ធិដាស់តឿន និង ទាំងសិទ្ធិលុបចោលកិច្ចសន្យា វាគឺជាមធ្យោបាយដើម្បីរំលាយទំនាក់ទំនង គតិយុត្តអចិរភាព ដែលបានកើតឡើង ដោយសារអំពើតំណាងដោយគ្មានសិទ្ធិ ហើយផ្អែកតាមអចិរភាពនៃទំនាក់ទំនងគតិយុត្តនោះ អ្នកដែលទទួលនូវការបាត់បង់ផលប្រយោជន៍ខ្លាំងនោះគឺភាគីម្ខាងទៀត C ហេតុនេះ ដើម្បីការពារផលប្រយោជន៍ C ទោះបីជា ក្នុងអំឡុងពេលដាស់តឿនក៏ដោយ ក៏ C អាចលុបចោលកិច្ចសន្យាបានដែរ ដែលនេះជាមូលហេតុជាក់លាក់មួយផងដែរ។

ផ្ទុយទៅវិញ គំនិតទី២ ដែលមិនទទួលស្គាល់ការលុបចោលគឺ ដោយសារសកម្មភាពរបស់ C ផ្ទុយទៅនឹងគោលការណ៍នៃភាពសុចរិត និងស្មោះត្រង់ (Estoppel ក្រមរដ្ឋប្បវេណីមាត្រា ៥) ពោលគឺ C បាន កំណត់ពេលឲ្យ A ផ្តល់ ឬមិនផ្តល់សច្ចានុមតិ ប៉ុន្តែ បែរជា C លុបចោលវិញ នេះគឺជា អាកប្បកិរិយាផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់។

**៤.៨.៥.ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ**

ជាគោលការណ៍ ភាគីម្ខាងទៀតនៃសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិ មិនអាចអះអាងថាអានុភាពនៃសកម្មភាពត្រូវមាន ចំពោះអ្នកតំណាងដោយគ្មានសិទ្ធិឡើយ ប៉ុន្តែ ប្រសិនបើអ្នកតំណាងដោយគ្មានសិទ្ធិមិនអាចបញ្ជាក់នូវសិទ្ធិតំណាង ឬ មិនអាចទទួលសច្ចានុមតិពីម្ចាស់សិទ្ធិបានទេ នោះអ្នកតំណាងដោយគ្មានសិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ឬ ទទួលខុសត្រូវក្នុងការសងការខូចខាត តាមការជ្រើសរើសរបស់ភាគីម្ខាងទៀត (មាត្រា ៣៧១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

ការទទួលខុសត្រូវក្នុងការអនុវត្ត និង ការទទួលខុសត្រូវក្នុងការសងការខូចខាត៖

ភាគីម្ខាងទៀតអាចទាមទារឲ្យអ្នកតំណាងដោយគ្មានសិទ្ធិ អនុវត្តកិច្ចសន្យា ឬ សងសំណងការខូចខាតបានក្នុងនាមជាការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ ។

ត្រង់ចំណុចនេះ នឹងធ្វើការពន្យល់ចំពោះទំនាក់ទំនងមាត្រា ៣៦៩ កថាខណ្ឌទី២ និង មាត្រា ៣៧១។ ដូចបានលើកឡើងពីមុន មាត្រា ៣៦៩ កថាខណ្ឌទី២ ទោះបីជាអ្នកតំណាងដោយគ្មានសិទ្ធិក៏ដោយ ក៏ អ្នកតំណាងនោះមិនមែនជាភាគីនៃកិច្ចសន្យាដែរ ហេតុនេះ ជាគោលការណ៍ កិច្ចសន្យានោះមិនមានអានុភាពចំពោះអ្នកតំណាងដោយគ្មានសិទ្ធិទេ។

ផ្ទុយទៅវិញ ប្រសិនបើភាគីម្ខាងទៀតមិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាងទេ នោះច្បាប់ក៏បានកំណត់អំពីការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ ផ្អែកតាមមាត្រា ៣៧១ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍: ក្នុងករណីនៃកិច្ចសន្យាលក់ទិញរថយន្តដែលមានភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិជាអ្នកលក់ អ្នកតំណាងដោយគ្មានសិទ្ធិមានកាតព្វកិច្ចត្រូវបង់ប្រាក់ចំពោះភាគីម្ខាងទៀតនោះ។ ក្នុងករណីនេះ អ្នកតំណាងដោយគ្មានសិទ្ធិអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះបាន។ ផ្ទុយទៅវិញ ក្នុងករណីកិច្ចសន្យាលក់ទិញរថយន្តដែលមានភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិជាអ្នកទិញវិញនោះ អ្នកតំណាង

ដោយគ្មានសិទ្ធិមិនមានកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនោះទេ ដូចនេះ អ្នកតំណាងដោយគ្មានសិទ្ធិត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះពីម្ចាស់សិទ្ធិហើយប្រគល់ឲ្យភាគីម្ខាងទៀត។ ប្រសិនបើអ្នកតំណាងមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិពីម្ចាស់សិទ្ធិបានទេ នោះភាគីម្ខាងទៀតអាចទាមទារសំណងការខូចខាតបាន។ អ្នកតំណាងដោយគ្មានសិទ្ធិអាចរួចផុតពីការទទួលខុសត្រូវបាននៅក្នុងករណីអាចបង្ហាញអំពីមូលហេតុណាមួយដូចខាងក្រោម៖

- ករណីភាគីម្ខាងទៀតបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង (មាត្រា៣៧១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)
- ករណីអ្នកតំណាងដោយគ្មានសិទ្ធិ គ្មានកំហុសនៅក្នុងការធ្វើអំពើតំណាងដោយគ្មានសិទ្ធិ ហើយទោះបីភាគីម្ខាងទៀតមិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង ដោយមានកំហុសក៏ដោយ (មាត្រា ៣៧១ វាក្យខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។
- ករណីម្ចាស់សិទ្ធិបានផ្តល់សច្ចានុមតិ (មាត្រា ៣៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ករណីដែលអ្នកតំណាងដោយគ្មានសិទ្ធិអាចបញ្ជាក់ថាខ្លួនបានទទួលសិទ្ធិតំណាងពីម្ចាស់សិទ្ធិ មាត្រា ៣៧១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

  <u>ខ្លឹមសារនៃមាត្រា ៣៧១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី គឺដូចក្នុងតារាងខាងក្រោម</u>៖

A : ម្ចាស់សិទ្ធិ B : អ្នកតំណាងដោយគ្មានសិទ្ធិ C : ភាគីម្ខាងទៀតនៃកិច្ចសន្យា

<table>
<tr><td colspan="2">C (ភាគីម្ខាងទៀត)</td><td colspan="2">B (អ្នកតំណាងដោយគ្មានសិទ្ធិ)</td><td>តើ B ត្រូវទទួលខុសត្រូវដែរ ឬ ទេ?</td></tr>
<tr><td colspan="2">C បានដឹងថា B ជាអ្នកតំណាងដោយគ្មានសិទ្ធិ</td><td colspan="2"></td><td>B មិនទទួលខុសត្រូវ (មាត្រា ៣៧១ វាក្យខណ្ឌទី២)</td></tr>
<tr><td rowspan="2">C មិនបានដឹងថា B ជាអ្នកតំណាងដោយគ្មានសិទ្ធិ</td><td rowspan="2">C មានកំហុសចំពោះការ ដែលមិនបានដឹងថា B ជាអ្នកតំណាងដោយគ្មានសិទ្ធិ</td><td rowspan="2">B មិនបានដឹងថា ខ្លួនជាអ្នកតំណាងដោយគ្មានសិទ្ធិ</td><td>B គ្មានកំហុសចំពោះការដែលមិនបានដឹងថាខ្លួនជាអ្នកតំណាងដោយគ្មានសិទ្ធិ</td><td>B មិនទទួលខុសត្រូវ (មាត្រា ៣៧១ វាក្យខណ្ឌទី២)</td></tr>
<tr><td>B មានកំហុសចំពោះការដែលមិនបានដឹងថាខ្លួនជាអ្នកតំណាងដោយគ្មានសិទ្ធិ</td><td>B ទទួលខុសត្រូវ</td></tr>
</table>

| | | | |
|---|---|---|---|
| | | B បានដឹងថាខ្លួនជាអ្នកតំណាងដោយគ្មានសិទ្ធិ | B ទទួលខុសត្រូវ |
| | C ពុំមានកំហុសចំពោះ ការ ដែលមិនបានដឹងថា B ជាអ្នកតំណាងដោយគ្មានសិទ្ធិ | | B ទទួលខុសត្រូវ |

**៤.៩.ការតំណាងដែលមានលក្ខណៈជារូបភាព**

ការតំណាងដែលមានលក្ខណៈជារូបភាព គឺជាប្រព័ន្ធមួយដែលការពារចំពោះភាគីម្ខាងទៀតដែលបានជឿថាអ្នកតំណាងដោយគ្មានសិទ្ធិមានសិទ្ធិតំណាង។ ក្នុងករណីនេះអានុភាពនៃការតំណាងដោយគ្មានសិទ្ធិមានចំពោះម្ចាស់សិទ្ធិ។

ការតំណាងដែលមានលក្ខណៈជារូបភាពនេះមាន៣ទម្រង់៖

① ករណីអ្នកតំណាងបានចុះកិច្ចសន្យាហួសទំហំនៃសិទ្ធិតំណាង (មាត្រា ៣៧២កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ គេហៅថាការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសទំហំនៃសិទ្ធិ។

② ករណីក្រោយពេលសិទ្ធិតំណាងរបស់អ្នកតំណាងបានរលត់ភាគីម្ខាងទៀតបានចុះកិច្ចសន្យាជាមួយបុគ្គលដែលនិយាយថាខ្លួនជាអ្នកតំណាង (មាត្រា៣៧២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ គេហៅថាការតំណាងដែលមានលក្ខណៈជារូបភាពក្រោយសិទ្ធិតំណាងបានរលត់។

③ ករណីម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងឲ្យអ្នកផ្សេង ប៉ុន្តែ ម្ចាស់សិទ្ធិបានបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាងនោះឲ្យទៅអ្នកផ្សេង ឬ អនុញ្ញាតឲ្យអ្នកផ្សេងនោះបង្ហាញថាអ្នកនោះមានសិទ្ធិតំណាងហើយភាគីម្ខាងទៀតបានចុះកិច្ចសន្យាជាមួយអ្នកផ្សេងនោះ(មាត្រា ៣៧២ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ គេហៅថាការតំណាងដែលមានលក្ខណៈជារូបភាពតាមរយៈការបង្ហាញថាបានប្រគល់សិទ្ធិ។

នៅក្នុងទម្រង់ទាំង៣ខាងលើនេះសុទ្ធតែមានភ្ជាប់នូវលក្ខខណ្ឌ២គឺ៖

១.ម្ចាស់សិទ្ធិជាប់ពាក់ព័ន្ធនឹងការបង្កើតរូបភាពខាងក្រៅ ដែលមើលទៅហាក់ដូចជាអ្នកតំណាងដោយគ្មានសិទ្ធិមានសិទ្ធិតំណាង។

២.ភាគីម្ខាងទៀតជឿថាអ្នកតំណាងដោយគ្មានសិទ្ធិមានសិទ្ធិតំណាង។

ការតំណាងដែលមានលក្ខណៈជារូបភាពទាំង ៣ ទម្រង់ មានអានុភាពដូចគ្នានឹងករណីការកកើតនូវសិទ្ធិតំណាង គឺម្ចាស់សិទ្ធិទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យាចំពោះភាគីម្ខាងទៀត។

### ៤.៩.១.លក្ខខណ្ឌនៃការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសទំហំនៃសិទ្ធិ

១. អ្នកតំណាងបានទទួលសិទ្ធិតំណាងពីម្ចាស់សិទ្ធិ

២. អ្នកតំណាងបានធ្វើសកម្មភាពហួសពីទំហំនៃសិទ្ធិតំណាង

៣. ភាគីម្ខាងទៀតជឿជាក់ថា B មានសិទ្ធិតំណាងដោយគ្មានកំហុស

ឧទាហរណ៍៖ A មានរថយន្តមួយគ្រឿង ហើយ A បានប្រគល់សិទ្ធិតំណាងជួលរថយន្តឲ្យទៅ B តាមរយៈលិខិតមួយដោយមិនបានសរសេរពីខ្លឹមសារនៃសិទ្ធិតំណាងទេ គឺមានត្រឹមតែហត្ថលេខារបស់ A ប៉ុណ្ណោះ។ ក្រោយមក B បានលក់រថយន្តនោះឲ្យទៅ C ដោយ B បានសរសេរបន្ថែម ពីសិទ្ធិតំណាងឲ្យលក់រថយន្ត នៅលើលិខិតនោះ។ C ឃើញលិខិតនោះក៏ជឿជាក់ ថា B ពិតជាអ្នកតំណាងរបស់ A ហេតុនេះ C ក៏សម្រេចចិត្តទិញរថយន្តនោះពី B ។ ក្នុងករណីនេះ A ត្រូវប្រគល់រថយន្ត ព្រមទាំងលិខិតផ្សេងៗទៀត ឲ្យទៅ C ។

សកម្មភាពរបស់ B គឺធ្វើហួសពីទំហំនៃសិទ្ធិតំណាង ព្រោះ A បានប្រគល់សិទ្ធិតំណាងឲ្យ B ត្រឹមតែជួលរថយន្តប៉ុណ្ណោះ។ ប៉ុន្តែ ភាគីម្ខាងទៀត បានឃើញលិខិតដែល B បានបង្ហាញក៏ជឿជាក់ដោយគ្មានកំហុស ថា B ពិតជាមានសិទ្ធិតំណាងក្នុងការលក់រថយន្តនោះមែន ហេតុនេះ អានុភាពនៃកិច្ចសន្យាមានចំពោះ A ។

### ៤.៩.២.លក្ខខណ្ឌនៃការតំណាងដែលមានលក្ខណៈជារូបភាពក្រោយសិទ្ធិតំណាងបានរលត់

១.នៅក្រោយពេលសិទ្ធិតំណាងបានរលត់ ភាគីម្ខាងទៀតបានបង្កើតកិច្ចសន្យាជាមួយបុគ្គលដែលសិទ្ធិតំណាងបានរលត់ហើយ។

២.ភាគីម្ខាងទៀតមិនបានដឹងថាសិទ្ធិតំណាងបានរលត់ទេ ហើយមិនមានកំហុសក្នុងការមិនបានដឹង (ការតវ៉ារបស់ចុងចម្លើយ)។

ឧទាហរណ៍៖ A បានទិញរថយន្តថ្មី ហើយបានប្រគល់សិទ្ធិតំណាងឲ្យ B ដើម្បីលក់រថយន្តចាស់របស់ខ្លួននៅក្នុងលិខិតអាណត្តិ។ ប៉ុន្តែ រថយន្តថ្មីរបស់គាត់ស្រាប់តែខូច គាត់បានប្រាប់ទៅ B ឲ្យបញ្ឈប់ការលក់រថយន្តចាស់របស់គាត់។ ប៉ុន្តែ B មិនបានប្រគល់លិខិតអាណត្តិឲ្យទៅ A វិញទេ បែរជា បានប្រើប្រាស់លិខិតអាណត្តិនោះលក់រថយន្តចាស់នោះឲ្យទៅ X ។ ការបង្កើតកិច្ចសន្យាលក់ទិញរវាង B និង X បានធ្វើឡើងនៅក្រោយពេលដែលសិទ្ធិតំណាងរបស់ B បានរលត់ ដូចនេះ អំពើរបស់ B គឺជា ការតំណាងដោយគ្មានសិទ្ធិ។ ប្រសិនបើ X មិនបានដឹងអំពីការរលត់សិទ្ធិតំណាងរបស់ B ហើយគ្មានកំហុស ក្នុងការមិនបានដឹងទេនោះ ការតំណាងដែលមានលក្ខណៈជារូបភាព ក្រោយពេលសិទ្ធិតំណាងបានរលត់នឹងកើតមានឡើង ហើយអានុភាពនៃកិច្ចសន្យានោះ ត្រូវមានចំពោះ A ហើយ A មានកាតព្វកិច្ចត្រូវប្រគល់រថយន្តចាស់នោះឲ្យទៅ X ។

**៤.៩.៣.លក្ខខណ្ឌនៃការតំណាងដែលមានលក្ខណៈជារូបភាពតាមរយៈការបង្ហាញថាបានប្រគល់សិទ្ធិតំណាង**

១. ម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាង។

២. ម្ចាស់សិទ្ធិបានបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាងនោះ ឬ អនុញ្ញាតឲ្យអ្នកផ្សេងនោះបង្ហាញថាអ្នកនោះមានសិទ្ធិតំណាង។

៣. ភាគីម្ខាងទៀតមិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង ហើយគ្មានកំហុសក្នុងការមិនបានដឹង (ការតវ៉ារបស់ចុងចម្លើយ)។

ឧទាហរណ៍(**ករណីបានបង្ហាញដូចជាបានប្រគល់សិទ្ធិតំណាង**) ៖ A មានដីនៅខេត្តបាត់ដំបង ប៉ុន្តែគាត់ត្រូវបានចាត់តាំងឲ្យទៅក្រៅប្រទេសរយៈពេលវែង។ មិត្តភក្តិរបស់គាត់កំពុងស្នាក់នៅលើដីនោះ ដូចនេះ គាត់មិនចង់លក់ដីនោះទេ ប៉ុន្តែ គាត់គិតថាប្រសិនបើថ្ងៃក្រោយមិត្តភក្តិរើចេញគាត់នឹងលក់។ A បានប្រគល់លិខិតអាណត្តិឲ្យក្រុមហ៊ុនអចលនទ្រព្យ B ដើម្បីឲ្យលក់ដីហើយបាននិយាយថា "ឥឡូវមិនទាន់ចង់លក់ទេ ប៉ុន្តែប្រសិនបើថ្ងៃក្រោយត្រូវលក់ខ្ញុំនឹងពឹងពាក់ឲ្យធ្វើជាអ្នកតំណាងឲ្យខ្ញុំក្នុងការបង្កើតកិច្ចសន្យា ដូចនេះ ខ្ញុំប្រគល់លិខិតអាណត្តិឲ្យជាមុនសម្រាប់ពេលដែលត្រូវលក់នោះមកដល់ នៅពេលដែលខ្ញុំសម្រេចចិត្តលក់ខ្ញុំនឹងទាក់ទងមក" ។ ប៉ុន្តែ នៅមុនពេលដែល A ទាក់ទងមក B បានប្រើប្រាស់លិខិតអាណត្តិនោះលក់ដីនៅបាត់ដំបងឲ្យទៅ Y ។ B មិនត្រូវបានប្រគល់សិទ្ធិតំណាងឲ្យទេ ហេតុនេះកិច្ចសន្យាដែល B បានបង្កើតជាមួយ Y គឺជាអំពើ តំណាងដោយគ្មានសិទ្ធិ។ ប្រសិនបើ Y មិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាងហើយមិនមានកំហុសក្នុងការ មិនបានដឹងទេ នោះការតំណាងដែលមានលក្ខណៈជារូបភាពតាមរយៈការបង្ហាញថាបានប្រគល់សិទ្ធិនឹងកើត មានឡើង ហើយអានុភាពនៃកិច្ចសន្យានឹងកើតមានចំពោះ A ហើយ A មានកាតព្វកិច្ចប្រគល់ដីនោះឲ្យទៅ Y ។

ឧទាហរណ៍(**ករណីម្ចាស់សិទ្ធិបានអនុញ្ញាតឲ្យអ្នកផ្សេងបង្ហាញថាអ្នកនោះមានសិទ្ធិតំណាង**) ៖ A បានធ្វើជំនួញលក់គ្រឿងស្មូនដែលមានគុណភាពល្អដោយដាក់ឈ្មោះម៉ាកថា "សេរ៉ាមិចA" ហើយក៏ល្បីឈ្មោះសុះសាយ។ B ជាបងប្រុសរបស់ A ហើយធ្វើការក្នុងនាមជាលេខារបស់ A ។ A មិនធ្លាប់បានផ្តល់សិទ្ធិតំណាងឲ្យទៅ B ទេ ប៉ុន្តែ B បានប្រើប្រាស់នាមប័ណ្ណដែលមានសរសេរថា "អ្នកតំណាងរបស់សេរ៉ាមិច A" ហើយ A ក៏បានដឹង និងបាន ទទួលស្គាល់ផងដែរ។ B បានបង្កើតកិច្ចសន្យាជាមួយអតិថិជន X របស់សេរ៉ាមិច A ក្នុងនាមជាអ្នកតំណាងរបស់ A ក្នុងការលក់គ្រឿងស្មូនដែលមានគុណភាពល្អ និង តម្លៃខ្ពស់របស់ A ។ ប្រសិនបើ X មិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង ហើយគ្មានកំហុសក្នុងការមិនបានដឹងទេនោះ ការតំណាងដែលមានលក្ខណៈជារូបភាពតាម រយៈការបង្ហាញថាបានប្រគល់សិទ្ធិតំណាងនឹងកើតមានឡើង ហើយអានុភាពនៃកិច្ចសន្យាលក់ទិញនេះ

នឹង មានអានុភាពចំពោះ A ហើយ A មានកាតព្វកិច្ចត្រូវប្រគល់គ្រឿងស្នូនដែលមានគុណភាពល្អ និងតម្លៃខ្ពស់នោះ ឲ្យទៅ X ។

### ៤.១០.វិការៈនៃអំពើតំណាង

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ (មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី)។ ចុះប្រសិនបើអ្នកតំណាងបានបង្កើតកិច្ចសន្យាដើម្បីម្ចាស់សិទ្ធិ តើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃវិការៈក្នុងការបង្ហាញឆន្ទៈគួរធ្វើចំពោះម្ចាស់សិទ្ធិ ឬអ្នកតំណាង?

ក្នុងករណីដែលអានុភាពនៃកិច្ចសន្យាដែលអ្នកបង្ហាញឆន្ទៈបង្កើតត្រូវទទួលនូវឥទ្ធិពលដោយសារមានការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ឬ ដោយសារមានកំហុសក្នុងការដឹង ឬ មិនដឹងហេតុណាមួយ អត្ថិភាព ឬ នត្ថិភាពនៃហេតុនោះ ត្រូវវិនិច្ឆ័យចំពោះអ្នកតំណាង ព្រោះអ្នកតំណាងជាអ្នកបង្ហាញឆន្ទៈ (មាត្រា ៣៧៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ A ប្រគល់សិទ្ធិតំណាងឲ្យ B ទៅទិញឡាន ក្នុងករណីភាគីម្ខាងទៀតដែលជាអ្នកលក់ C បានឆបោកអ្នកតំណាង B ឲ្យទិញឡានរបស់ខ្លួន ដូច្នេះ ការវិនិច្ឆ័យចំពោះការឆបោកត្រូវវិនិច្ឆ័យចំពោះ B ដែលជាអ្នកបានបង្ហាញឆន្ទៈ។ ដោយសារកិច្ចសន្យាមានអានុភាពចំពោះម្ចាស់សិទ្ធិ ដូច្នេះ ម្ចាស់សិទ្ធិអាច លុបចោលកិច្ចសន្យាបាន (មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី)។

A : ម្ចាស់សិទ្ធិ
B : អ្នកតំណាង
C : ភាគីម្ខាងទៀតនៃកិច្ចសន្យា




① A បានប្រគល់សិទ្ធិតំណាងឲ្យទៅ B

② C បានឆបោក B

③ B បានបង្កើតកិច្ចសន្យាដោយផ្អែកលើការឆបោកជាមួយ C

④ A អាចលុបចោលកិច្ចសន្យាជាមួយ C បាន

ប៉ុន្តែ បើម្ចាស់សិទ្ធិបានប្រគល់សិទ្ធិឲ្យអ្នកតំណាងធ្វើកិច្ចសន្យាដែលត្រូវបានកំណត់ពិសេស ម្ចាស់សិទ្ធិមិនអាចអះអាងថាអ្នកតំណាងមិនបានដឹងនូវហេតុណាដែលម្ចាស់សិទ្ធិបានដឹងនោះបានឡើយ។ ករណីនេះត្រូវបានយកមកអនុវត្តផងដែរចំពោះហេតុដែលម្ចាស់សិទ្ធិមិនបានដឹងដោយមានកំហុស (មាត្រា ៣៧៤ កថាខណ្ឌ ទី២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ ម្ចាស់សិទ្ធិដឹងថាភាគីម្ខាងទៀតគឺជាចោរដែលបានលួចជាវបុរាណមួយពីអ្នកដទៃ ប៉ុន្តែម្ចាស់សិទ្ធិបានឲ្យអ្នកតំណាងដែលមិនបានដឹងអំពីរឿងនេះទៅទិញជាវនោះ។ ទោះបីជាអ្នកតំណាងសុចរិត និងគ្មានកំហុសក៏ដោយ ក៏ម្ចាស់សិទ្ធិទុច្ចរិតនោះមិនអាចធ្វើលទ្ធកម្មដោយសុចរិតលើជាវនោះបានដែរ។

## ៤.១១.សមត្ថភាពនៃអ្នកតំណាង

ម្ចាស់សិទ្ធិអាចប្រគល់សិទ្ធិតំណាងដល់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបាន។ ក្នុងករណីនេះ ម្ចាស់សិទ្ធិមិនអាចលុបចោលកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពជាមួយនឹងភាគីម្ខាងទៀតបានទេ ដោយយកមូលហេតុនៃការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាងនោះបានឡើយ(មាត្រា៣៧៥ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ ម្ចាស់សិទ្ធិបានជ្រើសតាំងអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមរបបហិតូបត្ថម្ភឲ្យធ្វើជាអ្នកតំណាង ហើយអំពើតំណាងដែលបានធ្វើឡើងដើម្បីម្ចាស់សិទ្ធិដោយអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមរបបហិតូបត្ថម្ភមិនអាចលុបចោលបានឡើយ ព្រោះការលុបចោលដោយផ្អែកលើការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺជាប្រព័ន្ធមួយក្នុងការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។ ដោយឡែក អានុភាពនៃអំពើតំណាងគឺមានទៅលើម្ចាស់សិទ្ធិ ដូចនេះ អ្នកតំណាងដែលជាជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពនោះ មិនទទួលរងការខូចខាតផលប្រយោជន៍ឡើយ។

ប៉ុន្តែ ក្រោយពេលម្ចាស់សិទ្ធិបានជ្រើសតាំងជនដែលមានសមត្ថភាពឲ្យធ្វើជាអ្នកតំណាងទើបមានការប្រកាសអំពីរបបអាណាព្យាបាលទូទៅ ឬ របបហិតូបត្ថម្ភចំពោះអ្នកតំណាងនោះ សិទ្ធិតំណាងនឹងត្រូវរលត់ (មាត្រា ៣៦៨ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍១៖

១. A បានទុកចិត្តឲ្យ B (អនីតិជន) ទិញស្រូវឲ្យខ្លួន ហេតុនេះ A បានប្រគល់សិទ្ធិតំណាងឲ្យ B។

២. B បានទិញស្រូវពី C ក្នុងនាមជាអ្នកតំណាងរបស់ A

→ ទោះបី B ជាអនីតិជនក៏ដោយ ក៏កិច្ចសន្យានេះមានសុពលភាពដែរ ដូច្នេះ កិច្ចសន្យានេះមិនអាចលុបចោលបានទេ(មាត្រា ៣៧៥ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍២៖

១. A បានទុកចិត្តឲ្យ B (នីតិជន)ទិញស្រូវឲ្យខ្លួន ហេតុនេះ A បានប្រគល់សិទ្ធិតំណាងឲ្យ B។

២. B ត្រូវបានទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ (មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី)

៣. ក្នុងករណី B នៅតែទៅទិញស្រូវពី C ក្នុងនាមជាអ្នកតំណាងរបស់ A តើសិទ្ធិតំណាងនោះមានអានុភាពដែរ ឬទេ?

→ សិទ្ធិតំណាងត្រូវបានរលត់តាមមាត្រា ៣៦៨ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ហេតុនេះកិច្ចសន្យាទិញស្រូវ ក្លាយទៅជាកិច្ចសន្យាដែលធ្វើឡើងដោយអ្នកតំណាងដោយគ្មានសិទ្ធិ (មាត្រា ៣៦៩ នៃក្រមរដ្ឋប្បវេណី) ឬ កើតមានឡើងនូវការតំណាងដែលមានលក្ខណៈជារូបភាព(មាត្រា ៣៧២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ។

ឧទាហរណ៍៣៖

១. A បានទុកចិត្តឲ្យ B (នីតិជន)ទិញស្រូវឲ្យខ្លួន ហេតុនេះ A បានផ្ដល់សិទ្ធិតំណាងឲ្យ B។

២. A ត្រូវបានទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ (មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី)

៣. ក្នុងករណី B នៅតែទៅទិញស្រូវពី C ក្នុងនាមជាអ្នកតំណាងរបស់ A តើសិទ្ធិតំណាង នោះ មានអានុភាពដែរឬទេ?

→ អាណត្តិត្រូវបានបញ្ចប់តាម មាត្រា ៦៤៩ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណី នោះនាំឲ្យសិទ្ធិតំណាងត្រូវបានរលត់តាម មាត្រា ៣៦៨ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណី ហេតុនេះកិច្ចសន្យាទិញស្រូវក្លាយទៅជាកិច្ចសន្យាដែលធ្វើឡើងដោយអ្នកតំណាងដោយគ្មានសិទ្ធិ (មាត្រា ៣៦៩ នៃក្រមរដ្ឋប្បវេណី) ឬ កើតមានឡើងនូវការតំណាងដែលមានលក្ខណៈជារូបភាព(មាត្រា ៣៧២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ។

### ៤.១២.អនុតំណាង

ជាគោលការណ៍ អ្នកតំណាងដែលមានកិច្ចសន្យាជាមួយម្ចាស់សិទ្ធិមិនអាចជ្រើសរើសអនុតំណាង បានទេ ប៉ុន្តែ បើមានការយល់ព្រមពីម្ចាស់សិទ្ធិ ឬ មានហេតុដែលមិនអាចជៀសវាងបាន អ្នកតំណាងអាច ជ្រើសរើសអនុតំណាងបាន (មាត្រា ៣៧៦ នៃក្រមរដ្ឋប្បវេណី)។

អ្នកតំណាងដែលកំណត់ដោយច្បាប់អាចជ្រើសតាំងអនុតំណាងបាន ឬអត់គឺអាស្រ័យទៅតាមការបកស្រាយនៃសិទ្ធិតំណាងដែលកំណត់ដោយច្បាប់នីមួយៗ។

A : ម្ចាស់សិទ្ធិ

B : អ្នកតំណាងដោយឆន្ទៈ

C : អនុតំណាង

D : ភាគីម្ខាងទៀតនៃកិច្ចសន្យា




① A ប្រគល់សិទ្ធិតំណាងទៅឲ្យ B

② B ជ្រើសតាំង C ជាអនុតំណាង

③ C បង្កើតកិច្ចសន្យាជាមួយ D ក្នុងនាមជាអនុតំណាងរបស់ A

④ អានុភាពនៃកិច្ចសន្យាកើតមានចំពោះ A

**៤.១២.១.លក្ខខណ្ឌ**

- ការយល់ព្រមពីម្ចាស់សិទ្ធិ( ជាគោលការណ៍ )

ឧទាហរណ៍៖ A ជាម្ចាស់សិទ្ធិបានពឹងពាក់ B ជាអ្នកតំណាងខ្លួនដើម្បីចុះកិច្ចសន្យាជាមួយ D ប៉ុន្តែដោយសារ B មានធុរៈមិនអាចបំពេញកាតព្វកិច្ចនេះបាន ដូចនេះ B ក៏បានសុំការយល់ព្រមពី A ដើម្បីឲ្យ C ជាអនុតំណាងទៅចុះកិច្ចសន្យាជាមួយ D។

- ឬ មានហេតុដែលជៀសវាងមិនបាន( ករណីលើកលែង )

ដើម្បីទទួលស្គាល់នូវហេតុដែលជៀសវាងមិនបាន គឺ ① ប្រសិនបើមិនមានអនុតំណាង ម្ចាស់សិទ្ធិនឹងបាត់បង់ផលប្រយោជន៍ ហើយ ② មិនអាចទាក់ទងទៅម្ចាស់សិទ្ធិដើម្បីទទួលការយល់ព្រមបាន។

ហេតុដែលជៀសវាងមិនបាន៖ នៅពេលដែលរៀបនឹងបង្កើតកិច្ចសន្យាជាមួយភាគីម្ខាងទៀត អ្នកតំណាងក៏មានជម្ងឺមិនអាចបង្កើតកិច្ចសន្យាបាន។ គាត់មានការបារម្ភថា បើចុះកិច្ចសន្យាយឺតពេល ភាគីម្ខាងទៀតនឹងចុះកិច្ចសន្យាជាមួយអ្នកដទៃ។ ហេតុនេះ ដើម្បីទទួលបានការយល់ព្រម ក្នុងការជ្រើសតាំង អនុតំណាង អ្នកតំណាងគិតថានឹងទាក់ទងទៅម្ចាស់សិទ្ធិ។ ប៉ុន្តែ មិនអាចទាក់ទងជាមួយម្ចាស់សិទ្ធិបាន។ ករណីនេះ គឺជាហេតុដែលជៀសវាងមិនបាន។ អ្នកតំណាងអាចជ្រើសតាំងអនុតំណាងបាន ទោះបីជាគ្មានការយល់ព្រមពីម្ចាស់សិទ្ធិក៏ដោយ។

**៤.១២.២.ការទទួលខុសត្រូវរបស់អ្នកតំណាងក្នុងករណីដែលបានជ្រើសតាំងអនុតំណាង**

ក្នុងករណីដែលមានការខូចខាតទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិដោយសារអំពើរបស់អនុតំណាងដែលត្រូវបានជ្រើសតាំងដោយអ្នកតំណាង នោះអ្នកតំណាងត្រូវទទួលខុសត្រូវ។ ទំហំនៃការទទួលខុសត្រូវរបស់អ្នកតំណាង គឺអាស្រ័យទៅតាមស្ថានភាពដែលអ្នកតំណាងជ្រើសតាំងអនុតំណាងនោះ។

- **ប្រសិនបើអ្នកតំណាងបានជ្រើសតាំងអនុតំណាង ក្នុងករណីដែលមានការយល់ព្រមពីម្ចាស់សិទ្ធិ ឬ មានមូលហេតុដែលជៀសវាងមិនបាន៖**

អ្នកតំណាងត្រូវទទួលខុសត្រូវចំពោះម្ចាស់សិទ្ធិក្នុងការជ្រើសតាំងនិងត្រួតពិនិត្យអនុតំណាង (មាត្រា ៣៧៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើមានការខូចខាតកើតឡើងចំពោះម្ចាស់សិទ្ធិដោយសារ អ្នកតំណាងបានជ្រើសតាំងអនុតំណាងដែលមិនសមស្រប នោះអ្នកតំណាងត្រូវទទួលខុសត្រូវសងការខូចខាតចំពោះម្ចាស់សិទ្ធិ។ ម្យ៉ាងទៀត ទោះបីជា អ្នកតំណាងបានជ្រើសតាំងអនុតំណាង ដែលសមស្របក៏ដោយ ប្រសិនបើមានការខូចខាតកើតឡើងចំពោះម្ចាស់សិទ្ធិដោយសារ អ្នកតំណាងមិនបានត្រួតពិនិត្យអនុតំណាងឲ្យបានត្រឹមត្រូវ (ករណីមិនបានចង្អុលបង្ហាញអំពីវិធីចាំបាច់នៃការធ្វើសកម្មភាពតំណាង ឬ ករណីអ្នកតំណាងមិនបានប្រាប់ទៅអនុតំណាងឲ្យបានត្រឹមត្រូវនូវការណែនាំរបស់ម្ចាស់សិទ្ធិ) នោះអ្នកតំណាងត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតចំពោះម្ចាស់សិទ្ធិ។

ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកតំណាងធ្វើការជ្រើសតាំងអនុតំណាងដែលសមស្រប ហើយបានធ្វើការត្រួតពិនិត្យបានត្រឹមត្រូវ ប៉ុន្តែ មានការខូចខាតកើតឡើងចំពោះម្ចាស់សិទ្ធិ ដោយសារតែចេតនា ឬកំហុសរបស់អនុតំណាង នោះអ្នកតំណាងមិនទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតទេ គឺមានតែអនុតំណាងប៉ុណ្ណោះដែលត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត។

- **ក្នុងករណីដែលអ្នកតំណាងបានជ្រើសតាំងអនុតំណាងតាមការកំណត់របស់ម្ចាស់សិទ្ធិ៖**

ប្រសិនបើក្នុងករណី អ្នកតំណាងបានជ្រើសតាំងអនុតំណាង តាមការកំណត់របស់ម្ចាស់សិទ្ធិ អ្នកតំណាងមិនត្រូវទទួលខុសត្រូវនូវអំពើរបស់អនុតំណាងនោះទេ លើកលែងតែក្នុងករណីដែលអ្នកតំណាងបានដឹងអំពីភាពមិនសមស្រប ឬ ភាពមិនស្មោះត្រង់របស់អនុតំណាងតែមិនបានជូនដំណឹងអំពី ការណ៍នោះទៅម្ចាស់សិទ្ធិ ឬមិនបានដកអនុតំណាងនោះចេញ នោះអ្នកតំណាងត្រូវទទួលខុសត្រូវ (មាត្រា ៣៧៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

- **ក្នុងករណីដែលអ្នកតំណាងបានជ្រើសតាំងអនុតំណាង ដោយមិនមានការយល់ព្រមពីម្ចាស់សិទ្ធិ ឬ មិនមានមូលហេតុដែលមិនអាចជៀសវាងបាន៖**

ក្នុងករណីអ្នកតំណាងមិនបានបំពេញលក្ខខណ្ឌដើម្បីជ្រើសតាំងអនុតំណាង អំពើរបស់អនុតំណាងមិនមានអានុភាពចំពោះម្ចាស់សិទ្ធិទេ (មាត្រា ៣៧៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ ទោះបីអនុតំណាងបានបង្កើតកិច្ចសន្យាក៏ដោយ ក៏អានុភាពនៃកិច្ចសន្យា មិនកើតមានឡើងចំពោះម្ចាស់សិទ្ធិដែរ។ ប៉ុន្តែមានការចាំបាច់ក្នុងការការពារភាគីម្ខាងទៀតដែលបានជឿជាក់ថា អនុតំណាងមានសិទ្ធិតំណាង។ ហេតុនេះ ប្រសិនបើ ភាគីម្ខាងទៀត បានបំពេញលក្ខខណ្ឌតាមមាត្រា៣៧១ នៃក្រមរដ្ឋប្បវេណី(*សូមមើលតារាងនៅក្នុង*

*ចំណុច ៤.៨.៥.ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ*) នោះ ភាគីម្ខាងទៀតអាចទាមទារឲ្យ **អនុតំណាង** អនុវត្តកិច្ចសន្យា ឬ សងសំណងការខូចខាតបាន។ ម្យ៉ាងទៀត ភាគីម្ខាងទៀតក៏អាចទាមទារឲ្យម្ចាស់សិទ្ធិ អនុវត្តដោយផ្អែក លើការតំណាង ដែលមានលក្ខណៈជារូបភាពបាន ប្រសិនបើបានបំពេញលក្ខខណ្ឌតាមមាត្រា ៣៧២ នៃក្រមរដ្ឋប្បវេណី ។ លើសពីនេះ ក្នុងករណីដែលភាគីម្ខាង ទៀតមិនបានដឹងថាអនុតំណាងនោះគ្មានសិទ្ធិតំណាងទេ ហើយគ្មានកំហុសក្នុងការមិនបានដឹងនោះ ភាគីម្ខាងទៀតអាចទាមទារឲ្យ **អ្នកតំណាង** អនុវត្តតាមកិច្ចសន្យា ឬអាចទាមទារសំណងនៃការខូចខាតបានតាម មាត្រា៣៧៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

A : ម្ចាស់សិទ្ធិ

B : អ្នកតំណាងដោយឆន្ទៈ

C : អនុតំណាង

D : ភាគីម្ខាងទៀតនៃកិច្ចសន្យា




① A ប្រគល់សិទ្ធិតំណាងទៅឲ្យ B

② B ជ្រើសរើស C ធ្វើជាអនុតំណាង ដោយគ្មានការយល់ព្រមពី A និង គ្មានហេតុដែលជៀសវាងមិនបាន

③ C មិនមែនជាអនុតំណាងរបស់ A ទេ

④ C បង្កើតកិច្ចសន្យាជាមួយ D ក្នុងនាមជាអនុតំណាងរបស់ A

⑤ អានុភាពនៃកិច្ចសន្យាមិនកើតមានឡើងចំពោះ A ទេ

＊ការការពារ D

- D អាចទាមទារឲ្យ A អនុវត្ត ប្រសិនបើបានបំពេញលក្ខខណ្ឌតាមមាត្រា ៣៧២ នៃក្រមរដ្ឋប្បវេណី ឬ
- D អាចទាមទារឲ្យ B អនុវត្ត ឬ សងសំណងការខូចខាត ប្រសិនបើបានបំពេញលក្ខខណ្ឌតាមមាត្រា ៣៧៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឬ

- D អាចទាមទារឲ្យ C អនុវត្ត ឬ សងសំណងការខូចខាតតាមមាត្រា ៣៧១ នៃក្រមរដ្ឋប្បវេណី
＊ការការពារ A : ក្នុងករណីដែល D ទាមទារឲ្យ A អនុវត្តដោយផ្អែកលើមាត្រា ៣៧២ នៃក្រមរដ្ឋប្បវេណី ហើយ A បានអនុវត្តតាមការទាមទាររបស់ D ។ A អាចទាមទារសំណងការខូចខាតពី B ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច (មាត្រា៣៩៨ នៃក្រមរដ្ឋប្បវេណី)ឬពី C តាម អំពើអនីត្យានុកូល (មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី)។

**៤.១២.៣.ឋានៈនៃអនុតំណាង**

អំពើដែលអនុតំណាងបានធ្វើក្នុងទំហំនៃសិទ្ធិរបស់ខ្លួនដោយបញ្ជាក់ថាធ្វើដើម្បីម្ចាស់សិទ្ធិត្រូវជាចំណងចងម្ចាស់សិទ្ធិ(មាត្រា ៣៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ អនុតំណាងត្រូវមានសិទ្ធិ និងករណីយកិច្ចចំពោះម្ចាស់សិទ្ធិ ដូចគ្នានឹងអ្នកតំណាងដែរ(មាត្រា៣៧៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ និយាយរួមអានុភាពនៃកិច្ចសន្យាដែលអនុតំណាងបានបង្កើតមានអានុភាពចំពោះម្ចាស់សិទ្ធិដូចករណីអ្នកតំណាងបង្កើតកិច្ចសន្យាដែរ។

ឧទាហរណ៍៖ នៅពេលម្ចាស់សិទ្ធិប្រគល់សិទ្ធិតំណាងឲ្យអ្នកតំណាង ម្ចាស់សិទ្ធិ និងអ្នកតំណាងបានចុះកិច្ចសន្យាអាណត្តិជាមួយគ្នា។ អ្នកតំណាងមានករណីយកិច្ចចំពោះម្ចាស់សិទ្ធិ ក្នុងការគ្រប់គ្រងឲ្យបានល្អ និងប្រុងប្រយ័ត្ន (មាត្រា ៦៤០ នៃក្រមរដ្ឋប្បវេណី) និង ករណីយកិច្ចប្រគល់(មាត្រា ៦៤២ នៃក្រមរដ្ឋប្បវេណី) ដោយផ្អែកតាមកិច្ចសន្យាអាណត្តិព្រមទាំងមានសិទ្ធិទាមទារឲ្យសងមកវិញនូវសោហ៊ុយ (មាត្រា ៦៤៦ នៃក្រមរដ្ឋប្បវេណី)ជាអាទិ៍។ អនុតំណាងក៏មានសិទ្ធិ និង ករណីយកិច្ច ដូចអ្នកតំណាងមានចំពោះម្ចាស់សិទ្ធិ ផងដែរ។

ទំនាក់ទំនងរវាងអនុតំណាង និង ម្ចាស់សិទ្ធិត្រូវអនុវត្តដូចគ្នាទៅនឹងបញ្ញត្តិស្តីពីអ្នកតំណាងដែរ ដោយចាត់ទុកអនុតំណាងជាអ្នកតំណាង(មាត្រា ៣៧៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ប្រសិនបើប្រយោជន៍របស់ម្ចាស់សិទ្ធិ និង ប្រយោជន៍របស់អនុតំណាងផ្ទុយគ្នា នោះអនុតំណាងគ្មានសិទ្ធិតំណាងទេ (មាត្រា៣៦៧ នៃក្រមរដ្ឋប្បវេណី) ហើយប្រសិនបើអនុតំណាងទទួលមរណភាព ធនក្ស័យ ឬ ត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព នោះសិទ្ធិតំណាងរបស់អនុតំណាងនឹងត្រូវរលត់ (មាត្រា ៣៦៨ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលអនុតំណាងបានធ្វើអំពើតំណាងដោយគ្មានសិទ្ធិ នោះអនុតំណាងត្រូវទទួលខុសត្រូវតាមមាត្រា ៣៧១ នៃក្រមរដ្ឋប្បវេណី ។

ចំណុចដែលម្ចាស់សិទ្ធិត្រូវប្រុងប្រយ័ត្ន៖

- ជ្រើសរើសអ្នកដែលអាចទុកចិត្តបានឲ្យធ្វើជាអ្នកតំណាង
- នៅពេលប្រគល់លិខិតតំណាងត្រូវកំណត់រយៈពេលនៃការតំណាងនោះទើបមានសុវត្ថិភាព
- នៅពេលសិទ្ធិតំណាងត្រូវបានរលត់ត្រូវឲ្យអ្នកតំណាងប្រគល់លិខិតតំណាងមកឲ្យម្ចាស់វិញទើបប្រសើរ
- នៅពេលសិទ្ធិតំណាងត្រូវបានរលត់ ត្រូវធ្វើការជូនដំណឹងទៅដៃគូរពាណិជ្ជកម្មទើបមានសុវត្ថិភាព។

# ៥.កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន

## ៥.១.និយមន័យ

កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន គឺជាប្រភេទនៃកិច្ចសន្យាមួយដែលសិទ្ធិកើតចេញពីការ ព្រមព្រៀងរបស់គូភាគី មានចំពោះតតិយជននោះ (មាត្រា ៣៧៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រម រដ្ឋប្បវេណី)។ ឧទាហរណ៍ ករណីមានការសន្យាពិសេសភ្ជាប់ជាមួយនឹងកិច្ចសន្យាលក់ទិញថា "តតិយជនជាអ្នកមានសិទ្ធិទាមទារឲ្យបង់ប្រាក់" នោះនាំឲ្យកិច្ចសន្យាលក់ទិញនេះក្លាយជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន។ ម្យ៉ាងទៀត ករណីមានខសន្យាពិសេសភ្ជាប់ជាមួយនឹងកិច្ចសន្យាអាណត្តិថា "តតិយជនជាអ្នកមានសិទ្ធិទទួលបានផលប្រយោជន៍នៃកិច្ចសន្យាអាណត្តិ" នោះនាំឲ្យកិច្ចសន្យាអាណត្តិនេះក្លាយជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន។

ជាគោលការណ៍ អានុភាពនៃកិច្ចសន្យាមានតែចំពោះគូភាគីទេ គឺមិនមានអានុភាពចំពោះតតិយជនទេ។ ដោយឡែក កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន គឺជាកិច្ចសន្យាដែលផ្តល់សិទ្ធិឲ្យតតិយជន តែមិនផ្តល់កាតព្វកិច្ចឲ្យតតិយជននោះទេ ហេតុនេះហើយទើប ក្រមរដ្ឋប្បវេណីទទួលស្គាល់ឲ្យមានកិច្ចសន្យាបែបនេះ។

ឧទាហរណ៍ ៖ A (អ្នកលក់) បានចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយ B (អ្នកទិញ)ក្នុងតម្លៃ ៨.០០០ ដុល្លារ។ នៅក្នុងកិច្ចសន្យាលក់ទិញមានភ្ជាប់ជាមួយខពិសេសថា " C ជាអ្នកមានសិទ្ធិទាមទារប្រាក់ ពី B មិនមែន A ទេ" ដូចនេះ កិច្ចសន្យាលក់ទិញនេះគឺជា កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន។

## ៥.២.ពាក្យបច្ចេកទេស

អ្នកព្រមផ្តល់៖ អ្នកដែលត្រូវផ្តល់តាវកាលិកទៅតតិយជន (មាត្រា ៣៧៩ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងឧទាហរណ៍ខាងលើគឺ B (អ្នកទិញ)។

អ្នកទាមទារការផ្ដល់៖ ភាគីម្ខាងទៀតរបស់អ្នកព្រមផ្ដល់ (មាត្រា ៣៧៩ កថាខណ្ឌទី១ វាក្យខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងឧទាហរណ៍ខាងលើគឺ A (អ្នកលក់)។

អ្នកទទួលផលប្រយោជន៍៖ តតិយជនដែលនឹងទទួលតាវកាលិក (មាត្រា ៣៧៩ កថាខណ្ឌទី១ វាក្យខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងឧទាហរណ៍ខាងលើគឺ C (បុគ្គលដែលមានសិទ្ធិទទួលប្រាក់)។

ឧទាហរណ៍ទី១(ករណីអ្នកទាមទារការផ្ដល់គឺជាអ្នកលក់)៖

A (អ្នកលក់) បានចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយ B (អ្នកទិញ)ក្នុងតម្លៃ៨.000ដុល្លារ។ នៅក្នុងកិច្ចសន្យាលក់ទិញមានភ្ជាប់ជាមួយខពិសេសថា "C មានសិទ្ធិទាមទារប្រាក់មិនមែន A ទេ"។

កិច្ចសន្យាលក់ទិញនេះគឺជា កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន។




* កិច្ចសន្យានេះ ជាកិច្ចសន្យារវាង A និង B ។ C មិនមែនជាភាគីនៃកិច្ចសន្យាទេ។

ឧទាហរណ៍ទី២(ករណីអ្នកទាមទារការផ្ដល់គឺជាអ្នកទិញ)៖

A ជាឪពុកបានចុះកិច្ចសន្យាទិញរថយន្តជាមួយ B ដោយ A ជាអ្នកចេញលុយឲ្យ B ហើយនៅក្នុងកិច្ចសន្យានោះ គឺ C ដែលកូនរបស់ A ជាអ្នកទទួលរថយន្ត។ ដូច្នេះ កិច្ចសន្យានេះគឺកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន។




## ៥.៣.តួនាទីនៃកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន

បើមើលតាមឧទាហរណ៍ទី១ខាងលើ B បានទទួលរថយន្តនិងបានបង់ប្រាក់រួចហើយ ដូចនេះតុល្យភាពនៃការចំណាយរបស់ B មិនខុសពីកិច្ចសន្យាលក់ទិញធម្មតានោះទេ។ ប៉ុន្តែ ឃើញថា C ហាក់ដូចជា

ចំណេញព្រោះមិនប្រគល់រថយន្តក៏អាចទទួលបានប្រាក់ដែរ។ ហេតុអ្វីបានជា A បង្កើតកិច្ចសន្យាដែលខាតបង់ផលប្រយោជន៍របស់ខ្លួនហើយឲ្យ C ជាអ្នកទទួលផលប្រយោជន៍?

ឧទាហរណ៍១៖ A (អ្នកលក់) និង B (អ្នកទិញ) បានបង្កើតកិច្ចសន្យាលក់រថយន្តក្នុងតម្លៃ ៨.០០០ ដុល្លារ។ នៅក្នុងកិច្ចសន្យានេះមានភ្ជាប់ ខសន្យាពិសេសដោយផ្តល់ឲ្យ C នូវសិទ្ធិទាមទារប្រាក់។ កិច្ចសន្យានេះជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនដែលមាន A ជាអ្នកទាមទារការផ្តល់ B ជា អ្នកព្រមផ្តល់ C ជាអ្នកទទួលផលប្រយោជន៍។ ផ្អែកតាមកិច្ចសន្យានេះ A ត្រូវប្រគល់រថយន្តទៅ B ហើយ B បង់ប្រាក់៨.០០០ដុល្លារឲ្យ C ។ ការពិត A បានខ្ចីប្រាក់របស់ C ចំនួន១០.០០០ដុល្លារ។ នៅមុនពេលបង្កើតកិច្ចសន្យាលក់ទិញ A មិនមានប្រាក់បង់ឲ្យ C ទេ ហេតុនេះហើយក៏បាននិយាយទៅ C ថាចង់សងប្រាក់ដោយសិទ្ធិលើបំណុលជាប្រាក់ដែលខ្លួនមានចំពោះ B ហើយ C ក៏យល់ព្រម។ C បានទទួលសិទ្ធិ លើបំណុល ជាប្រាក់ចំនួន៨.០០០ដុល្លារពី B ដូចនេះប្រាក់ដែល A នៅជំពាក់ C ត្រូវបានកាត់បន្ថយមកត្រឹម ២.០០០ ដុល្លារ។ នេះជាករណីសងដោយយកវត្ថុជំនួសដែល A យកសិទ្ធិលើបំណុលជាប្រាក់ទៅសងជំនួសប្រាក់ដែលបានខ្ចីពី C ដូចនេះ ចាំបាច់ត្រូវមានការយល់ព្រមពី C (មាត្រា ៤៤២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍នេះ A និង B បានបង្កើតនូវកិច្ចសន្យាលក់ទិញធម្មតា ហើយស្រដៀងគ្នាទៅនឹងករណី A បានទទួលប្រាក់ពី B ក្រោយមក A បានយកប្រាក់ដែលជំពាក់ទៅសង C ។ ប្រសិនបើ យើងអនុវត្តកិច្ចសន្យាដែលបង្កើតឡើងសម្រាប់តតិយជន គឺភាគីបានចុះកិច្ចព្រមព្រៀងចាប់តាំងពីពេលបង្កើតកិច្ចសន្យា។ ប៉ុន្តែ វាមិនមែនជាអនុប្បទានសិទ្ធិលើបំណុលទេ បើអនុប្បទានសិទ្ធិលើបំណុល A មានសិទ្ធិលើបំណុលទៅលើ B រួចបានផ្ទេរសិទ្ធិលើបំណុលនេះទៅឲ្យ C ។ ករណីនេះ សិទ្ធិលើបំណុលមិនធ្លាក់ទៅលើ A ទេ គឺតាមរយៈកិច្ចសន្យានេះនាំឲ្យសិទ្ធិលើបំណុលធ្លាក់ទៅលើ C តែម្តង ដូច្នេះ B ត្រូវបង់ប្រាក់ដោយផ្ទាល់ទៅ C ។

ឧទាហរណ៍២៖ A បានគិតថានឹងឲ្យដីរបស់ខ្លួនជាអំណោយដល់កូនរបស់គាត់គឺ C ដែលជិតរៀបអាពាហ៍ពិពាហ៍។ A ឃើញ B មានដីល្អមួយកន្លែងហើយក៏សម្រេចចិត្តយកដីនោះធ្វើជាអំណោយ។ A បានចុះកិច្ចសន្យាលក់ទិញដី ជាមួយ B ដោយមាន A ជាអ្នកទិញនិង B ជាអ្នកលក់។ នៅក្នុងកិច្ចសន្យានេះបានភ្ជាប់នូវការសន្យាពិសេសដោយឲ្យ C មានសិទ្ធិទាមទារឲ្យប្រគល់ដី។ កិច្ចសន្យានេះជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ដែលមាន A ជាអ្នកទាមទារការផ្តល់ B ជាអ្នកព្រមផ្តល់ C ជាអ្នកទទួលផលប្រយោជន៍។ ឧទាហរណ៍នេះ ស្រដៀងគ្នាទៅនឹងករណី A ទិញដីពី B ហើយ A ធ្វើប្រទានកម្មដីនោះឲ្យទៅ C។ ប៉ុន្តែ មិនមែនមានន័យថាការចុះបញ្ជីដីត្រូវផ្ទេរពី B ទៅ A ហើយពី A ទៅ C ទេ។ តាមរយៈ ការប្រើប្រាស់កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនគឺដីត្រូវផ្ទេរពី B ទៅ C ដោយផ្ទាល់ ដូចនេះអាចសន្សំសំចៃសោហ៊ុយនៃការចុះបញ្ជីបាន។

ឧទាហរណ៍ទី៣ ៖ A (អ្នកចុះកិច្ចសន្យាធានារ៉ាប់រង) បានចុះកិច្ចសន្យាធានារ៉ាប់រងជីវិតជាមួយ B (ក្រុមហ៊ុនធានារ៉ាប់រង)។ អត្ថន័យនៃកិច្ចសន្យាគឺ A បង់ប្រាក់ធានារ៉ាប់រងចំពោះ B ចំនួន៥០ដុល្លារ ជារៀងរាល់

ខែ ហើយនៅពេលដែល A ទទួលមរណភាព B នឹងបង់ប្រាក់ធានារ៉ាប់រងចំនួន១០.០០០ដុល្លារ ចំពោះ C។ កិច្ចសន្យាធានារ៉ាប់រងជីវិតនេះជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនដោយមាន A ជា អ្នកទាមទារការផ្តល់ B ជាអ្នកព្រមផ្តល់ហើយ C ជាអ្នកទទួលផលប្រយោជន៍។

ឧទាហរណ៍ទី៤៖ A (ឪពុកម្តាយ) បានបង្កើតកិច្ចសន្យាអាណត្តិក្នុងការវះកាត់ឲ្យ C ដែលជាកូនរបស់ A ជាមួយ B (គ្រូពេទ្យ)។ កិច្ចសន្យាអាណត្តិក្នុងការវះកាត់នេះជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ដែលមាន A ជាអ្នកទាមទារការផ្តល់ B ជាអ្នកព្រមផ្តល់ហើយ C ជាអ្នកទទួលផលប្រយោជន៍។

**ករណីឧទាហរណ៍ដែលមានភាពមិនច្បាស់លាស់ថាតើជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ឬអត់៖** A (អ្នកទិញ) បានបង្កើតកិច្ចសន្យាលក់ទិញចិញ្ចៀនជាមួយក្រុមហ៊ុន B (លក់ទិញតាមអ៊ីនធឺណេត) ដើម្បីទិញចិញ្ចៀនធ្វើជាអំណោយសម្រាប់ភរិយា C របស់គាត់ដែលកំពុងស្នាក់នៅក្រៅប្រទេស។ A បានសំណូមពរឲ្យ B ផ្ញើចិញ្ចៀនទៅដល់ផ្ទះរបស់ C។ តើកិច្ចសន្យានេះជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនដែលមាន C ជាអ្នកទទួលផលប្រយោជន៍ ឬទេ? ឬក៏គ្រាន់តែជា កិច្ចសន្យាលក់ទិញចិញ្ចៀនធម្មតារវាង A និង B ដែលមានចែងថាទីកន្លែងសងចិញ្ចៀនគឺជាផ្ទះរបស់ C? តើត្រូវនឹងមួយណានោះ គឺ អាស្រ័យទៅលើអត្ថន័យនៃកិច្ចសន្យារវាង A និង B ។ ប្រសិនបើនេះ ជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនដើម្បីឲ្យ C មានឋានៈជាអ្នកទទួលផលប្រយោជន៍ ក្នុងករណីដែល B មិនបានផ្ញើចិញ្ចៀនមកទេ C អាចប្តឹងទាមទារ B បាន (មាត្រា ៣៧៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ម្យ៉ាងទៀត ដើម្បីឲ្យ A រំលាយកិច្ចសន្យាលក់ទិញ បន្ទាប់ពី C បានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ចាំបាច់ត្រូវមានការយល់ព្រមពី C (មាត្រា ៣៨៣ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ផ្ទុយទៅវិញ ករណីដដែលនេះ មិនមែនជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនទេ គឺគ្រាន់តែជាកិច្ចសន្យាដែលមានចែងពីកន្លែងសង ចិញ្ចៀននោះ C មិនមានសិទ្ធិអ្វីទាំងអស់ C មិនអាចប្តឹង B ហើយ A អាចរំលាយកិច្ចសន្យាលក់ទិញបានដោយមិនចាំបាច់មានការយល់ព្រមពី C ទេ។ តើត្រូវនឹងមួយណានោះ គឺ អាស្រ័យទៅលើអត្ថន័យនៃការព្រមព្រៀងរវាង A និង B ប៉ុន្តែក្នុងករណីបែបនេះ ភាគច្រើនគួរបកស្រាយថា មិនមែនជាកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនទេ គ្រាន់តែជាកិច្ចសន្យាដែលមានចែងពីកន្លែងសងចិញ្ចៀនប៉ុណ្ណោះ។

### ៥.៤.លក្ខខណ្ឌ

លក្ខខណ្ឌនៃកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនគឺការសន្យាថា "សិទ្ធិដែលកើតឡើងពីកិច្ចសន្យានោះត្រូវធ្លាក់ទៅលើតតិយជន" នៅពេលបង្កើតកិច្ចសន្យា។

ការយល់ព្រមរបស់អ្នកទទួលផលប្រយោជន៍គឺមិនចាំបាច់ទេ។ ម្យ៉ាងទៀត ប្រសិនបើស្តង់ដានៃការកំណត់អ្នកទទួលផលប្រយោជន៍មានភាពច្បាស់លាស់ហើយ នោះអត្ថិភាពនៃអ្នកទទួលផលប្រយោជន៍ នៅពេលបង្កើតកិច្ចសន្យាគឺមិនចាំបាច់ទេ (មាត្រា ៣៨០ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ នៅពេលដែល

អ្នកព្រមផ្តល់ត្រូវប្រគល់តាវកាលិក នោះអ្នកទទួលផលប្រយោជន៍ត្រូវតែមានអត្ថិភាព។ ប្រសិនបើមិនមានអត្ថិភាពទេ នោះអានុភាពនៃការសន្យាសម្រាប់តតិយជននឹងត្រូវបាត់បង់ ហើយអ្នកព្រមផ្តល់អាច អនុវត្តចំពោះអ្នកទាមទារការផ្តល់បាន(មាត្រា ៣៨០ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី )។ ករណីនត្ថិភាពនៃអ្នកទទួលផលប្រយោជន៍មានដូចជា ករណីអ្នកទទួលផលប្រយោជន៍គឺជាទារកនៅក្នុងគភ៌ ឬ អ្នកទទួលផលប្រយោជន៍ជាក្រុមហ៊ុនដែលមិនទាន់ត្រូវបានបង្កើតជាដើម។

## ៥.៥. ទំនាក់ទំនងរវាងគូភាគី

### ៥.៥.១. ទំនាក់ទំនងរវាងអ្នកទទួលផលប្រយោជន៍ និង អ្នកព្រមផ្តល់

អ្នកទទួលផលប្រយោជន៍អាចទាមទារតាវកាលិកចំពោះអ្នកព្រមផ្តល់ដោយចំពោះបាន (មាត្រា ៣៧៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ ក្នុងករណីដែលអ្នកព្រមផ្តល់មិនអនុវត្តកាតព្វកិច្ច អ្នកទទួលផលប្រយោជន៍អាចដាក់ពាក្យបណ្តឹងទាមទារចំពោះអ្នកព្រមផ្តល់បាន។ ប៉ុន្តែ ក្នុងករណីដែលអ្នកព្រមផ្តល់មានការតវ៉ាដែលកើតចេញពីកិច្ចសន្យានោះ អ្នកទទួលផលប្រយោជន៍ត្រូវទទួលការអះអាងនៃការតវ៉ានោះ (មាត្រា ៣៨២ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ A (អ្នកទិញ) និង B (អ្នកលក់) បានបង្កើតកិច្ចសន្យាលក់ទិញ ដែលមាន A ជាអ្នកទាមទារការផ្តល់ B ជាអ្នកព្រមផ្តល់ហើយ C ជាអ្នកទទួលផលប្រយោជន៍ (មិនមានចែងអំពីថ្ងៃកំណត់បង់ប្រាក់ និង ថ្ងៃកំណត់ប្រគល់វត្ថុទេ)។ C អាចទាមទារចំពោះ B ឲ្យប្រគល់វត្ថុបាន ប៉ុន្តែក្នុងករណីដែល A មិនបានបង់ប្រាក់ B អាចអះអាងតវ៉ាឲ្យអនុវត្តព្រមគ្នា និង បដិសេធប្រគល់វត្ថុដែលជាកម្មវត្ថុចំពោះ C បាន។




### ៥.៥.២.ទំនាក់ទំនងរវាងអ្នកទទួលផលប្រយោជន៍ និងអ្នកទាមទារការផ្តល់

អ្នកទទួលផលប្រយោជន៍ និង អ្នកព្រមផ្តល់ គ្មានទំនាក់ទំនងសិទ្ធិ និង កាតព្វកិច្ចឡើយ។ ប៉ុន្តែ ក្នុងអំឡុងពេលដែលអ្នកទទួលផលប្រយោជន៍មិនទាន់បង្ហាញឆន្ទៈទទួលផលប្រយោជន៍ ចំពោះអ្នកព្រមផ្តល់ ឬ អ្នកទាមទារការផ្តល់ អ្នកទាមទារការផ្តល់អាចដកការសន្យាផ្តល់សិទ្ធិឲ្យទៅអ្នកទទួលផលប្រយោជន៍នោះ នៅពេលណាក៏បានដែរ ដោយជូនដំណឹងទៅអ្នកព្រមផ្តល់ និង អ្នកទទួលផលប្រយោជន៍នោះ (មាត្រា ៣៨១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍៖ A (អ្នកលក់) និង B (អ្នកទិញ) បានបង្កើត កិច្ចសន្យាលក់ទិញ

ដែលមាន A ជាអ្នកទាមទារការផ្តល់ B ជាអ្នកព្រមផ្តល់ ហើយ C ជាអ្នកទទួលផលប្រយោជន៍។ C មានសិទ្ធិទាមទារប្រាក់ពី B ប៉ុន្តែ បើនៅមុនពេលដែល C បង្ហាញឆន្ទៈទទួលផលប្រយោជន៍ A អាចដកកិច្ចសន្យាដែលមាន C ជាអ្នកទទួលផលប្រយោជន៍បាន។ ក្នុងករណីនេះ C បាត់បង់សិទ្ធិ ទាមទារប្រាក់ពី B ហើយ A ទាមទារប្រាក់ពី B (ក្លាយជាកិច្ចសន្យាលក់ទិញធម្មតា)។ ប៉ុន្តែ ក្រោយពីអ្នកទទួល ផលប្រយោជន៍បានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ ភាគីនៃកិច្ចសន្យាមិនអាចប្តូរ ឬ រំលត់នូវសិទ្ធិរបស់អ្នកទទួលផលប្រយោជន៍បានឡើយ (មាត្រា ៣៨១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

### ៥.៥.៣.ទំនាក់ទំនងរវាងអ្នកទាមទារការផ្តល់ និងអ្នកព្រមផ្តល់

អ្នកព្រមផ្តល់ មានសិទ្ធិទាមទារឲ្យអ្នកទាមទារការផ្តល់អនុវត្តកិច្ចសន្យា ហើយ អ្នកទាមទារការផ្តល់មានកាតព្វកិច្ចអនុវត្តកិច្ចសន្យាចំពោះអ្នកព្រមផ្តល់។




❖ នៅពេលដែល C បានបង្ហាញឆន្ទៈថាព្រមទទួលផលប្រយោជន៍(យកឡាន) តែ A ដែលជាអ្នកទាមទារការផ្តល់ មិនព្រមបង់ប្រាក់ទៅឲ្យអ្នកព្រមផ្តល់ B ឡើយ ដែលជាហេតុធ្វើឲ្យ B មិនប្រគល់ឡានឲ្យទៅអ្នកទទួលផលប្រយោជន៍ C ដែរ។ ដូច្នេះ C មិនអាចទាមទារឲ្យ A បង់ប្រាក់ទៅ B បានទេ ប៉ុន្តែ B អាចប្តឹងទាមទារប្រាក់ពី A បាន។ ផ្ទុយទៅវិញបើ B រំលាយកិច្ចសន្យា នោះ C នឹងមិនបានទទួលឡានទេ។

## ៥.៦.មោឃភាព ការលុបចោល និង ការរំលាយកិច្ចសន្យា

**មោឃភាព និង ការលុបចោលកិច្ចសន្យា៖** ក្នុងករណីដែលមានហេតុនៃមោឃភាព ឬការលុបចោលកិច្ចសន្យារវាងអ្នកទាមទារការផ្តល់និងអ្នកព្រមផ្តល់ នោះអ្នកទាមទារការផ្តល់ ឬ អ្នកព្រមផ្តល់អាចអះអាង អំពីមោឃភាព ឬ ការលុបចោលកិច្ចសន្យាបាន ទោះបីមុន ឬ ក្រោយការបង្ហាញឆន្ទៈ ព្រមទទួលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ក៏ដោយ។ ការយល់ព្រមរបស់អ្នកទទួលផលប្រយោជន៍គឺ មិនចាំបាច់ទេ។

ឧទាហរណ៍៖ A (អ្នកលក់ ដែលជាអ្នកទាមទារការផ្តល់)បានឆបោក B (អ្នកទិញដែលជាអ្នកព្រមផ្តល់) ហើយបង្កើតកិច្ចសន្យាលក់ទិញ ដែល C ជាអ្នកទទួលផលប្រយោជន៍។ B អាចលុបចោល កិច្ចសន្យាដោយផ្អែកលើការឆបោកបាន ទោះបីជាគ្មានការយល់ព្រមពី C ក៏ដោយ។

**ការរំលាយកិច្ចសន្យាដោយអ្នកព្រមផ្តល់៖** ប្រសិនបើអ្នកទាមទារការផ្តល់បានបំពានកិច្ចសន្យា អ្នកព្រមផ្តល់អាចរំលាយកិច្ចសន្យាបាន (មាត្រា ៣៨៣ កថាខណ្ឌទី២ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណី) ទោះបីមុន ឬក្រោយការបង្ហាញឆន្ទៈព្រមទទួលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ក៏ដោយ។ ការយល់ព្រមរបស់អ្នកទទួលផលប្រយោជន៍គឺ មិនចាំបាច់ទេ។

**ការរំលាយកិច្ចសន្យាដោយអ្នកទាមទារការផ្តល់** ៖ ប្រសិនបើ អ្នកព្រមផ្តល់បានបំពានកិច្ចសន្យា នោះអ្នកទាមទារការផ្តល់អាចរំលាយកិច្ចសន្យានោះបាន។ ប៉ុន្តែ នៅពេលមានការបង្ហាញឆន្ទៈព្រមទទួលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ បើគ្មានការយល់ព្រមពីអ្នកទទួលផលប្រយោជន៍ នោះអ្នកទាមទារការផ្តល់មិនអាចធ្វើការរំលាយបានទេ (មាត្រា ៣៨៣ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ពីព្រោះម្ចាស់បំណុលរបស់អ្នកព្រមផ្តល់ដែលមិនអនុវត្តកាតព្វកិច្ចគឺជា អ្នកទទួលប្រយោជន៍ ហេតុនេះដើម្បីវិនិច្ឆ័យថា ត្រូវរំលាយកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ឬ អត់ គឺត្រូវគោរពតាមឆន្ទៈរបស់អ្នកទទួលផលប្រយោជន៍។ ទោះបីជាបែបនេះក៏ដោយ ដោយសារតែអ្នកទទួលផលប្រយោជន៍មិនមែនជាភាគីនៃកិច្ចសន្យា ដូចនេះ អ្នកទទួលផលប្រយោជន៍មិនអាចរំលាយកិច្ចសន្យាដោយខ្លួនឯងបានទេ។ ការរំលាយកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចអាចធ្វើបានតែក្នុងករណីដែលមានការយល់ព្រមពីអ្នកទាមទារ ការផ្តល់ និង អ្នកទទួលផលប្រយោជន៍ប៉ុណ្ណោះ។

**<u>ចំណុចបញ្ហា៖</u>**

A : អ្នកទាមទារការផ្តល់

B : អ្នកព្រមផ្តល់

C : អ្នកទទួលផលប្រយោជន៍

បញ្ហា៖ A បានទិញរថយន្តពី B ។ B បានសន្យាថានឹងប្រគល់រថយន្តនោះទៅ C (កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន)។ ដល់ថ្ងៃអនុវត្ត B បានយករថយន្តនោះទៅឲ្យដល់ផ្ទះរបស់ C តែ C បានបោះបង់សិទ្ធិដោយប្រកែកមិនទទួលយករថយន្តឡើយ។ ក្នុងករណីនេះ B មិនដឹងថា តើត្រូវប្រគល់រថយន្តទៅនរណា នោះទេ។ ករណីនេះ នឹងមានបញ្ហា។

នៅប្រទេសកម្ពុជា សិទ្ធិក្នុងការទទួលផលប្រយោជន៍នឹងកើតមានឡើង **<u>នៅពេលបង្កើតកិច្ចសន្យា</u>**។ ហេតុនេះ ដោយសារតែ អត្ថិភាពនៃអ្នកទទួលផលប្រយោជន៍គឺមានតាំងពីដំបូង ដូច្នេះទោះបីជា អ្នកទទួលផលប្រយោជន៍បដិសេធមិនទទួលកម្មវត្ថុក៏ដោយ ក៏មិនអាចក្លាយទៅជានត្ថិភាពនៃអ្នកទទួលផលប្រយោជន៍ឡើយ តែវានឹងក្លាយទៅជា **<u>ការបោះបង់សិទ្ធិក្នុងការទទួលផលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍</u>**។ ដោយសារតែមានអត្ថិភាពនៃអ្នកទទួលផលប្រយោជន៍នោះគប្បីគិតថា កិច្ចសន្យាប្រហែលជាមានសុពលភាព។ ប៉ុន្តែ

ដោយសារតែ C បានបោះបង់សិទ្ធិនោះ A ត្រូវកំណត់អ្នកទទួលផលប្រយោជន៍ថ្មីក្រៅពីបុគ្គល C ឬក៏ A ត្រូវទទួលយករថយន្តដោយខ្លួនឯង។

- នត្ថិភាពនៃអ្នកទទួលផលប្រយោជន៍ ⟶ ប្រគល់វត្ថុឲ្យអ្នកទាមទារការផ្តល់(មាត្រា ៣៨០ នៃក្រមរដ្ឋប្បវេណី)
- អ្នកទទួលផលប្រយោជន៍បោះបង់សិទ្ធិ ⟶ ប្រគល់វត្ថុឲ្យអ្នកទាមទារការផ្តល់

# ក្រុមការងារ

# រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

# ឯកសារសិក្ខាសាលា

# និង

# កម្រងសំណួរ និង ចម្លើយ

# ទាក់ទងនឹងសិក្ខាសាលា

## ២០១៤-២០១៥

# ឯកសារសិក្ខាសាលា

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ

ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

២០១៤~២០១៥

# សិក្ខាសាលា

១.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

២.នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

៣.ការប្រៀបធៀបនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល
និង នីតិវិធីរដ្ឋប្បវេណី

៤.នីតិវិធីនៃការបញ្ជូន

៥.សុំកូន

៦.ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

# សិក្ខាសាលា
# ស្តីពី
# នីតិវិធីត្រៀមសម្រាប់
# ការទាញហេតុផល

## នីតិវិធី
## ត្រៀមសម្រាប់ការទាញហេតុផល
## PPOA

ក្រុមការងារនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

ខែធ្នូ ឆ្នាំ២០១៤

1

## I.សេចក្តីផ្តើម

- ដើម្បីធានាអោយបានការទាញហេតុផលដោយផ្ទាល់មាត់មានភាពឆាប់រហ័សនិងល្អិតល្អន់
- ដើម្បីទទួលបានសាលក្រមមួយដែលឆ្លើយតបនឹងការពិត

☛ មាត្រា ១០៣ ក្រមនីតិវិធីរដ្ឋប្បវេណី

2

## II.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១.អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

- ធ្វើយ៉ាងណាអោយការទាញហេតុផលដោយផ្ទាល់មាត់ គ្មានស្មុគស្មាញ
- ធ្វើយ៉ាងណាអោយការទាញហេតុផលដោយផ្ទាល់មាត់មានភាពឆាប់រហ័ស
- ធ្វើយ៉ាងណាអោយតុលាការងាយស្រួលក្នុងការស្វែងរកការពិត

3

## ២.លំហូរនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ក. ការត្រៀមរៀបចំនីតិវិធីសម្រាប់ការទាញហេតុផល

- ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុ
- ការកោះហៅគូភាគី
  - ☛ មាត្រា ៨០ និងមាត្រា ១០៥. ១ ក្រមនីតិវិធីរដ្ឋប្បវេណី
- ការបង្គាប់ឲ្យគូភាគីដាក់ឯកសារត្រៀម
  - ☛ មាត្រា ១០១ និងមាត្រា ១០២ ក្រមនីតិវិធីរដ្ឋប្បវេណី

4

## ខ.សកម្មភាពនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

■ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ គឺជាអ្នកដឹកនាំ ចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

☛ មាត្រា ៨៩ ក្រមនីតិវិធីរដ្ឋប្បវេណី

■ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមិនចាំបាច់ធ្វើជាសាធារណៈទេ

☛ មាត្រា ១០៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី

■ តុលាការ ត្រូវសាកល្បងធ្វើការផ្សះផ្សាជាដំបូងសិន លើកលែងតែតុលាការយល់ឃើញថាមិនសមរម្យ

☛ មាត្រា ១០៤ ក្រមនីតិវិធីរដ្ឋប្បវេណី

5

■ នៅគ្រប់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ

☛ មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

■នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចជារូបមន្តដូចខាងក្រោម:

-សញ្ញាណរឿងក្តី

-ឈ្មោះចៅក្រម និងក្រឡាបញ្ជី

-ឈ្មោះភាគី អ្នកតំណាង ជំនួយការ និងអ្នកបកប្រែដែលបង្ហាញខ្លួន

-ពេលវេលា និងទីកន្លែង

■នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចជាសារធាតុ ដូចខាងក្រោម:

-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារ

-ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំពិនិត្យភស្តុតាង

-ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគីចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និងការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ

-ការដកពាក្យបណ្តឹង ការផ្សះផ្សារ ការលះបង់ការទាមទារ និងទទួលស្គាល់ការទាមទារ

-ចំណុចដែលតុលាការបង្គាប់ឲ្យកត់ត្រា និងចំណុចដែលអនុញ្ញាតឲ្យកត់ត្រាតាមការទាមទាររបស់ភាគី

-ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ

☛ មាត្រា ១១០ និងមាត្រា ១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

■ភាគី ឬអ្នកដទៃដែលពាក់ព័ន្ធ អាចប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

☛ មាត្រា ១១២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

6

## ១.ការរៀបចំនូវការអះអាងរបស់ភាគី

■ ក្រមនីតិវិធីរដ្ឋប្បវេណី បង្កើតឲ្យមានប្រព័ន្ធឯកសារត្រៀម

☛ មាត្រា ១០១ និងមាត្រា ១០២ ក្រមនីតិវិធីរដ្ឋប្បវេណី

■ក្រមរដ្ឋប្បវេណីបង្កើតឲ្យមានបទប្បញ្ញត្តិស្តីពីសិទ្ធិឲ្យបំភ្លឺ

សិទ្ធិឲ្យបំភ្លឺ គឺជាសិទ្ធិអំណាចដែលត្រូវបានទទួលស្គាល់ចំពោះតុលាការ ដើម្បីបំពេញមុខងារក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌។

☛ មាត្រា ៩០ ក្រមនីតិវិធីរដ្ឋប្បវេណី

■ភាគីត្រូវធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំជាមុននូវយុត្តិសាស្ត្រ និងមធ្យោបាយតទល់ ឬការពារខ្លួន មុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់សម្រាប់ការពារនិងបំពេញការអះអាងរបស់ខ្លួន។

☛ មាត្រា ៩២ ក្រមនីតិវិធីរដ្ឋប្បវេណី

■ ការលើកចោលមធ្យោបាយតទល់ ឬការពារខ្លួន

-ភាគី ដាក់មធ្យោបាយតទល់ ឬការពារខ្លួនយឺតយ៉ាវ ដោយចេតនា ឬមានកំហុសធ្ងន់ធ្ងរ

-មធ្យោបាយតទល់ ឬការពារខ្លួនមានអត្ថន័យមិនច្បាស់លាស់ ក្នុងករណីដែលភាគីមិនធ្វើការបំភ្លឺចាំបាច់ ឬមិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកោះហៅឲ្យមកបំភ្លឺ

☛ មាត្រា ៩៤ ក្រមនីតិវិធីរដ្ឋប្បវេណី

7

■ការរៀបចំអះអាងរបស់ភាគី

-តុលាការឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍អំពី:

.ខ្លឹមសារនៃការសាលក្រមដែលទាមទារដោយដើមចោទ

.អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ

.អង្គហេតុដែលជាមូលហេតុនៃការទាមទារ

-តុលាការឲ្យចុងចម្លើយធ្វើសេចក្តីថ្លៃការណ៍ដូចខាងក្រោម:

.សេចក្តីថ្លៃការណ៍តបនឹងខ្លឹមសារនៃសាលក្រមដែលទាមទារដោយ ដើមចោទ

.ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុ

.អង្គហេតុតវ៉ា

.ការពិនិត្យភស្តុតាង

❖ ការស្នើសុំឲ្យពិនិត្យភស្តុតាង និងការពិនិត្យភស្តុតាងជាឯកសារយោងទៅតាមភាគី។

☛ មាត្រា១០៦ ក្រមនីតិរដ្ឋប្បវេណី។

8

■ការកំណត់ចំណុចវិវាទនៃរឿងក្តី

-ចំណុចវិវាទ គឺជាអង្គហេតុចម្បងនិងអង្គហេតុប្រយោលសំខាន់ៗទាំងឡាយណាដែលគូភាគីយល់មិនស្របគ្នា

-អង្គហេតុចម្បង គឺជាអង្គហេតុចាំបាច់ដែលនាំឲ្យកើតមានឡើងនូវអានុភាពតាមផ្លូវច្បាប់

-អង្គហេតុចម្បងមាន ៤ ប្រភេទ ហើយមានលំដាប់៖

.អង្គហេតុនៃការបង្កើតសិទ្ធិ

ឧ. លោក A បានអះអាងថា ១.គាត់បានឲ្យលោក B ខ្ចីប្រាក់ចំនួន១០លានរៀល ២.បានប្រគល់ប្រាក់កម្ចីចំនួន១០លានរៀល ឲ្យទៅលោក B ៣. អង្គហេតុចាំបាច់ដើម្បីបង្កើតសិទ្ធិទាមទារឲ្យសងប្រាក់កម្ចី ដូចជាក្នុងករណីថ្ងៃកំណត់សងបានមកដល់ជាដើម។

.អង្គហេតុដែលរារាំងសិទ្ធិ

ឧ. លោកB បានអះអាងថាកិច្ចសន្យាត្រូវមោឃភាពយោងតាមការភាន់ច្រឡំ។

.អង្គហេតុរំលត់សិទ្ធិ

ឧ.លោក B បានអះអាងថា បានសងប្រាក់កម្ចីចំនួន១០លានរៀល ឲ្យទៅលោក A រួចហើយ

.អង្គហេតុដែលជាឧបសគ្គនៃសិទ្ធិ

ឧ. លោកBបានអះអាងដោយតវ៉ាឲ្យអនុវត្តព្រមគ្នា។

9

-ទម្រង់អាកប្បកិរិយារបស់ភាគីចុងចម្លើយចំពោះការអះអាងអំពីអត្ថិភាពឬ នត្ថិភាពនៃអង្គហេតុរបស់ដើមចោទ មាន៤ទម្រង់:

- ❖ ការសារភាព
- ❖ ការបដិសេធ
- ❖ ការមិនដឹង
- ❖ ការនៅស្ងៀមស្ងាត់

-ការអះអាងបដិសេធ និងការអះអាងថាមិនដឹងរបស់ចុងចម្លើយចំពោះអង្គហេតុដែលដើមចោទលើកឡើង គឺជាចំណុចវិវាទនៃរឿងក្តី។

☛ មាត្រា ៩៦ និងមាត្រា ១២៣ ក្រមនីតិវិធីរដ្ឋប្បវេណី

10

- ភស្តុតាងដែលត្រូវបញ្ជាក់ចំពោះចំណុចវិវាទ

ភស្តុតាង គឺជាមនុស្ស ឬ វត្ថុ

-ភស្តុតាងជាមនុស្ស (ភាគី សាក្សី អ្នកកោសលវិច័យ...)

-ភស្តុតាងជាវត្ថុ (ឯកសារជាភស្តុតាង)

- ភស្តុតាងស្រប គឺ ជាភស្តុតាងដែលដាក់ដើម្បីធ្វើការបញ្ជាក់នូវអង្គហេតុដោយភាគីដែលត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងអំពីអង្គហេតុណាមួយ( វិក័យប័ត្រប្រគល់ប្រាក់)។

- ភស្តុតាងផ្ទុយ គឺ ជាភស្តុតាងដែលដាក់ដើម្បីតវ៉ាចំពោះអង្គហេតុដោយភាគីដែលមិនបានទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងអំពីអង្គហេតុណាមួយ (សាក្សីបានផ្តល់ចម្លើយថាវិក័យប័ត្រនោះ គឺត្រូវបានបន្លំ)។

11

## ២.ការបំភ្លឺនូវចំណុចវិវាទ និងការរៀបចំភស្តុតាង

- តុលាការ និងគូភាគីជាអ្នកកំណត់ចំណុចវិវាទនៃរឿងក្តី
- តុលាការ ត្រូវកំណត់ភស្តុតាងដែលត្រូវយកទៅពិនិត្យក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

12

## គ.ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

■ តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុ និង ភស្តុតាង ដែលត្រូវធ្វើការពិនិត្យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផល ដោយផ្ទាល់មាត់

■ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផល ដោយផ្ទាល់មាត់ និងត្រូវធ្វើការកោះហៅគូភាគី

☛ មាត្រា ១០៧ និងមាត្រា ១១៣ ក្រមនីតិវិធីរដ្ឋប្បវេណី

13

## ឃ.អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

■ គូភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបានទៀតទេ

■ករណីលើកលែង

-មធ្យោបាយតទល់ ឬការពារខ្លួនទាក់ទងនឹងចំណុចដែលតុលាការ ត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ។

-ឬការដាក់មធ្យោបាយថ្មីនោះមិនធ្វើឲ្យមានការយឺតយ៉ាវខ្លាំងដល់ នីតិវិធី ឬភាគីបានធ្វើសេចក្តីបញ្ជាក់ថាខ្លួនមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅមុនការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរ។

☛ មាត្រា ៩៣, មាត្រា៩៤ កថាខណ្ឌទី១ និងមាត្រា ១០៨ ក្រមនីតិវិធីរដ្ឋប្បវេណី

14

## ៣.សកម្មភាពបណ្ដឹងដែលអាចធ្វើបាននៅក្នុងនីតិវិធី ត្រៀមសម្រាប់ការទាញហេតុផល

- បណ្ដឹងតប(មាត្រា ៨៦ )
- ការបន្ថែម ឬផ្លាស់ប្ដូរកម្មវត្ថុបណ្ដឹង (មាត្រា៨៥)
- ពាក្យស្នើសុំពិនិត្យភស្តុតាង(មាត្រា១២៥)
- ពាក្យសុំដីកាសម្រេចឲ្យផ្ដល់ឯកសារ (មាត្រា ១៥១)

15

## ៤.ការបំបែក និងការបញ្ចូលរឿងក្ដី

- ការបំបែករឿងក្ដី
  បើយល់ឃើញថា មានភាពចាំបាច់តុលាការអាចបំបែករឿងក្ដីមួយ ទៅជារឿងក្ដីពីរ ឬច្រើនបាន
- ការបញ្ចូលរឿងក្ដី
  បើយល់ឃើញថា មានភាពចាំបាច់តុលាការអាចបញ្ចូលរឿងក្ដីពីរ ឬច្រើនដែលកំពុងត្រូវបានចាត់ការតុលាការតែមួយ ជារឿងក្ដីតែមួយបាន
- ការបំបែកនឹងបញ្ចូលរឿងក្ដី ត្រូវធ្វើឡើងដោយដីកាសម្រេច
- ☛ មាត្រា ៩៩ ក្រមនីតិវិធីរដ្ឋប្បវេណី

16

## III.ករណីសិក្សា

- រឿងក្តីទាមទារប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ
- រឿងក្តីទាមទារឲ្យប្រគល់អចលនវត្ថុដោយផ្អែកលើសិទ្ធិលើកម្មសិទ្ធិ
- រឿងក្តីបណ្តឹងលែងលះ

17

## ករណីសិក្សា
## រឿងក្តីទាមទារប្រាក់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

លោក A និងលោក B ជាមិត្តជិតស្និតនឹងគ្នា។ នៅថ្ងៃទី០១-០១-២០១៤ លោក A បានឱ្យលោក B ខ្ចីប្រាក់ចំនួន ១០លានរៀល តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤។ ថ្ងៃកំណត់សងនៅថ្ងៃទី០១-០៥-២០១៤។ ថ្ងៃកំណត់សងបានកន្លងផុតទៅ លោក A បានទៅទារប្រាក់ពីលោក B តែត្រូវបានលោក B ប្រកែកមិនព្រមបង់។ តាមរយៈការប្រកែកនេះ លោក A បានដាក់ពាក្យបណ្តឹងទៅតុលាការ។

18

## ការរៀបចំការអះអាងរបស់ភាគី

| ការអះអាងរបស់ដើមចោទA | ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់B ចំពោះអង្គហេតុដែលA បានអះអាង |
|---|---|
| -ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១ -០១-២០១៤ រវាង A និង B<br><br>-A បានប្រគល់ប្រាក់ ១០លានរៀល ទៅឲ្យលោក B ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤។<br><br>-កាលបរិច្ឆេទសងបានមកដល់ (អង្គហេតុជាក់ស្តែង) | -B បានសារភាពថា ខ្លួនពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០១-០១-២០១៤ ជាមួយ A<br><br>-B បដិសេធថា ខ្លួនមិនទាន់បានទទួលប្រាក់កម្ចី ១០លានរៀលពី A |

19

## ចំណុចវិវាទ

- ផ្អែកតាមការអះអាងខាងលើនេះ ចំណុចវិវាទនៃរឿងក្តីនេះគឺ តើដើមចោទ A បានប្រគល់ កម្ចីចំនួន ១០ លាន រៀល ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ ឱ្យ ទៅ ចុងចំលើយដែរឬទេ?

20

# ភស្តុតាង និងបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង

- ចំពោះចំណុចវិវាទខាងលើនេះ ដើមចោទ A ត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងថា ខ្លួនបានប្រគល់ប្រាក់កម្ចីចំនួន ១០លានរៀល ឱ្យទៅចុងចំលើយ។ ភស្តុតាងដែលត្រូវយកមកបញ្ជាក់ អាចជាវិក័យបត្រទទួលប្រាក់កម្ចី ឬសាក្សីដែលដឹងឮក្នុងការប្រគល់ប្រាក់កម្ចី។

21

# ករណីសិក្សា
# រឿងក្តីទាមទារឲ្យប្រគល់អចលនវត្ថុដោយផ្អែកលើកម្មសិទ្ធិ

- លោក A និងលោក ជាមិត្តជិតស្និតនឹងគ្នា។ នៅថ្ងៃទី០១-០១-២០១៤ លោក B បានលក់ដីទំហំ ៣០ម គុណនឹង ៤០ម មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១១១១ ចុះថ្ងៃទី ០១-០២-២០០៥ មានទីតាំងស្ថិត នៅភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទៅឱ្យលោក A ក្នុងតម្លៃ ១០ម៉ឺន ដុល្លាសហរដ្ឋអាមេរិក តាមកិច្ចសន្យាលក់ផ្តាច់ (ទម្រង់យថាភូត)ចុះថ្ងៃទី០១-០១-២០១៤ ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឱ្យលោក A ជាកម្មសិទ្ធិករនៅថ្ងៃទី០១-០២-២០១៤។ នៅថ្ងៃទី០១-០៣-២០១៤ លោក B បានទៅកាន់កាប់ដីដែលបានលក់ឱ្យ លោក A ។ ដោយឃើញដូច្នេះ លោក A បានទៅសុំឱ្យលោក B ប្រគល់ដីមកឱ្យខ្លួនកាន់កាប់ តែត្រូវបានលោក B បដិសេធ ។ តាមរយៈការបដិសេធនេះ លោក A បានដាក់ពាក្យបណ្តឹងទៅតុលាការ ។

22

# ការរៀបចំការអះអាងរបស់ភាគី

**ការអះអាងរបស់ដើមចោទ A**

-A ជាកម្មសិទ្ធិករនៃដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ១១១១ ចុះថ្ងៃទី០១-០២-២០០៥ មានទីតាំងស្ថិត នៅភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-B កាន់កាប់ដី ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ១១១១ ចុះថ្ងៃទី០១-០២-២០០៥

**ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់**A **ចំពោះអង្គហេតុដែល** B **បានអះអាង**

-A បានបដិសេធថា មិនបានជួលដី និងប្រគល់ដីឱ្យទៅ B ទេ

**ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់**B **ចំពោះអង្គហេតុដែល** A **បានអះអាង**

- B ទទួលស្គាល់ថាដី គឺជាកម្មសិទ្ធិរបស់ A

- B ទទួលស្គាល់ថា ខ្លួនបានកាន់កាប់ដីរបស់ A

**ការអះអាងរបស់ចុងចំលើយ B**

-B អះអាងថា គាត់បានជួលដីពី A ដោយផ្អែកលើ ភតិសន្យា ចុះថ្ងៃទី០១-០៣-២០១៤ រហូតដល់ថ្ងៃទី ២៨-០២-២០១៥ រវាង លោក A និង B

-B អះអាងថា A បានប្រគល់ដីឱ្យទៅ B ដោយផ្អែកលើកិច្ចសន្យាជួលនៅថ្ងៃទី ០១-០៣-២០១៤

23

# ចំណុចវិវាទ

ផ្អែកតាមការអះអាងខាងលើនេះ ចំណុចវិវាទនៃរឿងក្ដីនេះ គឺតើចុងចំលើយ B បានធ្វើភតិសន្យា ចុះថ្ងៃទី ០១-០៣-២០១៤ ជាមួយដើមចោទ A និងប្រគល់ដី ដែរឬទេ?

24

## ភស្តុតាង និងបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង

ចំពោះចំណុចវិវាទខាងលើនេះ ចុងចំលើយ B ត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងថា ខ្លួនបានធ្វើកិច្ចសន្យាជាមួយដើមចោទ និងដើមចោទ ប្រគល់ដីឱ្យទៅ B ។ ភស្តុតាងដែលត្រូវយកមកបញ្ជាក់ គឺអត្ថិភាពនៃកិច្ចសន្យា (លិខិតកិច្ចសន្យា ឬសាក្សី ដែលដឹងឮអំពីការបង្កើតកិច្ចសន្យា) ។

25

## ករណីសិក្សា
## រឿងក្ដីលែងលះ

លោក B និងអ្នកស្រី A ជាប្ដីប្រពន្ធនឹងគ្នា( មានសំបុត្រអាពាហ៍ ពិពាហ៍) ។ ក្នុងការរួមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធលោក B និងអ្នកស្រី A តែងតែមានទំនាស់ជាមួយគ្នា ។ ដោយការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ ពុំចុះសម្រុងគ្នាយ៉ាងដូច្នេះ អ្នកស្រី A បានដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការ ។

26

# ការរៀបចំការអះអាងរបស់ភាគី

| **ការអះអាងរបស់ដើមចោទ A** | **ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ B ចំពោះការអះអាងរបស់ A** |
| --- | --- |
| -អ្នកស្រី A និងលោក B បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា<br>-លោក B បានវាយខ្លួនជាប្រចាំនៅពេលឈ្លោះប្រកែកគ្នា | -លោក Bសារភាពថា ខ្លួន និងអ្នកស្រី A បានរៀបអាពាហ៍ ពិពាហ៍នឹងគ្នា<br>-លោក B បដិសេធថា ខ្លួនមិនបានវាយដំអ្នកស្រី A ទេ |

27

# ចំណុចវិវាទ

ផ្អែកតាមការអះអាងខាងលើនេះ ចំណុចវិវាទនៃរឿងក្ដីនេះ គឺតើចុងចំលើយ B បានវាយដំលើអ្នកស្រី A ជាប្រចាំពេលដែលដើមចោទ និងចុងចំលើយ ឈ្លោះប្រកែកគ្នា ដែរឬទេ ?

28

## ភស្តុតាង និងបន្ទុកទទួលខុសត្រូវ ក្នុងការបញ្ជាក់ភស្តុតាង

ចំពោះចំណុចវិវាទខាងលើនេះ ដើមចោទ A ត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងថា ខ្លួនពិតជាត្រូវបានចុងចំលើយ B វាយដំពេលឈ្លោះប្រកែកគ្នាម្តងៗ ។ ភស្តុតាងដែល ត្រូវយកមកបញ្ជាក់ អាចជាស្នាមរបួសដែលបន្សល់ទុកនៅនឹងខ្លួនដើមចោទ រូបថតដែលបញ្ជាក់ពីរបួសស្នាម ឬសាក្សីដែលដឹងឮពីការវាយដំ ។

29

---

# សូមអរគុណ!

## សំនួរ & ចម្លើយ!

30

# មេរៀនស្តីពី

# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

## I-សេចក្តីផ្តើម

នៅពេលដើមចោទ ដាក់ពាក្យបណ្តឹងទៅតុលាការ តុលាការត្រូវធ្វើការជំនុំជម្រះចំពោះរាល់ការទាមទាររបស់ដើមចោទ និងចេញសាលក្រម ដោយធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ។ ដូច្នេះដើម្បីធានាឱ្យបាននូវការទាញហេតុផលដោយផ្ទាល់មាត់មួយដែលល្អិតល្អន់ និងទទួលបាននូវសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិត ចាំបាច់ត្រូវមានការត្រៀមរៀបចំសម្រាប់ការទាញហេតុផល ។ ដើម្បីសម្រេចនូវគោលបំណងនេះ អ្នកនិពន្ធក្រមនីតិវិធីរដ្ឋប្បវេណីបានបង្កើតបទប្បញ្ញត្តិថា មុននឹងធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ចាំបាច់ត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ហេតុដូច្នេះ យើងអាចលើកជាសំណួរបានថា តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានអត្ថន័យយ៉ាងណា? ហើយសកម្មភាពអ្វីខ្លះ ដែលតុលាការ និងភាគី ត្រូវធ្វើនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីឱ្យការទាញហេតុផលមួយដែលល្អិតល្អន់ និងទទួលបាននូវសាលក្រមមួយដែលឆ្លើយតបនឹងការពិត ?

**មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា " នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការ i) ត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី ii) បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និង iii) រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ។" ។**

## II-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១-អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដើម្បីលើកកំពស់ និងសម្រួលដល់ការទាញហេតុផលដោយផ្ទាល់មាត់ និងការកាត់តែងលិខិតសាលក្រម ឱ្យប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ បានសេចក្តីថា នីតិវិធីត្រៀម

នេះ គឺធ្វើយ៉ាងណាឱ្យការទាញហេតុផលដោយផ្ទាល់មាត់ គ្មានភាពស្មុគស្មាញ គ្មានអូសបន្លាយពេលវេលាដោយឥតប្រយោជន៍ និងងាយស្រួលក្នុងការស្វែងរកការពិត ដើម្បីឆ្លើយតបនឹងការទទួលខុសត្រូវរបស់តុលាការដែលមានបញ្ញត្តិក្នុងមាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា " តុលាការ ត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស........." ។**

## ២. លំហូរនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ក. ការត្រៀមរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

យើងដឹងហើយថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺមានគោលបំណង **i)** រៀបចំនូវសេចក្តីអះអាងរបស់ភាគី **ii)** បំភ្លឺនូវចំណុចវិវាទនៃរឿងក្តី និង **iii)** រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តី ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ។ ដូច្នេះហើយ នៅពេលពាក្យបណ្តឹងរបស់ដើមចោទ ត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផលឱ្យបានឆាប់រហ័ស និងកោះហៅគូភាគី ( មាត្រា ៨០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ តុលាការ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងរបស់ដើមចោទត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស ដូចជា គ្រោះធម្មជាតិ ឬអសន្តិសុខ ជាដើម (មាត្រា ៨០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលគូភាគីអាចចូលរួមបាន ( មាត្រា ១០៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

### ខ. សកម្មភាពនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ចៅក្រម ឬប្រធានក្រុមប្រឹក្សា គឺជាអ្នកដឹកនាំចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចៅក្រម ឬប្រធានក្រុមប្រឹក្សា អាចអនុញ្ញាតឱ្យភាគីណាមួយនិយាយបាន និងអាចហាមភាគីដែលមិនស្តាប់បញ្ជារបស់ខ្លួន មិនឱ្យនិយាយបាន ( មាត្រា ៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមិនចាំបាច់ធ្វើជាសាធារណៈទេ ។

ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន (មាត្រា ១០៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ តុលាការត្រូវសាកល្បងផ្សះផ្សាជាលើកដំបូងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកលែងតែយល់ឃើញថាមិនសមរម្យ (មាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅគ្រប់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការ ត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ ព្រោះថា មានសកម្មភាពជាច្រើនដែលកើតឡើង ដោយចៅក្រម ភាគី ឬអ្នកតំណាង ហើយ សកម្មភាពទាំងនោះអាចនឹងបញ្ជាក់បាន លុះត្រាតែមានការកត់ត្រាទុក (មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ម្យ៉ាងវិញទៀត កំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលនេះ មានអនុភាពក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ (មាត្រា ២៧៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវសរសេរអំពីចំណុចជារូបមន្ត និងចំណុចជាសារធាតុដែលមានចែងក្នុងបញ្ញត្តិមាត្រា ១១០ និងមាត្រា ១១១ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី (សូមពិនិត្យមើលមាត្រា ១១០ និងមាត្រា ១១១)។ ចំពោះកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគី ឬអ្នកដទៃទៀតដែលពាក់ព័ន្ធ អាចប្តឹងតវ៉ាបាន ហើយសេចក្តីប្តឹងតវ៉ានេះ ក្រឡាបញ្ជី ត្រូវកត់ក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលនោះ (មាត្រា ១១២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ភាពត្រឹមត្រូវក្នុងអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ជាក់បានដោយកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកលែងតែករណីដែលកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលបានបាត់ ឬវិនាស (មាត្រា ១១២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

### i)-ការរៀបចំនូវការអះអាងរបស់ភាគី និងភស្តុតាង

ដើម្បីអាចរៀបចំនូវការអះអាងរបស់ភាគី និងភស្តុតាង ឱ្យមានប្រសិទ្ធិភាព ក្រមនីតិវិធីរដ្ឋប្បវេណី បានបង្កើតឱ្យមានប្រព័ន្ធនៃឯកសារត្រៀម (មាត្រា ១០១ និងមាត្រា ១០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ឯកសារត្រៀម គឺជាឯកសារដែលភាគីនីមួយៗ ជូនដំណឹងជាមុនទៅតុលាការ និងភាគីម្ខាងទៀត អំពីចំណុចដែលខ្លួននឹងធ្វើសេចក្តីថ្លែងការណ៍នៅក្នុងកាលបរិច្ឆេទនីមួយៗដែលបានកំណត់ ។ ក្រៅពីការបង្កើតប្រព័ន្ធឯកសារត្រៀមនេះ ក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានបង្កើតបទប្បញ្ញត្តិស្តីពីសិទ្ធិឱ្យបំភ្លឺ (មាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ផងដែរ ។ ការបង្កើតប្រព័ន្ធឯកសារត្រៀម និងសិទ្ធិឱ្យបំភ្លឺនេះ គឺក្នុងគោលបំណងធ្វើឱ្យតុលាការ និងគូភាគី អាចកំណត់បានអង្គហេតុដែលក្លាយ

ជាមូលដ្ឋានសម្រាប់ចេញសាលក្រម តាមរយៈការសួរភាគីអំពីចំណុចដែលមិនច្បាស់លាស់នៃអង្គហេតុដែលភាគីបានអះអាង និងតាមរយៈការជំរុញឱ្យធ្វើការអះអាងអង្គហេតុសមរម្យថ្មីទៀត ឬការដាក់ភស្តុតាងថ្មីបាន ដើម្បីការជម្រះក្តីមួយប្រកបដោយភាពឆាប់រហ័ស មានសមភាពរវាងភាគី និងភាគី និងមានភាពយុត្តិធម៌ ។

បន្ទាប់ពីគូភាគីបានឯកសារត្រៀមរបស់ខ្លួនមកតុលាការរួចហើយ ដើមចោទ នឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រនូវឯកសារត្រៀមរបស់ខ្លួនក្នុងកាលបរិច្ឆេទដែលបានកំណត់ ។ ការធ្វើសេចក្តីថ្លែងការណ៍នេះ គេហៅថា មធ្យោបាយតទល់ រីឯចុងចំលើយ នឹងធ្វើសេចក្តីថ្លែងការណ៍ គាំទ្រនូវឯកសារត្រៀមរបស់ខ្លួននៅកាលបរិច្ឆេទដែលបានកំណត់ដូចដើមចោទដែរ ។ ការធ្វើសេចក្តីថ្លែងការណ៍នេះ គេហៅថា មធ្យោបាយការពារ ។ (មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

ការរៀបចំនូវការអះអាង និងភស្តុតាង ត្រូវចាប់ផ្តើមដំបូងដោយសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ដើមចោទក្នុងកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលជាលើកដំបូងដែលតុលាការបានកំណត់ ។ នៅក្នុងសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ដើមចោទ ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ (មាត្រា ៧៥ កថាខណ្ឌទី២ ចំណុចខ ឃ្លាទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ (មាត្រា ៧៥ កថាខណ្ឌទី២ ចំណុចខ ឃ្លាទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងដែលត្រូវធ្វើការបញ្ជាក់ចំពោះការទាមទាររបស់ខ្លួន (មាត្រា ៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ តាមរយៈសេចក្តីថ្លែងការណ៍របស់ដើមចោទនេះ តុលាការនឹងឱ្យចុងចំលើយ ធ្វើសេចក្តីថ្លែងការណ៍តប ។ នៅក្នុងសេចក្តីថ្លែងការណ៍តបរបស់ចុងចំលើយ ចុងចំលើយ ត្រូវធ្វើសេចក្តីថ្លែងការណ៍តបចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុ អង្គហេតុតវ៉ាចំពោះអង្គហេតុដែលដើមចោទបានលើកឡើង និងភស្តុតាងដែលត្រូវធ្វើការបញ្ជាក់ចំពោះអង្គហេតុនោះ (មាត្រា ១០១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី )។ ជាទូទៅ តុលាការតែងតែបង្គាប់គូភាគីដាក់ឯកសារត្រៀមតបត្តទៅវិញទៅមក ហើយឯកសារត្រៀមនេះ គូភាគីត្រូវដាក់ទៅតាមការកំណត់របស់តុលាការ(មាត្រា ១០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) ។ ជាធម្មតា តុលាការតែងតែបង្គាប់ឱ្យគូភាគីដាក់ឯសារត្រៀមនៅមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយធ្វើការបញ្ជូនឯកសារត្រៀមនេះ ទៅឱ្យភាគីម្ខាង

ទៀត ដើម្បីឱ្យភាគីម្ខាងទៀតនោះ ត្រៀមខ្លួនឆ្លើយតបនឹងការអះអាងរបស់ភាគីម្ខាងទៀត ។ ការធ្វើបែបនេះ គឺដើម្បីអាចឱ្យតុលាការរៀបចំការអះអាង និងភស្តុតាង បានឆាប់រហ័ស និងល្អិតល្អន់។

ក្រោយពីសេចក្តីថ្លែងការណ៍របស់គូភាគីនៅក្នុងកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានបញ្ចប់ តុលាការនឹងអាចរៀបចំនូវការអះអាងរបស់គូភាគីថាតើអង្គហេតុណាខ្លះដែលគ្មានវិវាទ អង្គហេតុណាខ្លះទៀតដែលមានវិវាទ ហើយភស្តុតាងណាខ្លះដែលទាក់ទងនឹងចំណុចវិវាទ ដែលត្រូវធ្វើការពិនិត្យនៅក្នុងកាលបរិច្ឆេទនៃការទាញ ហេតុផលដោយផ្ទាល់មាត់នៅពេលខាងមុខ ។

ចំណុចវិវាទ គឺជាអង្គហេតុចំបងទាំងឡាយណាដែលគូភាគីយល់មិនស្របគ្នា ។ អង្គហេតុចំបង គឺជាអង្គហេតុដែលនាំឱ្យមានអានុភាពតាមផ្លូវច្បាប់ ។ វាមានន័យថា ជាអង្គហេតុដែលបង្កើតសិទ្ធិ ឬអង្គហេតុដែលជាឧបសគ្គនៃសិទ្ធិ ឬអង្គហេតុរារាំងការអនុវត្តសិទ្ធិ ឬអង្គហេតុរំលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ។ ឧទាហរណ៍ : លោក A បានអះអាងថា ១-គាត់បានបង្កើតកិច្ចសន្យាខ្ចីបរិភោគ ១០ លានរៀល ជាមួយលោក B នៅថ្ងៃទី០១-០១-២០១៤ ២-គាត់បានប្រគល់ប្រាក់ ១០លាន រៀល ឱ្យលោក B នៅថ្ងៃទី០១-០១-២០១៤ ៣-កាលកំណត់សងបានមកដល់ ការអះអាងអំពីអង្គហេតុទាំងបីនេះ គឺជាការអះអាងអំពីអង្គហេតុបង្កើតសិទ្ធិលើបំណុល ។ ការអះអាងអំពីអង្គហេតុនេះ គឺជាអះអាងអំពីអង្គហេតុនៃការកកើតសិទ្ធិលើបំណុល ។ ក្នុងករណីភាគីណាមួយបានអះអាងអំពីអង្គហេតុនៃការលុបចោលកិច្ចសន្យា មោឃភាពនៃកិច្ចសន្យា ឬរំលាយកិច្ចសន្យា ការអះអាងនេះ គឺជាការអះអាងអំពីអង្គហេតុដែលជាឧបសគ្គនៃការកកើតសិទ្ធិ ។ ក្នុងករណីដែលលោក A បានអះអាងថាបានឱ្យលោក B ខ្ចីប្រាក់ចំនួន ១០ លានរៀល តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ ប្រសិនបើលោក B អះអាងតបវិញថា គាត់មិនទាន់បានទទួលប្រាក់ ១០ លានរៀលនោះទេ ការអះអាងតបនេះចាត់ទុកថា ជាការបដិសេធនូវអង្គហេតុទី២។ នៅក្នុងករណីដដែលនេះ ប្រសិនបើលោក B អះអាងថា បានសងប្រាក់ចំនួន ១០ លានរៀលដែលជាប្រាក់កម្ចីទៅឱ្យលោក A រួចហើយ ការអះអាងថាបានសងនេះ គឺជាអង្គហេតុរំលត់សិទ្ធិ ។

ជាទូទៅក្នុងករណីដែលភាគីណាមួយ បានអះអាងអំពីអត្ថិភាពនៃអង្គហេតុណាមួយ ក្រមនីតិវិធីរដ្ឋប្បវេណី

បែងចែកអាកប្បកិរិយារបស់ភាគីម្ខាងទៀតជា ០៤ ប្រភេទ : ប្រភេទទី១ គឺភាគីម្ខាងទៀតនោះ អាចធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអង្គហេតុនោះ ការអះអាងបែបនេះ គេហៅថា ការបដិសេធ (ការមិនទទួលស្គាល់) ប្រភេទទី២ គឺភាគីម្ខាងទៀតនោះ អាចធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនោះ ដែលការអះអាងបែបនេះ គេហៅថា ការសារភាព (មាត្រា ១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ប្រភេទទី៣ គឺភាគីម្ខាងទៀតនោះ អាចធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ ដែលការអះអាងបែបនេះ គេហៅថា សេចក្តីថ្លែងការណ៍អំពីការមិនបានដឹង(មាត្រា ៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ប្រភេទទី៤ គឺភាគីម្ខាងទៀតនោះ មិនឆ្លើយអ្វីទាំងអស់ (មាត្រា ៩៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ប្រភេទទី១ និងទី៣ គឺជាចំណុចវិវាទនៃរឿងក្តី ចំពោះប្រភេទទី២ និងទី៤ ពុំមែនជាចំណុចវិវាទនៃរឿងក្តីទេ ព្រោះថា អង្គហេតុដែលគូភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលចាត់ទុកថាបានសារភាព តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុទាំងនេះដោយភស្តុតាងទេ (មាត្រា ១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ហេតុដូច្នេះ មានតែចំណុចវិវាទនៃរឿងក្តីទេ ដែលតុលាការ ត្រូវធ្វើការទទួលស្គាល់ដោយផ្អែកលើភស្តុតាង ( មាត្រា ១២៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

វិធីសាស្ត្រក្នុងការកំណត់ចំណុចវិវាទ នឹងធ្វើការពន្យល់នៅក្នុងចំណុចទី៣ស្តីពីរឿងក្តីគំរូ ។

ភស្តុតាង គឺជាឯកសារ ឬវត្ថុ ជាដើម ដែលមានភាពចាំបាច់សម្រាប់ធ្វើការបញ្ជាក់អង្គហេតុណាមួយ ។ ភស្តុតាងអាចមាន ភស្តុតាងជាមនុស្ស(ភាគី សាក្សី អ្នកកោសលវិច័យ...) និងភស្តុតាងជាវត្ថុ (កិច្ចសន្យា ឬឯកសារផ្សេងៗទៀត )។ ភស្តុតាងដែលគូភាគីស្នើសុំឱ្យតុលាការពិនិត្យ អាចជាភស្តុតាងស្រប និងភស្តុតាងផ្ទុយ ។ ភស្តុតាងស្របគឺជាភស្តុតាងដែលភាគីម្ខាងមានបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់អង្គហេតុ (ឧទាហរណ៍ លោក A បានអះអាងថាគាត់បានឱ្យលោក B ខ្ចីប្រាក់ចំនួន ១០ លានរៀល តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ ការអះអាងនេះ ត្រូវបានលោក B បដិសេធថា ខ្លួនពុំបានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយលោក A ទេ ដូច្នេះ លិខិតកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ ឬសាក្សីដែលដឹងឮអំពីការបង្កើតកិច្ចសន្យា គឺជាភស្តុតាងស្រប) ។ ចំពោះភស្តុតាងផ្ទុយ គឺជាភស្តុតាងដែលត្រូវបានដាក់ដោយភាគីម្ខាង ដើម្បីតវ៉ាចំពោះអង្គហេតដើម្បីធ្វើឱ្យតុលាការមានមន្ទិលទៅលើអត្ថិភាពនៃអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត (ឧទាហរណ៍ លោក A បានអះអាងថា បានឱ្យ

លោក B ខ្ចីប្រាក់ចំនួន ១០ លានរៀល តាមកិច្ចសន្យាខ្ចី បរិភោគ ចុះថ្ងៃទី០១-០១-២០១៤ បន្ទាប់មកលោក B បានអះអាងបដិសេធការអះអាងនេះ ហើយធ្វើការអះអាងថាលោក A ឱ្យខ្លួនជាអំណោយ ដូច្នេះ កិច្ចសន្យាប្រទានកម្ម គឺជាភស្តុតាងផ្ទុយ) ។

ក្នុងករណីដែលភាគីណាមួយ អះអាងអំពីអត្ថិភាព មោឃភាព ការរំលាយ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ភាគីនោះ គឺមានបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាងចំពោះអត្ថិភាព មោឃភាព ការរំលាយ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ។ (សូមពិនិត្យមើលរឿងក្តីគំរូ)

## ii)-iii)-ការបំភ្លឺនូវចំណុចវិវាទ និងភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ

ក្រោយពីតុលាការរៀបចំនូវការអះអាង និងភស្តុតាងរួចហើយ តុលាការ និងភាគី នឹងឃើញយ៉ាងច្បាស់លាស់ នូវចំណុចវិវាទនៃរឿងក្តី និងភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនោះ ដែលចំណុចនេះ នឹងត្រូវធ្វើការពិនិត្យនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។

ចំណុចវិវាទនៃរឿងក្តី ត្រូវបានកំណត់ និងត្រូវបានទទួលស្គាល់រួមគ្នាដោយតុលាការ និងគូភាគី ។ ក្រោយពីកំណត់បាននូវចំណុចវិវាទនៃរឿងក្តីហើយ តុលាការ ត្រូវកំណត់នូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ហើយនឹងត្រូវធ្វើការពិនិត្យនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ចំណុចវិវាទនៃរឿងក្តី ប្រែប្រួលទៅតាមការអះអាងរបស់គូភាគី និងប្រភេទនៃរឿងក្តី (សូមមើលរឿងក្តីគំរូ) ។

## iv)-ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគី នូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ក្រៅពីការបញ្ជាក់អំពីអង្គហេតុ និងភស្តុតាងដែលនឹងត្រូវធ្វើការពិនិត្យ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីឱ្យមកចូលរួមតាមកាលបរិច្ឆេទដែលបានកំណត់ (១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## v)-នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី ១

ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១១៦ កថាខណ្ឌទី ១ និងទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គូភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបានទៀតទេ (មាត្រា ១០៨ និង ១១៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប្រសិនបើអនុញ្ញាតឱ្យភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាននោះ ការណ៍ដែលកំណត់ចំណុចវិវាទ និងភស្តុតាងដែលត្រូវធ្វើការពិនិត្យនឹងពុំមានន័យខ្លឹមសារអ្វីឡើយ ។ មធ្យោបាយតទល់ និងការពារខ្លួន ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យទៅតាមដំណើរការនៃបណ្តឹង (មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ផ្អែកតាមមាត្រា ៩៣ និងមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាគោលការណ៍ ភាគីអាចការដាក់មធ្យោបាយតទល់ និងការពារខ្លួនបានតែនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុណ្ណោះ ។ អានុភាពនេះ ក៏នឹងមានដូចគ្នាផងដែរទៅលើការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ផងដែរ (មាត្រា ២៧៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ មានបទប្បញ្ញត្តិលើកលែងដែលអាចឱ្យភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានដែរ មានដូចជា ករណីដែលមធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឧទាហរណ៍ៈ អត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចរបស់តុលាការ (មាត្រា ១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) អត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការដកហូតសមត្ថកិច្ចជំនុំជម្រះ (មាត្រា ២៧ កថាខណ្ឌទី២ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី) ឬការដាក់មធ្យោបាយថ្មីនោះ មិនធ្វើឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធី ឧទាហរណ៍ ករណីដែលភាគីស្នើសុំឱ្យពិនិត្យភស្តុតាងដែលអាចពិនិត្យភ្លាមៗ ដែលរួមមានដូចជា ឯកសារដែលភាគីដាក់មកតាមខ្លួនមកតុលាការក្នុងកាលបរិច្ឆេទនៃការទាញហេតុផល ឬសាក្សីដែលភាគីនាំមកជាមួយជាដើម និងក្នុងករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ នៅមុខការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរ ឧទាហរណ៍ ករណីភាគីស្នើសុំឱ្យពិនិត្យភស្តុតាងដែលទើប នឹងត្រូវ

បានរកឃើញ ឬករណីអះអាងអំពីអង្គហេតុ ដែលកើតឡើងនៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាដើម ។

## ៣-សកម្មភាពបណ្តឹងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញ ហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រៅពីការធ្វើសកម្មភាពចាំបាច់ដើម្បីរៀបចំការអះអាងរបស់ភាគី ការរៀបចំចំណុចវិវាទ និងការរៀបចំភស្តុតាងដែលត្រូវពិនិត្យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ឬដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងអាចពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង ( មាត្រា ១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ជាងនេះទៅទៀត តុលាការអាចទទួលយកនូវពាក្យសុំ និងពាក្យបណ្តឹង ជាអាទិ៍ ។ ពាក្យសុំមានដូចជាកាស្នើសុំឱ្យពិនិត្យភស្តុតាងរបស់ភាគី (មាត្រា ១២៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ពាក្យសុំធ្វើកោសលវិច័យរបស់ភាគី (កថាខណ្ឌទី១ មាត្រា ១៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ (មាត្រា ១៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)...។ ពាក្យបណ្តឹងមានដូចជា ការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង (មាត្រា ៨៤នៃក្រមនីតិវិធីរដ្ឋប្បវេណី) ការដាក់បណ្តឹងតប (មាត្រា ៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## ៤-ការបំបែក និងការបញ្ចូលរឿងក្តីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងដំណើការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើយល់ឃើញជាចាំបាច់ តុលាការអាចបំបែករឿងក្តីមួយទៅជារឿងក្តីផ្សេងគ្នា ហើយធ្វើការជំនុំជម្រះលើរឿងក្តីទាំងនោះដាច់ពីគ្នាបាន (មាត្រា ៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ឧទាហរណ៍ ប្រសិនបើនៅក្នុងបណ្តឹងតែមួយដើមចោទបានទាមទារឱ្យចុងចំលើយបង់ប្រាក់កម្ចីផង និងឱ្យប្រគល់អចលនវត្ថុផង តុលាការអាចបំបែកការទាមទារឱ្យប្រគល់អចលនវត្ថុពីការទាមទារប្រាក់កម្ចីបាន (មាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ផ្ទុយទៅវិញ តុលាការ ក៏អាចបញ្ចូលការទាមទារពីរ ឬច្រើន ដែលកំពុងត្រូវបានចាត់ការក្នុងតុលាការតែមួយ ជាសំណុំរឿងតែមួយ ហើយធ្វើការជំនុំជម្រះដោយនីតិវិធីតែមួយបានដែរ។ ឧទាហរណ៍ ប្រសិនបើដើមចោទ ធ្វើបានទាមទារឱ្យចុងចំលើយបង់ប្រាក់កម្ចី ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះ

ថ្ងៃទី០១-០៨-២០១៤ ហើយក្រោយមកដើមចោទបានទាមទារឱ្យចុងចំលើយបង់ប្រាក់កម្ចី ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០៩-២០១៤ ទៅតុលាការតែមួយ តុលាការអាចបញ្ចូលការទាមទារទាំងពីរនេះក្នុងសំណុំរឿងតែមួយបាន ។

ការបំបែក និងការរួមបញ្ចូលរឿងក្តី តុលាការត្រូវធ្វើដោយដីកាសម្រេច ( មាត្រា ៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ ដីកាសម្រេចនេះមិនអាចប្តឹងជំទាស់បានទេ ( មាត្រា ២៥៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## III-រឿងក្តីគំរូ

### ១_រឿងក្តីទាមទារប្រាក់ដោយផ្អែកលើកកិច្ចសន្យាខ្ចីបរិភោគ

លោក A និងលោក B ជាមិត្តជិតស្និតនឹងគ្នា ។ នៅថ្ងៃទី០១-០១-២០១៤ លោក A បានឱ្យលោក B ខ្ចីប្រាក់ចំនួន ១០ លានរៀល តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ ។ ថ្ងៃកំណត់សងនៅថ្ងៃទី០១-០៥-២០១៤ ។ ថ្ងៃកំណត់សងបានកន្លងផុតទៅ លោក A បានទៅទារប្រាក់ពីលោក B តែត្រូវបានលោក B ប្រកែកមិនព្រមបង់ ។ តាមរយៈការប្រកែកនេះ លោក A បានដាក់ពាក្យបណ្តឹងទៅតុលាការ ។

### ការរៀបចំការអះអាងរបស់ភាគី

| **ការអះអាងរបស់ដើមចោទ A** | **ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ B ចំពោះអង្គហេតុដែលA បានអះអាង** |
|---|---|
| -ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ រវាង A និង B<br>-Aបានប្រគល់ប្រាក់ ១០ លាន រៀល ទៅឱ្យលោក B ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤<br>-កាលបរិច្ឆេទសង បានមកដល់( អង្គហេតុជាក់ស្តែង) | -B បានសារភាពថា ខ្លួនពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ ជាមួយ A<br>-B បដិសេធថា ខ្លួនមិនទាន់បានទទួលប្រាក់កម្ចី ១០ លានរៀល ពី A |

## ចំណុចវិវាទ

ផ្អែកតាមការអះអាងខាងលើនេះ ចំណុចវិវាទនៃរឿងក្ដីនេះ គឺតើដើមចោទ A បានប្រគល់កម្ចីចំនួន ១០ លានរៀល ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០១-០១-២០១៤ ឱ្យទៅចុងចំលើយដែរឬទេ?

## ភស្តុតាង និងបន្ទុកទទួលខុសត្រូវក្នុងបញ្ជាក់ភស្តុតាង

ចំពោះចំណុចវិវាទខាងលើនេះ ដើមចោទ A ត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងថា ខ្លួនបានប្រគល់ប្រាក់កម្ចីចំនួន ១០លានរៀល ឱ្យទៅចុងចំលើយ ។ ភស្តុតាងដែលត្រូវយកមកបញ្ជាក់អាចជាវិក័យបត្រទទួលប្រាក់កម្ចី ឬសាក្សីដែលដឹងឮក្នុងការប្រគល់ប្រាក់កម្ចី ។

## ២-រឿងក្ដីទាមទារឱ្យប្រគល់អចលនវត្ថុដោយផ្អែកលើកម្មសិទ្ធិ

លោក A និងលោក B ជាមិត្តជិតស្និតនឹងគ្នា។ នៅថ្ងៃទី០១-០១-២០១៤ លោក B បានលក់ដីទំហំ ៣០ម គុណនឹង ៤០ម មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១១១១ ចុះថ្ងៃទី០១-០២-២០០៥ មានទីតាំងស្ថិតនៅភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទៅឱ្យលោក A ក្នុងតម្លៃ ១០ម៉ឺន ដុល្លាសហរដ្ឋអាមេរិក តាមកិច្ចសន្យាលក់ផ្ដាច់(ទម្រង់យថាភូត)ចុះថ្ងៃទី០១-០១-២០១៤ ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឱ្យលោក A ជាកម្មសិទ្ធិករ នៅថ្ងៃទី០១-០២-២០១៤ ។ នៅថ្ងៃទី០១-០៣-២០១៤ លោក B បានទៅកាន់កាប់ដីដែលបានលក់ឱ្យលោក A។ ដោយឃើញដូច្នេះ លោក A បានទៅសុំឱ្យលោក B ប្រគល់ដីមកឱ្យខ្លួនកាន់កាប់ តែត្រូវបានលោក B បដិសេធ ។ តាមរយៈការបដិសេធនេះ លោក A បានដាក់ពាក្យបណ្ដឹងទៅតុលាការ ។

## ការរៀបចំការអះអាងរបស់ភាគី

| ការអះអាងរបស់ដើមចោទ A | ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់B ចំពោះអង្គហេតុដែល A បានអះអាង |
|---|---|
| -A ជាកម្មសិទ្ធិករនៃដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ១១១១ ចុះថ្ងៃទី០១-០២-២០០៥ មានទីតាំងស្ថិត នៅភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>-B កាន់កាប់ដី ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១១១១ ចុះថ្ងៃទី០១-០២-២០០៥<br>**ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់A ចំពោះអង្គហេតុដែល B បានអះអាង**<br>-A បានបដិសេធថា មិនបានជួលដី និងប្រគល់ដីឱ្យទៅ B ទេ | - Bទទួលស្គាល់ថាដី គឺជាកម្មសិទ្ធិរបស់ A<br>- B ទទួលស្គាល់ថា ខ្លួនបានកាន់កាប់ដីរបស់ A<br>**ការអះអាងរបស់ចុងចំលើយ B**<br>-B អះអាងថា គាត់បានជួលដីពី A ដោយផ្អែកលើភតិសន្យា ចុះថ្ងៃទី០១-០៣-២០១៤ រហូតដល់ថ្ងៃទី ២៨-០២-២០១៥ រវាង លោក A និង B<br>-B អះអាងថា A បានប្រគល់ដីឱ្យទៅ B ដោយផ្អែកលើកិច្ចសន្យាជួលនៅថ្ងៃទី ០១-០៣-២០១៤ |

## ចំណុចវិវាទ

ផ្អែកតាមការអះអាងខាងលើនេះ ចំណុចវិវាទនៃរឿងក្តីនេះគឺ តើចុងចំលើយ B បានធ្វើភតិសន្យា ចុះថ្ងៃទី ០១-០៣-២០១៤ ជាមួយដើមចោទ A និងប្រគល់ដី ដែរឬទេ?

## ភស្តុតាង និងបន្ទុកទទួលខុសត្រូវក្នុងបញ្ជាក់ភស្តុតាង

ចំពោះចំណុចវិវាទខាងលើនេះ ចុងចំលើយ B ត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងថា ខ្លួនបានធ្វើភតិសន្យា ជាមួយដើមចោទ និងដើមចោទ ប្រគល់ដីឱ្យទៅ B ។ ភស្តុតាងដែលត្រូវយកមកបញ្ជាក់ គឺអត្ថិភាពនៃភតិកិច្ចសន្យា (លិខិតភតិកិច្ចសន្យា ឬសាក្សី ដែលដឹងឮអំពីការបង្កើតកិច្ចសន្យា) ។

## ៣-រឿងលែងលះ

លោក B និងអ្នកស្រី A ជាប្តីប្រពន្ធនឹងគ្នា( មានសំបុត្រអាពាហ៍ ពិពាហ៍) ។ ក្នុងការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធលោក B និងអ្នកស្រី A តែងតែមានទំនាស់ជាមួយគ្នា ។ ដោយការរស់នៅជាមួយគ្នាជាប្តីប្រពន្ធពុំចុះសម្រុងគ្នាយ៉ាងដូច្នេះ អ្នកស្រី A បានដាក់ពាក្យបណ្តឹងលែងលះទៅតុលាការ ។

### ការរៀបចំការអះអាងរបស់ភាគី

| ការអះអាងរបស់ដើមចោទ A | ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ B ចំពោះការអះអាងរបស់ A |
|---|---|
| -អ្នកស្រី A និងលោក B បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា<br>-លោក B បានវាយខ្លួនជាប្រចាំនៅពេលឈ្លោះប្រកែកគ្នា | -លោក Bសារភាពថា ខ្លួន និងអ្នកស្រី A បានរៀបអាពាហ៍ ពិពាហ៍នឹងគ្នា<br>-លោក B បដិសេធថា ខ្លួនមិនបានវាយដំអ្នកស្រី A ទេ |

### ចំណុចវិវាទ

ផ្អែកតាមការអះអាងខាងលើនេះ ចំណុចវិវាទនៃរឿងក្តីនេះ គឺតើចុងចំលើយ B បានវាយដំលើអ្នកស្រី A ជាប្រចាំពេលដែលដើមចោទ និងចុងចំលើយ ឈ្លោះប្រកែកគ្នា ដែរឬទេ ?

### ភស្តុតាង និងបន្ទុកទទួលខុសត្រូវក្នុងបញ្ជាក់ភស្តុតាង

ចំពោះចំណុចវិវាទខាងលើនេះ ដើមចោទ A ត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងថា ខ្លួនពិតជាត្រូវបានចុងចំលើយ B វាយដំពេលឈ្លោះប្រកែកគ្នាម្តងៗ។ ភស្តុតាងដែល ត្រូវយកមកបញ្ជាក់ អាចជាស្នាមរបួសដែលបន្សល់ទុកនៅនឹងខ្លួនដើមចោទ រូបថតដែលបញ្ជាក់ពីរបួសស្នាម ឬសាក្សីដែលដឹងឮពីការវាយដំ ។

# សិក្ខាសាលា
# ស្តីពី

# នីតិវិធីនៃរឿងក្តី
# រដ្ឋប្បវេណីដែលមិនមែន
# ជាបណ្តឹង

# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

**NON-LITIGATION CIVIL PROCEDURE**

ក្រុមការងារនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

1

## ការចូលជាធរមានអនុវត្តនៃច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

- ថ្ងៃទី ១០. ៧. ២០១០ ប្រកាសឱ្យប្រើ
- ថ្ងៃទី ២១. ១២. ២០១១ អនុវត្តនៅទូទាំងប្រទេស

☛ មាត្រា ៥៦ នីរម. "ច្បាប់នេះត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ។"

☛ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រកាសឱ្យប្រើនៅថ្ងៃទី ៣១.៥.២០១១ អនុវត្តនៅទូទាំងប្រទេសនៅថ្ងៃទី ២១.១២.២០១១ (ម.៨៤ ចអក) ។

☛ សេចក្តីជូនដំណឹងរបស់ក្រសួងយុត្តិធម៌លេខ ១០/ស្តីពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ។

2

## ទំហំនៃច្បាប់ស្តីពី
## នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

☛ សរុប ៥៦ មាត្រា ចែកជា ១០ ជំពូក

- ជំពូកទី ១ បទប្បញ្ញត្តិទូទៅ (មាត្រា ១-៣)
- ជំពូកទី ២ តុលាការ (មាត្រា ៤-១៤)
- ជំពូកទី ៣ ជនពាក់ព័ន្ធ (មាត្រា ១៥-២១)
- ជំពូកទី ៤ ប្រាក់ប្រដាប់ក្តី (មាត្រា ២២-២៥)
- ជំពូកទី ៥ ការវិនិច្ឆ័យ (មាត្រា ២៦-៣៤)
- ជំពូកទី ៦ ការសម្រេចសេចក្តី (មាត្រា ៣៥-៣៨)

3

- ជំពូកទី ៧ បណ្តឹងឧបាស្រ័យ (មាត្រា ៣៩-៤២)
- ជំពូកទី ៨ ការចាត់ចែងរក្សាការពារ (មាត្រា ៤៣-៤៩)
- ជំពូកទី ៩ បទប្បញ្ញត្តិពេសេសស្តីពីរឿងក្តីផ្សេងៗ(មាត្រា ៥០-៥៥)
- ជំពូកទី ១០ អវសានប្បញ្ញត្តិ (មាត្រា ៥៦)

## រចនាសម្ព័ន្ធនៃច្បាប់ស្តីពី
## នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

- ជំពូក ▶ ផ្នែក ▶ មាត្រា ▶ កថាខណ្ឌ ▶ វាក្យខណ្ឌ ▶ ចំណុច
- តារាងឧបសម្ព័ន្ធ

4

## ១. គោលបំណងនៃច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

☛ ធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ម.២) ។

▸ ចំពោះវិវាទទាក់ទងនឹងអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនិងកាតព្វកិច្ចដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ជាធម្មតាត្រូវសម្រេចសេចក្តីតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

↓ ប៉ុន្តែ

▸ ក្រៅពីបណ្តឹងរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណីបានចែងនូវចំណុចពាក់ព័ន្ធនឹងជីវភាពរវាងបុគ្គលឯកជនដែលគួរឲ្យរដ្ឋត្រូវធ្វើអន្តរាគមន៍ ដោយសារតែរដ្ឋមានលក្ខណៈដូចជាអាណាព្យាបាល ឬមានការចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ។

↓ ដូច្នេះ នីតិវិធីបែបនេះ

➡ ត្រូវសម្រេចតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ។

5

## ២. វិសាលភាពនៃច្បាប់នេះ

■ តើច្បាប់នេះអនុវត្តចំពោះរឿងក្តីបែបណា ?

☛ ច្បាប់នេះអនុវត្តចំពោះរឿងក្តី ដូចមានក្នុងចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗនៃតារាងឧបសម្ព័ន្ធ (ម.៣ ក.១) ។

☛ ក្នុងតារាងឧបសម្ព័ន្ធបានបែងចែកជា ៥ ផ្នែក ដែលផ្នែកនីមួយៗបានកំណត់អំពីចំណុចដែលត្រូវសម្រេចសេចក្តី ដោយបែងចែកទៅតាម គន្ថី នៃក្រមរដ្ឋប្បវេណី និងកំណត់អំពីតុលាការដែលមានសមត្ថកិច្ច ។

ឧ. ការប្រកាសអំពីការបាត់ខ្លួន យោងតាមមាត្រា ៥១ (មានកំណត់ក្នុងផ្នែកទី ១ ចំណុចទី ៩ )

ឧ. ការលែងលះដោយការព្រមព្រៀង យោងតាមមាត្រា ៩៧៩ (មានកំណត់ក្នុងផ្នែកទី ៤ ចំណុចទី ៥)

6

## ៣. សមត្ថកិច្ចសាលាជម្រះក្តី

☛ រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងឧបសម្ព័ន្ធ (ម.៤ ក.១) ។

☛ សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់ដោយយកពេលដាក់ពាក្យសុំ (ម.៤ ក.២) ។

☛ ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបានដោយសារច្បាប់ ឬហេតុការពិត ឬករណីដែលសមត្ថកិច្ចសាលាជម្រះក្តី មិនអាចកំណត់ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូល ត្រូវកំណត់តុលាការដែលមានសម្តកិច្ចដោយដីកាសម្រេច តាមពាក្យសុំ និងមិនអាចប្តឹងឧបាស្រ័យបាន (ម.៥) ។

☛ តុលាការដែលយល់ថា រឿងក្តីមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ ត្រូវបញ្ជូនរឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ (ម.៦) ។

7

☛ ក្នុងករណីមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្តីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្តីនោះត្រូវមានសមត្ថកិច្ច។

ប៉ុន្តែប្រសិនបើយល់ឃើញសមរម្យដើម្បីចាត់ចែងរឿងក្តី តុលាការអាចផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធ (ម.៧) ។

☛ តុលាការអាចពិនិត្យភស្តុតាង ចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចដោយឆន្ទានុសិទ្ធរបស់ខ្លួនបាន (ម.៨) ។

☛ ដីកាសម្រេចផ្ទេរ និងដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន (ម.៩) ។

☛ ដីកាសម្រេចផ្ទេរដែលចូលជាស្ថាពរ ត្រូវមានអានុភាពឲ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម (ម.១០ ក.១) ។

☛ តុលាការដែលទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានឡើយ (ម.១០ ក.២) ។

8

## ៤. រចនាសម្ព័ន្ធតុលាការ

☛ ជាគោលការណ៍ចៅក្រមម្នាក់ (ម.១១ ក.១)

☛ ករណីលើកលែង ចៅក្រម ៣ រូប (ក្រុមប្រឹក្សាជំនុំជម្រះ)

ក្នុងករណីដែលតុលាការយល់ឃើញថា គួរតែត្រូវបានវិនិច្ឆ័យ និងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយគិតពិចារណាអំពីចំនួនជនដែលពាក់ព័ន្ធ និងបញ្ហាផ្សេងទៀត (ម.១១ ក.២) ។

**ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ** (ម.១២-១៣)

- ត្រូវធ្វើជាអសាធារណៈ
- បានបើកនិងដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- ចៅក្រមម្នាក់ៗ ត្រូវបញ្ចេញយោបល់របស់ខ្លួនក្នុងការពិភាក្សា
- ដំណើរការពិភាក្សា យោបល់ចៅក្រម និងសម្លេងមតិត្រូវរក្សាសម្ងាត់
- ចៅក្រមម្នាក់ៗក្នុងក្រុមប្រឹក្សាជំនុំជម្រះមានសិទ្ធិសម្រេចស្មើគ្នា ហើយត្រូវសម្រេចតាមមតិភាគច្រើន ។

9

## ៥. ឈ្មោះភាគីនៅក្នុងនីតិវិធីផ្សេងៗ

☛ ជនដែលពាក់ព័ន្ធនៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងគឺ ៖

**អ្នកដាក់ពាក្យសុំ / ភាគីម្ខាងទៀត** (ម.១៥,២៧,២៩...)

☛ ភាគីនៅក្នុងនីតិវិធីជម្រះក្តីលើកទី១ គឺ ៖

**ដើមចោទ / ចុងចម្លើយ**

☛ ភាគីនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ គឺ ៖

**ម្ចាស់បំណុល / កូនបំណុល**

☛ ភាគីនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ គឺ ៖ (ម.៣៤៧ កនីរ)

**ម្ចាស់បំណុលនៃការអនុវត្ត / កូនបំណុលនៃការអនុវត្ត**

10

## ▫ ៦. សមត្ថភាពក្នុងការធ្វើសកម្មភាពនីតិវិធី (ម.១៧)

☛ បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯង អាចតាំងខ្លួនជាជនពាក់ព័ន្ធនៅក្នុងនីតិវិធីបាន ។

☛ អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ ត្រូវធ្វើសកម្មភាពនីតិវិធីដោយអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងតែ ៖

- ▸ អនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យ ។
- ▸ អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅធ្វើសកម្មភាពពាក់ព័ន្ធនឹងឋានៈរបស់ខ្លួន ។

ឧ. មាត្រា ៩៦៨ ករណី (ការចាត់ទុកជានីតិជនដោយអាពាហ៍ពិពាហ៍)

➡ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយអាចធ្វើសកម្មភាពដោយឯករាជ្យ បាន ។

ឧ. មាត្រា ៩៥៣ ក.៣ ករណី (ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន)

➡ ពាក្យសុំសេចក្ដីសម្រេចពីតុលាការជំនួសការយល់ព្រមចំពោះការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន អាចធ្វើដោយឯករាជ្យបាន ។

11

## ■ អ្នកតំណាងដោយអាណត្តិក្នុងរឿងក្ដីមិនមែនបណ្ដឹង (ម.១៨)

☛ ជនពាក់ព័ន្ធអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីទាំងអស់ ដោយខ្លួនឯងផ្ទាល់ ឬតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនជ្រើសតាំង ។

☛ អ្នកតំណាងដោយអាណត្តិត្រូវតែជា ៖ (ម.១៩)

១. មេធាវី

២. ជនដែលទទួលការអនុញ្ញាតពីតុលាការ

✯ រឿងក្ដីមិនមែនបណ្ដឹងខុសគ្នានឹងរឿងក្ដីជាបណ្ដឹង ដែលរឿងក្ដីមិនមែនជាបណ្ដឹង តុលាការចូលរួម មានលក្ខណៈដូចជា អាណាព្យាបាល ដោយឆន្ទានុសិទ្ធិ និងមានករណីច្រើនដែលជនពាក់ព័ន្ធមិនចាំបាច់មានចំណេះដឹងច្រើនអំពីច្បាប់ និងបទពិសោធន៍ច្រើនដូចរឿងក្ដីជាបណ្ដឹង

➡ អ្នកតំណាងដោយអាណត្តិអាចមិនមែនជាមេធាវី ។

12

■ **អ្នកតំណាងដោយអាណត្តិក្នុងរឿងក្តីបណ្តឹង**

☛ អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីបណ្តឹង ត្រូវតែជាមេធាវី ។ លើកលែងតែ ចំណុច កខគ កថាខណ្ឌទី ១ មាត្រា ៥៣ ក្រមនីតិវិធីរដ្ឋប្បវេណី ។

■ **អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីចាត់ចែងរក្សាការពារ**

☛ ជាគោលការណ៍ អ្នកតំណាងដោយអាណត្តិ ក្នុងនីតិវិធីចាត់ចែងរក្សាការពារ ត្រូវតែជាមេធាវី (ម.៥៣ ដែលស្ថិតក្នុងគន្ថីទី ១ បទប្បញ្ញត្តិទូទៅ) ។

■ **អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីអនុវត្តដោយបង្ខំ**

☛ ជាគោលការណ៍អ្នកតំណាងដោយអាណត្តិ នៅក្នុងនីតិវិធីបណ្តឹង ឬបណ្តឹងជំទាស់ ត្រូវតែជាមេធាវី (ម.៣៤៨ ក.១.ក) ។

13

## ៧. **ប្រាក់ប្រដាប់ក្តី** (ម.២២)

☛ ដើម្បីដាក់ពាក្យសុំតាមនីតិវិធីមិនមែនបណ្តឹងត្រូវបង់ពន្ធ ៥០០០ រៀល

☛ ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ (ម.៦២) និងប្រាក់ប្រដាប់ក្តីភាគី (ម.៦៣) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវអនុវត្តនៅក្នុងរឿងក្តីមិនមែនជាបណ្តឹង ។

☛ ប្រាក់ប្រដាប់ក្តីខាងលើជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

☛ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់រដ្ឋ ក្នុងករណីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬតុលាការបានចាប់ផ្តើមនីតិវិធីដោយឆន្ទានុសិទ្ធិ ។

✯ ក្នុងនីតិវិធីបណ្តឹង ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់ភាគីចាញក្តី ។
(ម.៦៤ ក.១ កនីវិ)

14

## ៨. ការវិនិច្ឆ័យ

**ក**). របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ (ម.២៦)

☛ ពាក្យសុំអាចជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ។

☛ ពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម ៖

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និងឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ. ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ។

☛ ពាក្យសុំដោយផ្ទាល់មាត់ ត្រូវធ្វើក្នុងកំណត់ហេតុដោយក្រឡាបញ្ជី ។

☛ បើមានឯកសារជាភស្តុតាង ត្រូវភ្ជាប់ឯកសារដើម ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ទៅតុលាការនៅពេលដាក់ពាក្យសុំ ។

15

**ខ**). ការស្រាវជ្រាវនិងពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ (ម.២៧)

☛តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

☛ បើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និងធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

✯ នីតិវិធីមិនមែនបណ្តឹងមិនឈរលើ គោលការណ៍ភាគី ទេ គឺឈរលើគោលការណ៍ឆន្ទានុសិទ្ធិ ។

✯ ផ្ទុយពីនីតិវិធីបណ្តឹងដែលត្រូវគោរពគោលការណ៍ភាគី ។ (ម. ៩៥ និង ម.១២៤ កនីវិ)

✯ ការដែលមាត្រា ២៧ ជ្រើសយកគោលការណ៍ផ្សេងពីគោលការណ៍នៃក្រមនីតិវិធីរដ្ឋប្បវេណីដោយហេតុថា រឿងក្តីដែលបានកំណត់នៅក្នុងច្បាប់នេះជាទូទៅ ទាក់ទងនឹងផលប្រយោជន៍សាធារណៈយ៉ាងខ្លាំងផង ហើយចាំបាច់ក្នុងការស្វែងរកការពិតផងដែរ ។

16

**ឌ**). ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ (ម.២៨)

☛ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុ ផលដោយផ្ទាល់មាត់ឡើយ។

☛ ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាច សួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលយល់ឃើញថា ចាំបាច់បាន ។ ក្នុងករណីនេះតុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

✯ ការពិនិត្យភស្តុតាងអាចធ្វើនៅក្នុងបន្ទប់ជាអសាធារណៈ ។

✯ ការដែលមាត្រា ២៨ ជ្រើសយកគោលការណ៍នេះដោយហេតុថា រឿងក្តីដែលបានកំណត់នៅក្នុងច្បាប់នេះ ភាគច្រើនជារឿងក្តីដែលចាំបាច់ត្រូវរក្សាការសម្ងាត់ផ្ទាល់ខ្លួនយ៉ាងខ្លាំង ឬរឿងក្តីដែលមិនសូវចាំបាច់ចំពោះមុខនោះទេ ។

17

**ឍ**). ការចូលរួមរបស់តំណាងអយ្យការ (ម.៣០)

☛ បើយល់ឃើញថាចាំបាច់ត្រូការពារ ផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅអយ្យការអំពីរឿងក្តី និងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬក្នុងកាលបរិច្ឆេទនៃការសាកសួរ ។

☛ បើយល់ឃើញថា ចាំបាច់ការពារផលប្រយោជន៍សាធារណៈ តំណាងអយ្យការអាចបញ្ចេញមតិចំពោះរឿងក្តី និងចូលរួមក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬក្នុងកាលបរិច្ឆេទនៃការសាកសួរ ។

✯ ពាក្យ "ផលប្រយោជន៍សាធារណៈ" អាចនិយាយថាជា "ផលប្រយោជន៍សង្គមទាំងមូល" ។ ពាក្យថា "ផលប្រយោជន៍សាធារណៈ" ផ្ទុយនឹងពាក្យ "ផលប្រយោជន៍ ឯកជន" ។

18

ខ). ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍ (ម.៣១)
☛ បើយល់ឃើញថាសមរម្យតុលាការអាចឲ្យជនក្រៅពីអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀតក្នុងចំណោមជនពាក់ព័ន្ធចូលរួមក្នុងនីតិវិធីបានដោយមានការអនុញ្ញាត ពីតុលាការ ។

ឆ). ការទទួលបន្តនូវនីតិវិធី (ម.៣២)
☛ បើអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀតមិនអាចបន្តនីតិវិធីដោយសារមរណភាព ការបាត់បង់លក្ខណសម្បត្តិ ឬ មូលហេតុផ្សេងទៀត ជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំ អាចដាក់ពាក្យសុំទទួលបន្តនូវនីតិវិធីបាន ។

ឆ). ការមើលសំណុំរឿង ជាអាទ៍ (ម.៣៣)
☛ បើយល់ឃើញថាសមរម្យ តុលាការអាចបង្គាប់ឲ្យក្រឡាបញ្ជី ថតសំណុំរឿង ឬប្រគល់ឯកសារសម្លងយថាភូត ជាអាទ៍ តាមពាក្យសុំរបស់ជនដែលពាក់ព័ន្ធដោយឲ្យបង់សោហ៊ុយ ។

19

ជ). ការអនុវត្តដូចគ្នាតាមក្រមនីតិវិធីរដ្ឋប្បវេណី (ម.៣៤)

☛ បញ្ញាត្តិស្តីពីកាបរិច្ឆេទ អំឡុងពេល វិធីធ្វើសេចក្តីបញ្ជាក់ដំបូងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង លើកលែងតែមានភាពផ្ទុយគ្នា នឹងលក្ខណៈនៃនីតិវិធីមិនមែនបណ្តឹង ។

☛ បញ្ញត្តិស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ការសាកសួរសាក្សី ការសាកសួរភាគី កោសលវិច័យ ការត្រួតពិនិត្យ និងភស្តុតាងជាឯកសារ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងនីតិវិធីមិនមែនជាបណ្តឹង លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីមិនមែនជាបណ្តឹង ។

20

## ៩. ការសម្រេចសេចក្តី

**ក**). វិធីសម្រេចសេចក្តី

☛ ការសម្រេចសេចក្តី នៅក្នុងនីតិវិធីរឿងក្តីមិនមែនជាបណ្តឹង ត្រូវធ្វើឡើងដោយដីកាសម្រេច (ម.៣ ក.២) ។

☛ ការសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ (ម.៣៥)

☛ ចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងដីកាសម្រេច ៖

① សំអាងហេតុ

② សេចក្តីសម្រេចបញ្ចប់

③ ហត្ថលេខារបស់ចៅក្រម

**ខ**). ការជូនដំណឹងអំពីដីកាសម្រេច (ម.៣៦)

☛ ដីកាសម្រេចត្រូវជូនដំណឹងទៅជនដែលទទួលដីកាសម្រេចនេះ ។

☛ ការជូនដំណឹងត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ ។

21

**គ**). ការចូលជាស្ថាពរ និងការបង្កើតអានុភាពនៃដីកាសម្រេច (ម.៣៧)

☛ ដីកាសម្រេច មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេល សម្រាប់ការប្តឹងជំទាស់ ២ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ (ម.៣៧) ។

☛ ការចូលជាស្ថាពរនៃដីកាសម្រេចត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ដែលធ្វើឡើងនៅក្នុងកាលបរិច្ឆេទសម្រាប់ប្តឹងជំទាស់ ។

☛ ដីកាសម្រេច មិនត្រូវមានអានុភាពឡើយបើមិនទាន់ចូលជាស្ថាពរទេ ។

**ឃ**). អានុភាពនៃដីកាសម្រេច (ម.៣៨)

☛ ដីកាសម្រេច បង្គាប់ឲ្យបង់ប្រាក់ ប្រគល់វត្ថុ អនុវត្តករណីកិច្ចចុះបញ្ជីឬផ្តល់តាវកាលិកផ្សេងទៀតដែលចូលជាស្ថាពរត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

22

## ១០. បណ្តឹងឧបាស្រ័យ

☛ បណ្តឹងឧបាស្រ័យ ជាបណ្តឹងរបស់ភាគី ដែលពុំយល់ស្របនឹងសេចក្តីសម្រេចណាមួយ (ដីកាសម្រេច,សាលក្រម,សាលដីកា) របស់ចៅក្រម ឬតុលាការដើម្បីទាមទារឲ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម ។

**ក**). បណ្តឹងជំទាស់ក្នុងនីតិវិធីមិនមែនបណ្តឹង

☛ បុគ្គលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេច អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់មិនមែនជាបណ្តឹង (ម.៣៩ ក.១) ។

☛ ក្នុងករណីដែលចេញដីកាសម្រេច តាមតែពាក្យសុំប៉ុណ្ណោះ មានតែជនដែលដាក់ពាក្យសុំទេ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលបាន (ម.៣៩ ក.២) ។

23

☛ បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុង ២ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីដីកាសម្រេច (ម.៤០) ។

**ខ**). នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ (ម.៤២)

☛ ក្រៅពីបញ្ញត្តិនៃជំពូកទី ៥ (ការវិនិច្ឆ័យ) នៃច្បាប់មិនមែនបណ្តឹង បញ្ញត្តិនៃជំពូកទី ៤ (បណ្តឹងជំទាស់) គន្លឹទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការ ជាន់ខ្ពស់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងជំពូកទី ៧ នៃច្បាប់មិនមែនជាបណ្តឹង ។

24




25

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ**១៣៣** "**ច**"

# ដីកាសម្រេច

យើង **សេខ នាខ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានឃើញមាត្រា ៩៧៩មាត្រា ១០៣៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ៨៦ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១៤ ដែលមាន៖

## អ្នកដាក់ពាក្យសុំ

ឈ្មោះ **កសជ** ភេទស្រី កើតថ្ងៃទី ១៤ ខែឧសភា ឆ្នាំ១៩៧៣ សញ្ជាតិខ្មែរ ទីលំនៅ បច្ចុប្បន្ន ផ្ទះលេខ១៣៧C ផ្លូវលេខ ៥៣BT សង្កាត់បឹងទំពន់ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី **គមស** ការិយាល័យមេធាវី **ក្រុមមេធាវីកម្ពុជា**ស្ថិតនៅអគារលេខ១៥៩-១៦០ ផ្លូវលេខ១១៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

## ភាគីម្ខាងទៀត

ឈ្មោះ **កណរ** ភេទប្រុសកើតថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៧២ សញ្ជាតិខ្មែរទីលំនៅបច្ចុប្បន្ន ផ្ទះលេខ១៣៧C ផ្លូវលេខ ៥៣BT សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## ការទាមទាររបស់អ្នកដាក់ពាក្យសុំ ៖

សុំដីកាសម្រេចលែងលះពីឈ្មោះ កណរ តាមកិច្ចព្រមព្រៀងលែងលះ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីសាកសួរឃើញថា ៖

១. ឈ្មោះ **កសជ** និងឈ្មោះ **កណរ** ពិតជាបានរៀបការ និងចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចមានក្នុងសេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍លេខ ៤៧ ឃ.ដ.ត ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៥ប្រាកដមែន ។

២. ក្រោយពេលរៀបអាពាហ៍ពិពាហ៍ គឺពិតជារស់នៅមិនចុះសម្រុងនឹងគ្នា ដែលធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាមួយគ្នាប្រាកដមែន។ ម្យ៉ាងទៀត បើពិនិត្យលើកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៤ និងការអះអាងរបស់គូភាគី បញ្ជាក់ថា ភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ ពិពាហ៍ប្រាកដមែន។

៣. ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍គូភាគីមានកូនបីនាក់មានឈ្មោះ **រសម** ភេទស្រី កើតថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ឈ្មោះ **រសយ** ភេទស្រី កើតថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ និងឈ្មោះ **រជឆ**ភេទប្រុស កើតថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ គូភាគីបានព្រមព្រៀងគ្នាកំណត់យកឪពុកឈ្មោះ **ភឈរ** ជាអ្នកមានអំណាចមេបាលើកូនទាំងបីនាក់។

៤. អ្នកដាក់ពាក្យសុំត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីតាមមាត្រា ២២ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

**១**. ឲ្យអ្នកដាក់ពាក្យសុំឈ្មោះ **ភសជ** ដែលមានអំណាចមេបាលើកូនឈ្មោះឈ្មោះ **រសម** ភេទស្រី កើតថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ឈ្មោះ **រសយ** ភេទស្រី កើតថ្ងៃ ទី២១ ខែធ្នូ ឆ្នាំ១៩៩៩ និងឈ្មោះ **រជឆ** ភេទប្រុស កើតថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ តាមការព្រមព្រៀងរបស់គូភាគី និងភាគីម្ខាងទៀតឈ្មោះ **ភឈរ** លែងលះគ្នា។ តាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

**២**. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៤

**ចៅក្រម**

ហត្ថលេខា និងត្រា **សេខ នាខ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៤

**ចៅក្រម**

**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ..........................តរ.

# ដីកាសម្រេច

យើង **សេខ នាខ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញមាត្រា៣ និងមាត្រាពាក់ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
- បានឃើញមាត្រា ១០៣៩ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី
- បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ១៩៩០ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣ ដែលមាន ៖

**អ្នកដាក់ពាក្យសុំ**

១. ឈ្មោះ **ចសត** ភេទប្រុស កើតថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៩៧៨ សញ្ជាតិខ្មែរ មានទី លំនៅបច្ចុប្បន្នផ្ទះលេខ០៦ ផ្លូវលេខ៥៨០ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

២. ឈ្មោះ **ចសប** ភេទស្រី កើតថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៧៧ សញ្ជាតិខ្មែរ មានទីលំនៅ បច្ចុប្បន្ន ផ្លូវលំ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី **ពសយ** មានការិយាល័យផ្ទះលេខ អឺ២-១០ ផ្លូវ លេខ ២៨៩ កែង៥១៦ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**អនីតិជន**

១. ឈ្មោះ **ចសបអ** ភេទស្រី កើតថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្លូវលំ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សុំឱ្យតុលាការចេញដីកាសម្រេច ៖**

ផ្លាស់ប្តូរអំណាចមេបាលើកូនឈ្មោះ **ចសបអ** ភេទស្រី កើតថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣ ពីឈ្មោះ **ចសប** ដែលត្រូវជាម្តាយបង្កើតមកឲ្យឈ្មោះ **ចសត** ត្រូវជា ឪពុកបង្កើតជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាតាមការព្រមព្រៀង ។

## សំអាងហេតុ

១. តាមពាក្យសុំរបស់ឈ្មោះ **ចសត** បានអះអាងថា កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០ សាលាដំបូងរាជធានីភ្នំពេញ បានចេញសាលក្រមលេខ ៥៥ "ឈ" ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០ ដែលមានខ្លឹមសារត្រង់ចំណុចទី៤ ប្រគល់កូនឈ្មោះ **ចសបអ** ភេទស្រី កើត ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៣ ឲ្យទៅឈ្មោះ **ចសប** គ្រប់គ្រងថែរក្សាតាមការព្រមព្រៀងរបស់ គូភាគី ។ ចាប់តាំងពីទទួល

បានពីការសម្រេចរបស់តុលាការរួចមក កូនរបស់ខ្លួនឈ្មោះ **ចសបអ** គឺពុំដែលបានរស់នៅជាមួយម្តាយឈ្មោះ **ចសប** ទេ កូននេះភាគច្រើនរស់នៅជា មួយខ្លួនច្រើនជាងម្តាយ ពីព្រោះម្តាយពុំសូវមានជីវភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់កូនទេ ។ ដោយឃើញ ស្ថានភាពគ្រួសាររបស់ឈ្មោះ **ចសប** ជួបការលំបាកក្នុងការផ្គត់ផ្គង់កូនស្រី លើការសិក្សា និងរស់នៅទើបឈ្មោះ **ចសប** សម្រេចចិត្តប្រគល់កូនឈ្មោះ **ចសបអ** ភេទស្រី កើតថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៣ មកឲ្យខ្លួនជាឪពុកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាវិញ តាមការព្រមព្រៀងចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៣ ដោយមានលោកមេធាវី **ពសឃ** ជាអ្នកបញ្ជាក់លើឯកសារកិច្ចព្រមព្រៀងនេះ ។

២. តាមការអះអាងរបស់ឈ្មោះ **ចសប** បានបញ្ជាក់ថា ពាក្យសុំផ្លាសប្តូរអំណាចមេបា របស់អ្នកដាក់ពាក្យសុំដូចមានភ្ជាប់មកជាមួយ មូលហេតុក្នុងពាក្យសុំ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ខ្លួនយល់ព្រមដោយស្ម័គ្រចិត្តដោយពុំមានការបង្ខិតបង្ខំទេ ។ មូលហេតុសំខាន់ដែលខ្លួនយល់ ព្រមប្រគល់អំណាចមេបាទៅឲ្យឈ្មោះ **ចសត** ដោយសារខ្លួនពុំមានលទ្ធភាពថែរក្សាកូនឲ្យបានល្អដូចលោក**ចសត** ឡើយ ។

៣. តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ៥៤៨ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤ បញ្ជាក់ថាឈ្មោះ **ចសត** និងឈ្មោះ **ចសប** គឺជាឪពុកម្តាយបង្កើតរបស់ឈ្មោះ **ចសបអ** ប្រាកដមែន ។

៤. តាមសាលក្រមលេខ ៥៥ "ឈ" ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០ បានបញ្ជាក់ថា ឈ្មោះ **ចសត** និងឈ្មោះ **ចសប** ពិតជាបានផ្តាច់សមគ្គសង្វាសពីគ្នាតាមការព្រមព្រៀងគ្នា ហើយតុលាការបានសម្រេចប្រគល់កូនឈ្មោះ **ចសបអ** ឲ្យម្តាយឈ្មោះ **ចសប** ជាអ្នកគ្រប់គ្រង ។

៥. តាមកិច្ចព្រមព្រៀងស្តីពីការប្រគល់កូនឲ្យទៅប្តីចិញ្ចឹមថែរក្សា និងគ្រប់គ្រង ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៣ បញ្ជាក់ថា ឈ្មោះ **ចសប** ជាម្តាយសុខចិត្តប្រគល់កូនស្រីឈ្មោះ **ចសបអ** ភេទស្រី កើតថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣ ឲ្យទៅឈ្មោះ **ចសត** ជាឪពុកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា ។

៦. តាមមាត្រា ១០៣៩ នៃក្រមរដ្ឋប្បវេណី តុលាការអាចផ្លាស់ប្តូរអ្នកដែលមានអំណាចមេបាតាមការទាមទាររបស់ញាតិរបស់កូនបាន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ។

៧. តាមពាក្យសុំរបស់ឈ្មោះ **ចសត** ដែលជាឪពុក និងតាមការអះអាងរបស់ឈ្មោះ **ចសប** ដែលជាម្តាយបញ្ជាក់ថាការផ្លាស់ប្តូរអំណាចមេបាលើកូនឈ្មោះ**ចសបអ** ឲ្យទៅឈ្មោះ **ចសត** គឺជាការចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ។

៨. ដោយផ្អែកតាមហេតុផលដូចមានក្នុងសំអាងហេតុខាងលើ និងដើម្បីផលប្រយោជន៍របស់កូនឈ្មោះ **ចសបអ** ដូច្នេះគប្បីតុលាការសម្រេចផ្លាស់ប្តូរអំណាចមេបាលើកូនឈ្មោះ **ចសបអ** ភេទស្រី កើតថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣ ពីឈ្មោះ **ចសប** ភេទស្រី កើតថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៧៧ ទៅឲ្យឈ្មោះ **ចសត** ភេទប្រុស កើតថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៩៧៨ វិញតាមការព្រមព្រៀងតាមការព្រមព្រៀង។

៩. ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាណ្តឹង ។

## សេចក្ដីសម្រេចបញ្ចប់

**១**. ផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបាលើកូនឈ្មោះ **ចសចអ** ភេទស្រី កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០០៣ ពីឈ្មោះ **ចសប** ភេទស្រី កើតថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៧៧ ទៅឲ្យឈ្មោះ **ចសត** ភេទប្រុស កើតថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៩៧៨ វិញតាមការព្រមព្រៀង។

**២**. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣
**ចៅក្រម**
ហត្ថលេខា និងត្រា **សេខ នាខ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣
**ក្រឡាបញ្ជី**

បានឃើញ
**ចៅក្រម**

# សិក្ខាសាលា
# ស្តីពី

# ការរៀបចំផៀបនីតិវិធី
# បណ្តឹងទាក់ទងនឹង
# បាន:បុគ្គល និង
# នីតិវិធីរដ្ឋប្បវេណី

## ការប្រៀបធៀប
## នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង
## នីតិវិធីរដ្ឋប្បវេណី

1

សេចក្តីផ្តើម

១-សមត្ថកិច្ចតុលាការ

២-ភាគីក្នុងរឿងក្តី

៣-សវនាការជាអសាធារណៈ

៤-វិធានក្នុងការពិនិត្យភស្តុតាង

៥-វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម

2

# សេចក្តីផ្តើម

- ជាច្បាប់បញ្ញត្តនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី
- អ្វីជាបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ?
- ជាប្រភេទរឿងដែលពាក់ពន្ធ័នឹងជីវិតឯកជនរបស់ពួកគេ
- មានការពាក់ពន្ធ័នឹងផលប្រយោជន៍សាធារណៈ
- មានលក្ខណៈពិសេសមួយចំនួនៈ
  - ការកំណត់យកគោលការណ៍នៃការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ
  - ការពង្រីកអានុភាពនៃសាលក្រមដែលចូលជាស្ថាពរដល់តតិយជន
  - ការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ

3

## រឿងក្តីដែលស្ថិតនៅក្រោមច្បាប់នេះ (យោងបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី )

- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ (មាត្រា៩៥៨)
- បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ ( មាត្រា ៩៥៩-៩៦៣)
- បណ្តឹងទាមទារលែងលះគ្នា ( មាត្រា ៩៧៨)
- បណ្តឹងបដិសេធបិតុភាព ( មាត្រា ៩៩០-៩៩១)
- បណ្តឹងទាមទារឱ្យទទួលស្គាល់ ( មាត្រា១០០១ )
- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ( មាត្រា១០០២)
- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមាតុភាព( មាត្រា ១០០៤-១០០៥)
- បណ្តឹងទាមទារកាត់កាល់ ( មាត្រា ១០១៦ និងមាត្រា ១០៣១)
- បណ្តឹងផ្សេងទៀតដែលមានបំណងបង្កើតទំនាក់ទំនងឋានៈបុគ្គល

4

## ១_សមត្ថកិច្ចតុលាការ(មាត្រា៥)

- សមត្ថកិច្ចផ្ដាច់មុខ និងសមត្ថកិច្ចមិនផ្ដាច់មុខ
- **សមត្ថកិច្ចផ្ដាច់មុខ**របស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋាន របស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬ លំនៅឋាននាពេល ដែលភាគីនោះទទួលមរណភាព( ម.៥កថាខណ្ឌ១)
- ក្នុងករណីដែលមិនអាចកំណត់តុលាការមានសមត្ថកិច្ចបាន : សាលាដំបូងរាជធានីជាតុលាការមានសមត្ថកិច្ច( ម.៥កថាខណ្ឌ៣)
- ករណីត្រូវផ្ទេរបណ្ដឹងចៀសវាងការយឺតយ៉ាវ( មាត្រា៦)

5

## ២_ភាគី(មាត្រា៧_៩ និបឋ)

- សមត្ថភាពក្នុងការធ្វើបណ្ដឹង : ច្បាប់ទទួលស្គាល់សិទ្ធិធ្វើបណ្ដឹងរបស់អសមត្ថជន ដោយមិនអនុវត្តតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមួយចំនួន (មាត្រា៨) ដោយសម្របសម្រួលឱ្យមានជំនួយផ្នែកច្បាប់ចូលជួយភាគីនោះ
- ចុងចម្លើយត្រូវបានកំណត់រួចជាស្រេច យោងតាមមាត្រា៧:
  - ភាគីម្ខាងទៀតនៃទំនាក់ទំនងឋានៈបុគ្គល( ម.៧ កថាខណ្ឌ១)
  - ភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គល( ម.៧ កថាខណ្ឌ២)
  - បើចុងចម្លើយខាងលើបានទទួលមរណភាព : តំណាងអយ្យការត្រូវក្លាយជាចុងចម្លើយ( ម.៧ កថាខណ្ឌ៣) ។ ចំណុចនេះបានចែងខុសពីក្រមនីតិវិធីរដ្ឋប្បវេណីដែលកំណត់ថា បើចុងចម្លើយទទួលមរណភាព ត្រូវស្វែងរកសន្តតិជនមកបន្ត នីតិវិធី ( មាត្រា ១៧៣-២ ចំណុច ក) ឬជ្រើសរើសតំណាងថ្មី( មាត្រា១៧៣-២ ចំណុច ង)

6

■ មរណភាពរបស់ដើមចោទ : បណ្តឹងនោះត្រូវចប់ដោយស្វ័យប្រវត្តិ (ម.១៩)

■ មរណភាពរបស់ចុងចម្លើយ (ម.២០) :

- ក្នុងករណីដែលភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គលជាចុងចម្លើយ
- បើចុងចម្លើយទាំងអស់ទទួលមរណភាព
- ក្នុងរឿងលែងលះ និងកាត់កាល់ : ចប់ដោយស្វយ័ប្រវត្តិ

7

## ៣.ការជំនុំជម្រះជាអសាធារណៈ(ម.១៦)

■ ក្នុងនីតិវិធីរដ្ឋប្បវេណី ជាគោលការណ៍ ការជំនុំជម្រះត្រូវធ្វើជាសាធារណៈ ហើយករណីណីពិសេស អាចធ្វើជាអសាធារណៈ (មាត្រា១១៥នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ផ្ទុយទៅវិញ ក្នុងនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាគោលការណ៍ ត្រូវធ្វើជាអសាធារណៈ ដោយសារ :

- កម្មវត្ថុនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មានចំណុចជាច្រើនដែលពាក់ព័ន្ធជិតស្និទ្ធទៅនឹងការសម្ងាត់នៃជីវភាពរស់នៅរបស់បុគ្គលឯកជន
- ការជំនុំជម្រះជាសាធារណៈ អាចនាំឱ្យគូភាគីមានការរអារក្នុងការអះអាង
- ការបារម្ភថាអាចមានការរង្គោះរង្គើរដល់សណ្តាប់ធ្នាប់

■ ក្នុងកាលៈទេសៈពិសេស តុលាការអាច ធ្វើជាសាធារណៈ

8

## ៤_វិធានក្នុងការពិនិត្យភស្តុតាង(មាត្រា១៣_១៥)

- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ( មាត្រា១៤)
  - តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគី មកធ្វើជាមូលដ្ឋាននៃសាលក្រមបាន (មាត្រា១៤ នីបឋ)ដែលផ្ទុយនឹងមាត្រា៩៥នៃក្រមនីតិវិធីរដ្ឋប្បវេណី។
  - តុលាការត្រូវសួរមតិពីភាគី ចំពោះអង្គហេតុដែលខ្លួនបានស្រាវជ្រាវ
- ការសាកសួរសាមីភាគី ( មាត្រា១៥ នីបឋ)
  - តុលាការអាចបង្គាប់ឱ្យនាំខ្លួន ( មាត្រា១៥ កថាខណ្ឌ២ នីបឋ)
  - តុលាការអាចពិន័យមិនលើសពី១លានរៀល

9

- បញ្ញត្តិមិនអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី( មាត្រា១៣ នីបឋ) :
  - មាត្រា ៩៤ ( ការលើកចោលមធ្យោបាយដែលបានដាក់យឺតយ៉ាវ )
  - មាត្រា ៩៦ កថាខណ្ឌទី១ ( ការចាត់ទុកថាបានសារភាព)
  - មាត្រា ១៤០ កថាខណ្ឌទី២ ( ការសាកសួរសាមីភាគី)
  - មាត្រា ១៥៣ ( ករណីភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ )
  - មាត្រា ១៥៦ កថាខណ្ឌទី៤ ( ប្រៀបធៀបអក្សរដែលសរសេរដោយដៃ)
  - មាត្រា ២០០ ( សាលក្រមកំបាំងមុខដើមចោទ)
  - មាត្រា ២០១ កថាខណ្ឌទី២ ( សាលក្រមកំបាំងមុខចុងចម្លើយ)
  - គោលការណ៏សម្រេចសេចក្តីដោយភស្តុតាង ( មាត្រា ១២៣ កថាខ័ណ្ឌទី២)
  - មាត្រា ២២០ ដល់មាត្រា ២២២ ។

10

**៥_វិសាលភាពនៃបុគ្គលដែលទទួលអានុភាពនៃសាលក្រម(មាត្រា១៧)**

- នៅក្នុងរឿងក្តីធម្មតា: ជាគោលការណ៍ សាលក្រមស្ថាពរមានអានុភាពចំពោះតែភាគីប៉ុណ្ណោះ ( មាត្រា១៩៨ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី)
- ចំពោះរឿងក្តីទាក់ទងនឹងឋានៈបុគ្គល : មាត្រា១៧ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលចែងថា "*សាលក្រម ឬសាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានអានុភាពចំពោះតតិយជនដែរ*"។

11

## ឧទាហរណ៍ចំពោះរឿងក្តី ដែលអនុវត្តតាម
## ច្បាប់ស្តីពីនីតិវិធីបណ្តឹង ទាក់ទងនឹងឋានៈបុគ្គល

សូមលើកជាឧទាហរណ៍ចំពោះប្រភេទនៃសំណុំរឿងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានចែងក្នុងមាត្រា ០៣ នៃច្បាប់នេះ ដូចខាងក្រោម(ទៅតាមលេខលំដាប់នៅក្នុងមាត្រា៣)

**ក.** បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

**ឧ.** បុរស A និងនារី B មានបំណងក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ។ ប៉ុន្តែក្រោយមកបុរស A ក៏បានបាត់ខ្លួនដោយមូលហេតុណាមួយ ហើយនារី B មិនបានដឹងអំពីព័ត៌មាននេះទេ ។ បន្ទាប់មកទៀត ដោយមានការច្រឡំស្មានថាបុរស C ដែលជាបងប្អូនភ្លោះជាមួយនឹងបុរស A នារី B ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរស C ។ ដោយយោងលើមូលហេតុការភាន់ច្រឡំលើមនុស្ស នារី B អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ជាបុរស C បាន។ ។

**ខ.** បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាម) នៃក្រមរដ្ឋប្បវេណី ។

**ឧ.** បុរស A មានអាយុ២១ឆ្នាំ បានស្តីដណ្តឹងនារី B ដែលមានអាយុទើបតែ ១៨ឆ្នាំ ហើយដោយមានការឯកភាពគ្នាពីចាស់ទុំ អ្នកទាំងពីរបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា ។ ករណីនេះ ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការអាចដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ដោយលើកឡើងពីមូលហេតុអាពាហ៍ពិពាហ៍ផ្ទុយទៅនឹងអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍បាន ។

**ឧ.** បុរស A បានរៀបដែលកំពុងមានចំណងអាពាហ៍ពិពាហ៍ជាមួយនារី B បានរៀបអាពាហ៍ពិពាហ៍និងទៅចុះសំបុត្រអាពាហ៍ពិពាហ៍ថ្មីមួយទៀតជាមួយនារី C ដែលរស់នៅខេត្តឆ្ងាយពីផ្ទះរបស់ខ្លួន ។ ករណីនេះនារី B ជាប្រពន្ធ អាចដាក់ពាក្យបណ្តឹងទាមទារឲ្យលុបអាពាហ៍ពិពាហ៍ក្រោយរវាងបុរស A ជាមួយនារី C បាន ។

**គ.** បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

**ឧ.** ដោយយោងលើ មូលហេតុដែលនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បុរស A បានប្រព្រឹត្តនូវអំពើផិតក្បត់ហើយ មិនបានជួយទំនុកបម្រុងដល់គ្រួសារ ចាកចោលលំនៅដ្ឋានដោយគ្មានមូលហេតុត្រឹមត្រូវជាដើម នារី B អាចដាក់ពាក្យបណ្តឹងលែងលះពីបុរស A បាន ។

**ឃ.** បណ្តឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពី ជនត្រូវបានសន្មតថាជាឪពុក) និងមាត្រា ៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

**ឧ.** ក្នុងនាមជាឪពុកលោក A បានចុះសំបុត្រកំណើតឲ្យកូន B ។ ប្រសិនបើ B មិនមែនជាកូនបង្កើតរបស់ខ្លួនទេ នោះលោក A ត្រូវអះអាង អំពីទំនាក់ទំនង ខ្លួនជាមួយ B ថាមិន

ជាកូនបង្កើត នោះគាត់អាចដាក់ពាក្យបណ្តឹងសុំបដិសេធបិតុភាពបាន ។ ដូចគ្នាដែរ B ដែល បានដឹងពីហេតុការណ៍នេះ ក៏អាចប្តឹងសុំបដិសេធបិតុភាពរបស់ លោក A បានដែរ ។

**ង.** បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យ ទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

**ឧ.** ការមិនបានរៀបអាពាហ៍ពិពាហ៍រវាងលោក A និងនារី C ព្រមទាំងមានកូន B ។ លោក A មិនមានឆន្ទៈចង់រៀបការជាមួយនារី C ទេ ហើយបានបដិសេធមិនទទួលស្គាល់ B ជាកូនទេ។ ហេតុដូច្នេះ B អាចដាក់ពាក្យបណ្តឹង ឲ្យទទួលស្គាល់ ថាខ្លួនជាកូនរបស់ឪពុក A បាន ។

**ច.** បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

**ឧ.** A មានកូន C និង D ប៉ុន្តែ ត្រូវបានចុះបញ្ជីសំបុត្រកំណើតកូន B និង C ទៅវិញ។ ចំពោះ B គឺ A អាចដាក់ពាក្យបណ្តឹងសុំបដិសេធបុត្តភាពបាន។ ដូចគ្នាផងដែរ B ក៏អាចប្តឹងសុំឲ្យបញ្ជាក់ពីនត្ថិភាពនៃបុត្តភាពចំពោះ A បាន។

**ឆ.** បណ្តឹងដែលមានគោលបំណងបញ្ជាក់ពីអត្ថិភាព នៃមាតុភាពតាមបញ្ញត្តិមាត្រា១០០៤(បណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និងមាត្រា១០០៥ ( បណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីម្តាយ) នៃក្រមរដ្ឋប្បវេណី។

**ឧ.** ម្តាយ B បានបោះបង់កូន A ចោលបន្ទាប់ពីបានបង្កើតរួច។ នៅពេលដែល A បានធំដឹងក្តីហើយបានដឹងថា B ជាម្តាយបង្កើត។ នោះ A អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូនចំពោះ B បាន។ ដូចគ្នា ផងដែរ B ក៏អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីម្តាយបាន ប៉ុន្តែ ដោយសារតែ B បានបោះបង់ A ចោល ដូច្នេះគឺអាចលើកចោលពាក្យបណ្តឹង យោងទៅតាមក្រមរដ្ឋប្បវេណីមាត្រា១០០៥ កថាខណ្ឌទី៧បាន។

**ជ.** បណ្តឹងទាមទារកាត់កាល់(តាមមាត្រា ១០១៦)

**ឧ.** ឪពុកម្តាយចិញ្ចឹម AB បានបង្កើតសុំកូនពេញលេញជាមួយកូនចិញ្ចឹម C ។ ក្រោយពេលរស់នៅ ជាមួយគ្នា ឪពុកម្តាយចិញ្ចឹម AB បានបោះបង់កូន C ដោយគំនិតទុច្ចរិត ។ ហើយប្រសិនបើក្នុងករណីដែល DE ដែលជាឪពុកម្តាយបង្កើតរបស់ C អាចគ្រប់គ្រងថែរក្សា C បានដោយសមរម្យ នោះ C D E អាចដាក់ពាក្យបណ្តឹងទាមទារកាត់កាល់ពីឪពុកម្តាយចិញ្ចឹម AB បាន។

**ឈ.** បណ្តឹងទាមទារកាត់កាល់ (តាមមាត្រា ១០៣១)

**ឧ.** ឪពុកម្តាយចិញ្ចឹម AB បានបង្កើតសុំកូនធម្មតាជាមួយកូនចិញ្ចឹម C ។ ក្រោយមកដោយសារតែឪពុកម្តាយចិញ្ចឹម AB បានធ្វើបាប C នោះធ្វើឲ្យទំនាក់ទំនងមានការប្រេះស្រាំ ហើយមានការពិបាកក្នុងការបន្តសុំកូនទៅមុខទៀត។ ក្នុងករណីប្រសិនបើ C នៅជាអនីតិជននៅឡើយ បុគ្គលដែលត្រូវក្លាយទៅជាអ្នកតំណាងដែលច្បាប់បានកំណត់ (ឧ. DEដែលជាឪពុកម្តាយបង្កើតរបស់C) គឺ អាចដាក់ពាក្យបណ្តឹងទាមទារការកាត់កាល់ពីឪពុកម្តាយចិញ្ចឹម AB បានក្រោយពេលកាត់កាល់។

៣.បណ្ដឹងផ្សេងទៀតដែលមានគោលបំណងបង្កើតទំនាក់ទំនងឋានៈបុគ្គល ចំណុចនេះក្រុមការងារមិនទាន់អាចរកឧទាហរណ៍ដាក់ឱ្យចំបានទេ។

## ការប្រៀបធៀប

## នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង នីតិវិធីរដ្ឋប្បវេណី

### សញ្ញាណ

-ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាច្បាប់បញ្ញត្តនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះនីតិវិធីស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។ ការបង្កើតច្បាប់នេះឡើងដើម្បីធានាការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**-អ្វីជាបណ្តឹងទាក់ទងនឹងឋានៈបុគ្គល?** បណ្តឹងទាក់ទងនឹងឋានៈបុគ្គល គឺជាបណ្តឹងដែលមានគោលបំណងទាមទារឱ្យបង្កើត ឬបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ទំនាក់ទំនងឪពុកម្តាយនិងកូន ឬទំនាក់ទំនងឋានៈបុគ្គលផ្សេងទៀត ដែលជាទំនាក់ទំនងគតិយុត្តិរវាងបុគ្គលឯកជន ។ ទំនាក់ទំនងទាំងនេះជាទំនាក់ទំនងក្នុងគ្រួសារមួយ ដែលអាចនិយាយបានថា ជាប្រភេទរឿងដែលពាក់ពន្ធ័នឹង**ជីវិតឯកជន**របស់ពួកគេ ។

ការកំណត់នូវទំនាក់ទំនងគតិយុត្តិដែលជាកម្មវត្ថុនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលខាងលើ ត្រូវបានធ្វើឡើងដើម្បីឱ្យមានសណ្តាប់ធ្នាប់ក្នុងសង្គម ព្រោះទំនាក់ទំនងបែបនេះនាំឱ្យមានសិទ្ធិ និងកាតព្វកិច្ចមួយចំនួន ដែលគេតែងយល់ថា វាមានការពាក់ពន្ធ័នឹង**ផលប្រយោជន៍សាធារណៈ ។**

មូលហេតុខាងលើ ការបង្កើតឱ្យមានច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវបានរៀបចំឡើងដោយផ្អែកលើលក្ខណៈពិសេសដូចខាងក្រោម :

-កំរិតនូវគោលការណ៍នៃសិទ្ធិចាត់ចែង និងគោលការណ៍នៃការទាញហេតុផល ហើយជ្រើសរើសយកគោលការណ៍នៃការស្រាវជ្រាវដោយឆន្ទានុសិទ្ធិមកអនុវត្តក្នុងនីតិវិធី ។

-ពង្រឹងនូវស្ថិរភាពនៃទំនាក់ទំនងឋានៈបុគ្គល ដោយត្រូវកំនត់សមត្ថកិច្ចច្បាស់លាស់ ការប្រមូលផ្តុំបណ្តឹង ការប្រមូលភស្តុតាង ធ្វើយ៉ាងណាឱ្យអាចដោះស្រាយទាំងស្រុងព្រមជា មួយគ្នានូវវិវាទស្តីពីទំនាក់ទំនងឋានៈបុគ្គលរវាងភាគីដូចគ្នា

-ពង្រីកអានុភាពនៃសាលក្រមដែលចូលជាស្ថាពរដល់តតិយជនផងដែរ

-ការទាញហេតុផលដោយផ្ទាល់មាត់ មិនចាំបាច់ធ្វើជាសាធារណៈទេ ដោយសារប៉ះពាល់ដល់ជីវិតឯកជនរបស់ពួកគេ ។

យោងតាមមាត្រា ៣ ***"បណ្តឹងទាក់ទងនឹងឋានៈបុគ្គល"*** សំដៅទៅលើបណ្តឹងមួយចំនួនដូចខាងក្រោមៈ

-បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ ផ្អែកតាមបញ្ញត្តិមាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី)

-បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ ផ្អែកតាមបញ្ញត្តិមាត្រា ៩៥៩-៩៦៣ នៃក្រមរដ្ឋប្បវេណី

-បណ្តឹងទាមទារលែងលះគ្នា ផ្អែកតាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី

-បណ្តឹងបដិសេធបិតុភាព ផ្អែកតាមបញ្ញត្តិមាត្រា ៩៩០-៩៩១ នៃក្រមរដ្ឋប្បវេណី

-បណ្ដឹងទាមទារឱ្យទទួលស្គាល់ ផ្អែកតាមបញ្ញត្តិមាត្រា ១០០១ នៃក្រមរដ្ឋប្បវេណី

-បណ្ដឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ផ្អែកតាមបញ្ញត្តិមាត្រា ១០០២ នៃក្រមរដ្ឋប្បវេណី

-បណ្ដឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមាតុភាព ផ្អែកតាមបញ្ញត្តិមាត្រា ១០០៤ -១០០៥ នៃក្រមរដ្ឋប្បវេណី

-បណ្ដឹងទាមទារកាត់កាល់ ផ្អែកតាមបញ្ញត្តិមាត្រា ១០១៦ និងមាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណី

-បណ្ដឹងផ្សេងទៀតដែលមានបំណងបង្កើតទំនាក់ទំនងឋានៈបុគ្គល ផ្អែកតាមបញ្ញត្តិមាត្រា ៣ ចំណុច ៧ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល

*នីតិវិធីទាំងពីរមានចំណុចខុសគ្នាច្រើន ប៉ុន្តែចំណុចសំខាន់ៗដែលត្រូវលើកយកមកបង្ហាញនៅពេលនេះមាន:*

១-ការកំណត់សមត្ថកិច្ចតុលាការ

២-ភាគីក្នុងរឿងក្ដី

៣-សវនាការជាអសាធារណៈ

៤-វិធានក្នុងការពិនិត្យភស្តុតាង

៥-វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម

1. **សមត្ថកិច្ចតុលាការ** ( មាត្រា ៥ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល )

សមត្ថកិច្ចតុលាការត្រូវបានកំណត់ថា ជាសមត្ថកិច្ចផ្ដាច់មុខ និងសមត្ថកិច្ចមិនផ្ដាច់មុខ ។ សមត្ថកិច្ចមិនផ្ដាច់មុខ សំដៅលើសមត្ថកិច្ចរបស់តុលាការដែលអាចទទួលការជំនុំជម្រះក្ដីតាមការប្ដឹងទាមទាររបស់ភាគី ទោះបីមានការព្រមព្រៀងកំណត់សមត្ថកិច្ចជាមុន ឬគ្មានការព្រមព្រៀងក៏ដោយ ដូចជា ការព្រមព្រៀងកំណត់សមត្ថកិច្ចតាមមាត្រា ១៣នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬសមត្ថកិច្ចកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ តាមមាត្រា ១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីជាដើម ។ ផ្ទុយទៅវិញ សមត្ថកិច្ចផ្ដាច់មុខ ច្បាប់មិនទទួលស្គាល់សិទ្ធិជម្រះក្ដីរបស់តុលាការដូចឧទាហរណ៍ខាងលើទេ ក្នុងករណីដែលមានបណ្ដឹងលើកម្មវត្ថុមួយចំនួន ដូចជាករណីលែងលះ ដែលមានចែងក្នុងមាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

1.1. **ការកំណត់សមត្ថកិច្ចក្នុងរឿងក្ដីទាក់ទងនឹងឋានៈបុគ្គល : ជាសមត្ថកិច្ចផ្ដាច់មុខ**

ក្នុងបំណងពង្រឹងស្ថេរភាពទំនាក់ទំនងឋានៈបុគ្គល ច្បាប់បានកំណត់យក សមត្ថកិច្ចតុលាការដើម្បីដោះស្រាយវិវាទទាក់ទងនឹងឋានៈបុគ្គល ថាជាសមត្ថកិច្ចផ្ដាច់មុខ។ មាត្រា ៥ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលចែងថា *"១-បណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវស្ថិតនៅក្រោម**សមត្ថកិច្ចផ្ដាច់មុខ**របស់*

*សាលាដំបូង ដែលមានសមត្ថកិច្ចទៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬលំនៅឋាននាពេលដែលភាគីនោះទទួលមរណភាព" ។*

ការចែងបែបនេះដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវតុលាការដែលចាត់ការបណ្តឹងស្តីពីឋានៈបុគ្គល ហើយបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលអាចប្តឹងដោយបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ច្រើននាក់ អាចត្រូវប្រមូលផ្តុំ ដោយយកកន្លែងដែលអាចមានសាមីភាគី ញាតិ ឬមិត្តភក្តិដែលជាភស្តុតាងល្អៗដើម្បីសម្រួលនូវការអះអាង និងបញ្ជាក់របស់ភាគី ព្រមទាំងសម្រួលនូវការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ ដើម្បីកំណត់ជាស្ថាពរនូវទំនាក់ទំនងឋានៈបុគ្គល ដោយសារបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានលក្ខណៈជាផលប្រយោជន៍សាធារណៈ ហេតុដូច្នេះ គប្បីសម្របសម្រួលទៅនឹងតម្រូវការក្នុងការស្វែងរកភាពពិតជាសារធាតុព្រមទាំងតម្រូវការ ក្នុងការរកដំណោះស្រាយវិវាទទាំងស្រុងតាមរយៈការវិនិច្ឆ័យតែមួយលើក ។

1.2. **ជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ (ករណីមិនច្បាស់)**

ក្នុងករណីដែល បើមិនអាចកំណត់តុលាការមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ៥ បាន បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានីភ្នំពេញ ។ កថាខណ្ឌទី ៣ នៃមាត្រា ៥ គឺជាបញ្ញត្តិដែលសម្រួលឱ្យគូភាគីអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបាន ក្នុងករណីដែលមិនអាចកំណត់សមត្ថកិច្ចតាមកថាខណ្ឌទី ១ និងទី ២នៃមាត្រា ៥ បានក៏ដោយ ។

**សំគាល់: ករណីត្រូវផ្ទេរបណ្តឹងចៀសវាងការយឺតយ៉ាវ**

យោងតាមមាត្រា ៦ ទោះបីជាបណ្តឹងទាក់ទងនឹងឋានៈបុគ្គលណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ តុលាការនោះអាចផ្ទេរបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬផ្នែកណាមួយ ទៅតុលាការ**ផ្សេងទៀតដែលមានសមត្ថកិច្ចបាន** ( ក្នុងករណីដែលមានតុលាការច្រើនដែលមានសមត្ថកិច្ចប្រជែងគ្នា ) ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬដើម្បីធ្វើអោយមានសមធម៌រវាងគូភាគីដោយពិចារណាអំពីលំនៅឋានរបស់ភាគី និងសាក្សីដែលត្រូវសាកសួរ និងកាលៈទេសៈផ្សេងៗ។

2. **ភាគី** ( មាត្រា ៧-៩ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល )

2.1. **សមត្ថភាពក្នុងការធ្វើបណ្តឹង**

ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ច្បាប់ទទួលស្គាល់សិទ្ធិធ្វើបណ្តឹងរបស់អសមត្ថជនផងដែរ ដោយសារបណ្តឹងប្រភេទនេះ ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅលើលក្ខណៈបុគ្គលរបស់ភាគី ហើយតាមគោលការណ៍នៃក្រមរដ្ឋប្បវេណីដែលទទួលស្គាល់ និងគោរពឆន្ទៈរបស់សាមីខ្លួន ការទទួលស្គាល់សិទ្ធិប្តឹងប្រភេទនេះ ត្រូវបានអនុញ្ញាតដោយសម្របសម្រួលឱ្យ**មានជំនួយផ្នែកច្បាប់**ចូលអន្តរាគមន៍ ។ ហេតុនេះ បញ្ញត្តិស្តីពីការក៏រិតសមត្ថភាពក្នុងក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តក្នុងរឿងក្តីប្រភេទនេះទេ ។ មាត្រា ៨ កថាខណ្ឌទី ១ ចែងថា *"ចំពោះសកម្មភាពបណ្តឹងក្នុងនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិនៃ**មាត្រា ១៨** (សិទ្ធិលុបចោលសកម្មភាព) **មាត្រា ២៦** (សិទ្ធិលុបចោលសកម្មភាព) និង**មាត្រា ៣០** (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី និង*

*កថាខណ្ឌទី៣ នៃ**មាត្រា ៣២** (សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែល គ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង) និង **មាត្រា ៣៣** (បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និងអ្នកតំណាងដែលច្បាប់បានកំណត់) នៃក្រមនីតិវិធីរដ្ឋប្បវេណី **មិនត្រូវយកមកអនុវត្តឡើយ"** ។*

ក្នុងករណីមានបណ្តឹងបែបនេះ តុលាការអាចជ្រើសតាំងមេធាវីឱ្យធ្វើជាតំណាងតាមពាក្យសុំ ដោយឆន្ទានុសិទ្ធិ ឬបង្គាប់ឱ្យជ្រើសតាំង ដោយតុលាការជាអ្នកកំណត់ចំនួនប្រាក់កម្រៃសម្រាប់មេធាវី ហើយចំនួនទឹកប្រាក់នេះ ចាត់ចូលជាប្រាក់ប្រដាប់ក្តី( មាត្រា ៨ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ) ។

2.2. **ចុងចម្លើយ**

ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ចុងចម្លើយត្រូវបានកំណត់រួចជាស្រេចតាមមាត្រា ៧ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដោយសារអ្នកទាំងនោះមានការពាក់ព័ន្ធ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីបញ្ជាក់ការពិត ក៏ដូចជាតម្រូវការការពារតតិយជន។ មាត្រា ៧ កំណត់ដូចខាងក្រោម:

-ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយភាគីម្ខាងនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ **ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ** លើកលែងតែមានបញ្ញត្តិពិសេស ។

-ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានដាក់ឡើងដោយជនដែលមិនមែនជាភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនេះ **ភាគីសងខាងនៃទំនាក់ទំនងឋានៈបុគ្គលនេះ** ត្រូវជាចុងចម្លើយ ហើយនៅក្រោយពេលដែលភាគីណាមួយបានទទួលមរណភាព ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

-ក្នុងករណីដែលជនដែលត្រូវជាចុងចម្លើយនៃបណ្តឹង តាមបញ្ញត្តិនៃកថាខ័ណ្ឌទី១ ឬ កថាខ័ណ្ឌទី២ខាងលើនេះទទួលមរណភាព ហើយគ្មានជនណាត្រូវជាចុងចម្លើយទេនោះ **តំណាងអយ្យការ**ត្រូវក្លាយជាចុងចម្លើយ ។

2.3. **មរណភាពរបស់ដើមចោទ**

នៅពេលដែលបណ្តឹងកំពុងចាត់ការ ហើយដើមចោទនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានទទួលមរណភាព បណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវចប់ដោយស្វ័យប្រវត្តិ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស (មាត្រា ២៤ កថាខណ្ឌទី ២, មាត្រា ២៥ កថាខណ្ឌទី ២ និងមាត្រា ២៦ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ ការកំណត់បែបនេះដោយសារ **សិទ្ធិបង្កើត ឬផលប្រយោជន៍ក្នុងការបញ្ជាក់នូវទំនាក់ទំនងឋានៈបុគ្គល** គឺជាសិទ្ធិ ឬផលប្រយោជន៍ផ្តាច់មុខរបស់សាមីភាគី ដូច្នេះ នៅពេលដែលដើមចោទទទួលមរណភាព បណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវបញ្ចប់ដែរ ដូច្នេះ បញ្ញត្តិនៃកថាខណ្ឌទី ១ ចំណុច **ក** និង កថាខណ្ឌទី ២ ចំណុច **ក** នៃមាត្រា ១៧៣ (ការផ្អាក និងការទទួលបន្តនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តទេ។

2.4. **មរណភាពរបស់ចុងចម្លើយ**

-ក្នុងករណីដែលភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គល ត្រូវក្លាយជាចុងចម្លើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) ហើយប្រសិនបើភាគីណាមួយទទួលមរណភាព បណ្ដឹងនេះត្រូវបន្តនីតិវិធី ដោយយក**ភាគីម្នាក់ទៀត**នោះមកធ្វើជាចុងចម្លើយ ។ ក្នុងករណីនេះ បញ្ញត្តិនៃចំណុច **ក** កថាខណ្ឌទី ១ នៃមាត្រា ១៧៣ (ការផ្អាក និងការទទួលបន្តនូវនីតិវិធីនៃបណ្ដឹង )នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ។

-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬកថាខណ្ឌទី ២ នៃមាត្រា ៧ ប្រសិនបើចុងចម្លើយទាំងអស់ទទួលមរណភាព បណ្ដឹងនេះត្រូវបន្តនីតិវិធីដោយយក**តំណាងអយ្យការ**មកធ្វើជាចុងចម្លើយ (កថាខណ្ឌទី ២ នៃមាត្រា ២០ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ ដូច្នេះ បញ្ញត្តិនៃកថាខណ្ឌទី ១ ចំណុច **ក** និង កថាខណ្ឌទី ២ ចំណុច **ក** នៃមាត្រា ១៧៣ (ការផ្អាក និងការទទួលបន្តនីតិវិធីនៃបណ្ដឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តទេ។

-ក្នុងករណីដែលចុងចម្លើយនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលដែលមានគោលបំណង**លែងលះ ឬកាត់កាល់** បានទទួលមរណភាពនៅពេលដែលបណ្ដឹងនេះកំពុងត្រូវបានចាត់ការ បណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនេះត្រូវចប់ដោយស្វ័យប្រវត្តិ (មាត្រា ៧ កថាខណ្ឌទី ៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។

3. **ការជំនុំជម្រះជាអសាធារណៈ** (មាត្រា ១៦ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល )

ក្នុងនីតិវិធីរដ្ឋប្បវេណី ជាគោលការណ៍ ការជំនុំជម្រះត្រូវធ្វើជាសាធារណៈ ហើយករណីណីពិសេស អាចធ្វើជាអសាធារណៈ (មាត្រា ១១៥)។ ផ្ទុយទៅវិញ ក្នុងនីតិវិធីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ជាគោលការណ៍ ត្រូវធ្វើជាអសាធារណៈ ដោយសារកម្មវត្ថុនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មានចំណុចជាច្រើនដែលពាក់ព័ន្ធជិតស្និទ្ធទៅនឹងការសម្ងាត់នៃជីវភាពរស់នៅរបស់បុគ្គលឯកជន ។ ការជំនុំជម្រះជាសាធារណៈ អាចនាំឱ្យគូភាគីមានការរអារក្នុងការអះអាង និងបញ្ជាក់ភស្តុតាងឱ្យបានគ្រប់គ្រាន់ ដោយសារភាគីនោះបារម្ភថា ការរៀបរាប់ហេតុការណ៍នោះធ្វើឱ្យមានការអៀនខ្មាស់ និងឱ្យគេដឹងឮជាសាធារណៈនូវការសម្ងាត់របស់ខ្លួន ជាបច្ច័យ នាំឱ្យមានការ**បំពានដល់សិទ្ធិពឹងពាក់តុលាការ**របស់គូភាគី ។ ម្យ៉ាងទៀត **ការបារម្ភថាអាចមានការរង្គោះរង្គើរដល់សណ្ដាប់ធ្នាប់**ពាក់ព័ន្ធនឹងឋានៈបុគ្គល ដែលជាមូលដ្ឋាននៃការចិញ្ចឹមជីវិតក្នុងសង្គមរបស់បុគ្គល ដោយសារការបង្កើត ឬការបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គលមិនត្រឹមត្រូវ ដោយផ្អែកលើការអះអាង និងការបញ្ជាក់ភស្តុតាងមិនគ្រប់គ្រាន់របស់ភាគី ។

ដោយគិតដល់ចំណុចទាំងនេះ ជាគោលការណ៍ ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលមិនត្រូវឱ្យបើចំហរជាសាធារណៈទេ (មាត្រា ១៦ កថាខណ្ឌទី ១) **តែក្នុងលក្ខណៈពិសេស តុលាការអាច ធ្វើជាសាធារណៈ** ឬអាចអនុញ្ញាតឱ្យបុគ្គលដែលខ្លួនយល់ថាសមរម្យចូលស្ដាប់បាន (មាត្រា ១៦ កថាខណ្ឌទី ២) ដែលជាបញ្ញត្តិផ្ទុយពីក្រមនីតិវិធី( មាត្រា ១១៥)។

គួរកត់សំគាល់ថា ការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ ប៉ុន្តែការប្រកាសសេចក្ដីសម្រេច

ត្រូវធ្វើជាសាធារណៈ( មាត្រា ១ នៃច្បាប់ស្តីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងមាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

4. **វិធានក្នុងការពិនិត្យភស្តុតាង**( មាត្រា ១៣-១៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល )

4.1. **ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ**

មាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលចែងថា *"នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគី មកធ្វើជាមូលដ្ឋាននៃសាលក្រមបាន ។ ក្នុងករណីនេះ តុលាការ**ត្រូវសួរមតិពីភាគីស្តីពីអង្គហេតុនោះ"*** ។

ការកំណត់បែបនេះដោយសារកម្មវត្ថុនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវធ្វើឡើងដោយផ្អែកលើអង្គ-ហេតុពិត ហើយមិនអនុញ្ញាតឱ្យភាគីចាត់ចែងដោយឆន្ទៈរបស់ខ្លួនទេ ។ តុលាការអាចទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុណាមួយដោយផ្អែកលើភស្តុតាង ទោះបីជាភាគីមិនអះអាងអំពីអង្គហេតុនោះក៏ដោយ ។ ប៉ុន្តែ តុលាការត្រូវផ្តល់ឱកាសឱ្យភាគីឆ្លើយតបវិញ ដោយស្តាប់ការពន្យល់មតិរបស់ភាគីនោះ ។

ផ្ទុយនឹងគោលការណ៍នេះ តាមក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់យកគោលការណ៍នៃការទាញហេតុផលដែលជាគោលការណ៍ តុលាការពិចារណាតែលើភស្តុតាងដែលគូភាគីបានដាក់ និងអះអាងតែប៉ុណ្ណោះ ដូចមានបញ្ជាក់ក្នុងមាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

4.2. **ការសាកសួរសាមីភាគី**

ដោយសារច្បាប់ កំណត់យកគោលការណ៍ឆន្ទានុសិទ្ធិក្នុងការស្រាវជ្រាវរកភស្តុតាង ការសាកសួរសាមីភាគីមានការចាំបាច់ខ្លាំង ហេតុនេះ ច្បាប់អនុញ្ញាតឱ្យនាំខ្លួន ឬអាចពិន័យបាន។ ក្នុងករណីដែលសាកសួរសាមីភាគី តុលាការអាចបង្គាប់ឱ្យភាគីនោះ មកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ( មាត្រា ១៥ កថាខណ្ឌទី ១) ។

តុលាការអាចបង្គាប់ឱ្យនាំខ្លួនភាគីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន ។ ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ។

ប្រសិនបើភាគីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ ( មួយលាន) រៀលបាន ដោយដីកាសម្រេច ។ ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ( មាត្រា ១៥ កថាខណ្ឌទី ២ នៃច្បាប់ស្តីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងមាត្រា ១៣២ កថាខណ្ឌទី ២ ដល់ទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

4.3. **បញ្ញត្តិមិនអនុវត្តតាមក្រមនីតិវិធី**

ដោយសារច្បាប់ កំណត់យក**គោលការណ៍ឆន្ទានុសិទ្ធិ**ក្នុងការស្រាវជ្រាវរកភស្តុតាង វិធានក្នុងការពិនិត្យភស្តុតាងមួយចំនួនដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មិនអាចយកមកអនុវត្តក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានទេ ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ មាត្រាទាំងនោះ គឺៈ

មាត្រា ៩៤ ( ការលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនដែលបានដាក់យឺតយ៉ាវ )

មាត្រា ៩៦ កថាខណ្ឌទី ១ ( ការចាត់ទុកថាបានសារភាព)

មាត្រា ១៤០ កថាខណ្ឌទី ២ ( ការសាកសួរសាមីភាគី)

មាត្រា ១៥៣ ( អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ )

មាត្រា ១៥៦ កថាខណ្ឌទី ៤ ( ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ)

មាត្រា ២០០ ( សាលក្រមកំបាំងមុខដើមចោទ)

មាត្រា ២០១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ( សាលក្រមកំបាំងមុខចុងចម្លើយ)

មាត្រា ១២៣ កថាខណ្ឌទី ២ ( អានុភាពតាមផ្លូវច្បាប់នៃអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ)

មាត្រា ២២០ ដល់មាត្រា ២២២ ។

សំគាល់ : ក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការមិនអាចចេញជាកំណត់ហេតុសះជាដើម្បីបញ្ចប់រឿងទេ គឺត្រូវចេញជាសាលក្រម (ឬដីកាសម្រេច ក្នុងករណីមួយចំនួន) ។ ជាមួយគ្នានេះ ក៏មិនត្រូវច្រឡំនឹងស្មារតីនៃមាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណីដែរ ។

5. **វិសាលភាពនៃបុគ្គលដែលទទួលអានុភាពនៃសាលក្រម** ( មាត្រា ១៧ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល )

ជាគោលការណ៍ សាលក្រមស្ថាពរមានអានុភាពចំពោះតែភាគីប៉ុណ្ណោះ ដូចមានចែងក្នុងមាត្រា ១៩៨ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ប៉ុន្តែ ចំពោះកម្មវត្ថុនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលវិញ ឋានៈបុគ្គលទាមទារឱ្យសង្គមទទួលស្គាល់ទំនាក់ទំនងរបស់គូភាគី ដូចជា ទំនាក់ទំនងឪពុកម្តាយ និងកូនតាមផ្លូវច្បាប់រវាងគូភាគីត្រូវមានអានុភាពតាមផ្លូវច្បាប់ចំពោះមុខតតិយជនផងដែរ ។

មាត្រា ១៧ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលចែងថា *"សាលក្រម ឬសាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មានអានុភាពចំពោះតតិយជនដែរ"* ។

ឧទាហរណ៍ : បើសាលក្រមប្រកាសលែងលះ នាំឱ្យមានអានុភាពផ្តាច់ទំនាក់ទំនងញាតិ ហេតុនេះ គ្មានទំនាក់ទំនងញាតិពន្ធទៀតទេ ។ ជនដែលមិនមែនជាភាគីនៃសាលក្រម រួមមានឪពុកក្មេក ម្តាយក្មេក បងថ្លៃ ប្អូនថ្លៃ....ត្រូវកាត់ផ្តាច់ដែរ ។

ឧទាហរណ៍ : តុលាការប្រកាសទទួលស្គាល់បិតុភាពរវាងលោក " ក " ជាឪពុក និងលោក " ខ " នាំឱ្យមានអានុភាពដល់លោក " គ " ត្រូវជាកូន ដែលជាតតិយជនមិនមែនជាភាគីនៃសាលក្រមត្រូវមានកាតព្វកិច្ច យោងតាមមាត្រា ១១៤០ នៃក្រមរដ្ឋប្បវេណី ហើយក៏ត្រូវបែងចែកមរតកពាក់កណ្តាលរបស់ឪពុកឱ្យទៅលោក " ខ " ដែរ នៅពេលធ្វើសន្តតិកម្ម ។

ឧទាហរណ៍ : បើមានសាលក្រមប្រកាសទទួលស្គាល់ទំនាក់ទំនងឪពុក និងកូន បើឪពុកឱ្យទ្រព្យទាំង

អស់ទៅជនម្នាក់( អច្ច័យលាភី) ជននោះ ត្រូវទទួលស្គាល់សិទ្ធិទាមទារភាគបំរុងរបស់កូនដែលមានចំពោះទ្រព្យខាងលើ ដោយសារមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណីទទួលស្គាល់ភាគបំរុងរបស់កូន ។

តាមខ្លឹមសារខាងលើ ដើម្បីឱ្យមានអានុភាពនៃសាលក្រមស្ថាពរនេះកើតមានឡើងលើតតិយជនដែលមិនបានធ្វើបណ្តឹងដោយខ្លួនឯងសោះនោះ មានចាំបាច់ត្រូវធ្វើយ៉ាងណាកុំឱ្យមាន**ការបំពានដោយមិនត្រឹមត្រូវនូវផលប្រយោជន៍**របស់តតិយជននោះ ។ ហេតុនេះហើយបានជាក្នុងច្បាប់នេះ និងក្នុងក្រមរដ្ឋប្បវេណីមានចែងដូចខាងក្រោមដើម្បីតម្រូវនឹងទស្សនៈនេះ :

-ធ្វើការកម្រិតតែជនដែលយល់ឃើញថាត្រឹមត្រូវបំផុត ដើម្បីការរកភាពពិតជាសារធាតុ ជាអ្នកមានលក្ខណៈសម្បត្តិជាភាគីនៅក្នុងមាត្រា ៦ ហើយរំពឹងថា អ្នកនោះអាចធ្វើបណ្តឹងបានពេញលេញ

-ធ្វើការកម្រិតនូវគោលការណ៍នៃសិទ្ធិចាត់ចែង និងគោលការណ៍នៃការទាញហេតុផល ហើយជ្រើសរើសយកគោលការណ៍ស្រាវជ្រាវដោយឆន្ទានុសិទ្ធិ នៅក្នុងមាត្រា ១២ និងមាត្រា ១៣ ) ។

-ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹងរបស់តតិយជន ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៣៤) ការចូលរួមរបស់តំណាងអយ្យការ ( មាត្រា ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងមាត្រា ៣ ( ការអះអាងអង្គហេតុដោយតំណាងអយ្យការ) ក៏ជាបញ្ញត្តិដែលធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់តតិយជនដែរ ។

ក្នុងករណីដែលមានការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ ដោយយកមូលហេតុផ្ទុយនឹងការហាមឃាត់មិនឱ្យមាន**ទ្វេពន្ធភាព** ហើយបើការទាមទារនេះត្រូវបានច្រានចោល **ជាករណីលើកលែង**នៃសាលក្រមស្ថាពរដែលច្រានចោលនូវការទាមទារនោះ មិនមានអានុភាពទៅលើសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុនរបស់ភាគី ( សហព័ទ្ធមុន) ដែលមិនបានចូលរួមអន្តរគមន៍ក្នុងបណ្តឹងដែលទាក់ទងនឹងការទាមទារនោះ ហើយអាចធ្វើការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍បាន ដោយយោងតាមកថាខ័ណ្ឌទី២ មាត្រា ៩៦០ ( ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់) នៃក្រមរដ្ឋប្បវេណី ( មាត្រា ១៧ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល) ។

# សិក្ខាសាលា
# ស្តីពី
# នីតិវិធីនៃការបញ្ជូន

1

# នីតិវិធីនៃការបញ្ជូន

ក្រុមការងារនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

ខែធ្នូ ឆ្នាំ២០១៤

2

## ១-នីតិវិធីនៃការបញ្ជូន

១.អត្ថន័យនៃការបញ្ជូន
២.ស្ថាប័នដែលធ្វើការបញ្ជូន
៣.របាយការណ៍បញ្ជូន
៤.ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង
៥.ការបញ្ជូនដោយការប្រគល់
    ៥.១ ការបញ្ជូនដោយការជួបប្រទះ
    ៥.២ ការបញ្ជូនដោយបង្គ្រប់កិច្ច
    ៥.៣ ការបញ្ជូនដោយទុកចោល
៦.ការបញ្ជូនទៅបរទេស
៧.ការបញ្ជូនតាមការផ្សាយជាសាធារណៈ

3

# អត្ថន័យនៃការបញ្ជូន

❖ <u>ការបញ្ជូន</u> គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បី***ជូនដំណឹង***អំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។

- <u>**ការជូនដំណឹង**</u> គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូន ដោយអ្នកប្រតិបត្តិការបញ្ជូនអាចប្រើគ្រប់មធ្យោបាយដូចជា តាមទូរស័ព្ទ អ៊ីម៉ែល ប្រៃសនីយ៍ សំបុត្រ ដើម្បីឲ្យអ្នកត្រូវទទួលការបញ្ជូនបានដឹង ហើយក្នុងនោះនីតិវិធីនៃការបញ្ជូន ក៏ជាមធ្យោបាយមួយនៃការជូនដំណឹងដែរ។

4

# ឯកសារដែលត្រូវធ្វើការបញ្ជូន

❖ ឯកសារដែលច្បាប់កំណត់ឲ្យធ្វើការបញ្ជូនៈ

- ពាក្យបណ្តឹង (ម.៧៩ ក្រមនីតិវិធី)
- ពាក្យសុំបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង (ម.៨៤-៣ ក្រមនីតិវិធីរ/ណី)
- អនុសារសាលក្រម (ម.១៩០ ក្រមនីតិវិធីរ/ណី)
- ពាក្យបណ្តឹងទាស់ (ម.២០៦-៤ ក្រមនីតិវិធីរ/ណី)
- លិខិតដកពាក្យបណ្តឹង (ម.២១៧-៤ ក្រមនីតិវិធីរ/ណី)
- ដីកាសម្រេចចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ (ម.៤១៩-២ ក្រមនីតិវិធីរ/ណី)
- ដីកាសម្រេចរក្សាការពារ (ម.៥៤៣ ក្រមនីតិវិធីរ/ណី)

# ឯកសារដែលអាចធ្វើការជូនដំណឹង

- ការកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្តើមនីតិវិធីយោងតាមពាក្យបណ្តឹងទាស់ (ម.២០៨-២ ក្រមនីតិវិធីរ/ណី)
- ដីកាសម្រេច (ម.២៣១-១ ក្រមនីតិវិធីរ/ណី)
- កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ (ម.៤៤០-២ ក្រមនីតិវិធីរ/ណី)
- ការកំណត់ពេលបង់ថ្លៃលក់ (ម.៤៧៨ ក្រមនីតិវិធីរ/ណី)

<u>កំណត់សម្គាល់</u>

- ទោះជាមានបញ្ញត្តិមួយចំនួននៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ឲ្យធ្វើការជូនដំណឹងក៏ដោយ យកល្អគប្បីគួរតែធ្វើការបញ្ជូន ដើម្បីមានរបាយការណ៍បញ្ជូនទុកក្នុងសំណុំរឿងជាសំអាង ជៀសវាងភាគីតវ៉ាថា ពួកគាត់មិនបានទទួលដំណឹងពីតុលាការ។
- ខាងលើនេះគ្រាន់តែជាមធ្យោបាយមួយប៉ុណ្ណោះ។ ប្រសិនបើធ្វើតាមវិធីនេះទាំងអស់ នោះអាចនឹងមានការធុញទ្រាន់និងស្មុគស្មាញ ហេតុនេះ យើងអាចធ្វើតាមវិធីមួយទៀតគឺ *ធ្វើការជូនដំណឹងដូចធម្មតា ប៉ុន្តែក្រោយជូនដំណឹងហើយត្រូវធ្វើកំណត់ហេតុអំពីការជូនដំណឹងនេះ ហើយរក្សាកំណត់ហេតុអំពីការជូនដំណឹងនេះនៅក្នុងសំណុំរឿង ។*



# អត្ថន័យនៃការបញ្ជូន

- អានុភាពគតិយុត្តចម្បងមួយនៃការបញ្ជូន គឺ <u>***អំឡុងពេលដែលអាចប្តឹងទៅតុលាការជាន់ខ្ពស់***</u> បាននឹងចាប់ផ្តើមដំណើរការ (ម.២៦៤ និង ម.២៦៨ ក្រមនីតិវិធីរ/ណី)។
- ***ការបញ្ជូន*** ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ លើកលែងតែមានបញ្ញត្តិ ពិសេសក្នុងច្បាប់ (ម.២៤៦-១ក្រមនីតិវិធីរ/ណី)។
- ឯកសារដែលត្រូវបញ្ជូន គឺ***ឯកសារថតចម្លង*** លើកលែង តែមានបញ្ញត្តិពិសេសក្នុងច្បាប់(ម.២៤៧-២ក្រមនីតិវិធីរ/ណី)។

7

# ២-១ស្ថាប័នចាត់ចែងកិច្ចការបញ្ជូន

❖២-១ ស្ថាប័នចាត់ចែងកិច្ចការបញ្ជូនៈ

1. **មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន**
   - ក្រឡាបញ្ជី (ម. ២៤៦ កថាខណ្ឌទី២ ក្រមនីតិវិធីរ/ណី)។
2. **មុខងាររបស់មន្ត្រីរដ្ឋបាលទទួលកិច្ចការបញ្ជូនៈ**
   - ធ្វើ ឬផ្តល់សេចក្តីបញ្ជាក់នូវឯកសារ សម្រាប់ប្រើក្នុងការបញ្ជូន
   - ប្រគល់អំណាចនៃការបញ្ជូនឯកសារនេះទៅឲ្យ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន
   - បន្ទាប់មក ទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន និង
   - ត្រូវយករបាយការណ៍នៃការបញ្ជូននេះទៅជូនចៅក្រម ដើម្បីឲ្យចៅក្រមពិនិត្យ ថាតើការបញ្ជូននេះត្រឹមត្រូវហើយ ឬនៅ
   - ចុងក្រោយ មន្ត្រីរដ្ឋបាលដែលទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវរក្សាទុក របាយការណ៍នៃការបញ្ជូននេះទុកក្នុងសំណុំរឿង ដោយរៀបចំទុកឲ្យបានត្រឹមត្រូវទៅតាមកាលបរិច្ឆេទនៃលំដាប់ឯកសារ។

8

# ២.២ ស្ថាប័នប្រតិបត្តិការបញ្ជូន

❖ស្ថាប័នប្រតិបត្តិការបញ្ជូនៈ

**មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន** (ម. ២៤៦ កថាខណ្ឌទី៣ ក្រមនីតិវិធីរ/ណី)

- បុគ្គលិកប្រៃសនីយ៍
- អាជ្ញាសាលា
- ក្រឡាបញ្ជី

# មុខងារមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន

❖ <u>មុខងាររបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន</u>:

❖ ធ្វើការបញ្ជូនដោយដាក់លាក់ចំពោះជនដែលត្រូវទទួលការបញ្ជូន។

❖ ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូនតាម ម.២៥៤ ក្រមនីតិវិធីរ/ណី។

❖ ត្រូវដាក់របាយការណ៍អំពីការបញ្ជូននេះទៅតុលាការដើម។

<u>កំណត់សម្គាល់</u>

ដោយសារតែស្ថានភាពបច្ចុប្បន្នរបស់យើងមិនទាន់មានមន្ត្រីអាជ្ញាសាលា ហេតុនេះដើម្បី សម្រួលដល់ការអនុវត្តច្បាប់ ក្រសួងយុត្តិធម៌ក៏បានចេញសេចក្តីប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ច ការអាជ្ញាសាលា <u>លេខ ៣០ កយប្រក/០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧</u> ដោយកំណត់យក ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងជាអ្នកអនុវត្តកិច្ចការអាជ្ញាសាលា ដើរតួនាទីក្នុងនាមជាមន្ត្រីទទួល បន្ទុកកិច្ចការអាជ្ញាសាលានៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងស្ថិតនៅក្រោមជាបណ្តោះអាសន្នរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីអាជ្ញាសាលា។



# ៣. របាយការណ៍បញ្ជូន

- របាយការណ៍បញ្ជូន ត្រូវមានបញ្ជាក់ចំណុចដូចបានកំណត់ក្នុង ម.២៥៤ កថាខណ្ឌទី២ ក្រមនីតិវិធីរ/ណី។

# ៤-ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង

❑ទាល់តែបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រម និងច្បាប់ផ្សេងទៀតបាន ទើបបុគ្គលនោះអាចធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងបាន (ម.៣២ កថាខណ្ឌទី ២ក្រម រ/ណី)។

❑បុគ្គលដែលអសមត្ថភាពក្នុងការធ្វើបណ្ដឹងមាន (ម.១៧ ក្រមរ/ណី)៖

- ➢អនីតិជន
- ➢ជននៅក្រោមអាណាព្យាបាលទូទៅ
- ➢ជននៅក្រោមហិតូបត្ថម្ភ

❖ជនទាំង៣ប្រភេទនេះ គឺត្រូវធ្វើសកម្មភាពបណ្ដឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់។



# ៤-ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង

**❑ករណីលើកលែងចំពោះ៖**

1. អនីតិជនដែលទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្ម ពីអ្នកមានអំណាចមេបា ឬអ្នកអាណា ព្យាបាលសម្រាប់អនីតិជន (ម. ២០-១ ក្រមរ/ណី)។
2. អនីតិជនដែលទទួលបានអត្តាធិនភាព (ម. ២១ ក្រមរ/ណី)។

➢អនីតិជនទាំង២ប្រភេទនេះ គឺអាចធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងបាន ដោយមិនចាំបាច់ ឆ្លងអ្នកតំណាងដែលច្បាប់បានកំណត់ទ័

➢ចំពោះអនីតិជនដែលទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្ម មានសមត្ថភាពក្នុងការធ្វើបណ្ដឹង បានត្រឹមតែបណ្ដឹង "**<u>ទាក់ទងនឹងជំនួញ</u>**" ដែលអនុញ្ញាតនោះប៉ុណ្ណោះ។ ដូចនេះទោះបីជាអនីតិជនដែល ទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្មក៏ដោយ បើមិនមែនជាបណ្ដឹងទាក់ទងនឹងអាជីវកម្មដែលបានអនុញ្ញាតនោះទេ អនីតិជននោះនៅតែជាបុគ្គលអសមត្ថភាពដដែល។

13

## ៤-ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង

❑ អ្នកតំណាងដែលច្បាប់បានកំណត់៖

- ➢ ចំពោះ អនីតិជន សំដៅលើ អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាល (ម.១០៣៤ និង ម.១០៦៧ ក្រមរ/ណី)។
- ➢ ចំពោះ ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅលើអ្នកអាណាព្យាបាលទូទៅ (ម.២៥ ក្រមរ/ណី)។
- ➢ ចំពោះជននៅក្រោមហិតូបត្ថម្ភ សំដៅលើ ហិតូបត្ថម្ភកៈ (ម.២៩ ក្រមរ/ណី) ។

14

## ៤-ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង

❖ <u>ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង</u> ត្រូវបញ្ជូនទៅអ្នកណាដែលច្បាប់បានកំណត់ (ម. ២៤៨-១ ក្រមនីតិវិធីរ/ណី)។

- ➢ បើមានអ្នកតំណាងដែលច្បាប់បានកំណត់រួមគ្នាច្រើននាក់ ការបញ្ជូនអាចធ្វើទៅអ្នកតំណាងដែលច្បាប់បានកំណត់ណាមួយជាការគ្រប់គ្រាន់ (ម. ២៤៨ ក្រមនីតិវិធីរ/ណី)។

❖ <u>ការបញ្ជូនទៅបុគ្គលដែលជាប់ពន្ធនាគារ</u> ត្រូវធ្វើចំពោះប្រធានពន្ធនាគារ (ម. ២៤៨-៣ ក្រមនីតិវិធីរ/ណី)។

15

# វិធីនៃការបញ្ជូន

- ❖ការបញ្ជូនដោយការប្រគល់
- ❖ការបញ្ជូនដោយការជួបប្រទះ
- ❖ការបញ្ជូនដោយបង្គ្រប់កិច្ច
- ❖ការបញ្ជូនដោយទុកចោល
- ❖ការបញ្ជូនទៅបរទេស
- ❖ការបញ្ជូនដោយការផ្សាយជាសាធារណៈ

16

# ៥-ការបញ្ជូនដោយការប្រគល់

- ❑ជាគោលការណ៍ត្រូវប្រគល់ឯកសារទៅឲ្យ ជនដែលត្រូវទទួលការបញ្ជូន (ម. ២៤៧-១ ក្រមនីតិវិធីរ/ណី)។
- ❑ជាគោលការណ៍ ត្រូវបញ្ជូនទៅលំនៅឋានទីសំណាក់ ទីកន្លែងអាជីវកម្ម និងទីស្នាក់របស់ជន ដែលត្រូវទទួលការបញ្ជូន (ម. ២៤៩ ក្រមនីតិវិធីរ/ណី)។
  - ❑<u>លំនៅឋាន</u> គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន ម.៣៤ ក្រមរ/ណី)។
  - ❑ទី<u>សំណាក់:</u> ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរបស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន (ម.៣៥ ក្រមរ/ណី)។
- ❑ការបញ្ជូនទៅអ្នកតំណាង ដែលច្បាប់បានកំណត់ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់អ្នកតំណាងនោះបាន។

17

# ៥-ការបញ្ជូនដោយការប្រគល់

- <u>ករណីលើកលែង</u> ត្រូវបញ្ជូនទៅទីដែលត្រូវបញ្ជូន ឬអ្នកដែលទទួលការបញ្ជូន ត្រូវបញ្ជូនទៅ ទីកន្លែងដែលបានជូនដំណឹងនោះ (ម. ២៥០ កថាខណ្ឌទី៤ ក្រមនីតិវិធីរ/ណី)។

- ការជូនដំណឹងខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ (ម.២៥០ កថាខណ្ឌទី៣ ក្រមនីតិវិធីរ/ណី)។

- ពាក្យបណ្តឹងដែលមានបញ្ជាក់អំពីទីកន្លែងដែលត្រូវបញ្ជូន ឬអ្នកដែលទទួលការបញ្ជូន យើងចាត់ទុកថាភាគីបានជូនដំណឹងជាលាយល័ក្ខណ៍អំពីទីកន្លែងដែលត្រូវបញ្ជូនរួច។

18

# ពាក្យបណ្តឹង

<u>ពាក្យបណ្តឹង</u>

-ដើមចោទឈ្មោះ ក ភេទស្រី អាយុ ៣០ឆ្នាំ មានទីលំនៅផ្លូវលេខ ២៣៧ ផ្ទះលេខ ៣៨ ភូមិ០៧ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ចុងចម្លើយឈ្មោះ ខ ភេទប្រុស អាយុ ៣៣ឆ្នាំ មានទីលំនៅផ្លូវលេខ ២៣៧ ផ្ទះលេខ ៣៨ ភូមិ០៧ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។
(ទីកន្លែងដែលត្រូវបញ្ជូនរបស់ដើមចោទៈ ផ្ទះលេខ ១១៧ ផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកង ទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

បើដើមចោទមានការជូនដំណឹងបែបនេះ យើងត្រូវបញ្ជូនទៅដើមចោទទៅតាមអាស័យដ្ឋាន ដែលបានជូនដំណឹង គឺផ្ទះលេខ ១១៧ ផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកង ទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ)។

- ការជូនដំណឹងខាងលើ មានអានុភាពរហូតដល់តុលាការជាន់ខ្ពស់។
- បើអ្នកទទួលការបញ្ជូនមិនចេះអក្សរ គប្បីពន្យល់នូវខ្លឹមសារនៃ ឯកសារនេះទៅអ្នកទទួល នោះនៅពេលប្រគល់ឯកសារ (ម. ២៤៧-៣ ក្រមនីតិវិធីរ/ណី)។

19

## ៥-១ ការបញ្ជូនដោយការជួបប្រទះ (ម.២៥១ ក្រមនីតិវិធីរ/ណី)

- ករណីពុំច្បាស់ថា ជនដែលត្រូវទទួលការបញ្ជូនមានលំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម និងទីស្នាក់ការនៅក្នុងប្រទេសកម្ពុជា។
- លើកលែងតែមានករណីដែលភាគីបានជូនដំណឹងពី ទីកន្លែង ដែលត្រូវធ្វើការបញ្ជូនតាម ម.២៥០-១ ក្រមនីតិវិធីរ/ណី ត្រូវបញ្ជូនទៅកន្លែងដែល ភាគីបានជូនដំណឹងនោះ។
- ទោះជនដែលត្រូវទទួលការបញ្ជូនមានលំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម និងទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាច្បាស់លាស់ និងមានការជូនដំណឹងពីទីកន្លែងដែលត្រូវធ្វើការបញ្ជូនក៏ដោយ បើភាគីមិនប្រកែកចំពោះការបញ្ជូននៅកន្លែងដែលជួបប្រទះទេ គឺអាចធ្វើបាន។
  - *ឧទាហរណ៍៖ ករណីទូរស័ព្ទហៅភាគីមកតុលាការ ហើយប្រគល់ឯកសារទៅគូភាគីនៅតុលាការ ។*

20

## ៥-២ ការបញ្ជូនដោយបង្គ្រប់កិច្ច (ម.២៥២ -១ក្រមនីតិវិធីរ/ណី)

- ករណីពុំបានជួបជន ដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូនទេ គឺអាចប្រគល់ឯកសារនោះទៅឲ្យអ្នកបំរើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬអ្នកនៅជាមួយដែលមានការយល់ដឹងសមរម្យ។

❖ <u>អ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ:</u>

- អ្នកដែលយល់ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន
- យល់ពីអត្ថន័យនៃឯកសារដែលបានទទួល និង
- មានសមត្ថភាពអាចយកឯកសារនោះ ទៅប្រគល់ឲ្យជនដែលត្រូវទទួលការបញ្ជូន។

➢ <u>ឧទាហរណ៍:</u>

- ករណីដែលចុងចម្លើយជាក្រុមហ៊ុន ត្រូវបញ្ជូនទៅក្រុមហ៊ុននោះ។
- ភរិយា អាចទទួលជំនួសប្ដីដែលជាបុគ្គលដែលត្រូវទទួលការបញ្ជូនបាន ប៉ុន្តែបើភរិយាជា អ្នកប្ដឹងប្ដី នោះការទទួលការបញ្ជូនរបស់ភរិយាជំនួសប្ដី នឹងត្រូវចាត់ទុកជាមោឃៈ ព្រោះមានទំនាស់ ផលប្រយោជន៍ ម្យ៉ាងទៀតយើងមិនរំពឹងថាភរិយានឹងយកឯកសារដែលត្រូវបញ្ជូននោះទៅឲ្យប្ដីទេ)។ (ការអនុវត្តដោយស្រដៀង ម.២៥២ ក្រមនីតិវិធីរ/ណី)។

21

# ៥-៣. ការបញ្ជូនដោយទុកចោល (ម.២៥២-២ ក្រមនីតិវិធីរ/ណី)

❖បើជនដែលទទួលការបញ្ជូន ឬជនដែលត្រូវទទួលការបញ្ជូន ដោយការបង្គ្រប់កិច្ច មិនព្រមទទួលការបញ្ជូន ដោយគ្មានមូលហេតុត្រឹមត្រូវ អាចទុកឯកសារដែលត្រូវបញ្ជូនចោលនៅទីកន្លែងនោះបាន។

ឧទាហរណ៍

- ដីការកោះត្រូវបញ្ជូនទៅឲ្យលោក A(ដើមចោទ) ពេលអាជ្ញាសាលាយកឯកសារនោះទៅដល់ផ្ទះលោក A មិនបានជួបលោក A ទេ ជួបតែកញ្ញា B ដែលជាអ្នកបម្រើរបស់លោក A អាជ្ញាសាលាក៏ប្រគល់ ឯកសារនោះឲ្យទៅកញ្ញា B ដើម្បីទុកឲ្យលោក A តែកញ្ញា B បានបដិសេធមិនទទួលដោយសំអាង ថាខ្លួនជាអ្នកបម្រើមិនហ៊ានទទួល ការសំអាងបែបនេះ គឺមិនអាចនិយាយថាមានមូលហេតុត្រឹមត្រូវទេ អាជ្ញាសាលា ក៏បានទុកឯកសារនៅទីនោះ គឺនៅចំពោះមុខកញ្ញា B។
- ករណីឧទាហរណ៍ដូចខាងលើដែល កញ្ញា B បានបដិសេធមិនទទួលដោយសំអាង ថា លោក A និងក្រុមគ្រួសារគាត់ទាំងអស់មិននៅទេ ពួកគាត់បានទៅបរទេសអស់ហើយ ទាល់តែ ២ខែក្រោយបានមកវិញ ហើយខ្លួនគ្មានមធ្យោបាយអាចទាក់ទងគាត់បានទេ ការសំអាងបែបនេះ គឺ មានមូលហេតុត្រឹមត្រូវ នោះមិនអាចទុកឯកសារនៅកន្លែងនោះបានទេ។

22

# ៦- ការបញ្ជូនទៅបរទេស (ម. ២៥៣ ក្រមនីតិវិធីរ/ណី)

- ករណី: **ជនដែលត្រូវទទួលការបញ្ជូន** មានទីលំនៅនៅបរទេស ហើយពុំមានទីសំណាក់ ទីកន្លែង អាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនចំពោះជននេះ **អាចមានរបៀប២** ដើម្បីបញ្ជូន:
  1. ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។
  2. ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរ តែរស់នៅបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។

❑មុននឹងបញ្ជូន តុលាការគប្បីពិនិត្យមើល អនុសញ្ញា ឬសន្ធិសញ្ញារវាងប្រទេសនោះនឹងប្រទេសកម្ពុជា ឬកិច្ចព្រមព្រៀងផ្សេងទៀត ឬការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ព្រោះមានករណីខ្លះក្នុងបទដ្ឋានគតិយុត្តិទាំងនេះមានកំណត់ពីរបៀបនៃការបញ្ជូន។

❑ចំពោះការបញ្ជូនទៅជនបរទេសដែលរស់នៅក្នុងព្រះរាជាណាច្រកម្ពុជាវិញ ត្រូវប្រើតាមវិធីនៃការបញ្ជូនដូចជាការបញ្ជូនចំពោះជនជាតិខ្មែរដែរ។

23

# ៧- ការបញ្ជូនតាមការផ្សាយជាសាធារណៈ

៧-១. លក្ខខណ្ឌ

➢ករណី ទោះប្រឹងប្រែងស្រាវជ្រាវរកយ៉ាងណា ***ក៏មិនអាចដឹងពីទីកន្លែងដែលត្រូវបញ្ជូន***។

➢ករណី យើងដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែ ***ការបញ្ជូនមិនអាចធ្វើបាន*** ទោះជាយើងព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ។

➢ករណី ***មិនអាចធ្វើការបញ្ជូនទៅបរទេស*** ដោយការប្រគល់កិច្ចការបញ្ជូន។

➢ករណីតុលាការ***មិនបានទទួលលិខិតបញ្ជាក់*** ពីការបញ្ជូនពីក្រសួង ឬស្ថាប័ន ដែលមានសមត្ថកិច្ចនៅបរទេស***ក្នុងអំឡុង ៦ខែគិតចាប់ពីពេលបញ្ជូន***។

❖ឲ្យតែមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងលើ គឺអាចធ្វើការបញ្ជូន តាមការផ្សាយជាសាធារណៈបាន។

24

# ៧-ការបញ្ជូនតាមការផ្សាយជាសាធារណៈ (ត)

➢ទាល់តែមានពាក្យសុំរបស់ភាគីដែលសុំឲ្យតុលាការធ្វើការបញ្ជូនតាមការ ផ្សាយជាសាធារណៈ និងបន្ទាប់ពីទទួលបានការអនុញ្ញាតពីតុលាការ (ម. ២៥៥ កថាខណ្ឌទី១ ក្រមនីតិវិធីរ/ណី) ទើបអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន។

❖ប៉ុន្តែដើម្បីជៀសវាងការយឺតយ៉ាវ តុលាការក៏អាចបង្គាប់ឲ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ដោយឆន្ទានុសិទ្ធិទោះជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ក្នុងករណីដែលតុលាការយល់ឃើញថាមានការចាំបាច់ (ម.២៥៥ កថាខណ្ឌ១ និង២ ក្រមនីតិវិធីរ/ណី)។

25

# ៧-ការបញ្ជូនតាមការផ្សាយជាសាធារណៈ (ត)

<u>សម្គាល់</u>:

- បើការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវបានធ្វើ ក្នុងករណីដែលលក្ខខណ្ឌដែលការ បញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលត្រូវបានបំពេញហើយ តែនៅមិនអាចបញ្ជូនបាន នោះក្រឡាបញ្ជី គប្បីជូនដំណឹងដោយរបៀបសមរម្យ (តាមទូរស័ព្ទ, ផ្ញើតាមបុស្តិ៍ប្រៃ សនីយ ឬបិទ នៅលំនៅឋាន, ទីសំណាក់របស់អ្នកដែលត្រូវទទួលការបញ្ជូនជាដើម) អំពីហេតុដែលនាំឲ្យធ្វើការបញ្ជូនជាសាធារណៈទៅភាគីដែលត្រូវទទួលការបញ្ជូននោះ (ម. ២៥៥ កថាខណ្ឌទី៣ ក្រមនីតិវិធីរ/ណី)។
- ការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពី<u>**លើកទី២ទៅ**</u> ចំពោះភាគីដដែល តុលាការត្រូវ ធ្វើដោយឆន្ទានុសិទ្ធិ ប៉ុន្តែចំពោះករណីការបញ្ជូនទៅជនដែលនៅបរទេស ត្រូវតែមានពាក្យសុំរបស់ ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ (ម. ២៥៥ កថាខណ្ឌទី៤ ក្រមនីតិវិធីរ/ណី)។

26

# ៧-២. របៀបបញ្ជូន

## <u>របៀបបញ្ជូន</u>

- ក្រឡាបញ្ជី ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាស របស់តុលាការ ឬទីកន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប (អាចបុស្តិ៍, សាលាឃុំ ...ជាដើម) និងត្រូវប្រកាសថា ក្រឡាបញ្ជី ជាអ្នករក្សាទុកនៅឯកសារដែលធ្វើការបញ្ជូន ហើយឯកសារនេះនិងអាច ប្រគល់ឲ្យជនដែលត្រូវទទួល ការបញ្ជូននៅពេលណាក៏បាន (ម. ២៥៦- ១ និង ២ ក្រមនីតិវិធីរ/ណី)។
- តុលាការអាចចុះក្នុងរាជកិច្ច ឬក្នុងសារព័ត៌មាន ផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ (ម.២៥៦ វាក្យខណ្ឌទី២ កថាខណ្ឌទី៣ ក្រមនីតិវិធីរ/ណី)។
- ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីមិនចាំបាច់ផ្សាយក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានក៏បាន។

# ៧-៣. អានុភាព

- <u>ការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈ</u> នឹងមានអានុភាពជាការបញ្ជូននៅក្រោយ អំឡុងពេល <u>**២សប្តាហ៍**</u>បានកន្លងហួស ដោយគិតពីថ្ងៃដែលបានបិទប្រកាសតាម ម. ២៥៧-១ ក្រមនីតិវិធីរ/ណី)។
- ក៏ប៉ុន្តែ ការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈជាលើកទី២ ទៅនឹងមានអានុភាពនៅថ្ងៃ បន្ទាប់ពីថ្ងៃបិទប្រកាសនោះ (ម. ២៥៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ ក្រមនីតិវិធីរ/ណី)។
- អានុភាពនៅទីនេះ មានន័យថា ការបញ្ជូនមានសុពលភាព ហើយត្រូវចាត់ទុកថា អ្នកដែលត្រូវទទួលការបញ្ជូនបានទទួលការបញ្ជូននេះ។
- ចំពោះ <u>**ការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈ**</u> ដែលត្រូវធ្វើនៅបរទេស នឹងមានអានុភាពជាការបញ្ជូន នៅក្រោយអំឡុងពេល <u>០៦ សប្តាហ៍</u> បន្ទាប់ពីថ្ងៃបិទប្រកាស (ម. ២៥៧-២ ក្រមនីតិវិធីរ/ណី)។



គំនូសបំព្រួញលំហូរនីតិវិធីនៃការបញ្ជូន



29

# សូមអរគុណ!

សំនួរ-ចម្លើយ!


មានការជូនដំណឹងអំពីទីកន្លែងដែលត្រូវបញ្ជូន
បញ្ជូនទៅកន្លែងដែលត្រូវបញ្ជូន(២៥០-៤)
សម្រេចការបញ្ជូន
បញ្ជូនដោយបង្គ្រប់កិច្ចទៅកន្លែងដែលត្រូវបញ្ជូន (២៥២-១)
មិនសម្រេច
ការបញ្ជូនដោយការផ្សាយជាសាធារណៈ (២៥៥-១ខ)
បដិសេធមិនទទួល
បញ្ជូនដោយទុកចោល(២៥២-២)
មិនសម្រេច
ដឹងកន្លែងច្បាស់
បុគ្គល
លំនៅដ្ឋាន ទីសំណាក់
នីតិបុគ្គល
ទីកន្លែងអាជីវកម្ម ទីស្នាក់ការ លំនៅដ្ឋាន ឬ ទីសំណាក់ របស់អ្នកតំណាង
បញ្ជូនដោយបង្គ្រប់កិច្ចទៅកន្លែងដែលត្រូវបញ្ជូន (២៥២-១)
គ្មានការជូនដំណឹងអំពីទីកន្លែងដែលត្រូវបញ្ជូន
កន្លែងដែលត្រូវបញ្ជូន (២៤៩)
ពុំច្បាស់ថាជនដែលត្រូវទទួលការបញ្ជូនមានលំនៅដ្ឋានដើមនៅប្រទេសកម្ពុជា
បញ្ជូនដោយជួបប្រទះ (២៥១ វាក្យ.១)
សម្រេចការបញ្ជូន
ទោះបីប្រឹងប្រែងស្រាវជ្រាវរកយ៉ាងណា ក៏មិនអាចដឹងពីលំនៅដ្ឋាន ជាដើម
មិនសម្រេច
ការបញ្ជូនដោយការផ្សាយជាសាធារណៈ (២៥៥-១ក)

# នីតិវិធីនៃការបញ្ជូន

## ១.អត្ថន័យនៃការបញ្ជូន ៖

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។

ការជូនដំណឹង គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូនដោយអ្នកប្រតិបត្តិការបញ្ជូន អាចប្រើគ្រប់មធ្យោបាយដែលអាចធ្វើបានដែលមានដូចជា តាមទូរស័ព្ទ អ៊ីម៉ែល តាមប្រៃសនីយ៍ តាមសំបុត្រ ដើម្បីឲ្យអ្នកត្រូវទទួលការបញ្ជូនបានដឹង ហើយក្នុងនោះនីតិវិធីនៃការបញ្ជូនក៏ជាមធ្យោបាយមួយនៃការជូនដំណឹងផងដែរ។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានឯកសារខ្លះដែលច្បាប់បានបញ្ញត្តិឲ្យត្រូវធ្វើការបញ្ជូន។ ចំណែក ឯកសារខ្លះទៀត ច្បាប់កំណត់ដោយគ្រាន់តែឲ្យធ្វើការជូនដំណឹងប៉ុណ្ណោះ។

ឯកសារដែលច្បាប់កំណត់ឲ្យធ្វើការបញ្ជូនមានដូចជា: ពាក្យបណ្តឹងតាមមាត្រា ៧៩ ក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុបណ្តឹងតាមមាត្រា ៨៥-៣ ក្រមនីតិវិធីរដ្ឋប្បវេណី អនុស្សារសាលក្រម មាត្រា ១៩០ ក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យបណ្តឹងទាស់តាមមាត្រា ២០៦-៤ ក្រមនីតិវិធីរដ្ឋប្បវេណី លិខិតដកពាក្យបណ្តឹងតាមមាត្រា ២១៧-៤ ក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ តាមមាត្រា ៤១៩-២ ក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចរក្សាការពារតាមមាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណីជាដើម។

រីឯឯកសារដែលច្បាប់កំណត់ឲ្យគ្រាន់តែធ្វើការជូនដំណឹងមានដូចជា៖ ការកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្តើមនីតិវិធីយោងតាមពាក្យបណ្តឹងទាស់តាមមាត្រា ២០៨-២ ក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចតាមមាត្រា ២៣១-១ ក្រមនីតិវិធីរដ្ឋប្បវេណី កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តាមមាត្រា ៤៤០-២ ក្រមនីតិវិធីរដ្ឋប្បវេណី ការកំណត់ពេលបង់ថ្លៃលក់តាមមាត្រា៤៧៨ ក្រមនីតិវិធីរដ្ឋប្បវេណីជាដើម។

ទោះជាមានបញ្ញត្តិមួយចំនួននៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ឲ្យធ្វើការជូនដំណឹងក៏ដោយ យកល្អគប្បីគួរធ្វើការបញ្ជូន ដើម្បីមានរបាយការណ៍បញ្ជូនទុកក្នុងសំណុំរឿងជាសំអាង ជៀសវាងភាគីតវ៉ាថា ពួកគាត់មិនបានទទួលដំណឹងពីតុលាការ។

ជាគោលការណ៍ ការបញ្ជូនត្រូវធ្វើដោយឆន្ទានុសិទ្ធិ លើកលែងតែករណីមានបញ្ញត្តិពិសេសក្នុងច្បាប់។ ហើយឯកសារដែលត្រូវបញ្ជូន គឺជាឯកសារថតចម្លង លើកលែងតែករណីមានបញ្ញត្តិពិសេសក្នុងច្បាប់ផងដែរ។

## ២.ស្ថាប័នដែលធ្វើការបញ្ជូន ៖

ស្ថាប័នដែលធ្វើការបញ្ជូនមាន២ គឺស្ថាប័នចាត់ចែងកិច្ចការបញ្ជូន និងស្ថាប័នប្រតិបត្តិការបញ្ជូន។

### ២.១ ស្ថាប័នចាត់ចែងកិច្ចការបញ្ជូន ៖

ស្ថាប័នចាត់ចែងកិច្ចការបញ្ជូននេះ គឺមានមន្ត្រីរដ្ឋបាលដែលទទួលបន្ទុកកិច្ចការបញ្ជូន មន្ត្រីនៅទីនេះសំដៅលើ ក្រឡាបញ្ជី (មាត្រា ២៤៦-២ នៃក្រមនីតិវិធីរ/ណី)។ មុខងាររបស់មន្ត្រីរដ្ឋបាលដែលទទួលបន្ទុកកិច្ចការបញ្ជូន គឺធ្វើ ឬផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូន ហើយ ប្រគល់អំណាចនៃការបញ្ជូនឯកសារនេះទៅឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ហើយបន្ទាប់មកទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ រួចត្រូវយករបាយការណ៍នៃការបញ្ជូននេះទៅជូនចៅក្រម ដើម្បីឲ្យចៅក្រមពិនិត្យថាតើការបញ្ជូននេះត្រឹមត្រូវហើយ ឬនៅ។ ចុងក្រោយមន្ត្រីរដ្ឋបាលដែលទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវរក្សារ របាយការណ៍នៃការបញ្ជូននេះ និងទុកក្នុងសំណុំរឿង ដោយរៀបចំទុកឲ្យបានត្រឹមត្រូវទៅតាមកាលបរិច្ឆេទនៃលំដាប់ឯកសារ។

## ២.២ ស្ថាប័នប្រតិបត្តិការបញ្ជូន ៖

ស្ថាប័នប្រតិបត្តិការបញ្ជូននេះ គឺមានមន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូនមន្ត្រីនៅទីនេះសំដៅលើបុគ្គលិកប្រៃសនីយ៍ អាជ្ញាសាលា និងក្រឡាបញ្ជី (មាត្រា ២៤៦-៣ នៃក្រមនីតិវិធីរ/ណី)។ មុខងាររបស់មន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូន គឺធ្វើការបញ្ជូនដោយដាក់លាក់ចំពោះជនដែលត្រូវទទួលការបញ្ជូន ហើយត្រូវធ្វើរបាយការណ៍អំពីការបញ្ជូនតាមមាត្រា ២៥៤ នៃក្រមនីតិវិធីរ/ណី រួចត្រូវដាក់របាយការណ៍អំពីការបញ្ជូននេះទៅតុលាការដើម។

**<u>ចំណាំ៖</u>** ដោយសារតែស្ថានភាពបច្ចុប្បន្នរបស់យើងមិនទាន់មានមន្ត្រីអាជ្ញាសាលា ហេតុនេះដើម្បីសម្រួលដល់ការអនុវត្តច្បាប់ ក្រសួងយុត្តិធម៌ក៏បានចេញសេចក្តីប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ ៣០ កយប្រក/០៧ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧ ដោយកំណត់យកព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងជាអ្នកអនុវត្តកិច្ចការអាជ្ញាសាលា ដើរតួនាទីក្នុងនាមជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលានៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងដែលព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ស្ថិតនៅក្រោមជាបណ្តោះអាសន្នរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីអាជ្ញាសាលា។ តាមសេចក្តីប្រកាសនេះ រាល់កិច្ចការបញ្ជូនទាំងឡាយដែលជាតួនាទីរបស់អាជ្ញាសាលា គឺត្រូវធ្វើជំនួសដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។

## ៣. របាយការណ៍បញ្ជូន ៖

របាយការណ៍បញ្ជូនត្រូវមានបញ្ជាក់អំពីចំណុចដូចខាងក្រោម (មាត្រា ២៥៤-២ នៃក្រមនីតិវិធីរ/ណី)៖

**ក.** សញ្ញាណនៃរឿងក្តី៖ ត្រូវសរសេរបញ្ជាក់អំពីប្រភេទនៃរឿងក្តី អាចជារឿងក្តីទាមទារប្រាក់កម្ចី រឿងក្តីលែងលះ ឬសុំបែងចែកមរតកជាដើម។

**ខ.**ឯកសារដែលបានបញ្ជូន៖ ត្រូវសរសេរឈ្មោះឯកសារដែលយើងត្រូវបញ្ជូនឯកសារទាំងនោះអាចមានដូចជា ដីកោះហៅឲ្យចូលមកធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ឬដីកាសម្រេចរក្សាការពារជាដើម។

**គ.** ជនដែលត្រូវទទួលការបញ្ជូនៈ ត្រូវសរសេរឈ្មោះជនដែលត្រូវទទួលការបញ្ជូន អាចជាដើមចោទ ចុងចម្លើយ ឬសាក្សីជាដើម ហើយយកល្អគួរសរសេរពីអាស័យដ្ឋានរបស់ជននេះផង។

**ឃ.** ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលទទួលឯកសារ។

**ង.** ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូនៈ បញ្ជាក់អំពីទីកន្លែងដែលបានធ្វើការបញ្ជូន អាចជាទីលំនៅ ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន និងត្រូវបញ្ជាក់ផងថា ការបញ្ជូននេះធ្វើនៅថ្ងៃទីប៉ុន្មាន ខែណា ឆ្នាំណា។

**ច.** វិធីបញ្ជូនៈ វាអាចមានវិធីច្រើនក្នុងការបញ្ជូន ហើយវិធីនេះមានដូចជាៈ

ក. ការបញ្ជូនដោយការប្រគល់

ខ. ការបញ្ជូនដោយការជួបប្រទះ

គ. ការបញ្ជូនដោយបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោល

ហើយបើមានករណីដូចខាងក្រោម មន្រ្តីទទួលបន្ទុកប្រតិបត្តិការបញ្ជូនត្រូវបញ្ជាក់អំពីហេតុនៃការបញ្ជូននៅក្នុងរបាយការណ៍ៈ

១. ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូនមិនចេះអក្សរ មាត្រា ២៤៧-៣ នៃក្រមនីតិវិធីរ/ណីៈ គប្បីបញ្ជាក់ថា ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននេះមិនចេះអានអក្សរ។

២. ក្នុងករណីបានប្រគល់ទៅឲ្យអ្នក ដែលមានការយល់ដឹងសមរម្យចំពោះការ ទទួលឯកសារមាត្រា ២៥២-១ នៃក្រមនីតិវិធីរ/ណី (គប្បីបញ្ជាក់អត្តសញ្ញាណ របស់អ្នកទទួល នេះផង)ៈ គប្បីបញ្ជាក់ថា ខ្ញុំបានប្រគល់ទៅឲ្យអ្នកដែលមានការយល់ដឹង សមរម្យចំពោះការ ទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយ ផ្ទាល់នៅទីកន្លែង ដែលត្រូវបញ្ជូននោះទេ។

៣. ក្នុងករណីឯកសារត្រូវបានទុកចោលនៅទីកន្លែង ដែលត្រូវបញ្ជូនមាត្រា ២៥២-២ នៃក្រមនីតិវិធីរ/ណី (គប្បីបញ្ជាក់អត្តសញ្ញាណរបស់អ្នកទទួលនេះផង): គប្បីបញ្ជាក់ថា ឯកសារត្រូវបានទុកចោលនៅទីកន្លែងដែលត្រូវបញ្ជូន ដោយហេតុថាបុគ្គលនោះមិនព្រមទទួលការបញ្ជូនដោយ គ្មានហេតុផល ហេតុផលរបស់បុគ្គលនោះ ដូចជាខ្ញុំមិនទទួលជាដើម។

**ឆ.** ឈ្មោះ ហត្ថលេខារបស់អ្នកប្រតិបត្តិការបញ្ជូនៈ ចំពោះឈ្មោះរបស់អ្នកប្រតិបត្តិការបញ្ជូន ក្រមនីតិវិធីរដ្ឋប្បវេណីមិនមានចែងថាអោយសរសេរនៅលើរបាយការណ៍នោះទេ។ ប៉ុន្តែយកល្អយើងគួរគប្បីសរសេរដើម្បីងាយស្រួលទាំងតុលាការ និងគូភាគីអាចដឹងថាអ្នកណាជាទទួលបន្ទុកប្រតិបត្តិការបញ្ជូន។

**ជ.** ឈ្មោះរបស់អ្នកចាត់ចែងកិច្ចការបញ្ជូនៈ ឈ្មោះរបស់អ្នកចាត់ចែងការបញ្ជូននេះ ក្រមនីតិវិធីរដ្ឋប្បវេណីក៏មិនមានចែងថាអោយសរសេរនៅលើរបាយការណ៍ដែរ។ ប៉ុន្តែយកល្អយើងគួរគប្បីសរសេរ ដើម្បីងាយស្រួលទាំងតុលាការ និងគូភាគីអាចដឹងថាអ្នកណាជាក្រឡាបញ្ជីទទួលបន្ទុករឿងក្តី។

**ឈ.** កាលបរិច្ឆេទធ្វើរបាយការណ៍ និងកាលបរិច្ឆេទផ្ញើរបាយការណ៍ចេញ៖ កាលបរិច្ឆេទទាំង ២ នេះ ក្រមនីតិវិធីរដ្ឋប្បវេណីក៏មិនមានចែងថាអោយសរសេរនៅលើរបាយការណ៍ដែរ។ ប៉ុន្តែយកល្អ យើង គួរគប្បីសរសេរ ដើម្បីងាយស្រួលតុលាការតាមដានសំណុំរឿង។

ករណីដែលព្យាយាមបញ្ជូនតាមគ្រប់វិធី តែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូន ត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះជូនទៅតុលាការ ដោយគប្បីបញ្ជាក់ថាខ្ញុំមិនអាចធ្វើការ បញ្ជូនឯកសារដែលត្រូវបញ្ជូនបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបជន ដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះ។

## ៤. ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង ៖

មុននឹងយល់ច្បាស់ថា ដើម្បីធ្វើការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង ស្ថាប័ន ចាត់ចែងការបញ្ជូន និងស្ថាប័នទទួលបន្ទុកកិច្ចការបញ្ជូនត្រូវធ្វើរបៀបណាខ្លះនោះ យើងត្រូវយល់ជា មុនសិនថា បុគ្គលបែបណាដែលអសមត្ថភាពក្នុងការធ្វើបណ្តឹង។

ជាគោលការណ៍ ទាល់តែបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិ នៃក្រម និងច្បាប់ផ្សេងទៀតបាន ទើបបុគ្គលនោះអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន (មាត្រា៣២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរ/ណី) ហើយតាមមាត្រា ១៦ នៃក្រមរ/ណី បានកំណត់ថា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមិនអាចធ្វើ សកម្មភាពបណ្តឹងដោយខ្លួនឯងបានទេ (អសមត្ថភាពក្នុងការធ្វើបណ្តឹង)។ ដូចនេះ សកម្មភាព បណ្តឹងរបស់ ជនទាំង ៣ ប្រភេទនេះ គឺត្រូវធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ប៉ុន្តែមាន ករណីលើកលែងចំពោះ៖

**១.** អនីតិជនដែលទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្មពីអ្នកមានអំណាចមេបា ឬអ្នកអាណា ព្យាបាលសម្រាប់អនីតិជន (មាត្រា ២០-១ នៃក្រមរ/ណី)។

**២.** អនីតិជនដែលទទួលបានអត្តាធិនភាព (មាត្រា ២១ នៃក្រមរ/ណី)។

អនីតិជនទាំង ២ប្រភេទនេះ គឺអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន ដោយមិនចាំបាច់ ឆ្លងអ្នកតំណាងដែលច្បាប់បានកំណត់។ ចំពោះអនីតិជនដែលទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្ម មានសមត្ថភាពក្នុងការធ្វើបណ្តឹងបានត្រឹមតែបណ្តឹង "ទាក់ទងនឹងជំនួញ" ដែលអនុញ្ញាតនោះ ប៉ុណ្ណោះ។ ដូចនេះទោះបីជាអនីតិជនដែលទទួលបានការអនុញ្ញាតិឲ្យធ្វើអាជីវកម្មក៏ដោយ បើមិនមែន ជាបណ្តឹង ទាក់ទងនឹងអាជីវកម្មដែលបានអនុញ្ញាតិនោះទេ អនីតិជននោះនៅតែជាបុគ្គលអសមត្ថ ភាពដដែល។

<u>**កំណត់សំគាល់:**</u>

-អ្នកតំណាងដែលច្បាប់បានកំណត់ចំពោះអនីតិជន សំដៅលើអ្នកមានអំណាចមេបា ឬអ្នក អាណាព្យាបាល (មាត្រា ១០៣៤, ១០៥៣, ១០៦៧ និង ១០៧៩ កថាខណ្ឌទី១ នៃក្រម រ/ណី)។

-អ្នកតំណាងដែលច្បាប់បានកំណត់ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ សំដៅលើអ្នកអាណាព្យាបាលទូទៅ (មាត្រា ២៥ និង មាត្រា ១១១៤ កថាខណ្ឌទី ១ នៃក្រមរ/ណី)។

-អ្នកតំណាងដែលច្បាប់បានកំណត់ចំពោះជននៅក្រោមហិតូបត្ថម្ភ សំដៅលើហិតូបត្ថម្ភកៈ (មាត្រា២៩, ៣០ និង មាត្រា ១០៣៩ កថាខណ្ឌទី ១ នៃក្រមរ/ណី)។

ដោយសារតែមានជនមួយចំនួន ដែលច្បាប់កំណត់អោយអសមត្ថភាពក្នុងការធ្វើបណ្តឹងនេះ ហើយ ទើបមាត្រា ២៤៨ នៃក្រមនីតិវិធីរ/ណីបានចែងថា ករណីការបញ្ជូនត្រូវធ្វើទៅបុគ្គលដែលអសមត្ថភាពក្នុងការធ្វើបណ្តឹង អ្នកទទួលបន្ទុកការបញ្ជូន ត្រូវបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកទាំងនោះ។ ហើយបើមានអ្នកតំណាងដែលច្បាប់បានកំណត់រួមគ្នាច្រើននាក់ ការបញ្ជូនអាចធ្វើទៅអ្នកតំណាងដែលច្បាប់បានកំណត់ណាមួយជាការគ្រប់គ្រាន់។

ចំពោះការបញ្ជូនទៅជនដែលជាប់ឃុំនៅក្នុងពន្ធនាគារ គឺត្រូវបញ្ជូនទៅឲ្យប្រធានពន្ធនាគារ ហើយជនដែលជាប់ឃុំនៅក្នុងពន្ធនាគារ មិនចាត់ទុកថាជាជនដែលអសមត្ថភាពក្នុងការធ្វើបណ្តឹងទេ។ ប៉ុន្តែច្បាប់បញ្ញត្តិឲ្យបញ្ជូនទៅប្រធានពន្ធនាគារ ការកំណត់បែបនេះដោយសារតែប្រធានពន្ធនាគារ គឺជាអ្នកគ្រប់គ្រងអ្នកជាប់ឃុំទាំងនោះ (មាត្រា ២៤៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរ/ណី)។

## ៥. ការបញ្ជូនដោយការប្រគល់ ៖

ជាគោលការណ៍ការបញ្ជូនត្រូវធ្វើតាម វិធីប្រគល់ឯកសារទៅឲ្យជនដែលត្រូវទទួលការ បញ្ជូននេះគេហៅថាការបញ្ជូនដោយប្រគល់ (មាត្រា ២៤៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរ/ណី។ ជាគោលការណ៍ទីកន្លែងដែលត្រូវធ្វើការបញ្ជូនដោយការប្រគល់ គឺនៅលំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន (មាត្រា ២៤៩ នៃក្រមនីតិវិធី រ/ណី) ហើយបើការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់អ្នកតំណាងនោះបាន។ ប៉ុន្តែក្នុងករណីដែលភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់បានជូនដំណឹង អំពីទីកន្លែងដែលត្រូវបញ្ជូន ឬអ្នកដែលទទួលការបញ្ជូន គឺត្រូវបញ្ជូនទៅទីកន្លែងដែលបានជូនដំណឹងនោះ (មាត្រា ២៥០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរ/ណី)។ ការជូនដំណឹងនេះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ទើបអាចទទួលយកបាន (មាត្រា ២៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរ/ណី)។ មានករណីខ្លះភាគី ឬអ្នក តំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិ បានសរសេរបញ្ជាក់រួចជាស្រេចនៅក្នុង ពាក្យបណ្តឹងអំពីទីកន្លែងដែលត្រូវបញ្ជូន បើក្នុងពាក្យបណ្តឹងបានសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូន បែបនេះ យើងចាត់ទុកថាភាគីបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីទីកន្លែងដែលត្រូវបញ្ជូនរួចហើយ ហើយការជូនដំណឹងអំពីទីកន្លែងដែលត្រូវបញ្ជូនបើធ្វើតាមនីតិវិធីបានត្រឹមត្រូវហើយ គឺអានុភាពរបស់វាបន្តរហូតដល់តុលាការជាន់ខ្ពស់។ ដើម្បីងាយស្រួលសម្រាប់ធ្វើការបញ្ជូនយកល្អតុលាការគួរតែសួរភាគីអំពីទីកន្លែងដែលត្រូវបញ្ជូន ហើយឲ្យភាគីជូនដំណឹងជាលាយលក្ខអក្សរអំពីទីកន្លែងដែលត្រូវ បញ្ជូននេះមកតុលាការ។

ឧទាហរណ៍៖

ពាក្យបណ្តឹង

-ដើមចោទឈ្មោះ **ក** ភេទស្រី អាយុ ៣០ឆ្នាំ មានទីលំនៅផ្ទះលេខ ២៣៧ ផ្លូវលេខ ៣៨ ភូមិ ០៧ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ចុងចម្លើយឈ្មោះ **ខ** ភេទប្រុស អាយុ ៣៣ឆ្នាំ មានទីលំនៅផ្ទះលេខ ២៣៧ ផ្លូវលេខ ៣៨ ភូមិ០៧ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

(ទីកន្លែងដែលត្រូវបញ្ជូនរបស់ដើមចោទៈ ផ្ទះលេខ ១១៧ ផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកង ទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។)

បើដើមចោទមានការជូនដំណឹងបែបនេះ យើងត្រូវបញ្ជូនទៅដើមចោទទៅតាមអាស័យដ្ឋាន ដែលបានជូនដំណឹង គឺផ្ទះលេខ ១១៧ ផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកង ទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ)។

បើអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូន គប្បីពន្យល់នូវខ្លឹមសារនៃ ឯកសារនេះទៅអ្នកទទួលនោះ នៅពេលប្រគល់ឯកសារ (មាត្រា ២៤៧-៣នៃក្រមនីតិវិធីរ/ណី)។

បែបផែនពិសេសនៃការបញ្ជូនដោយប្រគល់មានដូចខាងក្រោមៈ

### ៥.១ ការបញ្ជូនដោយការជួបប្រទះ ៖

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ពុំច្បាស់លាស់ថា មានលំនៅឋាន, ទីសំណាក់, ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលជួប ជននោះ លើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬអ្នក ដែលទទួលការបញ្ជូនតាមមាត្រា ២៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរ/ណី ត្រូវតែបញ្ជូនទៅទីកន្លែង ដែលបានជូនដំណឹងនោះ។ ម្យ៉ាងទៀតទោះបីមាន លំនៅឋាន, ទីសំណាក់, ទីកន្លែងអាជីវកម្ម ឬទី ស្នាក់ការច្បាស់លាស់នៅក្នុងប្រទេសកម្ពុជា ឬមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬអ្នកដែលទទួលការបញ្ជូនក៏ដោយ ក៏អាចធ្វើការបញ្ជូននៅទីកន្លែងដែលបានជួបប្រទះជននោះបាន ដែរ ប្រសិនបើជននោះមិនប្រកែកចំពោះការទទួលការបញ្ជូនទេ។ នេះគេហៅថាការ បញ្ជូនដោយ ការជួបប្រទះ (មាត្រា ២៥១ នៃក្រមនីតិវិធីរ/ណី)។

### ៥.២ ការបញ្ជូនដោយបង្គ្រប់កិច្ច ៖

ប្រសិនបើមិនបានជួបជនដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូនទេ អាច ប្រគល់ ឯកសារនោះទៅឲ្យអ្នកបម្រើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយ ដែលមាន ការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះ។ នេះគេហៅថា ការបញ្ជូនដោយបង្គ្រប់ កិច្ច (មាត្រា ២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរ/ណី)។ តើបុគ្គលបែបដែលយើងចាត់ទុកជាអ្នកដែល មានការយល់ ដឹងសមរម្យក្នុងការទទួលឯកសារ? អ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួល ឯកសារ គឺជាអ្នកដែលយល់ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន, យល់ពីអត្ថន័យនៃឯកសារដែល បានទទួល និងមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឲ្យជនដែលត្រូវទទួលការបញ្ជូន។

**<u>ឧទាហរណ៍:</u>**

-ករណីដែលចុងចម្លើយជាក្រុមហ៊ុន ត្រូវបញ្ជូនទៅបុគ្គលិករបស់ក្រុមហ៊ុននោះ។

-ភរិយា អាចទទួលជំនួសប្តីដែលជាបុគ្គលដែលត្រូវទទួលការបញ្ជូនបាន ប៉ុន្តែបើភរិយាជាអ្នកប្តឹងប្តី នោះការទទួលការបញ្ជូនរបស់ភរិយាជំនួសប្តី នឹងត្រូវចាត់ទុកជាមោឃៈ ព្រោះមានទំនាស់ផលប្រយោជន៍ ម្យ៉ាងទៀតយើងមិនរំពឹងថាភរិយានឹងយកឯកសារដែលត្រូវបញ្ជូននោះទៅឲ្យប្តីទេ។

### ៥.៣ ការបញ្ជូនដោយទុកចោល ៖

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬជនដែលត្រូវទទួលការបញ្ជូនដោយបង្គ្រប់កិច្ច តាមមាត្រា ២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរ/ណី មិនទទួលការបញ្ជូន ដោយគ្មានមូលហេតុត្រឹមត្រូវទេ មន្រ្តីប្រតិបត្តិការបញ្ជូន អាចទុកឯកសារដែលត្រូវបញ្ជូននោះចោលនៅទីកន្លែងនោះបាន ហើយកិច្ចការនេះមានអានុភាពជាការបញ្ជូនដែរ។ នេះគេហៅថា ការបញ្ជូនដោយទុកចោល (មាត្រា ២៥២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរ/ណី)។

ឧទាហរណ៍:

-ដីការកោះត្រូវបញ្ជូនទៅឲ្យលោក A ពេលអាជ្ញាសាលាយកឯកសារនោះទៅដល់ផ្ទះលោក A មិនបានជួបលោក A ទេ ជួបតែកញ្ញា B ដែលជាអ្នកបម្រើរបស់លោក A អាជ្ញាសាលាក៏ប្រគល់ ឯកសារនោះឲ្យទៅកញ្ញា B ដើម្បីទុកឲ្យលោក A តែកញ្ញា B បានបដិសេធមិនទទួលដោយសំអាង ថាខ្លួនជាអ្នកបម្រើមិនហ៊ានទទួល ការសំអាងបែបនេះ គឺមិនមានមូលហេតុត្រឹមត្រូវទេ អាជ្ញាសាលា ក៏បានទុកឯកសារនៅទីនោះ គឺនៅចំពោះមុខកញ្ញា B។

-ករណីឧទាហរណ៍ដូចខាងលើដដែល កញ្ញា B បានបដិសេធមិនទទួលដោយសំអាង ថាលោក A និងក្រុមគ្រួសារគាត់ទាំងអស់មិននៅទេ ពួកគាត់បានទៅបរទេសអស់ហើយ ទាល់តែ ២ខែក្រោយបានមកវិញ ហើយខ្លួនគ្មានមធ្យោបាយអាចទាក់ទងគាត់បានទេ ការសំអាងបែបនេះ គឺ មានមូលហេតុត្រឹមត្រូវ នោះមិនអាចទុកឯកសារនៅកន្លែងនោះបានទេ។

## ៦. ការបញ្ជូនទៅបរទេស ៖

បើជនដែលត្រូវទទួលការបញ្ជូនមានទីលំនៅនៅបរទេស ហើយពុំមានទីសំណាក់, ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនចំពោះជននេះ គឺត្រូវបញ្ជូនទៅប្រទេសរបស់ជននោះ ដោយអាចមានរបៀប២ដើម្បីបញ្ជូន៖

១.ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។

២.ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។

ទោះបីប្រើវិធីណាមួយក្នុងចំណោមវិធី២ ខាងលើក៏ដោយ មុននឹងសម្រេចថាបញ្ជូនឲ្យស្ថាប័នណាជាអ្នកមាននួនាទីក្នុងការបញ្ជូន តុលាការគប្បីពិនិត្យមើលអនុសញ្ញា ឬសន្ធិសញ្ញារវាងប្រទេសនោះ និងប្រទេសកម្ពុជា ឬកិច្ចព្រមព្រៀងផ្សេងទៀត ឬការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្រែងលោក្នុងបទដ្ឋានគតិយុត្តិទាំងនេះមានកំណត់ពីរបៀបនៃការបញ្ជូន។

ចំពោះករណីបញ្ជូនទៅជនបរទេសដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវប្រើតាមវិធីនៃការបញ្ជូនដូចជាការបញ្ជូនចំពោះជនជាតិខ្មែរដែរ។

## ៧. ការបញ្ជូនតាមការផ្សាយជាសាធារណៈ ៖

### ៧.១ លក្ខខណ្ឌ ៖

ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន គឺត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

-ករណីទោះប្រឹងប្រែងស្រាវជ្រាវរកយ៉ាងណា ក៏មិនអាចដឹងពីទីកន្លែងដែលត្រូវបញ្ជូន។

-ករណីយើងដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែការបញ្ជូនមិនអាចធ្វើបានទោះជាយើងព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ។

-ករណីមិនអាចធ្វើការបញ្ជូនទៅបរទេសដោយការប្រគល់កិច្ចការបញ្ជូន។

-ករណីតុលាការមិនបានទទួលលិខិតបញ្ជាក់ពីការបញ្ជូនពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសក្នុងអំឡុង៦ខែគិតចាប់ពីពេលបញ្ជូន។

ជាក់ស្តែង ឲ្យតែមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងអស់ខាងលើគឺ ក្រឡាបញ្ជីអាចធ្វើ ការបញ្ជូនតាមការផ្សាយជាសាធារណៈបាន។

ជាគោលការណ៍ដើម្បីអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន គឺត្រូវតែមានពាក្យសុំរបស់ភាគីដែលសុំឲ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ និងបន្ទាប់ពីទទួលការអនុញ្ញាតពីតុលាការ (មាត្រា ២៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរ/ណី)។ ប៉ុន្តែដើម្បីជៀសវាងការយឺតយ៉ាវ តុលាការក៏អាចបង្គាប់ឲ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិទោះជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ (មាត្រា ២៥៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរ/ណី)។

<u>ចូរចងចាំថា</u>៖

-បើការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវបានធ្វើ ក្នុងករណីដែលលក្ខខណ្ឌដែលការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលត្រូវបានបំពេញហើយ តែនៅមិនអាចបញ្ជូនបាននោះក្រឡាបញ្ជី គប្បីជូនដំណឹងដោយរបៀបសមរម្យ (តាមទូរស័ព្ទ, ផ្ញើតាមបុស្តិ៍ ប្រៃសនីយ ឬបិទនៅលំនៅឋាន, ទីសំណាក់របស់អ្នកដែលត្រូវទទួលការបញ្ជូនជាដើម) អំពីហេតុដែលនាំឲ្យធ្វើការបញ្ជូនជាសាធារណៈទៅភាគីដែលត្រូវទទួលការបញ្ជូននោះ (មាត្រា ២៥៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរ/ណី)។

-ការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពីលើកទី ២ទៅចំពោះភាគីដដែល តុលាការត្រូវធ្វើដោយឆន្ទានុសិទ្ធិ។ ប៉ុន្តែ ចំពោះករណីការបញ្ជូនទៅជនដែលនៅបរទេស ត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ (មាត្រា២៥៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរ/ណី)។

### ៧.២ របៀបបញ្ជូន ៖

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវធ្វើឡើងដោយវិធីដែលក្រឡាបញ្ជីបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ឬទីកន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប (អាចបិទនៅប៉ុស្តិ៍នគរបាលរដ្ឋបាល, សាលាឃុំ ជាដើម) ដែលក្នុងលិខិតបញ្ជូននោះត្រូវប្រកាសថាក្រឡាបញ្ជីជាអ្នករក្សាទុកនៅឯកសារដែលធ្វើការបញ្ជូន ហើយឯកសារនេះ និងអាចប្រគល់ឲ្យជនដែលត្រូវទទួលការបញ្ជូននៅពេលណាក៏បាន (មាត្រា២៥៦-១ និង ២ នៃក្រមនីតិវិធីរ/ណី)។ លើសពីនេះ តុលាការអាចចុះក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ (មាត្រា២៥៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរ/ណី)។

ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីមិនចាំបាច់ផ្សាយក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានក៏បាន ព្រោះតាមមាត្រា ២៥៦ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរ/ណី បានចែងថា: ការបញ្ជូនទៅបរទេសដែលបានធ្វើតាមមាត្រា ២៥៣ នៃក្រមនីតិវិធីរ/ណី ត្រូវបានចាត់ទុកថា ក្រឡាបញ្ជីបានជូនដំណឹងពីការបញ្ជូនតាមការផ្សាយជាសាធារណៈនេះទៅជនដែលទទួលការបញ្ជូន ហើយក្នុងនោះក្រឡាបញ្ជីគ្រាន់តែបញ្ជាក់លើរបាយការណ៍បញ្ជូនថា បានជូនដំណឹងពីការបញ្ជូន តាមការផ្សាយជាសាធារណៈនេះ ទៅជនដែលត្រូវទទួលការបញ្ជូនហើយជាការគ្រប់គ្រាន់។

### ៧.៣ អានុភាព ៖

ការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ នឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ២សប្តាហ៍បានកន្លងហួស ដោយគិតពីថ្ងៃដែលបានបិទប្រកាសតាមមាត្រា ២៥៧-១ នៃក្រមនីតិវិធីរ/ណី។ ក៏ប៉ុន្តែការបញ្ជូនតាមការផ្សាយជាសាធារណៈជាលើកទី២ ទៅនឹងមានអានុភាពនៅ ថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាសនោះ (តាមមាត្រា ២៥៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរ/ណី)។ ហើយចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលត្រូវធ្វើនៅបរទេស នឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ៦សប្តាហ៍ បន្ទាប់ពីថ្ងៃបិទប្រកាស (តាមមាត្រា ២៥៧-២ នៃក្រមនីតិវិធីរ/ណី)។

អានុភាពនៅទីនេះ មានន័យថាការបញ្ជូនមានសុពលភាព ហើយត្រូវចាត់ទុកថាអ្នកដែលត្រូវទទួលការបញ្ជូន បានទទួលការបញ្ជូននេះ។

ការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ គឺជារបបចាំបាច់មួយ ដើម្បីឲ្យដើមចោទអាចធ្វើបណ្តឹងបាន ទោះជាក្នុងករណីដែលមិនដឹងលំនៅដ្ឋានជាដើមរបស់ចុងចម្លើយក៏ដោយ។ ក៏ប៉ុន្តែមិន

មានការរំពឹងថា ការបញ្ជូនតាមវិធីនេះវាពិបាកនឹងរំពឹងថា ជនដែលត្រូវទទួលការបញ្ជូនបានដឹងអំពីការបញ្ជូននេះ ដូចនេះហើយយើងត្រូវបកស្រាយលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៥៥ កថាខណ្ឌទី១ ចាប់ពីចំណុច "ក" ដល់ "ឃ" ឲ្យបានប្រិតប្រៀង៕

ក្រឡាបញ្ជី
[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*******

**សាលាដំបូង**

**រាជធានីភ្នំពេញ**

*******

សំណុំរឿងរដ្ឋប្បវេណី

លេខ: [redacted]

ចុះថ្ងៃទី ០៨-០៧-២០១៤

# ដីកាកោះ

## ស្តីពីកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

ដើមចោទ(ឈ្មោះ .................ភេទ ប្រុស សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៣E3 ផ្លូវលេខ .......... សង្កាត់..............ខណ្ឌ............. រាជធានីភ្នំពេញ ) សូមចូលខ្លួនមកតុលាការ។

តាមកាលបរិច្ឆេទ: **នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ វេលាម៉ោង ០៨:០០នាទីព្រឹក។**

**ទីកន្លែង:** សាលាដំបូងរាជធានីភ្នំពេញ (ជាន់ទី៣ បន្ទប់ "ង") ។

**ដើម្បី:** ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

**ពីដំណើររឿង:** (បណ្តឹងលែងលះ)

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះអោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទិននឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅភ្នំពេញ . ថ្ងៃទី ខែ កក្កដា ឆ្នាំ ២០១៤

**ចៅក្រម**

យើង.........................................................................................................

បានប្រគល់ដីកាកោះនេះអោយ ដើមចោទ(ឈ្មោះ............ទីលំនៅផ្ទះលេខ.....................

ផ្លូវ.................. ក្រុម.................. ភូមិ........................ ឃុំ/សង្កាត់.........................

ស្រុក/ខណ្ឌ.......................ខេត្ត/រាជធានី...................)នៅថ្ងៃទី.....................ខែ..................

ឆ្នាំ.........................ដោយផ្ទាល់រួចហើយ។

ដោយយើងបានទុកចុងដីកានេះមួយច្បាប់ឲ្យសាមីខ្លួនហើយប្រាប់ថាត្រូវប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេល ខ្លួនចូលទៅដល់សាលាដំបូងរាជធានីភ្នំពេញ។

| **អ្នកទទួលដីកា** | **អ្នកប្រគល់ដីកា** |
| --- | --- |
| ហត្ថលេខា ឬផ្តិតមេដៃ | ហត្ថលេខា |

ក្រឡាបញ្ជី
[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*******

# ដីកាកោះ

## ស្តីពីកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**សាលាដំបូងរាជធានីភ្នំពេញ**
*******

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

សំណុំរឿងរដ្ឋប្បវេណី
លេខ: [redacted]
ចុះថ្ងៃទី ០៨-០៧-២០១៤

ចុងចោទ(ឈ្មោះ ..........ភេទស្រី សញ្ជាតិ ខ្មែរ មានអាសយដ្ឋានលេខ 42 KENT ST LAWRENCE, MA 01843 USA )សូមចូលខ្លួនមកតុលាការ។

**តាមកាលបរិច្ឆេទ:** នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ វេលាម៉ោង ០៨:០០នាទីព្រឹក។

**ទីកន្លែង:** សាលាដំបូងរាជធានីភ្នំពេញ(ជាន់ទី៣ បន្ទប់ "ង") ។

**ដើម្បី:** នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

**ពីដំណើររឿង:** (បណ្តឹងលែងលះ)

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះអោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទិននឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅភ្នំពេញ . ថ្ងៃទី ខែ កក្កដា ឆ្នាំ ២០១៤

**ចៅក្រម**

យើង..................................................................................................................
បានប្រគល់ដីកាកោះនេះអោយចុងចោទ(ឈ្មោះ................................ទីលំនៅផ្ទះលេខ...........
.......... ផ្លូវ.................. ក្រុម................. ភូមិ........................ ឃុំ/សង្កាត់........................
ស្រុក/ខណ្ឌ......................ខេត្ត/រាជធានី.............)នៅថ្ងៃទី....................ខែ..................ឆ្នាំ..
......................ផ្ទាល់រួចហើយ ។

ដោយយើងបានទុកចុងដីកានេះមួយច្បាប់ឲ្យសាមីខ្លួនហើយប្រាប់ថាត្រូវប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេល ខ្លួនចូលទៅដល់សាលាដំបូងរាជធានីភ្នំពេញ។

| **អ្នកទទួលដីកា** | **អ្នកប្រគល់ដីកា** |
| --- | --- |
| ហត្ថលេខា ឬផ្តិតមេដៃ | ហត្ថលេខា |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

## ដីកាបង្គាប់ឲ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លេខ:...................ត.រ

**បានឃើញ** មាត្រា ២៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី
**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ....................ខែ.................ឆ្នាំ.....................
**បានឃើញ** របាយការណ៍អំពីការបញ្ជូនចុះថ្ងៃទី............ខែ...................ឆ្នាំ.................

### សំអាងហេតុ

កាលពីថ្ងៃទី..............ខែ...................ឆ្នាំ......................តុលាការបានចេញដីកាកោះហៅឈ្មោះ....................................................ជាចុងចម្លើយឲ្យចូលកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី.................ខែ......................ឆ្នាំ......................ដើម្បីចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែផ្អែកទៅតាមរបាយការណ៍អំពីការបញ្ជូនចុះថ្ងៃទី....................ខែ.................ឆ្នាំ......................របស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ថាពុំអាចធ្វើការបញ្ជូនដីកាកោះទៅឲ្យចុងចម្លើយទៅតាមរបៀបនៃការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលបានឡើយ ។

### ហេតុដូច្នេះសម្រេច

តុលាការ អនុញ្ញាតចំពោះពាក្យសុំឲ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ។

រាជធានីភ្នំពេញ , ថ្ងៃទី..........ខែ ........... ឆ្នាំ ................
**ចៅក្រម**

# សិក្ខាសាលា
# ស្ដីពី

# ស៊ំក្ទូន

# រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

# ស្តុំកូន

## ក្រមរដ្ឋប្បវេណី

ឧទ្ទេសនាមដោយ ៖ លោកស្រី ចាំង ស៊ីណាត

ខែ ឧសភា ឆ្នាំ ២០១៥

1

# ស្តុំកូន

- ប្រភេទនៃស្តុំកូន ៖
  - ✓ ស្តុំកូនពេញលេញ
  - ✓ ស្តុំកូនធម្មតា

2

## ផ្នែកទី ១. សុំកូនពេញលេញ

ក. ការបង្កើតសុំកូនពេញលេញ

✓ បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់ពួកគាត់ (មាត្រា ១០០៧)។

ឧទាហរណ៍ ៖ ចាន់នី និង សុភាព មានទីលំនៅនៅរាជធានីភ្នំពេញ មានបំណងសុំយកកូនអាយុ ២ ឆ្នាំ របស់ ផានី ដែលមានទីលំនៅនៅខេត្តសៀមរាប។ ដូច្នេះ ចាន់នី និង សុភាព ត្រូវដាក់ពាក្យសុំទៅសាលាដំបូងរាជធានីភ្នំពេញ។

✓ តុលាការចេញ ដីកាសម្រេច (មាត្រា ៣ កថា. ២ ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

3

១. លក្ខខណ្ឌទាក់ទងនឹងកូនសុំ ៖

- កូនសុំត្រូវមានអាយុតិចជាង ៨ ឆ្នាំ (មាត្រា ១០១០ នៃក.រ.) ។
- ជាអញ្ញត្រកម្ម (ការលើកលែង) តុលាការអាចបង្កើតសុំកូនពេញលេញ ទោះបីជាកូនសុំមានអាយុចាប់ពី ៨ឆ្នាំ ឡើងទៅក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ក្រមរដ្ឋប្បវេណីមិនបានបញ្ជាក់ថា តើត្រូវមានមូលហេតុអ្វីខ្លះដែលអាចឱ្យតុលាការសម្រេចយ៉ាងដូច្នេះបានឡើយ។ ជាលទ្ធផល យុត្តិសាស្ត្ររបស់តុលាការនឹងកំណត់ពីបញ្ហានេះ នាពេលអនាគតខាងមុខ។

4

ឧទាហរណ៍ ៖ កូនសុំបានរស់នៅជាមួយឪពុកម្តាយចិញ្ចឹម តាំងពីអាយុ ៧ ឆ្នាំ រហូតដល់អាយុ ១៥ ឆ្នាំ ទើបដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញ។ ក្នុងស្ថានភាពបែបនេះ តុលាការប្រហែលជាអាចបង្កើតស្មុំកូនពេញលេញបាន ទោះបីជាកូនមានអាយុ ១៥ ឆ្នាំ ក៏ដោយ។

5

• ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ លើកលែងតែករណីដែលឪពុកម្តាយបង្កើតមិនអាចបង្ហាញឆន្ទៈបាន មានការធ្វើបាបកូន បោះបង់កូនចោលដោយទុច្ចរិត ឬហេតុដទៃទៀត ដែលបំពានផលប្រយោជន៍របស់កុមារយ៉ាងធ្ងន់ធ្ងរ (មាត្រា ១០១១ នៃក.រ)។

ឧទាហរណ៍ ៖ ឪពុកម្តាយបង្កើតបានឱ្យកូនដើរសុំទាន យកប្រាក់មកឱ្យខ្លួនចាយ វាយ ផឹកស្រា ហើយបដិសេធមិនឱ្យកូនទៅអ្នកដទៃចិញ្ចឹម ឬ ករណីដែលឪពុកម្តាយបង្កើតបានបាត់ខ្លួន មិនទាន់អាចរកឃើញ ជាដើម។

6

ម្យ៉ាងវិញទៀត មាត្រា ១០១២ នៃក្រមរដ្ឋប្បវេណី ថែមទាំងបាន កំណត់នូវលក្ខខណ្ឌជាសារធាតុមួយទៀត ដែលជាមូលដ្ឋានអាចឱ្យ តុលាការសម្រេចសេចក្តីបង្កើតសុំកូនពេញលេញបាន។ តាមពិត កុមារ ដែលនឹងក្លាយជាកូនសុំពេញលេញ មិនមែនជាកុមារដែលរស់នៅដោយ សុខសប្បាយទេ មុនពេលបង្កើតសុំកូនពេញលេញ។

7

ដូច្នេះ ជាទូទៅ តុលាការនឹងសម្រេចបង្កើតសុំកូនពេញលេញ លុះត្រាតែតុលាការយល់ឃើញថា មានការពិបាកយ៉ាងខ្លាំង ឬមិនសម រម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ តាយបង្កើត ឬមានស្ថានភាពពិសេសផ្សេងៗទៀត ដែលតុលាការយល់ ឃើញថា មានភាពចាំបាច់ត្រូវបង្កើតសុំកូនពេញលេញ ដើម្បីផល ប្រយោជន៍របស់កុមារ។

ស្ថានភាពទាំងនោះមានដូចជា ករណីដែលឪពុកម្តាយបាត់ខ្លួន ឬមានវិបត្តិផ្នែករាងកាយ មានជីវភាពក្រីក្រខ្លាំងដែលមិនអាចចិញ្ចឹម បីបាច់ថែរក្សាកូនបានល្អ ឬ ករណីដែលឪពុកម្តាយធ្វើបាបកូន ឬបោះ បង់កូនចោល ។ល។ និង។ល។

8

២. លក្ខខណ្ឌទាក់ទងនឹងឪពុកម្តាយចិញ្ចឹម ៖

ជាដំបូង បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ (មាត្រា ១០០៨ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ បុគ្គលនៅលីវមិនអាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមនៃកូនសុំពេញលេញបានឡើយ។

មួយវិញទៀត ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើប្រពន្ធ ឬ ប្តីម្ខាងទៀត មិនបានក្លាយជាម្តាយ ឬឪពុកចិញ្ចឹម។ និយាយមួយបែបទៀតថា ទាំងប្តី ទាំងប្រពន្ធ ត្រូវតែក្លាយជាឪពុកម្តាយចិញ្ចឹមរបស់កូនសុំពេញលេញ ដោយក្រមរដ្ឋប្បវេណីមិនអនុញ្ញាតឱ្យនារីម្នាក់ដែលមានប្តី ហើយសុំកុមារម្នាក់មកធ្វើជាកូនចិញ្ចឹម ដោយរូបនាងក្លាយជាម្តាយចិញ្ចឹម ចំណែកឯប្តីរបស់នាងមិនក្លាយទៅជាឪពុកចិញ្ចឹមរបស់កូននោះទេ។ 9

ក៏ប៉ុន្តែជាករណីលើកលែង ប្រសិនបើជាការសុំកូនរបស់សហព័ទ្ធម្ខាងទៀត ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យតែសហព័ទ្ធម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបាន (មាត្រា ១០០៨ កថា. ២ វាក្យ. ២ នៃក.រ.)។

ឧទាហរណ៍ ៖ ចិន្តា ជាស្ត្រីមេម៉ាយមានកូនម្នាក់ឈ្មោះ សំខាន់ ដែលមានអាយុ ៥ ឆ្នាំ។ នៅឆ្នាំ ២០១៣ នេះ ចិន្តា បានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរសម្នាក់ឈ្មោះ សារី។ ក្រោយពីរៀបការរួចហើយ សារី មានបំណងបង្កើតសុំកូនពេញលេញជាមួយនឹង សំខាន់ ដែលជាកូនរបស់ ចិន្តា។ នៅក្នុងករណីបែបនេះ ចិន្តា គឺជាម្តាយបង្កើតរបស់ សំខាន់ ទៅហើយ នាងមិនអាចក្លាយជាម្តាយចិញ្ចឹមរបស់ សំខាន់ នោះទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យ សារី តែម្នាក់ឯងក្លាយជាឪពុកចិញ្ចឹមរបស់ សំខាន់ បាន។ 10

ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ ឆ្នាំ (មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ ៖ សុភា និង សារី បានរៀបការជាមួយគ្នាអស់រយៈពេល ៥ ឆ្នាំ មកហើយ តែពួកគេមិនមានកូនជាមួយគ្នាឡើយ។ សុភា មានអាយុ ២៥ ឆ្នាំ ចំណែកឯ សារី មានអាយុ ៣០ ឆ្នាំ។ ឥឡូវនេះ អ្នកទាំងពីរមានបំណងសុំក្មេងម្នាក់ដែលមានអាយុ ៧ ឆ្នាំ មកចិញ្ចឹមធ្វើជាកូនសុំពេញលេញ។

11

ក្នុងករណីបែបនេះ សុភា និង សារី សុទ្ធតែមានអាយុចាប់ពី ២៥ ឆ្នាំ ដែលអាចសុំកូនអ្នកដទៃមកចិញ្ចឹមបាន រីឯ សារី មានអាយុ ៣០ ឆ្នាំ ពោលគឺមានអាយុលើសក្មេងដែលនឹងក្លាយជាកូនសុំចំនួន ២៣ ឆ្នាំ ក៏ប៉ុន្តែ សុភា នាងមានអាយុលើសក្មេងដែលនឹងក្លាយជាកូនសុំត្រឹមតែ ១៧ ឆ្នាំ ប៉ុណ្ណោះ ដូចនេះ សុភា មិនបានបំពេញលក្ខខណ្ឌដែលតម្រូវតាមមាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណីឡើយ មានន័យថា អ្នកទាំងពីរមិនអាចក្លាយទៅជាឪពុកម្តាយចិញ្ចឹម តាមរយៈសុំកូនពេញលេញចំពោះក្មេងដែលមានអាយុ ៧ ឆ្នាំ នោះឡើយ។

12

៣. អំឡុងពេលសាកល្បង

ការបង្កើតឱ្យមានស្មុំកូនពេញលេញ គឺដើម្បីបង្កើតគ្រួសារថ្មីមួយដល់កុមារដែលអភ័ព្វ។ ហេតុដូច្នេះហើយទើប ក្រមរដ្ឋប្បវេណីតម្រូវឱ្យតុលាការធ្វើការពិចារណា ទៅលើស្ថានភាពរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបានធ្វើ នៅក្នុងការគ្រប់គ្រងកុមារដែលនឹងក្លាយជាកូនសុំ ក្នុងអំឡុងពេលសាកល្បងចិញ្ចឹម ដែលមានរយៈពេលយ៉ាងតិច ៦ ខែ ជាគោលការណ៍ (មាត្រា ១០១៣ នៃក.រ.)។ ក្នុងន័យនេះ រយៈពេលសាកល្បងអាចមានរយៈពេលតិចជាងនេះបាន ក្នុងករណីពិសេស។ 13

ឧទាហរណ៍ ៖ កូនសុំធ្លាប់បានរស់នៅជាមួយនឹងឪពុកម្ដាយចិញ្ចឹម ជាយូរណាស់មកហើយ តាំងពីមុនពេលដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញទៅទៀត។ ក្នុងករណីយ៉ាងនេះ តុលាការអាចកំណត់រយៈពេលសាកល្បងខ្លីជាង ៦ ខែ ឬ មិនកំណត់រយៈពេលសាកល្បងតែម្ដងក៏បានដែរ។

ដូច្នេះ ប្រសិនបើតុលាការយល់ឃើញថា នៅក្នុងអំឡុងពេលសាកល្បងនេះ កុមារមិនអាចរស់នៅចុះសម្រុងជាមួយនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមទេ ភាគច្រើន តុលាការនឹងមិនសម្រេចឱ្យបង្កើតស្មុំកូនពេញលេញទេ ពីព្រោះថា ការធ្វើបែបនេះអាចនឹងធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្ត ក៏ដូចជាផលប្រយោជន៍របស់កុមារនាពេលអនាគត។ 14

ខ. អានុភាពសុំកូនពេញលេញ

✓ ផ្ដាច់ចំណងញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត (មាត្រា ១០១៤ នៃក.រ.) ។ ហេតុដូច្នេះ កូនសុំពេញលេញ និង ឪពុកម្ដាយបង្កើតលែងមានសិទ្ធិសន្តតិកម្មរវាងគ្នាហើយ។

✓ ករណីលើកលែង ៖ សុំកូនរបស់សហព័ទ្ធម្ខាងទៀត។

ឧទាហរណ៍ ៖ លោក ភក្តី បានរៀបការជាមួយលោកស្រី កញ្ញា ដែលជាស្រីមេម៉ាយមានកូនម្នាក់ឈ្មោះ សំបូរ អាយុ ៥ឆ្នាំ។ ក្រោយពីបានរៀបការរួច លោក ភក្តី បានសុំយក សំបូរ ធ្វើជាកូនសុំពេញលេញ។ នៅក្នុងករណីនេះ ចំណងញាតិរវាង សំបូរ និង លោកស្រី កញ្ញា ដែលជាម្ដាយបង្កើត នៅតែមានអត្ថិភាពជាដដែល ដោយមិនកាត់ផ្ដាច់នោះទេ។ 15

✓ បង្កើតទំនាក់ទំនងញាតិជាមួយនឹងឪពុកម្ដាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម ដូចជាទំនាក់ទំនងជាមួយនឹងកូនបង្កើតដែរ (មាត្រា ១០១៥ កថា. ១ នៃក.រ.) ។

✓ កូនសុំអាចប្រើនាមត្រកូលមុនសុំកូន ឬនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមបាន (មាត្រា ១០១៥ កថា. ២ នៃក.រ.)។

✓ ត្រូវធ្វើបញ្ជីកំណើតថ្មី។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើតថ្មី ឬ សេចក្ដីចម្លងនៃសំបុត្រកំណើត ឬ ឯកសារដកស្រង់កំណើត មិនត្រូវសរសេរពីចំណុចសុំកូនទេ (មាត្រា ១០១៨ នៃក.រ.)។

✓កូនសុំពេញលេញ មានសិទ្ធិទាមទារចំពោះតុលាការ ឱ្យបង្ហាញព័ត៌មានក្នុងទំហំចាំបាច់ កាលបើគាត់ក្លាយជានីតិជន នៅក្នុងករណីមានគោលបំណងត្រឹមត្រូវ (មាត្រា ១០១៩ នៃក.រ.) ។ 16

គ. ការកាត់កាល់ស្មុំកូនពេញលេញ (មាត្រា ១០១៦ ក្រមរដ្ឋប្បវេណី)

✓ ត្រូវដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់។

✓ អ្នកមានសិទ្ធិដាក់ពាក្យបណ្ដឹង ៖ ឪពុកម្ដាយបង្កើត កូនសុំ តំណាងអយ្យការ។ ឪពុកម្ដាយចិញ្ចឹម មិនអាចប្ដឹងទាមទារកាត់កាល់ស្មុំកូនពេញលេញបានទេ។

✓ តុលាការចេញ "សាលក្រម" (មាត្រា ៣ ចំណុច ជ. នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល) ។

17

✓ មូលហេតុនៃការកាត់កាល់ស្មុំកូនពេញលេញ ៖

- ឪពុកម្ដាយចិញ្ចឹមធ្វើបាបកូន បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងទៀតដែលបំពានផលប្រយោជន៍កូនយ៉ាងធ្ងន់ធ្ងរ និង (ត្រូវតែមានមូលហេតុទាំងពីរជាដាច់ខាត)
- ឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាកូនដោយសមរម្យ។

ឧទាហរណ៍ ៖ បន្ទាប់ពីបានបង្កើតស្មុំកូនពេញលេញរួចហើយ កូនសុំបានទៅរស់នៅជាមួយនឹងឪពុកម្ដាយចិញ្ចឹម។ នៅក្នុងអំឡុងពេលនៃការរស់នៅមួយរយៈជាមួយនឹងឪពុកម្ដាយចិញ្ចឹម កូនសុំបានទទួលរងនូវការធ្វើបាបឥតត្រាប្រណីពីសំណាក់ម្ដាយចិញ្ចឹម ហើយឪពុកចិញ្ចឹមក៏មិនបានចាត់វិធានការ ដើម្បីទប់ស្កាត់សកម្មភាពធ្វើបាបរបស់ម្ដាយចិញ្ចឹមមកលើកូនសុំដែរ។

18

ជាងនេះទៀត ឪពុកម្តាយបង្កើតរបស់កូនសុំដែលពីមុនមានជីវភាព ក្រីក្រតោកយ៉ាកខ្លាំង ដោយសារតែមានជម្ងឺប្រចាំកាយ ក៏បានធូរ ស្បើយពីជម្ងឺ ហើយអាចប្រកបកិច្ចការជំនួញដើម្បីចិញ្ចឹមជីវភាពបាន ល្អប្រសើរជាងមុន។

ក្នុងករណីបែបនេះ ឪពុកម្តាយបង្កើតដែលមានបំណងចង់ទាមទារ កូនយកមកវិញ ត្រូវដាក់ពាក្យបណ្តឹងទាមទារកាត់កាល់ ហើយបើ តុលាការយល់ឃើញថា មានភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃលក្ខខណ្ឌ នៃការកាត់កាល់ទាំងពីរដូចបានកំណត់ខាងលើនេះ តុលាការនឹង ចេញសាលក្រមដើម្បីប្រកាសពីការកាត់កាល់សុំកូនពេញលេញ។

19

សម្គាល់ ៖ នៅក្នុងករណីដែលឪពុកម្តាយចិញ្ចឹមបានធ្វើបាបកូន ក៏ប៉ុន្តែ ឪពុកម្តាយបង្កើតមិនមានលទ្ធភាពសមរម្យដើម្បីគ្រប់គ្រងថែ រក្សាកូនទេ ឬបានស្លាប់បាត់បង់ជីវិតទៅហើយ ជាដើមនោះ តុលាការ មិនអាចកាត់កាល់សុំកូនពេញលេញបានទេ ពីព្រោះតែខ្វះលក្ខខណ្ឌទី ២ ដែលកំណត់ដោយច្បាប់។ នៅក្នុងករណីនេះ គេអាចប្រើវិធី ការព្យួរ ឬដកហូតអំណាចមេបាពីឪពុកម្តាយចិញ្ចឹម (មាត្រា ១០៤៨ ក្រម) ហើយជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនវិញ ដើម្បី ការពារផលប្រយោជនរបស់អនីតិជននោះ។

20

✓ អានុភាពនៃការកាត់កាល់ ៖

- ផ្តាច់ទំនាក់ទំនងញាតិភាពជាមួយនឹងឪពុកម្តាយចិញ្ចឹម
- ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតកើតឡើងវិញ។

21

# ផ្នែកទី ២. សុំកូនធម្មតា

ក. ការបង្កើតសុំកូនធម្មតា

✓ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និង កូនសុំ ដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់កូនសុំ (ឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

ឧទាហរណ៍ ៖ ចាន់នី និង សុភាព មានទីលំនៅនៅរាជធានីភ្នំពេញ មានបំណងសុំយកកូនអាយុ ២ ឆ្នាំ របស់ ផានី ដែលមានទីលំនៅនៅខេត្តសៀមរាប។ ដូច្នេះ ចាន់នី សុភាព និង ផានី ត្រូវដាក់ពាក្យសុំទៅសាលាដំបូងខេត្តសៀមរាប។

✓ តុលាការចេញ ដីកាសម្រេច (មាត្រា ៣ នៃច្បាប់ខាងលើ)។ 22

១. លក្ខខណ្ឌទាក់ទងនឹងកូនសុំ ៖

• មិនកំណត់អាយុរបស់កូនសុំទេ តែកូនសុំមិនត្រូវមានអាយុច្រើនជាងឪពុកម្ដាយចិញ្ចឹមទេ។

• កូនសុំមិនត្រូវជាបុព្វញាតិរបស់ឪពុកម្ដាយចិញ្ចឹមទេ។

ឧទាហរណ៍ ៖ កញ្ញា មានអាយុ ៤០ ឆ្នាំ ហើយប្អូនប្រុសពៅរបស់គាត់ឈ្មោះ ដារ៉ា មានអាយុទើបតែ ១៨ ឆ្នាំប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ កញ្ញា បានរៀបការ ហើយមានកូនប្រុសម្នាក់ឈ្មោះ សំបូរ មានអាយុ ២២ ឆ្នាំ។

23

ក្នុងករណីយ៉ាងនេះ សំបូរ មានអាយុច្រើនជាង ដារ៉ា។ ក៏ប៉ុន្តែ បើគិតពីទំនាក់ទំនងញាតិវិញ ដារ៉ា ត្រូវជាពូរបស់ សំបូរ ពោលគឺ ដារ៉ា ជាបុព្វញាតិរបស់ សំបូរ។ ដូច្នេះ សំបូរ មិនអាចសុំយក ដារ៉ា មកធ្វើជាកូនសុំធម្មតាបានឡើយ ទោះបីជា សំបូរ មានអាយុច្រើនជាង ដារ៉ា ក៏ដោយ។

24

ជាធម្មតា ប្រសិនបើបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកដែលត្រូវផ្ដល់ការយល់ព្រមទៅនឹងការបង្កើតស្មុំកូនធម្មតា គឺអ្នកតំណាងតាមច្បាប់កំណត់របស់អនីតិជន ពោលគឺ អ្នកមានអំណាចមេបា (ឧ. ឪពុកម្ដាយបង្កើត) ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ក៏ប៉ុន្តែ ប្រសិនបើអនីតិជននោះបានដល់អាយុ ១៥ ឆ្នាំ ហើយត្រូវតែទទួលការយល់ព្រមពីអនីតិជននោះផង ទើបអាចបង្កើតស្មុំកូនធម្មតាបាន (មាត្រា ១០២៤ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី)។

25

ប្រសិនបើបុគ្គលដែលនឹងក្លាយជាកូនសុំ គឺជាអនីតិជន ភាពចាំបាច់ពិសេសនៃការបង្កើតស្មុំកូនដើម្បីផលប្រយោជន៍របស់កូនសុំ គឺជាមូលដ្ឋានដ៏សំខាន់ ដើម្បីឱ្យតុលាការសម្រេចសេចក្ដីឱ្យបង្កើតស្មុំកូនធម្មតាបាន (មាត្រា ១០២៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងការវិនិច្ឆ័យពីស្ថានភាពនេះ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្ដាយម្ខាងទៀតរបស់អនីតិជនដែលមិនមានអំណាចមេបាលើអនីតិជន ព្រមទាំងសួរយោបល់របស់អនីតិជននោះផ្ទាល់តែម្ដង ប្រសិនបើអនីតិជននោះអាចបង្ហាញឆន្ទៈបាន។

26

ទន្ទឹមនឹងនេះដែរ នៅក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំគឺជានីតិជន តុលាការនឹងសម្រេចឱ្យបង្កើតស្មុំកូនធម្មតា បើបានពិនិត្យឃើញថាមានឆន្ទៈពិតប្រាកដ ក្នុងការបង្កើតទំនាក់ទំនងស្មុំកូនធម្មតាជាមួយនឹងឪពុកម្ដាយចិញ្ចឹម (មាត្រា ១០២៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

27

២. លក្ខខណ្ឌទាក់ទងនឹងឪពុកម្ដាយចិញ្ចឹម

○ បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ត្រូវតែមានអាយុចាប់ពី ២៥ ឆ្នាំ ឡើងទៅ ហើយមិនត្រូវជាបច្ឆាញាតិ និងត្រូវមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាកូនសុំ (មាត្រា ១០២០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

○បុគ្គលដែលនឹងក្លាយជាឪពុក ឬម្ដាយចិញ្ចឹម អាចជាបុគ្គលដែលមានសហព័ទ្ធក៏បាន ឬជាបុគ្គលដែលមិនមានសហព័ទ្ធក៏បានដែរ។

28

○ ប្រសិនបើជាបុគ្គលដែលមានសហព័ទ្ធ គឺចាំបាច់ត្រូវតែមានការយល់ព្រមពីសំណាក់សហព័ទ្ធម្ខាងទៀតផង ទើបសហព័ទ្ធម្ខាងអាចដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាបាន។
ក៏ប៉ុន្តែ នៅក្នុងករណីដែលមានតែសហព័ទ្ធម្ខាងជាអ្នកដាក់ពាក្យសុំ នោះស្មុំកូនមានអានុភាពតែចំពោះសហព័ទ្ធ ដែលបានដាក់ពាក្យសុំបង្កើតស្មុំកូននោះតែប៉ុណ្ណោះ។

29

○ ក៏ប៉ុន្តែ បើបុគ្គលដែលមានសហព័ទ្ធ ហើយមានបំណងសុំកូនដែលជាអនីតិជន មាត្រា ១០២១ នៃក្រមរដ្ឋប្បវេណី តម្រូវឱ្យសហព័ទ្ធទាំងពីរនាក់ដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាដោយសហការគ្នា។ ប្រសិនបើសហព័ទ្ធម្ខាងមិនអាចបង្ហាញឆន្ទៈបាន ដូចជាករណីមានជម្ងឺផ្នែកស្មារតី ជាដើម ការដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាអាចធ្វើឡើងដោយសហព័ទ្ធតែម្ខាងបាន។

30

○ដូចគ្នាដែរ ប្រសិនបើជាការសុំបង្កើតស្មុំកូនធម្មតាជាមួយនឹងកូនជាអនីតិជនរបស់សហព័ទ្ធម្ខាងទៀត ការដាក់ពាក្យសុំនឹងត្រូវធ្វើដោយសហព័ទ្ធតែម្ខាងប៉ុណ្ណោះ (មាត្រា ១០២១ និង មាត្រា ១០២២ នៃក្រមរដ្ឋប្បវេណី)។

○ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវតែមានឆន្ទៈពិតប្រាកដ ក្នុងការបង្កើតទំនាក់ទំនងស្មុំកូន។ ដូចនេះ បើតុលាការយល់ឃើញថា ស្មុំកូនត្រូវបានបំពាន ក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទផ្សេងគ្នា ឬ ដូចគ្នា ឬក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត តុលាការនឹងមិនចេញសេចក្តីសម្រេចបង្កើតស្មុំកូនធម្មតាឡើយ (មាត្រា ១០២៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

31

ខ. អានុភាពស្មុំកូនធម្មតា

✓ មិនផ្តាច់ចំណងញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត (មាត្រា ១០២៦ កថា. ១ ក.រ.)។ ហេតុដូច្នេះ កូនសុំធម្មតានៅតែមានសិទ្ធិធ្វើសន្តតិកម្មពីឪពុកម្តាយបង្កើតជាដដែល ហើយសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចនៅតែមានអត្ថិភាព។

✓ បង្កើតទំនាក់ទំនងញាតិជាមួយនឹងឪពុកម្តាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម ដូចជាទំនាក់ទំនងជាមួយនឹងកូនបង្កើតដែរ (មាត្រា ១០២៧ កថា. ១ ក.រ)។

32

✓ កូនសុំអាចប្រើនាមត្រកូលមុនស្មុំកូន ឬនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមបាន (មាត្រា ១០២៧ កថា. ២ ក.រ)។

✓កូនសុំជាអនីតិជន ត្រូវស្ថិតនៅក្រោមអំណាចមេបា របស់ឪពុកម្ដាយចិញ្ចឹម (មាត្រា ១០២៧ កថា. ៣ ក.រ)។ ប៉ុន្តែ បើបានយកកូនបង្កើតរបស់សហព័ទ្ធម្ខាងមកធ្វើជាកូនសុំ គឺត្រូវស្ថិតក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និងសហព័ទ្ធ។

✓ ស្មុំកូនធម្មតា ត្រូវចុះនៅលើរឹមទំព័រនៃបញ្ជីកំណើតរបស់កូនសុំ ពោលគឺមិនតម្រូវឱ្យធ្វើបញ្ជីកំណើតថ្មីទេ (មាត្រា ១០៣៣ ក.រ)។

33

គ. ការកាត់កាល់ស្មុំកូនធម្មតា

✓ ការកាត់កាល់តាមការព្រមព្រៀង (មាត្រា ១០២៨ នៃក.រ.) ៖

○ ភាគីទាំងសងខាងនៃស្មុំកូន ត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់កូនសុំ (តារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីរឿងក្ដីរដ្ឋ-ប្បវេណីដែលមិនមែនជាបណ្ដឹង)។

○ តុលាការធ្វើការសម្រេចសេចក្ដី ដោយចេញជា ដីកាសម្រេច ។

○ នៅក្នុងករណីដែលកូនសុំគឺជាអនីតិជន ពាក្យសុំព្រមព្រៀងកាត់កាល់ត្រូវធ្វើឡើងដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់កំណត់របស់អនីតិជននោះ ក្រោយពេលកាត់កាល់ (ឧទាហរណ៍ ៖ ឪពុកម្ដាយបង្កើតរបស់កូនសុំ)។

34

○ ក្រមរដ្ឋប្បវេណីតម្រូវឱ្យកូនសុំជាអនីតិជន ដែលមានអាយុដល់ ១៥ ឆ្នាំ ផ្តល់ការយល់ព្រមទៅនឹងការកាត់កាល់នេះផង ទើបបាន។

○ ក្រៅពីនេះ នៅពេលដែលអនីតិជនអាចបង្ហាញឆន្ទៈបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះផង ពាក់ព័ន្ធនឹងការកាត់កាល់សុំកូនធម្មតា។

○ សហព័ទ្ធទាំងសងខាងដែលជាឪពុកម្តាយចិញ្ចឹម តាមរយៈការដាក់ពាក្យសុំបង្កើតសុំកូនដោយសហការគ្នា ត្រូវដាក់ពាក្យសុំកាត់កាល់នេះជាមួយគ្នា លើកលែងតែសហព័ទ្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈខ្លួនបាន (មាត្រា ១០២៩) (ឧទាហរណ៍ ៖ មានជម្ងឺធ្ងន់ធ្ងរខ្លាំង)។

35

ឧទាហរណ៍ ៖ ចិន្តា អាយុ ៣៥ ឆ្នាំ និង ដារី អាយុ ២០ ឆ្នាំ គឺជាម្តាយចិញ្ចឹម និង កូនសុំធម្មតា។ ក្រោយពីមានទំនាស់ពាក្យសំដីជាមួយគ្នាហើយ ដារី ក៏បានចាកចេញពីលំនៅឋានរបស់ ចិន្តា នៅភ្នំពេញ ទៅរស់នៅខេត្តសៀមរាប។ បន្ទាប់ពីបានពិភាក្សាគ្នារួចមក ចិន្តា និង ដារី ក៏ព្រមព្រៀងគ្នាកាត់កាល់សុំកូនធម្មតា។ ក្នុងករណីនេះ ចិន្តា និង ដារី ត្រូវធ្វើពាក្យសុំមួយ ហើយដាក់ជូនទៅសាលាដំបូងខេត្តសៀមរាប។

36

✓ ភាគីម្ខាងនៃសុំកូន អាចដាក់ ពាក្យបណ្ដឹងទាមទារកាត់កាល់សុំកូនធម្មតា (មាត្រា ១០៣១ ក្រមរដ្ឋប្បវេណី) ៖

- ❖ ភាគីសុំកូន ៖ ឪពុកម្ដាយចិញ្ចឹម ឬ កូនសុំ។
- ❖ ប្រសិនបើកូនសុំជាអនីតិជននៅឡើយ អ្នកដែលនឹងក្លាយជាអ្នកតំណាងតាមច្បាប់កំណត់របស់កូនសុំ គឺជាអ្នកដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់នេះ។ ជាងនេះទៅទៀត បើកូនសុំបានដល់អាយុ ១៥ ឆ្នាំហើយ ត្រូវតែមានការយល់ព្រមពីអនីតិជននោះផងទើបបាន។

37

- ❖ ក្នុងន័យដើម្បីការពារផលប្រយោជន៍របស់អនីតិជន ក្រមរដ្ឋប្បវេណី បានធ្វើការហាមឃាត់ការដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់ ពីសំណាក់ឪពុកម្ដាយចិញ្ចឹម ប្រសិនបើកូនសុំនៅជាអនីតិជននៅឡើយ (មាត្រា ១០៣១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

38

❖ មូលហេតុនៃការកាត់កាល់សុំកូនធម៌តា ៖

- ភាគីម្ខាងបោះបង់ចោលភាគីម្ខាងទៀតដោយទុច្ចរិត។
- មិនច្បាស់ថា ភាគីម្ខាងរស់ ឬ ស្លាប់ ក្នុងអំឡុងពេលយ៉ាងតិច ១ ឆ្នាំ។
- ហេតុធ្ងន់ធ្ងរផ្សេងៗទៀតដែលពិបាកបន្តទំនាក់ទំនងសុំកូន។

39

ឧទាហរណ៍ ៖ មុនី និង រដ្ឋា បានសុំ ដានី មកធ្វើជាកូនចិញ្ចឹមតាមរយៈសុំកូនធម៌តា តាំងពីពេលដែល ដានី មានអាយុ ១៥ ឆ្នាំមកម្ល៉េះ។ មកដល់បច្ចុប្បន្ននេះ មុនី និង រដ្ឋា សុទ្ធតែមានវ័យចំណាស់អស់ទៅហើយ ចំណែកឯ ដានី វិញក៏មានអាយុ ៣០ ឆ្នាំហើយដែរ។ ប៉ុន្តែ រយៈពេល ៣ ឆ្នាំ ហើយ ដែល ដានី មិនដែលមកលេង ឬទូរស័ព្ទមកសួរសុខទុក្ខ មុនី និង រដ្ឋា ដែលជាឪពុកម្តាយចិញ្ចឹមឡើយ ហើយក៏មិនដែលទំនុកបម្រុងដល់ជីវភាពរបស់ មុនី

40

និង វដ្ឋា ដែរ។ ក្នុងករណីបែបនេះ មុនី និង វដ្ឋា អាចដាក់ពាក្យបណ្តឹងទាមទារកាត់កាល់ចំពោះ ដានី បាន។ នៅក្នុងករណីដែលតុលាការយល់ឃើញថា មានមូលហេតុដូចបានចែងនៅមាត្រា ១០៣១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី តុលាការនឹងចេញសាលក្រមសម្រេចកាត់កាល់ស្មុំកូនធម្មតារវាង មុនី, វដ្ឋា និង ដានី ទោះបីជា ដានី មិនយល់ព្រមទៅនឹងការកាត់កាល់នេះក៏ដោយ ។

41

✓ អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា ៖

- ការកាត់កាល់ស្មុំកូនធម្មតា មិនមានអានុភាពប្រតិសកម្ម (ភាពធាក់ថយក្រោយ) ឡើយ បានសេចក្តីថា ការកាត់កាល់មានអានុភាពបញ្ចប់ស្មុំកូនធម្មតា គិតចាប់ពីពេលកាត់កាល់តទៅ។
- ដូច្នេះ ទំនាក់ទំនងញាតិរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម ត្រូវបញ្ចប់នៅពេលនោះ ពោលគឺកូនសុំ និងឪពុកម្តាយចិញ្ចឹមលែងមានសិទ្ធិ និងករណីយកិច្ចចំពោះគ្នាទៅវិញទៅមកទៀតហើយ។
- ក៏ប៉ុន្តែ កូនសុំនៅតែអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមបាន (មាត្រា ១០៣២ នៃក្រមរដ្ឋប្បវេណី)។

42

✓ ជារួម ភាពខុសប្លែកគ្នា រវាងស្មុំកូនទាំងពីរប្រភេទមានដូចតទៅ ៖

| ស្មុំកូនពេញលេញ | ស្មុំកូនធម្មតា |
|---|---|
| -កូនសុំត្រូវមានអាយុតិចជាង ៨ ឆ្នាំ ជាគោលការណ៍។ | -កូនសុំអាចជាអនីតិជន ឬនីតិជនក៏បានដែរ។ |
| -តុលាការអាចបង្កើតស្មុំកូនបានលុះត្រាតែ មានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាល លើកលែងតែនៅក្នុងករណីពិសេស។ | -នៅក្នុងករណីដែលកូនសុំជាអនីតិជន ត្រូវតែមានការយល់ព្រមពីអ្នកមានអំណាចមេបាប៉ុណ្ណោះ (ក្នុងករណីដែល ឪពុកម្តាយលែងលះគ្នា មានតែឪពុក ឬម្តាយតែម្ខាងប៉ុណ្ណោះ ដែលជាអ្នកមានអំណាចមេបាលើកូនជាអនីតិជន)។ |

43

| ស្មុំកូនពេញលេញ | ស្មុំកូនធម្មតា |
|---|---|
| -ផ្តាច់ចំណងញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត និងញាតិលោហិតរបស់ឪពុកម្តាយបង្កើត។ | -ពុំផ្តាច់ចំណងញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតទេ។ |
| -ការកាត់កាល់មានតែ ០១ ប្រភេទ | -ការកាត់កាល់មានពីរប្រភេទ។ |
| -តុលាការសម្រេចពីការកាត់កាល់តាម សាលក្រម ។ | -ការកាត់កាល់តាមការព្រមព្រៀង ៖ តុលាការសម្រេចជា ដីកាសម្រេច។<br>-ការកាត់កាល់តាមពាក្យបណ្តឹង ៖ តុលាការសម្រេចជា សាលក្រម។ |

44

សូមអរគុណ !

45

# សុំកូន (តាមបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណី)

*ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តឱ្យមានសុំកូនពីរប្រភេទគឺ ៖ សុំកូនពេញលេញ និង សុំកូនធម្មតា។ តាមខ្លឹមសារនៃក្រមរដ្ឋប្បវេណី ការបង្កើតសុំកូនពេញលេញត្រូវគោរពតាមលក្ខខណ្ឌដែលមានភាពតឹងរឹងជាងការបង្កើតសុំកូនធម្មតា ។ ការកំណត់យ៉ាងដូច្នេះដោយសារតែក្រោយពីបង្កើតសុំកូនពេញលេញហើយ ចំណងញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតត្រូវបញ្ចប់។ ផ្ទុយទៅវិញ ចំណងញាតិភាពរវាងកូនសុំធម្មតា និង ឪពុកម្តាយបង្កើតនៅតែបន្តអត្ថិភាព ទន្ទឹមគ្នានឹងការបង្កើតចំណងញាតិភាពជាមួយនឹងឪពុកម្តាយចិញ្ចឹម។*

**ផ្នែកទី ១. សុំកូនពេញលេញ**

*សុំកូនពេញលេញអាចបង្កើតបាន លុះត្រាតែបានបំពេញលក្ខខណ្ឌកំណត់មួយចំនួន ហើយមានអានុភាពបញ្ចប់ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត។ ទោះបីជាយ៉ាងណាក្តី សុំកូនពេញលេញអាចកាត់កាល់បាន កាលបើមានមូលហេតុត្រឹមត្រូវតាមច្បាប់។*

**១. ការបង្កើតសុំកូនពេញលេញ**

*ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវបំពេញតាមលក្ខខណ្ឌទម្រង់ និង លក្ខខណ្ឌគ្រឹះមួយចំនួនខាងក្រោម។*

*១.១. លក្ខខណ្ឌទម្រង់*

*មាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណីបានចែងថា ៖ បើយល់ឃើញថាមានលក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១០០៨ ដល់មាត្រា ១០១២ ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន។*

*យោងតាមអត្ថន័យនៃបទបញ្ញត្តិខាងលើនេះ ឃើញថា ការបង្កើតសុំកូនពេញលេញ ត្រូវតែប្រកាសដោយតុលាការ។ អ្នកដែលមានសិទ្ធិដាក់ពាក្យសុំបង្កើតសុំកូនពេញលេញ គឺ **បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម** ដែលត្រូវដាក់ពាក្យសុំនេះទៅតុលាការនៃលំនៅឋានរបស់គាត់ (បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម) (**មាត្រា ៤ កថាខណ្ឌទី ១ នៃតារាងឧបសម្ព័ន្ធផ្នែកទី ៤-៧ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**) ។*

*នៅក្នុងករណីបែបនេះ តុលាការនឹងសម្រេចដោយចេញជា **ដីកាសម្រេច** ផ្អែកតាមបទបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។*

***១.២. លក្ខខណ្ឌទាក់ទងនឹងកូនសុំ***

*ជាដំបូង កូនសុំត្រូវតែមានអាយុតិចជាង ៨ ឆ្នាំ (**មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី**)។*

ដោយហេតុថា មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា**ជាគោលការណ៍** កូនសុំត្រូវមានអាយុ ៨ **ឆ្នាំ** ហេតុដូច្នេះហើយទើបមានការបកស្រាយថា **ជាអញ្ញត្រកម្ម** (ការលើកលែង) តុលាការអាចបង្កើតស្មុំកូនពេញលេញ ទោះបីជាកូនសុំមានអាយុចាប់ពី ៨ឆ្នាំ ឡើងទៅក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ក្រមរដ្ឋប្បវេណីមិនបានបញ្ជាក់ថា តើត្រូវមានមូលហេតុអ្វីខ្លះដែលអាចឱ្យតុលាការសម្រេចយ៉ាងដូច្នេះបានឡើយ។ ជាលទ្ធផល យុត្តិសាស្ត្ររបស់តុលាការនឹងកំណត់ពីបញ្ហានេះ នាពេលអនាគតខាងមុខ។

ក្រៅពីនេះ ក្រមរដ្ឋប្បវេណីតម្រូវឱ្យមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ ដើម្បីបង្កើតស្មុំកូនពេញលេញ (**មាត្រា ១០១១ វាក្យខណ្ឌទី ១**)។ យ៉ាងណាមិញ តុលាការអាចសម្រេចបង្កើតស្មុំកូនពេញលេញ ដោយមិនចាំបាច់ទទួលការយល់ព្រមខាងលើនេះបាន ក្នុងករណីដែល (**មាត្រា ១០១១ វាក្យខណ្ឌទី ២**) ៖

-ឪពុកម្តាយមិនអាចបង្ហាញឆន្ទៈបាន។

-មានការធ្វើបាបកូនដោយឪពុកម្តាយ បោះបង់កូនចោលដោយគំនិតទុច្ចរិត។

-ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំ យ៉ាងធ្ងន់ធ្ងរ។

ម្យ៉ាងវិញទៀត **មាត្រា ១០១២ នៃក្រមរដ្ឋប្បវេណី** ថែមទាំងបានកំណត់នូវលក្ខខណ្ឌជាសារធាតុមួយទៀត ដែលជាមូលដ្ឋានអាចឱ្យតុលាការសម្រេចសេចក្តីបង្កើតស្មុំកូនពេញលេញបាន។ តាមពិត កុមារដែលនឹងក្លាយជាកូនសុំពេញលេញមិនមែនជាកុមារដែលរស់នៅដោយសុខសប្បាយទេ មុនពេលបង្កើតស្មុំកូនពេញលេញ។ ដូច្នេះ ជាទូទៅ តុលាការនឹងសម្រេចបង្កើតស្មុំកូនពេញលេញ លុះត្រាតែតុលាការយល់ឃើញថា មានការពិបាកយ៉ាងខ្លាំង ឬមិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬមានស្ថានភាពពិសេសផ្សេងៗទៀត ដែលតុលាការយល់ឃើញថា មានភាពចាំបាច់ត្រូវបង្កើតស្មុំកូនពេញលេញ ដើម្បីផលប្រយោជន៍របស់កុមារ។ ស្ថានភាពទាំងនោះមានដូចជា ករណីដែលឪពុកម្តាយបាត់ខ្លួន ឬមានវិបត្តិផ្នែករាងកាយ មានជីវភាពក្រីក្រខ្លាំងដែលមិនអាចចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អ ឬ ករណីដែលឪពុកម្តាយធ្វើបាបកូន ឬបោះបង់កូនចោល ។ល។ និង។ល។

ជាងនេះទៅទៀត ការបង្កើតឱ្យមានស្មុំកូនពេញលេញ គឺដើម្បីបង្កើតគ្រួសារថ្មីមួយដល់កុមារដែលអភ័ព្វ។ ហេតុដូច្នេះហើយទើប ក្រមរដ្ឋប្បវេណីតម្រូវឱ្យតុលាការធ្វើការពិចារណា ទៅលើស្ថានភាពរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានធ្វើ នៅក្នុងការគ្រប់គ្រងកុមារដែលនឹងក្លាយជាកូនសុំ ក្នុងអំឡុងពេលសាកល្បងចិញ្ចឹម ដែលមានរយៈពេលយ៉ាងតិច ៦ ខែ ជាគោលការណ៍ (**មាត្រា ១០១៣**)។ ក្នុងន័យនេះ រយៈពេលសាកល្បងអាចមានរយៈពេលតិចជាងនេះបាន ក្នុងករណីពិសេស។ ដូច្នេះ ប្រសិនបើតុលាការយល់ឃើញថា នៅក្នុងអំឡុងពេលសាកល្បងនេះ កុមារមិនអាចរស់នៅចុះសម្រុងជាមួយនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមទេ ភាគ

ច្រើន តុលាការនឹងមិនសម្រេចឱ្យបង្កើតសុំកូនពេញលេញទេ ពីព្រោះថា ការធ្វើបែបនេះអាចនឹងធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្ត ក៏ដូចជាផលប្រយោជន៍របស់កុមារនាពេលអនាគត។

### ១.៣. លក្ខខណ្ឌទាក់ទងនឹងឪពុកម្តាយចិញ្ចឹម

ជាដំបូង បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ (**មាត្រា ១០០៨**)។ ដូច្នេះ បុគ្គលនៅលីវមិនអាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមនៃកូនសុំពេញលេញបានឡើយ។ មួយវិញទៀត ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើប្រពន្ធ ឬ ប្តីម្ខាងទៀត មិនបានក្លាយជាម្តាយ ឬឪពុកចិញ្ចឹម។ និយាយមួយបែបទៀតថា ទាំងប្តី ទាំងប្រពន្ធ ត្រូវតែក្លាយជាឪពុកម្តាយចិញ្ចឹមរបស់កូនសុំពេញលេញ ដោយក្រមរដ្ឋប្បវេណីមិនអនុញ្ញាតឱ្យនារីម្នាក់ដែលមានប្តី ហើយសុំកុមារម្នាក់មកធ្វើជាកូនចិញ្ចឹម ដោយរូបនាងក្លាយជាម្តាយចិញ្ចឹម ចំណែកឯប្តីរបស់នាងមិនក្លាយទៅជាឪពុកចិញ្ចឹមរបស់កូននោះទេ។ ក៏ប៉ុន្តែជាករណីលើកលែង ប្រសិនបើជាការសុំកូនរបស់សហព័ទ្ធម្ខាងទៀត ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យតែសហព័ទ្ធម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបាន។

បន្ថែមលើសពីនេះទៀត ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ ឆ្នាំ (**មាត្រា ១០០៩**)។

## ២. អានុភាពនៃសុំកូនពេញលេញ

អានុភាពដ៏សំខាន់មួយនៃសុំកូនពេញលេញ គឺការបញ្ចប់ញាតិភាពរវាងកូនសុំជាមួយនឹងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត។ ក៏ប៉ុន្តែ ប្រសិនបើជាការបង្កើតសុំកូនពេញលេញជាមួយនឹងកូនរបស់សហព័ទ្ធម្ខាងទៀត ញាតិភាពរវាងកូនសុំ និងសហព័ទ្ធម្ខាងទៀតដែលជាឪពុក ឬ ម្តាយបង្កើតរបស់កូននោះ ព្រមទាំងញាតិលោហិតរបស់គាត់ មិនត្រូវបញ្ចប់ឡើយ (**មាត្រា ១០១៤**)។

ព្រមពេលជាមួយគ្នានេះ ចំណងញាតិរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមនឹងត្រូវបង្កើតឡើង ហើយកូនសុំនឹងទទួលឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ព្រមទាំងមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម (**មាត្រា ១០១៥**)។ ដូច្នេះ កូនសុំត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម។ ក៏ប៉ុន្តែ កូនសុំអាចប្រើនាមត្រកូលមុនសុំកូនក៏បាន ឬក៏ប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បានដែរ។

បន្ទាប់ពីបង្កើតសុំកូនពេញលេញរួចហើយ ត្រូវធ្វើសំបុត្រកំណើតថ្មីឱ្យកូនសុំ ហើយនៅក្នុងសំបុត្រកំណើតនោះ មិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ (**មាត្រា ១០១៨**)។ ទោះជាយ៉ាងនេះក្តី នៅពេលដែលកូនសុំបានក្លាយជានីតិជន កូនសុំមានសិទ្ធិទាមទារឱ្យបង្ហាញព័ត៌មានទាក់ទងក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងក្តីទាក់ទងនឹងសុំកូន។ ក៏ប៉ុន្តែ សិទ្ធិទាមទារនេះអាចអនុវត្តបានតែ ក្នុងករណីដែលមានគោលបំណងត្រឹមត្រូវតែប៉ុណ្ណោះ ដូចជាករណីចាំបាច់ដើម្បីព្យាបាលជម្ងឺ ឬ ដើម្បីរៀបអាពាហ៍ពិពាហ៍ ជាដើម (**មាត្រា ១០១៩**)។

## ៣. ការកាត់កាល់ស្មុំកូនពេញលេញ

*ការកាត់កាល់ស្មុំកូនពេញលេញ ត្រូវគោរពទៅតាមនីតិវិធីដែលកំណត់នៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (**មាត្រា ៣ ចំណុច ជ. នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល**) ហើយមានអានុភាពផ្តាច់ទំនាក់ទំនងញាតិរវាងកូនសុំជាមួយនឹងឪពុកម្តាយចិញ្ចឹម។*

### *៣.១. លក្ខខណ្ឌនៃការកាត់កាល់ស្មុំកូនពេញលេញ*

***-លក្ខខណ្ឌទម្រង់ ៖***

*ការកាត់កាល់ស្មុំកូនពេញលេញ ត្រូវធ្វើឡើងតាមរយៈបណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិមាត្រា **១០១៦** នៃក្រមរដ្ឋប្បវេណី។ អ្នកដែលមានសិទ្ធិដាក់ពាក្យបណ្តឹងនេះរួមមាន ៖ កូនសុំ ឪពុកម្តាយបង្កើត និង តំណាងអយ្យការ។ ដូច្នេះ ឪពុកម្តាយចិញ្ចឹមមិនមានសិទ្ធិដាក់ពាក្យបណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណីឡើយ។ ក្នុងករណីនេះ តុលាការធ្វើការសម្រេចសេចក្តីដោយចេញជា **សាលក្រម** ។*

***-មូលហេតុនៃការកាត់កាល់ ៖***

*ដើម្បីអាចកាត់កាល់ស្មុំកូនពេញលេញបាន ត្រូវមានមូលហេតុចំនួនពីរយ៉ាង ដែលត្រូវតែបំពេញជាដាច់ខាត ៖*

*១. មានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ។*

*២. ឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។*

### *៣.២. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ*

*ការកាត់កាល់ស្មុំកូនពេញលេញ មានអានុភាពផ្តាច់ញាតិភាពរវាងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម ជាមួយនឹងកូនសុំ ហើយញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ (**មាត្រា ១០១៧**)។*

## ផ្នែកទី ២. ស្មុំកូនធម្មតា

*មិនខុសប្លែកពីករណីស្មុំកូនពេញលេញឡើយ ការបង្កើតស្មុំកូនធម្មតា ត្រូវអនុលោមទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ក៏ប៉ុន្តែស្មុំកូននេះមិនមានអានុភាពបញ្ចប់ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ឡើយ។ ទន្ទឹមនឹងនេះផងដែរ ការកាត់កាល់ស្មុំកូនធម្មតាអាចធ្វើទៅបាន តាមរបៀបពីរយ៉ាង ខុសប្លែកពីការកាត់កាល់ស្មុំកូនពេញលេញ។*

## ១. ការបង្កើតសុំកូនធម្មតា

*ដើម្បីបង្កើតសុំកូនធម្មតា លក្ខខណ្ឌមួយចំនួនត្រូវតែបំពេញ ជាពិសេសគឺត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់តុលាការ។*

### *១.១. លក្ខខណ្ឌទម្រង់*

*ពាក្យសុំបង្កើតសុំកូនធម្មតា ត្រូវដាក់ដោយបុគ្គលដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹមជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយជាកូនសុំ (មាត្រា ១ កថាខណ្ឌទី ១, តារាងឧបសម្ព័ន្ធ ផ្នែក ៤ - ៩ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំ គឺជាអនីតិជន ត្រូវឱ្យអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំខាងលើនេះ* **(មាត្រា ១០២០)**។ *នៅក្នុងការវិនិច្ឆ័យសេចក្តីលើរឿងនេះ តុលាការធ្វើការសម្រេចសេចក្តីដោយចេញជា* **ដីកាសម្រេច** *ផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។*

### *១.២. លក្ខខណ្ឌទាក់ទងនឹងកូនសុំ*

*ក្រមរដ្ឋប្បវេណីមិនបានកំណត់ពីអាយុអប្បបរមានៃកូនសុំ ដើម្បីអាចក្លាយជាកូនសុំធម្មតាបាននោះទេ។ ក៏ប៉ុន្តែ មាត្រា ១០២០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី តម្រូវឱ្យ៖*

*-បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ។*

*-បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ។*

*ជាធម្មតា ប្រសិនបើបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកដែលត្រូវផ្តល់ការយល់ព្រមទៅនឹងការបង្កើតសុំកូនធម្មតា គឺអ្នកតំណាងតាមច្បាប់កំណត់របស់អនីតិជន ពោលគឺ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ក៏ប៉ុន្តែ ប្រសិនបើអនីតិជននោះបានដល់អាយុ ១៥ ឆ្នាំ ហើយត្រូវតែទទួលការយល់ព្រមពីអនីតិជននោះផង ទើបអាចបង្កើតសុំកូនធម្មតាបាន* **(មាត្រា ១០២៤ កថាខណ្ឌទី ៣)**។

*លើសពីនេះទៀត ប្រសិនបើបុគ្គលដែលនឹងក្លាយជាកូនសុំ គឺជាអនីតិជន ភាពចាំបាច់ពិសេសនៃការបង្កើតសុំកូនដើម្បីផលប្រយោជន៍របស់កូនសុំ គឺជាមូលដ្ឋានដ៏សំខាន់ ដើម្បីឱ្យតុលាការសម្រេចសេចក្តីឱ្យបង្កើតសុំកូនធម្មតាបាន* **(មាត្រា ១០២៤ កថាខណ្ឌទី ១)** ។ *នៅក្នុងការវិនិច្ឆ័យពីស្ថានភាពនេះ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្តាយម្ខាងទៀតរបស់អនីតិជនដែលមិនមានអំណាចមេបាលើអនីតិជន ព្រមទាំងសួរយោបល់របស់អនីតិជននោះផ្ទាល់តែម្តង ប្រសិនបើអនីតិជននោះអាចបង្ហាញឆន្ទៈបាន។*

*ទន្ទឹមនឹងនេះដែរ នៅក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំគឺជានីតិជន តុលាការនឹងសម្រេចឱ្យបង្កើតសុំកូនធម្មតា បើពិនិត្យឃើញថាមានឆន្ទៈពិតប្រាកដ ក្នុងការបង្កើតទំនាក់ទំនងសុំកូនធម្មតាជាមួយនឹងឪពុកម្តាយចិញ្ចឹម* **(មាត្រា ១០២៣ កថាខណ្ឌទី ១)**។

### *១.៣. លក្ខខណ្ឌទាក់ទងនឹងឪពុកម្តាយចិញ្ចឹម*

*តាមក្រមរដ្ឋប្បវេណី បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវតែមានអាយុចាប់ពី២៥ ឆ្នាំ ឡើងទៅ ហើយមិនត្រូវជាបច្ឆាញាតិ និងត្រូវមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាកូនសុំ* **(មាត្រា ១០២០ កថាខណ្ឌទី ១)**។

*ជាមួយគ្នានេះ បុគ្គលដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹម អាចជាបុគ្គលដែលមានសហព័ទ្ធក៏បាន ឬជាបុគ្គលដែលមិនមានសហព័ទ្ធក៏បានដែរ។ ប្រសិនបើជាបុគ្គលដែលមានសហព័ទ្ធ គឺចាំបាច់ត្រូវតែមានការយល់ព្រមពីសំណាក់សហព័ទ្ធម្ខាងទៀតផង ទើបសហព័ទ្ធម្ខាងអាចដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាបាន។ ក៏ប៉ុន្តែ បើបុគ្គលដែលមានសហព័ទ្ធ ហើយមានបំណងសុំកូនដែលជាអនីតិជន មាត្រា ១០២១ នៃក្រមរដ្ឋប្បវេណី តម្រូវឱ្យសហព័ទ្ធទាំងពីរនាក់ដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាដោយសហការគ្នា។ ការទាមទារយ៉ាងដូច្នេះ គឺដើម្បីរក្សាស្ថិរភាពគ្រួសារ និងធានាបរិស្ថានទំនុកបម្រុងកុមារដែលមានលំនឹងល្អ។ ក៏ប៉ុន្តែ ប្រសិនបើសហព័ទ្ធម្ខាងមិនអាចបង្ហាញឆន្ទៈបាន ដូចជាករណីមានជម្ងឺផ្លូវស្មារតី ជាដើម ការដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាអាចធ្វើឡើងដោយសហព័ទ្ធតែម្ខាងបាន។ ដូចគ្នាដែរ ប្រសិនបើជាការសុំបង្កើតស្មុំកូនធម្មតាជាមួយនឹងកូនជាអនីតិជនរបស់សហព័ទ្ធម្ខាងទៀត ការដាក់ពាក្យសុំនឹងត្រូវធ្វើដោយសហព័ទ្ធតែម្ខាងប៉ុណ្ណោះ* **(មាត្រា ១០២១ និង មាត្រា ១០២២)**។

*ក្រៅពីនេះទៀត បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវតែមានឆន្ទៈពិតប្រាកដ ក្នុងការបង្កើតទំនាក់ទំនងស្មុំកូន។ ក្នុងន័យនេះ បើតុលាការយល់ឃើញថា ស្មុំកូនត្រូវបានបំពាន ក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទផ្សេងគ្នា ឬ ដូចគ្នា ឬក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត តុលាការនឹងមិនចេញសេចក្តីសម្រេចបង្កើតស្មុំកូនធម្មតាឡើយ* **(មាត្រា ១០២៣ កថាខណ្ឌទី ២)**។

*ជាងនេះទៅទៀត អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតា ដោយយកអនីតិជនដែលនៅក្រោមអាណាព្យាបាលរបស់ខ្លួនមកធ្វើជាកូនសុំធម្មតាបាន។ ដូចគ្នាដែរ អ្នកអាណាព្យាបាលទូទៅក៏អាចដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតា ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន ធ្វើជាកូនសុំបានដែរ។ នៅក្នុងស្ថានភាពបែបនេះ តុលាការនឹងអាចសម្រេចឱ្យបង្កើតស្មុំកូនធម្មតាបាន តែក្នុងករណីដែលមានការអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សា និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាល ក្នុងពេលកន្លងមក* **(មាត្រា ១០២៥)**។

## ២. អានុភាពនៃស្មុំកូនធម្មតា

*ដូចដែលបានបញ្ជាក់នៅខាងលើរួចហើយ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតនៅតែបន្តអត្ថិភាពជាដដែល។ ដូច្នេះ ឪពុកម្តាយបង្កើត និង កូនសុំធម្មតា មានសិទ្ធិបន្តសន្តតិកម្មពីគ្នាទៅវិញទៅមកជាធម្មតា* **(មាត្រា ១០២៦)**។

*ព្រមពេលជាមួយគ្នានេះ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមត្រូវបានបង្កើតឡើង។ មិនខុសប្លែកពីកូនសុំពេញលេញឡើយ កូនសុំធម្មតាមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមដែរ នៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម (**មាត្រា ១០២៧**)។*

*លើសពីនេះទៀត កូនសុំធម្មតាអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ឬនាមត្រកូលមុនសុំកូនក៏បានដែរ។ ប្រសិនបើកូនសុំជាអនីតិជន កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម។ ប៉ុន្តែក្នុងករណីដែលជាសុំកូនរបស់សហព័ទ្ធម្ខាងទៀត កូនសុំជាអនីតិជនត្រូវស្ថិតក្រោមអំណាចមេបារួមរបស់សហព័ទ្ធទាំងសងខាង។*

*ផ្ទុយពីករណីសុំកូនពេញលេញ ក្រមរដ្ឋប្បវេណីមិនតម្រូវឱ្យធ្វើបញ្ជីកំណើតថ្មីទេ ក្រោយពេលបង្កើតសុំកូនធម្មតាហើយនោះ។ មាត្រា ១០៣៣ នៃក្រមរដ្ឋប្បវេណី គ្រាន់តែតម្រូវឱ្យសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំតែប៉ុណ្ណោះ (**មាត្រា ១០៣៣**)។*

### ៣. ការកាត់កាល់សុំកូនធម្មតា

*ខុសប្លែកពីការកាត់កាល់សុំកូនពេញលេញ សុំកូនធម្មតាអាចត្រូវកាត់កាល់តាមពីររបៀប ក៏ប៉ុន្តែការកាត់កាល់សុំកូនធម្មតានាំឱ្យមានអានុភាព ដូចជាការកាត់កាល់សុំកូនពេញលេញដែរ។*

#### *៣.១. វិធីកាត់កាល់សុំកូនធម្មតា*

*ការកាត់កាល់សុំកូនធម្មតាអាចធ្វើបានយ៉ាងងាយស្រួល កាលបើមានការព្រមព្រៀងរវាងភាគីនៃសុំកូន ហើយនៅក្នុងករណីដែលភាគីម្ខាងនៃសុំកូនមានបំណងកាត់កាល់ជាឯកតោភាគី គាត់ត្រូវតែដាក់ពាក្យបណ្ដឹង។*

##### *៣.១.១. ការកាត់កាល់សុំកូនធម្មតាតាមការព្រមព្រៀង*

*ក្រោយពីបានបង្កើតសុំកូនធម្មតាហើយ ភាគីនៃសុំកូនអាចព្រមព្រៀងគ្នាដើម្បីកាត់កាល់សុំកូននេះបាន (**មាត្រា ១០២៨ កថាខណ្ឌទី ១**)។ ក្នុងករណីនេះ ភាគីទាំងសងខាងនៃសុំកូនត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់កូនសុំ (**មាត្រា ៤ កថាខណ្ឌទី ១, តារាងឧបសម្ព័ន្ធផ្នែកទី ៤-១០ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**)។ តុលាការនឹងធ្វើការសម្រេចសេចក្តី ដោយចេញជា **ដីកាសម្រេច** យោងទៅតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។*

*ម្យ៉ាងវិញទៀត នៅក្នុងករណីដែលកូនសុំគឺជាអនីតិជន ពាក្យសុំព្រមព្រៀងកាត់កាល់ត្រូវធ្វើឡើងដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់កំណត់របស់អនីតិជននោះ ក្រោយពេលកាត់កាល់។ ជាទូទៅ បុគ្គលដែលនឹងក្លាយទៅជាអ្នកតំណាងដែលច្បាប់កំណត់របស់អនីតិជន គឺជាឪពុកម្ដាយបង្កើតរបស់អនីតិជននោះតែម្តង ។ ប៉ុន្តែ ប្រសិនបើឪពុកម្ដាយបង្កើតរបស់អនីតិជនបានលែងលះគ្នា អ្នកទាំងពីរត្រូវពិភាក្សាគ្នាដើម្បីកំណត់ថា តើនរណានឹង*

*ក្លាយជាអ្នកមានអំណាចមេបាលើអនីតិជន ហើយបើការពិភាក្សាមិនអាចធ្វើបានទេ តុលាការជាអ្នកកំណត់ថាឪពុកបង្កើត ឬ ម្ដាយបង្កើតដែលនឹងក្លាយជាអ្នកមានអំណាចមេបាលើកូន។*

*ក្នុងអត្ថន័យប្រហាក់ប្រហែលទៅនឹងការបង្កើតសុំកូនធម្មតាដែរ ក្រមរដ្ឋ-ប្បវេណីតម្រូវឱ្យកូនសុំជាអនីតិជនដែលមានអាយុដល់ ១៥ ឆ្នាំ ផ្ដល់ការយល់ព្រមទៅនឹងការកាត់កាល់នេះផង ទើបបាន។ ក្រៅពីនេះ នៅពេលដែលអនីតិជនអាចបង្ហាញឆន្ទៈបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះផង ពាក់ព័ន្ធនឹងការកាត់កាល់សុំកូនធម្មតា។*

*នៅខាងផ្នែកភាគីនៃឪពុកម្ដាយចិញ្ចឹមវិញ ក្រមរដ្ឋប្បវេណីបានតម្រូវឱ្យសហព័ទ្ធទាំងសងខាងដែលជាឪពុកម្ដាយចិញ្ចឹម តាមរយៈការដាក់ពាក្យសុំបង្កើតសុំកូនដោយសហការគ្នា ត្រូវដាក់ពាក្យសុំកាត់កាល់នេះជាមួយគ្នា លើកលែងតែសហព័ទ្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈខ្លួនបាន* **(មាត្រា ១០២៩)**។

*ក្រោយពីបានទទួលពាក្យសុំកាត់កាល់តាមការព្រមព្រៀងនេះ តុលាការត្រូវពិនិត្យមើលថាតើភាគីពិតជាមានឆន្ទៈក្នុងការរំលាយទំនាក់ទំនងសុំកូនដែរឬទេ ដើម្បីធ្វើការសម្រេចសេចក្ដី* **(មាត្រា ១០៣០)**។

### *៣.១.២. ការកាត់កាល់សុំកូនធម្មតាតាមពាក្យបណ្ដឹងរបស់ភាគីម្ខាង*

*ផ្ទុយពីករណីខាងលើ ប្រសិនបើមិនអាចទទួលបានការព្រមព្រៀងក្នុងការស្នើសុំកាត់កាល់សុំកូនធម្មតាទេ ភាគីម្ខាងនៃសុំកូនធម្មតាអាចដាក់* ***ពាក្យបណ្ដឹងទាមទារកាត់កាល់សុំកូនធម្មតា*** *បាន ដោយយោងទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល (មាត្រា ៣ ចំណុច ឈ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ ក្នុងករណីនេះ តុលាការធ្វើការសម្រេចសេចក្ដី ដោយចេញជា* ***សាលក្រម*** ។

*យោងតាមអត្ថន័យនៃមាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណី ភាគីខាងឪពុកម្ដាយចិញ្ចឹមអាចដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់បាន ហើយភាគីខាងកូនសុំធម្មតាក៏អាចដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់បានដែរ។*

*ប្រសិនបើកូនសុំជាអនីតិជននៅឡើយ អ្នកដែលនឹងក្លាយជាអ្នកតំណាងតាមច្បាប់កំណត់របស់កូនសុំ គឺជាអ្នកដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់នេះ។ ជាងនេះទៅទៀត បើកូនសុំបានដល់អាយុ ១៥ ឆ្នាំហើយ ត្រូវតែមានការយល់ព្រមពីអនីតិជននោះផងទើបបាន។*

*ក្នុងន័យដើម្បីការពារផលប្រយោជន៍របស់អនីតិជន ក្រមរដ្ឋប្បវេណីបានធ្វើការហាមឃាត់ការដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់ ពីសំណាក់ឪពុកម្ដាយចិញ្ចឹម ប្រសិនបើកូនសុំនៅជាអនីតិជននៅឡើយ* **(មាត្រា ១០៣១ កថាខណ្ឌទី ២)**។

*ជាមួយគ្នានេះ ការទាមទារកាត់កាល់សុំកូនធម្មតាត្រូវតែមានមូលហេតុដូចបានចែងនៅមាត្រា ១០៣១ កថាខណ្ឌទី ១ ពោលគឺ ៖*

*-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត។*

*-បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ ឆ្នាំ ថា ភាគីម្ខាងទៀតនៅរស់ ឬទទួលមរណភាព។*

*-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលនាំឱ្យពិបាកក្នុងការបន្តសុំកូន។*

***៣.២. អានុភាពនៃការកាត់កាល់សុំកូនធម្មតា***

*មិនខុសប្លែកពីអានុភាពនៃការកាត់កាល់សុំកូនពេញលេញទេ ការកាត់កាល់សុំកូនធម្មតា មិនមានអានុភាពប្រតិសកម្ម (**ភាពធាក់ថយក្រោយ**) ឡើយ បានសេចក្ដីថា ការកាត់កាល់មានអានុភាពបញ្ចប់សុំកូនធម្មតា គិតចាប់ពីពេលកាត់កាល់តទៅ។ ដូច្នេះ ទំនាក់ទំនងញាតិរវាងកូនសុំ និង ឪពុកម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម ត្រូវបញ្ចប់នៅពេលនោះ ។ ក៏ប៉ុន្តែ កូនសុំនៅតែអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមបាន* (**មាត្រា ១០៣២**)។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣៧៧៧

**សាលាដំបូង** ......

**ដីកាសម្រេចលេខ:** ...............
ថ្ងៃទី ...... ខែ...... ឆ្នាំ ......

# ដីកាសម្រេចបង្កើតសុំកូនពេញលេញ

យើង ................................... ចៅក្រមនៃសាលាដំបូង ...................។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០០៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ ៖**

១. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

២. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

**ឪពុកម្តាយបង្កើត ៖**

១. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

២. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

**កូនឈ្មោះ** ៖ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្ដាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ** ៖ បង្កើតសុំកូនពេញលេញរវាងឈ្មោះ **ក.** ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្ដាយចិញ្ចឹម និង ឈ្មោះ **គ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ........ ដែលមានឋានៈជាកូនសុំ។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ភេទប្រុស កើតនៅថ្ងៃទី .... ខែ ..... ឆ្នាំ.......... ដោយមានសំបុត្រកំណើតលេខ .... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ជាប្ដី និង ឈ្មោះ **ខ.** ភេទស្រី កើតថ្ងៃទី ... ខែ ... ឆ្នាំ ... គឺជាសហព័ទ្ធនឹងគ្នា ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ។ ឈ្មោះ **គ.** ភេទ ... កើតនៅថ្ងៃទី .... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ **ក.** មានអាយុ ... និង ឈ្មោះ **ខ.** មានអាយុ ... ពោលគឺមានអាយុលើសឈ្មោះ **គ.** លើសពី ២០ ឆ្នាំ។ ដូច្នេះ អ្នកដាក់ពាក្យសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនពេញលេញ តាមមាត្រា ១០០៨ មាត្រា ១០០៩ និង មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី។

២. ឈ្មោះ **ង.** និង ឈ្មោះ **ច.** ត្រូវជាឪពុកម្ដាយបង្កើតរបស់ឈ្មោះ **គ.** បានយល់ព្រមឱ្យឈ្មោះ **គ.** ទៅឈ្មោះ **ក.** និង ឈ្មោះ **ខ.** ចិញ្ចឹមធ្វើជាកូនសុំពេញលេញ ដោយសារតែពួកខ្លួនមិនមានលទ្ធភាពសមរម្យក្នុងការចិញ្ចឹមបីបាច់ថែរក្សាឈ្មោះ **គ.**។

៣. បន្ទាប់ពីឈ្មោះ **ក.** និង ឈ្មោះ **ខ.** បានសាកល្បងចិញ្ចឹមឈ្មោះ **គ.** អស់រយៈពេល ... កន្លងមក ឃើញថា ឈ្មោះ **ក.** និង ឈ្មោះ **ខ.** បានរស់នៅចុះសម្រុងជាមួយនឹងឈ្មោះ **គ.**។

៤. មានស្ថានភាពគ្រប់គ្រាន់ដែលជាមូលដ្ឋានក្នុងការបង្កើតសុំកូនពេញលេញ សមស្របទៅតាមផលប្រយោជន៍កូន។

៥. យោងតាមមាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ប្រាក់ប្រដាប់ក្ដីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

# សេចក្តីសម្រេចបញ្ចប់

១. បង្កើតសុំកូនពេញលេញ រវាងឈ្មោះ **ក.** ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ...... ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្តាយចិញ្ចឹម និង ឈ្មោះ **គ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង** ......

**ដីកាសម្រេចលេខ:** ……………

ថ្ងៃទី …... ខែ… … ឆ្នាំ …….

# ដីកាសម្រេចបង្កើតសុំកូនធម៌តា

យើង …………………………….. ចៅក្រមនៃសាលាដំបូង ………………។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/ ០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០២០ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ** ៖

១. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

២. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ** ៖ បង្កើតសុំកូនធម្មតារវាងឈ្មោះ **ក.** ភេទ …... កើតថ្ងៃទី…. ខែ ….. ឆ្នាំ ……. ដែលមានឋានៈជាម្តាយចិញ្ចឹម និង ឈ្មោះ **ខ.** ភេទ … កើតថ្ងៃទី……. ខែ ……. ឆ្នាំ ……… ដែលមានឋានៈជាកូនសុំ។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ជាស្ត្រីមេម៉ាយ កើតនៅថ្ងៃទី .... ខែ ..... ឆ្នាំ.......... ដោយមានសំបុត្រកំណើតលេខ .... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ពោលគឺមានអាយុ ..... បានព្រមព្រៀងបង្កើតសុំកូនធម៌តា ជាមួយនឹងឈ្មោះ **ខ.** នៅ លីវ ដែលកើតនៅថ្ងៃទី .... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ **ខ.** មានអាយុតិចជាងអ្នកដាក់ពាក្យសុំឈ្មោះ **ក.** ហើយក៏មិនមែនជាបុព្វញាតិរបស់អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ដែរ។

២. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** និង អ្នកដាក់ពាក្យសុំឈ្មោះ **ខ.** មានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងជាម្តាយ និងកូន។

៣. អ្នកដាក់ពាក្យសុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនធម៌តាបាន តាមមាត្រា ១០២០ នៃក្រមរដ្ឋប្បវេណី។

៤. យោងតាមមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## សេចក្តីសម្រេចបញ្ចប់

១. បង្កើតសុំកូនធម៌តា រវាងឈ្មោះ **ក.** ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ដែលមានឋានៈជាម្តាយចិញ្ចឹម និង ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

# សិក្ខាសាលា
# ស្តីពី
# ដីកាសម្រេចចាត់ចែងជា
# បណ្តោះអាសន្ន

**រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**



# ដីកាសម្រេចចាត់ចែង ជាបណ្ដោះអាសន្ន

1

## គោលគំនិតនៃការចាត់ចែងជាបណ្ដោះអាសន្ន

- មានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល ( មាត្រា ៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី )។

2

# ប្លង់នៃការសិក្សា

ផ្នែកទី ១-ប្រភេទនៃការចាត់ចែងរក្សាការពារ

ផ្នែកទី ២-នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន

ផ្នែកទី ៣-ការអនុវត្តដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

3

# ផ្នែកទី ១ : ប្រភេទនៃការចាត់ចែងរក្សាការពារ

- ការរឹបអូសជាបណ្ដោះអាសន្ន "មិនធ្វើបទបង្ហាញ"
- ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃ វិវាទ
- ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះ អាសន្ន (មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) "មិនធ្វើបទបង្ហាញ"

4

## ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

- រក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ
- ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុ។

មាត្រា ៥៣១

5

## ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

- <u>**ឧទាហរណ៍**</u> :

ក លក់ដីឱ្យ <u>ខ</u> និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឱ្យ ខ។ លុះក្រោយមក <u>ក</u> បានរំលាយកិច្ចសន្យាលក់ទិញដី ប៉ុន្តែមិនទាន់បានចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឱ្យ <u>ក</u> វិញទេ។
ដូច្នេះ <u>ក</u> អាចសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ព្រោះខ្លាច <u>ខ</u> ផ្ទេរកម្មសិទ្ធិទៅឱ្យអ្នកដទៃ។

6

## ភាគីនៅក្នុងនីតិវិធីនៃការក្សាការពារ

- ម្ចាស់បំណុល
- កូនបំណុល

7

## ផ្នែកទី២៖ នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន

ក-សមត្ថកិច្ចតុលាការ

ខ-ពាក្យសុំ

គ-នីតិវិធីនៃការសាកសួរភាគី

ឃ-ប្រាតិភោគ

ង-ការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

ច-ការបញ្ជូនដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

8

## ក_សមត្ថកិច្ចតុលាការ

- ជាសមត្ថកិច្ចផ្តាច់មុខ ( មាត្រា ៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

សមត្ថកិច្ចផ្តាច់មុខ : មិនអាចធ្វើការផ្លាស់ប្តូរ តាមការព្រមព្រៀង របស់ គូភាគីបានទេ ។

ឧទាហរណ៏ៈ- បណ្តឹងលែងលះ និងបណ្តឹងទាមទារអោយបញ្ជាក់អំពីអត្ថិភាព រឺនត្ថិភាពនៃ បុគ្គភាព "មាត្រា ១០-១ " ។

- បណ្តឹងទាមទារអោយជំនុំជំរះសារជាថ្មី "មាត្រា៣០៩ "

- នីតិវិធីដាស់តឿន "មាត្រា ៣២០-៣ "

9

## សមត្ថកិច្ចតុលាការ

១-សាលាដំបូងមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ"មាត្រា៥៤០" ។

<u>**ឧទាហរណ៏**</u> **:**<u>**ក**</u> ជាម្ចាស់បំណុលមានទីលំនៅ នៅខេត្តបាត់ដំបង <u>**ខ**</u> ជាកូនបំណុលមានទីលំនៅ នៅភ្នំពេញ ចង់ឱ្យមានការចាត់ចែងជាបណ្តោះអាសន្ន ចំពោះដីមួយកន្លែងរបស់កូនបំណុល ស្ថិតក្នុងខេត្តកំពង់ចាម ។ <u>**ក**</u> អាចដាក់ពាក្យសុំទៅតុលាការខេត្តកំពង់ចាមបាន ពីព្រោះដីដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅខេត្តកំពង់ចាម ។ ទន្ទឹមនឹងនោះ ម្ចាស់បំណុលក៏អាចដាក់ពាក្យសុំនៅតុលាការភ្នំពេញបានដែរ ។

# សមត្ថកិច្ចតុលាការ (មាត្រា ៥៤០)

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី (មើល មាត្រា ៨-៩-១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

-ពាក្យបណ្តឹងអង្គសេចក្តីនៅសាលាដំបូង : តុលាការនៃការជំនុំជម្រះលើកទី១

- បណ្តឹងឧទ្ធរណ៍ : តុលាការនៃការជំនុំជម្រះបណ្តឹង ឧទ្ធរណ៍

-បណ្តឹង តុលាការកំពូល : តុលាការនៃការជំនុំជម្រះលើកទី១

11

# សមត្ថកិច្ចតុលាការ (មាត្រា ៥៤០)

- ឧទាហរណ៍ :កូនបំណុល<u>ខ</u> ដែលមានទីលំនៅ នៅក្រុងភ្នំពេញ ហើយម្ចាស់បំណុល <u>ក</u> បានដាក់ពាក្យបណ្តឹងលើអង្គសេចក្តីនៅក្រុងភ្នំពេញ នោះសាលាដំបូងក្រុងភ្នំពេញជាតុលាការមានសមត្ថកិច្ច។ ដូនេះ <u>ក</u> អាចដាក់ពាក្យសុំដីកាចាត់ចែងនៅភ្នំពេញបាន ទោះបីដីដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅខេត្តណាក៏ដោយ ។
- ម្ចាស់បំណុលក៏អាចដាក់ពាក្យទៅ តុលាការមានសមត្ថកិច្ចលើទីកន្លែងដែលដី នោះស្ថិតនៅបាន ទោះបីបណ្តឹងអង្គសេចក្តីត្រូវបានដាក់នៅសាលាដំបូងភ្នំពេញក៏ដោយ ។

12

## ខ_ពាក្យសុំឱ្យចេញដីកាសម្រេច

- លាយលក្ខណ៍អក្សរ ( មាត្រា ៥៣៤-ក)
- ឈ្មោះ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងកំណត់ដោយច្បាប( មាត្រា៥៤១-១-ក)
- ខ្លឹមសារនៃដីកាសម្រេចចាត់ចែងដែលអ្នកដាក់ពាក្យសុំ ទាមទារ ( មាត្រា ៥៤១-១-ខ) ។

ឧទា- សុំដីកាចាត់ចែងបណ្តោះអាសន្នហាមឃាត់មិនអោយកូនបំណុល ចុះបញ្ជីផ្ទេរកម្មសិទិនៅលើដីដែលជាកម្មវត្ថុនៃវិវាទជាដើម ។ 13

## ពាក្យសុំឱ្យចេញដីកាសម្រេច

- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

( ត្រូវសរសេរឱ្យច្បាស់លាស់ និងភស្តុតាងតាមហេតុនីមួយៗ សេចក្តីបញ្ជាក់ដំបូង) ។

- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ គឺត្រូវតែជា **សិទ្ធិប្រត្យក្ស** ឬត្រូវបានចាត់ទុកដូចជាសិទ្ធិប្រត្យក្សដែរ

**<u>ឧទាហរណ៍</u> :** ម្ចាស់បំណុលបាន សុំដីកាចាត់ចែងមិនឱ្យកូនបំណុលផ្ទេរកម្មសិទ្ធិដីដែលជាកម្មវត្ថុនៃវិវាទ ដូចនេះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារគឺ កម្មសិទ្ធិ ។ 14

## ពាក្យសុំឱ្យចេញដីកាសម្រេច

- ភាពចាំបាច់នៃការរក្សាការពារ ( ត្រូវសរសេរឱ្យច្បាស់លាស់ និងសរសេរនូវភស្តុតាងតាមហេតុនីមួយៗ : សេចក្តីបញ្ជាក់ដំបូង មាត្រា ៥៤១-៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

លក្ខណវិនិច្ឆ័យសំខាន់ៗនៃភាពចាំបាច់នៃការចាត់ចែងបណ្តោះអាសន្នគឺ:

១-បារម្ភថាម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាននៅមុនពេលសាលក្រមចុងក្រោយត្រូវបានចេញ

២-ឬនឹងលំបាកយ៉ាងខ្លាំងក្នុងការអនុវតសិទ្ធិ នៅមុនពេលសាលក្រមចុងក្រោយត្រូវបានចេញ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។

ឧទា:-ហាមឃាត់ ខ មិនអោយផ្ទេរកម្មសិទ្ធិ ព្រោះខ្លាច ខ ផ្ទេរកម្មសិទ្ធិឱ្យអ្នកដទៃ

15

## ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ

- អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធ ៥000រៀល "មាត្រា ៥៣៧-១"
- តុលាការត្រូវពិនិត្យលើពាក្យសុំ ដូចករណីពិនិត្យលើពាក្យបណ្តឹងនៅក្នុងនីតិវិធីនៃបណ្តឹងដែរ ( មាត្រា ៥៣៩ និងមាត្រា ៧៨ នៃក្រមនីតិវិធី) ។
- ប៉ុន្តែការបញ្ជូនពាក្យសុំទៅឱ្យកូនបំណុល ពុំអាចមកអនុវត្តបានទេ ព្រោះខុសទៅនឹងគោលគំនិតនៃនីតិវិធីនៃការចាត់ចែងរក្សាការពារ ។

16

## គ.នីតិវិធីនៃការសាកសួរភាគី

- មិនបាច់ទាញហេតុផលដោយផ្ទាល់មាត់ទេ (មាត្រា ៥៣៩-មាត្រា ១១៤-១-២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- អាចសាកសួរម្ចាស់បំណុលបាន (សេចក្តីបញ្ជាក់ដំបូង)។

17

## ឃ.ប្រាតិភោគសម្រាប់ដីកាសម្រេច

- តុលាការអាចឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ (មាត្រា ៥៤២)។
- ប្រាតិភោគត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ (មាត្រា ៥៣៦)។
- អាចចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ មុនចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។
- អាចបង្គាប់ឱ្យដាក់ប្រាតិភោគ នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។

18


ដីការក្សាការពារឱ្យដាក់ប្រាតិភោគ
ពាក្យសុំ
សួរម្ចាស់បំណុល និងវិនិច្ឆ័យរឿង
មានសេចក្តីបញ្ជាក់ដំបូង
គ្មានសេចក្តីបញ្ជាក់ដំបូង
ដីកាសម្រេចបង្គាប់
ឱ្យដាក់ប្រាតិភោគ
មានការតម្កល់
គ្មានការតម្កល់
ដីការក្សាការពារ
ដីកាលើកចោល
19


ដីការក្សាការពារភ្ជាប់លក្ខខណ្ឌ
ពាក្យសុំ
សួរម្ចាស់បំណុល និងវិនិច្ឆ័យរឿង
មានសេចក្តី
បញ្ជាក់ដំបូង
គ្មានសេចក្តី
បញ្ជាក់ដំបូង
ដីការក្សាការពារ *(ដាក់ប្រាតិភោគ
ជាលក្ខខណ្ឌនៃការអនុវត្ត)*
ដីកាលើកចោល
20

## ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

- ប្រាតិភោគនេះ សម្រាប់សងទៅកូនបំណុលក្នុងករណី ដែលការចេញដីកាសម្រេចចាត់ចែងរក្សាការពារ នាំឱ្យកូនបំណុលទទួលរងនូវការខូចខាត ដោយសារកំហុសរបស់ម្ចាស់បំណុល ។
- កូនបំណុលត្រូវដាក់ពាក្យបណ្ដឹងទាមទារសំណងនៃការខូចខាតពីម្ចាស់បំណុល ។
- កូនបំណុលមានសិទ្ធិទទួលការសងចំពោះប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដែលត្រូវបានតម្កល់ ឬផ្ញើ ជា ***អាទិភាព*** ( មាត្រា ៧២) ។

21

## ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

<u>ឧទាហរណ៍</u> ៖ ក លក់ដីឲ្យទៅ ខ ហើយបន្ទាប់មកក៏បានចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យទៅ ខ ដែរ។ ក្រោយមក ក បានរំលាយកិច្ចសន្យាលក់ទិញ ក៏ប៉ុន្តែការចុះបញ្ជីផ្ទេរកម្មសិទ្ធិ មិនទាន់ត្រូវបានផ្ទេរទៅឲ្យ ក នៅឡើយទេ។ ដូច្នេះ ក បានដាក់ពាក្យសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ព្រោះគាត់ខ្លាច ខ ផ្ទេរកម្មសិទ្ធិទៅឲ្យអ្នកដទៃ។ តុលាការទទួលស្គាល់ពាក្យសុំនេះ។

ដោយសារតែការហាមឃាត់របស់ ក ខ បានបាត់បង់ឱកាសលក់ដីនៅក្នុងតម្លៃថ្លៃជាងមុន។ បន្ទាប់មកនៅក្នុងបណ្ដឹងអង្គសេចក្ដី តុលាការរកឃើញថាការរំលាយកិច្ច មិនត្រឹមត្រូវទេ។ ដូច្នេះ ប្រាតិភោគ គឺសម្រាប់ការពារករណីបែបនេះ។

22

# ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

- **ទំរង់នៃដីកាសំរេចអំពីប្រាតិភោគ**

សាលាដំបូងខេត្តកណ្តាល **ដីកាសម្រេចអំពីប្រាតិភោគ**

លេខ -បានឃើញសំណុំរឿងរក្សាការពារលេខ.......

ភាគី........

ខ្លឹមសារនៃដីកាចាត់ចែងបណ្តោះអាសន្នដែលអ្នកដាក់ពាក្យសុំទាមទារ......

យោងលើករណីនៃពាក្យសុំ ចាត់ចែងជាបណ្តោះអាសន្ន រវាងភាគី ខាងលើ តុលាការសំរេចដូចខាងក្រោម:

**សេចក្តីសំរេចបញ្ចប់**

ម្ចាស់បំណុលត្រូវផ្ញើប្រាក់ចំនួន..............ជាប្រាតិភោគសំរាប់កូនបំណុល នៅត្រឹមថ្ងៃទី........

ថ្ងៃ.......ខែ.........ឆ្នាំ............

ចៅក្រម

23

# ខ. ការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

- ទៅតាមកម្រិតនៃភាពចាំបាច់ ដើម្បីសម្រេចគោលបំណង នៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជា បណ្តោះអាសន្ន (មាត្រា ៥៤៨នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

**ឧទាហរណ៍** :

- ហាមឃាត់កូនបំណុលឈ្មោះ ខ ក្នុងការផ្ទេរកម្មសិទ្ធិ ។

24

## វិធីចាត់ចែងបណ្តោះអាសន្ន (មាត្រា ៥៤៩)

- គឺមានតែមួយគត់គឺ បង្គាប់ឱ្យកូនបំណុលបញ្ឈប់ការធ្វើសកម្មភាព។

បញ្ឈប់ការផ្ទេរកម្មសិទ្ធិ ,បញ្ឈប់ការផ្ទេរការកាន់កាប់ តុលាការអាចបង្គាប់អោយអ្នកមើលថែគ្រប់គ្រងទ្រព្យនោះបាន។

25

## វិធីចាត់ចែងបណ្តោះអាសន្ន (មាត្រា ៥៤៩)

- ចំណាំ៖ ក្នុងករណីដែលតុលាការបង្គាប់ឲ្យអ្នកមើលថែ គ្រប់គ្រងទ្រព្យនោះ តុលាការមិនអាចចេញដីកាសម្រេច បើមិនបានឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន។ (មាត្រា ៥៤៨ កថាខណ្ឌទី ២ និង ទី ៤)

26

## វិធីចាត់ចែងបណ្ដោះអាសន្ន (មាត្រា ៥៤៩)

- ឧទាហរណ៍ ៖ ក ជួលម៉ូតូឲ្យទៅ ខ។ ពីរ ឬបីខែក្រោយមក ខ មិនបានបង់ថ្លៃឈ្នួលជួលម៉ូតូទេ។ បន្ទាប់មក ក ក៏បានរំលាយកិច្ចសន្យា ប៉ុន្តែ ខ បដិសេធមិនព្រមប្រគល់ម៉ូតូ។ ក ក៏បានដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ ខ មិនឲ្យផ្ទេរការកាន់កាប់ម៉ូតូដោយផ្អែកទៅលើសិទ្ធិទាមទារឲ្យប្រគល់ម៉ូតូត្រឡប់មកវិញដោយផ្អែកលើកម្មសិទ្ធិ។
- នៅក្នុងករណីនេះ អ្នកមើលថែ គឺជាអ្នកកាន់កាប់ម៉ូតូ ដូច្នេះ មានន័យថា វាគឺជាការបង្កើតឋានៈថ្មីមួយតាមផ្លូវច្បាប់ (ប្រៀបធៀបមាត្រា ៥៤៨ កថាខណ្ឌទី ២)។ ដូច្នេះ ទោះបីជាពាក្យសុំនេះ គឺជាការចាត់ចែងជាបណ្ដោះអាសន្នចំពោះកម្មវត្ថុនៃវិវាទ ការទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរ គឺមានលក្ខណៈចាំបាច់។

27

## អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្ន (មាត្រា ៥៧១)

- ឧទាហរណ៍ ៖ ក ជួលម៉ូតូឲ្យទៅ ខ។ ពីរ ឬបីខែក្រោយមក ខ មិនបានបង់ថ្លៃឈ្នួលជួលម៉ូតូទេ។ បន្ទាប់មក ក ក៏បានរំលាយកិច្ចសន្យា ប៉ុន្តែ ខ បដិសេធមិនព្រមប្រគល់ម៉ូតូ។ ក ក៏បានដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ ខ មិនឲ្យផ្ទេរការកាន់កាប់ម៉ូតូដោយផ្អែកទៅលើសិទ្ធិទាមទារឲ្យប្រគល់ម៉ូតូត្រឡប់មកវិញដោយផ្អែកលើកម្មសិទ្ធិ។

28

## អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្ន ( មាត្រា ៥៧១ )

- នៅក្នុងករណីដែលពាក្យសុំនេះ ត្រូវបានទទួលស្គាល់ ហើយវាត្រូវបានអនុវត្ត នោះ ក អាចធ្វើការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ប៉ុន្តែអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថាការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានធ្វើហើយ។
- ជនដែលកាន់កាប់ម៉ូតូនេះ នៅក្រោយពេលការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នត្រូវបានអនុវត្ត ត្រូវបានសន្មតថា **កាន់កាប់វត្ថុនោះដោយដឹងថាការ**អនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានធ្វើហើយ។

29

## ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

- ត្រូវសម្រេចពីបន្ទុកនៃប្រាក់ប្រដាប់ក្ដីនៅក្នុងដីកាសម្រេចរក្សាការពារ ( មាត្រា ៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

30

# ច_ការបញ្ជូនដីកាសម្រេច

- តុលាការត្រូវបញ្ជូនដីកាសម្រេចទៅភាគី ( មាត្រា ៥៤៣) ។
- បញ្ជូនដីកាសម្រេចទៅឱ្យម្ចាស់បំណុល ។
- បញ្ជូនដីកាសម្រេចរក្សាការពារឱ្យទៅកូនបំណុល( មាត្រា៥៦២ កថាខណ្ឌទី ៣) ។
- តើត្រូវបញ្ជូនដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារឱ្យទៅម្ចាស់បំណុល និង កូនបំណុលដែរឬទេ ? មាត្រា ៥៤៤ ប្រើពាក្យ "ជូនដំណឹង" ( មើលមាត្រា ២១៣) ។
- ករណីម្ចាស់បំណុលដកពាក្យសុំដីកាចាត់ចែង ត្រូវចាត់ទុកថាគ្មានពាក្យសុំតាំងពីដំបូង ដូចនេះមិនចាំបាច់ធ្វើការបញ្ជូនទេ។

31

# សង្ខេបលំហូរនីតិវិធីចាត់ចែងបណ្តោះអាសន្ន

១- ម្ចាស់បំណុលដាក់ពាក្យសុំ

២- តុលាការពិនិត្យពាក្យសុំ និង ពន្ធដាក់ពាក្យសុំ

៣- បើពាក្យសុំពុំត្រឹមត្រូវ  តុលាការចេញដីកាបង្គាប់អោយកែតំរូវ ។

- បើមិនទាន់បង់ពន្ធ តុលាការចេញដីកាបង្គាប់អោយ បង់ពន្ធ

៤-តុលាការអាចសាកសួរភាគីបន្ថែមបាន

៥- ម្ចាស់បំណុលដាក់ប្រាតិភោគ

៦- ចេញដីកាចាត់ចែងបណ្តោះអាសន្ន

៧- ការបញ្ជូន

32

## ផ្នែកទី ៣_ការអនុវត្តដីកាសម្រេចចាត់ចែង

ក-សមត្ថកិច្ច

ខ-ពាក្យសុំឱ្យអនុវត្តដីកាសំរេចចាត់ចែងជាបណ្តោះអាសន្ន

គ-វិធីអនុវត្តដីកាសំរេចចាត់ចែងជាបណ្តោះអាសន្ន

33

## ក_សមត្ថកិច្ច

**តុលាការអនុវត្តដីកាចាត់ចែងរក្សាការពារ :**

- តុលាការអនុវត្ត ។
- អាជ្ញាសាលា ។

( មាត្រា ៥៣២ កថាខណ្ឌទី២-៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

34

## ខ. ពាក្យសុំឱ្យអនុវត្តដីកាចាត់ចែងរក្សាការពារ

- ត្រូវដាក់ក្នុងអំឡុងពេល ២ សប្តាហ៍ ចាប់ពីថ្ងៃដែលដីកាសម្រេចចាត់ចែង រក្សាការពារត្រូវបានបញ្ជូនទៅម្ចាស់បំណុល ( មាត្រា ៥៦២ កថាខណ្ឌទី ២) ។ បើដាក់ពាក្យសុំក្រោយ ២សប្តាហ៍ ដីកាចាត់ចែងរក្សាការពារនោះពុំអាចអនុវត្តបានទេ ករណីនេះ អ្នកអនុវត្តត្រូវលើកចោលពាក្យសុំអនុវត្ត រីឯម្ចាស់បំណុលអាចដាក់ ពាក្យសុំដីកាសំរេចជាថ្មីម្តងទៀត ។
- ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ( មាត្រា ៥៣៤ ចំណុច ច.) ។

35

## ពាក្យសុំឱ្យអនុវត្តដីកាចាត់ចែងរក្សាការពារ

- សរសេរនូវចំណុចដូចចែងក្នុងមាត្រា ៣៤៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ( មាត្រា ៥៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- ត្រូវបង់សោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ( មាត្រា ៥៣៧-២-៣-៥ នៃក្រមនីតិវិធី) ។

36

## ពាក្យសុំឱ្យអនុវត្តដីកាចាត់ចែងរក្សាការពារ

- ពាក្យសុំត្រូវភ្ជាប់ជាមួយនូវលិខិតចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ( មាត្រា ៥៦២ កថា. ១ វ៉ា. ១) ។
- ដីកាសម្រេចរក្សាការពារ ត្រូវភ្ជាប់ជាមួយនូវរូបមន្តអនុវត្តប្រសិនបើការអនុវត្តការរក្សាការពារចំពោះ ឬសម្រាប់ជនក្រៅពីភាគីកំណត់នៅក្នុងដីកា ( មាត្រា ៥៦២ កថា.១ វ៉ា.២)

37

## គ~វិធីអនុវត្តការរក្សាការពារ

**ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន**

**( មាត្រា ៥៧០.មាត្រា ៥៧១)**

- ដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ( មាត្រា ៥៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

38

សូមអរគុណ

39

# ប្រៀបធៀបការរឹបអូសជាបណ្តោះអាសន្ន ,ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

| ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន<br>(មាត្រា ៥៣១ ចំណុច ក, ៥៤៥) | ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ<br>(មាត្រា ៥៣១ ចំណុច ខ, ៥៤៨ កថាខណ្ឌទី១) | ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន<br>(មាត្រា ៥៣១ ចំណុច គ, ៥៤៨ កថាខណ្ឌទី២) |
| --- | --- | --- |
| ១.រក្សាស្ថានភាពដើមនៃទ្រព្យកូនបំណុល<br>២.សិទ្ធិលើបំណុល<br>(គោលបំណងឱ្យសងជាប្រាក់)<br>៣.នីតិវិធី<br>➢មិនធ្វើការទាញហេតុផលផ្ទាល់មាត់<br>(រក្សាការសម្ងាត់ និងលឿន)<br>➢អាចបង្គាប់ឱ្យដាក់ប្រាតិភោគ(៥៤២)<br>➢ត្រូវកំណត់ពីប្រាក់រំដោះ (៥៤៧)<br>➢វិធីចាត់ចែង៖ រឹបអូសទ្រព្យកូនបំណុល | ១.រក្សាស្ថានភាពដើមនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ<br>២.សិទ្ធិប្រត្យក្ស<br>៣.នីតិវិធី<br>➢មិនធ្វើការទាញហេតុផលផ្ទាល់មាត់<br>(រក្សាការសម្ងាត់ និងលឿន)<br>➢អាចបង្គាប់ឱ្យដាក់ប្រាតិភោគ(៥៤២)<br>➢មិនកំណត់ពីប្រាក់រំដោះ<br>➢វិធីចាត់ចែង៖ បង្គាប់ឱ្យកូនបំណុលបញ្ឈប់ ការធ្វើសកម្មភាព (មិនឱ្យសកម្មភាព) ឬឱ្យ | ១.បំបាត់ចោលជាបណ្តោះអាសន្ននូវហានិភ័យ ដែលអាចនឹងកើតមានចំពោះម្ចាស់បំណុល<br>២.សិទ្ធិប្រត្រក្ស ឬសិទ្ធិលើបំណុល<br>(លើកលែងគោលបំណងឱ្យជាប្រាក់)<br>៣.នីតិវិធី<br>➢ទាញហេតុផលផ្ទាល់មាត់ ឬសាកសួរភាគី<br>(មិនរក្សាការសម្ងាត់ និងយូរ ព្រោះប៉ះពាល់កូនបំណុលធ្ងន់ធ្ងរ) (៥៤៨/៤)<br>➢អាចបង្គាប់ឱ្យដាក់ប្រាតិភោគ(៥៤២)<br>➢មិនកំណត់ពីប្រាក់រំដោះ<br>➢វិធីចាត់ចែង៖ កំណត់ក្នុងមាត្រា ៥៤៩ |

| | | |
|---|---|---|
| ➢វិធីអនុវត្តៈ<br>-អចលនវត្ថុ៖ ចុះបញ្ជីផ្ទុកផ្ដាក់ (៩៦៧)<br>-ចលនវត្ថុ៖ អាជ្ញាសាលាកាន់កាប់ (៩៦៥)<br>-សិទ្ធិលើបំណុល៖ បញ្ជូនដីកាសម្រេចហាមឃាត់មិនឱ្យកូនបំណុលទី៣សងទៅកូនបំណុល (៩៦៦) | អ្នកមើលថែគ្រប់គ្រងវត្ថុនោះ (៩៤៩)<br>➢វិធីអនុវត្តៈ ដូចការរឹបអូសបណ្ដោះអាសន្ន ឬអនុវត្តដោយបង្ខំ (៩៧០, ៩៧១) | ➢វិធីអនុវត្តៈ ដូចការរឹបអូសបណ្ដោះអាសន្ន ឬអនុវត្តដោយបង្ខំ (៩៧០) |
| ***<u>ឧទាហរណ៍:</u>*** *ក ជំពាក់ប្រាក់ **ខ** ចំនួន ២០០០ ដុល្លាអាមេរិក។ ពេលដល់កំណត់សងប្រាក់ **ក** មិនបានយកប្រាក់ **ខ**។ **ក** មានតែដី A មួយកន្លែង។ បច្ចុប្បន្ន **ក** ជំពាក់ប្រាក់ម្ចាស់បំណុលផ្សេងច្រើននាក់ និងកំពុងរៀបចំលក់ដី A នោះ។ ដូច្នេះ ខ អាចស្នើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននូវដី A។* | ***<u>ឧទាហរណ៍:</u>*** *ក លក់ដីឱ្យ **ខ** និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឱ្យ **ខ**។ លុះក្រោយមក **ក** បានរំលាយកិច្ចសន្យាលក់ទិញដី ប៉ុន្តែមិនទាន់បានចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឱ្យ **ក** វិញទេ។ ដូច្នេះ **ក** អាចសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ព្រោះខ្លាច <u>**ខ**</u> ផ្ទេរកម្មសិទ្ធិទៅឱ្យអ្នកដទៃ។* | ***<u>ឧទាហរណ៍:</u>*** *ក បានធ្វើរបងនៅលើដីដែលជាកម្មសិទ្ធិរបស់ **ខ** និងបិទផ្លូវមិនឱ្យ **ខ** ចេញចូលដីនោះបាន។ ដូច្នេះ **ខ** អាចស្នើសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ដើម្បីឱ្យវាយរបងចេញ។* |

# ក្រមុ

# សំណួរ និង ចម្លើយ

# ទាក់ទងនឹងសិក្ខាសាលា

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ

ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

២០១៤~២០១៥

# មាតិកា

ទំព័រ

❖ **គំរូពាក្យសុំដីកាសម្រេចលែងលះតាមការព្រមព្រៀង**........................................ ១

❖ **កម្រងសំណួរ និង ចម្លើយ**.................................................................................. ៣

១. តើអ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិខុសគ្នាដូចម្ដេច?................. ៣

២. ហេតុអ្វីបានជាច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងអនុញ្ញាតឲ្យជននៅក្រោមអាណាព្យាបាលទូទៅធ្វើសកម្មភាពបណ្ដឹង (មាត្រា ១៧ កថាខណ្ឌទី ២)?................................ ៣

៣. ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង អនុវត្តតែករណីដែលភាគីព្រមព្រៀងគ្នា និង គ្មានវិវាទ។ ហេតុអ្វីបានជាច្បាប់នេះ ត្រូវយកមកអនុវត្តនៅក្នុងការបែងចែកមត៌កដែលកំណត់ក្នុងផ្នែកទី ៥ ចំណុច ១៧ ដែលជាករណីសន្តតិជនមានវិវាទ?................................................................ ៤

៤. ភាគីមានសាលក្រមស្ថាពរដែលមានកម្មវត្ថុទាមទារឲ្យប្រគល់អចលនវត្ថុ ហើយនេះ គឺជាការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកលើ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី នៅមុនពេលអនុវត្តច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។ ភាគីមិនបានអនុវត្តសាលក្រមនេះភ្លាមៗទេ ក្រោយពីរយៈពេលយូរបានកន្លងផុតទៅ ភាគីក៏បានព្រមព្រៀងគ្នាអនុវត្តសាលក្រមនេះ។ ដោយបារម្ភអំពីសោហ៊ុយអនុវត្ត និង គ្មានបំណងក្នុងការអនុវត្តសាលក្រម ពួកគាត់ក៏បានព្រមព្រៀងគ្នាដាក់ពាក្យសុំថ្មី នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ទៅតុលាការ។ តើតុលាការអាចអនុវត្តច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង តារាងឧបសម្ព័ន្ធ ផ្នែក ៤ ចំណុច ៦ បានដែរឬទេ ?................ ៤

៥. នៅក្នុងករណីដែលប្ដីនិងប្រពន្ធរស់នៅជាអនីតិសង្វាសបានធ្វើការលែងលះគ្នានៅសាលាសង្កាត់ ហើយបានឯកភាពគ្នាប្រគល់កូនចំនួនពីរនាក់ឲ្យទៅប្រពន្ធជាអ្នកគ្រប់គ្រង ហើយប្ដីក៏នៅតែអាចប្រាស្រ័យទាក់ជាមួយកូនដូចធម្មតា។ ប៉ុន្តែ ក្រោយមកប្រពន្ធបានដឹងថា ប្ដីត្រៀមនឹងរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ប្រពន្ធក៏ខឹង ហើយមិនអនុញ្ញាតអោយប្ដីមកលេងកូនដូចសព្វដងទៀត។ តើប្ដីត្រូវធ្វើដូចម្ដេច? តើប្ដីអាចប្ដឹងដកអំណាចមេបាពីប្រពន្ធបានដែរឬទេ?.............................................................................. ៥

៦. ចំពោះការលែងលះដោយការព្រមព្រៀង ដោយភ្ជាប់ជាមួយកិច្ចសន្យាព្រមព្រៀងគ្នាលែងលះ តើតុលាការគួរចេញដីកាសម្រេច ឬសាលក្រម?.............................................................................. ៥

៧. នៅពេលដែលដីកាសម្រេចលើរឿងក្ដីមិនមែនជាបណ្ដឹង បានចូលជាស្ថាពរ តើក្រឡាបញ្ជីត្រូវបញ្ជាក់អំពីការចូលជាស្ថាពរ ដូចសាលក្រមដែរឬទេ ?...................................................................... ៥

៨. ពីរសប្ដាហ៍ក្រោយចេញដីកាសម្រេច គឺចំថ្ងៃអាទិត្យ ឬ ថ្ងៃបុណ្យ។ តើភាគី អាចប្ដឹងជំទាស់នៅថ្ងៃចន្ទ ឬថ្ងៃបន្ទាប់បានដែរឬទេ?.............................................................................................. ៦

៩. តុលាការចេញដីកាសម្រេច។ ២ ថ្ងៃក្រោយមក ភាគីព្រមព្រៀងគ្នាមិនប្ដឹងជំទាស់។ តើភាគីអាចប្ដឹងជំទាស់បានទេ ក្រោយរយៈពេល ២ សប្ដាហ៍កន្លងផុត ? ...... ៦

១០. បន្ទាប់ពីតុលាការចេញដីកាសម្រេចនៃនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនបណ្ដឹង ភាគីបានព្រមព្រៀងគ្នាមិនប្ដឹងជំទាស់។ តើភាគីអាចសុំបញ្ជាក់ស្ថាពរបានដែរឬទេ? ...... ៦

១១. សូមលើកជាឧទាហរណ៍ចំពោះរឿងក្ដីដែលអនុវត្តតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។ ...... ៧

១២. តើច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មានវិសាលភាពគ្របដណ្ដប់លើការបញ្ជាក់អំពីបុគ្គល (គន្ទីទី ២) និង សន្តតិកម្ម (គន្ទីទី ៨) ដែរឬទេ? ...... ៩

១៣. ក្រសួងបានចេញប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ បើមានបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីការផ្លាស់ប្ដូរ ការកែប្រែ ការកើនឡើង និងការថយចុះនៃទ្រព្យ តើនេះគឺជាប្រភេទនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលដែរឬទេ ? ...... ៩

១៤. រឿងក្ដីមានជនពាក់ព័ន្ធច្រើន តើអាចបង្កើតក្រុមប្រឹក្សាជំនុំជម្រះពីដំបូងបានដែរឬទេ? ...... ៩

១៥. តើតុលាការត្រូវបង្កើត សៀវភៅចុះបញ្ជីសំណុំរឿងទាក់ទងនឹងឋានៈបុគ្គល ដាច់ដោយឡែកពីសៀវភៅចុះបញ្ជីបណ្ដឹងរដ្ឋប្បវេណី? ...... ១០

១៦. ចំពោះបណ្ដឹងទាមទារឲ្យទទួលស្គាល់ ឬបណ្ដឹងបដិសេធបិតុភាព តើអនីតិជនមានសមត្ថភាពក្នុងការធ្វើបណ្ដឹងដែរឬទេ? ...... ១០

១៧. បណ្ដឹងលែងលះដើមចោទបានដាក់ពាក្យបណ្ដឹងទៅតុលាការខេត្តសៀមរាប។ តែចុងចម្លើយបានប្ដូរទីលំនៅទៅរស់នៅខេត្តបន្ទាយមានជ័យ ហើយដើមចោទបានជាប់ពន្ធនាគារនៅខេត្តឧត្ដរមានជ័យ តើតុលាការនៅខេត្តសៀមរាបនៅតែមានសមត្ថកិច្ចលើបណ្ដឹងលែងលះនោះ។ ...... ១១

១៨. A និង B រស់នៅជាអនីតិសង្វាស បានដាក់ពាក្យសុំ ឬ ពាក្យបណ្ដឹងលែងលះ។ តើតុលាការត្រូវធ្វើដូចម្ដេច? ...... ១១

១៩. ទាក់ទងនឹងបណ្ដឹងលែងលះ ភាគីម្ខាងមិនបានទាមទារឲ្យភាគីម្ខាងទៀតទទួលបន្ទុកនៃសោហ៊ុយចិញ្ចឹមកូនទេ ហើយតុលាការក៏បានចេញសាលក្រមរួចទៅហើយដែរ។ ប៉ុន្តែក្រោយមក ភាគីដែលចិញ្ចឹមកូនត្រូវបានស្លាប់ តើកូនដែលជាអនីតិជនអាចប្ដឹងទៅតុលាការឲ្យភាគីម្ខាងទៀតនោះទទួលបន្ទុកចិញ្ចឹមខ្លួនបានដែរឬទេ? ...... ១១

២០. X ជាម្ដាយរបស់ Y1 បានធ្វើប្រទានកម្មដោយប្រគល់នូវផ្ទះ១ខ្នងឲ្យទៅកូន Y1Y2 ក្នុងចំណងដៃអាពាហ៍ពិពាហ៍។ ក្រោយមកប្ដីប្រពន្ធ Y1Y2 លែងលះគ្នា Y2បានទាមទារទៅ Y1ឲ្យបែងចែកទ្រព្យសម្បត្តិ

ដែលជាផ្ទះនោះ។ ម្តាយX បានដាក់ពាក្យបណ្តឹងផ្សេង ដោយយោងលើសិទ្ធិលើកម្មសិទ្ធិទាមទារឲ្យ Y1Y2 ប្រគល់ផ្ទះមកវិញបានដែរ ឬទេ?........................................................................................ ១២

២១.គូភាគីកំពុងដំណើការលែងលះគ្នានៅតុលាការ ហើយមានតតិយជនមួយទៀតបានដាក់ពាក្យបណ្តឹងថាភាគីប្តីមានបំណុលជាមួយគាត់។
នៅក្នុងករណីដែលតុលាការ បានបញ្ចូលរឿងក្តីហើយ តើគួរបំបែកសំណុំរឿងឬទេ?.................. ១២

២២.នីតិវិធីបណ្តឹងផ្សេងគ្នាមិនអាចបញ្ចូលនៅក្នុងបណ្តឹងតែមួយបានទេ លើកលែងតែការទាមទារពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងការទាមទារពាក់ព័ន្ធនឹងការខូចខាតដែលកើតមានឡើងដោយអង្គហេតុ ដែលជាមូលហេតុនៃការទាមទារពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះ។
អង្គហេតុ ៖ មានបណ្តឹងពីរកំពុងចាត់ការ។ បណ្តឹងមួយ គឺជាបណ្តឹងលែងលះរវាង ប្តី X និងប្រពន្ធ Y ចំណែកឯបណ្តឹងមួយទៀត គឺជាបណ្តឹងទាមទារអោយសងបំណុលដែលធ្វើឡើងដោយម្ចាស់បំណុលរបស់ប្តី។
១. តើបណ្តឹងទាំងពីរនេះ អាចបញ្ចូលគ្នាបានដែរឬទេ?
២.ក្នុងករណីដែលប្តី ឬ ប្រពន្ធទទួលមរណភាព តើតុលាការត្រូវចាត់ការបណ្តឹងទាំងពីរនេះយ៉ាងដូចម្តេច?.................................................................................................................. ១៣

២៣.នៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រសិនបើភាគីទទួលមរណភាព ហើយមិនមានសន្តតិជន តើតុលាការអាចចេញសាលក្រម ឬដីកាសម្រេចដើម្បីបញ្ចប់នីតិវិធីបណ្តឹង? .............................. ១៣

២៤.ក្នុងដំណើរការនីតិវិធីលែងលះ ចុងចម្លើយបានបាត់ខ្លួន។ ក្នុងករណីនេះ តើតុលាការត្រូវចេញសាលក្រមកំបាំងមុខ ឬ សាលក្រមធម្មតា? ...................................................................................... ១៤

២៥.នៅក្នុងរឿងក្តីកំបាំងមុខ ទាក់ទងនឹងឋានៈបុគ្គល តើចុងចម្លើយអាចប្តឹងទាស់បានដែរឬទេ?......... ១៥

២៦.តើដីកាសម្រេចដែលមានចែងនៅក្នុងមាត្រា ២២ នៃច្បាប់ស្តីពីនិតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលអាចជាលិខិតអនុវត្តអនុវត្តដែរឬទេ?........................................................................... ១៥

២៧.នៅក្នុងរឿងក្តីតែមួយ តែមានសាលក្រមពីរ មួយសាលក្រមលើនីតិវិធីស្តីពីឋានៈបុគ្គល និងមួយទៀតជាសាលក្រមលើនីតិវិធីរដ្ឋប្បវេណី តើសាលក្រមមួយណាមានអានុភាព?........................................ ១៦

២៨.តើមេឃុំ និង នគរបាល អាចធ្វើការបញ្ជូនបានដែរឬទេ? ច្បាប់អនុញ្ញាតការបញ្ជូន មានតែ ក្រឡាបញ្ជីអាជ្ញាសាលា ប្រែសនីយ៍។........................................................................................... ១៧

២៩.តើការបញ្ជូនដោយអាជ្ញាសាលាត្រូវធ្វើតាមរយៈលិខិតអនុសិដ្ឋដូចគ្នានឹងបុគ្គលិកប្រៃសនីយ៍ដែរ ឬទេ ?........................................................................................................................ ១៧

៣០.តើដីកាកោះ អាចត្រូវបានបញ្ជូន នៅថ្ងៃសៅរ៍ អាទិត្យ ឬនៅថ្ងៃបុណ្យ ឬខុសម៉ោងរដ្ឋបាល ដូចជាពេលថ្ងៃត្រង់ ឬពេលយប់ បានដែរឬទេ? ........................................................................... ១៧

៣១.រាល់ការបញ្ជូនដីកា តុលាការបញ្ជូនទៅអ្នកតំណាងដោយអាណត្តិ (មេធាវី) ហើយក្រឡាបញ្ជីមិនបានបញ្ជូនទៅគូភាគីទេ (ដើមបណ្តឹង និង ចុងចម្លើយ)។ តើដីកានេះ មានអានុភាពតាមផ្លូវច្បាប់ដែរឬទេ ?.....១៨

៣២.អ្នកបញ្ជូនបានធ្វើការបញ្ជូនទៅដល់ជនដែលត្រូវទទួលការបញ្ជូន ហើយបានអោយជននោះចុះហត្ថលេខាលើលិខិតដែលត្រូវបញ្ជូន និងរបាយការណ៍នៃការបញ្ជូន។ តើការអនុវត្តបែបនេះ មានការខុសឆ្គងនឹងនីតិវិធីរដ្ឋប្បវេណីដែរឬទេ? ........................................................................................................១៨

៣៣.តើការបញ្ជូនដោយការប្រគល់ ចាំបាច់ត្រូវបិទផ្និតដោយស្រោមសំបុត្រដែរឬទេ? ការបញ្ជូនដោយគ្មានស្រោមសំបុត្រ ដោយអ្នកទទួលជំនួស ឬដោយទុកចោល តើប៉ះពាល់ដល់សិទ្ធិបុគ្គលភាពឯកជនរបស់ជនដែលត្រូវទទួលការបញ្ជូនដែរឬទេ? ...................................................................................១៨

៣៤.នៅក្នុងករណីដែលដីកាសម្រេច ត្រូវបានបញ្ជូនទៅចុងចម្លើយ ប៉ុន្តែ ចុងចម្លើយជេប្រមាថ មើលងាយ និងប្រលែងឆ្កែឲ្យខាំ។ អ្នកបញ្ជូនដីកាសម្រេច បានសរសេរហេតុការណ៍នេះនៅក្នុងរបាយការណ៍ ដែលត្រូវបញ្ជូនមកតុលាការវិញ។ តើការបញ្ជូននៅក្នុងករណីនេះ មានអានុភាពដែរឬទេ ?.......................១៩

៣៥.ដីកាកោះ ត្រូវបានបញ្ជូនឲ្យទៅលោក A។ នៅពេលអាជ្ញាសាលាទៅដល់ផ្ទះ ឬទីសំណាក់របស់លោក A គឺមិនបានជួបលោក A ទេ ប៉ុន្តែបានជួបកញ្ញា B ដែលជាអ្នកបម្រើ។ កញ្ញា B បដិសេធមិនហ៊ានទទួលទេ ដោយសំអាងហេតុថា លោក A បានហាមដាច់ខាត មិនឲ្យទទួលរាល់ឯកសារទាំងអស់ តើដីកាសម្រេចនោះ អាចទុកចោលបានដែរឬទេ? ..........................................................................................១៩

៣៦.ប្រសិនបើអ្នកបញ្ជូនដីកាសម្រេច ឬដីកាកោះ បានយកឯកសារទៅដល់ទីកន្លែង ប៉ុន្តែមិនបានជួបអ្នកណាម្នាក់សោះ ឬផ្ទះនោះបិទទ្វារចោល ឬជួលឲ្យអ្នកផ្សេងស្នាក់នៅ ហើយមិនអាចទំនាក់ទំនងបានជាមួយម្ចាស់ផ្ទះទេ។ តើអ្នកបញ្ជូនអាចទុកដីកានោះចោលបានដែរឬទេ ? .................................................១៩

៣៧.ក្រឡាបញ្ជី បានបញ្ជូនដីកាដល់ផ្ទះគូភាគីហើយ ប៉ុន្តែ អាសយដ្ឋានត្រូវបានផ្លាស់ប្តូរ។ តើក្រឡាបញ្ជីត្រូវធ្វើយ៉ាងដូចម្តេចបន្ទាប់មកទៀត?.........................................................................................២០

៣៨.ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ តើការបង្គាប់ឲ្យផ្សាយជាសាធារណៈ អាចធ្វើឡើងដោយផ្ទាល់មាត់ ឬត្រូវធ្វើជាលាយលក្ខណ៍អក្សរ ? .........................................................................២០

៣៩.តើប្រកាសស្តីពីការជូនដំណឹងតាមការផ្សាយជាសាធារណៈ ក្រៅពីដីកាកោះមានទម្រង់ដូចម្តេច? តើត្រូវចុះហត្ថលេខាដោយអ្នកណា?......................................................................................................២១

៤០.តាមរយៈការផ្សាយជាសាធារណៈ តើត្រូវចុះកាសែត ឬ យ៉ាងណា?.........................................២១

៤១.សូមពិព័ណនាអំពីនីតិវិធីទាំងមូលនៃការបញ្ជូនទៅបរទេស។ តើត្រូវបញ្ជូនតាមរយៈក្រសួងយុត្តិធម៌ បានដែរឬទេ ? តើតុលាការកម្ពុជាត្រូវបកប្រែឯកសារដែលត្រូវបញ្ជូនជាភាសាបរទេស ឬ ទេ ?............២១

៤២.សូមពន្យល់អត្ថន័យនៃមាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច ឃ។..........................................២៣

៤៣.ប្រសិនបើចុងចម្លើយរស់នៅបរទេស តើតុលាការគប្បីកំណត់រយៈពេលប៉ុន្មាន ដើម្បីឲ្យចុងចម្លើយអាចចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ? ........ ២៣

៤៤.ប្រពន្ធជាជនជាតិខ្មែរ បានរៀបអាពាហ៍ពិពាហ៍ជាមួយប្ដីជាជនជាតិបារាំង ហើយប្ដីបានត្រឡប់ទៅប្រទេសបារាំងវិញ ដោយគ្មានទាក់ទង និងផ្ដល់ដំណឹងមកប្រពន្ធសោះ។ ប្រពន្ធបានដាក់ពាក្យបណ្ដឹងទៅតុលាការសុំលែងលះ តែប្រពន្ធមិនស្គាល់ពីអាសយដ្ឋានរបស់ប្ដីទេ។ តើតុលាការ ត្រូវធ្វើការប្រកាសស្ដីពីការបាត់ខ្លួន ឬ ធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ? ........ ២៤

៤៥.តើសាលាឧទ្ធរណ៍អាចសម្រេចអំពីមោឃភាពបានដែរឬទេ នៅពេលដែលក្រឡាបញ្ជីចារស្លាពរលើសាលក្រមខុសនីតិវិធី ឬមានកំហុស? ........ ២៤

៤៦.តើតុលាការកំណត់ចំណុចវិវាទនៅពេលណា? ........ ២៥

៤៧.តើស្មុំកូនអាចសុំកូនបានចំនួនប៉ុន្មាន បើច្បាប់មិនបានចែងកំណត់ផងនោះ? ........ ២៥

៤៨.ជាធម្មតា នៅពេលប្រជាពលរដ្ឋចង់បង្កើតស្មុំកូន ពួកគាត់តែងតែទៅសាលាឃុំ ប៉ុន្តែមិនទៅតុលាការ។ បន្ទាប់មក ពួកគាត់បានធ្វើកិច្ចសន្យាទាក់ទងនឹងស្មុំកូននៅសាលាឃុំ។ តើស្មុំកូននេះអាចត្រូវបានទទួលស្គាល់ដោយច្បាប់ ? ........ ២៥

៤៩.សូមពិព៌ណនាអំពីនីតិវិធីក្នុងការផ្លាស់ត្រកូល ក្នុងករណីស្មុំកូន ឬ កាត់កាល់ស្មុំកូនធម្មតា ។ ........ ២៥

៥០.តួនាទីរបស់តំណាងអយ្យការ នៅក្នុងករណីដែលឪពុកបង្កើតបានប្រព្រឹត្តិអំពើអនាចារលើកូនស្រីបង្កើតរបស់ខ្លួន។ ........ ២៦

៥១.តើបងប្អូនបង្កើតអាចស្មុំកូនបានដែរឬទេ? ........ ២៦

៥២.ឪពុកម្ដាយបង្កើត ចង់បង្កើតស្មុំកូនពេញលេញជាមួយនឹងឪពុកម្ដាយចិញ្ចឹម។ ទាំងឪពុកម្ដាយចិញ្ចឹម និងឪពុកម្ដាយបង្កើតគឺក្រីក្រ។ តើពួកគាត់អាចបង្កើតស្មុំកូនពេញលេញបានដែរឬទេ? ........ ២៦

៥៣.តើបុគ្គលអាយុ ២០ ឆ្នាំ អាចធ្វើជាកូនសុំពេញលេញបានដែរឬទេ? ........ ២៦

៥៤.ឪពុកម្ដាយចិញ្ចឹម បានយកកូនឈ្មោះ ABC មកចិញ្ចឹមតាំងពីអាយុ ៥ ឆ្នាំ មកម្លេះ។ ពួកគាត់ បានចិញ្ចឹមកូននោះរហូតដល់ធំពេញវ័យ រៀនចប់បរិញ្ញាបត្រជាន់ខ្ពស់។ តើឪពុកម្ដាយចិញ្ចឹម អាចដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញ ឬ ស្មុំកូនធម្មតាបានដែរ ឬទេ ? ........ ២៧

៥៥.តើព្រះសង្ឃ ឬ ដូនជីអាចបង្កើតស្មុំកូនបានដែរឬទេ? ........ ២៨

៥៦.តើសហព័ន្ធអាចទៅសុំកូនពេញលេញពីមណ្ឌលកុមារកំព្រាបានដែរឬទេ? ........ ២៨

៥៧.តើពោះម៉ាយអាចស្មុំកូនបានដែរឬទេ? ........ ២៨

៥៨.ឪពុកម្តាយចិញ្ចឹម ចង់បង្កើតស្មុំកូនពេញលេញជាមួយកូនសុំ ដែលរស់នៅជាមួយនឹងម្តាយ ហើយដែលមិនដឹងថាឪពុករស់នៅទីណាទេ។ តើពួកគាត់អាចបង្កើតស្មុំកូនពេញលេញដែរឬទេ? នៅក្នុងករណីដែលស្មុំកូនពេញលេញ ត្រូវបង្កើតហើយ បន្ទាប់មកឪពុកក៏មានវត្តមាន តើឪពុកអាចរំលាយស្មុំកូនពេញលេញដែរឬទេ?........ ២៩

៥៩.សូមពន្យល់នីតិវិធីទាំងមូលនៃមាត្រា ១០១៣ ។........ ២៩

➢ សំណួរពាក់ព័ន្ធ៖

១. តើតុលាការត្រូវចេញដីកាសម្រេចចាប់ផ្តើមអំឡុងពេលចិញ្ចឹមសាកល្បងដែរឬទេ?

២. តើឪពុកម្តាយបង្កើត គប្បីប្រគល់កូនឲ្យទៅឪពុកម្តាយចិញ្ចឹមនៅពេលណា?

៣. តើអំឡុងពេលចិញ្ចឹមសាកល្បង ត្រូវចាប់ផ្តើមនៅពេលណា?

៤. តើនរណាគឺជាអ្នកទទួលខុសត្រូវក្នុងអំឡុងពេលចិញ្ចឹមសាកល្បង?

៦០.នៅពេលកំណត់អំឡុងពេលចិញ្ចឹមសាកល្បង តើតុលាការត្រូវចេញសេចក្តីសម្រេចអ្វី?........ ៣១

៦១.ក. បើឪពុកម្តាយបង្កើតមិនព្រមផ្តាច់ទំនាក់ទំនងជាមួយកូនសុំ។ តើឪពុកម្តាយចិញ្ចឹមត្រូវធ្វើដូចម្តេច?

ខ. ប្តី H និងប្រពន្ធ W បានលែងលះគ្នានឹងគ្នា ហើយ W គឺជាអ្នកមានអំណាចមេបាលើកូនS។ ក្រោយមក W បានរៀបការជាមួយ X ហើយ X ក៏យល់ព្រមបង្កើតស្មុំកូនពេញលេញជាមួយ S។ ប៉ុន្តែ H មិនព្រម។ តើ H អាចដាក់ពាក្យសុំដកអំណាចមេបាបានដែរទេ?

គ. ប្តី H និងប្រពន្ធ W បានលែងលះគ្នានឹងគ្នា ហើយ W គឺជាអ្នកមានអំណាចមេបាលើកូនS។ ក្រោយមក W បានរៀបការជាមួយ X ហើយ X ក៏យល់ព្រមបង្កើតស្មុំកូនពេញលេញជាមួយ S។ X ចង់ប្តូរត្រកូលរបស់ S ឲ្យប្រើត្រកូលដូចខ្លួន ប៉ុន្តែ H បដិសេធនឹងការប្តូរត្រកូលនេះ។ តើប្តីអាចបដិសេធបានដែរឬទេ?........ ៣១

៦២.តើតុលាការអាចសម្រេចឲ្យបង្កើតស្មុំកូន រវាងបុគ្គលដែលក្លាយជាឪពុកម្តាយចិញ្ចឹម និង កូនសុំច្រើននាក់នៅក្នុងរឿងក្តីតែមួយបានដែរឬទេ?........ ៣២

៦៣.នៅពេលតុលាការសម្រេចបង្កើតស្មុំកូនពេញលេញ តើតុលាការត្រូវពិចារណាអំពីឆន្ទៈរបស់កូនសុំដែរឬទេ?........ ៣២

៦៤.តើតុលាការអាចចេញដីកាសម្រេចបង្កើតស្មុំកូនពេញលេញ នៅក្នុងរយៈពេលចិញ្ចឹមសាកល្បង ៦ ខែ បានដែរឬទេ ?........ ៣៣

៦៥.តុលាការកំពុងចាត់ការនីតិវិធីស្មុំកូនពេញលេញ ហើយបន្ទាប់មកសហព័ទ្ធម្ខាង (ឪពុក ឬម្តាយចិញ្ចឹម) ស្លាប់។ តើអាចបង្កើតស្មុំកូនបានដែរឬទេ? តើនីតិវិធីត្រូវធ្វើដូចម្តេច?........ ៣៣

៦៦.ក្នុងករណីនៃស្មុំកូនពេញលេញ តើឪពុកម្តាយបង្កើតអាចកាត់កាលកូនស្មុំបានដែរឬទេ? ហេតុអ្វីបានជាច្បាប់មិនអនុញ្ញាតឲ្យមានការកាត់កាល់រវាងឪពុកម្តាយ និងកូនបង្កើត?........ ៣៤

៦៧.នៅក្នុងករណីដែលសុំកូនពេញលេញត្រូវបានបង្កើតឡើង នៅពេលដែលឪពុកម្តាយនៅក្រ ប៉ុន្តែក្រោយមក ពួកគាត់មានសំណាងត្រូវឆ្នោត ហើយមានលុយច្រើន តើកូននោះអាចត្រឡប់មកវិញដែរឬទេ ?.....៣៤

៦៨.នៅក្រោយពេលចេញដីកាសម្រេចបង្កើតសុំកូនរួចហើយ កូនសុំមិនចង់រស់នៅជាមួយឪពុកម្តាយចិញ្ចឹម តើកូនសុំអាចត្រឡប់ទៅរស់នៅជាមួយឪពុកម្តាយបង្កើតវិញបានដែរឬទេ?................................៣៥

៦៩.ក្រោយពីការបង្កើតសុំកូនពេញលេញ កូនសុំបានវាយធ្វើបាបឪពុកម្តាយចិញ្ចឹម។ តើឪពុកម្តាយចិញ្ចឹមអាចកាត់កាល់កូនសុំពេញលេញបានដែរឬទេ? តើពួកគាត់ត្រូវធ្វើដូចម្តេច?...............................៣៦

៧០.នៅពេលបណ្តឹងសុំកាត់កាល់កំពុងចាត់ការ ភាគីព្រមព្រៀងគ្នាកាត់កាល់។ តើតុលាការត្រូវធ្វើដូចម្តេច?..................................................................................................៣៦

៧១.នៅពេលតុលាការចេញសាលក្រមកាត់កាល់ តើសាលក្រមនេះ មានអានុភាពដោយស្វ័យប្រវត្តិ ឬចាំបាច់នីតិវិធីដទៃផ្សេងទៀត?...........................................................................................................៣៧

៧២.ក្រោយពីបង្កើតសុំកូនពេញលេញ ឪពុកម្តាយចិញ្ចឹម បានឲ្យកូនសុំទៅអ្នកផ្សេងទៀតដើម្បីបង្កើតសុំកូនពេញលេញ។ បន្ទាប់មក ឪពុកម្តាយចិញ្ចឹមថ្មី កាត់កាល់សុំកូនពេញលេញ។ តើកូនសុំត្រូវទៅរស់ជានៅជាមួយឪពុកម្តាយបង្កើត ឬឪពុកម្តាយចិញ្ចឹមមុន? ..................................................................៣៧

៧៣.តើឪពុកម្តាយចិញ្ចឹមដែលបានកាត់កាល់កូនសុំធម្មតា ឬ កូនសុំពេញលេញ ដោយសារតែកូនសុំប្រព្រឹត្តបទល្មើស ត្រូវទទួលខុសត្រូវសងការខូចខាតទៅឱ្យជនរងគ្រោះក្នុងនាមជាអ្នកមានអំណាចមេបាដែរឬទេ ?........................................................................................................................៣៨

៧៤.នៅក្រោយពេលកាត់កាល់ តើឪពុកម្តាយចិញ្ចឹមអាចទាមទារសោហ៊ុយដែលខ្លួនចំណាយសម្រាប់ចិញ្ចឹមកូនសុំបានដែរឬទេ?.................................................................................................................៣៩

៧៥.តើការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន ខុសគ្នាដូចម្តេច? ឧទាហរណ៍ចំពោះទ្រព្យរួម តើត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះ អាសន្ន ឬ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ?.........................................................................៣៩

៧៦.តើពាក្យ "សិទ្ធិលើបំណុល" តាមមាត្រា ៤០២ ដល់មាត្រា ៤១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ខុសគ្នានឹងពាក្យ "សិទ្ធិលើបំណុល" តាមមាត្រា ៥៣១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូចម្តេច?............៤០

៧៧. ក មានដីមួយកន្លែង ហើយគាត់សាងសង់អាគារលើដីនោះ ដោយគ្មានការអនុញ្ញាតពីមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី។ ដូច្នេះ មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី បានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ហាមឃាត់នូវការសាងសង់ ដោយសម្អាងថា អាគារដែលកំពុងសាងសង់មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងមិនមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ តើតុលាការអាចចេញដីកាសម្រេចរក្សាការពារបានដែរ ឬទេ?...............................................៤១

៧៨. ក បានជួលផ្ទះឱ្យ ខ ។ ក មិនមានការងារអ្វីធ្វើទេហើយជីវភាពរបស់កគឺផ្អែកលើប្រាក់ឈ្នួលផ្ទះនេះប៉ុណ្ណោះ។ លុះក្រោយមកខ មិនបានបង់ថ្លៃឈ្នួលផ្ទះឱ្យ ក ទេ ទោះបីជា ក បានដាស់តឿន ខ ឱ្យបង់ប្រាក់ឈ្នួលក៏ដោយក៏ ខ នៅតែមិនបង់ប្រាក់ឈ្នួលដែរ។ ដូច្នេះ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅ ក មានគម្រោងជួលផ្ទះនេះឲ្យទៅអ្នកផ្សេង។ តើ ក អាចទាមទារឱ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដើម្បីឱ្យ ខ ចាកចេញពីផ្ទះរបស់ខ្លួនបានដែរ ឬទេ?.......................................... ៤២

៧៩.អង្គហេតុនៃរឿងក្ដីអំពើហឹង្សាក្នុងគ្រួសារ៖ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ លោកស្រី ក និងលោក ខ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ អ្នកទាំងពីរមានកូន ១នាក់ ឈ្មោះ គ។ ចាប់តាំងពីឆ្នាំ២០១៤មក លោក ខ តែងតែវាយធ្វើបាបលោកស្រី ក និងកូនឈ្មោះ គ ជារៀងរាល់ថ្ងៃ បណ្ដាលឲ្យមានស្នាមជាំ និងរបួសក្បាល។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ លោកស្រី ក បានដាក់ពាក្យបណ្ដឹងលែងលះលោក ខ និងសុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ គ។

តើលោកស្រី ក អាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារស្នើសុំឲ្យលោក ខ ចាកចេញពីផ្ទះ និងស្នើសុំគ្រប់គ្រងកូនឈ្មោះ គ បណ្ដោះអាសន្នបានដែរ ឬទេ?.......................................................... ៤៣

៨០.ម្ចាស់បំណុលដាក់ពាក្យសុំឱ្យរឹបអូសជាបណ្ដោះអាសន្ន ចំពោះចលនវត្ថុរបស់កូនបំណុល ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ចលនវត្ថុច្បាស់លាស់។

តើតុលាការត្រូវចាត់ទុកករណីនេះយ៉ាងដូចម្ដេច?............................................................. ៤៤

៨១.នៅក្នុងមាត្រា ៥៤១ មិនមានតម្រូវឲ្យម្ចាស់បំណុលដាក់ឯកសារបញ្ជាក់នូវកម្មសិទ្ធិរបស់កូនបំណុលលើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នទេ។ ដូច្នេះ ប្រសិនបើម្ចាស់បំណុល មិនបានដាក់នូវឯកសារបញ្ជាក់កម្មសិទ្ធិរបស់កូនបំណុល តើតុលាការត្រូវធ្វើដូចម្ដេច? .......................................... ៤៥

៨២.នៅក្នុងដីការឹបអូសជាបណ្ដោះអាសន្ន ដើម្បីធ្វើសេចក្ដីបញ្ជាក់ថា កូនបំណុលមាន សិទ្ធិលើដីដែលមិនបានចុះបញ្ជី តើត្រូវដាក់ឯកសារអ្វីខ្លះ?.................................................................................... ៤៥

នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន ដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូងថា ម្ចាស់ បំណុលមានសិទ្ធិលើដីដែលមិនបានចុះបញ្ជី តើត្រូវដាក់ឯកសារអ្វីខ្លះ?........................................................................ ៤៦

៨៣.ចំពោះដីមិនទាន់ចុះបញ្ជីតើអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងបានដែរឬទេ? តើក្រលាបញ្ជីត្រូវធ្វើការផ្អាកផ្ទាក់ដូចម្ដេច?..................................................... ៤៦

៨៤.តើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្នត្រូវកំណត់ចំនួនទឹកប្រាក់ដូចម្ដេច?........................ ៤៧

៨៥.តើឧបករណ៍ដែលអាចជូញដូរបានមានអ្វីខ្លះ?.............................................................................. ៤៨

៨៦.តើតុលាការគប្បីបញ្ជូនតែដីកាសម្រេច ឬជាមួយនឹងឯកសារផ្សេងទៀត ដូចជា ឯកសារថតចម្លងនៃពាក្យសុំ និងសេចក្ដីបញ្ជាក់ដំបូង?.................................................................................................... ៤៨

៨៧.តើកូនបំណុល អាចដាក់ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចរក្សាការពារបានគ្រប់ពេលឬទេ?......... ៤៩

៨៨.ម្ចាស់បំណុលដាក់ពាក្យសុំឱ្យតុលាការចេញ ដីកាសម្រេចរក្សាការពារលើដីស្រែរបស់កូនបំណុល។ អំឡុងពេល ២ សប្ដាហ៍បានកន្លងផុតបន្ទាប់ពីចេញដីកាសម្រេច ម្ចាស់បំណុលមិនបានដាក់ពាក្យសុំអនុវត្ត នោះទេ។ បន្ទាប់មក កូនបំណុលដាក់ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារនោះវិញ។ តើតុលាការ អាចលុបចោលដីកាសម្រេចតាមពាក្យសុំរបស់កូនបំណុលដែរ ឬទេ?........................................ ៥០

៨៩.ដីកាសម្រេចរក្សាការពារមិនត្រូវបានគេយកទៅអនុវត្តក្នុងរយៈពេល ២សប្ដាហ៍ ដែលនាំឱ្យអស់សុពល ភាពអនុវត្ត។ តើម្ចាស់បំណុលអាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារលើកម្មវត្ថុដដែលនេះ ម្ដងទៀត បានដែរ ឬទេ?................................................................................................ ៥០

៩០.នៅក្នុងករណីដែលម្ចាស់បំណុល មិនអាចដាក់នូវឯកសារដែលមានចែងនៅក្នុងមាត្រា ៥៥៧ កថាខណ្ឌ ទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងអំឡុងពេលដែលបានកំណត់ តុលាការត្រូវលុបចោលដីកាសម្រេច ចាត់ចែងរក្សាការពារ។
តើម្ចាស់បំណុលអាចដឹងអំពីការណ៍ ដែលតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ដោយរបៀបណា?............................................................................................ ៥១

៩១.ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៥៥៧ "បណ្ដឹងអង្គសេចក្ដី" តើអាចអនុវត្តរឿងក្ដី ព្រហ្មទណ្ឌបាន ដែរ ឬទេ?.......................................................................................................... ៥១

## ❖ គំរូពាក្យសុំដីកាសម្រេចលែងលះតាមការព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំដីកាសម្រេចលែងលះតាមការព្រមព្រៀង**

**-សហអ្នកដាក់ពាក្យសុំ:**

*១-ឈ្មោះ ..................ភេទ........ កើតថ្ងៃទី...... ខែ...........ឆ្នាំ............ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ............ ផ្លូវលេខ............ភូមិ..........សង្កាត់............. ខណ្ឌ................ រាជធានីភ្នំពេញ ។*

*-តំណាងដោយអាណ្ណាតិឈ្មោះ ..................ភេទ........ កើតថ្ងៃទី...... ខែ...........ឆ្នាំ............ ទីលំនៅបច្ចុប្បន្នផ្ទះលេខ............ ផ្លូវលេខ............ភូមិ..........សង្កាត់............. ខណ្ឌ................ រាជធានីភ្នំពេញ ។*

*២-ឈ្មោះ ..................ភេទ........កើតថ្ងៃទី........ ខែ..........ឆ្នាំ.............ទីលំនៅបច្ចុប្បន្ន ភូមិ ............. សង្កាត់........... ខណ្ឌ.................. រាជធានីភ្នំពេញ ។*

*-តំណាងដោយអាណ្ណាតិឈ្មោះ ..................ភេទ........ កើតថ្ងៃទី...... ខែ...........ឆ្នាំ............ ទីលំនៅបច្ចុប្បន្នផ្ទះលេខ............ ផ្លូវលេខ............ភូមិ..........សង្កាត់............. ខណ្ឌ................ រាជធានីភ្នំពេញ ។*

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*សូមមេត្តាជ្រាប ។*

**ខ្លឹមសារនៃដីកាសម្រេចដែលទាមទារ ៖**

*១-អនុញ្ញាតឲ្យឈ្មោះ........... និងឈ្មោះ ........... លែងលះពីគ្នា តាមការព្រមព្រៀង ។*

*២-អោយយើងខ្ញុំ ជាអ្នកទទួលបន្ទុកប្រាក់ប្រាប់ក្តី ។*

**អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

*សេចក្តីដូចមានចែងក្នុងការទាមទារខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន* **ឯកឧត្តមប្រធាន** *មេត្តាជ្រាបថា: ខ្ញុំបាទ និងប្រពន្ធបានរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ.............. និងបានចុះសំបុត្រអាពាហ៍ ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ ដោយសារការរស់នៅជាមួយគ្នាកន្លងមកមិនចុះសម្រុងនឹងគ្នា និងឧស្សាហ៍មានការខ្វែងគំនិតគ្នាជាញឹកញាប់ ជាហេតុធ្វើឲ្យពួកយើងឯកភាពគ្នាលែងលះតាមការព្រមព្រៀង។ ការរស់នៅជាមួយគ្នាកន្លងមក ពុំបង្កើតឲ្យមានទ្រព្យសម្បត្តិរួម ឬបំណុលរួមទេ ហើយក៏ពុំមានកូនដែរ។*

*អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម* **ឯកឧត្តមប្រធាន** *មេត្តាចេញដីកាសម្រេចតាមកម្មវត្ថុខាងលើនេះ ដោយសេចក្តីអនុគ្រោះ។*

*សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងពីរ។*

*រាជធានីភ្នំពេញ, ថ្ងៃទី.......ខែ.............ឆ្នាំ២០១៦*

**ស្នាមមេដៃស្តាំអ្នកដាក់ពាក្យសុំ**

**ស្នាមមេដៃស្តាំ ស្នាមមេដៃស្តាំ**

......................

....................

**ឯកសារយោង** :

*-សំបុត្រអាពាហ៍ពិពាហ៍លេខ........ចុះថ្ងៃទី....... ខែ.......... ឆ្នាំ............. ។*

*-កិច្ចព្រមព្រៀងលែងលះចុះថ្ងៃទី........ខែ...............ឆ្នាំ..............។*

## ❖ កម្រងសំណួរ និង ចម្លើយ

**សំណួរ ១**

**តើអ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិខុសគ្នាដូចម្ដេច?**

**ចម្លើយ**

**អ្នកតំណាងដែលច្បាប់បានកំណត់** មានន័យថាការជ្រើសរើសអ្នកតំណាង គឺមិនផ្អែកទៅតាមឆន្ទៈរបស់ម្ចាស់សិទ្ធិទេ ហើយម្ចាស់សិទ្ធិដែលជាជនដែលត្រូវបានកម្រិតសមត្ថភាពរួមមាន ៖ ១. អនីតិជន (មាត្រា ១៧ អត្ថន័យនៃអនីតិជន) ២. ជននៅក្រោមអាណាព្យាបាលទូទៅ (មាត្រា ២៤ ការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) និង ៣. ជននៅក្រោមហិតូបត្ថម្ភ (មាត្រា ២៨ ការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ) ។
ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់រួមមាន ១.អ្នកមានសិទ្ធិអំណាចមេបា (ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន), ២.អ្នកអាណាព្យាបាលទូទៅ។ ៣. ហិតូបត្ថម្ភកៈ គ្មានសិទ្ធិតំណាងទេ ដូច្នេះ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ។

**អ្នកតំណាងដោយអាណត្តិ** មានន័យថាការជ្រើសរើសអ្នកតំណាងគឺផ្អែកទៅតាមឆន្ទៈរបស់ម្ចាស់សិទ្ធិ។ អ្នកតំណាងដោយអាណត្តិនៅក្នុងបណ្ដឹង គឺសំដៅទៅលើអ្នកដែលទទួលបាននូវសិទ្ធិអំណាចក្នុងការអនុវត្តសកម្មភាពបណ្ដឹង ដោយបានធ្វើកិច្ចសន្យាអាណត្តិជាមួយម្ចាស់សិទ្ធិ ដើម្បីធ្វើសកម្មភាពក្នុងនីតិវិធីបណ្ដឹងចំពោះមុខតុលាការជំនួសម្ចាស់សិទ្ធិ ។ លក្ខណសម្បត្តិរបស់អ្នកតំណាងដោយអាណត្តិនៅក្នុងបណ្ដឹងគឺបានកំណត់យ៉ាងច្បាស់ឆ្លើយតបទៅនឹងប្រភេទនៃនីតិវិធីនីមួយៗ ដែលចាំបាច់មានមេធាវី ឬ មិនចាំបាច់មានមេធាវីជាអាទិ៍ (ជនដែលទទួលស្គាល់ដោយតុលាការជាអាទិ៍) ។

ឧទាហរណ៍៖ អ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី (មាត្រា ៥៣ វាក្យខណ្ឌនៃកថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

ឧទាហរណ៍៖ អ្នកតំណាងដោយអាណត្តិដែលអាចមិនមែនជាមេធាវីក៏បាន (មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច ក ខ គ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា ១៩ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ជាដើម ។

**សំណួរ ២**

**ហេតុអ្វីបានជាច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងអនុញ្ញាតឲ្យជននៅក្រោមអាណាព្យាបាលទូទៅធ្វើសកម្មភាពបណ្ដឹង (មាត្រា ១៧ កថាខណ្ឌទី ២)?**

**ចម្លើយ**

ការចែងបែបនេះ គឺដើម្បីផលប្រយោជន៍ និង ដើម្បីការពារបុគ្គលទាំងនោះ។ ជាពិសេសជាមួយនឹងទំនាក់ទំនងក្នុងគ្រួសារ ទោះបីជាបុគ្គលនោះគឺជាជននៅក្រោមអាណាព្យាបាលទូទៅ គាត់ក៏អាចធ្វើសកម្មភាពបណ្ដឹងបានដែរ ដរាបណាគាត់មានសមត្ថភាពខាងឆន្ទៈ ព្រោះសាលក្រមនេះ មានអានុភាពយ៉ាងខ្លាំងទៅលើជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។

**ឧទាហរណ៍**: ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន, ការកំណត់អាណាព្យាបាលទូទៅ, ការបញ្ឈប់អាណាព្យាបាលទូទៅ.....។ ល។

**សំណួរ ៣**

**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង អនុវត្តតែករណីដែលភាគីព្រមព្រៀងគ្នា និង គ្មានវិវាទ។ ហេតុអ្វីបានជាច្បាប់នេះ ត្រូវយកមកអនុវត្តនៅក្នុងការបែងចែកមត៌កដែលកំណត់ក្នុងផ្នែកទី ៥ ចំណុច ១៧ ដែលជាករណីសន្តតិជនមានវិវាទ?**

**ចម្លើយ**

មូលហេតុចម្បង គឺថាច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង អនុវត្ត មិនត្រឹមតែក្នុងរឿងក្តីដែលភាគីធ្វើការព្រមព្រៀងគ្នា ឬរឿងក្តីដែលគ្មានវិវាទនោះទេ ប៉ុន្តែថែមទាំងរឿងក្តីដែលមានវិវាទផងដែរ។

**សំណួរ ៤**

**ភាគីមានសាលក្រមស្ថាពរដែលមានកម្មវត្ថុទាមទារឲ្យប្រគល់អចលនវត្ថុ ហើយនេះ គឺជាការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកលើមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី នៅមុនពេលអនុវត្តច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ភាគីមិនបានអនុវត្តសាលក្រមនេះភ្លាមៗទេ ក្រោយពីរយៈពេលយូរបានកន្លងផុតទៅ ភាគីក៏បានព្រមព្រៀងគ្នាអនុវត្តសាលក្រមនេះ។ ដោយបារម្ភអំពីសោហ៊ុយអនុវត្ត និង គ្មានបំណងក្នុងការអនុវត្តសាលក្រម ពួកគាត់ក៏បានព្រមព្រៀងគ្នាដាក់ពាក្យសុំថ្មី នៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ទៅតុលាការ។ តើតុលាការអាចអនុវត្តច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង តារាងឧបសម្ព័ន្ធ ផ្នែក ៤ ចំណុច ៦ បានដែរឬទេ ?**

**ចម្លើយ**

ផ្អែកតាមករណីខាងលើ ភាគីទាំងពីរបានឆ្លងកាត់នីតិវិធីរឿងក្តីធម្មតារួចហើយ ការទាមទារ គឺការបែងចែកទ្រព្យសម្បត្តិ នៅមុនពេលអនុវត្តច្បាប់ស្តីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយគូភាគីមានសាលក្រមស្ថាពរទៀតផង។

ដូច្នេះ យោងតាមគោលការណ៍អាជ្ញាអស់ជំនុំនៃរឿងក្តី តុលាការមិនអាចលើកយកសំណុំរឿងដែលមានភាគីដដែលមកជំនុំជម្រះម្តងទៀតបានទេ ទោះបីវាជាច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងក៏ដោយ។

នៅក្នុងករណីនេះ ភាគីអាចស្នើសុំភាគីម្ខាងទៀតឲ្យប្រគល់ផ្ទះដោយស្ម័គ្រចិត្ត ព្រោះ ភាគីម្ខាងទៀតបានព្រមព្រៀងប្រគល់ហើយ។ ប្រសិនបើភាគីម្ខាងទៀតបដិសេធ ភាគីនេះ អាចដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រមនេះបាន។

**សំណួរ ៥**

**នៅក្នុងករណីដែលប្ដីនិងប្រពន្ធរស់នៅជាអនីតិសង្វាស បានធ្វើការលែងលះគ្នានៅសាលាសង្កាត់ ហើយបានឯកភាពគ្នាប្រគល់កូនចំនួនពីរនាក់ឲ្យទៅប្រពន្ធជាអ្នកគ្រប់គ្រង ហើយប្ដីក៏នៅតែអាចប្រាស្រ័យទាក់ជាមួយកូនដូចធម្មតា។ ប៉ុន្តែ ក្រោយមកប្រពន្ធបានដឹងថា ប្ដីត្រៀមនឹងរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ប្រពន្ធក៏ខឹង ហើយមិនអនុញ្ញាតអោយប្ដីមកលេងកូនដូចសព្វដងទៀត។ តើប្ដីត្រូវធ្វើដូចម្ដេច? តើប្ដីអាចប្ដឹងដកអំណាចមេបាពីប្រពន្ធបានដែរឬទេ?**

**ចម្លើយ**

យោងតាមអង្គហេតុខាងលើ ប្ដីប្រពន្ធទាំងពីរនាក់ បានព្រមព្រៀងលែងលះគ្នានៅសាលាសង្កាត់ និងបានព្រមព្រៀងគ្នាពីបញ្ហានៃសិទ្ធិអំណាចមេបាលើកូនរួចរាល់ហើយ ប៉ុន្តែដោយសារតែមានវិវាទកើតឡើងទើបប្រពន្ធមិនអនុញ្ញាតអោយប្ដី ជួបប្រាស្រ័យទាក់ទងជាមួយកូន។ ក្នុងករណីនេះ ឪពុកដែលជាអ្នកគ្មានអំណាចមេបា តាមផ្លូវច្បាប់ អាចមានវិធីពីរះ

១-សិទ្ធិសុំផ្លាស់ប្ដូរអំណាចមេបា

យោងតាមបញ្ញត្តិច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ផ្នែកទី៤ ចំណុច១២ តាមមាត្រា១០៣៩ នៃក្រមរដ្ឋប្បវេណី ទោះបីជាគូរភាគី មានការព្រមព្រៀងគ្នាពីអំណាចមេបាលើកូនរួចរាល់ហើយក៏ដោយ ក៏ច្បាប់នូវតែអនុញ្ញាតអោយភាគីមានសិទ្ធិក្នុងការសុំផ្លាស់ប្ដូរសិទ្ធិអំណាចអាណាព្យាបាលលើកូន បើសិនជាភាគីមានមូលហេតុត្រឹមត្រូវក្នុងការសុំផ្លាស់ប្ដូរអំណាចអាណាព្យាបាល។

២-សិទ្ធិសុំសេចក្ដីសម្រេចពីរបៀបចូលជួបប្រាស្រ័យទាក់ទងជាមួយកូន

ផ្ទុយទៅវិញ បើភាគីប្ដី មិនចង់សុំផ្លាស់ប្ដូរអំណាចមេបា យោងតាមបញ្ញត្តិច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ផ្នែកទី៤ ចំណុច១២ តាមមាត្រា១០៣៨ នៃក្រមរដ្ឋប្បវេណីទេនោះ ភាគីខាងប្ដី អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីអោយតុលាការចេញសេចក្ដីសម្រេចពីរបៀបចូលជួបប្រាស្រ័យទាក់ទងជាមួយកូន យោងតាមបញ្ញត្តិច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ផ្នែកទី៤ ចំណុច១៣ តាម មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណីបាន។

**សំណួរ ៦**

**ចំពោះការលែងលះដោយការព្រមព្រៀងដោយភ្ជាប់ជាមួយកិច្ចសន្យាព្រមព្រៀងគ្នាលែងលះ តើតុលាការគួរចេញដីកាសម្រេច ឬសាលក្រម?**

**ចម្លើយ**

នីតិវិធីនៃរឿងក្ដីមិនមែនបណ្ដឹងត្រូវចេញដោយដីកាសម្រេច (មាត្រា ៣ កថាខណ្ឌទី២ តារាងឧបសម្ព័ន្ធ ផ្នែកទី ៤ ចំណុចទី ៥ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

**សំណួរ ៧**

**នៅពេលដែលដីកាសម្រេចលើរឿងក្ដីមិនមែនជាបណ្ដឹង បានចូលជាស្ថាពរ តើក្រឡាបញ្ជីត្រូវបញ្ជាក់អំពីការចូលជាស្ថាពរ ដូចសាលក្រមដែរឬទេ ?**

**ចម្លើយ**

ក្រឡាបញ្ជី ត្រូវបញ្ជាក់អំពីការចូលជាស្ថាពរ។ តាមមាត្រា ២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថាពេលសាលក្រមចូលជាស្ថាពរ ក្រឡាបញ្ជី ត្រូវបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ទើបភាគីអាចយកសាលក្រមនេះទៅអនុវត្តបាន។ រីឯដីកាសម្រេចលើរឿងក្តីមិនមែនជាបណ្តឹង ដែលជានីតិវិធីមួយផ្សេងពីនីតិវិធីរដ្ឋប្បវេណី ក៏ទាមទារអោយមានការបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេចដូចគ្នា។

ផ្អែកតាមមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចក៏ជាលិខិតអនុវត្តមួយប្រភេទផងដែរ ដូច្នេះដើម្បីអោយលិខិតអនុវត្តអាច អនុវត្តបានលុះត្រាតែ មានលិខិតបញ្ជាក់ស្ថាពរ និងភ្ជាប់ជាមួយរូបមន្តអនុវត្ត។

**សំណួរ ៨**

**ពីរសប្តាហ៍ក្រោយចេញដីកាសម្រេច គឺចំថ្ងៃអាទិត្យ ឬ ថ្ងៃបុណ្យ។ តើភាគី អាចប្តឹងជំទាស់នៅថ្ងៃចន្ទ ឬ ថ្ងៃបន្ទាប់បានដែរឬទេ?**

**ចម្លើយ**

យោងតាម **មាត្រា ៣៤ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង មាត្រា ២៤៣ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី** ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេលត្រូវជាថ្ងៃបុណ្យ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃធ្វើការបន្ទាប់ពីថ្ងៃឈប់នោះ។

**សំណួរ ៩**

**តុលាការចេញដីកាសម្រេច។ ២ ថ្ងៃក្រោយមក ភាគីព្រមព្រៀងគ្នាមិនប្តឹងជំទាស់។ តើភាគីអាចប្តឹងជំទាស់បានទេ ក្រោយរយៈពេល ២ សប្តាហ៍កន្លងផុត ?**

**ចម្លើយ**

ប្រសិនបើមិនទាន់ផុតអំឡុងពេលប្តឹងជំទាស់ ២ សប្តាហ៍ទេ នោះភាគីនៅតែអាចប្តឹងជំទាស់បានដដែលទោះបីជាភាគីបានឯកភាពគ្នាមិនប្តឹងក៏ដោយ។ ប៉ុន្តែនៅក្នុងករណីដែល តុលាការនៃបណ្តឹងជំទាស់រកឃើញថា ភាគីបានព្រមព្រៀងគ្នាអត់ប្តឹងជំទាស់ នោះតុលាការ ត្រូវលើកចោលបណ្តឹងជំទាស់ ព្រោះបណ្តឹងនេះខុសច្បាប់ (មាត្រា ៤២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា ៣០៤, មាត្រា ២៨៦,មាត្រា ២៦០ នៃក្រមរដ្ឋប្បវេណី និង សូមមើលសេចក្តីកំណត់ មាត្រា ២៦០ នៃក្រមរដ្ឋប្បវេណី)។

**សំណួរ ១០**

**បន្ទាប់ពីតុលាការចេញដីកាសម្រេចនៃនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ភាគីបានព្រមព្រៀងគ្នាមិនប្តឹងជំទាស់។ តើភាគីអាចសុំបញ្ជាក់ស្ថាពរបានដែរឬទេ?**

**ចម្លើយ**

យោងអង្គហេតុខាងលើ ផ្អែកតាម **មាត្រា ៣៧** នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង បានកំណត់ថា ដីកាសម្រេច មិនត្រូវចូលជាស្ថាពរនៅមុនផុតអំឡុងពេលប្តឹងជំទាស់។ ការចូលជាស្ថាពរនៃដីកាសម្រេច ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ និងដីកាសម្រេចនេះមិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ។

បើយើងពិនិត្យមើលមាត្រានេះឃើញថា ដីកាសម្រេច មិនត្រូវចូលជាស្ថាពរនៅមុនផុតអំឡុងពេលប្តឹងជំទាស់ឡើយ ប៉ុន្តែផ្អែកតាមបញ្ញត្តិមាត្រា **៤២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង** បានកំណត់ថា បញ្ញត្តិនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់។

យោងតាម មាត្រា **២៦០ និង មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី** បានកំណត់ថា ភាគីអាចព្រមព្រៀងគ្នាមិនប្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់ (សាលាឧទ្ធរណ៍ និងកំពូល)បាន ដូច្នេះផ្អែកតាមបញ្ញត្តិមាត្រាទាំងពីរនៃក្រមនីតិវិធីរដ្ឋប្បវេណី គឺភាគីអាចបញ្ជាក់ស្ថាពរបាន ទោះបីជាមិនទាន់ផុតអំឡុងពេលនៃបណ្តឹងជំទាស់ក៏ដោយ។

**សំណួរ ១១**

**សូមលើកជាឧទាហរណ៍ ចំពោះរឿងក្តីដែលអនុវត្តតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។**

**ចម្លើយ**

ឧទាហរណ៍ចំពោះប្រភេទនៃសំណុំរឿងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានចែងក្នុង មាត្រា ៣ នៃច្បាប់នេះ មានដូចខាងក្រោម (ទៅតាមលេខលំដាប់នៅក្នុងមាត្រា៣) ៖

**ក**. បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

**ឧ**. បុរស A និងនារី B មានបំណងក្នុងការរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នា ។ ប៉ុន្តែ ក្រោយមកបុរស A ក៏បានបាត់ខ្លួនដោយមូលហេតុណាមួយ ហើយនារី B មិនបានដឹងអំពីព័ត៌មាននេះទេ ។ បន្ទាប់មកទៀត ដោយមានការច្រឡំស្មានថាបុរស C ដែលជាបងប្អូនភ្លោះ ជាមួយនឹងបុរស A នារី B ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរស C ។ ដោយយោងលើមូលហេតុការភាន់ច្រឡំលើមនុស្ស នារី B អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ជាបុរស C បាន។ ។

**ខ**. បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាម) នៃក្រមរដ្ឋប្បវេណី ។

**ឧ**. បុរស A មានអាយុ២១ឆ្នាំ បានស្តីដណ្តឹងនារី B ដែលមានអាយុទើបតែ ១៤ឆ្នាំហើយដោយមានការឯកភាពគ្នាពីចាស់ទុំ អ្នកទាំងពីរបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា ។ ករណីនេះ ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការអាចដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ដោយលើកឡើងពីមូលហេតុអាពាហ៍ពិពាហ៍ផ្ទុយទៅនឹងអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍បាន ។

ឧ. បុរស A បានរៀបដែលកំពុងមានចំណងអាពាហ៍ពិពាហ៍ជាមួយនារី B បានរៀបអាពាហ៍ពិពាហ៍ និងទៅចុះសំបុត្រអាពាហ៍ពិពាហ៍ថ្មីមួយទៀតជាមួយនារី C ដែលរស់នៅខេត្តឆ្ងាយពីផ្ទះរបស់ខ្លួន ។ ករណីនេះនារី B ជាប្រពន្ធ អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យលុបអាពាហ៍ពិពាហ៍ក្រោយរវាងបុរស A ជាមួយនារី C បាន ។

**គ.** បណ្ដឹងទាមទារលែងលះគ្នា តាមបញ្ញត្តិមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

ឧ. ដោយយោងលើ មូលហេតុដែលនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បុរស A បានប្រព្រឹត្តនូវអំពើផិតក្បត់ហើយ មិនបានជួយទំនុកបម្រុងដល់គ្រួសារ ចាកចោលលំនៅដ្ឋានដោយគ្មានមូលហេតុត្រឹមត្រូវជាដើម នារី B អាចដាក់ពាក្យបណ្ដឹងលែងលះពីបុរស A បាន ។

**ឃ.** បណ្ដឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្ដឹងបដិសេធបិតុភាពពី ជនត្រូវបានសន្មតថាជាឪពុក) និងមាត្រា ៩៩១ (បណ្ដឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

ឧ. ក្នុងនាមជាឪពុកលោក A បានចុះសំបុត្រកំណើតឲ្យកូន B ។ ប្រសិនបើ B មិនមែនជាកូនបង្កើតរបស់ខ្លួនទេ នោះលោក A ត្រូវអះអាង អំពីទំនាក់ទំនង ខ្លួនជាមួយ B ថាមិនជាកូនបង្កើត នោះគាត់អាចដាក់ពាក្យបណ្ដឹងសុំបដិសេធបិតុភាពបាន ។ ដូចគ្នាដែរ B ដែលបានដឹងពីហេតុការណ៍នេះ ក៏អាចប្ដឹងសុំបដិសេធបិតុភាពរបស់ លោក A បានដែរ ។

**ង.** បណ្ដឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្ដឹងទាមទារឱ្យ ទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

ឧ. ការមិនបានរៀបអាពាហ៍ពិពាហ៍រវាងលោក A និងនារី C ព្រមទាំងមានកូន B ។ លោក A មិនមានឆន្ទៈចង់រៀបការជាមួយនារី C ទេ ហើយបានបដិសេធមិនទទួលស្គាល់ B ជាកូនទេ។ ហេតុដូច្នេះ B អាចដាក់ពាក្យបណ្ដឹង ឲ្យទទួលស្គាល់ ថាខ្លួនជាកូនរបស់ឪពុក A បាន ។

**ច.** បណ្ដឹងដែលមានគោលបំណងបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

ឧ. A មានកូន C និង D ប៉ុន្តែ ត្រូវបានចុះបញ្ជីសំបុត្រកំណើតកូន B និង C ទៅវិញ។ ចំពោះ B គឺ A អាចដាក់ពាក្យបណ្ដឹងសុំបដិសេធបុត្តភាពបាន។ ដូចគ្នាផងដែរ B ក៏អាចប្ដឹងសុំឲ្យបញ្ជាក់ពីនត្តិភាពនៃបុត្តភាពចំពោះ A បាន។

**ឆ.** បណ្ដឹងដែលមានគោលបំណងបញ្ជាក់ពីអត្ថិភាព នៃមាតុភាពតាមបញ្ញត្តិមាត្រា ១០០៤ (បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និងមាត្រា១០០៥ ( បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីម្ដាយ) នៃក្រមរដ្ឋប្បវេណី។

ឧ. ម្ដាយ B បានបោះបង់កូន A ចោលបន្ទាប់ពីបានបង្កើតរួច។ នៅពេលដែល A បានធំដឹងក្ដីហើយបានដឹងថា B ជាម្ដាយបង្កើត។ នោះ A អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូនចំពោះ B បាន។ ដូចគ្នា ផងដែរ B ក៏អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីម្ដាយបាន ប៉ុន្តែ ដោយសារតែ B បានបោះបង់ A ចោល ដូច្នេះគឺអាចលើកចោលពាក្យបណ្ដឹង យោងទៅតាមក្រមរដ្ឋប្បវេណីមាត្រា១០០៥ កថាខណ្ឌទី៧បាន។

**ជ.** បណ្ដឹងទាមទារកាត់កាល់(តាមមាត្រា ១០១៦)។

ឧ. ឪពុកម្ដាយចិញ្ចឹម AB បានបង្កើតសុំកូនពេញលេញជាមួយកូនចិញ្ចឹម C ។ ក្រោយពេលរស់នៅជាមួយគ្នា ឪពុកម្ដាយចិញ្ចឹម AB បានបោះបង់កូន C ដោយគំនិតទុច្ចរិត ។ ហើយប្រសិនបើក្នុងករណីដែល

DE ដែលជាឪពុកម្ដាយបង្កើតរបស់ C អាចគ្រប់គ្រងថែរក្សា C បានដោយសមរម្យ នោះ C D E អាចដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់ពីឪពុកម្ដាយចិញ្ចឹម AB បាន។

**ឈ.** បណ្ដឹងទាមទារកាត់កាល់ (តាមមាត្រា ១០៣១)។

**ឧ.** ឪពុកម្ដាយចិញ្ចឹម AB បានបង្កើតសុំកូនធម្មតាជាមួយកូនចិញ្ចឹម C ។ ក្រោយមកដោយសារតែឪពុកម្ដាយចិញ្ចឹម AB បានធ្វើបាប C នោះធ្វើឲ្យទំនាក់ទំនងមានការប្រេះស្រាំហើយមានការពិបាកក្នុងការបន្តសុំកូនទៅមុខទៀត។ ក្នុងករណីប្រសិនបើ C នៅជាអនីតិជននៅឡើយ បុគ្គលដែលត្រូវក្លាយទៅជាអ្នកតំណាងដែលច្បាប់បានកំណត់ (ឧ. DEដែលជាឪពុកម្ដាយបង្កើតរបស់C) គឺអាចដាក់ពាក្យបណ្ដឹងទាមទារការកាត់កាល់ ពីឪពុកម្ដាយចិញ្ចឹម AB បានក្រោយពេលកាត់កាល់។

**៣.**បណ្ដឹងផ្សេងទៀតដែលមានគោលបំណងបង្កើតទំនាក់ទំនងឋានៈបុគ្គល ចំណុចនេះក្រុមការងារមិនទាន់អាចរកឧទាហរណ៍ដាក់ឱ្យចំបានទេ។

**សំណួរ ១២**

**តើច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មានវិសាលភាពគ្របដណ្ដប់លើការបញ្ជាក់អំពីបុគ្គល (គន្ថីទី ២) និង សន្តតិកម្ម (គន្ថីទី ៨) ដែរឬទេ?**

**ចម្លើយ**

គ្មានវិសាលភាពទេ។ ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលមិនមានវិសាលភាពគ្រប់ដណ្ដប់លើការបញ្ជាក់អំពីបុគ្គល (គន្ថីទី២) និងសន្តតិកម្ម (គន្ថីទី៨) ទេ ព្រោះ ចំណុចទាំងនេះ មិនមានចែងនៅក្នុងមាត្រា ៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។ ការបញ្ជាក់អំពីបុគ្គល (គន្ថីទី២) និង សន្តតិកម្ម (គន្ថីទី៨) ស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (ផ្នែក១ និង ផ្នែក៥ នៃតារាងឧបសម្ពន្ធ័ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង) ។

**សំណួរ ១៣**

**ក្រសួងបានចេញប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ បើមានបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីការផ្លាស់ប្ដូរ ការកែប្រែ ការកើនឡើង និងការថយចុះនៃទ្រព្យ តើនេះគឺជាប្រភេទនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលដែរឬទេ ?**

**ចម្លើយ**

មិនមែនទេ។

ជាដំបូង បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីការផ្លាស់ប្ដូរ ការកែប្រែ ការកើនឡើង និងការថយចុះនៃទ្រព្យ គឺជាបណ្ដឹងខុសច្បាប់ ព្រោះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺជា "កិច្ចសន្យា" ហើយវាមិនអាចទៅរួចទេ ដែលតុលាការជ្រៀតជ្រែកលើរឿងកិច្ចសន្យា។

**សំណួរ ១៤**

**រឿងក្ដីមានជនពាក់ព័ន្ធច្រើន តើអាចបង្កើតក្រុមប្រឹក្សាជំនុំជម្រះពីដំបូងបានដែរឬទេ?**

**ចម្លើយ**

ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមាត្រា ៣ គឺបានកំណត់អំពីវិសាលភាពនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៣ កថាខណ្ឌទី ១ បានចែងថា "នៅសាលាដំបូងរឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២" ។ លើសពីនេះ មាត្រា ដដែលកថាខណ្ឌទី ២ចែងថា "ចំពោះរឿងក្តីខាងក្រោមនេះ ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមៈ

ក. រឿងក្តីដែលកម្មវត្ថុមានតម្លៃមិនតិចជាង ៥.០០០.០០០(ប្រាំលាន)រៀល ហើយដែលតុលាការទទួលស្គាល់ថាគួរតែត្រូវបានវិនិច្ឆ័យ និងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយពិចារណាចំនួននៃគូភាគី និងបញ្ហាផ្សេងទៀត ។

ខ. រឿងក្តីដែលច្បាប់កំណត់ថា "ត្រូវវិនិច្ឆ័យ និងជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម" និងបានកំណត់ពីរឿងក្តីដែលអាចវិនិច្ឆ័យជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

នៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដោយសារតែបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គលមិនបានចែងថា ការវិនិច្ឆ័យនិងជម្រះក្តីត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមនោះទេ។ ដូច្នេះ រឿងក្តីនៅក្នុង មាត្រា ២៣ កថាខណ្ឌទី ២ ចំនុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនអាចយកមកអនុវត្តបានទេ។

ម្យ៉ាងទៀត ដោយសារតែ តម្លៃកម្មវត្ថុនៃបណ្តឹងនៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវបានគណនាចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែនរៀល) (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៦០ កថាខណ្ឌទី៣) ប្រសិនបើ នៅក្នុងករណីដែលតុលាការទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យ និងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃអង្គចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូរភាគី និង បញ្ហាផ្សេងៗទៀត នោះចៅក្រមអាចធ្វើការវិនិច្ឆ័យដោយក្រុមប្រឹក្សាជំនុំជម្រះនៃអង្គចៅក្រម ចំពោះរឿងក្តីនោះតាំងពីដំបូងបាន។

**សំណួរ ១៥**

**តើតុលាការត្រូវបង្កើតសៀវភៅចុះបញ្ជីសំណុំរឿងទាក់ទងនឹងឋានៈបុគ្គលដាច់ដោយឡែកពីសៀវភៅចុះបញ្ជីបណ្តឹងរដ្ឋប្បវេណី?**

**ចម្លើយ**

ការចុះសំណុំរឿងទាក់ទងនឹងឋានៈបុគ្គលទៅក្នុងសៀវភៅចុះបញ្ជីបណ្តឹងរដ្ឋប្បវេណី ឬ ចុះក្នុងសៀវភៅដាច់ដោយឡែក គឺអាស្រ័យទៅតាមរដ្ឋបាលរបស់តុលាការនីមួយៗ ។

**សំណួរ ១៦**

**ចំពោះបណ្តឹងទាមទារឲ្យទទួលស្គាល់ ឬបណ្តឹងបដិសេធបិតុភាព តើអនីតិជនមានសមត្ថភាពក្នុងការធ្វើបណ្តឹងដែរឬទេ?**

**ចម្លើយ**

នៅក្នុងបណ្តឹងខាងលើ អនីតិជន មានសមត្ថភាពក្នុងការធ្វើបណ្តឹង (មាត្រា ៨ កថាខណ្ឌទី ១ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ ក៏ប៉ុន្តែ នៅក្នុងករណីខ្លះ វាមានការលំបាកសម្រាប់អនីតិជនក្នុង

ការធ្វើបណ្ដឹងដោយខ្លួនឯងផ្ទាល់ឲ្យបានត្រឹមត្រូវ។ ដូច្នេះ ប្រសិនបើមានភាពចាំបាច់ តុលាការអាចជ្រើសរើសតាំងមេធាវីសម្រាប់អនីតិជនបាន តាមរយៈការស្នើសុំ (មាត្រា ៨ កថាខណ្ឌទី ២) និង តាមរយៈឆន្ទានុសិទ្ធិរបស់តុលាការ (មាត្រា ៨ កថាខណ្ឌទី ៣) ។

**សំណួរ ១៧**

**បណ្ដឹងលែងលះដើមចោទបានដាក់ពាក្យបណ្ដឹងទៅតុលាការខេត្តសៀមរាប។ តែចុងចម្លើយបានប្ដូរទីលំនៅទៅរស់នៅខេត្តបន្ទាយមានជ័យ ហើយដើមចោទបានជាប់ពន្ធនាគារនៅខេត្តឧត្ដរមានជ័យ តើតុលាការនៅខេត្តសៀមរាបនៅតែមានសមត្ថកិច្ចលើបណ្ដឹងលែងលះនោះ។**

**ចម្លើយ**

សមត្ថកិច្ចផ្ដាច់មុខលើបណ្ដឹងនេះ គឺសាលាដំបូងខេត្តសៀមរាប (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០ កថាខណ្ឌទី១ និង មាត្រា ១៧)។ ហើយដោយសារតែតុលាការផ្សេងមិនមានសមត្ថកិច្ចទេ ដោយផ្អែកតាមការផ្ទេរលំនៅឋានរបស់គូភាគី (ក្រមនីតិវិធី មាត្រា ១៧) ដូចនេះ ក្រៅពីសាលាដំបូងខេត្តសៀមរាប តុលាការផ្សេងគ្មានសមត្ថកិច្ចទេ។ ហេតុដូច្នេះ យោងតាមការកំណត់អំពីការផ្ទេរសមត្ថកិច្ចទៅតុលាការផ្សេងនៅក្នុងមាត្រា ៦ (ការផ្ទេរបណ្ដឹងដើម្បីចៀសវាងការយឺតយ៉ាវ) ក៏មិនអាចធ្វើការផ្ទេរទៅតុលាការផ្សេងបានដែរ។

**សំណួរ ១៨**

**A និង B រស់នៅជាអនីតិសង្វាស បានដាក់ពាក្យសុំ ឬ ពាក្យបណ្ដឹងលែងលះ តើតុលាការត្រូវធ្វើដូចម្ដេច?**

**ចម្លើយ**

តុលាការត្រូវចេញសាលក្រមលើកបណ្ដឹងនោះចោល ផ្អែកលើមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ តុលាការ គួរគប្បីសរសេរសំអាងហេតុបញ្ជាក់ឲ្យភាគីបានយល់ថា "ដោយគូភាគីពុំមានជាប់ចំណងអាពាហ៍ពិពាហ៍ ហើយការរស់នៅជាអនីតិសង្វាសបានរលាយរួចទៅហើយ ដូច្នេះ គូភាគីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួន ដោយភាគីម្ខាងទៀតមិនមានសិទ្ធិជំទាស់ការរៀបអាពាហ៍ពិពាហ៍របស់ភាគីម្ខាងទៀតបានឡើយ"។

**សំណួរ ១៩**

**ទាក់ទងនឹងបណ្ដឹងលែងលះ ភាគីម្ខាងមិនបានទាមទារឲ្យភាគីម្ខាងទៀតទទួលបន្ទុកនៃសោហ៊ុយចិញ្ចឹមកូនទេ ហើយតុលាការក៏បានចេញសាលក្រមរួចទៅហើយដែរ។ ប៉ុន្តែក្រោយមក ភាគីដែលចិញ្ចឹមកូនត្រូវបានស្លាប់ តើកូនដែលជាអនីតិជនអាចប្ដឹងទៅតុលាការឲ្យភាគីម្ខាងទៀតនោះទទួលបន្ទុកចិញ្ចឹមខ្លួនបានដែរឬទេ?**

**ចម្លើយ**

ឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបាលើកូនជាអនីតិជនក្រោយលែងលះ មានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទៅអ្នកដែលមានអំណាចមេបា រហូតដល់កូនជាអនីតិជន

នោះដល់វ័យនីតិភាព (ក្រមរដ្ឋប្បវេណី មាត្រា ១០៤០ កថាខណ្ឌទី ១)។ ពោល គឺឪពុក ឬ ម្ដាយដែលពុំមានសិទ្ធិអំណាចមេបាលើកូនជាអនីតិជនប៉ុណ្ណោះ ដែលមានករណីកិច្ចបង់សោហ៊ុយគ្រប់គ្រងថែរក្សាកូន។

ប៉ុន្តែ នៅពេលលែងលះគ្នា អ្នកដែលមានអំណាចមេបាបានស្លាប់ ហើយកូនបានធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា នោះឪពុកដែលជាអ្នកពុំមានអំណាចមេបានឹងត្រូវក្លាយជាអ្នកដែលមានអំណាចមេបា (ក្រមរដ្ឋប្បវេណី មាត្រា ១០៥១កថាខណ្ឌទី ៣)។

ក្នុងរឿងក្ដីនេះ ម្ដាយដែលជាអ្នកមានអំណាចមេបាបានស្លាប់ ហើយប្រសិនបើ កូនបានធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា នោះឪពុកដែលមិនមានអំណាចមេបានឹងក្លាយទៅជាអ្នកមានអំណាមេបា។ ក្នុងករណីនេះ យោងតាមមាត្រា១០៣៤ អ្នកដែលមានអំណាចមេបាមានសិទ្ធិ និងករណីកិច្ចត្រូវបីបាច់ថែរក្សារូបកាយកូន។

ដូច្នេះ កូនដែលជាអនីតិជនមិនអាចទាមទារសោហ៊ុយចិញ្ចឹមបីបាច់ពីឪពុកដែលជាអ្នកមានអំណាចមេបាបានទេ។ ប៉ុន្តែ អាចទាមទារឲ្យបីបាច់ថែរក្សារូបកាយរបស់ខ្លួនបាន។

**សំណួរ ២០**

**X ជាម្ដាយរបស់Y1 បានធ្វើប្រទានកម្មដោយប្រគល់នូវផ្ទះ១ខ្នងឲ្យទៅកូន Y1Y2 ក្នុងចំណងដៃអាពាហ៍ពិពាហ៍។ ក្រោយមកប្ដីប្រពន្ធ Y1Y2 លែងលះគ្នា Y2បានទាមទារទៅ Y1ឲ្យបែងចែកទ្រព្យសម្បត្តិដែលជាផ្ទះនោះ។ ម្ដាយX បានដាក់ពាក្យបណ្ដឹងផ្សេង ដោយយោងលើសិទ្ធិលើកម្មសិទ្ធិទាមទារឲ្យ Y1Y2 ប្រគល់ផ្ទះមកវិញបានដែរ ឬទេ?**

**ចម្លើយ**

ម្ដាយអាចដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីដោយយក Y1Y2 ដែលជាអ្នកកាន់កាប់លើផ្ទះនោះធ្វើជាចុងចម្លើយដោយទាមទារឲ្យប្រគល់ផ្ទះមកវិញផ្អែកតាមសិទ្ធិលើកម្មសិទ្ធិ។ ប៉ុន្តែ ដោយសារតែក្រោយអាពាហ៍ពិពាហ៍របស់Y1Y2 ម្ដាយXបានធ្វើប្រទានកម្មផ្ទះនោះទៅឲ្យY1 ដូច្នេះ ក្នុងករណីដែលកម្មសិទ្ធិបានបាត់បង់តាមរយៈកិច្ចសន្យាប្រទានកម្ម ពាក្យបណ្ដឹងនោះនឹងត្រូវបានច្រានចោល លើកលែងតែក្នុងករណីដែលកិច្ចសន្យាប្រទានកម្មរលត់ដោយមូលហេតុណាមួយ ។

**សំណួរ ២១**

**គូភាគីកំពុងដំណើការលែងលះគ្នានៅតុលាការ ហើយមានតតិយជនមួយទៀតបានដាក់ពាក្យបណ្ដឹងថាភាគីប្ដីមានបំណុលជាមួយគាត់។ នៅក្នុងករណីដែលតុលាការ បានបញ្ចូលរឿងក្ដីហើយ តើគួរបំបែកសំណុំរឿងឬទេ?**

**ចម្លើយ**

បណ្ដឹងលែងលះ និង បណ្ដឹងទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់របស់តតិយជន ចំពោះភាគីណាមួយ គឺមិនអាចបញ្ចូលគ្នាបានទេ (មាត្រា ៧៧ ក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងករណីដែលតតិយជនបានដាក់ពាក្យបណ្ដឹង ហើយតុលាការបានទទួលពាក្យបណ្ដឹងហើយបញ្ចូលរឿងក្ដីដោយមានមិនត្រឹមត្រូវ នោះតុលាការត្រូវបំបែកសំណុំរឿងក្ដីនោះភ្លាម។

**សំណួរ ២២**

**នីតិវិធីបណ្ដឹងផ្សេងគ្នាមិនអាចបញ្ចូលនៅក្នុងបណ្ដឹងតែមួយបានទេ លើកលែងតែការទាមទារពាក់ព័ន្ធនឹងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និងការទាមទារពាក់ព័ន្ធនឹងការខូចខាតដែលកើតមានឡើងដោយអង្គហេតុដែលជាមូលហេតុនៃការទាមទារពាក់ព័ន្ធនឹងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនោះ។**

**អង្គហេតុ ៖ មានបណ្ដឹងពីរកំពុងចាត់ការ។ បណ្ដឹងមួយ គឺជាបណ្ដឹងលែងលះរវាង ប្ដី X និងប្រពន្ធ Y ចំណែកឯបណ្ដឹងមួយទៀត គឺជាបណ្ដឹងទាមទារអោយសងបំណុលដែលធ្វើឡើងដោយម្ចាស់បំណុលរបស់ប្ដី។**

**១. តើបណ្ដឹងទាំងពីរនេះ អាចបញ្ចូលគ្នាបានដែរឬទេ?**

**២. ក្នុងករណីដែលប្ដី ឬប្រពន្ធ ទទួលមរណភាព តើតុលាការត្រូវចាត់ការបណ្ដឹងទាំងពីរនេះយ៉ាងដូចម្ដេច?**

**ចម្លើយ**

១. បណ្ដឹងទាំងពីរនេះ ពុំអាចបញ្ចូលគ្នាបានទេ ពីព្រោះថា បណ្ដឹងនីមួយៗនឹងត្រូវចាត់ការដោយនីតិវិធីផ្សេងគ្នា។ ច្បាស់ជានេះទៀត មានន័យថា បណ្ដឹងលែងលះ (សន្មតថាមិនព្រមព្រៀង) នឹងត្រូវដោះស្រាយតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល រីឯបណ្ដឹងទាមទារឲ្យសងបំណុល នឹងត្រូវចាត់ការតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ផ្អែកលើ មាត្រា ៣ នៃច្បាប់ស្ដីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និង មាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២. ក្នុងករណីដែល ប្ដី ឬប្រពន្ធបានទទួលមរណភាព តុលាការនឹងត្រូវចាត់ការដោយផ្អែកលើនីតិវិធីបណ្ដឹងផ្សេងគ្នា៖

- បណ្ដឹងលែងលះ ៖ ក្នុងករណីដែល ប្ដី ឬ ប្រពន្ធទទួលមរណភាព នោះបណ្ដឹងនឹងត្រូវចប់ ដោយស្វ័យប្រវត្តិ (មាត្រា ១៩ និង មាត្រា ២០ កថាខណ្ឌទី ៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។
- បណ្ដឹងទាមទារឲ្យសងបំណុល ៖ ក្នុងករណីដែលចុងចម្លើយជាប្ដីនោះ ទទួលមរណភាព តុលាការត្រូវផ្អាកនីតិវិធីបណ្ដឹង យោងលើមាត្រា ១៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទាប់មក តុលាការត្រូវបន្តនីតិវិធីបណ្ដឹង ដោយយោងលើមាត្រា ១៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដើម្បីងាយស្រួលយល់ឲ្យបានលម្អិត សូមមើលមាត្រា ១៧៣ ដល់មាត្រា ១៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីជាការស្រេច។

**សំណួរ ២៣**

**នៅក្នុងនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ប្រសិនបើភាគីទទួលមរណភាព ហើយមិនមានសន្តតិជនតើតុលាការអាចចេញសាលក្រម ឬដីកាសម្រេចដើម្បីបញ្ចប់នីតិវិធីបណ្ដឹង?**

**ចំលើយ**

ជាគោលការណ៍ដែលមានចែងក្នុងមាត្រា ១៧៤ (ការបញ្ចប់នូវនីតិវិធីបណ្ដឹងដោយស្វ័យប្រវត្តិ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលភាគីទទួលមរណភាព ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះ នីតិវិធីនៃបណ្ដឹងត្រូវបញ្ចប់។ ក្នុងករណីនេះ តុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្ដឹងនោះ។

ចំពោះមរណភាពរបស់ភាគី នៅក្នុងនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលត្រូវបែងចែកទៅតាមករណីមរណភាពរបស់ដើមចោទ និងមរណភាពរបស់ចុងចម្លើយ។

មាត្រា ១៩ (មរណភាពរបស់ដើមចោទ) នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានចែងថា "ក្នុងករណីដែលដើមចោទនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទទួលមរណភាពនៅពេលបណ្តឹងនោះកំពុងចាត់ការ នោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស"។ មាត្រានេះបានបញ្ញត្តជាគោលការណ៍អំពីការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ក្នុងករណីដែលដើមចោទក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទទួលមរណភាព លើកលែងតែករណីដែលមានបញ្ញត្តិពិសេស ដូចជាមាត្រា ២៤ កថាខណ្ឌទី ២ មាត្រា ២៥ កថាខណ្ឌទី ២ និង មាត្រា ២៦ កថាខណ្ឌទី ៣។

កថាខណ្ឌទី ២ នៃមាត្រា ២០ (មរណភាពរបស់ចុងចម្លើយ) នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បានចែងថា "ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី១ ឬទី២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើ ចុងចម្លើយទាំងអស់ទទួលមរណភាព បណ្តឹងនេះត្រូវបន្តនីតិវិធីដោយយកតំណាងអយ្យការមកធ្វើជាចុងចម្លើយ"។ ជាងនេះ ទៅទៀត មាត្រា ២៦ កថាខណ្ឌទី ២ គឺបានបញ្ញត្តដូចគ្នានឹងមាត្រា ២០ កថាខណ្ឌទី ២។ បញ្ញត្តិនេះបានចែង អំពីករណីដែលចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងអស់ទទួលមរណភាព ដោយត្រូវអោយបន្តនីតិវិធីដោយយកតំណាងអយ្យការមកធ្វើជាចុងចម្លើយ។ ហេតុនេះ បណ្តឹងទាក់ទងនឹងឋានៈបុគ្គលមិនត្រូវបានបញ្ចប់ដោយមរណភាពរបស់ចុងម្លើយឡើយ។ ប៉ុន្តែ មាត្រា ២០ កថាខណ្ឌទី ៣ នៃច្បាប់ដដែលបានចែងថា "ក្នុងករណីដែលចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានគោលបំណងលែងលះគ្នា ឬកាត់កាល់ ទទួលមរណភាពនៅពេលបណ្តឹងនេះកំពុងត្រូវបានចាត់ការបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនេះត្រូវចប់ដោយស្វ័យប្រវត្តិ ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើក៏ដោយ។" បញ្ញត្តិនេះជាអញ្ញត្រកម្ម ចំពោះមរណភាពរបស់ចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលចំពោះបណ្តឹងដែលមានគោលបំណងលែងលះគ្នា ឬកាត់កាល់។ ហេតុនេះ ចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានគោលបំណងលែងលះគ្នា ឬកាត់កាល់ ប្រសិនបើចុងម្លើយទទួលមរណភាព នោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនេះត្រូវចប់ដោយស្វ័យប្រវត្តិ។

ដោយសារច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនបានបញ្ញត្តអំពីនីតិវិធីក្នុងការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ហេតុនេះយើងត្រូវអនុវត្តតាមបញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ។

ដូច្នេះ ករណីមរណភាពរបស់ភាគីនៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលនាំអោយបញ្ចប់នីតិវិធីបណ្តឹងដោយស្វ័យប្រវត្តិ តុលាការត្រូវចេញសាលក្រមប្រកាសបញ្ចប់បណ្តឹងនោះ តាមមាត្រា ១៧៤ (ការបញ្ចប់នូវនីតិវិធីបណ្តឹងដោយស្វ័យប្រវត្តិ) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សំណួរ ២៤

**ក្នុងដំណើរការនីតិវិធីលែងលះ ចុងចម្លើយបានបាត់ខ្លួន។ ក្នុងករណីនេះ តើតុលាការត្រូវចេញសាលក្រមកំបាំងមុខ ឬ សាលក្រមធម្មតា?**

## ចម្លើយ

នៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ១៣ កថាខណ្ឌទី១ ត្រូវបានលើកលែងការអនុវត្តសាលក្រមកំបាំងមុខដែលចែងនៅក្នុង មាត្រា ២០១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ប៉ុន្តែ ក្នុងករណីនេះមិនមែនមានន័យថា ការអវត្តមានរបស់ចុងចម្លើយ មិនអាចដំណើរនីតិវិធីបាននោះទេ

គ្រាន់មានន័យថា មិនត្រូវបានអនុវត្ត ការចាត់ទុកថាបានសារភាព ដែលមានចែងនៅក្នុងមាត្រាដដែលនេះតែប៉ុណ្ណោះ។

ដូច្នេះ តុលាការ អាចធ្វើការប្រកាសសាលក្រមធម្មតាដោយអវត្តមានរបស់ចុងចម្លើយបាន ដោយផ្អែកលើការស្រាវជ្រាវភស្តុតាងដែលបានដាក់មុនពេលបាត់ខ្លួនជាដើម (មាត្រា ១៨៨ កថាខណ្ឌ ទី ២)។

## សំណួរ ២៥

**នៅក្នុងរឿងក្តីកំបាំងមុខទាក់ទងនឹងឋានៈបុគ្គល តើចុងចម្លើយអាចប្តឹងទាស់បានដែរឬទេ?**

## ចម្លើយ

យោងតាមមាត្រា ១៣ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងមាត្រា ២០១ កថាខណ្ឌ២ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី មិនអាចត្រូវបានយកមកប្រើប្រាស់ទេ។ ពោល គឺដោយសារតែនៅក្នុងនីតិវិធីរឿងក្តីទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តស្តីពីសាលក្រមកំបាំងមុខពុំត្រូវបានយកមកប្រើប្រាស់ ដូច្នេះ ចុងចម្លើយមិនអាចប្តឹងទាស់បានទេ ។

ហេតុដូច្នេះ ប្រសិនបើចុងចោទធ្វើការប្តឹងទាស់នោះបណ្តឹងទាស់នោះ គឺមិនត្រឹមត្រូវតាមច្បាប់ទេ ហើយតុលាការត្រូវលើកចោលបណ្តឹងនោះ ដោយសាលក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ២០៧ កថាខណ្ឌទី២ បន្ទាត់ខាងមុខ)។

ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ២០១ កថាខណ្ឌទី ២ "សាលក្រមកំបាំងមុខ" ដោយសារតែចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ជាលទ្ធផល គឺត្រូវបានចាត់ទុកថាចុងចម្លើយបានសារភាពចំពោះការអះអាងរបស់ដើមចោទទាក់ទងនឹងអង្គហេតុ ហើយត្រូវបានប្រកាសសាលក្រមឬសាលដីកាទទួលស្គាល់ការទាមទាររបស់ដើមចោទ។ ផ្ទុយទៅវិញ ប្រសិនបើចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេនោះ តុលាការទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទយោងទៅតាមភស្តុតាងដែលបានដាក់ដោយដើមចោទ ហើយប្រសិនបើប្រកាសសាលក្រមឬសាលដីកាទទួលស្គាល់ការទាមទាររបស់ដើមចោទពេលចុងចោទ អវត្តមាននោះ គឺមិនយោងតាមមាត្រា ២០១ កថាខណ្ឌទី ២ "សាលក្រមកំបាំងមុខ"ទេ ហើយត្រូវបានហៅថា សាលក្រមធម្មតា។

ហេតុដូច្នេះ ចំពោះរឿងក្តីទាក់ទងនឹងឋានៈបុគ្គល ទោះបីជាក្នុងករណីដែលអវត្តមាននៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ប្រសិនបើទទួលស្គាល់អង្គហេតុដែលបានអះអាងដោយដើមចោទ យោងតាមភស្តុតាងដែលដើមចោទបានដាក់នោះ គឺអាចប្រកាសសាលក្រម ឬ សាលដីកាទទួលស្គាល់ការទាមទាររបស់ដើមចោទបាន ។

## សំណួរ ២៦

**តើដីកាសម្រេចដែលមានចែងនៅក្នុងមាត្រា ២២ នៃច្បាប់ស្តីពីនិតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល អាចជាលិខិតអនុវត្តអនុវត្តដែរឬទេ?**

## ចម្លើយ

ដីកាសម្រេចនេះ គឺជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

កថាខណ្ឌ ២ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលចែងថា "ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន ឬបង់ប្រាក់ ឬផ្ដល់តាវកាលិកផ្សេងទៀត ក្នុងសាលក្រមឬសាលដីកា ដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះបាន"។ រីឯកថាខណ្ឌទី ១ មាត្រា ២៣ ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលចែងថា "ក្នុងករណីដែលមានបុគ្គលណាធ្វេសប្រហែលមិនអនុវត្តនូវករណីយកិច្ចដែលមានគោលបំណងឱ្យបង់ប្រាក់ ឬឱ្យផ្ដល់តាវកាលិកនូវទ្រព្យសម្បត្តិផ្សេង ដែលកំណត់ដោយសេចក្ដីសម្រេច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២២ ខាងលើនោះ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការដែលបានធ្វើការសម្រេចសេចក្ដីនេះ អាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកមានករណីយកិច្ច អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យមួយតាមពាក្យសុំរបស់អ្នកមានសិទ្ធិបាន"។

យើងឃើញថា ដីកាសម្រេចនេះជាប្រភេទដីកាសម្រេចបង្គាប់ឱ្យផ្ដល់តាវកាលិក ហេតុនេះ យោងតាមចំណុច គ កថាខណ្ឌទី ២ មាត្រា ៣៥០ ក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចនេះ គឺជាលិខិតអនុវត្ត ។

**សំណួរ ២៧**

**នៅក្នុងរឿងក្ដីតែមួយ តែមានសាលក្រមពីរ មួយសាលក្រមលើនីតិវិធីស្ដីពីឋានៈបុគ្គល និងមួយទៀតជាសាលក្រមលើនីតិវិធីរដ្ឋប្បវេណី តើសាលក្រមមួយណាមានអានុភាព?**

**ចម្លើយ**

ដោយសារតែរឿងក្ដីដែលត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី និង តាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល គឺមានលក្ខណៈខុសគ្នា (ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលមាត្រា ៣) ចំពោះសាលក្រមឬសាលដីកាដែលយោងតាមច្បាប់ឋានៈបុគ្គលនិងសាលក្រម ឬ សាលដីកា ដែលយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្ដីតែមួយ គឺមិនត្រូវបានប្រកាសឡើយ។ ម្យ៉ាងវិញទៀត នៅពេលដែលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ ដោយសារតែអានុភាពនៃអាជ្ញាអស់ជំនុំត្រូវកើតឡើង យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ១ ចំពោះរឿងក្ដីដូចគ្នាត្រូវបានប្រកាសសាលក្រម ឬ សាលដីកា ២ គឺមិនមែនជារឿងបែបសាមញ្ញនោះទេ។ ប៉ុន្តែ ប្រសិនបើរឿងក្ដីមួយតែមានសាលក្រម២ ទោះបីជាយោងតាមសាលក្រម ឬ សាលដីកាណាមួយក៏ដោយក៏មានសុពលភាពដែរ ហើយអាចអនុវត្តដោយស្របច្បាប់ ។ ប៉ុន្តែ ប្រសិនបើសាលក្រមឬ សាលដីកាដែលចូលជាស្ថាពរក្រោយ មានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកា ដែលចូលជាស្ថាពរ មុន នោះគឺជាមូលហេតុនៃការជំនុំជម្រះសារជាថ្មី(មាត្រា ៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១០) ប្រសិនបើគូរភាគីដាក់ពាក្យបណ្ដឹងជំនុំជម្រះសារជាថ្មីចំពោះសាលក្រមឬសាលដីកាដែលចូលជាស្ថាពរក្រោយ ហើយត្រូវបានធ្វើការចាប់ផ្ដើមជំនុំជម្រះសារជាថ្មីនោះគឺអាចធ្វើការលុបចោលសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរក្រោយបាន (មាត្រា ៣១៦ កថាខណ្ឌទី១)។

**សូមបញ្ជាក់ថា** មុនការអនុវត្តច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ចំពោះរឿងក្ដីទាំងអស់ដែលត្រូវអនុវត្តតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល តែត្រូវបានប្រកាសសាលក្រមដោយយោងទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយក៏នីតិវិធីដែលបានអនុវត្តគឺស្របច្បាប់។

**សំណួរ ២៨**

**តើមេឃុំ និង នគរបាល អាចធ្វើការបញ្ជូនបានដែរឬទេ? ច្បាប់អនុញ្ញាតការបញ្ជូន មានតែ ក្រឡាបញ្ជី អាជ្ញាសាលា ប្រៃសនីយ៍។**

**ចម្លើយ**

កថាខណ្ឌទី ៣ នៃមាត្រា ២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា "ការបញ្ជូន ត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី។ ផ្អែកតាមខ្លឹមសារនៃមាត្រានេះ មេឃុំ និងនគរបាល មិនអាចធ្វើការបញ្ជូនបានទេ។ ក្នុងករណីដែលមានមូលហេតុពិសេសមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា អាចឲ្យអ្នកអនុវត្តកិច្ចការជំនួសខ្លួន ផ្អែកតាមកថាខណ្ឌទី ៣ នៃមាត្រា ២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនស្ថិតនៅក្រោម ផ្អែកតាម កថាខណ្ឌទី ១ ប្រការ ២ នៃ ប្រកាស លេខ ៣០ កយប្រក / ០៧ស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០០៧ របស់ក្រសួងយុត្តិធម៌។

**សំណួរ ២៩**

**តើការបញ្ជូនដោយអាជ្ញាសាលា ត្រូវធ្វើតាមរយៈលិខិតអនុសិដ្ឋដូចគ្នានឹងបុគ្គលិកប្រៃសនីយ៍ដែរឬទេ ?**

**ចម្លើយ**

ការបញ្ជូនដោយអាជ្ញាសាលា មិនត្រូវធ្វើតាមរយៈលិខិតអនុសិដ្ឋដែលបុគ្គលិកប្រៃសនីយ៍ត្រូវធ្វើនោះទេ ព្រោះនៅពេលអាជ្ញាសាលាធ្វើការបញ្ជូន អាជ្ញាសាលាត្រូវធ្វើរបាយការណ៍នៃការបញ្ជូន។

**សំណួរ ៣០**

**តើដីកាកោះ អាចត្រូវបានបញ្ជូន នៅថ្ងៃសៅរ៍ អាទិត្យ ឬនៅថ្ងៃបុណ្យ ឬខុសម៉ោងរដ្ឋបាល ដូចជាពេលថ្ងៃត្រង់ ឬពេលយប់ បានដែរឬទេ?**

**ចម្លើយ**

ក្រមនីតិវិធីរដ្ឋប្បវេណីមិនមានចែងការកំណត់លើការបញ្ជូននៅថ្ងៃសៅរ៍ អាទិត្យ ឬនៅថ្ងៃបុណ្យ ឬពេលសម្រាកនោះទេ។ ដូចនេះ ប្រសិនបើការបញ្ជូនបានធ្វើឡើងនៅសៅរ៍ អាទិត្យ ឬនៅថ្ងៃបុណ្យ ឬពេលសម្រាក ការបញ្ជូននោះនឹងមានអានុភាព។

ប៉ុន្តែ ក្នុងការអនុវត្ត មន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន មិនដែលធ្វើការបញ្ជូនដីកាកោះទៅឲ្យជនដែលត្រូវទទួលការបញ្ជូននៅថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យ ឬខុសម៉ោងរដ្ឋបាល ដូចជាថ្ងៃត្រង់ ឬពេលយប់បានទេ ដោយហេតុថា ម៉ោងធ្វើការរបស់មន្ត្រី ត្រូវបានកំណត់ដោយផ្អែកតាមអនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការគ្រប់គ្រងអវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

ប៉ុន្តែ ក្នុងករណីដែលមិនអាចជៀសវាងបាន មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនអាចធ្វើការបញ្ជូនដីកាកោះទៅឲ្យជនដែលត្រូវទទួលការបញ្ជូននៅថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យ ឬខុសម៉ោងរដ្ឋបាលបានដោយអាចប្រែប្រួល ម៉ោងធ្វើការផ្អែកតាមអនុក្រឹត្យខាងលើ។

**សំណួរ ៣១**

**រាល់ការបញ្ជូនដីកា តុលាការបញ្ជូនទៅអ្នកតំណាងដោយអាណត្តិ (មេធាវី) ហើយក្រឡាបញ្ជីមិនបានបញ្ជូនទៅគូភាគីទេ (ដើមបណ្ដឹង និង ចុងចម្លើយ)។ តើដីកានេះ មានអានុភាពតាមផ្លូវច្បាប់ដែរឬទេ ?**

**ចម្លើយ**

បើគូភាគីមានអ្នកតំណាងដោយអាណត្តិ (មេធាវី) ហើយអ្នកតំណាងដោយអាណត្តិនេះ ត្រូវបានគេផ្ដល់ឲ្យនូវសិទ្ធិក្នុងការទទួលនូវឯកសារពីតុលាការ នោះក្រឡាបញ្ជីត្រូវធ្វើការពិនិត្យទៅលើលិខិតប្រគល់សិទ្ធិ ហើយបន្ទាប់មក ដីកាត្រូវបញ្ជូនឲ្យតែអ្នកតំណាងដោយអាណត្តិ (មេធាវី) បានហើយ ហើយអានុភាពតាមផ្លូវច្បាប់នឹងកើតមានឡើងនៅពេលដែលអ្នកតំណាងដោយអាណត្តិ (មេធាវី) បានទទួលដីកានោះ។

**សំណួរ ៣២**

**អ្នកបញ្ជូនបានធ្វើការបញ្ជូនទៅដល់ជនដែលត្រូវទទួលការបញ្ជូន ហើយបានអោយជននោះចុះហត្ថលេខាលើលិខិតដែលត្រូវបញ្ជូន និងរបាយការណ៍នៃការបញ្ជូន។ តើការអនុវត្តបែបនេះ មានការខុសឆ្គងនឹងនីតិវិធីរដ្ឋប្បវេណីដែរឬទេ?**

**ចម្លើយ**

ចំពោះករណីនេះ ផ្អែកតាមមាត្រា ២៥៤ កថាខណ្ឌទី ២ ចំណុច ច គឺតម្រូវឲ្យអ្នកទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវធ្វើរបាយការណ៍ ហើយត្រូវឲ្យជនដែលត្រូវទទួលការបញ្ជូននេះចុះហត្ថលេខា ឬផ្ដិតស្នាមមេដៃលើរបាយការណ៍បញ្ជូននោះជាការគ្រប់គ្រាន់ ដោយមិនចាំបាច់តម្រូវឲ្យអ្នកទទួលការបញ្ជូនចុះហត្ថលេខា ឬផ្ដិតស្នាមមេដៃនៅលើឯកសារដែលត្រូវធ្វើការបញ្ជូននោះទេ។

ក៏ប៉ុន្តែ ក្នុងករណីដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនធ្វើដូច្នេះក្នុងនីតិវិធី ក៏ពុំមានកំហុសឆ្គងអ្វីដែរ។

**សំណួរ ៣៣**

**តើការបញ្ជូនដោយការប្រគល់ ចាំបាច់ត្រូវបិទផ្និតដោយស្រោមសំបុត្រដែរឬទេ? ការបញ្ជូនដោយគ្មានស្រោមសំបុត្រ ដោយអ្នកទទួលជំនួស ឬដោយទុកចោល តើប៉ះពាល់ដល់សិទ្ធិបុគ្គលភាពឯកជនរបស់ជនដែលត្រូវទទួលការបញ្ជូនដែរឬទេ?**

**ចម្លើយ**

ករណីនេះ ដើម្បីឲ្យមានភាពហ្មត់ចត់ និងបង្ហាញពីការយកចិត្តទុកដាក់ មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូនគប្បីត្រូវរៀបចំឯកសារដែលត្រូវទទួលការបញ្ជូនឲ្យមានសណ្ដាប់ធ្នាប់ ដាក់ស្រោមសំបុត្រ បិទភ្ជិតឲ្យបានត្រឹមត្រូវ មុននឹងប្រគល់ឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ដើម្បីបង្ហាញពីការយកចិត្តទុកដាក់ ឬក៏ធ្វើឲ្យមានភាពងាយស្រួលនៅក្នុងការបញ្ជូនផងដែរ។

ដូច្នេះ ដើម្បីជៀសវាងបញ្ហាបែកធ្លាយនូវឯកសារដែលត្រូវបញ្ជូន ឯកសារដែលត្រូវធ្វើការបញ្ជូនគប្បីបិទជិតដាក់ក្នុងស្រោមសំបុត្រ។

**សំណួរ ៣៤**

**នៅក្នុងករណីដែលដីកាសម្រេច ត្រូវបានបញ្ជូនទៅចុងចម្លើយ ប៉ុន្តែ ចុងចម្លើយជេប្រមាថ មើលងាយ និង ប្រលែងផ្តែឲ្យខាំ។ អ្នកបញ្ជូនដីកាសម្រេច បានសរសេរហេតុការណ៍នេះនៅក្នុងរបាយការណ៍ ដែលត្រូវបញ្ជូនមកតុលាការវិញ។ តើការបញ្ជូននៅក្នុងករណីនេះ មានអានុភាពដែរឬទេ ?**

**ចម្លើយ**

ការបញ្ជូននៅក្នុងករណីនេះមានអានុភាព ដោយមន្ត្រីទទួលបន្ទុកការបញ្ជូន ទុកដីកាសម្រេចនោះចោលនៅទីនោះ (មាត្រា ២៥២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) រួចហើយសរសេរហេតុការណ៍នេះនៅក្នុងរបាយការណ៍បញ្ជូន (មាត្រា ២៥៤ កថាខណ្ឌទី ២ ចំណុច ឆ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**សំណួរ ៣៥**

**ដីកាកោះ ត្រូវបានបញ្ជូនឲ្យទៅលោក A។ នៅពេលអាជ្ញាសាលាទៅដល់ផ្ទះ ឬទីសំណាក់របស់លោក A គឺមិនបានជួបលោក A ទេ ប៉ុន្តែបានជួបកញ្ញា B ដែលជាអ្នកបម្រើ។ កញ្ញា B បដិសេធមិនហ៊ានទទួលទេ ដោយសំអាងហេតុថា លោក A បានហាមដាច់ខាត មិនឲ្យទទួលរាល់ឯកសារទាំងអស់ តើដីកាសម្រេចនោះ អាចទុកចោលបានដែរឬទេ?**

**ចម្លើយ**

"អ្នកបម្រើតាមផ្ទះ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ" គឺសំដៅលើបុគ្គល ដែលត្រូវបានជួលដោយជនត្រូវទទួលការបញ្ជូន ឬបុគ្គលដែលពាក់ព័ន្ធនឹងកិច្ចការជំនួញរបស់ជនដែលត្រូវទទួលការបញ្ជូន។ ជាធម្មតា អ្នកបម្រើ គឺជា "អ្នកបម្រើតាមផ្ទះ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ"។ នៅក្នុងករណីនេះ ប្រសិនបើអ្នកបម្រើមានការយល់ដឹងសមរម្យក្នុងការទទួលដីកាកោះ នោះមន្ត្រីទទួលបន្ទុកការបញ្ជូនអាចទុកដីកាសម្រេចចោលនៅទីនោះបាន ព្រោះការបដិសេធរបស់កញ្ញា B នេះមិនមានមូលហេតុត្រឹមត្រូវទេ (មាត្រា ២៥២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងករណីដែលអ្នកបម្រើនោះ មិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូន គប្បីពន្យល់នូវខ្លឹមសារនៃឯកសារ នៅពេលប្រគល់ឯកសារ (ប្រៀបធៀបមាត្រា ២៤៧ កថាខណ្ឌទី ៣)។

**សំណួរ ៣៦**

**ប្រសិនបើអ្នកបញ្ជូនដីកាសម្រេច ឬដីកាកោះ បានយកឯកសារទៅដល់ទីកន្លែង ប៉ុន្តែ មិនបានជួបអ្នកណាម្នាក់សោះ ឬផ្ទះនោះបិទទ្វារចោល ឬជួលឲ្យអ្នកផ្សេងស្នាក់នៅ ហើយមិនអាចទំនាក់ទំនងបានជាមួយម្ចាស់ផ្ទះទេ។ តើអ្នកបញ្ជូនអាចទុកដីកានោះចោលបានដែរឬទេ ?**

**ចម្លើយ**

ដីកានេះ មិនអាចទុកចោលនៅទីនោះបានទេ។ យើងអាចទុកចោលបាន លុះត្រាតែ យើងយកដីកាសម្រេចនោះទៅជួបអ្នកដែលត្រូវទទួលហើយ ឬអ្នកនៅជាមួយជាដើម ប៉ុន្តែ អ្នកទាំងនោះមិនព្រមទទួលដោយគ្មានមូលហេតុសមរម្យ ឬនៅក្នុងករណីដែលភាគី បានជូនដំណឹងអំពីកន្លែងបញ្ជូនទៅតុលាការ ទើប

យើងអាចទុកដីកាសម្រេចចោលនៅទីនោះបាន។ នៅក្នុងករណីសំណួរនេះ គឺយើងមិនអាចទំនាក់ទំនងបាននោះទេ ដូចនេះ ជាដំបូងយើងត្រូវស្វែងរកមូលហេតុ ដែលក្រឡាបញ្ជីមិនអាចបញ្ជូនឯកសារ។

នៅក្នុងករណីដែលអាសយដ្ឋាននេះ គឺពិតជាកន្លែងបញ្ជូន (សូមមើលមាត្រា ២៤៩ នៃក្រមរដ្ឋប្បវេណី) ហើយ ក្រឡាបញ្ជីមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូន ឧទាហរណ៍ គាត់តែងតែចេញទៅក្រៅបាត់ នៅពេលដែលក្រឡាបញ្ជីយកឯកសារទៅ ហើយទោះបីជាក្រឡាបញ្ជីបានព្យាយាមច្រើនដងក៏ដោយ ដូច្នេះដីកានេះត្រូវបញ្ជូនតាមការផ្សាយជាសាធារណៈ តាមពាក្យសុំ ដោយទទួលការអនុញ្ញាតពីតុលាការ (មាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី) បន្ទាប់ពីប្រកាសផ្សាយជាសាធារណៈហើយ ក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យមួយទៅអ្នកដែលត្រូវទទួលការ បញ្ជូនឲ្យបានដឹងពីហេតុការណ៍ដែលបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈនោះ (មាត្រា ២៥៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងករណីដែលភាគីផ្លាស់ប្តូរលំនៅឋាន តុលាការត្រូវស្រាវជ្រាវលំនៅឋានថ្មីរបស់ជននោះ។ នៅក្នុងករណីដែលតុលាការស្វែងរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬកន្លែងផ្សេងទៀត ដែលត្រូវធ្វើការបញ្ជូន នៅតែមិនឃើញ បន្ទាប់ពីបានខិតខំប្រឹងប្រែង នោះដីកា ត្រូវនេះ ត្រូវធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ តាមសុំ ដោយទទួលការអនុញ្ញាតពីតុលាការ (មាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច ក)។

**សំណួរ ៣៧**

**ក្រឡាបញ្ជី បានបញ្ជូនដីកាដល់ផ្ទះគូភាគីហើយ ប៉ុន្តែ អាសយដ្ឋានត្រូវបានផ្លាស់ប្តូរ។ តើក្រឡាបញ្ជីត្រូវធ្វើយ៉ាងដូចម្តេចបន្ទាប់មកទៀត?**

**ចម្លើយ**

ជាគោលការណ៍តាមមាត្រា ២៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការបញ្ជូនយើង ត្រូវបញ្ជូនទៅកាន់លំនៅដ្ឋានរបស់ភាគី ដូចនេះករណីសំណួរនេះយើងត្រូវប្រាកដថាទីតាំងផ្ទះ ដែលយើងត្រូវបញ្ជូនទៅនោះ គឺជាលំនៅឋានរបស់ភាគីដែលត្រូវទទួលការបញ្ជូន។ ប្រសិនបើ ទីតាំងផ្ទះដែលយើងត្រូវបញ្ជូនទៅនោះ ពិតជាលំនៅឋានរបស់ភាគីដែលត្រូវទទួលការបញ្ជូនហើយ ប៉ុន្តែអាសយដ្ឋានត្រូវបានផ្លាស់ប្តូរ នោះយើងត្រូវធ្វើការបញ្ជូនដីកានោះតាមការផ្សាយជាសាធារណៈតាមពាក្យសុំ នៅក្នុងករណីដែលតុលាការទទួលស្គាល់ថាទីកន្លែងបញ្ជូននៅតែរកមិនឃើញ បន្ទាប់ពីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវ (មាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**សំណួរ ៣៨**

**ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ តើការបង្គាប់ឲ្យផ្សាយជាសាធារណៈ អាចធ្វើឡើងដោយផ្ទាល់មាត់ ឬត្រូវធ្វើជាលាយលក្ខណ៍អក្សរ ?**

**ចម្លើយ**

ការបង្គាប់ឲ្យផ្សាយជាសាធារណៈ អាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ជាលាយលក្ខណ៍អក្សរក៏បាន ព្រោះ មាត្រា ២៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពុំបានចែងកំណត់ថាការបង្គាប់ឲ្យផ្សាយជាសាធារណៈត្រូវធ្វើ

ផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរនោះទេ។ ក៏ប៉ុន្តែ ដើម្បីបញ្ជាក់អំពីនីតិវិធីនៅក្នុងសំណុំរឿង គប្បីធ្វើជាលាយលក្ខណ៍អក្សរ។

**សំណួរ ៣៩**

**តើប្រកាសស្តីពីការជូនដំណឹងតាមការផ្សាយជាសាធារណៈ ក្រៅពីដីកាកោះមានទម្រង់ដូចម្តេច? តើត្រូវចុះហត្ថលេខាដោយអ្នកណា?**

**ចម្លើយ**

ចំពោះប្រកាសស្តីពីការជូនដំណឹងតាមការផ្សាយជាសាធារណៈ ក្រៅពីដីកាកោះ ពុំទាន់មានទម្រង់ច្បាស់លាស់សម្រាប់ការអនុវត្តជាទូទៅនោះទេ ក៏ប៉ុន្តែក្នុងលិខិតជូនដំណឹងនេះ គប្បីសសេរចូលនូវចំណុចសំខាន់ៗមួយចំនួនដូចជា៖

- ចំណងជើង ៖ សេចក្តីជូនដំណឹងអំពីការផ្សាយជាសាធារណៈ
- មូលហេតុនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ
- ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលត្រូវទទួលការបញ្ជូន
- សញ្ញាណនៃរឿងក្តី
- កាលបរិច្ឆេទនៃនីតិវិធី និង
- ខ្លឹមសារនៃឯកសារ ៖ តើឯកសារណាដែលត្រូវធ្វើការបញ្ជូនតាមរយៈការផ្សាយជាសាធារណៈ
- សិទ្ធិទទួលបានឯកសាដែលរក្សាទុកដោយក្រឡាបញ្ជី រួមទាំងចំណុចផ្សេងៗទៀតដែលយល់ថាចាំបាច់។

ក្រឡាបញ្ជីដែលធ្វើកិច្ចការនេះ ត្រូវចុះហត្ថលេខាលើលិខិតជូនដំណឹងនោះ។

**សំណួរ ៤០**

**តាមរយៈការផ្សាយជាសាធារណៈ តើត្រូវចុះកាសែត ឬ យ៉ាងណា?**

**ចម្លើយ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ (ក្រមនីតិវិធិរដ្ឋប្បវេណី មាត្រា ២៥៦ កថាខណ្ឌទី១ )។ ម្យ៉ាងវិញទៀត តុលាការអាចចុះនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារៈហើយ (ក្រមនីតិវិធិរដ្ឋប្បវេណី មាត្រា ២៥៦ កថាខណ្ឌទី៣ ) ប៉ុន្តែក៏ពុំមានបញ្ញត្តិណាដែលចែងថា តុលាការចាំបាច់ត្រូវតែចុះក្នុងកាសែតឡើយ។ ដូច្នេះ តុលាការអាចចុះក្នុងសារព័ត៌មាន ផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារៈហើយ ឬ មិនបាច់ចុះក៏បានដែរ។

**សំណួរ ៤១**

**សូមពិព៌ណនាអំពីនីតិវិធីទាំងមូលនៃការបញ្ជូនទៅបរទេស។ តើត្រូវបញ្ជូនតាមរយៈក្រសួងយុត្តិធម៌ បានដែរឬទេ ? តើតុលាការកម្ពុជាត្រូវបកប្រែឯកសារដែលត្រូវបញ្ជូនជាភាសាបរទេស ឬ ទេ ?**

**ចម្លើយ**

ផ្អែកតាមខ្លឹមសារនេះ ថាខណ្ឌទី ១ នៃមាត្រា ២៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា "ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស តុលាការ ត្រូវប្រគល់កិច្ចការនេះឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬឯកអគ្គរាជទូត ឬភារធារី ឬកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសនោះឲ្យធ្វើបាន"។ ផ្អែកតាមខ្លឹមសារនៃបទបញ្ញត្តិនេះ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូនមានលំនៅឋាននៅបរទេស ហើយពុំមានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនចំពោះជននោះ ត្រូវធ្វើការបញ្ជូនទៅប្រទេសរបស់ជននោះរស់នៅ។ ក្នុងករណីនេះ ការបញ្ជូនមាន ០២ របៀបៈ

របៀបទី ១៖ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូនជាជនបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចតាមផ្លូវច្បាប់ ឬស្ថាប័នកណ្តាលនៃប្រទេសនោះ ជាអ្នកអនុវត្តការបញ្ជូន (ប៉ុន្តែ ប្រសិនបើប្រទេសនោះអនុញ្ញាត គេអាចប្រើការបញ្ជូនរបស់ឯកអគ្គរាជទូត ឬភារធារី ឬកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសនោះបាន)។

របៀបទី ២៖ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស ជាទូទៅគប្បីបញ្ជូនដោយប្រគល់ឲ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ព្រះរាជណាចក្រកម្ពុជាប្រចាំប្រទេសនោះ ជាអ្នកអនុវត្តការបញ្ជូន (ប៉ុន្តែ បើសិនជាមានការសហការពីប្រទេសនោះ គេអាចប្រើការបញ្ជូនរបស់ស្ថាប័នដែលមានសមត្ថកិច្ចតាមផ្លូវច្បាប់ ឬស្ថាប័នកណ្តាលនៃប្រទេសនោះបាន)។

តាមសារាចរណ៍ណែនាំរបស់ក្រសួងយុត្តិធម៌ (លេខ ១៤៤៨ កយ អក/០៦ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៦) រាល់លិខិតដែលតុលាការ ត្រូវធ្វើការបញ្ជូនទៅក្រសួង ឬ ស្ថាប័នដទៃ ត្រូវធ្វើតាមរយៈក្រសួងយុត្តិធម៌។

ប៉ុន្តែ ការបញ្ជូនចំពោះបុគ្គលដែលនៅបរទេស ត្រូវមានការអនុញ្ញាតពីប្រទេសនោះជាដាច់ខាត។ ដូច្នេះ តុលាការត្រូវពិនិត្យថា តើព្រះរាជាណាចក្រកម្ពុជា និងប្រទេសនោះ មានសន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀង ឬការជួយគ្នាទៅវិញទៅមកស្តីពីវិស័យរដ្ឋប្បវេណីឬទេ? ប្រសិនបើមាន តុលាការត្រូវពិនិត្យមើលថា សន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀង ឬការជួយគ្នាទៅវិញទៅមកស្តីពីវិស័យរដ្ឋប្បវេណី មានចែងអំពីការបញ្ជូនដែរឬទេ។ ប្រសិនបើមានចែងអំពីការបញ្ជូន តុលាការត្រូវធ្វើការបញ្ជូនតាមខ្លឹមសារដែលបានកំណត់នៅក្នុងសន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀង ឬការជួយគ្នាទៅវិញទៅមកស្តីពីវិស័យរដ្ឋប្បវេណីនោះ។ ប្រសិនបើ ព្រះរាជាណាចក្រកម្ពុជា និងប្រទេសនោះ ពុំមានសន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀង ឬការជួយគ្នាទៅវិញទៅមកស្តីពីវិស័យរដ្ឋប្បវេណីទេ ឬប្រសិនបើសន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀង ឬការជួយគ្នាទៅវិញទៅមកស្តីវិស័យរដ្ឋប្បវេណី ពុំបានកំណត់អំពីវិធាននៃការបញ្ជូនទេ តុលាការអាចសាកសួរយោបល់ទៅស្ថានទូត ស្ថានកុងស៊ុល ឬ ភារធារីនៃប្រទេសនោះថា អាចធ្វើការបញ្ជូនបានដែរឬទេ? ប្រសិនបើស្ថានទូត ស្ថានកុងស៊ុល ឬ ភារធារីនៃប្រទេសនោះឆ្លើយថា មិនអាចធ្វើការបញ្ជូនបានទេ ការបញ្ជូនត្រូវធ្វើឡើងតាមរបៀបការបញ្ជូនតាមការផ្សាយជាសាធារណៈ ផ្អែកតាមមាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ភាសាដែលត្រូវប្រើប្រាស់នៅក្នុងតុលាការកម្ពុជា គឺជាភាសាខ្មែរ ( មាត្រា ៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយពុំមានមាត្រាណាមួយក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលតម្រូវឲ្យបកប្រែឯកសារដែលត្រូវបញ្ជូនទៅបរទេសនោះឡើយ។ ប៉ុន្តែ ប្រសិនបើសន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀង ឬការជួយគ្នាទៅវិញទៅមកស្តីពីវិស័យរដ្ឋប្បវេណី តម្រូវឲ្យបកប្រែឯកសារបញ្ជូន តុលាការត្រូវធ្វើតាមវិធាននោះ។

**សំណួរ ៤២**

**សូមពន្យល់អត្ថន័យនៃមាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច ឃ។**

**ចម្លើយ**

អត្ថន័យមាត្រា២៥៥ កថាខណ្ឌទី១ ចំណុច ឃ មានន័យថា ៖

ករណីនេះ ជាលក្ខខណ្ឌមួយសម្រាប់ធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ដូច្នេះ ចំណុច (ឃ) គឺមានន័យថា ប្រសិនបើបានធ្វើការបញ្ជូនប្រគល់ឲ្យក្រសួង ឬស្ថាប័ន ដែលមានសមត្ថកិច្ចនៅបរទេស ឲ្យធ្វើតាមបញ្ញត្តិនៃមាត្រា ២៥៣ រួចហើយ ហើយតុលាការមិនបានទទួលលិខិតបញ្ជាក់អំពីការបញ្ជូននោះក្នុងអំឡុងពេល៦ (ប្រាំមួយ) ខែ ចាប់តាំងពីពេលបញ្ជូននោះមក គឺជាលក្ខខណ្ឌមួយដែលអនុញ្ញាតឲ្យតុលាការធ្វើនីតិវិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈបាន។ ដូច្នេះហើយ ក៏អាចបកស្រាយបានដែរថា បើមិនទាន់ដល់អំឡុងពេល៦ខែទេ តុលាការក៏មិនអាចធ្វើនីតិវិធីបញ្ជូន តាមការផ្សាយជាសាធារណៈដែរ គប្បីរង់ចាំដំណឹង ឬលិខិតបញ្ជាក់អំពីការបញ្ជូនដែលបានធ្វើកន្លងមកនោះសិន។

**សំណួរ ៤៣**

**ប្រសិនបើចុងចម្លើយរស់នៅបរទេស តើតុលាការគប្បីកំណត់រយៈពេលប៉ុន្មាន ដើម្បីឲ្យចុងចម្លើយអាចចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ?**

**ចម្លើយ**

ចំពោះការបញ្ជូនដែលមានចុងចម្លើយរស់នៅបរទេស ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ពុំមានមាត្រាណាមួយកំណត់អំឡុងពេលជាក់លាក់នោះទេ។

ផ្អែកតាមមាត្រា ៨០ នៃក្រមនីតិវិធី អំឡុងពេលនៃការកោះហៅបានកំណត់រយៈពេល៣០ថ្ងៃ ក៏ប៉ុន្តែក៏មានចំណុចលើកលែងដែរ ដែលអនុញ្ញាតឲ្យធ្វើការកោះហៅលើសពីអំឡុងពេល៣០ថ្ងៃដែរ ក្នុងករណីដែលមានមូលហេតុពិសេស។

ហេតុដូច្នេះ ចំណុចនៃការបញ្ជូនទៅបរទេស ក៏អាចបកស្រាយក្នុងមូលហេតុពិសេស នេះបានដែរ។

ដោយឡែក ផ្អែកលើមាត្រា ២៥៥ ចំណុច ឃ (អំឡុងពេលដែលអាចធ្វើនីតិវិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ) បានកំណត់អំឡុងពេល ៦ខែ។

ដូច្នេះ ចំពោះអំឡុងពេលនេះ ពុំមានការកំណត់ជាក់លាក់នោះទេ គឺតុលាការត្រូវពិចារណាស្ថានភាពនៃរឿងក្តី ការត្រៀមការពារខ្លួនរបស់ចុងចម្លើយ ចំនួនចុងម្លើយ ចម្ងាយនៃប្រទេសដែលចុងចម្លើយស្ថិតនៅ ឬក៏រយៈពេលសម្រាប់ធ្វើកិច្ចការបញ្ជូននេះចំពោះក្រសួង ឬ ស្ថាប័ននៅក្នុងប្រទេស និងក្រសួង ឬស្ថាប័ននៅបរទេសដែលទទួលបន្ទុក និងប្រតិបត្តិនូវកិច្ចការនេះ។

ដូច្នេះ ជារួមតុលាការគប្បីពិចារណាអំពីស្ថានភាពទាំងឡាយខាងលើ ដើម្បីធ្វើការកំណត់អំឡុងពេលសមរម្យដែលអនុញ្ញាឲ្យចុងចម្លើយអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមនីតិវិធីរបស់តុលាការបាន។

**សំណួរ ៤៤**

**ប្រពន្ធជាជនជាតិខ្មែរ បានរៀបអាពាហ៍ពិពាហ៍ជាមួយប្តីជាជនជាតិបារាំង ហើយប្តីបានត្រឡប់ទៅប្រទេសបារាំងវិញ ដោយគ្មានទាក់ទង និងផ្តល់ដំណឹងមកប្រពន្ធសោះ។ ប្រពន្ធបានដាក់ពាក្យបណ្តឹងទៅតុលាការសុំលែងលះ តែប្រពន្ធមិនស្គាល់ពីអាសយដ្ឋានរបស់ប្តីទេ។ តើតុលាការ ត្រូវធ្វើការប្រកាសស្តីពីការបាត់ខ្លួន ឬ ធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ?**

**ចម្លើយ**

តុលាការមិនត្រូវធ្វើការប្រកាសអំពីការបាត់ខ្លួនប្តីដែលជាជនជាតិបារាំងទេ ព្រោះថា ការប្រកាសអំពីការបាត់ខ្លួនត្រូវធ្វើឡើងនៅពេលដែលមានពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជនដូចមានបញ្ញត្តក្នុងកថាខណ្ឌទី ១ មាត្រា ៤១ នៃក្រមរដ្ឋប្បវេណី ហើយដើម្បីអាចប្រកាស អំពីការបាត់ខ្លួននេះ ត្រូវមានលក្ខខណ្ឌដែលបញ្ញត្តក្នុងមាត្រា ៤១ នៃក្រមរដ្ឋប្បវេណីទើបតុលាការអាចធ្វើការប្រកាសអំពីការបាត់ខ្លួនប្តីជនជាតិបារាំងបាន។

ប្រពន្ធអាចដាក់ពាក្យបណ្តឹងលែងលះទៅសាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅដ្ឋានរបស់ប្រពន្ធ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០ កថាខណ្ឌទី ១។ តុលាការមានភាពចាំបាច់ក្នុងការបញ្ជូនពាក្យបណ្តឹង និងដីកាកោះទៅប្តី ប៉ុន្តែ លំនៅដ្ឋានរបស់ប្តីពុំមានភាពច្បាស់លាស់ឡើយ។ ប្រសិនបើ បានដឹងទីសំណាក់របស់ប្តី តុលាការនឹងធ្វើការបញ្ជូនទៅទីសំណាក់នោះ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៤៩) ។ ប្រសិនបើទីសំណាក់នៅប្រទេសបារាំង នឹងធ្វើការបញ្ជូនដោយការបញ្ជូនដែលត្រូវធ្វើនៅបរទេស(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៥៣)។ ប្រសិនបើ បានធ្វើការស្រាវជ្រាវដោយសមរម្យហើយ នៅតែមិនអាចរកឃើញលំនៅដ្ឋាន ឬក៏ទីសំណាក់របស់ប្តី តុលាការអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈតាមពាក្យសុំរបស់ប្រពន្ធ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុចទី១) ។

ពាក្យបណ្តឹងដែលដើមចោទប្តឹងសុំលែងលះចុងចម្លើយ ដើមចោទត្រូវសរសេរអំពីអាសយដ្ឋានរបស់ចុងចម្លើយ ផ្អែកតាមចំណុច ក កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែ ដោយសារតែអាសយដ្ឋានរបស់ប្តីមិនច្បាស់លាស់ ដើមចោទអាចសរសេរនៅក្នុងពាក្យបណ្តឹងថា "អាសយដ្ឋានមិនច្បាស់លាស់" ក៏បានដែរ។ ប៉ុន្តែ ក្នុងករណីដែលបានដឹងអំពីទីសំណាក់របស់ប្តី ប្រពន្ធត្រូវសរសេរទីសំណាក់របស់ប្តី (ក្រមរដ្ឋប្បវេណីមាត្រា ៣៦) ហើយប្រសិនបើមិនបានដឹងអំពីទីសំណាក់របស់ប្តី ប្រពន្ធត្រូវសរសេរលំនៅដ្ឋានចុងក្រោយ (លំនៅដ្ឋានដែលប្តីនិងប្រពន្ធបានរស់នៅជាមួយគ្នាក្នុងព្រះរាជាណាចក្រកម្ពុជា) របស់ប្តី (យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០ កថាខណ្ឌទី ២)។

**សំណួរ ៤៥**

**តើសាលាឧទ្ធរណ៍ អាចសម្រេចអំពីមោឃភាពបានដែរឬទេ នៅពេលដែលក្រឡាបញ្ជីចារស្លាពរលើសាលក្រម ខុសនីតិវិធី ឬមានកំហុស?**

**ចម្លើយ**

ករណីដែលក្រឡាបញ្ជីបានចារស្លាពរលើសាលក្រមដោយខុសនីតិវិធី ឬ មានកំហុស សាលាឧទ្ធរណ៍

មិនអាចសម្រេចករណីនេះបានទេ ពោល គឺត្រូវអនុវត្តតាមមាត្រា ២១៥ (បណ្ដឹងតវ៉ាអំពីការចាត់ចែងរបស់ក្រឡាបញ្ជី) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សំណួរ ៤៦**

**តើតុលាការកំណត់ចំណុចវិវាទនៅពេលណា?**

**ចម្លើយ**

តុលាការកំណត់ចំណុចវិវាទ នៅក្រោយពេលដែលតុលាការបានរៀបចំការអះអាងរបស់គូភាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១០៧ មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**សំណួរ ៤៧**

**តើសុំកូនអាចសុំកូនបានចំនួនប៉ុន្មាន បើច្បាប់មិនបានចែងកំណត់ផងនោះ?**

**ចម្លើយ**

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មិនបានបញ្ញត្តកម្រិតអំពីចំនួនកូនសុំ ដែលបុគ្គលម្នាក់អាចសុំបាននោះទេ។ ដូច្នេះ បុគ្គលម្នាក់អាចសុំកូនបានច្រើននាក់ ប្រសិនបើតុលាការដែលសម្រេចបង្កើតសុំកូនយល់ឃើញថា មានភាពចាំបាច់ដើម្បីផលប្រយោជន៍របស់កូន។

**សំណួរ ៤៨**

**ជាធម្មតា នៅពេលប្រជាពលរដ្ឋចង់បង្កើតសុំកូន ពួកគាត់តែងតែទៅសាលាឃុំ ប៉ុន្តែមិនទៅតុលាការ។ បន្ទាប់មក ពួកគាត់បានធ្វើកិច្ចសន្យាទាក់ទងនឹងសុំកូននៅសាលាឃុំ។ តើសុំកូននេះអាចត្រូវបានទទួលស្គាល់ដោយច្បាប់ ?**

**ចម្លើយ**

ករណីដែលឪពុកម្ដាយចិញ្ចឹមមានបំណងចង់បង្កើតកូនសុំ រួមទាំងសុំកូនពេញលេញ និងសុំកូនធម្មតា គឺ តម្រូវឲ្យឪពុកម្ដាយចិញ្ចឹមនោះ ដាក់ពាក្យសុំទៅតុលាការ ដោយយោងតាមមាត្រា ១០០៧ និង មាត្រា ១០២០ នៃក្រមរដ្ឋប្បវេណី ។ ចំពោះការបង្កើតសុំកូន ដែលឪពុកម្ដាយចិញ្ចឹមបានដាក់ពាក្យសុំនៅសាលាឃុំ គឺសាលាឃុំពុំមានសមត្ថកិច្ចតាមច្បាប់ឡើយ។

**សំណួរ ៤៩**

**សូមពិព៌ណនាអំពីនីតិវិធីក្នុងការផ្លាស់ត្រកូល ក្នុងករណីសុំកូន ឬ កាត់កាល់សុំកូនធម្មតា ។**

**ចម្លើយ**

ករណីមានពាក្យសុំ តុលាការនឹងសម្រេចដោយចេញដីកាលើកចោលពាក្យសុំ ព្រោះការសុំផ្លាស់ប្ដូរឈ្មោះមិនមាននៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីរឿងក្ដីរដ្ឋប្បវេណីមិនមែនបណ្ដឹងទេ ប៉ុន្តែ តុលាការគួរគប្បី

សរសេរពន្យល់នៅក្នុងសំអាងហេតុ អំពីភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានក្នុងការផ្លាស់ប្តូរត្រកូលតាមអានុភាព នៃដីកាសម្រេចសុំកូន ឬ កាត់ កាល់សុំកូនធម្មតា និង មាត្រា ១០១៥ កថាខណ្ឌទី ២ មាត្រា ១០២៧ កថាខណ្ឌទី ២ និង មាត្រា ១០៣២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។

**សំណួរ ៥០**

**តួនាទីរបស់តំណាងអយ្យការ នៅក្នុងករណីដែលឪពុកបង្កើត ប្រព្រឹត្តិអំពើអនាចារលើកូនស្រីបង្កើតរបស់ខ្លួន។**

**ចម្លើយ**

នៅក្នុងករណីដែលឪពុកបង្កើតបានប្រព្រឹត្តអំពើអនាចារ មកលើកូនស្រីបង្កើត តំណាងអយ្យការដែលជាម្ចាស់បណ្តឹងអាជ្ញា មានតួនាទីជាអ្នកចោទប្រកាន់លើឪពុកបង្កើតពីបទល្មើសព្រហ្មទណ្ឌ ដែលគាត់បានប្រព្រឹត្តទៅលើកូនស្រីរបស់គាត់ ស្របទៅតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

ប្រសិនបើរឿងហេតុបែបនេះកើតឡើងរវាងឪពុកចិញ្ចឹម និង កូនស្រីដែលជាកូនសុំពេញលេញវិញ តំណាងអយ្យការដែលបានដឹងពីអត្ថិភាពនៃអំពើប្រព្រឹត្តដែលប៉ះពាល់ផលប្រយោជន៍របស់កូនសុំ អាចដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់សុំកូនពេញលេញបាន ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១០១៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។ ក៏ប៉ុន្តែ បណ្តឹងទាមទារកាត់កាល់សុំកូនពេញលេញ នឹងទទួលបានជោគជ័យ ប្រសិនបើមានគ្រប់លក្ខខណ្ឌដែលបានកំណត់ នៅក្នុងបញ្ញត្តិនៃមាត្រាខាងលើនេះ។

**សំណួរ ៥១**

**តើបងប្អូនបង្កើតអាចសុំកូនបានដែរឬទេ?**

**ចម្លើយ**

ក្រមរដ្ឋប្បវេណីមិនបានហាមឃាត់ការបង្កើតសុំកូន រវាងបុគ្គលដែលមានទំនាក់ទំនងញាតិលោហិតជាមួយគ្នានោះទេ ឲ្យតែបំពេញនូវរាល់លក្ខខណ្ឌដែលក្រមរដ្ឋប្បវេណីតម្រូវ គឺជាការគ្រប់គ្រាន់ហើយ។ ដូច្នេះ ប្រសិនបើនារីម្នាក់មានបំណងចង់សុំយកកូនរបស់បងស្រីបង្កើតរបស់គាត់ មកធ្វើជាកូនសុំ គាត់ប្រាកដជាអាចធ្វើបាន ប្រសិនបើបានបំពេញនូវរាល់លក្ខខណ្ឌពាក់ព័ន្ធនឹងសុំកូន។

**សំណួរ ៥២**

**ឪពុកម្តាយបង្កើត ចង់បង្កើតសុំកូនពេញលេញជាមួយនឹងឪពុកម្តាយចិញ្ចឹម។ ទាំងឪពុកម្តាយចិញ្ចឹម និង ឪពុកម្តាយបង្កើតគឺក្រីក្រ។ តើពួកគាត់អាចបង្កើតសុំកូនពេញលេញបានដែរឬទេ?**

**ចម្លើយ**

គោលបំណងដើម្បីបង្កើតសុំកូនពេញលេញ គឺដើម្បីផ្តល់ឱ្យកុមារនូវគ្រួសារកក់ក្តៅដ៏ល្អមួយ។ ក្រមរដ្ឋប្បវេណីពុំបានបង្កើតលក្ខខណ្ឌជីវភាពរបស់ឪពុកម្តាយចិញ្ចឹមថាត្រូវតែជាអ្នកមាននោះឡើយ ពោលគឺពួក

គេអាចនឹងបង្កើតស៊ុំកូនពេញលេញបាន។ ប៉ុន្តែមាត្រា១០១២ នៃក្រមនេះ បានបញ្ជាក់ថាស៊ុំកូនពេញលេញត្រូវបានបង្កើត ក្នុងករណីដែលឪពុកម្ដាយបង្កើតមានការលំបាកក្នុងការគ្រប់គ្រងថែរក្សាកុមារ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍កុមារ ជាដើម ដូចនេះយើងអាចនិយាយបានថាប្រសិនបើឪពុកម្ដាយបង្កើតដែលមានជីវភាពក្រីក្រ មានការពិបាកក្នុងការថែទាំកុមារ អាចនឹងបង្កើតស៊ុំកូនជាមួយនឹងឪពុកម្ដាយចិញ្ចឹមបាន ដើម្បីជាប្រយោជន៍ឱ្យដល់កុមារ។ ផ្ទុយទៅវិញប្រសិនបើជីវភាពរបស់ឪពុកម្ដាយចិញ្ចឹមនោះដូចគ្នាទៅនឹងឪពុកម្ដាយបង្កើតទេ វាពុំមានអ្វីជាប្រយោជន៍ឱ្យដល់កុមារនោះឡើយ។

**សំណួរ ៥៣**

**តើបុគ្គលអាយុ ២០ ឆ្នាំ អាចធ្វើជាកូនសុំពេញលេញបានដែរឬទេ?**

**ចម្លើយ**

មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណីបានចែងថា ៖ ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ ឆ្នាំ។ ការប្រើពាក្យ "**ជាគោលការណ៍**" នៅក្នុងបញ្ញត្តិនេះ នាំឲ្យមានការបកស្រាយថា ជាអញ្ញត្រកម្ម កូនសុំអាចមានអាយុលើសពី ៨ ឆ្នាំបាន។ ក៏ប៉ុន្តែព្រមជាមួយគ្នានេះ ក្រមរដ្ឋប្បវេណីមិនបានចែងពីស្ថានភាពដែលអនុញ្ញាតឲ្យតុលាការបង្កើតស៊ុំកូនពេញលេញ កាលបើកូនសុំមានអាយុលើសពី ៨ ឆ្នាំនោះទេ។ ជាងនេះទៅទៀត ក្រមរដ្ឋប្បវេណីក៏មិនបានចែងពីកម្រិតនៃអាយុអតិបរមារបស់កូនសុំ នៅក្នុងករណីអញ្ញត្រកម្មនេះដែរ។

ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើ យើងគួរតែពិនិត្យជាបឋមទៅលើគោលបំណងនៃស៊ុំកូនពេញលេញជាមុនសិន។ ជាការពិត ស៊ុំកូនពេញលេញត្រូវបានបង្កើតឡើង ដើម្បីផ្ដល់នូវគ្រួសារដ៏ពេញលេញ និងមានលំនឹងសម្រាប់កុមារអភ័ព្វ ពោលគឺបង្កើតទំនាក់ទំនងឲ្យដូចគ្នាទៅនឹងទំនាក់ទំនងជាមួយនឹងកូនបង្កើតអញ្ចឹងដែរ។ ការការពារកុមារដែលជាទំពាំងស្នងឬស្សីរបស់ប្រទេសជាតិ គឺជាភាពចាំបាច់ដែលច្បាប់ត្រូវតែលើកស្ទួយ។ នៅពេលដែលបុគ្គលម្នាក់ឈានដល់វ័យនីតិភាពហើយ បុគ្គលនោះចេះគិតគូរពិចារណាដោយខ្លួនឯង ដោយឯករាជ្យ និងមិនចាំបាច់ត្រូវការការថែទាំពីអ្នកដទៃទៀតឡើយ។ ដោយសារតែមូលហេតុនេះហើយ ទើបមាត្រា ១០១០ នៃក្រមរដ្ឋប្បវេណីកំណត់អាយុកូនសុំតិចជាង ៨ ឆ្នាំ បានសេចក្ដីថា កូនសុំគឺជាកុមារនៅតូចដែលត្រូវការជាចាំបាច់នូវការថ្នាក់ថ្នមចិញ្ចឹមបីបាច់ថែរក្សាពីសំណាក់ឪពុកម្ដាយ។

យោងតាមការបកស្រាយខាងលើ ឃើញថា ប្រសិនបើបុគ្គលម្នាក់ឈានដល់អាយុ ២០ ឆ្នាំហើយនោះជាធម្មតា គាត់មិនអាចក្លាយជាកូនសុំពេញលេញបានឡើយ។ ម្យ៉ាងវិញទៀត ទោះបីជាក្នុងស្ថានភាពពិសេសយ៉ាងណាក៏ដោយ នៅពេលដែលគាត់បានក្លាយជានីតិជនហើយនោះ ពុំមានភាពចាំបាច់ត្រូវបង្កើតស៊ុំកូនពេញលេញសម្រាប់គាត់ឡើយ។

ជារួមមក បុគ្គលដែលមានអាយុ ២០ ឆ្នាំ មិនអាចក្លាយជាកូនសុំពេញលេញបានទេ។

**សំណួរ ៥៤**

**ឪពុកម្ដាយចិញ្ចឹម បានយកកូនឈ្មោះ ABC មកចិញ្ចឹមតាំងពីអាយុ ៥ ឆ្នាំ មកម្ល៉េះ។ ពួកគាត់ បានចិញ្ចឹមកូននោះរហូតដល់ធំពេញវ័យ រៀនចប់បរិញ្ញាបត្រជាន់ខ្ពស់។ តើឪពុកម្ដាយចិញ្ចឹម អាចដាក់ពាក្យសុំបង្កើតស៊ុំកូនពេញលេញ ឬ ស៊ុំកូនធម្មតាបានដែរ ឬទេ ?**

**ចម្លើយ**

ឪពុកម្ដាយចិញ្ចឹម អាចបង្កើតស្មុំកូនធម្មតា ប៉ុន្តែមិនអាចបង្កើតស្មុំកូនពេញលេញបានទេ។

វាបង្ហាញបានថា ABC មានអាយុ ២៥ ឆ្នាំ រៀនចប់ master។ ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ ឆ្នាំ មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះបើពិនិត្យមើលអំពីលក្ខខណ្ឌអាយុរបស់កូនសុំ ដោយយោងតាមមាត្រានេះ ឃើញថា មិនអាចទទួលស្គាល់ការសុំបង្កើតស្មុំកូនពេញលេញដោយ XY បានទេ ។ ក៏ប៉ុន្តែក៏មានករណីលើកលែងដែរ ដោយហេតុថា មាត្រា ១០១០ គឺជាគោលការណ៍ប៉ុណ្ណោះ ។ ករណីសំណួរនេះអាចចាត់ទុកបានថា ជាឧទាហរណ៍នៃអង្គហេតុមួយនៃករណីលើកលែងនៃមាត្រា ១០១០។

នៅក្នុងករណីនេះ កូនសុំមានអាយុច្រើនពេក ក្នុងការបង្កើតស្មុំកូនពេញលេញ។ ដូច្នេះ XY មិនអាចដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញបានទេ ប៉ុន្តែអាចបង្កើតស្មុំកូនធម្មតាបាន។

**សំណួរ ៥៥**

**តើព្រះសង្ឃ ឬ ដូនជីអាចបង្កើតស្មុំកូនបានដែរឬទេ?**

**ចម្លើយ**

ព្រះសង្ឃ ឬដូនជី អាចស្មុំកូនបាន ដោយហេតុថា បញ្ញត្តិស្តីពីស្មុំកូន នៃក្រមរដ្ឋប្បវេណី ពុំបានហាមឃាត់ ។ របបស្មុំកូនពេញលេញមានគោលគំនិតផ្ដល់នូវគ្រួសារមួយ ដែលត្រូវមានទាំងឪពុក មានទាំងម្ដាយទាំងពីរ ហើយត្រូវមានស្នេហភាពដល់កុមារអភ័ព្វ ដូច្នេះស្មុំកូនពេញលេញ ឬស្មុំកូនធម្មតាដែលជាអនីតិជនដោយព្រះសង្ឃ ឬដូនជី តុលាការត្រូវពិចារណាឱ្យម៉ត់ចត់បំផុត ។

**សំណួរ ៥៦**

**តើសហព័ន្ធអាចទៅសុំកូនពេញលេញពីមណ្ឌលកុមារកំព្រាបានដែរឬទេ?**

**ចម្លើយ**

ការរកអ្នកស្នងត្រកូល រកអ្នកស្នងទ្រព្យសម្បត្តិ រកឪពុកម្ដាយសម្រាប់កុមារកំព្រា ជាអាទិ៍ គឺជាគោលបំណងនៃស្មុំកូន ។ ចំពោះស្មុំកូនពេញលេញ គឺជារបបសម្រាប់ផ្ដល់គ្រួសារប្រកបដោយសុខដុមរមនាមួយចំពោះកុមារអភ័ព្វ ដែលនឹងក្លាយជាកូនចិញ្ចឹម ឱ្យមានសុខភាពល្អ និងមានអនាគតប្រសើរ ។ ដូច្នេះកុមារដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា អាចជាកម្មវត្ថុនៃស្មុំកូនពេញលេញរបស់សហព័ទ្ធ ក៏ប៉ុន្តែដើម្បីឱ្យមានអានុភាពតាមផ្លូវច្បាប់នូវសិទ្ធិ និងករណីយកិច្ច ត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការ ។

**សំណួរ ៥៧**

**តើពោះម៉ាយអាចស្មុំកូនបានដែរឬទេ?**

**ចម្លើយ**

ដោយហេតុថា ស្មុំកូនពេញលេញ អ្នកដាក់ពាក្យសុំត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ (មាត្រា ១០០៨) ដូច្នេះ បុរសពោះម៉ាយអាចស្មុំកូនបានតែចំពោះស្មុំកូនធម្មតាប៉ុណ្ណោះ (មាត្រា ១០២០ កថាខណ្ឌទី ១)។

**សំណួរ ៥៨**

**ឪពុកម្ដាយចិញ្ចឹម ចង់បង្កើតស្មុំកូនពេញលេញជាមួយកូនសុំ ដែលរស់នៅជាមួយនឹងម្ដាយ ហើយដែលមិនដឹងថាឪពុករស់នៅទីណាទេ។ តើពួកគាត់អាចបង្កើតស្មុំកូនពេញលេញដែរឬទេ? នៅក្នុងករណីដែលស្មុំកូនពេញលេញ ត្រូវបង្កើតហើយ បន្ទាប់មកឪពុកក៏មានវត្តមាន តើឪពុកអាចរំលាយស្មុំកូនពេញលេញដែរឬទេ?**

**ចម្លើយ**

ស្មុំកូនពេលលេញ ជាស្មុំកូនមួយដែលមានលក្ខណៈតឹងរ៉ឹងណាស់ ព្រោះមានលក្ខខណ្ឌច្រើនដែលត្រូវតែបំពេញ។ ស្មុំកូនពេញលេញនេះអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីឪពុកម្ដាយបង្កើត។ ប្រសិនបើគ្មានការយល់ព្រមពីឪពុកទេ ស្មុំកូនពេញលេញពុំអាចធ្វើទៅបានឡើយ។ ស្មុំកូនពេញលេញ នឹងធ្វើអោយចំណងញាតិរបស់កូនសុំ និងឪពុកត្រូវបានកាត់ផ្ដាច់ ដូចនេះ វាប៉ះពាល់ដល់សិទ្ធិអ្នកដែលជាឪពុកយ៉ាងខ្លាំង ប្រសិនបើអនុញ្ញាតិអោយមានស្មុំកូនពេញលេញដោយពុំចាំបាច់មានការយល់ព្រមពីឪពុក។ ប៉ុន្តែ ប្រសិនបើមិនអនុញ្ញាតឱ្យមានការបង្កើតស្មុំកូនពេញលេញទេ នោះកូនសុំអាចនឹងខាតប្រយោជន៍ផងដែរ។ ដូចនេះ ដើម្បីធានាបាននូវផលប្រយោជន៍របស់កូនសុំ មាត្រា១០១១ នៃក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យមានស្មុំកូនពេញលេញបើទោះជាពុំមានការយល់ព្រមពីឪពុកម្ដាយបង្កើតក៏ដោយ។

ចំពោះការសុំរំលាយស្មុំកូនពេញលេញនោះ ឃើញថាក្រមរដ្ឋប្បវេណីពុំបានកំណត់អំពីសិទ្ធិរបស់ឪពុកបង្កើតនោះឡើយ ប៉ុន្តែ ប្រសិនបើឪពុកបង្កើតនោះអាចនឹងមានលទ្ធភាពមើលថែកូនសុំវិញបាន ហើយឪពុកម្ដាយចិញ្ចឹមមើលថែកូនសុំពុំបានល្អ ឪពុកបង្កើតអាចសុំឱ្យមានការកាត់កាលស្មុំកូនពេញលេញ តាមមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី។

**សំណួរ ៥៩**

**សូមពន្យល់នីតិវិធីទាំងមូលនៃមាត្រា ១០១៣ ។**

**ចំលើយ**

លំហូរនៃនីតិវិធី គឺមានដូចខាងក្រោម ៖

| | ភាគី | តុលាការ | តតិយជន, អាជ្ញាធរពាក់ព័ន្ធ |
|---|---|---|---|
| ១ | ដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញ | | |
| ២ | | ពិនិត្យពន្ធដាក់ពាក្យសុំ<br>ពិនិត្យសមត្ថកិច្ច | |

| | | | |
|---|---|---|---|
| | | ពិនិត្យលក្ខខណ្ឌមួយចំនួនដើម្បីទទួលស្គាល់ពាក្យសុំ[1]<br>● លក្ខខណ្ឌទាក់ទងនឹងឪពុកម្ដាយចិញ្ចឹម<br>● លក្ខខណ្ឌទាក់ទងនឹងកូនសុំ<br>● ការយល់ព្រមរបស់ឪពុកម្ដាយបង្កើត | |
| ៣ | | កំណត់កាលបរិច្ឆេទសម្រាប់ការសាកសួរ<br>កោះហៅភាគី ឪពុកម្ដាយចិញ្ចឹម | |
| ៤ | ការសាកសួរភាគី, ការសាកសួរសាក្សី (ឪពុកម្ដាយបង្កើត)<br>បញ្ជាក់ពីការយល់ព្រមរបស់ឪពុកម្ដាយបង្កើត និង លក្ខខណ្ឌដទៃទៀតដើម្បីបង្កើតស្មុំកូនពេញលេញ[2] | | |
| ៥ | | (ចៅក្រមបង្គាប់ឲ្យធ្វើការស្រាវជ្រាវក្នុងអំឡុងពេលសាកល្បង) | |
| ៦ | បុគ្គលដែលចៅក្រមបង្គាប់ ត្រូវធ្វើការស្រាវជ្រាវពីស្ថានភាពនៃឪពុកម្ដាយចិញ្ចឹម និងកូនសុំ ថាតើពួកគាត់រស់នៅជាមួយគ្នាយ៉ាងដូចម្ដេច។<br>• ទៅផ្ទះរបស់ពួកគាត់ពីរ ឬបីដង<br>• ស្ដាប់ (ទទួលព័ត៌មាន) ពីមេឃុំ អ្នកជិតខាង និង លោកគ្រូអ្នកគ្រូ<br>• ហើយនឹងធ្វើការស្រាវជ្រាវដទៃផ្សេងទៀត ប្រសិនបើភាពចាំបាច់ | | |
| ៧ | | បុគ្គលដែលចៅក្រមបង្គាប់ ត្រូវដាក់របាយការណ៍នៃអំឡុងពេលចិញ្ចឹមសាកល្បងទៅតុលាការ | |
| ៨ | | តុលាការត្រូវធ្វើការវិនិច្ឆ័យអំពីពាក្យសុំ | |

➢ ខាងក្រោមនេះ គឺជាសំណួរពាក់ព័ន្ធមួយចំនួនៈ

**១. តើតុលាការត្រូវចេញដីកាសម្រេចចាប់ផ្ដើមអំឡុងពេលចិញ្ចឹមសាកល្បងដែរឬទេ?**

ក្នុងករណីមួយចំនួន ភាគីស្នើតុលាការឲ្យចេញដីកាសម្រេច ដើម្បីបញ្ជៀសនូវការចាប់ខ្លួន ព្រោះនគរបាល និងមេឃុំ មិនអាចដឹងអំពីមូលហេតុដែលឪពុកម្ដាយចិញ្ចឹម និងកូនសុំរស់នៅជាមួយគ្នា។ ក៏ប៉ុន្តែ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង មិនអនុញ្ញាតឲ្យតុលាការចេញដីកាសម្រេចចាប់ផ្ដើមអំឡុងពេលចិញ្ចឹមសាកល្បង ហើយមាត្រា ១០១៣ នៃក្រមរដ្ឋប្បវេណីក៏មិនបានអនុញ្ញាត។ ដូច្នេះ យើងមិនអាចចេញដីកាសម្រេចដើម្បីចាប់ផ្ដើមអំឡុងពេលចិញ្ចឹមសាកល្បង ៦ ខែ។ សម្រាប់ជាដំណោះស្រាយនៅក្នុងការអនុវត្ត ក្រឡាបញ្ជី ត្រូវធ្វើរបាយការណ៍ (សូមមើលចំណុច ៤ នៃលំហូរនីតិវិធីខាងលើ) ភាគីអាចស្នើសុំចម្លងកំណត់ហេតុ ដើម្បីបញ្ជៀសនូវការចាប់ខ្លួន។ លើសពីនេះទៅទៀត នៅពេលតុលាការសាកសួរឪពុកម្ដាយបង្កើត និងឪពុកម្ដាយចិញ្ចឹម គេអាចផ្ញើលិខិតជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចអំពីការណ៍ ដែលតុលាការអនុញ្ញាតឲ្យឪពុកម្ដាយចិញ្ចឹម ធ្វើការចិញ្ចឹមកូនសុំសាកល្បងក្នុងរយៈពេល ៦ ខែ។

**២. តើឪពុកម្ដាយបង្កើត គប្បីប្រគល់កូនឲ្យទៅឪពុកម្ដាយចិញ្ចឹមនៅពេលណា?**

---

[1] . នៅក្នុងករណីដែលតុលាការពិនិត្យឃើញច្បាស់ថា ពាក្យសុំ មិនបានបំពេញលក្ខខណ្ឌក្នុងការបង្កើតស្មុំកូនពេញលេញទេ ដូចជា អ្នកដាក់ពាក្យសុំមិនមានសហព័ទ្ធ, គាត់មានអាយុក្មេងពេកក្នុងការបង្កើតស្មុំកូនពេញលេញ ឬ កូនសុំមានអាយុច្រើនជាដើម ដូចនេះ តុលាការត្រូវលើកចោលពាក្យសុំ។

2. វាមិនមានភាពចាំបាច់ក្នុងការសាកសួរកូនសុំទេ ព្រោះកូនសុំមានអាយុតិចណាស់។ ក្នុងករណីដែលតុលាការពិនិត្យឃើញថា មិនមានការព្រមព្រៀងពីឪពុកម្ដាយបង្កើត នោះតុលាការត្រូវលើកចោលពាក្យសុំ ។

ឪពុកម្តាយបង្កើត អាចប្រគល់កូននៅពេលណាក៏បាន មិនចាំបាច់មានការវិនិច្ឆ័យពីតុលាការទេ ហើយ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងក្រមនីតិវិធីរដ្ឋប្បវេណី មិនបាន ចែងអំពីការវិនិច្ឆ័យបែបនេះទេ។

**៣. តើអំឡុងពេលចិញ្ចឹមសាកល្បង ត្រូវចាប់ផ្តើមនៅពេលណា?**

សម្រាប់បុគ្គលដែលទទួលខុសត្រូវក្នុងការសរសេររបាយការណ៍ អំពីអំឡុងពេលចិញ្ចឹមសាកល្បង ៦ ខែ វាមានភាពល្អប្រសើរក្នុងការចេញសេចក្តីសម្រេច ដើម្បីជួយពួកគាត់ឲ្យធ្វើការស្រាវជ្រាវ ដោយមិនមានការរារាំង ដោយភាគីផ្សេងទៀត ទោះបីជា សេចក្តីបង្គាប់នេះ មិនមានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីនៃ រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ប្រសិនបើយើងអាចចេញសេចក្តីបង្គាប់ នោះអំឡុងពេលចិញ្ចឹម សាកល្បង ៦ ខែ ត្រូវចាប់ផ្តើមគិតចាប់ពីពេលដែលចេញដីកាសម្រេចបង្គាប់ឲ្យស្រាវជ្រាវ។

**៤. តើនរណាគឺជាអ្នកទទួលខុសត្រូវក្នុងអំឡុងពេលចិញ្ចឹមសាកល្បង?**

ស្ថាប័នដែលត្រូវទទួលបន្ទុក មិនត្រូវបានបញ្ញត្តទេ។ បុគ្គលដែលត្រូវទទួលខុសត្រូវចំពោះសោហ៊ុយ ចំណាយ ក៏មិនត្រូវបានបញ្ញត្តដែរ។ ការស្រាវជ្រាវ ត្រូវធ្វើឡើងនៅផ្ទះ ឬសាលា តាមរយៈការសាកសួរអ្នកជិត ខាង ឬគ្រូបង្រៀននៅសាលា (សូមមើលលំហូរនីតិវិធីទី ៦)។ យើង គប្បីបន្តការពិភាក្សាអំពីអ្នកណាដែលសាក សមបំផុតក្នុងការទទួលខុសត្រូវចំពោះការងារនេះ ៖ ក្រឡាបញ្ជី អាជ្ញាសាលា ព្រះរាជអាជ្ញ ព្រះរាជអាជ្ញរង ឬ អាជ្ញាធរផ្សេងៗ ទៀត ដែលមិនមែនជាមន្ត្រីតុលាការ ជាអាទិ៍។

**សំណួរ ៦០**

**នៅពេលកំណត់អំឡុងពេលចិញ្ចឹមសាកល្បង តើតុលាការត្រូវចេញសេចក្តីសម្រេចអ្វី?**

**ចម្លើយ**

មាត្រា១០១៣ នៃក្រមរដ្ឋប្បវេណី បាននិយាយពីអំឡុងពេលចិញ្ចឹមសាកល្បង ដែលតុលាការត្រូវ សម្រេចកំណត់អំឡុងពេលចិញ្ចឹមសាកល្បងយ៉ាងតិច៦ខែ ហើយជាគោលការណ៍រាល់សេចក្តីសម្រេចរបស់ តុលាការត្រូវធ្វើឡើងក្រោមទម្រង់ជាសាលក្រម ឬដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នីតិវិធីដែលអនុវត្តក្នុងរឿងសុំកូនពេញលេញនេះ ជានីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយ ដែលត្រូវសម្រេចសេចក្តីដោយដីកាសម្រេច។ ដូចនេះ ប្រសិនបើពិនិត្យមើលពីលំហូរនីតិវិធីវិញ គឺក្រោយពី ពិនិត្យមើលពាក្យសុំរបស់អ្នកដាក់ពាក្យសុំថាត្រឹមត្រូវតាមល័ក្ខខ័ណ្ឌទម្រង់ហើយ តុលាការត្រូវកោះហៅឪពុក ម្តាយចិញ្ចឹមមកសាកសួរ ហើយត្រូវសម្រេចអំពីអំឡុងពេលចិញ្ចឹមសាកល្បង ដោយចេញដីកាសម្រេចកំណត់ អំឡុងពេលចិញ្ចឹមសាកល្បង។

ប៉ុន្តែ ប្រសិនបើឪពុកម្តាយចិញ្ចឹមនោះបានចិញ្ចឹមកូនសុំជាយូរមកហើយ ហើយទើបនឹងដាក់ពាក្យសុំ នោះ តុលាការអាចនឹងពិចារណាមិនកំណត់អំឡុងពេលចិញ្ចឹមសាកល្បងក៏បាន។

**សំណួរ ៦១**

**ក. បើឪពុកម្តាយបង្កើតមិនព្រមផ្តាច់ទំនាក់ទំនងជាមួយកូនសុំ។ តើឪពុកម្តាយចិញ្ចឹមត្រូវធ្វើដូចម្តេច?**

**ខ. ប្តី H និងប្រពន្ធ W បានលែងលះគ្នានឹងគ្នា ហើយ W គឺជាអ្នកមានអំណាចមេបាលើកូនS។ ក្រោយ មក W បានរៀបការជាមួយ X ហើយ X ក៏យល់ព្រមបង្កើតសុំកូនពេញលេញជាមួយ S។ ប៉ុន្តែ H មិនព្រម។**

**តើ H អាចដាក់ពាក្យសុំដកអំណាចមេបាបានដែរទេ?**

**គ. ប្ដី H និងប្រពន្ធ W បានលែងលះគ្នានឹងគ្នា ហើយ W គឺជាអ្នកមានអំណាចមេបាលើកូន S។ ក្រោយមក W បានរៀបការជាមួយ X ហើយ X ក៏យល់ព្រមបង្កើតសុំកូនពេញលេញជាមួយ S។ X ចង់ប្ដូរត្រកូលរបស់ S ឲ្យប្រើត្រកូលដូចខ្លួន ប៉ុន្តែ H បដិសេធនឹងការប្ដូរត្រកូលនេះ។ តើប្ដីអាចបដិសេធបានដែរឬទេ?**

**ចម្លើយ**

ក. យោងតាម មាត្រា១០១១ ចែងជាគោលការណ៍ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ដូចនេះ H មានសិទ្ធិបដិសេធនូវការបង្កើតសុំកូនពេញលេញរវាង X ជាមួយ S បាន។ ប្រសិនបើតុលាការពិនិត្យឃើញមានហេតុផល ដូចមានចែងក្នុងវាក្យខណ្ឌ ២ នៃមាត្រាដដែល ទោះបីជា H បដិសេធក៏ដោយ ក៏តុលាការអាចបង្កើតសុំកូនពេញលេញបាន ដើម្បីជាឧត្ដមប្រយោជន៍របស់ក្មេង។

ខ. ក្រោយពេលតុលាការបង្កើតសុំកូនពេញលេញ បើមានមូលហេតុដូចក្នុងមាត្រា ១០៤៨ H អាចដាក់ពាក្យសុំដកអំណាចមេបាបាន។

គ. H មិនបានផ្ដល់ការយល់ព្រមក្នុងការបង្កើតសុំកូនពេញលេញ នៅក្នុងករណីនេះទេ។ ដូច្នេះ សុំកូនពេញលេញមិនអាចត្រូវបានបង្កើតឡើង។ ជាលទ្ធផល S មិនអាចប្រើនាមត្រកូលរបស់ X បានទេ។

**សំណួរ ៦២**

**តើតុលាការអាចសម្រេចឲ្យបង្កើតសុំកូន រវាងបុគ្គលដែលក្លាយជាឪពុកម្ដាយចិញ្ចឹម និង កូនសុំច្រើននាក់នៅក្នុងរឿងក្ដីតែមួយបានដែរឬទេ?**

**ចម្លើយ**

ក្រមរដ្ឋប្បវេណី ក៏ដូចជាច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង មិនមានបញ្ញត្តិជាក់ច្បាស់ដើម្បីដោះស្រាយបញ្ហានេះឡើយ។ ជាងនេះទៅទៀត ក៏មិនមានមាត្រាណា ដែលអនុញ្ញាតឲ្យធ្វើការបញ្ចូលនូវការទាមទារ នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដូចមាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ។ ដោយឃើញពីស្ថានភាពនេះ នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យ តុលាការត្រូវពិចារណាឲ្យបានល្អិតល្អន់ចំពោះកុមារម្នាក់ៗ ដោយឡែករៀងៗខ្លួន ដោយអនុលោមទៅតាមលក្ខខណ្ឌដែលក្រមរដ្ឋប្បវេណីបានកំណត់។ ដូច្នេះ មិនគួរអនុញ្ញាតឲ្យមាននីតិវិធីបែបនេះទេ ក្នុងគោលបំណងដើម្បីបញ្ជាក់សេចក្ដីសម្រេចរបស់តុលាការឲ្យបានច្បាស់លាស់ ពោលគឺ ប្រសិនបើសហព័ទ្ធមួយគូមានបំណងចង់សុំកុមារពីរនាក់ មកធ្វើជាកូនចិញ្ចឹមរបស់គាត់ ចាំបាច់ត្រូវមានរឿងក្ដីចំនួនពីរ ដើម្បីឲ្យដំណើរការវិនិច្ឆ័យគ្របដណ្ដប់ទៅលើកុមារម្នាក់ៗ ដាច់ដោយឡែកពីគ្នា។

**សំណួរ ៦៣**

**នៅពេលតុលាការសម្រេចបង្កើតសុំកូនពេញលេញ តើតុលាការត្រូវពិចារណាអំពីឆន្ទៈរបស់កូនសុំដែរឬទេ?**

**ចម្លើយ**

គោលបំណងចម្បងនៃការបង្កើតស្មុំកូនពេញលេញ គឺដើម្បីផ្តល់ឱ្យកុមារនូវគ្រួសារថ្មីមួយដែលល្អ។ ដូច្នេះ ប្រសិនបើតុលាការយល់ឃើញថា ឪពុកម្តាយបង្កើតរបស់កុមារបានផ្តល់ឱ្យកុមារនូវសេចក្តីសុខហើយ តុលាការអាចសួរអំពីឆន្ទៈរបស់កុមារដែលជាកូនសុំក៏បាន ហើយតុលាការក៏អាចនឹងលើកចោលពាក្យសុំបង្កើតស្មុំកូនពេញលេញដែរ ប្រសិនបើ កុមារបង្ហាញថា ការរស់នៅជាមួយឪពុកម្តាយបង្កើតនោះខ្លួនបានសេចក្តីសុខស្រួលហើយនោះ ផ្ទុយទៅវិញដោយហេតុថាស្មុំកូនពេញលេញអាចធ្វើបានប្រសិនបើកូនសុំនោះអាយុក្រោម៨ឆ្នាំ ដូចនេះវាអាចនឹងលំបាកក្នុងការសាកសួរពីឆន្ទៈរបស់កូនសុំ។ ក្រមរដ្ឋប្បវេណីពុំបានហាមឃាត់ការសាកសួរឆន្ទៈរបស់កូនសុំនោះទេ ដូចនេះចៅក្រមអាចនឹងធ្វើការសាកសួរបានប្រសិនបើយល់ឃើញថាចាំបាច់។

**សំណួរ ៦៤**

**តើតុលាការអាចចេញដីកាសម្រេចបង្កើតស្មុំកូនពេញលេញ នៅក្នុងរយៈពេលចិញ្ចឹមសាកល្បង ៦ ខែបានដែរឬទេ ?**

**ចម្លើយ**

ការចិញ្ចឹមសាកល្បង (មាត្រា ១០១៣) គឺជាលក្ខខណ្ឌមួយ ដើម្បីបង្កើតស្មុំកូនពេញលេញ។ ជាគោល-ការណ៍ របាយការណ៍ ឬឯកសារស្តីពីលទ្ធផលនៃការចិញ្ចឹមសាកល្បងរបស់ឪពុកម្តាយចិញ្ចឹម នឹងត្រូវផ្តល់ជូនតុលាការ នៅក្រោយរយៈពេល ៦ ខែ បានបញ្ចប់។ វាមានន័យថា នៅមុនរយៈពេល ៦ខែ តុលាការពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីយកមកធ្វើជាធនធានភស្តុតាងដើម្បីចេញសេចក្តីសម្រេចបង្កើតស្មុំកូនពេញលេញបានទេ។ តុលាការមិនអាចចេញដីកាសម្រេចបង្កើតស្មុំកូនពេញលេញ នៅក្នុងរយៈពេលចិញ្ចឹមសាកល្បង ៦ ខែបានទេ។ ក៏ប៉ុន្តែ ដោយសារលក្ខខណ្ឌនេះ គឺដើម្បីត្រួតពិនិត្យអំឡុងពេលចិញ្ចឹមសាកល្បងយ៉ាងតិច ៦ ខែ ដូច្នេះ តុលាការអាចចេញដីកាសម្រេចនៅក្នុងរយៈពេល ៦ ខែបាន នៅក្នុងករណីដែលអ្នកដាក់ពាក្យសុំបានដាក់នូវរបាយការណ៍សមរម្យអំពីការចិញ្ចឹមសាកល្បងសម្រាប់រយៈពេល ៦ ខែ។

**សំណួរ ៦៥**

**តុលាការកំពុងចាត់ការនីតិវិធីស្មុំកូនពេញលេញ ហើយបន្ទាប់មកសហព័ទ្ធម្ខាង (ឪពុក ឬម្តាយចិញ្ចឹម) ស្លាប់។ តើអាចបង្កើតស្មុំកូនបានដែរឬទេ? តើនីតិវិធីត្រូវធ្វើដូចម្តេច?**

**ចម្លើយ**

មាត្រា ៣២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង អាចយកមកអនុវត្ត ដូច្នេះ នីតិវិធីនៃការទទួលបន្ត គឺមានភាពចាំបាច់ ដើម្បីបន្តនីតិវិធីខាងលើ។ ផ្អែកតាមក្រមរដ្ឋប្បវេណី មាត្រា ១០០៨ ចែងអំពីលក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលត្រូវក្លាយជាឪពុកម្តាយចិញ្ចឹម នៅក្នុងស្មុំកូនពេញលេញ ត្រូវជាបុគ្គលដែលមានសហព័ទ្ធ។ តាមអង្គហេតុ នៅពេលតុលាការកំពុងចាត់ការនីតិវិធីស្មុំកូនពេញលេញ ហើយបន្ទាប់មកសហព័ទ្ធម្ខាង (ឪពុក ឬម្តាយចិញ្ចឹម) ស្លាប់ នាំឲ្យខ្វះលក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញ ដោយសារពុំមានជនដែលមានលក្ខណសម្បត្តិដែលអាចបន្តនីតិវិធីបណ្តឹង។

ក្នុងករណីនេះ ជាការយល់ឃើញ តុលាការត្រូវលើកចោលពាក្យសុំដោយដីកាសម្រេច។

**សំណួរ ៦៦**

**ក្នុងករណីនៃសុំកូនពេញលេញ តើឪពុកម្ដាយបង្កើតអាចកាត់កាលកូនសុំបានដែរឬទេ? ហេតុអ្វីបានជាច្បាប់មិនអនុញ្ញាតឲ្យមានការកាត់កាល់រវាងឪពុកម្ដាយ និងកូនបង្កើត?**

**ចម្លើយ**

ការបង្កើតឲ្យមានយន្តការនៃសុំកូនពេញលេញ គឺមានគោលបំណងផ្ដល់ឱ្យកុមារអភ័ព្វនូវការគ្រប់គ្រងថែរក្សានៅក្នុងក្រុមគ្រួសារមួយឲ្យដូចជាកូនបង្កើតអញ្ចឹងដែរ។ ហេតុដូច្នេះ ជាគោលការណ៍ មិនគួរទទួលស្គាល់ឱ្យមានការកាត់កាល់សុំកូននេះឡើយ គឺដូចទៅនឹងករណីនៃកូនបង្កើតដែលមិនអាចត្រូវបានកាត់កាល់ដោយឪពុកម្ដាយបង្កើតនោះទេ ទោះបីជាមានមូលហេតុយ៉ាងណាក៏ដោយ។ ដោយហេតុថា ការបង្កើតសុំកូនពេញលេញមានគោលដៅចម្បង គឺដើម្បីការពារផលប្រយោជន៍របស់កុមារ ដូចនេះ ប្រសិនបើមានភស្តុតាងជាក់ច្បាស់ថា ការបន្តទំនាក់ទំនងសុំកូននឹងបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរនោះ ក៏គួរគប្បីតែអនុញ្ញាតឱ្យមានការកាត់កាល់សុំកូននេះបានដែរ។ ព្រោះតែមូលហេតុយ៉ាងនេះហើយ ទើបមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យមានការកាត់កាល់សុំកូនពេញលេញ កាលបើមានមូលហេតុជាក់លាក់ដូចបានចែងនៅក្នុងបទប្បញ្ញត្តិនេះ។

បើយើងពិនិត្យទៅលើមូលហេតុនៃការកាត់កាល់សុំកូនពេញលេញ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឃើញថា អ្នកដែលបំពានផលប្រយោជន៍របស់កូនសុំ ហើយដែលជាមូលហេតុនាំឲ្យមានការកាត់កាល់សុំកូន គឺឪពុកម្ដាយចិញ្ចឹម។ ហេតុនេះ ការកាត់កាល់អាចនឹងប្រព្រឹត្តទៅបាន កាលបើឪពុកម្ដាយចិញ្ចឹមបានធ្វើបាបកូន បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ បានធ្វើអំពើហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ។ ក្នុងន័យនេះ ឪពុកម្ដាយចិញ្ចឹមមិនគួរទទួលបានសិទ្ធិក្នុងការប្ដឹងទាមទារកាត់កាល់សុំកូនពេញលេញ ដោយលើកយកមូលហេតុថា ខ្លួនបានធ្វើបាបកូន បោះបង់កូនចោល ជាដើមឡើយ។

**បុគ្គលដែលបានប្រព្រឹត្តអំពើជាកំហុស មិនអាចលើកសំអាងពីកំហុសឆ្គងរបស់ខ្លួន ដើម្បីអះអាងពីសិទ្ធិតាមច្បាប់ណាមួយឡើយ។ នេះគឺជាហេតុផលដ៏សមគួរមួយដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យឪពុកម្ដាយចិញ្ចឹមមានសិទ្ធិប្ដឹងទាមទារកាត់កាល់សុំកូនពេញលេញឡើយ។ មាត្រា ១០១៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី អនុញ្ញាតឱ្យតែ កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការប៉ុណ្ណោះ ដែលមានសិទ្ធិដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់សុំកូនពេញលេញ។**

**សំណួរ ៦៧**

**នៅក្នុងករណីដែលសុំកូនពេញលេញត្រូវបានបង្កើតឡើង នៅពេលដែលឪពុកម្ដាយនៅក្រ ប៉ុន្តែក្រោយមក ពួកគាត់មានសំណាងត្រូវឆ្នោត ហើយមានលុយច្រើន តើកូននោះអាចត្រឡប់មកវិញដែរឬទេ ?**

**ចម្លើយ**

យោងតាមក្រមរដ្ឋប្បវេណី សុំកូនមានពីរប្រភេទគឺ សុំកូនពេញលេញ និង សុំកូនធម្មតា។ ដើម្បីឱ្យមានភាពច្បាស់លាស់ ការឆ្លើយតបទៅនឹងសំណួរខាងលើនឹងត្រូវរៀបចំ ដោយផ្អែកលើប្រភេទនៃសុំកូននីមួយៗ។

ក្រោយពីបានបង្កើតសុំកូនពេញលេញរួចហើយ សុំកូនពេញលេញមានអានុភាពផ្តាច់ចំណងញាតិរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត (មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ ដើម្បីភ្ជាប់ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនសុំឡើងវិញ ចាំបាច់ត្រូវតែមានការកាត់កាល់សុំកូនជាមុនសិន ពោលគឺត្រូវផ្តាច់ទំនាក់ទំនងរវាងកូនសុំ ជាមួយនឹងឪពុកម្តាយចិញ្ចឹមសិន ទើបញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ (មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ការកាត់កាល់សុំកូនពេញលេញអាចធ្វើទៅបាន លុះត្រាតែមានមូលហេតុពីរយ៉ាងរួមផ្សំគ្នា ផ្អែកតាមមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី ពោលគឺ ៖

- ✓ បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ។
- ✓ បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

ជាការពិត លក្ខខណ្ឌទាំងពីរខាងលើនេះត្រូវតែបំពេញជាដាច់ខាត ទើបអាចនឹងកាត់កាល់សុំកូនពេញលេញបាន ដូច្នេះ ប្រសិនបើឪពុកម្តាយបង្កើតមានជីវភាពធូរធារឡើងវិញ មានន័យថា ពួកគាត់អាចគ្រប់គ្រងថែរក្សាកូនដោយសមរម្យបាន ក៏ប៉ុន្តែប្រសិនបើឪពុកម្តាយចិញ្ចឹមមិនបានធ្វើអំពើណាមួយដែលបំពានផលប្រយោជន៍របស់កូនសុំផងនោះ គឺមិនអាចនឹងកាត់កាល់សុំកូនពេញលេញបានទេ។

ចំណែកឯការបង្កើតសុំកូនធម្មតាវិញ ពុំមានអានុភាពបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំ ជាមួយនឹងឪពុកម្តាយបង្កើតនោះទេ (មាត្រា ១០២៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ឪពុកម្តាយចិញ្ចឹមជាអ្នកមានអំណាចមេបាលើកូនសុំ ដែលជាអនីតិជន (មាត្រា ១០២៧ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ហេតុនេះ ប្រសិនបើឪពុកម្តាយបង្កើតមានបំណងចង់ទាមទារយកកូនមកគ្រប់គ្រងតាមផ្លូវច្បាប់វិញ គឺត្រូវកាត់កាល់សុំកូនជាមុនសិន។ ការកាត់កាល់សុំកូនធម្មតាអាចធ្វើបាន តាមរយៈការព្រមព្រៀង ដូច្នេះ ឪពុកម្តាយបង្កើតដែលមានបំណងចង់យកកូនមកវិញ អាចធ្វើការពិភាក្សាជាមួយនឹងឪពុកម្តាយចិញ្ចឹម ដើម្បីឈានទៅដល់ការព្រមព្រៀងក្នុងការកាត់កាល់សុំកូនធម្មតា។ ប្រសិនបើមិនពុំមានការព្រមព្រៀងទេនោះ ចាំបាច់ត្រូវដាក់ពាក្យបណ្តឹងទាមទារកាត់កាល់សុំកូនធម្មតា ហើយពាក្យបណ្តឹងនេះអាចនឹងទទួលជោគជ័យ លុះត្រាតែមានមូលហេតុដូចបានកំណត់ក្នុងមាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណី។ ចំពោះស្ថានភាពដែលឪពុកម្តាយបង្កើតគ្រាន់តែមានជីវភាពធូរធារឡើងវិញ តែឯកឯង គឺមិនមែនជាមូលហេតុនៃការកាត់កាល់តាមខ្លឹមសារនៃមាត្រាខាងលើទេ។

**សំណួរ ៦៨**

**នៅក្រោយពេលចេញដីកាសម្រេចបង្កើតសុំកូនរួចហើយ កូនសុំមិនចង់រស់នៅជាមួយឪពុកម្តាយចិញ្ចឹម តើកូនសុំអាចត្រឡប់ទៅរស់នៅជាមួយឪពុកម្តាយបង្កើតវិញបានដែរឬទេ?**

**ចម្លើយ**

១. ក្នុងករណីសុំកូនពេញលេញ

ការបង្កើតស្មុំកូនបែបនេះគឺដើម្បីបង្កើតគ្រួសារថ្មីដល់កូនសុំដែលជាអភ័ព្វកុមារ ដូចនេះ ឃើញថាប្រសិនបើកុមារនោះរស់នៅមានសេចក្តីសុខជាមួយនឹងឪពុកម្តាយបង្កើតនោះ កុមារដែលជាកូនសុំ មិនមែនជាកម្មវត្ថុនៃស្មុំកូនពេញលេញហើយ។ ក្រោយការបង្កើតស្មុំកូនពេញលេញ ចំណងញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបានកាត់ផ្តាច់ (មាត្រា១០១៤ នៃក្រមរដ្ឋប្បវេណី) ដែលនេះមានន័យថាកុមារពុំអាចទៅរស់នៅជាមួយឪពុកម្តាយបង្កើតវិញនោះទេ។ ផ្ទុយទៅវិញប្រសិនបើការរស់នៅជាមួយឪពុកម្តាយចិញ្ចឹមនោះ ធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ធ្ងន់ធ្ងររបស់កុមារ ឧទាហរណ៍៖ ពុំបញ្ជូនកូនចិញ្ចឹមឱ្យទៅរៀនជាដើម ហើយប្រសិនបើឪពុកម្តាយបង្កើតមានលទ្ធភាពចិញ្ចឹមកូនបានល្អជាឪពុកម្តាយចិញ្ចឹមនោះ កូនសុំអាចដាក់ពាក្យសុំកាត់កាលស្មុំកូនពេញលេញនេះបាន ហើយវិលទៅរស់នៅជាមួយនឹងឪពុកម្តាយបង្កើតខ្លួនវិញ (មាត្រា១០១៦ នៃក្រមរដ្ឋប្បវេណី)។

២. ក្នុងករណីស្មុំកូនធម្មតា

ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើតមិនត្រូវបានកាត់ផ្តាច់ឡើយ ដូចនេះ កូនសុំអាចត្រឡប់ទៅរស់នៅជាមួយនឹងឪពុកម្តាយបង្កើតវិញបាន។

**សំណួរ ៦៩**

**ក្រោយពីការបង្កើតស្មុំកូនពេញលេញ កូនសុំបានវាយធ្វើបាបឪពុកម្តាយចិញ្ចឹម។ តើឪពុកម្តាយចិញ្ចឹមអាចកាត់កាល់កូនសុំពេញលេញបានដែរឬទេ? តើពួកគាត់ត្រូវធ្វើដូចម្តេច?**

**ចម្លើយ**

លក្ខខណ្ឌដើម្បីអាចកាត់កាលស្មុំកូនបាន គឺមានចែងក្នុងមាត្រា១០១៦ ហើយករណីដែលកូនសុំវាយធ្វើបាបឪពុកម្តាយចិញ្ចឹមនោះ ពុំមែនជាលក្ខខណ្ឌដែលអនុញ្ញាតឱ្យកាត់កាលឡើយ។ ដូចនេះ ឪពុកម្តាយចិញ្ចឹមពុំអាចសុំកាត់កាលកូនសុំ ដោយមូលហេតុកូនសុំវាយធ្វើបាបនោះឡើយ។

មាត្រា១០៥០ បានកំណត់ពីការលាឈប់របស់អ្នកដែលមានអំណាចមេបា ដែលក្នុងករណីនេះគឺឪពុកម្តាយចិញ្ចឹមគឺជាអ្នកដែលមានអំណាចមេបា។ ដូចនេះ ឧទាហរណ៍ប្រសិនបើក្នុងករណីដែលឪពុកម្តាយចិញ្ចឹមត្រូវបានកូនសុំវាយធ្វើបាបរហូតដល់ត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយមិនអាចធ្វើជាអ្នកមានអំណាចមេបាបានបន្តទៀត តុលាការអាចអនុញ្ញាតឱ្យមានការលាឈប់ពីអ្នកមានអំណាចមេបានេះបាន។

**សំណួរ ៧០**

**នៅពេលបណ្តឹងសុំកាត់កាល់កំពុងចាត់ការ ភាគីព្រមព្រៀងគ្នាកាត់កាល់។ តើតុលាការត្រូវធ្វើដូចម្តេច?**

**ចម្លើយ**

ចំពោះសំណួរខាងលើ គឺភាគីបានដាក់ពាក្យបណ្តឹងកាត់កាល់ ហើយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ទើបភាគីទាំងសងខាងព្រមព្រៀងគ្នាកាត់កាល់ ករណីនេះ តុលាការនៅតែចេញសាលក្រម " អំពីការកាត់កាល់ស្មុំកូន " ពុំមែនចេញដីកាសម្រេចឡើយ ដោយតាមបញ្ញត្តិមាត្រា ១០៣១ និងមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី។ ដោយសារតែគ្មាននីតិវិធីដែលអនុញ្ញាតឲ្យមាននីតិវិធីផ្ទេរពីនីតិវិធីពាក្យបណ្តឹងទៅនីតិវិធីនៃពាក្យសុំ។ ដូច្នេះ គេមិនអាចផ្ទេរនីតិវិធីបណ្តឹងទៅជានីតិវិធីពាក្យសុំបានទេ។

សម្រាប់ព័ត៌មានបន្ថែម "ស្មុំកូនធម្មតា" ដែលគូភាគីបានធ្វើការព្រមព្រៀងគ្នាជាមុន បន្ទាប់មកគឺភាគីដាក់ពាក្យសុំកាត់កាល់ទៅ តុលាការ ដើម្បីបង្ហាញឆន្ទៈពិតប្រាកដរបស់គូភាគីទាំងសងខាង ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្ដាយចិញ្ចឹម និងកូនស្មុំ ដោយយោងតាមបញ្ញត្តិមាត្រា ១០៣០ និងមាត្រា ១០២៨ កថាខណ្ឌទី ២ (សម្រាប់កូនស្មុំជាអនីតិជន)។ ដូច្នេះ តុលាការត្រូវចេញដីកាសម្រេច ផ្អែកតាមមាត្រា ៣ កថាខណ្ឌទី ២ តារាងឧបសម្ព័ន្ធ ផ្នែក ៤ ចំណុច ១០ នៃច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

**សំណួរ ៧១**

**នៅពេលតុលាការចេញសាលក្រមកាត់កាល់ តើសាលក្រមនេះ មានអានុភាពដោយស្វ័យប្រវត្តិ ឬចាំបាច់នីតិវិធីដទៃផ្សេងទៀត?**

**ចម្លើយ**

តុលាការអាចចេញសាលក្រមកាត់កាល់ស្មុំកូនពេញលេញ និង ស្មុំកូនធម្មតាបាន ដោយយោងតាមមាត្រា ១០១៦ និង មាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណី និង មាត្រា ៣ ចំណុច ជ និង ឈ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។

ករណីដែលពុំមានភាគីណាមួយ ឬជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ប្ដឹងឧបាស្រ័យចំពោះសាលក្រមស្ដីពីការកាត់កាល់នេះទេ នោះសាលក្រមនឹងចូលជាស្ថាពរ។ សាលក្រមនេះមិនមែនជាសាលក្រមដែលបង្គាប់ឲ្យផ្ដល់តាវកាលិកនោះទេ ប៉ុន្តែវាជាសាលក្រមសម្រាប់ការបង្កើតទំនាក់ទំនងគតិយុត្ត។ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលក្រមស្ថាពរនេះ មិនមែនជាលិខិតអនុវត្ត ដែលត្រូវយកទៅអនុវត្តដោយបង្ខំ ដើម្បីចុះបញ្ជីអត្រានុកូលដ្ឋាននោះទេ។ នៅពេលដែលសាលក្រមត្រូវបានបញ្ចប់ជាស្ថាពរ ការកាត់កាល់នឹងមានអានុភាពដោយស្វ័យប្រវត្តិ។ មានន័យថា ភាគីអាចយកសាលក្រមស្ថាពរនេះទៅធ្វើការចុះបញ្ជីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬសង្កាត់បាន ដោយពុំចាំបាច់ឆ្លងតាមនីតិវិធីអនុវត្តដោយបង្ខំ ដោយតុលាការអនុវត្ត ឬអាជ្ញាសាលាឡើយ ហើយមន្ត្រីអត្រាអនុកូលដ្ឋានសមត្ថកិច្ចត្រូវទទួល និងចុះបញ្ជី (តាមមាត្រា ៩ ចំណុច ៧ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០០ ស្ដីពីអត្រានុកូលដ្ឋាន) ដើម្បីចុះបញ្ជីនៃការកាត់កាល់។ លើសពីនេះ ក្នុងករណីការកាត់កាល់ស្មុំកូនពេញលេញ ញាតិភាពរវាងកូន និងឪពុកម្ដាយបង្កើតគួរតែចុះបញ្ជីផងដែរ (អានុភាពនៃបង្កើតឡើងវិញនូវញាតិភាពរវាងកូន និងឪពុកម្ដាយបង្កើតនេះ បង្កើតឲ្យមានញាតិលោហិតរបស់ឪពុកម្ដាយបង្កើតជាមួយកូននេះ ឡើងវិញផងដែរ មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណី)។

**សំណួរ ៧២**

**ក្រោយពីបង្កើតស្មុំកូនពេញលេញ ឪពុកម្ដាយចិញ្ចឹម បានឲ្យកូនសុំទៅអ្នកផ្សេងទៀតដើម្បីបង្កើតស្មុំកូនពេញលេញ។ បន្ទាប់មក ឪពុកម្ដាយចិញ្ចឹមថ្មី កាត់កាល់ស្មុំកូនពេញលេញ។ តើកូនសុំត្រូវទៅរស់ជានៅជាមួយឪពុកម្ដាយបង្កើត ឬឪពុកម្ដាយចិញ្ចឹមមុន?**

**ចម្លើយ**

នៅពេលសុំកូនពេញលេញត្រូវបានបង្កើត នោះមានន័យថា ចំណងញាតិរវាងកូនសុំ និងឪពុកម្ដាយបង្កើតត្រូវបានផ្ដាច់ (មាត្រា១០១៤ នៃក្រមរដ្ឋប្បវេណី)។

ករណីដែលឪពុកម្ដាយចិញ្ចឹមទី ១ បានបង្កើតសុំកូនជាមួយនឹងឪពុកម្ដាយចិញ្ចឹមទី ២ហើយនោះ ឪពុកម្ដាយចិញ្ចឹមទី១ ក៏ដូចគ្នានឹងឪពុកម្ដាយចិញ្ចឹមទី២ដែរ អាចនឹងកាត់កាលកូនសុំបាន លុះត្រាតែលក្ខខណ្ឌនៃមាត្រា ១០១៦ ត្រូវបានគោរព ដែលក្នុងនោះ គឺឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ពោលគឺឪពុកម្ដាយបង្កើតមានលទ្ធភាពនឹងចិញ្ចឹមកូនវិញ។

ថ្វីត្បិតចំណងញាតិនៃឪពុកម្ដាយបង្កើត ត្រូវបានកាត់ផ្ដាច់ក្រោយពីការបង្កើតសុំកូនពេញលេញ ប៉ុន្តែមាត្រា១០១៦ បានអនុញ្ញាតិឱ្យឪពុកម្ដាយបង្កើត មានសិទ្ធិដាក់ពាក្យបណ្ដឹងឱ្យកាត់កាលសុំកូនវិញបាន ហើយមាត្រាដដែលនេះពុំបានអនុញ្ញាតឱ្យឪពុកម្ដាយចិញ្ចឹមទី ១ ដាក់ពាក្យបណ្ដឹងនេះទេ។ ដូចនេះក្រោយពីមានការបង្កើតសុំកូនពេញលេញជាមួយនឹងឪពុកម្ដាយចិញ្ចឹមទី២ ហើយ ឪពុកម្ដាយចិញ្ចឹមទី ១ ពុំមានចំណងញាតិអ្វីជាមួយនឹងកូនសុំទេ ហើយពុំមានសិទ្ធិដាក់ពាក្យបណ្ដឹងកាត់កាលដូចឪពុកម្ដាយបង្កើតនោះឡើយ។

នេះមានន័យថាក្រោយការកាត់កាលសុំកូនពេញលេញ កូនសុំត្រូវវិលទៅរស់នៅជាមួយនឹងឪពុកម្ដាយបង្កើតវិញ (មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណី)។

**សំណួរ ៧៣**

**តើឪពុកម្ដាយចិញ្ចឹមដែលបានកាត់កាល់កូនសុំធម្មតា ឬ កូនសុំពេញលេញដោយ សារតែកូនសុំប្រព្រឹត្តបទល្មើស ត្រូវទទួលខុសត្រូវសងការខូចខាតទៅឱ្យជនរងគ្រោះ ក្នុងនាមជាអ្នកមានអំណាចមេបាដែរឬទេ ?**

**ចម្លើយ**

ជាដំបូង ត្រូវកត់សម្គាល់ថា ឪពុកម្ដាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់សុំកូនពេញលេញបានឡើយ (មាត្រា ១០១៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ដូចគ្នាដែរ ប្រសិនបើកូនសុំធម្មតានៅជាអនីតិជននៅឡើយ ឪពុកម្ដាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់សុំកូនធម្មតាបានឡើយ (មាត្រា ១០៣១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

ដូចបានបកស្រាយនៅក្នុងសំណួរមុនៗ សុំកូនពេញលេញ និង សុំកូនធម្មតា អាចត្រូវកាត់កាល់បាននៅក្នុងលក្ខខណ្ឌដែលកំណត់ដោយក្រមរដ្ឋប្បវេណី (មាត្រា ១០១៦ មាត្រា ១០២៨ និង មាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងករណីដែលសុំកូនត្រូវបានកាត់កាល់រួចហើយ រាល់អំពើដែលកូនសុំបានប្រព្រឹត្តក្រោយថ្ងៃកាត់កាល់ មិនស្ថិតនៅក្នុងការទទួលខុសត្រូវរបស់អតីតឪពុកម្ដាយចិញ្ចឹមទៀតទេ ពីព្រោះថា ពួកគាត់លែងជាឪពុកម្ដាយចិញ្ចឹម ឬ ជាអ្នកមានអំណាចមេបាលើកូននោះទៀតហើយ។ ក៏ប៉ុន្តែ អំពើរបស់កូនសុំដែលបានកើតនៅមុនថ្ងៃកាត់កាល់ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ឪពុកម្ដាយ ចិញ្ចឹមដដែល ដោយហេតុថា ពួកគាត់គឺជាអ្នកដែលមានករណីយកិច្ចត្រួតពិនិត្យ ស្របតាមបញ្ញត្តិមាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណី។ សូមបញ្ជាក់ថា ការកាត់កាល់សុំកូនមានអានុភាព នៅពេលដែលសេចក្ដីសម្រេចរបស់តុលាការ ដែលប្រកាសការកាត់កាល់សុំកូនបានចូលជាស្ថាពរ ហើយការកាត់កាល់នេះ មានអានុភាពបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំ ជាមួយនឹងឪពុកម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម គិតចាប់ពីពេលនោះឆ្ពោះទៅមុខ (មាត្រា ១០១៧ និង មាត្រា ១០៣២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ។

**សំណួរ ៧៤**

**នៅក្រោយពេលកាត់កាល់ តើឪពុកម្ដាយចិញ្ចឹមអាចទាមទារសោហ៊ុយដែលខ្លួនចំណាយសម្រាប់ចិញ្ចឹមកូនសុំបានដែរឬទេ?**

**ចម្លើយ**

នៅមុនពេលមានការកាត់កាល់សុំកូនពេញលេញ ឪពុកម្ដាយចិញ្ចឹមគឺជាអ្នកមានអំណាចមេបាលើកូនសុំដែលជាអនីតិជន ហើយដែលត្រូវមានករណីយកិច្ចនៅក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនសុំ (មាត្រា ១០៣៤ នៃក្រមរដ្ឋប្បវេណី)។ ចំណែកឯ ការកាត់កាល់សុំកូនវិញ មិនមានអានុភាពប្រតិសកម្មនោះទេ បានសេចក្ដីថា ការកាត់កាល់សុំកូនមានអានុភាពបញ្ចប់សុំកូនឆ្ពោះទៅពេលអនាគត (មាត្រា ១០១៧ និង មាត្រា ១០៣២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ សោហ៊ុយដែលឪពុកម្ដាយចិញ្ចឹមបានប្រើប្រាស់ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនសុំ គឺជាសោហ៊ុយដែលគាត់បានចំណាយ ដោយសារតែច្បាប់តម្រូវ។ ក្នុងអត្ថន័យនេះ ពួកគាត់មិនអាចទាមទារឲ្យនរណាម្នាក់សងសោហ៊ុយនេះមកពួកគាត់វិញបានឡើយ។

**សំណួរ ៧៥**

**តើការរឹបអូសជាបណ្ដោះអាសន្ន និងការចាត់ចែងជាបណ្ដោះអាសន្ន ខុសគ្នាដូចម្ដេច? ឧទាហរណ៍ ចំពោះទ្រព្យរួម តើត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះ អាសន្ន ឬ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ?**

**ចម្លើយ**

ការរឹបអូសជាបណ្ដោះអាសន្ន គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យ សម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងសងជាប្រាក់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៣១ ចំនុច ក) ។ ដីកាសម្រេចរឹបអូស ជាបណ្ដោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមាន ការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤៥ កថាខណ្ឌទី១)។

ការចាត់ចែងជាបណ្ដោះអាសន្នមាន ២ ប្រភេទគឺ ការចាត់ចែងជាបណ្ដោះ អាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។

ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៣១ ចំនុច ខ) ។ តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ បាន ក្នុងករណីមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤៨ កថាខណ្ឌទី១)។

ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន គឺជាការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូលជា ស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៣១ ចំនុច គ)។ តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការ ខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤៨ កថាខណ្ឌទី២) ។

ការចាត់ចែងរក្សាការពារលើទ្រព្យសម្បត្តិរួមក្នុងអង្គហេតុនីមួយៗ ក៏មានករណី ខ្លះជាការរឹបអូសជាបណ្ដោះអាសន្ន និង ករណីខ្លះជាការចាត់ចែងជាបណ្ដោះអាសន្នផងដែរ។ ក្នុងករណីសិទ្ធិដែលនឹងត្រូវរក្សាការពារជាសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ ត្រូវតែពាក្យសុំរឹបអូសជាបណ្ដោះអាសន្ន ហើយក្នុងករណី សិទ្ធិដែលនឹងត្រូវរក្សាការពារក្រៅពីសិទ្ធិខាងលើនេះ (សិទ្ធិទាមទារឲ្យប្រគល់វត្ថុ សិទ្ធិទាមទារឲ្យផ្ទេរការចុះបញ្ជីអចលនវត្ថុ ជាដើម) ត្រូវដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្ន។

ឧទាហរណ៍៖ (**ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**) **ក** ជាប្ដី បានឲ្យ **ខ** ជាប្រពន្ធ ខ្ចីប្រាក់ ៥០០០០០ រៀល ហើយពួកគាត់មានទ្រព្យសម្បត្តិរួមដែលជាម៉ូតូមួយគ្រឿង ហើយដែលចុះបញ្ជីដោយដាក់ឈ្មោះ ខ ជាកម្មសិទ្ធិករ។ ដោយសារតែ ខ មិនមានទ្រព្យសម្បត្តិអ្វីផ្សេងឡើយ ដូច្នេះ ក ព្រួយបារម្ភថា ប្រសិនបើ ខ លក់ម៉ូតូនោះបាត់ទៅ ប្រាក់ដែលបានឲ្យទៅ ខ ខ្ចីនឹងមិនអាចសងត្រឡប់មកវិញឡើយ។ ដូច្នេះ ក បានដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយមូលហេតុថា សិទ្ធិដែលនឹងត្រូវរក្សាការពារ គឺជាសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់។

ឧទាហរណ៍៖ (**ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ**) **ក** ជាប្ដី និង **ខ** ជាប្រពន្ធ មានទ្រព្យសម្បត្តិរួមដែលជាម៉ូតូមួយគ្រឿង ហើយចុះបញ្ជីដាក់ ឈ្មោះ **ខ** ជាកម្មសិទ្ធិករ។ ខ ជំពាក់បំណុលគេច្រើន ហើយដោយសារតែព្រួយបារម្ភថា ខ នឹងលក់ម៉ូតូទៅឲ្យតតិយជន ដូច្នេះ ក បានទាមទារចំពោះ ខ ឲ្យចុះបញ្ជីម៉ូតូដោយដាក់ ឈ្មោះរួមគ្នា ។ ខ មិនបានធ្វើតាមការទាមទាររបស់ ក ទេ ហើយប្រសិនបើ ខ លក់ម៉ូតូទៅឲ្យតតិយជន ហើយផ្ទេរឈ្មោះដែលបានចុះបញ្ជី ក នឹងមិនអាចយកម៉ូតូមកធ្វើការចុះបញ្ជីដោយឈ្មោះរួមទៀតបានឡើយ។ ហេតុដូច្នេះ ក បានដាក់ពាក្យសុំដីកាសម្រេចចាត់ចែង ជាបណ្ដោះអាសន្ន ដោយហាមឃាត់ការលក់ ការដូរ ការជួល ការបញ្ចាំ និងការចាត់ចែង ផ្សេងទៀតចំពោះម៉ូតូ ដោយមូលហេតុថា សិទ្ធិដែលនឹងត្រូវរក្សាការពារ ជាសិទ្ធិផ្សេងពីសិទ្ធិ លើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ (សិទ្ធិទាមទារឲ្យផ្ទេរឈ្មោះចុះបញ្ជីរបស់ម៉ូតូ) ។

## សំណួរ ៧៦

**តើពាក្យ "សិទ្ធិលើបំណុល" តាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤០២ ដល់មាត្រា ៤១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ខុសគ្នានឹងពាក្យ "សិទ្ធិលើបំណុល" តាមមាត្រា ៥៣១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីដូចម្ដេច?**

## ចម្លើយ

ពាក្យថា "សិទ្ធិលើបំណុល" ដែលមានចែងក្នុងមាត្រា ៤០២ ដល់មាត្រា ៤១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺសំដៅលើ "សិទ្ធិលើបំណុល" ដែលកូនបំណុលមានលើកូនបំណុលទី៣។

ឧទាហរណ៍៖ **ក** ឲ្យ ប្រាក់ **ខ**ខ្ចីចំនួន ៣០០ ដុល្លារ។ ហើយបានទទួលសាលក្រមស្ថាពរពីតុលាការសម្រេចឱ្យ **ខ** សងប្រាក់ **ក** ចំនួន ៣០០ ដុល្លារ។ ប៉ុន្តែ **ខ** បានឲ្យប្រាក់ **គ** ខ្ចីចំនួន៥០០ដុល្លារ។ ក្នុងករណីនេះ ក្នុងនាម **ខ** ជាកូនបំណុលនៃការអនុវត្ត ដូច្នេះ **ក** ដែលជាម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំរឹបអូស "សិទ្ធិលើបំណុល" ទៅតុលាការលើប្រាក់៥០០ដុល្លារដែល **ខ** មានចំពោះ **គ** (កូនបំណុលទី៣) បាន។

ប៉ុន្តែ ចំពោះពាក្យថា "សិទ្ធិលើបំណុល" ដែលមានចែងក្នុងមាត្រា ៥៣១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺសំដៅលើសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានលើកូនបំណុលដោយផ្ទាល់ មិនមែនសិទ្ធិលើបំណុលដែលកូនបំណុលមានលើកូនបំណុលទី៣ទេ។

ឧទាហរណ៍៖ **ក** ឲ្យប្រាក់ **ខ** ខ្ចីចំនួន ៥០០ ដុល្លារ។ ប៉ុន្តែ ទោះបីជាថ្ងៃកំណត់សងប្រាក់បានមកដល់ក៏ដោយក៏ **ខ** មិនបានសងប្រាក់ **ក** ដែរ ។ ហេតុដូច្នេះ **ក** អាចដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នលើទ្រព្យសម្បត្តិរបស់កូនបំណុល **ខ** បាន ផ្អែកតាមមាត្រា ៥៣១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី។ "សិទ្ធិលើបំណុល" ក្នុងមាត្រា ៥៣១ ចំណុច ក គឺជា "សិទ្ធិលើបំណុល"(សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ) ដែលម្ចាស់បំណុល **ក** មានលើកូនបំណុល **ខ**។

ដូច្នេះ សិទ្ធិលើបំណុលដែលកូនបំណុលនៃការអនុវត្តមានចំពោះកូនបំណុលទី៣ ដែលមានចែងចាប់ពីមាត្រា ៤០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺខុសគ្នាពី "សិទ្ធិលើបំណុល" ដែលចែងក្នុងមាត្រានេះ។

**សំណួរ ៧៧**

**ក មានដីមួយកន្លែង ហើយគាត់សាងសង់អាគារលើដីនោះ ដោយគ្មានការអនុញ្ញាតពីមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី។ ដូច្នេះ មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី បានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ហាមឃាត់នូវការសាងសង់ ដោយសម្អាងថា អាគារដែលកំពុងសាងសង់មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងមិនមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។**

**តើតុលាការអាចចេញដីកាសម្រេចរក្សាការពារបានដែរ ឬទេ?**

**ចម្លើយ**

ជាគោលការណ៍ ការចេញដីកាសម្រេចរក្សាការពារ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងលើសិទ្ធិ និង ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ ព្រមទាំងភាពចាំបាច់ក្នុងការចេញដីកាសម្រេចរក្សាការពារ (មាត្រា ៥៤១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

មាត្រា ២០ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតការសាងសង់ ចែងថា "សាលាក្រុង ឬសាលាខេត្ត អាចប្តឹងទៅតុលាការមានសមត្ថកិច្ចអោយចេញដីកាកិច្ចការប្រញាប់ ដោយផ្អាកការសាងសង់ ឬផ្លាស់ប្តូរទ្រង់ទ្រាយសំណង់ដែលពុំត្រឹមត្រូវ ឬគ្មានច្បាប់នោះ។

រីឯមាត្រា ២ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតការសាងសង់ ចែងពី សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន។

ផ្អែកតាមមាត្រា ២ និងមាត្រា ២០ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតការសាងសង់ខាងលើ អាចកំណត់បានដូចខាងក្រោម៖

**១.សិទ្ធិដែលត្រូវរក្សាការពារ៖** សិទ្ធិផ្អាកការសាងសង់សំណង់ខុសច្បាប់ ចែងក្នុងមាត្រា ២ និង២០ នៃអនុក្រឹត្យលេខ ៨៦ ស្តីពីលិខិតអនុញ្ញាតការសាងសង់។

**២.ម្ចាស់សិទ្ធិ៖** សាលាក្រុង ឬសាលាខេត្ត។

**៣.ភាពចាំបាច់៖** បង្ហាញថា កូនបំណុលកំពុងសាងសង់សំណង់។

ដូច្នេះបើបំពេញលក្ខខណ្ឌទាំងបីខាងលើ តុលាការអាចចេញដីកាសម្រេចរក្សាការពារហាមឃាត់ការសាងសង់សំណង់បាន។

**ចំណាំ៖** អ្នកមានសិទ្ធិដាក់ពាក្យសុំ គឺសាលាក្រុង ឬសាលាខេត្ត មិនមែនមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី។

## សំណួរ ៧៨

**ក បានជួលផ្ទះឱ្យ ខ ។ ក មិនមានការងារអ្វីធ្វើទេ ហើយជីវភាពរបស់កគឺផ្អែកលើប្រាក់ឈ្នួលផ្ទះនេះប៉ុណ្ណោះ។ លុះក្រោយមកខ មិនបានបង់ថ្លៃឈ្នួលផ្ទះឱ្យ ក ទេ ទោះបីជា ក បានដាស់តឿន ខ ឱ្យបង់ប្រាក់ឈ្នួលក៏ដោយក៏ ខ នៅតែមិនបង់ប្រាក់ឈ្នួលដែរ។ ដូច្នេះ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅ ក មានគម្រោង ជួលផ្ទះនេះឲ្យទៅអ្នកផ្សេង។ តើ ក អាចទាមទារឱ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដើម្បីឱ្យ ខ ចាកចេញពីផ្ទះរបស់ខ្លួនបានដែរ ឬទេ?**

## ចម្លើយ

ក្នុងករណីដែល **ក** អាចទាមទារឱ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយឱ្យ **ខ** ប្រគល់ផ្ទះ៖

ក ចាំបាច់ត្រូវមានសេចក្តីបញ្ជាក់ដំបូងដូចខាងក្រោម (មាត្រា ៥៤១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ៣ វាក្យខណ្ឌទី ៤ មាត្រាដដែល កថាខណ្ឌទី ៣ និង មាត្រា ៥៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

**១.សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ៖** សិទ្ធិទាមទារឲ្យប្រគល់ដីយោងទៅតាមសិទ្ធិលើកម្មសិទ្ធិលើដី (ក្រមរដ្ឋប្បវេណីមាត្រា ១៥៥ វាក្យខណ្ឌទី ១)

1) **ក** ជាអ្នកដែលមានសិទ្ធិលើកម្មសិទ្ធិលើដីនោះ(ក្រមរដ្ឋប្បវេណីមាត្រា១៥៥វាក្យខណ្ឌទី១)
2) **ខ** កំពុងកាន់កាប់លើដីនោះ(ក្រមរដ្ឋប្បវេណីមាត្រា១៥៥វាក្យខណ្ឌទី១)
3) **ខ** កាន់កាប់យោងទៅតាមភតិសន្យារវាង**ក**និង**ខ**។ថ្ងៃកំណត់សងបាន មកដល់ តែ **ខ** មិនបានបង់ប្រាក់ឈ្នួលផ្ទះទេ (មាត្រា ៦១០ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី)ម្យ៉ាងទៀតទោះបីជា **ក** បានដាស់តឿន ឬ មិនបានដាស់តឿនឲ្យបង់ប្រាក់ថ្លៃឈ្នួលផ្ទះតាម អំឡុងពេលដែលបានកំណត់សមរម្យក៏ដោយក៏ **ខ** មិនបានបង់ប្រាក់ដែរ (ក្រមរដ្ឋប្បវេណី មាត្រា ៤០៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី១) ដូច្នេះក្រោយអំឡុងពេលសមរម្យបានកន្លងផុត **ក** អាចបង្ហាញឆន្ទៈក្នុងការរំលាយភតិសន្យាជាមួយ **ខ** បាន (ក្រមរដ្ឋប្បវេណីមាត្រា ៤០៩ កថាខណ្ឌទី ១)។

**២.ភាពចាំបាច់៖** ក្នុងករណីមានភាពចាំបាច់ក្នុងការជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល **(ក)** ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤៨ កថាខណ្ឌទី ២៖ កាលដើមឡើយ ដើម្បីធ្វើការផ្ទេរសិទ្ធិកាន់កាប់ដែលមានលក្ខណៈបង្ខំលិខិតអនុវត្ត នៃសាលក្រម ឬ សាលដីកាដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជា បណ្តោះអាសន្ន ឬ ក៏សាលក្រម ឬសាលដីកាស្ថាពរដែលបង្គាប់ឲ្យ **ខ** ប្រគល់ដីទៅ **ក** (មាត្រា ៣៥០ កថាខណ្ឌទី ២ វាក្យខណ្ឌទី១ និង ទី២ នៃ

ក្រមនីតិវិធីរដ្ឋប្បវេណី) មានគោលការណ៍ដែល ក ធ្វើការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអាជ្ញាសាលា (មាត្រា ៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ដើម្បីធ្វើការចាត់ចែងជាបណ្តោះអាសន្នគឺមានភាពចាំបាច់ណាស់ដែលលោក ក ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងថា មានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ពេលកំពុងរង់ចាំសាលក្រម ឬ សាលដីកា។ (ជាទូទៅ ការបញ្ជាក់ដំបូងនោះ គឺ ពិបាកណាស់)។

ឧទាហរណ៍៖ ក មានចំណូលតិចតួច ហើយដោយសារតែ ការរង់ចាំនីតិវិធីចេញសាលក្រម ធ្វើឲ្យជីវភាពរស់នៅមានភាពលំបាក នេះជាអង្គហេតុមួយ ហើយអង្គ ហេតុមួយទៀត គឺ ខ មិនមានទ្រព្យសម្បត្តិទោះបីជានៅពេលអនាគតក៏មានភាព លំបាកក្នុងការបង់ថ្លៃឈ្នួល ផ្ទះដែរ។

<u>**ចំណាំ៖**</u> នេះជាប្រភេទដីកាចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។ ហេតុដូច្នេះ យោងតាមមាត្រា ៥៤៨ កថាខណ្ឌទី៤ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានភាពចាំបាច់ណាស់ដែលតុលាការត្រូវធ្វើការកោះហៅភាគី មកធ្វើការសាកសួរ ឬទាញហេតុផលផ្ទាល់មាត់ ។

### សំណួរ ៧៩

**អង្គហេតុនៃរឿងក្តីអំពើហឹង្សាក្នុងគ្រួសារ៖ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ លោកស្រី ក និងលោក ខ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ អ្នកទាំងពីរមានកូន ១នាក់ ឈ្មោះ គ។ ចាប់តាំងពីឆ្នាំ២០១៤មក លោក ខ តែងតែវាយធ្វើបាបលោកស្រី ក និងកូនឈ្មោះ គ ជារៀងរាល់ថ្ងៃ បណ្តាលឲ្យមានស្នាមជាំ និងរបួសក្បាល។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ លោកស្រី ក បានដាក់ពាក្យបណ្តឹងលែងលះលោក ខ និងសុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ គ។**

**តើលោកស្រី ក អាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារស្នើសុំឲ្យលោក ខ ចាកចេញពីផ្ទះ និងស្នើសុំគ្រប់គ្រងកូនឈ្មោះ គ បណ្តោះអាសន្នបានដែរ ឬទេ?**

### ចម្លើយ

មុននឹងពន្យល់ពីដីកាសម្រេចរក្សាការពារតាមក្រមរដ្ឋប្បវេណី យើងនឹងពន្យល់ពីដីកាការពារ តាមច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារជាមុនសិន។

**១.<u>ដីកាការពារ តាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ</u>**

ទាក់ទិននឹងការបំបែកលំនៅសង្វាស និងការគ្រប់គ្រងកូនជាបណ្តោះអាសន្ននៅពេលអំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះអាចដាក់ពាក្យសុំដីកាការពារចំពោះជនមុខសញ្ញា (អ្នកបង្កអំពើហិង្សា) តាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារបាន ប៉ុន្តែ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក.អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ (មាត្រា ២២ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ)

-ជនរងគ្រោះ ឬអ្នកតំណាងជនរងគ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានរបស់ជនរងគ្រោះ ឬមន្ត្រីភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ

-ជនណាម្នាក់ ដែលបានដឹងពីឧបទ្ទវហេតុនៃអំបើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិត ឬ ជនដែលតុលាការយល់ឃើញថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯង។

ខ.អ្នកដាក់ពាក្យសុំត្រូវបង្ហាញឱ្យឃើញថា មានភាពចាំបាច់រក្សាការពារសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ (មាត្រា ២៤ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ)។

បើបំពេញលក្ខខណ្ឌខាងលើហើយ តុលាការអាចចេញដីកាការពារបំបែកលំនៅឋានរួម ឬបំបែកជនរងគ្រោះ និងសម្រេចពីការថែរក្សាកូន និងសិទ្ធិសួរសុខទុក្ខកូនបាន តាមមាត្រា ២៥ កថាខណ្ឌទី ១ ចំណុចទី ២ និងកថាខណ្ឌទី ២ ចំណុចទី ២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។

**២.<u>ដីកាសម្រេចរក្សាការពារ តាមក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី</u>**

មាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណី បានចែងថា "តុលាការទទួលពាក្យបណ្ដឹងលែងលះគ្នា ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន.... តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន។"

ទោះបីច្បាប់អនុញ្ញាតឱ្យតុលាការ អាចចេញដីកាសម្រេចចាត់ចែងរក្សាការពារខាងលើក៏ដោយ តុលាការត្រូវធ្វើការពិចារណា ថាតើអ្នកដាក់ពាក្យសុំមានសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារដែរ ឬទេ? តើមានភាពចាំបាច់ក្នុងការចេញដីកាសម្រេចរក្សាការពារដែរ ឬទេ?

ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី អាចយកមកអនុវត្តនៅក្នុងការចាត់ចែងរក្សាការពារធម្មតាបាន ប៉ុន្តែវាមានការលំបាកសម្រាប់អ្នកដាក់ពាក្យសុំ ក្នុងការធ្វើសេចក្តីបញ្ជាក់ដំបូងអំពីសិទ្ធិដែលត្រូវបានរក្សាការពារ ដែលជាអំណាចមេបា និងការបំបែកលំនៅសង្វាស។ វាមានន័យថា អ្នកដាក់ពាក្យសុំត្រូវបង្ហាញថាខ្លួននឹងមានអំណាចមេបា នៅក្រោយការលែងលះ។ ចំពោះការឲ្យប្តីចាក់ចេញពីផ្ទះ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងថា កម្មសិទ្ធិករនៅលើផ្ទះនោះ នឹងក្លាយជាកម្មសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ក្រោយពេលលែងលះ។ ដូច្នេះវានឹងមានការលំបាកខ្លាំងក្នុងការធ្វើសេចក្តីបញ្ជាក់ដំបូងបែបនេះ។

បើអាចបង្ហាញសេចក្តីបញ្ជាក់ដំបូងខាងលើបាន តុលាការអាចចេញដីកាសម្រេចរក្សាការពារបានដោយផ្អែកលើសិទ្ធិ "ការទាមទារឱ្យប្រគល់កូន" ដែលមានចែងក្នុងមាត្រា ១០៤៧ និងសិទ្ធិ "ទាមទារឱ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ" ដែលមានចែងក្នុងមាត្រា ១៥៥ នៃក្រមរដ្ឋប្បវេណី។ ចំពោះភាពចាំបាច់វិញ គឺត្រូវបង្ហាញថាអំពើហិង្សាកំពុងកើតមាន ដើម្បីជៀសវាងលោក **ខ** ប្រើហិង្សាមកលើលោកស្រី **ក** និងកូនឈ្មោះ **គ** ដែលនាំមានគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងចំពោះលោកស្រី **ក** និងកូនឈ្មោះ **គ** តាមមាត្រា ៥៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សំណួរ ៨០**

**ម្ចាស់បំណុលដាក់ពាក្យសុំឱ្យរឹបអូសជាបណ្ដោះអាសន្ន ចំពោះចលនវត្ថុរបស់កូនបំណុល ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ចលនវត្ថុច្បាស់លាស់។**

**តើតុលាការត្រូវចាត់ទុកករណីនេះយ៉ាងដូចម្តេច?**

**ចម្លើយ**

ទាក់ទិននឹងចលនវត្ថុ តុលាការមិនចាំបាច់បង្គាប់ឲ្យម្ចាស់បំណុលធ្វើការបញ្ជាក់អំពីអត្តសញ្ញាណចលនវត្ថុឱ្យបានច្បាស់លាស់ទេ ព្រោះសញ្ញាណនៃចលនវត្ថុពិបាកក្នុងការបញ្ជាក់ណាស់ (មាត្រា ៥៤៦ វាក្យ

ខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប៉ុន្តែ បើចលនវត្ថុដែលត្រូវចុះបញ្ជី ដូចជារថយន្ត តុលាការចាំបាច់បង្គាប់ឲ្យធ្វើការបញ្ជាក់។

ហេតុដូច្នេះជាទូទៅ ចលនវត្ថុមិនមានភាពចាំបាច់ក្នុងការបញ្ជាក់ទេ ប៉ុន្តែ ប្រសិនបើបញ្ជាក់គឺជាការល្អ។

**សំណួរ ៨១**

**នៅក្នុងមាត្រា ៥៤១ មិនមានតម្រូវឲ្យម្ចាស់បំណុលដាក់ឯកសារបញ្ជាក់នូវកម្មសិទ្ធិរបស់កូនបំណុលលើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នទេ។ ដូច្នេះ ប្រសិនបើម្ចាស់បំណុល មិនបានដាក់នូវឯកសារបញ្ជាក់កម្មសិទ្ធិរបស់កូនបំណុល តើតុលាការត្រូវធ្វើដូចម្ដេច?**

**ចម្លើយ**

ជាគោលការណ៍ ភាគីត្រូវបញ្ជាក់នូវអង្គហេតុ ដើម្បីទទួលបាននូវសាលក្រម ឬដីកាសម្រេចដែលសម្រេចអោយខ្លួនឈ្នះ។ ម្ចាស់បំណុលត្រូវបញ្ជាក់នូវកម្មសិទ្ធិនៃទ្រព្យដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន (ប្រការ ៩ កថាខណ្ឌទី ១ ចំណុចទី ៣ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ តាមខ្លឹមសារនៃ មាត្រា 541 ចំនុចទី ២ និង ៣ បានបញ្ជាក់ថា អ្នកដាក់ពាក្យសុំត្រូវសរសេរឲ្យបានច្បាស់លាស់នូវភស្តុតាង និងត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង អំពីសិទ្ធិឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃនៃការរក្សាការពារ ដូចនេះ មានន័យថា វាគឺជាករណីលើកលែងទៅនឹងគោលការណ៍ខាងលើ វាមានលក្ខណៈគ្រប់គ្រាន់សម្រាប់ម្ចាស់បំណុល គ្រាន់តែធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីសិទ្ធិឬទំនាក់ទំនងគតិយុត្ត ដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារជំនួសឲ្យធ្វើការបញ្ជាក់អំពីចំណុចទាំងនោះ។

ដូច្នេះ ម្ចាស់បំណុលត្រូវបញ្ជាក់ពីកម្មសិទ្ធិរបស់កូនបំណុល។

ប្រសិនបើម្ចាស់បំណុលមិនបានដាក់ឯកសារដើម្បីបញ្ជាក់នោះទេ តុលាការអាចប្រាប់ឲ្យភាគីដាក់ឯកសារនោះ ហើយប្រសិនបើភាគីមិននៅតែមិនដាក់ទៀត នោះតុលាការអាចចេញដីកាសម្រេចលើកចោល។

**សំណួរ ៨២**

**នៅក្នុងដីការឹបអូសជាបណ្ដោះអាសន្ន ដើម្បីធ្វើសេចក្ដីបញ្ជាក់ថា កូនបំណុលមានសិទ្ធិលើដីដែលមិនបានចុះបញ្ជី តើត្រូវដាក់ឯកសារអ្វីខ្លះ?**

**នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន ដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូងថា ម្ចាស់បំណុលមានសិទ្ធិលើដីដែលមិនបានចុះបញ្ជី តើត្រូវដាក់ឯកសារអ្វីខ្លះ?**

**ចម្លើយ**

ចំពោះ**អចលនវត្ថុដែលបានចុះបញ្ជី** ឯកសារដែលបញ្ជាក់ ឬ បញ្ជាក់ដំបូងអំពីកម្មសិទ្ធិ គឺ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណី ដែលជនដទៃក្រៅពីកូនបំណុលត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ គឺ ឯកសារដែលបញ្ជាក់ថាអចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុល (សូមយោងមាត្រា ៤១៧ កថាខណ្ឌទី ៣ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

រីឯ**ដីដែលមិនបានចុះបញ្ជី** ឯកសារដែលបញ្ជាក់ ឬ បញ្ជាក់ដំបូងអំពីកម្មសិទ្ធិ គឺឯកសារដែលបញ្ជាក់ថាដីនោះជាកម្មសិទ្ធិរបស់កូនបំណុល (សូមយោងមាត្រា ៤១៧ កថាខណ្ឌទី ៣ ចំណុច ខ នៃក្រមនីតិវិធី

រដ្ឋប្បវេណី)។ មូលហេតុដែលដីដែលមិនទាន់បាន ចុះបញ្ជី មិនទាមទារឱ្យដាក់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី ព្រោះដីដែលមិនទាន់បានចុះបញ្ជីមិនមាននៅក្នុងសៀវភៅគល់បញ្ជីដីធ្លីទេ។ ដូច្នេះ ឱ្យតែ មានឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុល គឺគ្រប់គ្រាន់ហើយ។ ឧទាហរណ៍ ដូចជា ទី១.លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលចេញដោយមេឃុំ /ចៅសង្កាត់ឬស្រុក/ខណ្ឌ ឬ ទី២.ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី បានឃើញដោយ មេឃុំ/ចៅសង្កាត់ ឬ ទី៣.បង្កាន់ដៃពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចេញដោយមេឃុំ/ ចៅសង្កាត់ ឬ ទី៤បង្កាន់ដៃ ឬលិខិតប្រគល់ដីដែលចេញដោយមេឃោធាតំបន់ ឬភូមិភាគ ឬទី៥លិខិតបញ្ជាក់របស់មេភូមិឬចៅសង្កាត់ ជាដើម។

**សំណួរ ៨៣**

**ចំពោះដីមិនទាន់ចុះបញ្ជីតើអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងបានដែរឬទេ? តើក្រលាបញ្ជីត្រូវធ្វើការផ្ទុកផ្តាក់ដូចម្តេច?**

**ចម្លើយ**

កម្មវត្ថុនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងគឺ ចលនវត្ថុ និង អចលនវត្ថុ។ ចំពោះអចលនវត្ថុគឺមិនមែនត្រឹមតែដីដែលបានចុះបញ្ជីនោះទេ ដីដែលមិនទាន់ចុះបាន បញ្ជីក៏រាប់បញ្ចូលជាអចលនវត្ថុដែរ (មាត្រា៥៧០,មាត្រា៤១៧ កថា.ទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហេតុដូច្នេះ តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែងចំពោះដីដែលមិនទាន់ចុះបញ្ជីបាន។

ផ្អែកតាមប្រកាសអន្តរក្រសួងលេខ ២១៤ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអលនវត្ថុដែលមិនទាន់បានចុះបញ្ជី បានកំណត់អំពីនីតិវិធីផ្ទុកផ្តាក់ការចុះបញ្ជីនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះ អចលវត្ថុមិនទាន់ចុះបញ្ជីយ៉ាងច្បាស់ពីស្ថាប័នមានសត្តកិច្ច (ប្រការ ៥) និងនិទ្ទេសដែលត្រូវសរសេរក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី (ប្រការ ៦)។

យោងទៅតាមប្រកាសអន្តរក្រសួងនេះដែរ ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ទៅ*ស្ថាប័នមានសមត្ថកិច្ចទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី* (ប្រការ ៥) រួមមាន **<u>រដ្ឋបាលសុរិយោដីថ្នាក់រាជធានី-ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ</u>** ដែលអចលនវត្ថុតាំងនៅ (មាត្រា៥៧០, មាត្រា៥៦៧នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ បន្ទាប់មក *ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី* គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី-ខេត្តដែលបានទទួលលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីនឹងធ្វើការចាប់ផ្តើមនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីនោះ (ប្រការ ៧)។

<u>**ខ្លឹមសារដែលត្រូវចុះនិទ្ទេសនៅក្នុងលិខិតផ្ទុកផ្តាក់ និងឯកសារភ្ជាប់ មានដូចខាងក្រោម** (ប្រការ៦)៖</u>

**ក.កម្មវត្ថុ៖** ១.ចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូង។

២.ការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង

**ខ.អត្តសញ្ញាណនៃអចលនវត្ថុ៖** ទីតាំង ទំហំ និង លេខប័ណ្ណ

**គ.កម្មសិទ្ធិករ ឬ ភោគីនៃដីដែលត្រូវបានសន្មត៖** ឈ្មោះ និងអាសយដ្ឋាន

**ឃ.គោលបំណងនៃការចុះបញ្ជី៖** ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង

**ង.មូលហេតុ៖** ដីកាសម្រេចអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងចុះថ្ងៃទី ........ខែ.......ឆ្នាំ..........របស់តុលាការ.......លេខ.......

**ច.ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល**

**ឆ.ឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល**

**ឯកសារភ្ជាប់ ៖**

ក.ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

ខ.ឯកសារនៃសេចក្តីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិ ជាអាទិ៍ របស់កូនបំណុលនៃការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុដែលមិនទាន់ចុះបញ្ជី ដែលមានចែងក្នុងមាត្រា ៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សំណួរ ៨៤

**តើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នត្រូវកំណត់ចំនួនទឹកប្រាក់ដូចម្តេច?**

## ចម្លើយ

មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីបញ្ញត្តថា តុលាការត្រូវកំណត់ពីចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ (ប្រាក់រំដោះ) ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូស ជាបណ្តោះអាសន្ន។ ប៉ុន្តែ មាត្រានេះមិនបានកំណត់ថា តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ប៉ុន្មាន ចំពោះប្រាក់រំដោះនោះទេ។

ការរឹបអូសជាបណ្តោះអាសន្ន ធ្វើឡើងដើម្បីធានានូវសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ដែលម្ចាស់បំណុលមានចំពោះកូនបំណុល។ ក្នុងន័យនេះ បើសិទ្ធិលើបំណុលដែល ម្ចាស់បំណុលមានចំពោះកូនបំណុលត្រូវបានធានាតាមរយៈការផ្ញើប្រាក់រំដោះនោះ វិធានការនៃការរឹបអូសជាបណ្តោះអាសន្ននេះ នឹងមិនមានភាពចាំបាច់ទៀតឡើយ។

ដូច្នេះ ទោះបីមាត្រា ៥៤៧ មិនបានកំណត់ពីចំនួននៃប្រាក់រំដោះក៏ដោយ ក៏តុលាការអាចកំណត់ពីចំនួននៃប្រាក់រំដោះនោះបានដែរ។

ឧទាហរណ៍ទី១៖ សិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារមានចំនួន ១០០០ដុល្លារ ហើយតម្លៃនៃកម្មវត្ថុដែលបានរក្សាការពារមានចំនួន ៨០០ដុល្លារ។

នៅក្នុងឧទាហរណ៍នេះ សិទ្ធិដែលត្រូវបានរក្សាការពារមានចំនួន ១០០០ដុល្លារ ប៉ុន្តែ ម្ចាស់បំណុលអាចរឹបអូសបាននូវកម្មវត្ថុដែលមានតម្លៃត្រឹមតែ ៨០០ដុល្លារប៉ុណ្ណោះ ដែលមិនស្មើ នឹងសិទ្ធិដែលត្រូវបានរក្សាការពារនោះទេ។ គោលគំនិតនៃប្រាក់រំដោះ គឺជាការរំដោះកម្មវត្ថុពីការរឹបអូសជាបណ្តោះអាសន្នដោយការប្តូរកម្មវត្ថុជាមួយនឹងប្រាក់ ពោលគឺជារូបភាពនៃការផ្លាស់ប្តូរកម្មវត្ថុនឹងប្រាក់។ ដូច្នេះ ប្រាក់រំដោះនៅក្នុងឧទាហរណ៍នេះគឺ ចំនួន ៨០០ដុល្លារ។

ឧទាហរណ៍ទី២៖ សិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារមាន ចំនួន ៨០០ដុល្លារ ហើយ តម្លៃនៃកម្មវត្ថុដែលបានរក្សាការពារមានចំនួន ១០០០ដុល្លារ។

នៅក្នុងឧទាហរណ៍នេះ សិទ្ធិដែលត្រូវបានរក្សាការពារគឺ ៨០០ដុល្លារ ដូច្នេះ ចំពោះម្ចាស់បំណុលប្រសិនបើកូនបំណុលយកប្រាក់ចំនួន ៨០០ដុល្លារ មកធានា នោះគោលបំណងនៃការរក្សាការពារនឹងត្រូវបានបំពេញ។ ក្នុងឧទាហរណ៍នេះប្រាក់រំដោះ គឺចំនួន ៨០០ដុល្លារ។ ដូច្នេះ ប្រសិនបើកូនបំណុលផ្ញើប្រាក់ចំនួន ៨០០ដុល្លារនោះ នឹងមិនមានភាពចាំបាច់ក្នុងការរឹបអូសកម្មវត្ថុទុកទៀតទេ។

សរុបមក ក្នុងករណីដែលចំនួនប្រាក់នៃសិទ្ធិលើបំណុលដែលទាមទារលើសពីតម្លៃនៃកម្មវត្ថុ ជាគោលការណ៍នឹងត្រូវកំណត់យកតម្លៃនៃកម្មវត្ថុមកធ្វើជាចំនួននៃប្រាក់រំដោះ។ អាចនិយាយម៉្យាងទៀតបានថា ប្រសិនបើចំនួនប្រាក់នៃសិទ្ធិលើបំណុលដែលទាមទារ និង តម្លៃនៃកម្មវត្ថុមានតម្លៃណាមួយទាប នោះប្រាក់រំដោះនឹងកំណត់ទៅតាមតម្លៃដែលទាបនោះ។

**សំណួរ ៨៥**

**តើឧបករណ៍ដែលអាចជួញដូរបានមានអ្វីខ្លះ?**

**ចម្លើយ**

***ឧបករណ៍អាចជួញដូរបាន*** សំដៅដល់បញ្ជា ឬការសន្យាជាលាយលក្ខណ៍អក្សរ ដើម្បីទូទាត់សងចំនួនប្រាក់ជាកំណត់មួយ ដែលអាចផ្ទេរបានតាមរយៈការប្រគល់ ហើយកាលបើចាំបាច់ក៏មាន ***<u>បិដ្ឋិលេខ</u>*** ផងដែរ។ ឧបករណ៍អាចជួញដូរបាន ដែលគ្រប់គ្រងដោយច្បាប់នេះ រួមមាន***<u>មូលប្បទានប័ត្រ</u>*** ***<u>រូបិយាណត្តិ</u>*** ***<u>ប័ណ្ណសងតាមបញ្ជា</u>*** (មាត្រា ១ នៃច្បាប់ស្តីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់)។

***បិដ្ឋិលេខ*** សំដៅដល់ហត្ថលេខាលើខ្នងនៃឧបករណ៍អាចជួញដូរបានដោយមាន ឬគ្មានពាក្យបញ្ជាក់។ ដើម្បីមានប្រសិទ្ធិភាព បិដ្ឋិលេខត្រូវតែបានបំពេញបង្គ្រប់ដោយការប្រគល់ (មាត្រា ២ ចំណុចទី ៣៣ នៃច្បាប់ស្តីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់)។

***មូលប្បទានប័ត្រ*** សំដៅលើបញ្ជាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌឱ្យទៅធនាគារ និងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយទៅឱ្យ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬអ្នកកាន់ (មាត្រា ៣ នៃច្បាប់ស្តីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់)។

***រូបិយាណត្តិ*** សំដៅលើបញ្ជាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌ ចេញដោយបុគ្គលមួយទៅបុគ្គលដទៃ ចុះហត្ថលេខាដោយបុគ្គលអ្នកចេញបញ្ជា តម្រូវឱ្យបុគ្គលដែលជាអ្នកទទួលបញ្ជាទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬតាមបញ្ជាបុគ្គលមួយទៀត ឬអ្នកកាន់ (មាត្រា ៦០ នៃច្បាប់ស្តីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់)។

***ប័ណ្ណសងតាមបញ្ជា*** សំដៅលើការសន្យាជាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌដែលធ្វើឡើង និងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញប័ណ្ណដែលសន្យាសងចំនួនប្រាក់ជាកំណត់មួយទៅឱ្យ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ (មាត្រា ១៣៥ នៃច្បាប់ស្តីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់)។

**សំណួរ ៨៦**

**តើតុលាការគប្បីបញ្ជូនតែដីកាសម្រេច ឬជាមួយនឹងឯកសារផ្សេងទៀត ដូចជាឯកសារចតចម្លងនៃពាក្យសុំ និងសេចក្តីបញ្ជាក់ដំបូង?**

**ចម្លើយ**

ជាគោលការណ៍វិធានការនៃការចាត់ចែងរក្សាការពារ ជាវិធានការជាវិធានការបណ្តោះអាសន្ន និង

សម្ងាត់។ ហេតុដូច្នេះ បទបញ្ញត្តិនៃការបញ្ជូនពាក្យសុំដែលមានចែងក្នុងមាត្រា ៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវបានយកមកអនុវត្តនៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារឡើយ ព្រោះបើតុលាការធ្វើការបញ្ជូននូវពាក្យសុំឱ្យកូនបំណុលមុនចេញដីកាសម្រេច កូនបំណុលនឹងអាចចាត់ចែងវត្ថុដែលជាកម្មវត្ថុនៃដីកាសម្រេចនោះបាត់ ដូច្នេះដីកាសម្រេចដែលបានចេញនៅពេលក្រោយ នឹងមិនអាចអនុវត្តបានទេ។

ប៉ុន្តែពេលខ្លះ មាត្រា ៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក៏យកមកអនុវត្តនៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារបានដែរ បើមិនផ្ទុយពី គោលការណ៍នៃការសម្ងាត់។

ឧទាហរណ៍ បើតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នកំណត់ឋានៈជាបណ្ដោះអាសន្ន ដោយ**ឆ្លងកាត់**កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរកូនបំណុលដែលអាចចូលរួមបាន តាមមាត្រា ៥៤៨ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការគប្បីបញ្ជូនពាក្យសុំ និងសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល ទៅឱ្យកូនបំណុល។ ប៉ុន្តែបើតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នកំណត់ឋានៈជាបណ្ដោះអាសន្ន ដោយ**មិនឆ្លងកាត់**កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរកូនបំណុលដែលអាចចូលរួមបាន តាមមាត្រា ៥៤៨ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការមិនត្រូវបញ្ជូនពាក្យសុំ និងសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល ទៅឱ្យកូនបំណុលទេ ព្រោះបើបញ្ជូនឱ្យកូនបំណុលដឹងមុន គោលបំណងនៃការចេញដីកាសម្រេចនោះ នឹងមិនបានសម្រេចទេ។

ជាគោលការណ៍ ការសម្ងាត់នៃការចាត់ចែងរក្សាការពារ មានត្រឹមតែពេលដាក់ពាក្យសុំ រហូតដល់ពេលចេញដីកាសម្រេចតែប៉ុណ្ណោះ។ ហេតុដូច្នេះមាត្រា ៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តម្រូវឱ្យតុលាការបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ក្រោយពីតុលាការបានចេញដីកាសម្រេច។ ចំពោះការបញ្ជូននៃមាត្រា ៥៤៣ នេះ តម្រូវឱ្យតុលាការបញ្ជូនតែដីកាសម្រេចទេ ព្រោះសម្អាងហេតុនៃដីកាសម្រេចនោះ មានសរសេរនូវខ្លឹមនៃពាក្យសុំដែលម្ចាស់បំណុលទាមទារ ការអះអាងរបស់ម្ចាស់បំណុល និងភស្តុតាងដែលម្ចាស់បំណុលបានដាក់រួចហើយ ហេតុដូច្នេះចំពោះពាក្យសុំរបស់ម្ចាស់បំណុល និងសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល តុលាការអាចមានជម្រើសក្នុងការបញ្ជូនឱ្យកូនបំណុល ឬមិនបញ្ជូនបាន។

## សំណួរ ៨៧

**តើកូនបំណុល អាចដាក់ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចរក្សាការពារបានគ្រប់ពេលឬទេ?**

## ចម្លើយ

មាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ផ្ដល់សិទ្ធិដល់កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលចេញដីកាសម្រេចរក្សាការពារ។ មាត្រានេះ មិនបានកម្រិតពីថិរវេលារបស់កូនបំណុល ដើម្បីប្ដឹងតវ៉ាចំពោះដីកាសម្រេចរក្សាការពារទេ។ ដូច្នេះកូនបំណុល អាចប្ដឹងតវ៉ាចំពោះដីកាសម្រេចរក្សាការពារ បានគ្រប់ពេលវេលា ដោយធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃភាពមិនស្របច្បាប់នៃនីតិវិធីនេះ កង្វះភាពចាំបាច់ដាច់ខាតនៃការរក្សាការពារ ឬ ភាពគ្មានសិទ្ធិដែលត្រូវបានរក្សាការពារ។

**សំណួរ ៨៨**

**ម្ចាស់បំណុលដាក់ពាក្យសុំឱ្យតុលាការចេញ ដីកាសម្រេចរក្សាការពារលើដីស្រែរបស់កូនបំណុល។ អំឡុងពេល ២ សប្តាហ៍បានកន្លងផុតបន្ទាប់ពីចេញដីកាសម្រេច ម្ចាស់បំណុលមិនបានដាក់ពាក្យសុំអនុវត្ត នោះទេ។ បន្ទាប់មក កូនបំណុលដាក់ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារនោះវិញ។**

**តើតុលាការអាចលុបចោលដីកាសម្រេចតាមពាក្យសុំរបស់កូនបំណុលដែរ ឬទេ?**

**ចម្លើយ**

មាត្រា ៥៦២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា "ការអនុវត្តរក្សាការពារមិនត្រូវធ្វើឡើយ បើអំឡុងពេល ២ សប្តាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ***ត្រូវបានបញ្ជូនទៅម្ចាស់បំណុល***"។

អំឡុងពេល ២ សប្តាហ៍ខាងលើនេះ គឺសំដៅលើអំឡុងពេលនៃការអនុវត្តដីកាសម្រេចរក្សាការពារ គឺមិនមែនសំដៅលើអំឡុងពេលដែលជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារទេ។

មូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ មានតែចំនួន ៣ គឺ ទី១ មិនដាក់ពាក្យបណ្តឹងអង្គសេចក្តី (មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ទី២ ការផ្លាស់ប្តូរស្ថានភាព (មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងទី៣ ស្ថានភាពពិសេស (មាត្រា ៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ដូច្នេះ បើដីកាសម្រេចរក្សាការពារ មិនបានដាក់ពាក្យសុំអនុវត្តអំឡុងពេល ២ សប្តាហ៍ ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ***ត្រូវបានបញ្ជូនទៅម្ចាស់បំណុល*** ដូច្នេះ ដីកាសម្រេចរក្សាការពារនោះនឹងមិនមានអានុភាពអនុវត្តបានទៀតទេ ហើយតុលាការមិនអាច លុបចោលដីកាសម្រេចរក្សាការពារនោះ។

**ចំណាំ៖**

-អ្នកដាក់ពាក្យសុំ មិនមានផលប្រយោជន៍ក្នុងការដាក់ពាក្យសុំនេះទេ

-អំឡុងពេល ២ សប្តាហ៍នៃការអនុវត្តដីកាសម្រេចរក្សាការពារខាងលើ គឺគិតពីថ្ងៃម្ចាស់បំណុលទទួលបាននូវ "ការបញ្ជូន" ដីកាសម្រេចរក្សាការពារនោះ មិនមែនគិតពីថ្ងៃចេញដីកាសម្រេចរក្សាការពារទេ (មាត្រា ៥៦២ កថាខណ្ឌទី២)។

**សំណួរ ៨៩**

**ដីកាសម្រេចរក្សាការពារមិនត្រូវបានគេយកទៅអនុវត្តក្នុងរយៈពេល ២សប្តាហ៍ ដែលនាំឱ្យអស់សុពលភាពអនុវត្ត។**

**តើម្ចាស់បំណុលអាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារលើកម្មវត្ថុដដែលនេះម្តងទៀតបានដែរ ឬទេ?**

**ចម្លើយ**

បើដីកាសម្រេចរក្សាការពារមិនបានអនុវត្តក្នុងរយៈពេល ២ សប្តាហ៍ នាំឱ្យដីកាសម្រេចនោះលែងមានអានុភាពអនុវត្ត (មាត្រា ៥៦២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណីដែលម្ចាស់បំណុលមិនបានអនុវត្តដីកាសម្រេចនោះទេ ឱ្យតែភាពចាំបាច់នៃដីកាសម្រេចរក្សាការពារនៅតែមាន ម្ចាស់បំណុលនៅតែមានសិទ្ធិដាក់ពាក្យសុំដីកាសម្រេចរក្សាការពារថ្មីមួយទៀត លើកម្មវត្ថុដដែល។

**សំណួរ ៩០**

**នៅក្នុងករណីដែលម្ចាស់បំណុល មិនអាចដាក់នូវឯកសារដែលមានចែងនៅក្នុងមាត្រា ៥៥៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងអំឡុងពេលដែលបានកំណត់ តុលាការត្រូវលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ។**

**តើម្ចាស់បំណុលអាចដឹងអំពីការណ៍ ដែលតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដីដោយរបៀបណា?**

**ចម្លើយ**

បើមានពាក្យសុំពីកូនបំណុល ស្នើឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី តុលាការនឹងចេញដីកាបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ដោយកំណត់អំឡុងពេលមិនឱ្យតិចជាង ២ សប្ដាហ៍។ បន្ទាប់មកតុលាការគប្បីធ្វើការបញ្ជូនដីកាបង្គាប់នេះ ទៅឱ្យម្ចាស់បំណុល ព្រោះវាបង្កលក្ខណៈងាយស្រួលដល់តុលាការ ក្នុងការបញ្ជាក់អំពីកាលបរិច្ឆេទបានកន្លងផុតហើយ ឬនៅ។

ដូច្នេះ ការទទួលដំណឹងរបស់ម្ចាស់បំណុល ស្ដីពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី គឺទទួលតាមរយៈដីកាបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី។

**សំណួរ ៩១**

**ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៥៥៧ "បណ្ដឹងអង្គសេចក្ដី" តើអាចអនុវត្តរឿងក្ដីព្រហ្មទណ្ឌបានដែរ ឬទេ?**

**ចម្លើយ**

ជាគោលការណ៍ បណ្ដឹងព្រហ្មទណ្ឌមិនអាចចាត់ទុកជាបណ្ដឹងអង្គសេចក្ដីទេ។ ប៉ុន្តែ បណ្ដឹងព្រហ្មទណ្ឌអាចចាត់ទុកជាបណ្ដឹងអង្គសេចក្ដីបាន លុះត្រាតែនៅក្នុងបណ្ដឹង ព្រហ្មទណ្ឌនោះ មានបណ្ដឹងរដ្ឋប្បវេណីប្ដឹងជាមួយគ្នា (ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី) ដើម្បីទាមទារសំណងរដ្ឋប្បវេណី (មាត្រា ១៣ ដល់ ២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ឧទាហរណ៍: **ក** បានជិះរថយន្តបុក្រាសទិសបុក **ខ** បណ្ដាលឱ្យស្លាប់។ ករណីនេះ នៅក្នុងបណ្ដឹងព្រហ្មទណ្ឌ **ក** ត្រូវបានចោទប្រកាន់ពីបទបើកបរបណ្ដាលឱ្យអ្នកដទៃស្លាប់ដោយអចេតនា។ ជំណាល់គ្នានេះ ឪពុកម្ដាយលោក **ខ** អាចប្ដឹងទាមទារសំណងរដ្ឋប្បវេណីតាមរយៈអំពីអនីត្យានុកូលនៅក្នុងសំណុំរឿងព្រហ្មទណ្ឌបាន។ នៅក្នុងអំឡុងពេលចាប់ផ្ដើមនីតិវិធីបណ្ដឹងព្រហ្មទណ្ឌរហូតដល់ចេញសាលក្រមត្រូវចំណាយពេលវេលាច្រើន ហេតុដូច្នេះ ដើម្បីធានាសំណងដែលឪពុកម្ដាយលោក **ខ** នឹងទទួលបាននៅពេលមានសាលក្រមព្រហ្មទណ្ឌស្ថាពរ ឪពុកម្ដាយលោក ខ អាចស្នើសុំ ដីកាសម្រេចរក្សាការពារលើទ្រព្យសម្បត្តិណាមួយរបស់លោក **ក**។ ម្យ៉ាងវិញទៀត ក្នុងករណីដែល ឪពុកម្ដាយរបស់ ខ បានដាក់ពាក្យបណ្ដឹងទាមទារសំណងការខូចខាត គឺមិនអាចលុបចោលដីកាសម្រេចរក្សាការពារដោយ មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានឡើយ។

# ក្រុមការងារ
# គណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

# មាតិកា

**សិក្ខាសាលាធំលើកទី៦** "អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល" ថ្ងៃទី ២៦ មិថុនា ២០១៤

**អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល**..........1

សេចក្ដីផ្ដើម..........1

១. អត្ថន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល..........1

២. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល..........9

៣. ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល..........15

៤. ការបោះបង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល..........20

៥. អានុភាពនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល..........20

សន្និដ្ឋាន..........21

**សិក្ខាសាលាធំលើកទី៧** "អាពាហ៍ពិពាហ៍ និងការលែងលះ" ថ្ងៃទី ១១ កញ្ញា ២០១៤

**ការបង្កើតអាពាហ៍ពិពាហ៍**..........25

សេចក្ដីផ្ដើម..........25

១. កំជាប់ពាក្យ..........25

២. ការបង្កើតអាពាហ៍ពិពាហ៍..........28

៣. អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស..........33

៤. មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍..........34

**អានុភាពនៃអាពាហ៍ពិពាហ៍**..........41

សេចក្ដីផ្ដើម..........41

១. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះទំនាក់ទំនងបុគ្គល..........41

២. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះកាតព្វកិច្ចកំណត់ដោយក្រមរដ្ឋប្បវេណី..........43

៣. អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះទំនាក់ទំនងទ្រព្យ..........45

ផ្នែកទី៤- អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះអំពើ រឺសកម្មភាពដែលត្រូវលើកលែង និងការហាមឃាត់ដោយច្បាប់.....47

**ការលែងលះគ្នា**.....50

១.មូលហេតុនៃការលែងលះ.....51

២.អានុភាពនៃការលែងលះ.....54

៣.នីតិវិធីនៃការលែងលះ.....58

**សិក្ខាសាលាធំលើកទី៨ "ទំនាក់ទំនងរវាងឪពុកម្តាយនិងកូន រួមទាំងសុំកូន" ថ្ងៃទី ១៨ ធ្នូ ២០១៤**

**បុត្តភាព**.....67

សេចក្តីផ្តើម.....67

១. សំបុត្រកំណើត.....67

២. ការសម្រេចអំពីបុត្តភាព.....68

៣. បណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព.....78

**សុំកូន**.....82

១.សញ្ញាណទូទៅ.....82

២.តួនាទីនៃការសុំកូន និងគោបំណងនៃរបបសុំកូន ផលប្រយោជន៍នៃការសុំកូន.....82

៣.ល័ក្ខខ័ណ្ឌទូទៅសម្រាប់ការសុំកូន.....82

**អំណាចមេបា**.....95

១. ករណីឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍.....95

២. ករណីឪពុកម្តាយលែងលះគ្នា.....95

៣. ករណីឪពុកម្តាយមិនបានរៀបអាពាហ៍ពិពាហ៍.....96

**សិក្ខាសាលាធំលើកទី៩ "នីតិវិធីអនុវត្តដោយបង្ខំ" ថ្ងៃទី ០៧ ឧសភា ២០១៥**

**នីតិវិធីអនុវត្តដោយបង្ខំ**.....103

១. សញ្ញាណទូទៅ.....103

២. អនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ចំពោះចលនវត្ថុ.........................103
២. អនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ចំពោះចលនវត្ថុ.........................110
៣. អនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ចំពោះអចលនវត្ថុ.......................119
៤. ករណីសិក្សា..........................................................................................................130
**សិក្ខាសាលាធំលើកទី១០ "អង្គហេតុចម្បង និងការសរសេរពាក្យបណ្ដឹង" ថ្ងៃទី ២០ សីហា ២០១៥**
**អង្គហេតុចម្បង និងការសរសេរពាក្យបណ្ដឹង**..........................................................135
សេចក្ដីផ្ដើម...............................................................................................................135
១. សញ្ញាណទូទៅនៃបណ្ដឹង..........................................................................................135
២. បណ្ដឹងទាមទារឲ្យបញ្ជាក់.........................................................................................143
៣. បណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត..............................................148
៤. ទម្រង់នៃបណ្ដឹង......................................................................................................150
៥. អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬអង្គហេតុចម្បង.........................................157
**សិក្ខាសាលាធំលើកទី១១ "ភតិសន្យា និងសិទ្ធិជួលអចិន្ត្រៃយ៍" ថ្ងៃទី ១៨ កុម្ភៈ ២០១៦**
**គោលគំនិតនៃភតិសន្យា**.........................................................................................163
សេចក្ដីផ្ដើម...............................................................................................................163
១. និយមន័យ..............................................................................................................163
២. ការបង្កើតភតិសន្យា................................................................................................163
៣. ល័ក្ខខ័ណ្ឌតតាំង........................................................................................................165
៤. ប្រាក់កក់.................................................................................................................168
**អានុភាពនៃភតិសន្យា**...........................................................................................168
១. ការអាស្រ័យផល និងប្រើប្រាស់តាមវិធីប្រើប្រាស់ធម្មតា..................................................169
២. ករណីកិច្ចប្រុងប្រយ័ត្នរបស់ភតិកៈក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត..........................170
៣. ការជួសជុលវត្ថុជួល..................................................................................................170

៤. សិទ្ធិទាមទារអោយសងវិញ នូវសោហ៊ុយរបស់ភតិក:....173

៥. អំពីថ្លៃឈ្នួល....175

៦. ការទទួលខុសត្រូវក្នុងការធានាវិការ:....178

**អនុប្បទានសិទ្ធិជួល និងការជួលបន្តនូវវត្ថុជួល**....179

១ អនុប្បទានសិទ្ធិជួល និងការជួលបន្តនូវវត្ថុជួលដោយមានការយល់ព្រមពីភតិបតី....179

២ អនុប្បទានសិទ្ធិជួល និងការជួលបន្តនូវវត្ថុជួលដោយពុំមានការយល់ព្រមពីភតិបតី....179

៣ ទំនាក់ទំនងរបស់ភតិបតី ភតិក: និងភតិក:បន្ត ក្នុងការបញ្ចប់ភតិសន្យា និងអានុភាពនៃការជួលបន្ត....183

**ការបញ្ចប់ភតិសន្យា**....184

១. ការបញ្ចប់ភតិសន្យាដែលមានកំណត់អំឡុងពេល....184

២. ការស្នើសុំឲ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល....184

៣. ការបញ្ចប់ពិសេសនៃភតិសន្យា ដោយសន្តតិជនរបស់ភតិក:....185

៤. អានុភាពនៃការបញ្ចប់ភតិសន្យា....186

ករណីសិក្សា....188

**សិទ្ធិជួលអចិន្ត្រៃយ៍**....190

១. និយមន័យ មាត្រា ២៤៩ នៃក្រមរដ្ឋប្បវេណី....190

២. ការបង្កើត (មាត្រា ២៤៥ នៃក.រ)....190

៣-ល័ក្ខខ័ណ្ឌតតាំង....191

៤-អានុភាព....191

ចំណុចដូចគ្នា និង ចំណុចខុសគ្នារវាង សិទ្ធិជួលអចិន្ត្រៃយ៍ និង ភតិសន្យា....194

១. ការអនុវត្តមាត្រាពាក់ព័ន្ធនិងភតិសន្យា (មាត្រា ២៥៥ នៃក.រ)....194

២. ចំណុចខុសគ្នារវាងភតិសន្យា និង សិទ្ធិជួលអចិន្ត្រៃយ៍....195

៣. សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស....196

៤. ការធ្វើបដិទាន និងការរុះរើ នៅពេលបញ្ចប់ការជួលអចិន្ត្រៃយ៍....197

ករណីសិក្សា....199

**សិក្ខាសាលាតូចលើកទី១ "របៀបគណនាសំណងនៃការខូចខាតក្នុងករណីបំពានកិច្ចសន្យា" ថ្ងៃទី ០៦ ឧសភា ២០១៤**

១. សំណងនៃការខូចខាតផ្នែកសម្ភារៈ......203

២. សំណងនៃការខូចខាតផ្លូវចិត្ត......208

**សិក្ខាសាលាតូចលើកទី២ "អំពើអនីត្យានុកូលការគណនាសំណងនៃខូចខាត" ថ្ងៃទី ០៥ មិថុនា ២០១៤**

**អំពើអនីត្យានុកូលការគណនាសំណងនៃការខូចខាត**......215

១. ទស្សនាទាននៃអំពើអនីត្យានុកូល......215

២. ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល......216

៣. ការសម្រេចអំពីចំនួននៃសំណង......220

៤. ករណីសិក្សា......222

**សិក្ខាសាលាតូចលើកទី៣ "វិធីបែងចែកទ្រព្យក្រោយការលែងលះ" ថ្ងៃទី ១០ កក្កដា ២០១៤**

**វិធីបែងចែកទ្រព្យក្រោយការលែងលះ**......227

សេចក្ដីផ្ដើម......227

១. គោលគំនិតនៃវិធីបែងចែកទ្រព្យក្រោយការលែងលះ......227

២. មធ្យោបាយក្នុងការបែងចែកទ្រព្យសម្បត្តិ......230

៣. រូបមន្តដែលត្រូវគិតដោយតុលាការនៅពេលសម្រេចពីការបែងចែកទ្រព្យសម្បត្តិ......231

៤. ករណីសិក្សា......233

**សិក្ខាសាលាតូចលើកទី៤ "អនុប្បទានសិទ្ធិលើបំណុល" ថ្ងៃទី ២១ សីហា ២០១៤**

**អនុប្បទានសិទ្ធិលើបំណុល**......237

សេចក្ដីផ្ដើម......237

១. ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និងករណីដែលហាមមិនឲ្យធ្វើអនុប្បទានបាន......238

២. ល័ក្ខខ័ណ្ឌនៃការធ្វើអនុប្បទានសិទ្ធិលើបំណុល និងល័ក្ខខ័ណ្ឌតតាំង......240

៣. អានុភាពនៃការជូនដំណឹង និងការយល់ព្រម......245

៤. អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ......247

**សិក្ខាសាលាតូចលើកទី៥ "អាហារកាតព្វកិច្ច" ថ្ងៃទី ២៥ វិច្ឆិកា ២០១៤**

**អាហារកាតព្វកិច្ច**......253

១. ទស្សនាទាននៃអាហារកាតព្វកិច្ច......253

២. បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច......254

៣. បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច......254

៤. ការផ្គត់ផ្គង់ ការផ្លាស់ប្តូរ ឬការលុបចោល និងអនុប្បទានអាហារកាតព្វកិច្ច......255

៥. អាហារកាតព្វកិច្ច និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន......257

៦. អាហារកាតព្វកិច្ច និងអាហារកិច្ច......258

៧. ការគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច......258

៨. ករណីសិក្សា......259

**សិក្ខាសាលាតូចលើកទី៦ "អនិតីសង្វាស" ថ្ងៃទី ២៣ ខែ មករា ២០១៥**

**អនីតិសង្វាស**......267

១. ទស្សនាទាននៃអនីតិសង្វាស......267

២. អានុភាពនៃអនីតិសង្វាស......269

៣. ការអនុវត្តអនីតិសង្វាស......274

៤. ករណីសិក្សា......277

**សិក្ខាសាលាតូចលើកទី៧ "ការតំណាង" ថ្ងៃទី ២៦ កុម្ភះ ២០១៥**

**ការតំណាង**......285

១. សញ្ញាណទូទៅ......285

២. ប្រភព និងវិសាលភាពនៃការតំណាង......290

៣. ការតំណាងដោយគ្មានសិទ្ធិ និងការតំណាងដែលមានលក្ខណៈជារូបភាព......292

៤. ករណីសិក្សា......294

**សិក្ខាសាលាតូចលើកទី៨ "ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការលក់ទិញ" ថ្ងៃទី ០៧ មេសា ២០១៥**

**ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការលក់ទិញ**.....299

១. សញ្ញាណទូទៅ.....299

២. ល័ក្ខខ័ណ្ឌក្នុងការផ្ទេរកម្មសិទ្ធិលើអចលវត្ថុដោយការលក់ទិញ.....301

៣- ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដោយផ្អែកលើកិច្ចសន្យាលក់-ទិញ.....305

**សិក្ខាសាលាតូចលើកទី៩ "កិច្ចសន្យាបញ្ញើ" ថ្ងៃទី ៣០ កក្កដា ២០១៥**

**កិច្ចសន្យាបញ្ញើ**.....315

សញ្ញាណទូទៅ.....315

១. និយមន័យ.....315

២. ការបង្កើតកិច្ចសន្យាបញ្ញើ និងអានុភាព.....315

៣. ការបញ្ចប់កិច្ចសន្យាបញ្ញើ.....321

៤. សិទ្ធិនិងករណីយកិច្ចរបស់អ្នកទទួលបញ្ញើនិងអ្នកផ្ញើ.....323

៥. ការសម្រាលការទទួលខុសត្រូវសំណងនៃការខូចខាត.....325

៦. ករណីសិក្សា.....328

**សិក្ខាសាលាតូចលើកទី១០ "បណ្ដឹងតវ៉ារបស់តតិយជនក្នុងរឿងអនុវត្តដោយបង្ខំ និងរក្សាការពារ" ថ្ងៃទី ១៧ ធ្នូ ២០១៥**

**បណ្ដឹងតវ៉ារបស់តតិយជនក្នុងរឿងអនុវត្តដោយបង្ខំ និងរក្សាការពារ**.....335

១. គោលគំនិតទូទៅ.....335

២. អត្ថន័យតតិយជន.....335

៣. អត្ថន័យបណ្ដឹងតវ៉ារបស់តតិយជន.....335

៤. ភាគី.....336

៥. បណ្ដឹងតវ៉ារបស់តតិយជនក្នុងករណីអនុវត្តដោយបង្ខំ.....337

៦. បណ្តឹងតវ៉ារបស់តតិយជនក្នុងករណីដីកាសម្រេចរក្សាការពារ........................................342

៧. ការតវ៉ាចំពោះការអនុវត្ត......................................................................................342

៨. ករណីសិក្សា........................................................................................................345

**សិក្ខាសាលាតូចលើកទី១១ ការរៀបចំពាក្យបណ្តឹង និងឯកសារត្រៀម ថ្ងៃទី ០៣ មីនា ២០១៦**

**ការរៀបចំពាក្យបណ្តឹង និងឯកសារត្រៀម**...........................................................351

១. ការពន្យល់ទូទៅ..................................................................................................351

២. ការរៀបចំពាក្យបណ្តឹង.......................................................................................363

៣. ការរៀបចំឯកសារត្រៀម និង ឯកសារចម្លើយ.......................................................372

**សិក្ខាសាលាតូចលើកទី១២ ប្រាតិភោគដោយអនុប្បទាន ថ្ងៃទី ២៤ មីនា ២០១៦**

**ប្រាតិភោគដោយអនុប្បទាន**...................................................................................397

១. សញ្ញាណទូទៅ....................................................................................................397

២.ការបង្កើត និងអានុភាពតតាំង.................................................................................401

៣. អានុភាព.............................................................................................................405

៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន...............................................................414

# សិក្ខាសាលាគណៈមេធាវី(ធំ)លើកទី៦

## ប្រធានបទ៖ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ថ្ងៃទី ២៦ មិថុនា ២០១៤

# អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

## សេចក្តីផ្តើម

ទស្សនៈជាមូលដ្ឋាននៃអាជ្ញាយុកាលក្នុងទំនាក់ទំនងនៃសិទ្ធិ ឬចំណាងគតិយុត្តិផ្សេងៗគឺជាបញ្ហាចម្បងមួយដែលទាមទារឲ្យអ្នកច្បាប់ធ្វើការសិក្សាស៊ីជម្រៅ ដើម្បីយល់ច្បាស់អំពីគោលគំនិតក៏ដូចជាអត្ថប្រយោជន៍ដែលនាំឲ្យមានការបង្កើតអាជ្ញាយុកាលនេះឡើង។ ដោយហេតុថាក្នុងទំនាក់ទំនងគតិយុត្តិដែលឈានដល់ការបង្កើតឲ្យមានទំនាក់ទំនងនៃសិទ្ធិអាជ្ញាយុកាលតែងតែជាបញ្ហាប្រឈមមួយ ដែលមានលក្ខណៈស្មុគស្មាញ ដូច្នេះក្រុមការងារគណៈមេធាវីមានគោលបំណងចម្បងក្នុងការលើកឡើងអំពីប្រធានបទនេះ ដើម្បីយកមកសិក្សាលម្អិតក្នុងក្របខណ្ឌនៃទ្រឹស្តីផង និងការអនុវត្តជាក់ស្តែងផងដែលបានជួបប្រទះទាក់ទងនឹងបញ្ហានៃអាជ្ញាយុកាលនេះ។ ដើម្បីភាពងាយស្រួលក្នុងការសិក្សាស្វែងយល់ប្រធានបទនេះនឹងធ្វើការបង្ហាញទៅតាមលំដាប់លំដោយនៃបញ្ហា ស្តីអំពីអាជ្ញាយុកាលនៃសិទ្ធិលើបំណុលដែលមានបង្ហាញក្នុងចំណុចដូចខាងក្រោមនេះ៖

(១)អត្ថន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

(២)ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

(៣) ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

(៤) ការបោះបង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនិង

(៥) អានុភាពនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

តាមរយៈក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

## ១. អត្ថន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

### - អត្ថន័យ៖

អាជ្ញាយុកាលគឺជាប្រព័ន្ធដែលផ្តល់ការការពារនូវស្ថេរភាពតាមផ្លូវច្បាប់ចំពោះស្ថានភាពពិតជាក់ស្តែងដែលបានបន្តរយៈពេលយូរ នាំអោយម្ចាស់សិទ្ធិដែលមិនបានអនុវត្តសិទ្ធិរយៈពេលយូរនឹងត្រូវបាត់បង់សិទ្ធិ។

ផ្អែកតាមខ្លឹមសារនៃមាត្រា៤៨០នៃក្រមរដ្ឋប្បវេណីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលសំដៅលើការរំលត់សិទ្ធិលើបំណុលដោយផ្អែកលើករណីដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិក្នុងកំឡុងពេលដែលត្រូវបានកំណត់ មានន័យថា ការសម្រេចនូវអាជ្ញាយុកាលនាំអោយសិទ្ធិលើបំណុលផ្ទាល់តែម្តងដែលត្រូវរលត់ មិនមែនគ្រាន់តែជាការរលត់សិទ្ធិប្តឹងទាមទារតាមផ្លូវតុលាការនោះទេ។

**- គោលបំណង៖**

គោលបំណង ដែលនាំអោយមានការកំណត់ពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះឡើងក្នុងច្បាប់គឺដើម្បីគ្រប់គ្រងអោយមានស្ថេរភាពនិងការថែរក្សានូវសណ្តាប់ធ្នាប់សង្គម ដោយកំណត់នូវពេលវេលាជាក់លាក់មួយ និងមិនអនុញ្ញាតអោយទុកជម្លោះចោលក្នុងរយៈពេលមិនកំណត់ ដោយជួយជម្រុញអោយម្ចាស់បំណុលប្រញាប់ប្រញាល់ក្នុងការដាក់ពាក្យបណ្តឹង និងអាចបង្កនូវភាពងាយស្រួលដល់តុលាការក្នុងការទទួលបាននូវភស្តុតាងដែលនៅល្អ ងាយពិនិត្យ ព្រមទាំងសាក្សីដែលមាននៅមានការចងចាំល្អដូចនេះ ប្រសិនបើម្ចាស់បំណុលមិនបានការពារសិទ្ធិរបស់ខ្លួនទេនោះ គឺបានន័យថាម្ចាស់បំណុលមិនគួរទទួលបានសិទ្ធិនេះតទៀតឡើយ។

ម្យ៉ាងវិញទៀត វិធាននៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក៏មានគោលបំណងក្នុងការការពារដល់កូនបំណុលតាមរយៈការរិតត្បិតសិទ្ធិរបស់ម្ចាស់បំណុលអោយមានប្រសិទ្ធិភាពត្រឹមតែកាលកំណត់ជាក់លាក់មួយតែប៉ុណ្ណោះ ប្រសិនបើកូនបំណុលអាចត្រូវបានគេប្តឹងដោយពុំមានកាលកំណត់នោះ មានន័យថា កូនបំណុលនឹងពុំទទួលបាននូវភាពយុត្តិធម៌ឡើយ ព្រោះថាការកំណត់នូវអំឡុងពេលអាជ្ញាយុកាលនេះ ត្រូវពឹងផ្អែកលើកត្តាបីសំខាន់គឺ៖ ភាពយុត្តិធម៌ ភាពច្បាស់លាស់ និងគោលនយោបាយសាធារណៈ។

តាមរយៈក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការបែងចែកអាជ្ញាយុកាលជាពីរប្រភេទគឺអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល(មាត្រា៤៨០) និងអាជ្ញាយុកាលនៃលទ្ធកម្មនៃកម្មសិទ្ធិ(មាត្រា១៦២)។ ប៉ុន្តែ នៅក្នុងក្របខណ្ឌនៃការធ្វើបទបង្ហាញនេះ នាងខ្ញុំនឹងលើកយកតែបញ្ហាស្តីអំពីអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលមកធ្វើការបកស្រាយ និងពិចារណាតែប៉ុណ្ណោះ។

## ១.១. ល័ក្ខខ័ណ្ឌនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ល័ក្ខខ័ណ្ឌនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរួមមាន៖

- ករណីដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិលើបំណុលក្នុងកំឡុងពេលដែលត្រូវបានកំណត់ (មាត្រា៤៨០) មានន័យថា ប្រសិនបើពេលកំណត់ត្រូវបានកន្លងផុតហើយម្ចាស់បំណុលបាន

ព្រងើយកន្តើយក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន នាំអោយម្ចាស់បំណុលនឹងត្រូវបាត់បង់សិទ្ធិ ឬផ្ដោះសិទ្ធិនោះ។

ឧទាហរណ៍៖ ក្នុងកិច្ចសន្យាខ្ចីបរិភោគ(ក) បានខ្ចីប្រាក់ពី(ខ) ចំនួន១០,០០០ដុល្លាអាមេរិក ដែលមានកំណត់រយៈពេលសង១ឆ្នាំ។ ចំពោះករណីនេះ បើពេលកំណត់ត្រូវសងបានមកដល់ (ខ) ពុំបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទាមទារប្រាក់ពី(ក) ហើយរយៈពេល៥ឆ្នាំក៏បានកន្លងផុតនោះ(ខ)នឹងបាត់បង់សិទ្ធិក្នុងការទាមទាររបស់ខ្លួន (មាត្រា៤៨២ )។

- ករណីជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ លើកឡើងនូវអាជ្ញាយុកាល (មាត្រា៤៨៦ )។

ឧទាហរណ៍៖ នៅក្នុងបណ្ដឹងទាមទាររបស់ភាគីនៃកិច្ចសន្យាប្រសិនបើនៅក្នុងការទាមទារភាគីពុំបានលើកឡើងអំពីអាជ្ញាយុកាលទេនោះតុលាការនឹងពុំធ្វើការពិចារណាលើបញ្ហាអាជ្ញាយុកាលនេះទេ។

## គ. ការចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន (មាត្រា៤៨១)។ ពេលដែលអាចអនុវត្តសិទ្ធិលើបំណុលមានន័យថាពេលដែលលែងមានឧបសគ្គតាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិលើបំណុលនោះ។ ម្ចាស់បំណុល អាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន នៅពេលដែលលែងមានឧបសគ្គតាមផ្លូវច្បាប់នៅក្នុងការអនុវត្តសិទ្ធិ ពោលគឺឧបសគ្គតាមផ្លូវច្បាប់ ដែលហាមឃាត់មិនអោយម្ចាស់បំណុលអនុវត្តសិទ្ធិរបស់ខ្លួន។

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ ដែលមានថេរវេលាកំណត់អោយសងក្នុងរយៈពេលមួយឆ្នាំដូច្នោះប្រសិនបើរយៈពេលមួយឆ្នាំមិនទាន់បានកន្លងផុត ភាគីម្ខាងនៃកិច្ចសន្យាមិនអាចទាមទារអោយភាគីម្ខាងទៀតសងមុនពេលកំណត់បានឡើយ ដែលនេះបង្ហាញពីឧបសគ្គតាមផ្លូវច្បាប់នៅក្នុងការអនុវត្តសិទ្ធិ ពីព្រោះអាជ្ញាយុកាលប្រាំឆ្នាំមិនអាចគិតនៅក្នុងរយៈពេលនេះបានទេ។ ប៉ុន្តែនៅពេលដែលរយៈពេល មួយឆ្នាំកន្លងផុត នាំអោយលែងមានឧបសគ្គរាំងដល់ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់តទៅទៀតហើយ។ជាទូទៅ អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចាប់ផ្តើមនៅថ្ងៃបន្ទាប់ពីថ្ងៃដែលឧបសគ្គតាមផ្លូវច្បាប់ លែងមានអត្ថិភាព (មាត្រា ៣៣៤ កថាខណ្ឌទី១)។

ក៏ប៉ុន្តែសូមកត់សម្គាល់ទៅលើភាពខុសគ្នារវាង ពេលដែលសិទ្ធិលើបំណុលកើតឡើង និងពេលដែលអាចអនុវត្តសិទ្ធិលើបំណុល ដែលយើងអាចពិចារណាទៅលើស្ថានភាពបី ដូចខាងក្រោម៖

- **ករណីកិច្ចសន្យាមានកំណត់ពេលសងពិតប្រាកដ**

ប្រសិនបើកិច្ចសន្យាមានកំណត់ពេលសងពិតប្រាកដ ដើម្បីអនុវត្តកាតព្វកិច្ចនោះម្ចាស់បំណុលមិនអាចទាមទារអោយកូនបំណុលអនុវត្តកាតព្វកិច្ចមុនពេលកំណត់បានឡើយ។ ហេតុដូច្នេះ អំឡុងពេលអាជ្ញាយុកាលត្រូវគិតចាប់ពីពេលដែលសិទ្ធិលើបំណុលអាចអនុវត្តបាន ។

ឧទាហរណ៍៖ (ក) បានបង្កើតកិច្ចសន្យាលក់ទិញនាឡិកាបុរាណជាមួយ (ខ) នៅថ្ងៃទី០១ខែមករាឆ្នាំ២០១៤។នៅក្នុងកិច្ចសន្យា (ក) និង (ខ) បានព្រមព្រៀងគ្នាថា(ក) ត្រូវប្រគល់នាឡិកាបុរាណទៅឲ្យ(ខ)នៅថ្ងៃបង្កើតកិច្ចសន្យាហើយ (ខ) ត្រូវបង់ប្រាក់ថ្លៃលក់ទិញ៤ខែក្រោយថ្ងៃបង្កើតកិច្ចសន្យាគឺនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤។

ដូច្នេះ (ក) មិនអាចទាមទារឲ្យ (ខ) បង់ប្រាក់ថ្លៃទិញនាឡិកានៅមុនថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ បានទេព្រោះរយៈពេល៤ខែជាឧបសគ្គតាមផ្លូវច្បាប់ ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងត្រូវចាប់ផ្តើមគិតពីថ្ងៃទី០២ ខែឧសភាឆ្នាំ២០១៤។




- **ករណីកិច្ចសន្យាកំណត់ពេលសងមិនពិតប្រាកដ**

ប្រសិនបើកិច្ចសន្យាលក់ទិញមានកំណត់ពេលសងមិនពិតប្រាកដក្នុងការអនុវត្តកាតព្វកិច្ចម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួននៅមុនពេលកំណត់បានឡើយ។ ហេតុដូច្នេះ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវគិតចាប់ពីពេល ដែលពេលកំណត់មិនប្រាកដនោះបានមកដល់។

ឧទាហរណ៍៖ (ក) បានធ្វើកិច្ចសន្យាលក់ទិញកាណូតជាមួយ (ខ) នៅថ្ងៃទី០១ខែមេសាឆ្នាំ២០១៤។ (ក) និង (ខ) បានព្រមព្រៀងគ្នាថា(ខ) ត្រូវប្រគល់កាណូតឲ្យ(ក)នៅថ្ងៃទី០២ខែមេសាឆ្នាំ២០១៤ហើយ(ក) ត្រូវបង់ប្រាក់ថ្លៃទិញកាណូតចំនួនពីរម៉ឺនដុល្លារអាមេរិកអោយ (ខ) នៅពេលទឹកទន្លេមេគង្គនៅមុខព្រះបរមរាជវាំងឡើងដល់កំពស់១០ម៉ែត្រកន្លះ។ ការកំណត់យកករណីដែលទឹកទន្លេមេគង្គនៅមុខព្រះបរមរាជវាំងឡើងដល់កំពស់១០ម៉ែត្រកន្លះគឺជាការកំណត់ពេលវេលាមិនពិតប្រាកដហើយ (ខ) មិនអាចទាមទារឲ្យ (ក) ប្រគល់ប្រាក់នៅមុនពេលដែលទឹកទន្លេមេគង្គឡើងដល់កំពស់១០ម៉ែត្រកន្លះនោះទេ។អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងចាប់ផ្តើមគិត នៅថ្ងៃបន្ទាប់ពីទឹកទន្លេមេគង្គឡើងដល់កំពស់១០ម៉ែត្រកន្លះ។




- **ករណីកិច្ចសន្យាគ្មានកំណត់ពេលសង**

ប្រសិនបើកិច្ចសន្យាគ្មានកំណត់ពេលសងនោះទេ ក្នុងករណីមួយចំនួន កាលកំណត់សងត្រូវបានកំណត់ដោយច្បាប់។ ឧទាហរណ៍៖ ពាក់ព័ន្ធនឹងកិច្ចសន្យាជួល ម្ចាស់បំណុល (ភតិបតី) អាចទាមទារអោយកូនបណុល (ភតិកៈ) បង់ថ្លៃឈ្នួលនៅរៀងរាល់ចុងខែ ចំពោះការជួលចលនវត្ថុ និងផ្ទះ ឬអាគារ ហើយចំពោះដីធ្លី ត្រូវបង់នៅរៀងរាល់ចុងឆ្នាំ (មាត្រា៦១០ កថាខណ្ឌ២)។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវចាប់ផ្តើមពីថ្ងៃបន្ទាប់នៃកាលកំណត់សងដែលកំណត់ដោយច្បាប់។

ក៏ប៉ុន្តែ ប្រសិនបើកាលកំណត់សងមិនត្រូវបានកំណត់ដោយការព្រមព្រៀងរបស់គូភាគី ឬ ដោយច្បាប់ទេ នោះកាតព្វកិច្ចមិនមានកាលកំណត់សងទេ។ ក្នុងករណីនេះ ម្ចាស់បំណុលអាចទាមទារឲ្យអនុវត្តកាតព្វកិច្ចនៅពេលណាក៏បាន។ ឧទាហរណ៍៖ ទាក់ទងនឹងកិច្ចសន្យាលក់ទិញ អ្នកលក់អាចទាមទារឲ្យអ្នកទិញបង់ប្រាក់ភ្លាមៗ នៅពេលជូនដំណឹងអំពីការទាមទារ (ម.៥៥៥ កថាខណ្ឌ៣)។ ហេតុដូច្នេះ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវគិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះកើតមានឡើង។

ដោយឡែកនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ម្ចាស់បំណុលត្រូវទុករយៈពេលសមរម្យបន្ទាប់ពីការជូនដំណឹងទៅកូនបំណុល ដូច្នេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវចាប់ផ្តើមពីពេលដែលអំឡុងពេលសមរម្យបានកន្លងផុត។

<u>ឧទាហរណ៍</u> ៖ (ក) បានជួលរថយន្តពី (ខ) នៅថ្ងៃទី០១ខែមករាឆ្នាំ២០១៤ហើយ(ខ) ក៏បានប្រគល់រថយន្តអោយ (ក) នៅថ្ងៃដដែលនេះដែរ តែពុំបានកំណត់ថ្ងៃបង់ប្រាក់ឈ្នួលនោះទេ។ ក្នុងករណីនេះ(ខ) មានសិទ្ធិទាមទារ ឲ្យ (ក) បង់ប្រាក់ថ្លៃឈ្នួលមកខ្លួននៅចុងខែមករា ដោយផ្អែកលើ (មាត្រា៦១០)ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវចាប់រាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៤។




## ខ. អំឡុងពេលនៃការចាប់ផ្តើមអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

តាមរយៈមាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណី ជាគោលការណ៍អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺមានរយៈពេល៥(ប្រាំ)ឆ្នាំ លើកលែងតែករណីដែលមានបទប្បញ្ញត្តិផ្សេងនៅក្នុងក្រមនេះ ឬច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតបានកំណត់។ ហេតុដូច្នេះចំណុចចាប់ផ្តើមនៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាចប្រែប្រួលទៅតាមករណីនីមួយៗ។

ប៉ុន្តែតាមរយៈមាត្រា ៤៨៣ នៃក្រមរដ្ឋប្បវេណី បានចែងថា ៖ ចំពោះសិទ្ធិលើបំណុលទាក់ទងនឹងថ្លៃទំនិញ ឬសេវាដែលផលិតករឬពាណិជ្ជករលក់ទៅឲ្យអ្នកដែលមិនមែនជាពាណិជ្ជករនោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអំឡុងពេលខ្លីគឺ០២ (ពីរ) ឆ្នាំ។

សិទ្ធិលើបំណុល ដែលមានអំឡុងពេលអាជ្ញាយុកាលខ្លីនេះ គឺស្ថិតក្នុងប្រតិបត្តិការរបស់អ្នកប្រើប្រាស់ ដែលជាធម្មតាតែងតែមានការលំបាកក្នុងការថែរក្សាទុកនូវភស្តុតាងផ្សេងៗ។

ឧទាហរណ៍៖ (ក)បានទិញកុំព្យូទ័រមួយគ្រឿងនៅហាងរបស់(ខ)និងបានទទួលយកកុំព្យូទ័រនៅថ្ងៃទី០១ខែមករាឆ្នាំ២០១៤តែ(ក) ពុំមានប្រាក់គ្រប់គ្រាន់ឲ្យ(ខ)ដូច្នេះ(ក) និង (ខ) ក៏បានព្រមព្រៀងគ្នាលើកាលកំណត់សងប្រាក់ថ្លៃលក់កុំព្យូទ័រដែលនៅខ្វះក្នុងរយៈពេល០៣ខែទៀតគឺថ្ងៃទី០១ខែមេសាឆ្នាំ២០១៤ តែ(ក)នៅតែមិនបានបង់ប្រាក់ថ្លៃលក់កុំព្យូទ័រគ្រប់ចំនួនជូន (ខ)នោះទេ។ ក្នុងករណីនេះ សិទ្ធិលើបំណុលនេះនឹងត្រូវរលត់ ប្រសិនបើអំឡុងពេល២ឆ្នាំបានកន្លងផុត គិតចាប់ពីពេលដែលកាលកំណត់សងបានកន្លងហួស គឺនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤។




ដោយឡែក តាមរយៈមាត្រា៤៨៤-១ នៃក្រមរដ្ឋប្បវេណី បានចែងថា៖ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរដោយសាលក្រមឬសាលដីកាស្ថាពរការដោះស្រាយតាមផ្លូវតុលាការឬដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់កំឡុងពេលនៃអាជ្ញាយុកាលតិចជាង០៥ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះត្រូវមានអំឡុងពេល០៥(ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលជាស្ថាពរដែរ។

ឧទាហរណ៍៖ ប្រសិនបើសាលក្រមសម្រាប់ការអនុវត្តសិទ្ធិលើបំណុលដែលមានអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ២ឆ្នាំបានចូលជាស្ថាពរនៅថ្ងៃទី២៦-០៦-២០១៤អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះត្រូវចាប់ផ្តើមពីថ្ងៃទី២៧-០៦-២០១៤និងសម្រេចនៅពេលបញ្ចប់ថ្ងៃទី២៦-០៦-២០១៩។ "វិធី

ផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ" រួមបញ្ចូលទាំងកំណត់ហេតុលះបង់ ឬទទួលស្គាល់ (មាត្រា២២២ក្រមនីតិវិធីរដ្ឋប្បវេណី) និងដីកាសម្រេចដាស់តឿនដែលចូលជាស្ថាពរ (មាត្រា ៣៣៣ក្រមនីតិវិធីរដ្ឋប្បវេណី)។

<u>ឧទាហរណ៍</u>៖ (ក)បានទិញកុំព្យូទ័រមួយគ្រឿងនៅហាងរបស់(ខ) នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដោយ (ក) និង (ខ) បានព្រមព្រៀងគ្នាលើកាលកំណត់សងថ្លៃកុំព្យូទ័រនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤។ ប៉ុន្តែ (ក) មិនបានសងថ្លៃកុំព្យូទ័រមកអោយ (ខ) តាមកាលកំណត់ដែលបានព្រមព្រៀងនោះទេ ដូចនេះ (ខ) ក៏បានដាក់ពាក្យបណ្ដឹងទាមទារប្រាក់ពី (ក) នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤(ស្ថិតក្នុងអំឡុងពេលនៃអាជ្ញាយុកាល០២ឆ្នាំ) ហើយសាលក្រមដែលបង្គាប់អោយ (ក) សងប្រាក់ទៅ (ខ) បានចូលជាស្ថាពរនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥។ តាមរយៈឧទាហរណ៍ខាងលើ សិទ្ធិលើបំណុលរបស់ (ខ) គឺជាសិទ្ធិលើបំណុលស្ថាពរ តាមស្មារតីនៃមាត្រា៤៨៤ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះ សិទ្ធិលើបំណុលនេះ ត្រូវផុតអាជ្ញាយុកាលក្នុងអំឡុងពេល០៥ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥។




ផ្ទុយមកវិញបើនៅពេលដែលលិខិតទាំងនោះចូលជាស្ថាពរមុនពេលកំណត់ត្រូវអនុវត្តមិនទាន់មកដល់ នោះរយៈពេលនៃអាជ្ញាយុកាលគឺមានរយៈពេល០៥ឆ្នាំឬ០២ឆ្នាំគិតចាប់ពីពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចបានមកដល់ (មាត្រា៤៨៤ )។

ឧទាហរណ៍៖ សាលក្រមដែលបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើបំណុលដែលមានអាជ្ញាយុកាល ២ឆ្នាំ បានចូលជាស្ថាពរប៉ុន្តែសិទ្ធិលើបំណុលដែលបានបញ្ជាក់មិនទាន់ដល់កាលកំណត់សងទេនោះអំឡុងពេលនៃអាជ្ញាយុកាលនៃសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់គឺនៅតែ ២ឆ្នាំដដែលហើយត្រូវចាប់ផ្ដើមនៅពេលដែលសិទ្ធិលើបំណុលនោះដល់កាលកំណត់សង។

ក្រៅពីនេះទៀត គឺមានបទបញ្ញត្តិពិសេសផ្សេងទៀតជាច្រើន ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ក៏ដូចជាច្បាប់ផ្សេងៗទៀត ដែលកំណត់អំពីអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលខុសប្លែកពីបទបញ្ញត្តិខាងលើ។ តាមរយៈស្មារតីនៃមាត្រា៧៦៥ នៃក្រមរដ្ឋប្បវេណីបានកំណត់ថាសិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថាអាចទាមទារសំណងនៃការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬបើអំឡុងពេល ១០ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលអំពើអនីត្យានុកូលបានប្រព្រឹត្តឡើង។

## ១.២. ភាពចាំបាច់និងបុគ្គលដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

➢ តើមានជនណាខ្លះដែលត្រូវបានចាត់ទុកថាជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ ?

តុលាការអាចសម្រេចអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានប្រសិនបើបុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ និងបុគ្គលដទៃទៀតមានដូចជា ៖ កូនបំណុល កូនបំណុលដោយសាមគ្គី អ្នកធានា អ្នកធានាដោយវត្ថុ និងតតិយជនដែលបានធ្វើលទ្ធកម្ម (មាត្រា៧៦៦) បានលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនៅក្នុងការទាមទាររបស់ខ្លួន បើមិនដូច្នេះទេតុលាការមិនអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានឡើយ ដើម្បីចៀសវាងដល់ការបំពាន"គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន"(មាត្រា៤៨៦-១)។

# ២. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

## ២.១. គោលគំនិត

ការផ្អាកអាជ្ញាយុកាលគឺជាការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាលក្នុងករណីមានហេតុនៃការផ្អាក។ នៅពេលដែលសិទ្ធិលើបំណុលត្រូវបានអនុវត្តឬនៅពេលដែលអត្ថិភាពនៃសិទ្ធិលើបំណុលត្រូវបានបញ្ជាក់ក្នុងពេលដែលអំឡុងពេលនៃអាជ្ញាយុកាលកំពុងដំណើរការ ដូចនេះ អំឡុងពេលនៃអាជ្ញាយុកាលត្រូវចាប់ផ្តើមដំណើរការសាជាថ្មីដោយរាប់ឡើងវិញចាប់ពីសូន្យនេះហៅថា "ការផ្អាកនៃអាជ្ញាយុកាល" (មាត្រា ៤៩៤ ) ។

ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិមាន៖

- ការទាមទារតាមផ្លូវតុលាការក្នុងការចូលរួមនីតិវិធីធនក្ស័យឬការអនុវត្តសិទ្ធិលើបំណុលដែលមានលក្ខណៈប្រហាក់ប្រហែល។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវបានផ្អាកនៅពេលដែលបានដាក់ពាក្យបណ្តឹង ឬ នៅពេលដែលបានដាក់នូវឯកសារបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ទៅតុលាការ ឬ

បណ្ដឹងទាមទារបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី (មាត្រា៨៧នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "នៅពេលបានដាក់ពាក្យបណ្ដឹង" គឺជាពេលដែលដើមចោទដាក់ពាក្យបណ្ដឹងទៅតុលាការ (មាត្រា៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ឬដាក់បណ្ដឹងតប (មាត្រា៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ឬ អាចដាក់ពាក្យសុំចូលរួមអន្តរាគមន៍ជាសហបណ្ដឹង (មាត្រា៤៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងចាប់ផ្ដើមគិតសារជាថ្មីនៅពេលដែលសាលក្រម ឬសាលដីកាចូលជាស្ថាពរ (មាត្រា ៤៩៥)។

ឧទាហរណ៍៖ (ក) បានបង្កើតកិច្ចសន្យាលក់ទិញនាឡិកាបុរាណជាមួយ (ខ) នៅថ្ងៃទី០១ខែមករា ឆ្នាំ២០១៤។ នៅក្នុងកិច្ចសន្យា (ក)និង (ខ) បានព្រមព្រៀងគ្នាថា (ក) ត្រូវប្រគល់នាឡិកាបុរាណទៅឲ្យ (ខ) នៅថ្ងៃបង្កើតកិច្ចសន្យាហើយ(ខ) ត្រូវបង់ប្រាក់ថ្លៃលក់ទិញ៤ខែក្រោយថ្ងៃបង្កើតកិច្ចសន្យា គឺនៅថ្ងៃទី០១ខែឧសភា ឆ្នាំ២០១៤។ ប៉ុន្តែ(ខ)មិនបានបង់ប្រាក់តាមកាលកំណត់នោះទេដូចនេះនៅថ្ងៃទី០១ខែកក្កដាឆ្នាំ២០១៥ (ក) បានដាក់ពាក្យបណ្ដឹងទៅតុលាការ ដែលជាហេតុនាំអោយមានការផ្អាកអាជ្ញាយុកាល ហើយនៅថ្ងៃទី០១ខែមករាឆ្នាំ២០១៦តុលាការបានចេញសាលក្រមបង្គាប់ឲ្យបង់ប្រាក់ចូលជាស្ថាពរ។ ដូចនេះ អាជ្ញាយុកាលត្រូវចាប់ផ្ដើមគិតជាថ្មីបន្ទាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ គឺថ្ងៃទី០២ខែមករា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី០១ខែមករាឆ្នាំ២០២១។



- សកម្មភាពអនុវត្តដោយបង្ខំឬសកម្មភាពចាត់ចែងរក្សាការពារ។ សកម្មភាពអនុវត្តដោយបង្ខំ សំដៅលើសកម្មភាពដែលមានគោលដៅ ដើម្បីរឹបអូសការអនុវត្តនូវសិទ្ធិទាមទារអោយប្រគល់វត្ថុជាដើម និងការអនុវត្តសិទ្ធិប្រាតិភោគ។ រីឯសកម្មភាពចាត់ចែងរក្សាការពារគឺសំដៅទៅលើការរឹបអូស ឬការចាត់ចែងជាបណ្ដោះអាសន្ន។ សកម្មភាពទាំងពីរនេះបានបង្ហាញយ៉ាងច្បាស់លាស់នូវការអះអាងសិទ្ធិពីសំណាក់ម្ចាស់បំណុល ទើបក្រមរដ្ឋប្បវេណីចាត់ទុកថាសកម្មភាពទាំងពីរនេះជាហេតុនាំអោយផ្អាកអាជ្ញាយុកាល ។ អាជ្ញាយុកាលត្រូវផ្អាក នៅពេលដែលដាក់ពាក្យសុំអនុវត្តដោយបង្ខំ ឬដាក់ពាក្យសុំចាត់ចែងរក្សាការពារ។

ការផ្អាកនឹងមានអានុភាព នៅពេលដែលពាក្យសុំឲ្យអនុវត្តដោយបង្ខំ ត្រូវបានដាក់ទៅតុលាការ (មាត្រា៣៣៥ និង មាត្រា៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងចាប់ផ្ដើមគិតសាជាថ្មី នៅពេលដែលលែងមានមូលហេតុនៃការផ្អាក (មាត្រា៤៩៤)។ ដូច្នេះ ការផ្អាកនឹងបន្តអានុភាព ដរាបណាការចុះបញ្ជីអំពីការរឹបអូសនៅមានអត្ថិភាព។

ចំពោះការចាត់ចែងរក្សាការពារ ការផ្អាកនឹងមានអានុភាព នៅពេលដែលពាក្យសុំនៃការចាត់ចែងរក្សាការពារ ត្រូវបានដាក់ទៅតុលាការ (មាត្រា៥៣៩ និង៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងចាប់ផ្ដើមគិតសាជាថ្មី នៅពេលដែលមូលហេតុនៃការផ្អាកលែងមាន (មាត្រា៤៩៤)។ ដូច្នេះអានុភាពនៃការផ្អាកនៅតែមាន ដរាបណាការចុះបញ្ជីនៃការរឹបអូសជាបណ្ដោះអាសន្ននៅមានអត្ថិភាព។

<u>ឧទាហរណ៍</u>៖ (ក) បានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយ (ខ) ហើយ (ខ) បានបង្កើតហ៊ីប៉ូតែកដើម្បីធានាសិទ្ធិលើបំណុលនេះនៅថ្ងៃទី០១ខែមករាឆ្នាំ២០១៤ដោយកំណត់រយៈពេលសង២ឆ្នាំគឺថ្ងៃទី០១ខែមករាឆ្នាំ២០១៦។ ហ៊ីប៉ូតែកនេះបានបង្កើតដោយលិខិតយថាភូតនិងបានចុះបញ្ជី។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ក៏បានអនុវត្តហ៊ីប៉ូតែកដូចនេះនៅពេល (ក) អនុវត្តដោយបង្ខំដោយយកលិខិតយថាភូត ដែលជាលិខិតអនុវត្តមុនរយៈពេល៥ឆ្នាំនោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងត្រូវបានផ្អាក។



ប៉ុន្តែក្នុងករណីបណ្តឹងត្រូវបានលើកចោល ឬត្រូវបានដកវិញ នោះការដាក់ពាក្យបណ្តឹងដែលបានធ្វើកន្លងមក ពុំមានអានុភាពផ្អាកអាជ្ញាយុកាលនោះទេ។ តាមរយៈស្មារតីមាត្រា៤៩១ នៃក្រមរដ្ឋប្បវេណី ការលើកបណ្តឹងចោល គឺសំដៅលើការលើកបណ្តឹងចោល ដោយសារមូលហេតុនីតិវិធី និងការច្រានបណ្តឹងចោលដោយមូលហេតុសារធាតុផងដែរ។

ឧទាហរណ៍នៃមាត្រា៤៩១មានដូចជា ប្រសិនបើដើមចោទមិនបានបង់ជាមុននូវសោហ៊ុយសម្រាប់ធ្វើការកោះហៅ (មាត្រា៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ឬតុលាការបានលើកបណ្តឹងដែលមិនបានបំពេញល័ក្ខខ័ណ្ឌនៃមាត្រា៧៥ កថាខណ្ឌទី២ និងបញ្ជូនពាក្យបណ្តឹងមិនត្រឹមត្រូវទៅចុងចម្លើយ បន្ទាប់មកតុលាការបានចេញដីកាសម្រេចលើកបណ្តឹងចោល ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ឬសាលក្រមច្រានចោលការទាមទារនៅក្រោយការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងករណីទាំងនេះ ការផ្អាកមិនមានអានុភាពទេ។ ជាងនេះទៅទៀត នៅក្នុងករណីនៃការដកបណ្តឹង (មាត្រា២១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ការលើកបណ្តឹងចោល (មាត្រា៧៨ កថាខណ្ឌទី២) ឬសាលក្រមច្រានចោលការទាមទារនោះការផ្អាកក៏មិនមានអានុភាពដែរ នៅក្នុងករណីទាំងនេះ ប្រសិនបើពាក្យបណ្តឹងបានបញ្ជូនទៅដល់កូនបំណុល ការបង្អង់ដែលជាការទាមទារនឹងមានអានុភាព (មាត្រា ៤៩៥ កថាខណ្ឌទី២)។

ឧទាហរណ៍នៃមាត្រា៤៩២ មានដូចជាក្នុងករណីដែលការចាត់ចែងអនុវត្តដោយបង្ខំ ឬការរក្សាការពារ ត្រូវបានលុបចោលតាមពាក្យសុំរបស់ភាគី ឬដោយសារខ្វះល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ គឺត្រូវចាត់ទុកថា មិនមានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ។ ឧទាហរណ៍ នៅក្រោយការរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយការចុះបញ្ជីនៃការរឹបអូសជាបណ្តោះអាសន្ននៅមានអត្ថិភាពក្នុងរយៈពេលវែង ដូច្នេះ កូនបំណុលដាក់ពាក្យសុំឲ្យលុបចោលដីកាសម្រេចចាត់ចែងរក្សាការពារ ដោយមូលហេតុមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តី (មាត្រា៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីក្នុងអំឡុងពេល ដែលកំណត់ដោយតុលាការ នោះដីកាសម្រេចចាត់ចែងរក្សាការពារ ត្រូវបានលុបចោល ហើយការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នក៏ត្រូវបានលុបចោលដែរ (មាត្រា៥៦៤ និងមាត្រា៣៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយការផ្អាកក៏ត្រូវបានចាត់ទុកថាមិនបានកើតឡើងដែរ (មាត្រា៤៩២)។

ឧទាហរណ៍៖ (ក) បានបង្កើតកិច្ចសន្យាលក់ទិញនាឡិកាបុរាណជាមួយ (ខ)នៅថ្ងៃទី០១ខែមករា ឆ្នាំ២០១៤។ នៅក្នុងកិច្ចសន្យា (ក) និង (ខ) បានព្រមព្រៀងគ្នាថា (ក) ត្រូវប្រគល់នាឡិកាបុរាណទៅឲ្យ(ខ) នៅថ្ងៃបង្កើតកិច្ចសន្យាហើយ(ខ) ត្រូវបង់ប្រាក់ថ្លៃលក់ទិញ៤ខែក្រោយថ្ងៃបង្កើតកិច្ចសន្យាគឺនៅថ្ងៃទី០១ខែឧសភា ឆ្នាំ២០១៤។ ប៉ុន្តែ (ខ) ពុំបានបង់ថ្លៃលក់ទិញអោយ (ក) តាមកាលកំណត់នោះទេ។ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ (ក) បានដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នលើទ្រព្យរបស់(ខ) ដែលជាហេតុនាំអោយអាជ្ញាយុកាលត្រូវបានផ្អាក។ ក្រោយមក នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ (ក) ក៏បានដកពាក្យសុំរឹបអូសជាបណ្តោះអាសន្ននោះវិញ ដូចនេះអាជ្ញាយុកាលនៃការរំលត់លើបំណុលមិនត្រូវបានផ្អាកនោះទេដូចនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ មកវិញ រហូតដល់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩។




- ការទទួលស្គាល់កាតព្វកិច្ចដោយការសងមួយផ្នែកការបង់ការប្រាក់ការដាក់ប្រាតិភោគ ឬវិធីផ្សេងៗ (មាត្រា៤៨៩)៖

នៅពេលដែលកូនបំណុលបានទទួលស្គាល់អត្ថិភាពនៃកាតព្វកិច្ច ដោយបានធ្វើសកម្មភាពផ្សេងៗនាំអោយម្ចាស់បំណុលមានជំនឿជឿជាក់ទៅលើកូនបំណុល ហើយមិនបានធ្វើការអនុវត្តសិទ្ធិរបស់ខ្លួន នោះជាការមិនសមរម្យឡើយដែលអនុញ្ញាតអោយអាជ្ញាយុកាលមានដំណើរការហេតុដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបានកំណត់នូវសកម្មភាពផ្សេងៗរបស់កូនបំណុល ដែលចាត់ទុកថាជាការទទួលស្គាល់កាតព្វកិច្ចដោយការសងមួយផ្នែកការបង់ការប្រាក់ ឬការដាក់ប្រាតិភោគ ជាដើម។

ចំពោះការទទួលស្គាល់អត្ថិភាពនៃកាតព្វកិច្ចរបស់កូនបំណុល ការផ្អាកនឹងមានអានុភាព នៅពេលដែលការទទួលស្គាល់បានដល់ម្ចាស់បំណុល។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងចាប់ផ្តើមគិតសារជាថ្មី នៅពេលការទទួលស្គាល់មានអានុភាព។ "ការទទួលស្គាល់អត្ថិភាពនៃសិទ្ធិលើបំណុលតាមរយៈ

មធ្យោបាយផ្សេងៗទៀត” រាប់បញ្ចូលទាំងការអង្វររបស់កូនបំណុលសុំឲ្យម្ចាស់បំណុលពន្យាពេលសង / ការត្រួតពិនិត្យសមតុល្យនៃទឹកប្រាក់បន្ថែម ការដាក់ប្រាក់បញ្ញើបន្ថែម ឬការដកប្រាក់ចេញពីគណនេយ្យធនាគារ (ទាក់ទងនឹងសិទ្ធិលើបំណុលនៃគណនេយ្យធនាគារ)។

ឧទាហរណ៍៖(ក) បានបង្កើតកិច្ចសន្យាលក់ទិញនាឡិកាបុរាណជាមួយ (ខ) នៅថ្ងៃទី០១ខែមករាឆ្នាំ២០១៤។នៅក្នុងកិច្ចសន្យា (ក) និង (ខ) បានព្រមព្រៀងគ្នាថា (ក)ត្រូវប្រគល់នាឡិកាបុរាណទៅឲ្យ(ខ) នៅថ្ងៃបង្កើតកិច្ចសន្យាហើយ(ខ) ត្រូវបង់ប្រាក់ថ្លៃលក់ទិញ៤ខែក្រោយថ្ងៃបង្កើតកិច្ចសន្យា គឺនៅថ្ងៃទី០១ខែឧសភាឆ្នាំ២០១៤។ នៅថ្ងៃទី០១ខែតុលាឆ្នាំ២០១៦ (ខ) បានបង់ប្រាក់មួយផ្នែកដែលនេះជាហេតុនៃការផ្អាកអាជ្ញាយុកាលហើយអាជ្ញាយុកាលត្រូវគិតជាថ្មីចាប់ពីថ្ងៃទី០២ ខែតុលាឆ្នាំ២០១៦រហូតដល់ថ្ងៃទី០១ខែតុលាឆ្នាំ២០២១។




## ២.២. អានុភាពនៃការផ្អាកអាជ្ញាយុកាល

តាមរយៈមាត្រា៤៩០នៃក្រមរដ្ឋប្បវេណី អានុភាពនៃការផ្អាកអាជ្ញាយុកាលមានពីរករណីគឺ៖

- បើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកើតឡើងចំពោះកូនបំណុលនោះ បុគ្គលផ្សេងទៀតមិនអាចតវ៉ានឹងការផ្អាកនេះបានដែរ (មាត្រា៤៩០កថាខណ្ឌ១)។

ឧទាហរណ៍៖ ប្រសិនបើម្ចាស់បំណុលបានដាក់ពាក្យបណ្ដឹងចំពោះកូនបំណុលឬកូនបំណុលបានទទួលស្គាល់សិទ្ធិលើបំណុលនោះអាជ្ញាយុកាលនៃកាតព្វកិច្ចចំបង គឺត្រូវបានផ្អាក។ អ្នកធានានៃកាតព្វកិច្ចចំបង តតិយជនដែលបានបង្កើតហ៊ីប៉ូតែកនៃកាតព្វកិច្ចចំបង ឬតតិយជនទទួលបន្តនូវហ៊ីប៉ូតែកនោះមិន

អាចលើកឡើងពីអាជ្ញាយុកាលនៃកាតព្វកិច្ចចំបងបានដែរ។ ក្នុងករណីនេះអាជ្ញាយុកាលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាគឺត្រូវបានផ្អាកផងដែរ (មាត្រា៩០៩កថាខណ្ឌទី៤)។

- បើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកើតឡើងចំពោះភាគីដទៃទៀតក្រៅពីកូនបំណុលនោះការផ្អាកមានអានុភាពតែរវាងម្ចាស់បំណុលនិងភាគីនោះតែប៉ុណ្ណោះ (មាត្រា៤៩០កថាខណ្ឌ២)។ ប៉ុន្តែមានការលើកលែងដូចជាមាត្រា៤៩៣និង ៩០៩វាក្យខណ្ឌទី២។

<u>ឧទាហរណ៍៖</u>ប្រសិនបើម្ចាស់បំណុលបានអនុវត្តហ៊ីប៉ូតែករបស់តតិយជនដែលបង្កើតហ៊ីប៉ូតែកនោះអាជ្ញាយុកាលនៃកាតព្វកិច្ចចំបងនឹងត្រូវបានផ្អាក។ ប៉ុន្តែប្រសិនបើកូនបំណុលត្រូវបានជូនដំណឹងពីការអនុវត្តហ៊ីប៉ូតែកនោះកាតព្វកិច្ចចំបងនឹងត្រូវបានផ្អាកផងដែរ (មាត្រា៤៩៣វាក្យខណ្ឌទី២)។ ការជូនដំណឹងនេះអាចធ្វើបានដោយម្ចាស់បំណុលឬតុលាការអនុវត្ត (មាត្រា៤១៩កថាខណ្ឌទី២)។

<u>ឧទាហរណ៍៖</u> ក្នុងករណីដែលម្ចាស់បំណុលបានដាក់ពាក្យបណ្តឹងចំពោះអ្នកធានាដើម្បីដាស់តឿនឲ្យសងសិទ្ធិលើបំណុលដែលត្រូវបានធានាឬអ្នកធានាបានទទួលស្គាល់សិទ្ធិលើបំណុលដែលត្រូវបានធានានោះអាជ្ញាយុកាលនៃកាតព្វកិច្ចចំបងនឹងមិនត្រូវបានផ្អាកទេ។ ប៉ុន្តែប្រសិនបើអ្នកធានាជាអ្នកធានាដែលបានទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងនោះអាជ្ញាយុកាលនៃកាតព្វកិច្ចចម្បងនឹងត្រូវបានផ្អាកផងដែរ (មាត្រា៩០៩វាក្យខណ្ឌទី២)។

## ៣- ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

### ៣.១. គោលគំនិត

ការបង្អង់គឺជាការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាលតែនៅក្នុងអំឡុងពេលដែលត្រូវបង្អង់នោះតែប៉ុណ្ណោះ។ ការបង្អង់អាជ្ញាយុកាលគឺគ្រាន់តែជាការធ្វើកុំឲ្យអាជ្ញាយុកាលបានសំរេចតែប៉ុណ្ណោះមានន័យថាគ្រាន់តែជាការបញ្ឈប់នូវដំណើរការនៃអាជ្ញាយុកាលនៅដំណាក់កាលចុងក្រោយដែលជាពេលបញ្ចប់នៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (មាត្រា៤៩៥-៤៩៨)។

### ៣.២. មូលហេតុនៃការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

មូលហេតុនៃការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរួមមាន៖

- ការដាស់តឿន (មាត្រា៤៩៥-២)។

-អនីតិជនឬជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ (មាត្រា៤៩៦)

- សហព័ទ្ធ (មាត្រា៤៩៧ )

- មហន្តរាយធម្មជាតិ (មាត្រា៤៩៨ )

## ➢ ការដាស់តឿន

តាមរយៈមាត្រា ៤៩៥ (កថាខណ្ឌ២) នៃក្រមរដ្ឋប្បវេណី បានចែងថា ៖ ក្នុងករណីអ្នកមានសិទ្ធិបានដាស់តឿននៅពេលណាមួយក្នុងអំឡុងពេល០៦ខែ មុនផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល នោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងមិនត្រូវបានសម្រេចចំពោះអ្នកនោះក្នុងអំឡុងពេល០៦ខែ បន្ទាប់ពីការដាស់តឿនឡើយ ទោះបីជាការលើកចោល ឬការដកពាក្យបណ្ដឹងនោះ ស្ថិតក្នុងអំឡុងពេលដែលអាជ្ញាយុកាលត្រូវបានសំរេចក៏ដោយ ក៏ទទួលបានការបង្អង់ចំនួន ០៦ខែ ទៀតផងដែរ។

ឧទាហរណ៍នៃមាត្រា៤៩៥ (កថាខណ្ឌ៣) ប្រសិនបើកូនបំណុលដាក់ពាក្យប្ដឹង ដើម្បីបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិលើបំណុល បើម្ចាស់បំណុលបានអះអាងអំពីសិទ្ធិរបស់ខ្លួន ហើយការអះអាងនោះនឹងត្រូវចាត់ទុកថាជាការដាស់តឿន នោះអាជ្ញាយុកាលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងមិនត្រូវបានសម្រេចចំពោះអ្នកនោះក្នុងអំឡុងពេល០៦ខែ បន្ទាប់ពីសាលក្រម ឬសាលដីកានៃបណ្ដឹងនោះចូលជាស្ថាពរ។

ការដាស់តឿនគឺជាហេតុមួយនៃការបង្អង់ការសម្រេចអាជ្ញាយុកាលតែការដាស់តឿននេះគឺធ្វើបានតែម្ដងតែប៉ុណ្ណោះ ទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្ដងទៀតក៏ដោយ ក៏មិនអាចពន្យឺតការសម្រេចអាជ្ញាយុកាលនៃការរលត់សិទ្ធិដោយការដាស់តឿនម្ដងទៀតនោះដែរ។

ម្យ៉ាងវិញទៀតត្រូវចាត់ទុកជាការដាស់តឿនតាមផ្លូវតុលាការចាប់ពីពេលដែលបណ្ដឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្ដឹងត្រូវបានលើកចោល ឬដកវិញនោះ ដូចនេះ អាជ្ញាយុកាលមិនត្រូវបានសម្រេចឡើយ ក្នុងអំឡុងពេល០៦ខែ បន្ទាប់ពីការលើកបណ្ដឹងចោល ឬការដកពាក្យបណ្ដឹង។

ឧទាហរណ៍៖(ក) បានបង្កើតកិច្ចសន្យាលក់ទិញនាឡិកាបុរាណជាមួយ (ខ) នៅថ្ងៃទី០១ខែមករាឆ្នាំ ២០១៤។នៅក្នុងកិច្ចសន្យា (ក) និង (ខ) បានព្រមព្រៀងគ្នាថា (ក) ត្រូវប្រគល់នាឡិកាបុរាណទៅឲ្យ (ខ) នៅថ្ងៃបង្កើតកិច្ចសន្យា ហើយ(ខ) ត្រូវបង់ប្រាក់ថ្លៃលក់ទិញ៤ខែក្រោយថ្ងៃបង្កើតកិច្ចសន្យា គឺនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤។ ប៉ុន្តែ (ខ) ពុំបានបង់ថ្លៃលក់ទិញអោយ (ក) តាមកាលកំណត់នោះទេ។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ (ក) បានដាស់តឿនអោយ(ខ) សងប្រាក់មកខ្លួន ដូចនេះ អាជ្ញាយុកាលត្រូវបានបង្អង់ចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ។




- **អនីតិជនឬជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ**

ការបង្អង់អាជ្ញាយុកាលក្នុងករណីអនីតិជនឬជននៅក្រោមអាណាព្យាបាលទូទៅគឺធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់អនីតិជននិងជននៅក្រោមអាណាព្យាបាលទូទៅពីការដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានសំរេចដោយសារតែជនទាំងនោះពុំបានចាត់វិធានការឲ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានដោយសារខ្លួនជាអនីតិជនឬជននៅក្រោមអាណាព្យាបាលទូទៅគ្មានអ្នកតំណាងដែលច្បាប់កំណត់នៅអំឡុងពេល ០៦ខែមុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលដូចនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងមិនត្រូវបានសម្រេចក្នុងអំឡុងពេល០៦ខែក្រោយពីជននោះក្លាយជាសមត្ថជនឬមានអ្នកតំណាងដែលច្បាប់កំណត់ (មាត្រា៤៩៦នៃក្រមរដ្ឋប្បវេណី)។

<u>ឧទាហរណ៍</u>៖ (ក) ជាអនីតិជនអាយុ១៥ឆ្នាំ ហើយត្រូវឪពុកម្ដាយស្លាប់ចោលដោយគ្រោះថ្នាក់ចរាចរណ៍។ ពេលឪពុកម្ដាយរបស់(ក)នៅរស់ (ខ) បានជំពាក់បំណុលឪពុកម្ដាយរបស់ (ក) ចំនួន១០០០០$ ដូចនេះសិទ្ធិលើបំណុលនេះត្រូវបន្តទៅ(ក) ដែលជាកូនរបស់គាត់។ ចំពោះករណីនេះ ប្រសិនបើ (ក)ពុំបានដឹងអំពីអាជ្ញាយុកាលនៃសិទ្ធិលើបំណុលរបស់ខ្លួនដែលមានបន្តពីឪពុកម្ដាយរបស់ខ្លួន ហើយក៏គ្មានអ្នកតំណាងដែលច្បាប់កំណត់ក្នុងអំឡុងពេល០៦ខែ មុនអំឡុងពេលផុតអាជ្ញាយុកាល នោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចឡើយ បន្ទាប់ពី(ក)បានក្លាយជាសមត្ថជនឬមានអ្នកតំណាងដែលច្បាប់កំណត់។

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©




- **សហព័ទ្ធ**

ការចាត់វិធានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរវាងប្ដីនិងប្រពន្ធគឺជាការពិបាកមួយ ទើបច្បាប់បានកំណត់ទុកពេលវេលាមួយសមស្របក្រោយពីមានការរំលាយអាពាហ៍ពិពាហ៍ដើម្បីបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ចំពោះសិទ្ធិដែលសហព័ទ្ធម្ខាងមានលើសហព័ទ្ធម្ខាងទៀតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែក្រោយពីការរំលាយអាពាហ៍ពិពាហ៍ឡើយ (មាត្រា៥៩៧ នៃក្រមរដ្ឋប្បវេណី)។

<u>ឧទាហរណ៍</u> ៖ លោក(ក) និងអ្នកស្រី (ខ) ជាប្ដីប្រពន្ធនឹងគ្នា។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ លោក(ក) បានខ្ចីប្រាក់ពីអ្នកស្រី (ខ) ចំនួន១០០០០$ យកទៅវិនិយោគ ដោយសន្យាថាសងវិញនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល៥ឆ្នាំ គឺនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ហើយនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ អ្នកទាំងពីរបានលែងលះគ្នា ហើយសាលក្រមលែងលះបានចូលជាស្ថាពរនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល០៦ខែ ក្រោយពីសាលក្រមលែងលះចូលជាស្ថាពរ។



## ➢ មហន្តរាយធម្មជាតិ

ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិគឺសំដៅលើករណីអ្នកមានសិទ្ធិមិនអាចចាត់វិធានការឲ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិដូចជាខ្យល់ព្យុះ រញ្ជួយផែនដី ទឹកជំនន់ និងករណីប្រធានសក្តិផ្សេងៗជាដើម នៅពេលណាមួយក្នុងរយៈពេល០៦ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល នោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវបានសម្រេចក្នុងអំឡុងពេល ០៦ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុតឡើយ(មាត្រា៥៩៨ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ (ក) បានបង្កើតកិច្ចសន្យាលក់ទិញនាឡិកាបុរាណជាមួយ (ខ) នៅថ្ងៃទី០១ខែមករា ឆ្នាំ២០១៤។ នៅក្នុងកិច្ចសន្យា (ក) និង (ខ) បានព្រមព្រៀងគ្នាថា (ក) ត្រូវប្រគល់នាឡិកាបុរាណទៅឲ្យ (ខ) នៅថ្ងៃបង្កើតកិច្ចសន្យាហើយ(ខ) ត្រូវបង់ប្រាក់ថ្លៃលក់ទិញ៤ខែក្រោយថ្ងៃបង្កើតកិច្ចសន្យាគឺនៅថ្ងៃទី០១ខែឧសភា ឆ្នាំ២០១៤។ ប៉ុន្តែ (ខ) ពុំបានបង់ថ្លៃលក់ទិញ អោយ(ក) តាមកាលកំណត់នោះទេ។ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ មុនថ្ងៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរលត់ ក៏ស្រាប់តែមានទឹកជំនន់កើតឡើង ជាហេតុធ្វើអោយ(ក) មិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបានទាន់ពេលវេលា ហើយនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ទឹកជំនន់បានស្រកវិញ ដូចនេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានបង្អង់ចំនួន ០៦ខែ បន្ទាប់ពីថ្ងៃទឹកជំនន់ត្រូវបានស្រក គឺចាប់ពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ។



## ៤- ការបោះបង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនអាចបោះបង់ចោលជាមុនបានទេ តែអ្នកមានផលប្រយោជន៍ ពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាចបោះបង់ចោលផលប្រយោជន៍នោះបាន តែចំពោះផលប្រយោជន៍នៃអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល ដែលបានសំរេចហើយតែប៉ុណ្ណោះ (មាត្រា៤៨៧) មានន័យថាការសន្យាពិសេសរបស់កូនបំណុលក្នុងការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជាមុននឹងមិនមានអានុភាពនោះទេ។

## ៥- អានុភាពនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អានុភាពនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអានុភាពប្រតិសកម្មចាប់តាំងពីថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាល (មាត្រា ៤៨៥)។

### ៥.១.អានុភាពដាច់ខាតនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

នៅពេលដែលកូនបំណុលមានស្ថានភាពអាចរួចផុតពីកាតព្វកិច្ចដោយផ្ទាល់តាមរយៈអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវមានអានុភាពដាច់ខាតចំពោះបុគ្គលទាំងអស់ (មាត្រា៤៨៦ កថាខណ្ឌទី៣ វាក្យខណ្ឌទី១)។

<u>ឧទាហរណ៍</u>៖ (ក) បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តជាមួយ(ខ) នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ហើយក៏បានប្រគល់រថយន្តអោយ(ខ) នៅថ្ងៃដដែល។ ប៉ុន្តែ (ខ) មិនទាន់មានប្រាក់ដើម្បីបង់ថ្លៃទិញរថយន្ត ដូចនេះ (ក) និង (ខ) ក៏បានព្រមព្រៀងគ្នាដោយ (ខ) នឹងបង់ប្រាក់ថ្លៃទិញរថយន្តនោះនៅ០៦ខែក្រោយ ហើយ (គ) ជាអ្នកធានា ។ ក្នុងករណីដែលកូនបំណុល (ខ) លើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះកាតព្វកិច្ចរបស់(ខ)ក៏ត្រូវរលត់ទន្ទឹមនឹងនោះសិទ្ធិប្រាតិភោគក៏ត្រូវរលត់ដោយស្វ័យប្រវត្តិដែរ។ ដូចនេះ (ក) មិនអាចទាមទារអោយអ្នកធានា (គ) សងបំណុលមកខ្លួនដែរ (មាត្រា៩០៤ កថាខណ្ឌទី៣)។

### ៥.២.អានុភាពមិនដាច់ខាតនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

នៅពេលដែលមានសិទ្ធិលើកឡើងក្រៅពីកូនបំណុលបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អានុភាពនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិមានត្រឹមអានុភាពមិនដាច់ខាតប៉ុណ្ណោះ ក្នុងន័យនេះ គឺដើម្បីគោរពឆន្ទៈរបស់កូនបំណុល ស្តីពីចំណុចថាតើត្រូវទទួលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ឬយ៉ាងណា (មាត្រា៤៨៦ កថាខណ្ឌទី៣ វាក្យខណ្ឌទី២)។

<u>ឧទាហរណ៍</u>៖ (ក) បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តជាមួយ(ខ) នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ហើយក៏បានប្រគល់រថយន្តអោយ(ខ) នៅថ្ងៃដដែល។ ប៉ុន្តែ (ខ) មិនទាន់មានប្រាក់ដើម្បីបង់ថ្លៃទិញរថយន្ត

ដូចនេះ (ក) និង (ខ) ក៏បានព្រមព្រៀងគ្នាដោយ (ខ) នឹងបង់ប្រាក់ថ្លៃទិញរថយន្តនោះនៅ០៦ខែក្រោយហើយ (គ) ជាអ្នកធានា។ ក្នុងករណីដែលអ្នកធានា(គ) បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានធានា ក្នុងទំនាក់ទំនងរវាងអ្នកធានា(គ) និងម្ចាស់បំណុល(ក) នោះសិទ្ធិលើបំណុលត្រូវរលត់ អ្នកធានា(គ) ត្រូវរួចផុតពីកាតព្វកិច្ចធានា (មាត្រា៩០៤ កថាខណ្ឌទី៣)។ ប៉ុន្តែថាតើសិទ្ធិលើបំណុលត្រូវរំលត់ក្នុងទំនាក់ទំនងជាមួយកូនបំណុល ឬយ៉ាងណានោះ ត្រូវអាស្រ័យលើការជ្រើសរើសរបស់កូនបំណុល ពោលគឺដរាបណាកូនបំណុលមិនលើកឡើងទេ សិទ្ធិលើបំណុលមិនត្រូវបានរលត់ឡើយ (មាត្រា៤៨៦ កថាខណ្ឌ២ និងកថាខណ្ឌ៣ វាក្យខណ្ឌទី២ និងមាត្រា៩០៥ កថាខណ្ឌទី១)។

## សន្និដ្ឋាន

ជារួម យើងឃើញថាអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជាបញ្ញត្តិមួយក្នុងក្រមរដ្ឋប្បវេណីដែលផ្តល់ការសង្គ្រោះដល់កូនបំណុល ក្នុងករណីដែលម្ចាស់បំណុលធ្វេសប្រហែសមិនអើពើដល់សិទ្ធិលើបំណុលដែលខ្លួនមានហួសពីរយៈពេលដែលកំណត់ដោយច្បាប់។

យ៉ាងណាមិញ តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនក្នុងទំនាក់ទំនងរដ្ឋប្បវេណី និងគោលការណ៍នៃការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់ កូនបំណុល ដើម្បីទទួលបានផលប្រយោជន៍ពីគោលការណ៍អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចាំបាច់ត្រូវលើកឡើងអំពីគោលការណ៍នេះដោយផ្ទាល់នៅចំពោះមុខតុលាការវិនិច្ឆ័យ បើមិនដូច្នោះទេកូនបំណុលចាត់ទុកថាបានបោះបង់សិទ្ធិរបស់ខ្លួន។ ហេតុដូច្នេះភាពសកម្មនៃម្ចាស់បំណុលនិងកូនបំណុលនៃកាតព្វកិច្ចជាធាតុសំខាន់នៃគោលការណ៍អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

# សិក្ខាសាលាគណៈមេធាវី(ធំ)លើកទី៧

## ប្រធានបទ៖ អាពាហ៍ពិពាហ៍ និង ការលែងលះ

## ថ្ងៃទី ១១ កញ្ញា ២០១៤

# ការបង្កើតអាពាហ៍ពិពាហ៍

## សេចក្តីផ្តើម ៖

នៅប្រទេសកម្ពុជាយើងប្រកាន់ខ្ជាប់នូវប្រពៃណីទំនៀមទំលាប់ក្នុងការប្រារព្ធពិធីផ្សេងៗ ក្នុងនោះក៏មានពិធីរៀបអាពាហ៍ពិពាហ៍ផងដែរ។ តាមទំនៀមទំលាប់តាំងពីបុរាណ មុនឈានដល់ការរៀបអាពាហ៍ពិពាហ៍ គឺត្រូវឆ្លងកាត់ច្រើនដំណាក់កាល ដែលក្នុងនោះរួមមានពិធីកំជាប់ពាក្យជាដើម ប៉ុន្តែក៏អាស្រ័យទៅតាមស្ថានភាពគ្រួសារ និងទីកន្លែងនៃអាពាហ៍ពិពាហ៍នោះ។ ទោះបីជាយ៉ាងណាក៏ដោយទាំងនេះគ្រាន់តែជាការបំពេញតាមប្រពៃណីទំនៀមទំលាប់តែប៉ុណ្ណោះ ពោលគឺពុំទាន់ក្លាយជាអាពាហ៍ពិពាហ៍ស្របច្បាប់នៅឡើយទេ ។

ដូច្នេះដើម្បីទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់ តើបុរសនិងនារីត្រូវគោរពនូវល័ក្ខខ័ណ្ឌអ្វីខ្លះ? ហើយមានមូលហេតុស្របច្បាប់អ្វីខ្លះដែលអាចនាំអោយមានមោឃភាព និងលុបចោលអាពាហ៍ពិពាហ៍នោះ? ដើម្បីភាពងាយស្រួលក្នុងការសិក្សាស្វែងយល់ប្រធានបទនេះនឹងធ្វើការបង្ហាញទៅតាមលំដាប់លំដោយ ស្តីអំពីការបង្កើតអាពាហ៍ពិពាហ៍ដែលមានបង្ហាញក្នុងចំណុចដូចខាងក្រោមនេះ៖

(១) កំជាប់ពាក្យ

(២) ការបង្កើតអាពាហ៍ពិពាហ៍

(៣) អាពាហ៍ពិពាហ៍នៅបរទេស និង អាពាហ៍ពិពាហ៍ជាមួយបរទេស

(៤) មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

## ១. កំជាប់ពាក្យ

### ១.១. និយមន័យកំជាប់ពាក្យ

តាមរយៈ **មាត្រា៩៤៤ នៃក្រមរដ្ឋប្បវេណី កំជាប់ពាក្យ** គឺជាសេចក្តីសន្យា ដែលមនុស្សស្រី និងមនុស្សប្រុសថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានាពេលអនាគត និងដោយធ្វើពិធីកំជាប់ពាក្យ។

តាមទម្លាប់នៅប្រទេសកម្ពុជា ក្រៅពីការសន្យារវាងគូភាគីនៃកំជាប់ពាក្យ ពិធីសង្គមចាស់ចាត់ទុកថាជាការចាំបាច់សម្រាប់គូភាគីនៃកំជាប់ពាក្យ ពិធីលើកផ្កាស្លាក៏ជាល័ក្ខខ័ណ្ឌចាំបាច់ដែរដើម្បីបង្កើតកំជាប់ពាក្យ។ មាត្រានេះចែងយ៉ាងច្បាស់ថា កំជាប់ពាក្យនឹងមានអានុភាពដរាបណាភាគីសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគតដោយធ្វើពិធីកំជាប់ពាក្យ។

រក្សាសិទ្ធិគ្រប់បែបយ៉ាង © 

## ១.២. ការបង្កើតកំជាប់ពាក្យ

ការបង្កើតកំជាប់ពាក្យ ត្រូវកើតឡើងតាមផ្លូវច្បាប់ នៅពេលល័ក្ខខ័ណ្ឌត្រូវបានគោរពដូចខាងក្រោម ៖

### ក. សេចក្ដីសន្យា

ភាគីទាំងពីរដែលមានវ័យនីតិភាព បានបង្ហាញឆន្ទៈនៃការព្រមព្រៀងថានឹងយកគ្នាជាប្ដី-ប្រពន្ធតាមផ្លូវច្បាប់ ចំណែកឯអនីតិជនដែលអាចគោរពតាមល័ក្ខខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ក៏អាចធ្វើកំជាប់ពាក្យបាន។ មានតែភាគីនៃកំជាប់ពាក្យទេ ដែលអាចធ្វើការព្រមព្រៀងចំពោះកំជាប់ពាក្យ ប្រសិនបើឪពុកម្ដាយរបស់កូនជាអនីតិជន បានព្រមព្រៀងចំពោះកំជាប់ពាក្យជំនួសកូនរបស់ពួកគាត់ នោះការព្រមព្រៀងនោះនឹងមិនមានអានុភាពកំជាប់ពាក្យឡើយ។

### ខ. ពិធីកំជាប់ពាក្យ

ល័ក្ខខ័ណ្ឌទំរង់នៃពិធីកំជាប់ពាក្យ គឺជាពិធីកំជាប់ពាក្យ នៅក្នុងក្រមរដ្ឋប្បវេណីយើងហៅថាពិធីលើកស្លា តែពាក្យពិធីលើកស្លានេះ ត្រូវបានផ្លាស់ប្ដូរមកជាពិធីកំជាប់ពាក្យ ដើម្បីអោយមានលក្ខណៈគ្របដណ្ដប់លើប្រជាជនទូទៅ ។

## ១.៣. ការរំលាយកំជាប់ពាក្យ

កំជាប់ពាក្យត្រូវបានរំលាយដោយសារមូលហេតុ ៖

- រំលាយដោយអាពាហ៍ពិពាហ៍
- រំលាយដោយសារមរណភាពរបស់ភាគីណាមួយ
- រំលាយដោយការព្រមព្រៀងរបស់ភាគី
- រំលាយដោយការបដិសេធចោលដោយមានមូលហេតុត្រឹមត្រូវ
- រំលាយដោយការបដិសេធចោលដោយគ្មានមូលហេតុត្រឹមត្រូវ

## ១.៤. ល័ក្ខខ័ណ្ឌរំលាយកំជាប់ពាក្យ

### ក. ការសងជំនូន

ប្រទេសកម្ពុជាក៏ដូចជាប្រទេសមួយចំនួនទៀតដែរ តាមទំនៀមទំលាប់មានករណីជាច្រើនដែលការជូនដល់ភាគីម្ខាងទៀតនូវប្រាក់កាស និងទ្រព្យ (ជំនូន) ត្រូវបានធ្វើឡើងនៅពេលដែលមានគម្រោងរៀបអាពាហ៍ពិពាហ៍ ជាពិសេសភាគីម្ខាង អាចទាមទារអោយភាគីម្ខាងទៀតសងជំនូនមកវិញបានក្នុងករណីដែលកំជាប់ពាក្យត្រូវបានរំលាយ **(មាត្រា៩៤៥ ក.រ )**។ ផ្ទុយទៅវិញ នៅពេលដែលភាគី ដែល

បានភ្ជាប់ពាក្យ បានរៀបអាពាហ៍ពិពាហ៍ នោះភាគីមិនអាចទាមទារអោយសងជំនួននោះពីភាគីម្ខាង ទៀតបានទេ ទោះបីជាពួកគេបានលែងលះក៏ដោយ។

ការទទួលខុសត្រូវក្នុងការសងជំនួននេះ កើតឡើងដោយមិនគិតពីមូលហេតុនៃការរំលាយកំជាប់ពាក្យទេ លើកលែងតែការរំលាយដោយអាពាហ៍ពិពាហ៍។ ដូច្នេះ ទោះបីជាកំជាប់ពាក្យត្រូវបានរំលាយដោយមរណភាពរបស់ភាគីណាមួយក្តី ដោយការព្រមព្រៀងរបស់គូភាគីក្តី ឬដោយការបដិសេធចោលដោយមានមូលហេតុត្រឹមត្រូវក្តី ក៏ភាគីត្រូវសងជំនួនវិញដែរ។

## ខ. ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយពុំមានមូលហេតុត្រឹមត្រូវ

កំជាប់ពាក្យ គឺជាដំណើរការសង្គម ដែលជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយមានអត្ថន័យតាមផ្លូវច្បាប់លើសពីអ្វីដែលគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ។ ហេតុនេះ ក្នុងករណីដែលភាគីម្ខាងបដិសេធចោល កំជាប់ពាក្យដោយមិនត្រឹមត្រូវ ភាគីនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត។ មូលហេតុត្រឹមត្រូវរួមមាន ភាពមិនស្មោះត្រង់របស់ភាគីម្ខាងទៀត អំពើហិង្សាតាមរយៈពាក្យ សំដី ឬលើរូបរាងកាយ ឬអសមត្ថភាពផ្លូវកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។ ការខូចខាតក្នុងចំណុចនេះរួមមានការខូចខាតផ្នែកផ្លូវចិត្ត ក៏ដូចជាការខូចខាតផ្នែកទ្រព្យសម្បត្តិ ដូចជាការចំណាយប្រាក់សំរាប់កក់ភោជនីយដ្ឋានសំរាប់រៀបចំពិធីរៀបអាពាហ៍ពិពាហ៍ ឬចំណាយសម្រាប់កាត់រ៉ូបអាពាហ៍ពិពាហ៍(**មាត្រា ៩៤៦ក.រ**)។

## គ. នីតិវិធីដាក់ពាក្យបណ្តឹង

នៅពេលដែលកំជាប់ពាក្យត្រូវបានរំលាយ ឬបដិសេធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតមានសិទ្ធិធ្វើការប្តឹងទាមទារទៅតុលាការទាក់ទងទៅនឹងសំណង ដូចជាការសងជំនួន ការទទួលខុសត្រូវផ្សេងទៀត ដោយភាគីនោះត្រូវប្តឹងទៅតុលាការនៅក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះបានរលាយ (**មាត្រា៩៤៧ ក.រ** ) ។

## ២. ការបង្កើតអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តខ្លួនឡើយ (**មាត្រា ៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, មាត្រា ៣ កថាខណ្ឌ២ នៃច្បាប់ស្តីពីឯកពន្ធភាព**)។

ចំពោះអាពាហ៍ពិពាហ៍ដែលត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ គឺមានសុពលភាពតាមច្បាប់ថ្មីបច្ចុប្បន្ន។ មាត្រា៦២ នៃច្បាប់ស្តីពីការអនុវត្តក្រម សន្មតជាមុននូវសុពលភាពនៃអាពាហ៍ពាហ៍ដែលត្រូវបានបង្កើតឡើងតាមច្បាប់ចាស់ស្តីពីអាពាហ៍ពិព៉ា និងគ្រួសារ។

## ២.១. ល័ក្ខខ័ណ្ឌគ្រឹះ

ល័ក្ខខ័ណ្ឌគ្រឹះ គឺជាល័ក្ខខ័ណ្ឌចំបងដែលធ្វើអោយកើតមានចំណងអាពាហ៍ពិពាហ៍ ហើយ ដែលប្រជាពលរដ្ឋគ្រប់រូបត្រូវតែប្រតិបត្តិឲ្យខានតែបាន ព្រោះអាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពជីវិតរវាងបុរស និងនារី ដូច្នេះបុរស និងនារីចាំបាច់ត្រូវតែពេញវ័យទាំងផ្នែកសេដ្ឋកិច្ច សង្គម ផ្លូវចិត្ត និងផ្លូវកាយ ហើយវាគឺជាការកំណត់តាមច្បាប់ ជាពិសេស គឺជាល័ក្ខខ័ណ្ឌដែលទាមទារឲ្យមានការគោរពនូវល័ក្ខខ័ណ្ឌចំបងមួយចំនួនទៀតគឺ ៖

### ក. អាយុ និងភេទ

ប្រទេសនីមួយៗ តែងតែកំណត់អំពីអាយុអប្បបរមា ដែលសមរម្យសម្រាប់រៀបអាពាហ៍ពិពាហ៍។ ដោយឡែកនៅប្រទេសកម្ពុជាយើងវិញក៏ដូចគ្នាដែរ ដោយកំណត់យកការរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែមានភេទផ្ទុយគ្នា និងបានដល់នីតិភាព ជាអាយុអប្បបរិមាដែលសមរម្យអាចរៀបអាពាហ៍ពិពាហ៍បាន។ នីតិភាពចំណុចនេះ ជាធម្មតាមានន័យថា បានដល់អាយុ១៨ឆ្នាំ ប៉ុន្តែក៏រួមបញ្ចូលផងដែរនូវអាយុ១៦ឆ្នាំ ឬ១៧ឆ្នាំ ដែលទទួលបានអត្តាធីនភាព (មាត្រា២១)។ម្យ៉ាងទៀត ចំពោះករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជន ដែលមានអាយុ១៦ឆ្នាំ ឬ១៧ឆ្នាំ ពួកគេក៏អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ដោយគ្រាន់តែទទួលបានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលរបស់អនីតិជននោះ **(មាត្រា៩៤៨ ក.រ )**។

### ខ. ទ្វេពន្ធភាព

ដោយប្រទេសយើងអនុម័តយករបបឯកពន្ធភាព បុរសត្រូវបានហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ជាមួយនារីលើសពីម្នាក់ ហើយនារីក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយបុរស លើសពីម្នាក់បានដូចគ្នា។ តាមរយៈ **មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណី** ក៏បានហាមឃាត់មិនអោយមានទ្វេពន្ធភាពដែរ ពោលគឺបុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។

ទ្វេពន្ធភាព មានន័យថា ការរៀបអាពាហ៍ពិពាហ៍ពីរស្របច្បាប់។ ចំពោះការរៀបអាពាហ៍មួយ ស្របច្បាប់ និងមួយទៀតជាការរួមរស់បែបអនីតិសង្វាស នោះមិនត្រូវបានចាត់ទុកថាទ្វេពន្ធភាពទេ។

**ឧទាហរណ៍៖** (ក) និង (ខ) បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ក្រោយមកទំនាក់ទំនងពួកគេបានបែកបាក់ ប៉ុន្តែមិនទាន់បានលែងលះគ្នាទេ។ (ក) បានចាប់ផ្តើមរស់នៅជាមួយ (គ) ក្នុងករណីនេះ ប្រសិនបើ (ក) និង (គ) បានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ នោះនឹងអាចបង្កអោយជាទ្វេពន្ធភាព ហើយមន្ត្រីអត្រានុកូលដ្ឋាននឹងបដិសេធក្នុងការទទួលពាក្យសុំនោះ ( មាត្រា ៩៥៦ ក.រ )។ ប៉ុន្តែទំនាក់ទំនងរវាង (ក) និង (គ) អាចនៅតែត្រូវបានការពារដូចទំនាក់ទំនងនៃការរួមរស់បែបអនីតិសង្វាស ។

**ទ្វេពន្ធភាព និងការប្រកាសអំពីការបាត់ខ្លួន (មាត្រា៤៤)** ៖ ប្រសិនបើបុគ្គលម្នាក់ត្រូវបានប្រកាសអំពីការបាត់ខ្លួន នោះបុគ្គលនោះត្រូវបានចាត់ទុកថាបានទទួលមរណភាព (មាត្រា៤៣)។ ដូច្នេះសហព័ទ្ធរបស់

បុគ្គលដែលបានបាត់ខ្លួន អាចរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយបុគ្គលម្នាក់ទៀតបាន។ ប្រសិនបើបន្ទាប់ពីអាពាហ៍ពិពាហ៍ថ្មី បុគ្គលដែលបានបាត់ខ្លួននោះបានត្រឡប់មកវិញ ហើយការប្រកាសអំពីបាត់ខ្លួនត្រូវបានលុបចោល តើយើងត្រូវចាត់ការអាពាហ៍ពិពាហ៍ទាំងពីរនេះយ៉ាងដូម្តេច? ចំពោះករណីនេះ អាពាហ៍ពិពាហ៍មុនគឺត្រូវបានរំលាយនៅពេលរៀបអាពាហ៍ពិពាហ៍ថ្មី ហើយមានតែអាពាហ៍ពិពាហ៍ក្រោយទេដែលមានអានុភាព (មាត្រា៩៤ កថាខណ្ឌ៧) ដូច្នេះ ពុំមានទ្វេពន្ធភាពកើតឡើងនោះទេ។

## គ. គោលការណ៍វិធវភាព (**ការគោរពន្ធវភាពជាមេម៉ាយ**)

ក្រោយពីអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ឬ លុបចោល ដោយមូលហេតុប្តីស្លាប់ មោឃភាពអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែមិនត្រូវស្ថិតនៅក្នុងវិធវភាព (មេម៉ាយ) ចំនួន១២០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវ បានរលាយ ឬ លុបចោល។ ប៉ុន្តែ ករណីខាងលើមិនយកមកអនុវត្តឡើយចំពោះនារីមានផ្ទៃពោះ នៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរលាយ ឬ លុបចោល ហើយបានសំរាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត (**មាត្រា៩៥០ ក.រ**)។

## ឃ.ការហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយរវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិត ក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផងដែរ។ ការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នាបែបនេះ ត្រូវបានហាមឃាត់ ដោយសារការរៀបអាពាហ៍ពិពាហ៍រវាងសាច់ញាតិ វាមានលក្ខណៈផ្ទុយនឹងសីលធម៌សង្គម ហើយសង្គមភាគច្រើនក៏មិនទទួលស្គាល់អាពាហ៍ពិពាហ៍បែបនេះដែរ។ ម្យ៉ាងទៀត ការរៀបអាពាហ៍ពិពាហ៍រវាងសាច់ញាតិ លទ្ធភាពនៃពិការភាពចំពោះកូនដែលកើតមកវាមានកំណើនខ្ពស់ (**មាត្រា៩៥១ ក.រ**)។

- **ហាមឃាត់រវាងញាតិពន្ធ**

អាពាហ៍ពិពាហ៍ ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ ព្រោះការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងជនដែលធ្លាប់ជាញាតិពន្ធនៃខ្សែផ្ទាល់ ដោយសារតែញាតិលោហិតនៃខ្សែផ្ទាល់របស់សហព័ទ្ធ មានទំនាក់ទំនងប្រហាក់ប្រហែលនឹងញាតិលោហិត ខ្សែផ្ទាល់របស់ខ្លួនផ្ទាល់ ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូន ដូច្នេះតាមសីលធម៌សង្គមក៏អាពាហ៍ពិពាហ៍បែបនេះមិនមែនជាការគួរដែរ។

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៅក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផង ដោយសារតែនៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធនោះមាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួម ដែលមានលក្ខណៈជិតស្និទ្ធ ស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិ លោហិតដែរ។ ប៉ុន្តែ ដោយសារតែតាមទំនៀមទំលាប់នៅក្នុងប្រទេសកម្ពុជាមានករណីអាពាហ៍ពិពាហ៍ជាមួយបង ឬ ប្អូនប្រុស ដែលនៅលីវរបស់សពប្តី ឬករណីដែលប្រពន្ធបានទទួលមរណភាព ហើយប្អូនស្រី ឬបងស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ដើម្បីមើលថែទាំកូនរបស់បុគ្គលដែលទទួលមរណភាពនោះជាដើម ហើយម្យ៉ាង

ទៀត ការរៀបអាពាហ៍ពិពាហ៍រវាងបងប្អូនរបស់ប្តី និងបងប្អូនបង្កើតរបស់ប្រពន្ធក៏ឃើញមានផងដែរ ដូច្នេះ សហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គល ដែល ធ្លាប់ជាសាខាញាតិពន្ធនៅក្នុង៣ថ្នាក់បាន (មាត្រា៩៥២ ក.រ )។

## ខ. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

➢ **ត្រូវមានការយល់ព្រមពីអំណាចមេបា ឬ អាណាព្យាបាលរបស់អនីតិជន**

ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជននោះ មានន័យថា អាពាហ៍ពិពាហ៍របស់អនីតិជនអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមដែលមានលក្ខណៈជាការគ្រប់គ្រងថែរក្សា ដើម្បីបង្រ្គប់ភាពខ្វះខាតការវិនិច្ឆ័យរបស់អនីតិជននោះ។ ដោយសារគោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបារួម ចាំបាច់មានការយល់ព្រមពីអ្នកមានអំណាចមេបា។ ប្រសិនបើមានតែឪពុក ឬតែម្តាយ ជាអ្នកមានអំណាចមេបា នោះការយល់ព្រមពីឪពុក ឬម្តាយ ដែលមានអំណាចមេបា គឺមានភាពចាំបាច់។ ការយល់ព្រមពីឪពុក ឬម្តាយដែលមិនមានអំណាចមេបាគឺមិនចាំបាច់នោះទេ។ ប្រសិនបើអនីតិជនចង់រៀបអាពាហ៍ពិពាហ៍ ប៉ុន្តែមិនមានអ្នកមានអំណាចមេបា និងមិនមានអាណាព្យាបាលសម្រាប់អនីតិជនទេ នោះអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំងជាមុន (មាត្រា ១០៦៨ កថាខណ្ឌ២) និងការយល់ព្រមពីអាណាព្យាបាលសម្រាប់អនីតិជនមានភាពចាំបាច់។

ក្នុងករណីដែលឪពុកម្តាយជាអ្នកមានអំណាចមេបា ប៉ុន្តែឪពុក ឬ ម្តាយ បានបដិសេធផ្តល់ការយល់ព្រម នោះការយល់ព្រមរបស់ឪពុក ឬ ម្តាយម្នាក់ទៀតគឺគ្រប់គ្រាន់ (មាត្រា៩៥៣ កថាខណ្ឌ២ និង ៣)។

**ភាពចាំបាច់នៃការយល់ព្រម (A និង B មានបំណងរៀបអាពាហ៍ពិពាហ៍)**

| A | B | ភាពចាំបាច់នៃការយល់ព្រម |
|---|---|---|
| ១៨ ឆ្នាំ ឬ ចាស់ជាងនេះ | ១៨ ឆ្នាំ ឬ ចាស់ជាងនេះ | មិនចាំបាច់ |
| ១៨ ឆ្នាំ ឬ ចាស់ជាងនេះ | ១៦ ឬ ១៧ ឆ្នាំ (មិនទទួលបានអត្តាធីនភាព) | ការយល់ព្រមពីអ្នកមានអំណាចមេបារបស់ B ឬ អាណាព្យាបាលរបស់ B គឺមានភាពចាំបាច់ |
| ១៨ ឆ្នាំ ឬ ចាស់ជាងនេះ | ១៦ ឬ ១៧ ឆ្នាំ (ទទួលបានអត្តាធីនភាព) | មិនចាំបាច់ |

| | | |
|---|---|---|
| ១៦ ឬ ១៧ ឆ្នាំ (ទទួលបានអត្តាធីនភាព) | ១៦ ឬ ១៧ ឆ្នាំ (ទទួលបានអត្តាធីនភាព) | មិនចាំបាច់ |
| ១៦ ឬ ១៧ ឆ្នាំ (ទទួលបានអត្តាធីនភាព) | ១៦ ឬ ១៧ ឆ្នាំ (មិនទទួលបានអត្តាធីនភាព) | ការយល់ព្រមពីអ្នកមានអំណាចមេបាររបស់ B ឬ អាណាព្យាបាលរបស់ B គឺមានភាពចាំបាច់ |
| ១៦ ឬ ១៧ ឆ្នាំ (មិនទទួលបានអត្តាធីនភាព) | ១៦ ឬ ១៧ ឆ្នាំ (មិនទទួលបានអត្តាធីនភាព) | មិនអាចរៀបអាពាហ៍ពិពាហ៍ |

- **សេចក្ដីសម្រេចរបស់តុលាការជំនួសពីការយល់ព្រមរបស់អាណាព្យាបាលឬឪពុកម្ដាយរបស់អនីតិជន**

ក្នុងករណីដែលឪពុកម្ដាយ ឬ អាណាព្យាបាលបដិសេធការយល់ព្រម ដោយគ្មានមូលហេតុសមរម្យទេ អនីតិជនដែលមានគម្រោងរៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឲ្យធ្វើការសម្រេចសេចក្ដីជំនួសការយល់ព្រមរបស់ឪពុកម្ដាយ ឬ អាណាព្យាបាលនោះបាន (**មាត្រា៩៥៣.៣ ក.រ** )។

## ២.២. លក្ខខ័ណ្ឌទម្រង់

តាមរយៈក្រមរដ្ឋប្បេវណី មាត្រា៩៥៦ និងអនុក្រឹត្យលេខ ១០៣ អនប្រកប ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីអត្រានុកូលដ្ឋាន បានកំណត់ថាអាពាហ៍ពិពាហ៍នឹងយកជាផ្លូវការបាន លុះត្រាតែគូរស្រករបានអនុវត្តនូវល័ក្ខខ័ណ្ឌដែលជាការតំរូវចាំបាច់តាមដំណាក់កាលដូចខាងក្រោមនេះ ៖

### ក. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍មានអានុភាពដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (**មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ១០៣ អនប្រកប ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីអត្រានុកូលដ្ឋាន** )។

### ខ. ការបិទផ្សាយជាសាធារណៈ

បន្ទាប់ពីទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍រួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើការប្រកាសផ្សាយជាសាធារណៈនូវអាពាហ៍ពិពាហ៍នោះ ដោយបិទបណ្ណ័ប្រកាសនៅលំនៅរបស់នារី និងនៅទីស្នាក់ការឃុំ ឬសាលាសង្កាត់នៃសាម៉ីខ្លួននារីចំនួន០១ច្បាប់។ បណ្ណ័ប្រកាសអាពាហ៍ពិពាហ៍ ០២ ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរសដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬ សង្កាត់នៃសាម៉ីខ្លួន បុរស ០១ច្បាប់។

ប័ណ្ណប្រកាសត្រូវចុះ ៖

១-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅនៃអនាគត ប្តីប្រពន្ធ។

២-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅរបស់ឪពុកម្តាយនៃអនាគតប្តីប្រពន្ធ បើឪពុក ឬ ម្តាយស្លាប់ត្រូវដាក់ថាស្លាប់។

៣-រយៈពេលប្តឹងជំទាស់ ៖ បណ្ណ័ប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃមុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបានប្រសិនបើមិនមានការយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ។ ផុតរយៈពេល ១០ថ្ងៃអាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងជំទាស់អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបានលុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់សព្វគ្រប់ **(មាត្រា២៩ នៃអនុក្រឹត្យលេខ ១០៣ អនប្រកប ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន)**។

## គ. ការចុះសំបុត្រអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍នឹងមានអានុភាព បន្ទាប់ពីមានការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយមានសាក្សីគ្រប់អាយុការពីរនាក់ **(មាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៣០ នៃអនុក្រឹត្យលេខ ១០៣ អនប្រកប ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន )**។

ល័ក្ខខ័ណ្ឌទាំងនេះ គឺជាល័ក្ខខ័ណ្ឌចាំបាច់ដែលនាំអោយអាពាហ៍ពិពាហ៍មានចំណងគតិយុត្តតាមផ្លូវច្បាប់។ ទោះបីជាមានការគោរពល័ក្ខខ័ណ្ឌដែលបានកំណត់ និងមានការរៀបចំពិធីមង្គលការតាមប្រពៃណីទំនៀមទំលាប់ក៏ដោយ បើមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេប្តីប្រពន្ធទាំងពីររស់នៅត្រឹមតែជាអនីតិសង្វាសតែប៉ុណ្ណោះ គឺច្បាប់មិនទទួលស្គាល់ទេ។ បញ្ហានេះបានកើតមានភាគច្រើននៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ដោយសារការគ្រប់គ្រងខាងផ្នែកអត្រានុកូលដ្ឋានមិនទាន់មានប្រសិទ្ធិភាព និងកង្វះខាតចំណេះដឹងផ្នែកច្បាប់របស់ប្រជាជន។

## ៣. អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស

តាមរយៈ **មាត្រា៣៤ នៃអនុក្រឹត្យលេខ ១០៣ អនប្រកប ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន** ការរៀបអាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយបរទេស គឺជារឿងដែលល្អណាស់ ចំពោះគូស្រករនីមួយៗ ហើយក៏ត្រូវតែគោរពទៅលើច្បាប់ជាតិ បើសិនជារៀបអាពាហ៍ពិពាហ៍លើទឹកដីកម្ពុជា ប៉ុន្តែបើពលរដ្ឋខ្មែររៀបអាពាហ៍នៅបរទេស ក៏ត្រូវតែមានការអនុញ្ញាតឲ្យប្រើច្បាប់ខ្មែរ ព្រោះជាប្រយោជន៍ទូទៅចំពោះការរៀបចំលិខិតស្នាមផ្សេងៗដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់គាត់ជាពលរដ្ឋខ្មែរ។

## ៣.១. ការរៀបអាពាហ៍ពិពាហ៍របស់ពលរដ្ឋខ្មែរនៅបរទេស

ពលរដ្ឋខ្មែរដែលរស់នៅបរទេស អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយជូនដំណឹងជាសាធារណៈ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់កម្ពុជាប្រចាំនៅប្រទេសនោះ។ ការជូនដំណឹងជាសាធារណៈត្រូវបិទប្រកាសនៅបញ្ជរស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជាប្រចាំនៅប្រទេសនោះ **(មាត្រា៩៥៧ )**។

## ៣.២. ការរៀបអាពាហ៍ពិពាហ៍របស់ពលរដ្ឋខ្មែរជាមួយជនបរទេសនៅកម្ពុជា

ពលរដ្ឋកម្ពុជា ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដែលកំពុងរស់នៅប្រទេសកម្ពុជាត្រូវប្រព្រឹត្តទៅតាមច្បាប់នៃប្រទេសកម្ពុជា។

## ៣.៣. នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស

ដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម ៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍។
- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេស មានទិដ្ឋាការចូលប្រទេសកម្ពុជាដែលមានសុពលភាព។
- លិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅ។

ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។ ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា **(មាត្រា៦ នៃអនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស)**។

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

## ៤. មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

មោឃភាពនៃអាពាហ៍ពិពាហ៍ ជាការមិនកើតមានឡើងនូវអាពាហ៍ពិពាហ៍។ ការលុបចោលអាពាហ៍ពិពាហ៍គឺជាការរំលាយអាពាហ៍ពិពាហ៍ ដែលបានកើតមានឡើងម្តង និងមានអានុភាព។

## ៤.១. មូលហេតុនៃមោឃភាពនៃអាពាហ៍ពិពាហ៍

**តាមរយៈមាត្រា៩៥៨ នៃក្រមរដ្ឋប្បវេណី** បានកំណត់ថាអាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ ៖

- ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគីដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងៗទៀត។

➢ **ការភាន់ច្រឡំលើមនុស្ស ៖**

**ឧទាហរណ៍៖** A និង B មានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ ប៉ុន្តែដោយសារ C បានស្រលាញ់ A ដូចនេះ C ក៏បានផ្លាស់ប្តូរមុខមាត់របស់ខ្លួនឲ្យដូចមុខមាត់របស់ B តាមរយៈការវះកាត់កែមុខមាត់ និងរាងកាយ។ C បានបន្លំខ្លួនធ្វើជា B ហើយបានបោកប្រាស់ A ដោយនិយាយថា "តាមពិតទៅឈ្មោះរបស់ខ្ញុំមិនមែន B ទេ គឺឈ្មោះ C"។ ដោយសារតែ A បានជឿជាក់ទៅលើ C នោះនាំអោយ A និង C បានធ្វើតាមនីតិវិធី៤ដំណាក់កាលនៃមាត្រា ៩៥៥ កថាខណ្ឌ១ នៃក.រ។ ដូច្នេះ អាពាហ៍ពិពាហ៍នេះត្រូវបានចាត់ទុកជាមោឃៈ ព្រោះថាតាមច្បាប់ A និង C មិនបានរៀបអាពាហ៍ពិពាហ៍នឹងគ្នានោះទេ។

➢ **ការបង្ខំ ៖**

**ឧទាហរណ៍៖** A បានបង្ខំ B ឲ្យចុះហត្ថលេខាលើពាក្យសុំរៀបអាពាហ៍ពិពាហ៍ ហើយបាននាំ B ទៅបង្ហាញខ្លួននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយបានយកកាំបិតផ្ទង់ B ពីក្រោយ។ ក្នុងករណីនេះ B មិនបានបង្ហាញឆន្ទៈរៀបអាពាហ៍ពិពាហ៍ជាមួយ A នោះទេ ប៉ុន្តែ B បានធ្វើតាមបញ្ជារបស់ A ដោយសារតែ A បានយកកាំបិតផ្ទង់ B។ A និង B បានឆ្លងកាត់នីតិវិធីទាំង ៤ ដំណាក់កាលនៃមាត្រា ៩៥៥ កថាខណ្ឌ ១ នៃក.រ។ ដូច្នេះ អាពាហ៍ពិពាហ៍នេះត្រូវបានចាត់ទុកជាមោឃៈ ព្រោះថា តាមច្បាប់ A និង B មិនបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នានោះទេ។

- ប្រសិនបើភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍។ ប៉ុន្តែ ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នេះ មិនត្រូវបានរារាំងដោយសារហេតុនោះឡើយ។

## ៤.២. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍

ភាគីនីមួយៗ ញាតិសន្តានរបស់សាមីជន (មាត្រា ៩៣៨ នៃក.រ) ឬ តំណាងអយ្យការ អាចប្តឹងទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែនៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាព ហើយតំណាងអយ្យការ ពុំអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ។

ការលុបចោលអាពាហ៍ពិពាហ៍ត្រូវគោរពតាមមាត្រា៩៦០ ដល់មាត្រា ៩៦៣ នៃក.រ (មាត្រា ៩៥៩ នៃក.រ)។ ដូច្នេះ ការលុបចោលអាពាហ៍ពិពាហ៍ ដោយផ្អែកលើការខ្វះសមត្ថភាពខាងឆន្ទៈ (មាត្រា ១៤ នៃក.រ) នោះ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (មាត្រា ១៨, ២៦, ៣០ នៃក.រ) និងវិការៈក្នុងការបង្ហាញឆន្ទៈ (មាត្រា ៣៤៥ ដល់មាត្រា ៣៦៣ នៃក.រ) មិនត្រូវយកមកអនុវត្តចំពោះការលុបចោលអាពាហ៍ពិពាហ៍ទេ។

**អាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាការលុបចោល ក្នុងករណីកំណត់ដូចខាងក្រោមៈ**

ក. បុរស និងនារី ដែលមិនទាន់ដល់នីតិភាព (មិនទាន់គ្រប់អាយុ១៨ឆ្នាំ និងមិនបានទទួលអគ្គាធីនភាព តាមមាត្រា ២១ នៃក.រ) (**មាត្រា៩៤៨**)។

ខ. បុគ្គលដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់មិនទាន់រលាយ ហើយទៅរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត (**មាត្រា៩៤៩**)។

គ. នារីដែលស្ថិតក្នុងច្បាប់ហាមឃាត់ ក្នុងអំឡុងពេល១២០ថ្ងៃពុំទាន់កន្លងហួស ដោយគិតចាប់ថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល (**មាត្រា៩៥០**)។

ឃ. អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុង៣ថ្នាក់ (**មាត្រា៩៥១**)។

ង. អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់ ឬ សាខាញាតិពន្ធនៅក្នុង ៣ (បី) ថ្នាក់ (មាត្រា ៩៥២ នៃក.រ)។

ច. បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាមកំហែង (**មាត្រា៩៦៣**)។

➢ **ការឆបោក ៖**

**ឧទាហរណ៍ ៖** ដោយសារ A មានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយ B ដូចនេះ A បានបោកប្រាស់ B ថា A មានអាជ្ញាប័ណ្ណមេធាវី និងមានប្រាក់ខែ ៣០០០ ដុល្លារ។ B បានជឿ ហើយ A និង B បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ ក្រោយរៀបអាពាហ៍ពិពាហ៍ B បានដឹងថា A មិនមានអាជ្ញាប័ណ្ណមេធាវីទេ ហើយប្រាក់ខែរបស់ A គឺ៥០០ ដុល្លារតែប៉ុណ្ណោះ។ ដូច្នេះ B អាចលុបចោលអាពាហ៍ពិពាហ៍នេះបាន។

➢ **ការគំរាមកំហែង ៖**

**ឧទាហរណ៍ ៖** ដោយសារ A មានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយ B។ ដោយសារតែ A មានអំណាច ដូចនេះ A បានគំរាម B ថា ប្រសិនបើ B មិនព្រមរៀបអាពាហ៍ពិពាហ៍ជាមួយ A ទេ នោះគ្រួសាររបស់ Bនឹងបាត់បង់ការងារទាំងអស់គ្នា។ B បានយល់ព្រមនឹងសំណើសុំរៀបអាពាហ៍ពិពាហ៍របស់ A ដោយស្ទាក់ស្ទើរ ហើយ A និង B បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ ករណីនេះ B អាចលុបចោលអាពាហ៍ពិពាហ៍នេះបាន។

**តាមរយៈមាត្រា៩៥៦** ៖ ក្នុងចំណោមមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ខាងលើ មន្ត្រីអត្រានុកូលដ្ឋានគួរតែដឹងចាប់ពីចំណុច (ក) ដល់ចំណុច (ង)។ ដូច្នេះ ប្រសិនបើមានមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងនេះ នោះមន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធក្នុងការទទួលយកពាក្យសុំ (មាត្រា ៩៥៦ នៃក.រ)។ ជាធម្មតា ការលុបចោលអាពាហ៍ពិពាហ៍ដោយផ្អែកតាមចំណុច (ក) ដល់ចំណុច (ង) នឹងក្លាយជាចំណុចសំខាន់ក្នុងការពិភាក្សា នៅពេលដែលមន្ត្រីអត្រានុកូលដ្ឋានបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ដោយការភាន់ច្រឡំ។

**អានុភាពនៃការបំពានមាត្រា៩៥៣** ៖ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបដិសេធក្នុងការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងមាត្រា៩៥៣ នៃក.រ (មាត្រា ៩៥៦ នៃក.រ) មានន័យថា ប្រសិនបើអនីតិជនដែលរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនីតិជន មិនបានសុំការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន នោះមន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធក្នុងការទទួលយកពាក្យសុំរៀបអាពាហ៍ពិពាហ៍។ ផ្ទុយទៅវិញ មាត្រា ៩៦០ នៃក.រ មិនបានលើកឡើងពីការបំពានមាត្រា ៩៥៣ ជាមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍នោះទេ។ ដូច្នេះ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះដោយការភាន់ច្រឡំ ហើយដំណាក់កាលទាំង ៤ នៃមាត្រា ៩៥៥ ត្រូវបានបំពេញនោះអាពាហ៍ពិពាហ៍នឹងមានអានុភាព និងមិនអាចលុបចោលបានទេ។

**អានុភាពនៃការបំពានមាត្រា៩៥៤** ៖ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបដិសេធក្នុងការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងមាត្រា ៩៥៤នៃក.រ (មាត្រា ៩៥៦ នៃក.រ)។ នេះមានន័យថា ប្រសិនបើជននៅក្រោមអាណាព្យាបាលទូទៅ ខ្វះសមត្ថភាពខាងឆន្ទៈក្នុងកម្រិតអប្បបរិមា ដើម្បីរៀបអាពាហ៍ពិពាហ៍ នោះមន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធក្នុងការទទួលយកពាក្យសុំរៀបអាពាហ៍ពិពាហ៍។ ផ្ទុយទៅវិញ មាត្រា៩៦០ នៃក.រ មិនបានលើកឡើងពីការបំពានមាត្រា ៩៥៤ ជាមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍នោះទេ។ តាមពិតទៅ អាពាហ៍ពិពាហ៍របស់ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ ក្នុងកម្រិតអប្បបរិមាដើម្បីរៀបអាពាហ៍ពិពាហ៍ គឺជាអាពាហ៍ពិពាហ៍ដែលពុំមានឆន្ទៈរៀបអាពាហ៍ពិពាហ៍។ ដូច្នេះអាពាហ៍ពិពាហ៍ ដែលបំពាននឹងមាត្រា៩៥៤ នៃក.រ គឺត្រូវបានចាត់ទុកជាមោឃៈ (មាត្រា ៩៥៨ ចំណុច ក នៃក.រ)។

## ៤.៣. អានុភាពនៃមោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍

មោឃភាពនៃអាពាហ៍ពិពាហ៍ មានន័យថាអាពាហ៍ពិពាហ៍មិនដែលមានអានុភាពនោះទេ។

ការលុបចោលអាពាហ៍ពិពាហ៍ មានន័យថាអាពាហ៍ពិពាហ៍បានមានអានុភាពម្តង ប៉ុន្តែក្រោយមកត្រូវបានរំលាយ។ ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលនោះឡើយ (មាត្រា ៩៦៤ កថាខណ្ឌ១ នៃក.រ) ។

## ក. សំណងការខូចខាត

ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើទទួលបានទ្រព្យសម្បត្តិដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះត្រឹមកម្រិតនៃផលប្រយោជន៍ដែលទទួលបាន (មាត្រា ៩៦៤ កថាខណ្ឌ២ នៃក.រ)។ ចំពោះភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ ហើយបើភាគីម្ខាងទៀតសុចរិត ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ **(មាត្រា៩៦៤ កថាខណ្ឌ៣ ក.រ )**។

ការសន្មតបិតុភាព និងការបែងចែកទ្រព្យសម្បត្តិត្រូវអនុវត្តតាមបញ្ញត្តិស្តីពីការលែងលះគ្នាដូចខាងក្រោម៖

## ខ. ការសន្មតបិតុភាព ( មាត្រា ៩៨៨ )

- ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី។
- កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប)ថ្ងៃគិតចាប់ពីថ្ងៃ ដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬក្នុងអំឡុងពេល ៣០០ (បីរយ)ថ្ងៃ គិតចាប់ពីពេលដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ត្រូវសន្មតថា មានគភ៌នៅក្នុងអំឡុងពេលមានអាពាហ៍ពិពាហ៍នោះ។
- ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រាអំឡុង)៩៥០ (ពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតនៃក្រមនេះប្រសិនបើ បានបង្កើតកូនមិនអាចកំណត់ដោយយោងតាមបញ្ញត្តិនៃកថា ់ឪពុករបស់កូននោះខណ្ឌទី១ ២និងទី ខាងលើនេះទេជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។កូននេះ ត្រូវសន្មតថា

## គ. ការបែងចែកទ្រព្យសម្បត្តិ ( មាត្រា ៩៨០ )

- ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាម ការពិភាក្សារបស់ភាគីទាំងសងខាង។
- ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ ៖

➢ សហាព័ទ្ធនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា៩៧២ (ទ្រព្យសម្បត្តិដោយឡែក)។

➢ បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហាព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ភាគ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាងតុលាការ ក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើ ស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ឬការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវ

ចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងារ របស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍។

- គេហកិច្ចត្រូវចាត់ទុកថាមានតំលៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។

## ៤.៤. នីតិវិធីនៃមោឃភាព និងការលុបចោលនៃអាពាហ៍ពិពាហ៍

លក្ខណៈនៃនីតិវិធី ៖ ភាគីដែលមានបំណងទាមទារឲ្យមោឃភាព ឬលុបចោលអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យបណ្តឹងឋានៈបុគ្គល ដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (សូមមើលមាត្រា ៣ ចំណុច ក និង ខ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

### ក.បុគ្គលដែលអាចដាក់ពាក្យបណ្តឹងបាន (មាត្រា ៩៦០)

- ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ (មាត្រា៩៦០)

១- អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិពីមាត្រា ៩៤៨ ( អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥២ (ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ) នៃក្រមនេះ ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការ អាចទាមទារទៅតុលាការឲ្យលុប ចោលបាន។ ប៉ុន្តែនៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ។

២-ចំពោះអាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៩៤៩ (ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាព) ឬ មាត្រា៩៥០ (អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ សហព័ទ្ធរបស់ភាគី ឬសហព័ទ្ធមុននោះ ក៏អាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ។

### ខ. ការកម្រិតអំឡុងពេល (មាត្រា ៩៦១, ៩៦២, ៩៦៣ កថាខណ្ឌ២)

- ការរលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ដែលភាគីមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍(មាត្រា ៩៦១)

១-អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) នៃក្រមនេះ ប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ពុំអាចទាមទារអោយលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ។

២-ក្រោយពេលជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ជននោះក៏នៅតែអាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន នៅក្នុងអំឡុងពេល៣(បី)ខែចាប់ពីពេលដែលជននោះបានគ្រប់អាយុ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើជននោះបានធ្វើសច្ចានុមតិ បន្ទាប់ពីបានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ។

**- ការលុបចោលអាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត (មាត្រា ៩៦២)**

អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ ពុំអាចទាមទារឲ្យលុបចោលបានឡើយ ប្រសិនបើរយៈពេល ១២០ (មួយរយម្ភៃ)ថ្ងៃបានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មិនត្រូវបានរំលាយ ឬលុបចោល ឬប្រសិនបើនារីមានផ្ទៃពោះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។

**- ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម (មាត្រា ៩៦៣)**

១-បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាម អាចទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។

២-សិទ្ធិលុបចោលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវរលត់បើភាគីបានរកឃើញការឆបោក ឬបើអំឡុងពេល ៣ (បី) ខែ បានកន្លងផុត ក្រោយពីបានរួចខ្លួនផុតពីការគំរាម ឬបើបានធ្វើសច្ចានុមតិ។

- **ករណីសិក្សា ៖**

១. តើកំជាប់ពាក្យធ្វើឡើងដោយបុគ្គលខាងក្រោមនេះមានអានុភាពយ៉ាងដូចម្តេច?

* ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ
* អនីតិជន
* ជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ
* ជនដែលស្ថិតក្រោមហិតូបត្ថម្ភ

២. A និង B បានធ្វើកំជាប់ពាក្យដែលមានអានុភាព។ ក្រោយមក A បានបដិសេធក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយ B។ តើ B អាចដាក់ពាក្យបណ្តឹងបង្ខំឲ្យ A រៀបអាពាហ៍ពិពាហ៍បានដែរ ឬ ទេ?

៣. A និង B បានធ្វើកំជាប់ពាក្យដែលមានអានុភាព ដោយ A បានជូនជំនូន ៥០០០ ដុល្លារទៅ B។ បន្ទាប់មក A និងB បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ក្រោយមក ដោយសារតែរស់នៅមិនចុះសម្រុងគ្នា A បានចាកចេញពីផ្ទះទៅរស់នៅដោយឡែក និងបានទាមទារឲ្យ B សងជំនូនវិញ។ តើ A អាចទាមទារឲ្យ B សងជំនូនវិញបានដែរ ឬ ទេ?

៩. A និង B បានស្រលាញ់គ្នា ហើយបានសន្យាថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នា។ ប៉ុន្តែ A បានផ្លាស់ប្តូរចិត្ត ហើយបានឈប់ស្រលាញ់ B និងបានចាកចេញពី B នៅមុនពេលពួកគេបានរៀបចំពិធីកំជាប់ពាក្យ។ តើ A អាចទាមទារសំណងការខូចខាតពី B បានដែរ ឬទេ?

# អានុភាពនៃអាពាហ៍ពិពាហ៍

## សេចក្តីផ្តើម

តើអានុភាពនៃអាពាហ៍ពិពាហ៍ចាប់ផ្តើមពេលណា? ក្រមរដ្ឋប្បវេណីបានទទួលស្គាល់នូវអានុភាពនៃអាពាហ៍ពិពាហ៍តាមរយៈមាត្រា ៩៦៥ ដល់មាត្រា ៩៦៨។ ទោះបីជាការមានការរំលេចដាក់ច្បាស់តែ៤មាត្រាក៏ដោយ ក៏អានុភាពនៃអាពាហ៍ពិពាហ៍អាចរកឃើញនៅក្នុងមាត្រាផ្សេងទៀតនៃក្រមរដ្ឋប្បវេណី និងបញ្ញត្តិដទៃទៀតផងដែរ។ ប្រធានបទថ្ងៃនេះផ្តោតទៅលើតែអានុភាពនៃអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរតែប៉ុណ្ណោះ។

អ្វីដែលជាបញ្ហាថាតើអាពាហ៍ពិពាហ៍ចាប់ផ្តើមមានអានុភាពនៅពេលណា? យោងតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ដោយឡែកបញ្ហាមួយទៀតគឺ តើអាពាហ៍ពិពាហ៍ដែលបានធ្វើឡើងមុនឆ្នាំ ២០០០ ត្រូវមានអានុភាពដូចម្តេចទៅ? តាមមាត្រា ៤៥ ថ្មី អនក្រ.បក លេខ១៧ចុះថ្ងៃទី ១៤.០៦.២០០៤ និង មាត្រា៤៦ អនក្រ.បក លេខ ១០៣ ថ្ងៃទី ២៩ . ១២ . ២០០០ ត្រូវដាក់ពាក្យសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ចុះប្រសិនបើអានុភាពអាពាហ៍ពិពាហ៍ គិតចាប់ពីពេលចុះបញ្ជាក់អាពាហ៍ពិពាហ៍ នោះនឹងនាំឲ្យមានផលលំបាកទាក់ទងនិងទ្រព្យសម្បត្តិ មុនពេលអាពាហ៍ពិពាហ៍ត្រូវបានបញ្ជាក់។

## ផ្នែកទី ១- អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះទំនាក់ទំនងបុគ្គល

ដោយហេតុថា អាពាហ៍ពិពាហ៍ជាសញ្ញាណគតិយុត្តដែលទាក់ទងនឹងការគ្រប់គ្រងទំនាក់ទំនងបុគ្គលជាច្រើន នោះអានុភាពនៃអាពាហ៍ពិពាហ៍នឹងផ្តោតទៅលើការបង្កើតទំនាក់ទំនងញាតិពន្ធ (កថាខណ្ឌ ១) ការបង្កើតស្នំកូនពេញលេញ (កថាខណ្ឌ ២) ការប្រែប្រួលលើការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ (កថាខណ្ឌ ៣) និងការទទួលបាននីតិភាពរបស់អនីតិជនតាមរយៈអាពាហ៍ពិពាហ៍ (កថាខណ្ឌ ៤)។

- **កថាខណ្ឌ ១៖ ការបង្កើតទំនាក់ទំនងញាតិពន្ធ**

ក្រមរដ្ឋប្បវេណីមិនបានចែងឲ្យបានច្បាស់ អំពីការបង្កើតទំនាក់ទំនងញាតិពន្ធតាមរយៈអាពាហ៍ពិពាហ៍ទេ។ តែផ្ទុយទៅវិញ មាត្រា៩៨១ នៃក្រមរដ្ឋប្បវេណី បានចែងអំពីការរលត់ទំនាក់ទំនងញាតិពន្ធដោយសារការលែងលះ ឬមរណភាពរបស់សហព័ទ្ធ។ តាមន័យនេះ យើងអាចសន្និដ្ឋានបានថា អានុភាពនៃអាពាហ៍ពិពាហ៍ក៏បង្កើតឲ្យមានទំនាក់ទំនងញាតិថ្មី ពោលគឺញាតិពន្ធ។

តើញាតិពន្ធមានន័យដូចម្តេច?ញាតិពន្ធសំដៅលើចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត (សាច់ថ្លៃ)។ លើសពីនេះ ក្រមរដ្ឋប្បវេណីបានកំណត់នូវទំហំញាតិត្រឹមញាតិពន្ធក្នុងថ្នាក់ទី ៣។ ញាតិពន្ធថ្នាក់ទី១ រួមមាន ឪពុកម្តាយក្មេក និង កូនចុង ញាតិពន្ធថ្នាក់ទី ២ រួមមាន ជីដូនជីតាក្មេក បងប្អូនប្រុសស្រីថ្លៃ និងកូនរបស់កូនចុង។ ញាតិពន្ធថ្នាក់ទី៣ រួមមាន ជីដូនជីតាទួតក្មេក ពូមីងថ្លៃ ក្មួយប្រុស និងក្មួយស្រីថ្លៃ និងចៅរបស់កូនចុង។

ដូចនេះ ក្រោយអាពាហ៍ពិពាហ៍ត្រូវបានចុះបញ្ជី ទំនាក់ទំនងញាតិពន្ធត្រូវបានចាប់ផ្តើមដោយស្វ័យប្រវត្តិ។

- **កថាខណ្ឌ ២៖ ការបង្កើតសុំកូនពេញលេញ**

បុគ្គលដែលមានសហព័ទ្ធ អាចបង្កើតសុំកូនពេញលេញបាន។ យោងតាមមាត្រា ១០០៨ នៃក្រមរដ្ឋប្បវេណីបានចែងថាបុគ្គលដែលក្លាយជាឪពុក ឬម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។ ពាក្យសហព័ទ្ធដែលមានចែងក្នុងមាត្រា១០០៨ សំដៅទៅលើសហព័ទ្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬសហព័ទ្ធក្នុងន័យអនីតិសង្វាស? វាជាការលំបាកក្នុងការបកស្រាយ ប៉ុន្តែតាមទស្សនាទាននៃផ្នត់គំនិតរបស់ក្រមរដ្ឋប្បវេណីពាក្យសហព័ទ្ធសំដៅលើការប្រើប្រាស់ចំពោះអ្នកដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ។

ក្រៅពីនេះការតម្រូវឲ្យមានសហព័ទ្ធក្នុងការសុំកូនពេញលេញជាល័ក្ខខ័ណ្ឌមួយ ដើម្បីធានាការពារប្រយោជន៍ដល់កូនដែលត្រូវយកទៅចិញ្ចឹមផងដែរ។

- **កថាខណ្ឌ៣៖ ការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ**

អាពាហ៍ពិពាហ៍ក៏បើកលទ្ធភាពដល់សហព័ទ្ធម្ខាងក្នុងការប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមានមុនរៀបអាពាហ៍ពិពាហ៍បាន ដោយយោងតាមមាត្រា៩៦៥ នៃក្រមរដ្ឋប្បវេណី។ នេះមានន័យថា នាមត្រកូលរបស់ប្តី និងប្រពន្ធអាចដូចគ្នា និងអាចខុសគ្នា។

- **កថាខណ្ឌ៤៖ ការទទួលបាននីតិភាព**

មាត្រា៩៦៨ នៃក្រមរដ្ឋប្បវេណី បានចែងថា ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះបានចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ។ លើសពីនេះ មាត្រា២១ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីក៏បានបញ្ជាក់ដែរថា អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការ។ ហើយតាមមាត្រា២២ នៃក្រមរដ្ឋប្បវេណីបានចែងផងដែរថាអនីតិជនដែលទទួលអត្តាធីនភាពត្រូវចាត់ទុកថាដល់នីតិភាព។

ទាំងអស់នេះមានន័យថា អាពាហ៍ពិពាហ៍នាំមកនូវការទទួលបាននូវអត្តាធីនភាពដល់អនីតិជនដោយស្វ័យប្រវត្តិ ហើយនីតិភាពនេះនឹងមិនបាត់បង់ឡើយទោះបីជាការលែងលះកើតមានក៏ដោយ។

## ផ្នែកទី២- អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះភាគីកិច្ចកំណត់ដោយ ក្រមរដ្ឋប្បវេណី

ផ្អែកតាមក្រមរដ្ឋប្បវេណី សហព័ទ្ធមានកាតព្វកិច្ចរួមគ្នាជាច្រើន ដែលមិនមែនជាកាតព្វកិច្ចផ្តាច់មុខតែប្តី រឺប្រពន្ធនោះទេ។

- **កថាខណ្ឌ ១៖ ករណីយកិច្ចរួមរស់ សហការ និងសង្គ្រោះគ្នា**

មាត្រា៩៦៦ សំដៅទៅលើថា ប្តីប្រពន្ធដែលជាបុគ្គលឯករាជ្យ និងស្មើភាពគ្នា ត្រូវមានករណីកិច្ចសហការគ្នា ដើម្បីថែរក្សាជីវភាពអាពាហ៍ពិពាហ៍រួម និងដើម្បីឆ្លើយតបទៅនឹងករណីយកិច្ចដែលពួកគេមានសិទ្ធិស្មើគ្នា។ ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក គប្បីក្លាយជាករណីយកិច្ចគ្រឹះនៃអានុភាពអាពាហ៍ពិពាហ៍ ព្រោះករណីយកិច្ចនេះ ជាអ្នកបង្ខំឲ្យទំនាក់ទំនងបុគ្គល និងទ្រព្យមានលក្ខណៈល្អប្រសើរ។

ប្រសិនបើភាគីម្ខាងបានបំពាននូវករណីយកិច្ចនេះ នោះភាគីម្ខាងទៀតអាចដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាតបាន (មាត្រា ៧៩៣ នៃក.រ)។ លើសពីនេះទៀត ការបំពាននោះនឹងបង្កជាមូលហេតុមួយនៃការលែងលះ (មាត្រា ៩៧៨ នៃក.រ)។

- **កថាខណ្ឌ ២៖ សេរីភាពក្នុងការចូលរួមសកម្មភាពសង្គម និង ជ្រើសរើសវិជ្ជាជីវៈ**

មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណីបានចែងថា ប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួន។ ត្រង់ចំណុចនេះ នីតិនិពន្ធហាក់បីដូចជាបើកទូលាយដល់សេរីភាពបុគ្គល ទោះបីជាក្រោយរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ។

- **កថាខណ្ឌ ៣៖ ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍**

យោងតាមមាត្រា៩៧១នៃក្រមរដ្ឋប្បវេណីបានចែងថាប្តីប្រពន្ធត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។ នេះជាបញ្ញត្តិមួយគ្រប់គ្រងនូវទំនាក់ទំនងផ្ទៃក្នុងរវាងប្តី និងប្រពន្ធ។

ឧទាហរណ៍ A និង B ជាប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែកំពុងរស់នៅបែកពីគ្នា។ A ជាអ្នករកប្រាក់ចំណូល B ជាអ្នកមើលថែរក្សាកូន (C)។ B អាចទាមទារឲ្យ A បង់ប្រាក់ដើម្បីផ្គត់ផ្គង់ជីវភាពរបស់ B និង C។

*តើអ្វីខ្លះដែលជាសោហ៊ុយអាពាហ៍ពិពាហ៍?

សោហ៊ុយលើសម្លៀកបំពាក់ អាហារ កន្លែងស្នាក់នៅ សុខភាព ការសិក្សា និងការមើលថែរក្សាកូន សោហ៊ុយចិញ្ចឹមកូនដែលបានដល់នីតិភាព ប៉ុន្តែមិនអាចរស់នៅដោយឯករាជ្យបាន (សិស្សសាកលវិទ្យាល័យ មានជម្ងឺ ឬពិការជាដើម) សោហ៊ុយចិញ្ចឹម ឬ ផ្គត់ផ្គង់កូនរបស់សហព័ទ្ធ (កូនចុង) ឬ ឪពុកម្តាយរបស់សហព័ទ្ធ ដែលបានរស់នៅជាមួយគ្នានឹងប្តីប្រពន្ធនោះ។

* ការកំណត់ចំនួនសោហ៊ុយអាពាហ៍ពិពាហ៍

សោហ៊ុយអាពាហ៍ពិពាហ៍នឹងត្រូវបានបង់ដោយភាគីដែលមានប្រាក់ចំណូលច្រើនជាង ទៅឲ្យភាគីម្ខាងទៀតដែលមានប្រាក់ចំណូលតិចជាង។ ប្រសិនបើភាគីដែលបានទទួលបានមើលថែរក្សាកូន ឬ បានធ្វើការចំណាយពិសេស ដូចជាសោហ៊ុយព្យាបាល, នោះចំនួនទឹកប្រាក់នឹងត្រូវបានបង្កើន។ បន្ទាប់ពីមានការកំណត់ចំនួនសោហ៊ុយអាពាហ៍ពិពាហ៍តាមការព្រមព្រៀងឬតាមសេចក្តីសម្រេចរបស់តុលាការ ប្រសិនបើមានការប្រែប្រួលស្ថានភាពខ្លាំង ដូចជាការផ្លាស់ប្តូរការងារនៃភាគីណាម្ខាង ឬការធ្លាក់ខ្លួនឈឺនៃភាគីណាម្ខាងនោះភាគីណាមួយអាចដាក់ពាក្យសុំកែប្រែចំនួនសោហ៊ុយអាពាហ៍ពិពាហ៍ទៅតុលាការបាន។

- **កថាខណ្ឌ ៤៖ ការទទួលខុសត្រូវដោយសាមគ្គី**

មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចៈ

- សោហ៊ុយដើម្បីរក្សាជីវភាពរួមរស់របស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន
- កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធទាំងសងខាង បានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍ជាមួយម្ចាស់បំណុល ឬ កាតព្វកិច្ច និងករណីយកិច្ច ដែលប្តីឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរ ពីប្រពន្ធ ឬប្តីម្ខាងទៀត
- សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។

វាជាវិធានមួយដើម្បីគ្រប់គ្រងទំនាក់ទំនងខាងក្រៅរវាងប្តីប្រពន្ធនិងភាគីផ្សេងទៀត។

ឧទាហរណ៍៖ ពូ ក និង មីង ខ ជាប្តីប្រពន្ធ។ ពូ ក តែងតែលេងល្បែងរហូតក្លាយជាមុខរបរប្រចាំថ្ងៃ និងជំពាក់ប្រាក់គេដោយមានទាំងកិច្ចសន្យាខ្ចីប្រាក់ផង។ សូមបញ្ជាក់ថា មីង ខ អត់ដឹងទេ។ តើ មីង ខ ត្រូវទទួលខុសត្រូវលើបំណុលនេះដែរឬទេ? វាជាបញ្ហាមួយដែលពិបាកក្នុងការបកស្រាយ តើចូល មាត្រា ៩៧៥ ចំណុច១រឺ២។

ឧទាហរណ៍ A និង B ជាប្តីប្រពន្ធ។ ប្រសិនបើ A ត្រូវទទួលខុសត្រូវចំពោះសោហ៊ុយអាពាហ៍ពិពាហ៍ នោះ B គឺត្រូវទទួលខុសត្រូវដោយសាមគ្គីដោយស្វ័យប្រវត្តិផងដែរ ទោះបីជា B មិនបានដឹងពីការទទួលខុសត្រូវរបស់ A ក៏ដោយ។ ផ្ទុយទៅវិញ ប្រសិនបើA បានទិញអចលនវត្ថុមួយ, គ្រឿងអលង្ការដែលមានតម្លៃថ្លៃ, ឬ ប្រាក់កម្ចីសម្រាប់ការ កំសាន្ត នោះB នឹងមិនត្រូវទទួលខុសត្រូវដោយសាមគ្គីនោះទេ លុះត្រាតែB បានយល់ព្រម (មាត្រា ៩៧៥ ចំណុច ខ នៃក.រ)។

ឧទាហរណ៍៖ ប្រសិនបើប្តីប្រពន្ធបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមួយដែលចែងពីការលុបចោលនូវការទទួលខុសត្រូវដោយសាមគ្គី នោះម្ចាស់បំណុលរបស់ A មិនអាចទាមទារការទទួលខុសត្រូវដោយសាមគ្គីចំពោះ B (សហព័ទ្ធរបស់ A) បានឡើយ។

## ផ្នែកទី៣-អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះទំនាក់ទំនងទ្រព្យ

- **កថាខណ្ឌ ១៖ ទ្រព្យសម្បត្តិរួម**

អាពាហ៍ពិពាហ៍បានបង្កើតឲ្យមានការបែងចែកសញ្ញាណទ្រព្យជាពីរ គឺទ្រព្យរួម និងទ្រព្យដោយឡែក។ទ្រព្យដោយឡែកសំដៅលើទ្រព្យដែលសហព័ទ្ធមាននៅមុនពេលរៀអាពាហ៍ពិពាហ៍ ឬទ្រព្យដែលទទួលបានដោយប្រទានកម្មសន្តតិកម្ម អច្ច័យទានដែលអំឡុង ពេលអាពាហ៍ពិពាហ៍ ឬ តម្លៃតបនៃទ្រព្យទាំងនេះ មាត្រា ៩៧២នៃក្រមរដ្ឋប្បវេណី។

ក្រមក៏អនុញ្ញាតឲ្យគូភាគីចែងផ្ទុយ តាមរយៈការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីផងដែរ កុំអោយតែការចែងនោះប៉ះពាល់ដល់សិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង។

ក្រៅពីទ្រព្យដោយឡែក គឺជាទ្រព្យរួម ពោលគឺទ្រព្យដែលសហព័ទ្ធរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ មាត្រា ៩៧៣នៃក្រមរដ្ឋប្បវេណី។

វិធានខាងលើ ដែលទាក់ទងនឹងសោហ៊ុយអាពាហ៍ពិពាហ៍ ការទទួលខុសត្រូវដោយសាមគ្គី និងទ្រព្យសម្បត្តិរួម និងទ្រព្យដោយឡែក អាចត្រូវបានកែប្រែតាមរយៈកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (មាត្រា ៩៦៩)។

ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្រសួងយុត្តិធម៌ នោះពួកគេអាចអះអាងកិច្ចសន្យានោះចំពោះតតិយជនបាន (អនុក្រឹត្យស្តីពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) និងមាត្រា មាត្រា ៩៧០។

*តើខាងក្រោមនេះជាទ្រព្យសម្បត្តិរួមរឺទេ ៖

– ប្រាក់បៀវត្សរ៍ដែលទទួលបានដោយសហព័ទ្ធម្ខាង ក្រោយពេលរស់នៅបែកគ្នា មុនពេលលែងលះ?
– ការកើនឡើងនូវតម្លៃទីផ្សារនៃអចលនវត្ថុមួយដែលជាទ្រព្យសម្បត្តិដោយឡែក?
– តម្លៃតបស្នងដែលទទួលបានដោយការលក់អចលនវត្ថុមួយដែលជាទ្រព្យសម្បត្តិដោយឡែក?
– ប្រាក់ថ្លៃឈ្នួលតាមរយៈការជួលអចលនវត្ថុមួយដែលជាទ្រព្យសម្បត្តិដោយឡែក?
– ការប្រាក់នៃប្រាក់តម្កល់ក្នុងធនាគារដែលជាទ្រព្យសម្បត្តិដោយឡែក?

- **កថាខណ្ឌ ២៖ ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យ**

ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយផ្អែកតាមមាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី។

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

- **កថាខណ្ឌ ៣៖ ការចាត់ចែងទ្រព្យសម្បត្តិរួម**

ដើម្បីចាត់ចែងទ្រព្យសម្បត្តិរួមបាន គឺត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬការអនុញ្ញាតពីតុលាការជាការចាំបាច់ (មាត្រា ៩៧៦ កថាខណ្ឌទី ១, កថាខណ្ឌទី ២) ទោះបីជាសហព័ទ្ធម្ខាងមានបំណងចាត់ចែងត្រឹមតែចំណែករបស់ខ្លួននៃទ្រព្យសម្បត្តិរួមក៏ដោយ ប្រសិនបើសហព័ទ្ធម្ខាងបានចាត់ចែងទ្រព្យសម្បត្តិរួមដោយពុំមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬមិនមានការអនុញ្ញាតពីតុលាការ នោះសហព័ទ្ធម្ខាងទៀត អាចទាមទារឲ្យតុលាការលុបចោលនូវការចាត់ចែងក្នុងអំឡុងពេល២ឆ្នាំបាន ក្នុងករណីអចលនវត្ថុសម្រាប់ការរស់នៅ ឬ ១ ឆ្នាំ ក្នុងករណីផ្សេងទៀត (មាត្រា ៩៧៦ កថាខណ្ឌទី ៣)។

- **កថាខណ្ឌ ៤៖ ការអាស្រ័យនៅលើទ្រព្យដោយឡែក**

ក្រមបានបើកលទ្ធភាពឲ្យសហព័ទ្ធម្ខាងក្នុងការអាស្រ័យនៅលើទ្រព្យ ជាអចលនវត្ថុរបស់សហព័ទ្ធម្ខាងទៀតបាន ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនេះក៏ដោយមាត្រា៩៧៧ នៃក្រមរដ្ឋប្បវេណី។

## ផ្នែកទី ៤៖ អានុភាពនៃអាពាហ៍ពិពាហ៍ចំពោះអំពើ រឺសកម្មភាពដែលត្រូវលើកលែង និងការហាមឃាត់ដោយច្បាប់

បញ្ញត្តិខ្លះនៃក្រមរដ្ឋប្បវេណី ក៏បានបង្ហាញនូវវត្តមាននៃបញ្ញត្តិពិសេសពាក់ព័ន្ធនឹងការហាមឃាត់នូវសកម្មភាពមួយចំនួន ដែលសហព័ទ្ធមិនត្រូវធ្វើក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍។ ក្នុងនោះមានការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ (កថាខណ្ឌ ១) និងការហាមឃាត់នូវទ្វេពន្ធភាព ឬការរៀបអាពាហ៍ពិពាហ៍ជាមួយញាតិពន្ធ (កថាខណ្ឌ ២) រួមទាំងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរបើមានការបំពាន។

- **កថាខណ្ឌ ១៖ ការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ**

តាមទស្សនាទាននៃក្រមព្រហ្មទណ្ឌ គ្រួសារមានអភ័យឯកសិទ្ធិពិសេសក្នុងការមិនទទួលខុសត្រូវនូវបទល្មើសលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ មានន័យថា ក្រោយរៀបអាពាហ៍ពិពាហ៍ការលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាង ដោយសហព័ទ្ធម្ខាងមិនត្រូវទទួលខុសត្រូវលើទោសព្រហ្មទណ្ឌទេ តាមមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ។ យើងបានរកឃើញមាត្រាពាក់ព័ន្ធផ្សេងទៀត ដែលជាបទល្មើស ប៉ុន្តែត្រូវបានលើកលែងអោយរួចផុតពីទោស។

- មាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌចំពោះសហព័ទ្ធរបស់ចារី ------------------------------ត្រូវបានរួចផុតពីទោស កាលបើបានដឹងពីបទឧក្រិដ្ឋដែលអាចបង្ការ រឺ បន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនប្ដឹងបរិហារដល់អាជ្ញាធរ។
- មាត្រា ៥៣៩ នៃក្រមព្រហ្មទណ្ឌចំពោះសហព័ទ្ធរបស់ចារី ត្រូវបានរួចផុតពីទោស កាលបើមានភស្តុតាងបង្ហាញអោយឃើញភាពស្លូតត្រង់របស់ជនត្រូវចោទ------------------ហើយមិនផ្ដល់ភស្តុតាងដល់អាជ្ញាធរ។

- មាត្រា ៥៩៤ នៃក្រមព្រហ្មទណ្ឌចំពោះសហព័ទ្ធរបស់ចារី ត្រូវបានរួចផុតពីទោសពីបទផ្តល់ជំនួយដល់ចារី -----------------------------------------------------------------។
  - **កថាខណ្ឌ ២៖ ការហាមឃាត់ដោយច្បាប់ និង ការទទួលខុសត្រូវព្រហ្មទណ្ឌ**
- មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី បានធ្វើការហាមឃាត់មិនឲ្យមានការរៀបអាពាហ៍ ពិពាហ៍ជាថ្មី ចំពោះសហព័ទ្ធដែលកំពុងស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍។
- មាត្រា ៩៥២ បានធ្វើការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ និងសាខាញាតិពន្ធនៅក្នុងបីថ្នាក់។ តែច្បាប់បានលើកលែងករណីដែលសហព័ទ្ធណាម្នាក់បានទទួលមរណភាពនោះសហព័ទ្ធនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយនឹងសាខាញាតិពន្ធនៅក្នុងថ្នាក់ទី៣បាន។

ដោយឡែកក្រមព្រហ្មទណ្ឌ ទ្វេពន្ធភាព និង ការរួមភេទជាមួយញាតិពន្ធក្នុងបីថ្នាក់ ជាបទល្មើសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា ៣៥០ មាត្រា ៣៥១ និងមាត្រា ៣៥២ នៃក្រមព្រហ្មទណ្ឌ។ លើសពីនេះ ការប្រើហឹង្សាលើសហព័ទ្ធ រឺអនីតិសង្វាសជន រួមទាំងការគំរាមថានឹងសម្លាប់ក៏ជាបទល្មើសផងដែរ មាត្រា ២២២ មាត្រា២៣៣ ។

ករណីសិក្សា៖




- **ករណីទី ១៖** A បានទិញអាហារ និងសម្លៀកបំពាក់ពី X សម្រាប់ជីវភាពអាពាហ៍ពិពាហ៍របស់គេ។

(១) ប្រសិនបើ A មិនបានបង់ប្រាក់ទៅ X៖ X អាចរឹបអូសទ្រព្យសម្បត្តិដោយឡែករបស់ A ទ្រព្យសម្បត្តិរួមរបស់ A និង B និងទ្រព្យសម្បត្តិដោយឡែករបស់ B (មាត្រា ៩៧៥ ចំណុច ក នៃក.រ)។

(២) ប្រសិនបើ A បានបង់ប្រាក់ដោយប្រើប្រាក់បៀវត្សរ៍របស់ A ដែល A រកបានក្រោយអាពាហ៍ពិពាហ៍៖ អាហារ និងសម្លៀកបំពាក់ក្លាយជាទ្រព្យសម្បត្តិរួម ដោយសារប្រាក់បៀវត្សរ៍របស់ A គឺជាទ្រព្យសម្បត្តិរួម។

(៣) ប្រសិនបើ A បានបង់ប្រាក់ដោយប្រើប្រាក់តម្កល់របស់ A ក្នុងធនាគារដែល A បានទុកតាំងពីមុនពេលរៀបអាពាហ៍ពិពាហ៍ នោះតើ A អាចទាមទារឲ្យ B បង់ប្រាក់ពាក់កណ្តាលបានដែរ ឬ ទេ?

- **ករណីទី ២៖** A បានទិញអចលនវត្ថុមួយពី X ដោយពុំមានការយល់ព្រមពី B។

(១) ប្រសិនបើ A មិនបានបង់ប្រាក់ទៅ X៖ X អាចរឹបអូសទ្រព្យសម្បត្តិដោយឡែករបស់ A និងចំនែកនៃទ្រព្យសម្បត្តិរួមរបស់ A ប៉ុន្តែ X មិនអាចរឹបអូសនូវទ្រព្យសម្បត្តិដោយឡែករបស់ B ឬ ចំនែកនៃទ្រព្យសម្បត្តិរួមរបស់ B បានឡើយ (មាត្រា ៩៧៥ ចំណុច ខ នៃក.រ)។

(២) ប្រសិនបើ A បានបង់ប្រាក់ដោយប្រើនូវប្រាក់តម្កល់ក្នុងធនាគារដែលបានបង្កើតនៅក្រោយពេលអាពាហ៍ពិពាហ៍៖ B អាចទាមទារឲ្យតុលាការលុបចោលកិច្ចសន្យា (មាត្រា ៩៧៦ កថាខណ្ឌទី ៣ នៃក.រ)។ ប្រសិនបើ B មិនបានលុបចោលទេ តើ B អាចទាមទារឲ្យ A សងប្រាក់ដែលជាចំនែករបស់ B បានដែរ ឬ ទេ?

(៣) ប្រសិនបើ A បានបង់ប្រាក់ដោយប្រើប្រាក់តម្កល់ក្នុងធនាគាររបស់ A ដែល A បានរក្សាទុកតាំងពីមុនពេលអាពាហ៍ពិពាហ៍៖ អចលនវត្ថុនោះក្លាយជាទ្រព្យសម្បត្តិដោយឡែករបស់ A (មាត្រា ៩៧២ ចំណុច គ នៃក.រ)។

# ការលែងលះគ្នា

## ១. មូលហេតុនៃការលែងលះ

១.១ ការលែងលះដោយគ្មានការព្រមព្រៀង

១.២ ការលែងលះដោយការព្រមព្រៀង

## ២. អានុភាពនៃការលែងលះ

២.១ អានុភាពលើស្ថានភាពគ្រួសារ

ក. ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ (មាត្រា ៩៤១-១ ក.រ)

ខ. នាមត្រកូលអាចត្រូវបានផ្លាស់ប្តូរ (មាត្រា ៩៨១ ក.រ)

គ. អ្នកមានអំណាចមេបានឹងត្រូវបានសម្រេច (មាត្រា ១០៣៧-ក.រ)

ឃ. អានុភាពនៃអត្ថាធីនភាពនៅតែមាន (មាត្រា ២១-៣ ក.រ)

២.២ អានុភាពលើទ្រព្យសម្បត្តិ និងកាតព្វកិច្ច

ក. កាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមកត្រូវបញ្ចប់(មាត្រា៩៦៦-ក.រ)

ខ. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់លែងយកមកអនុវត្ត (មាត្រា៩៧១ ដល់ ៩៧៧-ក.រ)

គ. ការបែងចែកទ្រព្យសម្បត្តិកើតមានឡើង (មាត្រា ៩៨០-ក.រ)

ឃ. កាតព្វកិច្ចបង់សំណងជំងឺចិត្តអាចកើតមាន (មាត្រា ៧៤៣ និង៧៤៤ ក .រ)

ង. ការលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាតអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀត (មាត្រា ៧៦-ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងមាត្រា៧៨ -ច្បាប់ស្តីពីការអនុវត្តក្រម)

## ៣. នីតិវិធីនៃការលែងលះ

៣.១ ការលែងលះដោយគ្មានការព្រមព្រៀង (មាត្រា ៩៧៨-ក.រ)

ក. ការដាក់ពាក្យទៅឃុំ-សង្កាត់ (មាត្រា១០ ក្រមនីតិវិធី.)

ខ. ការដាក់ពាក្យបណ្តឹងទៅតុលាការ

គ ការទាមទារពាក់ព័ន្ធនឹងការលែងលះ

- សោហ៊ុយអាពាហ៍ពិពាហ៍ (មាត្រា ៩៧១ នៃក.រ)

- សោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន (មាត្រា ១០៤០ នៃក.រ)

- ការបែងចែកទ្រព្យសម្បត្តិ (មាត្រា ៩៨០ នៃក.រ)

- សំណាងជម្ងឺចិត្ត (មាត្រា ៧៤៣ នៃក.រ)

- ការសម្រេចអំពីអ្នកមានអំណាចមេបា (មាត្រា ១០៣៧ នៃក.រ)

៣.២ ការលែងលះដោយការព្រមព្រៀង (មាត្រា ៩៧៩ នៃក.រ)

នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្នបានប្រឈមមុខនឹងបញ្ហានៃការលែងលះគ្នា។ ប៉ុន្តែភាគី ប្តី ឬប្រពន្ធនៅមិនទាន់ដឹងនូវឡើយ ថាតើការលែងលះគ្នាបែបណាដែលស្របច្បាប់ ហើយពុំនាំមក នូវជំលោះនាពេលអនាគត។

មុននឹងឈានដល់ការលែងលះគ្នា វាត្រូវចាប់ផ្តើមឡើងដោយការរៀបអាពាហ៍ពិពាហ៍ជាមុននៅចំណុចនេះយើងត្រូវសួរថា អ្វីទៅជាអាពាហ៍ពិពាហ៍? ធ្វើដូចម្តេចដើម្បីអោអាពាហ៍ពិពាហ៍មួយស្របច្បាប់? អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាស ជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តខ្លួនឡើយ។ អាពាហ៍ពិពាហ៍ ជាកិច្ចសន្យាពិសេសមួយ ដែលត្រូវគោរពតាល័ក្ខខ័ណ្ឌការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជី នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន(មាត្រា៩៥៥-ក.រ)។

ដូចនេះ នៅពេលដែលប្តី ឬប្រពន្ធមានបញ្ហានឹងគ្នា ហើយមិនអាចបន្តការរួមរស់នៅជាមួយគ្នាបុគ្គលទាំងពីរត្រូវការលែងលះគ្នា។ ការលែងលះគ្នាគឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការពេញច្បាប់ក្នុងពេលរួមរស់នៅជាមួយគ្នា (មាត្រា ៣៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩) ។

## ១.មូលហេតុនៃការលែងលះ

### ១-១ការលែងលះដោយគ្មានការព្រមព្រៀង

ប្រសិនបើដើមបណ្តឹងអាចបញ្ជាក់មូលហេតុណាមួយពីចំណុច ក ដល់ចំណុច ង ក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ ដោយជោគជ័យបាន នោះជាទូទៅតុលាការនឹងចេញសាលក្រមសំរេចអោយ លែងលះ។

មាត្រា៩៧៨ មូលហេតុនៃការលែងលះគ្នា៖

ក- បើបានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ។

ខ- បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ។

គ- បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង០១ឆ្នាំ។

ឃ- បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង០១ឆ្នាំផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

ង- ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹម

ថានឹងអាចបដិទានឡើងវិញបាន ។

<u>ឧទាហរណ៍ចំណុច(ក)</u>៖ លោក A និងអ្នកស្រី B បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ តាំងពីដើមឆ្នាំ ២០១៣។ ក្រោយមកលោក A បានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធជាមួយនារីខាងក្រៅ។ ដូចនេះ អ្នកស្រី B ជាជនរងគ្រោះ អាចដាក់ពាក្យបណ្តឹងលែងលះ ដោយសំអាងលើមូលហេតុខាងលើនេះ ព្រោះ លោក A ជាអ្នកធ្វើអោយបែកបាក់ចំណងអាពាហ៍ពិពាហ៍ ។

<u>ឧទាហរណ៍ចំណុច(ខ)</u>៖ លោក A និងអ្នកស្រី B បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់តាំងពីដើមឆ្នាំ ២០១២។ ក្រោយពីការរួមរស់នៅជាមួយគ្នា បានមួយរយៈ លោក A មានទំនាស់ជាមួយអ្នកស្រី B ក្រោយ មកលោក A បានបែងចែកបន្ទប់គេងជាមួយលោកស្រី B និងមិនបានយកចិត្តទុកដាក់ថែរក្សាក្រុមគ្រួសារ ទោះបីជាប្រពន្ធនិងកូនមានជំងឺ ឬបញ្ហាដ៏ទៃផ្សេងទៀត ក៏លោក A មិនសហការនិងជួយសង្គ្រោះ។ ក្នុង ករណីនេះ ទោះបីជាលោក A និងអ្នកស្រី B រស់នៅក្រោមដំបូលផ្ទះតែមួយ តែការរស់នៅរបស់គាត់វាផ្ទុយ អំពីគោលបំណងអាពាហ៍ពិពាហ៍ដែលប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នា ទៅវិញទៅមក(មាត្រា៩៦៦ ក.រ.)។

ការបោះបង់សហព័ទ្ធនៅចំណុចនេះ គឺមិនមែនមានន័យថាលុះត្រាតែលោក A បានចាកចេញពី លំនៅឋានចោលអ្នកស្រី B ឡើយ។ ចំណុចដែលសំខាន់ តើវាមានមូលហេតុត្រឹមត្រូវណាមួយដើម្បី បញ្ជាក់ថាលោក A បង្ហាញសកម្មភាពប្រាសចាកអំពីគោលបំណងនៃអាពាហ៍ពិពាហ៍ ដូចជាចេតនា អាក្រក់រំលោភលើករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក(មាត្រា៩៦៦នៃក.រ) ឬចេតនាអាក្រក់រំលោភលើករណីយកិច្ចទទួលបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ (មាត្រា៩៧១ ក.រ)។

ដូចនេះ តុលាការអាចសំរេចលែងលះតាមពាក្យបណ្តឹងដូចមានចែងក្នុងមាត្រា៩៧៨ ចំនុច ខ និង មាត្រា ៦៣ អន្តរបញ្ញត្តិស្តីពីមូលហេតុ នៃការលែងលះគ្នានៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

<u>ឧទាហរណ៍ចំណុច(គ)</u>៖ លោក A និងអ្នកស្រី B បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់តាំងពីដើមឆ្នាំ ២០១០។ ជាធម្មតាលោកA បានទៅបំពេញការងារនិងចាកចេញពីផ្ទះជារៀងរាល់ម៉ោង៨ព្រឹក និងត្រលប់ មកវិញវេលាម៉ោង៥ ឬ៦ល្ងាច។ លុះដល់ថ្ងៃទី១០-០៥-២០១៣ មិនឃើញលោក A ត្រលប់មកផ្ទះវិញ ដែលធ្វើឲ្យអ្នកស្រី B និងក្រុមគ្រួសារមានការព្រួយបារម្ភ។ អ្នកស្រី B បានប្រើប្រាស់គ្រប់មធ្យោបាយដើម្បី ទាក់ទង ឬទទួលព័ត៌មានអំពីការស្លាប់ឬ ការរស់របស់លោក A។ ទោះបីជាខំប្រឹងបែបណា ក៏អ្នកស្រី B មិនទទួលបានដំណឹងអំពីលោក A ឡើយ។ ករណីមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ឬរស់អស់រយៈពេល ជាងមួយឆ្នាំ គឺចាប់រាប់ពីថ្ងៃចុងក្រោយដែលអ្នកស្រីB មិនបានទទួលដំណឹង(អត់ដឹង)។

**<u>ឧទាហរណ៍ចំណុច(ឃ)</u>៖** លោក A និងអ្នកស្រី B បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់តាំងពីដើមឆ្នាំ ២០១១។ ក្រោយមកលោកA បានឈ្លោះប្រកែកជាមួយនឹងអ្នកស្រី B ហើយលោក Aបានចាកចេញពីផ្ទះ ដោយរស់នៅបែកពីអ្នកស្រី Bអស់រយៈពេលជាងមួយឆ្នាំ។ លោក A មិនបានទទួលខុសត្រូវបន្ទុកនៃសោហ៊ុយនៃអាពាហ៍ពិពាហ៍(មាត្រា៩៧១ ក.រ.) ចាប់ពីពេលនោះមក និងមិនបានថែរក្សា គ្រប់គ្រង អប់រំកូនរបស់ខ្លួនឡើយ(មាត្រា៩៧៥-ក ក.រ.)។

ប៉ុន្តែករណីខ្លះមិនអាចចាត់ទុកថា ជាការរស់នៅបែកបាក់គ្នាជាបន្តបន្ទាប់អស់រយៈពេលជាងមួយឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ឡើយ ព្រោះមានករណីខ្លះដូចជាលោកA បានទទួលនូវអាហារូបករណ៍ទៅសិក្សានៅឯបរទេស ហើយលោក A តែងតែទំនាក់ទំនងមកក្រុមគ្រួសារ និងបានផ្ញើប្រាក់ជូនក្រុមគ្រួសារ ដើម្បីទទួលខុសត្រូវបន្ទុកនៃសោហ៊ុយនៃអាពាហ៍ពិពាហ៍ ដូចនេះគ្មានមូលហេតុណាមួយដែលតុលាការសម្រេចឲ្យលែងលះ ដោយយោងតាមអង្គហេតុនៃបណ្ដឹងដែលអ្នកស្រី B បានលើកខាងលើ។

**<u>ឧទាហរណ៍ចំណុច(ង)</u>៖** ចំណុចនេះជាចំណុចទូទៅមួយដែលភាគីបានលើកជាមូលហេតុក្នុងការលែងលះ ដោយសំអាងថាអាពាហ៍ពិពាហ៍ដែលបែកបាក់នេះ គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។

លោក A និងអ្នកស្រី B បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់តាំងពីដើមឆ្នាំ២០១២។ ក្រោយមកលោក A តែងតែឈ្លោះជាមួយអ្នកស្រី B និងជាញឹកញាប់ បានប្រើហិង្សាទៅលើអ្នកស្រី B ព្រមទាំងមានពេលខ្លះជេរប្រមាថមើលងាយភរិយា និងបុព្វញាតិរបស់សហព័ទ្ធ។

តុលាការក៏ពិចារណាផងដែរ ថាតើជាអំពើហឹង្សាលើរាងកាយ ឬក៏ការជេរប្រមាថពីភាគីម្ខាង

តើភាគីម្ខាងទៀតមានរងរបួសត្រឹមកម្រិតណា ចេតនារបស់គូភាគី ទំលាប់នៃការផឹកច្រើនរបស់ភាគី ម្ខាងទៀត ទំលាប់លេងល្បែង ការចំណាយលុយខ្ជះខ្ជាយ ការមិនអើពើជាមួយសាច់ញាតិ។

ជាទូទៅ ដើមបណ្ដឹងអាចបង្ហាញអំពីមូលហេតុនៃការលែងលះ មួយចំណុច ឬច្រើនចំណុច ចាប់ពីចំណុច **ក** ដល់ ចំណុច **ង**។ ប្រសិនដើមបណ្ដឹងអាចបង្ហាញភស្តុតាងចំណុចណាមួយនៃ ចំណុចទាំងអស់បានដោយជោគជ័យ នោះតុលាការនឹងចេញសាលក្រមសម្រេចលែងលះ។ ករណីខ្លះ ទោះបីជាតុលាការទទួលស្គាល់ចំណុចមួយនៃចំណុចដ៏ទៃផ្សេងទៀតដែលជាមូលហេតុនៃការលែងលះ ក៏តុលាការនៅតែមានឆន្ទានុសិទ្ធិលើចោលបណ្ដឹងសុំលែងលះ ដោយផ្អែកតាមមាត្រា៩៧៨ កថាខណ្ឌទី២ និងកថាខណ្ឌទី៣។

**<u>ក្នុងករណីខ្លះ តុលាការក៏នៅតែលើកចោលបណ្ដឹងតាមរយៈមាត្រា៩៧៨ កថាខណ្ឌទី២ ឬទី៣</u>៖**

- ទោះបីជាក្នុងករណីបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះក៏ដោយ ប្រសិនបើយល់ ឃើញថាការលែងលះគ្នានោះនឹងបណ្តាលអោយការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនក្រលំបាក យ៉ាងខ្លាំង ឬមានការឈឺចាប់ពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ដូចជា កត្តាផ្លូវចិត្ត កត្តាសង្គម កត្តាសេដ្ឋកិច្ច និងអំឡុងពេលដែលរស់នៅបែកគ្នា។
- ក្នុងករណីដែលមានមូលហេតុដោយការបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទាន ឡើងវិញ ឬបើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង០១ឆ្នាំផ្ទុយនឹងគោល បំណងនៃអាពាហ៍ពិពាហ៍ ប្រសិនបើតុលាការយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុច្ចរិត ដោយជនដែលទាមទារអោយលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះដោយឆន្ទានុសិទ្ធិបាន។

**១-២ ការលែងលះដោយការព្រមព្រៀង (មាត្រា៩៧៩ ក.រ)**

ប្រសិនបើភាគីទាំងពីរគ្មានឆន្ទៈរួមរស់នៅជាមួយគ្នាតទៅទៀតទេ ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យលែងលះទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា។ ប៉ុន្តែតុលាការអាចអោយលែងលះគ្នាបានក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។

## ២.អានុភាពនៃការលែងលះ

ការលែងលះគ្នារំលាយអានុភាពអាពាហ៍ពិពាហ៍ ចាត់តាំងពីថ្ងៃនៃការលែងលះគ្នានោះចូលជាស្ថាពរះ

### ២-១ អានុភាពលើស្ថានភាពគ្រួសារ

*ក. ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ(មាត្រា៩៩១-១ ក.រ)*

ទំនាក់ទំនងញាតិពន្ធត្រូវបញ្ចប់ដោយការលែងលះគ្នា (ខ្សែថ្នាក់ទី៣) (មាត្រា៩៣៨-គ ក.រ.)

*ខ. នាមត្រកូលអាចត្រូវបានផ្លាស់ប្តូរ(មាត្រា៩៨១ ក.រ)*

ប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មីដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។

នៅប្រទេសកម្ពុជា ប្រជាជនភាគច្រើនមិនផ្លាស់ប្តូរនាមត្រកូលនៅពេលរៀអាពាហ៍ពិពាហ៍ ដូច្នេះករណីរឿងក្តីភាគច្រើនពួកគេមិនចាំបាច់ធ្វើការផ្លាស់ប្តូរនាមត្រកូល នៅពេលលែងលះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើមានភាគីណាមួយបានផ្លាស់ប្តូរនាមត្រកូលនៅពេលរៀបអាពាហ៍ពិពាហ៍ ភាគី

ដែលបានផ្លាស់ប្តូរនាមត្រកូលនោះ នៅតែអាចបន្តការប្រើប្រាស់នាមត្រកូលដែលបានផ្លាស់ប្តូរ ឬអាចត្រឡប់ មកប្រើនាមត្រកូលមុនពេលរៀបអាពាហ៍ពិពាហ៍។

*គ. អ្នកមានអំណាចមេបានឹងត្រូវបានសម្រេច(មាត្រា១០៣៧ ក.រ) (រាប់បញ្ចូលទាំងកូនសុំ)*

ដើម្បីផលប្រយោជន៍របស់កូន ការឲ្យភាគីណាមួយរក្សាកូនត្រូវសម្រេចតាមការយល់ព្រមនៃប្តីប្រពន្ធដែលលែងលះគ្នានោះ។ ជាគោលការណ៍កូនដែលនៅបៅដោះត្រូវឲ្យទៅម្តាយ។

ក្នុងករណីដែលគូភាគីមិនឯកភាពគ្នាក្នុងការរក្សាកូនលើអំណាចមេបា តុលាការត្រូវសំរេច ដោយគិតផលប្រយោជន៍របស់កូន ដូចជាកូននេះអាចទទួលបាននូវការអប់រំល្អ ការចិញ្ចឹមបីបាច់ល្អ ព្រមទាំងមានស្ថានភាពកក់ក្តៅ និងល្អនៅពេលដែលកូននោះរួមរស់នៅជាមួយ។ ទោះបីជាយ៉ាងណា ក៏ដោយភាគីដែលមិនបានរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូន ហើយមានសិទ្ធិប្តឹងទៅតុលាការគ្រប់ពេលវេលា ឲ្យដកសិទ្ធិរក្សាកូនពីភាគីម្ខាងនោះបាន បើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូន (មាត្រា១០៣៩-១០៤០)។

*ឃ. អានុភាពនៃអគ្គាធិនភាពនៅតែមាន(មាត្រា២១-៣ និងមាត្រា៩៦៨ ក.រ)*

ក្នុងករណីដែលអនីតិជនដែលបានទទួលនូវអគ្គាធិនភាពដោយការរៀបអាពាហ៍ពិពាហ៍ (មាត្រា២១-២, មាត្រា២២ និងមាត្រា៩៦៨ ក.រ.) ហើយបានលែងលះគ្នា តើគួរឲ្យនៅក្រោមអំណាចមេបារបស់ឪពុកម្តាយ ឬឲ្យមានអានុភាពដដែលក្រោយពេលបានទទួលអគ្គាធិនភាពម្តងហើយនោះ? ដូចនេះមាត្រា២១-៣ ក.រ បានចែងយ៉ាងច្បាស់ថាអានុភាពនៃអគ្គាធិនភាពនៅតែមាន។

## ២-២ អានុភាពលើទ្រព្យសម្បត្តិ និងភាតព្វកិច្ច

*ក. ភាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមកត្រូវបញ្ចប់ (មាត្រា៩៦៦ ក.រ)*

ប្តីប្រពន្ធមានករណីយកិច្ចស្រលាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និងជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល ហើយមានសិទ្ធិស្មើៗគ្នា និងមានករណីយកិច្ចសហការគ្នា ដើម្បីថែរក្សា ជីវភាពអាពាហ៍ពិពាហ៍រួម។ ប៉ុន្តែអ្វីទាំងអស់នេះនឹងត្រូវបញ្ចប់ដោយការលែងលះគ្នា។

*ខ. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់លែងយកមកអនុវត្ត (មាត្រា៩៧១ដល់ ៩៧៧ ក.រ)*

ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ ដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត (មាត្រា៩៧១ ក.រ.) ទ្រព្យសម្បត្តិដោយឡែកដែលស្ថិតនៅក្រោម សហព័ទ្ធណាម្នាក់ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយ ប្រទានកម្ម សន្តិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិ ដែលបានកំណត់ក្នុងចំណុច (ក) និងចំណុច (ខ) នៃមាត្រា៩៧២ ក.រ.។ ទ្រព្យសម្បត្តិរួម (មាត្រា៩៧៣ ក.រ.) ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ (មាត្រា៩៧៤ ក.រ.) ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច (មាត្រា៩៧៥ ក.រ.) ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ (មាត្រា ៩៧៦ ក.រ.) និងការអាស្រ័យនូវទ្រព្យសម្បត្តិដោយឡែក(មាត្រា ៩៧៧ និងមាត្រា៩៨០-២-ក ក.រ.) នឹងលែងយកមកអនុវត្តទៀតហើយ។

*គ. ការបែងចែកទ្រព្យសម្បត្តិកើតមានឡើង(មាត្រា៩៨០-ក.រ) (អាចមើលបន្ថែមសិក្ខា សាលាតូចលើកទី៣)*

- ប្រសិនបើពួកគេមានកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នោះអនុវត្តតាមកិច្ចសន្យានោះ (មាត្រា ៩៦៩-១ នៃ.ក.រ។
- ប្រសិនបើពួកគេមិនមានកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធទេប៉ុន្តែពួកគេអាចមានការព្រមព្រៀងគ្នាលើការបែងចែក នោះអនុវត្តតាមការព្រមព្រៀងនោះ (មាត្រា ៩៧៦ ក.រ)
- ប្រសិនបើពួកគេមិនមានកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ហើយពួកគេមិនអាចមានការព្រមព្រៀងគ្នាអំពីការបែងចែកទេ នោះអនុវត្តតាមការសម្រេចរបស់តុលាការ យោងតាមច្បាប់ស្តីពី នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ផ្នែកទី៤ ចំណុចទី៦ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមានជាបណ្តឹង-ការបែងចែកទ្រព្យសម្បត្តិដោយយោងតាមបញ្ញត្តិមាត្រា៩៨០ ក.រ ទោះព្រមព្រៀង និងមិនព្រមព្រៀងក្តី)។

**<u>ឧទាហរណ៍</u>៖**

មុនពេលអាពាហ៍ពិពាហ៍លោក A និងអ្នកស្រី B បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ ក្រោយមកអ្នកទាំងពីរបានលែងលះគ្នា។ ដូចនេះករណីការលែងលះគ្នានេះ ការបែងចែងទ្រព្យសម្បត្តិត្រូវអនុលោមតាមប្រពន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។

ផ្ទុយទៅវិញ បើមុន និងក្រោយអាពាហ៍ពិពាហ៍ លោក A និងអ្នកស្រី B ពុំបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយក្រោយមកអ្នកទាំងពីរបានលែងលះគ្នាដោយការព្រមព្រៀងធ្វើការបែងចែកទ្រព្យសម្បត្តិ។ ដូចនេះការបែងចែកទ្រព្យសម្បត្តិត្រូវអនុលោមតាមការព្រមព្រៀងរបស់គូភាគី។

លើសពីនេះទៅទៀត បើមិនមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយគូភាគីមិនមានការព្រមព្រៀងគ្នាទេ នោះត្រូវដាក់ពាក្យសុំធ្វើការបែងចែកទ្រព្យសម្បត្តិ អនុលោមតាមផ្នែកទី៤ ចំណុចទី៦ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមានជាបណ្តឹង។

ដូចនេះតុលាការនឹងពិចារណា:

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក)។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក១ ភាគ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍។

គ-*កាតព្វកិច្ចបង់សំណងជំងឺចិត្តអាចកើតមាន(មាត្រា៧៤៣ និងមាត្រា៧៤៤ ក.រ)*

ក្នុងករណីលែងលះគ្នាខ្លះ ភាគីដែលគ្មានកំហុស ហើយដែលត្រូវភាគីម្ខាងទៀតបំពានដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ ហើយសំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ អាចជាការខូចខាតដោយសារការឈឺចាប់ខាងផ្លូវចិត្ត ការអាប់ឱនកិត្តិយសក្នុងសង្គម និងគ្រួសារ ជាអាទិ៍។

**<u>ឧទាហរណ៍</u>៖**

លោក A និងអ្នកស្រី B បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ក្នុងឆ្នាំ២០១២។ អ្នកទាំងពីរបានបង្កើតនូវគ្រួសារមួយដ៏សុខដុមរមនា ក្រោយមកលោក A បានប្រព្រឹត្តិអំពើផិតក្បត់ទៅលើសហព័ទ្ធដែលជាហេតុធ្វើអោយមានការបែកបាក់ និងការលែងលះ។

**ចំណុចសំខាន់នៃរឿងក្តីនេះ យើងត្រូវសួរថា តើនរណាជាអ្នកធ្វើអោយបែកបាក់ចំណងអាពាហ៍ពិពាហ៍? ដូចនេះ ភាគីដែលរងគ្រោះអាចទាមទារ អោយភាគីបំពានបង់សំណងជំងឺចិត្ត។**

ឃ. *ការលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាតអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀត (មាត្រា៧៦-ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងមាត្រា៧៨ -ច្បាប់ស្តីពីការអនុវត្តក្រម)*

ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាតអាចស្នើសុំអាហារកិច្ចពីភាគី ម្ខាងទៀតបាន។ ភាគីខាងក្រោយនេះត្រូវជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។ កម្រិតអាហារកិច្ច ត្រូវសំរេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង។ ក្នុងករណីដែលគូភាគីទាំងសងខាងមិនឯកភាពគ្នាតុលាការត្រូវសំរេចសេចក្តី។ បើជនដែលទទួលអាហារកិច្ច រៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតឡើយ។

## ៣.នីតិវិធីនៃការលែងលះ

### ៣-១ការលែងលះដោយគ្មានការព្រមព្រៀង( មាត្រា៩៧៨-ក.រ )

*ក. ការដាក់ពាក្យសុំទៅឃុំ-សង្កាត់ (មាត្រា១០ ក្រមនីតិវិធី.)*

មុនពេលដាក់ពាក្យបណ្តឹងទៅតុលាការ ភាគីណាមួយនៃអាពាហ៍ពិពាហ៍អាចជ្រើសរើសដាក់ពាក្យសុំលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់នៅទីសំណាក់ ឬលំនៅដ្ឋានដូចមានចែងក្នុង កថាខណ្ឌ ទី១ ឬ កថាខណ្ឌទី៣នៃមាត្រា១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តី បុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីនោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាចធ្វើការផ្សះផ្សា ក្នុងអំឡុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំ។ ក្នុងករណីការផ្សះផ្សាមិនបានសំរេចត្រូវ បញ្ជូនរឿងជាបន្ទាន់ទៅតុលាការ (ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់នេះ គ្រាន់តែជាជំរើសតែ ប៉ុណ្ណោះ មានន័យថា ភាគីណាមួយអាចរំលងនូវការដាក់ពាក្យសុំទៅឃុំ ឬសង្កាត់បាន ហើយដាក់ ពាក្យបណ្តឹងទៅតុលាការផ្ទាល់តែម្តងបាន)

*ខ. ការដាក់ពាក្យបណ្តឹងទៅតុលាការ*

-ប្រសិនបើ ភាគីណាមួយបានដាក់ពាក្យលែងលះទៅតុលាការ តាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS) ឬប្រសិនបើឃុំ ឬសង្កាត់បញ្ជូនរឿងទៅតុលាការ នោះតុលាការត្រូវ ចាត់ការបណ្តឹងលែងលះ។

– ក្រោយពីបានទទួលសំណុំរឿង បើយល់ឃើញថាជាការចាំបាច់ តុលាការដែលទទួល ពាក្យបណ្តឹងលែងលះគ្នាអាចចេញដីកាសំរេចបង្គាប់ធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថៃរក្សា ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ន្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូនតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន។(រ.ក ៩៨៣មាត្រា)

- តុលាការនឹងព្យាយាមការផ្សះផ្សាមួយលើកជាពីរលើក )មាត្រា៩៨៥ ក.រ.) ទោះបីជាភាគីម្ខាងទៀតទាមទារយ៉ាងខ្លាំងចំពោះការលែងលះនេះក៏ដោយ។ បើការផ្សះផ្សាពុំអាចសំរេចបានទេ តុលាការ ត្រូវយកបណ្តឹងលែងលះគ្នាមកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម តុលាការត្រូវពិនិត្យលើ រឿងក្តីនិងកំណត់អំពីអត្ថិភាព ឬនត្ថិភាព នៃមូលហេតុនៃការលែងលះ ដែលត្រូវ (វ.នៃក១កថាខណ្ឌ ៩៧៨មាត្រា) នមូលហេតុណាមួយ នៃការលែងបានទាមទារដោយដើមចោទ។ ប្រសិនបើតុលាការ បានរកឃើញថាមាលះ ដែលទាមទារដោយដើមចោទ នោះតុលាការត្រូវចេញសាលក្រមសម្រេចលែងលះ លុះត្រាតែតុលាការមិនច្រានចោលការទាមទារ ដោយផ្អែកតាមមាត្រា៩៧៨ កថាខណ្ឌទី២ ឬទី៣។

*គ. ការទាមទារពាក់ព័ន្ធនឹងការលែងលះ*

(១) <u>សោហ៊ុយអាពាហ៍ពិពាហ៍(មាត្រា៩៧១នៃក.រ)</u>

នៅក្នុងករណីលែងលះខ្លះ ភាគីប្តី ឬ ប្រពន្ធ អាចទាមទារសោហ៊ុយអាពាហ៍ពិពាហ៍ ព្រោះបន្ទុកនៃសោហ៊ុយ ដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតំរូវអោយប្តី-ប្រពន្ធចែករំលែកសោហ៊ុយ ទៅតាមទ្រព្យសម្បត្តិប្រាក់ចំណូលឋានៈក្នុងសង្គម និងមុខរបរជាដើមរបស់ប្តី-ប្រពន្ធ។ នៅក្នុងអំឡុងពេលជាស្វាមី និងភរិយាមានភាគីណាម្នាក់បានខកខានក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន។

**នៅក្នុងករណីនេះ ភាគីដែលបានដាក់ពាក្យសុំសោហ៊ុយអាពាហ៍ពិពាហ៍ ត្រូវអនុលោមតាមផ្នែកទី៤ ចំណុចទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយពាក្យសុំនេះត្រូវធ្វើឡើងដោយឡែកពីពាក្យបណ្តឹងសុំលែងលះ។**

(២) <u>សោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន (មាត្រា១០៤០ ក.រ.)</u>

- តាមការព្រមព្រៀងរបស់គូភាគីកថា ១០៤០មាត្រា)-២ ក (វ.
- ប្រសិនបើគូភាគីមិនអាចពិភាក្សាគ្នាបាន នោះគឺផ្អែកតាមការសម្រេចរបស់តុលាការ ដោយផ្អែកលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ច របស់ឪពុក-ម្តាយ (៦និងទី ៤កថាខណ្ឌទី១០៤០មាត្រា)។
- ម្យ៉ាងទៀត ការចូលជួប និងការប្រាស្រ័យទាក់ទងគ្នានេះ មិនគួរត្រូវបានផ្សារភ្ជាប់ជាមួយនឹង ការបែងចែកបន្ទុកនៃសោហ៊ុយ ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគ្មានគិតគូរហ្មត់ចត់ឡើយ។ មានន័យថាទោះបីជាឪពុក ឬ ម្តាយ ដែលមិនរស់នៅជាមួយកូន ពុំបានទទួលបន្ទុកនូវចំណែក សោហ៊ុយ ដើម្បីគ្រប់គ្រងថែរក្សាកូនក៏ដោយ ក៏រឿងនោះមិនត្រូវយកមកធ្វើជាមូលហេតុក្នុងការ ហាមឃាត់ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូននោះ មិនអោយចូលជួប ឬប្រាស្រ័យទាក់ទងជាមួយកូន ឬក្នុងការតម្រូវអោយឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូននោះ បង់ប្រាក់ចំណែកសោហ៊ុយ ដើម្បីថែរក្សាកូន ដើម្បីជាថ្នូរនឹងការយល់ព្រមអោយចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូននោះដែរ។ ការចូលជួប និងការប្រាស្រ័យទាក់ទងនេះ មិនត្រូវយកមកប្រើជាមធ្យោបាយក្នុងការចរចាឡើយ។

នៅក្នុងករណីការទាមទារសោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន ភាគីអាចដាក់ពាក្យសុំអនុលោមតាមផ្នែកទី៤ ចំណុចទី១៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប៉ុន្តែករណីនេះអាចដាក់បញ្ចូលជាមួយនឹងពាក្យបណ្តឹងលែងលះ ដោយអនុលោមតាមមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

(៣) <u>ការបែងចែកទ្រព្យសម្បត្តិ(មាត្រា៩៨០នៃក.រ)</u>

ភាគីណាមួយអាចដាក់ពាក្យសុំបែងចែកទ្រព្យសម្បត្តិ។ ក្នុងករណីទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ ភាគីអាចដាក់ពាក្យសុំ ដោយអនុលោមតាមផ្នែកទី ៤ ចំណុចទី ៦ នៃឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប៉ុន្តែករណីនេះអាចបញ្ចូលជាមួយនឹងពាក្យបណ្តឹងលែងលះ ដោយផ្អែកតាមមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

(៤) <u>សំណងជំងឺចិត្ត(មាត្រា៧៤៣ នៃក.រ)</u>

ភាគីដែលរងគ្រោះអាចទាមទារសំណងជំងឺចិត្តពីភាគីដែលធ្វើអោយបែកបាក់ចំណងអាពាហ៍ពិពាហ៍តាមរយៈពាក្យបណ្តឹងសុំលែងលះ (មាត្រា១១នៃ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

(៥) <u>ការសម្រេចអំពីអ្នកមានអំណាចមេបា(មាត្រា១០៣៧នៃក.រ)</u>

- ជាធម្មតាតុលាការនឹងមិនពិចារណារចំពោះកូនដែលនៅក្នុងផ្ទៃម្តាយ ដោយធ្វើការសម្រេចអំពីអ្នកណាមានអំណាចមេបានោះទេ។ ប៉ុន្តែអំណាចមេបានេះ នឹងត្រូវសំរេច នៅពេលកូនចាប់ផ្តើម មានកំណើតតាមការពិភាក្សារបស់គូភាគី។
- ប៉ុន្តែក្នុងករណីមិនអាចពិភាក្សាគ្នាបាននោះទេ តុលាការជាអ្នកសំរេចដោយពិចារណាទៅលើ ផលប្រយោជន៍របស់កូននោះ (មាត្រា ១០៣៧ កថាខណ្ឌទី ២ ទី ៣ និងមាត្រា ១០៣៩ នៃ ក.រ)។

នៅក្នុងករណីការសំរេចអំពីអ្នកមានអំណាចមេបា ត្រូវធ្វើឡើងអនុលោមមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ពោលគឺនៅក្នុងបណ្តឹង ទាមទារលែងលះ តុលាការត្រូវកំណត់អំពីអ្នកមានអំណាចមេបា ទោះបីជាគូភាគីមិនបានដាក់ពាក្យសុំឲ្យកំណត់អ្នកមានអំណាចមេបាក៏ដោយ។

| ពាក្យបណ្តឹង | មុនពេលចេញសាលក្រម | ក្រោយពេលចេញសាលក្រម |
|---|---|---|
| សោហ៊ុយអាពាហ៍ពិពាហ៍ #៩៧១ ក.រ. | -ធ្វើដោយឡែកតាមពាក្យសុំ ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជា | -ពាក្យសុំ ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែន |

| | | |
|---|---|---|
| | បណ្តឹង (NSCC) | ជាបណ្តឹង (NSCC) |
| សោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន<br>#១០៥០ ក.រ. | -ដាក់បញ្ចូលជាមួយពាក្យបណ្តឹងលែងលះដោយផ្អែកតាមមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS)<br>-ក៏អាចធ្វើដោយឡែកតាមពាក្យសុំផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី១៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (NSCC) | -ពាក្យសុំ<br>ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី១៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (NSCC) |
| ការបែងចែកទ្រព្យសម្បត្តិ<br>#៩៥០ ក.រ. | -ដាក់បញ្ចូលជាមួយពាក្យបណ្តឹងលែងលះដោយផ្អែកតាមមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS)<br>-ក៏អាចធ្វើដោយឡែកតាមពាក្យសុំផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (NSCC) | -ពាក្យសុំ<br>ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (NSCC) |
| សំណងជំងឺចិត្ត<br>#៧៥៣ ក.រ. | -ដាក់បញ្ចូលជាមួយពាក្យបណ្តឹងលែងលះដោយផ្អែកតាមមាត្រា ១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS) | -តាមបណ្តឹងធម្មតា ក្រមនីតិវិធីរដ្ឋប្បវេណី (CCP) អំពើអនីត្យានុកូល |
| ការសម្រេចអំពីអ្នកមានអំណាចមេបា<br>#១០៣៧ ក.រ. | -លក្ខណៈស្វ័យប្រវត្តិបញ្ចូលក្នុងពាក្យបណ្តឹងលែងលះផ្អែកតាមមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS) | -អត់មាន។ |

## ៣-២ ការលែងលះដោយការព្រមព្រៀង( មាត្រា៩៧៩ នៃក.រ)

*ក.* *ដាក់ពាក្យសុំទៅតុលាការយោងតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (សូមមើលមាត្រា១ ឧបសម្ព័ន្ធ ៤ ចំណុច ៥)*

*ខ.* *ប្រសិនបើពួកគេព្រមព្រៀងលែងលះ ប៉ុន្តែមិនព្រមព្រៀងចំពោះបញ្ហាខាងក្រោម នោះពួកគេអាចដាក់ករណីមួយៗដោយឯករាជ្យទៅតុលាការបាន។*

(១) សោហ៊ុយអាពាហ៍ពិពាហ៍ (មាត្រា៩៧១នៃក.រ) ផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឧបសម្ព័ន្ធ ៤ ចំណុច ២។

(២) សោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន (មាត្រា១០៤០នៃក.រ) ផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឧបសម្ព័ន្ធ ៤ ចំណុច ១៣។

(៣) ការបែងចែកទ្រព្យសម្បត្តិ (មាត្រា៩៨០នៃក.រ) ផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឧបសម្ព័ន្ធ ៤ ចំណុច ៦។

(៤) សំណងជម្ងឺចិត្ត (មាត្រា៧៤៣នៃក.រ) ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី។

(៥) ពាក់ព័ន្ធនឹងការសម្រេចអំពីអ្នកមានអំណាចមេបា (មាត្រា ១០៣៧) ប្តីប្រពន្ធត្រូវព្រមព្រៀងថាអ្នកណាគឺជាអ្នកមានអំណាចមេបា។ ប្រសិនបើពួកគេព្រមព្រៀងលែងលះ ប៉ុន្តែមិនព្រមព្រៀងថាអ្នកណាជាអ្នកមានអំណាចមេបា នោះពួកគេត្រូវធ្វើដូចម្តេច? ដោយសារច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមិនបានកំណត់ចាប់ពីមាត្រា ១០៣៧ នៃក.រ នោះពួកគេត្រូវដាក់ពាក្យបណ្តឹងលែងលះ ដែលតុលាការនឹងសម្រេចថាអ្នកណាជាអ្នកមានអំណាចមេបា (មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

| ពាក្យសុំ | មុនពេលចេញដីកាសម្រេច | ក្រោយពេលចេញដីកាសម្រេច |
|---|---|---|
| សោហ៊ុយអាពាហ៍ពិពាហ៍ #៩៧១ ក.រ. | -ដាក់បញ្ចូលជាមួយពាក្យសុំ ផ្អែកតាមឧបសម្ព័ន្ធផ្អែកទី៤ ចំណុចទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជា | -ពាក្យសុំ ផ្អែកតាមឧបសម្ព័ន្ធផ្អែកទី៤ ចំណុចទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែន |

| | បណ្ដឹង (NSCC) | ជាបណ្ដឹង (NSCC) |
|---|---|---|
| សោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន<br>#១០៤០ ក.រ. | -ដាក់បញ្ចូលជាមួយពាក្យសុំ<br>ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី១៣ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (NSCC) | -ពាក្យសុំ<br>ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី១៣ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (NSCC) |
| ការបែងចែកទ្រព្យសម្បត្តិ<br>#៩៨០ ក.រ. | -ដាក់បញ្ចូលជាមួយពាក្យសុំ<br>ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី៦ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (NSCC) | -ពាក្យសុំ<br>ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី៤ ចំណុចទី៦ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (NSCC) |
| សំណងជំងឺចិត្ត<br>#៧៤៣ ក.រ. | -តាមបណ្ដឹងធម្មតា ក្រមនីតិវិធីរដ្ឋប្បវេណី (CCP) អំពើអនីត្យានុកូល | -តាមបណ្ដឹងធម្មតា ក្រមនីតិវិធីរដ្ឋប្បវេណី (CCP) អំពើអនីត្យានុកូល |
| ការសម្រេចអំពីអ្នកមានអំណាចមេបា<br>#១០៣៧ ក.រ. | -ត្រូវបញ្ចូលក្នុងពាក្យសុំបើមានការព្រមព្រៀង ប៉ុន្តែបើមិនព្រមព្រៀងសម្រេចអំពីអ្នកមានអំណាចមេបា នោះមានន័យថាមិនព្រមព្រៀងចំពោះការលែងលះដូចនេះត្រូវធ្វើពាក្យបណ្ដឹងលែងលះ<br>ផ្អែកតាមមាត្រា២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល (LPS) | -អត់មាន។ |

ឯកសារភ្ជាប់៖

-បញ្ហានានាជុំវិញការលែងលះ (ករណីប្រទេសជប៉ុន) ដោយក្រុមការងារចម្រុះ៤ស្ថាប័ន។

-វិធីបែងចែកទ្រព្យសម្បត្តិក្រោយពេលលែងលះ (ឯកសារសិក្ខាសាលាតូចលើកទី៣)។

# សិក្ខាសាលាគណៈមេធាវី(ធំ)លើកទី៨

ប្រធានបទ៖ ទំនាក់ទំនងរវាងឪពុកម្តាយនិងកូន រួមទាំងសុំកូន

ថ្ងៃទី ១៨ ធ្នូ ២០១៤

# បុត្តភាព

## សេចក្តីផ្តើម៖

នៅក្នុងសង្គមយើងសព្វថ្ងៃមានមនុស្សប្រុសស្រីពេញវ័យ ជាច្រើនបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដើម្បីបង្កើតបានជាគ្រួសារមួយ។ នៅក្នុងគ្រួសារមួយដែលមានតែប្តីនិងប្រពន្ធតែពីរនាក់នោះ វាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ឬក៏អាចហៅថាវាមិនទាន់ជាគ្រួសារមួយពេញលេញ និងមានសុភមង្គលទេ។ ប្រសិនបើចង់បានគ្រួសារមួយពេញលេញ ទាល់តែមានអ្វីមួយមកបំពេញបន្ថែមដែលគេហៅថាកូន។ កូន គឺជាធាតុផ្សំមួយយ៉ាងសំខាន់នៅក្នុងគ្រួសារមួយដែលផ្សាភ្ជាប់ទំនាក់ទំនងរវាងប្តីនិងប្រពន្ធឲ្យកាន់តែប្រសើរឡើង ហើយហេតុដូច្នេះហើយទើបនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាយើង បានចែងបញ្ញត្តិមួយចំនួនទាក់ទងនឹងទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ ក្នុងទំនាក់ទំនងរវាងឪពុកម្តាយ និងកូននេះ គេចែកជាពីរផ្នែក គឺទំនាក់ទំនងរវាងឪពុកម្តាយ និងកូនបង្កើត និងទំនាក់ទំនងរវាងឪពុកម្តាយ និងកូនចិញ្ចឹម (កូនសុំ)។

ខ្ញុំបាទ សុំលើកយកតែករណីទំនាក់ទំនងរវាងឪពុកម្តាយ និងកូនបង្កើត យកមកធ្វើបទបង្ហាញតែប៉ុណ្ណោះ។ សំនួរសួរថា៖ តើធ្វើយ៉ាងម៉េចទើបគេដឹងថា ជាឪពុកម្តាយ និងកូន នឹងគ្នា?

## ១. សំបុត្រកំណើត៖

សំបុត្រកំណើត គឺជាលិខិតមួយដែលកត់ត្រាអំពីប្រវត្តិរបស់កូនដែលទើបនឹងកើត ហើយគេក៏អាចដឹងផងដែរថាអ្នកណាជាឪពុកម្តាយរបស់កូននេះ។ តាមអនុក្រឹត្យលេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន និងក្រមរដ្ឋប្បវេណី បានកំណត់ច្បាស់អំពីកាតព្វកិច្ចដែលត្រូវទៅចុះសំបុត្រកំណើតរបស់កូននៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានរបស់ឪពុក ឬម្តាយបន្ទាប់ពីកូនកើតមកមិនឲ្យលើសពី ៣០ថ្ងៃឡើយ គឺមានឪពុកម្តាយ ឬញាតិជានីតិជន។ នៅក្នុងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន បានកំណត់ថា បើហួសរយៈពេល៣០ថ្ងៃ ឪពុកម្តាយ ឬសាច់ញាតិ មិនបានមកសុំចុះសំបុត្រកំណើតទេ បើសិនជាចង់ចុះ ត្រូវសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី (មាត្រា២៥/១) ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីក្នុងមាត្រា៩៨៥/២ កំណត់ថា ពិន័យស៊ីវិល មិនលើសពី ១០,០០០ រៀល។ ម្យ៉ាងទៀតចំពោះការរាប់អាយុវិញ គឺគេរាប់ចាប់ពីថ្ងៃដែលកូននោះកើតមក។

ឧទា. កូនកើតនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤។ កូននឹងមានអាយុ១ឆ្នាំពេញ នៅយប់ម៉ោង ០ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៥។

## ២. ការសម្រេចអំពីបុត្តភាពៈ

តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ បានបែងចែករវាងកូនមានខាន់ស្លា និងកូនឥតខាន់ស្លា ដោយផ្អែកលើចំណងអាពាហ៍ពិពាហ៍របស់ឪពុកម្តាយនៃកូននោះជាមូលដ្ឋាន។ ដោយឡែកក្រមនេះ មិនបានបែងចែករវាងកូនមានខាន់ស្លា និងកូនឥតខាន់ស្លានោះទេ តែបែរជាបានចែងនូវបញ្ញត្តិមួយចំនួនទាក់ទងនឹងមាតុភាព និងបិតុភាព ទៅវិញ។

ទាក់ទងនឹងមាតុភាព ស្ត្រីដែលបានសម្រាលកូនគឺជាម្តាយ។ ទាក់ទងនឹងបិតុភាពវិញ បុរសដែលបានផ្តល់មេជីវិតដើម្បីការបង្កកំណើតរបស់កូន គឺជាឪពុក។ វាជាការងាយស្រួលសម្រាប់ម្តាយក្នុងការបញ្ជាក់ថាគាត់បានសម្រាលកូន ព្រោះគាត់អាចទទួលបានសំបុត្របញ្ជាក់កំណើតដែលចេញដោយវេជ្ជបណ្ឌិត ឬ គិលានុប្បដ្ឋាយិកាផ្នែកសម្ភព។ នៅពេលដែលម្តាយបានដាក់ជូននូវសំបុត្របញ្ជាក់កំណើតជាមួយគ្នានឹងរបាយការណ៍អំពីកំណើត នោះឈ្មោះរបស់គាត់នឹងត្រូវបានចុះនៅលើសំបុត្រកំណើត (មាត្រា ៩៨៧ នៃក.រ)។ ផ្ទុយទៅវិញ វាមិនមែនជាការងាយស្រួលទេសម្រាប់ឪពុកក្នុងការបញ្ជាក់ថាគាត់ជាអ្នកដែលបានផ្តល់មេជីវិតសម្រាប់ការបង្កកំណើត។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានសន្មតប្តីរបស់ម្តាយ ថាជាឪពុករបស់កូន (មាត្រា ៩៨៨ នៃក.រ) និងឈ្មោះរបស់គាត់ត្រូវបានចុះក្នុងសំបុត្រកំណើត។ ក្នុងករណីជាច្រើន ម្តាយនិងឪពុកត្រូវបានកំណត់ដោយមាត្រា ៩៨៧ និង ៩៨៨ នៃក.រ។

ប៉ុន្តែ ក្នុងករណីមួយចំនួន មាត្រា ៩៨៧ និង៩៨៨ នៃក.រ មិនអាចកំណត់ពីម្តាយនិងឪពុកបានទេ។ ឧទាហរណ៍ ប្រសិនបើម្តាយបានបាត់ខ្លួនអស់រយៈពេលយូរបន្ទាប់ពីពេលសម្រាល នោះវាមិនងាយស្រួលសម្រាប់គាត់ក្នុងការបញ្ជាក់ពីអង្គហេតុនៃការសម្រាលទេ ឬប្រសិនបើឪពុកមិនបានរៀបអាពាហ៍ពិពាហ៍ជាមួយម្តាយ នោះគាត់នឹងស្ថិតនៅក្រៅវិសាលភាពនៃការសន្មត។ លើសពីនេះទៀត ប្រសិនបើនៅលើសំបុត្រកំណើតបានចុះឈ្មោះអ្នកផ្សេងដែលមិនមែនជាម្តាយ ឬ ជាឪពុក នោះវាគួរតែមានមធ្យោបាយដើម្បីលុបចោលអ្នកដែលមិនមែនជាម្តាយ ឬឪពុកនោះ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ក្រមរដ្ឋប្បវេណី បានផ្តល់មធ្យោបាយ ៤ (មាត្រា ៩៨៩ ដល់ មាត្រា ១០០៦ នៃក.រ)។

១. បណ្តឹងបដិសេធបិតុភាព (មាត្រា ៩៨៩ ដល់មាត្រា ៩៩២ នៃក.រ)៖ ប្រសិនបើអ្នកដែលមិនមែនជាឪពុកម្តាយត្រូវបានសន្មតថាជាឪពុក តាមមាត្រា ៩៨៨ នៃក.រ នោះការសន្មតដែលខុសនោះ អាចត្រូវបានបដិសេធតាមរយៈបណ្តឹងនេះ។

២. ការទទួលស្គាល់ (មាត្រា ៩៩៣ ដល់មាត្រា ១០០១ នៃក.រ)៖ ប្រសិនបើឪពុកស្ថិតនៅក្រៅវិសាលភាពនៃការសន្មតនៃមាត្រា ៩៨៨ នៃក.រ នោះឪពុកអាចត្រូវបានចុះក្នុងសំបុត្រកំណើតដោយការទទួលស្គាល់។

៣. បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព (មាត្រា ១០០២ ដល់មាត្រា ១០០៣ នៃក.រ)៖ ប្រសិនបើឈ្មោះរបស់បុរសដែលមិនមែនជាឪពុក ដែលមិនស្ថិតក្រោមការសន្មតនៃមាត្រា ៩៨៨ នៃក.រ ត្រូវបានចុះថាជាឪពុកក្នុងសំបុត្រកំណើត ឬប្រសិនឈ្មោះរបស់ស្ត្រីដែលមិនមែនជាម្ដាយត្រូវបានចុះក្នុងសំបុត្រកំណើតថាជាម្ដាយ ឧទាហរណ៍ ដោយការធ្វើសំបុត្របញ្ជាក់កំណើតក្លែងក្លាយ នោះទំនាក់ទំនងរវាងអ្នកដែលមិនមែនជាឪពុកម្ដាយ និងកូន អាចត្រូវបានបដិសេធតាមរយៈបណ្ដឹងនេះ។

៤. បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព (មាត្រា ១០០៤ ដល់មាត្រា ១០០៦ នៃក.រ)៖ ប្រសិនបើឈ្មោះរបស់ម្ដាយមិនត្រូវបានចុះក្នុងសំបុត្រកំណើត នោះឈ្មោះរបស់ម្ដាយអាចត្រូវបានចុះក្នុងសំបុត្រកំណើតតាមរយៈបណ្ដឹងនេះ។

### ២.១ អំពីមាតុភាព៖

តាមមាត្រា៩៨៧ នៃក្រម បានចែងថា ស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូន។ អង្គហេតុសម្រាលកូន គឺបញ្ជាក់យ៉ាងច្បាស់ដែលមិនអាចប្រកែកបាន គឺថាស្ត្រីដែលបានសម្រាលកូន កូននោះជាកូន បង្កើតរបស់ស្ត្រីនោះ។ ហើយម្យ៉ាងទៀត ចំពោះអង្គហេតុសម្រាលកូននេះ មិនត្រឹមតែអាចកំណត់អំពីចំណងមាតុភាពដែលកើតដំណាលពេល និងចំណងបុត្តភាពនោះទេ គឺអាចឲ្យគេនឹកឃើញពីចំណងបិតុភាពផងដែរ ចំពោះបុរសដែលមានទំនាក់ទំនងនឹងម្ដាយនោះ។

ដោយសារបច្ចុប្បន្ននេះមានការរីកចំរើននៃបច្ចេកវិទ្យាវេជ្ជសាស្ត្រក្នុងការផ្ដល់កំណើតទារកការផ្ដល់កំណើតកូនខាងក្រៅរាងកាយ ត្រូវបានធ្វើឡើងនៅដោយប្រើមេជីវិត (អូវ៉ុល និងអូវ៉េ) របស់បុរស និងស្ត្រី យកទៅដាក់ ក្នុងស្បូនរបស់ស្ត្រីផ្សេងម្នាក់ទៀតជាអ្នកបង្កើតជំនួស ដូច្នេះគឺវាផ្ទុយនឹងមាត្រានេះ។ សួរថា តើស្ត្រីដែលបានបង្កើតកូននោះ ជាម្ដាយបង្កើតរបស់កូននោះឬទេ? ហើយចុះស្ត្រីជាអ្នកផ្ដល់អូវ៉ុល នោះជាម្ដាយបង្កើតឬទេ?

> នៅពេលយើងអនុវត្តតាមមាត្រា ៩៨៧ នៃក.រ នោះស្ត្រីដែលបានសម្រាលបុត្រគឺជាម្ដាយរបស់កូននោះ ហើយស្ត្រីដែលបានផ្ដល់មេជីវិតស្រីមិនមែនជាម្ដាយរបស់កូននោះទេ។ លទ្ធភាពគឺការអនុវត្តនៅថ្ងៃអនាគតនៃច្បាប់ពិសេសចំពោះបញ្ហានេះ ប៉ុន្តែកន្លងមក គោលការណ៍នៃក្រមរដ្ឋប្បវេណីនេះគ្រប់គ្រងចំពោះបញ្ហានេះ។

## ២.២ អំពីបិតុភាព៖

### ក. ការសន្មតបិតុភាព (មាត្រា៩៨៨ ក.រ)

ប្តីរបស់ប្រពន្ធដែលបានសម្រាលកូន ត្រូវបានសន្មតថាជាឪពុករបស់កូននោះ ក្នុងករណី៖

- ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ (មាត្រា៩៨៨ កថាខណ្ឌទី ១ នៃក.រ)។ ដូច្នេះប្រសិនបើកាលបរិច្ឆេទនៃការបង្កកំណើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ជាក់ ឧទាហរណ៍ តាមរយៈសំបុត្រពេទ្យ ដើម្បីបញ្ជាក់ពីកាលបរិច្ឆេទនៃការបង្កកំណើត នោះប្តីរបស់ម្តាយត្រូវបានសន្មតថាជាឪពុករបស់កូន។ វាមិនចាំបាច់ក្នុងការបញ្ជាក់ថាប្តីនោះគឺជាអ្នកផ្តល់មេជីវិតប្រុសសម្រាប់ការបង្កកំណើតនោះទេ។
- កូនដែលបានកើតនៅក្រោយអំឡុងពេល១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬក្នុងអំឡុងពេល៣០០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍-ពិពាហ៍ ត្រូវសន្មតថាមានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ (មាត្រា ៩៨៨ កថាខណ្ឌទី ២ នៃក.រ)។ ដូច្នេះ ប្រសិនបើកូនត្រូវបានបញ្ជាក់ថាបានកើតក្នុងអំឡុងពេលនោះ ឧទាហរណ៍ តាមរយៈសំបុត្របញ្ជាក់កំណើតដែលចេញដោយគិលានុប្បដ្ឋាយិកាផ្ទែកសម្ភព នោះកូននោះត្រូវបានសន្មតថាជាគភ៌ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ (មាត្រា ៩៨៨ កថាខណ្ឌទី ២ នៃក.រ) ហើយដូច្នេះ ប្តីរបស់ម្តាយត្រូវបានសន្មតថាជាឪពុករបស់កូន (មាត្រា ៩៨៨ កថាខណ្ឌទី ១ នៃក.រ)។ ក្នុងករណីនេះ វាមិនមានភាពចាំបាច់ក្នុងការបញ្ជាក់ពីកាលបរិច្ឆេទនៃការបង្កកំណើតទេ និងមិនចាំបាច់បញ្ជាក់ពីការផ្តល់មេជីវិតប្រុសរបស់ប្តីនោះទេ។
- ក្នុងករណីដែលស្រ្តីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ផ្ទុយនឹងបញ្ញត្តិនៃមាត្រា៩៥០ នៃក.រ (អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត)បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះតាមចំណុចខាងលើ ត្រូវសន្មតថាកូននោះ ជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។

**ឧទា**. ក និង ខ បានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ ឆ្នាំ២០១២។ ក ជាប្តីបានទៅធ្វើការនៅខេត្តឆ្ងាយ ក្នុងឆ្នាំ ២០១៣ ដោយមិនដែលត្រឡប់មកផ្ទះវិញទេ ស្រាប់តែនៅឆ្នាំ ២០១៤ ខ ជាប្រពន្ធបានបង្កើតកូនម្នាក់ គ។ ក្នុងករណីនេះ ទោះយ៉ាងណាក៏ដោយ ក៏គេសន្មតថា ក ជាឪពុករបស់កូននោះដែរ ព្រោះថានៅក្នុងចំណងអាពាហ៍ពិពាហ៍។

**ឧទា**. ក និង ខ បានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ ឆ្នាំ២០១២។ នៅថ្ងៃទី០១-០៥-២០១៣ ក ជាប្តីបានទទួលមរណភាព។ ក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ខ បានសម្រាលកូនម្នាក់។ ដោយសារ ខ សម្រាលកូនក្នុងរយៈពេល ៣០០ថ្ងៃ ក្រោយ ក ទទួលមរណភាព នោះ កូនដែល ខ បានបង្កើត ត្រូវសន្មតថា ជាកូនរបស់ ក។



រៀបអាពាហ៍ពិពាហ៍
ការរំលាយអាពាហ៍ពិពាហ៍
១៨០ថ្ងៃ
៣០០ថ្ងៃ
កូនដែលកើតក្នុងអំឡុងពេលនេះ ត្រូវបានសន្មតថាមានគភ៌ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ (មាត្រា ៩៨៨ កថាខណ្ឌ២ នៃក.រ) ហើយដូច្នេះ ត្រូវបានសន្មតថាជាកូនរបស់ប្តី (មាត្រា ៩៨៨ កថាខណ្ឌ១ នៃក.រ)។




១ ២ ៣ .................. ១៧៩ ១៨០ ១៨១
ការចុះសំបុត្រអាពាហ៍ពិពាហ៍
ត្រូវបានសន្មតជាកូនរបស់ប្តី




១ ២ ៣ .................. ២៩៩ ៣០០ ៣០១
ការរំលាយអាពាហ៍ពិពាហ៍
ត្រូវបានសន្មតជាកូនរបស់ប្តី

**ខ. ការបដិសេធបិតុភាព (មាត្រា៩៨៩ ក.រ)**

ទោះជាមានការសន្មតបិតុភាព ក៏ជនដែលគេសន្មតថាជាឪពុក ឬកូននោះអាចសុំបដិសេធបិតុភាព បានដែរដោយអនុវត្តតាមវិធីដូចខាងក្រោម។ ពាក្យបណ្តឹងត្រូវអនុវត្តតាម នីតិវិធីនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (LPS 3) ៖

**ខ.១ បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវសន្មតថាជាឪពុក** (មាត្រា ៩៩០ ក.រ)

ក្នុងករណីដែលបិតុភាពត្រូវបានសន្មត ដូចចំណុច ក ខាងលើ ជនដែលត្រូវបានសន្មតថាជាឪពុករបស់កូន អាចដាក់**ពាក្យបណ្តឹងបដិសេធបិតុភាព**បាន។ ការដាក់បណ្តឹងបដិសេធបិតុភាពនេះ ត្រូវធ្វើឡើងដោយជនដែលសន្មតថាជាឪពុក ក្នុងអំឡុងពេល៦ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងពីកំណើតរបស់កូន។ បើជនដែលបានសន្មតថាជាឪពុក ជាជនដែលស្ថិតនៅក្រោមអាណាព្យា-បាលទូទៅ អ្នកអាណាព្យាបាលទូទៅអាចដាក់ពាក្យបណ្តឹងជំនួសបាន ក្នុងអំឡុងពេល៦ខែ គិត ចាប់ពីពេលដែលដឹងពីកំណើតរបស់កូន ឬជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅខ្លួនឯងអាចដាក់បណ្តឹងបដិសេធបិតុភាពបានទោះជាហួសអំឡុង ពេលកំណត់ខាងលើក៏ដោយ ប៉ុន្តែត្រូវធ្វើក្នុងអំឡុងពេល៦ខែ គិតចាប់ពីថ្ងៃដែល**លុបចោលការប្រកាសចាប់ ផ្តើមអាណាព្យាបាលទូទៅនោះ** (មាត្រា២៧ ក.រ)។

មរណភាពរបស់ប្តី នៅមុនពេលដាក់ពាក្យបណ្តឹង៖ ប្រសិនបើប្តីបានទទួលមរណភាពមុនពេលដាក់ពាក្យបណ្តឹងបដិសេធបិតុភាព នោះជនណាមួយដែលសិទ្ធិទទួលមតិករបស់គាត់អាចត្រូវបានបំពានដោយសារកូន ក៏ដូចជាញាតិលោហិតរបស់ប្តីក្នុង៣ថ្នាក់ អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន។ ពាក្យបណ្តឹងនេះត្រូវដាក់ក្នុងអំឡុងពេល ១ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ប្តី (LPS 24 (1))។

មរណភាពរបស់ម្តាយ នៅមុនពេលដាក់ពាក្យបណ្តឹង៖ បញ្ហា៖ ប្តីចង់ដាក់ពាក្យបណ្តឹងបដិសេធបិតុភាព។ ប៉ុន្តែម្តាយរបស់កូនបានទទួលមរណភាពទៅហើយ ហើយពុំមានអាណា-ព្យាបាលសម្រាប់អនីតិជនទៀត។ កូននៅមានអាយុ ០ ឆ្នាំនៅឡើយ។ ក្នុងករណីនេះ ប្តីត្រូវដាក់ពាក្យសុំឲ្យជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូន (មាត្រា ៣៦ នៃក្រមនីតិវិធី)ព្រោះកូនគឺជាជនខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង (មាត្រា ១៤ នៃក.រ, មាត្រា ៣២ កថាខណ្ឌទី ២ នៃក្រមនីតិវិធី)។

**ឧទា.** ក និង ខ បានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ ឆ្នាំ២០១២។ ក ជាប្តីមិនបាននៅផ្ទះមួយឆ្នាំក្នុងឆ្នាំ ២០១៣ ស្រាប់តែនៅក្នុងឆ្នាំ២០១៤ ខ បានសម្រាលកូនម្នាក់។ តាមច្បាប់ ក ត្រូវបានគេសន្មតថា ជាឪពុករបស់កូននោះ ព្រោះថា ខ សម្រាលកូននៅក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែ ក អាចប្តឹងបដិសេធបិតុភាពបានក្នុងរយៈពេល៦ខែ ចាប់ពីថ្ងៃដែលដឹងពីកំណើតរបស់កូននោះ។ ផ្ទុយទៅវិញបើ ក ជាជនស្ថិតក្រោមអាណាព្យាបាលទូទៅ ហើយក្នុងខែមេសា ឆ្នាំ២០១៥ ទើបមានសាលក្រមលុបចោលការប្រកាសចាប់ផ្តើម

អាណាព្យាបាលទូទៅ ទោះបីជាហួសកាលកំណត់៦ខែក៏ដោយ ក៏ ក នៅតែប្តឹងបានដែរ ដោយគិតចាប់ពីខែ មេសា ឆ្នាំ២០១៥ ទៅ។

* បញ្ហា៖ ប្តីរបស់ម្តាយបានកំពុងរស់នៅជាមួយកូនអស់រយៈពេល ១ឆ្នាំ។ បន្ទាប់មក ម្តាយបានប្រាប់ទៅប្តីថា "ប្រាប់ការពិត កូននេះមិនមែនជាកូនរបស់អ្នកទេ។" ប្តីបានខឹងយ៉ាងខ្លាំង ហើយចង់បដិសេធបិតុភាព។ ប៉ុន្តែ រយៈពេល ៦ខែ បានកន្លងផុតទៅហើយតាំងពីប្តីបានដឹងពីកំណើតរបស់កូន ដូច្នេះប្តីនោះមិនអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបានទេ។

មានមតិមួយចំនួនអាចលើកឡើងថាការសន្និដ្ឋានបែបនេះគឺមិនសមហេតុផល ហើយរយៈពេល ៦ខែ គួរតែចាប់ផ្តើមពីថ្ងៃដែលប្តីបានដឹងពីនត្ថិភាពនៃទំនាក់ទំនងឪពុក និងកូន។

### ខ.២ បណ្តឹងបដិសេធបិតុភាព ពីកូន (មាត្រា ៩៩១)

ក្រៅពីឪពុកអាចប្តឹងបដិសេធបិតុភាព កូនក៏អាចប្តឹងបដិសេធបិតុភាពបានដែរ តាមមាត្រា៩៩១ កថាខណ្ឌ១។ ប្រសិនបើកូននៅជាអនីតិជន នោះម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់កូននោះ ជាអ្នកប្តឹង ហើយតុលាការជាអ្នកជ្រើសតាំងអ្នកតំណាងពិសេស ក្នុងករណីកូននោះ គ្មានម្តាយអនុវត្តអំណាចមេបា ឬអ្នកអាណាព្យាបាល។ ម្យ៉ាងទៀត កូនមានសិទ្ធិប្តឹងបដិសេធបិតុភាព ក្នុងអំឡុងពេល៦ខែ គិតចាប់ពីថ្ងៃដែល កូននោះ ពេញនីតិភាព ប៉ុន្តែប្រសិនបើកូននៅជាជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវបានគណនាដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ។

មរណភាពរបស់កូននៅមុនពេលដាក់ពាក្យបណ្តឹង៖ ប្រសិនបើកូនបានទទួលមរណភាព នៅមុនពេលដាក់ពាក្យបណ្តឹងបដិសេធបិតុភាព នោះបច្ឆាញាតិផ្ទាល់ណាមួយរបស់កូនដែលបានទទួលមរណភាពនោះ អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន។ ពាក្យបណ្តឹងនេះត្រូវដាក់ក្នុងអំឡុងពេល ១ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់កូន (LPS 24 (1))។

**ឧទា.** ក និង ខ រៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ២០១០ ហើយ កជាប្តីបានចាកចេញពីផ្ទះទៅស្រុកឆ្ងាយ អស់

រយៈពេល១ឆ្នាំ ២០១១។ នៅប្រហែលជាចុងឆ្នាំ២០១១ ខ បានសម្រាលកូនម្នាក់។ ដូច្នេះ គេសន្មតថា ក ជាឪពុករបស់កូននោះ។ ប៉ុន្តែតាមមាត្រា៩៩១ កូនអាចប្តឹងបដិសេធបិតុភាពរបស់ ក បាន។

### ខ.៣ អានុភាពប្រតិសកម្មនៃបណ្ដឹងបដិសេធបិតុភាព (មាត្រា ៩៩២ ក.រ)

ប្រសិនបើមានសេចក្ដីសម្រេចបដិសេធបិតុភាព អំពីបណ្ដឹងបដិសេធបិតុភាព នោះមានន័យថា ឪពុកដែលបានសន្មតថាជាឪពុករបស់កូននោះ មិនមែនជាឪពុករបស់កូននោះតាំងពីកំណើតរបស់កូន។

**ឧទា.** A (ប្ដី) និង B (ប្រពន្ធ) បានរៀបអាពាហ៍ពិពាហ៍។ B បានសម្រាលកូន C ដែលមិនមែនជាកូនរបស់ A ទេ ប៉ុន្តែត្រូវបានសន្មតថាជាកូនរបស់ A។ បន្ទាប់ពី A បានទទួលមរណភាព ម្ដាយរបស់ A (D) បានដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពចំពោះ C (LPS 24 (1))។ ការទាមទារត្រូវបានទទួលស្គាល់ដោយតុលាការ។ ដោយសារអានុភាពប្រតិសកម្មនៃសាលក្រមនេះ C ត្រូវបានចាត់ទុកថាមិនដែលជាកូនរបស់ A ឡើយ ហើយដូច្នេះ C មិនអាចទទួលបន្តនូវទ្រព្យសម្បត្តិរបស់ A បានទេ។

**ឧទា.** A (ប្ដី) និង B (ប្រពន្ធ) បានរៀបអាពាហ៍ពិពាហ៍។ B បានសម្រាលកូន C ដែលមិនមែនជាកូនរបស់ A ទេ ប៉ុន្តែត្រូវបានសន្មតថាជាកូនរបស់ A។ A បានកំពុងមើលថែរក្សា C អស់រយៈពេល ៣ ឆ្នាំ និងបានចំណាយប្រាក់អស់ ១០.០០០ ដុល្លារ។ ក្រោយមក B បានដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ហើយការទាមទារនេះត្រូវបានទទួលស្គាល់ដោយតុលាការ។ ដោយសារតែអានុភាពប្រតិសកម្មនៃសាលក្រមនេះ C ត្រូវបានចាត់ទុកថាមិនដែលជាកូនរបស់ A ទេ ហើយដូច្នេះ A មិនដែលមានកាតព្វកិច្ចមើលថែរក្សា C នោះទេ។ ចំនួនទឹកប្រាក់ ១០.០០០ ដុល្លារ ដែល A បានចំណាយសម្រាប់ C ក្លាយជាសេចក្ដីចម្រើនដោយឥតហេតុ ហើយ A អាចដាក់ពាក្យបណ្ដឹងទាមទារប្រាក់ ១០.០០០ ដុល្លារពី B វិញបាន។

* កម្មវត្ថុនៃការពិនិត្យដោយតុលាការ

ប្រសិនបើពាក្យបណ្ដឹងបដិសេធបិតុភាពត្រូវបានដាក់ នោះតុលាការនឹងពិនិត្យភស្តុតាងដើម្បីកំណត់ថា តើបុគ្គលដែលត្រូវបានសន្មតថាជាឪពុកនោះ គឺជាឪពុក ឬ មិនមែន។ តុលាការនឹងពិចារណា ១) ការធ្វើតេស្តឈាម, ២) ការធ្វើតេស្ត DNA, ៣) ឱកាសដែលប្រពន្ធចាប់មានកំណើតកូនរបស់ប្ដី, ៤) ឱកាសដែលប្រពន្ធចាប់មានកំណើតកូនរបស់បុរសផ្សេងក្រៅពីប្ដី ជាដើម។

## ២.៣ អំពីការទទួលស្គាល់៖

ការទទួលស្គាល់ គឺជាមធ្យោបាយមួយសម្រាប់ឪពុកដែលមិនត្រូវបានសន្មតថាជាឪពុកតាមមាត្រា ៩៨៨ នៃក.រ ដើម្បីបានចុះក្នុងសំបុត្រកំណើត។ ការទទួលស្គាល់មាន ២ ប្រភេទគឺ៖ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត និងការទទួលស្គាល់ដោយបង្ខំ។

ការទទួលស្គាល់ដោយស្ម័គ្រចិត្ត ត្រូវបានធ្វើឡើងដោយឪពុកស្ម័គ្រចិត្តទទួលស្គាល់កូនតាមរយៈការដាក់នូវទម្រង់ទទួលស្គាល់ជូនមន្ត្រីអត្រានុកូលដ្ឋាន(មាត្រា៩៩៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី១ នៃក.រ), តាមរយៈមតកសាសន៍ (មាត្រា ៩៩៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក.រ), ឬ តាមរយៈការដាក់ជូននូវរបាយការណ៍អំពីកំណើតដែលចុះហត្ថលេខាដោយឪពុក (មាត្រា ៩៩៨ នៃក.រ)។

ការទទួលស្គាល់ដោយបង្ខំ គឺជាពាក្យបណ្ដឹងដែលត្រូវបានដាក់ដោយកូនចំពោះឪពុក ដើម្បីបង្ខំឲ្យឪពុកទទួលស្គាល់ខ្លួនជាកូន។ នីតិវិធីត្រូវអនុវត្តតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល (LPS 3 ចំណុច ង, 26)។

### ក. ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន។ ប៉ុន្តែបើកូននោះ មានឪពុកតាមផ្លូវច្បាប់ (ឪពុកដែលសន្មត) ពុំអាចទទួលស្គាល់បានទេ (មាត្រា៩៩៣ ក.រ)។

**ឧទា.** ករណីប្ដីប្រពន្ធ មានកូនម្នាក់ ដោយចុះក្នុងសំបុត្រកំណើតថា ប្ដីជាឪពុក និងប្រពន្ធជាម្ដាយ។ ក្រោយមកមានការសង្ស័យថាកូន ឬ មានភាពជាក់ច្បាស់ថា កូននោះជាកូនរបស់ម្ដាយជាមួយបុរសដទៃ។ ទោះជាយ៉ាងនេះក៏ដោយ ក៏បុរសដទៃនោះ មិនអាចធ្វើការទទួលស្គាល់កូននោះ ដោយស្ម័គ្រចិត្តបានដែរ ព្រោះថាកូននោះមានឪពុកតាមច្បាប់រួចហើយ។ ករណីនេះ គួរតែមានការប្ដឹងបដិសេធបិតុភាពជាមុនសិន ទើបអាចធ្វើការទទួលស្គាល់ដោយស្ម័គ្រចិត្តបាន។

### ខ. ការទទួលស្គាល់របស់ឪពុក

ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន។ ប៉ុន្តែឪពុកអាចទទួលស្គាល់កូន ដែលជាទារកនៅក្នុងគភ៌បាន លុះត្រាតែមានការយល់ព្រមពីម្ដាយ (មាត្រា ៩៩៥ ក.រ)។ មានន័យថា ប្ដីអាចទទួលស្គាល់កូនដែលបង្កើតដោយប្រពន្ធខ្លួនបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកណាគេទេ ប៉ុន្តែប្រសិន បើ កូននោះនៅជាទារកក្នុងគភ៌ម្ដាយវិញ នោះការទទួលស្គាល់ត្រូវមានការយល់ព្រមពីម្ដាយ ព្រោះថា មាន តែម្ដាយទេដែលដឹងថា ឪពុករបស់កូននោះជាអ្នកណា។

### គ. សមត្ថភាពក្នុងការទទួលស្គាល់

ករណីឪពុកជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ (មានន័យថាជនដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព) ក៏អាចធ្វើការទទួលស្គាល់កូនបាន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ដែរ។ ព្រោះថាការទទួលស្គាល់ មិនតម្រូវឲ្យមានការតំណាង ឬការយល់ព្រមពីអ្នកតំណាងដែលច្បាប់កំណត់ទេ (មាត្រា ៩៩៤ នៃក.រ)។ ប៉ុន្តែ ទោះបីជាមិនតម្រូវឲ្យមានសមត្ថភាព

ក្នុងការធ្វើសកម្មភាពក៏ដោយ ក៏សមត្ថភាពខាងឆន្ទៈជាអប្បបរមាដើម្បីយល់ដឹងពីអត្ថន័យនៃការទទួលស្គាល់គឺជាភាពចាំបាច់។ ដូច្នេះ បុគ្គលម្នាក់ដែលបានបាត់បង់ស្មារតី ឬ វិចារណញ្ញាណ ដោយសារតែជម្ងឺធ្ងន់ធ្ងរនោះ មិនអាចធ្វើការទទួលស្គាល់បានទេ។

**ឃ. ការទទួលស្គាល់កូនជានីតិជន និងកូនដែលបានទទួលមរណភាព**(មាត្រា៩៩៦ ក.រ)

- ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជនបាន លុះត្រាតែមានការយល់ព្រមពីកូន នោះ។ ព្រោះថា កូនដែលជានីតិជននោះ អាចធ្វើការសម្រេចចិត្តបានដោយខ្លួនឯង ឬអាចមានករណីខ្លះទៀត គឺគេទប់ស្កាត់ការកេងយកប្រយោជន៍របស់ឪពុក ដោយសារតែពេលកូននៅជាអនីតិជន ឪពុកបានបោះបង់ ចោលកូននោះ ដល់ពេលឥឡូវឪពុកនោះទទួលស្គាល់កូន ព្រោះចង់ឲ្យកូននោះ ជួយផ្គត់ផ្គង់ជីវភាពផ្សេងៗ។
- ម្យ៉ាងទៀត ឪពុកក៏អាចទទួលស្គាល់កូន ដែលបានទទួលមរណភាពបានដែរ តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់។ ប៉ុន្តែបើបច្ឆាញាតិផ្ទាល់នោះជានីតិជន ត្រូវទទួលការយល់ព្រមពីជននោះ។ តាមពិតទៅការទទួលស្គាល់កូនដែលទទួលមរណភាពហើយ វាហាក់បីដូចជាគ្មានបានប្រយោជន៍អ្វីទាំងអស់ ប្រសិនបើកូនដែលទទួលមរណភាពនោះ គ្មានបច្ឆាញាតិផ្ទាល់ទេនោះ ប៉ុន្តែក្នុងបញ្ញត្តិនេះ គឺគេមានបំណង ចង់ផ្សាភ្ជាប់ចំណងរបស់ឪពុក និងបច្ឆាញាតិផ្ទាល់នោះ ព្រោះថាជាជីតា និងចៅនឹងគ្នា។

**ង. ទម្រង់នៃការទទួលស្គាល់** (មាត្រា ៩៩៧)

ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន។ ការទទួលស្គាល់ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ។ នីតិវិធីនៃការទទួលស្គាល់តាមរយៈមតកសាសន៍ត្រូវធ្វើឡើងដោយអ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ១២២០ នៃក.រ)។

ការយល់ព្រមរបស់ម្ដាយ (ក្នុងមាត្រា៩៩៥-២) អាចធ្វើបាន ដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ។

**ច. អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើត និងការទទួលស្គាល់** (មាត្រា៩៩៨)

បើបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខាឬផ្ដិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថាបានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត។ ក្នុងករណីនេះ ពុំចាំបាច់មានការទទួលស្គាលថ្មី ឬជូនដំណឹងជាថ្មីម្ដងទៀតទេ។

**ឆ. អានុភាពប្រតិសកម្មនៃការទទួលស្គាល់** (មាត្រា ៩៩៩)

ការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះ។ ប៉ុន្តែការទទួលស្គាល់ ពុំអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចហើយឡើយ។ ជាលទ្ធផលនៃអានុភាពប្រតិសកម្ម ឪពុកដែលធ្វើការទទួលស្គាល់ត្រូវបានចាត់ទុកថាបានជាកូនបំណុលក្នុងការចិញ្ចឹមបីបាច់កូនតាំងពីកំណើតរបស់កូន ហើយកូនត្រូវបានចាត់ទុកថាបានជាសន្តតិជនរបស់ឪពុកដែលធ្វើការទទួលស្គាល់ តាំងពីកំណើតរបស់កូន។

បន្ទាប់ពីការទទួលស្គាល់ ឪពុកអាចជាអ្នកមានអំណាចមេបា តាមរយៈការពិភាក្សាជាមួយម្ដាយ ឬតាមរយៈដីកាសម្រេចរបស់តុលាការ (មាត្រា ១០៣៨ កថាខណ្ឌទី ២, ទី ៣ នៃក.រ)។ ប្រសិនបើឪពុក និងម្ដាយបានរៀបអាពាហ៍ពិពាហ៍ក្រោយការទទួលស្គាល់ នោះពួកគេអាចអនុវត្តអំណាចមេបាដោយសហការគ្នាបាន (មាត្រា ១០៣៨ កថាខណ្ឌទី ៤ នៃក.រ)។

បន្ទាប់ពីការទទួលស្គាល់ ឪពុកដែលមិនបានរស់នៅជាមួយកូន អាចពិភាក្សាជាមួយម្ដាយ អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទងជាមួយកូន និងការទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (មាត្រា ១០៤០ កថាខណ្ឌទី៣ នៃក.រ)។ ក្នុងករណីការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ នោះតុលាការត្រូវកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទងជាមួយកូន និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ (មាត្រា ១០៤០ កថាខណ្ឌទី ៤ នៃក.រ)។

**ឧទា**. ឪពុក ទទួលស្គាល់កូនអាយុ១២ឆ្នាំម្នាក់ នោះបិតុភាពរវាងឪពុក និងកូននោះ ចាត់ទុកថាមានតាំងពីពេលកំណើតរបស់កូនមកដោយសារមានលក្ខណៈប្រតិសកម្ម។ ដូច្នេះ ទោះបីជាឪពុកបាន ទទួលមរណៈពេលមុនពេលទទួលស្គាល់ក៏ដោយ ក៏ជាលទ្ធផលនៃអានុភាពប្រតិសកម្មនៃការទទួលស្គាល់ កូននោះត្រូវក្លាយជាសន្តតិជនរបស់ឪពុកនោះដែរ។ ប៉ុន្តែបើការទទួលស្គាល់ត្រូវបានធ្វើឡើងក្រោយពីសហសន្តតិជនផ្សេងទៀតបានបែងចែករួចរាល់ហើយ ឬ បានចាត់ចែងមត៌ក នោះកូនដែលបានត្រូវបានទទួលស្គាល់មិនអាចទាមទារឲ្យប្រគល់នូវទ្រព្យនោះបានទេ ប៉ុន្តែត្រូវមានសិទ្ធិទាមទារឲ្យសងដោយតម្លៃតែប៉ុណ្ណោះ (មាត្រា ១២៧៤ នៃក.រ)។

**ជ. ការហាមឃាត់មិនឲ្យដកការទទួលស្គាល់ចេញ** (មាត្រា ១០០០)

ឪពុក ដែលបានទទួលស្គាល់កូនហើយ ពុំអាចលុបចោលការទទួលស្គាល់នោះបានឡើយ។ ដូច្នេះ ប្រសិនបើឪពុកបានទទួលស្គាល់កូន ដោយការភាន់ច្រឡំ, ការឆបោក, ឬ ការគំរាមកំហែង នោះឪពុកនោះមិនអាចលុបចោលការទទួលស្គាល់បានឡើយ។ នេះក៏ព្រោះតែនៅពេលជនដែលធ្វើការទទួល

ស្គាល់ គឺជាឪពុករបស់កូនដែលត្រូវបានទទួលស្គាល់ នោះទំនាក់ទំនងឪពុកម្ដាយ និងកូនដែលត្រូវបានបង្កើតឡើង

ម្ដងហើយ មិនគួរត្រូវបានលុបចោលទេ។ ផ្ទុយទៅវិញ ប្រសិនបើគេដឹងថាជនដែលធ្វើការទទួលស្គាល់ នោះមិនមែនជាឪពុករបស់កូនដែលត្រូវបានគេទទួលស្គាល់ទេ នោះអានុភាពនៃការទទួលស្គាល់អាចត្រូវបានបដិសេធដោយពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព (មាត្រា ១០០២ នៃក.រ)។

### ឈ. បណ្ដឹងទាមទារឲ្យទទួលស្គាល់៖ (មាត្រា១០០១)

កូន អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់បាន (មាត្រា ១០០១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក.រ)។ នីតិវិធីនៃបណ្ដឹងនេះត្រូវអនុវត្តតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល (LPS 3 ចំណុច ង, 26)។ ប៉ុន្តែ កូនដែលមិនបានយល់ព្រម នៅពេលឪពុកចង់ទទួលស្គាល់កូន (សូមមើលមាត្រា ៩៦៦ នៃក.រ) នោះកូនពុំអាចទាមទារឲ្យទទួលស្គាល់បានឡើយ (មាត្រា ១០០១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក.រ)។ នេះក៏ព្រោះតែការបដិសេធក្នុងការផ្ដល់ការយល់ព្រម ត្រូវបានចាត់ទុកថាដូចជា ការបោះបង់ចោលសិទ្ធិក្នុងការទទួលបានការទទួលស្គាល់។ ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះអាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់បាន (មាត្រា ១០០១ កថាខណ្ឌទី ២ នៃក.រ)។ កូន ឬបច្ឆាញាតិផ្ទាល់ របស់កូនអាចដាក់បណ្ដឹងទាមទារឲ្យទទួលស្គាល់បាន ក្នុងអំឡុងពេល១ឆ្នាំ ដោយគិតចាប់ពីពេលដែលបាន ដឹងថាជាឪពុក (មាត្រា ១០០១ កថាខណ្ឌទី ៣ នៃក.រ)។

ក្នុងករណីដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេល១ឆ្នាំ ត្រូវគណនា គិតចាប់ពីពេលដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះបាន ក្លាយជានីតិជន ឬពេលដែលមានការលុបចោលការប្រកាស ចាប់ផ្ដើមអាណាព្យាបាលទូទៅ (មាត្រា ២៧) (មាត្រា ១០០១ កថាខណ្ឌទី ៤ នៃក.រ)។

កូន ឬបច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល ១ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក (មាត្រា ១០០១ កថាខណ្ឌទី ៥ នៃក.រ)។

## ៣. បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

### ក. បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

ជានីតិវិធីក្នុងការទាមទារទៅតុលាការឲ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ក្នុងករណីបិតុភាព ឬ មាតុភាព ត្រូវបានបង្កើតឡើងដោយផ្ទុយនឹងការពិតជាក់ស្ដែង។ តាមមាត្រា ១០០២ បានចែងថា ៖

- កូនអាចដាក់ពាក្យបណ្តឹងទៅតុលាការ ឲ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ឬមាតុភាព ចំពោះជន ដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុក ក៏ដោយ ឬជន ដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះបីជាគ្មានហេតុដែលបានសម្រាល ក៏ដោយ (មាត្រា ១០០២ កថាខណ្ឌទី ១ នៃក.រ)។

- ជន ដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុក ក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន (មាត្រា ១០០២ កថាខណ្ឌទី ២ នៃក.រ)។

- ជន ដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាមិនបានសម្រាលកូននោះ ក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃមាតុភាពជាមួយកូនបាន (មាត្រា ១០០២ កថាខណ្ឌទី ៣ នៃក.រ)។

- បណ្តឹងរបស់ ឪពុក ឬ ម្តាយ ដែលទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ពុំអាចដាក់បានឡើយ ប្រសិនបើបិតុភាព ឬមាតុភាពតាមផ្លូវច្បាប់ កើតឡើយដោយចេតនា ឬកំហុសធ្ងន់ធ្ងររបស់ជនដែលត្រូវ បានចុះជាឪពុក ឬម្តាយនៅក្នុងសៀវភៅកំណើត ឬបើអំឡុងពេល២០ឆ្នាំបានកន្លងផុត គិតចាប់ពីថ្ងៃ កំណើត របស់កូន ឬថ្ងៃដែលអានុភាពនៃការទទួលស្គាល់បានកើតឡើង (មាត្រា ១០០២ កថាខណ្ឌទី ៤ នៃក.រ)។

**ខ. អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព** (មាត្រា១០០៣)

ការបញ្ជាក់នត្ថិភាពនៃបុត្តភាព ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ។

ចំណុចៈ ប្រសិនបើឈ្មោះរបស់បុគ្គលដែលមិនមែនជាឪពុកត្រូវបានចុះក្នុងសំបុត្រកំណើតថាជាឪពុក វាអាចត្រូវបានកែតម្រូវតាមរយៈបណ្តឹងបដិសេធបិតុភាព (មាត្រា ៩៨៩ ដល់មាត្រា ៩៩២ នៃក.រ) ឬ បណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃបុត្តភាព (មាត្រា ១០០២ ដល់មាត្រា ១០០៣ នៃក.រ)។ ភាពខុសគ្នានៃប្រព័ន្ធទាំងនោះគឺដូច្នេះ។ ប្រសិនបើឈ្មោះរបស់បុគ្គលដែលមិនមែនជាឪពុកត្រូវបានកត់ត្រាក្នុងសំបុត្រកំណើតដោយផ្អែកតាមការសន្មតនៃមាត្រា ៩៨៨ នៃក.រ នោះបណ្តឹងបដិសេធបិតុភាពត្រូវបានយកមកប្រើ។ ផ្ទុយទៅវិញ ប្រសិនបើឈ្មោះរបស់បុគ្គលដែលមិនមែនជាឪពុកត្រូវបានកត់ត្រាក្នុងសំបុត្រកំណើត ដោយផ្អែកតាមការទទួលស្គាល់ នោះបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពត្រូវបានយកមកប្រើ។

### ៣.៣ បណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

តាមមាត្រា៩៨៧ នៃក.រ បានចែងថា ស្ត្រីដែលផ្តល់កំណើតឲ្យកូន ជាម្តាយរបស់កូននោះ។ ប៉ុន្តែ មានករណីខ្លះ ទោះបីជាស្ត្រីនោះបានផ្តល់កំណើតឲ្យកូនក៏ដោយ ក៏មាតុភាពរបស់កូននោះមិនត្រូវបាន

បង្កើតឡើងដែរ ព្រោះម្ដាយមិនបានចុះឈ្មោះរបស់ខ្លួននៅលើសំបុត្រកំណើតទេ។ ដូច្នេះ ទើបគេបង្កើតឲ្យមានបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន និង ពីម្ដាយ។

**ក. បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន** (មាត្រា ១០០៤)

- កូន អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីដែលបានបង្កើតខ្លួនបាន (មាត្រា ១០០៤ កថាខណ្ឌទី ១ នៃក.រ)។ ប្រសិនបើកូននោះបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងជំនួសបាន (មាត្រា ១០០៤ កថាខណ្ឌទី ២ នៃក.រ)។ កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងបាន ក្នុងអំឡុងពេល១ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលបានដឹងថាជាម្ដាយ (មាត្រា ១០០៣ កថាខណ្ឌទី ៣ នៃក.រ)។
- ក្នុងករណីដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលបានដឹងថាជាម្ដាយ អំឡុងពេល១ឆ្នាំត្រូវគណនា ដោយគិតចាប់ពីពេលដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ (មាត្រា ១០០៤ កថាខណ្ឌទី ៤ នៃក.រ)។
- កូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ក្នុងអំឡុងពេល១ឆ្នាំគិតចាប់ពីថ្ងៃមរណភាពរបស់ម្ដាយ ប្រសិនបើដឹងថាជាម្ដាយ នៅក្រោយមរណភាពរបស់ម្ដាយ (មាត្រា ១០០៤ កថាខណ្ឌទី ៥ នៃក.រ)។

ឧទា.

**ខ. បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីម្ដាយ** (មាត្រា ១០០៥)

- ម្ដាយ អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះកូនដែលខ្លួនបានបង្កើតបាន ក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ពីថ្ងៃដែលខ្លួនបានដឹងថាជាកូន។ ម្ដាយអាចដាក់ពាក្យបណ្ដឹងចំពោះ កូនដែលបានទទួលមរណភាពបាន តែក្នុងករណីកូននោះ មានបច្ឆាញាតិផ្ទាល់ ក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ ពីថ្ងៃមរណភាពរបស់កូន ប្រសិនបើបានដឹងថាជាកូន នៅក្រោយមរណភាពរបស់កូន (មាត្រា ១០០៥ កថាខណ្ឌទី ១ ដល់ទី ៥ នៃក.រ)។
- ប្រសិនបើម្ដាយជាជននៅក្រោមអាណាព្យាបាលទូទៅគាត់អាចដាក់បណ្ដឹងទាមទារឲ្យបញ្ជាក់ អត្ថិភាពនៃមាតុភាពបានក្នុងអំឡុងពេល១ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ (មាត្រា ១០០៥ កថាខណ្ឌទី ៥ នៃក.រ)។
- ក្នុងករណីដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូន ជានីតិជន បើគ្មានការយល់ព្រមពីកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះទេ ម្ដាយមិនអាចអាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់ពីអត្ថិភាពនៃមាតុភាព បានឡើយ (មាត្រា ១០០៥ កថាខណ្ឌទី ៦ នៃក.រ)។

- ទោះបីជាក្នុងករណីដែលអង្គហេតុ នៃការបង្កើតកូន ត្រូវបានបញ្ជាក់ក៏ដោយ បើការបញ្ជាក់មាតុភាព ផ្ទុយនឹងប្រយោជន៍របស់កូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ តុលាការអាចអាចលើកចោលបណ្តឹង របស់ម្តាយបាន (មាត្រា ១០០៥ កថាខណ្ឌទី ៧ នៃក.រ)។

**គ. អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព** (មាត្រា ១០០៦)

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន នោះ។ ប៉ុន្តែ អានុភាពប្រតិសកម្មនេះ ពុំអាចបំពានសិទ្ធិដែលតតិយជន បានធ្វើលទ្ធកម្មរួយហើយឡើយ។

ឧទា.

ករណីៈ ទារកទើបនឹងកើតត្រូវបានផ្លាស់ប្តូរគ្នានៅមន្ទីរពេទ្យ។ ជាលទ្ធផល X (កូនរបស់ A និង B) ត្រូវបានចុះថាជាកូនរបស់ C និង D ហើយ Y (កូនរបស់ C និង D) ត្រូវបានចុះថាជាកូនរបស់ A និង B។ បីបួនខែក្រោយមក A និង B បានកត់សម្គាល់ឃើញថាកូនរបស់ពួកគេមិនមែនជា Y ទេ គឺ X។ A និង B ចង់លុបឈ្មោះរបស់ខ្លួនចេញពីសំបុត្រកំណើតរបស់ Y ហើយចង់ចុះក្នុងសំបុត្រកំណើតរបស់ X។ តើ A និង B គួរអនុវត្តតាមនីតិវិធីបែបណា? (A គឺជាបុរស, B គឺជាស្ត្រី)។

# ស្មុំកូន

## ១. សញ្ញាណទូទៅ

- **និយមន័យ៖** គឺជាការបង្កើតទំនាក់ទំនងញាតិលោហិតថ្មី។ ដើម្បីបង្កើតសន្តតិជននៃទ្រព្យសម្បត្តិរបស់គ្រួសារចិញ្ចឹម ក៏ដូចជាបន្ថែមកម្លាំងការងារ នឹងមើលថែរក្សា ឪពុកម្តាយចិញ្ចឹម និងមានអ្នកមើលថែរក្សា កូនចិញ្ចឹម(កូនស្មុំ) នោះផងដែល។

## ២. តួនាទីនៃការស្មុំកូន នឹងគោលបំណងនៃរបបស្មុំកូន ផលប្រយោជន៍នៃការស្មុំកូន

- តើការបង្កើតឲ្យមានរបបស្មុំកូនដើម្បីអ្វី និងផលប្រយោជន៍អ្វី?

ជាគោលការណ៍ ដើម្បីមានអ្នកស្នងត្រកូល និងមើលថែរក្សាខ្លួននៅពេលដែលខ្លួនចាស់ និងមានអ្នកមើលថែរក្សាកូនដូចគ្នា។

❖ អត្ថប្រយោជន៍

- បង្កើតសន្តតិជន នៃទ្រព្យសម្បត្តិរបស់ឪពុកម្តាយ
- មានកម្លាំងការងារ(ស្នងអាជីវកម្ម)
- អ្នកដែលគ្មានកូនអាចរកកូនបាន
- កូនដែលកំព្រាមានឪពុកម្តាយ
- កាត់បន្ថយកូនកំព្រា នឹងជួយដល់ប្រមុខរាជរដ្ឋាភិបាល

## ៣. ល័ក្ខខ័ណ្ឌទូទៅសម្រាប់ការស្មុំកូនមាន៤ចំនុចៈ

- អាយុរបស់ឪពុកម្តាយចិញ្ចឹម នឹងកូនស្មុំ
- ការចូលរួមរបស់ភាគីដែលមាន ផលប្រយោជន៍ពាក់ព័ន្ធ (ឪពុកម្តាយបង្កើតរបស់កូន និងឪពុកម្តាយចិញ្ចឹម តំណាងអយ្យការ)
- អំឡុងពេលសាកល្បងចិញ្ចឹម (ពេញលេញ)
- មូលដ្ឋានវិនិច្ឆ័យដែលតុលាការ និងពិចារណា

❖ **ប្រភេទនៃការស្មុំកូនមាន២គឺៈ**

1. ស្មុំកូនពេញលេញៈ បង្កើតទំនាក់ទនងញាតិលោហិតថ្មី និងបញ្ចប់ទំនាក់ទំនងញាតិចាស់។
2. ស្មុំកូនធម្មតាៈ បង្កើតទំនាក់ទំនងញាតិលោហិតថ្មី និងបន្តទំនាក់ទំនងញាតិចាស់។

- **ស្មុំកូនពេញលេញ**

**និយមន័យ៖** ស្មុំកូនពេញលេញ គឺជាការបង្កើតទំនាក់ទំនងញាតិលោហិតថ្មី និងបញ្ចប់ទំនាក់ទំនងញាតិលោហិតចាស់។

❖ **ការបង្កើតសុំកូនពេញលេញ**

បុគ្គលដែលមានបំណងចង់ក្លាយជាឪពុកកម្តាយចិញ្ចឹម គឺត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់ឪពុកម្តាយចិញ្ចឹម (មាត្រា ១០០៧) ហើយតុលាការចេញដីកាសម្រេច (មាត្រា ២ កថាខណ្ឌ២នៃច្បាប់ស្តីពីនិតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង)។

EX : A និង B មានទីលំនៅ នៅរាជធានីភ្នំពេញមានបំណងសុំយកកូនឈ្មោះ D ទៅចិញ្ចឹមហើយ D មានទីលំនៅឯខេត្តប៉ៃលិន។ ដូចនេះ A និង B ត្រូវដាក់ពាក្យសុំរបស់ខ្លួនទៅសាលាដំបូងរាជធានីភ្នំពេញ។

❖ **ល័ក្ខខ័ណ្ឌនៃការបង្កើត**

ឪពុកម្តាយចិញ្ចឹមៈ ត្រូវមានសហព័ទ្ធ (មាត្រា ១០០៨) បុគ្គលដែលនៅលីវមិនបានទេ។ បើយើងនិយាយរួមប្តី ឬប្រពន្ធតែម្ខាងពុំអាចក្លាយជាឪពុកម្តាយចិញ្ចឹមបានឡើយ ប្រសិនបើប្តី ឬប្រពន្ធតែម្ខាងមិនបានក្លាយទៅជាឪពុកម្តាយចិញ្ចឹមបានទេ នោះមិនអាចបង្កើតនូវការសុំកូនពេញលេញបាននោះទេ បើយើងនិយាយជុំវិញ ប្រពន្ធ និង ប្តីត្រូវខ្លាយជាឪពុកម្តាយចិញ្ចឹមទាំងពីរនាក់។

ប៉ុន្តែមានករណីពិសេស ប្រសិនបើការសុំកូនរបស់សហព័ទ្ធម្ខាងទៀត ច្បាប់ បានអនុញ្ញាតឲ្យសហព័ទ្ធម្ខាងក្លាយជាឪពុកម្តាយចិញ្ចឹមបាន (មាត្រា ១០០៨ នៃក្រមរដ្ឋប្បវេណី)។

EX : B ជាស្រ្តីមេម៉ាយមានកូនបីឈ្មោះ A B C ដែលមានអាយុ ៤ ៥ ៦ ឆ្នាំ។ នៅឆ្នាំ ២០១៤ B បានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយបុរសម្នាក់ឈ្មោះ Z។ ក្រោយពីរៀបការរួចហើយ Z មានបំណង់ចងបាន A B C ធ្វើជាកូនចិញ្ចឹម តាមរយៈការដាក់ពាក្យសុំកូនពេញលេញ ដែលជាកូនបង្កើតរបស់B។ នៅក្នុងករណី បែបនេះB គឺជាម្តាយបង្កើតហើយដូចនេះ B មិនអាចក្លាយជាម្តាយចិញ្ចឹម បាននោះ ទេ។

- ក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យ Z តែម្នាក់ឯងក្លាយជាឪពុកចិញ្ចឹមរបស់ A B C។

❖ **អាយុរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំ**

- ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅ (មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណី)
- ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ឆ្នាំ (មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណី)

EX: ដារ៉ា និងភារីបានរៀបអាពាហ៍ពិពាណ៍អស់រយៈពេល៥ឆ្នាំហើយ ប៉ុន្តែអ្នកទាំងពីរពុំមានកូនជាមួយគ្នាទេ។ អ្នកទាំងពីរមានអាយុលើស ២៥ឆ្នាំហើយពួកគាត់ មានបំណងចង់បង្កើតសុំកូនពេញលេញ ទៅលើក្មេងម្នាក់ដែលមានអាយុ ៣ឆ្នាំយកមកធ្វើជាកូនសុំពេញលេញរបស់ពួកគាត់។

<u>**សំណួរះ**</u>

- តើពេលណាជាពេលមូលដ្ឋានសម្រាប់កំណត់ការបំពេញនូវអាយុអតិបរិមា ?

➢ អាយុត្រូវតែច្រើនជាងកូនសុំយ៉ាងតិច ២០ឆ្នាំ

EX: ដារ៉ា និងភារីជាសហព័ន្ធ ហើយដារ៉ាមាអាយុ ២៦ឆ្នាំ ភារីមានអាយុ ២៨ឆ្នាំ បើយើងពិនិត្យទៅលើអាយុអ្នកទាំងពីរគឺសុទ្ធតែមានអាយុលើសពី ២៥ឆ្នាំហើយ។ គាត់មានបំណងចង់សុំកូនពេញលេញមួយ ប៉ុន្តែកូននោះមានអាយុ ៧ឆ្នាំ ដូចនេះពួកគាត់ទាំងពីរមិនអាចធ្វើការសុំកូនពេញលេញបានទេ (មាត្រា ១០០៩ នៃក្រមរដ្ឋប្ប វេណី) ដោយសារតែ ដារ៉ាមិនមានអាយុលើសកូននោះ ២០ឆ្នាំឡើយ។

មានន័យថាអ្នកទាំងពីរមិនអាចក្លាយជាឪពុកម្តាយចិញ្ចឹម តាមរយៈការសុំកូន ពេញលេញចំពោះក្មេងម្នាក់នោះបានឡើយ។

❖ **អាយុរបស់កូនសុំ**

- ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ឆ្នាំ (មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី)

<u>**សំណួរ៖**</u>

- តើកូនសុំពេញលេញអាចមានអាយុលើស ៨ឆ្នាំបានដែរឬទេ? ហើយ តុលាការមានមូលហេតុអ្វីខ្លះ?

ឧទាហរណ៍៖ កូនសុំបានរស់នៅជាមួយឪពុកម្តាយចិញ្ចឹមតាំងពីអាយុ ៧ឆ្នាំរហូតដល់អាយុ ១៥ឆ្នាំទើបឪពុកម្តាយដាក់ពាក្យសុំបង្កើតសុំកូនពេញលេញ។

- ក្នុងស្ថានភាពបែបនេះ តុលាការប្រែជាអាចបង្កើតសុំកូនពេញលេញបានទោះបីជាកូនអាយុ ១៥ឆ្នាំក៏ដោយ។
- ការចូលរួមរបស់កុមារដែលនឹងត្រូវក្លាយជាកូនសុំ
- មិនមានភាពចាំបាច់ (កុមារដែលនឹងក្លាយជាកូនសុំក៏មានអាយុក្មេងពេក)។
- ការចូលរួមរបស់ឪពុកម្តាយបង្កើតរបស់បុគ្គលដែលត្រូវក្លាយជាកូនសុំ
- ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬអាណាព្យាបាលសម្រាប់ អនីតិជនរបស់កូនសុំ ប៉ុន្តែមានការលើកលែងដែលឪពុកម្តាយបង្កើតមិនអាច បង្ហាញ ឆន្ទៈបាន មានការធ្វើបាបកូនបោះបង់កូនចោលដោយទុច្ចរិត ឬហេតុដទៃទៀត ដែលបំពានផលប្រយោជន៍របស់កុមារយ៉ាងធ្ងន់ធ្ងរ។
- ឪពុកម្តាយបង្កើតមានសិទ្ធិអាចដកនូវការយល់ព្រម បានរហូតដល់ពេលដីកា សម្រេចចូលជាស្ថាពរ ប្រសិនបើករណីនោះដែលឪពុកម្តាយបង្កើតដកការយល់ ព្រមនោះតុលាការត្រូវបដិសេធន៍ចោលនូវពាក្យសុំបង្កើនកូនសុំពេញលេញ។ មាត្រា ១០១២ នៃក្រមរដ្ឋប្បវេណី
- មាត្រា ១០១១ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍ទី១៖ ឪពុកម្តាយបង្កើតបានអោយកូនរបស់ខ្លួនដើរសុំទាន យកប្រាក់មកអោយ ខ្លួនចាយវាយ ផឹកស្រា ហើយបដិសេធន៍មិនអោយកូនទៅអ្នកដទៃចិញ្ចឹម ឬករណី ម្តាយឪពុកបង្កើតរត់បាត់ខ្លួន។

ឧទាហរណ៍ទី២៖ នៅពេលបុគ្គលដែលត្រូវក្លាយជាឪពុកម្ដាយចិញ្ចឹមបានដាក់ពាក្យសុំទៅតុលាការហើយបានហៅឪពុកម្ដាយបង្កើតមកនៅ ឪពុកម្ដាយបង្កើតនោះបានយល់ព្រមដោយបញ្ហា ប៉ុន្តែក្រោយពេលដែលតុលាការមិនចេញដីការសម្រេចនោះ ឪពុកម្ដាយបង្កើតបានដាក់នូវការយល់ព្រមនោះត្រលប់មកវិញ តុលាការត្រូវបដិសេធន៍ ពាក្យសុំរបស់បុគ្គលដែលត្រូវក្លាយជាឪពុកម្ដាយចិញ្ចឹមចោល។

+ អំឡុងពេលនៃការសាកល្បងចិញ្ចឹម

- ការបង្កើតអោយមានសុំកូនពេញលេញ គឺដើម្បីបង្កើតនូវគ្រួសារ ថ្មីមួយដល់កុមារដែល អភ័ព្វ។
- ក្រមរដ្ឋប្បវេណីតម្រូវអោយតុលាការ ធ្វើការពិចារណាទៅលើស្ថានភាពរបស់ បុគ្គលដែល នឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបានធ្វើនៅក្នុងការគ្រប់គ្រងកុមារ ដែលនឹងក្លាយជាកូនសុំក្នុងអំឡុងពេលសាកល្បងចិញ្ចឹមដែលមានរយៈពេលយ៉ាងតិច ៦ខែជាគោលការណ៍។ រយៈពេល៦ខែ អាចទៅមុខ ឬក្រោយពេលដាក់ពាក្យសុំ។ ប្រសិនបើនៅមុនពេលដាក់ពាក្យសុំ បុគ្គលដែលនឹងក្លាយជា ឪពុកម្ដាយចិញ្ចឹមត្រូវដាក់នូវភស្តុតាងដែលអាចជឿជាក់បានជូនតុលាការដើម្បីបញ្ជាក់នូវស្ថានភាពរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ដែលមានការចិញ្ចឹមបីបាច់ថែរក្សាកូនដែលត្រូវសុំនោះបានយ៉ាងល្អ។ ហេតុដូចនេះក្នុង ន័យនេះរយៈពេលសាកល្បងអាចមានរយៈពេលតិចជាងនេះបានក្នុងករណីពិសេស។ តុលាការ និងពិចារណាលទ្ធភាពរបស់បុគ្គលដែល នឹងក្លាយជាឪពុកម្ដាយចិញ្ចឹម និងភាពចុះសម្រុងគ្នារវាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម និងកុមារដែលនឹងក្លាយជាកូនសុំ។
អង្គហេតុជាធម្មតាអំឡុងពេលសាកល្បងចិញ្ចឹមចាប់ផ្ដើមនៅពេលឪពុកម្ដាយបង្កើតស្ម័គ្រចិត្តប្រគល់កូនអោយទៅបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។ ប្រសិនបើឪពុកម្ដាយបង្កើតបានកំពុងធ្វើបានកូននោះ។

ឧទាហរណ៍ ៖ កូនសុំធ្លាប់បានរស់នៅជាមួយ និងឪពុកម្ដាយចិញ្ចឹម ជាយូរណាស់មកហើយ តាំងពីមុនពេលដាក់ពាក្យសុំបង្កើតកូនស្មុំពេញលេញទៅទៀត។ ក្នុងករណីនេះ តុលាការអាចកំណត់រយៈពេលសាកល្បងខ្លីជាង ៦ខែ ឬមិនកំណត់រយៈពេលសាកល្បងតែម្ដងក៏បានដែរ។

ដូច្នេះ បើតុលាការយល់ឃើញថា នៅក្នុងអំឡុងពេលសាកល្បងនេះ កុមារមិនអាចរស់នៅចុះសម្រុងជាមួយ នឹងបុគ្គលដែល នឹងក្លាយជាឪពុកម្ដាយចិញ្ចឹមទេ ភាគច្រើនតុលាការ និងមិនសម្រេចឲ្យបង្កើតស្មុំកូនពេញលេញទេ ពីព្រោះថាការធ្វើបែបនេះអាច នឹងធ្វើឲ្យប៉ះពាល់ដល់ទឹកចិត្តក៏ដូចជាផលប្រយោជន៍របស់កុមារនាពេលអនាគត។

- ករណីជាក់ស្តែង: បណ្ដឹងនៅតុលាការរបស់យើងផ្ទាល់ អានុភាពស្មុំកូនពេញលេញមាត្រា ១០១៩នៃក្រមរដ្ឋប្បវេណី (ឪពុកម្ដាយបង្កើត)

- ផ្តាច់ចំណង់ញាតិលោហិត (ញាតិភាព) ជាមួយនិងឪពុកម្តាយបង្កើត (មាត្រា១០១៨នៃក្រមរដ្ឋប្បវេណី។ កូនសុំពេញលេញ និងឪពុកម្តាយបង្កើតលែងមានសិទ្ធិសន្តតិកម្មរវាងគ្នាហើយ។
- ករណីលើកលែង: សុំកូនរបស់សហព័ទ្ធម្ខាងទៀត។

ឧទាហរណ៍ ៖ លោកស្រី x បានរៀបការជាមួយលោក z ហើយ x មានកូនម្នាក់គឺ c ដែលមានអាយុ ៥ឆ្នាំ។ z បានសុំយក c ជាកូនចិញ្ចឹមពេញលេញក្នុងករណីនេះ c នឹង x មិនបានផ្តាច់ចំណងញាតិលោហិតនោះទេ ហើយ x ដែលជាម្តាយបង្កើត នៅតែមានអត្តិភាពដដែល។

❖ **ក្រោយពីបង្កើតសុំកូនពេញលេញកូនសុំ:**

- លែងទទួលបាននូវសិទ្ធិជាសន្តតិកម្មនូវទ្រព្យ
- មិនទទួលនូវកាតព្វកិច្ចគ្នាទៅវិញទៅមកទេ។
- ឪពុកម្តាយបង្កើតលែងមានសិទ្ធិទៅសួរសុខទុក្ខ។ ប៉ុន្តែនៅតែមានការហាមឃាតនូវការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត គឺនៅតែយកមកអនុវត្ត (មាត្រា ៩៥ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី)

❖ **ឪពុកម្តាយបង្កើត**

- កូនសុំមានឋានៈដូចគ្នា និងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនឹងត្រូវទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នា នឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹមកូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬមាននាមត្រកូលមុនរបស់ខ្លួនបាន។ (មាត្រា ១០១៥-២-១ នៃក្រមរដ្ឋប្បវេណី) កូនសុំត្រូវនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម។ (មាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណី)

កូនសុំពេញលេញមានសិទ្ធិទាមទារចំពោះតុលាការឲ្យបង្ហាញព័ត៌មាន ក្នុងទំហំចាំបាច់ការបើគាត់ក្លាយជានីតិជន នៅក្នុងករណីមានគោលបំណងត្រឹមត្រូវ។

❖ ការចុះបញ្ជីកំណើត:

ក្នុងករណី កូនសុំពេញលេញត្រូវបានបង្កើតឡើង បញ្ជីកំណើតរបស់កូនសុំត្រូវធ្វើថ្មី ប៉ុន្តែនៅក្នុងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើតឬឯកការសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ។ (មាត្រា ១០១៨ នៃក្រមរដ្ឋប្បវេណី)

❖ **មូលដ្ឋាននៃការវិនិច្ឆ័យរបស់តុលាការ**

▪ មាត្រា ១០១២ នៃក្រមរដ្ឋប្បវេណី:

- ការលំបាកក្នុងការគ្រប់គ្រងថែរក្សាកូន ៖ ក្រីក្រខ្លាំង មានជំងឺផ្លូវកាយ ឬខាងស្មារតីធ្ងន់ធ្ងរ កំពុងបាត់ខ្លួន

- ភាពមិនសមស្របក្នុងការថែរក្សាកូនៈ ការបំពានធ្វើបានខាងផ្លូវកាយ ឬតាមរយៈពាក្យសម្ដី ការធ្វេសប្រហែសមិនអើពើក្នុងការថែរក្សាកូន។
- ភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនៈ មានភាពល្អប្រសើរសម្រាប់កូននោះ ទោះផ្នែកស្មារតី និងសំភារៈក្នុងការរស់នៅជាមួយបុគ្គលដែល នឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ជាជាងរស់នៅជាមួយឪពុកម្ដាយបង្កើត។
- ជាទូទៅ កុមារដែលក្លាយជាកូនសុំពេញលេញមិនមែនជាកុមារដែលរស់នៅ សុខសប្បាយទេ មុនពេលបង្កើតសុំកូនទូទៅសម្រាប់តុលាការ និងសម្រេចបង្កើតសុំកូនពេញលេញ លុះត្រាតែតុលាការយល់ឃើញថា មានការពិបាកយ៉ាងខ្លាំង ឬមិនសមរម្យក្នុងការគ្រប់គ្រងថែរក្សាកុមារ ដែលនឹងក្លាយជាកូនសុំដោយឪពុកម្ដាយបង្កើត ឬមានស្ថានភាពពិសេសផ្សេងៗទៀត ដែលតុលាការយល់ឃើញថា មានភាពចាំបាច់ត្រូវបង្កើតកូនសុំពេញលេញ ដើម្បីផលប្រយោជន៍របស់កុមារ។

  ចំពោះស្ថានភាពទាំងនោះមានៈ

  - ការបាត់ខ្លួនរបស់ឪពុកម្ដាយ
  - ការមានវិបត្តិផ្នែករាងកាយ
  - មានជីវភាពក្រីក្រខ្លាំងពេក
  - ធ្វើបាបកូន និងបោះបង់កូន។ ល ។

❖ **ការកាត់កាល**

- មាត្រា១០១៦ នៃក្រមរដ្ឋប្បវេណី នឹងមាត្រា ៣នៃក្រមរដ្ឋប្បវេណីស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនិងឋានៈបុគ្គល។

\+ **ត្រូវដាក់ពាក្យបណ្ដឹងទាមទារកាត់កាលៈ**

- អ្នកដែលមានសិទ្ធិដាក់ពាក្យបណ្ដឹង ៖ ឪពុកម្ដាយបង្កើត កូនសុំតំណាងអយ្យការ។
- ចំពោះឪពុកម្ដាយបង្កើតមិនអាចប្ដឹងទាមទារកាត់កាលសុំកូនពេញលេញបានទេ។
- ល័ក្ខខ័ណ្ឌទាំងពីរ នៃមាត្រា ១០១៦ នៃក្រមកថាខណ្ឌទី ១ ចំណុច ក និង ខ ត្រូវតែបំពេញ។ ដូច្នេះប្រសិនបើឪពុកម្ដាយបង្កើតបានទទួលមរណភាពនោះការកាត់កាល់គឺមិនអាចកើតឡើងបានទេព្រោះថាមាត្រា១០១៦ កថាខណ្ឌទី១ ចំណុចខ នៃក្រមរដ្ឋប្បវេណីមិនអាចបំពេញ។

**តារាង**

| | | |
|---|---|---|
| ដើមចោទកូនសុំ | ចុងចម្លើយឪពុកម្ដាយចិញ្ចឹម | មាត្រា១០១៦កថ១នៃឋានៈបុគ្គល |
| ឪពុកម្ដាយបង្កើត | ឪពុកម្ដាយចិញ្ចឹមនិងកូនសុំ | មាត្រា១០១៦កថ២នៃឋានៈបុគ្គល |
| ព្រះរាជអាជ្ញា | ឪពុកម្ដាយចិញ្ចឹមនិងកូនសុំ | មាត្រា១០១៦កថ២នៃឋានៈបុគ្គល |

- **មូលហេតុនៃការកាត់កាល់កូនស្មុំ**

+ ឪពុកម្ដាយចិញ្ចឹមធ្វើបាបកូន បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬហេតុផ្សេងទៀតដែលបំពានផលប្រយោជន៍កូនយ៉ាងធ្ងន់ធ្ងរ។

+ ឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

ឧទាហរណ៍ ៖ បន្ទាប់ពីបានបង្កើតកូនស្មុំពេញលេញ ហើយកូនសុំបានទៅរស់នៅជាមួយឪពុកម្ដាយចិញ្ចឹម។ ក្រោយមកការរស់នៅរបស់កូនសុំនោះមានការធ្វើបាបពីសំណាក់ឪពុកម្ដាយចិញ្ចឹម ហើយឪពុកម្ដាយចិញ្ចឹមនោះមិនបានចាត់វិធានការ ទប់ស្កាត់សកម្មភាពធ្វើបាបទៅកូនសុំនោះ។ (ឪពុកម្ដាយចិញ្ចឹមធ្វើបាប)

ឧទាហរណ៍ ៖ ឪពុកម្ដាយបង្កើតរបស់កូនសុំដែលពីមុនដែលមាននេះជីវភាពក្រីក្រយ៉ាងខ្លាំងដោយសារតែមានជម្ងឺ នោះបានធូរស្បើយឡើយវិញ អាចប្រកបរបបដើម្បីចិញ្ចឹមជីវភាពបានល្អប្រសើរជាងមុន។ ករណីនេះ បើឪពុកម្ដាយមានបំណងចង់ទាមទារកូនយកមកវិញ ត្រូវដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់ ហើយតុលាការត្រូវពិនិត្យ និងពិចារណាទៅលើភស្តុតាងដែលបញ្ជាក់ពីអត្ថិភាពនៃល័ក្ខខ័ណ្ឌ នៃការកាត់កាល ហើយបើមានល័ក្ខខ័ណ្ឌទាំង២ហើយតុលាការនឹងចេញសាលក្រមដើម្បីកាត់កាលស្មុំកូនពេញលេញ។

- ក្នុងករណីដែលឪពុកម្ដាយចិញ្ចឹមបានធ្វើបាបកូនស្មុំក៏ប៉ុន្តែឪពុកម្ដាយបង្កើតមិនមានលទ្ធភាពសមរម្យជីវភាពគ្រប់គ្រងកូនទេនោះ ឬបានស្លាប់បាត់បង់ជីវភាពនិងបាត់ខ្លួនដោយរកមិនឃើញជាដើមនោះ តុលាការមិនអាចកាត់កាលកូនស្មុំពេញលេញបានទេ ល័ក្ខខ័ណ្ឌនៃមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែមានវិធីមួយទៀត គឺមាត្រា១០៤៨ ការព្យួរ ឬដកហូតអំណាចមេបាពីឪពុកម្ដាយចិញ្ចឹម ហើយជ្រើសតាំងអ្នកតំណាង ឬអាណាព្យាបាលសំរាប់អនីតិជនដើម្បីជាផលប្រយោជន៍របស់កុមារក៏ដូចជាកូនស្មុំនោះ។

**+អានុភាព នៃការកាត់កាល**

1. ផ្ដាច់ទំនាក់ទំនងញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម

2. កូនសុំ និងឪពុកម្ដាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើត ដែលបានបញ្ចប់ដោយសុំកូននោះ ត្រូវបានបង្កើតវិញហើយគិតចាប់ពីថ្ងៃកាត់កាល (មាត្រា១០១៧ នៃក្រមរដ្ឋប្បវេណី)។

**<u>សុំកូនធម្មតា:</u>**

**និយមន័យ:** បង្កើតទំនាក់ទំនងញាតិលោហិតថ្មី និង បន្តទំនាក់ទំនងញាតិចាស់។

- ការបង្កើតសុំកូនធម្មតា ៖ បុគ្គលដែល និង ក្លាយជាឪពុកម្ដាយចិញ្ចឹម និង កូនសុំ ដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់កូនសុំ។

ឧទាហរណ៍ ៖ ពុទ្ធា និង ធីតា មានទីលំនៅខេត្តព្រះសីហនុ មានបំណងសុំយកកូនអាយុ ៨ឆ្នាំ ហើយគាត់រស់នៅទីក្រុងភ្នំពេញ។

សំនួរៈតើ ពទ្ធា និង ធីតា ត្រូវដាក់ពាក្យសុំកូននៅទីណា?

- ក្នុងករណីនេះ ពុទ្ធា និង ធីតា ត្រូវដាក់ពាក្យសុំនៅភ្នំពេញ។

របៀបដាក់ពាក្យៈតាមរយៈលិខិតជាលាយលក្ខណ៍ជាអក្សរ ឬ តាមរយៈការដាក់ពាក្យដោយផ្ទាល់មាត់ (មាត្រា២៦ រឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

ចំពោះកូនសុំជានីតិជននោះ គឺបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមជាមួយគ្នា និងបុគ្គលដែលនឹងក្លាយជាកូនសុំ (មាត្រា១០២០ កថាខណ្ឌទី១ នៃក្រម រដ្ឋប្បវេណី)។

កូនសុំជាអនីតិជន នោះគឺបុគ្គលដែល នឹងក្លាយជាឪពុកម្ដាយចិញ្ចឹមជាមួយគ្នា និងឪពុកម្ដាយបង្កើតរបស់បុគ្គលដែលនិង ក្លាយជាកូនសុំ (មាត្រា១០២០ កថាខណ្ឌ ទី២ នៃក្រមរដ្ឋប្បវេណី)។

ពន្ធដាក់ពាក្យសុំគឺ ៥០០០ រៀល (មាត្រា២២ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង)។

តុលាការចេញដីកាសម្រេចត្រូវធ្វើជាលាយលក្ខណ៍ជាអក្សរត្រូវសរសេរសំអាងហេតុ និងសេចក្ដីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្ដីសម្រេចនេះ (មាត្រា៣៥នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង)។ ដីកាសម្រេចត្រូវបានបញ្ជូន ឬផ្ញើជូនជនដែលត្រូវទទួលដីកាសម្រេចនោះ (មាត្រា ៣៦ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង)។

បណ្ដឹងឧបាស្រ័យៈបុគ្គលណាដែលមានសិទ្ធិ ឬផលប្រយោជន៍តាមផ្លូវច្បាប់របស់គាត់អាចត្រូវបានប៉ះពាល់ដោយផ្ទាល់ដោយដីកាសម្រេចដែលបានចេញ អាចដាក់ពាក្យបណ្ដឹងជំទាស់បាន (មាត្រា ៣៧ កថាកណ្ឌទី១ នៃច្បាប់ស្ដីពី នីតិវិធីរឿងក្ដី រដ្ឋប្បវេណីមិនមែនជាបណ្ដឹង)។

រយៈពេលនៃបណ្ដឹងជំទាស់នោះត្រូវធ្វើឡើងក្នុងអំឡុងពេល ពីរសប្ដាហ៍ចាប់ពីពេលទទួលបានលិខិតជូនដំណឹងនៃដីកាសម្រេច (មាត្រា ៣៨ កថាខណ្ឌ១ នៃមិនមែនបណ្ដឹង)។

**ល័ក្ខខ័ណ្ឌឪពុកម្ដាយចិញ្ចឹម**

- បុគ្គលដែលក្លាយជាឪពុកម្ដាយចិញ្ចឹមត្រូវតែមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ ហើយមិនត្រូវជាបច្ឆាញាតិ និងត្រូវមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយកូនសុំ (មាត្រា ១០២០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)

- បុគ្គលដែលក្លាយជាឪពុកម្ដាយ ឬម្ដាយចិញ្ចឹមអាចជាបុគ្គលដែលមានសហព័ទ្ធក៏បាន ឬជាបុគ្គលដែលមិនមានសហព័ទ្ធក៏បានដែរ។

- បុគ្គលដែលមានសហព័ទ្ធ គឺចាំបាត់ត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ទើបអាចដាក់ពាក្យសុំបាន។ នៅក្នុងករណីដែលមានតែសហព័ទ្ធតែម្ខាង ជាអ្នកដាក់ពាក្យនោះកូនសុំមានអានុភាពតែចំពោះអ្នកដែលដាក់ពាក្យសុំតែប៉ុណ្ណោះ។ (នីតិជន)

ចំពោះអនីតិជន បុគ្គលដែលមានសហព័ទ្ធ ហើយមានបំណងចងបានកូនសុំធម្មតា ត្រូវបញ្ញត្តិទៅមាត្រា ១០២១ នៃក្រមរដ្ឋប្បវេណី ដែលតម្រូវអោយសហព័ទ្ធទាំងពីរដាក់ពាក្យសុំដោយសហការគ្នា។ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនអាចបង្ហាញឆន្ទៈបាន ដូចជាករណីមាន ជម្ងឺផ្លែកស្មារតីជាដើម ការដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាអាចធ្វើឡើងដោយសហព័ទ្ធតែម្ខាងបាន។ មាត្រា ២០២២ នៃក្រមរដ្ឋប្បវេណី។

ឪពុកម្ដាយចិញ្ចឹមត្រូវតែមានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងស្មុំកូន។ ដូចនេះបើការតុលាយល់ឃើញថាស្មុំកូនត្រូវបានបំពាន ក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទផ្សេងគ្នា ឬដូចគ្នា ឬក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត។

**ល័ក្ខខ័ណ្ឌរបស់កូនសុំ**

អាយុរបស់កូនសុំ ពុំត្រូវបានកំណត់ឡើយ ប៉ុន្តែបុគ្គលដែលនឹងក្លាយជាកូនសុំ មិនអាចជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ (មាត្រា ១០២០-១-២ ក្រមរដ្ឋប្បវេណី)

ឧទាហរណ៍ ៖ A មានអាយុ ៣០ឆ្នាំ ហើយប្អូនប្រុសពៅរបស់គាត់ឈ្មោះ B មាន អាយុទើបតែ ១៨ ឆ្នាំ។ ទន្ទឹមនឹងនេះ A បានរៀបការ ហើយមានកូនប្រុសម្នាក់ឈ្មោះ C មានអាយុ ២២ឆ្នាំ។

សំណួរ៖ ក្នុងករណីខាងលើ តើ C អាចយក B ធ្វើជាកូនសុំធម្មតាបានដែរឬទេ?

មានអាយុច្រើនជាង B ប៉ុន្តែ C និង B មានទំនាក់ទំនងញាតិដោយ C ត្រូវបុព្វញាតិពូរបស់ B ដូចនេះC មានបំណងចងបង្កើតកូនសុំធម្មតាមិនបានឡើយ បើទោះ C អាយុច្រើនផងក៏ដោយ ។

\+ ចំពោះកូនសុំជាអនីតិជន ត្រូវមានការយល់ព្រមពីអ្នកមានអំណាចមេបា។ ព្រោះគឺត្រូវគិតដល់ផលប្រយោជន៍កូនសុំធម្មតា (មាត្រា ១០២៤ ជាមូលដ្ឋានសំខាន់) ។

បើកូនសុំជាអនីតិជនដែលមានអាយុ ១៥ឆ្នាំឡើងទៅត្រូវមានការយល់ព្រម ពីសំណាក់កូនសុំនោះ (មាត្រា ១០២៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)

-បុគ្គលដែលក្លាយជាកូនសុំ ជានីតិជនមានសិទ្ធិដាក់ពាក្យសុំកូនធម្មតាដោយខ្លួនឯង ហើយតុលាការ និងចេញដីកាសម្រេចអោយបង្កើតទំនាកទំនងញាតិលោហិតជាមួយឪពុកម្តាយចិញ្ចឹម

\+ អានុភាពនៃការសុំកូនបង្កើត ៖ (មាត្រា១០២៦ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី)

- មិនផ្តាច់ចំណងញាតិឪពុកម្តាយបង្កើត
- មានសិទ្ធិទទួលការផ្គត់ផ្គង់អាហារិកិច្ច
- មានសិទ្ធិទាមទារ
- មានសិទ្ធិធ្វើសន្តតិកម្មពីឪពុកម្តាយបង្កើត

រវាងឪពុកម្តាយចិញ្ចឹម (មាត្រា១០២៧ កថាខណ្ឌទី១,២,៣ នៃក្រមរដ្ឋប្ប វេណី)

- ទំនាក់ទំនងញាតិថ្មីជាមួយឪពុកម្តាយចិញ្ចឹម
- មានទំនាក់ទំនងញាតិរបស់ឪពុកម្តាយចិញ្ចឹមជាមួយកូនសុំ
- មានសិទ្ធិដូចជាកូនបង្កើតគឺទទួលបានសន្តតិកម្មពីឪពុកម្តាយចិញ្ចឹម
- កូនសុំអាចប្រើប្រាស់ត្រកូល មុនសុំកូន ឬប្រើប្រាស់ត្រកូលតាមឪពុកម្តាយ ចិញ្ចឹម

- កូនសុំជានីតិជនត្រូវ ស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម (សហព័ទ្ធជាអ្នកដាក់ពាក្យសុំ) ប៉ុន្តែក្នុងករណីមានសហព័ទ្ធម្ខាងណាជាអ្នកពាក្យសុំ ភាគីនោះមានអំណាចមេបាលើកូនសុំ។

+ ការចុះបញ្ជី

- សំរាប់កូនសុំធម្មតា ត្រូវបានបង្កើត ត្រូវសរសេរសុំកូនធម្មតានៅលើ ទំព័រនៃ បញ្ជីកំណើតរបស់កូនសុំនោះ (នៃក្រមរដ្ឋប្បវេណី ១០៣៣មាត្រា)

+ ការកាត់កាល់

**១-ការកាត់កាល់ដោយព្រមព្រៀង**

- កាត់កាល់ដោយព្រមព្រៀង អនុវត្តច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង
- ភាគីទាំងសងខាងនៃសុំកូន ត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅដ្ឋានរបស់កូនសុំ
- ពាក្យសុំដែលធ្វើឡើងដោយកូនសុំ តុលាការមិនពិចារណាទៅលើមូលហេតុ(មាត្រា១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)
- កូនសុំជានីតិជនត្រូវមានអ្នកតំណាងដែលច្បាប់កំណត់ដោយការកាត់កាល់
- កូនសុំមានអាយុ១៥ឆ្នាំ អាចបង្ហាញឆន្ទៈបានត្រូវមានការយល់ព្រមពីកូនសុំ ហើយតុលាការហៅមកសួរ (មាត្រា១០២៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)
- បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ការកាត់កាល់គឺជាឪពុកម្តាយបង្កើត
- ឪពុកម្តាយជាសហព័ទ្ធត្រូវសហការគ្នាក្នុងការការពារអោយសុំកាត់កាល់ ប៉ុន្តែ បើមានសហព័ទ្ធ មិនអាចបង្ហាញឆន្ទៈខ្លួនឯងបាន (មាត្រា១០២៩ នៃក្រមរដ្ឋប្បវេណី) បញ្ហាមានជំងឺធ្ងន់ធ្ងរ មានជំងឺផ្នែកស្មារតី។

ឧទាហរណ៍ A និង B ជាសហព័ទ្ធមាន C ជាកូនចិញ្ចឹមមានអាយុ២០ឆ្នាំ។ C មានទំនាស់ជាមួយឪពុកម្តាយចិញ្ចឹមរបស់ខ្លួន ហើយបានចាកចេញពីលំនៅដ្ឋានរបស់ A និង B ហើយទៅរស់នៅខេត្តសៀមរាប ក្រោយមកឪពុកម្តាយចិញ្ចឹម និងកូនសុំបានពិភាក្សាគ្នាព្រមព្រៀងកាត់កាល់សុំកូនធម្មតា តើ A និង B ជាមួយនឹង C គួរតែដាក់ពាក្យសុំនៅសាលាដំបូងណា ក្នុងករណីនេះឪពុកម្តាយចិញ្ចឹម និងកូនសុំត្រូវបានធ្វើពាក្យកាត់កាល់សុំកូនធម្មតានៅសាលាដំបូងខេត្តសៀមរាប។

**២-កាត់កាល់ដោយបណ្តឹង**

- អនុវត្តច្បាប់ស្តីពីបណ្តឹងឋានៈបុគ្គល និងមាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី។
- ភាគីម្ខាងនៃស្មុំកូនអាចដាក់ពាក្យបណ្តឹងទាមទារកាត់កាល់ស្មុំកូនធម្មតា។
- ក្នុងអំឡុងពេលដែលកូនស្មុំពុំទាន់ដល់នីតិភាព ឪពុកម្តាយមិនអាចដាក់ពាក្យបណ្តឹងកាត់

កាល់បានទេ ប៉ុន្តែកូនសុំអាចទាមទារកាត់កាល់ឪពុកម្តាយចិញ្ចឹមបាន។

- ក្នុងន័យដើម្បីការពារផលប្រយោជន៍របស់នីតិជន ក្រមរដ្ឋប្បវេណីបានធ្វើការហាមឃាត់ដាក់ពាក្យបណ្តឹងទាមទារកាត់កាល់ពីសំណាក់ឪពុកម្តាយចិញ្ចឹម ប្រសិនបើកូនសុំនៅជានីតិជននៅឡើយ (មាត្រា ១០៣១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)

ក្នុងករណីកូនសុំជានីតិជន

| ដើមចោទ | ចុងចម្លើយ | មាត្រា |
|---|---|---|
| ឪពុកម្តាយចិញ្ចឹម | កូនសុំ | ម.១០៣១ កថា១ នៃក.រ<br>ម.៧ កថា១ នៃច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល |
| កូនសុំ | ឪពុកម្តាយចិញ្ចឹម | ម.១០៣១ កថា១ នៃក.រ<br>ម.៧ កថា១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល |

ក្នុងករណីកូនសុំជាអនីតិជន

| ដើមចោទ | ចុងចម្លើយ | មាត្រា |
|---|---|---|
| ឪពុកម្តាយចិញ្ចឹម | ? | ម.១០៣១ កថា១ នៃក.រ |
| បុគ្គលដែលត្រូវក្លាយជា អ្នកតំណាងដែលច្បាប់បានកំណត់ក្រោយពីកាត់កាល់ | ឪពុកម្តាយចិញ្ចឹម | ម.១០៣១ កថា៣ នៃក.រ<br>ម.១០២៨ កថា២,៣,៤ នៃក.រ |

+មូលហេតុនៃការកាត់កាល់សុំកូនធម្មតា

- ភាគីម្ខាងបោះបង់ចោលភាគីម្ខាងមួយទៀតដោយទុច្ចរិត
- មិនច្បាស់ថា ភាគីម្ខាងរស់ ឬស្លាប់ ក្នុងកំឡុងពេលយ៉ាងតិច ០១ឆ្នាំ
- ហេតុធ្ងន់ធ្ងរផ្សេងៗទៀត ដែលពិបាកបន្តទំនាក់ទំនងសុំកូន។

ឧទាហរណ៍ ៖ A និង B បានសុំ C មកធ្វើជាកូនចិញ្ចឹម តាមរយៈសុំកូនធម្មតា នៅពេលដែល C មានអាយុ១៥ឆ្នាំមកម្ល៉េះ។ ហើយបច្ចុប្បន្ន A និង B ក៏មានវ័យចំណាស់ទៅហើយ រីឯ C វិញមានអាយុ២៥ ឆ្នាំទៅហើយ។ ប៉ុន្តែរយៈពេល០៥ឆ្នាំទៅហើយដែល C មិនដែលទៅសួរសុខទុក្ខ A និង B ដែលជាឪពុកម្តាយចិញ្ចឹមឡើយ ហើយក៏មិនដែលទំនុកបំរុងដល់ជីវភាព A និង B ឡើយ។

+អានុភាពទាំងឡាយនៃការសុំកូនធម្មតាត្រូវបញ្ចប់ឆ្ពោះទៅអនាគតដោយការកាត់កាល់។

# អំណាចមេបា

អ្នកដែលមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចត្រូវបីបាច់ថែរក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូននោះរហូតដល់កូនពេញនីតិភាព ហើយការប្រើប្រាស់អំណាចមេបានេះ ត្រូវធ្វើឡើងដោយសហការគ្នា ដែលសិទ្ធិនិងករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបាត្រូវបានចែងនៅក្នុងក្រមរដ្ឋប្បវេណីចាប់ពីមាត្រា ១០៤៣ រហូតដល់មាត្រា ១០៤៧។

ផ្អែកតាមក្រមរដ្ឋប្បវេណីខ្ញុំធ្វើការបែងចែកប្រភេទឬស្ថានភាពនៃអ្នកមានអំណាចមេបាជាបីប្រភេទ ៖

## ១. ករណីឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ ៖

ជាគោលការណ៍ ឪពុកនិងម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ជាអ្នកមានអំណាចមេបា ហើយពួកគេត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ទៅលើការសិក្សាអប់រំកូន ការស្នាក់នៅរបស់កូន ការប្រកបវិជ្ជាជីវៈ និងការដាក់ទណ្ឌកម្មកូន។ ក្នុងករណី ឪពុក ឬម្តាយណាម្ខាងមិនអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬម្តាយម្ខាងទៀត ត្រូវប្រើប្រាស់អំណាចមេបានោះទាំងស្រុង (មាត្រា ១០៣៦ នៃក.រ)។

## ២. ករណីឪពុកម្តាយលែងលះគ្នា ៖

គូភាគីនៃការលែងលះ អាចពិភាក្សាគ្នាកំណត់អំពីថា អ្នកណាមានអំណាចមេបា (ឪពុក ឬ ម្តាយ) ក្រោយពីមានការព្រមព្រៀងគ្នារួចហើយ ត្រូវដាក់ពាក្យស្នើសុំឲ្យតុលាការទទួលស្គាល់ពាក្យស្នើសុំនេះ (មាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក.រ, មាត្រា ៩៧៩ នៃក.រ, ឧបសម្ព័ន្ធ ចំណុច ៤ និង ៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប៉ុន្តែក្នុងករណីគូភាគីមិនមានការឯកភាពគ្នាទេលើអ្នកដែលមានអំណាចមេបា នោះតុលាការត្រូវធ្វើការកំណត់អ្នកមានអំណាចមេបា ដោយពិចារណាលើប្រយោជន៍របស់កូន (មាត្រា ១០៣៧ កថាខណ្ឌទី ៣ នៃក.រ, មាត្រា ២២ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

ប្រសិនបើការលែងលះនេះកើតមានមុនកំណើតកូន ម្តាយគឺជាអ្នកមានអំណាចមេបាលើកូនកើតមកនោះ តែក្រោយកំណើតកូនឪពុកម្តាយអាចពិភាក្សាគ្នាកំណត់យកឪពុកជាអ្នកមានអំណាចមេបាលើកូនក៏បាន (មាត្រា ១០៣៧ កថាខណ្ឌទី ២ នៃក.រ)។

### ៣. ករណីឪពុកម្ដាយមិនបានរៀបអាពាហ៍ពិពាហ៍ ៖

តាមក្រមរដ្ឋប្បវេណី មាត្រា ១០៣៨ អ្នកមានអំណាចមេបាលើកូនដែលម្ដាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍ ហើយបានបង្កើតកូននោះអ្នកមានអំណាចមេបាគឺម្ដាយ។ យើងអាចចោទជាសំណួរថា ហេតុអ្វីបានជាត្រូវកំណត់បែបនេះ ព្រោះថាយើងមិនអាចកំណត់បានថា អ្នកណាជាឪពុករបស់ក្មេងដែលបានកើតមកពិតប្រាកដបាន ដូច្នេះវាជាសត្យានុម័តក្មេងដែលកើតពីផ្ទៃម្ដាយនោះជាអ្នកមានអំណាចមេបា។ ក្នុងករណីមានការទាមទារថា ឪពុកមានអំណាចមេបាលើកូនដែលកើតមកនោះ លុះត្រាតែឪពុកដាក់ពាក្យស្នើសុំទទួលស្គាល់កូន (ការស្នើសុំទទួលស្គាល់បិតុភាព)។

ក្រោយពីកំណត់ថាអ្នកណាមានអំណាចមេបារួចហើយ តាមរយៈការពិភាក្សាគ្នា ឬតាមការសម្រេចរបស់តុលាការ អ្នកដែលគ្មានអំណាចមេបា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយចំណាយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ការចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន ត្រូវមានការពិភាក្សាព្រមព្រៀងគ្នារវាងឪពុកនិងម្ដាយ ហើយក្នុងករណីមិនមានការព្រមព្រៀងគ្នាទេ តុលាការត្រូវសម្រេចកំណត់អំពីរបៀបនៃការចូលជួបប្រាស្រ័យទាក់ទងគ្នានេះ ដើម្បីជៀសវាងការបាត់បង់ផលប្រយោជន៍ចាំបាច់របស់កូន (មាត្រា ១០៤០ កថាខណ្ឌទី ៣ និងទី ៤ នៃក.រ)។

អ្នកដែលគ្មានអំណាចមេបា អាចទាមទារឲ្យអ្នកដែលមានអំណាចមេបារាយការណ៍អំពីស្ថានភាពរបស់កូន។ ការរាយការណ៍នេះ ត្រូវមានការព្រមព្រៀងគ្នា ហើយបើគ្មានការព្រមព្រៀងគ្នាទេគឺតុលាការជាអ្នកកំណត់អំពីរបៀបនៃការរាយការណ៍ និងខ្លឹមសាររបស់វា (មាត្រា ១០៤១ នៃក.រ)។

ខាងក្រោមនេះជាតារាងសង្ខេបពីអ្នកមានអំណាចមេបា ទៅតាមករណីនីមួយៗដូចខាងក្រោម ៖

| **ឪពុកម្ដាយរៀបអាពាហ៍ពិពាហ៍** | |
|---|---|
| ឪពុកម្ដាយនៅមានចំណងអាពាហ៍ពិពាហ៍ | ឪពុកនិងម្ដាយ ជាអ្នកមានអំណាចមេបា ហើយអំណាចមេបាត្រូវប្រើប្រាស់រួមគ្នា និងដោយសហការគ្នា (មាត្រា ១០៣៦ នៃក.រ)។ |
| ឪពុកម្ដាយមានចំណងអាពាហ៍ពិពាហ៍ តែឪពុកបានកំពុងបាត់ខ្លួនអស់រយៈពេលច្រើនឆ្នាំ (ពុំមានការប្រកាសអំពីការបាត់ខ្លួនទេ) | ឪពុកនិងម្ដាយជាអ្នកមានអំណាចមេបា ប៉ុន្តែម្ដាយអាចអនុវត្តអំណាចមេបាតែម្នាក់ឯងបាន (មាត្រា ១០៣៦ នៃក.រ)។ |

| | |
|---|---|
| ឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ តែឪពុកស្ថិតក្រោមអាណាព្យាបាល | ឪពុកនិងម្តាយជាអ្នកមានអំណាចមេបា ប៉ុន្តែម្តាយអាចអនុវត្តអំណាចមេបាតែម្នាក់ឯងបាន (មាត្រា ១០៣៦ នៃក.រ)។ |
| ឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ តែម្តាយស្ថិតនៅក្រោមអាយុ ១៦ ឆ្នាំ | ឪពុកនិងម្តាយជាអ្នកមានអំណាចមេបា ប៉ុន្តែម្តាយអាចអនុវត្តអំណាចមេបាតែម្នាក់ឯងបាន (មាត្រា ១០៣៦ នៃក.រ)។ ម្តាយត្រូវបានចាត់ទុកថាបានដល់នីតិភាព (មាត្រា ២២ នៃក.រ)។ |
| ឪពុក ឬ ម្តាយ បានទទួលមរណភាព | អ្នកមានអំណាចមេបាគឺ ឪពុក ឬម្តាយដែលនៅរស់ |
| ទាំងឪពុកនិងម្តាយបានទទួលមរណភាព | គ្មានអ្នកមានអំណាចមេបា របបអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើម (មាត្រា ១០៦៧ នៃក.រ)។ |
| **ករណីលែងលះ** | |
| ឪពុកម្តាយបានលែងលះគ្នាមុនកំណើតកូន | អ្នកមានអំណាចមេបា គឺម្តាយដែលអាចត្រូវបានផ្លាស់ប្តូរទៅឪពុកតាមរយៈការពិភាក្សា ឬតាមរយៈដីកាសម្រេចរបស់តុលាការ (មាត្រា ១០៣៧ កថាខណ្ឌទី ២ និងទី ៣ នៃក.រ)។ |
| ឪពុកម្តាយបានលែងលះគ្នាក្រោយកំណើតកូន | អ្នកមានអំណាចមេបា គឺផ្អែកតាមការពិភាក្សាគ្នា ក្នុងករណីមិនអាចពិភាក្សាគ្នាបាន តុលាការត្រូវសម្រេចដោយគិតអំពីផលប្រយោជន៍កូន (មាត្រា ១០៣៧ កថាខណ្ឌទី ១ និងទី ៣ នៃក.រ, មាត្រា ២២ កថាខណ្ឌទី ១ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ |

| **ករណីឪពុកម្តាយមិនបានរៀបអាពាហ៍ពិពាហ៍** | |
|---|---|
| ឪពុកមិនទទួលស្គាល់កូន ហើយមិនទាន់រៀបអាពាហ៍ពិពាហ៍ | អ្នកមានអំណាចមេបាលើកូនគឺ ម្តាយ (មាត្រា ១០៣៨ កថាខណ្ឌទី ១ នៃក.រ)។ |
| ឪពុកមិនទទួលស្គាល់កូន ហើយបានរៀបអាពាហ៍ពិពាហ៍ | អ្នកមានអំណាចមេបាលើកូនគឺម្តាយ (មាត្រា ១០៣៨ កថាខណ្ឌទី ១ នៃក.រ)។ |
| ឪពុកបានទទួលស្គាល់កូន ហើយឪពុកម្តាយមិនទាន់រៀបអាពាហ៍ពិពាហ៍ | អ្នកមានអំណាចមេបា គឺម្តាយដែលអាចត្រូវបានផ្លាស់ប្តូរទៅឪពុកផ្អែកតាមការពិភាក្សាគ្នា ក្នុងករណីមិនអាចពិភាក្សាគ្នាបាន តុលាការត្រូវសម្រេចដោយគិតពីផលប្រយោជន៍កូន (មាត្រា ១០៣៨ កថាខណ្ឌទី ១ ទី២ និងទី៣ នៃក.រ)។ |
| ឪពុកបានទទួលស្គាល់កូន ហើយឪពុកម្តាយបានរៀបអាពាហ៍ពិពាហ៍ | អ្នកមានអំណាចមេបាលើកូន គឺឪពុកនិងម្តាយ ហើយពួកគេត្រូវអនុវត្តអំណាចមេបាដោយសហការគ្នា (មាត្រា ១០៣៨ កថាខណ្ឌទី ៤ នៃក.រ)។ |

**ករណីមានការព្យួរ ឬដកហូតអំណាចមេបា ៖** ឪពុក ឬម្តាយដែលបានអនុវត្តអំណាចមេបាដោយបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬមានការធ្វេសប្រហែសក្នុងការបំពេញករណីកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា នោះតុលាការអាចប្រកាសព្យួរ ឬដកហូតអំណាចមេបាបានតាមការទាមទាររបស់ញាតិក្នុង ៤ថ្នាក់របស់កូន មេឃុំ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខមាលភាពកុមារ ឬតំណាងអយ្យការ (មាត្រា ១០៤៨)។

ប្រសិនបើការព្យួរ ឬការដកហូតអំណាចមេបាបានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសព្យួរ ឬការដកហូតសិទ្ធិអំណាចក្នុងនាមអ្នកមានអំណាចមេបា តាមការទាមទាររបស់សាមីជនដែលបានទទួលការព្យួរ ឬការដកហូតអំណាចមេបានោះ ឬញាតិក្នុងបួនថ្នាក់របស់ជននោះ (មាត្រា ១០៤៩)។

បើមានមូលហេតុដែលមិនអាចជៀសវាងបាន ឪពុក ឬម្ដាយដែលមានអំណាចមេបា អាចលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាបាន ដោយត្រូវដាក់ពាក្យសុំទៅតុលាការ។ ប៉ុន្តែបើមូលហេតុនោះត្រូវបានបញ្ចប់ ឪពុក ឬម្ដាយដែលបានលាឈប់នោះអាចមកទទួល បដិទាននូវអំណាចមេបានោះវិញបាន ដោយត្រូវស្នើសុំទៅតុលាការដូចគ្នាដែរ (មាត្រា ១០៥០)។

ក្នុងករណីឪពុកម្ដាយតែម្ខាងជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ក្នុងស្ថានភាពគ្មានអ្នកមានអំណាចមេបាដោយសារអ្នកមានអំណាចមេបានោះត្រូវបានប្រកាសព្យួរ ដកហូត ឬលាឈប់ ពីការធ្វើជាអ្នកមានអំណាចមេបា នោះតុលាការអាចយកឪពុក ឬម្ដាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន តាមរយៈឆន្ទានុសិទ្ធិ ឬតាមរយៈការដាក់ពាក្យសុំពីឪពុក ឬម្ដាយម្ខាងទៀត ឬញាតិក្នុងបួនថ្នាក់របស់កូន។

បញ្ហាមួយចំនួនដែលតែងតែកើតមានឡើងក្នុងការអនុវត្ត គឺការទាមទារឲ្យប្រគល់កូនដែលមានចែងក្នុងមាត្រា ១០៤៧ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍ៈ ប្ដីប្រពន្ធលែងលះគ្នា ប្ដីបានដាក់ពាក្យបណ្ដឹងលែងលះគ្នា និងសុំកំណត់អ្នកមានអំណាចមេបាលើកូន ដែលក្នុងពេលបច្ចុប្បន្ននេះ កូនកំពុងបិតនៅក្រោមការគ្រប់គ្រងរបស់ម្ដាយ។ យើងសន្មតថាតុលាការបានសម្រេចអំពីការលែងលះគ្នានេះ និងសម្រេចប្រគល់កូនឲ្យទៅឪពុកជាអ្នកមានអំណាចមេបាលើកូន (មាត្រា ២២ កថាខណ្ឌទី ២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល) តែប្រពន្ធមិនព្រមប្រគល់កូនឲ្យប្ដី។ ក្នុងករណីខាងលើនេះប្ដីអាចដាក់ពាក្យសុំអនុវត្តឲ្យប្រពន្ធប្រគល់កូនឲ្យមកខ្លួន ដោយត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំឲ្យអ្នកដែលពុំមានអំណាចមេបាប្រគល់កូនមកខ្លួនបានតាមមាត្រា ៣៤៩ កថាខណ្ឌ ២ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺការអនុវត្តបង្ខំដោយផ្ទាល់ ឬការអនុវត្តបង្ខំដោយប្រយោល (មាត្រា ៥២៥ និងមាត្រា ៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប៉ុន្តែប្រសិនបើក្នុងសាលក្រមនោះ មិនបានបង្គាប់ឲ្យប្រពន្ធប្រគល់កូនទេ នោះប្ដីត្រូវធ្វើនីតិវិធីបណ្ដឹងថ្មីគឺបណ្ដឹងទាមទារឲ្យប្រគល់កូន តាមមាត្រា១០៤៧ កថាខណ្ឌ ២។

ផ្អែកតាមបណ្ដឹងខាងលើនេះ ដើមបណ្ដឹងអាចដាក់ពាក្យសុំដីកាចាត់ចែងបណ្ដោះអាសន្នចំពោះការប្រគល់កូនមុនពេលចេញសាលក្រមបានដោយផ្អែកតាមមាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណីមាត្រា ៥៣១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី, និងច្បាប់ស្ដីពិនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា២១ កថាខណ្ឌទី១។

# សិក្ខាសាលាគណៈមេធាវី(ធំ)លើកទី៩

## ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ

ថ្ងៃទី ០៧ ឧសភា ២០១៥

# នីតិវិធីអនុវត្តដោយបង្ខំ

## ១. សញ្ញាណទូទៅ

**១.១.អត្ថន័យនៃការអនុវត្តដោយបង្ខំ** ៖ នីតិវិធី ដែលធ្វើឡើងដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិតាមផ្លូវច្បាប់រដ្ឋប្បវេណី គេហៅថា **ការអនុវត្តដោយបង្ខំ**។ នីតិវិធីនេះ មានគោលបំណងសម្រេចចុងក្រោយបង្អស់នូវសិទ្ធិទាមទាររបស់បុគ្គលឯកជន ហេតុនេះ ដំបូងបំផុតត្រូវគិតដល់ការការពារផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ដោយធ្វើយ៉ាងណាឲ្យនីតិវិធីអនុវត្តអាចធ្វើឡើងដោយងាយស្រួល និងបានឆាប់រហ័ស។

**១.២.វិធាននៃការអនុវត្តដោយបង្ខំ** ៖ ការអនុវត្តដោយបង្ខំអាចធ្វើឡើងតាមរយៈការអនុវត្ត ដោយផ្ទាល់ ដោយប្រយោល និងជំនួស។ **ការអនុវត្តដោយផ្ទាល់** ៖ គឺជាមធ្យោបាយសម្រេចតាវកាលិកដោយផ្ទាល់ តាមរយៈស្ថាប័នអនុវត្ត ដើម្បីទទួលបានការសងប្រាក់ ឬការប្រគល់វត្ថុ រីឯ **ការអនុវត្តជំនួស** ៖ គឺជាវិធីអនុញ្ញាតឲ្យម្ចាស់បំណុល ឬតតិយជនសម្រេចខ្លឹមសារនៃតាវកាលិកជំនួសកូនបំណុលនៃការអនុវត្ត ហើយប្រមូលសោហ៊ុយនោះពីកូនបំណុលនៃការអនុវត្តត្រលប់មកវិញ ដូចជា ប្រសិនបើខ្លឹមសារនៃសាលក្រមបង្គាប់ឲ្យកូនបំណុលរុះរើសំណង់ ប៉ុន្តែកូនបំណុលមិនរុះរើ ហេតុនេះ ការអនុវត្តជំនួសនឹងត្រូវបានយកមកអនុវត្ត។

**ការអនុវត្តដោយប្រយោល** ៖ គឺជាមធ្យោបាយគាបសង្កត់ផ្នែកផ្លូវចិត្តទៅលើកូនបំណុលនៃការអនុវត្ត ដើម្បីឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចជា ការបង្គាប់ឲ្យបង់ប្រាក់ ជាអាទិ៍ ហើយវិធាននេះ ច្រើនតែអនុវត្តក្នុងករណី តាវកាលិកដែលមានគោលបំណងឲ្យធ្វើសកម្មភាព ឬមិនឲ្យធ្វើសកម្មភាពអ្វីមួយដែលមិនអាចជំនួសបាន។

**១.៣.ស្ថាប័នអនុវត្ត** ៖ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នមួយហៅថា **ស្ថាប័នអនុវត្ត** ដែលជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ ស្ថាប័ននេះត្រូវបានបែងចែកជាពីរ គឺ **តុលាការអនុវត្ត** និង **អាជ្ញាសាលា**។ ស្ថាប័ននះមានចរិកផ្ទុយគ្នា អាស្រ័យទៅលើកម្មវត្ថុ និងប្រភេទនៃការអនុវត្តដោយបង្ខំ (CCP336-2)។ តុលាការអនុវត្ត គឺជាតុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំទៅលើការលក់អចលនវត្ថុ (CCP418) ការអនុវត្តសិទ្ធិលើបំណុល (CCP403) ការលក់នាវា (CCP455) ជាអាទិ៍។ ចំណែកឯ អាជ្ញាសាលា គឺជាយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានា (CCP246-3)

ដែលចេញដោយតុលាការនិងធ្វើការអនុវត្តដោយបង្ខំដូចជាការប្រគល់ចលនវត្ថុ (CCP525) ការប្រគល់អចលនវត្ថុ (CCP524) ការលក់ចលនវត្ថុ (CCP384) ជាអាទិ៍។ របបអាជ្ញាសាលាត្រូវបានកំណត់ដោយច្បាប់ដោយឡែក (សេចក្តីព្រៀងច្បាប់អាជ្ញាសាលា) ហេតុនេះ បច្ចុប្បន្នគឺព្រះរាជអាជ្ញា (ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា)។

**១.៤.ភាគីនៃការអនុវត្តដោយបង្ខំ** ៖ នៅក្នុងការអនុវត្តដោយបង្ខំ បុគ្គលដែលដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ហៅថា **ម្ចាស់បំណុលនៃការអនុវត្ត** ហើយភាគីម្ខាងទៀតនៃការអនុវត្ត ហៅថា**កូនបំណុលនៃការអនុវត្ត** ដោយរាប់បញ្ចូលទាំងតតិយជន (អ្នកធានាដោយវត្ថុ) ដាក់វត្ថុដើម្បីធានាបំណុលរបស់កូនបំណុលនៅក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគ (CCP347)។

**១.៥.កម្មវត្ថុនៃការអនុវត្តដោយបង្ខំ** ៖ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ត្រូវបានហៅថា **ទ្រព្យសម្បត្តិទទួលខុសត្រូវ**។ ទ្រព្យសម្បត្តិដែលកូនបំណុលត្រូវទទួលខុសត្រូវតាមរយៈការអនុវត្តដោយបង្ខំ គឺជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬទ្រព្យដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនបំណុល ប៉ុន្តែក្នុងករណីការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត គឺជាទ្រព្យដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ។ ជាគោលការណ៍ ទោះបីជាទ្រព្យសម្បត្តិទាំងអស់ដែលជាកម្មសិទ្ធិរបស់កូនបំណុលក្លាយជាទ្រព្យទទួលខុសត្រូវក៏ដោយ ក្នុងករណីមានហេតុផលពិសេស ដូចជា ប្រដាប់ប្រដាស្លៀកពាក់ គ្រឿងបរិភោគ ប្រាក់បៀវត្សរ៍ ឬប្រាក់ឈ្នួលជាអាទិ៍ ដែលជាទ្រព្យសម្បត្តិច្បាប់ហាមឃាត់មិនឲ្យរឹបអូស (CCP280&CCP382)។ ម្យ៉ាងវិញទៀតចំពោះទ្រព្យសម្បត្តិដែលកូនបំណុលនៃការអនុវត្តបានធ្វើអនុប្បទានដោយស្របច្បាប់ និងអនុប្បទានិកមានល័ក្ខខ័ណ្ឌតតាំង នឹងការអនុវត្តដោយបង្ខំ នាំឲ្យទ្រព្យនោះមិនមែនជាទ្រព្យទទួលខុសត្រូវរបស់កូនបំណុលនៃការអនុវត្តនោះទេ លើកលែងតែកូនបំណុលនៃការអនុវត្តអនុប្បទានទ្រព្យសម្បត្តិរបស់ខ្លួនដោយដឹងថា អនុប្បទាននោះ នាំឲ្យខូចខាតដល់ម្ចាស់បំណុលនៃការអនុវត្ត។ ករណីនេះ ម្ចាស់បំណុលនៃការអនុវត្ត អាចលុបចោលអនុប្បទាននោះបាន ដើម្បីធ្វើបដិទាននូវទ្រព្យ ទទួលខុសត្រូវ និងដាក់ទ្រព្យនោះជាកម្មវត្ថុនៃការទទួលខុសត្រូវ តាមរយៈសិទ្ធិលុបចោលនូវអំពើនាំឲ្យខូចប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត (CC428)។

ទ្រព្យសម្បត្តិដែលត្រូវទទួលខុសត្រូវ ត្រូវបានកម្រិតនៅក្នុងទំហំមួយជាក់លាក់ ហើយការអនុវត្តដោយបង្ខំ មិនអាចធ្វើទៅបានចំពោះទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្តនោះទេ ដូចជា

សន្តតិជនរបស់កូនបំណុលនៃការអនុវត្តយល់ព្រមដោយមានកម្រិតចំពោះសន្តតិកម្ម នាំឲ្យការទទួលខុសត្រូវ ត្រឹមទំហំនៃមតិក (CC1256 &CC1258)។

**១.៦.ឧបទ្ទវហេតុនៃការអនុវត្ត ៖**

**បណ្ដឹងជំទាស់** ៖ ការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ត្រូវបានធ្វើឡើងក្រោមទម្រង់ជាការសម្រេចសេចក្ដី ដោយចេញដីកាសម្រេច (CCP337-1)។ នៅក្នុងការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត បើដីកាសម្រេចបំពានទៅលើក្រមនីតិវិធី ឬផ្ទុយច្បាប់ វិធីឧបាស្រ័យចំពោះដីកាសម្រេចនេះ គឺតាមរយៈបណ្ដឹងជំទាស់ ប៉ុន្តែបណ្ដឹងជំទាស់អាចធ្វើទៅបានលុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ ហេតុនេះ បណ្ដឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំអាចធ្វើបាន ក្នុងករណីដែលមានបញ្ញត្តិជាក់លាក់នៅក្នុងមាត្រានីមួយៗដែរ ដូចជា មាត្រា **៤០៣ កថាខណ្ឌទី១១ ៤១៩ កថាខណ្ឌទី៣ ៤៤៤ កថាខណ្ឌទី១** ជាអាទិ៍។ ជាគោលការណ៍ បណ្ដឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម (CCP305) ប៉ុន្តែទោះបីជាមានបញ្ញត្តិបែបនេះក៏ដោយ ក្នុងនីតិវិធីអនុវត្តដោយបង្ខំ បើគ្រាន់តែមានបណ្ដឹងជំទាស់មិនផ្អាកអានុភាពនៃដីកាសម្រេចដើមនោះទេ (CCP343-1)។ ប៉ុន្តែមានករណីខ្លះ ដែលគ្មានប្រយោជន៍ក្នុងការជួយដល់ភាគីដែលធ្វើបណ្ដឹង ហេតុនេះ តុលាការអាចសម្រួលដោយចេញដីកាសម្រេចជា បណ្ដោះអាសន្ន ដើម្បីផ្អាកការអនុវត្ត ដូចជាដីកាសម្រេចបង្គាប់ឲ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយឲ្យដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគ និងដីកាសម្រេចបង្គាប់ឲ្យផ្អាកនីតិវិធីអនុវត្តដោយបង្ខំមួយផ្នែក ឬទាំងមូល ដោយឲ្យដាក់ប្រាតិភោគ ឬមិនដាក់ប្រតិភោគ រហូតចេញសេចក្ដីសម្រេចអំពីបណ្ដឹងនោះ(CCP343-2)។ បណ្ដឹងជំទាស់ ជាការប្រឆាំងនឹងដីកាសម្រេចលុបចោល ជាអាទិ៍ និងដីកាសម្រេចនានារបស់តុលាការអនុវត្ត ដែលច្បាប់អនុញ្ញាតឲ្យប្ដឹងជំទាស់ (CCP345)។

**ការតវ៉ាចំពោះការអនុវត្ត** ៖ គឺជាឧបាស្រ័យដែលមានភាពងាយស្រួល និងឆាប់រហ័សជាងការដាក់ពាក្យបណ្ដឹងជំទាស់ ហើយយកមូលហេតុថា ស្ថាប័នអនុវត្តបានបំពានទៅលើបញ្ញត្តិនៃនីតិវិធី ដែលខ្លួនត្រូវពិនិត្យ និងគោរពតាម។ ការតវ៉ាចំពោះការអនុវត្ត អាចធ្វើបានចំពោះ ទី១ ការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្ដឹងជំទាស់បាន ទី២ ការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និងការយឺតយ៉ាវ ឬធ្វេសប្រហែស ក្នុងការចាត់ចែងការអនុវត្ត (CCP344-2)។ ការតវ៉ាចំពោះការអនុវត្ត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ទៅតុលាការអនុវត្តដែលពាក់ព័ន្ធ ប៉ុន្តែប្រសិនបើ ការតវ៉ាចំពោះការអនុវត្តធ្វើឡើង ចំពោះការចាត់ចែងរបស់អាជ្ញាសាលាអាចតវ៉ាទៅសាលាដំបូង ដែលអាជ្ញាសាលានោះស្ថិតនៅ។ តុលាការអនុវតឬសាលាដំបូងធ្វើការសម្រេចសេចក្ដីអំពីការតវ៉ាចំពោះការអនុវត្តដោយដីកាសម្រេច។ ក្នុង

ករណី តុលាការអនុវត្ត ឬសាលាដំបូងយល់ឃើញថា ការតវ៉ាចំពោះការអនុវត្តផ្ទុយនឹងច្បាប់ ឬពុំមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញ ដីកាសម្រេចលើកចោលពាក្យសុំតវ៉ានោះ។ ផ្ទុយទៅវិញ បើការតវ៉ាចំពោះការអនុវត្តមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តនោះ ឬបង្គាប់ឲ្យអាជ្ញាសាលាលុបចោលការ ចាត់ចែងការអនុវត្ត ឬហាមឃាត់ការអនុវត្ត បើការចាត់ចែងនោះធ្វើឡើងដោយអាជ្ញាសាលា។ ដីកាសម្រេចរបស់ តុលាការអនុវត្ត ដែលលុបចោលនីតិវិធីអនុវត្តដោយបង្ខំ ដីកាសម្រេចរបស់សាលាដំបូងដែលបង្គាប់ឲ្យអាជ្ញាសាលាលុបចោលនីតិវិធីអនុវត្តដោយបង្ខំ និងដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីអនុវត្តដោយបង្ខំ អាចប្តឹងជំទាស់បាន (CCP345-2)។

ទោះបីជាស្ថិតនៅដំណាក់កាលនៃការអនុវត្តដោយបង្ខំក៏ដោយ ច្បាប់ទទួលស្គាល់ការធ្វើបណ្តឹងរបស់ភាគី ដែលសិទ្ធិរបស់ខ្លួនត្រូវបានបំពាន ដោយការអនុវត្តដោយបង្ខំដែលផ្អែកលើលិខិតអនុវត្តជាមូលដ្ឋាន ហើយបណ្តឹងពាក់ព័ន្ធនឹងការអនុវត្ត មានគោលបំណងឲ្យតុលាការវិនិច្ឆ័យតាមនីតិវិធីបណ្តឹង និងដកចេញនូវការអនុវត្តដោយបង្ខំ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី បណ្តឹងពាក់ព័ន្ធនឹងការអនុវត្ត រួមមានបណ្តឹងតវ៉ាចំពោះការទាមទារ បណ្តឹងតវ៉ា ចំពោះតតិយជន និងបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត។

**បណ្តឹងតវ៉ាចំពោះការទាមទារ** ៖ ជាបណ្តឹងដែលមាន គោលបំណងបញ្ជាក់ច្បាស់ដោយយោងតាមនីតិវិធីបណ្តឹងថា ការអនុវត្តដោយបង្ខំមិនត្រូវបានអនុញ្ញាតដោយផ្អែកលើលិខិតអនុវត្តដែលកំណត់។ បណ្តឹងនេះធ្វើឡើងដោយកូនបំណុលនៃការអនុវត្តដោយផ្អែកលើមូលដ្ឋានទាក់ទងនឹងអត្ថិភាព ឬនត្ថិភាព ឬអត្ថន័យនៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ដូចជា ករណីសិទ្ធិទាមទារបានរលត់ដោយការសង ការទូទាត់ នវកម្ម ការលើកលែង ការរំលាយកិច្ចសន្យា ឬការលុបចោលកិច្ចសន្យា (CCP363-1)។ បណ្តឹងនេះអាចធ្វើបានទាក់ទងនឹងប្រភេទនៃលិខិតអនុវត្តទាំងអស់បាន ប៉ុន្តែ មូលហេតុនៃការតវ៉ាទាក់ទងនឹងសាលក្រម ឬ សាលដីកាស្ថាពរនេះ ត្រូវបានកម្រិតត្រឹមតែហេតុដែលកើតឡើងនៅក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់តាម មាត្រា ១៩៤ កថាខណ្ឌទី២ (CCP363-2)។

បណ្តឹងតវ៉ាចំពោះការទាមទារ អាចធ្វើឡើងបានក្នុងករណីដែលមានវិវាទអំពីអត្ថិភាព និងអត្ថន័យនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តប៉ុន្តែចំពោះសិទ្ធិទាមទារដែលបានបញ្ជាក់នៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន និងនៅក្នុងដីកា សម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន បណ្តឹងនេះមិនអាចធ្វើបានទេ បើលិខិតអនុវត្តនោះមិនទាន់ចូលជាស្ថាពរ (CCP363-1-2)។

ការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ មិនរារាំងដល់ការចាប់ផ្ដើម ឬការបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធនោះទេ ប៉ុន្តែប្រសិនបើមានបង្កាន់ដៃទទួលការសង ឬលិខិតពន្យាពេលសង ដែលម្ចាស់បំណុលបានធ្វើឡើងនៅក្រោយពេលបង្កើតលិខិតអនុវត្ត នោះកូនបំណុលអាចទាមទារឲ្យផ្អាកការអនុវត្តដោយបង្ខំដោយដាក់ឯកសារទាំងនោះទៅស្ថាប័នអនុវត្ត (CCP370-2-b)។ ម្យ៉ាងវិញទៀត ដើម្បីរារាំងនូវអានុភាពនៃការអនុវត្តនេះ ប្រសិនបើមានសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវអះអាង តុលាការដែលធ្វើការសម្រេចអំពីបណ្ដឹងតវ៉ាចំពោះការទាមទារ អាចបង្គាប់ឲ្យធ្វើការចាត់ចែងមួយរយៈ ដូចជាការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬព្រមជាមួយគ្នានោះ លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ តាមពាក្យសុំដោយដីកាសម្រេចរហូតដល់ចេញសាលក្រមចុងក្រោយអំពីបណ្ដឹងតវ៉ាចំពោះការទាមទារ (CCP367-1)។ ក្នុងករណីកូនបំណុលអាចទទួលបានការផ្អាក ឬការលុបចោល ជាអាទិ៍ នូវនីតិវិធីនៃការអនុវត្តដោយបង្ខំ ដោយដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចទៅស្ថាប័នអនុវត្ត (CCP370-1-g ;2-a)។

ការវិនិច្ឆ័យទៅលើបណ្ដឹងតវ៉ាចំពោះការទាមទារ ត្រូវធ្វើឡើងតាមនីតិវិធីបណ្ដឹងក្នុងករណីនេះ កូនបំណុលត្រូវអះអាង និងផ្ដល់ភស្តុតាងអំពីការរលត់នូវសិទ្ធិទាមទារឲ្យផ្ដល់តាវកាលិកដែលជាហេតុកើតឡើងក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (CCP363-2) ។ បើការទាមទារនោះត្រឹមត្រូវ តុលាការត្រូវធ្វើសេចក្ដីសម្រេច ឬ ចេញសាលក្រម ឬសាលដីកាចុងក្រោយ ជាអាទិ៍ ដោយធ្វើការប្រកាសនូវសេចក្ដីបញ្ចប់ នៃសាលក្រម ឬសាលដីកានោះ មិនអនុញ្ញាតឲ្យមានការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធ។ ប្រសិនបើកូនបំណុលនៃការអនុវត្តបានដាក់សាលក្រម ឬសាលដីកាជាអាទិ៍ទៅតុលាការអនុវត្ត នោះតុលាការអនុវត្តត្រូវផ្អាកការអនុវត្តដោយបង្ខំ និងលុបចោលការចាត់ចែងការអនុវត្ត (មាត្រា៣៧០ កថាខណ្ឌទី ១ ចំណុច ខ ក.ន.រ)។ ប៉ុន្តែ បើពុំមានហេតុផលត្រឹមត្រូវទេ តុលាការត្រូវចេញសាលក្រម ឬសាលដីកាចុងក្រោយច្រានចោលការទាមទារ ក្នុងករណីនេះ ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលពាក់ព័ន្ធត្រូវបានអនុញ្ញាត។

**បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត** ៖ ធ្វើឡើងក្នុងគោលបំណងឲ្យកូនបំណុលនៃការអនុវត្តទាមទារកុំឲ្យ ធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ពិសេស ដោយអះអាង អំពីនត្ថិភាពនៃហេតុដែលត្រូវនឹងល័ក្ខខ័ណ្ឌនៃការផ្ដល់រូបមន្តអនុវត្ត ដោយយកម្ចាស់បំណុល នៃការអនុវត្តធ្វើជាចុងចម្លើយ។ ប្រសិនបើ ទទួលស្គាល់ការទាមទាររបស់កូនបំណុលនៃការអនុវត្ត តុលាការត្រូវប្រកាសនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមចុងក្រោយថា មិនអនុញ្ញាតឲ្យធ្វើការអនុវត្តដោយបង្ខំ ដោយ ផ្អែកលើលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្តនោះ

(CCP364-1)។ ប្រសិនបើកូនបំណុលនៃការអនុវត្តបានដាក់សាលក្រម ឬ សាលដីកា ជាអាទ៍ ទៅតុលាការអនុវត្ត នោះតុលាការអនុវត្តត្រូវផ្អាកការអនុវត្តដោយបង្ខំ និងលុបចោលការចាត់ចែងការអនុវត្ត (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ ក.ន.រ)។

**បណ្ដឹងតវ៉ារបស់តតិយជន** ៖ ជាបណ្ដឹងដែលតតិយជនប្ដឹងប្រឆាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ដោយអះអាងថាកម្មវត្ថុនៃការអនុវត្ត មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវ របស់កូនបំណុលនៃការអនុវត្តនោះទេ ហើយទាមទារឲ្យដកចេញនូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិនោះ(CCP365-1)។

ការដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន មិនផ្អាកដោយស្វ័យប្រវត្តិនូវការអនុវត្តដោយបង្ខំទេ ហើយការ មិនរារាំងការបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំដែរ ប៉ុន្តែប្រសិនបើ តតិយជនដែលជាដើមចោទនៃបណ្ដឹងធ្វើ សេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃការតវ៉ា នោះតុលាការអាចបង្គាប់ឲ្យធ្វើការចាត់ចែងមួយរយៈ ដូចជាការផ្អាក មួយរយៈនូវការអនុវត្តដោយបង្ខំ ឬលុបចោលនូវការចាត់ចែងដែលបានធ្វើរួចហើយ (CCP 367)។

ប្រសិនបើ តុលាការយល់ឃើញថា ការតវ៉ាមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញសាលក្រមឬសាលដីកាដែលប្រកាសថា ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុនោះត្រូវហាមឃាត់។ ប្រសិនបើកូនបំណុលនៃការអនុវត្តបានដាក់សាលក្រម ឬ សាលដីកា ជាអាទ៍ ទៅតុលាការអនុវត្ត នោះតុលាការអនុវត្តត្រូវផ្អាកការអនុវត្តដោយបង្ខំ និងលុបចោលការចាត់ចែងការអនុវត្ត (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ ក.ន.រ)។ ប៉ុន្តែប្រសិនបើយល់ឃើញថា ការតវ៉ានោះគ្មានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញសាលក្រមច្រានចោលការទាមទារ។

**១.៧.ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ** ៖ ដើម្បីធ្វើការអនុវត្តដោយបង្ខំត្រូវបំពេញល័ក្ខខ័ណ្ឌ

- ពាក្យសុំអនុវត្តដោយបង្ខំ(CCP349)
- ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត (CCP350, 354)
- អត្តសញ្ញាណទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលនៃការអនុវត្ត

**១.៨.សោហ៊ុយសម្រាប់ការអនុវត្តដោយបង្ខំ** ៖ ជាការចំណាយដែលត្រូវធ្វើឡើងដោយ

ស្ថាប័នអនុវត្ត និងភាគីដែលជាសេចក្ដីត្រូវការសម្រាប់ការអនុវត្តដោយបង្ខំ។ ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់សោហ៊ុយនៃការអនុវត្តជាមុន (CCP 375) ហើយនឹងទទួលបានមកវិញ នៅពេលចប់នីតិវិធីដោយកូនបំណុលនៃការអនុវត្តជាអ្នកទទួលបន្ទុក (CCP 376) ដែលមានលក្ខណៈស្រដៀងគ្នានឹងភាគីចាញ់ក្ដីត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដីនៃនីតិវិធីបណ្ដឹងផងដែរ។ សោហ៊ុយសម្រាប់ការអនុវត្ត ដូចជា ទី១

**ពន្ធដាក់ពាក្យសុំ** ត្រូវបង់ចំនួន ១០,០០០ (មួយម៉ឺន) រៀល នៅពេលដាក់ពាក្យសុំទៅតុលាការអនុវត្ត (មាត្រា៣៧២ កថាខណ្ឌទី ១) ប្រសិនបើដាក់ទៅអាជ្ញាសាលា ត្រូវបង់ពន្ធតាមការកំណត់ផ្សេង។ ទី២ **សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ** (មាត្រា ៣៧៣) ដូចជាចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការក្នុងការបញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេងៗដើម្បីនីតិវិធីអនុវត្តដោយបង្ខំ ដូចជា សោហ៊ុយរបស់អ្នកវាយតម្លៃអចលនវត្ថុ ជាអាទិ៍។ ទី៣ **សោហ៊ុយភាគី** (មាត្រា ៣៧៤) គឺជាសោហ៊ុយដែលតុលាការកំណត់ថាចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ដូចជា សោហ៊ុយសម្រាប់ដាក់ឯកសារ សោហ៊ុយធ្វើដំណើររបស់ម្ចាស់បំណុលនៃការអនុវត្តសោហ៊ុយសម្រាប់ការចុះបញ្ជី ឬសោហ៊ុយសម្រាប់ទទួលបានឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី ជាអាទិ៍។

១.៩.**ប្រភេទផ្សេងៗនៃការអនុវត្តដោយបង្ខំ** ៖ ការអនុវត្តដោយបង្ខំត្រូវបានបែងចែកជា ០៣ ប្រភេទ គឺទី១ ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ (CCP379 ដល់ CCP495) **ទី២** ការអនុវត្តសិទ្ធិប្រាតិភោគ (CCP496 ដល់ CCP523) **ទី៣** ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឲ្យសងជាប្រាក់ (CCP524 ដល់ CCP529)។

# ២. អនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ចំពោះចលនវត្ថុ

## ២.១. ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ អាចធ្វើទៅបានលុះត្រាតែមាន ៖

- **លិខិតអនុវត្ត** ( កំណត់ក្នុងមាត្រា៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធី ឬ មាត្រា ៤៩៦ ក្រមនីតិវិធី ក្នុងករណីអនុវត្តសិទ្ធិប្រាតិភោគ)
- **ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយជាមួយរូបមន្តអនុវត្ត** (កំណត់ក្នុងមាត្រា ៣៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធី)

## ២.២.នីតិវិធីក្នុងការសុំអនុវត្ត

### ក. អំពីពាក្យសុំ

បន្ទាប់ពីម្ចាស់បំណុលនៃការអនុវត្តទទួលបាន **លិខិតអនុវត្ត** ណាមួយដែលបានកំណត់ ក្នុង(មាត្រា៣៥០នៃក្រមនីតិវិធី)ហើយ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំឲ្យផ្តល់ **រូបមន្តអនុវត្ត** ទៅតុលាការដែលចេញលិខិតអនុវត្តនោះ (មាត្រា៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក្រមនីតិវិធី)។ លើកលែងតែ **លិខិតអនុវត្ត** ដែលកំណត់ក្នុងចំណុច **ច** កថាខណ្ឌទី២ នៃ មាត្រា៣៥០ នៃក្រមនីតិវិធី ដែលត្រូវផ្តល់ដោយសារការី ដែលរក្សាទុកនូវលិខិតដើមនោះ (មាត្រា៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី២ ក្រមនីតិវិធី)។

ក្រោយពីទទួលបានលិខិតរូបមន្តអនុវត្ត ម្ចាស់បំណុល នៃការអនុវត្តត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុមួយទៀត។

## ខ. ពាក្យសុំរូបមន្តអនុវត្ត

**ក្នុងពាក្យសុំត្រូវបញ្ជាក់៖** ១/ពីឈ្មោះ ឬ នាមករណ៍ អាសយដ្ឋានរបស់ម្ចាស់បំណុល នៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត, ឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ២/សញ្ញាណនៃលិខិតអនុវត្ត ៣/ហេតុការណ៍ និងមូលហេតុបើការទាមទារឲ្យផ្តល់រូបមន្ត អនុវត្តនោះធ្វើឡើងតាមបញ្ញត្តិ មាត្រា៣៥៦ (រូបមន្តអនុវត្តពិសេស) ឬ កថាខណ្ឌទី១ នៃមាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ ជាអាទិ៍) មាត្រា៣៥៥ នៃក្រមនីតិវិធី។

## គ. ពាក្យសុំអនុវត្តដោយបង្ខំ

ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរដោយបញ្ជាក់ពី ៖

- ឈ្មោះ ឬនាមករណ៍ អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្តីសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ

"សញ្ញាណនៃទ្រព្យសម្បត្តិ"៖ ប្រសិនបើបានដឹងអាចសរសេរពី ប្រភេទ និងឈ្មោះនៃចលនវត្ថុនោះ ប្រសិនបើមិនបានដឹងសរសេរត្រឹមតែ "ចលនវត្ថុ"។

**ពាក្យសុំអនុវត្តដោយបង្ខំ** ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរពី **ទីកន្លែង ប្រភេទ ឈ្មោះ** នៃចលនវត្ថុដែលត្រូវរឹបអូស (មាត្រា៣៨៤ កថាខណ្ឌទី២ ក្រមនីតិវិធី)។ ជាធម្មតា ទីកន្លែងអាចជាផ្ទះ ឬកន្លែងធ្វើការរបស់កូនបំណុលនៃការអនុវត្ត ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដឹងពីចលនវត្ថុជាក់លាក់ ម្ចាស់បំណុលអាចសរសេរអំពី ឈ្មោះ ទីកន្លែង និងប្រភេទនៃចលនវត្ថុនោះ។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលនៃការអនុវត្តមិនបានដឹងពីទីកន្លែង ប្រភេទ និងឈ្មោះ ចលនវត្ថុ ដែលត្រូវរឹបអូសជាក់លាក់នោះទេ ក្នុងករណីបែបនេះពាក្យសុំត្រូវសរសេរថា "សញ្ញាណ នៃទ្រព្យសម្បត្តិដែលជាគោលដៅ នៃការអនុវត្ត គឺ **ចលនវត្ថុ**", ទីកន្លែងនៃចលនវត្ថុដែលត្រូវរឹបអូស ៖ **ផ្ទះរបស់កូនបំណុល**នៃការអនុវត្ត ដែលស្ថិតនៅ ..."

**ទ្រព្យសម្បត្តិដែលត្រូវអនុវត្តដោយបង្ខំ៖** គឺទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬ ទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រង និងកាន់កាប់ដោយកូនបំណុល។ ករណីមាន ចលនវត្ថុច្រើននៅទីកន្លែងដែលត្រូវរឹបអូស នោះចលនវត្ថុទាំងអស់ជាគោលដៅនៃការអនុវត្ត។

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត សុំឲ្យអនុវត្តដោយបង្ខំតែផ្នែកណាមួយនៃសិទ្ធិ ទាមទារដែលបានសរសេរក្នុងលិខិតអនុវត្តបង្គាប់ឲ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឲ្យអនុវត្តដោយបង្ខំ (មាត្រា ៣៩៩ នៃក្រមនីតិវិធី)។

## ការដាក់ពាក្យសុំអនុវត្ត

- នៅពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត(មាត្រា ៣៩៩ នៃក្រមនីតិវិធី)។
- ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវធ្វើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើ ទីកន្លែងដែលវត្ថុជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅ (មាត្រា៣៨៤ កថាខណ្ឌទី១ នៃក្រមនីតិវិធី)។ ម្ចាស់បំណុលនៃការអនុវត្តអាចសុំឲ្យអនុវត្តលើចលនវត្ថុ និងទីកន្លែងច្រើនក្នុងពាក្យសុំតែមួយបើចលនវត្ថុ និងទីកន្លែង នោះស្ថិតនៅក្នុងដែនសមត្ថកិច្ចតុលាការអនុវត្តតែមួយ ។

## ឃ. សោហ៊ុយសម្រាប់ការអនុវត្ត

ម្ចាស់បំណុលនៃការអនុវត្តត្រូវចំណាយសោហ៊ុយសម្រាប់ការអនុវត្តដូចជា ពន្ធដាក់ពាក្យសុំ (មាត្រា ៣៧២ ក្រមនីតិវិធី ដែលចំនួនដែលត្រូវបង់ត្រូវកំណត់ដោយច្បាប់ស្តីពីអាជ្ញាសាលា ប៉ុន្តែវានៅជាសេចក្តីព្រាងច្បាប់នៅឡើយ។) សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ (មាត្រា ៣៧៣ ក្រមនីតិវិធី) និងសោហ៊ុយភាគី (មាត្រា ៣៧៤ ក្រមនីតិវិធី)។

**សោហ៊ុយសម្រាប់ការអនុវត្តនេះ** ម្ចាស់បំណុលនៃការអនុវត្ត ដែលបានដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ បើម្ចាស់បំណុលនៃការអនុវត្តមិនបានបង់សោហ៊ុយនោះជាមុនទេ តុលាការ អនុវត្តអាចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំ ឬ លុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន។ ចំពោះដីកាសម្រេចលើកចោលនេះអាចប្តឹងជំទាស់បាន(មាត្រា ៣៧៥ នៃក្រមនីតិវិធី)។

**ស្ថាប័នអនុវត្ត ៖** ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការអនុវត្តការអនុវត្តដោយបង្ខំ គឺអាជ្ញា សាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅ (មាត្រា ៣៨៤ នៃក្រមនីតិវិធី)។

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

## ២.៣. ការអនុវត្តដោយបង្ខំ

- ការអនុវត្តដោយបង្ខំអាចផ្ដើមធ្វើទៅបាន លុះត្រាតែ**ឯកសារចម្លងយថាភូត ឬ ឯកសារ ចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្ដីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្ត** នៅពេលចូលជាស្ថាពរ បានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុនរួចហើយ (មាត្រា៣៦០ នៃក្រមនីតិវិធី)។ ប្រសិនបើឯកសារចម្លងយថាភូត ឬ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្តត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តរួចហើយ នោះម្ចាស់បំណុលនៃការ អនុវត្តពុំចាំបាច់ធ្វើការបញ្ជូនម្ដងទៀតនោះទេ ជាពិសេសក្នុងករណីនៃការប្រើអនុសារសាលក្រម ជាលិខិតអនុវត្ត លិខិតអនុវត្តគួរតែត្រូវបានបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្តរួចហើយ ដោយ ពុំចាំបាច់មានពាក្យសុំ (មាត្រា១៩០ ក្រមនីតិវិធី)។

ក្នុងករណីនៃការប្រើឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការផ្សះផ្សា ឬការទទួលស្គាល់ នោះការបញ្ជូនគឺអាស្រ័យទៅលើការអនុវត្តព្រោះពុំមានបញ្ញត្តិដែលចែងពីការបញ្ជូនឲ្យ ទៅកូនបំណុលនៃការអនុវត្តដោយពុំចាំបាច់មានពាក្យសុំ។ ប្រសិនបើនៅមិនទាន់បានបញ្ជូន ទៅឲ្យកូនបំណុលនៃការអនុវត្តទេ នោះម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំបញ្ជូនទៅក្រឡាបញ្ជី ក្នុងករណីនេះ អាជ្ញាសាលាអាចយកឯកសារចម្លងយថាភូត ឬ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ទៅទីកន្លែងនៃចលនវត្ថុដែលត្រូវរឹបអូស និងប្រគល់វាឲ្យទៅកូនបំណុលនៃការអនុវត្តបាន ព្រោះអាជ្ញាសាលាគឺជាស្ថាប័នដែលអនុវត្តការបញ្ជូន (មាត្រា ២៤៧ កថាខណ្ឌទី ៣ ក្រមនីតិវិធី)។ ពាក់ព័ន្ធនឹងការបញ្ជូនដោយអាជ្ញាសាលា សូមមើលប្រកាស។

- បន្ទាប់ពីទទួលបាននូវពាក្យសុំអនុវត្តដោយបង្ខំ អាជ្ញាសាលាត្រូវសម្រេចអំពីកាលបរិច្ឆេទនៃការចុះអនុវត្តរឹបអូស (ក្នុងការអនុវត្តប្រទេសជប៉ុនអាជ្ញាសាលាជូនដំណឹងពីកាលបរិច្ឆេទ នោះ ទៅម្ចាស់បំណុលនៃការអនុវត្ត ព្រោះម្ចាស់បំណុលនៃការអនុវត្តអាចចង់ទៅទីកន្លែងនៃចលនវត្ថុដែលត្រូវរឹបអូសជាមួយនឹងអាជ្ញាសាលា)។ អាជ្ញាសាលាមិនជូនដំណឹងទៅកូនបំណុល នៃការអនុវត្តទេ ព្រោះកូនបំណុលនៃការអនុវត្តអាចលាក់ទុកចលនវត្ថុដែលត្រូវរឹបអូសនោះ។
- នៅពេលចុះទៅដល់កន្លែងអនុវត្តបើជួបកូនបំណុលនៃកាអនុវត្ត អាជ្ញាសាលាត្រូវដាស់ តឿនឲ្យកូនបំណុលនៃការអនុវត្តនោះសងបំណុលដោយស្ម័គ្រចិត្តនៅមុនពេលចាប់ផ្ដើមរឹបអូស អាជ្ញាសាលាអាចទទួលសំណងនៃបំណុល និងសោហ៊ុយសម្រាប់ការអនុវត្តសម្រាប់ម្ចាស់ បំណុលនៃការអនុវត្តបាន (មាត្រា៣៨៤ នៃក្រមនីតិវិធី)។

## ក. ការរឹបអូស

ការអនុវត្តដោយបង្ខំគឺត្រូវចាប់ផ្ដើមដោយការរឹបអូសវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនបំណុលដោយអាជ្ញាសាលា។ អាជ្ញាសាលាអាចចូលទៅទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀតដែល

កូនបំណុលនៃការអនុវត្តកាន់កាប់ដើម្បីធ្វើការឆែកឆេររកចលនវត្ថុដែលត្រូវរឹបអូស ក្នុងករណីចាំបាច់អាជ្ញាសាលាអាចធ្វើការបើកទ្វារដែលបិទ ទូដែក និងប្រអប់ ផ្សេងៗបាន។

ប្រសិនបើចលនវត្ថុដែលត្រូវរឹបអូសនោះ ត្រូវបានកាន់កាប់ដោយម្ចាស់បំណុលនៃការអនុវត្ត(ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តដែលជាកម្មវត្ថុនៃបញ្ញើ ឬសិទ្ធិឃាត់ទុកជាអាទិ៍) ម្ចាស់បំណុលនៃការអនុវត្តអាចប្រគល់វត្ថុនោះដោយស្ម័គ្រចិត្តទៅអាជ្ញាសាលា ដើម្បីធ្វើការរឹបអូស (មាត្រា ៣៨៦ នៃក្រមនីតិវិធី)។

**ជាគោលការណ៍** ការរឹបអូសមិនត្រូវរឹបអូសវត្ថុណាដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ របស់កូនបំណុលនោះទេ (មាត្រា៣៨០ នៃក្រមនីតិវិធី)។ ប្រសិនបើមានចលនវត្ថុដែលអាចរឹបអូសបានច្រើននោះអាជ្ញាសាលាត្រូវជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូសដោយពិចារណាពី ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត (មាត្រា៣៨៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធី)។

ក្រោយពីជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវការចុះបញ្ជីចលនវត្ថុដែលត្រូវរឹបអូស និងបិទស្លាក ឬដាក់សញ្ញានៃការរឹបអូសដោយវិធីផ្សេងទៀត។ អាជ្ញាសាលាអាចរឹបអូសទ្រព្យសម្បត្តិទាំងអស់ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តបាន ដោយពុំចាំបាច់បញ្ជាក់ពីកម្មសិទ្ធិករពិតប្រាកដនៃចលនវត្ថុឡើយ។ ទោះបីជាចលនវត្ថុនោះជាកម្មសិទ្ធិរបស់តតិយជនក៏ដោយ នោះអាជ្ញាសាលាអាចរឹបអូសបាន ឲ្យតែចលនវត្ថុនោះត្រូវបានកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត។ ទោះបីជាកូនបំណុលនៃការអនុវត្តអះអាងថា "នេះមិនមែនជាទ្រព្យសម្បត្តិរបស់ខ្លួនទេ ខ្លួនបានខ្ចីវាពីមិត្តភក្តិទេ" ក៏អាជ្ញាសាលានៅតែអាចរឹបអូសវាបានដែរ។

តតិយជនដែលជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិនោះ អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការ រឹបអូសនោះបាន តាម(មាត្រា៣៦៥ នៃក្រមនីតិវិធី)។

**ការអនុវត្តត្រួតគ្នា** ក្នុងករណីមានពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រួតគ្នា ចំពោះទីកន្លែងរឹបអូសដូចគ្នា អាជ្ញាសាលា នឹងរឹបអូសចលនវត្ថុដែលមិនទាន់បានរឹបអូស ប៉ុន្តែបើគ្មានចលនវត្ថុដែលត្រូវរឹបអូសទេ អាជ្ញាសាលាត្រូវធ្វើការរួមបញ្ចូលរឿងក្តីការអនុវត្តចំពោះចលនវត្ថុថ្មី និងរឿងក្តីអនុវត្តចំពោះចលនវត្ថុមុន ជាមួយគ្នា(មាត្រា៣៨៨ កថាខណ្ឌទី១ នៃក្រម នីតិវិធី)។ មានន័យថា ការរឹបអូសចំពោះរឿងក្តីក្រោយ ត្រូវបានចាត់ទុកថាបានរឹបអូសក្នុងរឿងក្តីមុន នៅពេលរួមបញ្ចូលរឿងក្តី ហើយពាក្យសុំនៃរឿងក្តីក្រោយមានអានុភាពជាការទាមទារឲ្យចែកចំណែក(មាត្រា៣៨៨ កថាខណ្ឌទី២ នៃក្រមនីតិវិធី)។ ម្យ៉ាងវិញទៀត ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តមុន បានដកពាក្យសុំ ឬនីតិវិធីបានចាប់ផ្តើមត្រូវបានផ្អាក ឬ

លុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីមុន ត្រូវចាត់ទុកថាបានរឹបអូសដើម្បីរឿងក្តីក្រោយ (មាត្រា៣៨៨ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធី)។

**ការថែរក្សា និងគ្រប់គ្រងវត្ថុរឹបអូស**

ជាគោលការណ៍ អាជ្ញាសាលាជាអ្នកថែរក្សាចលនវត្ថុដែលបានរឹបអូសនោះដោយខ្លួនឯង (មាត្រា ៣៨៥ កថាខណ្ឌទី១ ក្រមនីតិវិធី)។ **ឧទាហរណ៍** អាជ្ញាសាលាអាចយកគ្រឿងអលង្ការ សាច់ប្រាក់ ជាដើម ចេញពីផ្ទះរបស់កូនបំណុលនៃការអនុវត្ត និងរក្សាវាទុកនៅកន្លែងណាមួយក្រោមការគ្រប់គ្រងរបស់អាជ្ញាសាលា ប៉ុន្តែប្រសិនបើចលនវត្ថុដែលបានរឹបអូសមានទំហំធំ ដូចជា រថយន្ត ឬ គ្រឿងម៉ាស៊ីនធំៗ នោះ អាជ្ញាសាលាមិនអាចមានកន្លែងរក្សាទុក ករណីនេះ អាជ្ញាសាលាមានជម្រើស២ គឺ **ទី១** ជួលឃ្លាំង ឬទីកន្លែងណាមួយដើម្បីរក្សាទុកដោយសោហ៊ុយ ជួលជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្ត ហើយចុងក្រោយនឹងត្រូវទូទាត់ពីប្រាក់ដែលបានពីការលក់ចលនវត្ថុដែលបានរឹបអូសនោះ។ **ទី២** គឺអនុញ្ញាតឲ្យកូនបំណុលនៃការអនុវត្តកាន់កាប់ថែរក្សាគ្រប់គ្រងចលនវត្ថុដែលត្រូវបានរឹបអូស និងអនុញ្ញាតឲ្យប្រើប្រាស់នូវចលនវត្ថុនោះបាន។ ក្នុងករណីនេះ អាជ្ញាសាលាត្រូវបិទស្លាក ឬ ដាក់សញ្ញារឹបអូសដោយវិធីផ្សេងទៀត លើចលនវត្ថុដែលបានរឹបអូសនោះ (មាត្រា ៣៨៥ កថាខណ្ឌទី ៤ និងទី ៥ នៃក្រមនីតិវិធី)។

**ប្រសិនបើកូនបំណុលនៃការអនុវត្តបកស្លាក ឬ សញ្ញានោះចេញ តើវានឹងក្លាយជាបទល្មើសព្រហ្មទណ្ឌដែរ ឬ ទេ? មាត្រា ៥៧៨ និងមាត្រា៥៨១ ក្រមព្រហ្មទណ្ឌ**

បើយល់ថាចាំបាច់ អាជ្ញាសាលាអាចយកចលនវត្ថុដែលត្រូវបានរឹបអូសមកថែរក្សាគ្រប់គ្រង ដោយខ្លួនឯង និងលុបចោលការអនុញ្ញាតឲ្យប្រើប្រាស់នោះរបស់កូនបំណុលនៃការអនុវត្តវិញបាន (មាត្រា ៣៨៥ កថាខណ្ឌទី៥ ក្រមនីតិវិធី)។

**ការរឹបអូសវត្ថុដែលកាប់កាប់ដោយបុគ្គលផ្សេង ៖** ទោះបីវត្ថុជាកម្មវត្ថុនៃការអនុវត្តកាន់កាប់ ដោយបុគ្គលផ្សេងក៏ដោយ ក៏អាជ្ញាសាលាអាចអនុវត្តការរឹបអូសដូចគ្នានឹងការរឹបអូសវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តដែរ បើតតិយជននោះមិនបដិសេធអំពីការប្រគល់ចលនវត្ថុនោះ (មាត្រា៣៨៦ នៃក្រមនីតិវិធី)។

**ការរឹបអូសចលនវត្ថុដែលមានចុះបញ្ជី ៖** ប្រសិនបើចលនវត្ថុដែលត្រូវរឹបអូសមានចុះបញ្ជី ក្នុងសៀវភៅចុះបញ្ជី អាជ្ញាសាលាត្រូវផ្ទុកផ្ដាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរនូវហេតុ ការណ៍នៃការរឹបអូសចូលទៅក្នុងសៀវភៅចុះបញ្ជីនោះការរឹបអូសនឹងមានអានុភាពដូចជា រថយន្ត ទោចក្រយានយន្ត ជាដើម (មាត្រា៣៨៥ ក្រមនីតិវិធី)។ ប្រសិនបើរថយន្ត ឬទោចក្រ យានយន្ត ត្រូវបានចុះបញ្ជីក្រោមឈ្មោះរបស់តតិយជនក្រៅពីកូនបំណុលនៃការអនុវត្ត រថយន្ត ឬទោចក្រ យានយន្តនោះមិនអាចរឹបអូសបានទេ។

**អានុភាពនៃការរឹបអូស** នាំឲ្យកូនបំណុលនៃការអនុវត្តមិនអាចាត់ចែងទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសនោះ ហើយការរឹបអូសនេះក៏មានអានុភាព ទៅលើផលធម្មជាតិដែលកើតចេញពីចលនវត្ថុដែលត្រូវបានរឹបអូសនោះផងដែរ (មាត្រា៣៨៩ ក្រមនីតិវិធី)។

### ខ. ការហាមមិនឲ្យរឹបអូស

- នៅពេលចុះទៅអនុវត្តការរឹបអូស អាជ្ញាសាលាត្រូវពិនិត្យ និងប៉ាន់ប្រមាណពីតម្លៃនៃ ចលនវត្ថុដែលបានរឹបអូស មិនត្រូវរឹបអូសឲ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុល របស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្តនោះទេ។ ប្រសិនបើក្រោយ ពេលរឹបអូសដឹងថាការរឹបអូសនោះលើសកម្រិតហើយ អាជ្ញាសាលាត្រូវលុបចោលផ្នែកដែល លើសនោះ ។(នៃក្រមនីតិវិធី ៣៩១មាត្រា)
- អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ បើប៉ាន់ប្រមាណឃើញថាតម្លៃដែលបានមកពីការលក់វត្ថុដែលរឹបអូសនោះមិនមានសេសសល់ បន្ទាប់ពីសងសោហ៊ុយសម្រាប់នីតិវិធីហើយ (មាត្រា៣៩២ កថាខណ្ឌទី១ ក្រមនីតិវិធី)។

### គ. ការលុបចោលការរឹបអូស

អាជ្ញាសាលាត្រូវលុបចោលការរឹបអូស បើប៉ាន់ប្រមាណឃើញថាប្រាក់ដែលបានមកពីការ លក់ចលនវត្ថុដែលត្រូវរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីសងសិទ្ធិលើបំណុលដែល មានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធីតាមមាត្រា៣៩២ នៃក្រមនីតិវិធី។ អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុ ដែលបានរឹបអូសរួចហើយបានប្រសិនបើបានអនុវត្តការលក់តាមនីតិវិធីសមរម្យហើយ នៅតែមិនអាចលក់ចលនវត្ថុដែលរឹបអូសនោះបាន ហើយប៉ាន់ប្រមាណឃើញថានៅតែមិនអាចលក់បាននៅពេលអនាគត ក្រមនីតិវិធី)។ ៣៩៣មាត្រា)

បើសិនអាជ្ញាសាលាមិនព្រមលុបចោលការរឹបអូសនោះទេ អាចប្តឹងតវ៉ាចំពោះការអនុវត្ត តាម (មាត្រា៣៩៤ នៃក្រមនីតិវិធី)។

## ២.៤. ការលក់

អាជ្ញាសាលាត្រូវលក់ចលនវត្ថុដែលត្រូវបានរឹបអូស តាមវិធីលក់ឡាយឡុងដោយ ផ្ទាល់ មាត់ ឬដោយដាក់ស្រោមសំបុត្រ (មាត្រា៣៩៥ កថាខណ្ឌទី១ ក្រមនីតិវិធី)។ តែប្រសិនបើយល់ឃើញថាសមរម្យដោយពិចារណា អំពីប្រភេទ និងចំនួននៃចលនវត្ថុ អាជ្ញាសាលាអាចអនុវត្តការលក់តាមរបៀបផ្សេង ក្រៅពីរបៀបលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយដាក់ស្រោមសំបុត្រ ឬអាចឲ្យបុគ្គលផ្សេងពីអាជ្ញាសាលាអនុវត្តការលក់ជំនួសបាន ដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា៣៩៥ កថាខណ្ឌទី២ ក្រមនីតិវិធី)។

### ក. វិធីលក់

(យោងតាមមាត្រា៣៩៥ ក្រមនីតិវិធី)

- អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវដាក់លក់ និង វិធីក្នុងការលក់ចលនវត្ថុនោះ ដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ។
- កូនបំណុលនៃការអនុវត្តមិនអាចស្នើទិញចលនវត្ថុនោះបានឡើយ។
- ចំពោះអ្នកដែលអាជ្ញាសាលាអនុញ្ញាតឲ្យទិញ អ្នកទិញត្រូវបង់ប្រាក់ថ្លៃទិញចលនវត្ថុនោះភ្លាមៗនៅពេលដែលសម្រេចថាចលនវត្ថុនោះលក់ឲ្យអ្នកទិញម្នាក់នោះ។ ប្រសិនបើចលនវត្ថុ នោះត្រូវបានដាក់លក់ម្តងទៀតដោយសារអ្នកទិញមិនបានបង់ថ្លៃទិញ អ្នកសុំទិញដែលមិនបាន បង់ថ្លៃនោះមិនអាចស្នើសុំទិញម្តងទៀតបានឡើយ។
- ករណីបើការរឹបអូសចលនវត្ថុដែលមានតម្លៃខ្ពស់ អាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយ តម្លៃដើម្បីធ្វើការវាយតម្លៃចលនវត្ថុនោះនៅមុនពេលប្រកាសលក់ជាសាធារណៈ។
- អាជ្ញាសាលាអាចកម្រិតជនមួយចំនួនមិនឲ្យចូលទៅកន្លែងលក់ ឬដេញជនទាំងនោះ ចេញពីកន្លែងលក់ ឬមិនឲ្យស្នើសុំទិញចលនវត្ថុលក់នោះបាន ប្រសិនបើជនទាំងនោះបានធ្វើ សកម្មភាពរំខានដល់ដំណើរនៃការលក់ ដូចជា រំខានដល់អ្នកដទៃទៀតក្នុងការធ្វើសំណើទិញ ឬ បានឃុបឃិតដើម្បីបញ្ចុះតម្លៃលក់ (មាត្រា៣៩៦ ក្រមនីតិវិធី)។

### ខ. ការបែងចែកចំណែក

បន្ទាប់ពីចលនវត្ថុដែលបានរឹបអូសត្រូវបានលក់ ម្ចាស់បំណុលនៃការអនុវត្តទទួលបាន ចំណែកដោយស្វ័យប្រវត្តិ ដោយពុំចាំបាច់ធ្វើការទាមទារឲ្យបែងចែកចំណែកទេ។ ម្ចាស់បំណុលផ្សេងទៀតអាចទទួលបានចំណែក ក្នុងករណីពួកគេទាមទារឲ្យបែងចែកចំណែក (មាត្រា៣៩៨ក្រមនីតិវិធី)។

- **ការទាមទារឲ្យបែងចែកចំណែក**

ម្ចាស់បំណុលដែលត្រូវទទួលចំណែកគឺទី១ ម្ចាស់បំណុលនៃការអនុវត្តទី២ ម្ចាស់បំណុលដែលបានធ្វើការទាមទារឲ្យចែកចំណែក តាមរយៈការរួមបញ្ចូលរឿងក្តីទី៣ ម្ចាស់បំណុលដែលបានធ្វើការទាមទារឲ្យចែកចំណែក (មាត្រា៣៩៨ ក្រមនីតិវិធី)។

#### (១) ម្ចាស់បំណុលដែលមិនត្រូវបានធានា

- ប្រសិនបើម្ចាស់បំណុលមានលិខិតអនុវត្តរួចហើយ គាត់អាចដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ចំពោះកូនបំណុលតែមួយនៅទីកន្លែងតែមួយបាន។ ករណីអនុវត្តក្រោយនេះត្រូវបានរួមបញ្ចូលជាមួយនឹងករណីអនុវត្តមុន (មាត្រា៣៨៨ កថាខណ្ឌទី១ ក្រមនីតិវិធី) ហើយពាក្យសុំក្រោយនេះមានអានុភាពជាការទាមទារឲ្យបែងចែកចំណែក (មាត្រា៣៨៨ កថាខណ្ឌទី២ ក្រមនីតិវិធី)។

- ប្រសិនបើម្ចាស់បំណុលមិនមានលិខិតអនុវត្តទេ អាចដាក់ពាក្យសុំរឹបអូសបណ្តោះអាសន្ន ចំពោះចលនវត្ថុ ចំពោះកូនបំណុលតែមួយ នៅទីកន្លែងតែមួយបាន។ ពាក្យសុំនេះមានអានុភាពជាការទាមទារឲ្យបែងចែកចំណែក (មាត្រា៥៦៥ កថាខណ្ឌទី៤, មាត្រា៣៨៨ កថាខណ្ឌទី១ និងទី ២ ក្រមនីតិវិធី) ចំពោះកូនបំណុលដែលមានដីកាសម្រេចឲ្យរឹបអូសបណ្តោះអាសន្ន។

**(២) ម្ចាស់បំណុលដែលត្រូវបានធានា**

ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំលើចលនវត្ថុដែលបានរឹបអូស អាចធ្វើការទាមទារឲ្យបែងចែកចំណែកបាន ដោយដាក់នូវឯកសារបញ្ជាក់អំពីសិទ្ធិនោះ (មាត្រា៣៩៤ ក្រមនីតិវិធី) ការទាមទារឲ្យបែងចែកចំណែកនេះត្រូវដាក់ទៅអាជ្ញាសាលា។

ឬ ជំនួសឲ្យការទាមទារឲ្យបែងចែកចំណែក ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ អាចជ្រើសរើសដាក់ពាក្យសុំអនុវត្តសិទ្ធិប្រាតិភោគបាន (មាត្រា៥០២,៣៨៨ ក្រមនីតិវិធី)។ ករណីអនុវត្តសិទ្ធិប្រាតិភោគក្រោយនេះត្រូវបានរួមបញ្ចូលជាមួយនឹងករណីអនុវត្តមុន (មាត្រា៣៨៨ កថាខណ្ឌទី១ ក្រមនីតិវិធី) និងពាក្យសុំក្រោយនេះមានអានុភាពជាការទាមទារឲ្យបែងចែកចំណែក (មាត្រា៣៨៨ កថាខណ្ឌទី២ ក្រមនីតិវិធី)។

- **ការបែងចែកដោយអាជ្ញាសាលា**

ប្រសិនបើម្ចាស់បំណុលមានតែម្នាក់ ឬច្រើននាក់ហើយប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលរឹបអូស ឬប្រាក់ដែលបានរឹបអូសអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់នីតិវិធីក្នុងការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវបែងចែក ចំណែកឲ្យទៅម្ចាស់បំណុលនីមួយៗ ទៅតាមសិទ្ធិលើបំណុលរបស់ពួកគេ។ ចំពោះប្រាក់ដែល នៅសេសសល់ត្រូវប្រគល់ឲ្យទៅកូនបំណុលនៃការអនុវត្តវិញ (មាត្រា៣៩៩ កថាខណ្ឌទី១ ក្រមនីតិវិធី)។

ករណីបើប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលរឹបអូស ឬប្រាក់ដែលបានរឹបអូស មិនអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ អាជ្ញាសាលាត្រូវកំណត់ថ្ងៃណាមួយ ក្នុងអំឡុងពេល ២ (ពីរ)សប្តាហ៍ ដើម្បីពិភាក្សាអំពីការចែកចំណែកនៃប្រាក់ដែលបានមកពី ការលក់ ឬប្រាក់ដែលបានពីការរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និងទីកន្លែងទៅម្ចាស់ បំណុលនីមួយៗ។

បើការពិភាក្សារវាងម្ចាស់បំណុលទាំងអស់ មានការស្រុះស្រួលឯកភាពគ្នាដាច់ស្រេចហើយ អាជ្ញាសាលាត្រូវធ្វើការបែងចែកចំណែកទៅតាមការព្រមព្រៀងរបស់ម្ចាស់បំណុលនីមួយៗ (មាត្រា ៣៩៩ កថាខណ្ឌទី២ ក្រមនីតិវិធី)។

ទោះបីជាការពិភាក្សាអាចធ្វើទៅបាន អាជ្ញាសាលាមិនអាចធ្វើការបែងចែកចំណែកទេ ប្រសិនបើម្ចាស់បំណុលមិនបានបង្ហាញខ្លួនមកទទួលចំណែក។ ក្នុងករណីនេះអាជ្ញាសាលាត្រូវផ្ញើ ទុកនូវទឹកប្រាក់ស្មើនឹងចំណែកចំពោះម្ចាស់បំណុល នៅសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា ៤០០ កថាខណ្ឌទី២ ក្រមនីតិវិធី)។

- **ការបញ្ជូនរឿងទៅសាលាដំបូង**

បើការពិភាក្សានោះមិនមានការឯកភាព ឬដាច់ស្រេចនោះទេ អាជ្ញាសាលាត្រូវរាយ ការណ៍ពីហេតុការណ៍នេះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា៤០១ ក្រមនីតិវិធី)។

លើសពីនេះទៀត ទោះបីជាល័ក្ខខ័ណ្ឌទាំងអស់នៃ មាត្រា៣៩៩ កថាខណ្ឌទី១ ឬទី២ នៃក្រមនីតិវិធី ត្រូវបានបំពេញក៏ដោយ ប្រសិនបើសិទ្ធិលើបំណុលមានលក្ខណៈដូចខាងក្រោម ក៏អាជ្ញាសាលាមិនអាចធ្វើការបែងចែកចំណែកឲ្យម្ចាស់បំណុលនៃសិទ្ធិលើបំណុលនោះបានដែរ។ ក្នុងករណីនេះ អាជ្ញាសាលាត្រូវផ្ញើទុកនូវទឹកប្រាក់ស្មើនឹងចំណែកចំពោះសិទ្ធិលើបំណុល នោះ នៅសាលាដំបូងដែលខ្លួនស្ថិតនៅ និងត្រូវព្រៀងរបាយការណ៍អំពីស្ថានភាពនោះ៖

(ក) សិទ្ធិលើបំណុលជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌបង្អង់ ឬ ហេតុការណ៍ជាក់លាក់ណាមួយ

(ខ) សិទ្ធិលើបំណុលដែលជាសិទ្ធិលើបំណុលនៃការរឹបអូសជាបណ្ដោះអាសន្នដោយម្ចាស់បំណុល

(គ) ឯកសារដែលមានចែងក្នុងចំណុច (ក) នៃកថាខណ្ឌទី២ នៃមាត្រា៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ត្រូវបានដាក់ ឬ

(ឃ) ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលហាមឃាត់ជាបណ្ដោះអាសន្ននូវការ អនុវត្តឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ ពាក់ព័ន្ធនឹងសិទ្ធិលើបំណុល ដែលបានដាក់។

- **ការបែងចែកចំណែកដោយសាលាដំបូង**

តុលាការនៃការអនុវត្តនោះត្រូវរៀបចំបែងចែកចំណែក បើមូលហេតុនៃការផ្ញើប្រាក់បានរលត់ករណីដែលមានការជូនដំណឹងតាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា៤០០(ការផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) ឬប្រសិនបើមានរបាយការណ៍តាមមាត្រា៤០១ (ការជូនដំណឹងទៅសាលាដំបូង) ដោយកំណត់កាលបរិច្ឆេទនៃការបែងចែកចំណែក ហើយផ្ដល់ដំណឹងអំពីពេលវេលា និងទីកន្លែងទៅម្ចាស់បំណុលដែលត្រូវទទួលបានការចែកចំណែក និងកូនបំណុល (មាត្រា៤៨៨ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធី)។

តុលាការដែលត្រូវអនុវត្តបែងចែកចំណែកត្រូវធ្វើតារាងចែកចំណែក នៅកាលបរិច្ឆេទនៃ ការបែងចែកចំណែកនោះ (មាត្រា៤៩០ កថាខណ្ឌទី១ នៃក្រមនីតិវិធី) លើកលែងតែក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ អាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត (មាត្រា ៤៨៩ ក្រមនីតិវិធី)។

តុលាការដែលត្រូវអនុវត្តបែងចែកចំណែកដោយផ្អែកលើតារាងចំណែក (មាត្រា៤៨៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធី)។

## ៣. អនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ចំពោះអចលនវត្ថុ

ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ចំពោះអចលនវត្ថុ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការអនុវត្ត (CCP៨១៨) ហើយជាធម្មតាអចលនវត្ថុមានតម្លៃខ្ពស់ និងអាចមានម្ចាស់សិទ្ធិជាច្រើនពាក់ព័ន្ធនឹងវត្ថុនោះ ហេតុនេះត្រូវបង្កើតយន្តការមួយដែលសមស្របសម្រាប់គ្រប់គ្រងភាពស្មុគស្មាញនៃការអនុវត្តសិទ្ធិទាំងនេះ។ នៅពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវភ្ជាប់នូវឯកសារនានាដែលជាល័ក្ខខ័ណ្ឌគោល ដូចជា លិខិតអនុវត្ត រូបមន្តអនុវត្ត ឯកសារបញ្ជាក់អត្តសញ្ញាណអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ឬរបស់អ្នកធានាដោយវត្ថុ (ករណីអនុវត្តសិទ្ធិប្រាតិភោគ)។

ដើម្បីអនុវត្តនិងសម្រេចសិទ្ធិទាំងនេះ យន្តការគាំទ្រគឺ ទី១ នីតិវិធីរឹបអូស ទី២ នីតិវិធីលក់ និងទី៣ នីតិវិធីចែកចំណែក គឺជាយន្តការអនុវត្តសិទ្ធិ តាមរយៈការរឹបអូសដើម្បីលក់ប្តូរជាប្រាក់ ហើយយកប្រាក់នោះទៅទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលត្រូវបានសម្រេចសេចក្តីជាស្ថាពរក្នុងសាលក្រម ឬសាលដីការបស់តុលាការអង្គសេចក្តី ដែលជាលទ្ធផលនៃការអនុវត្តសិទ្ធិស្ថាពរឲ្យបានសម្រេចជាលក្ខណៈ សត្យានុម័ត។

### ៣.១.នីតិវិធីរឹបអូស

\+ **ការប្រកាសរឹបអូស** ៖ នៅពេលតុលាការអនុវត្តបានទទួលពាក្យសុំអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្តដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ដោយចង្អុលបង្ហាញអំពីភាគីនៃ សំណុំរឿងអនុវត្ត កម្មវត្ថុនៃ

ការអនុវត្តប្រកាសអំពីការរឹបអូសអចលនវត្ថុនោះ ហើយបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត (CCP៤១៩)។

+ **ការចុះបញ្ជីរឹបអូស** ៖ នៅពេលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានចេញ ក្រឡាបញ្ជីទទួលបន្ទុក ត្រូវធ្វើលិខិតផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបន្ទាន់ (CCP៤២០) ហើយចំពោះដីដែលមិនទាន់បានចុះបញ្ជី ស្ថាប័ន មានសមត្ថកិច្ចត្រូវចុះបញ្ជីកម្មសិទ្ធិលើអចលនវត្ថុនោះ បន្ទាប់មកចុះបញ្ជីអំពីការរឹបអូស (នីតិវិធីត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និង ការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី)។ មួយវិញទៀត ប្រសិនបើបានរឹបអូសចំណែកកម្មសិទ្ធិអវិភាគ ការរឹបអូសត្រូវចុះចំពោះចំណែករបស់កូនបំណុលនៃការអនុវត្តប៉ុណ្ណោះ ហើយបន្ទាប់ពីបានចុះបញ្ជីរឹបអូសដោយផ្អែកលើលិខិតផ្ទុកផ្តាក់នេះ ហើយស្ថាប័នមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងនៃសេចក្តីបញ្ជាក់សម្រាប់ការចុះបញ្ជីនេះមកឲ្យក្រឡាបញ្ជីទទួលបន្ទុក(CCP៤២០-២)។

+ **អានុភាពនៃការរឹបអូស** ៖ ជាគោលការណ៍អានុភាពនៃការរឹបអូស កើតឡើងនៅពេលដីកាសម្រេច ចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានបញ្ជូនទៅឲ្យកូនបំណុល នៃការអនុវត្ត (CCP៤២១-២) ប៉ុន្តែប្រសិនបើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើឡើងមុនពេលបញ្ជូនដីកាសម្រេច នោះការរឹបអូសបង្កើតអានុភាពនៅពេលចុះបញ្ជី ហើយដីកាសម្រេចនេះ គប្បីបញ្ជូនទៅកូនបំណុលនៃការអនុវត្ត បន្ទាប់ពីចុះបញ្ជីរឹបអូស ដើម្បីកុំឲ្យកូនបំណុលនៃការអនុវត្តមានឱកាសធ្វើអនុប្បទានទៅតតិយជន។ អានុភាពចម្បងនៃការរឹបអូសគឺហាមឃាត់កូនបំណុលនៃការអនុវត្តមិនឲ្យចាត់ចែង ហើយអាជ្ញាធរមានសមត្ថកិច្ចជាអ្នកមានសិទ្ធិចាត់ចែង (តុលាការអនុវត្ត)។ នៅពេលការរឹបអូសបង្កើតអានុភាព កូនបំណុលនៃការអនុវត្តអាចប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស បាន តាមវិធីប្រើប្រាស់ធម្មតា (CCP៤២១-៣)។ ការប្រើប្រាស់ជាធម្មតា ដូចជាស្នាក់នៅ ដាំដំណាំ ទទួលប្រាក់ឈ្នួលដែលបានកំពុងជួលឲ្យអ្នកដទៃ។ ប៉ុន្តែសម្រាប់ការជួលឲ្យអ្នកដទៃ បន្ទាប់ពីការរឹបអូសបង្កើតអានុភាព ឬការបង្កើតសិទ្ធិប្រើប្រាស់ថ្មី ឬសកម្មភាពនានាដែលនាំឲ្យថ្លៃលក់អចលនវត្ថុធ្លាក់ចុះ ដូចជា បោះបង់អចលនវត្ថុ ឬអនុញ្ញាតឲ្យតតិយជនកាន់កាប់ដោយខុសច្បាប់ ជាអាទិ៍ ត្រូវចាត់ទុកជាការចាត់ចែង ហេតុនេះត្រូវបានហាមឃាត់ ប៉ុន្តែម្ចាស់បំណុលដទៃ អាចរឹបអូសអចលនវត្ថុនេះ តាមរយៈ*ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា* (CCP៤២៤ និង CCP ៥១១)។

បន្ទាប់ពីការរឹបអូសបង្កើតអានុភាព តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ដោយដីកាសម្រេច ដោយកំណត់អំឡុងពេលចាំបាច់ សម្រាប់ធ្វើឯកសារលម្អិតអំពីវត្ថុ និងផ្តល់ឱកាសឲ្យម្ចាស់បំណុលនានាធ្វើការអនុវត្តសិទ្ធិ ក្នុងរយៈពេលសមរម្យមួយ ហើយធ្វើការប្រកាសជាសាធារណៈអំពីពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឲ្យចែកចំណែក (CCP៤២២-២)។ នៅពេលកំណត់រួចហើយ តុលាការអនុវត្តត្រូវដាស់តឿន (ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មុនពេលចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនេះ, ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលបានចុះបញ្ជីនៅមុនពេលចុះបញ្ជីអំពីការរឹបអូស ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬអាករសាធារណៈ) ឲ្យរាយការណ៍អំពីសិទ្ធិរបស់ខ្លួនមកតុលាការអនុវត្ត និងក្នុងករណីមិនបានរាយការណ៍ ឬរាយការណ៍មិនពិត ដោយចេតនា ឬមានកំហុស ម្ចាស់បំណុលនឹងទទួលបានការចែកចំណែក ប៉ុន្តែត្រូវទទួលខុសត្រូវសងការខូចខាត(CCP៤២៣-៣)។ ការខូចខាតសម្រាប់ករណីនេះ មានដូចជា សោហ៊ុយរួមសម្រាប់ការអនុវត្ត, ការខូចខាតជាក់ស្តែងរបស់ម្ចាស់បំណុលផ្សេង (រាយការណ៍ មិនពិត)និងចំណែកម្ចាស់បំណុលត្រូវបាន ប៉ុន្តែមិនបាន(មិនបានរាយការណ៍)ជាអាទិ៍។

ចំពោះម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ មិនទទួលឥទ្ធិពលអំពីការលក់ដោយបង្ខំនោះទេ ហើយសិទ្ធិនេះនៅតែបន្តអត្ថិភាពក្រោយការលក់ (CCP៤៣១-១) ប៉ុន្តែម្ចាស់បំណុលនេះអាចអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួន ហើយទទួលការសងដែលមានអាទិភាព នៅពេលមានការលក់ដោយបង្ខំដោយផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុលដទៃ ហេតុនេះការដាស់តឿនដើម្បីបញ្ជាក់អំពីឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ (CCP៤២២-៣)។

**ប្រសិនបើកូនបំណុលនៃការអនុវត្តបានចាត់ចែងអចលនវត្ថុដែលបានរឹបអូស៖**

ប្រសិនបើកូនបំណុលនៃការអនុវត្តបានចាត់ចែងអចលនវត្ថុដែលបានរឹបអូសក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដូចជាការលក់ ឬការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ នោះការចាត់ចែងនឹងត្រូវបានចុះបញ្ជីទោះបីជាមានការចុះបញ្ជីអំពីការរឹបអូសក៏ដោយ។ កម្មសិទ្ធិរបស់អ្នកទិញ ឬសិទ្ធិជួលអចិន្ត្រៃយ៍របស់អ្នកជួលអចិន្ត្រៃយ៍ ត្រូវបានចុះបញ្ជី ប៉ុន្តែការចុះបញ្ជីគឺទាបជាង/អន់ជាងការចុះបញ្ជីអំពីការរឹបអូស។ ដូច្នេះ ប្រសិនបើនីតិវិធីនៃការអនុវត្តដោយបង្ខំបានដំណើរការ ហើយការបង់ថ្លៃលក់ទិញត្រូវបានធ្វើរួចរាល់ នោះការចុះបញ្ជីអំពីការចាត់ចែងត្រូវបានលុបចោល (មាត្រា ៤៣១ កថាខណ្ឌទី ២ មាត្រា ៤៤៨ កថាខណ្ឌទី ១ នៃក.ន.រ)។ ផ្ទុយទៅវិញ ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានដកចេញ ឬ មិនត្រូវបានបន្ត នោះការចុះបញ្ជីអំពីការរឹបអូសនឹងត្រូវបានលុបចោល (មាត្រា ៤២៨ នៃក.ន.រ) ហើយការចុះបញ្ជីអំពីការចាត់ចែងនឹងមានអានុភាពពេញលេញ។

លិខិតដែលត្រូវចេញក្នុងដំណាក់កាលនេះមានដូចជា ៖

- ដីកាសម្រេចចាប់ផ្តើមការអនុវត្តដោយបង្ខំ (CCP៤១៩)
- របាយការណ៍ស្តីពីការបញ្ជូណដីកាសម្រេចនេះ (CCP២៤៦~CCP២៥៧)
- លិខិតផ្ទុកផ្តាក់ចុះបញ្ជីអំពីការរឹបអូស (CCP៤២០)
- ឯកសារចម្លងនៃសេចក្តីបញ្ជាក់អំពីការចុះបញ្ជីរឹបអូសអចលនវត្ថុ (CCP៤២០-២)
- ដីកាសម្រេចអំពីពេលវេលាចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក (CCP៤២២)

### ៣.២.នីតិវិធីលក់

ការលក់ត្រូវធ្វើឡើងដោយតុលាការអនុវត្តក្នុងនាមអ្នកមានសិទ្ធិចាត់ចែងដែលបានទទួលតាមរយៈអានុភាពនៃការរឹបអូស ហេតុនេះការលក់ឡាយឡុងតាមផ្លូវតុលាការគឺជានីតិវិធីប្រកាសឲ្យអ្នកស្នើសុំទិញមកទិញវត្ថុនេះ ដោយកំណត់បុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលទាំងនោះ ឲ្យក្លាយជាអ្នកទិញ រីឯដីកាសម្រេចអនុញ្ញាតឲ្យលក់ ចាត់ទុកជាការបង្ហាញឆន្ទៈរបស់តុលាការអនុវត្តក្នុងនាមអ្នកលក់ចំពោះអ្នកទិញ ហើយចំពោះតម្លៃលក់វិញ គឺផ្អែកលើរបាយការណ៍របស់អ្នកវាយតម្លៃដែលត្រូវបានចាត់តាំងដោយតុលាការ និងបន្ទាប់ពីបានតម្លៃលក់នោះមក តុលាការអនុវត្តពិចារណាអំពីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ដោយប្រើមូលដ្ឋាននៃតម្លៃលក់ ក្នុងការកំណត់តម្លៃលក់អប្បបរមា ហេតុនេះតម្លៃលក់នេះមិនមែនជាតម្លៃទីផ្សារនោះទេ គឺជាតម្លៃលក់ឡាយឡុងតាមផ្លូវតុលាការ ដោយធ្វើយ៉ាងណាឲ្យមានភាពឆាប់រហ័ស នាំឲ្យតុលាការអនុវត្តពិចារណាផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ខ្ពស់ជាងផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត។

ផ្អែកលើរបបគតិយុត្តនេះ នីតិវិធីនៃការលក់ ត្រូវបានកំណត់ជា ៣ (បី) ជំហាន ទី១ ការរៀបចំការលក់ ទី២ ការអនុវត្តការលក់ និងទី៣ ការអនុញ្ញាតការលក់។

+ **ការរៀបចំលក់** ៖ នៅពេលការរឹបអូសបង្កើតអានុភាព តុលាការអនុវត្តនឹងបន្តនីតិវិធី ក្នុងនាមជាអ្នកមានសិទ្ធិចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសតាម រូបភាពវាយតម្លៃអចលនវត្ថុ មុនពេលប្រកាសលក់ឡាយឡុងតាមផ្លូវតុលាការ ហេតុនេះតុលាការអនុវត្តនឹងចេញដីកាសម្រេចចាត់តាំងអ្នកវាយតម្លៃ ឲ្យស្រាវជ្រាវអំពីស្ថានភាព បច្ចុប្បន្ននៃអចលនវត្ថុនោះ និងធ្វើឯកសារលម្អិតអំពីវត្ថុនោះ។ នៅពេលអ្នកវាយតម្លៃ អាចកំណត់តម្លៃអចលនវត្ថុនោះបានហើយ ត្រូវធ្វើ

ជាបោយការណ៍ផ្ញើមកតុលាការអនុវត្ត ហើយអ្នកស្រាវជ្រាវ ក៏ត្រូវផ្ញើបាយការណ៍អំពីស្ថានភាពបច្ចុប្បន្ននៃវត្ថុមកផងដែរ ដើម្បីជាមូលដ្ឋានក្នុងការកសាងឯកសារលម្អិតអំពីអចលនវត្ថុនោះ។ បន្ទាប់មក តុលាការអនុវត្ត នឹងចេញដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ចេញដីកាសម្រេចអនុវត្តការលក់ និងធ្វើការជូនដំណឹងជាសាធារណៈអំពីការលក់ឡាយឡុងតាមផ្លូវតុលាការនេះ ថាតើធ្វើការដេញថ្លៃ តាមរយៈស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ឬកំណត់វិធីលក់ផ្សេងពីនេះ ដូចជាធ្វើការចរចាដោយផ្ទាល់ជាមួយនឹងម្ចាស់បំណុលនៃការអនុវត្ត ឬម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ឬម្ចាស់បំណុលដទៃផ្សេងទៀត ឬភតិកៈជាអាទិ៍។

**ប្រសិនបើតម្លៃលក់អប្បបរមាមិនសមរម្យះ**

ម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការអនុវត្តបាន (មាត្រា ៣៩៤ ក.ន.រ) និងសុំឲ្យតុលាការអនុវត្តផ្លាស់ប្តូរតម្លៃលក់អប្បបរមា (មាត្រា ៤៣២ កថាខណ្ឌទី ២ ក.ន.រ)។ ប្រសិនបើតុលាការមិនផ្លាស់ប្តូរតម្លៃលក់អប្បបរមាទេ នោះម្ចាស់បំណុលនៃការអនុវត្តអាចដកពាក្យសុំអនុវត្តដោយបង្ខំបាន (មាត្រា ៤៤៦ ក.ន.រ)។ ក្នុងករណីនេះ ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តអាចរកឱកាសធ្វើការលក់ទិញជាលក្ខណៈឯកជនក្រៅផ្លូវតុលាការបាន។ ប្រសិនបើតុលាការអនុវត្តមិនបានផ្លាស់ប្តូរតម្លៃលក់អប្បបរមា ហើយម្ចាស់បំណុលនៃការអនុវត្តមិនបានដកពាក្យសុំអនុវត្តដោយបង្ខំទេ នោះការលក់នឹងត្រូវធ្វើឡើងតាមតម្លៃលក់អប្បបរមាដែលមិនមានសមរម្យនោះ។ ក្រោយការលក់ តុលាការអនុវត្តនឹងចេញដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យលក់។ ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តអាចថ្លែងយោបល់មុនពេលចេញដីកាសម្រេចបាន (មាត្រា ៤៤១ ក.ន.រ)។ ប្រសិនបើដីកាសម្រេចអនុញ្ញាតឲ្យលក់ត្រូវបានចេញ (មាត្រា ៤៤២ កថាខណ្ឌទី ១ ក.ន.រ) នោះពួកគេអាចប្តឹងជំទាស់នឹងដីកាសម្រេចអនុញ្ញាតនោះបាន (មាត្រា ៤៤៤ កថាខណ្ឌទី ២ មាត្រា ៤៤២ កថាខណ្ឌទី ២ ចំណុច ឃ ក.ន.រ)។

+**ការអនុវត្តការលក់៖** អ្នកដែលទទួលបន្ទុកអនុវត្តការលក់គឺជាអាជ្ញាសាលា (CCP៤៣៩-១) ដោយអាជ្ញាសាលាត្រូវអនុវត្តតាមខ្លឹមសារដូចមានកំណត់ក្នុងដីកាសម្រេចអនុវត្តការលក់របស់តុលាការអនុវត្ត ដូចជាទីកន្លែងលក់ កាលបរិច្ឆេទលក់ តម្លៃលក់អប្បបរមា វិធីលក់ (ស្រោមសំបុត្រ ឬផ្ទាល់មាត់ ឬទម្រង់ផ្សេងទៀត) បង្ហាញឯកសារលម្អិតអំពីវត្ថុ អ្នកធ្វើសំណើទិញត្រូវដាក់ប្រាក់ធានាចំនួន ១០% (ដប់ភាគរយ) នៃតម្លៃលក់អប្បបរមា ជាអាទិ៍។ នៅពេលមានអ្នកធ្វើសំណើទិញ អាជ្ញាសាលាត្រូវកំណត់អ្នកធ្វើសំណើទិញក្នុងតម្លៃអតិបរមា ពីក្នុងចំណោមអ្នកស្នើសុំទិញដោយស្របច្បាប់ ហើយប្រកាសអំពីលទ្ធផល នៃការលក់ឡាយឡុងនោះ និងប្រកាសបញ្ចប់ការលក់

ឡាយឡុង ហើយអាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងនេះ និងតម្រូវឲ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬអ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនោះ រីឯអ្នកស្នើសុំទិញដទៃទៀត អាចស្នើសុំឲ្យ តុលាការអនុវត្តប្រគល់ប្រាក់ធានាមកឲ្យខ្លួនវិញ(CCP៤៣៧-២)។ បុគ្គលដែលត្រូវបានកំណត់ថាជាអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា មិនអាចដកសំណើរបស់ខ្លួនបានឡើយ ហើយមានកាតព្វកិច្ចបង់ប្រាក់ដែលនៅសល់បង្គ្រប់ លើកលែងតែតុលាការអនុវត្តបានចេញដីកាសម្រេចមិនអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ។ បន្ទាប់មកអាជ្ញាសាលានឹងបញ្ជូនកំណត់ហេតុនៃការលក់ឡាយឡុងនេះទៅតុលាការអនុវត្ត។ ផ្ទុយទៅវិញ ប្រសិនបើគ្មានអ្នកស្នើសុំទិញក្នុងអំឡុងពេលដែលបានកំណត់ដោយតុលាការអនុវត្តនោះទេ អាជ្ញាសាលា ត្រូវធ្វើកំណត់ហេតុបញ្ចប់កាលបរិច្ឆេទនៃការលក់ ដោយបញ្ជាក់ថាគ្មានអ្នកស្នើសុំទិញ ហើយបញ្ជូនកំណត់ហេតុនេះទៅតុលាការអនុវត្ត។ ប្រសិនបើមានស្ថានភាពបែបនេះ តុលាការអនុវត្តត្រូវកំណត់សាជាថ្មី ហើយឲ្យអាជ្ញាសាលាអនុវត្តការលក់ម្តងទៀត ដោយប្រើមធ្យោបាយដដែល ឬមធ្យោបាយថ្មី ហើយអាចបន្ថយតម្លៃលក់អប្បបរមាបាន ហើយប្រសិនបើនៅតែគ្មានអ្នកស្នើសុំទិញទៀត តុលាការអនុវត្តអាចបង្គាប់ឲ្យអាជ្ញាសាលាធ្វើការចរចាដោយផ្ទាល់ជាមួយនឹងម្ចាស់បំណុលនៃការអនុវត្ត (CCP៤៣២-២) ជាអាទិ៍។

+ **ការអនុញ្ញាតការលក់** ៖ នៅពេលបានទទួលកំណត់ហេតុនៃការលក់ឡាយឡុងរបស់អាជ្ញាសាលា តុលាការអនុវត្តនឹងស្តាប់យោបល់របស់បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ពិនិត្យនីតិវិធីទាំងមូលចាប់ពីចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំរហូតដល់ពេលកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា មុនពេលចេញដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ ហេតុនេះតុលាការអនុវត្តនឹងធ្វើកំណត់ហេតុស្តីពីកាលបរិច្ឆេទចេញដីកាសម្រេចការលក់ ហើយប្រកាសអំពីការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ និងជូនដំណឹងអំពីហេតុការណ៍នេះទៅជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ដើម្បីឲ្យបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចបញ្ចេញយោបល់អំពីហេតុនេះក្នុងកាលបរិច្ឆេទនៃការចេញដីកាសម្រេចការលក់(CCP៤៤១)។ បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ ត្រូវលើកយោបល់ដោយប្រើមូលហេតុគតិយុត្ត ដូចជា អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានពុំមានលក្ខណៈសម្បត្តិ (CCP៤៤២-២-ខ) ជាអាទិ៍។ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធរួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែក អ្នកស្នើសុំទិញក្នុងការលក់ដោយបង្ខំ ជនដែលមានសិទ្ធិប្រត្យក្សលើអចលនវត្ថុជាដើម។ ប្រសិនបើគ្មានហេតុដូចមានកំណត់ក្នុងមាត្រា ៤៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ តុលាការអនុវត្តនឹងចេញដីកាសម្រេចអនុញ្ញាតឲ្យលក់ និងជូនដំណឹងអំពីហេតុនេះទៅបុគ្គលដែល

មានផលប្រយោជន៍ពាក់ព័ន្ធ ហេតុនេះដីកាសម្រេចអនុញ្ញាតឲ្យលក់ពុំមានអានុភាពនោះទេ ប្រសិនបើមិនទាន់ចូលជាស្ថាពរ (CCP៤៤៥-៤)។ នៅពេលដីកាសម្រេចអនុញ្ញាតឲ្យលក់បង្កើតអានុភាព តុលាការអនុវត្តនឹងកំណត់អំឡុងពេលបង់ថ្លៃលក់ ដែលស្ថិតក្នុងអំឡុងពេល ០១ (**មួយ**) **ខែ** គិតចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ ហើយអ្នកទិញនឹងធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ (CCP៤៤៧-៤)។ ប្រសិនបើអ្នកទិញជាម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក ដូចជាម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែក នោះអ្នកទិញនោះអាចបង់ថ្លៃលក់ ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការចែកចំណែកនៅកាលបរិច្ឆេទនៃការចែកចំណែកបាន ដោយស្នើសុំទៅតុលាការអនុវត្ត នៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ (មាត្រា ៤៤៧ កថាខណ្ឌទី ៣ ក.ន.រ)។ បន្ទាប់មកក្រឡាបញ្ជីទទួលបន្ទុកនឹងធ្វើលិខិតផ្ទុកផ្តាក់ចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឲ្យអ្នកទិញ និងលុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្ន ហើយសោហ៊ុយចាំបាច់សម្រាប់ការចុះបញ្ជីគឺជាបន្ទុករបស់អ្នកទិញ (CCP៤៤៨-៣)។ ដោយឡែក នៅក្នុងការលក់នេះ មានគោលការណ៍ពីរ គឺគោលការណ៍លុបចោល និងគោលការណ៍ទទួលបន្ត ហើយសម្រាប់កម្ពុជា គឺជ្រើសរើសយកគោលការណ៍ទទួលបន្ត (CCP៤៣១-១)។

មួយវិញទៀត ប្រសិនបើអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា មិនបានបង់ថ្លៃលក់តាមកាលបរិច្ឆេទដែលត្រូវបានកំណត់ដោយតុលាការអនុវត្តនោះទេ ចាត់ទុកថាដីកាសម្រេច អនុញ្ញាតឲ្យលក់បាត់បង់អានុភាព (CCP៤៥១-១) នាំឲ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាបាត់សិទ្ធិទិញអចលនវត្ថុ និងមិនអាចទទួលបានប្រាក់ធានាវិញទេ។ ប្រាក់ធានាដែលបានរឹបអូសនេះនឹងក្លាយជាថ្លៃលក់ និងត្រូវបានចែកទៅឲ្យម្ចាស់បំណុល (មាត្រា ៤៥២ កថាខណ្ឌទី ១ ក.ន.រ)។ តុលាការអនុវត្តនឹងធ្វើការលក់ម្តងទៀត ប៉ុន្តែអ្នកស្នើសុំទិញនេះគ្មានលក្ខណៈសម្បត្តិស្នើសុំទិញទៀតទេ (CCP៤៥១-៣)។

លិខិតដែលត្រូវចេញក្នុងដំណាក់កាលនេះមានដូចជា ៖

- ដីកាសម្រេចចាត់តាំងអ្នកវាយតម្លៃ (CCP៤៣០)
- របាយការណ៍ស្តីពីការវាយតម្លៃ (CCP៤៣០-៥)
- ដីកាសម្រេចបង្គាប់ឲ្យស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃវត្ថុ (CCP៤៣៤-២)
- របាយការណ៍ស្តីពីការស្រាវជ្រាវ (CCP៤៣០-៥)
- ឯកសារលម្អិតអំពីវត្ថុ (CCP៤៣៤)
- ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា (CCP៤៣២)

- ដីកាសម្រេចបង្គាប់ឲ្យអនុវត្តការលក់ (CCP៤៣៦-៣)
- លិខិតជូនដំណឹង (CCP៤២២-២)
- កំណត់ហេតុស្តីពីការលក់ឡាយឡុង (CCP៤៣៩)
- ដីកាសម្រេចអនុញ្ញាតឲ្យលក់ (CCP៤៤២)
- ដីកាសម្រេចកំណត់អំពីអំឡុងពេលបង់ថ្លៃលក់ (CCP៤៤៧)
- លិខិតផ្ទុកផ្តាក់ចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិនិងលុបចោលការចុះបញ្ជីរឹបអូស (CCP៤៤៨)

## ៣.៣.នីតិវិធីចែកចំណែក

នៅពេលថ្លៃលក់បានបង់រួចហើយដោយអ្នកទិញមកតុលាការអនុវត្ត តាមការកំណត់ តុលាការអនុវត្ត ត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយជូនដំណឹងទៅម្ចាស់បំណុលដែលនឹងត្រូវទទួលចំណែក និងកូនបំណុលនៃការអនុវត្ត អំពីទីកន្លែងនៃការចែកចំណែក (CCP៤៨៨-១) ជាអាទិ៍។

នីតិវិធីចែកចំណែកនឹងអាចត្រូវបានធ្វើឡើងដោយអាជ្ញាសាលា (ចលនវត្ថុ) ឬតុលាការអនុវត្ត (អចលនវត្ថុ ជាអាទិ៍)។ ប្រសិនបើការចែកចំណែកត្រូវបានធ្វើឡើងដោយ តុលាការអនុវត្ត តុលាការអនុវត្តនឹងរៀបចំនីតិវិធីនេះជាជំហានៗ ដូចជា រៀបចំការចែកចំណែក ធ្វើតារាងចែកចំណែក និងអនុវត្តការចែកចំណែក។

+ **ការរៀបចំចែកចំណែក** ៖ តុលាការអនុវត្តនឹងកំណត់កាលបរិច្ឆេទចែកចំណែក ទីកន្លែងចែកចំណែក កំណត់ម្ចាស់បំណុលដែលត្រូវទទួលចំណែក(CCP៤៥៣ និងCCP៤៩០-២-គ)។

+ **តារាងចែកចំណែក** ៖ ករណីមានម្ចាស់បំណុលតែម្នាក់ ឬករណីម្ចាស់បំណុលមានច្រើននាក់ ប៉ុន្តែទឹកប្រាក់នោះមានគ្រប់គ្រាន់សម្រាប់សងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត តុលាការអនុវត្តមិនចាំបាច់ធ្វើតារាងចែកចំណែកនោះទេ ហើយប្រសិនបើនៅសល់ តុលាការអនុវត្តត្រូវប្រគល់ ទៅឲ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៤៨៩ (២) ក.ន.រ) និងប្រសិនបើពិនិត្យឃើញថាមិនគ្រប់គ្រាន់ តុលាការអនុវត្ត ត្រូវធ្វើតារាងចែកចំណែក ហើយមូលដ្ឋាននៃការកសាងតារាងនេះ គឺផ្អែកលើលិខិតគណនាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ។

+ **ការអនុវត្តការចែកចំណែក** ៖ ករណីចែកចំណែកមិនធ្វើតាមតារាងចែកចំណែក ឬគ្មានតារាងចែកចំណែក តុលាការអនុវត្តត្រូវប្រគល់ប្រាក់នោះទៅឲ្យម្ចាស់បំណុលនីមួយៗ។ ករណីចែកចំណែកធ្វើតាមតារាងចែកចំណែក គឺតុលាការអនុវត្តប្រគល់ប្រាក់ចំណែកឲ្យទៅម្ចាស់បំណុលដែលមានវត្តមាននៅកាលបរិច្ឆេទនៃការចែកចំណែក ទៅតាមលំដាប់លំដោយនៃតារាងចែកចំណែក។

លិខិតដែលត្រូវចេញក្នុងដំណាក់កាលនេះមានដូចជា ៖

- ដីកាសម្រេចអំពីពេលវេលាចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក (CCP៤២២)
- ពាក្យសុំទាមទារឲ្យចែកចំណែក (CCP៤២៦)
- លិខិតជូនដំណឹង (CCP៤)
- ដីកាសម្រេចកំណត់អំពីកាលបរិច្ឆេទនៃការចែកចំណែក (CCP៤៨៨-១)
- លិខិតដាស់តឿន (CCP៤២២-២)
- លិខិតគណនាសិទ្ធិលើបំណុល (CCP៤២៣)
- តារាងចែកចំណែក (CCP៤៩០-១)
- កំណត់ហេតុស្តីពីការចែកចំណែក (CCP៤៩០-៤)

+ **ការប្រគល់អចលនវត្ថុ** ៖ ក្រោយចំណាត់ការរបស់តុលាការអនុវត្ត កូនបំណុលនៃការអនុវត្ត ឬអ្នកកាន់កាប់អចលនវត្ថុ ត្រូវប្រគល់អចលនវត្ថុឲ្យទៅអ្នកទិញ ហេតុនេះប្រសិនបើមិនប្រគល់ដោយស្មគ្រ័ចិត្តនោះទេ អ្នកទិញអាចដាក់ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យប្រគល់អចលនវត្ថុទៅតុលាការអនុវត្ត ក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ហើយ(CCP៤៥០)។ ប្រសិនបើអ្នកទិញចង់បណ្តេញអ្នកកាន់កាប់ចេញដោយបង្ខំ បន្ទាប់ពីរយៈពេល ៦ ខែបានកន្លងផុត នោះអ្នកទិញត្រូវដាក់ពាក្យបណ្តឹងតាមក្រមនីតិវិធី។

ដីកាសម្រេចបង្គាប់ឲ្យប្រគល់អចលនវត្ថុ គឺជានីតិវិធីបន្ទាប់បន្សំនៃនីតិវិធីអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ ហើយត្រូវបានបង្កើតឡើងដើម្បីផ្តល់ភាពងាយស្រួល ចំណេញពេលវេលាសោហ៊ុយ មានលទ្ធភាពលក់ក្នុងតម្លៃខ្ពស់ តាមរយៈការសម្របសម្រួលឲ្យអ្នកទិញទទួលបានការកាន់កាប់ឲ្យឆាប់រហ័ស ដោយមិនតម្រូវឲ្យអ្នកទិញដាក់ពាក្យបណ្តឹងទាមទារអចលនវត្ថុផ្អែកលើកម្មសិទ្ធិនោះទេ ហេតុនេះ នៅពេលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឲ្យប្រគល់អចលនវត្ថុ ចំពោះកូនបំណុលនៃការអនុវត្ត ឬអ្នកកាន់កាប់អចលនវត្ថុ លុះត្រាតែ អ្នកកាន់កាប់នោះគ្មានមូលហេតុគតិយុត្តនៃការកាន់កាប់ដោយផ្អែកទៅលើសិទ្ធិតតាំងជាមួយនឹងអ្នកទិញ សម្រាប់សំណុំរឿងនៃការអនុវត្តនោះ និងមុនពេលចេញ

ដីកាសម្រេច តុលាការអនុវត្ត ត្រូវសួរអ្នកកាន់កាប់ ហើយដីកាសម្រេចនេះអាចអនុវត្តបានលុះត្រាតែចូលជាស្ថាពរ ដោយផុតសិទ្ធិប្តឹងជំទាស់របស់បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ (អ្នកកាន់កាប់ ជាអាទិ៍) ឬតុលាការនៃបណ្តឹងជំទាស់សម្រេចតម្កល់ដីកាសម្រេចដើម។

ដោយសារដីកាសម្រេចនេះជាលិខិតអនុវត្តតាមមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ ក.ន.រ នោះអ្នកទិញអាចដាក់ពាក្យសុំអនុវត្តដោយបង្ខំដើម្បីបណ្តេញអ្នកកាន់កាប់ចេញបាន ដោយផ្អែកលើដីកាសម្រេច។

\+ **ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា (CCP៥២៥)** ៖ នៅពេលសំណុំរឿងអនុវត្តដោយបង្ខំ បាននឹងកំពុងចាត់ការ ម្ចាស់បំណុលនៃការអនុវត្តផ្សេងទៀតបានដាក់ពាក្យសុំអនុវត្ត ដោយបង្ខំចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសម្រាប់សំណុំរឿងមុនករណីនេះតុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ផងដែរ ហេតុនេះ ដីកាសម្រេចនេះនឹងបញ្ជូនទៅកូនបំណុលនៃការអនុវត្ត និងធ្វើនីតិវិធីចុះបញ្ជីរឹបអូស ស្ថានភាពបែបនេះ ហៅថា ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា។ ប្រសិនបើដីកាសម្រេចមុន មានដំណើរការទៅមុខ នីតិវិធីនៃការលក់ដោយផ្អែកលើដីកាសម្រេចក្រោយ នឹងពុំមានដំណើរការនោះទេ ហើយម្ចាស់បំណុលនៃការអនុវត្តដែលទទួលបានដីកាសម្រេចក្រោយ ត្រូវបានពអនុវត្តដូចគ្នានឹងម្ចាស់បំណុលទាមទារឲ្យចែកចំណែក (CCP៥៥៣-ក)។ ម្យ៉ាងវិញទៀត ការជូនដំណឹងទៅឲ្យម្ចាស់បំណុលនៃការអនុវត្តផ្អែកលើដីកាសម្រេចមុន ដើម្បីឲ្យដឹងអំពីហេតុនៃដីកាសម្រេចចាប់ផ្តើមត្រួតគ្នា, អំពីផលប៉ះពាល់នៃចំនួនទឹកប្រាក់ដែលម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបាន, ផ្តល់ឱកាសឲ្យអនុវត្តលើទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុល និងប្រសិនបើនីតិវិធអនុវត្តដោយបង្ខំផ្អែកលើដីកាសម្រេចមុនត្រូវបានលុបចោល នាំឲ្យដីកាសម្រេចក្រោយនឹងត្រូវបន្តដោយស្វ័យប្រវត្តិ(CCP៥២៥-២)។

តុលាការអនុវត្ត បានបន្តនីតិវិធីដោយផ្អែកលើដីកាសម្រេចក្រោយនីតិវិធីលក់នឹងបន្ត ប៉ុន្តែក្នុងករណី សិទ្ធិផ្សេងៗត្រូវបានបង្កើតឡើងចំពោះអចលនវត្ថុនេះ ដូចជា ផលុបភោគ សិទ្ធិជួលអចិន្ត្រៃយ៍ ឬកម្មសិទ្ធិជាអាទិ៍ ក្រោយចុះបញ្ជីរឹបអូសផ្អែកលើដីកាសម្រេចមុន ប៉ុន្តែចុះបញ្ជីមុនដីកាសម្រេចក្រោយសិទ្ធិទាំងនេះមិនអាចតតាំងជាមួយនឹងដីកាសម្រេចមុននោះទេ ប៉ុន្តែអាចតតាំងជាមួយនឹងដីកាសម្រេចក្រោយ។ ហេតុនេះ ប្រសិនបើអចលនវត្ថុនោះ ត្រូវបានលក់ ដោយផ្អែកលើដីកាសម្រេចដើម សិទ្ធិទាំងនេះត្រូវរលត់ ប៉ុន្តែ ប្រសិនបើការលក់ផ្អែកលើដីកាសម្រេចក្រោយសិទ្ធិទាំងនេះបន្តអាទិភាព នាំឲ្យអ្នកទិញនឹងទទួលបន្ទុក ឬម្ចាស់សិទ្ធិទាំងនេះអាចតតាំងបាន ហើយអានុភាពនៃការលក់នឹងប្រែប្រួល អាស្រ័យទៅលើការលក់ផ្អែកលើដីកាសម្រេចមុន ឬដីកាសម្រេចក្រោយ និងការបន្តនីតិវិធីលក់ តាមដីកាសម្រេចក្រោយអាចធ្វើបានលុះត្រាតែគ្មានសិទ្ធិដែលអាចតតាំង(CCP៥២៥-៤) ហើយប្រសិនបើមានស្ថានភាពនេះតុលាការអនុវត្តគប្បីវាយតម្លៃ និងកំណត់តម្លៃលក់អប្បបរមាឡើងវិញ (CCP៥៣០ និងCCP៥៣២)។ ម្យ៉ាងវិញទៀត ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ដោយផ្អែកលើដីកាសម្រេចក្រោយបានដាក់ពាក្យសុំអនុវត្ត

ក្រោយពេលកូនបំណុលនៃការអនុវត្តចាត់ចែងអចលនវត្ថុនោះ តាមរយៈការលក់ទៅឲ្យតតិយជន ដោយបានចុះបញ្ជីកម្មសិទ្ធិ ជាអាទិ៍ តុលាការអនុវត្តមិនត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនោះទេ ដោយហេតុថា តតិយជនអាចតតាំងជាមួយនឹងអ្នកទិញតាមផ្លូវតុលាការបាន នាំឲ្យការចេញដីកាសម្រេចបង្គាប់ឲ្យប្រគល់អចលនវត្ថុ ក៏មិនអាចធ្វើទៅបានផងដែរ (CCP៤២៤-៤-៣ និងCCP៤៥០-១-២)។ ទោះបីជាតតិយជន ដែលបានទិញអចលនវត្ថុនេះទុច្ចរិត ក៏តតិយជននោះនៅតែអាចតតាំងជាមួយនឹងអ្នកទិញតាមផ្លូវតុលាការបានផងដែរ ដោយហេតុថា ទុច្ចរិត ឬសុចរិត ឬកាន់កាប់ គឺជាល័ក្ខខ័ណ្ឌ អនុវត្តចំពោះចលនវត្ថុ (CC១៩៣ និង CC១៣៤-២) ចំណែកអចលនវត្ថុល័ក្ខខ័ណ្ឌតតាំងគឺ ចុះបញ្ជី។ (CCP១៣៤-១)។

លើសពីនេះទៅទៀត ម្ចាស់បំណុលផ្សេងទៀត បានចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន ក្រោយពេលចេញដីកាសម្រេចមុន ប៉ុន្តែមុនពេលចេញដីកាសម្រេចក្រោយ មិនអាចតតាំងជាមួយនឹងអ្នកទិញដែលផ្អែកលើដីកាសម្រេចក្រោយបានទេ ដោយហេតុថា ម្ចាស់បំណុលផ្សេងទៀត ដែលបានធ្វើនីតិវិធីរឹបអូសជាបណ្តោះអាសន្ន គឺមានគោលបំណងលក់អចលនវត្ថុនោះ ដើម្បីប្តូរជាប្រាក់ទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ខ្លួន នាំឲ្យការរឹបអូសជាបណ្តោះអាសន្ន ត្រូវរលត់ក្រោយការលក់ (CCP៤៣១-៣)។ ម្ចាស់បំណុលនេះមានសិទ្ធិទទួលចំណែក (មាត្រា ៤៥៣ ចំណុច គ ក.ន.រ) ទោះបីជាការចែកចំណែកត្រូវបានតម្កល់ទុក រហូតដល់សាលក្រមនៃបណ្តឹងអង្គសេចក្តីចូលជាស្ថាពរ (មាត្រា៤៩៤ កថាខណ្ឌទី ១ ចំណុច ខ ក.ន.រ)។ ផ្ទុយទៅវិញ ប្រសិនបើ ជាការចាត់ចែងជាបណ្តោះអាសន្ន គឺម្ចាស់បំណុលមានបំណងរក្សាសិទ្ធិ ដូចជាការពារកម្មសិទ្ធិរបស់តតិយជន ឬហាមឃាត់ការផ្ទេរការកាន់កាប់ ជាអាទិ៍ មិនមែនគោលបំណងឲ្យសងជាប្រាក់នោះទេ ហេតុនេះត្រូវពិចារណាអំពីពេលវេលានៃការចុះបញ្ជី នាំឲ្យប្រសិនបើបានចុះបញ្ជីមុន គឺអាចតតាំងជាមួយនឹងអ្នកទិញបាន។

+ **ម្ចាស់បំណុលដែលត្រូវទទួលចំណែក (មាត្រា ៤៥៣ ក.ន.រ)៖** ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត និងម្ចាស់បំណុលដែលទទួលបានដីកាសម្រេចចាប់ផ្តើមត្រួតគ្នា ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែក (មាត្រា ៤៥៣ ចំណុច ខ ក.ន.រ) និងម្ចាស់បំណុលដែលបានចុះបញ្ជីការរឹបអូសជាបណ្តោះអាសន្ន មុនការចុះបញ្ជីអំពីការអនុវត្តដោយបង្ខំលើកដំបូង (មាត្រា ៤៥៣ ចំណុច គ ក.ន.រ) ត្រូវទទួលចំណែក។ ម្ចាស់បំណុលដែលអាចធ្វើការទាមទារឲ្យចែកចំណែក គឺមានចែងក្នុងមាត្រា ៤២៦ កថាខណ្ឌទី ១ ក.ន.រ ដែលមាន ១) ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត លើកលែងតែអ្នកដែលមានសិទ្ធិប្រាតិភោគប្រត្យក្សដែលនៅបន្តអត្ថិភាពក្រោយការលក់ ២) ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ក្រោយការចុះបញ្ជីអំពីការអនុវត្តដោយបង្ខំ ៣) ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថាមានឯកសិទ្ធិទូទៅ។ ការទាមទារឲ្យបែងចែកចំណែកត្រូវធ្វើឡើងក្នុងអំឡុងពេលនៃការកំណត់ចុងក្រោយនៃការទាមទារឲ្យចែកចំណែក ដោយផ្ទាល់ទៅតុលាការអនុវត្តដែលទទួល

បន្ទុករឿងក្តីអនុវត្ត ដោយសរសេរនូវមូលហេតុ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ការប្រាក់ និងសិទ្ធិលើបំណុលបន្ទាប់បន្សំផ្សេងទៀត លើកលែងតែករណីដែលម្ចាស់បំណុលបានដាក់ពាក្យសុំអនុវត្តដោយបង្ខំថ្មីមួយទៀត ដែលតុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្តើមត្រួតគ្នា។ តុលាការអនុវត្តនឹងធ្វើការជូនដំណឹងអំពីហេតុនេះទៅម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត។ ប៉ុន្តែ ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវបានតុលាការអនុវត្តចេញដីកាសម្រេចលើកចោលពាក្យសុំ ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន (មាត្រា ៤២៦ ក.ន.រ)។

## ៤. ករណីសិក្សា

(1) ករណី X មានសិទ្ធិជួលនិងបានកាន់កាប់លើដីដែលបានរឹបអូស ប៉ុន្តែឯកសារលំអិតមិនបានរៀបរាប់អំពីសិទ្ធិជួលរបស់ X នោះទេ។ Y បានទិញដីនេះតាមរយៈការលក់ដោយបង្ខំនិងបានបង់ប្រាក់រួច។ បន្ទាប់ពីបង់ប្រាក់រួច Y បានដឹងអំពីសិទ្ធិជួលរបស់ X ។ ដោយសារ X បានកាន់កាប់ដីនេះ តាំងពីមុនពេលរឹបអូស តើ X អាចអះអាងអំពីសិទ្ធិជួលរបស់ខ្លួនចំពោះ Y បានដែរឬទេ? ហេតុអ្វី? **តើយើង ត្រូវការពារ Y បានយ៉ាងដូចម្តេច?**

(2) ករណីឯកសារបានបញ្ជាក់ថា X មានសិទ្ធិជួលនិងបានកាន់កាប់លើដីដែលបានរឹបអូស ហើយតុលាការអនុវត្តបានកំណត់តម្លៃអប្បរមាទាបជាងតម្លៃដែលមិនមានសិទ្ធិជួល។ Y បានទិញដីតាមតម្លៃទាបនេះ។ ប៉ុន្តែតាមពិតដីនេះពុំមានសិទ្ធិជួលនោះទេ។

តើកូនបំណុលនៃការអនុវត្តអាចទាមទារឲ្យ Y បង់ប្រាក់បន្ថែមដោយផ្អែកលើសេចក្តីចម្រើនឥតហេតុបានឬទេ?

(3) A បានឈ្នះក្តី ទទួលបានសាលក្រមផ្តល់តាវការលិកនូវទឹកប្រាក់ចំនួន ១០,០០០ដុល្លា ចំពោះ B នៅតុលាការសាលាដំបូង សាលក្រមបានប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន ។ A បានរឹបអូសអចលនវត្ថុរបស់ B ដោយផ្អែកតាមការប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន ហើយC បានក្លាយជាអ្នកទិញតាមរយៈការលក់ដោយបង្ខំ និងបានបង់ថ្លៃលក់រួចហើយ។ ប៉ុន្តែ B បានប្តឹងឧទ្ធរណ៍និងបានទទួលសាលដីកាលុបចោលសាលក្រមតុលាការសាលាដំបូង។ សាលដីកាសាលាឧទ្ធរណ៍គឺជាឯកសារមួយនៃមាត្រា៣៧០ កថាខណ្ឌ១ ចំណុចក នៃក.ន.រ។ B បានយកសាលដីកាសាលាឧទ្ធរណ៍ ជូនទៅតុលាការអនុវត្ត បន្ទាប់ពីការបង់ថ្លៃលក់របស់ C។

**តើ B អាចទាមទារឲ្យ C ប្រគល់កម្មសិទ្ធិអចលនវត្ថុត្រឡប់វិញបានឬទេ?**

(4) នៅក្នុងមាត្រា៣៧០ កថាខណ្ឌ១ ចំណុចក នៃក.ន.រ បានចែងថា តុលាការអនុវត្តឬអាជ្ញាសាលាត្រូវផ្អាកនូវការអនុវត្តដោយបង្ខំ ហើយត្រូវលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ប្រសិនបើមានឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចថាលុបចោលលិខិតអនុវត្ត ក្រៅពីលិខិតយថាភូតដែលបានកំណត់ក្នុងចំណុច ច កថាខណ្ឌ២ នៃមាត្រា៣៥០ ក.ន.រ ឬឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថាលុបចោលការប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន។

A, B និង C ជាតួអង្គក្នុងករណីសិក្សាទី (៣)។

តើត្រូវការពារ C តាមវិធីណា?

(5) A បានឈ្នះក្តី ទទួលបានសាលក្រមផ្តល់តាវការលិកន្ទវទឹកប្រាក់ចំនួន ១០,០០០ដុល្លា ចំពោះ B នៅតុលាការសាលាដំបូង។ សាលក្រមបានចូលជាស្ថាពរ។ B បានសងប្រាក់១០,០០០ដុល្លា ទៅឲ្យ A ដោយស្ម័គ្រចិត្ត។ ប៉ុន្តែ A បានរឹបអូសអចលនវត្ថុរបស់ B ដោយផ្អែកលើសាលក្រមស្ថាពរ។ B ដាក់ពាក្យប្តឹងតវ៉ាចំពោះការទាមទារ (ម.៣៦៣ ក.ន.រ)។ នៅពេលបណ្តឹងតវ៉ាកំពុងចាត់ការ C បានទិញអចលនវត្ថុតាមរយៈការលក់ដោយបង្ខំ ហើយបានបង់ថ្លៃលក់។ ក្រោយការបង់ថ្លៃលក់ B បានឈ្នះលើបណ្តឹងតវ៉ាចំពោះការទាមទារនិងបានទទួលសាលក្រមហាមឃាត់ការអនុវត្តដោយបង្ខំ។ សាលក្រមនេះគឺ ឯកសារមួយនៃមាត្រា៣៧០ កថាខណ្ឌ១ ចំណុចខ នៃក.ន.រ។ B បានយកសាលក្រមនៃបណ្តឹងតវ៉ាចំពោះការទាមទារ ជូនទៅតុលាការអនុវត្ត បន្ទាប់ពីការបង់ថ្លៃលក់របស់C។

**តើ B អាចទាមទារឲ្យC ប្រគល់កម្មសិទ្ធិអចលនវត្ថុរបស់ខ្លួនត្រឡប់មកវិញបានឬទេ?**

(6) ករណីម្ចាស់បំណុល X បានឈ្នះក្តី Y លើបណ្តឹងទាមទារប្រាក់ចំនួន ១០ លានដុល្លា តាមរយៈសេចក្តីសម្រេចមជ្ឈតករបរទេស។

ដោយសារ X ត្រូវរឹបអូសអចលនទ្រព្យរបស់ Y នៅប្រទេស Cហើយ X ក៏បានដាក់ពាក្យសុំអនុវត្តសេចក្តីមជ្ឈតករនេះ។ សាលាឧទ្ធរណ៍នៃប្រទេស C មានសមត្ថកិច្ចសម្រេចលើរឿងនេះ បានចេញដីកាសម្រេចទទួលស្គាល់ឲ្យអនុវត្តសេចក្តីសម្រេចមជ្ឈតករបរទេសនេះ។ Y បានប្តឹងជំទាស់ទៅតុលាការកំពូល ប៉ុន្តែតុលាការកំពូលសម្រេចចុងក្រោយ ដោយបានទទួលស្គាល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ហើយសេចក្តីសម្រេចនេះ បានចូលជាស្ថារពរ។

បន្ទាប់ពីបានលិខិតបញ្ជាក់ការចូលជាស្ថាពរ និងរូបមន្តអនុវត្ត X បានដាក់ពាក្យសុំអនុវត្តដោយបង្ខំ ហើយតុលាការអនុវត្តបានចេញដីការឹបអូស អចលនវត្ថុរបស់ Y ក្នុងនោះមានដី ( L1, L2, L3) តុលាការបានចាត់ឲ្យអាជ្ញាសាលាធ្វើការស្រាវជ្រាវស្ថានភាពជាក់ស្តែងដីទាំងនេះ ហើយបានធ្វើឯកសារលំអិត និងបានកំណត់តម្លៃអប្បរមា បន្ទាប់មកបានប្រកាសផ្សាយជាសាធារណៈអំពីការលក់ឡាយឡុង និងកាលបរិច្ឆេទនៃការដេញថ្លៃ។ អ្នកទិញមួយចំនួនបានដាក់ពាក្យចូលរួមដេញថ្លៃ ហើយបានកក់ប្រាក់ ចំនួន ១០% នៃតម្លៃអប្បរមាដែលបានប្រកាសលក់ដោយបង្ខំនេះ។ នៅកាលបរិច្ឆេទដេញថ្លៃ ស្រាប់តែមានដីកាសម្រេចពីសាលាឧទ្ធរណ៍សម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំនេះតាមមាត្រា ៣៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយសំអាងលើពាក្យបណ្តឹងសុំឲ្យជំនុំជម្រះសាជាថ្មីរបស់កូនបំណុលនៃការអនុវត្ត Y។

១.តើការទទួលយកបណ្តឹងជំនុំជម្រះសាជាថ្មី របស់សាលាឧទ្ធរណ៍ត្រឹមត្រូវតាមនីតិវិធីច្បាប់ ដែរឬទេ?

២.តើដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំរបស់សាលាឧទ្ធរណ៍នេះមានអានុភាពអនុវត្ត ដែលតុលាការអនុវត្តនៃសាលាដំបូងមានសមត្ថកិច្ចត្រូវតែអនុវត្តតាមដែរឬទេ?

៣.តើម្ចាស់បំណុលនៃការអនុវត្ត X មានសិទ្ធិធ្វើអ្វីខ្លះចំពោះរឿងនេះ?

៩.ប្រសិនបើតុលាការអនុវត្តសម្រេចផ្អាកតាមដីកាសម្រេចបង្គាប់ឲ្យផ្អាករបស់សាលាឧទ្ធរណ៍ អ្នកទិញដែលបានកក់ប្រាក់ចូលរួមដេញថ្លៃរួចហើយ អាចធ្វើអ្វីបាន?

(7) A ជាម្ចាស់បំណុលនៃការអនុវត្ត, B ជាកូនបំណុលនៃការអនុវត្ត, ដី L ជាកម្មវត្ថុនៃការអនុវត្តដែលជាកម្មសិទ្ធិរបស់ B, C គឺជាតតិយជន, X ជាតុលាការអនុវត្ត

→ X បានរឹបអូសដី L ផ្អែកតាមពាក្យសុំរបស់ A

→ C បានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនេះ

**តើត្រូវដោះស្រាយដូចម្តេច?**

# សិក្ខាសាលាគណៈមេធាវី(ធំ)លើកទី១០

## ប្រធានបទ៖ អង្គហេតុចម្បង និងការសរសេរពាក្យបណ្ដឹង

## ថ្ងៃទី ២០ សីហា ២០១៥

# អង្គហេតុចម្បង និងការសរសេរពាក្យបណ្តឹង

## សេចក្តីផ្តើម

បុគ្គលទាំងអស់ដែលរស់នៅក្នុងសង្គម រមែងផ្សារភ្ជាប់គ្នាដោយទំនាក់ទំនងការងារ ពាណិជ្ជកម្ម ទំនាក់ទំនងបុគ្គលឯកជន ដូចជាចំណងគ្រួសារ កូន និងទ្រព្យជាដើម។ ទំនាក់ទំនងទាំងនេះអាចប្រព្រឹត្តទៅដោយរលូន និងទំនាក់ទំនងមួយចំនួនពេបប្រទះនឹងភាពប្រេះឆា។ ជាទូទៅ ភាគីដែលរងនូវវិវាទតែងតែធ្វើការផ្សះផ្សាគ្នាតាមរយៈមធ្យោបាយផ្សេងៗដូចជាការចរចារ ការសម្របសម្រួល និងការដោះស្រាយដោយប្រើប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាដើម។ ក្នុងករណីដែលវិវាទមិនត្រូវបានដោះស្រាយដោយជោគជ័យ មានន័យថា ភាគីបរាជ័យក្នុងការដោះស្រាយវិវាទដោយខ្លួនឯង ភាគីនៃវិវាទចាំបាច់ត្រូវតែធ្វើការបញ្ជូនវិវាទទៅដោះស្រាយនៅតុលាការ។ ដូច្នេះវិវាទ គឺជាដើមចមនៃបណ្តឹង ហើយបណ្តឹងគឺជាមូលហេតុដែលនាំឲ្យមានសេចក្តីសម្រេចរបស់តុលាការ។ ជាគោលការណ៍ យើងនិយាយថា "គ្មានបណ្តឹង គឺគ្មានសាលក្រម" ដែលបណ្តឹងគឺជាដើមហេតុដែលនាំឲ្យមាននីតិវិធីបណ្តឹងកើតឡើង។

បណ្តឹងត្រូវបានមនុស្សទូទៅស្គាល់ថា ជាមធ្យោបាយតែមួយដែលអាចនាំវិវាទទៅឲ្យតុលាការ និងដែលអនុញ្ញាតឲ្យតុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងបាន។

ហេតុដូច្នេះ តើបណ្តឹងគឺជាអ្វី? តើបណ្តឹងមានទម្រង់បែបណា? តើចំណុចអ្វីខ្លះដែលត្រូវសរសេរក្នុងបណ្តឹង? ចម្លល់ទាំងអស់នេះ ត្រូវធ្វើការបង្ហាញនៅក្នុងបទបង្ហាញនាឱកាសនេះ។

### ១. សញ្ញាណទូទៅនៃបណ្តឹង

បណ្តឹងសំដៅលើសកម្មភាពទាមទារមួយ ដែលធ្វើឡើងដោយដើមចោទចំពោះចុងចម្លើយទៅកាន់តុលាការនៃការជំនុំជម្រះក្តី ដោយបានអះអាងអំពីអត្ថិភាព ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ ហើយទាមទារអោយតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដោយផ្អែកទៅលើការអះអាងទាំងនេះ តាមរយៈការដាក់ពាក្យបណ្តឹង។ បណ្តឹងអាចកើតមានចាប់ពីពេលដែលមានការដាក់ពាក្យបណ្តឹង ដូច្នេះ នីតិវិធីបណ្តឹងនឹងត្រូវចាប់ផ្តើម។

បុគ្គលណាក៏ដោយដែលមានសមត្ថភាពតាមផ្លូវច្បាប់សុទ្ធតែអាចធ្វើពាក្យបណ្តឹង ដើម្បីឲ្យតុលាការធ្វើការសម្រេចសេចក្តីចំពោះការទាមទាររបស់ខ្លួន ហើយការធ្វើបណ្តឹងអាចធ្វើឡើងដោយបុគ្គលឯកជនខ្លួនឯង ឬតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសរើស ដែលអ្នកតំណាងដែលអាចធ្វើសកម្មភាពបណ្តឹងក្នុងន័យនេះគឺត្រូវតែជាមេធាវី លើកលែងតែករណីពិសេសមួយចំនួនដូចមានចែងនៅ

ក្នុងមាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ទោះបីជាបណ្តឹងត្រូវបានធ្វើឡើងដោយភាគីខ្លួនឯងក្តី ឬដោយមេធាវីក្តី ក៏បណ្តឹងទាំងនោះចាំបាច់ត្រូវតែគោរពតាមវិធានដែលកំណត់អំពីចំណុចផ្សេងៗដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹង ដូចមានកំណត់នៅក្នុងមាត្រា ៧៥ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះបណ្តឹងដែលធ្វើឡើងដោយពុំបានគោរពតាមវិធាននានាដូចមានកំណត់ដូចក្នុងមាត្រាខាងលើនេះទេ នោះតុលាការអាចលើកបណ្តឹងនោះចោលដោយសេចក្តីសម្រេច [1] ។

កាលណាតុលាការទទួលបានពាក្យបណ្តឹង តុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹង ដោយធ្វើការជំនុំជម្រះទៅលើបណ្តឹងនោះ និងចេញសេចក្តីសម្រេចតាមរយៈសាលក្រម ។ សាលក្រម [2] គឺជាលទ្ធផលចុងក្រោយរបស់បណ្តឹង ដែលតុលាការត្រូវឆ្លើយតបទៅនឹងបណ្តឹងរបស់ភាគីតាមរយៈការទាមទារនានានៅក្នុងបណ្តឹងមានន័យថា បើភាគីទាមទារអ្វីមួយ តុលាការត្រូវធ្វើការឆ្លើយតបទៅនឹងការទាមទារនោះ បន្ទាប់ពីខ្លួនយល់ឃើញ ឬសំអាងហេតុដែលកើតចេញពីអំណះអំណាងរបស់ភាគី ដោយមានការផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាង។ ដូច្នេះជាគោលការណ៍ តុលាការធ្វើការជំនុំជម្រះ និងចេញសាលក្រមត្រឹមតែទំហំដែលបានទាមទារនៅក្នុងបណ្តឹងតែប៉ុណ្ណោះ [3] ។

ដើម្បីអោយតុលាការអាចចេញសាលក្រម ដើម្បីឆ្លើយតបទៅនឹងការទាមទារតាមផ្លូវបណ្តឹងណាមួយបាន ភាគីដែលដាក់ពាក្យបណ្តឹង និងតុលាការដែលទទួលពាក្យបណ្តឹងត្រូវយល់ដឹងអំពីប្រភេទនៃបណ្តឹង ដែលត្រូវបានបែងចែកទៅតាមបទដ្ឋានផ្សេងៗគ្នា ហើយដែលប្រភេទបណ្តឹងត្រូវបានចែកចេញជា៖

**១. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក**

**២. បណ្តឹងទាមទារឲ្យបញ្ជាក់ និង**

**៣. បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្តិ ។**

តើបណ្តឹងទាំងបីខាងលើមានអត្ថន័យខ្លឹមសារយ៉ាងណាខ្លះ ?

---

[1] មាត្រា ៧៨ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[2] មាត្រា១៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[3] មាត្រា ១៨២ កថាខណ្ឌទី ១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី៖

១. តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគី បានសុំ

២. តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ ។

## ១. បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក

បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក គឺជាបណ្ដឹងមួយដែលទាមទារឲ្យតុលាការចេញសាលក្រម បង្គាប់ឲ្យចុងចម្លើយផ្ដល់តាវកាលិកកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្ដល់តាវកាលិក យោងតាមការកំណត់តាមផ្លូវច្បាប់សារធាតុ ។

### ១.១ ប្រភេទនៃបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក

បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកមានច្រើនប្រភេទដូចជា៖

➢ ការទាមទារប្រាក់ជាក់លាក់

<u>ករណីទី១៖</u>

ដើមចោទ A ទាមទារអោយចុងចម្លើយ B សងប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារ ដោយផ្អែក

លើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើងកាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ ហើយ

ទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យ B សងប្រាក់នោះ។

- <u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖</u>

បង្គាប់ឲ្យចុងចម្លើយ B សងប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅឲ្យដើមចោទ A។

➢ ការទាមទារឲ្យចាកចេញ និងប្រគល់អចលនវត្ថុជាក់លាក់ (ដី ឬផ្ទះ)

<u>ករណីទី២៖</u>

B បានសង់ផ្ទះមួយនៅលើដីរបស់ A ដោយពុំមានការអនុញ្ញាតពី A។ A ចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យ B រុះរើផ្ទះចេញពីដីរបស់ខ្លួន។

-<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖</u>

បង្គាប់ឲ្យចុងចម្លើយ B ចាកចេញ និងប្រគល់ដី ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធកម្មវត្ថុ ទៅឲ្យដើមចោទ A។

➢ ការទាមទារឲ្យប្រគល់ចលនវត្ថុកំណត់ជាក់លាក់មួយ

<u>ករណីទី៣៖</u>

A បានទិញរថយន្តមួយគ្រឿងពី B ប៉ុន្តែ B មិនបានប្រគល់រថយន្តនោះមកអោយ A នោះទេ។ A ចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យប្រគល់រថយន្តមកឲ្យខ្លួន។

- **<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖</u>**
  បង្គាប់ឲ្យចុងចម្លើយ B ប្រគល់រថយន្តទៅឲ្យដើមចោទ A (ត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃរថយន្ត ដូចជា លេខចុះបញ្ជី ពណ៌ ប្រភេទ ឆ្នាំផលិត ស៊េរី ជាដើម)។

➢ **ការទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដី**

- **<u>ករណីទី៤៖</u>**
  A បានទិញដីមួយកន្លែងពី B នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ ប៉ុន្តែ B មិនបានសហការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីនោះទេ។ ដូច្នេះ A ចង់ដាក់ពាក្យបណ្តឹងដើម្បីចុះបញ្ជីផ្ទេរកម្មសិទ្ធិដី។

  -**<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖</u>**

  បង្គាប់ឲ្យចុងចម្លើយ B ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលពាក់ព័ន្ធនឹងដីដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ A ដោយផ្អែកលើកិច្ចសន្យាលក់ទិញដី ដែលបានធ្វើកាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

**សំគាល់៖** ក្នុងករណីដែលដើមបណ្តឹង A ឈ្នះក្តី នោះ A អាចយកសាលក្រមស្ថាពរដែលមានអត្ថន័យបង្គាប់ឲ្យចុងចម្លើយ B ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលនៃដីនេះ ទៅចុះបញ្ជីតែឯកឯងនៅការិយាល័យសុរិយោដីបាន [4] ។

➢ **ការទាមទារឲ្យលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិដី**

  **<u>ករណីទី៥៖</u>**

  A បានលក់ដីមួយកន្លែងទៅឲ្យ B និងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិដីទាំងមូលពី A ទៅ B រួចរាល់ហើយ។ តែក្រោយមក A បានលុបចោលកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ និងចង់ ដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលការចុះបញ្ជីរបស់ B។

- **<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖</u>**
  បង្គាប់ឲ្យចុងចម្លើយ B ធ្វើនីតិវិធីលុបចោលការចុះបញ្ជី ផ្ទេរកម្មសិទ្ធិដីដែលមានកំណត់ក្នុងឧបសម្ព័ន្ធនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ចំពោះដីដែលមានបញ្ជាក់ក្នុងឧបសម្ព័ន្ធកម្មវត្ថុ ទៅឲ្យដើមចោទ A ដោយផ្អែកលើមូលហេតុនៃការលុបចោលកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[4] មាត្រា ៥២៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ១.២ បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន និងបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត

ការធ្វើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក ចែកចេញជាពីរប្រភេទគឺៈ បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន និងបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត។

### ក. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន

សំដៅទៅលើបណ្តឹងដែលធ្វើឡើងដោយដើមចោទ ដោយមានការអះអាងអំពីសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកមួយដែលពេលកំណត់នៃការអនុវត្តនោះបានមកដល់ហើយ ឬអាចហៅម្យ៉ាងទៀតថាបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន គឺជាបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនៃករណីដែលពេលកំណត់ត្រូវអនុវត្តសិទ្ធិទាមទារដែលអះអាងដោយដើមចោទបានមកដល់ មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងការវិនិច្ឆ័យទៅលើអង្គហេតុ។ ករណីទាំង ៥ ដូចបានបង្ហាញខាងលើ គឺជាឧទាហរណ៍នៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន។

### ខ. បណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលអនាគត

សំដៅទៅលើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកដែលដើមចោទបានដាក់ឡើង ដោយមានការអះអាងអំពី សិទ្ធិទាមទារឲ្យផ្តល់តាវកាលិកមួយដែលពេលកំណត់ត្រូវអនុវត្តនោះមិនទាន់មកដល់នៅឡើយ ដូចនេះ គេអាចដាក់ពាក្យបណ្តឹងបាន តែក្នុងករណីដែលមានការចាំបាច់ទាមទារ បែបនេះជាមុនតែប៉ុណ្ណោះ[5]។

ជាធម្មតា ភាពចាំបាច់ត្រូវបានទទួលស្គាល់ នៅពេលមានមូលហេតុដែលរំពឹងទុកថាកូនបំណុលនឹងអនុវត្តកាតព្វកិច្ចនៅថ្ងៃកំណត់សង ដូចជាករណីដែលកូនបំណុលបានបដិសេធនឹងអត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួនមុនដល់ថ្ងៃកំណត់សង ឬករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនមួយផ្នែកមុនពេលផ្នែកផ្សេងទៀតនៃកាតព្វកិច្ចដល់កំណត់សង។ ភាពចាំបាច់ត្រូវបានទទួលស្គាល់ផងដែរ ក្នុងករណីដែលការខូចខាតរបស់ម្ចាស់បំណុលមិនអាចជួសជុលបាន ប្រសិនបើពុំមានការសង នៅពេលដល់ថ្ងៃកំណត់សងមកដល់ ដូចជាករណីបង់អាហារកាតព្វកិច្ច ឬបង់សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន។

ករណីចាំបាច់ក្នុងការទាមទារជាមុន មានច្រើនប្រភេទដូចជាៈ

---

[5] មាត្រា ៧៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីៈ បណ្តឹងទាមទារការផ្តល់តាវកាលិកនៅពេលអនាគត អាចធ្វើឡើងបានលុះត្រាតែមានភាពចាំបាច់តម្រូវឲ្យធ្វើការទាមទារនោះជាមុន។

-**<u>ករណីទី១</u>៖**

A បានឲ្យ B ខ្ចីប្រាក់ចំនួន ១០០០ (មួយពាន់) ដុល្លារ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៤។ មុនថ្ងៃកំណត់សងមកដល់ មុខជំនួញរបស់ B ជួបប្រទះនឹងបញ្ហាធ្ងន់ធ្ងរ ហើយ B បានផ្ញើលិខិតមួយច្បាប់ទៅប្រាប់ A ថា "សុំទោស តែទ្រព្យសម្បត្តិរបស់ខ្ញុំរលាយអស់ហើយ។ សូមលើកលែងបំណុលដែលខ្ញុំបានជំពាក់ផង ព្រោះខ្ញុំនឹងពុំមានប្រាក់សងបំណុលលោកវិញទេ"។ ក្នុងស្ថានភាពនេះយើងអាចរំពឹងទុកថា B នឹងមិនសងប្រាក់ A វិញនោះទេ បើទោះជាកាលកំណត់សងបានមកដល់ក៏ដោយ។ ដូច្នេះ A ចង់ដាក់ពាក្យបណ្តឹងទាមទារឲ្យ B សងប្រាក់នាពេលអនាគត នៅថ្ងៃដែលកាលកំណត់សងមកដល់។

-**<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ</u>៖**

បង្គាប់ឲ្យចុងចម្លើយ B បង់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅ A នៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០១៥ មកដល់។

-**<u>ករណីទី២</u>៖**

A បានឲ្យ B ខ្ចីប្រាក់ចំនួន $១០០០ (មួយពាន់) ដុល្លារ សម្រាប់រយៈពេល ០១ ឆ្នាំ ក្នុង អត្រាការប្រាក់ ១០% ក្នុងមួយឆ្នាំ និងអត្រាការប្រាក់យឺតយ៉ាវចំនួន ១៥% ក្នុងមួយឆ្នាំ។ នៅពេលដល់ថ្ងៃកំណត់សង (៣១/០៥/២០១៥) បានមកដល់ B មិនបានសងប្រាក់ដើម (១០០០ដុល្លារ) និងការប្រាក់ (១០០ដុល្លារ) នោះទេ ដូច្នេះ B នឹងមិនអាចបង់ការប្រាក់យឺតយ៉ាវ (១៥%ក្នុងមួយឆ្នាំ) ដែលនឹងកើតឡើងនាពេលអនាគតនោះទេ។

-**<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ</u>៖**

១) បង្គាប់ឲ្យចុងចម្លើយ B បង់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅដើមចោទ A។

២) បង្គាប់ឲ្យចុងចម្លើយ B បង់ប្រាក់ចំនួន ១០០ (មួយរយ) ដុល្លារអាមេរិកទៅដើមចោទ A និងប្រាក់ចំនួន ១៥ (ដប់ប្រាំ) ភាគរយក្នុងមួយឆ្នាំ នៃចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ខាងលើនេះ ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៥ រហូតមកដល់ពេលសងប្រាក់រួច។

-**<u>ករណីទី៣</u>៖**

ក្នុងពេលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ A និង B មានកូនស្រីម្នាក់។ ក្រោយមក A និង B បានលែងលះគ្នា។ B បានព្រមព្រៀងជាមួយ A បង់ប្រាក់ចំនួន ៣០០ (បីរយ) ដុល្លារ ជារៀងរាល់

ចុងខែ ជាសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន។ ប៉ុន្តែក្រោយមក B បានឈប់បង់ប្រាក់នោះ។ A ចង់ដាក់ពាក្យបណ្ដឹងទាមទារសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ចាប់ពីខែនេះ (សីហា ២០១៥) រហូតដល់ពេលដែលកូនក្លាយជា នីតិជន (ខែកក្កដា ឆ្នាំ២០២០)។

-<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារៈ</u>

បង្គាប់ឲ្យចុងចម្លើយ B បង់ប្រាក់ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក នៅរៀងរាល់ចុងខែនីមួយៗ ចាប់ពីខែ សីហា ឆ្នាំ ២០១៥ ដល់ខែ កក្កដា ឆ្នាំ ២០២០ ទៅដើមចោទ A។

**បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលបច្ចុប្បន្ន** មានន័យថា ជាបណ្ដឹងដែលកាលបរិច្ឆេទកំណត់នៃ សិទ្ធិលើបំណុលមកដល់ មុនពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ក្នុងការវិនិច្ឆ័យទៅលើអង្គហេតុ។ **បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគត** មានន័យថាជាបណ្ដឹងដែលកាលបរិច្ឆេទកំណត់សងនៃសិទ្ធិបំណុលមកដល់ ក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងការវិនិច្ឆ័យ។ ដូច្នេះ ក្នុងករណីមួយចំនួន ដើមចោទបានធ្វើការទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគត ប៉ុន្តែកាលបរិច្ឆេទកំណត់សងបានមកដល់ ក្នុងអំឡុងពេលនីតិវិធី ហើយបណ្ដឹងត្រូវបានប្ដូរទៅជាបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលចប្ចុប្បន្ន ។ ដើមចោទមិនត្រូវការប្ដូរការទាមទារនោះទេ ព្រោះការទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគតរបស់ដើមចោទត្រូវបានចាត់ទុកថា រាប់បញ្ចូលទាំងការ ទាមទារឲ្យផ្ដល់តាវកាលិកនាពេលបច្ចុប្បន្នផងដែរ ក្នុងករណីដែលកាលបរិច្ឆេទកំណត់សងមកដល់ ។

**ឧទាហរណ៍ៈ** នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៥ A បានដាក់ពាក្យបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគត ដោយទាមទារឲ្យ " បង្គាប់ឲ្យចុងចម្លើយ B បង់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅឲ្យដើមចោទ A នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ មកដល់ "។ ប៉ុន្តែនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ បានមកដល់ក្នុងពេលនីតិវិធី ហើយសាលក្រមបានចេញថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០១៥។ សាលក្រមនោះសរសេរថា " បង្គាប់ឲ្យចុងចម្លើយ B បង់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅដើមចោទ A " ។

ផ្ទុយទៅវិញប្រសិនបើដើមចោទបានដាក់ពាក្យបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេល បច្ចុប្បន្ន តែតុលាការបានចេញសាលក្រមនៃបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគតនោះ ដើមចោទត្រូវការបន្ថែមនូវការទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគត ព្រោះការទាមទារឲ្យផ្ដល់ តាវកាលិកនាពេលបច្ចុប្បន្នមិនត្រូវបានចាត់ទុកថារាប់បញ្ចូលទាំងការទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគតនោះទេ។

**ឧទាហរណ៍៖** ដើមចោទបានដាក់ពាក្យបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន។ ចុងចម្លើយបានដាក់ការតវ៉ា ដែលពួកគេបានព្រមព្រៀងគ្នាចំពោះកាលបរិច្ឆេទកំណត់សងដែលនៅរយៈពេល ១ឆ្នាំក្រោយ។ តុលាការបានទទួលស្គាល់ការតវ៉ា និងបានគិតថាកាលបរិច្ឆេទកំណត់ សងមិនទាន់មកដល់។ ក្នុងករណីនេះ ដើមចោទគួរតែបន្ថែមការទាមទារឲ្យផ្តល់តាវកាលិកនាពេល អនាគត ដោយផ្អែកតាមមាត្រា ៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើដើមចោទមិនបានបន្ថែម ការទាមទារនាពេលអនាគតទេ នោះតុលាការនឹងច្រានចោលការទាមទារ។

## ១.៣ សាលក្រមនៃបណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

ប្រសិនបើតុលាការបានទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិ តាមការដែលដើមចោទបានអះអាង នោះតុលាការត្រូវចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយផ្តល់តាវកាលិកដែលមានខ្លឹមសារកំណត់មួយជាក់លាក់ ដូចជាការបង់ប្រាក់ ឬការប្រគល់អចលនវត្ថុ ជាដើម។ សាលក្រមប្រភេទនេះហៅថា **"សាលក្រមបង្គាប់ឲ្យផ្តល់តាវកាលិក"** ដែលមានអានុភាពកំណត់ជាស្ថាពរអំពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ភាគីចំពោះតាវកាលិកនោះ ដែលគេឲ្យឈ្មោះថា **"អាជ្ញាអស់ជំនុំសារធាតុ"**[6] ហើយមានអានុភាពអនុវត្តមានន័យថា ដើមចោទអាចសម្រេចនូវសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយសាលក្រម តាមការអនុវត្តដោយបង្ខំដោយផ្អែកទៅលើសាលក្រមនោះ។ សាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកគឺជាឧទាហរណ៍ចម្បងមួយនៃលិខិតអនុវត្ត[7] ។

ក្នុងករណីដែលតុលាការមិនទទួលស្គាល់ការទាមទាររបស់ដើមចោទ នោះតុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា "ច្រានចោលការទាមទាររបស់ដើមចោទ" ហើយសាលក្រមប្រភេទនេះក៏មាន "អាជ្ញាអស់ជំនុំសារធាតុ" ផងដែរ ដោយកំណត់ជាស្ថាពរនូវនត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកដែលអះអាងដោយដើមចោទ។

[6] មាត្រា ១៩៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[7] មាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច ក និងខ នៃក្រមនីតិវិធីរដ្ឋប្បវេណី៖ លិខិតអនុវត្តគឺជាលិខិតដែលបានកំណត់ដូចខាងក្រោមនេះ៖

ក-សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ

ខ-សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន ។

**<u>ការអនុវត្តសាលក្រមនៃបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគត</u>**

ប្រសិនបើសាលក្រមនៃបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគត មានភ្ជាប់ជាមួយ នឹងល័ក្ខខ័ណ្ឌ ឬពេលកំណត់មិនពិតប្រាកដ នោះដើមចោទអាចទទួលនូវរូបមន្តអនុវត្ត លុះត្រាតែ គាត់បានបញ្ជាក់ពីការបំពេញនូវល័ក្ខខ័ណ្ឌ ឬការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ (មាត្រា ៣៥៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

ប្រសិនបើសាលក្រមនៃបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនាពេលអនាគតមានភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ នោះដើមចោទអាចទទួលនូវរូបមន្តអនុវត្តបាន មុនពេលកំណត់ពិតប្រាកដនោះបានមកដល់ ប៉ុន្តែអាចចាប់ផ្ដើមនីតិវិធីនៃការអនុវត្តដោយបង្ខំបាន តែនៅក្រោយពេលកំណត់ពិតប្រាកដនោះបានមកដល់ (មាត្រា ៣៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ២. បណ្តឹងទាមទារឲ្យបញ្ជាក់

បណ្ដឹងទាមទារឲ្យបញ្ជាក់ គឺជាបណ្ដឹងមួយប្រភេទដែលដើមចោទទាមទារឲ្យចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដោយផ្អែកលើការអះអាងរបស់ដើមចោទនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តមួយកំណត់យ៉ាងជាក់លាក់នៅក្នុងបណ្ដឹង។

បណ្ដឹងទាមទារឲ្យបញ្ជាក់ ដែលមានគោលបំណងអះអាងនូវអត្ថិភាពនៃសិទ្ធិជាអាទ៍ហៅថា **"បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយសកម្ម"** រីឯបណ្ដឹងដែលអះអាងនូវនត្ថិភាពនៃសិទ្ធិ ហៅថា **"បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយអកម្ម"** ។

- <u>ករណីទី១</u> ៖(បណ្ដឹងទាមទារឲ្យបញ្ជាក់ដោយសកម្ម)

A បានជួលដីមួយកន្លែងពី B នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៤ ហើយបានរស់នៅលើដីនោះតាំងពីពេលនោះមក។ ក្រោយមក B ចង់បណ្ដេញ A ចេញ និងបានផ្ញើលិខិតជូនដំណឹងជាច្រើនដងទៅ A ដោយបង្គាប់ឲ្យរើចេញពីដីនោះ។ Aចង់រស់នៅទីនោះបន្ត និងចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិជួលរបស់ខ្លួន ។

- <u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ</u>៖

បញ្ជាក់ថាសិទ្ធិជួលដោយផ្អែកលើភតិសន្យា ដែលដើមចោទ A គឺជាភតិកៈ និងចុងចម្លើយ B គឺជាភតិបតី ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៤ មានអត្ថិភាពលើដីដែលមានបញ្ជាក់ក្នុងឧបសម្ព័ន្ធកម្មវត្ថុ។

- <u>ករណីទី២</u>(បណ្តឹងទាមទារឲ្យបញ្ជាក់ដោយអកម្ម) ៖

A បានឲ្យ B ខ្ចីប្រាក់ចំនួន ១០០០ (មួយពាន់)ដុល្លារ តាមរយៈកិច្ចសន្យាខ្ចីបរិភោគនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០១៤។ B បានសងប្រាក់គ្រប់ចំនួន តែ A នៅតែទាមទារឲ្យ B សងប្រាក់។ B ចង់ដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួន។

- <u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារៈ</u>

បញ្ជាក់ថាកាតព្វកិច្ចបង់ប្រាក់ដើមរបស់ដើមចោទ B ក្នុងចំនួន ១.០០០ (មួយពាន់) ដុល្លាអាមេរិក និងការប្រាក់យឺតយ៉ាវ ទៅឲ្យចុងចម្លើយ A ដោយផ្អែកលើ កិច្ចសន្យាខ្ចីបរិភោគរវាងដើមចោទ B និងចុងចម្លើយ A ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៤ មិនមានអត្ថិភាពទេ។

## ២.១ កម្មវត្ថុនៃបណ្តឹងទាមទារឲ្យបញ្ជាក់

ជាគោលការណ៍ បណ្តឹងទាមទារឲ្យបញ្ជាក់សំដៅតែទៅលើការបញ្ជាក់អំពី "អត្ថិភាព" ឬ "នត្ថិភាព" នៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលមានជាក់ស្តែងតែប៉ុណ្ណោះ គឺមិនរាប់បញ្ចូលអំពីការផ្តល់តាវកាលិកណាមួយនោះទេ។ ចំណុចនេះ គឺចង់បញ្ជាក់ថា ជាគោលការណ៍ គឺមិនអនុញ្ញាតឲ្យធ្វើការទាមទារបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះទេ[8] ។

**ឧទាហរណ៍ ៖**

ប្រសិនបើដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការទាមទារអោយ "បញ្ជាក់អំពីអង្គហេតុថាA បានសាងសង់អគារ" ឬក៏ "បញ្ជាក់អំពីអង្គហេតុថា B បានធ្វើឲ្យខូចខាតរថយន្តរបស់ A" នោះបណ្តឹងទាមទារឲ្យបញ្ជាក់របៀបនេះនឹងត្រូវតុលាការលើកចោល ដោយមូលហេតុខ្វះផលប្រយោជន៍នៃបណ្តឹង ពីព្រោះខ្លឹមសារនៃការទាមទាររបស់ដើមចោទ គឺដើម្បីបញ្ជាក់អំពីអង្គហេតុតែប៉ុណ្ណោះ។

- បណ្តឹងទាមទារឲ្យបញ្ជាក់ គឺកម្រិតត្រឹមការទាមទារឲ្យបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ "នាពេលបច្ចុប្បន្ន" គឺមិនអនុញ្ញាតឲ្យធ្វើក្នុងអតីតកាល ឬអនាគតកាលឡើយ។

ទោះបីជាទំនាក់ទំនងគតិយុត្តក្នុងពេលអតីតកាលត្រូវបានបញ្ជាក់ដោយសាលក្រមដែលបានចូលជាស្ថាពរក៏ដោយ ក៏ស្ថានភាពនៃទំនាក់ទំនងនោះអាចត្រូវបានផ្លាស់ប្តូរនាពេលបច្ចុប្បន្ន។ ឬបើទោះបីជា

---

[8] មានគំនិតមួយថាបណ្តឹងទាមទារឲ្យបញ្ជាក់អំពីអង្គហេតុដែលឯកសារត្រូវបានធ្វើឡើងដោយត្រឹមត្រូវអាចទទួលយកបាន លុះត្រាតែឯកសារមានលក្ខណៈបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តមួយ (ដូចជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរ) ដោយសារតែការទាម ទារឲ្យបញ្ជាក់នោះនឹងមានផលប្រយោជន៍ក្នុងការដោះស្រាយវិវាទ ។ ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ គឺសំដៅទៅលើការធ្វើឯកសារ តើត្រូវបានបង្កើតឡើងដោយផ្អែកលើឆន្ទៈពិតប្រាកដ និងត្រឹមត្រូវ របស់ជនដែលបានធ្វើលិខិតនោះពិតមែន ឬយ៉ាងណា គឺ មិនមែនសំដៅទៅលើខ្លឹមសារដែលមានចុះក្នុងឯកសារនោះស៊ីសង្វាក់ទៅនឹងអង្គហេតុជាក់ស្តែងនោះទេ ។ ដូច្នេះ ទោះបីជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជាក់ថាបានធ្វើឡើងដោយត្រឹមត្រូវ នោះសុពលភាពនៃកិច្ចសន្យា ឬអត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ច ដែលកើតឡើងពីកិច្ចសន្យា មិនត្រូវបានបញ្ជាក់ ។

ទំនាក់ទំនងគតិយុត្តនាពេលអនាគត ត្រូវបានបញ្ជាក់ដោយសាលក្រមស្ថាពរក៏ដោយ ក៏ទំនាក់ទំនងនោះអាចនឹងប្រែប្រួល មុនពេលកាលបរិច្ឆេទនាពេលអនាគតនោះមកដល់។ ហេតុដូច្នេះសាលក្រមនេះ មិនអាចដោះស្រាយវិវាទដែលកំពុងកើតមាននាពេលបច្ចុប្បន្នបានឡើយ។

**ឧទាហរណ៍៖**

A បានលក់គ្រឿងចក្រទៅឲ្យ B ប៉ុន្តែក្រោយមក A បានលុបចោលកិច្ចសន្យា។ B បានទាមទារ A ឲ្យប្រគល់គ្រឿងចក្រមកឲ្យខ្លួនប៉ុន្តែ A បដិសេធការអនុវត្តកាតព្វកិច្ចប្រគល់គ្រឿងចក្រ ដោយមូលហេតុការលុបចោលកិច្ចសន្យា។ A បានដាក់ពាក្យបណ្តឹងដើម្បីបញ្ជាក់អំពីមោឃភាពនៃកិច្ចសន្យា។ ក៏ប៉ុន្តែបណ្តឹងបែបនេះ គឺពុំបានបង្ហាញអំពីផលប្រយោជន៍នៃបណ្តឹងនោះឡើយ ពីព្រោះបណ្តឹងនេះគឺជាបណ្តឹងទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តនាពេលអតីតកាល ដែលមិនអាចដោះស្រាយវិវាទរវាង A និង B បាន ហេតុនេះការទាមទារនឹងត្រូវបានច្រានចោល។ តើនឹងមានអ្វីកើតឡើង ប្រសិនបើបណ្តឹងនោះត្រូវបានទទួលយកដោយមានកំហុសដោយតុលាការ? ប្រសិនបើ A ឈ្នះក្តី នោះសាលក្រមនឹងកំណត់អំពីមោឃភាពនៃកិច្ចសន្យា ដែលសាលក្រមនេះអាចនឹងដោះស្រាយវិវាទខាងលើនេះបាន។ ក៏ប៉ុន្តែ ប្រសិនបើ A ចាញ់ក្តីវិញ នោះមានន័យថាសេចក្តីសម្រេចក្នុងសាលក្រម នឹងកំណត់អំពីសុពលភាពនៃកិច្ចសន្យាទៅវិញ ប៉ុន្តែពុំបានកំណត់អំពីអត្ថិភាពនៃកាតព្វកិច្ចរបស់ A ឡើយ។ ដូច្នេះ ទោះបីជាមានសាលក្រមហើយក៏ដោយ A នៅតែអាចអះអាងថាខ្លួនគ្មានកាតព្វកិច្ចនោះទេ។ A អាចនឹងនិយាយថា "យល់ព្រម ខ្ញុំទទួលស្គាល់ថាកិច្ចសន្យានេះមានសុពលភាព ប៉ុន្តែកាតព្វកិច្ចរបស់ខ្ញុំត្រូវបានរលត់ដោយសារតែខ្ញុំបានបំពេញកាតព្វកិច្ចនោះចប់រួចរាល់ ឬបំណុលរបស់ខ្ញុំត្រូវបានលើកលែង ឬក៏ផុតអាជ្ញាយុកាលនៃការរំលត់ទៅហើយ"។ A ក៏អាចនឹងធ្វើបណ្តឹងទីពីរទៅតុលាការ ដើម្បីបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួន។

ការផ្តល់ឱកាសលើកទី២ដល់ A គឺមិនមានភាពចាំបាច់ និងជាការខាតពេលនៃនីតិវិធីតុលាការ។

ដូច្នេះដើម្បីចៀសវាងនូវបញ្ហានេះ បណ្តឹងលើកទីមួយរបស់ A គួរតែជាបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច។ ប្រសិនបើ A ធ្វើបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចគឺអាចទទួលយកបានដោយសារតែបណ្តឹងបញ្ជាក់ប្រភេទនេះគឺជាបណ្តឹងបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិនាពេលបច្ចុប្បន្ន។

- ក៏ប៉ុន្តែមានករណីលើកលែងពិសេសដែលការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តក្នុងអតីតកាល និងអនាគតកាលអាចធ្វើទៅបាន ពោលគឺដោយសារភាពចាំបាច់ក្នុងការដោះស្រាយវិវាទ តាមផ្លូវច្បាប់ដែលកំពុងមាននាពេលបច្ចុប្បន្ននេះ តែប៉ុណ្ណោះ។ ថាតើបណ្តឹងទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដែលមានក្នុងអតីតកាល ឬនាពេលអនាគតកាល អាចទទួលយកបានដែរ ឬអត់នោះ គឺអាស្រ័យលើការអនុវត្តរបស់ប្រទេសកម្ពុជានាពេលអនាគត។ ប៉ុន្តែ

នេះជាឧទាហរណ៍ អំពីករណីប្រឌិតមួយដែលលើកឡើងអំពី ថាតើបណ្ដឹងទាំងនោះមានប្រយោជន៍ក្នុងការដោះស្រាយវិវាទយ៉ាងណាខ្លះ?

**ឧទាហរណ៍៖**

A និង B បានចុះកិច្ចសន្យាមួយ។ យោងតាមកិច្ចសន្យានោះ A ត្រូវទិញទំនិញពី B ជារៀងរាល់ខែ។ A បានលុបចោលកិច្ចសន្យា ប៉ុន្តែ B បានបន្តផ្ញើវិក័យបត្រជារៀងរាល់ខែ។ ប្រសិនបើសុពលភាពនៃកិច្ចសន្យានៅតែមិនច្បាស់លាស់ នោះវិវាទរវាង A និង B នឹងកាន់តែធំឡើងៗ។ ផ្ទុយទៅវិញប្រសិនបើសុពលភាព ឬមោឃភាពនៃកិច្ចសន្យាត្រូវបានបញ្ជាក់ នោះវិវាទនឹងត្រូវបានដោះស្រាយ (ប្រសិនបើកិច្ចសន្យាត្រូវបានបញ្ជាក់ថាមានសុពលភាព នោះ A នឹងស្វែងរកមធ្យោបាយដើម្បីរំលាយកិច្ចសន្យា។ ប្រសិនបើកិច្ចសន្យាត្រូវបានបញ្ជាក់ថាមោឃភាពនោះ B នឹងលែងផ្ញើវិក័យបត្រទៀត)។

- បណ្ដឹងទាមទារឲ្យបញ្ជាក់ មានគោលបំណងដើម្បីការពារផលប្រយោជន៍របស់ភាគី ក្នុងគោលបំណងដើម្បីដោះស្រាយវិវាទដែលកើតចេញពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ) [9] (ហេតុដូច្នេះបណ្ដឹងនេះមិនអនុញ្ញាតឲ្យធ្វើការទាមទារការបញ្ជាក់ការបកស្រាយអំពីសុពលភាព ឬមោឃភាពនៃច្បាប់ណាមួយបានឡើយ។

**ឧទាហរណ៍៖**

A បានចំណាយសោហ៊ុយមេធាវីអស់ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក ដើម្បីចរចារជាមួយ B ព្រោះ B បានបំពានកិច្ចសន្យាដែលបានធ្វើជាមួយ A។ A បានគិតថាការខូចខាតដែលមានចែងក្នុងមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី គួរតែរាប់បញ្ចូលទាំងសោហ៊ុយមេធាវី។ Aចង់ដាក់ពាក្យបណ្ដឹងចំពោះ B។ ក្នុងករណីនេះ ប្រសិនបើ A ទាមទារឲ្យ " ចុងចម្លើយ B ត្រូវបង់ប្រាក់ចំនួន ១០០០(មួយពាន់)ដុល្លារ ទៅឲ្យដើមចោទ A " នោះបណ្ដឹងនេះគឺពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ជាក់ស្ដែងមួយ។ ផ្ទុយទៅវិញ ប្រសិនបើ A ទាមទារឲ្យ "បញ្ជាក់ការខូចខាតដែលមានចែងក្នុងមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី រាប់បញ្ចូលទាំងសោហ៊ុយមេធាវី " នោះបណ្ដឹងនេះមិនពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ជាក់ស្ដែងនោះទេ ហេតុដូច្នេះការទាមទារនឹងត្រូវតុលាការច្រានចោល។

## ២.២ សាលក្រមនៃបណ្ដឹងទាមទារឲ្យបញ្ជាក់

គោលបំណងនៃបណ្ដឹងទាមទារឲ្យបញ្ជាក់ គឺជាការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយដែលអះអាងដោយដើមចោទ។ ហេតុដូច្នេះតុលាការត្រូវចេញសាលក្រមដែលមាន

[9] មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី៖ បណ្ដឹងអាចធ្វើឡើងបាន ក្នុងករណីដែលបណ្ដឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និងដែលវិវាទនោះអាចដោះស្រាយបានដោយសាលក្រម ។

ខ្លឹមសារបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលសាលក្រមដែលទទួលស្គាល់អំពីភាពត្រឹមត្រូវនៃការទាមទារ ឈ្មោះថា "**សាលក្រមបញ្ជាក់**" ។

សាលក្រមបញ្ជាក់មានអានុភាពទៅលើការវិនិច្ឆ័យអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តណាមួយដែលមាននៅក្នុងខ្លឹមសារនៃសាលក្រមនោះ។ សិទ្ធិជាក់លាក់នេះមិនអាចយកមកវិនិច្ឆ័យម្តងទៀតបានឡើយ ពីព្រោះវាជាអាជ្ញាអស់ជំនុំជាសារធាតុ ហើយមានអានុភាពស្ថាពរ។ ចំពោះសាលក្រមដែលធ្វើការច្រានចោលការទាមទារឲ្យបញ្ជាក់ ក៏មានអានុភាពជាអាជ្ញាអស់ជំនុំជាសារធាតុ ផងដែរ។

ម្យ៉ាងវិញទៀត ក្នុងករណីដែលអត្ថិភាព ឬនត្ថិភាពនៃកាតព្វកិច្ចជាចំណុចវិវាទ មានបណ្តឹងទាមទារឲ្យបញ្ជាក់អសកម្មមួយប្រភេទ ដែលជនដែលត្រូវបានចង្អុលថា កូនបំណុលដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចក្នុងនាមជាដើមចោទ។ សាលក្រមច្រានចោលនូវការទាមទារក្នុងបណ្តឹងទាមទារឲ្យបញ្ជាក់នេះ នឹងមានអានុភាពជាអាជ្ញាអស់ជំនុំសារធាតុ ចំពោះការវិនិច្ឆ័យថា "កាតព្វកិច្ចដែលដើមចោទបានអះអាងថាពុំមាននោះ មានអត្ថិភាព "។ ចំពោះចុងចម្លើយ សាលក្រមនេះគឺជាសាលក្រមបញ្ជាក់ជាស្ថាពរនូវអត្ថិភាពនៃសិទ្ធិលើបំណុល ក៏ប៉ុន្តែ នេះក៏ជាសាលក្រមបញ្ជាក់ ហើយពុំមានអានុភាពអនុវត្តទេ ហេតុនេះហើយ មិនអាចក្លាយទៅជាលិខិត អនុវត្ត ដើម្បីសម្រេចសិទ្ធិលើបំណុលដែលត្រូវបានទទួលស្គាល់ក្នុងសាលក្រមនោះឡើយ។

## ៣. បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត (ការកកើតមានឡើង ការប្តូរ ឬការរំលត់) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬអំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់ជាក់លាក់ដែលជាការទាមទារតាមផ្លូវបណ្តឹង **ឧទាហរណ៍៖** បណ្តឹងសុំលែងលះ។ នៅក្នុងករណីលែងលះតាមរយៈបណ្តឹងសុំលែងលះ ទោះបីជាភាគីម្ខាងបានបង្ហាញឆន្ទៈលែងលះគ្នាក៏ដោយ ក៏អានុភាពនៃការលែងលះមិនទាន់មាននៅឡើយ ពោលគឺទាល់តែមានសាលក្រមពីតុលាការសម្រេចឲ្យលែងលះ ទើបយើងអាចនិយាយថាចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយតាមផ្លូវច្បាប់។ ជាគោលការណ៍ ច្បាប់ទទួលស្គាល់នូវការបង្កើតទំនាក់ទំនងគតិយុត្តថ្មី ដោយផ្អែកលើឆន្ទៈភាគីណាម្ខាង ប៉ុន្តែមានករណីមួយចំនួនដើម្បីឲ្យអានុភាពនៃការបង្កើតទំនាក់ទំនងគតិយុត្តកើតមានឡើង ការបង្ហាញឆន្ទៈរបស់ភាគីតែម្ខាងគឺមិនទាន់គ្រប់គ្រាន់ គឺចាំបាច់ត្រូវមានបណ្តឹង ហើយតុលាការត្រូវចេញសាលក្រមឆ្លើយតបទៅនឹងបណ្តឹងនោះ។ ដែល បណ្តឹងមានអានុភាពបែបនេះហើយ គេហៅថា បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត។

ឧទាហរណ៍មួយចំនួនទៀតដែលបង្ហាញអំពីអានុភាពនៃបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តមានដូចជា ទំនាក់ទំនងឋានៈបុគ្គល រួមមានការរៀបអាពាហ៍ពិពាហ៍ សុំកូន ជាដើម។

**ករណីទី១៖** A បានរៀបអាពាហ៍ពិពាហ៍ជាមួយ B ប៉ុន្តែឥឡូវ A ចង់លែងលះជាមួយ B តាមរយៈការដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការ ដោយយោងលើមូលហេតុដូចមានចែងក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

-**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖** សុំលែងលះរវាងដើមចោទ A និងចុងចម្លើយ B។

**ករណីទី២៖** A គឺជាកូនរបស់ B (ឪពុក) និង C (ម្ដាយ) ប៉ុន្តែ B និង C មិនបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាទេ។ B មិនបានទទួលស្គាល់ A ជាកូនរបស់ខ្លួនទេ។ ដូច្នេះ A ចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់ (មាត្រា ១០០១ នៃក្រមរដ្ឋប្បវេណី)។

-**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖** សុំទទួលស្គាល់ដើមចោទA ជាកូនរបស់ចុងចម្លើយ B។

**ករណីទី៣៖** A បានសុំ B មកចិញ្ចឹម (សុំកូនធម្មតា) ប៉ុន្តែឥឡូវគាត់ចង់កាត់កាល់ B វិញ។ ដូច្នេះ A ចង់ដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់ (មាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណី)។

-**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖** សុំកាត់កាល់រវាងដើមចោទ A និងចុងចម្លើយ B។

## ៣.១ កម្មវត្ថុនៃបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

បណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តត្រូវមានការអះអាងអំពីអត្ថិភាពនៃសិទ្ធិតាមទំនាក់ទំនងនោះ ឬត្រូវមានការអះអាងអំពីអត្ថិភាពនៃមូលហេតុ ក្នុងការបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ដូចជា មូលហេតុនៃការសុំជំនុំជម្រះសាជាថ្មីទៅលើសាលក្រមស្ថាពរ ជាដើម។

ទោះបីជាបណ្ដឹងដែលមានគោលបំណងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តដូចគ្នាក៏ដោយ តែមិនបានអះអាងអំពីសិទ្ធិ និងមូលហេតុនៃការបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តទេនោះ ហើយតុលាការក៏គ្មានមូលដ្ឋានតាមផ្លូវច្បាប់ណាមួយដើម្បីយកមកបង្កើតទំនាក់ទំនងគតិយុត្តទេនោះ ដូច្នេះ បណ្ដឹងបែបនេះមិនចាត់ចូលជាបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តដូចដែលបានរៀបរាប់មកពីខាងដើមនោះទេ។ បណ្ដឹងបែបនេះ គេហៅថា "**បណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តតាមទម្រង់** " **ឧទាហរណ៍៖** បណ្ដឹងឲ្យបែងចែកវត្ថុដែលជាកម្មសិទ្ធិអវិភាគ [10] ។ បណ្ដឹង

[10] មាត្រា ២១១ នៃក្រមរដ្ឋប្បវេណី៖ សិទ្ធិទាមទារបែងចែកវត្ថុកម្មសិទ្ធិអវិភាគ

ប្រភេទនេះ ទោះជាមានការបង្ហាញឆន្ទៈពីភាគីក៏ដោយ ក៏គ្មានអានុភាពអនុវត្តដែរ ប្រសិនបើមិនបានឆ្លងកាត់តាមការធ្វើសេចក្ដីសម្រេចដោយសាលក្រមរបស់តុលាការទេនោះ។

## ៣.២ សាលក្រមចំពោះបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

ប្រសិនបើតុលាការទទួលស្គាល់តាមការអះអាងរបស់ដើមចោទចំពោះការទាមទារ នោះតុលាការត្រូវចេញសាលក្រមកំណត់នូវទំនាក់ទំនងគតិយុត្តមួយយ៉ាងជាក់លាក់។ សាលក្រមប្រភេទនេះហៅថា "**សាលក្រមបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត**"។ សាលក្រមខាងលើនេះ មានអានុភាពប្រតិសកម្ម (ឧទាហរណ៍ សាលក្រមរំលាយចោលនូវសេចក្ដីសម្រេចរបស់មហាសន្និបាទម្ចាស់ហ៊ុនជាដើម មានន័យថា បើតុលាការទទួលស្គាល់ការរំលាយចោលនូវសេចក្ដីសម្រេចរបស់មហាសន្និបាទម្ចាស់ហ៊ុន នោះសាលក្រមមានអានុភាពប្រតិសកម្មទៅចាប់ពីពេលដែលសាលក្រមបានចូលជាស្ថាពរ ដោយអ្វីៗដែលបានធ្វើពីមុនរបស់ម្ចាស់ហ៊ុន ត្រូវចាត់ទុកថានិរាករណ៍) ឬមានអានុភាពឆ្ពោះទៅអនាគត (ឧទាហរណ៍ សាលក្រមលែងលះ)។ អានុភាពទាំងនេះ វាអាស្រ័យទៅនឹងការកំណត់ដោយច្បាប់សារធាតុ ឬតាមច្បាប់នីតិវិធីស្របតាមខ្លឹមសារនៃសាលក្រម។

សាលក្រមបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត នឹងបង្កើតជាអាជ្ញាអស់ជំនុំសារធាតុចំពោះការវិនិច្ឆ័យថា មានសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ឬមានមូលហេតុបង្កើតទំនាក់ទំនងគតិយុត្តដែលដើមចោទបានអះអាង។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការមិនទទួលស្គាល់តាមការទាមទាររបស់ដើមចោទ នោះតុលាការត្រូវចេញសាលក្រមច្រានចោល។ សាលក្រមច្រានចោលនេះ មិនមានអានុភាពបង្កើតទំនាក់ទំនងគតិយុត្តទេ ប៉ុន្តែចំណុចវិនិច្ឆ័យអំពី "ពុំមានសិទ្ធិបង្កើត ឬពុំមានមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះ វាមានអានុភាពអាជ្ញាអស់ជំនុំសារធាតុរវាងភាគី ដែលលក្ខណៈរបៀបនេះហៅថា "សាលក្រមបញ្ជាក់"។

ជារួមមក ផលប្រយោជន៍នៃការធ្វើបណ្ដឹងចំពោះការទាមទារឲ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្តអាចទទួលស្គាល់បាន លុះត្រាតែអត្ថិភាពនៃសិទ្ធិ និងអត្ថិភាពនៃមូលហេតុនោះ មានចែងក្នុងលក្ខខណ្ឌដែលមានកំណត់ក្នុងច្បាប់។

### ៤. ទម្រង់នៃបណ្ដឹង

ក្រមនីតិវិធីរដ្ឋប្បវេណីបានធ្វើការបែងចែកបណ្ដឹងជាបីប្រភេទ គឺបណ្ដឹងទាមទារអោយផ្ដល់តាវកាលិក បណ្ដឹងទាមទារអោយបញ្ជាក់ និងបណ្ដឹងទាមទារអោយបង្កើត ប្ដូរ ឬរំលត់នូវទំនាក់ទំនង

គតិយុត្ត។ រាល់ការដាក់ពាក្យបណ្តឹង ភាគីដែលមានផលប្រយោជន៍[11] ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតុលាការ[12] ។

ជាទូទៅនៅក្នុងពាក្យបណ្តឹង ដើមចោទ ឬមេធាវីត្រូវសរសេរអំពីការទាមទារ និងអះអាងអំពីអង្គហេតុ។ មាត្រា៧៥ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ផ្តល់នូវវិធានជាក់លាក់អំពីចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង។ ការយល់ដឹងអំពីវិធាននេះ គឺពិតជាមានភាពចាំបាច់ខ្លាំងណាស់ ព្រោះថាការធ្វេសប្រហែសក្នុងការអនុវត្តតាមវិធាននេះ អាចធ្វើអោយដើមចោទចាញ់ក្តី។

### ៤.១. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

អនុលោមតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីមានចំណុចដែលតម្រូវអោយដើមចោទត្រូវតែសរ-សេរជាដាច់ខាត និងចំណុចមិនចាប់បង្ខំ។ មាត្រា ៧៥-២ ក្នុងករណីដែល មិនបានសរសេរឬសរសេរមិនច្បាស់លាស់នូវចំណុចៈ

(ក). ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

(ខ) ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការនូវទាមទារ។

នោះតុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់អោយកែតម្រូវចំណុចខ្វះខាត [13] ។ ប្រសិនបើដើមចោទមិនបានកែ ឬមិនអាចកែនូវចំណុចខ្វះខាតក្នុងអំឡុងពេលដែលតុលាការបានកំណត់ទេនោះ តុលាការត្រូវលើកចោលពាក្យបណ្តឹងដោយដីកាសម្រេច[14]។

ក្នុងករណីដែលបណ្តឹងត្រូវបានលើកចោល នោះរឿងក្តីត្រូវបានបញ្ចប់ដោយពុំមានការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ និងពុំឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។

ចំពោះដីកាសម្រេចលើកចោលពាក្យបណ្តឹងអាចធ្វើការប្តឹងជំទាស់បាន[15]។

ចំពោះចំណុចមិនចាប់បង្ខំ គឺកថាខណ្ឌទី៣ នៃមាត្រា ៧៥ អង្គហេតុដែលជាមូលហេតុនៃការទាមទារ(ឬអង្គហេតុចម្បង) និងអង្គហេតុសំខាន់ៗទាក់ទងទៅនិងមូលហេតុនៃការទាមទារ និងភស្តុតាង

---

[11] មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[12] មាត្រា ៧៥-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[13] មាត្រា ៧៨-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[14] មាត្រា ៧៨-២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[15] មាត្រា ៧៨-៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ច្បាប់មិនចាប់បង្ខំ ឬតម្រូវអោយដើមចោទត្រូវតែសរសេរនៅក្នុងពាក្យបណ្ដឹងរបស់ខ្លួននោះទេ គ្រាន់តែប្រើពាក្យថាគប្បីសរសេរ មានន័យថា ដើមចោទអាចសរសេររៀបរាប់អំពីអង្គហេតុទាំងនោះនៅក្នុងបណ្ដឹងរបស់ខ្លួនក៏បាន មិនសរសេរក៏បាន ហើយការមិនសរសេររបស់ដើមចោទមិនមែនជាមូលហេតុនៃការបង្គាប់អោយកែតម្រូវរបស់តុលាការនោះទេ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ចំណុចសំខាន់ដែលអាចបញ្ជាក់ពីសិទ្ធិទាមទាររបស់ដើមចោទបានច្បាស់លាស់នោះ គឺនៅកថាខណ្ឌទី៣ នៃមាត្រា ៧៥ នេះឯង។ ក្នុងកថាខណ្ឌទី២ ពាក់ព័ន្ធនិងភាគី ការទាមទារ និងអង្គហេតុបញ្ជាក់ការទាមទារ ដែលតម្រូវអោយដើមចោទត្រូវតែសរសេរ នោះវាពិតជាសំខាន់ព្រោះថា បើមិនសរសេរអោយបានច្បាស់លាស់ថា អ្នកណាជាដើមចោទ? អ្នកណាជាចុងចម្លើយ? ហើយដើមចោទត្រូវការអ្វី?ទើបប្តឹងមកតុលាការ និងមិនបានបញ្ជាក់ពីការទាមទាររបស់ខ្លួនផ្អែកលើអង្គហេតុមួយណានោះ តុលាការមិន អាចយល់ដឹងបានដោយខ្លួនឯង ហើយធ្វើការកំណត់ភាគី និងការទាមទារដោយខ្លួនឯងបានដែរ។ ផ្ទុយទៅវិញ បើល័ក្ខខ័ណ្ឌដែលមានចែងក្នុងកថាខណ្ឌទី២ ត្រង់ចំណុច(ក) និង(ខ) ត្រូវបានបំពេញហើយនោះ ពាក្យបណ្ដឹងរបស់ដើម-ចោទអាចអោយតុលាការយល់ដឹងបានថា អ្នកណាជាដើមចោទ និងអ្នកណាជាចុងចម្លើយ ហើយអ្វីជាការទាមទាររបស់ដើមចោទ នោះតុលាការនិងទទួលយកពាក្យបណ្ដឹងនោះមកចាត់ការបាន ប៉ុន្តែសួរថា ការសរសេពាក្យបណ្ដឹងបែបនេះពេញលក្ខណៈហើយឬនៅ?

ចម្លើយគឺបណ្ដឹងបែបនេះមិនទាន់គ្រប់លក្ខណៈនៅឡើយទេ ព្រោះថាដើមបណ្ដឹងមិនទាន់បានបញ្ជាក់ពីសិទ្ធនិងផលប្រយោជន៍តាមផ្លូវច្បាប់ដែលខ្លួនមានក្នុងការធ្វើបណ្ដឹងមកតុលាការ។ ម្យ៉ាងបើពិនិត្យលើគោលការណ៍ចំពោះមុខ តុលាការត្រូវផ្ញើពាក្យបណ្ដឹង និងសេចក្ដីបញ្ជាក់ដំបូងរបស់ដើមចោទទៅអោយចុងចម្លើយដើម្បីធ្វើការឆ្លើយតបនឹងបណ្ដឹងនោះ ក្នុងករណីដែលដើមចោទមិនបានសរសេរអ្វីសោះអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ចុងចម្លើយក៏មិនអាចយល់ដឹងបានអំពីអង្គហេតុកកើតសិទ្ធិទាមទាររបស់ដើមចោទនោះដែរ ហេតុនេះនៅពេលដែលតុលាការទទួលយកបណ្ដឹងរបៀបនោះមកចាត់ការ ហើយក្នុងករណីដែលដើមចោទមិនអាចបញ្ជាក់ពីអង្គហេតុកកើតសិទ្ធិទាមទាររបស់ខ្លួនបាននៅពេលក្រោយ នោះដើមចោទត្រូវធ្វើការអះអាងអំពីអង្គហេតុកកើតសិទ្ធិរបស់ខ្លួននៅក្នុងនីតិវិធីត្រៀម។ ហើយប្រសិនបើនៅក្នុងនីតិវិធីត្រៀម ដើមចោទនៅតែមិនអាចអះអាង ឬ មិនព្រមអះអាងអំពីអង្គហេតុកកើតសិទ្ធិ នោះតុលាការនឹងច្រានចោលការទាមទាររបស់ដើមចោទ។ ការមិនសរសេរបញ្ជាក់អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារនាំអោយមានការយឺតយ៉ាវនីតិវិធី និងមានហានិភ័យចំពោះការទាមទាររបស់ដើមចោទ ដែលងាយក្នុងការធ្វើអោយដើមចោទចាញ់ក្តី ហេតុនេះយើងជាមេធាវី គប្បីសរសេចំណុចនេះអោយបានច្បាស់លាស់នៅក្នុងបណ្ដឹង។

## គ. អត្តសញ្ញាណរបស់ភាគី[16]

នៅក្នុងបណ្តឹង ដើមចោទ ឬមេធាវី ត្រូវសរសេរជាចាំបាច់នូវ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ភាគីគឺជាចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ដើម្បីបញ្ជាក់ថាអ្នកណាជាដើមចោទ អ្នកណាជាចុងចម្លើយ បើជារូបវ័ន្តបុគ្គលត្រូវធ្វើសរសេរឈ្មោះបុគ្គលនោះ ព្រមទាំងអាសយដ្ឋាន។ តែបើជានីតិបុគ្គលត្រូវសរសេរនាមករណ៍ ឬឈ្មោះ និងទីតាំងនៃទីស្នាក់ការនៃនីតិបុគ្គល និងអត្តសញ្ញាណនៃអ្នកតំណាង។

ជាគោលការណ៍ អានុភាពនៃសាលក្រមដែលចេញដោយតុលាការ នឹងមានឥទ្ធិពលទៅលើភាគី ហើយត្រូវចងភាគីនោះ[17]ហេតុដូច្នេះក្នុងករណីមានការភ័ន្តច្រឡំភាគី នោះសាលក្រមដែលតុលាការចេញនឹងមានបញ្ហា ព្រោះថាពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយ តុលាការត្រូវមានករណីកិច្ចធ្វើការវិនិច្ឆ័យស្តីពីវិវាទរវាងដើមចោទ និងចុងចម្លើយនោះ ហើយក្នុងករណីមានការភ័ន្តច្រឡំភាគី និងមិនស្គាល់ភាគីនោះសាលក្រមនិងមិនអាចអនុវត្តទៅបាន ឬអាចប៉ះពាល់ដល់ផលប្រយោជន៍តតិយជន។

ចំណុចសំខាន់មួយទៀតដែលមេធាវី ក៏ដូចជាអ្នកសិក្សាច្បាប់ត្រូវតែយកចិត្តទុក្ខដាក់នោះ គឺសមត្ថភាព ភាគីក្នុងការធ្វើបណ្តឹង និងអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពធ្វើបណ្តឹង[18]។ ព្រោះថាមានតែបុគ្គលដែលមានសិទ្ធិ និងករណីយកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀតទេ ដែលអាចទទួលឋានៈជាភាគីដើមចោទ ឬចុងចម្លើយ។

<u>ចំណាំ</u> នៅក្នុងការសរសេរពាក្យបណ្តឹង ចំណុចដែលត្រូវសរសេរបញ្ជាក់ពីអ្នកតំណាងដោយអាណត្តិមិនមែនជាករណីចាំបាច់នោះទេ មានន័យថា ទោះបីមិនបានសរសេរបញ្ជាក់ពីពត៌មាននៃអ្នកតំណាង ក៏មិនមែនជាកម្មវត្ថុនៃការបង្គាប់អោយកែតម្រូវពាក្យបណ្តឹងនោះដែល។

<u>ឧទាហរណ៍</u>

ដើមចោទ A ភេទប្រុស អាយុ ៤០ឆ្នាំ មានអាសយដ្ឋានផ្ទះលេខ ១១១ ផ្លូវលេខ ១២ សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ។

*មានលោកស្រីDជាមេធាវីតំណាងដោយអាណត្តិមានការិយាល័យមេធាវីការពារច្បាប់អាសយដ្ឋាន អាគារ AA ផ្លូវ១១ សង្កាត់ទូលទំពូង ខណ្ឌចំការមន រាជធានីភ្នំពេញ។ (មិនមែនជាល័ក្ខខ័ណ្ឌចាំបាច់)*

[16] មាត្រា ៧៥-២-ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[17] មាត្រា ១៩៨-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[18] មាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ចុងចម្លើយ B ភេទប្រុស អាយុ ៥៥ឆ្នាំ មានអាសយដ្ឋានផ្ទះលេខ ៣៣៣ ផ្លូវ ៥៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

## ខ. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ

ការទាមទាររបស់ដើមចោទត្រូវតែជាការទាមទារដែលមានផលប្រយោជន៍ និងត្រូវបានកំណត់ដោយច្បាប់សារធាតុ[19]។ នៅក្នុងពាក្យបណ្តឹងដើមចោទត្រូវតែសរសេរនូវខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលខ្លួនទាមទារអោយតុលាការចេញ។ ខ្លឹមសារនៃសាលក្រមដែលទាមទារអោយតុលាការចេញគឺជាចំណុចសំខាន់ ដែលចាំបាច់ត្រូវសរសេរបញ្ជាក់អោយច្បាស់លាស់នៅក្នុងពាក្យបណ្តឹង។

*ឧទាហរណ៍*

<u>បណ្តឹងទាមទារអោយផ្តល់តាវកាលិក</u>

បង្គាប់អោយចុងចម្លើយឈ្មោះ Y បង់ប្រាក់ ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ជាមួយនឹងការប្រាក់ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ រហូតដល់ថ្ងៃសងរួចទៅអោយដើមចោទឈ្មោះ X។

<u>បណ្តឹងទាមទារអោយបញ្ជាក់</u>

បញ្ជាក់ថាដើមចោទមានកម្មសិទ្ធិលើដី L

<u>បណ្តឹងទាមទារអោយបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត</u>

សុំលែងលះរវាងដើមចោទ X និងចុងចម្លើយ Y

## គ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុចំបាច់សម្រាប់បញ្ជាក់បង្ហាញអំពីការអះអាងអំពីសិទ្ធិទាមទារតាមផ្លូវបណ្តឹង ដែលដើមចោទទាមទារអោយតុលាការធ្វើការជំនុំជម្រះ និងចេញសាលក្រមនៃ បណ្តឹងនេះ។

ចំពោះប្រភេទបណ្តឹងទាមទារអោយបញ្ជាក់អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត មិនអាចធ្វើការញែករវាងការទាមទារ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារបានទេ ព្រោះប្រភេទបណ្តឹងនេះគេសរសេរបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្ត នៅក្នុងការទាមទារតែម្តង។ ចំពោះបណ្តឹងទាមទារអោយបង្កើត ប្តូរ ឬរំលត់នូវទំនាក់ទំនងគតិយុត្ត មានប្រភេទខ្លះក៏មិនអាចញែកដាច់ពីគ្នាបានដែរ។

[19] មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ដោយឡែកបណ្តឹងទាមទារអោយផ្តល់តាវកាលិក យើងអាចចែកដាច់រវាងការទាមទារ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ព្រោះថាប្រភេទបណ្តឹងនេះការទាមទារអាចមានភាពមិនច្បាស់លាស់ ហេតុនេះទាមទារអោយមានការបញ្ជាក់ពីអង្គហេតុចាំបាច់ ដើម្បីអាចអោយតុលាការយល់ដឹងបានអំពីសិទ្ធិដែលគាំទ្រការទាមទាររបស់ដើមចោទ។

ទោះក្នុងស្ថានភាពនៃបណ្តឹងមួយណាក៏ដោយក៏ការទាមទារទាំងអស់របស់ដើមចោទ ត្រូវការអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារដដែល ព្រោះនេះជាល័ក្ខខ័ណ្ឌតម្រូវដែលកំណត់ដោយច្បាប់[20]។

ខាងក្រោមនេះយើងខ្ញុំនឹងបង្ហាញអំពីការទាមទារ និងអង្គហេតុបញ្ជាក់ការទាមទារ ៖

<u>**បណ្តឹងទាមទារអោយបញ្ជាក់**</u>

<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ</u>

បញ្ជាក់ថាដើមចោទមាន <u>**កម្មសិទ្ធិលើដី L មានទីតាំងផ្លូវលេខ១១ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ**</u> (គឺអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ)

<u>**បណ្តឹងទាមទារអោយបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត**</u>

<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ</u>

សុំលែងលះរវាង <u>**ដើមចោទ X និងចុងចម្លើយ Y**</u> (គឺអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ)

<u>**បណ្តឹងទាមទារអោយផ្តល់តាវកាលិក**</u>

<u>**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ**</u>

បង្គាប់អោយចុងចម្លើយ Y បង់ប្រាក់ ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ជាមួយនឹងការប្រាក់ ៥% ក្នុងមួយឆ្នាំរហូតដល់ថ្ងៃសងរួចទៅអោយដើមចោទ X។

<u>**អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ**</u>

- សិទ្ធិទាមទារអោយសងប្រាក់ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ
- កាលបរិច្ឆេទនៃកិច្ចសន្យា ចុះថ្ងៃទី ០១-០១-២០១៤
- គូភាគីនៃកិច្ចសន្យា៖ X និង Y
- ប្រាក់ដើម៖ ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក

[20] មាត្រា ៧៥-២-ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- កាលកំណត់សងៈ ថ្ងៃទី៣១-១២-២០១៤

<u>អង្គហេតុដែលជាមូលហេតុនៃការទាមទារ</u>

**ប្រាក់ដើម ៥០០០$**

១. X បានយល់ព្រមអោយ Y ខ្ចីលុយចំនួន ៥០០០$ នៅថ្ងៃទី១-០១-២០១៤[21]

២. X បានប្រគល់លុយចំនួន ៥០០០$ ទៅអោយ Y នៅថ្ងៃទី ១-០១-២០១៤ [22]

៣. ការប្រគល់ប្រាក់ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១-១-២០១៤

៤. X និង Y បានព្រមព្រៀងគ្នាថាកាលបរិច្ឆេទកំណត់សងគឺនៅថ្ងៃទី៣១-១២-២០១៤[23]

៥. ថ្ងៃទី៣១-១២-២០១៤ បានមកដល់ [24]

**ការប្រាក់ ៥%ក្នុងមួយឆ្នាំ**

១. X និង Y បានព្រមព្រៀងគ្នាអំពីការប្រាក់ដោយមានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខា ដោយ Y [25]

២.អត្រាការប្រាក់ក្នុងកិច្ចសន្យាគឺ ៥% ក្នុងមួយឆ្នាំ [26]

៣. ថ្ងៃទី១-១-២០១៥ បានមកដល់ [27]

នៅក្នុងប្រភេទបណ្តឹងទី១ និងទី២ គឺបណ្តឹងទាមទារអោយបញ្ជាក់ និងបណ្តឹងទាមទារអោយបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ឃើញថាបណ្តឹងទាំងពីរនេះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការទាមទាររួចទៅហើយ ហេតុនេះយើងមិនចាំបាច់សរសេរអង្គហេតុចាំបាច់បញ្ជាក់ការទាមទារម្តងទៀតទេ។

ផ្ទុយទៅវិញបណ្តឹងទាមទារផ្តល់តាវការលិក មិនមានបញ្ជាក់ច្បាស់លាស់នៅក្នុងការទាមទារនោះទេ ហេតុនេះចាំបាច់ត្រូវសរសេរបញ្ជាក់ពីអង្គហេតុដើម្បីបញ្ជាក់ការទាមទារ។

[21] មាត្រា ៥៧៨, ៥៧៩ ក្រមរដ្ឋប្បវេណី
[22] មាត្រា ៥៧៨, ៥៩១ ក្រមរដ្ឋប្បវេណី
[23] មាត្រា ៥៩១-១, ៥៩៤ ក្រមរដ្ឋប្បវេណី
[24] មាត្រា ៥៩១-១, ៥៩៤ ក្រមដ្ឋប្បវេណី
[25] មាត្រា ៥៨៣-៣ ក្រមរដ្ឋប្បវេណី
[26] មាត្រា ៥៨៤ ក្រមរដ្ឋប្បវេណី
[27] មាត្រា ៥៨៦-១ក្រមរដ្ឋប្បវេណី

គួររំលឹកផងដែរថា ពេលខ្លះអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ត្រូវបានអ្នកសរសេរពាក្យបណ្ដឹង ដាក់បញ្ចូលទៅក្នុងអង្គហេតុជាមូលហេតុនៃការទាមទារទៅវិញ។

ដូច្នេះយើងត្រូវសិក្សាលំអិតថាអ្វីទៅជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ[28]។

## ៥. អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬអង្គហេតុចម្បង

### ៥.១. ទ្រឹស្ដីនៃអង្គហេតុចម្បង

គោលបំណងនៃបណ្ដឹងរដ្ឋប្បវេណី គឺរក្សាការពារសិទ្ធិដែលត្រូវបានចែងដោយច្បាប់សារធាតុ ដូចនេះកម្មវត្ថុនៃការវិនិច្ឆ័យក្នុងនីតិវិធីបណ្ដឹងគឺជាសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលស្ថិតនៅក្រោមច្បាប់សារធាតុ។ នៅក្នុងបណ្ដឹងរដ្ឋប្បវេណី តុលាការត្រូវសម្រេចថាតើបណ្ដឹងទាមទារនោះ មាន ឬ គ្មានមូលហេតុត្រឹមត្រូវ មានន័យថា ដើមចោទមាន ឬគ្មានសិទ្ធិ ហើយសិទ្ធិទាមទាររបស់ដើមចោទ គឺជាចំណុចដែលតុលាការមិនអាចយល់ដឹងផ្ទាល់បានទេ ពីព្រោះសិទ្ធិគឺជាទស្សនវិស័យអរូបី ដែលមិនអាចប៉ះ ឬមើលបាន។ ដូច្នេះ ដើម្បីវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ តុលាការត្រូវវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលកើតឡើងសិទ្ធិនោះ ពីព្រោះអង្គហេតុ គឺជាចំណុចដែលអាចយល់ដឹងអំពីអត្ថិភាព ឬនត្ថិភាពបានដោយភស្តុតាង។ ឧទាហរណ៍៖ X ដាក់ពាក្យបណ្ដឹងទាមទារឲ្យ Y បញ្ជាក់កម្មសិទ្ធិនៃនាឡិកាដែលគាត់កាន់កាប់ ទោះបី X ដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់នូវកម្មសិទ្ធិនោះ ក៏កម្មសិទ្ធិជាទស្សនអរូបី មិនអាចប៉ះ ឬមើលបានទេ ដោយឡែកនាឡិកាជាវត្ថុ ដូចនេះ អាចប៉ះ ឬមើលបាន ប៉ុន្តែកម្មសិទ្ធិនៃនាឡិកាជាទស្សនវិស័យអរូបី មិនអាចយល់ដឹងថា អ្នកណាជាកម្មសិទ្ធិករឡើយ ទោះបីជាអាចប៉ះ ឬមើលបានក៏ដោយ។ ដូចនេះ ដើម្បីបញ្ជាក់កម្មសិទ្ធិ តុលាការតម្រូវឲ្យកម្មសិទ្ធិករអះអាងនូវអង្គហេតុដែលកើតឡើងនូវសិទ្ធិនោះ ដូចជា ប្រសិនបើ X បានទិញនាឡិកានោះនៅផ្សារ តុលាការឲ្យដើមចោទនោះអះអាងថាទិញពីពេលណា? ពីអ្នកណា? តម្លៃប៉ុន្មាន? និងឲ្យដើមចោទដាក់ភស្តុតាងដូចជា កិច្ចសន្យាលក់ទិញ ឬ វិក័យបត្រ ជាអាទិ៍ ហើយតាមរយៈភស្តុតាងនេះ តុលាការអាចយល់ដឹងអំពីកិច្ចសន្យាលក់ទិញ និងដឹងថា អ្នកណាជាកម្មសិទ្ធិករនៃនាឡិកានោះ។ អង្គហេតុ ដូចជាកិច្ចសន្យាលក់ទិញនេះ គឺជាអង្គហេតុដែលជាមូលហេតុនៃការបង្កើតទំនាក់ទំនងតាមផ្លូវច្បាប់ ដែលយើងហៅថា "**អង្គហេតុចម្បង**"។

[28] មាត្រា ៧៥-៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

### ៥.២. រចនាសម្ព័ន្ធក្រមនីតិវិធីរដ្ឋប្បវេណី

- **ការទាមទារ៖**

តុលាការមិនដឹងអំពីអត្ថិភាព នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលភាគីដាក់ ពាក្យបណ្ដឹងទាមទារនោះដោយភ្នែកនោះទេ ព្រោះវាមានលក្ខណៈអរូបី។ គោលការណ៍សិទ្ធិចាត់ចែង ត្រូវបានអនុវត្តនៅដំណាក់កាលទាមទារនេះ គឺមានន័យថា ភាគីអាចសម្រេចចិត្តបាន នៅពេលណាដែលអាចចាប់ផ្ដើមបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី១ ) បញ្ចប់បណ្ដឹង (មាត្រា ៩៧ មាត្រា ១០៤ និងមាត្រា ២១៧) ខ្លឹមសារបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី២ ចំណុច ខ )។ ភាគីអាចបញ្ចប់បណ្ដឹងបានដោយការដកពាក្យបណ្ដឹង ការលះបង់ ឬការទទួលស្គាល់ការទាមទារ ការសះជាតាមផ្លូវបណ្ដឹង[29]។

ករណីដើមចោទទាមទារ ហើយចុងចម្លើយទទួលស្គាល់ការទាមទារ នោះតុលាការកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរ (មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ករណីដើមចោទទាមទារ ហើយចុងចម្លើយមិនទទួលស្គាល់ការទាមទារ នោះតុលាការនឹងឲ្យដើមចោទអះអាងអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ ។

- **ការអះអាងអង្គហេតុ៖**

តុលាការត្រូវពិនិត្យមើល តើមានអង្គហេតុដែលជាមូលហេតុនៃការទាមទារដែរឬទេ? តើមានអង្គហេតុតវ៉ាដែរឬទេ? តើមានអង្គហេតុតវ៉ាតបដែរឬទេ?

អង្គហេតុដែលជាមូលហេតុនៃការទាមទារ ជាប្រភេទនៃអង្គហេតុចម្បង គឺអង្គហេតុអំពីកំណើតសិទ្ធិ។ ករណីដើមចោទមិនអាចអះអាងអង្គហេតុអំពីកំណើតសិទ្ធិគ្រប់គ្រាន់នោះទេ តុលាការនឹងច្រានចោលការទាមទាររបស់ដើមចោទ។

ដើម្បីប្រឆាំងនឹងដើមចោទ ចុងចម្លើយអាចមិនទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬក៏អះអាងអង្គហេតុតវ៉ា។ អង្គហេតុតវ៉ាជាប្រភេទនៃអង្គហេតុចម្បង រួមមាន៖ អង្គហេតុរាំងការកកើតសិទ្ធិ អង្គហេតុរលត់សិទ្ធិ និងអង្គហេតុទប់ស្កាត់ការប្រើប្រាស់សិទ្ធិ។

- ❖ **ប្រភេទទាំងបួននៃអង្គហេតុចម្បង៖**
- ➢ <u>អង្គហេតុនៃការកកើតឡើងនៃសិទ្ធិ៖</u>

[29] មាត្រា ២២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

សិទ្ធិទាមទារដោយផ្អែកតាមក្រមរដ្ឋប្បវេណី ឧទាហរណ៍: សិទ្ធិទាមទារតម្លៃផ្អែកលើកិច្ចសន្យាលក់ទិញ (យោងតាមមាត្រា ៥១៥ មាត្រា ៥៥៤ និងមាត្រា ៥៥៥)។

- <u>**អង្គហេតុនៃការរារាំងការកកើតសិទ្ធិ៖**</u>
  មានន័យថា គឺរាំងសិទ្ធិមិនឲ្យកើតមាន អត់មានសិទ្ធិទាមទារ។
  អង្គហេតុផ្សេងបានរារាំងអានុភាពនៃកិច្ចសន្យា (ឧទាហរណ៍: កិច្ចសន្យាផ្ទុយសណ្ដាប់ធ្នាប់សាធារណៈ យោងតាមមាត្រា ៣៥៤ ... ទោះបីកិច្ចសន្យាមានក៏ដោយ ក៏ប៉ុន្តែមានអង្គហេតុផ្សេងរារាំងអានុភាពនៃកិច្ចសន្យានោះ)។
- <u>**អង្គហេតុនៃការរលត់សិទ្ធិ៖**</u>
  សិទ្ធិកើតមានហើយ តែសិទ្ធិនោះត្រូវបានរលត់ទៅវិញ (ឧទាហរណ៍: ដោយការសង យោងតាមមាត្រា ៤៣៣ នៃក្រមរដ្ឋប្បវេណី)។
- <u>**អង្គហេតុនៃការទប់ស្កាត់ការប្រើប្រាស់សិទ្ធិ៖**</u>
  សិទ្ធិកើតមានហើយ គឺមិនទាន់រលត់ទៅវិញទេ តែមិនទាន់អាចអនុវត្តសិទ្ធិនោះបានដោយអង្គហេតុផ្សេងៗ (ឧទាហរណ៍: សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ដែលមានចែងក្នុងមាត្រា ៥៥១ និងមាត្រា ៥៥៨ នៃក្រមរដ្ឋប្បវេណី ... ទោះម្ចាស់បំណុលមានសិទ្ធិហើយក៏ដោយ តែកូនបំណុលអាចបដិសេធសិទ្ធិនោះបាន)។

- **ការបញ្ជាក់ភស្តុតាង៖**

តុលាការពិនិត្យតែភស្តុតាងដែលផ្តល់ដោយភាគីតែប៉ុណ្ណោះ ។ ការបញ្ជាក់ភស្តុតាងត្រូវធ្វើនៅដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់។

ករណីដើមចោទអះអាងអង្គហេតុអំពីកំណើតសិទ្ធិ ហើយចុងចម្លើយមិនទទួលស្គាល់អង្គហេតុនោះ ដើមចោទត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ដោយភស្តុតាង។

ករណីដើមចោទអះអាងអង្គហេតុអំពីកំណើតសិទ្ធិ ហើយចុងចម្លើយអះអាងអង្គហេតុតវ៉ា នោះចុងចម្លើយទទួលបន្ទុកក្នុងការបញ្ជាក់ដោយភស្តុតាងចំពោះអង្គហេតុតវ៉ានោះ។

ជារួម គឺអង្គហេតុណាដែលភាគីណាមួយអះអាង ភាគីនោះត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ដោយភស្តុតាង លើកលែងតែភាគីម្ខាងទៀតបានសារភាព។

### ៥.៣. ការទទួលខុសត្រូវក្នុងការបញ្ជាក់

ដើម្បីចេញសាលក្រម តុលាការពិចារណា គឺពិចារណាទៅលើអង្គហេតុដែលកើតមាន ដើម្បីផ្ទៀងផ្ទាត់នឹងច្បាប់។ អង្គហេតុត្រូវបានទទួលស្គាល់ដោយតុលាការ តាមរយៈការសារភាព ឬតុលាការអាចទទួល

ស្គាល់អង្គហេតុដែលមានវិវាទតាមរយៈភស្តុតាងដែលភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ស្នើសុំឲ្យពិនិត្យ។ ពុំមានអង្គហេតុណាមួយដែលភាគីទាំងសងខាងទទួលខុសត្រូវក្នុងការបញ្ជាក់នោះទេ។

ការទទួលខុសត្រូវក្នុងការបញ្ជាក់ គឺជាហានិភ័យ ឬការខូចខាតផលប្រយោជន៍ ដែលភាគីណាមួយនឹងទទួលខុសត្រូវ ដែលខ្លឹមសារថា ក្នុងករណីទោះបីជាតុលាការពិនិត្យមើលភស្តុតាងហើយក៏ដោយ តុលាការមិនអាចយល់ដឹងបានថាអង្គហេតុនោះពិតជាមាននោះទេ តុលាការនឹងសន្មតថាអង្គហេតុនោះអត់មាន។

# សិក្ខាសាលាគណៈមេធាវី(ធំ)លើកទី១១

## ប្រធានបទ៖ ភតិសន្យា និងសិទ្ធិជួលអចិន្ត្រៃយ៍

## ថ្ងៃទី ១៨ កុម្ភៈ ២០១៦

# ភតិសន្យា និង សិទ្ធជួលអចិន្ត្រៃយ៍

## ជំពូកទី ១.  គោលគំនិតនៃភតិសន្យា

### សេចក្តីផ្តើម

ជាញឹកញាប់គេតែងឃើញមានកិច្ចសន្យាជាច្រើនប្រភេទ ត្រូវបានប្រើប្រាស់ដើម្បីបំពេញសេចក្តីត្រូវការប្រចាំថ្ងៃ និង ក្នុងសកម្មភាពពាណិជ្ជកម្មជាដើម ដែលមានដូចជាកិច្ចសន្យាទិញលក់កិច្ចសន្យាខ្ចីបរិភោគ កិច្ចសន្យាខ្ចីប្រើ កិច្ចសន្យាការងារ កិច្ចសន្យាសាងសង់ និង កិច្ចសន្យាជួល ជាដើម។ កិច្ចសន្យាជួល ឬ ហៅថាភតិសន្យាតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គេតែងសង្កេតឃើញមានស្ទើរគ្រប់ទីកន្លែងទាំងសម្រាប់ការជួលចលនវត្ថុ និង ជួលអចលន វត្ថុ។ ភតិសន្យាខ្លះទាមទារអោយភាគីនៃកិច្ចសន្យាយល់ដឹងអោយបានច្រើនអំពីខ្លឹមសារ និង អត្ថន័យនៃកិច្ចសន្យាដូចជា ការបង្កើតកិច្ចសន្យាដែលច្បាប់ទទួលស្គាល់សិទ្ធិ និង កាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យា និង ការរំលាយកិច្ចសន្យាជាដើម។

ហេតុនេះដើម្បីជាពន្លឺនៃការយល់ដឹងខ្លះៗដែលទាក់ទងនឹងភតិសន្យានេះ ឯកសារនេះនឹងអាចជួយជាជំនួយស្មារតីខ្លះៗសម្រាប់ការស្វែងយល់។

### ១. និយមន័យ

ភតិសន្យា គឺជាកិច្ចសន្យាមួយដែលភាគីម្ខាងអនុញ្ញាតឲ្យភាគីម្ខាងទៀតប្រើប្រាស់ និងអាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃ (ក.រ៥៩៦)។ តាមនិយមន័យខាងលើ គឺមានន័យថាភតិបតី (តាមច្បាប់ភូមិបាលឆ្នាំ២០០១ ប្រើពាក្យថាភតិសន្យាបតី) យល់ព្រមអោយភាគីម្ខាងទៀតដែលជាភតិកៈទទួលបាននូវសិទ្ធិក្នុងការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុដែលជួលដោយភតិកៈត្រូវផ្តល់ជាតម្លៃតបស្នងទៅអោយភតិបតីនូវប្រាក់ឈ្នួលតាមការព្រមព្រៀង។ សេចក្តីដែលបានរៀបរាប់ក្នុងនិយមន័យខាងលើអាចជាចលនវត្ថុ និង អចលនវត្ថុសុទ្ធតែអាចយកធ្វើជាកម្មវត្ថុនៃភតិសន្យាបាន (ក.រ 596-2)។

### ២. ការបង្កើតភតិសន្យា

ភតិសន្យាអាចត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងគូភាគី។ ភតិសន្យាអាចត្រូវបានបង្កើតឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏បាន(ក.រ597)។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងគឺការធ្វើជាលាយលក្ខណ៍អក្សរគឺមានភាពប្រសើរព្រោះវាធ្វើអោយខ្លឹមសារនៃកិច្ចសន្យាមានភាពច្បាស់លាស់ និងជាក់លាក់ជាងភតិសន្យាដែលធ្វើដោយផ្ទាល់មាត់ដែលភាគីម្ខាងងាយនឹងបដិសេធន៍ក្នុងការអនុវត្តកាតព្វកិច្ច ដែលខ្លួនត្រូវបំពេញដែលជាហេតុធ្វើអោយភាគីម្ខាងទៀតពិបាកក្នុងការបញ្ជាក់ភស្តុតាង។ ម្យ៉ាងទៀតភតិសន្យាដែលធ្វើឡើងដោយផ្ទាល់មាត់ត្រូវបានច្បាប់ចាត់ទុកថាជាភតិសន្យាដែលគ្មានកំណត់អំឡុងពេល (ក.រ៥៩៩-២) ដែលបើកសិទ្ធិអោយភាគីណាមួយងាយស្រួលក្នុងការបញ្ចប់កិច្ចសន្យា (ក.រ៦១៥)។

**ឧទាហរណ៍ៈ ភតិបតីព្រមព្រៀងជួលផ្ទះអោយទៅភតិកៈក្នុងអំឡុងពេល៥ឆ្នាំ តាមការព្រមព្រៀង ប៉ុន្តែបានធ្វើកិច្ចសន្យាត្រឹមតែផ្ទាល់មាត់ប៉ុណ្ណោះ។ ក្នុងករណីនេះប្រសិនបើ ភាគីភតិបតីមានបំណងបញ្ចប់កិច្ចសន្យាជួលមុនអំឡុងពេល៥ឆ្នាំនោះគឺភតិបតីអាចធ្វើបាន និងដូចគ្នាដែរចំពោះភតិកៈ។**

ដើម្បីបង្កើតភតិសន្យាគឺ មានចំណុចសំខាន់ចំនួន ៣ គឺៈ

**ក).វត្ថុដែលជាកម្មវត្ថុនៃភតិសន្យាៈ** ជាទូទៅ គេច្រើនសំដៅដល់ចលនវត្ថុ និង អចលនវត្ថុសុទ្ធតែគេអាចយកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាជួលបាន (ក.រ596-2)។

**ខ).ចំនួនថ្លៃឈ្នួលៈ** ភតិសន្យាមានអានុភាពនៅពេលដែលការបង្ហាញឆន្ទៈត្រូវបានធ្វើតាម រយៈការចុះកិច្ចសន្យា ក្នុងករណីនេះ ភតិកៈមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួលព្រមទាំងត្រូវបង់ថ្លៃឈ្នួល។ ថ្លៃឈ្នួលសម្រាប់កិច្ចសន្យាជួល គឺតម្រូវអោយមាន ប៉ុន្តែ អាចជាការតម្រូវអោយអនុវត្តកាតព្វកិច្ចជំនួសក៏បានអាស្រ័យតាមការព្រមព្រៀងព្រោះថា បើមិនមានកំណត់ថ្លៃឈ្នួលទេ នោះអាចចូលទៅក្នុងប្រភេទនៃកិច្ចសន្យាផ្សេងទៀតដូចជាកិច្ចសន្យាខ្ចីប្រើ (ក.រ៦២៥) ឬក៏ផលុបភោគជាដើម (ក.រ២៥៦)។

**គ).អំឡុងពេលនៃភតិសន្យាៈ** ជាធម្មតា កិច្ចសន្យាជួល គឺត្រូវមានកំណត់អំឡុងពេលជាក់លាក់ការធ្វើបែបនេះ គឺផ្តល់លក្ខណៈងាយដល់គូភាគីក្នុងការសម្រេចចិត្តនានាពាក់ព័ន្ធនឹងវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជួលនោះ។ ប៉ុន្តែ ភតិសន្យាដែលពុំមានកំណត់អំឡុងពេលក៏នៅតែមាន សុពលភាពដដែល (ក.រ៥៩៩-១)។ ក្នុងករណីមានកំណត់អំឡុងពេលជាក់លាក់គឺ ត្រូវអនុវត្តតាមការព្រមព្រៀងរបស់គូភាគី ប៉ុន្តែ ករណីការជួលអចលនវត្ថុដែលមានកំណត់អំឡុងពេលចាប់ពី ១៥ឆ្នាំឡើងទៅគឺត្រូវអនុវលោមតាមក្រមរដ្ឋប្បវេណី (ក.រ២៤៤សិទ្ធិជួលអចិន្ត្រៃយ៍) ដែលនឹងលើកយកមកបង្ហាញនៅផ្នែកក្រោយ។ ម្យ៉ាងទៀត ករណីដែលភាគីមិនបានកំណត់អំឡុងពេលទេនោះភាគីអាចជូនដំណឹងរំលាយកិច្ចសន្យាពេលណាក៏បានហើយ ភតិសន្យានឹងត្រូវបញ្ចប់ក្នុងកំឡុងពេលជាក់លាក់មួយ (ក.រ615)។

**ករណីទី 1**: X បានយល់ព្រមជួលដីទៅ Y ក្នុងរយៈពេល 5 ឆ្នាំ សម្រាប់ការធ្វើកសិកម្ម។

X និង Y បានចុះហត្ថលេខាលើកិច្ចសន្យាជួលជាលាយល័ក្ខណ៍អក្សរ ប៉ុន្តែ មិនទាន់បានកំណត់ថ្លៃឈ្នួលនៅឡើយ ដោយសារស្ថិតនៅក្នុងការចរចា។ ចំនួនទឹកប្រាក់នៃការជួលនេះនឹងត្រូវបានបំពេញបន្ថែមនៅពេលមានការព្រមព្រៀងគ្នាលើចំនួនប្រាក់ឈ្នួល។ ទោះជាយ៉ាងណា មុនពេលពួកគេឈានដល់កិច្ចព្រមព្រៀងលើចំនួនប្រាក់ឈ្នួលនេះ Y បានចាប់ផ្តើមធ្វើកសិកម្មលើដីនោះ។ តើ X អាចបណ្តេញ Y ចេញពីដីនោះដែរឬទេ?

**ករណីទី 2 :** X បានយល់ព្រមជួលដីទៅ Y ក្នុងរយៈពេល 5 ឆ្នាំសម្រាប់ការធ្វើកសិកម្មតាមកិច្ចសន្យាជាលាយលក្ខអក្សរ។ពួកគេមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់លើថ្លៃឈ្នួលទេគ្រាន់តែយល់ព្រមលើទំហំ10% នៃទិន្នផលដែលបានពីដីកសិកម្ម។ តើករណីនេះ ភតិសន្យាត្រូវបានបង្កើតហើយ ឬនៅ?

## ៣. ល័ក្ខខ័ណ្ឌតតាំង

នៅក្នុងភតិសន្យា ល័ក្ខខ័ណ្ឌតតាំងសំដៅដល់ការបើកសិទ្ធិអោយភតិកៈអះអាង អំពីសិទ្ធិភតិសន្យាលើវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជួលប្រឆាំងនឹងតតិយជន នៅពេលដែលខ្លួនបានគោរពតាមល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់។

### ៣.១. ល័ក្ខខ័ណ្ឌតតាំងដោយផ្អែកលើការកាន់កាប់ជាក់ស្តែង

ជាទូទៅភតិបតី មានកម្មសិទ្ធិនៅលើវត្ថុដែលជាកម្មវត្ថុនៃការជួល ដូច្នេះភតិបតីអាចធ្វើ អនុប្បទានសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការជួលអោយទៅតតិយជនបាន។ តតិយជនដែលជាម្ចាស់កម្មសិទ្ធិថ្មី ត្រូវទទួលបានការការពារនូវកម្មសិទ្ធិ ហើយអាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនចំពោះគ្រប់បុគ្គលទាំងអស់។ ផ្ទុយទៅវិញ សម្រាប់ភតិសន្យា ភតិកៈ អាចអះអាងពីសិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់ខ្លួនបានចំពោះតែភតិបតីប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើម្ចាស់កម្មសិទ្ធិថ្មីទាមទារឲ្យភតិកៈប្រគល់មកវិញនូវវត្ថុដែលជាកម្មវត្ថុនៃភតិសន្យា នោះជាទូទៅ ភតិកៈត្រូវតែប្រគល់ត្រឡប់វិញ។

ក៏ប៉ុន្តែ ក្នុងស្ថានភាពបែបនេះវានឹងធ្វើឲ្យភតិកៈស្ថិតនៅក្នុងស្ថានភាពដែលចាញ់ប្រៀប ឬខូចខាតផលប្រយោជន៍ធ្ងន់ធ្ងរ ព្រោះវាពាក់ព័ន្ធខ្លាំងនឹងជីវភាពរស់នៅរបស់ភតិកៈ ជាពិសេសក្នុងករណីនៃភតិសន្យាអចលនវត្ថុ ដូចជាក្នុងករណីដែល ភតិកៈជួលទីតាំងដីដើម្បីបើកអាជីវកម្មជាដើម ដែលភតិកៈត្រូវចំណាយលើការសាងសង់ និងកែលំអរច្រើន។ ហេតុដូចនេះ ហើយបានជាក្រមរដ្ឋប្បវេណីកម្ពុជាបានបញ្ញត្តិថា នៅក្នុងករណីនៃភតិសន្យាអចលនវត្ថុ ភតិកៈអាចអះអាងពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងភតិសន្យាចំពោះជនដែលធ្វើលទ្ធកម្មបន្តនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះបានដោយផ្អែកទៅលើអង្គហេតុថា ភតិកៈ បានកាន់កាប់ និង ប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុជួលនោះ(ក.រ៥៩៨-១ )។

ហេតុនេះ ការអះអាងអំពីល័ក្ខខ័ណ្ឌតតាំងចំពោះជនដែលទទួលបាននូវលទ្ធកម្មសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដែលជាកម្មវត្ថុនៃភតិសន្យាបានលុះត្រាតែ ភតិកៈអាចបង្ហាញភស្តុតាងអំពីការចូលកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ប៉ុន្តែសម្រាប់ភតិកៈដែលមិនចូលកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងទេ នោះច្បាប់ពុំសូវការពារឡើយ។

**ករណីទី៣:** X ជាភតិបតី ហើយ Y ជាភតិក:។ អ្នកទាំងពីរបានព្រមព្រៀងបង្កើតកិច្ចសន្យាជួលផ្ទះហើយ Y បានចូលកាន់កាប់ និង អាស្រ័យផលលើផ្ទះនោះ។ ក្រោយមក X បានលក់ផ្ទះនេះទៅអោយ Z។ បន្ទាប់មក Z បានទាមទារអោយ Y ចាកចេញ និងប្រគល់ផ្ទះដោយអះអាងថាខ្លួនជាកម្មសិទ្ធិករ។ តើក្នុងករណីនេះ Y អាចបដិសេធមិនចាកចេញបានទេ? មូលហេតុអ្វី?




**ចំណុចបញ្ហាទី ១**: តើភតិសន្យានៃចលនវត្ថុទទួលបានល័ក្ខខ័ណ្ឌតតាំងដែរឬទេ? ឧទាហរណ៍ X ជាភតិបតី Y ជាភតិក:។ ពួកគេបានធ្វើកិច្ចសន្យាជួលម៉ាស៊ីនចម្លង ហើយ Y បានកាន់កាប់ និងអាស្រ័យផលពីម៉ាស៊ីននោះ។ ក្រោយមកទៀត X បានលក់ម៉ាស៊ីនចម្លងនោះទៅឲ្យ Z។ ហើយ Z បានទាមទារម៉ាស៊ីនចម្លងនោះពី Y ដោយអះអាងថាគាត់ជាម្ចាស់ម៉ាស៊ីនចម្លងនោះ។ ក្នុងករណីនេះ តើ Y អាចបដិសេធមិនប្រគល់ម៉ាស៊ីនចម្លងដែរឬទេ? តើហេតុអ្វី?

### ៣.២. ការអនុវត្តសិទ្ធិទាមទារអោយប្រគល់វិញ ឬ បញ្ឈប់ការរារាំង ឬ ការបង្ការជាមុន

ក្នុងករណីភតិសន្យានៃអចលនវត្ថុជាមួយល័ក្ខខ័ណ្ឌតតាំង បើមានការបំពានដោយជាក់ស្តែងដោយតតិយជន ចំពោះភតិក: ទោះតតិយជននោះ ជាម្ចាស់កម្មសិទ្ធិករថ្មីដែលបានទិញពី ភតិបតីក៏ដោយ នៅពេលមានការបំពានដោយកំរោល ដូចជាការបណ្តេញចេញដោយបង្ខំ ឬ ដោយហឹង្សាជាដើម នោះភតិក: អាចទាមទារទៅតុលាការដើម្បីអោយមានការប្រគល់ត្រលប់វិញនូវវត្ថុដែលជាកម្មវត្ថុនៃការជួលនោះ។

លើសពីនេះទៀត ភតិកៈក៏អាចប្តឹងដើម្បីបញ្ឈប់ការរារាំង ឬ ដើម្បីបង្ការជាមុននូវការរារាំង ដោយបំពានពីតតិយជនបាន ប្រសិនបើ ខ្លួនមានហេតុផលសមស្របដែលអាចមើលឃើញដោយសមហេតុផលថា ពិតជានឹងមានការរារាំង ឬ ការបំពានពីតតិយជនណាមួយ ដែលធ្វើអោយខ្លួនមិន អាចអនុវត្តសិទ្ធិជួលបាន។ នេះគឺជាការទទួលស្គាល់នូវសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ចំពោះសិទ្ធិជួលដែលមានអានុភាពតតាំង (មាត្រា ៥៩៨-២ នៃក.រ )។

**ករណីទី 4** : X បានជួលដីមួយកន្លែងទៅឲ្យ Y។ បន្ទាប់ពី Y បានចាប់ផ្តើមកាន់កាប់ដីនោះ Z បានបណ្តេញ Y ដោយខុសច្បាប់ និង បានកាន់កាប់ដីនោះថែមទៀតផង។ តើ Y អាចបណ្តេញ Z និងកាន់កាប់ដីនោះវិញដែរ ឬទេ?

**ករណីទី 5** : A បានជួលទូកមួយគ្រឿងទៅឲ្យ B។ B បានកាន់កាប់ទូកនោះ ប៉ុន្តែក្រោយមក C បានយកទូកនោះទុកនៅឯផ្ទះរបស់ខ្លួន។ តើ B អាចទាមទារទូកនោះត្រឡប់មកវិញដែរ ឬទេ?

**ករណីទី 6** : X បានជួលដីមួយកន្លែងទៅឲ្យ Y។ មុនពេល Y ចាប់ផ្តើមកាន់កាប់ដីនោះ Z បានកាន់កាប់ដីនោះដោយខុសច្បាប់។ តើ Y អាចបណ្តេញ Z ចេញដែរ ឬទេ?

## ៤. ប្រាក់កក់

នៅក្នុងភតិសន្យា ប្រាក់កក់ វាជាសេរីភាព និងការជ្រើសរើសរបស់ភាគីនៃកិច្ចសន្យាថា តើតម្រូវអោយមានប្រាក់កក់ ឬមិនតម្រូវអោយមានកក់ប្រាក់។ ជាការអនុវត្ត ភាគច្រើនភតិសន្យា ភាគីភតិបតីតែងតម្រូវអោយមានការកក់ប្រាក់ជាមុន ដើម្បីធ្វើជាប្រាក់តម្កល់សម្រាប់ធានាក្នុងករណីមានការខូចខាត ឬមានការបាត់បង់ វត្ថុជួល ដោយប្រការណាមួយ ឬ ភាគីភតិកៈខកខានក្នុងការបង់ប្រាក់ឈ្នួល នោះភតិបតីអាចយកប្រាក់កក់នោះមកធ្វើការកាត់កងចំពោះការខូចខាត ឬបាត់បង់ ឬទូទាត់ការខកខានការបង់ប្រាក់ឈ្នួលនោះ។ ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ប្រាក់កក់មិនមែនជា ល័ក្ខខ័ណ្ឌតម្រូវដែលត្រូវតែមានទេ ពោលគឺមានក៏បាន គ្មានក៏បាន។ នៅក្នុងប្រទេសកម្ពុជា ភតិសន្យាខ្លះភាគីបានកំណត់អំពីប្រាក់កក់ ដែលប្រាក់កក់នោះ ទុកធានាចំពោះការសងការខូចខាត ឬការខកខានក្នុងការបង់ប្រាក់ឈ្នួលនៅពេលចប់កិច្ចសន្យាជួល ប៉ុន្តែ ពេលខ្លះភាគីភតិកៈច្រើនតែទាមទារទូទាត់ប្រាក់កក់នេះជាប្រាក់ឈ្នួលខែដំបូង។

នៅប្រទេសជប៉ុន តុលាការកំពូលប្រទេសជប៉ុន បានបកស្រាយថា ភតិកៈមិនអាចធ្វើការទូទាត់ប្រាក់ឈ្នួលដែលមិនទាន់បានបង់ជាមួយនឹងប្រាក់កក់ទេ ព្រោះថាភតិបតីមានសិទ្ធិរក្សាទុកប្រាក់កក់នេះរហូតដល់ពេលចប់កិច្ចសន្យា។

ឧ. ភតិកៈបានកក់ប្រាក់ស្មើនឹងចំនួន ៤ខែ។ ភតិកៈបានខកខានក្នុងការបង់ប្រាក់ឈ្នួលចំនួន ៣ខែ។ ក្នុងករណីនេះ ភតិបតីអាចទាមទារឲ្យភតិកៈបង់ប្រាក់ឈ្នួលដែលខកខានចំនួន ៣ខែ ហើយក្នុងករណីភតិកៈ បដិសេធក្នុងការបង់ នោះភតិបតីអាចរំលាយកិច្ចសន្យាបាន ដោយសម្អាងថា ភតិកៈបំពានកិច្ចសន្យា បើទោះបីជាភតិបតីមានប្រាក់ក្នុងដៃគ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ក៏ដោយ។

ក្នុងករណីនេះតុលាការកំពូលរបស់ប្រទេសជប៉ុនបកស្រាយថាប្រាក់កក់ គឺតម្កល់ទុកធានាសំណងនូវការខូចខាត ទាំងឡាយដែលបានកើតឡើង រហូតដល់ពេលដែលវត្ថុជួលត្រូវបានប្រគល់ត្រឡប់វិញអោយទៅភតិបតី។ នេះមានន័យថាចំនួនសិទ្ធិលើបំណុលដែលត្រូវបានធានា អាចត្រូវបានកំណត់ ក្រោយពេលដែលវត្ថុជួលត្រូវបានប្រគល់ត្រឡប់វិញនូវវត្ថុជួលជាមុនសិន ហើយបន្ទាប់មកទើបភតិកៈមានសិទ្ធិទទួលបានការប្រគល់ប្រាក់កក់ត្រឡប់វិញ។ ភតិកៈ មិនអាច បដិសេធក្នុងការប្រគល់វត្ថុជួល ដោយអះអាងអំពីការអនុវត្តព្រមគ្នាជាមួយនឹងការប្រគល់ប្រាក់កក់ត្រឡប់វិញបានទេ។

## ជំពូកទី២. អានុភាពនៃភតិសន្យា

### ១. ការអាស្រ័យផល និងប្រើប្រាស់តាមវិធីប្រើប្រាស់ធម្មតា

នៅពេលភតិសន្យាត្រូវបានបង្កើតឡើង ភតិកៈមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ដោយផ្អែកតាមវិធីប្រើប្រាស់ ហើយភតិកៈក៏មានករណីកិច្ចដូចគ្នាដែរដោយផ្អែកតាម ការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ដូចជាការចូលទៅរស់នៅក្នុងផ្ទះ ការប្រកបអាជីវកម្មដែលស្របច្បាប់ជាដើម។ សិទ្ធិប្រើប្រាស់នេះត្រូវបានប្រើប្រាស់ដោយសេរី និងពេញលេញ និងមិនត្រូវរារាំង ឬ រំខានដោយភតិបតី (មាត្រា ៦០០ នៃក.រ)។

ប្រសិនបើការប្រើប្រាស់នោះត្រូវបានរំខាន ឬរាំងស្ទះដោយតតិយជនមួយផ្សេងទៀតក្រៅពីភតិបតី ភតីកៈអាចលុបបំបាត់ការរំខាន ឬ ឧបសគ្គដោយការអនុវត្តសិទ្ធិដើម្បីទាមទារឲ្យបញ្ឈប់ការរំខានដោយផ្អែកលើភតិសន្យាដែលមានល័ក្ខខ័ណ្ឌតតាំង (មាត្រា 598-2 នៃក.រ) ឬដែលផ្អែកលើមូលដ្ឋានលើសិទ្ធិនៃការកាន់កាប់ ( មាត្រា 236 នៃក.រ)។

**ករណីទី 7 :** X បានជួលផ្ទះទៅឲ្យ Y ហើយ Y បានចាប់ផ្តើមកាន់កាប់ និងប្រើប្រាស់ផ្ទះនោះ។ ប្រសិនបើ X រំខានដល់ Y ក្នុងការប្រើប្រាស់ផ្ទះនោះ Y អាចបញ្ឈប់ការរំខានដោយផ្អែកលើកិច្ចសន្យាជួល (មាត្រា 600 នៃក.រ)។ ប្រសិនបើ Z ដែលជាតតិយជនបានរំខាន Y ក្នុងការប្រើប្រាស់ផ្ទះ Y បញ្ឈប់ការរំខានដោយប្រើសិទ្ធិក្នុងការទាមទារយកចេញការរំខានដោយផ្អែកលើភតិសន្យាជាមួយល័ក្ខខ័ណ្ឌតតាំង (មាត្រា 598-2នៃក.រ) ។

**ករណីទី 8 :** X បានជួលទូកមួយគ្រឿងទៅឲ្យ Y ហើយ Y បានចាប់ផ្តើមកាន់កាប់ និង ប្រើប្រាស់ទូកនោះ។ ប្រសិនបើ X រំខានដល់ Y ក្នុងការប្រើប្រាស់ទូកនោះ Y អាចបញ្ឈប់ការរំខានដោយអានុភាពនៃកិច្ចសន្យាជួល (មាត្រា 600នៃក.រ)។ ប្រសិនបើ Z ដែលជាតតិយជនបានរំខាន Y ក្នុងការប្រើទូកនោះ Y អាចបញ្ឈប់ការរំខានដោយការប្រើសិទ្ធិក្នុងការទាមទារយកចេញនូវការរំខានដោយផ្អែកលើសិទ្ធិនៃការកាន់កាប់ (មាត្រា 238នៃក.រ)។

## ២. ករណីកិច្ចប្រុងប្រយ័ត្នរបស់ភតិកៈក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត

ភតិកៈទោះបីមានសិទ្ធិប្រើប្រាស់វត្ថុជួលដោយសេរី និងផ្អែកតាមមុខងាររបស់វាក៏ដោយ ក៏ភតិកៈមានករណីកិច្ចត្រូវគ្រប់គ្រង និង អាស្រ័យផលវត្ថុជួលដោយប្រុងប្រយ័ត្ន និងក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ ការគ្រប់គ្រងដោយសុចរិត មានដូចជា ការបោសសម្អាតជាប្រចាំ ការបិទទ្វា ឬ បង្អួចនៅពេលមានភ្លៀង ការប្រុងប្រយ័ត្នកុំអោយប្រលាក់ ឬ កូត ឬរហែកក្រដាសរចនាជញ្ជាំងនៅពេលមានការផ្លាស់ប្តូរទីតាំងគ្រឿងសង្ហារឹមជាដើម និងការថែទាំជាប្រចាំដើម្បីអោយវត្ថុជួលនៅរក្សាស្ថានភាពល្អប្រហាក់ប្រហែលនឹងស្ថានភាពពេលជួលដែរ។ តែការប្រើប្រាស់តាមលក្ខណៈសឹករិចរិលរបស់វត្ថុជួលតាមមុខងាររបស់វាគឺជាការប្រើប្រាស់ធម្មតា (មាត្រា៦០១នៃក.រ, មាត្រា ៦១៨-២នៃក.រ)។

ឧ. ដូចជាការជួលឡានក្នុងគោលបំណងយកទៅរត់ឈ្នួល នោះភតិកៈអាចប្រើឡានដឹកភ្ញៀវ សឹកកង់ឡានខ្លាំង ដែលត្រូវដូរជារៀងរាល់ ២ខែម្តង។

ក្នុងករណីភតិកៈមិនបានប្រើប្រាស់ និងអាស្រ័យផលវត្ថុជួលក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតទេ នោះនឹងជាមូលហេតុ ដែលអាចអោយភតិបតីរំលាយកិច្ចសន្យាជួលបាន (ក.រ៦០១-២)។

## ៣. ការជួសជុលវត្ថុជួល

ក្នុងអំឡុងពេលជួលជាទូទៅ ភតិកៈ ជាអ្នកកាន់កាប់ ប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួលទោះដោយផ្ទាល់ ឬដោយប្រយោល ហេតុនេះ នៅពេលមានការប្រើប្រាស់តែងតែមានការបែកបាក់ ឬ ការខូចខាតផ្សេងៗកើតមានជៀសមិនផុត ដែលតម្រូវអោយមានការជួសជុល។ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ថា

ការជួសជុលទាំងឡាយណាដែលមានភាពចាំបាច់សម្រាប់ការប្រើប្រាស់ និងអាស្រ័យផលនៃវត្ថុជួលនោះ គឺជាការទទួលខុសត្រូវរបស់ ភតិបតី ដែលមានដូចជា ការជួសជុលការជ្រាបទឹកភ្លៀង ការផ្លាស់ប្តូរសសរដែលពុក ការចាប់បំពេញនូវស្នាមប្រេះជ្រៅៗនៅលើជញ្ជាំង ការផ្លាស់ប្តូរបំពង់បង្ហូរទឹកដែលលិច ការផ្លាស់ប្តូរបង្អួចដែលបែកបាក់ ការជួសជុលម៉ាស៊ីនត្រជាក់ ដែលខូចដែលជារបស់ភតិបតី ការជួលជុលដំបូល ឬធ្នឹម ជាដើម(ក.រ៦០២)។

ដើម្បីអោយករណីកិច្ចជួសជុលកើតឡើង មានល័ក្ខខ័ណ្ឌចំនួន២ ដែលត្រូវបំពេញគឺៈ

១). ភាពចាំបាច់នៃការជួសជុល និង ២). លទ្ធភាពនៃការជួសជុល។

១). **ភាពចាំបាច់នៃការជួសជុលៈ** ប្រសិនបើការខូចខាតកើតមានឡើងតែបន្តិចបន្តួចដែល មិនរំខានដល់ភតិកៈក្នុងការប្រើប្រាស់ និងអាស្រ័យផលនៃវត្ថុជួលទេ នោះកាតព្វកិច្ចជួសជុលរបស់ភតិបតីមិនកើតមានឡើងទេ។ ឧ.ស្នាមប្រេះដែលមិនជ្រៅនៅលើផ្ទៃជញ្ជាំង សភាពប្រឡាក់របស់អាគារដោយសារការសាងសង់ជាយូរឆ្នាំហើយ។

២). **លទ្ធភាពនៃការជួសជុលៈ** ប្រសិនបើមើលទៅឃើញថាមិនមានលទ្ធភាពក្នុងការជួសជុលការខូចខាតនោះទេ នោះកាតព្វកិច្ចជួសជុលមិនកើតឡើងទេ។ ក្នុងករណីនេះ ភតិកៈ មិនអាចទាមទារអោយភតិបតីជួសជុលបានទេ ប៉ុន្តែ អាចទាមទារកាត់បន្ថយថ្លៃឈ្នួល ឬបញ្ចប់ភតិសន្យាបាន(ក.រ៦០៧)។

ទោះបី ភតិបតីមិនបានប្រព្រឹត្តកំហុសក៏ដោយ ក៏ភតិកៈ នៅតែអាចទាមទារអោយ ភតិបតីជួសជុលការខូចខាតនោះបានដែលមានន័យថា កំហុសរបស់ភតិបតីមិនមែនជាល័ក្ខខ័ណ្ឌចាំបាច់ក្នុងការកកើតករណីកិច្ចជួសជុលនោះទេ។ ដូចជាការខូចខាតនោះកើតឡើងដោយករណី ប្រធានសក្តិក៏ដោយ ក៏ភតិបតីមានករណីកិច្ចត្រូវជួសជុលការខូចខាតនោះដែរ។

បញ្ញត្តិនេះ គឺជាបញ្ញត្តិតាមការស្ម័គ្រចិត្ត ហេតុនេះ ភតិសន្យាភាគច្រើនអោយ ភតិបតីរួចផុតពីករណីកិច្ចជួសជុលការខូចខាត លើកលែងការខូចខាតនោះមានទំហំធំ។ ហើយការព្រមព្រៀងបែបនេះគឺមានសុពលភាព។

> ករណីពិចារណារ ៖ មាត្រា ១១១ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលត្រូវបាននិរាករណ៍ដោយមាត្រា ៨០ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលបានចែងថា "អ្នកជួល ត្រូវធានាការថែទាំទ្រព្យជាធម្មតា និងត្រូវសងមកវិញក្នុងស្ថានភាពមួយស្របតាមស្ថានភាពអចលនវត្ថុ និងសម្ភារៈ នៅពេលផុតកំណត់កិច្ចសន្យាជួល ដោយគិតទាំងតម្លៃនៃ ការខូចខាតដែលកើតពីការប្រើប្រាស់មិនធម្មតា..."។

**ករណីទី 9 :** X បានជួលផ្ទះឲ្យទៅ Y ក្នុងតម្លៃ$ 300 / ខែ។ 6 ខែក្រោយពីការប្រើប្រាស់ផ្ទះជាធម្មតាជញ្ជាំងនៅក្រៅផ្ទះបានកោសកកិតបន្តិចបន្តួច។ Y ទាមទារឲ្យX ផាត់ពណ៌ថ្មីលើជញ្ជាំងពេញផ្ទះទាំងមូល។ X អាចបដិសេធការទាមទារនេះបានព្រោះការកោសកកិតនោះនឹងមិនរំខានដល់ការប្រើប្រាស់ផ្ទះនោះទេ។

**ករណីទី 10:** X បានជួលផ្ទះឲ្យទៅ Y ក្នុងតម្លៃ$ 300 ក្នុងមួយខែ។ ថ្ងៃមួយបង្អួចផ្ទះមួយបានខូចដោយសារតែព្យុះទីហ្វុងធំមួយ។ ពេលដែល Y ទាមទារឲ្យ X ជួសជុលបង្អួចដែលខូចនោះ X ត្រូវជួសជុលបង្អួចដែលខូចនោះព្រោះការខូចខាតនេះបានបង្កឡើងដោយករណីប្រធានសក្តិ។

**ករណីទី 11:** X បានជួលផ្ទះឲ្យទៅ Y ក្នុងតម្លៃ $ 250 ក្នុងមួយខែ។ តម្លៃនេះមានកម្រិតទាបជាងតម្លៃទីផ្សារដោយសារពួកគេបានយល់ស្របគ្នាថាYនឹងទទួលខុសត្រូវជួសជុលការខូចខាតលើកលែងតែការជួសជុលណាដែលមានទំហំធំ។ 6ខែក្រោយមកសំណាញ់មូសក៏រហែកហើយម៉ាស៊ីនត្រជាក់បានខូចថែមទៀត។ ប្រសិនបើ Y តម្រូវឲ្យ X ជួសជុលការខូចខាតទាំងនេះ X អាចបដិសេធការទាមទារនេះដោយយោងតាមកិច្ចព្រមព្រៀងពិសេសរបស់ពួកគេ។

* ដោយសារ ប្រការ ដែលបានចែកក្នុងកិច្ចសន្យា "ការជួសជុលណាដែលមានទំហំធំ" មិនទាន់ច្បាស់លាស់នៅឡើយ នោះជាការប្រសើរជាងដែលបញ្ជាក់ឲ្យបានច្បាស់ក្នុងកិច្ចសន្យាពីទំហំនៃការជួសជុលនោះដែលត្រូវរ៉ាប់រងដោយ Y។ ឧទាហរណ៍ " Y ត្រូវទទួលខុសត្រូវចំពោះការផ្លាស់ប្តូរអំពូល អគ្គីសនី ជួសជុលសំណាញ់មូស ជួសជុលម៉ាស៊ីនត្រជាក់ ជួសជុលបង្អួចដែលខូច និងជួសជុលជញ្ជាំងកកិតស្នាមជាដើម ... "។

**ចំណុចបញ្ហាទី ២:** ប្រសិនបើការខូចខាតបង្កឡើងដោយកំហុស ឬសកម្មភាពដោយចេតនារបស់ ភតិកៈ តើភតិបតីនៅតែទទួលខុសត្រូវជួសជុលដែរឬទេ? ឧទាហរណ៍៖ X បានជួលរថយន្តមួយគ្រឿងឲ្យទៅ Y ដោយតម្លៃ 100 $ ក្នុងមួយខែ។ Y បានជួបគ្រោះថ្នាក់ចរាចរណ៍ដោយសារកំហុសរបស់ Y និងបានធ្វើឲ្យបែកកញ្ចក់រថយន្តនោះ។ Y បានទាមទារឲ្យ X ជួសជុលកញ្ចក់ដែលខូចនោះ។ តើ X អាចបដិសេធការជួសជុលដោយលើហេតុផលថាកញ្ចក់បានខូចដោយសារតែកំហុសរបស់ Y ដែរ ឬទេ?

ក្នុងអំឡុងពេលជួលបើទោះបីជាភតិកៈជាអ្នកអនុវត្តសិទ្ធិកាន់កាប់ និងអាស្រ័យផល លើវត្ថុជួលក៏ដោយ ក៏ភតិបតីអាចធ្វើសកម្មភាពចាំបាច់ដើម្បីថែរក្សាវត្ថុជួលបានដែរ ដូចជាការជួសជុលជាដើម។ ភតិកៈមិនអាចបដិសេធនឹងសកម្មភាពនេះបានឡើយ(មាត្រា៦០៣កថាខណ្ឌទី១នៃក.រ)។ លើកលែងតែការ

ជួសជុលនោះធ្វើអោយភតិកៈមិនអាចសម្រេចបាននូវគោលដៅភតិសន្យាក្នុងករណីនេះភតិកៈ អាចទាមទារអោយ រំលាយភតិសន្យាបាន ដូចជាករណីការជួសជុលនោះនឹងចំណាយពេលវេលាយូរដែលធ្វើអោយភតិកៈមិនអាចអនុវត្តសិទ្ធិជួលតាមឆន្ទៈរបស់ខ្លួនបាន ឬក្នុងករណីដែលគោលដៅនៃភតិសន្យាមិនត្រូវបានរារាំងទាំងស្រុងទេនោះភតិកៈអាចទាមទារអោយបន្ថយថ្លៃឈ្នួលបានដែរ (ក.រ៦០៣-២)។

**ករណីកិច្ចជូនដំណឹងរបស់ភតិកៈ**

ក្នុងអំឡុងពេលជួល ភតិកៈ ត្រូវមានករណីកិច្ចជូនដំណឹងដល់ភតិបតី ដោយមិនពន្យារពេល ក្នុងករណីដែលមានការចាំបាច់ត្រូវជួសជុលវត្ថុជួល ឬក្នុងករណីដែលមានតតិយជនណាមួយអះអាងអំពីសិទ្ធិពាក់ព័ន្ធនឹងវត្ថុជួលនោះ (ក.រ611)។ ការខកខានមិនជូនដំណឹង ដល់ភតិបតី អំពីបញ្ហាទាំងនេះហើយបណ្តាលអោយមានការខូចខាតកាន់តែអាក្រក់ទៅ ឬ ធ្ងន់ធ្ងរទៅកើតឡើងចំពោះវត្ថុជួល នោះភតិកៈត្រូវទទួលខុសត្រូវ ចំពោះសំណងនៃការខូចខាតទាំងនោះ លើកលែងតែភតិបតីបានដឹងអំពីបញ្ហានោះរួចហើយ។ ការកំណត់អំពីករណីកិច្ចរបស់ភតិកៈក្នុងការជូនដំណឹងនេះ ដើម្បីអាចអោយភតិបតីអាចចាត់វិធានការនានាទាន់ពេលវេលាដើម្បីជួសជុល ឬថែរក្សាវត្ថុជួលនោះ និងក៏ជាផលប្រយោជន៍របស់ភតិកៈផងដែរ ព្រោះបើវត្ថុជួលទទួលរងការខូចខាតធ្ងន់ធ្ងរខ្លាំង នោះនឹងបណ្តាលអោយភតិកៈមិនអាចអនុវត្តសិទ្ធិជួលតាមគោលបំណងរបស់ខ្លួន។

## ៤. សិទ្ធិទាមទារអោយសងវិញ នូវសោហ៊ុយរបស់ភតិកៈ

ភតិកៈមានសិទ្ធិទាមទារឲ្យសងមកវិញនូវសោហ៊ុយចាំបាច់ និង សោហ៊ុយដែល ចំណាយដើម្បីបង្កើនតម្លៃពីភតិបតីបាន។

នៅផ្នែកខាងលើ យើងបានដឹងរួចហើយថា ភតិបតីមានករណីកិច្ចធ្វើការជួសជុលវត្ថុជួលដែលមានការខូចខាត ឬ បែកបាក់ដែលចាំបាច់ ( មាត្រា ៦០២ នៃក្រមរដ្ឋ/ណី)។ ប៉ុន្តែ ក្នុងករណីចាំបាច់ ភតិកៈអាចជ្រើសរើសយកការជួសជុល ការខូចខាតដែលមានលក្ខណៈចាំបាច់ ទោះបីជាពុំមានការព្រមព្រៀងជាមុនពីភតិបតីក៏ដោយ ហើយភតិកៈក៏អាចទាមទារនូវប្រាក់ដែលបានចំណាយលើការជួសជុលពីភតិបតីមកវិញបានដែរ (មាត្រា ៦០៤ កថាខណ្ឌទី១ នៃក្រមរដ្ឋ/ណី)។ សោហ៊ុយហៅថា " សោហ៊ុយចាំបាច់"។ សោហ៊ុយចាំបាច់ គឺមិនមែនត្រឹមតែសោហ៊ុយ ជួសជុលក្នុងករណីដែលវត្ថុជួលនោះបានបាក់បែកប៉ុណ្ណោះទេ គឺរួមបញ្ចូលទាំងសោហ៊ុយដើម្បីថែរក្សា ករណីមានការព្រួយបារម្ភថាវត្ថុជួលនោះនឹងត្រូវបាក់បែក។

- ឧទាហរណ៍នៃសោហ៊ុយចាំបាច់៖ គឺជាចំណាយជួសជុលដែលចាំបាច់ និង ចំណាយ ថែរក្សាដែលចាំបាច់ មានដូចជា ការចាក់ដីបំពេញកន្លែងប្រហោងនៅលើដីជួលដើម្បីការពារទឹកជន់លិច ការធ្វើដំបូលផ្ទះអោយរឹងមាំ ដើម្បីកុំអោយលិចទឹកភ្លៀង ជាអាទ៏។

- សោហ៊ុយដែលចំណាយដើម្បីបង្កើនតម្លៃគឺ ជាសោហ៊ុយដែលចំណាយដើម្បីឲ្យវត្ថុជួលកើនឡើងនូវតម្លៃ។ លុះត្រាតែ នៅក្នុងករណីដែលកម្រិតនៃកំណើនតម្លៃនោះនៅតែមាន នាពេលបញ្ចប់ភតិសន្យាតែប៉ុណ្ណោះទេ ទើបភតិកៈអាចទាមទារឲ្យភតិបតីសងមកវិញបាន(ក្រមរដ្ឋ/ណីមាត្រា ៦០៤ កថាខណ្ឌទី២)។ ភតិបតីធ្វើការជ្រើសរើសនូវការសងណាមួយក្នុងចំណោម ២ នេះ ថាតើធ្វើការសងនូវប្រាក់ដែលភតិកៈបានចំណាយ ឬ ធ្វើការសងនូវកំណើននៃតម្លៃប្រាក់ដែលនៅតែមាន? ប៉ុន្តែ ជាទូទៅ ភតិបតីជ្រើសរើសនូវការសងណាដែលមានតម្លៃថោកជាង។ ឧទាហរណ៍នៃសោហ៊ុយដែលចំណាយដើម្បីបង្កើនតម្លៃ ៖ក្រាលកំរាលថ្មនៅលើដីជួល រុះរើផ្នែកខាងក្រៅនៃហាងដែលចាស់ចេញរួចជំនួសដោយការកែលំអរថ្មី និងស្អាត ការសាងសង់ប្រព័ន្ធបង្ហូរទឹកស្អុយ ជាដើម។
  ការចំណាយចំពោះសោហ៊ុយចាំបាច់ និង សោហ៊ុយដែលចំណាយដើម្បីបង្កើនតម្លៃខាងលើ គឺ ភតិកៈ មិនចាំបាច់សុំការយល់ព្រមពីភតិបតីជាមុននោះទេ។

| | សោហ៊ុយចាំបាច់ | សោហ៊ុយដែលចំណាយដើម្បីបង្កើនតម្លៃ |
|---|---|---|
| អត្ថន័យ | សោហ៊ុយដែលចំណាយដើម្បីជួសជុល និង ថែរក្សាវត្ថុជួល | សោហ៊ុយដែលចំណាយដើម្បីឲ្យវត្ថុជួលកើនឡើងនូវតម្លៃ |
| នៅពេលចំណាយសោហ៊ុយ តើមានភាពចាំបាច់ក្នុងការទទួលការយល់ព្រម និង ត្រូវជូនដំណឹងទៅភតិបតីដែរឬ ទេ? | មិនមាន | មិនមាន |
| ភាពចាំបាច់ដើម្បីទាមទារ | សោហ៊ុយចាំបាច់ដែលបានចំណាយ | ការចំណាយលើសោហ៊ុយដែលចំណាយដើម្បីបង្កើនតម្លៃ និងកម្រិតនៃកំណើន តម្លៃដែលនៅតែមាននាពេល បញ្ចប់ភតិសន្យា។ |
| ពេលដែលអាចទាមទារ | អាចទាមទារបាន "ភ្លាមៗ" នៅពេលដែលបានចំណាយ | អាចទាមទារបាន"នាពេលបញ្ចប់ភតិសន្យា"។ ប៉ុន្តែ ក្នុងករណីដែល |

| | | |
|---|---|---|
| | សោហ៊ុយចាំបាច់ | តុលាការ បានអនុញ្ញាតដោយកំណត់ អំឡុងពេលសមរម្យចំពោះភតិបតីដោយអាចទាមទារបាន ប្រសិនបើអំឡុងពេលដែលបានកំណត់នោះបានកន្លងផុត (មាត្រា ៦០៤ កថាខណ្ឌទី២នៃក.រ) |
| ប្រាក់ដែលអាចទាមទារ | ប្រាក់នៃសោហ៊ុយចាំបាច់ដែលបានចំណាយទាំងអស់ | ភតិបតីធ្វើការជ្រើសរើស មួយក្នុងចំណោមទាំងពីរនេះ គឺប្រាក់នៃសោហ៊ុយដែលបានចំណាយដើម្បីបង្កើនតម្លៃ ឬ ប្រាក់នៃកំណើនតម្លៃដែលនៅតែមាន |

- **សិទ្ធិឃាត់ទុកៈ**

  ប្រសិនបើភតិកៈ មានសិទ្ធិលើបំណុលលើសោហ៊ុយចាំបាច់ ឬសោហ៊ុយដែលចំណាយដើម្បីបង្កើនតម្លៃចាប់ពីពេលបញ្ចប់ភតិសន្យា នោះភតិកៈមានសិទ្ធិឃាត់ទុកវត្ថុជួល (មាត្រា ៧៧៤ នៃក.រ)។ ប៉ុន្តែ លើកលែងតែតុលាការបានអនុញ្ញាត ដោយកំណត់អំឡុងពេលសមរម្យដល់ភតិបតី ផ្អែកតាមការទាមទាររបស់ភតិបតី។

- **អំឡុងពេលអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាត និង ការទាមទារអោយសង សោហ៊ុយមកវិញៈ**

  ភតិបតី អាចទាមទារសំណងនៃការខូចខាត ដែលកើតមានឡើងចំពោះវត្ថុជួលនៅពេលប្រើប្រាស់ និង អាស្រ័យផល ក្នុងអំឡុងពេលជួលពីភតិកៈ ដែលបានអនុវត្តផ្ទុយពីអត្ថន័យនៃភតិសន្យា។ ភតិកៈ ក៏អាចទាមទារអោយសងមកវិញនូវសោហ៊ុយចាំបាច់ដែលខ្លួនបានចំណាយពីភតិបតីមកវិញបានដែរ។ ការអនុវត្តសិទ្ធិទាមទារនេះ គឺមាន រយៈពេល ១ឆ្នាំ គិតពីពេលដែលភតិបតីបានទទួលវត្ថុជួលមកវិញ។ ករណី ភតិបតី ឬ ភតិកៈ មិនធ្វើការទាមទារក្នុងអំឡុងពេលនេះទេ នោះចាត់ទុកថាបានបោះបង់សិទ្ធិទាមទារ។ អំឡុងពេលនេះពុំមែនជាអំឡុងពេលសម្រាប់ការដាក់ពាក្យបណ្តឹងទៅតុលាការទេ ពោលគឺ ប្រសិនបើភាគីម្ខាងនៃភតិសន្យាបានជូនដំណឹង អំពីឆន្ទៈអនុវត្តសិទ្ធិទាមទារតាមក្រៅផ្លូវតុលាការក្នុងអំឡុងពេល ១ឆ្នាំ នោះវាជាការគ្រប់គ្រាន់ហើយនិងមិនធ្វើអោយរលត់សិទ្ធិទាមទារទេ (មាត្រា៦២១ នៃក.រ។

## ៥. អំពីថ្លៃឈ្នួល:

- ករណីកិច្ចបង់ថ្លៃឈ្នួល:
- ភតិក: មានករណីកិច្ចបង់ថ្លៃឈ្នួល ទៅឲ្យភតិបតី ទៅតាមពេលវេលាដែលបានកំណត់តាមការព្រមព្រៀងនៃភតិសន្យា (មាត្រា ៦១០ កថាខណ្ឌទី១ នៃ ក.រ)។ ភតិក: និងភតិបតីអាចកំណត់ពេលវេលាក្នុងការបង់ផ្អែកតាមការព្រមព្រៀង ដូច្នេះ ទោះបីជា ព្រមព្រៀងបង់ប្រាក់នៅរៀងរាល់ដើមខែ ឬនៅរៀងរាល់ចុងខែក៏ដោយ ក៏គ្មានបញ្ហាអ្វីដែរ។ ភាគីក៏អាចព្រមព្រៀងគ្នាកំណត់អំពីរបៀបនៃការបង់ប្រាក់ឈ្នួលដែរ ដូចជាធ្វើការបង់តាមរយៈធនាគារ ឬ ការកំណត់ទីតាំងប្រគល់ថ្លៃឈ្នួលជាអាទិ៍ផងដែរ។
- ក្នុងករណីដែលមិនបានកំណត់ជាពិសេស នៅក្នុងកិច្ចសន្យាអំពីពេលវេលាដែលត្រូវបង់ថ្លៃឈ្នួលទេ ផ្អែកតាមក្រមរដ្ឋប្បវេណីកម្ពុជា រាប់ចាប់ពីពេលប្រើប្រាស់ ឬ អាស្រ័យផលមកត្រូវបង់ប្រាក់ឈ្នួលដូចដែលបានកំណត់ខាងក្រោម៖
    - ចំពោះវត្ថុជួលដែលជាចលនវត្ថុ ភតិក:ត្រូវបង់ប្រាក់ឈ្នួលរៀងរាល់ចុងខែ។
    - ចំពោះវត្ថុជួលដែលជាអចលនវត្ថុដូចជា ផ្ទះ ឬ អាគារ ភតិក: ត្រូវបង់ថ្លៃឈ្នួលរៀងរាល់ចុងខែ។
    - ចំពោះវត្ថុជួលជាអចលនវត្ថុដូចជាដីធ្លី ភតិក: ត្រូវបង់ថ្លៃឈ្នួលរៀងរាល់ចុងឆ្នាំ។
    - ចំពោះវត្ថុជួលដែលមានរដូវប្រមូលផល ភតិក: ត្រូវបង់ថ្លៃឈ្នួលនៅក្រោយពេលរដូវប្រមូលផលនោះកន្លងផុត ដោយគ្មានការយឺតយ៉ាវ។

**សំនួរសិក្សាទី១២**:

X បានបង្កើតកិច្ចសន្យាជួលផ្ទះសម្រាប់ស្នាក់នៅអោយទៅ Y ក្នុងរយៈពេល ៥ ឆ្នាំ។ កិច្ចសន្យាបានធ្វើនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥។ ពួកគេបានកំណត់ថ្លៃឈ្នួលចំនួន ៥០០ដុល្លារក្នុងមួយខែ។ ប៉ុន្តែ មិនបានកំណត់ពេលវេលាជាក់លាក់អំពីការបង់ប្រាក់ឈ្នួលនោះទេ។ X បានប្រគល់ផ្ទះអោយ Y នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥។ X បានទាមទារអោយ Y បង់ប្រាក់ឈ្នួលសម្រាប់ខែទី១ នៅពេលថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៥ បានមកដល់ តែ Y បានបដិសេធ។ ក្នុងករណីនេះ តើ Y ត្រូវបង់នៅពេលណា?

- ការទាមទារអោយបន្ថយថ្លៃឈ្នួលៈ
- សិទ្ធិរំលាយ និង សិទ្ធិទាមទារអោយបន្ថយថ្លៃឈ្នួលដោយសារចំណូលថយចុះក្នុងអំឡុងពេលជួល ប្រសិនបើភតិកៈនៃដីដែលមានគោលបំណងអាស្រ័យពីដី ទទួលផលតិចជាងថ្លៃឈ្នួល ដោយសារករណីប្រធានសក្តិ ភតិកៈអាចទាមទារអោយបន្ថយថ្លៃឈ្នួលរហូតដល់ត្រឹមចំនួនទឹកប្រាក់នៃការអាស្រ័យផលនោះបាន។ ស្ថានភាពដែលអាចទាមទារអោយបន្ថយថ្លៃនោះមានដូចជា ដីកសិកម្ម ដីស្រែ ចំការដំណាំ ជា ដើម។ ប៉ុន្តែ ករណីនេះមិនអនុវត្តគ្រប់ករណីទាំងអស់នោះទេ ដូចជាការជួលផ្ទះល្វែង ដីសម្រាប់រោងចក្រផលិតទំនិញ ដីសម្រាប់ទីលានវាយកូនហ្គោល មិនមែនជាកម្មវត្ថុសម្រាប់ការទាមទារអោយបន្ថយថ្លៃឈ្នួលនោះទេ។ ដោយហេតុថា ការលក់ទំនិញដែលផលិតដោយរោងចក្រមិនបានចំណេញមិនមែនជាផលពីដីទេ។ ករណីទាមទារអោយបន្ថយថ្លៃខាងលើមិនសូវជាកើតឡើងប៉ុន្មានទេ នឹងច្រើនតែកើតឡើងចំពោះការជួលដីធ្វើស្រែចំការជាដើម ដែលផលទទួលបានពីការដាំដុះនោះអាចទទួលបានទិន្នផលតិចដោយសារកត្តាប្រធានសក្តិ គ្រោះធម្មជាតិ ជាដើម (មាត្រា ៦០៦ កថាខណ្ឌទី ១ នៃ ក.រ)។ ក្នុងករណីនេះ អាស្រ័យផលមានន័យថា គឺប្រាក់កាត់បន្ថយនៃសោហ៊ុយចាំបាច់ដែលបានមកពីដំណាំ។ សោហ៊ុយចាំបាច់នេះ សោហ៊ុយក្នុងការចំណាយលើកំលាំងពលកម្ម ការថែទាំដំណាំ ចំណាយលើការទិញដី ទិញថ្នាំសម្លាប់សត្វល្អិត ការបង់ពន្ធជាដើម។ ចំណែកឯ ប្រធានសក្តិ សំដៅដល់គ្រោះធម្មជាតិនានាដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ភាពចង្រៃនៃសត្វល្អិត ជាដើម។ ប្រសិនបើការទទួលបានផលតិចជាងថ្លៃឈ្នួលចេះតែអូសបន្លាយរហូតដល់ ២ ឆ្នាំជាប់ៗគ្នា ឬ ច្រើនជាងនេះ ដោយសារករណីប្រធានសក្តិ នោះភតិកៈអាចរំលាយភតិសន្យាបាន (មាត្រា ៦០៦ កថាខណ្ឌទី២ នៃក.រ)។
- សិទ្ធិរំលាយ និងសិទ្ធិទាមទារអោយបន្ថយថ្លៃឈ្នួលដោយសារការបាត់បង់ ឬវិនាសវត្ថុជួលបើវត្ថុជួលមួយភាគត្រូវបានបាត់បង់ ឬវិនាសដោយមិនមែនជាកំហុសរបស់ភតិកៈទេ ភតិកៈអាចទាមទារអោយបន្ថយថ្លៃឈ្នួលទៅតាមសមាមាត្រនៃភាគដែលត្រូវបាត់បង់ ឬវិនាសនោះ (មាត្រា៦០៧ កថាខណ្ឌទី១ នៃក.រ)។

**សំគាល់៖** នៅប្រទេសជប៉ុនវិញភាគច្រើនគឺបកស្រាយថា នៅពេលមានការទាមទារអោយបន្ថយថ្លៃឈ្នួល នោះថ្លៃឈ្នួលត្រូវបន្ថយដោយប្រតិសកម្ម គឺគណនាចាប់ពីពេលដែលវត្ថុនោះបាត់បង់មួយភាគ។ លើសពីនេះ បើភតិកៈពុំអាចសម្រេចគោលបំណងដែលបានធ្វើកិច្ចសន្យាជួល ទៅលើភាគដែលនៅសេសសល់នោះទេ ភតិកៈអាចរំលាយភតិសន្យាបាន (មាត្រា ៦០៧ កថាខណ្ឌទី២ នៃ ក្រមរដ្ឋ/ណី)។ យ៉ាងណាមិញ ប្រសិនបើ ការបាត់បង់ ឬវិនាសមួយផ្នែកអាចធ្វើការជួសជុលបាននោះភតិកៈអាចទាមទារឲ្យភតិបតីជួសជុលបាន (មាត្រា៦០២ នៃក.រ)។ ម្យ៉ាងទៀត ប្រសិនបើ ភតិកៈជាអ្នកជួសជុលដោយផ្ទាល់ ភតិកៈក៏អាចទាមទារឲ្យសងមកវិញនូវសោហ៊ុយចាំបាច់ពីភតិបតីបានដែរ (ក.រ មាត្រា ៦០៤ កថាខណ្ឌទី ១)។

ក្នុងករណីដែលវត្ថុជួលត្រូវបានបាត់បង់ ឬវិនាសមួយផ្នែក ឬត្រូវបានបាត់បង់ ឬវិនាសទាំងស្រុង ប្រសិនបើធ្វើការសរុបនូវទំនាក់ទំនងគតិយុត្តគឺមានដូចខាងក្រោមនេះ៖

| | បាត់បង់ ឬ វិនាសមួយផ្នែក | បាត់បង់ ឬ វិនាសទាំងស្រុង |
|---|---|---|
| ក្នុងករណីដែលភតិបតី និង ភតិកៈពុំមានកំហុសទាំងសងខាង | - ភតិកៈអាចទាមទារឲ្យបន្ថយថ្លៃឈ្នួលពីភតិបតីបាន (ក.រ៦០៧កថាខណ្ឌ១)។ ម្យ៉ាងទៀត បើភតិកៈពុំអាចសម្រេចគោលបំណងដែលបានធ្វើកិច្ចសន្យាជួលទៅលើភាគដែលនៅសេសសល់នោះទេ ភតិកៈអាចរំលាយភតិសន្យាបាន(ម.៦០៧កថាខណ្ឌទី២ នៃ ក.រ)។<br>- ប្រសិនបើ ការបាត់បង់ ឬ វិនាសមួយ ផ្នែកអាចធ្វើការជួសជុលបាន នោះ ភតិកៈអាចទាមទារឲ្យភតិបតីជួសជុលបាន (មាត្រា ៦០២ នៃក.រ)។ ឬ ប្រសិនបើ ភតិកៈ ជាអ្នកជួសជុលដោយផ្ទាល់ភតិកៈក៏អាចទាមទារឲ្យសងមកវិញនូវសោហ៊ុយចាំបាច់ពីភតិបតីបានដែរ (មាត្រា ៦០៤ កថាខណ្ឌ១) | - ករណីជាក់ស្តែងនៅប្រទេសជប៉ុនបានមកស្រាយថាភតិសន្យាត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ ដោយសារ អលទ្ធភាពក្នុងការសម្រេចគោលបំណង។ ការបកស្រាយបែបនេះមិនមានមាត្រាចែងទេ ប៉ុន្តែ ដោយសារតែការដែលបន្ត ភតិសន្យានៃនត្ថិភាពវត្ថុជួលវាមានលក្ខណៈមិនធម្មតានោះទេ។ ទើបធ្វើការបកស្រាយបែបនេះ។ |
| ក្នុងករណីដែលភតិបតីមានកំហុស | - ដូចខាងលើ<br>- ភតិកៈអាចទាមទារសំណងការ ខូចខាតផ្អែកតាមការមិនអនុវត្តកាតព្វកិច្ចពីភតិបតីបាន(ក.រម. ៣៩៨) | - ដូចខាងលើភតិកៈអាចទាមទារសំណងការខូច ខាតផ្អែកតាមការមិនអនុវត្តកាតព្វកិច្ចពីភតិបតីបាន (ក្រម.រ/ណីម.៣៩៨) |
| ក្នុងករណីដែលភតិកៈមានកំហុស | - ភតិកៈមិនអាចទាមទារឲ្យបន្ថយថ្លៃឈ្នួលពីភតិបតីបានទេ ហើយក៏មិនអាចរំលាយកិច្ចសន្យាបានដែរ។ ហេតុដូច្នេះ ភតិកៈនឹងបន្តការប្រើប្រាស់វត្ថុជួលដែលបានបាត់បង់មួយផ្នែកនោះ។<br>- ក្នុងករណីដែលអាចជួសជុលការវិនាស ឬបាត់បង់នោះបាន តើភតិកៈអាចទាមទារ | - មូលហេតុដូចខាងលើដែរ ការអនុវត្តជាក់ស្តែងនៅប្រទេសជប៉ុនត្រូវបានបកស្រាយថា ភតិសន្យាត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ។<br>- ភតិបតីអាចទាមទារសំណងការខូចខាតផ្អែកតាមការមិនអនុវត្តកាតព្វកិច្ចពីភតិកៈបាន (ក្រម.រ/ |

| | | |
|---|---|---|
| | ឲ្យភតិបតីជួសជុលបានដែរឬទេ? (ក្រម.រ/ណីម.៦០២)។ យោងតាមបណ្តឹង ២ ខាងលើ។<br>ភតិបតីអាចទាមទារការខូចខាត ផ្អែកតាមការមិនអនុវត្តកាតព្វកិច្ចពីភតិកបាន (ក្រម.រ/ណី ម.៣៩៨)។ | ណី ម.៣៩៨)។ |

## ៦. ភារទទួលខុសត្រូវក្នុងការធានាវិការៈ

មាត្រា ៦០៥ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិពិសេសនៃការទទួលខុសត្រូវដែលអនុវត្តចំពោះភតិសន្យា ដែលតម្រូវអោយភតិបតីត្រូវប្រគល់វត្ថុជួលដែលល្អ ដែលអាចធ្វើអោយសម្រេចបាននូវគោលបំណងនៃការជួល ហេតុនេះ ភតិបតីត្រូវធានា និង ទទួលខុសត្រូវចំពោះវត្ថុជួលនៅពេលមានវិការៈកើតឡើងចំពោះវត្ថុជួល រីឯ ភតិកៈ ក៏ត្រូវតម្រូវអោយត្រួតពិនិត្យនូវវត្ថុដែលខ្លួនជួលផងដែរ។ ការទទួលខុសត្រូវរបស់ភតិបតីមានដូចខាងក្រោម៖

**សិទ្ធិរបស់ភតិកៈ**

1) ប្រសិនបើភតិបតី ប្រគល់វត្ថុជួលដែលមានវិការៈកំបាំងអោយទៅភតិកៈដែលធ្វើឲ្យ មិនអាចសម្រេចបាននូវគោលបំណងដែលបានធ្វើកិច្ចសន្យា នោះភតិកៈអាចទាមទាររំលាយកិច្ចសន្យាបាន (មាត្រា ៦០៥ កថាខណ្ឌទី៥ នៃក.រ)។ ឧទាហរណ៍៖ ក្នុងករណីជួលរថយន្តដែលម៉ាស៊ីនមានវិការៈ ដោយសារតែ ភតិកៈមិនអាចដឹកភ្ញៀវឲ្យទាន់ពេលវេលាទៅព្រលានយន្តហោះ ដូច្នេះ ទោះបីជាភតិបតីជួលជុលក៏ដោយ ក៏ភតិកៈអាចរំលាយភតិសន្យាបានដែរ។

2) ក្នុងករណីដែលអាចសម្រេចគោលបំណងនៃកិច្ចសន្យា ទោះបីជាវត្ថុជួលមានវិការៈ នោះភតិកៈអាចជ្រើសរើសវិធីបាន២។ វិធីទី១ គឺជាវិធីដែលភតិកៈ ទាមទារឲ្យភតិបតីជួសជុលវិការៈ ឬឲ្យដូរវត្ថុដែលគ្មានវិការៈនោះ។ ក្នុងករណីនេះ ដោយសារតែភតិកៈអាចប្រើប្រាស់វត្ថុជួលដែលគ្មានវិការៈ ហេតុនេះ ប្រាក់ថ្លៃឈ្នួលគឺរក្សាទុកដដែល។ ប៉ុន្តែចំពោះការទទួលបាននូវការបាត់បង់ផលប្រយោជន៍ត្រឹមការអនុវត្ត ការជួសជុល ឬការដូរ ភតិកៈអាចទាមទារសំណងការខូចខាតពីភតិបតីបាន (ក.រ មាត្រា.៦០៥ កថាខណ្ឌ២)។ វិធីទី២ គឺជាវិធីដែលភតិកៈបន្តការប្រើប្រាស់វត្ថុជួលនោះដដែល។ ក្នុងករណីនេះ ដោយសារតែ ភតិកៈបន្តការប្រើប្រាស់វត្ថុជួលដែលមានវិការៈ ដូច្នេះ ភតិកៈអាចទាមទារឲ្យបន្ថយថ្លៃឈ្នួលដោយគិតតាំងពីពេលដែលបានប្រគល់ (ក.រ មាត្រា ៦០៥ កថា ៤)។

**សិទ្ធិជួលជុលរបស់ភតិបតី**

ភតិបតីអាចជួសជុលវិការៈដោយសោហ៊ុយខ្លួនបានលុះត្រាតែមិនធ្វើឲ្យមានការខូចខាតដោយមិនត្រឹមត្រូវនូវផលប្រយោជន៍របស់ភតិកៈ (មាត្រា ៦០៥ កថាខណ្ឌទី៣នៃក.រ)។ ក្នុងករណីដែលភតិបតីបានជួសជុលរួចរាល់ហើយ ភតិកៈមិនអាចទាមទារឲ្យដូរវត្ថុដែលគ្មានវិការៈ និងមិនអាចទាមទារឲ្យបន្ថយថ្លៃឈ្នួលព្រមទាំងមិនអាចរំលាយភតិសន្យាបានទេ។ ប៉ុន្តែប្រសិនបើកើតមានឡើងនៅការខូចខាត នោះភតិកៈអាចទាមទារសំណងការខូចខាតបាន (ក.រ មាត្រា ៦០៥ កថាខណ្ឌ៣)។

**កម្រិតនៃការអនុវត្តសិទ្ធិរបស់ភតិកៈ**

ការទាមទារឲ្យជួសជុល ឲ្យដូរ ឲ្យបន្ថយថ្លៃឈ្នួល និងការរំលាយ ត្រូវអនុវត្តនៅ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលភតិកៈបានដឹង ឬពេល ដែលត្រូវដឹងអំពីហេតុនោះបាន (ក.រ មាត្រា ៦០៥ កថាខណ្ឌ៦)។

ម្យ៉ាងទៀត ប្រសិនបើ ភតិកៈមិនបានពិនិត្យស្ថានភាពនៃវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាថាត្រឹមត្រូវតាមស្ថានភាពដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យានៅពេលទទួលការប្រគល់វត្ថុដែលជាវត្ថុនោះ ភតិកៈមិនអាចទាមទារឲ្យភតិបតីទទួលខុសត្រូវបានឡើយចំពោះភាពខុសពីស្ថានភាពដែលបានកំណត់នៅក្នុងលិខិតកិច្ច សន្យា ដែលខ្លួនអាចដឹងដោយងាយស្រួលបើពិនិត្យ (ក.រមាត្រា ៦០៥ កថាខណ្ឌ១)។

ឧទាហរណ៍៖ ក្រោយការប្រគល់ផ្ទះដែលជាកម្មវត្ថុនៃកិច្ចសន្យាជួល ភតិកៈមិនបានយកចិត្តទុកដាក់ពិនិត្យមើលការ៉ូនៅក្នុងផ្ទះដែលបានប្រេះ និង ប្រលាក់ខ្លាំង ហេតុនេះ ក្រោយការប្រគល់ផ្ទះ ភតិកៈមិនអាចទាមទារអោយភតិបតីដូរការ៉ូ ដែលប្រេះ ឬ ប្រលាក់ខ្លាំងនោះបានទេ។

## ជំពូក ៣. អនុប្បទានសិទ្ធិជួល និងការជួលបន្តនូវវត្ថុជួល

ភតិកៈពុំអាចធ្វើអនុប្បទាន សិទ្ធិជួល ឬជួលបន្តនូវវត្ថុជួលបានឡើយ បើគ្មានការយល់ព្រមពីភតិបតីទេ លើកលែងតែករណីនៃសិទ្ធិជួលអចិន្ត្រៃយ៍ (មាត្រា ៦០៨ កថាខណ្ឌទី១)។

### ១. អនុប្បទានសិទ្ធិជួល និងការជួលបន្តនូវវត្ថុជួលដោយមានការយល់ព្រមពីភតិបតី

- **អនុប្បទានសិទ្ធិជួល**
- អត្ថន័យនៃអនុប្បទានសិទ្ធិជួលគឺថាភតិកៈ ធ្វើអនុប្បទានឋានៈរបស់ខ្លួនជាភតិកៈឲ្យតតិយជនផ្សេងទៀតក្រៅពីខ្លួន ដើម្បីបន្តឋានៈជាភតិកៈថ្មីជំនួសឋានៈរបស់ខ្លួនដែលជាភតិកៈមុន ហើយភតិកៈថ្មីទទួលខុសត្រូវផ្ទាល់ចំពោះភតិបតី។ ករណីនេះត្រូវមានការយល់ព្រមពីភតិបតីជាមុនសិន ។

ឧទាហរណ៍៖X បានជួលដីមួយកន្លែងឲ្យទៅ Y ។ Y បានធ្វើអប្បទានសិទ្ធិជួលអោយទៅ Z។

ក្នុងករណីនេះ Y បានចេញពីទំនាក់ទំនងជួល ហើយ Z បានក្លាយជាភតិកៈវិញ។

- **ការជួលបន្តនូវវត្ថុជួល**

អត្ថន័យនៃការជួលបន្តគឺ ភតិកៈ ជួលនូវវត្ថុជួលឲ្យទៅតតិយជន។ ករណីជួលនូវវត្ថុជួលទៅឲ្យតតិយជនភតិកៈដើមទទួលឋានៈជាភតិបតីបន្ត និងតតិយជនក្លាយជាភតិកៈបន្ត។ ក្នុងករណីនេះ តម្រូវឲ្យមានការយល់ព្រមជាមុនពីភតិបតី។

ភតិបតីបន្ត និង ភតិកៈបន្ត ត្រូវមានសិទ្ធិ និង កាតព្វកិច្ចដូចគ្នាទៅនឹងសិទ្ធិ ព្រមទាំងកាតព្វកិច្ចរវាងភតិបតី និងភតិកៈដែរ។ លើសពីនេះទៀត ភតិកៈបន្តត្រូវមានករណីយកិច្ចដោយផ្ទាល់ចំពោះភតិបតី (មាត្រា៦០៩ កថាខណ្ឌ១ នៃក.រ។ ចំពោះករណីយកិច្ចបង់ថ្លៃឈ្នួលបន្ត ភតិកៈបន្តពុំអាចយកការបង់ថ្លៃជាមុនទៅឲ្យភតិកៈ មកតតាំងជាមួយភតិបតីបានឡើយ។ ទោះបីជាភតិកៈបន្តត្រូវមានករណីយកិច្ចដោយផ្ទាល់ចំពោះភតិបតីក៏ដោយ ក៏មិនរាំងដល់ការអនុវត្តសិទ្ធិរបស់ភតិបតីចំពោះភតិកៈឡើយ (មាត្រា ៦០៩ កថាខណ្ឌទី ២ នៃក.រ)។ មានន័យថា ភតិបតីនៅមានសិទ្ធិចំពោះភតិកៈដដែល។

ឧទាហរណ៍៖X បានជួលដីមួយកន្លែងឲ្យទៅ Y។ Y បានជួលបន្តនូវដីនោះអោយទៅ Z។ ក្នុងករណីនេះ Y នៅតែជាភតិកៈ ហើយ Z បានក្លាយជាភតិកៈបន្ត ហើយ Y នៅមានករណីយកិច្ចចំពោះXផងដែរ។

**ចំណាំ៖**

១. ចំពោះការយល់ព្រម ភតិបតីអាចផ្តល់ចំពោះ ភតិកៈ អនុប្បទានិកនៃសិទ្ធិជួល ឬ ភតិកៈបន្ត (SCJ)។

២. នៅពេលដែលការយល់ព្រមត្រូវបានផ្តល់ ភតិបតីមិនអាចដកការយល់ព្រមនេះវិញបានទេ

## ២. អនុប្បទានសិទ្ធិជួល និងការជួលបន្តនូវវត្ថុជួលដោយពុំមានការយល់ព្រមពីភតិបតី

ទោះជាអនុប្បទានសិទ្ធិជួល និងការជួលបន្តនូវវត្ថុជួលដោយពុំមានការយល់ព្រមពីភតិបតីក៏ដោយ ក៏កិច្ចសន្យារវាងភតិកៈ ជាមួយ**ភតិកៈបន្ត** ឬ **អនុប្បទានិក**នៃសិទ្ធិជួលនោះនៅមានសុពលភាពដែរ។ ដូច្នេះ **អនុប្បទានិកនៃសិទ្ធិជួល** ឬ **ភតិកៈបន្ត** ត្រូវបង់ប្រាក់ថ្លៃឈ្នួលទៅអោយ**ភតិកៈ** ហើយ**ភតិកៈ**ត្រូវមានកាតព្វកិច្ចសុំការយល់ព្រមពី**ភតិបតី**។

ឧទាហរណ៍៖X បានជួលដីមួយកន្លែងឲ្យទៅ Y។ Y បានអនុប្បទានសិទ្ធិជួលដីនេះ ឬ ជួលបន្តឲ្យទៅ Z ដោយមិនមានការយល់ព្រមពី X។ ក្នុងករណីនេះ ទោះបីជាមិនមានការយល់ព្រមពី X ក៏ដោយ ក៏កិច្ចសន្យារវាង Y និង Z នៅតែមានសុពលភាព។ ដូច្នេះ Y ទទួលនូវកាតព្វកិច្ចសុំការយល់ព្រមពី X។ Z ទទួលកាតព្វកិច្ចបង់ប្រាក់ថ្លៃឈ្នួលអោយទៅ Y។

**ទំនាក់ទំនងរវាង X នឹង Y ៖**

ឧទាហរណ៍ខាងលើ ដែលជាទំនាក់ទំនងរវាង X និង Y មានគំនិត៣ ដែល អាចធ្វើបាន៖

១- X រំលាយភតិសន្យាដោយផ្អែកតាមមាត្រា ៦០៨ (កថាខណ្ឌទី ២ ) នៃ ក.រ។

២- X យល់ព្រមចំពោះ អនុប្បទានសិទ្ធិជួល ឬ ការជួលបន្ត។ ក្នុងករណីនេះ អនុប្បទានសិទ្ធិជួល ឬ ការជួលបន្តក្លាយជាមានសុពលភាព និងអាចអះអាងចំពោះ X បាន។

៣- X ធ្វើមិនដឹងមិនលឺ ឬ មិនខ្វល់ចំពោះ អនុប្បទានសិទ្ធិជួល ឬ ការជួលបន្ត។ ក្នុងករណីនេះ X នៅតែជាភតិបតី Y នៅតែជាភតិកៈ ហើយ Z មិនអាចអះអាងអំពីសិទ្ធិណាមួយចំពោះ X បានទេ។

**ទំនាក់ទំនងរវាង X នឹង Z ៖**

Z មិនអាចអះអាងមានសិទ្ធិកាន់កាប់ដីនោះទេ លុះត្រាតែមានការអនុញ្ញាតពី X។ ដូចនេះ X អាចទាមទារឱ្យ Z ប្រគល់ដីវិញបានដោយផ្អែកលើកម្មសិទ្ធិ (មាត្រា ១៥៥ នៃក.រ)។ ម្យ៉ាងទៀត X អាចទាមទារការបង់ប្រាក់ដែលមានចំនួនស្មើនឹងថ្លៃឈ្នួលបាន ដោយផ្អែកតាមសេចក្តីចម្រើនដោយឥតហេតុ (មាត្រា ៧៣៦ និង ៧៣៧ នៃ ក.រ)។

**ចំណុចបញ្ហាទី៣៖ ទ្រឹស្តីនៃការរំលោភលើសេចក្តីទុកចិត្ត**

SCJ បានបង្កើតទ្រឹស្តីនៃការរំលោភលើសេចក្តីទុកចិត្ត។ SCJ បានលើកឡើងថា ទោះបីជាភតិកៈអនុញ្ញាតឲ្យតតិយជនប្រើប្រាស់ និងអាស្រ័យផលលើវត្ថុជួលក៏ដោយ ក៏ភតិបតីមិនអាចបញ្ចប់ភតិសន្យាបានដែរ ប្រសិនបើមានស្ថានភាពពិសេសដែលចាត់ទុកសកម្មភាពរបស់ភតិកៈថាមិនរំលោភលើសេចក្តីទុកចិត្តរបស់ភតិបតី។ ការអនុវត្តទ្រឹស្តីនេះចំពោះប្រទេសកម្ពុជាគឺអាស្រ័យលើការអនុវត្តរបស់ប្រទេសកម្ពុជានាពេលអនាគត។

តាមទ្រឹស្តីរំលោភលើសេចក្តីទុកចិត្តរបស់ប្រទេសជប៉ុនចំពោះករណីអនុប្បទានសិទ្ធិជួល ឬ ការជួលបន្តខាងក្រោមនេះ មិនរំលោភលើសេចក្តីទុកចិត្តរបស់ភតិបតីនោះទេ ហើយដូច្នេះភតិបតីមិនអាចបញ្ចប់ភតិសន្យាបានទេ។

- ភតិកៈជាសាជីវកម្មចាស់មួយហើយសិទ្ធិជួលត្រូវបានផ្ទេរឲ្យសាជីវកម្មថ្មី។ ម្ចាស់សាជីវកម្មទាំងពីរនេះគឺជាមនុស្សតែម្នាក់ហើយរាល់ទ្រព្យសម្បត្តិរបស់សាជីវកម្មចាស់ត្រូវបានទទួលបន្តដោយសាជីវកម្មថ្មី មានន័យថាសាជីវកម្មទាំងពីរ ជាក់ស្តែងជាអង្គភាពតែមួយ។

- ភតិកៈបានជួលបន្តនូវបន្ទប់ជួលរបស់គាត់សម្រាប់រយៈពេលខ្លីទៅអោយមិត្តិភក្តិរបស់គាត់ក្នុងអំឡុងពេលដែលគាត់ទៅបរទេស ហើយមិត្តភក្តិនោះបានស្នាក់នៅក្នុងបន្ទប់ជួលនោះមួយរយៈខ្លីណាមួយ។

- ក្នុងករណីជួលផ្ទះទាំងមូល មានតែបន្ទប់មួយប៉ុណ្ណោះត្រូវបានជួលបន្ត ហើយមិនមានការផ្លាស់ប្តូរច្រើនទេចំពោះការប្រើប្រាស់ផ្ទះជួល។

* ទោះបីជាទ្រឹស្តីនៃការរំលោភលើសេចក្តីទុកចិត្តត្រូវបានយកមកអនុវត្តក្នុងប្រទេសកម្ពុជា ឬ អត់នោះ វាក៏អាចមានការរារាំងនូវការបញ្ចប់ភតិសន្យាដោយភតិបតី ដោយសារគោលការណ៍នៃការប្រើប្រាស់សិទ្ធិដោយបំពាន (មាត្រា ៤ នៃក.រ)។ ចំណុចនេះគឺចង់បានន័យថា ប្រសិនបើអនុប្បទានសិទ្ធិជួល ឬការជួលបន្តមិនបង្កការរំខានណាមួយដល់ភតិបតីទេ នោះការអនុវត្តសិទ្ធិបញ្ចប់ភតិសន្យារបស់ភតិបតីអាចនឹងត្រូវបានរារាំងដោយគោលការណ៍នៃការប្រើប្រាស់សិទ្ធិដោយបំពាន។

- **ទំនាក់ទំនងកិច្ចសន្យារវាងភតិបតី និងភតិកៈបន្តៈ**

  ពុំមានទំនាក់ទំនងកិច្ចសន្យារវាងភតិបតី និងភតិកៈបន្តទេ។ ប៉ុន្តែមាត្រា៦០៩នៃក.រ ជាពិសេសអនុញ្ញាតឲ្យភតិបតី អនុវត្តសិទ្ធិចំពោះភតិកៈបន្តដើម្បីការពារផលប្រយោជន៍របស់ភតិបតី។

- **ថ្លៃឈ្នួលៈ**

  ភតិបតីអាចទាមទារថ្លៃឈ្នួលពីភតិកៈក៏បាន (មាត្រា ៦០៩កថាខណ្ឌទី២នៃក.រ) ឬពីភតិកៈបន្តក៏បាន( មាត្រ៦០៩កថាខណ្ឌទី១នៃក.រ)។ ជាក់ស្តែង ជាធម្មតាភតិបតីទាមទារពីភតិកៈ ហើយក្នុងករណីដែលភតិកៈអលទ្ធភាពក្នុងការបង់ថ្លៃឈ្នួល នោះភតិបតីអាចទាមទារពី**ភតិកៈបន្ត**។ ចំនួនដែល ភតិបតីអាចទាមទារពី**ភតិកៈបន្ត**បាន គឺថ្លៃឈ្នួលនៃការជួលដើម(ថ្លៃឈ្នួលដែលភតិបតីបានព្រមព្រៀងជាមួយភតិកៈ) ឬ ថ្លៃឈ្នួលនៃការជួលបន្ត មួយណាដែលមានចំនួនទាបជាង។

- **ការបង់ថ្លៃជាមុនទៅឲ្យភតិកៈៈ**

ការបង់ថ្លៃជាមុនទៅឲ្យភតិកៈ មានន័យថា **ភតិកៈបន្ត**បានបង់ប្រាក់ថ្លៃឈ្នួលទៅឲ្យភតិកៈមុនពេលដែលកាលកំណត់ត្រូវបង់ប្រាក់ថ្លៃឈ្នួលនៃភតិសន្យាជួលបន្តមកដល់ ដូច្នេះការបង់ប្រាក់ជាមុននេះ មិនអាចអះអាងចំពោះភតិបតីបានទេ ។

ករណីបែបនេះ**ភតិកៈបន្ត**ត្រូវបង់ប្រាក់ថ្លៃឈ្នួលដែលស្មើតម្លៃឈ្នួលរបស់ភតិកៈ ឬទាបជា (ករណីភតិសន្យាបន្តមានថ្លៃទាបជាង) ទៅឲ្យភតិបតីតាមការទាមទារ ហើយ**ភតិកៈបន្ត**មានសិទ្ធិទាមទារអោយភតិកៈប្រគល់ប្រាក់ដែលបង់ជាមុននោះមកឲ្យខ្លួនវិញ។ (SCJ)

ឧទាហរណ៍៖ X ជា**ភតិបតី** Y ជា**ភតិកៈ/ភតិបតីបន្ត** Z ជា**ភតិកៈបន្ត**។ ថ្លៃឈ្នួលនៃភតិសន្យាមានចំនួន ១ ០០០$ ដល់កាលកំណត់នៅរៀងរាល់ថ្ងៃទី១០។ ថ្លៃនៃភតិសន្យាបន្តគឺមានចំនួន ១២០០$ ដល់កាលកំណត់នៅរៀងរាល់ថ្ងៃទី៥។ X បានលឺថា Y ជួបប្រទះនឹងវិបត្តិហិរញ្ញវត្ថុ ហើយបានគិតថា ប្រសិនបើ Z បានបង់ប្រាក់ចំនួន ១២០០$ ទៅអោយ Y នោះ Y នឹងប្រើប្រាស់លុយទាំងអស់នោះអស់តែម្តង ហើយនឹងមិនបានបង់ប្រាក់១ ០០០$ មកឲ្យ X ទៀត។

ដូច្នេះ X បានទាមទារ Z បង់ប្រាក់ថ្លៃឈ្នួលដោយផ្ទាល់ទៅឲ្យ X នៅថ្ងៃទី៥។ ចំនួនដែល X បានទាមទារនោះគឺ ១០០០$។ ប៉ុន្តែ Z បាននិយាយថា Z បានបង់ប្រាក់ចំនួន ១២០០ ដុល្លារួចហើយនៅថ្ងៃទី៤។ ការបង់ប្រាក់របស់ Z គឺជាការបង់ថ្លៃជាមុន ដូច្នេះ Z មិនអាចអះអាងពីការបង់ប្រាក់នោះចំពោះ X បានទេ។ Z ត្រូវបង់ប្រាក់ចំនួន១០០០ ដុល្លាទៅឲ្យ X ម្តងទៀត។ Z អាចទាមទារប្រាក់១០០០ដុល្លារពី Y មកវិញបាន។

## ៣.ទំនាក់ទំនងរបស់ភតិបតី ភតិកៈ និងភតិកៈបន្ត ក្នុងការបញ្ចប់ភតិសន្យា និងអានុភាពនៃការជួលបន្ត

(X៖ភតិបតី, Y៖ភតិកៈ, Z៖ភតិកៈបន្ត )

- **ការបញ្ចាប់ដោយផ្អែកលើកំហុសរបស់Y (SCJ)**

X បានបញ្ចប់ភតិសន្យារវាង X នឹង Y ដោយផ្អែកលើការខកខានក្នុងការបង់ប្រាក់ថ្លៃឈ្នួលរបស់ Y។ ការបញ្ចាប់ដោយផ្អែកលើការបំពានកិច្ចសន្យានេះ អាចយកមកអះអាងចំពោះ Z បាន។ ដូច្នេះភតិសន្យាបន្តរវាង Y និង Z ក៏ត្រូវបានបញ្ចប់ផងដែរ។

- **ការបញ្ចាប់ដោយផ្អែកលើការព្រមព្រៀងរវាង X នឹង Y (SCJ)**

X និង Y បានព្រមព្រៀងគ្នាបញ្ចប់ភតិសន្យារវាង X នឹង Y។ ការបញ្ចប់ដោយការព្រមព្រៀងនេះ មិនអាចយកមកអះអាងចំពោះ Z បានទេ។ ដូច្នេះភតិសន្យាបន្តរវាង Y និង Z នៅតែមានសុពលភាព។ នេះគឺដើម្បីការពារ Z ពីការសមគំនិតគ្នាយ៉ាងអាក្រក់រវាង X និង Y ដែលប៉ះពាល់ដល់ Z។

## ជំពូក ៤.ការបញ្ចប់ភតិសន្យា

ការបញ្ចប់ភតិសន្យាមួយ គឺត្រូវមានមូលហេតុច្បាស់លាស់ដូចខាងក្រោម៖

## ១. ការបញ្ចប់ភតិសន្យាដែលមានកំណត់អំឡុងពេល

ភតិសន្យាដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ដោយការផុតអំឡុងពេលដែលបានកំណត់នោះ (មាត្រា៦១២ ក.រ)។

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលអាគារ L អោយ Y មានរយៈពេល១ (មួយ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ ។ ដូច្នេះ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៥ ភតិសន្យានេះត្រូវបានផុតអំឡុងពេលជួលហើយ នាំអោយភតិសន្យាត្រូវបានបញ្ចប់ដោយកាលកំណត់។

**បញ្ជាក់៖** ទោះបីជាភតិសន្យាដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ដោយការផុតអំឡុងពេលក៏ដោយ ភាគីនៃភតិសន្យា ត្រូវតែធ្វើការជូនដំណឹងទៅភាគីម្ខាងទៀតដើម្បីបញ្ជាក់អំពីឆន្ទៈក្នុងការបន្តកិច្ចសន្យាទៀតឬអត់ដែលត្រូវធ្វើឡើងដូចខាងក្រោម៖

- ចំពោះភតិសន្យាជួលផ្ទះ ឬ អាគារ ភាគីត្រូវបង្ហាញឆន្ទៈមុនផុតកំណត់ពេល៣ខែ។
- ចំពោះភតិសន្យាជួលដីធ្លី ភាគីត្រូវបង្ហាញឆន្ទៈមុនផុតកំណត់ពេល ១ឆ្នាំ។

បើភាគីមិនបានបង្ហាញឆន្ទៈច្បាស់លាស់ក្នុងច្បាប់កំណត់ទេ នោះចាត់ទុកថា ភាគីបានយល់ព្រមបន្តជាថ្មី។ ប៉ុន្តែក្នុងករណីនេះ ភតិសន្យាត្រូវបានបន្តថ្មីនេះ គឺជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល (មាត្រា ៦១៣ ក.រ)។

## ២. ការស្នើសុំឲ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល

បើពុំបានកំណត់អឡុងពេលជួលនៅក្នុងកិច្ចសន្យាទេ ភាគីនីមួយៗអាចស្នើសុំឲ្យរំលាយកិច្ចសន្យានៅពេលណាក៏បាន។ ក្នុងករណីដែលការស្នើសុំឲ្យរំលាយ មិនបានបញ្ជាក់ពេលរំលាយ និងក្នុងករណីដែលអំឡុងពេលចាប់ពីពេលស្នើសុំឲ្យ រំលាយរហូតដល់ពេលរលាយ ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឲ្យរំលាយនោះ តិចជាងពេលដូចបានកំណត់ខាងក្រោមនេះ ភតិសន្យាត្រូវរំលាយ នៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឲ្យរំលាយ (មាត្រា ៦១៥ កថាខណ្ឌទី ១ នៃក.រ)៖

ក-១ (មួយ)ថ្ងៃ ចំពោះចលនវត្ថុ។

ខ-៣ (បី) ខែ ចំពោះអាគារ។

គ-១ (មួយ) ឆ្នាំ ចំពោះដីធ្លី។

ឧទាហរណ៍ ៖ X បានធ្វើកិច្ចសន្យាជួលរថយន្ត Lexus LX470 មួយគ្រឿង អោយ Y ដោយមិនបានកំណត់រយៈពេលទេ។ ស្រាប់តែ ១ (មួយ) ឆ្នាំ ក្រោយមក X បានធ្វើបានជូនដំណឹងទៅ (ថ្ងៃជូនដំណឹង ២៧ ខែមករា ឆ្នាំ ២០១៥) Y ថាខ្លួនឈប់ជួលឡានឲ្យ Y ទៀតហើយ ហើយឲ្យគិតថ្លៃឈ្នួលតាមចំនួនថ្ងៃ

ប្រើប្រាស់ជាក់ស្តែង និងបង្គាប់ឲ្យ Y យករថយន្តមកសងខ្លួននាថ្ងៃជូនដំណឹងនោះតែម្តង។ ករណីនេះកិច្ចសន្យាជួលមិនទាន់បានបញ្ចប់ទេ ត្រូវរង់ចាំ១ថ្ងៃទៀតគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃស្នើសុំឲ្យរំលាយ (សូមមើលមាត្រា ៣៣៤ កថាខណ្ឌទី ១ នៃក.រ) មានន័យថា X មិនអាចទាមទារឲ្យ Y ប្រគល់រថយន្តភ្លាមបានទេ ត្រូវរង់ចាំរហូតដល់ថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៥)មកដល់សិន។ បើដល់ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ភតិសន្យានេះត្រូវបានបញ្ចប់នៅពេលមានការរំលាយភតិសន្យា។

ឧទាហរណ៍៖X បានធ្វើកិច្ចសន្យាជួលអាគារ L អោយ Y មិនមានកំណត់អំឡុងពេល។ មួយឆ្នាំក្រោយមក X បានធ្វើការជូនដំណឹងឈប់ជួលអាគារទៅអោយ Y ភ្លាមៗ។ ករណីនេះ X ត្រូវជូនដំណឹងទៅ Y យ៉ាងតិច ៣ (បី) ខែ មុនការបញ្ចប់ភតិសន្យា មានន័យថា X ត្រូវរង់ចាំក្រោយពីការជូនដំណឹង ៣ (បី) ខែកន្លងផុតសិន។

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលដី L អោយ Y មិនមានកំណត់អំឡុងពេល។ មួយឆ្នាំក្រោយមក X បានធ្វើការជូនដំណឹងឈប់ជួលដី L ទៅអោយ Y ភ្លាមៗ។ ករណីនេះ X ត្រូវជូនដំណឹងទៅ Y យ៉ាងតិច ១ (មួយ) ឆ្នាំ មុនការបញ្ចប់ភតិសន្យា មានន័យថា X ត្រូវរង់ចាំក្រោយពីការជូនដំណឹង ១ (មួយ) ឆ្នាំកន្លងផុតសិន។

<u>ចំពោះភតិសន្យាមានរដូវប្រមូលផល</u>

ត្រូវធ្វើការស្នើសុំរំលាយកិច្ចសន្យានៅក្រោយរដូវនោះ មុនការចាប់ផ្តើមការធ្វើកសិកម្មសម្រាប់រដូវបន្ទាប់ (មាត្រា ៦១៥ កថាខណ្ឌទី ២ នៃក.រ)។

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលដីស្រែវស្សា L អោយ Y ដែលមិនកំណត់រយៈពេល។ នៅរដូវវស្សា ដែលស្រូវកំពុងលាស់ល្អស្រាប់តែ X ដែលមានបំណងលក់ដី L អោយនោះឲ្យតតិយជនផ្សេង ហើយដេញ Y ឈប់ឲ្យធ្វើស្រែតទៅទៀត។ ករណីនេះ X ត្រូវរង់ចាំ Y ប្រមូលផលស្រូវអស់ទើបជូនដំណឹងអំពីការបញ្ចាប់កិច្ចសន្យា ហើយរហូតដល់ឆ្នាំក្រោយពេលរដូវប្រមូលផលស្រូវអស់ទើបកិច្ចសន្យាត្រូវបានរំលាយ។

## ៣. ការបញ្ចប់ពិសេសនៃភតិសន្យា ដោយសន្តតិជនរបស់ភតិក:

ក្នុងករណីដែលភតិកៈបានទទួលមរណភាព ប្រសិនបើសន្តតិជនរបស់ភតិកៈនោះមិនមានបំណងបន្តកិច្ចសន្យាទេ មានសិទ្ធិរំលាយកិច្ចសន្យានោះបាន (មាត្រា ៦២០ ក.រ)។ តែផ្ទុយទៅវិញ ចំពោះសិទ្ធិសន្តតិជនរបស់ភតិបតីមិនមានចែងទេ។ ដូច្នេះសន្តតិជនរបស់ភតិបតីដែលបានទទួលមរណភាពត្រូវអនុវត្តបន្តកិច្ចសន្យា បើក្នុងករណីកិច្ចសន្យានោះមានអំឡុងពេលកំណត់ ហើយបើគ្មានអំឡុងពេលកំណត់ត្រូវអនុវត្តដូចមាត្រា ៦១៥ ក.រ។

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលផ្ទះមួយល្វែងអោយ Y ដែលមានកំណត់រយៈពេល៥ឆ្នាំដើម្បីបើកហាងលក់គុយទាវ។ ជាអកុសល Y បានទទួលមរណភាព។ Yមានកូន Zតែម្នាក់គត់ដែលជាវិស្វករ។ ដោយសារឪពុកស្លាប់ទៅ និងមិនមានអ្នកជួយមើលបន្តអាជីពលក់គុយទាវផង ដូច្នេះ Z មានសិទ្ធិបញ្ចប់កិច្ចសន្យាជួលផ្ទះដែលសពឪពុកគាត់បានធ្វើជាមួយ X បានទោះបីជាមិនទាន់ហួសអំឡុងពេលកំណត់តាមកិច្ចសន្យាក៏ដោយ មាត្រា ៦២០ ក.រ។

## ៤. អានុភាពនៃការបញ្ចប់ភតិសន្យា

### គ្មានអានុភាពប្រតិសកម្ម

ទោះនៅក្នុងករណីដែលបានរំលាយភតិសន្យា ការរំលាយកិច្ចសន្យានោះ ត្រូវមានឆ្ពោះទៅអនាគតតែប៉ុណ្ណោះ( មាត្រា ៦១៧ ក.រ)។

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលផ្ទះមួយល្វែងអោយ Y ដែលមានកំណត់រយៈពេល៥ឆ្នាំដើម្បីបើកហាងលក់គុយទាវ។ ជាអកុសល Y បានទទួលមរណភាព។ Yមានកូន Zតែម្នាក់គត់ដែលជាវិស្វករ។ ដោយសារឪពុកស្លាប់ទៅ និងមិនមានអ្នកជួយមើលបន្តអាជីពលក់គុយទាវផង ដូច្នេះ Z មានសិទ្ធិបញ្ចប់កិច្ចសន្យាជួលផ្ទះដែលសពឪពុកគាត់បានធ្វើជាមួយ X បាន ទោះបីជាមិនទាន់ហួសអំឡុងពេលកំណត់តាមកិច្ចសន្យាក៏ដោយ មាត្រា ៦២០ ក.រ។ ករណីនេះ Z មិនអាចទាមទារអោយ X ប្រគល់ប្រាក់ឈ្នួលដែលឪពុកខ្លួនបានបង់ទៅ X កន្លងមកហើយបានទេ គឺគ្រាន់តែមានអានុភាពបន្តទៅអនាគត់តែប៉ុណ្ណោះដែលធ្វើអោយ Z ឈប់បង់ប្រាក់បន្តតាមកិច្ចសន្យាជួលទៀត។

### ធ្វើបដិទាននូវវត្ថុជួលមកស្ថានភាពដើមវិញ

ធ្វើបដិទានវត្ថុជួលមកស្ថានភាពដើមដូចកាលពីភតិកៈបានទទួលការកាន់កាប់វត្ថុជួល (មាត្រា៦១៨ កថាខណ្ឌទី១នៃក.រ)។ ដូច្នេះភតិកៈត្រូវរុះរើចេញនូវឧបករណ៍ដែលភតិកៈបានដំឡើង សំអាតសំរាម និងភាពកខ្វក់ទាំងអស់ដែលភតិកៈបានធ្វើ និងជួសជុលរាល់ផ្នែកដែលខូចខាតដែលភតិកៈបានបង្កឡើង។ ប៉ុន្តែភតិកៈមិនទទួលកាតព្វកិច្ចក្នុងការជួសជុលការបែកបាក់ ខូចខាតដែលកើតឡើងដោយសារការប្រើប្រាស់ជាធម្មតាឡើយ (មាត្រា ៦១៨ កថាខណ្ឌទី ២ នៃ ក.រ)។

- **ការបែកបាក់ ខូចខាតដែលកើតឡើងដោយសារការប្រើប្រាស់ធម្មតា** (ដកស្រង់ចេញពីគោលការណ៍ ណែនាំ រៀបចំដោយក្រសួងដែនដីរបស់ប្រទេសជប៉ុន)៖
  ការស្លកពណ៌បិទជញ្ជាំង ដោយសារកន្លងហួសយូរឆ្នាំ ស្លាកនិងសឹកនៅលើតដ្ឋការ៉ូ ដោយសារការដាក់គ្រឿងសង្ហារឹមជាដើម។

- **ការបែកបាក់ ខូចខាតដែលកើតឡើងដោយសារកំហុសរបស់ភតិក:** (ដកស្រង់ចេញពីគោលការណ៍ ណែនាំ រៀបចំដោយក្រសួងដែនដីរបស់ប្រទេសជប៉ុន)៖ ឆ្កូតនៅលើជញ្ជាំងដោយសាភតិក:គូស បែកឥដ្ឋការ៉ូដោយសាភតិក:ដំដែកគោល។ល។

**ឧបករណ៍ដែលបានបំពាក់ទៅនឹងវត្ថុជួល**

ភតិក:ត្រូវរុះរើចេញនូវឧបករណ៍ នៅពេលបញ្ចប់ភតិសន្យា (ករណីយកិច្ចធ្វើបដិទានមកស្ថានភាពដើមវិញ មាត្រា ៦១៨ កថាខណ្ឌទី១ នៃក.រ)។ ប្រសិនបើភតិបតីបដិសេធក្នុងការរុះរើ ភតិក:នោះនៅតែអាចរុះរើបាន (សិទ្ធិរុះរើ មាត្រា ៦១៩ នៃក.រ)។

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលផ្ទះមួយល្វែងអោយ Y ហើយY បានតសំយ៉ាបមកមុខដើម្បីចតឡាន។ ក្រោយបញ្ចប់កិច្ចសន្យាជួល Y អាចរុះរើយកសំយ៉ាបដែលតនោះមកវិញបាន ទោះជា X មិនឯកភាពក៏ដោយ។

**អំឡុងពេលប្រើសិទ្ធិទាមទារសំណងនៃការខូចខាត និងការទាមទារសោហ៊ុយមកវិញ**

សំណងនៃការខូចខាតដែលកើតឡើងដោយសារភតិក: ក្នុងការប្រើប្រាស់ និងអាស្រ័យផលដែលផ្ទុយនឹងអត្ថន័យដើមនៃកិច្ចសន្យា និងការសងមកវិញនូវសោហ៊ុយដែលភតិក:បានចេញ ត្រូវទាមទារនៅក្នុងអំឡុងពេល១(មួយ)ឆ្នាំគិតចាប់ពីពេលដែលភតិបតីបានទទួលការសងវត្ថុជួលនោះ (មាត្រា ៦២១ នៃក.រ)។ ភតិក: ឬ ភតិបតី ត្រូវជូនដំណឹងទៅភាគីម្ខាងទៀត អំពីឆន្ទ:ក្នុងការអនុវត្តក្នុងអំឡុងពេល ១ឆ្នាំ ប៉ុន្តែការជូនដំណឹងនេះអាចធ្វើនៅក្រៅតុលាការក៏បាន។

**ករណីភតិបតីទាមទារសំណងការខូចខាតដោយប្រើប្រាស់**

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលផ្ទះមួយល្វែងអោយ Y ហើយ Y បានតសំយ៉ាបមកមុខដើម្បីចតឡាន ហើយបានកាត់ទ្វារកញ្ចក់ចេញ។ ក្រោយបញ្ចប់កិច្ចសន្យាជួល Y បានរុះរើយកសំយ៉ាបដែលតនោះមកវិញតែមិនបានដាក់ទ្វារកញ្ចក់វិញទេ។ ករណីនេះ X អាចទាមទារអោយ Y សងសំណងនៃការខូចខាតនៃទ្វារកញ្ចក់ដែលបានបាត់ ហើយ X ត្រូវជូនដំណឹងទៅ Y អំពីឆន្ទ:របស់ X ក្នុងការអនុវត្តការទាមទារសំណងនៃការខូចខាត ក្នុងអំឡុងពេល១ឆ្នាំ ចាប់ពីថ្ងៃ Y បានប្រគល់ផ្ទះ។

**ករណីភតិក:ទាមទារសោហ៊ុយដែលបានចេញ**

ឧទាហរណ៍៖ X បានធ្វើកិច្ចសន្យាជួលផ្ទះមួយល្វែងអោយ Y ហើយ Y បានធ្វើដំបូលលើដើម្បីកុំឲ្យទឹកស្រក់ចូល ដែលចំណាយអស់ប្រាក់ ៥០០០ ដុល្លាអាមេរិក។ ក្រោយបញ្ចប់កិច្ចសន្យាជួល តម្លៃនៃដំបូលបានថយចុះត្រឹម ២៥០០ដុល្លារ។ Y អាចទាមទារសោយហ៊ុយចំណាយដែលមានប្រយោជន៍សម្រាប់ការធ្វើដំបូលពី X វិញបាន។ ករណីនេះ Y ត្រូវជូនដំណឹងទៅ X អំពីឆន្ទ:របស់ Y ក្នុងការអនុវត្តការ

ទាមទារឲ្យសងវិញនូវសោហ៊ុយដែលមានប្រយោជន៍ក្នុងអំឡុងពេល១ឆ្នាំ ចាប់ពីថ្ងៃ Y បានប្រគល់ផ្ទះ។ ចំនួនដែលត្រូវសងវិញ គឺសោហ៊ុយដែលបានចំណាយជាក់ស្តែង ឬតម្លៃដែលនៅសល់ ដែលត្រូវបានកំណត់ដោយ X (មាត្រា ៦០៤ កថាខណ្ឌទី ២ នៃក.រ) ដូច្នេះ X នឹងជ្រើសរើសយក ២៥០០ ដុល្លារ។

## ជំពូក ៥.ករណីសិក្សា

**ករណីទី១ ៖ការផ្លាស់ប្តូរភតិបតី**

X គឺជាកម្មសិទ្ធិករនៃដី។ Xបានជួលដីឲ្យ Y។ Yបានបង់ប្រាក់កក់ឲ្យ X។ ក្រោយមក Xបានលក់ដីឲ្យ Z។

សំនួរទី១៖ តើ Z អាចដេញ Y ចេញបានដែរឬទេ?

សំនួរទី ២៖ តើ Z អាចទាមទារឲ្យ Y បង់ថ្លៃឈ្នួលទៅ Z បានដែរឬទេ?

សំនួរទី ៣៖ នៅពេលបញ្ចប់ភតិសន្យា តើ Y អាចទាមទារឲ្យ Z ប្រគល់ប្រាក់កក់វិញបានដែរឬទេ។

**ករណីទី២៖ ការផ្លាស់ប្តូរភតិក:**

X ជាកម្មសិទ្ធិករនៃដី។ X បានជួលដីឲ្យ Y។ Y បានបង់ប្រាកកក់ឲ្យ X។ Y បានសង់អាគារមួយនៅលើដីនោះ។ ក្រោយមក Y បានលក់សិទ្ធិជួល និងអាគារនោះឲ្យ Z។

សំនួរទី១៖ តើ X អាចដេញ Z ចេញបានដែរឬទេ?

សំនួរទី២៖ នៅពេលបញ្ចប់ភតិសន្យា តើ Z អាចទាមទារឲ្យ X ប្រគល់ប្រាក់កក់វិញបានដែរឬទេ?

**ករណីទី៣៖ វិសាលភាពនៃការជួលបន្ត ១៖** X ជាកម្មសិទ្ធិករនៃដី។ X បានជួលដីឲ្យ Y។ Y បានសង់អាគារមួយនៅលើដីនោះ។ ក្រោយមក Y បានជួលបន្ទប់មួយនៃអាគារនោះឲ្យទៅ Z។ សំនួរ៖ តើ Y ត្រូវសុំការយល់ព្រមពី X អំពីការជួលបន្ទប់ទៅឲ្យ Z ដែរឬទេ?

**ករណីទី៤៖ វិសាលភាពនៃការជួលបន្ត ២**

X បានជួលផ្ទះមួយឲ្យ Y។ Y បានជួលបន្ទប់មួយក្នុងផ្ទះនោះឲ្យទៅ Z។

សំនួរ៖ តើ Y ត្រូវសុំការយល់ព្រមពី X អំពីការជួលបន្ទប់ទៅឲ្យ Z ដែរឬទេ?

**ករណីទី៥៖ ការភ្ជាប់ដែលមិនចាំបាច់** (Unnecessary Attachment)

X បានជួលអាគារដែលមានកំពស់ពីរជាន់មួយទៅឲ្យ Y (អាគារនោះមានតែជាន់ក្រោមដី និងជាន់ទី១ ប៉ុណ្ណោះ)។ Y បានសាងសង់ និងបន្ថែមជាន់ទី២ ទៅលើអាគារនោះ។

សំនួរទី១៖ នៅពេលបញ្ចប់ភតិសន្យា តើ X អាចទាមទារឲ្យ Y រុះរើជាន់ទី ២ នោះចេញបានដែរឬទេ?

សំនួរទី២៖ នៅពេលបញ្ចប់ភតិសន្យា តើ Y អាចទាមទារឲ្យ X បង់ប្រាក់សម្រាប់តម្លៃនៃជាន់ទី២ នោះបានដែរឬទេ?

**ករណីទី៦៖ ការសាងសង់ដែលមិនចាំបាច់** (Unnecessary Building)

X បានជួលដីមួយកន្លែងឲ្យ Y។ Y បានសាងសង់អាគារមួយនៅលើដីនោះ។

សំនួរទី១៖ នៅពេលបញ្ចប់ភតិសន្យា តើ X អាចទាមទារឲ្យ Y រុះរើអាគារនោះចេញបានដែរឬទេ?

សំនួរទី២៖ នៅពេលបញ្ចប់ភតិសន្យា តើ Y អាចទាមទារឲ្យ X បង់ប្រាក់សម្រាប់តម្លៃនៃអាគារនោះបានដែរឬទេ?

**ករណីទី៧៖ អលទ្ធភាពទាំងស្រុង** (Whole Impossibility)

X បានជួលផ្ទះមួយឲ្យ Y។ ប៉ុន្តែដោយសារតែទឹកជំនន់ ផ្ទះនោះត្រូវបានខូចខាតបែកបាក់ទាំងស្រុង។

សំនួរទី១៖ តើ Y ត្រូវបន្តបង់ថ្លៃឈ្នួលដែរឬទេ?

សំនួរទី២៖ តើ Y អាចទាមទារឲ្យ X សាងសង់ផ្ទះឡើងវិញបានដែរឬទេ?

សំនួរទី៣៖ តើ X ឬ Y អាចបញ្ចប់ភតិសន្យា បានដែរឬទេ?

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

# សិទ្ធិជួលអចិន្ត្រៃយ៍

## ជំពូក ១. បទបញ្ញត្តិទូទៅ

### ១. និយមន័យ មាត្រា ២៤៤ នៃក្រមរដ្ឋប្បវេណី

សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅលើសិទ្ធិជួល **អចលនវត្ថុ រយៈពេលវែង ចាប់ពី ១៥ឆ្នាំឡើងទៅ។** ទស្សនៈសិទ្ធិជួលអចិន្ត្រៃយ៍ ដែលមានក្នុងក្រមរដ្ឋប្បវេណីនេះត្រូវបានស្រង់ចេញពីគោលគំនិត ការជួលរយៈពេលវែង មាត្រា១០៦កថាខណ្ឌ២នៃច្បាប់ភូមិបាល ដែលចែងថា ការជួលរយៈពេលវែង មានរយៈពេល១៥ឆ្នាំ រឺលើស។ ច្បាប់ភូមិបាលក៏មិនមានមាត្រាផ្សេងពីនេះដែលកំណត់អំពីអតិបរមា នៃការជួល រយៈ វែងនោះទេ។ មាត្រា ១០៨ កថាខណ្ឌ១ ច្បាប់ភូមិបាល បានទទួលស្គាល់ថាសិទ្ធិជួលរយៈពេលវែង ត្រូវចាត់ទុកជាសិទ្ធិភណ្ឌិក(សិទ្ធិប្រត្យក្ស) ដែលអាចផ្ទេរដោយយកថ្លៃ រឺសន្តតិកម្មបាន។ ក្រមរដ្ឋប្បវេណី មាត្រា១៣២ សិទ្ធិជួលអចិន្ត្រៃយ៍ ជាសិទ្ធិប្រត្យក្ស។

### ២. ការបង្កើត (មាត្រា ២៤៥ នៃក.រ)

សិទ្ធិជួលអចិន្ត្រៃយ៍ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ បើមិនបានធ្វើជាលាយល័ក្ខណ៍អក្សរទេពុំមានអានុភាពឡើយ។ ការធ្វើជាលាយលក្ខណ៍អក្សរនេះគឺមានអានុភាព រវាងតែគូភាគីប៉ុណ្ណោះ។ ការធ្វើជាលាយលក្ខណ៍អក្សរនេះគឺអាចធ្វើជាលិខិតឯកជនបាន ព្រោះតាមក្រមរដ្ឋប្បវេណី មិនតម្រូវថាចំបាច់អោយធ្វើតាម លិខិតយថាភូតនោះទេ។ ប្រកាសស្ដីពីនីតិវិធីចុះបញ្ជីទាក់ទងនឹងក្រមរដ្ឋប្បវេណី មិនតម្រូវឲ្យមានលិខិតយថាភូតសម្រាប់ការចុះបញ្ជីទេ (ឯកសារបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី, មាត្រា ២៧)។

***<u>តើការអនុវត្តរបស់មន្ត្រីចុះបញ្ជីយ៉ាងដូចម្ដេចដែរ?</u>***

សម្រាប់ការអនុវត្តជាក់ស្ដែងនៅកម្ពុជា គឺតម្រូវអោយមេឃុំ រឺចៅសង្កាត់ ចុះហត្ថលេខាលើកិច្ចសន្យារបស់ភាគី ឬសារការីក៏បាន តែប្រសិនបើអត់មានធ្វើបែបនេះទេ គឺអជ្ញាធរគេអត់ចុះអោយទេ។

អញ្ចឹងហើយយើងឃើញថា នៅក្នុងក្រមរដ្ឋប្បវេណីដែលជាច្បាប់សារធាតុតម្រូវគ្រាន់តែជាការព្រមព្រៀងរបស់គូភាគីប៉ុណ្ណោះ គឺអាចយកទៅចុះបញ្ជីបានហើយ ហើយប្រកាសស្ដីពីនីតិវិធីចុះបញ្ជីក៏មិនតម្រូវអោយធ្វើជាលិខិតយថាភូតអ្វីដែរ។

ដូចនេះយើងឃើញថាការអនុវត្តន៍ជាក់ស្ដែង និងទ្រឹស្ដីដែលមាន គឺអនុវត្តខុសគ្នា។

***<u>តើដីដែលមិនទាន់មានប័ណ្ណអាចចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍បានដែរឬទេ?</u>***

***<u>តើអាគារអាចចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍បានដែរឬទេ?</u>***

ជាគោលការណ៍ច្បាប់ដោយផ្អែកតាមមាត្រា២៤៥ នៃក្រមរដ្ឋប្បវេណីភាគីអាចបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បាន ដែលអានុភាពរបស់វាមានតែចំពោះតែគូភាគីប៉ុណ្ណោះ និងមិនអាចតតាំងជាមួយតតិយជន

បានឡើយ។ ដូច្នេះប្រសិនបើគូភាគីចង់ចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍ ទាល់តែអចលនវត្ថុនោះត្រូវបានចុះបញ្ជី។

- ទាំងភតិសន្យាដោយផ្ទាល់មាត់ ទាំងកិច្ចសន្យាសិទ្ធិជួលអចិន្ត្រៃយ៍ដោយផ្ទាល់មាត់ត្រូវបានចាត់ទុកជាភតិសន្យាជួលដែលពុំមានកំណត់អំឡុងពេល ដែលអាចត្រូវបានបញ្ចប់នៅ ពេលណាក៏បាន (មាត្រា ២៤៥ កថាខណ្ឌទី ២, ៥៩៩ កថាខណ្ឌទី ២ នៃក.រ)។

## ២.១. ធាតុផ្សំនៃសិទ្ធិជួលអចិន្ត្រៃយ៍

(១) វត្ថុ: ដែលជាកម្មវត្ថុនៃការជួលអចិន្ត្រៃយ៍ ត្រូវតែជាអចលនវត្ថុ ទើបអាចបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍បាន មាត្រា២៤៤។

អចលនវត្ថុ ក្នុងន័យនៃមាត្រា២៤៤ នេះគឺគ្របដណ្តប់ ទៅលើអាគារផងដែរ មានន័យថាសិទ្ធិជួលអចិន្ត្រៃយ៍ អាចបង្កើតលើអាគារបាន។

(២) ថ្លៃឈ្នួល: អ្នកជួលអចិន្ត្រៃយ៍ មានករណីកិច្ចបង់ថ្លៃឈ្នួល មាត្រា ២៤៨-១

(៣) អំឡុងពេល: នៃការជួលអចិន្ត្រៃយ៍ គឺចាប់ពី១៥ ឆ្នាំឡើងទៅ (មាត្រា ២៤៤ នៃក.រ) និង ៥០ ឆ្នាំ ឬ តិចជាងនេះ (មាត្រា ២៤៧ កថាខណ្ឌទី ១ នៃក.រ)។

## ៣-លក្ខខណ្ឌតតាំង

ក្នុងករណីសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវចុះបញ្ជី ពីសិទ្ធិជួលអចិន្ត្រៃយ៍ តាមមាត្រា ២៤៦ នៃក.រ

- អាចតតាំងចំពោះតតិយជន

ឧ-ម្ចាស់អចលនវត្ថុមួយបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ជាមួយអ្នកជួលអចិន្ត្រៃយ៍ពីរនាក់ដោយសិទ្ធិជួលអចិន្ត្រៃយ៍ទាំងពីរបង្កើតជាលាយលក្ខណ៍អក្សរ ហើយម្នាក់បានចុះបញ្ជីពីសិទ្ធិជួលអចិន្ត្រៃយ៍។

តើអ្នកណាមានសិទ្ធិជាងអ្នកណា?

- អាចតតាំងចំពោះអនុប្បទានិក(អ្នកទិញ)

មានន័យថាទោះបីជាកម្មវត្ថុ នៃសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានលក់ក៏ដោយ ក៏អ្នកដែល ជួលអចិន្ត្រៃយ៍ អាចតតាំង បានដែរបើគាត់បានចុះបញ្ជីពីសិទ្ធិជួលនេះបានមុន។

-ក្នុងករណីភតិសន្យា មាត្រា ៥៩៨ នៃក.រ

ប្រសិនបើអ្នកជួលអចិន្ត្រៃយ៍មិនបានចុះបញ្ជីពីសិទ្ធិជួលអចិន្ត្រៃយ៍របស់គាត់ទេ គាត់មិនអាចតតាំងពីសិទ្ធិជួលអចិន្ត្រៃយ៍បានទេ តែគាត់អាចតតាំងពី ភតិសន្យាក្នុងរយៈពេល ត្រឹម១៥ឆ្នាំបានដោយគាត់ត្រូវកាន់កាប់ និងប្រើប្រាស់ អាស្រ័យផលជាបន្តបន្ទាប់ នូវវត្ថុជួលនោះ។

| ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ | អានុភាព |
|---|---|
| ១-ការព្រមព្រៀង | ជាភតិសន្យាដែលមិនមានកំណត់អំឡុងពេល ហើយអាចរំលាយពេលណាក៏បាន។ |
| ២-ធ្វើជាលាយលក្ខ័អក្សរ | ចំពោះគូភាគី ការតតាំងត្រូវបានកម្រិត គឺអាចតតាំងជាមួយតតិយជនបានត្រឹម១៥ឆ្នាំបើអ្នកជួលបានកាន់កាប់។ |
| ៣-ចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ | ចំពោះគូភាគី អាចតតាំងជាមួយតតិយជនបាន។ |

- ករណីសាមញ្ញៈ X ជាអ្នកឲ្យជួលអចិន្ត្រៃយ៍ រីឯ Y ជាអ្នកជួលអចិន្ត្រៃយ៍ ហើយពួកគេបានចុះកិច្ចសន្យាសិទ្ធិជួលអចិន្ត្រៃយ៍នៃដីមួយកន្លែង ជាលាយលក្ខណ៍អក្សរ។ ក្រោយមក X បានលក់ដីឲ្យទៅ Z ហើយ Z បានទាមទារឲ្យ Y ចេញពីដីនោះ។ ប្រសិនបើ Y បានចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ នៅមុនការចុះបញ្ជីរបស់ Z នោះ Y អាចបដិសេធចំពោះការទាមទាររបស់ Z បាន ព្រោះ Y អាចអះអាងពីសិទ្ធិជួលអចិន្ត្រៃយ៍ចំពោះ Z បាន (មាត្រា ២៤៦ កថាខណ្ឌទី ២ នៃក.រ)។ ប្រសិនបើ Y មិនបានចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ នៅមុនការចុះបញ្ជីរបស់ Z ទេ នោះតើ Y អាចបដិសេធចំពោះការទាមទាររបស់ Z បានដែរ ឬ ទេ? សូមមើលមាត្រា ២៤៦ កថាខណ្ឌទី ៣ នៃក.រ។

## ៤-អានុភាព

### ៤-១-អំឡុងពេល មាត្រា២៤៧

- សិទ្ធិជួលអចិន្ត្រៃយ៍ មានអត្ថិភាពចាប់ពី១៥ឆ្នាំ ឡើងទៅ និង មិនអោយលើសពី៥០ឆ្នាំ។ ប៉ុន្តែក្នុងករណីគូភាគីបានបង្កើត លើសពី៥០ឆ្នាំ ត្រូវបន្ថយមកត្រឹម៥០ឆ្នាំ ។ (មាត្រា២៤៧-១)

- សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន ការព្រមព្រៀងរវាងអ្នកឲ្យជួលអចិន្ត្រៃយ៍ និង អ្នកជួលអចិន្ត្រៃយ៍ (មាត្រា ២៤៧ កថាខណ្ឌទី ២ នៃក.រ)។ ប្រសិនបើពុំមានភាគីណាមួយបដិសេធទៅនឹងការបន្តសាជាថ្មីនៃសិទ្ធិជួលអចិន្ត្រៃយ៍ក្នុងអំឡុងពេល ៣ ខែ(ចំពោះអាគារ) ឬ អំឡុងពេល ១ ឆ្នាំ (ចំពោះដីធ្លី) មុនផុតអំឡុងពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍ នោះសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបន្តសាជាថ្មី ជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល (មាត្រា ២៥៥, ៦១៣ នៃក.រ)។

<u>ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីមាត្រា៥១</u>

១- កិច្ចសន្យាជួលរយៈពេលវែងដែលបង្កើតមុនកាលបរិច្ឆេទអនុវត្តក្រម រយៈនៅសល់លើសពី៥០ឆ្នាំ នៅមានតែអត្ថិភាពដដែល។

២- កិច្ចសន្យាជួលរយៈពេលវែងដែលបង្កើតមុនកាលបរិច្ឆេទអនុវត្តក្រម ហើយរយៈពេលនៅសល់លើសពី៩៩ឆ្នាំ ត្រូវកំណត់ត្រឹម៩៩ឆ្នាំ ចាប់ពីកាលអនុវត្ត។

៣-ពុំមានកិច្ចសន្យាជួលរយៈពេលវែង ចាប់ពីពេលអនុវត្តក្រម។ សិទ្ធិជួលអចិន្ត្រៃយ៍ដែល បង្កើតឡើងបន្ទាប់ពីពេលអនុវត្តក្រមមិនត្រូវច្រើនជាង៥០ឆ្នាំឡើយ។

ប៉ុន្តែចំពោះករណី ដែលពាក្យសុំចុះបញ្ជីសិទ្ធិជួលរយៈពេលវែងបានដាក់មុនកាលបរិច្ឆេទអនុវត្តក្រម ហើយកាលបរិច្ឆេទចេញបណ្ណ័ក្រោយក្រម គឺអាចនៅមានឈ្មោះ កិច្ចសន្យាជួលរយៈពេលវែង ហើយរយៈពេលអាចលើសពី៥០ឆ្នាំដែរ។

**៤-២-ថ្លៃឈ្នួល ម២៤៨**

- អ្នកជួលអចិន្ត្រៃយ៍ត្រូវបង់ថ្លៃឈ្នួលតាមកិច្ចសន្យា ដែលបានកំណត់។

**បើអត់មានកំណត់ពេលទេ?**

- អ្នកជួលអចិន្ត្រៃយ៍ ត្រូវបង់នៅរាល់ដំណាច់ឆ្នាំ។
- ចំពោះវត្ថុប្រមូលផល ត្រូវបង់នៅក្រោយរដូវនោះដោយគ្មានការយឺតយ៉ាវ មាត្រា២៤៨-២

**-សិទ្ធិទាមទារតម្លើង និង បញ្ចុះថ្លៃឈ្នួល មាត្រា២៤៩**

ភាគីទាំងសងខាងនៃសិទ្ធិជួលអចិន្ត្រៃយ៍អាចទាមទារ អោយតម្លើង រឺបញ្ចុះថ្លៃឈ្នួល ចំពោះ "ស្ថានភាពផ្សេងៗ" រាប់បញ្ចូលទាំងការផ្លាស់ប្តូរពន្ធដែលវាយតម្លៃលើដី ការផ្លាស់ប្តូរតម្លៃដីលើទីផ្សារ ការផ្លាស់ប្តូរតម្លៃលើទីផ្សារជាទូទៅ ការផ្លាស់ប្តូរតម្លៃលើទីផ្សារនៃថ្លៃឈ្នួលក្នុងតំបន់។ ប្រសិនបើមិនអាចសម្របសម្រួលគ្នាតាមរយៈការពិភាក្សាគ្នាទេ ភាគីអាចប្តឹងទៅតុលាការអោយកំណត់តម្លៃសមរម្យ។

"ស្ថានភាពផ្សេងៗ" មិនរាប់បញ្ចូលនូវការបំផ្លាញវត្ថុជួលអចិន្ត្រៃយ៍មួយផ្នែកទេ។ ក្នុងករណីនោះ មាត្រា ៦០៧ ឬ មាត្រា ២៥១ នៃក.រ ត្រូវអនុវត្ត។

**៤-៣-អនុប្បទាន ជាអាទិ៍ នូវសិទ្ធិជួលអចិន្ត្រៃយ៍ មាត្រា ២៥២**

១- អាចធ្វើអនុប្បទានរឺចាត់ចែងផ្សេងដោយយកថ្លៃ រឺមិនយកថ្លៃបានមានន័យថាអាចអោយគេខ្ចីប្រើបាន។

២- អ្នកជួលអចិន្ត្រៃយ៍ អាចជួលបន្តបានដោយពុំមានការយល់ព្រមពីអ្នកអោយជួលអចិន្ត្រៃយ៍។

៣- សិទ្ធិជួលអចិន្ត្រៃយ៍អាចជាកម្មវត្ថុ សន្តតិកម្មបាន។

**ឧ- ភាគីបានចែងកិច្ចព្រមព្រៀងថា អ្នកជួលអចិន្ត្រៃយ៍ស្លាប់ កិច្ចសន្យាត្រូវបញ្ចប់?**

**៤-៤-សិទ្ធិទាមទារផ្អែកលើសិទ្ធិប្រត្យក្ស**

ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍អាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ប្រសិនបើសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានចុះបញ្ជី (មាត្រា ២៤៦ នៃក.រ)។ អាចទាមទារអោយប្រគល់វិញ អោយបញ្ឈប់ការរារាំង អោយបង្ការជាមុននូវការរារាំងចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ មាត្រា២៥៣។

**៤-៥-ការរំលាយសិទ្ធិជួលអចិន្ត្រៃយ៍**

**ក-សិទ្ធិរំលាយរបស់អ្នកអោយជួល មាត្រា២៥០**

អ្នកអោយជួលអាច រំលាយកិច្ចសន្យាជួលអចិន្ត្រៃយ៍បាន ដោយគ្រាន់តែធ្វើការជូនដំណឹងទៅអ្នកដែលជួលអចិន្ត្រៃយ៍ ក្នុងករណីដែលមិនបានបង់ថ្លៃឈ្នួលតាមកាលកំណត់ក្នុងអំឡុងពេល៣ឆ្នាំ។

**ខ-សិទ្ធិរំលាយរបស់អ្នកជួល មាត្រា២៥១**

អ្នកជួលអចិន្ត្រៃយ៍ អាចជូនដំណឹងដើម្បីរំលាយកិច្ចសន្យាជួលអចិន្ត្រៃយ៍ក្នុងករណី

១-កំឡុងពេល៣ឆ្នាំមិនបានចំណេញដោយសារករណីប្រធានសក្តិរីស្ថានភាពមិនអាចព្យាករណ៍ទុកមុនបាន។

២-ប្រាក់ចំណេញប្រចាំឆ្នាំ មិនអាចលើសថ្លៃឈ្នួល១ឆ្នាំ ដោយសារការខូចខាតផ្នែកណាមួយនៃអចលវត្ថុនោះ។

ឧ- ខ ចែងដាក់ថា ក្នុងករណីណាក៏ដោយអ្នកជួលអចិន្ត្រៃយ៍ មិនអាចរំលាយកិច្ចសន្យាជួលអចិន្ត្រៃយ៍បានឡើយ។

**៤-៦-ការធ្វើបដិទាន មាត្រា២៥៤**

នៅពេលបញ្ចប់កិច្ចសន្យាជួលអចិន្ត្រៃយ៍ ត្រូវទុកវត្ថុជួលអចិន្ត្រៃយ៍ដូចស្ថានភាពនាពេលបច្ចុប្បន្ន។ ជាគោលការណ៍អ្នកជួលអចិន្ត្រៃយ៍គ្មានករណីយកិច្ចធ្វើបដិទានសិទ្ធិទាមទារអោយសងសោហ៊ុយចំណាយបង្កើនតម្លៃដើម្បីកែលំអ រីសិទ្ធិរុះរើចេញទេ។ ប៉ុន្តែគូភាគីអាចធ្វើការសន្យាពិសេសលើចំណុចនេះបានដូចជាអ្នកអោយជួលត្រូវសងសោហ៊ុយមកអ្នកជួលដែលបានចំណាយដើម្បីកែលំអរអចលនវត្ថុនោះជាដើម។

ការសន្យាពិសេសនេះភាគីអាចធ្វើនៅក្រោយពេលបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ក៏បានប៉ុន្តែត្រូវធ្វើការចុះបញ្ជីការសន្យាពិសេសនេះទើបអាចតតាំងជាមួយតតិយជនបាន។

**អ្នកជួលអចិន្ត្រៃយ៍បានបំផ្លាញអចលនវត្ថុ រឺបានបំប្លែងជាសារវន្តៈ? មាត្រា២៥៤-១**

១. អ្នកឲ្យជួលបានទទួលកម្មសិទ្ធិពេញលេញនៃសំណង់ដោយគ្មានការទូទាត់នៃការចំណាយក្នុងការរៀបចំឬការប្រសើរឡើងណាមួយដែលធ្វើឡើងដោយអ្នកជួលអចិន្ត្រៃយ៍។

២. អ្នកឲ្យជួលមិនអាចបង្ខំអ្នកជួលអចិន្ត្រៃយ៍ ឲ្យប្រគល់អចលនវត្ថុដែលនៅស្ថានភាពដើមឡើយ។ នៅពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកអោយជួលអចិន្ត្រៃយ៍ អាចទាមទារអោយអ្នកជួលអចិន្ត្រៃយ៍ធ្វើបដិទានដោយប្រគល់អចលនវត្ថុតាមស្ថានភាពដើម ប្រសិនបើអ្នកជួលអចិន្ត្រៃយ៍បានបំផ្លាញ ឬបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុនោះ។

## ជំពូក២-ចំណុចដូចគ្នា និង ចំណុចខុសគ្នារវាង សិទ្ធិជួលអចិន្ត្រៃយ៍ និង គតិសន្យា

### ១-ការអនុវត្តមាត្រាពាក់ព័ន្ធនឹងគតិសន្យា (មាត្រា ២៥៥ នៃក.រ)

មាត្រាខាងក្រោមនេះអនុវត្តដូចគ្នាចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ដែលរួមមានៈ

មាត្រា ៦០០,សិទ្ធិ និងករណីកិច្ចប្រើប្រាស់ របស់ភតិក:

៦០១, ការគ្រប់គ្រងដោយសុច្ចរិតរបស់អ្នកជួល

៦០២, ករណីកិច្ចជួលជុលរបស់ភតិបតី

៦០៣, សកម្មភាពថែរក្សារបស់ភតិបតី

៦០៤ កថាខណ្ឌទី ១, សិទ្ធិទាមទារអោយសងវិញ នូវសោហ៊ុយរបស់ភតិកៈ
៦០៥, ការទទួលខុសត្រូវរបស់ភតិបតីចំពោះវិការៈវត្ថុ
៦០៧, សិទ្ធិរំលាយ និងទាមទារ បន្ថយថ្លៃឈ្នួលដោយសារការបាត់បង់វត្ថុមួយភាគ
៦០៩, ការជួលបន្ត
៦១១, ករណីកិច្ចជូនដំណឹងរបស់ភតិកៈ
៦១២, ការផុតអំឡុងពេលកំណត់
៦១៣, ការបដិសេធការបន្តជាថ្មី នូវភតិសន្យាអចលនវត្ថុ
៦១៦, ការរក្សាទុកសិទ្ធិរំលាយកិច្ចសន្យា
៦១៧, ភាពគ្មានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា
៦២០, សិទ្ធិរំលាយកិច្ចសន្យារបស់សន្តតិជន របស់ភតិកៈ
៦២១ អំឡុងពេល ទាមទារសំណងការខូចខាត និងការទាមទារអោយសងសោហ៊ុយមកវិញ ។

## ២-ចំណុចខុសគ្នារវាងភតិសន្យា និង សិទ្ធិជួលអចិន្ត្រៃយ៍

| | ***ភតិសន្យា*** | ***សិទ្ធិជួលអចិន្ត្រៃយ៍*** |
|---|---|---|
| **១ -ល័ក្ខខ័ណ្ឌតតាំង** | ការកាន់កាប់ និងការប្រើប្រាស់និងអាស្រ័យផលជាបន្តបន្ទាប់ | ការចុះបញ្ជី |
| **២-ការរំលាយ ដោយផ្អែកលើការខកខានក្នុងការបង់ថ្លៃឈ្នួល** | ការខកខានម្តងអាចជាមូលហេតុនៃការរំលាយ ទោះបីជាគោលការណ៍រំលោភលើសេចក្តីទុកចិត្តអាចកម្រិតនូវការរំលាយក៏ដោយ។ | ការខកខានក្នុងការបង់ថ្លៃឈ្នួលអស់រយៈពេល ៣ ឆ្នាំ គឺចាំបាច់សម្រាប់ការរំលាយ។ |
| **៣-អនុប្បទានសិទ្ធិជួល និងការជួលបន្តនូវកម្មវត្ថុនៃសិទ្ធិជួល** | ត្រូវមានការយល់ព្រម ពីភតិបតី មាត្រា ៦០៨ នៃក.រ។ | អ្នកជួលអចិន្ត្រៃយ៍អាចចាត់ចែងដោយសេរីនូវសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ជួលបន្តនូវកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ ដោយពុំមានការយល់ព្រមពីអ្នកឲ្យជួលអចិន្ត្រៃយ៍។ មាត្រា ២៥២ នៃក.រ។ |

| | | |
|---|---|---|
| **៤ - អំឡុងពេល និងការបន្តជាថ្មី** | អំឡុងពេលត្រូវតិចជាង រយៈពេល ១៥ ឆ្នាំ (មាត្រា ៥៩៩ កថាខណ្ឌទី ៣ នៃក.រ)។ | ចាប់ពី១៥ឆ្នាំឡើងទៅតែមិនលើស៥០ឆ្នាំ មាត្រា ២៤៧ នៃក.រ។ សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន តាមរយៈការព្រមព្រៀងរវាងអ្នកឲ្យជួលអចិន្ត្រៃយ៍ និងអ្នកជួលអចិន្ត្រៃយ៍ (មាត្រា ២៤៧ កថាខណ្ឌទី ២ នៃក.រ)។ ប្រសិនបើពុំមានភាគីណាមួយបដិសេធទៅនឹងការបន្តសាជាថ្មីនៃសិទ្ធិជួលអចិន្ត្រៃយ៍ ក្នុងអំឡុងពេល ៣ ខែ (ចំពោះអាគារ) ឬ អំឡុងពេល ១ ឆ្នាំ (ចំពោះដីធ្លី) មុនផុតអំឡុងពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍ នោះសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបន្តសាជាថ្មី ជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល (មាត្រា ២៥៥, ៦១៣ នៃក.រ)។ |
| **៥- កំណត់ពេលបង់ថ្លៃឈ្នួល** | ភតិកៈត្រូវបង់តាមកាលកំណត់។បើមិនបានកំណត់ទេ ចំពោះ ចលនវត្ថុ ផ្ទះ រឺ អាគារ ត្រូវបង់ចុងខែ ចំពោះដីធ្លីត្រូវបង់ចុងឆ្នាំ។ ចំពោះវត្ថុប្រមូលផលត្រូវបង់ ក្រោយពេលប្រមូលផលមាត្រា ៦១០ នៃក.រ។ | អត្ថន័យប្រហាក់ប្រហែល ភតិសន្យាដែរ មាត្រា ២៤៨ នៃក.រ |
| **៦- សិទ្ធិទាមទារឲ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល ដោយពិចារណាលើស្ថានភាពផ្សេងៗ** | ចំពោះភតិសន្យា ពុំមានមាត្រាចែង។ | មាត្រា ២៤៩ នៃក.រ។ "ស្ថានភាព ផ្សេងៗ" រាប់បញ្ចូលទាំងការផ្លាស់ប្តូរពន្ធដែលវាយតម្លៃលើដី , ការផ្លាស់ប្តូរតម្លៃដីលើទីផ្សារ, ការផ្លាស់ប្តូរតម្លៃលើទីផ្សារជាទូទៅ, ការផ្លាស់ប្តូរតម្លៃលើទីផ្សារនៃថ្លៃឈ្នួលក្នុងតំបន់។ "ស្ថានភាពផ្សេងៗ" មិនរាប់បញ្ចូលនូវការបំផ្លាញវត្ថុជួលអចិន្ត្រៃយ៍មួយផ្នែកទេ។ ក្នុងករណីនោះ មាត្រា ៦០៧ ឬ មាត្រា ២៥១ នៃក.រ ត្រូវអនុវត្ត។ |

| | | |
|---|---|---|
| **៧- ការរំលាយដោយអ្នកជួល ដោយសារមិនទទួលបានផលចំណេញ** | ប្រសិនបើអ្នកជួល ទទួលបានប្រាក់ចំណេញ មានចំនួនតិចជាងប្រាក់ឈ្នួលក្នុងរយៈពេល២ ឬច្រើនឆ្នាំជាប់គ្នា ដោយសារករណីប្រធានសក្តិ។ មាត្រា៦០៦ កថាខណ្ឌ២ ក.រ | ១- អ្នកជួលមិនអាចទទួលបានប្រាក់ ចំណេញរយៈពេល៣ឆ្នាំដោយសារតែកាលៈទេសៈមិនអាចដឹងមុន ឬប្រធានសក្តិ។<br>២- ប្រាក់ចំណេញប្រចាំឆ្នាំមិនលើសថ្លៃឈ្នួល ១ឆ្នាំ ដោយសារការខូចខាតផ្នែកណាមួយ នៃទ្រព្យដែលជួលនោះ។ មាត្រា២៥១ក.រ |

## ៣-សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស

ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ មាត្រា ២៥៣ នៃក.រ។ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍អាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ប្រសិនបើសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានចុះបញ្ជី (មាត្រា ២៤៦ នៃក.រ)។

- ចំពោះភតិសន្យា ភតិកៈ អាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ប្រសិនបើភតិកៈបានកាន់កាប់ជាក់ស្តែងនូវវត្ថុជួល (មាត្រា ៥៩៨ កថាខណ្ឌទី ២ នៃក.រ)។

**សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ផ្អែកតាមសិទ្ធិជួលអចិន្ត្រៃយ៍**

| | | | |
|---|---|---|---|
| បានចុះបញ្ជី | | | អាចអនុវត្តបាន |
| មិនបានចុះបញ្ជី | បានកាន់កាប់ | ក្នុងអំឡុងពេល១៥ ឆ្នាំ | អាចអនុវត្តបាន |
| | | ក្រោយ ១៥ ឆ្នាំ | មិនអាចអនុវត្តបាន |
| | មិនបានកាន់កាប់ | | មិនអាចអនុវត្តបាន |

## ៤-ការធ្វើបដិទាន និងការរុះរើ នៅពេលបញ្ចប់ការជួលអចិន្ត្រៃយ៍

ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ អ្នកអោយជួលមិនអាចទាមទារការស្តារឡើងវិញនៃវត្ថុជួល មាត្រា ២៥៤ កថា១ នៃក.រ ហើយអ្នកជួលមិនអាចយកចេញឧបករណ៍ដែលបានតំឡើងដែរ ២៥៤ កថា២ នៃក.រ ចំពោះភតិសន្យា ភតិបតីអាចទាមទារការស្តារឡើងវិញវត្ថុជួល មាត្រា ៦១៨ ហើយ ភតិកៈអាចយកចេញឧបករណ៍ដែលបានតំឡើង ៦១៩ នៃក.រ។

| |
|---|
| **ការប្រៀបធៀបរវាងភតិសន្យា និងសិទ្ធិជួលអចិន្ត្រៃយ៍**<br>ភតិសន្យា (មាត្រា ៦១៨ នៃក.រ)<br>**គោលការណ៍៖** នៅពេលប្រគល់វត្ថុវិញ ត្រូវធ្វើបដិទាននូវវត្ថុដូចស្ថានភាពរបស់វត្ថុ នៅពេលដែលការកាន់កាប់វត្ថុជួលត្រូវបានផ្ទេរ។ |

| |
|---|
| **សិទ្ធិជួលអចិន្ត្រៃយ៍ (មាត្រា ២៥៤ នៃក.រ)**<br>**គោលការណ៍៖** នៅពេលប្រគល់វត្ថុ ត្រូវរក្សាទុកវត្ថុដូចស្ថានភាពបច្ចុប្បន្ន។<br>ការលើកលែង៖ ត្រូវតែជូសជុល ប្រសិនបើអ្នកជួលអចិន្ត្រៃយ៍បានធ្វើឲ្យបាក់បែកនូវអចលនវត្ថុ ឬបានផ្លាស់ប្តូរលក្ខណៈទាំងស្រុង។ |

**ភតិសន្យា**

| | វត្ថុដែលអាចរុះរើបាន | វត្ថុដែលភ្ជាប់មិនអាចរុះរើបាន ដោយគ្មានបែកបាក់វត្ថុជួល។ |
|---|---|---|
| ភតិកៈចង់រុះរើវាចេញ ប៉ុន្តែភតិបតីចង់រក្សាវាទុក | ភតិកៈអាចរុះរើបាន (មាត្រា ៦១៩) | -ភតិកៈមិនអាចរុះរើបានទេ (១៨៦, ១២៥)។<br>-ភតិកៈអាចទាមទារឲ្យសងវិញនូវសោហ៊ុយ (៦០៤ កថា ២ នៃក.រ)។ |
| ភតិកៈមិនចង់រុះរើវាចេញទេ ប៉ុន្តែភតិបតីចង់ឲ្យភតិកៈរុះរើចេញ | ភតិកៈត្រូវរុះរើចេញ (៦១៨ កថា ១) | - ភតិកៈមិនចាំបាច់រុះរើចេញទេ(១៨៦, ១២៥)<br>- ភតិកៈអាចទាមទារឲ្យសងវិញនូវសោហ៊ុយ (៦០៤ កថា ២ នៃក.រ)។ |

**សិទ្ធិជួលអចិន្ត្រៃយ៍**

| | វត្ថុដែលភ្ជាប់ជាមួយនឹងដីដែលអាចរុះរើបាន | វត្ថុភ្ជាប់ដី ដែលមិនអាចរុះរើបាន ដោយគ្មានបាក់បែកវត្ថុជួល |
|---|---|---|
| អ្នកជួលអចិន្ត្រៃយ៍ចង់រុះរើចេញ ប៉ុន្តែអ្នកឲ្យជួលអចិន្ត្រៃយ៍ចង់រក្សាទុក | -អ្នកជួលអចិន្ត្រៃយ៍មិនត្រូវរុះរើចេញទេ (២៥៤ កថា ១)។<br>-អ្នកជួលអចិន្ត្រៃយ៍មិនអាចទាមទារសំណងបានទេ (២៥៤ កថា ២)។ | -អ្នកជួលអចិន្ត្រៃយ៍មិនត្រូវរុះរើចេញទេ (២៥៤ កថា ១)។<br>-អ្នកជួលអចិន្ត្រៃយ៍មិនអាចទាមទារសំណងបានទេ (២៥៤ កថា ២)។ |
| អ្នកជួលអចិន្ត្រៃយ៍មិនចង់រុះរើចេញទេ ប៉ុន្តែអ្នកឲ្យជួលអចិន្ត្រៃយ៍ចង់ឲ្យអ្នកជួលអចិន្ត្រៃយ៍រុះរើចេញ | -អ្នកជួលអចិន្ត្រៃយ៍មិនចាំបាច់រុះរើចេញទេ (២៥៤ កថា ១)។<br>-អ្នកជួលអចិន្ត្រៃយ៍មិនអាចទាមទារសំណងបានទេ (២៥៤ កថា ២)។ | -អ្នកជួលអចិន្ត្រៃយ៍មិនចាំបាច់រុះរើចេញទេ (២៥៤ កថា ១)។<br>-អ្នកជួលអចិន្ត្រៃយ៍មិនអាចទាមទារសំណងបានទេ (២៥៤ កថា ២)។ |

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

* វត្ថុភ្ជាប់ដែលអាចរុះរើយកចេញ៖ អាគារ, រុក្ខជាតិ, ដំណាំ
* វត្ថុភ្ជាប់ដែលមិនអាចរុះរើយកចេញដោយមិនកំទេចវត្ថុជួល៖ ប្រព័ន្ធបង្ហូរទឹកស្អុយ (sewage system), ក្តារក្រាល (floorboard), ក្រដាសរចនាជញ្ជាំង (wallpaper)។

## **ជំពូក ៣. ករណីសិក្សា**

ករណីទី ១៖ ការភ្ជាប់ដែលមិនចាំបាច់

X បានជួលអចិន្ត្រៃយ៍នូវដី និងអាគារកំពស់២ជាន់ឲ្យ Y (អាគារមានតែជាន់ក្រោមដី និងជាន់ទី១ ប៉ុណ្ណោះ។ Y បានសាងសង់ និងបានបន្ថែមជាន់ទី ២ ទៅនឹងអាគារនោះ។

សំនួរទី ១៖ នៅពេលបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ តើ X អាចទាមទារឲ្យ Y រុះរើជាន់ទី ២ ចេញបានដែរ ឬទេ?

សំនួរទី ២៖ នៅពេលបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ តើ Y អាចទាមទារឲ្យ X បង់ប្រាក់សម្រាប់តម្លៃនៃជាន់ទី ២ បានដែរ ឬទេ?

ករណីទី ២៖ អាគារដែលមិនចាំបាច់

X បានជួលអចិន្ត្រៃយ៍នូវដីមួយកន្លែងឲ្យ Y។ Y បានសាងសង់អាគារមួយនៅលើដីនោះ។

សំនួរទី១៖ នៅពេលបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ តើ X អាចទាមទារឲ្យ Y រុះរើអាគារនោះចេញបានដែរ ឬទេ?

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី១

## ប្រធានបទ៖ របៀបគណនាសំណងនៃការខូចខាត

## ក្នុងករណីបំពានកិច្ចសន្យា

ថ្ងៃទី ០៦ ឧសភា ២០១៤

# របៀបគណនាសំណងនៃការខូចខាត ក្នុងករណីបំពានកិច្ចសន្យា

ការទាមទារសំណងនៃការខូចខាត គឺជាមធ្យោបាយសង្គ្រោះមួយប្រភេទ ដែលត្រូវបានទទួលស្គាល់ក្នុងករណីមានការមិនអនុវត្តកាតព្វកិច្ច (បំពានកិច្ចសន្យា) (**មាត្រា៣៩០ នៃក្រមរដ្ឋប្បវេណី**)។ ប៉ុន្តែយើងអាចនឹងមានបញ្ហាក្នុងកំណត់អំពីទស្សនៈនៃការខូចខាត ថាតើការខូចខាតបែបណាដែលចាត់ទុកជាសំណងនៃការខូចខាត ដែលម្ចាស់បំណុលអាចទាមទារបាន។ ទាំងនេះគឺជាចំណុចដែលយើងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងសិក្ខាសាលាថ្ងៃនេះ។

ដើម្បីទាមទារសំណងនៃការខូចខាត ឬ ឲ្យកូនបំណុលទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត លុះត្រាតែកូនបំណុល (១)មិនអនុវត្តកាតព្វកិច្ច (២)មានកំហុសក្នុងការមិនអនុវត្តកាតព្វកិច្ច (៣) ការខូចខាត (**មាត្រា៣៩៨ នៃក្រមរដ្ឋប្បវេណី**)។ ដោយឡែក ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ទោះបីជាកូនបំណុល គ្មានកំហុសក៏ដោយ ក៏កូនបំណុលមិនរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវបានដែរ (**មាត្រា៣៩៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី**)។ ប៉ុន្តែក្នុងករណី ការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលយឺតយ៉ាវ ក្នុងករណីដែលកូនបំណុលគ្មានកំហុស កូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត (**មាត្រា៣៩៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី**)។ ជាគោលការណ៍ ដើម្បីទាមទារសំណង ដើមចោទត្រូវលើកឡើងអំពីការខូចខាត ហេតុនេះ ទោះបីជា មានការមិនអនុវត្តកាតព្វកិច្ចដោយកំហុសរបស់កូនបំណុលក៏ដោយ ប្រសិនបើពុំមានការខូចខាតកើតឡើងទេមិនអាចទាមទារសំណងបានទេ(**មាត្រា៣៩៨នៃក្រមរដ្ឋប្បវេណី**) លើកលែងតែ មានការកំណត់ជាមុនអំពីចំនួននៃការខូចខាតដូចមានចែងនៅក្នុងមាត្រា៤០៣។ ផ្ទុយទៅវិញ ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ការបង្ហាញអំពីការខូចខាត គឺជាចំណុចដែលពិបាក ហេតុនេះ ទោះបីជាគ្មានការបង្ហាញអំពីការខូចខាតក៏ដោយ ក៏សំណងនៃការខូចខាតត្រូវបានទទួលស្គាល់ ហើយក្នុងករណី ម្ចាស់បំណុលអាចបង្ហាញអង្គហេតុអំពីការខូចខាត ម្ចាស់បំណុលអាចទាមទារការខូចខាតផ្សេងទៀតអំពីការប្រាក់យឺតយ៉ាវ (**មាត្រា៣៩៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី**)។

នេះជាល័ក្ខខ័ណ្ឌក្នុងការទាមទារសំណងនៃការខូចខាត ហើយជាចំណុចសំខាន់ ប៉ុន្តែ ប្រធានបទថ្ងៃនេះ ផ្តោតទៅលើមូលដ្ឋានក្នុងការគណនាសំណងនៃការខូចខាតប៉ុណ្ណោះ ហេតុនេះ យើងខ្ញុំមិនធ្វើការបញ្ជាក់នូវចំណុចនីមួយៗស្តីពីល័ក្ខខ័ណ្ឌដើម្បីទាមទារសំណងនៃការខូចខាតនោះទេ។

ការខូចខាតដែលត្រូវបានចាត់ទុកជាសំណងនៃការខូចខាត ត្រូវបានបញ្ញត្តិនៅក្នុងមាត្រា៤០០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែសំណងនៃការខូចខាត ដែលភាគីអាចទាមទារបាន ត្រូវបានទទួលស្គាល់តាមបញ្ញត្តិនៃមាត្រា៤០១ ចំណុចក និងខតែប៉ុណ្ណោះ។ ទោះបីជាបែបនេះក៏ដោយ ប្រសិនបើយើងពិនិត្យទៅលើបញ្ញត្តិនៃមាត្រា៤០១ ចំណុចគ មានការទទួលស្គាល់សិទ្ធិទាមទារនូវផលប្រយោជន៍បន្ថែមលើសំណងនៃការខូចខាតដែលត្រូវបានបញ្ញត្តិនៅក្នុងចំណុចក និងខ នៃមាត្រា៤០១ ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយគំនិតព្យាបាទ ឬដោយអំពើមិនស្មោះត្រង់ហួសហេតុ។ ក្រៅពីសំណងនៃការខូចខាតផ្នែកសម្ភារៈ សំណងនៃការខូចខាតផ្លូវចិត្ត ក៏ត្រូវបានទទួលស្គាល់ផងដែរ ប៉ុន្តែសំណងនៃការខូចខាតផ្លូវចិត្ត ជាចំណុចដែលពិបាកនឹងធ្វើការបញ្ជាក់ និងសម្រេច ហេតុនេះ តុលាការត្រូវសម្រេចអំពីសំណងនៃការខូចខាតផ្លូវចិត្តដោយពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ (**មាត្រា៤០០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី**)។

## ១. សំណងនៃការខូចខាតផ្នែកសម្ភារៈ

ដើម្បីគណនាសំណងនៃការខូចខាត យើងត្រូវញែករវាង ការខូចខាតទាំងអស់ដែលជាបន្ទុករបស់ម្ចាស់បំណុល និងសំណងនៃការខូចខាតដែលម្ចាស់បំណុលអាចទាមទារបាន។ ការកំណត់បែបនេះដោយសារតែទំនាក់ទំនងរវាងហេតុ និងផលកើតឡើងបន្តដោយគ្មានការកំណត់ដែលជាលទ្ធផល កូនបំណុលអាចទទួលខុសត្រូវមានទំហំធំពេក ហេតុនេះ យើងគួរកំណត់នូវសំណងនៃការខូចខាតដែលអាចទាមទារបានក្នុងកម្រិតដែលសមហេតុផល។

### ១-១ ការខូចខាតទាំងអស់ដែលជាបន្ទុករបស់ម្ចាស់បំណុល

តាមមាត្រា៤០០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ការខូចខាតដែលម្ចាស់បំណុលបាត់បង់៖

(១) ផលប្រយោជន៍ពីការអនុវត្តដែលបានស្មានទុកជាមុន

ផលប្រយោជន៍ពីការអនុវត្តដែលបានស្មានទុកជាមុន គឺជាផលប្រយោជន៍ដែលភាគីម្ខាងនឹងបានទទួលក្នុងករណីដែលភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ច។ ឧទាហរណ៍ Bទិញរថយន្តពីA ដើម្បីបំរើអាជីវកម្មរបស់ខ្លួន ប៉ុន្តែដោយសារ A មិនប្រគល់រថយន្តឲ្យ Bទេ B ត្រូវជួល រថយន្តពីCក្នុង១ថ្ងៃ ៥០ដុល្លារ។ ផលប្រយោជន៍ដែល B ទទួលបានគឺ ការប្រើប្រាស់រថយន្ត ប្រសិនបើ Aប្រគល់រថយន្តឲ្យB Bមិនចាំបាច់ចំណាយលុយជួលរថយន្តពី C ក្នុង១ថ្ងៃ ៥០ដុល្លារនោះទេ ហេតុនេះចំនួន៥០ដុល្លារក្នុង១ថ្ងៃគឺជាផលប្រយោជន៍ពីការអនុវត្តកាតព្វកិច្ចដែលបានស្មានទុកជាមុន។

(២) សោហ៊ុយចំណាយដែលគ្មានប្រយោជន៍

សោហ៊ុយចំណាយដែលគ្មានប្រយោជន៍ គឺជាការចំណាយផ្សេងៗដែលជាបន្ទុករបស់ម្ចាស់បំណុលទាក់ទងនឹងការបង្កើតកិច្ចសន្យា។ ឧទាហរណ៍ ដើម្បីចចារគ្នាអំពីការលក់រថយន្ត B ត្រូវទៅជួប A នៅខេត្តសៀមរាប ដោយត្រូវចំណាយលុយ១០០ដុល្លារ សម្រាប់ថ្លៃឡាន ហូបចុក និងស្នាក់នៅ។

(៣) បន្ទុកដែលកើនឡើង

បន្ទុកដែលកើនឡើង គឺជាការចំណាយផ្សេងៗ ដែលម្ចាស់បំណុលបានចេញដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល។ ឧទាហរណ៍ ដោយសារ Aមិនប្រគល់ រថយន្តឲ្យB ដើម្បីដោះស្រាយគ្នាពីបញ្ហានេះ Bបានណាត់ជួបចចារជាមួយA ដោយចំណាយអស់១០០ដុល្លារ ក្នុងការជួលកន្លែងដើម្បីចចារគ្នា និងត្រូវចំណាយ១០០ដុល្លារ ក្នុងការបញ្ជូនលិខិតជាលាយលក្ខណ៍អក្សរទៅ A។

## ១.២ សំណងនៃការខូចខាតដែលម្ចាស់បំណុលអាចទាមទារបាន

ចំណុចដូចបានរៀបរាប់ខាងលើគឺជាចំណាយទាំងអស់ដែលម្ចាស់បំណុលត្រូវបាត់បង់ ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ដែលយើងចាត់ទុកថាជាសំណងនៃការខូចខាត ប៉ុន្តែមិនគ្រប់សំណងនៃការខូចខាតទាំងអស់ម្ចាស់បំណុលសុទ្ធតែអាចទាមទារបាននោះទេ។ មូលហេតុដែលមានកំណត់ទំហំនៃសំណងនៃការខូចខាតដែលអាចទាមទារបាន ដោយសារតែ មានទំនាក់ទំនងហេតុ និងផលកើតឡើងបន្តដោយគ្មានព្រំដែន ហេតុនេះយើងគប្បីកំណត់នូវសំណងនៃការខូចខាតក្នុងកម្រិតដែលសមហេតុផល។ ឧទាហរណ៍ A ខកខានក្នុងការអនុវត្តកាតព្វកិច្ចប្រគល់ឡានឲ្យ B ហេតុនេះ B ត្រូវដើរទៅសាលារៀន ហើយBត្រូវម៉ូតូបុកខណៈពេលដើរទៅសាលា Bរងរបួសស្រាល។ Bបានសម្រាកនៅមន្ទីរពេទ្យ ប៉ុន្តែដោយសារ ការចេញថ្នាំឲ្យប្រើប្រាស់ខុស Bត្រូវសម្រាកនៅក្នុងមន្ទីរពេទ្យអស់រយៈពេល៦ខែ។ ការសម្រាករយៈពេលយូរ B ត្រូវបានក្រុមហ៊ុនបណ្តេញចេញពីការងារ ហើយការបណ្តេញចេញនេះធ្វើឲ្យស្ថានភាពគ្រួសាររបស់ B គ្មានលំនឹងចុងបញ្ចប់ B ត្រូវលែងលះ។ ដោយសារមានការរន្ធត់ចិត្តយ៉ាងខ្លាំង

ដោយសារ ការលែងលះ B ក្លាយជាមនុស្សឆ្កួត ហើយបានសម្លាប់ X។ អង្គហេតុទាំងនេះ មើលទៅហាក់ដូចជាសំណងនៃការខូចខាតដែលBទទួលរង ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់Aដូចមានបញ្ញត្តិនៅក្នុងមាត្រា៤០០ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែវាហាក់ដូចជាមានទំហំធំពេក ហេតុនេះការកំណត់អំពីសំណងដែលអាចទាមទារបាន គួរដែលមានលក្ខណៈសមហេតុផល។ ការខូចខាតដែលម្ចាស់បំណុលអាចទាមទារបានត្រូវបានបញ្ញត្តិនៅក្នុងមាត្រា៤០១ ចំណុច ក និងខ នៃក្រមរដ្ឋប្បវេណីគឺការខូចខាតធម្មតា និងការខូចខាតពិសេសដែលគូភាគីអាចព្យាករបាន។

**ក- សំណងនៃការខូចខាតធម្មតា**

ការខូចខាតធម្មតា គឺជាការខូចខាតដែលកើតឡើងជាធម្មតាចំពោះម្ចាស់បំណុលដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល(**មាត្រា៤០១ចំណុចក នៃក្រមរដ្ឋប្បវេណី**)។ ឧទាហរណ៍ ដោយសារ A ខកខានក្នុងការប្រគល់រថយន្ត B ត្រូវជួលរថយន្តពី C ថ្លៃឈ្នួលរថយន្ត គឺជាការខូចខាតធម្មតា។ ឧទាហរណ៍ ដោយសារតែ X ខកខានក្នុងការប្រគល់ផ្ទះឲ្យ Y Y ត្រូវស្នាក់នៅសណ្ឋាគារ ថ្លៃឈ្នួលសណ្ឋាគារ គឺជាការខូចខាតធម្មតា។ ឧទាហរណ៍ ដោយសារ E ខកខានប្រគល់រថយន្តឲ្យ F F មិនអាចយករថយន្តជួលបន្តបាន (អាជីវកម្មជួល រថយន្ត) ប្រាក់ចំនេញពីការជួលរថយន្តបន្ត គឺជាការខូចខាតធម្មតា។

**ខ- សំណងនៃការខូចខាតពិសេស**

ការខូចខាតពិសេស គឺជាការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុលដោយសារ កាលៈទេសៈពិសេស ហើយគូភាគីនៃកិច្ចសន្យាអាចព្យាករណ៍បាននូវការខូចខាតនោះដែលនឹងអាចកើតឡើងនៅពេលធ្វើកិច្ចសន្យា។ ឧទាហរណ៍ AនិងBបានបង្កើតកិច្ចសន្យាលក់ទិញ រថយន្តក្នុងតម្លៃ១.០០០ដុល្លារ។ B បានចុះកិច្ចសន្យាលក់រថយន្តបន្តឲ្យទៅ C ក្នុងតម្លៃ ១.១០០ដុល្លារ A ខកខានប្រគល់រថយន្ត B នៅថ្ងៃកំណត់ នាំឲ្យ B មិនអាចអនុវត្តកាតព្វកិច្ចទាន់ពេលវេលាចំពោះCបាន ហេតុនេះ C រំលាយកិច្ចសន្យា តើ B អាចទាមទារប្រាក់ចំនេញ ១០០ដុល្លារពី A បានដែរឬទេ? កិច្ចសន្យារវាង B និងC គឺជាកាលៈទេសៈពិសេសដែលមានបញ្ញត្តិនៅក្នុងមាត្រា៤០១ចំណុចខនៃក្រមរដ្ឋប្បវេណីដូច្នោះBអាចទាមទារប្រាក់ចំនេញ ១០០ដុល្លារដែលបានបាត់បង់ លុះត្រាតែ A អាចព្យាករបាននូវការបាត់បង់ប្រាក់ចំនេញរបស់ B។

**គ- ផលប្រយោជន៍ក្រៅពីសំណងនៃការខូចខាត**

ក្រៅពីសំណងនៃការខូចខាតធម្មតា និងសំណងនៃការខូចខាតពិសេសដែលភាគីអាចព្យាករណ៍បាន ផលប្រយោជន៍ដែលកូនបំណុលទទួលបានលើសពីធម្មតា គឺជាផលប្រយោជន៍ដែលម្ចាស់បំណុលអាចទាមទារបាន ក្នុងករណីដែលការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ដោយមានឆន្ទៈព្យាបាទ ឬដោយអំពើមិនស្មោះត្រង់ហួសហេតុ (**មាត្រា៤០១ ចំណុចគ នៃក្រមរដ្ឋប្បវេណី**)។ ឧទាហរណ៍ A បានលក់មាន់ឈឺឲ្យBក្នុងគោលបំណងចង់ឲ្យកសិដ្ឋានចិញ្ចឹមមាន់របស់B ត្រូវបរាជ័យ មាន់ក្នុងកសិដ្ឋានរបស់B ត្រូវឆ្លងជម្ងឺ ហើយងាប់ទាំងអស់ ការខូចខាតទាំងអស់ត្រូវបាត់បង់ គឺ ប្រាក់ចំនេញពីការលក់មាន់ ការខាតបង់របស់ B ក្នុងការខកខានប្រគល់មាន់ទៅអតិថិជន(**មាត្រា៤០១ ចំណុច ក និងខ នៃក្រមរដ្ឋប្បវេណី**)។ ដោយសារតែ ការមិនអនុវត្ត កាតព្វកិច្ចរបស់A មានគំនិតព្យាបាទ ហេតុនេះ Bអាចទាមទារផលប្រយោជន៍ដែល A បានទទួលពីអំពើ ព្យាបាទនោះ។ ផលប្រយោជន៍នោះ រួមមាន ប្រាក់ចំនេញ ដែលបានទទួល

តាម រយៈការលក់ឡើងថ្លៃ ឬទទួលការបញ្ញាទិញច្រើនជាងមុន។ ឧទាហរណ៍ ជាធម្មតា កសិដ្ឋានរបស់ A រកចំណូលបាន៣០០០ដុល្លារក្នុង១ខែ ប៉ុន្តែបន្ទាប់ពីមាន់របស់ B ងាប់អស់ កសិដ្ឋានរបស់ A អាចរកចំណូលដល់៥០០០ដុល្លារក្នុង១ខែ ករណីនេះ B អាចទាមទារ២០០០ដុល្លារដែលផលប្រយោជន៍ ក្រៅពីសំណងនៃការខូចខាត។

## ១.៣ ការគណនាផលប្រយោជន៍ដែលរំពឹងទុកពីការអនុវត្ត

ម្ចាស់បំណុល អាចទាមទារសំណងនៃការខូចខាតដែលជាផលប្រយោជន៍ ដែលបាត់បង់បង់ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល (មាត្រា៤០០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ផលប្រយោជន៍ដែលបាត់បង់ គឺជាការបាត់បង់តម្លៃនៃកម្មវត្ថុ និងតម្លៃនៃការប្រើប្រាស់កម្មវត្ថុ។

### ក- គណនាតម្លៃនៃកម្មវត្ថុដែលបាត់បង់

ការគណនាសំណងនៃការខូចខាតជាក់ស្តែង ក្នុងករណីតម្លៃនៃកម្មវត្ថុដែលបាត់បង់ មានរូបមន្តដោយស្របតាមករណីដូចខាងក្រោមៈ

(១) ក្នុងករណីម្ចាស់បំណុលមានគោលបំណងរក្សាទុកកម្មវត្ថុ រូបមន្តនៃការគណនា

| |
|---|
| **តម្លៃទីផ្សារ - តម្លៃក្នុកិច្ចសន្យា =ចំនួននៃសំណងនៃការខូចខាត** |

ឧទាហរណ៍ Aបានចុះកិច្ចសន្យាទិញដីពីB ក្នុងតម្លៃ ១០០០០ដុល្លារ ក្នុងគោលបំណងរស់នៅ ប៉ុន្តែដោយសារB មិនប្រគល់ដី នាំឲ្យA មិនអាចទទួលបានដីនោះ ទេ ឥឡូវដីនេះ មានតម្លៃកើនឡើង ៣០០០០ដុល្លារ ករណីនេះ សំណងនៃការខូចខាតជាក់ស្តែង គឺ

| |
|---|
| ៣០០០០-១០០០០= ២០០០០ |

(២) ក្នុងករណី ម្ចាស់បំណុលមានគោលបំណងលក់បន្តនូវកម្មវត្ថុ រូបមន្តនៃការគណនា

| |
|---|
| **តម្លៃនៃការលក់បន្ត- តម្លៃនៅក្នុងកិច្ចសន្យា= ចំនួននៃការខូចខាត** |

ឧទាហរណ៍ X (ហាងលក់រាយ)បានចុះកិច្ចសន្យាទិញឡានពីក្រុមហ៊ុនY ក្នុងតម្លៃ ២០០០០ដុល្លារ X អាចលក់បន្តក្នុងមួយគ្រឿងតម្លៃ២៤០០០ដុល្លារ ប៉ុន្តែដោយសារY មិនប្រគល់ឡានហេតុនេះ Xមិនអាចលក់បន្តបានទេ ករណីនេះ សំណានៃការខូចខាតគឺ

| |
|---|
| ២៤០០០- ២០០០០ =៤០០០ |

(៣) ក្នុងករណីម្ចាស់បំណុលទិញវត្ថុជំនួសពីតតិយជន រូបមន្តនៃការគណនា

| |
|---|
| **តម្លៃទិញវត្ថុជំនួសកម្មវត្ថុ - តម្លៃក្នុងកិច្ចសន្យា= ចំនួននៃការខូចខាត** |

ឧទាហរណ៍ Oបានចុះកិច្ចសន្យាទិញដីពីPក្នុងគោលបំណងបើកភោជនីយដ្ឋាន តម្លៃ៤០០០០ ដុល្លារ ប៉ុន្តែដោយសារ Pមិនប្រគល់ដី Oបានចុះកិច្ចសន្យាទិញដីក្បែរនោះពីQ ក្នុងតម្លៃ ៤៥០០០ ដុល្លារ ករណីនេះ សំណងនៃការខូចខាត គឺ

| |
|---|
| ៤៥០០០ - ៤០០០០= ៥០០០ |

**ខ- ការគណនាតម្លៃនៃការប្រើប្រាស់ដែលបាត់បង់**

ការគណនាតម្លៃនៃការប្រើប្រាស់ដែលបាត់បង់ ផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

(១) ក្នុងករណីម្ចាស់បំណុលមានបំណងប្រើប្រាស់កម្មវត្ថុសម្រាប់រកផលប្រយោជន៍ ការគណនាសំណង គឺ ប្រាក់ចំណូលដែលបានបាត់បង់។

ឧទាហរណ៍ D អ្នកបើកតាក់ស៊ី ក្នុង១ថ្ងៃរកចំណូលបានពី១០០ទៅ១៥០ដុល្លារ។ ដោយសារឡានរបស់ខូច គាត់បានចុះកិច្ចសន្យាទិញរថយន្តថ្មីEដើម្បីបំរើឲ្យការងាររបស់គាត់ ប៉ុន្តែ Eមិនប្រគល់រថយន្តមកឲ្យD នាំឲ្យគាត់មិនអាចដឹកភ្ញៀវ និងបាត់បង់ប្រាក់ចំណូល សំណងនៃការខូចខាតករណីនេះ គឺ ចំណូលប្រចាំថ្ងៃរបស់D (១០០ដុល្លារក្នុងមួយថ្ងៃ)។

(២) ក្នុងករណីដែលម្ចាស់បំណុលបានចំណាយសោហ៊ុយជំនួសការប្រើប្រាស់កម្មវត្ថុ ការគណនាសំណង គឺចំនួននៃសោហ៊ុយចំណាយសម្រាប់ប្រើប្រាស់។

ឧទាហរណ៍ Fចុះកិច្ចសន្យាទិញរថយន្តពីG ដើម្បីបំរើឲ្យអាជីវកម្មសំអាងការរបស់គាត់ ប៉ុន្តែ G មិនប្រគល់រថយន្ត ហេតុនេះដើម្បីដំណើរការអាជីកម្មបាន F បានជួលរថយន្តពីH ដោយចំណាយក្នុង១ថ្ងៃអស់១០០ដុល្លារ សំណងនៃការខូចខាតករណីនេះគឺសោហ៊ុយដែលបានចេញជំនួសការប្រើប្រាស់រថយន្ត (១០០ដុល្លារក្នុងមួយថ្ងៃ)។

<u>**បព្រួញមូលដ្ឋាននៃសការគណនាសំណងនៃការខូចខាតផ្នែកសម្ភារៈ**</u>




## ២ សំណងនៃការខូចខាតផ្លូវចិត្ត

ក្រៅពីសំណងនៃការខូចខាតផ្នែកសម្ភារៈ ក្រមរដ្ឋប្បវេណីកម្ពុជា ទទួលស្គាល់ផងដែរ។ នៅសំណងនៃការខូចខាតផ្លូវចិត្តក្នុងករណីបំពានកិច្ចសន្យា (**មាត្រា៤០០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី**)។ ឧទាហរណ៍ Aបានឲ្យលុយ Bខ្ចី ចំនួន១.០០០ដុល្លារ សន្យាថា សងនៅថ្ងៃទី ១០/០៤/២០១៣។ តាមពិត Aជាមនុស្សដែលមិនសូវមានទ្រព្យធនទេ គាត់មិនសូវចង់ឲ្យBខ្ចីនោះទេ ពីព្រោះចំនួនទឹកប្រាក់នេះគាត់ទុក ចាត់ចែងដើម្បីជួសជុលផ្ទះរបស់គាត់ ប៉ុន្តែដោយសារ យោគយល់ Bជាមិត្តភ័ក្តនឹងគ្នាយូរឆ្នាំ និងការសន្យារបស់B គាត់ក៏សុខចិត្តឲ្យBខ្ចីលុយ។ ដល់កំណត់សងបានមកដល់ Bមិនអនុវត្តកាតព្វកិច្ចទេ Aមានការខូចចិត្ត យ៉ាងខ្លាំងរហូតដល់ធ្លាក់ខ្លួនឈឺ ដោយសារ គាត់គិតថា អស់រយៈពេល

ច្រើនខែហើយ មិនព្រមសងប្រាក់គាត់ គាត់គ្មានលុយដើម្បីជួសជុលផ្ទះ។ ក្នុងករណីនេះ ក្រៅពីសំណងនៃការខូចខាត ដែលបណ្ដាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់B Aអាចទាមទារសំណងជម្ងឺចិត្តបាន។

ការទាមទារសំណងនៃការខូចខាតផ្លូវចិត្តក៏មិនខុសគ្នានឹងការទាមទារសំណងនៃការខូចខាតផ្នែកសម្ភារៈនោះទេពោលគឺ ត្រូវគោរពនូវល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា៣៩៨ នៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែសំណងនៃការខូចខាតផ្លូវចិត្តពុំមានការបែងចែកច្បាស់លាស់ពីសំណងនៃការខូចខាតធម្មតា និងសំណងនៃការខូចខាតពិសេសដូចសំណងនៃការខូចខាតផ្នែកសម្ភារៈនោះទេ ហេតុនេះគ្មានការបែងចែកច្បាស់លាស់រវាងសំណងនៃការខូចខាតផ្លូវចិត្តទាំងអស់ និងសំណងនៃការខូចខាតផ្លូវចិត្តដែលអាចទាមទារបាននោះទេ មានន័យថា ឲ្យតែត្រូវល័ក្ខខ័ណ្ឌនៃមាត្រា៣៩៨ នៃក្រមរដ្ឋប្បវេណី សំណងនៃការខូចខាតផ្លូវចិត្តអាចទាមទារបានដោយពុំចាំបាច់កំណត់នូវចំនួនជាក់លាក់ទេ។ ទោះបីជាដើមចោទត្រូវទាមទារសំណងនៃការខូចខាតផ្លូវចិត្តនៅតុលាការក៏ដោយ ក៏ដើមចោទមិនចាំបាច់បញ្ជាក់ពីចំនួនសំណងនៃការខូចខាតផ្លូវចិត្ត និងលទ្ធភាពនៃការព្យាករណ៍នោះទេ។

ចំនួនសំណងនៃការខូចខាតផ្លូវចិត្ត គឺជាចំណុចដែលពិបាកក្នុងការកំណត់ ពីព្រោះ ការឈឺចាប់ផ្នែកផ្លូវចិត្តជាចំណុចអរូបីដែលយើងមិនអាចមើលឃើញ ហេតុនេះ ចំនួននៃការ ខូចខាតផ្លូវចិត្ត តុលាការត្រូវសម្រេចដោយផ្អែកលើកាលៈទេសៈជុំវិញផ្សេងៗ (មាត្រា៤០០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

| តារាងស្ដីពីសំណងនៃការខូចខាត ដែលម្ចាស់បំណុល អាចទាមទារបាន | |
|---|---|
| ការខូចខាតធម្មតា<br>(មាត្រា៤០១ ចំណុចក) | (១) ផលប្រយោជន៍ពីការអនុវត្ត<br>(២) ចំណាយដែលគ្មានប្រយោជន៍<br>(៣) បន្ទុកដែលកើនឡើង |
| ការខូចខាតពិសេស<br>ដែលអាចព្យាករណ៍បាន<br>(មាត្រា៤០១ ចំណុចខ) | (១) ផលប្រយោជន៍ពីការអនុវត្ត<br>(២) ចំណាយដែលគ្មានប្រយោជន៍<br>(៣) បន្ទុកដែលកើនឡើង |
| ផលប្រយោជន៍ក្រៅពី<br>សំណងនៃការខូចខាត<br>(មាត្រា៤០១ ចំណុចគ) | |
| សំណនៃការខូចខាតផ្លូវចិត្ត<br>(មាត្រា៤០០ កថាខណ្ឌទី២) | |

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី២

## ប្រធានបទ៖ អំពើអនីត្យានុកូលការគណនាសំណាងនៃខូចខាត

ថ្ងៃទី ០៥ មិថុនា ២០១៤

# អំពើអនីត្យានុកូល
# ការគណនាសំណងនៃការខូចខាត

## ១. ទស្សនាទាននៃអំពើអនីត្យានុកូល

(១)នៅពេលដែលមានអង្គហេតុមួយកើតឡើងរវាងភាគីដែលពុំមានទំនាក់ទំនងគតិយុត្តជាមួយគ្នាជាមុន ដូចជាទំនាក់ទំនងនៃកិច្ចសន្យាជាអាទិ៍ ដោយភាគីបានប្រព្រឹត្តអំពើណាមួយ បណ្ដាលឲ្យភាគីម្ខាងទៀតទទួលរងនូវការខូចខាត (ជនរងគ្រោះ) នាំឲ្យចារីត្រូវ ទទួលខុសត្រូវចំពោះការខូចខាតនោះ ករណីនេះ ហៅថាការទទួលខុសត្រូវចំពោះសំណង នៃការខូចខាតដោយផ្អែកលើ<u>អំពើអនីត្យានុកូល</u>។ អំពើអនីត្យានុកូល គឺជាអំពើបំពានច្បាប់ ឬសិទ្ធិ-ផលប្រយោជន៍អ្នកដទៃ។

(២) ក្រៅពីការទទួលខុសត្រូវចំពោះកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យា ភាគីនឹងអាចទទួលខុសត្រូវចំពោះកាតព្វកិច្ចផ្សេងៗទៀត ដែលច្បាប់បានបញ្ញត្តិ ដូចជាករណី អំពើអនីត្យានុកូល ឬសេចក្ដីចម្រើនដោយឥតហេតុ ជាអាទិ៍។ ប្រសិនបើមិនបញ្ញត្តិអំពីកាតព្វកិច្ច តាមច្បាប់ នឹងនាំឲ្យ នៅពេលមានការខូចខាតកើតមានឡើង គឺគ្មានអ្នកទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានការបំពាន ខ្វះការប្រុងប្រយ័ត្ន គ្មានហេតុតាមផ្លូវច្បាប់ ក៏ទទួលបាន ផលប្រយោជន៍ ឬរស់នៅក្នុងសង្គមខ្វះការលើកទឹកចិត្តក្នុងការជួយគ្នាទៅវិញទៅមក។

(៣) នៅក្នុងស្ថានភាពខ្លះ គប្បីធ្វើការបែងចែកឲ្យបានច្បាស់លាស់រវាងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ជាពិសេសការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ដោយហេតុថា គោលដៅនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជាទណ្ឌកម្មចំពោះបុគ្គលដែលបង្កឲ្យមានការអន្តរាយ និងស្ដារឡើងវិញនូវសណ្ដាប់ធ្នាប់សាធារណៈ (ផលប្រយោជន៍សាធារណៈ) រីឯគោលដៅនៃការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី រាប់បញ្ចូលទាំងការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល គឺជាសំណងនៃការខូចខាត ដែលជាគោលការណ៍ គឺជាប្រាក់ដែលត្រូវបង់ដោយចារីទៅឲ្យជនរងគ្រោះ (ផលប្រយោជន៍ឯកជន)។

(៤) អំពើអនីត្យានុកូលអាចវិវត្តន៍ទៅជាបទល្មើសព្រហ្មទណ្ឌ ហើយបទល្មើសព្រហ្មទណ្ឌគឺជាផ្នែកមួយនៃអំពើអនីត្យានុកូល ប៉ុន្តែមិនមែនគ្រប់អំពើអនីត្យានុកូល គឺជាបទល្មើសព្រហ្មទណ្ឌនោះទេ ដូចជាអំពើរំលោភបំពានសិទ្ធិបុគ្គល ដោយគ្មានបរិស្ថានជុំវិញល្អ ដោយខ្វះពន្លឺព្រះអាទិត្យ ដោយសម្លេងរំខាន ឬ

ធ្វេសប្រហែសក្នុងការលើកទូរទស្សន៍ បណ្ដាលឲ្យបាក់បែក ជាដើម គឺអំពើអនីត្យានុកូល មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។

(៥) អំពើអនីត្យានុកូលត្រូវបានបែងចែកជាពីរប្រភេទគឺ<u>**អំពើអនីត្យានុកូលទូទៅ**</u> និង<u>**អំពើអនីត្យានុកូលពិសេស**</u> ហើយប្រសិនបើអំពើអនីត្យានុកូលនោះប្រព្រឹត្តដោយមនុស្សច្រើននាក់ យើងហៅថា<u>**អំពើអនីត្យានុកូលរួម**</u> ហេតុនេះអ្នកប្រព្រឹត្តអំពើអនីត្យានុកូល ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព។ អំពើអនីត្យានុកូលទូទៅ ជាការបំពានច្បាប់ ឬសិទ្ធិ-ផលប្រយោជន៍របស់អ្នកដទៃ ដោយចំណុះឲ្យល័ក្ខខ័ណ្ឌកំហុស ប៉ុន្តែអំពើអនីត្យានុកូលពិសេស ជាអញ្ញត្រកម្មដោយមិនចំណុះល័ក្ខខ័ណ្ឌកំហុសនោះទេ និងត្រូវបានច្បាប់បញ្ញត្តិជាក់លាក់ ដូចជា ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់, សំណង់ដែលជាប់នឹងដី, អ្នកកាន់កាប់សត្វ ឬអំពើអនីត្យានុកូលរបស់មន្ត្រីរាជការ ជាអាទិ៍។

(៦) នៅពេលដែលមានអំពើអនីត្យានុកូលកើតឡើង ដើម្បីអាចទាមទារសំណងបាន លុះត្រាតែមានការខូចខាតកើតឡើង មានន័យថា ប្រសិនបើគ្មានការខូចខាតកើតឡើង មិនអាចទាមទារសំណងនៃការខូចខាតផ្អែកលើអំពើអនីត្យានុកូលនោះទេ ដូចជា A មានបំណងចាក់ B ប៉ុន្តែ ដោយសារ B បានដឹងខ្លួនមុន ហេតុនេះ B គ្មានរបួសនោះទេ ហើយ A ក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួន។

(៧) សំណងនៃការខូចខាតនៅក្នុងអំពើអនីត្យានុកូលត្រូវបានទទួលស្គាល់ក្រោម រូបភាពពីរបែប គឺសំណងនៃការខូចខាតផ្នែកសំភារៈ និងសំណងនៃការខូចខាតផ្លូវចិត្ត។

## ២. ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល

### ក.ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវ

+កំហុស ៖ ដើម្បីកំណត់អំពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលគឺទាមទារឲ្យមានកំហុសនៅពេលមានព្យសនកម្មកើតមានឡើង ហើយកំហុស គឺជាស្ថានភាពផ្លូវចិត្តរបស់បុគ្គលម្នាក់ៗដោយខ្លួនអាចយល់ដឹងអំពីអំពើនោះ និងលទ្ធផលដែលកើតចេញពីអំពើរបស់ខ្លួន។ កំហុសមានពីរប្រភេទ គឺកំហុសចេតនា និងកំហុសអចេតនា ដោយកំហុសចេតនា ជាការប្រព្រឹត្តអំពើណាមួយដោយបុគ្គលនោះអាចយល់ដឹង ឬព្យាករណ៍ទុកជាមុនបានអំពីលទ្ធផលនៃអំពើរបស់ខ្លួន ថានឹងអន្តរាយដល់អ្នកដទៃ ចំណែកឯ កំហុសអចេតនា គឺជាការបំពានករណីយកិច្ចប្រុងប្រយ័ត្ន មិនយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចដែលច្បាប់កំណត់។ ជាគោលការណ៍ជនដែលបំពានលើសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃទោះបីជាសំភារៈ ឬស្មារតីបុគ្គលនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដោយសារកំហុសរបស់ខ្លួន ប៉ុន្តែមានករណីខ្លះជាអញ្ញត្តិកម្មដោយមិនចំណុះឲ្យកំហុសនោះទេ ដូចជាអំពើអនីត្យានុកូល ដែលកើតចេញពីគ្រោះថ្នាក់ចរាចរណ៍បរិស្ថាន

ឬផលិតកម្ម ជាអាទិ៍។ កាតព្វកិច្ចបញ្ជាក់កំហុស ជាបន្ទុករបស់ជនរងគ្រោះ លើកលែងតែ កំហុសអាចមើលឃើញច្បាស់សម្រាប់ហេតុការណ៍ណាមួយ កាតព្វកិច្ចក្នុងការបញ្ជាក់គ្មានកំហុស ត្រូវធ្លាក់ទៅលើចារីវិញ (ករណីបំពុលបរិស្ថាន ដោយរោងចក្រស្លដែក ជាអាទិ៍)។

+**សមត្ថភាពទទួលខុសត្រូវ** ៖ សមត្ថភាពទទួលខុសត្រូវគឺជាលក្ខខ័ណ្ឌមួយទៀត ក្នុងការឲ្យបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ហើយបុគ្គលដែលច្បាប់ទទួលស្គាល់ថាមានសមត្ថភាពទទួលខុសត្រូវ គឺជាបុគ្គលដែលមានសមត្ថភាពយល់ដឹង និងមានសេរីភាពក្នុងការប្រព្រឹត្តអំពើនោះ ដោយហេតុថា ជនដែលមានអាយុក្រោម ១៨ (ដប់បួន) ឆ្នាំ ឬ ជនដែលមានស្ថានភាពមិនអាចយល់ដឹង-វិនិច្ឆ័យ ដោយសារវិបត្តិស្មារតី ឬហេតុផ្សេងទៀត មិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះទេ។

+**ចរិកផ្ទុយច្បាប់នៃអំពើបំពាន** ៖គឺជាអំពើបំពានសិទ្ធិឬផលប្រយោជន៍របស់អ្នកដទៃ ហើយបង្កឲ្យមានការអន្តរាយដោយសារតែអំពើនោះ ឬជាការប្រើប្រាស់សិទ្ធិដោយបំពានជាអាទិ៍។ សកម្មភាពនៃការបំពាន អាចស្តែងចេញតាមរយៈរូបភាព ០២ (ពីរ)រូបភាព ទី១គឺសកម្មភាពជាក់ស្តែងនៃការប្រព្រឹត្ត ទី២គឺរូបភាពអកម្ម ដូចជាបុគ្គលនោះមិនធ្វើអំពើណាមួយដែលជាកាតព្វកិច្ចរបស់ខ្លួន ឬជាការកំណត់របស់ច្បាប់ បណ្តាលឲ្យខូចខាតផលប្រយោជន៍របស់អ្នកដទៃ ហើយកម្មវត្ថុនៃការបំពានអាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬសិទ្ធិក្រៅពីទ្រព្យសម្បត្តិ។ អំពើរំលោភបំពានត្រូវបែងចែកជា០៤(បួន)រូបភាពដូចជាអំពើបំពានលើបទបញ្ញត្តិច្បាប់ អំពើបំពានលើសណ្តាប់ធ្នាប់សាធារណៈ ការប្រើប្រាស់សិទ្ធិដោយបំពាន និងការអន្តរាយដល់តតិយជនដោយសារវិការៈនៃវត្ថុ។ អំពើបំពានលើបទបញ្ញត្តិច្បាប់ គឺជាការបំពានសិទ្ធិ និងផលប្រយោជន៍របស់អ្នកដទៃ ដែលត្រូវបានការពារដោយច្បាប់ រីឯអំពើបំពានទៅលើសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌សង្គមវិញ គឺជាស្ថានភាពជាក់ស្តែងនៃការបំពាននោះ ដោយនៅក្នុងច្បាប់មិនមានបញ្ញត្តិ ប៉ុន្តែសង្គមចាត់ទុកអំពើនោះថាមិនត្រឹមត្រូវ ហើយចំពោះការប្រើប្រាស់សិទ្ធិដោយបំពានគឺជាស្ថានភាពនៃសិទ្ធិទទួលបានពន្លឺព្រះអាទិត្យ សិទ្ធិទទួលបាននូវបរិស្ថានល្អជុំវិញអាគារខ្ពស់ស៊ីមស្តែ អាកាសយានដ្ឋាន ចំណតរថយន្ត ជាអាទិ៍ រីឯការអន្តរាយដល់តតិយជនបង្កឡើងដោយវិការៈវត្ថុ ដូចជា ការទទួលខុសត្រូវរបស់ផលិតករចំពោះវត្ថុដែលមានគ្រោះថ្នាក់បង្កឲ្យមានគ្រោះថ្នាក់ដល់តតិយជន ដូចជាគ្រឿងចក្រ ឧបករណ៍ប្រើប្រាស់ ឬឱសថជាអាទិ៍ ដែលបង្កឲ្យមានការខូចខាតដល់អ្នកប្រើប្រាស់ជាដើម។

+**ព្យសនកម្ម** ៖ ទោះបីជាមានអំពើបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ ប្រសិនបើពុំមានព្យសនកម្មកើតឡើងនោះទេ គឺគ្មានការទទួលខុសត្រូវចំពោះសំណងនៃ

ការខូចខាតនោះទេ ដោយព្យសនកម្មនេះអាចជា ព្យសនកម្មទៅលើទ្រព្យសម្បត្តិ ឬ/និង សតិអារម្មណ៍។

+**ទំនាក់ទំនងហេតុផលរវាងអំពើបំពាន និងព្យសនកម្ម៖** ការទទួលខុសត្រូវចំពោះសំណងនៃការខូចខាត នៅពេលដែលមានទំនាក់ទំនងច្បាស់លាស់ជាក់លាក់ រវាងអំពើបំពានសិទ្ធិ និងព្យសនកម្ម ដោយអ្នកទាមទារមានករណីយកិច្ចបង្ហាញ មានន័យថា ព្យសនកម្មត្រូវតែកើតចេញដោយផ្ទាល់ពីអំពើរបស់ចារី ចំពោះជនរងគ្រោះទៅលើទ្រព្យសម្បត្តិ ឬក្រៅទ្រព្យសម្បត្តិ (រូបរាងកាយ ឬអាយុជីវិត)។

## ខ.លក្ខខណ្ឌនៃការបន្ថយការទទួលខុសត្រូវ

ប្រសិនបើចារីបានប្រព្រឹត្តអំពើអនីត្យានុកូល ប៉ុន្តែបានបំពេញលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌខាងក្រោមនេះ ចារីនឹងត្រូវបន្ថយការទទួលខុសត្រូវចំពោះអំពើ អនីត្យានុកូល ដែលបានកើតឡើង។

+**ធានារ៉ាប់រងសង្គម និងប្រាក់ចំណេញ**

ប្រសិនបើជនរងគ្រោះ ឬក្រុមគ្រួសារបានទទួលប្រាក់ធានារ៉ាប់រងសង្គម ការទទួលខុសត្រូវនឹងត្រូវបានបន្ថយ ឬ/និងជនរងគ្រោះបានទទួលផលចំណេញពីអំពើអនីត្យានុកូល ប្រាក់ចំណេញ ត្រូវបានដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត។ ករណីនេះ មានដូចជា ប្រសិនបើជនរងគ្រោះបានស្លាប់ នាំឲ្យចំណាយនាពេលអនាគតសម្រាប់ ជនរងគ្រោះគ្មាន ហេតុនេះចំនួនទឹកប្រាក់សន្មតមួយនៃការចំណាយសម្រាប់ការរស់នៅនាពេលអនាគត នឹងត្រូវបានបន្ថយចំនួនទឹកប្រាក់នៃសំណង។

+**កំហុសរួមរបស់ចារីនិងជនរងគ្រោះ**

ប្រសិនបើអ្នកបើកបរបានបើកបរក្នុងស្ថានភាពស្រវឹង ឬមានជាតិអាកុលដែលច្បាប់កម្រិត (A) បន្ទាប់មកក៏ជួបគ្រោះថ្នាក់ចរាចរណ៍ ដោយភាគីម្ខាងទៀត (B) បើកបរហួសល្បឿនកំណត់ និងបានបុក (A) បណ្តាលឲ្យរងរបួស ឬ (A) បានដើរឆ្លងផ្លូវដោយមិនគោរពភ្លើងសញ្ញាចរាចរណ៍ ហើយ (B) បានបើកបរក្នុងល្បឿនលើសកំណត់ ជាអាទិ៍។

**+ការព្រមព្រៀងរបស់ចារី និងជនរងគ្រោះ**

ប្រសិនបើអំពើអនីត្យានុកូលកើតមានឡើង ជនរងគ្រោះ និងអ្នកប្រព្រឹត្តអំពើអនីត្យានុកូល បានព្រមព្រៀងគ្នាអំពីចំនួននៃសំណង ទោះបីចំនួននៃសំណងនោះមិនឆ្លើយតបឬមិនសមស្របនឹងការខូចខាតក៏ដោយ ក៏អនុវត្តបានផងដែរ ប្រសិនបើផ្អែកលើឆន្ទៈពិតប្រាកដ របស់ភាគី ពីព្រោះនេះជាការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។

គ.ល័ក្ខខ័ណ្ឌនៃការមិនទទួលខុសត្រូវ

ប្រសិនបើចារីបានប្រព្រឹត្តអំពើអនីត្យានុកូល ប៉ុន្តែបានបំពេញល័ក្ខខ័ណ្ឌណាមួយ ក្នុងចំណោមល័ក្ខខ័ណ្ឌខាងក្រោម ចារីនឹងមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល។

**+កិច្ចការពារជាធម្មានុរូប ៖** គឺជាអំពើរំលោភបំពានដែលមិនអាចជៀសវាងបានដើម្បីការពារខ្លួន ឬទ្រព្យ សម្បត្តិរបស់ខ្លួន ឬអ្នកដទៃ ចំពោះអំពើបំពានដោយមិនត្រឹមត្រូវ ស្ថិតនៅក្នុងករណីដែលអំពើបំពាន និងអំពើ រំលោភនោះស្ថិតជិតគ្នា និងមានកម្រិតតុល្យភាពគ្នារវាងការការពារ និងការបំពាន។ កិច្ចការពាជាធម្មានុរូបពុំត្រូវ បានចាត់ទុកថាជាអំពើបំពានដោយខុសច្បាប់ឡើយ ដោយហេតុថា បុគ្គលដែលបានប្រព្រឹត្តអំពើនេះត្រូវបានច្បាប់ អនុញ្ញាតដើម្បីកុំឲ្យមានព្យសនកម្មធ្ងន់ធ្ងរកើតមានឡើង។

**+ស្ថានភាពចាំបាច់ ៖** សំដៅទៅលើអំពើរំលោភបំពានដែលមិនអាចជៀសវាងបាន ហើយដើម្បីការពារខ្លួន ឬទ្រព្យសម្បត្តិខ្លួន ឬអ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្នដែលស្ថិតនៅក្នុងករណីមានតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។

**+មូលហេតុផ្សេងទៀត ៖** អំពើដែលបង្កឲ្យមានការអន្តរាយក្នុងករណីដែលមានការយល់ព្រមពីសំណាក់ជនរងគ្រោះ លើកលែងតែ ការយល់ព្រមរបស់ជនរងគ្រោះនោះ មិនត្រូវបានសង្គមទទួលស្គាល់។ អំពើរបស់មន្ត្រីរាជការដែលទទួលនូវការអនុវត្តសិទ្ធិអំណាចសាធារណៈរបស់រដ្ឋ ដែលបង្កឲ្យមានការខូចខាតដល់អ្នកដទៃ ដោយគ្មានកំហុសក្នុងការអនុវត្តភារកិច្ច មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ដូចជា ការអនុវត្ត សាលក្រម ជាអាទិ៍។ ការអនុញ្ញាតរបស់រដ្ឋ ឬច្បាប់ ទៅតាមស្ថានភាពជាក់ស្តែងនៃសកម្មភាពនោះ ដូចជា ការធ្វើកូដកម្ម ឬបាតុកម្ម ទោះបីជាប៉ះពាល់ដលសិទ្ធិរបស់អ្នកដទៃ ក៏មិនទទួលខុសត្រូវនោះទេ។

## ៣. ការសម្រេចអំពីចំនួននៃសំណង

### ក.គោលការណ៍នៃការសង

ទី១ ទាមទារប្រាក់

ទី២ ទាមទារឲ្យធ្វើបដិទាន

ទី៣ ហាមឃាត់មិនឲ្យធ្វើអំពើណាមួយ (មាត្រា ៧៥៧ នៃក្រមរដ្ឋប្បវេណី)

### ខ.មូលដ្ឋាននៃការគណនាសំណងនៃការខូចខាតផ្នែកសំភារៈ

ទី១ ព្យសនកម្មដោយផ្ទាល់ (ទ្រព្យសម្បត្តិ និងក្រៅពីទ្រព្យសម្បត្តិ) ៖ ការបាត់បង់ទ្រព្យសម្បត្តិ ការបែកបាក់វត្ថុ ការរបួស មរណភាព ជាអាទិ៍។

ទី២ ការចំណាយនានា បន្ទាប់ពីអំពើអនីត្យានុកូលកើតឡើង ៖ សោហ៊ុយព្យាបាល សោហ៊ុយធ្វើដំណើរទៅមន្ទីរពេទ្យ ការចំណាយផ្សេងៗអំឡុងពេលសម្រាកនៅពេទ្យ សោហ៊ុយមើលថែរក្សារបស់គិលានុបដ្ឋាយិកា សោហ៊ុយបុណ្យសព សោហ៊ុយព្យាបាលនានាដែលអាចកើតមានឡើងនាពេលអនាគត ជាអាទិ៍។

ទី៣ ផលប្រយោជន៍នានាដែលត្រូវទទួលបាន ប្រសិនបើគ្មានអំពើអនីត្យានុកូល ៖

ជនរងគ្រោះមានការងារធ្វើ ប៉ុន្តែមិនអាចធ្វើការងារបានក្នុងអំឡុងពេលនោះ

ចំណូលមូលដ្ឋាន (ចំណូលដែលត្រូវទទួលពីការងារ) អំឡុងពេល អវត្តមាន ប្រពន្ធ កូន និង ប្រសិនបើ ជនរងគ្រោះបានស្លាប់ គឺចំណូលមូលដ្ឋានដែលត្រូវបានទទួល ហើយពេលវេលា ត្រូវចាត់ទុកថា អំឡុងពេលដែលជនរងគ្រោះអាចធ្វើការបានរហូតដល់ចូលនិវត្តន៍។

មួយវិញទៀត ការគណនានេះ ក៏រាប់បញ្ចូលការចំណាយផ្សេងៗនាពេលអនាគត ផងដែរ ដែលយើងចាត់ទុកថាជាផលប្រយោជន៍នាពេលអនាគត។ ទោះបីជាដូច្នេះក៏ដោយ ការចាត់ទុកថាជាសំណងនៃការខូចខាតផ្នែកសំភារៈ ត្រូវរំលូសនូវការចំណាយសម្រាប់ការរស់នៅ (ចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃ) របស់ជនរងគ្រោះ ហើយអំឡុងពេលដែលអាចធ្វើការបាន ឬអំឡុងពេលសម្រាកពីការងារ ត្រូវអនុវត្តតាមរូបមន្ត Leibniz ដែលជាវិធានទទួលបានផលប្រយោជន៍រយៈពេលវែង នាពេលអនាគតផ្តល់ឲ្យក្នុងពេលបច្ចុប្បន្នតែម្តង ហើយចាំបាច់ត្រូវតែដក ដើម្បីកុំឲ្យទទួលបាននូវការប្រាក់ខ្ពស់ហួសហេតុ។

**ផលប្រយោជន៍ដែលត្រូវបានទទួលពីការងារ = ប្រាក់ចំណូលមូលដ្ឋាន × ពេលវេលាសរុបដែលមិនបានបំពេញការងារ**

- **ជនរងគ្រោះបាត់បង់សមត្ថភាពធ្វើការ**

សម្រាប់ស្ថានភាពនេះមានការលំបាកក្នុងការគណនាអនុបាតនៃការបាត់បង់សមត្ថភាពក្នុងការធ្វើការ, ប្រសិនបើជនរងគ្រោះមិនអាចធ្វើចលនាបាន និងមិនអាចធ្វើការបានទាំងស្រុង យើងអាចចាត់ទុកថាការបាត់បង់សមត្ថភាពធ្វើការទាំងស្រុង។ ប៉ុន្តែ ប្រសិនបើជនរងគ្រោះអាចធ្វើចលនាដោយលំបាក ហើយគាត់អាចបន្តការងាររបស់គាត់ និងទទួលបានប្រាក់ខែធម្មតា តើអនុបាតនៃការបាត់បង់សមត្ថភាពធ្វើការត្រូវគណនា ដូចម្តេច? ចំពោះដំណោះស្រាយនៃបញ្ហានេះគឺយុត្តិសាស្ត្រនៅប្រទេសជប៉ុន គឺប្រើប្រាស់មូលដ្ឋាននៃបុព្វលាភធានារ៉ាប់រង សម្រាប់ករណីបាត់បង់សមត្ថភាពធ្វើការនេះ ដូចជា ប្រសិនបើ ដាច់ម្រាមដៃទាំងអស់ ត្រូវចាត់ទុកថា ៥៦% ប្រសិនបើ និយាយពុតិចៗ ត្រូវចាត់ទុកថា ២៧%។ ចំពោះស្ថានភាពនេះ នៅក្នុងបទបញ្ញត្តិស្តីពីធានារ៉ាប់រងកម្ពុជា ក៏មានផងដែរ ដូចមានកំណត់ក្នុងប្រការ ៣ នៃប្រកាសស្តីពីការធានារ៉ាប់រងទៅលើបុគ្គល ដោយកំណត់ពីទឹកប្រាក់យ៉ាងតិចចំនួន US$ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ឬ US$ ២៥០,០០០ (ពីររយហាសិបពាន់) ដុល្លារអាមេរិក ទៅតាមករណីនីមួយៗ ដែលបានកំណត់ក្នុងប័ណ្ណសន្យារ៉ាប់រង ហើយនៅក្នុងបញ្ញត្តិការងារ ក៏មានដែរ ដូចជាប្រការ ៨ និងប្រការ ១១ នៃប្រកាសស្តីពីគ្រោះថ្នាក់ការងារ ដែលអាចធ្វើជាមូលដ្ឋានក្នុងការពិចារណា។

**ប្រាក់ចំណូលមូលដ្ឋាន × អនុបាតនៃការបាត់បង់សមត្ថភាព × អំឡុងពេលដែលជនរងគ្រោះអាចធ្វើការបានរហូតដល់ចូលនិវត្តន៍**

**គ.មូលដ្ឋាននៃការគណនាសំណងនៃការខូចខាតផ្នែកផ្លូវចិត្ត**

ទី១ វិសាលភាពនៃកំហុសចំពោះអំពើបំពាន

ទី២ វិសាលភាពនៃការខូចខាត

ទី៣ សកម្មភាពរបស់ចារី ក្រោយអំពើបំពាន

**ចំនួននៃសំណងសម្រាប់អំពើអនីត្យានុកូល = (ការខូចខាតផ្នែកសំភារៈ +ការខូចខាតផ្នែកផ្លូវចិត្ត) – (កំហុសរបស់ជនរងគ្រោះ) – (ប្រាក់ចំណេញ)**

នៅពេលជនរងគ្រោះទាមទារសំណងផ្លូវចិត្ត មិនតម្រូវឲ្យបង្ហាញភស្តុតាងជាក់លាក់អំពីចំនួននៃសំណងនោះទេ ពីព្រោះមិនអាចទៅរួច ហើយចំនួនជាក់លាក់ត្រូវកំណត់ដោយតុលាការ ប៉ុន្តែ ជនរងគ្រោះ ឬអ្នកមានសិទ្ធិទាមទារ ត្រូវបង្ហាញពីភាពឈឺចាប់ ទំនាក់ទំនងគ្រួសារ សកម្មភាពនានាដែលជាអនុស្សាវរីយ៍ជាមួយគ្នាពីមុនមក រូបភាព ខ្សែវីដេអូ អារម្មណ៍ខ្លោចផ្សា ការបាក់ទឹកចិត្ត ជាអាទិ៍។

រក្សាសិទ្ធិគ្រប់បែបយ៉ាង © 

## ៤. ករណីសិក្សា

### ក.ការទាមទារសំណងករណីបែកបាក់វត្ថុ

ក្មេងៗបានចេញពីសាលាមុនម៉ោងកំណត់ដោយសារគ្រូជាប់រវល់មិនបានមកបង្រៀន ហេតុនេះ ក្មេងៗដែលជាសិស្សសាលាបានបបួលគ្នាលេងបាល់ទាត់ដែលមានគ្នាចំនួន ១០ (ដប់) នាក់ ចែកចេញជាពីរក្រុម ដោយម្ខាងៗមានចំនួន ០៥ នាក់។

នៅទីកន្លែងដែលលេងបាល់ទាត់នោះគឺមានបុរសម្នាក់បានចតរថយន្តនៅក្បែរនោះ ដោយសប្បាយនឹងការលេងបាល់ មិនបានចាប់អារម្មណ៍ ក្មេងជំទង់ម្នាក់ឈ្មោះ X អាយុប្រហែល ១៦ ឆ្នាំ បានទាត់បាល់ត្រូវរថយន្តដែលចតនោះ បណ្តាលឲ្យបែកកញ្ចក់មុខទាំងស្រុង។

តាមការអះអាងរបស់ម្ចាស់រថយន្ត បញ្ជាក់ថា កញ្ចក់រថយន្តខាងមុខនេះមានតម្លៃ **US$ ១៥០ (មួយរយហាសិប) ដុល្លារអាមេរិក** ហើយដោយសារតែបែកកញ្ចក់រថយន្ត គាត់ មិនអាចទៅធ្វើការទាន់ពេលកំណត់ ត្រូវថៅកែកាត់លុយអស់ចំនួន **US$ ១០០ (មួយរយ) ដុល្លារអាមេរិក**។ លើសពីនេះទៅទៀត គាត់ខ្មាស់គេ ហេតុនេះមានបំណងទាមទារសំណងនៃការខូចខាតផ្លូវចិត្តបន្ថែមទៀត។

**តើម្ចាស់រថយន្តអាចទាមទារសំណងនៃការខូចខាតបានចំនួនប៉ុន្មាន? ហេតុអ្វី?**

### ខ.ការទាមទារសំណងករណីបរិហាកេរ្តិ៍

A គឺជាតារាចម្រៀងដ៏ល្បីប្រចាំផលិតកម្មមួយ ដោយទទួលបានចំណូលអំពីមុខរបរនេះជាប្រចាំខែ ចំនួន **US$ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក** និងថ្លៃថតផ្សាយពាណិជ្ជកម្មសម្រាប់ក្រុមហ៊ុនភេសជ្ជៈ សម្រាប់រយៈពេល ០១ ឆ្នាំ មានតម្លៃខ្លួន **US$ ១៥,០០០ (ដប់ប្រាំពាន់) ដុល្លារអាមេរិក** ហើយ A មានអាយុ ២៣ ឆ្នាំ។ ល័ក្ខខ័ណ្ឌក្រុមហ៊ុនផលិតចម្រៀង និងក្រុមហ៊ុនភេសជ្ជៈ គឺមិនត្រូវឲ្យមានរឿងពាក់ព័ន្ធនឹង

ស្នេហាត្រីកោណ ជាអាទិ៍នោះទេ។

តារាចម្រៀង A មានបងប្អូនចំនួន ០៣ នាក់ ដោយរាប់ទាំងខ្លួនឯង និងឪពុក-ម្តាយ ក្នុងបន្ទុកទាំងអស់ ដោយខ្លួនត្រូវទទួលខុសត្រូវចំពោះគ្រួសារនេះទាំងមូល។ ថ្ងៃមួយ សារព័ត៌មានឈ្មោះ X បានចុះផ្សាយថា តារាចម្រៀង A មានទំនាក់ទំនងជាមួយប្តីគេដែលជា ឯកឧត្តមឧកញ៉ា ហើយឯកឧត្តមឧកញ៉ានោះបានទិញផ្ទះតម្លៃ **US$ ៣០០,០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក** ហើយព័ត៌មាននេះត្រូវបានសាធារណៈមតិចាប់អារម្មណ៍ ដោយបានកាត់បង្ហោះនៅលើបណ្តាញសង្គម និងបានធ្វើការចែកចាយព័ត៌មាននេះតៗគ្នា។

ព័ត៌មានទាំងនេះបានទៅដល់ ក្រុមហ៊ុនចម្រៀង ក្រុមហ៊ុនភេសជ្ជៈ បណ្ដាលឲ្យខឹង ជាខ្លាំង និងបានកោះហៅសាមីខ្លួន (A) មកបំភ្លឺ ហើយបានសម្រេចបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ដោយសារតែបំពានលើល័ក្ខខ័ណ្ឌ (មិនត្រូវឲ្យមានរឿងពាក់ព័ន្ធនឹងស្នេហាត្រីកោណ)។ ចាប់ពីពេលនោះមក A គ្មានការងារធ្វើ នាំឲ្យប៉ះពាល់ដល់ជីវភាពគ្រួសារ ហើយធាតុពិតគ្មានករណីដូចសារព័ត៌មាន X ចុះផ្សាយនេះទេ។

**តើ A អាចទាមទារសំណងនៃការខូចខាតបានចំនួនប៉ុន្មាន? ហេតុអ្វី?**

**ក្រៅពីការទាមទារសំណង តើ A អាចទាមទារអ្វីបានទៀត? ហេតុអ្វី?**

គ.ការទាមទារសំណងករណីបំពានលើរូបរាងកាយ

A គឺជាសិល្បៈករដ៏ស្អាត និងល្បីមួយរូប ដោយទទួលចំណូលអំពីការសំដែង និងការថតផ្សាយពាណិជ្ជកម្មឲ្យក្រុមហ៊ុននានា និងជាទូទៅទទួលបានចំណូល **US$ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក** ក្នុងមួយខែ។ A គឺជាអ្នកទទួលខុសត្រូវចំពោះបន្ទុកក្នុងគ្រួសារ ដែលមានប្អូន ពីរនាក់ និងឪពុក-ម្ដាយ ហើយ A មានអាយុ ២៥ ឆ្នាំ។

A មានទំនាក់ទំនងស្នេហាជាមួយនឹងអ្នកមានស្តុកស្តម្ភម្នាក់ដែលមានប្រពន្ធកូន រួចហើយ ដោយទទួលបានប្រាក់ឧបត្ថម្ភពីអ្នកមានស្តុកស្តម្ភនោះចំនួន **US$** ១,០០០ (មួយពាន់) ដុល្លារអាមេរិក ប្រចាំខែ ហើយចៃដន្យប្រពន្ធដើមអ្នកមានស្តុកស្តម្ភបានដឹងក៏បានប្រើអំពើហិង្សាចំពោះ A និងបានឆូតមុខ A ចំនួន ០១ កាំបិត ធ្វើឲ្យមានស្នាមលើផ្ទៃមុខ។

ក្រោយរងរបួស A បានសម្រាកព្យាបាល នៅមន្ទីរពេទ្យចំនួន ០៣ (បី) ខែ ដោយចំណាយប្រាក់អស់ **US$ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក** ប៉ុន្តែផ្ទៃមុខដែលមានស្នាមឆូតនោះ គឺសម្លាក និងការងារត្រូវបានក្រុមហ៊ុនបញ្ឈប់។ ព័ត៌មានអំពីព្រឹត្តការណ៍នេះត្រូវបាន ចុះផ្សាយជាសាធារណៈ និងទទួលបានការចាប់អារម្មណ៍ពីសាធារណជន។

**តើ A អាចទាមទារសំណងនៃការខូចខាតបានចំនួនប៉ុន្មាន? ហេតុអ្វី?**

**ក្រៅពីការទាមទារសំណង តើ A អាចទាមទារអ្វីបានទៀត? ហេតុអ្វី?**

### ឃ.ការទាមទារសំណងករណីបំពានលើជីវិត

Aគឺជាបុគ្គលិកជាន់ខ្ពស់នៃក្រុមហ៊ុនមួយដោយទទួលបានចំណូលអំពីមុខរបរនេះជាប្រចាំខែចំនួន **US$ ៥,០០០**(ប្រាំពាន់) **ដុល្លារអាមេរិក**និងជាមេគ្រួសារដែលមានកូន០២នាក់ និងប្រពន្ធក្នុងបន្ទុកគ្រួសារ។ A បានទិញធានារ៉ាប់រងអាយុជីវិត ដោយត្រូវបង់ជាប្រចាំខែ ចំនួន **US$ ១០០ (មួយរយ) ដុល្លារអាមេរិក**

ក្នុងកិច្ចសន្យាធានារ៉ាប់រងបានបញ្ជាក់ថាគឺប្រពន្ធជាអ្នកទទួលបានប្រយោជន៍ (បុព្វលាភធានារ៉ាប់រង) មានចំនួន **US$ ៥០០,០០០ (ប្រាំសែន) ដុល្លារអាមេរិក**។ A មានអាយុ ៣៥ ឆ្នាំ ហើយ។

A មានបេសកម្មទៅខេត្ត និងជាចៃដន្យអាក្រក់ A បានជួបប្រទេះនឹងគ្រោះថ្នាក់ចរាចរណ៍បណ្តាលឲ្យស្លាប់ ដោយសាររថយន្តកុងទីណ័រដែលជារបស់ក្រុមហ៊ុន X ដោយអ្នកបើកបរនោះ បើកបរក្នុងភាពស្រវឹងខ្លាំង បាត់បង់ស្មារតី។

**តើក្រុមគ្រួសារ A អាចទាមទារសំណងនៃការខូចខាតបានចំនួនប៉ុន្មាន? ហេតុអ្វី?**

**ក្រៅពីការទាមទារសំណង តើក្រុមគ្រួសារ A អាចទាមទារអ្វីបានទៀត? ហេតុអ្វី?**

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៣

## ប្រធានបទ៖ វិធីបែងចែកទ្រព្យក្រោយការលែងលះ

ថ្ងៃទី ១០ កក្កដា ២០១៤

# វិធីបែងចែកទ្រព្យក្រោយការលែងលះ

## សេចក្តីផ្តើម

អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាឪឡារិកមួយដែលធ្វើឡើងដោយបុគ្គលពីរនាក់ដើម្បីបង្កើតនូវចំណងគតិយុត្តិដ៏រឹងមាំមួយជាមួយគ្នា។ ដើម្បីបង្កើតនូវចំណងអាពាហ៍ពិពាហ៍ដែលមានលក្ខណៈត្រឹមត្រូវ និងមានសុពលភាពតាមផ្លូវច្បាប់ គូភាគី (សំដៅលើប្តី និងប្រពន្ធ) ត្រូវតែគោរពនូវល័ក្ខខ័ណ្ឌដែល មានលក្ខណៈប្រឹតប្រៀង និងច្បាស់លាស់បំផុត ពីព្រោះទម្រង់នៃកិច្ចសន្យានៃរឿងអាពាហ៍ពិពាហ៍ពុំ មានលក្ខណៈសាមញ្ញដូចកិច្ចសន្យាទូទៅមួយចំនួនឡើយ។ យ៉ាងណាមិញ ចំណងអាពាហ៍ពិពាហ៍ដ៍ រឹងមាំនេះ អាចនឹងត្រូវបានរំលាយទៅវិញ ដោយមូលហេតុមួយចំនួនដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណី តាមវិធីនៃការ "លែងលះ" ដែលសំដៅដល់ការរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍។ ការលែងលះ មិនត្រឹមតែបានកាត់ផ្តាច់នូវចំណងនៃអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ តែក៏ជះឥទ្ធិពលទៅលើការបែងចែកទ្រព្យសម្បត្តិ សិទ្ធិអំណាចក្នុងការគ្រប់គ្រងថែរក្សាកូន សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនីមួយៗក្រោយការលែងលះ ឋានៈរបស់បុគ្គល និងបញ្ហាផ្សេងដទៃទៀតជាច្រើន។

ហេតុដូច្នេះ ក្រុមការងារកិច្ចការរដ្ឋប្បវេណី មានគោលបំណងក្នុងការលើកយកប្រធានបទស្តីអំពី **"វិធីបែងចែកទ្រព្យក្រោយការលែងលះ"** ដែលការលែងលះនៅទីនេះ សន្មតថាជាការលែងលះដោយការព្រមព្រៀង និងតាមផ្លូវច្បាប់ ដើម្បីយកមកសិក្សាលម្អិតទៅលើបញ្ហាសំខាន់ៗដែលត្រូវពិចារណាក្រោយការលែងលះ ព្រមទាំងបញ្ហាប្រឈមនានាដែលជាវិបាកកើតចេញពីការលែងលះផងដែរ។ ដូចនេះ ដើម្បីឲ្យមានភាពងាយស្រួលយល់ យើងខ្ញុំសូមធ្វើបទបង្ហាញទៅលើបីចំណុចសំខាន់ៗដែលទាក់ទងនឹង **គោលគំនិតនៃវិធីបែងចែកទ្រព្យសម្បត្តិក្រោយការលែងលះ(១) គោលបំណងនៃការបែងចែកទ្រព្យសម្បត្តិក្រោយការលែងលះ(២) ព្រមទាំងរូបមន្តដែលត្រូវយកអនុវត្តក្នុងករណីមានការបែងចែកទ្រព្យក្រោយការលែងលះ(៣) និងការអនុវត្តចំពោះការរស់នៅបែបអនីតិសង្វាស (៤)។**

## ១- គោលគំនិតនៃវិធីបែងចែកទ្រព្យក្រោយការលែងលះ

ដោយហេតុថាការលែងលះ នឹងនាំឲ្យកើតមាននូវការផ្លាស់ប្តូរយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃឋានៈបុគ្គល និងការបែងចែកទ្រព្យសម្បត្តិ ដូច្នេះបណ្តឹងលែងលះដោយការព្រមព្រៀងត្រូវតែបញ្ជាក់ អំពីមូលហេតុនៃការស្នើសុំលែងលះ ក៏ដូចជាការស្នើសុំបែងចែកទ្រព្យផងដែរ ពីព្រោះបើគ្មានការ បង្ហាញឆន្ទៈបុគ្គលក្នុងការបែងចែកទ្រព្យទេ នោះតុលាការក៏មិនអាចនឹងសម្រេចអំពីបញ្ហាទ្រព្យបានដែរ។ ដូចនេះ យើងនឹងសិក្សាទៅលើ**អានុភាពនៃការបែងចែកទ្រព្យករណីលែងលះ(១.១) និងគោល បំណងនៃការបែងចែកទ្រព្យក្នុងករណីលែងលះ (១.២)**។

## ១.១ អានុភាពនៃការបែងចែកទ្រព្យករណីលែងលះ

យើងសង្កេតឃើញថាមានអានុភាពសំខាន់ៗចំនួនបីដែលកើតចេញពីករណីលែងលះគឺៈ

ក. អានុភាពទៅលើឋានៈនៃបុគ្គល (បុគ្គលក្នុងទីនេះសំដៅទៅលើប្តី និងប្រពន្ធ)

ខ. អានុភាពទៅលើទ្រព្យសម្បត្តិ និង

គ. អានុភាពទៅលើកូន ។

### ក. អានុភាពនៃការលែងលះទៅលើឋានៈបុគ្គល

ប្តីប្រពន្ធ ដែលនៅក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក យោងតាមមាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ផ្ទុយទៅវិញ កាតព្វកិច្ចខាងលើនេះនឹងត្រូវផុតរលត់ក្រោយមានការលែងលះ លើកលែងតែការផ្តល់ អាហារកាតព្វកិច្ចដល់ប្តី ឬប្រពន្ធ ឬកូន ដែលជាកាតព្វកិច្ចមួយដែលចាំបាច់ និងមិនផុតរលត់នោះទេ។ ម្យ៉ាងវិញទៀត ការលែងលះតាមផ្លូវច្បាប់ ក៏បានផ្តល់លទ្ធភាពដល់ប្តី ឬប្រពន្ធ ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ថ្មីអាចសម្រេចទៅបានផងដែរ។ ក្នុងករណីនេះ ភាគីខាងនារីក៏ត្រូវគោរពនូវរយៈពេលមួយដែលកំណត់ដោយច្បាប់ ពោលប្រសិនបើរយៈពេល ១២០ ថ្ងៃពុំទាន់បានផុតរលត់ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលនោះទេ អាពាហ៍ពិពាហ៍ថ្មីដែលកើតឡើងក្នុងអំឡុងពេលនោះត្រូវហាមឃាត់ (មាត្រា ៩៥០ នៃក.រ)។ ដោយឡែក ចំពោះករណីអនីតិជនដែលសន្មតថាបានដល់នីតិភាពដោយសារចំណងអាពាហ៍ពិពាហ៍ ក៏នៅតែសន្មតថាជានីតិជនដដែល ទោះជាចំណងអាពាហ៍ពិពាហ៍ត្រូវបានកាត់ផ្តាច់ទៅហើយក្តី (មាត្រា ៩៦៨ និងមាត្រា ២១-៣ នៃក.រ)។ លើសពីនេះទៅទៀត ប្តី ឬប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន (មាត្រា ៩៨១ នៃក.រ)។

### ខ. អានុភាពនៃការលែងលះទៅលើទ្រព្យសម្បត្តិ

ការបែងចែកទ្រព្យសម្បត្តិ គឺជាបញ្ហាស្មុគស្មាញមួយក្នុងចំណោមបញ្ហាដទៃទៀត ដែលកើតចេញពីការលែងលះ។ ហេតុដូច្នេះ អានុភាពនៃការលែងលះ គឺនាំឲ្យមានការធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរវាងប្តី និងប្រពន្ធដែលមាន។ ការជម្រះបញ្ជីទីនេះ សំដៅទៅលើការពិចារណាយ៉ាងលម្អិតទៅលើទ្រព្យសម្បត្តិប្តី និងប្រពន្ធដែលមាន ដោយហេតុថា ទ្រព្យសម្បត្តិក្នុងទីនេះអាចបែងចែកជាទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែករបស់ប្តី ឬទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ។ ច្បាប់បានទទួលស្គាល់នូវឆន្ទៈរបស់សហព័ទ្ធក្នុងការបែងចែកទ្រព្យរួម និងទ្រព្យដោយឡែករបស់ខ្លួនតាមការព្រមព្រៀង ដោយក្នុងករណីនេះ ប្រសិនបើមានការព្រមព្រៀងណាមួយកើតឡើង ប្តីប្រពន្ធត្រូវតែធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់នូវទំហំ ប្រភេទ និងតម្លៃនៃទ្រព្យសម្បត្តិដែលត្រូវបែងចែក។ ម្យ៉ាងវិញទៀត យោងតាមមាត្រា ៩៨០ នៃក.រ

ការបែងចែកទ្រព្យសម្បត្តិត្រូវធ្វើដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេត្រូវបែងចែកគ្នាដោយៈ

-សហព័ទ្ធនីមួយទទួលបាននូវទ្រព្យសម្បត្តិដោយឡែក (មាត្រា ៩៧២ នៃក.រ)

-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗត្រូវមានសិទ្ធិទទួលយក មួយភាគពីរ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែក្នុងករណីមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែក ទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថាន ភាពផ្លូវកាយ និងផ្លូវចិត្ត វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផល ប្រយោជន៍របស់កូន ជាអាទិ៍។ គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ (មាត្រា ៩៨០ នៃក.រ)។ ក្នុងការលែងលះគ្នា ភាគីដែលមានភាពខ្វះខាត ហើយគ្មានកំហុសអាចទាមទារឲ្យភាគីម្ខាងទៀតផ្តល់អាហារកាតព្វកិច្ចចំពោះខ្លួន ដែលតម្លៃនៃអាហារកាតព្វកិច្ចគឺអាស្រ័យទៅតាមស្ថានភាពធនធានរបស់ភាគីម្ខាងទៀត។

**គ. អានុភាពទៅលើកូន**

ការលែងលះ មិនត្រឹមតែជះឥទ្ធិពលទៅលើការបែងចែកទ្រព្យសម្បត្តិជាចម្បងនោះទេ តែក៏ ពាក់ព័ន្ធយ៉ាងខ្លាំងទៅដល់សិទ្ធិអំណាចរបស់គូភាគីទៅលើការគ្រប់គ្រងថែរក្សាកូនផងដែរ។ មានបញ្ហាប្រឈមជាច្រើនបានកើតឡើងទាក់ទិនទៅនឹងចំណុចនេះ ក្នុងករណីដែលឪពុកម្តាយមិនអាចឈានដល់ការព្រមព្រៀងក្នុងការប្រគល់សិទ្ធិទៅឲ្យភាគីណាមួយក្នុងការរក្សាសិទ្ធិគ្រប់គ្រងកូនបាន។ ហេតុនេះហើយ ពេលលែងលះ គូភាគីត្រូវតែធ្វើការសម្រេចព្រមព្រៀងទៅលើការកំណត់យកឪពុក ឬម្តាយ ណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សាគ្នាជាមុន។ ជាគោលការណ៍ ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតរបស់កូន នោះម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ តែបើក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេ-បាតាមការពិភាក្សារបស់ឪពុកម្តាយបាន។ ប្រសិនបើគូភាគី មិនអាចឈានទៅដល់ការព្រមព្រៀងក្នុងការកំណត់ថាឪពុក ឬម្តាយ ជាអ្នកមានអំណាចមេបាទៅលើកូននោះទេ នោះតុលាការត្រូវធ្វើការ សម្រេចសេចក្តីទៅតាមឥស្សរចិត្តរបស់ខ្លួនដោយពិចារណាទៅលើផលប្រយោជន៍របស់កូនជាធំ (យោងមាត្រា ១០៣៧ នៃក.រ)។ ទោះជាយ៉ាងណាក្តី ឪពុកឬម្តាយ ដែលពុំទទួលបានអំណាចមេបាក្រោយការលែងលះគ្នា នៅតែមានសិទ្ធិក្នុងការចេញចូលជួបប្រាស្រ័យទាក់ទងជាមួយកូនបានជាធម្មតា ហើយក៏នៅតែភ្ជាប់ករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងកូនផងដែរ។

### ១.២ គោលបំណងនៃការបែងចែកទ្រព្យ

ការបែងចែកទ្រព្យក្រោយការលែងលះ មានគោលបំណងចម្បងគឺនាំឲ្យមានសមភាពក្នុងការ បែងចែកទ្រព្យដែលរកបានដោយសហព័ទ្ធក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក៏ដូចជាអនុញ្ញាតឲ្យគូភាគីអាចយកទ្រព្យទាំងនេះទៅចិញ្ចឹមជីវិតក្រោយការលែងលះផងដែរ ជាពិសេសក្នុងករណីដែលភាគីម្ខាងមានការខ្វះខាតក្នុងជីវភាពរស់នៅ។

## ២. មធ្យោបាយក្នុងការបែងចែកទ្រព្យសម្បត្តិ

ការបែងចែកទ្រព្យសម្បត្តិអាចធ្វើឡើងក្រោមរូបភាព បីយ៉ាង គឺះ

**១. ការបែងចែកទ្រព្យតាមការព្រមព្រៀង**

ដូចដែលបានបញ្ជាក់ពីខាងដើមមកស្រាប់ថា ការបែងចែកទ្រព្យសម្បត្តិអាចធ្វើតាមវិធីសាមញ្ញមួយ គឺការព្រមព្រៀងគ្នារវាងសហព័ទ្ធ ដែលវាជាសិទ្ធិសេរីភាពពេញទីរបស់គូភាគី ទាំងទៅលើការបែងចែកទ្រព្យសម្បត្តិឯកជន និងបែងចែកទ្រព្យសម្បត្តិរួម ផងដែរ។ ប្រសិនបើសហព័ទ្ធបានធ្វើការព្រមព្រៀងក្នុងការបែងចែកទ្រព្យហើយ គូភាគីត្រូវតែចងកាតព្វកិច្ចគោរពតាមការព្រមព្រៀងនោះ ហើយ មិនអាចដាក់ពាក្យសុំបែងចែកទ្រព្យសម្បត្តិណាផ្សេងទៀតទៅតុលាការបាននោះទេ។

**<u>ឧទាហរណ៍</u>**ះ បុរស ក និងខ ជាសហព័ទ្ធដែលមានបំណងលែងលះគ្នា។ ក្នុងចំណងអាពាហ៍ពិពាហ៍ លោក ក និងនារី ខ មាននូវផ្ទះល្វែងមួយកន្លែង រថយន្តមួយគ្រឿង និងលុយសុទ្ធចំនួន១ម៉ឺនដុល្លា។ គូភាគីបានព្រមព្រៀងគ្នាថា លោក ក ប្រគល់នូវផ្ទះ និងលុយសុទ្ធអោយទៅនារី ខ តាមរយៈកិច្ចសន្យាបែងចែកទ្រព្យសម្បត្តិរួម។ ហេតុដូច្នេះ តាមកិច្ចសន្យា គឺនារី ខ មានសិទ្ធិទទួលបានផ្ទះ និង លុយសុទ្ធចំនួន ១ម៉ឺនដុល្លារ ហើយ ក មិនអាចទាមទារតាមផ្លូវតុលាការនាពេលក្រោយទៀត អោយផ្ទុយពីអ្វីដែលខ្លួនបានព្រមព្រៀងរួចមកហើយនោះទេ ។

**២.២ ការបែងចែកទ្រព្យតាមរយៈសាលក្រមបន្ទាប់បន្សំរបស់តុលាការ**

ប្រសិនបើភាគីណាមួយបានដាក់ពាក្យបណ្តឹងលែងលះ នោះភាគីនោះអាចដាក់ពាក្យសុំបែងចែកទ្រព្យសម្បត្តិក្នុងអំឡុងពេលនោះបាន ហើយតុលាការដែលបានទទួលពាក្យសុំត្រូវចេញសេចក្តីសម្រេចទាក់ទងទៅនឹងការបែងចែកទ្រព្យសម្បត្តិផងដែរ (មាត្រា៩៨០-២នៃក្រមរដ្ឋប្បវេណី និង មាត្រា ២២-១ និង ២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**២.៣ ការបែងចែកទ្រព្យតាមរយៈសេចក្តីសម្រេចរបស់តុលាការ**

បន្ទាប់ពីការលែងលះមានអានុភាព គូភាគីនៅតែអាចទាមទារការបែងចែកទ្រព្យសម្បត្តិតាមរយៈរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (យោងតាមមាត្រា៩៨០-២ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងដែលមិនមែនបណ្តឹង)។

## ៣. រូបមន្តដែលត្រូវគិតដោយតុលាការនៅពេលសម្រេចពីការបែងចែកទ្រព្យសម្បត្តិ

ក្នុងករណីដែលគូភាគីមិនអាចឈានដល់ការព្រមព្រៀងក្នុងការបែងចែកទ្រព្យសម្បត្តិនោះទេ ភាគីត្រូវដាក់បណ្តឹងលែងលះ ឬរឿងក្តីមិនមែនជាបណ្តឹងសុំបែងចែកទ្រព្យសម្បត្តិ។ តុលាការនឹងបែងចែកទ្រព្យសម្បត្តិរួម ប៉ុន្តែមិនអាចបែងចែកទ្រព្យសម្បត្តិដោយឡែកបានទេ ។

ដើម្បីសម្រេចពីការបែងចែកថាតើទ្រព្យសម្បត្តិរួម តុលាការត្រូវពិចារណាតាមដំណាក់កាលដូចខាងក្រោមគឺ៖

- **ដំណាក់កាលទី១៖ ការកំណត់ពីទំហំនៃទ្រព្យសម្បត្តិរួម**

ដើម្បីកំណត់ពីទំហំនៃទ្រព្យសម្បត្តិរួម គេត្រូវធ្វើការញែកចេញឲ្យដាច់ពីគ្នានូវទ្រព្យរួម និងទ្រព្យដោយឡែក ។ ហើយយើងត្រូវចាត់ថ្នាក់នៃទ្រព្យរួម និងទ្រព្យដោយឡែក ។

យោងតាមមាត្រា **៩៧២** នៃក្រមរដ្ឋប្បវេណី បានកំណត់ថា៖

១- ទ្រព្យដែលសហព័ទ្ធម្ខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍

២- ទ្រព្យដែលសហព័ទ្ធម្ខាងធ្វើលទ្ធកម្មក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ តាមរយៈប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន។

៣- ទ្រព្យដែលទទួលបានជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិ ដែលបានកំណត់ក្នុងចំណុច ក និងចំណុច ខ ខាងលើនេះ។

ម្យ៉ាងវិញទៀត មាត្រា **៩៧៣** នៃក្រមរដ្ឋប្បវេណី ក៏បានកំណត់អំពីទ្រព្យរួម ថា៖ ទ្រព្យរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក្រៅពីទ្រព្យដោយឡែក។

**<u>ឧទាហរណ៍</u>៖** ក្នុងអំលុងពេលមានចំណងអាពាហ៍ពិពាហ៍ លោក ក និងអ្នកស្រី ខ បានទិញដីមួយកន្លែងក្នុងតម្លៃ ១០ ម៉ឺនដុល្លារ។ នៅពេលបង់ប្រាក់ដំណាក់កាលដំបូង ឪពុករបស់អ្នក ស្រី ខ បានបង់ប្រាក់ចំនួន ១ ម៉ឺនដុល្លារ ហើយលុយដែលនៅសេសសល់ចំនួន ៩ម៉ឺន ដុល្លារទៀត ត្រូវបានបង់ដោយប្រាក់បៀវត្សដែលលោក ក រកបាន។ លោកស្រី ខ គឺជាមេផ្ទះ។ លុះក្រោយមក លោក ក និងអ្នកស្រី ខ ចង់ធ្វើការលែងលះ និងបែងចែកទ្រព្យ ហើយក្នុងពេលលែងលះដីនោះមានតម្លៃរហូតដល់១៥ម៉ឺនដុល្លារ។ តើដីនេះជាទ្រព្យរួម ឬទ្រព្យដោយឡែក ?

- **<u>ដំណាក់កាលទី២៖</u> ការវាយតម្លៃទ្រព្យរួមនីមួយៗ**

សំដៅទៅលើទ្រព្យរួមទាំងអស់ ដែលសហព័ទ្ធមានក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ហើយដែលទ្រព្យទាំងអស់នោះត្រូវធ្វើការវាយតម្លៃតាមរយៈរបាយការណ៍វាយតម្លៃដ៏ច្បាស់លាស់មួយ ។

ឧទាហរណ៍៖

- រថយន្ត= តម្លៃទីផ្សារនាពេលបច្ចុប្បន្ន
- ប្រាក់សុទ្ធតម្កល់ក្នុងធនាគារ = សមតុល្យដែលនៅសល់
- ប័ណ្ណធានារ៉ាប់រងអាយុជីវិត=ចំនួនប្រាក់ដែលត្រូវសងត្រលប់មកវិញនៅពេលលុបចោល
- ប័ណ្ណភាគហ៊ុន = តម្លៃលើទីផ្សារនាពេលបច្ចុប្បន្ន
- ចលនវត្ថុដែលមានតម្លៃ ដូចជា គ្រឿងអលង្ការ គ្រឿងសង្ហារឹម វត្ថុបុរាណ ជាដើម = របាយការណ៍វាយតម្លៃ។

**ដំណាក់កាលទី៣ ៖ ការកំណត់អនុបាត**

យោងតាមមាត្រា ៩៨០-២ ចំណុចក វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ជាគោលការណ៍សហព័ទ្ធមានសិទ្ធិទទួលបានទ្រព្យសម្បត្តិរួមម្នាក់ ១/២ គឺម្នាក់ៗទទួលបានពាក់កណ្តាលនៃទ្រព្យរួមទាំងអស់ ប្រសិនបើសហព័ទ្ធបានធ្វើការរកស៊ីទាំងអស់គ្នា ឬភាគីណាម្នាក់ជាមេផ្ទះរហូតមក។ ក៏ប៉ុន្តែ គោលការណ៍នេះអាចត្រូវបានមិនអនុវត្តតាម ក្នុងករណីពិសេស ហើយដែលមានការទាមទារពីភាគីណាម្ខាង ដើម្បីឲ្យបែងចែកទ្រព្យរួមខុសពីគោលការណ៍ខាងលើ (មាត្រា ៩៨០ កថា ២ ចំណុច ខ វាក្យខណ្ឌទី២ នៃ ក.រ)។

ឧទាហរណ៍៖ ប្រសិនបើប្រពន្ធជាមេផ្ទះ ដែលពឹងពាក់ទាំងស្រុងទៅលើការធ្វើការរបស់ប្តីហើយ ក្រោយការលែងលះ ប្រពន្ធត្រូវការរយៈពេល ពីរ ឬបីឆ្នាំ ដើម្បីអាចរស់នៅដោយឯករាជ្យបាន ដោយសារតែគាត់ខ្វះបទពិសោធន៍ក្នុងការរស់នៅក្នុងសង្គមតែឯង ឬដោយសារបញ្ហាសុខភាព ឬត្រូវថែទាំក្មេង ជាដើមនោះ តុលាការនឹងសម្រេចសេចក្តីដោយផ្តល់ច្រើនជាង ៥០% នៃទ្រព្យសម្បត្តិរួមទៅឲ្យប្រពន្ធ ដើម្បីផ្គត់ផ្គង់ជីវភាព រស់នៅរបស់ប្រពន្ធនោះ។

ដោយឡែក ប្រសិនបើប្រពន្ធជាមេផ្ទះ ប៉ុន្តែពុំបានយកចិត្តទុកដាក់ធ្វើកិច្ចការផ្ទះ គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ មិនយកចិត្តទុកដាក់ក្នុងការមើលថែទាំកូន ក្នុងខណៈពេលដែលប្តីជាអ្នកខិតខំធ្វើការបង្កើនចំណូលគ្រួសារ/ទ្រព្យសម្បត្តិ តែម្នាក់ឯង នោះតុលាការនឹងសម្រេចផ្តល់ទ្រព្យសម្បត្តិតិចជាង ៥០% ទៅឲ្យប្រពន្ធនោះបាន ។

**ដំណាក់កាលទី៤៖ ការកំណត់មធ្យោបាយនៃការបែងចែក**

យោងតាមមធ្យោបាយទាំងអស់ខាងលើ នាំឲ្យតុលាការអាចកំណត់នូវការបែងចែកទ្រព្យសម្បត្តិរួម តាមវិធីណាមួយដូចខាងក្រោម៖

- **ការបែងចែកតាមទ្រព្យជាក់ស្តែង**

ឧទាហរណ៍៖ ប្រសិនបើវត្ថុនៃការបែងចែកមានចំនួន ៤ តុលាការនឹងសម្រេចថាប្តីយកវត្ថុទី១ និងទី៤ ហើយប្រពន្ធយកវត្ថុទី២ និងទី៣ ។

- **ការបែងចែកតាមរយៈកម្មសិទ្ធិអវិភាគ**

ឧទាហរណ៍៖ ប្រសិនបើទ្រព្យរួម គឺជាអចលនវត្ថុដែលបានចុះបញ្ជីរួចក្រោមឈ្មោះរបស់ប្តីតែម្នាក់ នោះតុលាការនឹងសម្រេចថា "ប្តីត្រូវផ្ទេរការចុះបញ្ជីនៃចំណែក ៥០% នៃអចលនវត្ថុទៅឲ្យប្រពន្ធ" ។

- **ការបែងចែកតាមរយៈការលក់**

ឧទាហរណ៍៖ ប្រសិនបើទ្រព្យរួម គឺជាអចលនវត្ថុដែលបានចុះបញ្ជីរួចក្រោមឈ្មោះរបស់ប្តីតែម្នាក់។ ប្តីនិងប្រពន្ធបានលក់អចលនវត្ថុនៅមុនសេចក្តីសម្រេចរបស់តុលាការ ក្នុងតម្លៃ ១០០០០ ដុល្លារ នោះតុលាការនឹងសម្រេចថា "ប្តីត្រូវបង់ប្រាក់ ៥០០០ ដុល្លារ ឲ្យប្រពន្ធ"។

- **ការបែងចែកតាមរយៈការសងសំណង**

ឧទាហរណ៍៖ ករណីទ្រព្យរួម គឺអចលនវត្ថុដែលបានចុះបញ្ជីរួចក្រោមឈ្មោះរបស់ប្តីតែម្នាក់ នោះតុលាការនឹងសម្រេចថា "ប្តីត្រូវផ្ទេរការចុះបញ្ជីអចលនវត្ថុឲ្យប្រពន្ធ ហើយប្រពន្ធត្រូវបង់ប្រាក់ ៥០០០ ដុល្លារទៅឲ្យប្តី "។

## ៤. ករណីសិក្សា

ករណីសិក្សាទី១៖

ក និងខ បានកំពុងរស់នៅជាមួយគ្នាជាប្តីប្រពន្ធបែបអនីតិសង្វាស ប៉ុន្តែ ក ចង់រំលាយទំនាក់ទំនងជាមួយ ខ ។ តើ ក អាចដាក់ពាក្យសុំបែងចែកទ្រព្យសម្បត្តិ ក្នុងករណីលែងលះ តាមរយៈការអនុវត្តប្រដូចទៅនឹងមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី បានដែរឬទេ ?

ករណីសិក្សាទី២ ៖

លោក តារា បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកស្រី រស្មី នៅក្នុងឆ្នាំ១៩៩៨ បន្ទាប់ពីរៀបការពួកគាត់មានកូនប្រុសម្នាក់ ឈ្មោះ សក្កដា។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ លោក តារា និងអ្នកស្រី រស្មី មានទ្រព្យសម្បត្តិជាដីចំនួន០៩កន្លែង ដែលនៅក្នុងនោះដីចំនួន៣កន្លែងត្រូវបានដាក់ថាជា "ទ្រព្យដោយឡែកខាងប្តី" ដី៣កន្លែងទៀតដាក់ជាអំណោយដែលអ្នកស្រី រស្មី ទទួលបានពីឪពុកម្តាយរបស់គាត់ តែជាតុពិតដីទាំងបីកន្លែងនេះ គឺលោក តារា បានយកលុយដែលខ្លួនមានមុនពេលរៀបការទៅទិញពីឪពុកម្តាយក្មេករបស់គាត់ប៉ុណ្ណោះ ប៉ុន្តែក្នុងពេលទិញ-លក់ ភាគីទាំងពីរពុំបានចុះកិច្ចសន្យាទិញ-លក់អ្វីទាំងអស់ ដោយសារគិតថាជាឪពុក និងកូន ហើយក៏បានព្រមព្រៀងគ្នាដាក់ថាជាអំណោយ និងដីចំនួន៣កន្លែងទៀត គឺជាការចូលលុយគ្នាទិញ ដែលមានការចូលរួមពីបងស្រីលោក តារា ចំនួន៥០% និងឪពុករបស់អ្នកស្រីរស្មី

ចំនួន៥០% ។ ម្យ៉ាងទៀត ក៏នៅមានទឹកប្រាក់នៅក្នុងធនាគារអេស៊ីលីដា ចំនួន ៦០០០០ $ ទៀតដែលដាក់ក្នុងគណនេយ្យរបស់អ្នកស្រី រស្មី ។

រហូតមកដល់ឆ្នាំ២០១៣ ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា អ្នកស្រី រស្មី បានដាក់ពាក្យបណ្ដឹងទៅតុលាការសុំលែងលះពីលោក តារា ដោយស្នើសុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម ៖

១-ចេញសាលក្រមសំរេចផ្ដាច់ចំណងអាពាហ៍ពិពាហ៍ រវាងខ្លួន និងលោក តារា តាមនិតិវិធីច្បាប់ ។

២-ប្រគល់សិទ្ធិគ្រប់គ្រងកូនឈ្មោះ សក្កដា អោយលោក តារា។

៣-សុំបែងចែកទ្រព្យសម្បត្តិរួមទាំងអស់ម្នាក់ពាក់កណ្ដាលតាមច្បាប់។

ចំពោះករណីនេះ តើទ្រព្យរួមអាចបែងចែកជាពីរចំណែកតាមការទាមទាររបស់អ្នកស្រីរស្មីដែរឬទេ ?

<u>ករណីសិក្សាទី៣ ៖</u>

លោក រិទ្ធី និង អ្នកស្រី ពិសី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅក្នុងឆ្នាំ ១៩៩៥។ ក្រោយពីរៀបអាពាហ៍ពិពាហ៍រួច អ្នកទាំងពីរបានទិញដីមួយកន្លែងដើម្បីបើកជាកសិដ្ឋានចិញ្ចឹមទា លុះក្រោយមកពួកគាត់ក៏បានប្ដូរពីមុខរបរពីចិញ្ចឹមទា ទៅបើកហាងលក់ទំនិញវិញដោយមានការជួយមើលការគ្រប់គ្រងហាងពីកូនប្រុសឈ្មោះ ដារ៉ូ អាយុ១៥ឆ្នាំ។ រហូតដល់ឆ្នាំ២០១៣ អ្នកស្រី ពិសី បានដាក់ពាក្យសុំលែងលះពីលោក រិទ្ធី ដោយមូលហេតុ លោក រិទ្ធី មានស្នេហាលួចលាក់ជាមួយនារីដទៃទៀត។ ដូច្នេះ នៅក្នុងពាក្យបណ្ដឹងសុំលែងលះ អ្នកស្រី ពិសីបានស្នើសុំអោយតុលាការចេញសាលក្រមដូចខាងក្រោម ៖

១-សំរេចផ្ដាច់ចំណងអាពាហ៍ពិពាហ៍ រវាងខ្លួន និងលោក រិទ្ធី តាមនិតិវិធីច្បាប់។

២-សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ ដារ៉ូ អាយុ១៥ឆ្នាំ។

៣-សុំបែងចែកទ្រព្យសម្បត្តិរួម៨០% ដើម្បីចិញ្ចឹមកូន និងប្រគល់អោយលោក រិទ្ធី ចំនួន២០%

ស្របពេលជាមួយគ្នានោះដែរ កូនប្រុសឈ្មោះ ដារ៉ូ ក៏បានដាក់ពាក្យបណ្ដឹងក្នុងនាមតតិយជនទៅតុលាការ ដើម្បីសុំទាមទារបែងចែកទ្រព្យរួម ដែលទទួលបានពីការប្រកបអាជីវកម្មលក់ម៉ាស៊ីនត្រជាក់ ដោយយកមូលហេតុថា ខ្លួនបានជួយមើលហាង និង លក់ម៉ាស៊ីនត្រជាក់នេះតាំងពីបើកហាងដំបូងមកម្ល៉េះ។

-តើតុលាការអាចសម្រេចចេញសាលក្រមបែងចែកទ្រព្យរួមតាមការទាមទាររបស់អ្នកស្រីពិសីបានដែរឬទេ?

-តើកូនប្រុសឈ្មោះ ដារ៉ូ អាចទាមទារបែងចែកទ្រព្យរួមជាមួយឪពុកម្ដាយដូចការអះអាងរបស់ខ្លួនបានដែរឬទេ?

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៩

## ប្រធានបទ៖ អនុប្បទានសិទ្ធិលើបំណុល

## ថ្ងៃទី ២១ សីហា ២០១៤

# អនុប្បទានសិទ្ធិលើបំណុល

## សេចក្តីផ្តើម៖

ជាទូទៅ សិទ្ធិលើបំណុល វាខុសពីសិទ្ធិប្រត្យក្ស ព្រោះថាសិទ្ធិលើបំណុលមានភាពមិន ដាច់ខាត (សិទ្ធិដែលអាចតតាំងបានតែចំពោះកូនបំណុលប៉ុណ្ណោះ) រីឯសិទ្ធិប្រត្យក្សវិញ គឺមាន លក្ខណៈដាច់ខាត (ជាសិទ្ធិដែលអាចតតាំងចំពោះបុគ្គលគ្រប់រូប) ហេតុនេះហើយបានជាគេគិតថា សិទ្ធិលើបំណុល មិនអាចធ្វើអនុប្បទាន(ផ្ទេរ)បានទេ។ ប៉ុន្តែបើពិនិត្យលើក.រនេះ ត្រង់មាត្រា៥០១-១ ជាគោលការណ៍ សិទ្ធិ លើបំណុលគឺអាចធ្វើអនុប្បទានបានដោយសេរី។ ចំណែកឯអនុប្បទានវិញ ជាការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយី ទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។ សរុបមក អនុប្បទានសិទ្ធិលើបំណុល គឺជាការផ្ទេរសិទ្ធិលើបំណុលពីម្ចាស់សិទ្ធិលើបំណុល(អនុប្បទាយី) ទៅឲ្យតតិយជន (អនុប្បទានិក) ប៉ុន្តែការផ្ទេរនេះមិនត្រូវធ្វើឲ្យផ្លាស់ប្តូរ ឬកែប្រែនូវអត្តសញ្ញាណដើមនៃសិទ្ធិលើ បំណុល ឡើយ។

ឧទាហរណ៍




ម្យ៉ាងទៀតប្រសិនបើក្នុងករណីមានការផ្ទេរសិទ្ធិលើបំណុលដែលមានការធានាដោយសិទ្ធិប្រាតិភោគ នោះសិទ្ធិប្រាតិភោគនោះ ក៏ត្រូវបានផ្ទេរផងដែរ (ម.៧៧០ ក.រ)។

ឧទាហរណ៍



**សំនួរសួរថា៖** តើសិទ្ធិលើបំណុលទាំងអស់សុទ្ធតែអាចធ្វើអនុប្បទានបាន? ហើយគេត្រូវគោរពល័ក្ខខ័ណ្ឌអ្វីខ្លះ?

ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងយល់អំពីអនុប្បទានសិទ្ធិលើបំណុល យើងនឹងធ្វើការសិក្សាជាបន្តបន្ទាប់ដូចខាងក្រោម៖

## ១- ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និងករណីដែលហាមមិនឲ្យធ្វើអនុប្បទានបាន ៖

### ១-១ ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើបំណុល អាចធ្វើអនុប្បទានសិទ្ធិលើបំណុលរបស់ខ្លួនទៅឲ្យអ្នកផ្សេងបាន លើកលែងតែករណីដែល សិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន(ម.៥០១-១) ឬសិទ្ធិនោះហាមឃាត់ដោយច្បាប់។

**ក. សិទ្ធិដែលមានលក្ខណៈមិនអាចធ្វើអនុប្បទានបានៈ**

ឧទា៖ កាតព្វកិច្ចគូររូប, សិទ្ធិលើបំណុលសម្រាប់សោហ៊ុយផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់កូន...

**ខ. សិទ្ធិដែលហាមឃាត់ដោយច្បាប់ៈ**

ឧទា កិច្ចសន្យាការងារ (ម.៦៦៧), សិទ្ធិជួល (ម.៦០៨).....

ប៉ុន្តែក្នុងករណីខ្លះ សិទ្ធិលើបំណុលអាចធ្វើបាន ដោយមានការផ្តល់សច្ចានុម័តពីកូនបំណុល។

### ១-២ ករណីដែលហាមមិនឲ្យធ្វើអនុប្បទានបានៈ

ដោយសារសិទ្ធិលើបំណុលអាចធ្វើអនុប្បទានបានដោយសេរី ជាគោលការណ៍ ការចូលរួមរបស់កូនបំណុល គឺមិនតម្រូវឲ្យមាននោះទេ។ ដូច្នេះហើយ ប្រសិនបើកូនបំណុលមិនមានបំណងចង់ឲ្យមានការផ្ទេរសិទ្ធិលើបំណុលទៅឲ្យអ្នកផ្សេងនោះទេ កូនបំណុលត្រូវធ្វើការសន្យាពិសេសជាមួយនឹងម្ចាស់បំណុលជាមុន (ជាការបង្ហាញឆន្ទៈអំពីការសន្យាហាមមិនឲ្យធ្វើអនុប្បទាន) (ម.៥០១-២)។ ប៉ុន្តែ ការសន្យានេះគ្មានអានុភាពខ្លាំងនោះទេ ដោយសារតែការសន្យាហាមមិនឲ្យធ្វើអនុប្បទានមិនអាចតតាំងចំពោះតតិយជនសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរបានទេ (ម.៥០១-៣)។

ប្រសិនបើម្ចាស់បំណុល បានផ្ទេរសិទ្ធិលើបំណុលដែល បានសន្យាហាមិនឲ្យផ្ទេរ អនុប្បទាន ប៉ុន្តែ ក្រោយមក កូនបំណុលបានផ្តល់សច្ចានុម័តចំពោះការផ្ទេរនោះ ដូច្នេះការផ្ទេរ សិទ្ធិលើបំណុលនេះ ត្រូវមានអានុភាព។

ឧទាហរណ៍ទី១




ឧទាហរណ៍ទី២




ឧទាហរណ៍ទី៣



## ២- ល័ក្ខខ័ណ្ឌនៃការធ្វើអនុប្បទានសិទ្ធិលើបំណុល និងល័ក្ខខ័ណ្ឌតតាំង

### ២-១ ល័ក្ខខ័ណ្ឌនៃការធ្វើអនុប្បទានសិទ្ធិលើបំណុល:

ដើម្បីធ្វើអនុប្បទានសិទ្ធិលើបំណុលបាន ត្រូវមានល័ក្ខខ័ណ្ឌ ៣យ៉ាង គឺ:

- ការព្រមព្រៀងរវាងម្ចាស់បំណុល (អនុប្បទាយី) និងតតិយជន (អនុប្បទានិក)។ ការព្រមព្រៀងមិនកំណត់ពីទម្រង់ជាក់លាក់នោះទេ ដូច្នេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

- សិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបាន។

- គ្មានការសន្យាពិសេសដែលហាមមិនឲ្យធ្វើអនុប្បទាន។

### ២-២ ល័ក្ខខ័ណ្ឌតតាំង: មាន២ ប្រភេទគឺ

**ក- ល័ក្ខខ័ណ្ឌតតាំងចំពោះកូនបំណុល (ម.៥០៣)**

អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនអាចតតាំងចំពោះកូនបំណុល ឬតតិយជនផ្សេងទៀតបានឡើយ បើ**អនុប្បទាយី**មិនបានជូនដំណឹងទៅកូនបំណុលអំពីអនុប្បទាននេះ ឬបើកូនបំណុលមិនបានផ្តល់នូវការយល់ព្រមអំពីអនុប្បទាននេះចំពោះអនុប្បទាយី ឬអនុប្បទានិក (មាត្រា ៥០៣-១)។ មានន័យថា កូនបំណុលអាចប្រកែកក្នុងការសងបំណុលទៅអនុប្បទានិកបានរហូតដល់មានការទទួលដំណឹង ឬការយល់ព្រម។ ម្យ៉ាងវិញទៀត ដោយសារតែអនុប្បទាយី មិនមែនជាម្ចាស់បំណុលតទៅទៀត កូនបំណុលក៏អាចប្រកែកក្នុងការសងទៅអនុប្បទាយីផងដែរ។ ជារួមមក កូនបំណុល អាចប្រកែកសងបំណុលទៅម្ចាស់បំណុល ឬអនុប្បទានិកបានរហូតដល់មានការជូនដំណឹង ឬការយល់ព្រម។ ជាមួយគ្នាដែរ កូនបំណុលអាចជ្រើសរើសសងបំណុលទៅម្ចាស់បំណុល ឬអនុប្បទានិកបាន ហើយប្រសិន បើកូនបំណុលបានសងទៅម្ចាស់បំណុល ឬអនុប្បទានិករួច នោះបំណុលត្រូវបានរលត់។

បន្ទាប់ពីកូនបំណុលទទួលដំណឹង ឬផ្តល់ការយល់ព្រមរួច កូនបំណុលត្រូវសងបំណុលទៅអនុប្បទានិក។ ចំពោះទំរង់នៃការជូនដំណឹង ឬការយល់ព្រម ពុំមានបញ្ជាក់ច្បាស់អំពីទំរង់នោះទេ ដូច្នេះ ការជូនដំណឹង ឬការយល់ព្រម អាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏បាន។

ឧទាហរណ៍ទី១




ឧទាហរណ៍ទី២




ឧទាហរណ៍ទី៣



**ខ-ល័ក្ខខ័ណ្ឌតតាំងចំពោះតតិយជន**

ការជូនដំណឹង ឬការយល់ព្រម មិនអាចតតាំងនឹងតតិយជន ក្រៅពីកូនបំណុលបានឡើយ បើមិនបានធ្វើឡើងដោយលិខិតដែលមានចុះកាលបរិច្ឆេទស្ពាព (មាត្រា៥០៣-២, មាត្រា ៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី)។ តតិយជន រួមមាន អនុប្បទានិក, ម្ចាស់បំណុលរបស់អនុប្បទាយីដែលបានរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធ្វើអនុប្បទាន, និងម្ចាស់បំណុលរបស់អនុប្បទាយីដែលមានសិទ្ធិលើការបញ្ចាំលើសិទ្ធិលើបំណុលដែលត្រូវបានធ្វើអនុប្បទាន (ម.៨៤០, ម.៨៤១)។

ក្នុងករណីសិទ្ធិលើបំណុល ត្រូវបានធ្វើអនុប្បទានដល់បុគ្គលពីរនាក់ ឬច្រើននាក់ អនុប្បទានិកណា ដែលបានបំពេញល័ក្ខខ័ណ្ឌតតាំង (ការជូនដំណឹង ឬការយល់ព្រមមានចុះកាលបរិច្ឆេទស្ពាព) មុនគេ មានអាទិភាព។ លំដាប់ នៃពេលបំពេញល័ក្ខខ័ណ្ឌតតាំង គឺមិនកំណត់យកតាម កាលបរិច្ឆេទស្ពាពទេ ប៉ុន្តែត្រូវកំណត់ទៅតាម **ពេលវេលា នៃការមកដល់នៃការជូនដំណឹង ឬការយល់ព្រមរបស់កូនបំណុល** (ម.៥០៤-១)។ ករណីដែលមិនអាចកំណត់លំដាប់នៃពេលដែលការជូនដំណឹងនីមួយៗបានដល់ ឬពេលដែលកូនបំណុលបានយល់ព្រមទេ ត្រូវចាត់ទុកថាការជូនដំណឹងនីមួយៗបានដល់កូនបំណុល នៅ ពេលជាមួយគ្នា ឬកូនបំណុលបានយល់ព្រមជាមួយគ្នា។ ក្នុងករណីនេះ អនុប្បទានិកនីមួយៗអាចទាមទារ ឲ្យកូនបំណុលបានសងចំពោះសិទ្ធិលើបំណុលទាំងអស់ដែលខ្លួនបានទទួលដោយអនុប្បទាន។ ពេល ដែលកូនបំណុលបានសងចំពោះម្ចាស់បំណុលណាម្នាក់ កាតព្វកិច្ចត្រូវរលត់ (ម.៥០៥) ។

ឧទាហរណ៍ទី១



ឧទាហរណ៍ទី២




ឧទាហរណ៍ទី៣



ឧទាហរណ៍ទី៤




ឧទាហរណ៍ទី៥



**ចំណាំ៖** ប្រសិនបើអនុប្បទាយី មិនបានជូនដំណឹងដល់កូនបំណុល?

ដោយសារការជូនដំណឹងជាប្រយោជន៍របស់អនុប្បទានិក អនុប្បទាយីអាចមានការធ្វេសប្រហែសក្នុងការជូនដំណឹងដល់កូនបំណុល។ ប្រសិនបើអនុប្បទាយី មិនបានជូនដំណឹងដល់កូនបំណុលទេ អនុប្បទានិកអាចប្ដឹងទាមទារឲ្យអនុប្បទាយីជូនដំណឹងដល់កូនបំណុលទៅតុលាការបាន ។ បន្ទាប់ពីឈ្នះ និងទទួលបានសេចក្ដីសម្រេចចុងក្រោយ អនុប្បទានិកអាចផ្ញើសេចក្ដីសម្រេចទៅកូនបំណុលបាន ហើយកូនបំណុលត្រូវបានចាត់ទុកថា បានទទួលការជូនដំណឹងនៅពេលដែលទទួលបានសេចក្ដីសម្រេចចុងក្រោយ។ ប៉ុន្តែការធ្វើរបៀបនេះ គឺវាចំណាយពេលវេលាច្រើន ហើយមានផលវិបាកជាច្រើនផងដែរ ដូច្នេះ ដើម្បីបង្ខំឲ្យអនុប្បទាយីធ្វើការជូនដំណឹង អនុប្បទានិកគួរតែមានចែងអំពីកាតព្វកិច្ចរបស់ អនុប្បទាយីពីការជូនដំណឹងនៅក្នុងកិច្ចសន្យាអនុប្បទានសិទ្ធិលើបំណុលក្នុងពេលកំណត់ជាក់លាក់មួយ។ មានមធ្យោបាយមួយទៀត អាចអនុវត្តបានដែរ គឺអនុប្បទានិកព្រាងលិខិតជូនដំណឹងរួចទៅជួបជាមួយអនុប្បទាយីដើម្បីយកហត្ថលេខា បន្ទាប់មកយកទៅតុលាការបញ្ជាក់ពីកាលបរិច្ឆេទស្ថាពរ (ម.៨ ច្បាប់ស្ដីពីការអនុវត្តក្រម) និងបញ្ជូនទៅកូនបំណុលតាមលិខិតអនុសិដ្ឋ (ម.៧ ច្បាប់ស្ដីពីការអនុវត្តក្រម)។

## ៣- អានុភាពនៃការជូនដំណឹង និងការយល់ព្រម

ក្នុងករណីដែលមានតែការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌតតាំងទេ (មិនមានការយល់ព្រម) នោះកូនបំណុលអាចយកហេតុដែលអាចតតាំងចំពោះអនុប្បទាយី មកតតាំងចំពោះអនុប្បទានិកបាន (ម.៥០៥-២)។ គេអនុវត្តដូចគ្នាផងដែរ ករណីដែលកូនបំណុលផ្ដល់ការ**យល់ព្រមដោយមានការតវ៉ា**។ ផ្ទុយទៅវិញ ប្រសិនបើកូនបំណុលផ្ដល់**ការយល់ព្រមដោយគ្មានការតវ៉ា** កូនបំណុលមិនអាចលើកយក ហេតុណាមួយមកតវ៉ាជាមួយនឹងអនុប្បទាយី យកមកតតាំងចំពោះអនុប្បទានិកបានឡើយ(ម.៥០៥-១)។ គោលបំណងនៃការយល់ព្រមដោយគ្មានការតវ៉ា គឺធ្វើឡើងដើម្បីការពារទំនុកចិត្តរបស់អនុប្បទានិក និងសម្របសម្រួលក្នុងការផ្ទេរបំណុល។ នៅប្រទេសជប៉ុន ប្រសិនបើអនុប្បទានិកទទួលបាននូវផលប្រយោជន៍នៃការយល់ព្រមដោយគ្មានការតវ៉ា អនុប្បទានិកត្រូវតែជាជនសុចរិត គ្មានកំហុសធ្ងន់ធ្ងរ។

តើធ្វើយ៉ាងណាដើម្បីបែងចែករវាង **ការយល់ព្រមដោយមានការតវ៉ា** និង**ការយល់ព្រមដោយគ្មានការតវ៉ា**?

ប្រសិនបើ កូនបំណុលនិយាយថា "ខ្ញុំផ្ដល់ការយល់ព្រមចំពោះការធ្វើអនុប្បទាន ហើយខ្ញុំគ្មានការតវ៉ាទេ" នេះគឺបញ្ជាក់ច្បាស់ថា ជាការយល់ព្រមដោយគ្មានការតវ៉ា។ ប្រសិនបើកូនបំណុលនិយាយថា "ខ្ញុំផ្ដល់ការយល់ព្រមចំពោះការធ្វើអនុប្បទាន ប៉ុន្តែខ្ញុំមានការតវ៉ា" នេះអាចបញ្ជាក់បានថា ជាការយល់ព្រមដោយមានការតវ៉ា។ ចុះបើ កូនបំណុលនិយាយថា "ខ្ញុំផ្ដល់ការយល់ព្រមចំពោះការធ្វើអនុប្បទាន" តើមាន

ន័យយ៉ាងម៉េច? តាមការអនុវត្តនៅប្រទេសជប៉ុន ត្រង់នេះគឺគេបកស្រាយថា **ជាការផ្តល់ការយល់ព្រមដោយគ្មានការតវ៉ា**។ ប៉ុន្តែដោយពិចារណាទៅលើការប៉ះពាល់ដ៏ខ្លាំងនៃការផ្តល់ការយល់ព្រមដោយគ្មានការតវ៉ា ចំពោះកូនបំណុល មានមតិប្រឆាំងជាច្រើនលើកឡើងថា ករណីនេះជា**ការយល់ព្រមដោយមានការតវ៉ា**។

ឧទាហរណ៍៖ ការជូនដំណឹង ឬការយល់ព្រមដោយមានការតវ៉ា




ឧទាហរណ៍៖ ការយល់ព្រមដោយគ្មានការតវ៉ា (សន្មតថា អនុប្បទានិកសុចរិត)



## ៤-អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ

ក្នុងករណីសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ នោះក្នុងការធ្វើអនុប្បទាន គឺមិនចាំបាច់គិតពិចារណាអំពីល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទាន ដូចក្នុងករណីសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះទេ ដោយគ្រាន់តែធ្វើការប្រគល់មូលប័ត្រជាការស្រេច (មាត្រា៥០៦)។

- **សិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ៖** ជាសិទ្ធិលើបណុលដែលមិនត្រូវការប័ណ្ណតំណាងសិទ្ធិលើបំណុលសម្រាប់ការបង្កើត សម្រាប់រយៈពេលបន្ត សម្រាប់ការផ្ទេរ និងសម្រាប់ការអនុវត្តសិទ្ធិលើបំណុល និងម្ចាស់ បំណុលដែលបញ្ជាក់ដោយឈ្មោះ។

ឧទាហរណ៍៖ សិទ្ធិលើបំណុលលើកម្ចីប្រាក់របស់ ក មានចំពោះ ខ (កិច្ចសន្យាខ្ចីប្រាក់).....

- **សិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ៖** ជាសិទ្ធិលើបំណុល ដែលចាំបាច់ត្រូវការប័ណ្ណតំណាងសិទ្ធិលើបំណុលសម្រាប់ការបង្កើត សម្រាប់រយៈពេលបន្ត សម្រាប់ការផ្ទេរ និងការអនុវត្តសិទ្ធិលើបំណុល និងម្ចាស់បំណុលត្រូវបានបញ្ជាក់ដោយពិពរណ៌នា ឬការកាន់កាប់ប័ណ្ណតំណាងសិទ្ធិលើបំណុល។

ឧទាហរណ៍៖ មូលប្បទានប័ត្រ, ប័ណ្ណសងតាមបញ្ជា, សំបុត្រឡាន, សំបុត្រកុន.....។

**សេចក្តីសន្និដ្ឋាន៖**

<u>ផលប្រយោជន៍នៃការធ្វើអនុប្បទានសិទ្ធិលើបំណុល</u>

ឧទាហរណ៍ទី១៖



ឧទាហរណ៍ទី២៖




ករណី នៅប្រទេសជប៉ុន គេមានក្រុមហ៊ុនជាច្រើន ដែលជាក្រុមហ៊ុនទិញបំណុលបែបនេះ ហើយគេបានបែងចែកក្រុមហ៊ុនទាំងនោះ តាមប្រភេទរបស់គេ ដោយការបើកក្រុមហ៊ុនប្រភេទនីមួយៗ មានលក្ខខ័ណ្ឌផ្សេងៗគ្នា និងមានដើមទុនខុសៗគ្នា។

ខាងក្រោមជាឧទាហរណ៍ពាក់ព័ន្ធនឹងក្រុមហ៊ុន២ប្រភេទ ដែលមានលក្ខណៈងាយស្រួល យល់៖

ឧទាហរណ៍ទីមួយ៖ ក្រុមហ៊ុនប្រភេទ Servicer ជាក្រុមហ៊ុនដែលមានជំនាញខាងទារបំណុល ដល់កំណត់សង ប៉ុន្តែកូនបំណុលមិនព្រមសង ឬកូនបំណុលមិនមានលុយសង។



ឧទាហរណ៍ទី២៖ ក្រុមហ៊ុនប្រភេទ Factoring ជាក្រុមហ៊ុន ប្រមូលទិញតែបំណុលដែលមិនទាន់ដល់កំណត់សង។




-----------------------------

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៥

## ប្រធានបទ៖ អាហារកាតព្វកិច្ច

## ថ្ងៃទី ២៥ វិច្ឆិកា ២០១៤

# អាហារកាតព្វកិច្ច

## ១. ទស្សនាទាននៃអាហារកាតព្វកិច្ច

(១) ការរស់នៅក្នុងសង្គម តែងតែមានទំនាក់ទំនងគ្នា ទំនាក់ទំនងទាំងនេះ មាន លក្ខណៈជាទំនាក់ទំនងញាតិ និងទំនាក់ទំនងទ្រព្យ ហើយសម្រាប់ទំនាក់ទំនងញាតិដែលកំណត់ក្នុងច្បាប់ គឺទំនាក់ទំនងនេះ មានអានុភាពចម្បង ០២ **ទី១** សន្តតិកម្ម និង**ទី២** ទំនាក់ទំនងឪពុក-ម្តាយ និងកូន ដោយរាប់បញ្ចូលអាហារកាតពក្វិច្ច ជាអាទិ៍។

(២) អាហារកាតព្វកិច្ច ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅរបស់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា ដោយអាហារកាតព្វកិច្ចទាំងនេះមានបីទម្រង់ ទី១ **អាហារកាតព្វកិច្ចរវាងញាតិ** (មាត្រា ១១៤០ ដល់មាត្រា ១១៤៨) ទី២ **អាហារកាតព្វកិច្ចរវាងសហព័ទ្ធ** (មាត្រា ៩៦៦ និងមាត្រា ៩៧១) និង ទី៣**អាហារកាតព្វកិច្ចរវាងឪពុក-ម្តាយចំពោះកូនជាអនីតិជន** (មាត្រា ១០៣៤ និងមាត្រា ១០៥០)។

(៣) អាហារកាតព្វកិច្ច គឺជាជាអានុភាពនៃចំណងញាតិ ដែលសកម្មភាពនេះ គឺជាជំនួយផ្នែកហិរញ្ញវត្ថុ ចំពោះបុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពបានដោយខ្លួនឯង ដែលយើងហៅថា **ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច** រីឯភាគីម្ខាងទៀត ហៅថា **ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច**។

(៤) អាហារកាតព្វកិច្ច ដែលអាចក្លាយជាចំនួនទឹកប្រាក់នៃការ **ទ្រទ្រង់ជីវភាព** សម្រាប់បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច គឺជាទឹកប្រាក់ដែលនៅសល់ បន្ទាប់ពីបុគ្គលមានករណីយកិច្ចត្រូវទទួលបន្ទុកអាហារកាតព្វកិច្ចបានចំណាយសម្រាប់ជីវភាពគ្រួសារ ប្រពន្ធ កូន ចំណាយជាប្រចាំផ្ទាល់ខ្លួន ទៅតាមឋានៈក្នុងសង្គម ហើយចំនួនដែលនៅសល់នឹងក្លាយជាកម្មវត្ថុនៃអាហារកាតព្វកិច្ច។

## ២-បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច

(១) ជាគោលការណ៍ ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចគឺ ទី១ **ញាតិដែលរស់នៅជាមួយគ្នា** ទី២ **ញាតិលោហិតខ្សែផ្ទាល់** និងទី៣ **បងប្អូនបង្កើត** ហើយក្រៅពីអ្នកទាំងនោះ តុលាការអាចឲ្យ**ញាតិនៅក្នុងថ្នាក់ទី៣** ទទួលបន្ទុកករណីយកិច្ចអាហារកាតព្វកិច្ច ប្រសិនបើមាន**ស្ថានភាពពិសេស**។ **ស្ថានភាពពិសេស** គឺករណីដែលគ្មានញាតិ ដូចមានកំណត់ខាងលើ ឬមានញាតិដែលមានកំណត់ខាងលើ ប៉ុន្តែមិនអាចផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន ឬប្រសិនបើផ្គត់ផ្គង់បណ្តាលឲ្យធ្លាក់ខ្លួនក្រ ឬញាតិដែលមានកំណត់ខាងលើ នេះ មិនអាចទំនាក់ទំនងបាន ឬបាត់ខ្លួន។

(២) អាពាហ៍ពិពាហ៍ដែលត្រូវបានរលាយដោយសារមរណភាពរបស់សហព័ទ្ធម្ខាងអាហារកាតព្វកិច្ចរវាងញាតិ នៅតែមានអត្ថិភាពរវាងសហព័ទ្ធដែលនៅរស់ ជាមួយនឹងញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព លើកលែងតែ សហព័ទ្ធដែលនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មី ឬបង្ហាញឆន្ទៈផ្តាច់ទំនាក់ទំនងញាតិពន្ធតាមផ្លូវតុលាការ (CC៩៨១-២) ប៉ុន្តែ ប្រសិនបើ ស្ថានភាពផ្លាស់ប្តូរ តុលាការអាចលុបចោលនូវសេចក្តីសម្រេចនោះបាន[30]។

(៣) ប្រសិនបើជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចមានច្រើននាក់ ជននោះត្រូវកំណត់ជាក់លាក់ ដើម្បីឲ្យទទួលបន្ទុកអាហារកាតព្វកិច្ច តាមរយៈការពិភាក្សា ហើយប្រសិនបើការពិភាក្សាទទួលបរាជ័យ តុលាការត្រូវសម្រេចដោយពិចារណាទៅលើលទ្ធភាព ទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនដែលមានករណីយកិច្ច ហើយរាប់បញ្ចូលទាំងទំនាក់ទំនងបុគ្គល និងស្ថានភាពផ្សេងៗទៀត[31]។

## ៣-បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច

(១) ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច គឺជាអ្នកដែលទទួលប្រយោជន៍អំពីរបបអាហារកាតព្វកិច្ច ដោយសារស្ថានភាពដែលកំណត់ដោយច្បាប់ តាមរយៈចំណងញាតិ ជាអាទ៍ ហើយមានភាគីម្ខាងទៀត ដែលមានកាតព្វកិច្ចបំពេញកិច្ចនេះ ដោយសារតែច្បាប់កំណត់ ឬសេចក្តីសម្រេចរបស់តុលាការចំពោះបុគ្គលនោះ តាមរយៈការផ្គត់ផ្គង់ជីវភាពជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច។

---

[30] មាត្រា ១១៨០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

[31] មាត្រា ១១៨១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

(២) ប្រសិនបើមានជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចច្រើននាក់ ត្រូវកំណត់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចម្នាក់ ឬច្រើននាក់តាមការពិភាក្សា ហើយប្រសិនបើការពិភាក្សាមិនទទួលបានជោគជ័យ នោះទេ តុលាការនឹងធ្វើការសម្រេចដោយពិចារណាទៅលើលទ្ធភាព ទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ-ផ្លូវចិត្ត និង ទំនាក់ទំនងបុគ្គលរបស់ភាគី ហើយស្ថានភាពផ្សេងៗទៀត ផងដែរ។

(៣) ប្រសិនបើ មានភាពចាំបាច់ បុគ្គលមានសិទ្ធិទទួលអាហារកាតព្វកិច្ច អាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ដោយស្នើសុំឲ្យតុលាការចេញដីកាសម្រេចបង្គាប់ឲ្យចាត់ចែងជាបណ្ដោះអាសន្ន (មាត្រា ៤៣ នៃច្បាប់នីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង) និង CC៥៣១ ចំណុច "គ"។ នៅពេលដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងសេចក្ដីបញ្ជាក់ដំបូង ហើយប្រសិនបើ បំពេញគ្រប់លក្ខខណ្ឌ តុលាការនឹងចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នតាមការស្នើសុំ។ បន្ទាប់មក បុគ្គលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ត្រូវដាក់បណ្ដឹងអង្គសេចក្ដី ដែលជាបណ្ដឹងទាមទារឲ្យផ្ដល់អាហារកាតព្វកិច្ច ហើយបណ្ដឹងប្រភេទនេះ គឺជាប្រភេទរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដោយអ្នកដាក់ពាក្យសុំត្រូវបំពេញតាមលក្ខខណ្ឌនៃមាត្រា ២៦ នៃច្បាប់នីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (*គំរូពាក្យសុំ និងដីកាសម្រេចគឺជាឧបសម្ព័ន្ធនៃមេរៀននេះ*)។

## ៤.ការផ្គត់ផ្គង់ ការផ្លាស់ប្ដូរ ឬការលុបចោល និងអនុប្បទានអាហារកាតព្វកិច្ច

(១) របៀបផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាមធ្យោបាយមួយសម្រាប់ធានា ឬរក្សាជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយពិចារណាទៅលើ លទ្ធភាពរបស់ជនដែលមានកាតព្វកិច្ច និងស្ថានភាពផ្សេងៗ តាមរយៈការពិភាក្សាគ្នា ហើយប្រសិនបើការពិភាក្សាទទួលបរាជ័យ តុលាការនឹងធ្វើការសម្រេច[32]។

(២) របៀបផ្គត់ផ្គង់អាហារកាតព្វកិច្ច ជាវិធានការមួយសម្រាប់ជាមូលដ្ឋានក្នុងការ កំណត់មធ្យោបាយជាក់លាក់ចំពោះអ្នកដែលមានកាតព្វកិច្ច ដើម្បីកុំឲ្យមានបន្ទុកធ្ងន់ធ្ងរ និងមានលក្ខណៈមិនសមស្របដែលនឹងនាំឲ្យមិនមានប្រសិទ្ធភាព ហើយប៉ះពាល់ទៅដល់ជីវភាពរបស់អ្នកមានកាតព្វកិច្ចទៅវិញ។ ហេតុនេះ ត្រូវបកស្រាយពាក្យ "ជីវភាព" និងគោលបំណងនៃរបបអាហារកាព្វកិច្ច ដែលមានខ្លឹមសារថា របបអាហារកាតព្វកិច្ចត្រូវបានបង្កើតឡើង ដើម្បីធ្វើការផ្ដល់ប្រាក់ ឬទ្រព្យជាប្រចាំសម្រាប់ទ្រទ្រង់ជីវភាព

[32] មាត្រា ១១៩២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

ចាំបាច់របស់ជនដែលមានសិទ្ធិទទួលរបបអាហារកាតព្វកិច្ច ដូចជា អាហារបីពេល ស្នាក់នៅ ស្លៀកពាក់ រៀនសូត្រ សមរម្យ ឬព្យាបាលជម្ងឺជាធម្មតា លើសពីនេះ មិនគប្បីអនុវត្តនោះឡើយ។ គោលបំណងនៃរបបអាហារកាតព្វកិច្ចគឺផ្គត់ផ្គង់ជីវភាពរស់នៅជាអប្បបរមា ប៉ុន្តែអាហារកាតព្វកិច្ចរវាងសហព័ទ្ធ ដែលកើតចេញពីអានុភាពនៃអាពាហ៍ពិពាហ៍ និងអាហារកាតព្វកិច្ចរបស់ឳពុក-ម្ដាយចំពោះកូនជាអនីតិជន ដែលកើតចេញពីអានុភាពនៃអំណាចមេបា គឺជាទម្រង់នៃការ**ផ្គត់ផ្គង់ជីវភាពរស់នៅ** ដោយតម្រូវឲ្យជនទាំងនេះមានកម្រិតជីវភាពដូចគ្នា។ ផ្ទុយទៅវិញ អាហារកាតព្វកិច្ចរវាងញាតិ (**មាត្រា ១១៤០ ដល់មាត្រា ១១៤៥**) ត្រូវបានបកស្រាយថា ត្រូវផ្គត់ផ្គង់កូន ប្រពន្ធ រក្សាជីវភាពរបស់ខ្លួនឲ្យបានសមរម្យទៅនឹងមុខរបរ និងឋានៈរបស់ខ្លួនក្នុងសង្គម ហើយទ្រព្យដែលនៅសល់នឹងក្លាយជាកម្មវត្ថុសម្រាប់ផ្គត់ផ្គង់ជីវភាពញាតិក្រីក្រ ដែលជាទម្រង់នៃ**ករណីយកិច្ចទ្រទ្រង់ជីវភាព**។

(៣) ប្រសិនបើមានការផ្លាស់ប្ដូរស្ថានភាព ក្រោយពីបានពិភាក្សា ឬក្រោយពីមានការសម្រេចសេចក្ដីចំពោះជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ឬជនដែលទទួលអាហារកាតព្វកិច្ចជាក់លាក់ ឬរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ភាគីអាចផ្លាស់ប្ដូរបាន មានន័យថា ទំនាក់ទំនងនៃអាហារកាតព្វកិច្ចអាចត្រូវបានលុបចោល ឬផ្លាស់ប្ដូរអាស្រ័យទៅតាមស្ថានភាពនៃការពិភាក្សា និងប្រសិនបើការពិភាក្សាមិនទទួលបានជោគជ័យ តុលាការនឹងបង្គាប់ឲ្យលុបចោល ឬផ្លាស់ប្ដូរសេចក្ដីសម្រេចមុន[33]។

(៤) សិទ្ធិទាមទារអាហារកាតព្វកិច្ច ជាសិទ្ធិផ្ដាច់មុខរបស់បុគ្គលដែលត្រូវការចាំបាច់នូវអាហារកាតព្វកិច្ចនោះ ដោយសិទ្ធិនេះមិនអាចប្រើប្រាស់តាមទំនើងចិត្តរបស់ម្ចាស់សិទ្ធិនោះទេ ហើយអាហារកាតព្វកិច្ច ជាសិទ្ធិដែលមានលក្ខណៈដោយចំពោះសម្រាប់បុគ្គល និងជាសិទ្ធិដែលមិនអាចក្លាយជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬការបង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬសម្រាប់វិស័យជំនួញនោះឡើយ ហេតុនេះ អាហារកាតព្វកិច្ចមិនអាចក្លាយជាកម្មវត្ថុនៃការរឹបអូសតាមផ្លូវតុលាការ (មាត្រា ៣៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី), មិនអាចធ្វើឧបាទេសកម្ម (មាត្រា ៥២២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) និងមិនអាចធ្វើសន្ធតិកម្ម បាននោះទេ (មាត្រា ១១៤៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។

[33] មាត្រា ១១៤៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

## ៥. អាហារកាតព្វកិច្ច និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

(១) មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា "សិទ្ធិនិងករណីយកិច្ចរបស់ឪពុកម្តាយ ដែលមិនរស់នៅជាមួយកូន នៅក្រោយពេលលែងលះ ត្រូវមានករណីយកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន"។ ករណីយកិច្ចនេះ គឺជាអានុភាពនៃអំណាចមេបា ដែលជា**អាហារកាតព្វកិច្ចរវាងឪពុក-ម្តាយ ចំពោះកូនជាអនីតិជន**។

(២) មាត្រា ១០៣៤ នៃក្រមរដ្ឋប្បវេណី ជាផ្នែកមួយនៃករណីឪពុក-ម្តាយ មានកូនក្នុងបន្ទុក ព្រោះស្ថានភាពនេះ ជាករណីយកិច្ចរបស់អ្នកមានអំណាចមេបាចំពោះកូនជា អនីតិជន ហើយអ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ច ត្រូវបីបាច់ថែរក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ មួយវិញទៀត នៅក្នុងករណីលែងលះ ដែលមានកំណត់នៅក្នុងមាត្រា ១០៣៧ "ការសម្រេចអំពីអ្នកមានអំណាច មេបានៅពេលលែងលះ" គឺជាស្ថានភាពមួយ ដែលភាគីម្ខាងទៀតដែលគ្មានអំណាចមេបា ក្រោយការលែងលះ មានកាតព្វកិច្ចការពារផលប្រយោជន៍របស់កូន។

(៣) ប្រសិនបើមានការទាមទារអាហារកាតព្វកិច្ចពីញាតិរបស់អនីតិជន ដែលមានទ្រព្យសម្បត្តិដ៏ច្រើន ដែលទទួលបានតាមរយៈមតកសាសន៍របស់ឪពុក-ម្តាយខ្លួន ដោយ មានអ្នកអាណាព្យាបាលដែលត្រូវបានតែងតាំងដោយឪពុក-ម្តាយរបស់អនីតិជន ជាអាទិ៍ ហើយញាតិនោះមានបំណងឲ្យអនីតិជនទទួលបន្ទុកអាហារកាតព្វកិច្ច។ ស្ថានភាពនេះ ប្រសិនបើអនីតិជន យល់ព្រមមិនមានបញ្ហានោះទេ ប៉ុន្តែប្រសិនបើអនីតិជនមិនព្រម អាហារកាតព្វកិច្ចនោះ ក៏មិនអាចអនុវត្តបានផងដែរ ទោះបីជាមិនមានកំណត់ជាក់លាក់នៅក្នុងក្រមរដ្ឋប្បវេណីក៏ពិតមែន ប៉ុន្តែជាគោលការណ៍ ច្បាប់តែងតែងបញ្ញតិគ្រាំទ្រផលប្រយោជន៍របស់អនីតិជន។ អាហារកាតព្វកិច្ច គឺជាកាតព្វកិច្ច ឬការចំណាយដែលផ្ទុយពីផលប្រយោជន៍របស់អនីតិជន ហេតុនេះ អនីតិជនមិនអាចក្លាយជាជនដែលមានករណីយកិច្ចទទួលបន្ទុកអាហារកាតព្វកិច្ច ដូចមានកំណត់នៅក្នុងមាត្រា ១៤៤០ នៃក្រមរដ្ឋប្បវេណីនោះឡើយ ហើយគប្បីតម្កល់ឧត្តមផលប្រយោជន៍របស់អនីតិជន ***នេះជាទ្រឹស្តីទី១*** ដែលយើងហៅថា***ការបកស្រាយក្រម***។ ប៉ុន្តែមាន***ទ្រឹស្តីទី២*** ដែលយើងហៅថា ***ការអនុវត្តក្រម*** ដែលមានខ្លឹមសារថា ទោះបីជាអនីតិជនក៏ត្រូវទទួលខុសត្រូវចំពោះអាហារកាតព្វកិច្ច ផងដែរ ឲ្យតែបំពេញគ្រប់ល័ក្ខខ័ណ្ឌដូចមានកំណត់ក្នុងមាត្រា CC១១៤០។ ចំពោះទ្រឹស្តីទាំងពីរនេះ ទ្រឹស្តីដែលមានប្រជាប្រិយគឺទ្រឹស្តីទី២ ប៉ុន្តែ ប្រសិនបើការអនុវត្តជាបន្តបន្ទាប់ មានការប្រែប្រួល ទ្រឹស្តីទី១ នឹងអាចត្រូវបានយកមកអនុវត្ត។

## ៦.អាហារកាតព្វកិច្ច និងអាហារកិច្ច

(១) នៅក្នុងមាត្រា ៩៦៦ បានកំណត់ថា ប្ដី-ប្រពន្ធ ត្រូវមានជីវភាពរួមគ្នា សហការសង្គ្រោះគ្នាទៅវិញទៅមក និងមាត្រា ៩៧១ បានបញ្ញត្តិថា ប្ដី-ប្រពន្ធត្រូវមានចំណែកបន្ទុកនៃសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។ ករណីយកិច្ចនេះ គឺជា**អាហារកាតព្វកិច្ចរវាងសហព័ទ្ធ** ដែលជាអានុភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់។

(២) នៅក្នុងមាត្រា ៧៦ និងមាត្រា ៧៧ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩ បានកំណត់ថា ករណីមានការលែងលះ ភាគីដែលគ្មានកំហុសអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ទៅតាមលទ្ធភាពរបស់ភាគីនោះ ឬតាមការព្រមព្រៀងរបស់ភាគី ហើយប្រសិនបើមិនឯកភាពគ្នា តុលាការនឹងសម្រេច ប៉ុន្តែប្រសិនបើជនបានទទួលអាហារកិច្ច បានរៀបអាពាហ៍ពិពាហ៍ថ្មី ជននោះនឹងលែងទទួលបានអាហារកិច្ចបន្តទៀតហើយ។ តុលាការអាចបង្កើន ឬបន្ថយចំនួនអាហារកិច្ចប្រសិនបើមានសំណូមពររបស់ភាគី ដោយផ្អែកទៅលើលទ្ធភាពរបស់ភាគីដែលផ្ដល់អាហារកិច្ចហើយអាហារកិច្ចអាចផ្ដល់ជាប្រាក់ ឬវត្ថុផ្សេងៗ។

(៣) ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចរវាងសហព័ទ្ធ គឺជាអានុភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់ ដោយតម្រូវឲ្យជួយសង្គ្រោះគ្នាទៅវិញទៅមក ប៉ុន្តែអាហារ កាតព្វកិច្ចដែលមានកំណត់ក្នុងមាត្រា ១១៤០ ដល់មាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីសំដៅអាហារកាតព្វកិច្ចរវាងញាតិ ដោយមិនរាប់បញ្ចូលទំនាក់ទំនងសហព័ទ្ធ និងឪពុក- ម្ដាយចំពោះកូនជាអនីតិជននោះឡើយ។

## ៧.ការគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច

(១) នៅពេលដែលអាចកំណត់ភាគី, ខ្លឹមសារ, នីតិវិធីនៃការទាមទារ និងវិសាលភាព នៃបន្ទុកអាហារកាតព្វកិច្ច យើងត្រូវកំណត់ចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ចប្រចាំខែ ដោយពិចារណាអំពីស្ថានភាពជីវភាពរបស់បុគ្គលមានករណីយកិច្ចទទួលបន្ទុលអាហារកាតព្វកិច្ច ការចំណាយនានាក្រោយផ្គត់ផ្គង់ជីវភាពគ្រួសារ ស្ថេរភាពនៃសេដ្ឋកិច្ចរបស់ប្រទេស ដើម្បីជាមូលដ្ឋាននៃរូបមន្តមួយដ៏សមរម្យ។

(២) នេះជារូបមន្តដែលស្នើឡើងសម្រាប់ជាគំនិតយោបល់៖

¥កម្មវត្ថុនៃអាហារកាព្វកិច្ច = ចំណូលសរុបរបស់អ្នកមានកាតព្វកិច្ច - ពន្ធ
ជាអាទ៍ - ចំណាយលើអាជីវកម្ម - ចំណាយពិសេស

¥សោហ៊ុយសម្រាប់ជីវភាពអប្បបរមារបស់បុគ្គលមានសិទ្ធិ = (ថ្លៃស្នាក់នៅ
+អាហារបីពេល+សំលៀកបំពាក់ + ថ្លៃពេទ្យធម្មតា) –
ចំណូលរបស់អ្នកមានសិទ្ធិ

¥ទឹកប្រាក់នៃអាហារកាតព្វកិច្ច = សោហ៊ុយសម្រាប់ជីវភាពអប្បបរមា ឬ
កម្មវត្ថុនៃអាហារកាតព្វកិច្ចដែលទាបជាង

<u>កំណត់ចំណាំ</u> ៖

- ពន្ធ ជាអាទ៍ ៖ ពន្ធលើប្រាក់បៀវត្សន៍, ពន្ធធានារ៉ាបរង
- ចំណាយលើអាជីវកម្ម ៖ ចំណាយចាំបាច់សម្រាប់អាជីវកម្ម
- ចំណាយពិសេស៖ ចំណាយថេរក្នុងជីវភាពរស់នៅ ដូចជា ការចំណាយជាប្រចាំ សម្រាប់អាហារ ប្រពន្ធ ថ្លៃសិក្សាកូន និងការចំណាយជាប្រចាំផ្ទាល់ខ្លួន
- កម្មវត្ថុនៃអាហារកាតព្វកិច្ច៖ ទឹកប្រាក់ដែលនៅសល់បន្ទាប់ពីចាត់ចែងសម្រាប់ជីវភាពប្រចាំថ្ងៃរបស់អ្នកមានកាតព្វកិច្ច និងគ្រួសារអ្នកមានកាតព្វកិច្ច
- សោហ៊ុយជីវភាពអប្បបរមា ៖ ថ្លៃចំណាយទាបបំផុតដែលអាចទ្រទ្រង់ជីវភាព
- ទឹកប្រាក់នៃអាហារកាតព្វកិច្ច៖ គឺជាទឹកប្រាក់ដែលត្រូវបង់ជាក់ស្តែងរបស់អ្នកមានករណីយកិច្ច ទទួលបន្ទុកអាហារកាតព្វកិច្ច ចំពោះអ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ច

## ៨- ករណីសិក្សា

(១) X និង Y គឺជាបងប្អូនបង្កើត។ X បានធ្លាក់ខ្លួនក្រ ដោយមិនអាចធ្វើការបាន X បានស្នើសុំមករស់ជាមួយ Y ប៉ុន្តែ Y បានបដិសេធ។ X បាននិយាយថា ប្រសិនបើមិនឲ្យស្នាក់នៅជាមួយ សុំជួយទ្រទ្រង់ជីវភាពខ្លះៗ ផង ប៉ុន្តែ Y នៅតែបដិសេធ។ Y មានប្រពន្ធ និងកូនចំនួន ០២ នាក់ ដោយកូនទី១ មានអាយុ ១០ ឆ្នាំ និងកូនទី២ អាយុ ៥ ឆ្នាំ ហើយប្រពន្ធរបស់ Y ជាស្ត្រីមេផ្ទះ។ Y ជាបុគ្គលិកជាប់ខ្ពស់នៃក្រុមហ៊ុនឯក

ជនមួយ ដោយទទួលបានប្រាក់ខែចំនួន US$ ១,០០០ (មួយពាន់) ដុល្លារអាមេរិក។ Y មានផ្ទះផ្ទាល់ខ្លួន ប៉ុន្តែបច្ចុប្បន្ន កូនទី១របស់ Y កំពុងសម្រាកពេទ្យ ដោយកើតជម្ងឺគ្រុនឈាម ហើយប្រហែលជាត្រូវសម្រាកពេទ្យមួយសប្តាហ៍ និងចំណាយប្រាក់ចំនួន US$ ១,០០០ (មួយពាន់)។

តើករណីនេះត្រូវដោះស្រាយដូចម្តេចតាមច្បាប់?

(២) X មានប្រពន្ធឈ្មោះ Y ប៉ុន្តែ Y បានស្លាប់កាលពី៥ ឆ្នាំ មុន។ X មានកូនបីនាក់ឈ្មោះ A B និង C ហើយមានបងប្រុសម្នាក់ឈ្មោះ D។ X រស់នៅជាមួយនឹង B និង D ហើយបច្ចុប្បន្ននេះ X បាត់បង់សមត្ថភាពធ្វើការ និងមិនអាចរកប្រាក់ចំណូលបាននោះទេ។ X បានស្នើសុំឲ្យ B ជួយ ប៉ុន្តែ B បានបញ្ជាក់ថា A និង C មានលទ្ធភាពខ្ពស់ជាងខ្លួន រីឯ D ក៏ជាអ្នកមាន ផងដែរ សូមឲ្យពួកគេជួយ ទើបសមរម្យ។ B គ្មានប្រពន្ធកូននោះទេ និងធ្វើការងាររដ្ឋដោយទទួលបានប្រាក់ខែចំនួន US$ ៣០០ (បីរយ) ដុល្លារអាមេរិក ចំណែក A គឺជាពាណិជ្ជករ ដោយចំណូលប្រចាំឆ្នាំគឺ US$ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ហើយមានប្រពន្ធ (ពាណិជ្ជករ) និងកូនពីរនាក់ រីឯ C គឺជាគ្រូពេទ្យផ្នែកកុមារ មានកូនម្នាក់ ចំណែកប្តីបានលែងលះគ្នា និងបម្រើការងារនៅក្នុងគ្លីនីកឯកជនមួយ ទទួលបានប្រាក់ខែ និងប្រាក់រង្វាន់ ជាអាទិ៍ សរុប ២,០០០ (ពីរពាន់) ដុល្លារអាមេរិកក្នុងមួយខែ ហើយ D គឺនៅលីវ និងជាវិស្វករសំណង់បម្រើការងារនៅក្រុមហ៊ុនសំណង់ទទួលបានប្រាក់ខែ US$ ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិកក្នុងខែ ។

តើករណីនេះត្រូវដោះស្រាយដូចម្តេចតាមច្បាប់?

(៣) X បានស្លាប់ទៅដោយបានបន្សល់ទុកនូវមតិកជាច្រើនដែលមានតម្លៃ US$១,០០០,០០០ (មួយលាន) ដុល្លារអាមេរិក និងផ្ទះវីឡាមួយសម្រាប់កូនតែម្នាក់គត់របស់ X ឈ្មោះ Y ដែលទើបតែមានអាយុ ១០ ឆ្នាំ ហើយ X បានតែងតាំងអ្នកអាណាព្យាបាលសម្រាប់កូនខ្លួនឈ្មោះ Z សម្រាប់គ្រប់គ្រងកិច្ចការទាំងនេះ។ X មានប្អូនប្រុសបង្កើតម្នាក់ឈ្មោះ O ដែលបានបែកគ្នាជាយូរមកហើយ ទើបត្រលប់មកវិញ និងបានស្នើសុំឲ្យ X ជួយដោយសារខ្វះលទ្ធភាពគ្រប់បែបយ៉ាង ហើយនៅពេលដឹងថា X បានស្លាប់ និងបន្សល់ទុកមតិកជាច្រើន O បានស្នើសុំឲ្យកូនរបស់ X ឲ្យជួយគឺ Y។ Z ដែលជាអ្នកតំណាងឲ្យ Y បានបដិសេធ។ តើករណីនេះត្រូវដោះស្រាយដូចម្តេចតាមច្បាប់?

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច**

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ X ភេទស្រី អាយុ ៥០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៤ រាជធានីភ្នំពេញ។

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ Y ភេទប្រុស អាយុ ៥០ ឆ្នាំ សញ្ជាតិខ្មែរ មាន អាសយដ្ឋានស្ថិតនៅ ផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំតុលាការចេញដីកាសម្រេចដែលមានខ្លឹមសារថា ៖

(១) បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន **US$ ២០០ (ពីររយ) ដុល្លារអាមេរិក** ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ Y

**យោង** ៖

- មាត្រា ១១៤០ ដល់មាត្រា ១១៤៣ នៃក្រមរដ្ឋប្បវេណី
- មាត្រា ០៣ និងមាត្រា ២៦ នៃច្បាប់នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

សេចក្តីដូមានកំណត់ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន**មេត្តាជ្រាបថា៖

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

.

**ក-អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

-

-

-

**ខ-ភស្តុតាងជាឯកសារ**

-

-

-

សេចក្តីដូចជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេច តាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ស្នាមម្រាមដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ០១

ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

-ដីកាសម្រេចលេខ ០១ "ក"

ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤

**ដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច**

យើង W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ០៣ និងមាត្រា ២៦ នៃច្បាប់នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានឃើញមាត្រា ១១៤០ ដល់មាត្រា ១១៤៣ នៃក្រមរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ០១ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

រវាងអ្នកដាក់ពាក្យសុំឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

និងភាគីម្ខាងទៀតនៃពាក្យសុំឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**ខ្លឹមសារនៃដីកាសម្រេចដែលត្រូវបានស្នើសុំដោយអ្នកដាក់ពាក្យសុំ** (X)៖

-បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន **US$ ២០០ (ពីររយ) ដុល្លារអាមេរិក** ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ Y

**ក.ដំណើររឿង**

ក-១ ការអះអាងរបស់ X ៖

ក-២ ការអះអាងរបស់ Y ៖

**ខ.ភស្តុតាងក្នុងសំណុំរឿង**

ខ.១ ភស្តុតាងរបស់ X ៖

ខ.២ ភស្តុតាងរបស់ Y ៖

## នាពេលសាកសួរភាគីនៃសំណុំរឿង

-

-

-

## សំអាងហេតុ

-

-

-

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១.បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន US$ ២០០ (ពីររយ) ដុល្លារអាមេរិក ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ ទៅឲ្យឈ្មោះ X

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ Y

ដីកាសម្រេចនេះទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ នៅចំពោះមុខអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតនៃពាក្យសុំ។

ទុកសិទ្ធិឲ្យប្តឹងជំទាស់ក្នុងអំឡុងពេល ០២ ( ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤

**ចៅក្រម**

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៦

## ប្រធានបទ៖ អនិតិសង្វាស

## ថ្ងៃទី ២៣ ខែ មករា ២០១៥

# អនីតិសង្វាស

## ១.ទស្សនាទាននៃអនីតិសង្វាស

(១) អាពាហ៍ពិពាហ៍គឺជាចំណងគតិយុត្តដែលមានលក្ខណៈស្មុគស្មាញ និងមានបុគ្គលពាក់ព័ន្ធជាច្រើន ដែលតម្រូវឲ្យមានយន្តការគាំពារ។ អាពាហ៍ពិពាហ៍ស្របច្បាប់ គឺភាគីនៃចំណងអាពាហ៍ពិពាហ៍បានបំពេញល័ក្ខខ័ណ្ឌសារធាតុ ដូចជា នីតិជន, បុរស និងនារី ជាអាទិ៍និងបានបំពេញល័ក្ខខ័ណ្ឌទម្រង់ ដូចជា **ទី១** ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ **ទី២** ការជូនដំណឹងជាសាធារណៈ (ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍) **ទី៣** ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ **ទី៤** ចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ហើយសំបុត្រអាពាហ៍ពិពាហ៍ គឺជាភស្តុតាងបញ្ជាក់អំពីអាពាហ៍ពិពាហ៍ (**សមគ្គសង្វាសតាមច្បាប់**)។

(២) នៅពេលភាគីនៃអាពាហ៍ពិពាហ៍មិនបានបំពេញល័ក្ខខ័ណ្ឌច្បាប់ អាពាហ៍ពិពាហ៍ស្របច្បាប់មិនកើតឡើងនោះទេ ប៉ុន្តែអាពាហ៍ពិពាហ៍លក្ខណៈជាក់ស្តែង ទៅតាមប្រពៃណី ទំនៀមទម្លាប់នៃសង្គមបានកើតឡើង ករណីនេះ យើងហៅថា **អនីតិសង្វាស** (**សមគ្គសង្វាសតាមព្រឹត្តន័យ**)។

(៣) អនីតិសង្វាសជាទំនាក់ទំនង ដែលមិនត្រូវបានទទួលស្គាល់ជាសហព័ទ្ធ ឬ ប្តីប្រពន្ធស្របច្បាប់ ប៉ុន្តែ បុគ្គលនោះបានរស់នៅជាមួយគ្នា មានជីវភាពរួមគ្នា ដូចប្តី-ប្រពន្ធ និងមានឆន្ទៈរៀបអាពាហ៍ពិពាហ៍។

(៤) អនីតិសង្វាស និងអាពាហ៍ពិពាហ៍ស្របច្បាប់ ខុសគ្នាត្រង់ អត្ថិភាពនៃការចុះបញ្ជី អាពាហ៍ពិពាហ៍។ រីឯ អនីតិសង្វាស និងកំជាប់ពាក្យ ខុសគ្នាត្រង់ កំជាប់ពាក្យ មានឆន្ទៈនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត មានន័យថា មិនទាន់មានអាពាហ៍ពិពាហ៍ជាក់ស្តែង (CC៩៨៩)។ អនីតិសង្វាស និងសង្សា ឬគូដណ្តឹង គឺមានលក្ខណៈស្រពិចស្រពិល ស្ថិតនៅត្រង់ ថាតើមានជីវភាពរួមគ្នា និងមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ឬយ៉ាងណា?

(៥) ការបង្កើតអនីតិសង្វាសមិនតម្រូវឲ្យបំពេញល័ក្ខខ័ណ្ឌដូចអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ ហើយជាទូទៅ ទោះបីជាអនីតិជន ឬអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ក៏អនីតិសង្វាសអាចត្រូវបានបង្កើតឡើង ផងដែរ (CC៩៨៨, CC៩៨៩, CC៩៥៣)។ មួយវិញទៀត អនីតិសង្វាសអាចបង្កើត ក្នុងករណីបុគ្គលម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ មានទំនាក់ទំនងអនីតិសង្វាស

ជាមួយនឹងជនផ្សេងទៀត ក្រៅពីសហព័ទ្ធរបស់ខ្លួន ប៉ុន្តែសហព័ទ្ធស្របច្បាប់ត្រូវបានការពារ (CC៩៤៩)។ អនីតិសង្វាសរវាងញាតិ មិនអាចបង្កើតបានឡើយ (អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិពន្ធ) (CC៩៥១,CC៩៥២)។

(៦) តើភេទដូចគ្នាអាចបង្កើតអនីសង្វាសបានឬទេ?

នៅក្នុងក្រមរដ្ឋប្បវេណី ប្ដី-ប្រពន្ធ ត្រូវតែភេទផ្ទុយគ្នា ទើបអាចរៀបអាពាហ៍ពិពាហ៍ដោយស្រប ច្បាប់ (CC៩៤៨) ហេតុនេះ ភេទដូចគ្នា នឹងត្រូវពិចារណាថាតើជាអនីតិសង្វាស ឬស្ថិតក្នុងស្ថានភាពផ្សេង ទៀត។

(៧) ប្រសិនបើ គិតអំពីលក្ខណៈសង្គម ហេតុអ្វីមានអត្ថិភាពនៃអនីតិសង្វាស?

**@ ករណីប្រទេសជប៉ុន**

- ភាគីម្ខាងនៃអនីតិសង្វាស បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់រួចហើយ
- ភាគីនៃអនីតិសង្វាស ជាអនីតិជន
- ភាគីនៃអនីតិសង្វាស មិនអាចរៀបអាពាហ៍ស្របច្បាប់បាន ដោយសារ ស្ថានភាពផ្លូវចិត្ត ដូចជា មិនចង់មានចំណងផ្លូវច្បាប់ ឬមិនចង់ដូរត្រកូល ជាអាទិ៍
- ភាគីនៃអនីតិសង្វាស យឺតយ៉ាវក្នុងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ភាគីនៃអនីតិសង្វាស យល់ថាការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមាន សារៈសំខាន់ជាងការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ ជាអាទិ៍

**@ ករណីប្រទេសកម្ពុជា**

- ភាគីនៃអនីតិសង្វាស យល់ថាការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមាន សារៈសំខាន់ជាងការរៀបអាពាហ៍ពិពាហ៍តាមច្បាប់
- ភាគីនៃអនីតិសង្វាស យល់ថានីតិវិធីនៃអាពាហ៍ពិពាហ៍ស្របច្បាប់មាន លក្ខណៈស្មុគស្មាញ ចំណាយពេលវេលា ចំណាយថវិកា ឬមិនចង់ឲ្យមានចំណងផ្លូវច្បាប់ នៅ ពេលលែងលះ ត្រូវដំណើរការក្ដីនៅតុលាការ ជាអាទិ៍
- ភាគីនៃអនីតិសង្វាស មិនដឹង តើត្រូវធ្វើដូចម្ដេច ទើបទទួលបានអាពាហ៍

ពិពាហ៍ស្របច្បាប់ និងមិនយល់អំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ស្របច្បាប់ ជាអាទិ៍

- ការផ្សព្វផ្សាយអំពីអគ្រានុកូលដ្ឋានមិនទាន់ទូលំទូលាយខ្លាំង
- ស្ថានភាពមួយចំនួនទៀតដូចករណីប្រទេសជប៉ុន ផងដែរ

**តើអនីតិសង្វាសនឹងផ្តល់នូវវិបាកគតិយុត្តអ្វីខ្លះ**?

## ២.អានុភាពនៃអនីតិសង្វាស

✍ ប្រសិនបើបំពេញល័ក្ខខ័ណ្ឌនៃអនីតិសង្វាស នាំឲ្យមានវិបាកគតិយុត្តមួយចំនួនដែលត្រូវបានបកស្រាយប្រដូចនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ ដូចជា ៖

(១) ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក (CC៩៦៦)

ប្រសិនបើបុរស-នារីនោះ រស់នៅជាមួយគ្នាដូចប្តី-ប្រពន្ធ មានជីវភាពរួមគ្នា មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកថាជា អនីតិសង្វាស ក៏ដោយ ក៏ភាគីនៃអនីតិសង្វាស មានករណីយកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមកដូចប្តី-ប្រពន្ធ ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ (អាហារកាតព្វកិច្ចរវាងសហព័ទ្ធ) ផងដែរ។

(២) សេរីភាពនៃការជ្រើសរើសវិជ្ជាជីវៈ សិទ្ធិចូលរួមក្នុងសកម្មភាពសង្គម (CC៩៦៧)

ភាគីនៃអនីតិសង្វាស មានលក្ខណៈស្មើគ្នាជាលក្ខណៈសារធាតុក្នុងសកម្មភាពសង្គម ឬការប្រកបការងារ ដូចប្តី-ប្រពន្ធស្របច្បាប់ ផងដែរ។

(៣) បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ (CC៩៧១)

ប្តី-ប្រពន្ធស្របច្បាប់ ត្រូវទទួលខុសត្រូវចំពោះសោហ៊ុយអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត ហើយនៅពេលប្តី ប្រពន្ធរស់នៅបែកគ្នា សហព័ទ្ធមានចំណូលតិច អាចទាមទារឲ្យសហព័ទ្ធដែលមានចំណូលច្រើន ជួយទ្រទ្រង់ជីវភាពរហូតដល់ពេលលែងលះជាស្ថាពរ ឬចាប់ផ្តើមរស់នៅជាមួយគ្នា សាជាថ្មី។ ទោះបីជា អនីតិសង្វាស ក៏ត្រូវទទួលស្គាល់ថាភាគីនៃអនីតិសង្វាសត្រូវទទួលបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ ប៉ុន្តែដោយសារការបញ្ចប់អនីតិសង្វាសពេលវេលាមានលក្ខណៈមិនច្បាស់លាស់ ដូចករណីលែងលះ ហេតុនេះ មានសិទ្ធិទាមទារ ពីពេលជាក់លាក់ណាមួយដល់ពេលវេលាជាក់លាក់ផ្សេងមួយទៀត ត្រូវវិនិច្ឆ័យទៅលើស្ថានភាពជាក់ស្តែង។

(៤) ទ្រព្យរួម និងទ្រព្យដោយឡែក (CC៩៧២ និង CC៩៧៣)

ទ្រព្យរួមប្តី-ប្រពន្ធ ត្រូវបានតាក់តែងឡើងជាបទបញ្ញត្តិ ក្នុងគោលបំណងដោះស្រាយវិវាទដែលកើតមានជុំវិញទំនាក់ទំនងប្តី-ប្រពន្ធស្របច្បាប់ និងជៀសវាងការគម្រាមគំហែងដែលធ្វើឡើងដោយភាគីណាម្ខាងចំពោះជីវភាពរបស់ភាគីម្ខាងទៀត។ ទោះបីជា អនីតិសង្វាស ក៏ដោយ ត្រូវបានទទួលស្គាល់ថាទ្រព្យសម្បត្តិទាំងនោះជាទ្រព្យរួម ប្រសិនបើកើតឡើងនៅក្រោយពេលមានជីវភាពរួមគ្នា។

(៥) កាតព្វកិច្ចសាមគ្គី (CC៩៧៥)

ប្រសិនបើ ភាគីនៃអនីតិសង្វាស បានចំណាយដើម្បីជីវភាពរួម ការអប់រំ ការថែទាំ ការព្យាបាលកូនជាអាទិ៍ ឬសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរួម ឬកាតព្វកិច្ចផ្សេងៗ ដែលភាគីនៃអនីតិសង្វាសបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ជាមួយនឹងម្ចាស់បំណុល ឬតែម្ខាងបានបង្កើតកាតព្វកិច្ច ប៉ុន្តែម្ខាងទៀតយល់ព្រមតាមលិខិត នៅក្នុងអំឡុងពេលអនីតិសង្វាស ត្រូវចាត់ទុកជាកាតព្វកិច្ចសាមគ្គីរបស់ភាគីនៃអនីតិសង្វាស។

(៦) ការទាមទារសំណងនៃការខូចខាត (CC៧៦០-២)

បុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច តាមច្បាប់ ឬទំនៀមទម្លាប់ ឬកិច្ចសន្យា បានទទួលមរណភាពដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្ត (ភាគីនៃអនីតិសង្វាស) អាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួនដោយសារមរណភាពរបស់ជនរងគ្រោះ ដោយរាប់បញ្ចូលប្រាក់ជីវព្រឹត្ត សោហ៊ុយដែលបានចេញជំនួសជនរងគ្រោះ និងសោហ៊ុយបុណ្យសព ជាអាទិ៍។

(៧) ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តី-ប្រពន្ធ (CC៩៧៦)

ការចាត់ចែងទ្រព្យរួម ត្រូវមានការយល់ព្រមពីប្តី-ប្រពន្ធទាំងសងខាង លើកលែងតែមានស្ថានភាពពិសេសសម្រាប់ជីវភាពរួម ប្តី-ប្រពន្ធណាម្ខាងអាចចាត់ចែងទ្រព្យសម្បត្តរួមនោះបានដោយទទួលការអនុញ្ញាតពីតុលាការ ហើយប្រសិនបើបានចាត់ចែង ដោយគ្មានការយល់ព្រម ពីសហព័ទ្ធម្ខាងទៀត ឬគ្មានការអនុញ្ញាតពីតុលាការ សហព័ទ្ធដែលមិនបានយល់ព្រម អាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះបាន ទៅតុលាការ ក្នុងអំឡុងពេល ០២ ឆ្នាំ គិតចាប់ពីពេលដែលបានដឹង ប្រសិនបើទ្រព្យដែលចាត់ចែងនោះជាអចលនវត្ថុ និងអំឡុងពេល ០១ ឆ្នាំប្រសិនបើទ្រព្យចាត់ចែងនោះមិនមែនជាអចលនវត្ថុ។

(៨) ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក (CC#៩៧៧)

សហព័ទ្ធម្ខាងអាចអាស្រ័យនៅលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ សហព័ទ្ធម្ខាងទៀត ដែលត្រូវបានប្រើប្រាស់អាស្រ័យនៅជាលក្ខណៈគ្រួសារ ហេតុនេះ បើសហព័ទ្ធដែលជាកម្មសិទ្ធិករបានចាត់ចែងទ្រព្យដោយឡែករបស់ខ្លួន ក៏សហព័ទ្ធម្ខាងទៀត នៅតែមានសិទ្ធិអាស្រ័យនៅលើអចលនវត្ថុនោះ។

(៩) ការទាមទារសំណងផ្អែកលើអំពើអនីត្យានុកូល (CC៧៦០ កថាខណ្ឌទី៣)

ប្រសិនបើជនរងគ្រោះបានទទួលមរណភាពដោយអំពើអនីត្យានុកូល ***<u>សហព័ទ្ធ</u>*** ញាតិនៅក្នុង ០១ ថ្នាក់ និងញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតផ្នែកផ្លូវចិត្តបាន។ ប្រសិនបើមើបទបញ្ញត្តិនេះ ភាគីនៃអនីតិសង្វាស មិនអាចទាមទារសំណងនៃការខូចខាត ផ្អែកលើអំពើអនីត្យានុកូល ឡើយ។ ប៉ុន្តែមានរបបគតិយុត្តថ្មីមួយបានកើតឡើងនៅក្នុងសាលាក្តីខ្មែរក្រហម ដែលពាក់ព័ន្ធនឹងអនីតិសង្វាស ដោយបានបញ្ជាក់ថា **អនីតិសង្វាសជាចំណងពិសេសនៃសេចក្តីស្រលាញ់** និង អនុញ្ញាតឲ្យភាគីនៃអនីតិសង្វាសទាមទារសំណងខូចខាតផ្នែកផ្លូវចិត្ត ដែលមានលក្ខណៈសមូហភាពប៉ុណ្ណោះ(សាលដីកា កាំងហ្កេចអ៊ាវ ហៅឌុច ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ៣២៨ ដល់ ៣៣៣)។

ⓘ ចំពោះចំណុចដទៃផ្សេងទៀត ដែលជាអានុភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់ មិនមានអានុភាពចំពោះអនីតិសង្វាស នោះទេ ដូចជា ៖

(១) នាមត្រកូលរបស់ប្តី-ប្រពន្ធ (CC៩៦៥)

នៅពេលអាពាហ៍ពិពាហ៍ស្របច្បាប់បង្កើតអានុភាព ប្តី-ប្រពន្ធអាចប្រើប្រាស់នាមត្រកូលប្តី ឬប្រពន្ធ ឬនាមត្រកូលដើម ដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ នៅប្រទេសជប៉ុន នៅពេលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ប្រពន្ធត្រូវប្រើត្រកូលរបស់ប្តី ប៉ុន្តែនៅប្រទេសកម្ពុជា គឺជាជម្រើស មិនមានលក្ខណៈដាច់ខាតនោះទេ ហើយជាទម្លាប់ និងការអនុវត្តជាក់ស្តែង គឺប្តី-ប្រពន្ធ ប្រើនាមត្រកូលដើម ក្រោយពេលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ហេតុនេះអនីតិសង្វាសមិនអនុវត្តចំពោះករណីនោះឡើយ។

(២) ការទទួលបាននីតិភាពដោយអាពាហ៍ពិពាហ៍ (CC៩៦៨)

ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ អនីតិជននោះត្រូវបានចាត់ទុកថាបានទទួលអត្តាធីនភាព តាមរយៈអាពាហ៍ពិពាហ៍ ដោយមិនចាំបាច់មានសេចក្តីសម្រេចពីតុលាការនោះ

ទេ និងទោះបីក្រោយមកបានលែងលះក៏ដោយ ហើយបុគ្គលនោះមិនទាន់មានអាយុ ១៨ ឆ្នាំ ក៏ដោយ ក៏ត្រូវបានចាត់ទុកថានីតិជន ដដែល (អានុភាពនៃអត្តាធីនភាពមិនរលត់) (CC២១ និង CC២២) ហេតុនេះ អនីតិសង្វាស មិនអនុវត្តសម្រាប់ករណីនេះទេ។

(៣) កិច្ចសន្យាទ្រព្យសម្បត្តិប្តី-ប្រពន្ធ (CC៩៦៩)

ប្តី-ប្រពន្ធអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិ នៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប៉ុន្តែខចែងនៃកិច្ចសន្យានេះមិនអាចបំពានសិទ្ធិទាមទារភាគបម្រុង ឬអាហារ កាតព្វកិច្ច ឡើយ។ អត្ថន័យនៃប្រព័ន្ធទ្រព្យសម្បត្តិប្តី-ប្រពន្ធតាមកិច្ចសន្យា មានលក្ខណៈខុសគ្នាអំពីប្រព័ន្ធទ្រព្យសម្បត្តិប្តី-ប្រពន្ធតាមច្បាប់ ហើយប្រសិនបើមិនបានចុះបញ្ជីមិនអាចតតាំងជាមួយនឹងតតិយជន (CC៩៧០-២) ហេតុនេះអនីតិសង្វាស មិនអនុវត្តសម្រាប់ករណីនេះទេ។

(៤) ការសន្មតបិតុភាព (CC៩៨៨)

ស្ត្រីដែលបានសម្រាលកូនគឺជាម្តាយរបស់កូន (អង្គហេតុសម្រាលកូន CC៩៨៧) ហើយទារកក្នុងគភ៌ប្រពន្ធ ដែលមានក្នុងចំណងអាពាហ៍ពោពាហ៍ស្របច្បាប់ ត្រូវសន្មតថា ជាកូនរបស់ប្តី ឬកូនដែលកើតឡើងនៅក្រោយអំឡុងពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ ពិពាហ៍ស្រប់ច្បាប់ត្រូវបានបង្កើត ឬ អំឡុងពេល ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា ប្តីក្រោយជាឪពុករបស់កូននោះ។ ករណីនេះ មិនអាចអនុវត្តចំពោះអនីតិសង្វាស បានឡើយ ដោយហេតុថា គ្មានព្រឹត្តការណ៍នៃការសន្មតតាមច្បាប់ ឬគ្មានទំនាក់ទំនងឪពុកនិងកូន នោះទេ ហេតុនេះ កូនដែលកើតពីឪពុក-ម្តាយនៃទំនាក់ទំនង អនីតិសង្វាស បិតុភាពនឹងកើតមានឡើង លុះត្រាតែមានការទទួលស្គាល់ពីឪពុកចំពោះកូននោះ (CC៩៩៣ ដល់ CC៩៩៩)។ ប៉ុន្តែ ឪពុកនៅតែគ្មានអំណាចមេបា ដដែល មានន័យថា អ្នកមានអំណាចមេបា គឺម្តាយ (CC១០៣៦) លើកលែងតែឪពុកដាក់ពាក្យសុំទាមទារអំណាចមេបាពីម្តាយចំពោះកូន តាមផ្លូវតុលាការ ហើយតុលាការសម្រេចតាមការទាមទារនោះ នាំឲ្យអំណាចមេបាជារបស់ឪពុក មិនមែនជារបស់ម្តាយទៀតនោះទេ មានន័យថានៅតែជាអំណាចមេបាទោលដដែល (CC១០៣៨-៣) ដោយមូលដ្ឋានគឺតុលាការពិចារណាលើផលប្រយោជន៍ របស់កូនជាឧត្តមានុភាព។

(៥) សន្តតិកម្ម (CC១១៦១)

សហព័ទ្ធរបស់មតកជន គឺជាជាសន្តតិជនជានិច្ច ហេតុនេះ ភាគីម្ខាងនៃអនីតិសង្វាស មិនមែនជាសន្តតិជនរបស់ភាគីម្ខាងទៀតនៃអនីតិសង្វាសនោះទេ។ ប៉ុន្តែ ភាគីនៃអនីតិសង្វាស អាចដាក់ពាក្យសុំទៅតុលាការដើម្បីទទួលបានមតិកមួយផ្នែក ដោយប្រើឋានៈជាជនមាន និស្ស័យពិសេសបាន (CC១២៩៩)។

(៦) អាហារកិច្ច (មាត្រា ៧៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ)

ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រង់មាត្រា ៧៦ នៅមានសុពលភាពអនុវត្ត ចំពោះ ប្តី-ប្រពន្ធដែលបានលែងលះគ្នា ហើយភាគីម្ខាងមានកំហុស ភាគីនោះត្រូវទទួលខុសត្រូវចំពោះអាហារកិច្ច ក្រោយការលែងលះ ប្រសិនបើមានការស្នើសុំ។ អនីតិសង្វាស សម្រាប់ករណីនេះ មិនអនុវត្តបានឡើយ ទោះបីការរំលាយអនីតិសង្វាស ភាគីម្ខាងទៀតមានកំហុស ក៏ដោយ។

(៧) ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ (មាត្រា **៣៥៥** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៥** មាត្រា **៦** នៃច្បាប់ស្តីពីឯកពន្ធភាព)

នៅក្នុងក្រមព្រហ្មទណ្ឌបានចែងអំពីអភ័យឯកជនគ្រួសារ ដែលមានខ្លឹមសារថា ចំពោះបទល្មើសលួច ប្រសិនបើចារីនោះជាសហព័ទ្ធ បានលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាងទៀត ចារីនោះមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។ មួយវិញទៀត នៅក្នុងច្បាប់ឯកពន្ធភាព បានកំណត់បទល្មើស ០៣ ប្រភេទ ដូចជា **ទី១** ផិត (ការរួមសេវនកិច្ចរបស់បុរស ឬនារីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ពីមុនមិនទាន់រលាយ ជាមួយនឹងបុរស ឬនារីដទៃទៀត ដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន) **ទី២** ទ្វេរពន្ធភាព (បុរស ឬនារីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ពីមុនមិនទាន់រលាយ បានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី) **ទី៣** សហ្មន់ (បុរសឬនារី ដែលជាញាតិលោហិត ឬញាតិពន្ធនឹងគ្នា បានរួមសេវនកិច្ចជាមួយនឹងគ្នា)។

ជាគោលការណ៍ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យបកស្រាយប្រដូច ឬលក្ខណៈសទិសន័យនោះទេ ហេតុនេះ ប្រសិនបើ ភាគីនៃអនីតិសង្វាសបានលួចលុយរបស់ភាគីម្ខាងទៀតនៃទំនាក់ទំនងអនីតិសង្វាស ឬប្រើអំពើហិង្សាដោយចេតនា ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ប៉ុន្តែ ប្រសិនបើ ភាគីនៃអនីតិសង្វាស បានផិត មិនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

(៨) មូលហេតុនៃការលែងលះ (CC៩៧៨)

អាពាហ៍ពិពាហ៍មិនអាចត្រូវរំលាយដោយសេរី ឬការបង្ហាឆន្ទៈរបស់ភាគី នោះទេ ត្រូវមានការអនុញ្ញាត ឬសេចក្ដីសម្រេចរបស់តុលាការ ហេតុនេះ នៅពេលលែងលះ លុះត្រាតែ មានមូលហេតុណាមួយក្នុងចំណោមមូលហេតុនានា ដែលត្រូវបានច្បាប់កំណត់ ដូចជា **ទី១** ផិត **ទី២** បោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ **ទី៣** មិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង ០១ ឆ្នាំ **ទី៤** សហព័ទ្ធបានរស់នៅបែកគ្នា ជាបន្តបន្ទាប់ អស់រយៈពេលជាង ០១ ឆ្នាំ ផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍ **ទី៥** ទំនាក់ទំនងអាពាហ៍ពិពាហ៍បានបែកបាក់ និងគ្មានសង្ឃឹមថាអាចធ្វើបដិទានបាន។

ៗ ដោយឡែក មានចំណុចមួយចំនួនទៀត មានការលំបាកក្នុងការបែងចែក ថាតើ អនុវត្តប្រដូចចំពោះអនីតិសង្វាស ឬយ៉ាងណា ដូចជា៖

ចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ តុលាការដែលបានទទួលពាក្យបណ្ដឹងលែងលះ ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចចាត់ចែងរក្សាការពារ ដូចជា**ទី១** ការបំបែកលំនៅសង្វាស **ទី២** ការគ្រប់គ្រងថែរក្សាកូន **ទី៣** ការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ **ទី៤** អាហារកាតព្វកិច្ចរវាង សហព័ទ្ធ-បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និង **ទី៥** សោហ៊ុយចិញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬឆន្ទានុសិទ្ធិ។

ៗ *<u>ករណីទាំងនេះអនុវត្តចំពោះអនីតិសង្វាស បានឬមិនបាន ត្រូវវិនិច្ឆ័យស៊ីជម្រៅទៅលើ ស្ថានភាពជាក់ស្ដែងនៃទំនាក់ទំនងអនីតិសង្វាស តើមូលហេតុអ្វីបានជាភាគីនៃអនីតិសង្វាស-មិនចុះបញ្ជីអាពាហ៍ពិពាហ៍?</u>*

## ៣-ការអនុវត្តអនីតិសង្វាស

ការអនុវត្តអនីតិសង្វាសមិនទាន់មានលក្ខណៈឯកភាពគ្នា និងគោលការណ៍ច្បាស់លាស់ ក្នុងការបកស្រាយនៅឡើយនោះទេ ដោយហេតុថា ការអនុវត្តជាក់ស្ដែង មានសាលក្រមដែល ត្រូវបានចេញឲ្យរំលាយអនីតិសង្វាស និងសាលក្រមលើកចោលបណ្ដឹងទាមទារឲ្យរំលាយ អនីតិសង្វាស មានន័យថា តុលាការខ្លះទទួលស្គាល់ តុលាការខ្លះមិនទទួលស្គាល់។

នៅក្នុងនីតិវិធីនៃការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ អាចធ្វើឡើងតាមរយៈពាក្យសុំ ប្រសិនបើប្ដី-ប្រពន្ធនោះ ព្រមព្រៀងគ្នាលែងលះ (CC#៩៧៩) **ដោយប្រើនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង**។ ផ្ទុយទៅវិញ ប្រសិនបើប្ដីប្រពន្ធនោះមិនព្រមព្រៀងគ្នា លែងលះ នោះទេ ភាគីដែល

មានបំណងលែងលះ ត្រូវដាក់ពាក្យបណ្ដឹង (CC៩៨២) ដោយប្រើប្រាស់នីតិវិធីបណ្ដឹងឋានៈបុគ្គល និង មានមូលហេតុស្របច្បាប់ (CC៩៧៨)។

## តើត្រូវដោះស្រាយករណីអនីតិសង្វាសដូចម្ដេច?

(១) ការរំលាយអនីតិសង្វាស

ការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ (លែងលះ) ត្រូវតែមានដីកាសម្រេច ឬសាលក្រម របស់តុលាការ ប៉ុន្តែការរំលាយអនីតិសង្វាស មិនត្រូវការសេចក្ដីសម្រេចរបស់ តុលាការឡើយ។ ទោះបី មានពាក្យបណ្ដឹង ឬពាក្យសុំឲ្យរំលាយអនីតិសង្វាស ឬសុំផ្ដាច់អនីតិសង្វាស ឬសុំបញ្ជាក់នត្ថិភាពនៃ អាពាហ៍ពិពាហ៍ ក៏ដោយ ពាក្យបណ្ដឹងនោះនឹងត្រូវលើកចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការ ទាញហេតុផលដោយផ្ទាល់មាត់ (CCP៨១) ដោយហេតុថា បណ្ដឹងនេះជាបណ្ដឹងផ្ទុយច្បាប់ ហើយចំណុច ខ្វះខាតនោះមិនអាចកែតម្រូវបាន។

ប្រសិនបើភាគីនៃអនីតិសង្វាសមានឆន្ទៈរំលាយអនីតិសង្វាស ភាគីនោះអាចធ្វើឡើង តាមការព្រម ព្រៀងគ្នា ដោយហេតុថា អនីតិសង្វាស ជាព្រឹត្តន័យ ឬលក្ខណៈជាក់ស្ដែង មិនមែនជាចំណងគតិយុត្ត ហើយក្រមរដ្ឋប្បវេណី ឬច្បាប់វិជ្ជមានកម្ពុជា គ្មានបញ្ញត្តិសម្រាប់គ្រប់គ្រងនោះទេ ហេតុនេះ មិនអាច សម្រេចតាមផ្លូវតុលាការបាននោះទេ ពីព្រោះតុលាការសម្រេចសេចក្ដីផ្អែកលើភស្តុតាង និងច្បាប់ មិន មែនផ្អែកលើការយល់ឃើញ ឬឆន្ទានុសិទ្ធិក្រៅវង្វង់ច្បាប់ ឬហួសវិសាលភាពច្បាប់នោះទេ។

ដោយឡែក អនីតិសង្វាសអាចត្រូវបានបញ្ចប់ក្នុងករណី **ទី១** ការចុះបញ្ជីអាពាហ៍ពិពាហ៍ **ទី២** ការ ប្រកាសបាត់ខ្លួន **ទី៣** មរណភាព **ទី៤** ការឈប់រស់នៅជាមួយគ្នា លើកលែងតែ គ្មានហេតុផលសមរម្យ ទាល់តែសោះ។

(២) ការបែងចែកទ្រព្យ (CC៩៨០)

ប្រសិនបើ អនីតិសង្វាស ត្រូវបានរំលាយ ហើយភាគីនៃអនីតិសង្វាសពិភាក្សាគ្នាបែងចែកទ្រព្យ យើងអាចធ្វើការបកស្រាយប្រដូចនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ ដោយកំណត់អំពី ទ្រព្យរួម និងទ្រព្យ ដោយឡែក និងប្រសិនបើគ្មានការឯកភាពគ្នា តុលាការនឹងសម្រេច ដោយពិចារណាទៅលើទ្រព្យសម្បត្តិ រួម ការបរិចាគរបស់ភាគី ការថែរក្សា ការបង្កើនទ្រព្យ ផ្លូវចិត្ត ផ្លូវកាយ ស្ថានភាពប្រាក់ចំណូល លទ្ធភាពធ្វើ ការ និងផលប្រយោជន៍របស់កូន ជាអាទិ៍ ហើយការងារក្នុងផ្ទះ ត្រូវចាត់ទុកថាស្មើគ្នានឹងការក្រៅផ្ទះ។

(៣) អ្នកមានអំណាចមេបាចំពោះកូន

ឪពុកម្ដាយដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ត្រូវប្រើប្រាស់អំណាចមេបាដោយសហការ ហេតុនេះកូនដែលកើតឡើងនៅក្នុងទំនាក់ទំនងអនីតិសង្វាស គឺមានអំណាចមេបាទោលដែលជាម្ដាយ ដោយហេតុថា មានអង្គហេតុសម្រាលកូន ចំពោះឪពុកគឺគ្មានមូលហេតុសន្មតបិតុភាពតាមច្បាប់នោះទេ។ អ្នកមានអំណាចមេបាចំពោះកូននៃទំនាក់ទំនងអនីតិសង្វាសគឺម្ដាយ មិនមែនជាឪពុកនោះទេ។ ប្រសិនបើឪពុកបានស្នើសុំទទួលស្គាល់ដោយស្មគ្រ័ចិត្ត ចំពោះកូន និងបានចុះសំបុត្រកំណើតដោយដាក់ខ្លួនថាជាឪពុក នាំឲ្យមានទំនាក់ទំនងជាឪពុកនិងកូន (CC៩៩៣ ដល់ CC៩៩៩) ប៉ុន្តែឪពុកនោះនៅតែគ្មានអំណាចមេបា (CC១០៣៦)។

ឪពុកម្ដាយនៃចំណងអាពាហ៍ពិពាហ៍ ដែលពុំមានអំណាចមេបា ក្រោយការលែងលះ មានសិទ្ធិជួបប្រាស្រ័យទាក់ទងជាមួយនឹងកូន និងទទួលបន្ទុកសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន (CC១០៤០)។ ករណី អនីតិសង្វាស ម្ដាយមិនអាចទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនពីឪពុកបាននោះទេ លើកលែងតែ ឪពុកនោះបានទទួលស្គាល់កូន។ ប្រសិនបើឪពុកទទួលស្គាល់កូន អាចពិភាក្សា និងកំណត់ជាមួយម្ដាយ អំពីរបៀបចូលជួប ប្រាស័យទាក់ទងគ្នា និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន(CC១០៤០-៣)។

(៤) ការទាមទារសំណងនៃការខូចខាត

ប្រសិនបើភាគីនៃអនីតិសង្វាសបានប្រព្រឹត្តអំពើផិត ភាគីរងគ្រោះនៃអនីតិសង្វាសអាចទាមទារសំណងនៃការខូចខាត ប៉ុន្តែមិនអាចបណ្ដឹងព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលនោះឡើយ។

## ៤-ករណីសិក្សា

**ករណីសិក្សាទី ១ ៖** ការរំលាយអនីតិសង្វាស

| |
|---|
| A និង B ជាប្ដីប្រពន្ធបានរៀបការជាមួយគ្នាតាមប្រពៃណី ដោយបានសុំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ពីឃុំដែលពួកគាត់រស់នៅ។ បន្ទាប់មកក៏រៀបចំពិធីនៅភោជនីយដ្ឋាន ប៉ុន្តែមិនបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍នោះទេ។<br>ទី១ នៅពេលពួកគាត់លែងលះគ្នា តើត្រូវប្ដឹងទៅតុលាការដើម្បីលែងលះ ឬយ៉ាងណា?<br>ទី២ តើត្រូវបែងចែកទ្រព្យសម្បត្តិដូចម្ដេច? |

| |
|---|
| ទី៣ ប្រសិនបើ B ទៅរៀបការជាមួយនឹងបុគ្គលដទៃទៀត តើB ខុសនឹងច្បាប់ឯកពន្ធភាពឬទេ?<br>ទី៤ ប្រសិនបើ B បានបំផ្លាញ ឬលួយលុយ A តើត្រូវដោះស្រាយដូចម្តេច?<br>ទី៥ តើ A អាចទាមទារអ្វីបានខ្លះពី B? |

**ករណីសិក្សាទី ២** ៖ សិទ្ធិអាស្រ័យនៅរបស់ភាគីនៃអនីតិសង្វាសចំពោះអចលនវត្ថុរបស់ភាគីម្ខាងទៀតនៃអនីតិសង្វាស

| |
|---|
| A ជាប្តីអនីតិសង្វាស B ជាប្រពន្ធអនីតិសង្វាស។ A និង B បានរស់នៅជាមួយគ្នា នៅលើផ្ទះដែលជាកម្មសិទ្ធិរបស់ A។ A បានទទួលមរណភាព ហើយ C ដែលជាកូនតែម្នាក់គត់របស់ A បានក្លាយជាសន្តតិជន។ C បានទាមទារឲ្យ B ចាកចេញពីផ្ទះនេះ ដោយផ្អែកលើកម្មសិទ្ធិដែលបានទទួលតាមរយៈសន្តតិកម្ម។ B បានរស់នៅជាមួយ A អស់រយៈពេលជាយូរមកហើយ ប្រសិនបើចាកចេញពីផ្ទះនេះ B នឹងបាត់បង់ជម្រក។ តើករណីនេះ ត្រូវដោះស្រាយដូចម្តេច? |

**ករណីសិក្សាទី ៣** ៖ សិទ្ធិអាស្រ័យនៅរបស់ភាគីនៃអនីតិសង្វាសចំពោះការជួលអចលនវត្ថុរបស់ភាគីម្ខាងទៀតនៃអនីតិសង្វាស

| |
|---|
| A ជាប្តីអនីតិសង្វាស B ជាប្រពន្ធអនីតិសង្វាស។ A និង B បានរស់នៅជាមួយគ្នា នៅលើផ្ទះដែលA បានជួលពី X សម្រាប់រយៈពេល ១០ ឆ្នាំ។ A បានទទួលមរណភាព បន្ទាប់ពីជួលបាន រយៈពេល ៥ ឆ្នាំ ហើយ C ដែលជាកូនតែម្នាក់គត់របស់ A បានក្លាយជាសន្តតិជន។ ទោះបីជា A បានទទួលមរណភាពក៏ដោយ B បានបន្តរស់នៅលើផ្ទះជួលនេះ ប៉ុន្តែ X បានទាមទារឲ្យ B ចាកចេញពីផ្ទះនេះ ដោយនិយាយថា B មិនមែនជាភតិកៈ។ B បានរស់នៅជាមួយ A អស់រយៈពេលជាយូរមកហើយ ប្រសិនបើចាកចេញពីផ្ទះនេះ B នឹងបាត់បង់ជម្រក។<br>តើករណីនេះ ត្រូវដោះស្រាយដូចម្តេច? |

**ករណីសិក្សាទី ៤** ៖ ការទាមទារអំណាចមេបាចំពោះកូនដោយឪពុក ជាអាទិ៍ (អនីតិសង្វាស)

| |
|---|
| A ជាប្តីអនីតិសង្វាស B ជាប្រពន្ធអនីតិសង្វាស។ A និង B បានរស់នៅជាមួយគ្នា នៅលើផ្ទះដែលជាកម្មសិទ្ធិរបស់ A និង B តាំងពីឆ្នាំ ២០១០។ នៅក្នុងទំនាក់ទំនងអនីតិសង្វាសនេះ A និង B គឺមានកូនចំនួន ២ នាក់ ឈ្មោះ C និង D (ប្រុសម្នាក់អាយុ ០៥ ឆ្នាំ និងស្រីម្នាក់ អាយុ ០២ ឆ្នាំ) ហើយ កូនទាំងនេះមិន |

ទាន់មានសំបុត្រកំណើត នៅឡើយ។ B បានទៅធ្វើការនៅខេត្ត និងមានបុរសកំណាន់ផ្សេងទៀត។ B បានខ្ចី X ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក កាលពីឆ្នាំ ២០១២ ក្នុងរយៈពេល ០២ ឆ្នាំ សម្រាប់កិច្ចការជំនួញ និងគ្រួសារ។ បច្ចុប្បន្ន (ឆ្នាំ ២០១៥) A ទើបដឹងថា B មានបុរសកំណាន់ផ្សេងទៀតឈ្មោះ Y ហេតុនេះ A មានបំណងលែងលះ, សុំសិទ្ធិគ្រប់គ្រងកូន, បែងចែកទ្រព្យ, មិនទទួលខុសត្រូវចំពោះបំណុល, ទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន, ទាមទារសំណងនៃការខូចខាត។
តើករណីនេះ ត្រូវដោះស្រាយដូចម្តេច?

**ករណីសិក្សាទី ៥** ៖ ការទទួលស្គាល់របស់ឪពុកចំពោះកូន (អនីតិសង្វាស)

A ជាប្តីអនីតិសង្វាស B ជាប្រពន្ធអនីសង្វាស។ A និង B បានរស់នៅជាមួយគ្នា បានមួយរយៈខ្លីក៏បែកគ្នា។ បន្ទាប់មក B ក៏បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយនឹង X និងមានកូនម្នាក់ឈ្មោះ C ។ B បានទៅចុះសំបុត្រកំណើតឲ្យកូន ដោយប្រាប់ថាកូនឈ្មោះ C និងបញ្ជាក់ថា B ជាម្តាយ ហើយ X ជាឪពុក។ តាមពិត C គឺជាកូនរបស់ A និង B ប្រសិនបើ A មានបំណងទទួលស្គាល់កូន C ឲ្យបានត្រឹមត្រូវតាមច្បាប់ តើករណីនេះ ត្រូវដោះស្រាយដូចម្តេច?

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹង**

**ដើមចោទ** ៖ ឈ្មោះ A ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះ លេខ ១២ ផ្លូវលំ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៤ រាជធានីភ្នំពេញ។

**ចុងចម្លើយ** ៖ ឈ្មោះ B ភេទស្រី អាយុ ៣០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ៖

(១) ផ្តាច់អនីតិសង្វាសរវាង A និង B

(២) ផ្តល់សិទ្ធិគ្រប់គ្រងកូនឈ្មោះ C និង D ឲ្យទៅ A

(៣) បែងចែកទ្រព្យជាពីរចំណែកស្មើគ្នា

(៤) បង្គាប់ឲ្យ B បង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនឲ្យទៅ A ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិកក្នុងមួយខែ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៤ រហូតដល់កូនៗមាននីតិភាព

(៥) បំណុលទទួលខុសត្រូវរៀងៗខ្លួន

(៦) បង្គាប់ឲ្យ B បង់សំណងនៃការខូចខាតចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក

(៧) ប្រាក់ប្រដាបក្តីជាបន្ទុករបស់ B

**យោង** ៖ មាត្រា **៩៧៨** និងមាត្រា **៩៨២** នៃក្រមរដ្ឋប្បវេណី

សេចក្តីដូមានកំណត់ និងយោងខាងលើ ខ្ញុំបាទ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ .......................................................................................................

.........................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**ក-អង្គហេតុចាំបាច់សម្រាប់បញ្ជាក់ការទាមទារ**

-

-

-

**ខ-អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

-

-

-

**គ-ភស្តុតាង**

-

-

-

សេចក្តីដូចជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេច តាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥

**ស្នាមម្រាមដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងរដ្ឋប្បវេណីលេខ ០១

ចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ ២០១៥

-សាលក្រមលេខ ០១ "ក"

ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ

**<u>សាលក្រម</u>**

**តាងនាមប្រជារាស្ត្រខ្មែរ**

យើង W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញមាត្រា ៩៧៨ ,មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ០១ ចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ

ដើមចោទ ៖ ឈ្មោះ A ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះ លេខ ១២ ផ្លូវលំ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៤ រាជធានីភ្នំពេញ។

ចុងចម្លើយ ៖ ឈ្មោះ B ភេទស្រី អាយុ ៣០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**ខ្លឹមសារនៃសាលក្រមដែលត្រូវបានស្នើសុំដោយដើមចោទ** (A)៖

(១) ផ្តាច់អនីតិសង្វាសរវាង A និង B

(២) ផ្តល់សិទ្ធិគ្រប់គ្រងកូនឈ្មោះ C និង D ឲ្យទៅ A

(៣) បែងចែកទ្រព្យជាពីរចំណែកស្មើគ្នា

(៤) បង្គាប់ឲ្យ B បង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនឲ្យទៅ A ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិកក្នុងមួយខែ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៤ រហូតដល់កូនៗមាននីតិភាព

(៥) បំណុលទទួលខុសត្រូវរៀងៗខ្លួន

(៦) បង្គាប់ឲ្យ B បង់សំណងនៃការខូចខាតចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក

(៧) ប្រាក់ប្រដាបក្តីជាបន្ទុករបស់ B

**ក.ដំណើររឿង**

ក.១ ការអះអាងរបស់ A ៖

ក.២ ការអះអាងរបស់ B ៖

**ខ.ភស្តុតាងក្នុងសំណុំរឿង**

ខ.១ ភស្តុតាងរបស់ A ៖

ខ.២ ភស្តុតាងរបស់  B ៖

នាពេលសាកសួរភាគីនក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់

-

-

**សំអាងហេតុ**

-

-

**ហេតុដូច្នេះវិនិច្ឆ័យសេចក្តី**

១.លើកចោលពាក្យបណ្តឹងចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ របស់ដើមចោទ A

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ A

សាលក្រមនេះមិនទាញហេតុផលដោយផ្ទាល់មាត់នោះទេ និងត្រូវបានសម្រេចដោយប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចំពោះមុខដើមចោទនិងចុងចម្លើយ។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងអំឡុងពេល ០១ (មួយ) ខែ ដោយគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសាលក្រមនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៤

**ចៅក្រម**

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៧

## ប្រធានបទ៖ ការតំណាង

## ថ្ងៃទី ២៦ កុម្ភៈ ២០១៥

# ការតំណាង

## ១-សញ្ញាណទូទៅ

បុគ្គលនីមួយៗទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចបំពេញនូវសកម្មភាពនានា ក្នុងដែនកំណត់ដែលច្បាប់អនុញ្ញាត ដើម្បីផលប្រយោជន៍ត្រឹមត្រូវរបស់ខ្លួនបាន។ ប៉ុន្តែការធ្វើនូវសកម្មភាពគតិយុត្តទាំងនេះ ពុំចាំបាច់ត្រូវតែធ្វើឡើងដោយបុគ្គលខ្លួនឯងផ្ទាល់នោះឡើយ។ ចំពោះនីតិបុគ្គល ចាំបាច់ត្រូវអនុវត្តនូវសកម្មភាពផ្សេងៗ តាមរយៈអ្នកតំណាងរបស់ខ្លួន ដោយហេតុថានីតិបុគ្គល គ្រាន់តែជាបុគ្គលដែលនិម្មិតឡើងដោយច្បាប់ ជាបុគ្គលអរូប ដែលពុំមានរូបរាង និងអាចធ្វើសកម្មភាពបានដូចរូបវន្តបុគ្គលឡើយ។

ក្នុងការអនុវត្តជាក់ស្តែងយើងអាច ពិនិត្យឃើញនូវឧទាហរណ៍ដូចខាងក្រោម ៖

"**ក**"ជាម្ចាស់ផ្ទះ ហើយ"**ក**"បានស្នើសុំអោយ"ខ"ជួយជួលផ្ទះរបស់ខ្លួនអោយទៅតតិយជនណាមួយ ដោយសារខ្លួនជាប់រវល់ច្រើន និងត្រូវធ្វើដំណើរទៅបរទេសញឹកញាប់។ "**ខ**" បានព្រមព្រៀង ហើយក្រោយមក "**ខ**"ក៏បានចុះកិច្ចសន្យាជួលផ្ទះរបស់"**ក**" អោយទៅ"**គ**"។ កិច្ចសន្យាត្រូវបានចុះហត្ថលេខាដោយ "**ខ**" និង "**គ**"។

ជាធម្មតាកិច្ចសន្យាជួលដែលចុះរវាង "**ខ**" និង"**គ**"ខាងលើ ត្រូវមានអានុភាពចំពោះតែ"**ខ**" និង"**គ**" ។ ប៉ុន្តែដោយហេតុថា "**ខ**"ពុំមែនចុះកិច្ចសន្យាដើម្បីខ្លួនឯងទេ ពោលគឺ"**ខ**"ចុះកិច្ចសន្យាជំនួស"**ក**" ដូច្នេះកិច្ច- សន្យាជួលនេះ ពុំមានអានុភាពចំពោះ"**ខ**"ឡើយ ប៉ុន្តែវាកើតអានុភាពចំពោះ"**ក**"ទៅវិញ ដែលប្រៀបបីដូចជា "**ក**" ចុះកិច្ចសន្យាដោយផ្ទាល់ជាមួយ"**គ**" ។ យន្តការបែបនេះហៅថា "**ការតំណាង**" ។

ក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្នទទួល ស្គាល់នូវ "**របបតំណាង**" ដែលអនុញ្ញាតអោយបុគ្គល(**ម្ចាស់សិទ្ធិ**)ធ្វើនូវសកម្មភាពគតិយុត្តតាមរយៈបុគ្គលម្នាក់ទៀត(**អ្នកតំណាង**) ហើយសកម្មភាពដែលបានធ្វើដោយ **អ្នកតំណាង** បង្កើតអានុភាពចំពោះ **ម្ចាស់សិទ្ធិ** ដោយផ្ទាល់។

### ១-១-និយមន័យ និងគោលបំណង

**ក-និយមន័យ**ការតំណាងគឺជាទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យា ត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង[34]។

[34] មាត្រា៣៦៤ ក្រមរដ្ឋប្បវេណី

**ខ-គោលបំណង**

ស្វ័យភាពនៃបុគ្គលឯកជន ជាគោលការណ៍គ្រឹះដ៏សំខាន់មួយ នៃច្បាប់រដ្ឋប្បវេណី។ តាមរយៈគោលការណ៍នេះ បុគ្គលមិនត្រូវបានចងដោយកិច្ចសន្យា ដែលបង្កើតរវាងបុគ្គលដទៃនោះទេ។ ប៉ុន្តែបើទទួលស្គាល់តែគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ធ្វើអោយមានការខកខាននូវប្រតិបត្តការណ៍មួយចំនួន ក្នុងជីវភាពប្រចាំថ្ងៃនៃបុគ្គលឯកជន ព្រោះបុគ្គលម្នាក់មិនអាចធ្វើការច្រើនយ៉ាង ក្នុងពេលតែមួយបាន ឡើយ ។ តាមរយៈរបបនៃការតំណាង ស្វ័យភាពនៃបុគ្គលឯកជនត្រូវបានពង្រីក នាំអោយវិសាលភាពនៃសកម្មភាពរបស់បុគ្គលឯកជន ត្រូវបានលាតសន្ធឹងទូលំទូលាយជាងមុន។

ក្រៅអំពីការពង្រីកនូវស្វ័យភាពនៃបុគ្គលឯកជន របបនៃការតំណាង ក៍ត្រូវបានបង្កើតក្នុងបំណងធានាឲ្យបុគ្គលមួយចំនួនដែលជាអសមត្ថជនអាចអនុវត្តនូវសកម្មភាពនានា ដើម្បីសំរេចនូវសិទ្ធិ ឬផលប្រយោជន៍ដែលខ្លួនត្រូវបានទទួលបានតាមច្បាប់ផងដែរ។

**១.២-ផលប្រយោជន៍នៃការតំណាង**

របបនៃការតំណាង មាននូវផលប្រយោជន៍ ឬគុណសម្បត្តិមួយចំនួនដូចខាងក្រោម ៖

ក-ការពង្រីកទំហំនៃសកម្មភាពរបស់ម្ចាស់សិទ្ធិ ដែលនាំអោយម្ចាស់សិទ្ធិមានលទ្ធភាពធ្វើសកម្មភាពបានទូលំទូលាយ ។ ការពង្រីកនូវសកម្មភាពបែបនេះ នឹងជួយជំរុញដល់សកម្មភាពសេដ្ឋកិច្ច។

ខ-បង្កើនជំនាញ និងសមត្ថភាពរបស់ម្ចាស់សិទ្ធិ។ តាមរយៈការតំណាង ម្ចាស់សិទ្ធិអាច ប្រើប្រាស់ជំនាញ ឯកទេស ឬសមត្ថភាពរបស់បុគ្គលផ្សេងដើម្បីប្រសិទ្ធិភាពនៃសកម្មភាពរបស់ខ្លួន។

គ-នៅពេលម្ចាស់សិទ្ធិខ្លួនឯង មិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មពីព្រោះជម្ងឺ ឬខ្វះខាត សមត្ថភាពវិនិច្ឆ័យ នោះបើមានអ្នកតំណាងនោះអ្នកតំណាងអាចធ្វើប្រតិបត្តិការក្នុងនាមម្ចាស់សិទ្ធិបាន។

ឃ-អសមត្ថជន អាចធ្វើសកម្មភាព ទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ ដែលច្បាប់ផ្តល់ឲ្យបានតាមរយៈអ្នកតំណាងដែលច្បាប់កំណត់។

ង-នីតិបុគ្គលមិនអាចធ្វើសកម្មភាពដោយផ្ទាល់បានឡើយ ហេតុនេះគ្រប់សកម្មភាពរបស់នីតិបុគ្គល ត្រូវប្រើអ្នកតំណាងដោយជៀសមិនបាន (អ្នកតំណាងនីតិបុគ្គល)។

**១.៣-អានុភាព និងល័ក្ខខ័ណ្ឌនៃការតំណាង**

**ក-អានុភាព**

អានុភាពនៃសកម្មភាពតំណាងមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ។ ហេតុដូចនេះ បើអ្នកតំណាងបាន បង្កើតកិច្ចសន្យាជាមួយតតិយជន នោះម្ចាស់សិទ្ធិនឹងត្រូវចងកាតព្វកិច្ចដោយកិច្ចសន្យានោះ ទោះបីជាម្ចាស់សិទ្ធិមិនបានឃើញ និងដឹងអំពីល័ក្ខខ័ណ្ឌនៃកិច្ចសន្យាក៏ដោយ ។




### ខ.ល័ក្ខខ័ណ្ឌ

សកម្មភាពដែលបានធ្វើដោយអ្នកតំណាង មានអានុភាពចំពោះម្ចាស់សិទ្ធិ។ ប៉ុន្តែអានុភាពនេះ កើត ឡើងចំពោះម្ចាស់សិទ្ធិបាន លុះត្រាតែគោរពនូវល័ក្ខខ័ណ្ឌ ០៣ គឺៈ

១.ម្ចាស់សិទ្ធិបានផ្តល់សិទ្ធិអោយអ្នកតំណាងពាក់ព័ន្ធនឹងសកម្មភាពតំណាង។ អ្នកតំណាងត្រូវធ្វើសកម្មភាព ឬអនុវត្តនូវសិទ្ធិតំណាងរបស់ខ្លួន ក្នុងដែនកំណត់នៃការតំណាងប៉ុណ្ណោះ។

២.កិច្ចសន្យាត្រូវបានបង្កើតរវាងអ្នកតំណាង និងតតិយជន (ល័ក្ខខ័ណ្ឌបុគ្គល ពោលគឺកិច្ចសន្យាដែលមានអានុភាពដល់ម្ចាស់សិទ្ធិលុះត្រាតែជាកិច្ចសន្យាដែលធ្វើដោយអ្នកតំណាងនិងតតិយជន )។

៣.អ្នកតំណាងបានបង្ហាញឆន្ទៈក្នុងការធ្វើសកម្មភាពសម្រាប់ម្ចាស់សិទ្ធិ។ មានន័យថាភាគីម្ខាងនៃកិច្ចសន្យាបានយល់ដឹងថាសកម្មភាពនេះធ្វើក្នុងនាមអ្នកតំណាង។

<u>ចំណោទបញ្ហា</u> ៖ អ្នកតំណាង គឺ A ម្ចាស់សិទ្ធិគឺ B លោក A តែងតែសរសេរក្នុងកិច្ចសន្យាដោយដាក់ថា "A ក្នុងនាមជាអ្នកតំណាងអោយ B"។ ប្រសិនបើ A បានសរសេរឈ្មោះ A ឬ B តើកិច្ចសន្យានេះ នឹងមានអានុភាពដូចម្តេច ? ភាគីម្ខាងទៀតនៃកិច្ចសន្យាគឺ C។

### ១.៤.វិការៈនៃអំពើតំណាង

របបនៃការតំណាង អនុញ្ញាតអោយអ្នកតំណាងធ្វើសកម្មភាពគតិយុត្តក្នុងនាមនិងជំនួសអោយម្ចាស់សិទ្ធ។ ហេតុដូច្នេះជារូបភាពនៅពេលអនុវត្តសកម្មភាពជាក់ស្តែង ឬការចុះកិច្ចសន្យានានាម្ចាស់សិទ្ធិនឹងមិនអាច បង្ហាញនូវឆន្ទៈរបស់ខ្លួនបានឡើយ ប៉ុន្តែគឺអ្នកតំណាងទេ ដែលនឹងបង្ហាញឆន្ទៈនៅចំពោះមុខ

ភាគីម្ខាងទៀតនៃកិច្ចសន្យា។ ស្ថានភាពបែបនេះនាំអោយមានចំណោទឡើងថា តើក្នុងករណីដែលមានវិការៈក្នុងការបង្ហាញឆន្ទៈដូចជាការភាន់ច្រឡំ ការឆបោក គំរាមកំហែងជាអាទិ តើគេត្រូវគិតអំពីស្ថានភាពទាំងនេះកើតមានឡើងចំពោះអ្នកតំណាង ឬចំពោះម្ចាស់សិទ្ធិ?

ក្រមរដ្ឋប្បវេណីកម្ពុជាបានផ្តល់ដំណោះស្រាយចំពោះចំណោទបញ្ហានេះ។ ដោយហេតុថាអ្នកតំណាងជាអ្នកបង្ហាញនូវឆន្ទៈក្នុងការបង្កើតកិច្ចសន្យាជាមួយភាគីម្ខាងទៀត ហេតុនេះវិការៈនៃការបង្ហាញឆន្ទៈ ត្រូវគិតចំពោះអ្នកតំណាង ពោលគឺពុំមែនម្ចាស់សិទ្ធិឡើយ[35] ។

ប៉ុន្តែក្នុងករណីដែលម្ចាស់សិទ្ធិ បានប្រគល់អោយអ្នកតំណាងធ្វើកិច្ចសន្យា ដែលត្រូវបានកំណត់ពិសេស ហើយម្ចាស់សិទ្ធិបានដឹងអំពីស្ថានភាពនោះ ត្រូវចាត់ទុកថាអ្នកតំណាងក៏បានដឹងដែរ[36] ។ បញ្ញត្តិនេះត្រូវអនុវត្តផងដែរ ករណីម្ចាស់សិទ្ធិមិនបានដឹងដោយមានកំហុស។

<u>ឧទាហរណ៍ ៖</u>

ម្ចាស់សិទ្ធិ"ក" បានប្រគល់សិទ្ធិជូនអ្នកតំណាង "ខ" ក្នុងការចុះកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើដីរបស់ "គ" ប៉ុន្តែ "ក" បានដឹងយ៉ាងច្បាស់ថាដីនេះជាប់បន្ទុកប្រាតិភោគរួចហើយ ។ កិច្ចសន្យាត្រូវ បានចុះរវាង"ខ" និង "គ" ។ នៅពេលចុះបញ្ជីហ៊ីប៉ូតែក ស្រាប់តែ"ក" ពិនិត្យឃើញថា មានម្ចាស់បំណុល ហ៊ីប៉ូតែកចំនួន០៥ នាក់រួចហើយ បានចុះបញ្ជីលើដី ដែលនាំអោយតំលៃដីនៅសល់មិនសមស្របនឹងសិទ្ធិ លើបំណុលរបស់ខ្លួន ។ នៅពេលចុះកិច្ចសន្យាអ្នកតំណាង"ខ"មិនបានដឹងពីហេតុនេះទេ ហេតុនេះ"ក"ចង់លើកយកមូលហេតុនេះ ដើម្បីលុបចោលកិច្ចសន្យា ហើយស្នើសុំចុះបញ្ជីហ៊ីប៉ូតែកលើដីផ្សេងរបស់"គ" វិញ។

ករណីនេះ"ក" មិនអាចអះអាងអំពីវិការៈនេះបានឡើយ ដោយហេតុថា "ក"ខ្លួនឯងបានដឹង ឬមានកាតព្វកិច្ចត្រូវតែដឹងអំពីស្ថានភាពប្រាតិភោគចំពោះទ្រព្យធានា(ការចុះបញ្ជីជាសាធារណៈ)។ ហេតុនេះ"ក" មិនអាចស្នើសុំរំលាយ កិច្ចសន្យា ដោយសារវិការៈនៃឆន្ទៈរបស់"ខ" ដែលជាអ្នកតំណាងរបស់ខ្លួនបានឡើយ។

## ២.ប្រភព និងវិសាលភាពនៃការតំណាង

ក្នុងបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណី មិនបានកំណត់ជាក់លាក់អំពីសកម្មភាពគតិយុត្តណាអាចតំណាងបាន និងសកម្មភាពណា មិនអាចតំណាងបាននោះទេ ប៉ុន្តែយើងអាចពិនិត្យឃើញមានសកម្មភាពមួយចំនួនត្រូវបានច្បាប់កម្រិត មិនអោយធ្វើតាមរយៈអ្នកតំណាងឡើយ ដូចជាមតកសាសន៍ជាដើម។

[35] មាត្រា ៣៧៥-១ ក្រមរដ្ឋប្បវេណី

[36] មាត្រា ៣៧៥-២ ក្រមរដ្ឋប្បវេណី

### ២.១.ប្រភពនៃសិទ្ធិតំណាង

សិទ្ធិតំណាងកើតឡើងដោយការព្រមព្រៀងគ្នា(កិច្ចសន្យា)រវាងម្ចាស់សិទ្ធិនិងអ្នកតំណាង ឬដោយបញ្ញត្តិច្បាប់[37] ។

#### ក.សិទ្ធិតំណាងដោយបញ្ញត្តិច្បាប់

ដើម្បីការពារ និងធានានូវបុគ្គលមួយចំនួនដែលទន់ខ្សោយដូចជាអសមត្ថជន ឬអនីតិជនជាអាថិច្បាប់បានកំណត់អំពីអ្នកតំណាងសំរាប់ជនទាំងនោះ រួមទាំងទំហំនៃសិទ្ធិតំណាងផងដែរ។ អំណាចមេបារបបអាណាព្យាបាលទូទៅ របបអាណាព្យាបាលសំរាប់អនីតិជន ជាឧទាហរណ៍នៃសិទ្ធិតំណាងដែលកំណត់ដោយបញ្ញត្តិច្បាប់។

#### ខ.សិទ្ធិតំណាងដោយការព្រមព្រៀង

សិទ្ធិតំណាងអាចកើតឡើងដោយការព្រមព្រៀងគ្នារវាងម្ចាស់សិទ្ធិ និងអ្នកតំណាង។ នៅពេលដែលមានការព្រមព្រៀងគ្នាក្នុងការប្រគល់ និងទទួលនូវសិទ្ធិតំណាងរវាងម្ចាស់សិទ្ធិ និងអ្នកតំណាង ពេលនោះសិទ្ធិតំណាងមានអត្ថិភាពហើយ ទោះបីជាការព្រមព្រៀងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរក៏ដោយ។ តាមរយៈមាត្រា ៣៦៥ នៃក្រមរដ្ឋប្បវេណី សិទ្ធិតំណាងប្រភេទនេះ កើតឡើងនៅពេលមានកិច្ចសន្យារវាងម្ចាស់សិទ្ធិ និងអ្នកតំណាងដោយពុំទាមទារល័ក្ខខ័ណ្ឌទំរង់ជាលាយលក្ខណ៍អក្សរនោះឡើយ។

ជាទូទៅនៅពេលដែលម្ចាស់សិទ្ធិផ្តល់សិទ្ធិតំណាងទៅអោយអ្នកតំណាង នោះម្ចាស់សិទ្ធិតែងតែកំណត់អំពីអត្ថន័យនៃការតំណាង។

**ឧទាហរណ៍** ៖ លោក ក បានប្រគល់សិទ្ធិតំណាងអោយលោក ខ ក្នុងការទិញរថយន្តឲ្យខ្លួន។

### ២.២.វិសាលភាពនៃសិទ្ធិតំណាង

ដោយហេតុថាតាមរយៈរបបនៃការតំណាងនាំអោយសកម្មភាពរបស់អ្នកតំណាងត្រូវមានអានុភាពដោយផ្ទាល់ចំពោះម្ចាស់សិទ្ធិ ហេតុនេះការកំណត់អំពីវិសាលភាពនៃការតំណាងមានភាពចាំបាច់ជាទីបំផុត ដើម្បីកម្រិតព្រំដែននៃសកម្មភាពរបស់អ្នកតំណាង និងការពារផលប្រយោជន៍សមស្រប របស់ម្ចាស់សិទ្ធិផងដែរ។

[37] មាត្រា៣៦៥ ក្រមរដ្ឋប្បវេណី

### ក-ទំហំនៃសិទ្ធិតំណាង

ទំហំនៃសិទ្ធិតំណាង ត្រូវអាស្រ័យតាមការកកើតនៃសិទ្ធិតំណាងនោះ។

ចំពោះសិទ្ធិតំណាងដែល កើតដោយការព្រមព្រៀង ទំហំនៃសិទ្ធិតំណាងត្រូវកំណត់ក្នុងកិច្ចសន្យាដែលប្រគល់សិទ្ធិអោយអ្នកតំណាង។

<u>ឧទាហរណ៍</u> ៖ លោក (ក) បានផ្តល់សិទ្ធិតំណាងអោយទៅលោក (ខ) ក្នុងការស្វែងរកទិញ រថយន្តអោយខ្លួនដែលរថយន្តនោះ តម្លៃមិនអោយលើសពី ២០០០០$។ ករណីនេះយើងអាចនិយាយបានថាទំហំនៃសិទ្ធិតំណាងរបស់ (ខ) គឺមានទំហំមិនលើសពី ២០០០០$។

ចំពោះសិទ្ធិតំណាងដោយបញ្ញត្តិច្បាប់ ទំហំនៃសិទ្ធិតំណាង ក៏ត្រូវកំណត់ដោយបញ្ញត្តិច្បាប់ដែរ[38]។

ទំហំនៃសិទ្ធិតំណាងដោយបញ្ញត្តិច្បាប់ ភាគច្រើនមានភាពជាក់លាក់ ដោយហេតុថាបានកំណត់ច្បាស់លាស់ក្នុងបញ្ញត្តិច្បាប់ ដែលពុំសូវមានករណីទំហំនៃសិទ្ធិតំណាងពុំច្បាស់លាស់ឡើយ។ ប៉ុន្តែចំពោះ សិទ្ធិតំណាងដែលកើតការព្រមព្រៀង អាចមានករណីជាច្រើន ដែលទំហំនៃសិទ្ធិតំណាងមានភាពមិន ច្បាស់លាស់ ឬមិនបានកំណត់ជាក់លាក់ ក្នុងកិច្ចសន្យាតែម្តង។

ការតំណាងដោយបញ្ញត្តិច្បាប់ក៏ដោយ ការតំណាងដោយការព្រមព្រៀងក៏ដោយ ក្នុងករណីដែលទំហំនៃសិទ្ធិតំណាងមិនបានកំណត់ ឬមានភាពមិនច្បាស់លាស់ នោះអ្នកតំណាងត្រូវមានសិទ្ធិចំពោះអំពើថែរក្សានិងអំពើកែលំអប៉ុណ្ណោះ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះអំពើកែលំអ ដែលផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃការតំណាង[39]។

<u>ឧទាហរណ៍</u> ៖ "ក" ជាម្ចាស់ផ្ទះ បានប្រាប់(ផ្ទាល់មាត់)ទៅ "ខ" ដែលជាប្អូនប្រុសរបស់ខ្លួនថា "**ជួយមើលការជួសជុលផ្ទះអោយខ្លួនផង**" ។ "ខ" បានយល់ព្រម ហើយ"ខ" បានមកដល់ផ្ទះរបស់"ក" ដែលជាងកំពុងតែធ្វើការជួសជុល។ ភ្លាមនោះមេជាងបានមកប្រាប់ "ខ" ថាត្រូវទិញកុងទ័រទឹក០១គ្រឿង ជាបន្ទាន់ដើម្បីផ្លាស់កុងទ័រចាស់ដែលបែកធ្លាយ បើមិនដូច្នោះទេទឹកនឹងហូជ្រាបធ្វើឲ្យខូចជញ្ជាំង ដែលពាស ដោយក្រដាសលំអជាមិនខាន។ ដោយមិនអាចទាក់ទង"ក"បាននាពេលនោះ ហើយមេជាងប្រញាប់ខ្លាំង "ខ" បានទៅទិញ កុងទ័រទឹក០១គ្រឿងមក ដោយជំពាក់អ្នកលក់សិន។

ករណីនេះយើងពិនិត្យឃើញថា ទំហំនៃសិទ្ធិតំណាងដែល"ក" បានផ្តល់ជូន"ខ" ពុំត្រូវបានកំណត់ជាក់លាក់ឡើយ។ នៅពេលនោះសូម្បីតែ"ខ"ខ្លួនឯងក៏ប្រហែលជាពុំច្បាស់ថា តើ"ក" បាន ផ្តល់សិទ្ធិអោយ

---

[38] មាត្រា ៣៦៦ កថាខណ្ឌទី១

[39] មាត្រា ៣៦៦ កថាខណ្ឌទី ២

ខ្លួន ក្នុងការទិញកុងទ័រទឹកនោះ ឬអត់នោះទេ ប៉ុន្តែដោយសារតែបន្ទាន់ពេក និងមិនអាចទាក់ទង "ក" បាន ផង "ខ"ក៏ទិញសិនទៅ។

ករណីនេះកិច្ចសន្យាទិញ-លក់កុងទ័រទឹករវាង"ខ" និងអ្នកលក់ ត្រូវមានអានុភាពចំពោះ"ក" ដោយហេតុថា ថ្វីត្បិតតែទំហំនៃសិទ្ធិតំណាងរបស់"ខ"ក្នុងការទិញកុងទ័រទឹក មិនបានកំណត់ ឬមានភាពមិនច្បាស់លាស់ ប៉ុន្តែសកម្មភាពរបស់"ខ"នេះ គ្រឹមតែជាសកម្មភាពថែរក្សា និងមិនធ្វើអោយ ប្តូរលក្ខណៈនៃវត្ថុនោះឡើយ។ ដូច្នេះអ្នកលក់ អាចទារប្រាក់ថ្លៃកុងទ័រពី"ក"បាន។

### ខ-ការកម្រិតសិទ្ធិតំណាង

ទោះបីជាទំហំនៃសិទ្ធិតំណាងត្រូវកំណត់ច្បាស់លាស់យ៉ាងណាក៏ដោយ ក៏ពុំមែនមានន័យថាអ្នកតំណាងអាចធ្វើសកម្មភាពយ៉ាងទូលំទូលាយ ក្នុងទំហំនៃសិទ្ធិតំណាងនោះដោយគ្មានដែនកំណត់ដែរ។ ករណីនេះ សិទ្ធិតំណាងត្រូវបានកម្រិតដូចខាងក្រោម[40] ៖

- ចំពោះអំពើដែលផលប្រយោជន៍របសអ្នកតំណាង និងម្ចាស់សិទ្ធិមានភាពផ្ទុយគ្នានោះអ្នកតំណាងគ្មានសិទ្ធិឡើយ លើកលែងតែម្ចាស់សិទ្ធិយល់ព្រម។

ចំពោះកិច្ចការជំនួញរវាងម្ចាស់សិទ្ធិ និងអ្នកតំណាង ត្រូវសន្មតថាផលប្រយោជន៍ម្ចាស់សិទ្ធិ និងអ្នកតំណាង មានភាពផ្ទុយគ្នា។

- អ្នកតំណាង ធ្វើជាតំណាងអោយម្ចាស់សិទ្ធិផង ធ្វើជាតំណាងអោយតតិយជនផង ហើយផលប្រយោជន៍ម្ចាស់សិទ្ធិ និងតតិយជនផ្ទុយគ្នា នោះអ្នកតំណាងគ្មានសិទ្ធិឡើយ លើកលែងតែម្ចាស់សិទ្ធិយល់ព្រម។

## ២-៣-ការរលត់សិទ្ធិតំណាង

### ក-ការតំណាងដោយបញ្ញត្តិច្បាប់

ការតំណាងដែលច្បាប់បានកំណត់ ត្រូវរលត់ដោយសារមូលហេតុដែលបានកំណត់ក្នុងច្បាប់[41]។

### ខ-ការតំណាងដោយការព្រមព្រៀង

ការតំណាងដោយការព្រមព្រៀង ត្រូវរលត់ដោយសារមូលហេតុដូចខាងក្រោម ៖

- មរណភាព ធនក្ស័យ ឬការរំលាយរបស់ម្ចាស់សិទ្ធិ។
- មរណភាព ធនក្ស័យ ឬការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង។

[40] មាត្រា ៣៦៧ ក្រមរដ្ឋប្បវេណី

[41] មាត្រា ៣៦៨-២ ក្រមរដ្ឋប្បវេណី

- ការបញ្ចប់អាណត្តិកិច្ចសន្យាការងារ ឬទំនាក់ទំនងគតិយុត្តផ្សេងទៀត ដែលបានប្រគល់សិទ្ធិតំណាង។

## ៣-ការតំណាងដោយគ្មានសិទ្ធិ និងការតំណាងដែលមានលក្ខណៈជារូបភាព

### ៣-១-ការតំណាងដោយគ្មានសិទ្ធិ

ការតំណាងដោយគ្មានសិទ្ធិ គឺជាសកម្មភាពតំណាងដែលអ្នកតំណាងធ្វើដោយខ្លួនគ្មានសិទ្ធិ ហើយអានុភាពនៃសកម្មភាពតំណាងមិនកើតមានចំពោះម្ចាស់សិទ្ធិនោះទេ។

#### ក-ទំរង់នៃការតំណាងដោយគ្មានសិទ្ធិ

ការតំណាងដោយគ្មានសិទ្ធិ មាន៤ប្រភេទ ៖

១. ម្ចាស់សិទ្ធិមិនដែលផ្តល់សិទ្ធិតំណាងដល់អ្នកធ្វើសកម្មភាព ។

២.ម្ចាស់សិទ្ធិបានផ្តល់សិទ្ធិតំណាងដល់អ្នកធ្វើសកម្មភាព ប៉ុន្តែអ្នកធ្វើសកម្មភាពបានធ្វើសកម្មភាពក្រោយសិទ្ធិតំណាងត្រូវបានបញ្ចប់។

៣.ម្ចាស់សិទ្ធិបានផ្តល់សិទ្ធិតំណាងដល់អ្នកធ្វើសកម្មភាព ប៉ុន្តែអ្នកធ្វើសកម្មភាពហួសពីទំហំនៃទំហំ នៃសិទ្ធិតំណាង ។

៤.ម្ចាស់សិទ្ធិបានផ្តល់សិទ្ធិតំណាងដល់អ្នកធ្វើសកម្មភាព ហើយអ្នកធ្វើសកម្មភាបានធ្វើសកម្មភាពក្នុងទំហំតំណាង មុនពេលបញ្ចប់ការតំណាង ប៉ុន្តែសកម្មភាពនោះក្នុងការកម្រិតសិទ្ធិតំណាង [42]។

#### ខ-អានុភាពនៃការតំណាងដោយគ្មានសិទ្ធិ

អំពើដែលអ្នកគ្មានសិទ្ធិតំណាងធ្វើក្នុងនាមអ្នកតំណាងរបស់អ្នកដទៃ មិនត្រូវបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិឡើយ[43]។ ក៏ប៉ុន្តែបញ្ញត្តិនេះមិនត្រូវ យកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់សិទ្ធិបានផ្តល់សច្ចានុមតិចំពោះអំពើនោះ[44]។ និយាយជារួម កិច្ចសន្យាមិនបង្កើតអានុភាពទេ លុះត្រាតែម្ចាស់សិទ្ធិបានផ្តល់សច្ចានុមតិ ចំពោះកិច្ចសន្យានោះ។

ប្រសិនបើកិច្ចសន្យាមានអានុភាពដូចខាងលើ នោះភាគីម្ខាងទៀតអាចនិងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

---

[42] មាត្រា ៣៦៧ ក្រមរដ្ឋប្បវេណី

[43] មាត្រា ៣៦៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១

[44] មាត្រា ៣៦៩ កថាខណ្ឌទី៨ វាក្យខណ្ឌទី២

<u>**ឧទាហរណ៍**</u> ៖ ប្រសិនបើភាគីម្ខាងទៀតបានលក់ដីមួយកន្លែងទៅអោយអ្នកគ្មានសិទ្ធិតំណាង នោះភាគីម្ខាងទៀតត្រូវរង់ចាំម្ចាស់សិទ្ធិដើម្បីសម្រេចថាផ្តល់សច្ចានុមតិ ឬអត់។ ប្រសិនបើម្ចាស់សិទ្ធិប្រើរយៈពេលយូរក្នុងការសម្រេចចិត្ត ហើយចុងក្រោយបានសម្រេចថាមិនផ្តល់សច្ចានុមតិ នោះភាគីម្ខាងទៀតអាចបាត់បង់ឱកាស ក្នុងការលក់ដីនេះទៅអោយអ្នកផ្សេងទៀតក្នុងតម្លៃមួយដែលល្អជាងនេះ។ ដូច្នេះ ដើម្បីការពារភាគីម្ខាងទៀត ក្រមរដ្ឋប្បវេណីបានចែងពីមធ្យោបាយ ២យ៉ាងពីរ គឺភាគីម្ខាងទៀតអាចដាស់តឿនអោយម្ចាស់សិទ្ធិឆ្លើយអំពីការផ្តល់ ឬមិនផ្តល់សច្ចានុមតិ[45] ឬភាគីម្ខាងទៀតអាចលុបចោលកិច្ចសន្យាបាន[46]។

### គ-ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

ក្នុងករណីអ្នកតំណាងដែលធ្វើសកម្មភាពតំណាងសម្រាប់អ្នកដទៃ មិនអាចបញ្ជាក់អំពីសិទ្ធិតំណាងរបស់ខ្លួន ឬមិនអាចទទួលសច្ចានុមតិពីសាមីខ្លួនបានទេ អ្នកតំណាងដែលគ្មានសិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ឬទទួលខុសត្រូវក្នុងការសងសំណងការខូចខាត តាមរយៈការជ្រើសរើសរបស់ភាគីម្ខាងទៀត។

ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតបានដឹងពីនត្ថិភាពនៃសិទ្ធិតំណាង អ្នកតំណាងដែលគ្មានសិទ្ធិអាចរួចផុតពីការទទួលខុសត្រូវ។

អ្នកតំណាងដែលគ្មានសិទ្ធិគ្មានកំហុស ក្នុងការធ្វើសកម្មភាពតំណាងក៏ អាចរួចផុតពីការទទួលខុសត្រូវបានដែរ ទោះបីជាភាគីម្ខាងទៀតមិនបានដឹងពីនត្ថិភាពនៃសិទ្ធិតំណាង ដោយកំហុសក៏ដោយ។

### ៣-២-ការតំណាងដែលមានលក្ខណៈជារូបភាព

### ក. ការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសពីទំហំនៃសិទ្ធិតំណាង

ការតំណាងដែលមានលក្ខណៈជារូបភាពប្រភេទនេះ គឺជាការតំណាងដែលភាគីអ្នកតំណាងធ្វើសកម្មភាពហួសពីទំហំនៃសិទ្ធិតំណាង។ គោលបំណងនៃការតំណាងប្រភេទនេះ គឺដើម្បីការពារដល់ភាគីម្ខាងទៀតនៃកិច្ចសន្យា នៅពេលដែលអ្នកតំណាងបានធ្វើសកម្មភាព ដែលហួសពីទំហំនៃសិទ្ធិតំណាងរបស់ខ្លួន។ ហើយប្រសិនបើភាគីម្ខាងទៀតនោះមានការជឿជាក់ថា អ្នកមានសិទ្ធិតំណាងធ្វើសកម្មភាពនោះដោយមានសិទ្ធិតំណាង នោះភាគីអោយម្ចាស់សិទ្ធិអនុវត្តកាតព្វកិច្ចរបស់គេចំពោះខ្លួនបាន។

<u>**ឧទាហរណ៍**</u> ៖ លោក A បានប្រគល់សិទ្ធិតំណាង និងប្លង់ផ្ទះអោយលោក B ដើម្បីបង្កើត ហ៊ីប៉ូតែកអោយខ្លួន ប៉ុន្តែក្រោយពីបានប្លង់ផ្ទះពី A លោក B បានបង្កើតកិច្ចសន្យាទិញលក់ជាមួយ C ក្នុងនាម A។

[45] មាត្រា ៣៧០ កថាខណ្ឌទី៣

[46] មាត្រា ៣៧០ កថាខណ្ឌទី៤

សកម្មភាពរបស់ B បានធ្វើអោយ C ជឿជាក់ថា B ជាអ្នកតំណាងអោយម្ចាស់ផ្ទះ ហើយ ទទួលនូវសិទ្ធិតំណាងក្នុងការបង្កើតកិច្ចសន្យាលក់ផ្ទះនេះពិតប្រាកដមែន។ ហេតុនេះC អាចទាម ទារអោយ A ដែលជាម្ចាស់ផ្ទះអនុវត្តកិច្ចសន្យាទិញលក់ជាមួយខ្លួនបាន។

**ខ-ការតំណាងដែលមានលក្ខណៈជារូបភាពក្រោយការរលត់សិទ្ធិតំណាង**

ករណីនេះគឺសិទ្ធិតំណាងត្រូវបានបង្កើតឡើងដោយពិតប្រាកដ ប៉ុន្តែបន្ទាប់ពីសិទ្ធិតំណាងត្រូវបានរលត់ អ្នកតំណាងដោយគ្មានសិទ្ធិ គឺនៅតែធ្វើសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិតំណាងដែលធ្លាប់មានអត្ថិភាព។ ជាធម្មតាភាគីម្ខាងនៃកិច្ចសន្យា មិនបានដឹងអំពីការរលត់សិទ្ធិតំណាងនេះទេ ហេតុនេះដើម្បីការពារនូវផលប្រយោជន៍ភាគីម្ខាង នៃកិច្ចសន្យាដែលមិនបានដឹងពីការរលត់សិទ្ធិតំណាងនេះ ទើបច្បាប់ទទួលស្គាល់សិទ្ធរបស់ភាគីម្ខាង ក្នុងការអះអាងចំពោះម្ចាស់សិទ្ធិ អោយអនុវត្តកិច្ចសន្យាបាន។ ប្រសិនបើម្ចាស់សិទ្ធិចង់បដិសេធន៍មិនអនុវត្តកាតព្វកិច្ច នោះម្ចាស់សិទ្ធិត្រូវបញ្ជាក់អំពីការទុច្ចរិត និងមានកំហុសរបស់ភាគីម្ខាងទៀត ។ នេះជាការពារនូវជំនឿជឿជាក់របស់ភាគីម្ខាងទៀតក្នុងកិច្ចសន្យា។

<u>ឧទាហរណ៍</u> ៖ លោក ក ជាបុគ្គលិកផ្នែកទីផ្សាររបស់ ក្រុមហ៊ុន ខ ជាធម្មតា ក តែងតែធ្វើការ បញ្ជាទិញទំនិញពីក្រុមហ៊ុន គ តំណាងអោយ ខ។ ថ្ងៃមួយ ក បានបញ្ជាទិញទំនិញពីក្រុមហ៊ុន គ ប៉ុន្តែ ក្រោយមកបន្តិច ស្រាប់តែឮដំណឹងថា ក ត្រូវបានបញ្ឈប់ពីការងារ។

**គ-ការតំណាងដែលមានលក្ខណៈជារូបភាពដោយសារការបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាង**

ការតំណាងប្រភេទនេះ គឺជាប្រភេទតំណាងដែលគ្មានសិទ្ធិ ប៉ុន្តែដើម្បីការពារទំនុកចិត្តរបស់ភាគីម្ខាងនៃកិច្ចសន្យា ដែលមានការទុកចិត្តចំពោះម្ចាស់សិទ្ធិ ដែលបានបង្ហាញដូចខ្លួនបានប្រគល់សិទ្ធិតំណាងទៅអោយអ្នកតំណាង ឬបានធ្វើអោយមានការភ័ន្តច្រឡំថា ម្ចាស់សិទ្ធិពិតជាបានប្រគល់សិទ្ធិតំណាងទៅអោយអ្នកតំណាង នោះភាគីនៃកិច្ចសន្យាអាចអះអាងចំពោះម្ចាស់សិទ្ធិបាន។

## ៤-ករណីសិក្សា

**ករណីទី០១ ៖**

A ជាម្ចាស់នៃបារមួយកន្លែង។ B ជាបុគ្គលិករបស់ A។ A បានផ្តល់សិទ្ធិតំណាងឲ្យ B ជាមួយនឹងទំហំដែល B អាចទិញស្រាណាមួយ ក្នុងចំនួនថវិកា ៣០០០ ដុល្លារ ក្នុងមួយខែ។ X ជាហាងលក់ស្រាមួយដែលលក់ស្រាល្អជាងគេ។ B ក្នុងនាមជាអ្នកតំណាងឲ្យ A បានទិញស្រាវីស្គីដែលមានតម្លៃថ្លៃជាងគេក្នុង

តម្លៃ ៥០០ ដុល្លារ ពីX ដោយមានឆន្ទៈផឹកខ្លួនឯង។ នៅពេល X បានផ្ញើវិក្កយបត្រចំនួន ៥០០ ដុល្លារទៅ A A បានបដិសេធក្នុងការបង់ប្រាក់ ដោយសារ B បានផឹកស្រាវីស្គីនោះដោយខ្លួនឯង។

**ករណីទី០២ ៖**

A ជាប្តី ហើយ B ជាប្រពន្ធ។

B បានទិញសម្លៀកបំពាក់ជាច្រើនពី C។ B បានផ្តល់សម្លៀកបំពាក់នោះជាកាដូទៅ X ដែលជាមិត្តប្រុសរបស់ B។ C បានទាមទារឲ្យ A បង់ប្រាក់ថ្លៃទិញ ដោយផ្អែកតាមមាត្រា៩៧៥ ចំណុច ក នៃក.រ ប៉ុន្តែ A បានបដិសេធ ដោយសារ ការទិញ B មិនមែនជាសោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តី ប្រពន្ធនោះទេ។

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៨

## ប្រធានបទ៖ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការលក់ទិញ

### ថ្ងៃទី ០៧ មេសា ២០១៥

# ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការលក់ទិញ

## ១. សញ្ញាណទូទៅ

### ១.១ មូលហេតុនៃការផ្ទេរកម្មសិទ្ធិ

កម្មសិទ្ធិលើអចលនវត្ថុ ត្រូវបានផ្ទេរដោយមូលហេតុ ការព្រមព្រៀង សន្តតិកម្ម និងមូលហេតុផ្សេងទៀត។

(១) ការផ្ទេរកម្មសិទ្ធិតាមរយៈការព្រមព្រៀង

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុតាមរយៈការព្រមព្រៀងមានដូចជា លក់ទិញ ប្រទានកម្ម ការដូរជាអាទិ៍ ។

(២) ការផ្ទេរកម្មសិទ្ធិដោយមូលហេតុសន្តតិកម្ម

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសសន្តតិកម្ម រួមមាន សន្តតិកម្មតាមច្បាប់ សន្តតិកម្មតាមមតកសាសន៍ ការពិភាក្សាគ្នាបែងចែកមតិក និងអច្ច័យទាន។

(៣) ការផ្ទេរដោយមូលហេតុផ្សេងទៀត

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុផ្សេងទៀត មានដូចជា ការអនុវត្តដោយបង្ខំ ការអនុវត្តសិទ្ធិប្រាតិភោគ លទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល ការលុបចោល រំលាយ និងមោឃភាព។

### ១.២ គោលការណ៍នៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ផ្អែកលើគោលការណ៍ពីរ គឺ គោលការណ៍ផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង និងគោលកាណ៍នៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមិនធ្វើឡើងតាមការព្រមព្រៀង។

(១) ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុតាមការព្រមព្រៀង

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង គឺជាការផ្ទេរកម្មសិទ្ធិដែលកើតចេញអំពីការព្រមព្រៀង តាមរយៈកិច្ចសន្យាលក់ទិញ កិច្ចសន្យាដូរ កិច្ចសន្យាប្រទានកម្មជាអាទិ៍ (**មាត្រា៥១៥ មាត្រា៥៦៦ និងមាត្រា៥៦៨ នៃក្រមរដ្ឋប្បវេណី**)។ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មាន

អានុភាពលុះត្រាតែបានចុះបញ្ជី មានន័យថា ការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ (**មាត្រា១៣៥ នៃក្រមរដ្ឋប្បវេណី**)។

(២) ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុមិនធ្វើឡើងដោយការព្រមព្រៀង

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលមិនធ្វើឡើងដោយការព្រមព្រៀង គឺជាការផ្ទេរដោយមិនផ្អែកលើការព្រមព្រៀងរបស់ភាគីនោះទេ ហេតុនេះ បញ្ញត្តិនៃមាត្រា១៣៣ និង១៣៥នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ។ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលមិនធ្វើឡើងដោយការព្រមព្រៀង មានអានុភាពផ្ទេរដោយស្វ័យប្រវត្ត មុនពេលចុះបញ្ជី កាលបើមានមូលហេតុនៃការផ្ទេរកើតឡើងដូចជាសន្តតិកម្ម លទ្ធកម្មនៃកម្មសិទ្ធិដោយអាជ្ញាយុកាល ការលុបចោលជាអាទិ៍ (**មាត្រា១១៤៧ មាត្រា១៦២ និងមាត្រា៣៥៨ នៃក្រមរដ្ឋប្បវេណី**)។

| |
|---|
| ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសន្តតិកម្ម គឺជាការផ្ទេរកម្មសិទ្ធិដោយមិនផ្អែកតាមការព្រមព្រៀង ហេតុនេះកម្មសិទ្ធិលើអចលនត្ថុនឹងត្រូវបានផ្ទេរដោយស្វ័យប្រវត្តពីមតកជនទៅសន្តតិជនចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព(**មាត្រា១១៥៤នៃក្រមរដ្ឋប្បវេណី**)។ ក្នុងករណីសន្តតិកម្មតាមច្បាប់សន្តតិកម្មតាមមតកសាសន៍ និងអច្ច័យទានដូចមានបញ្ញត្តិនៅក្នុងមាត្រា១១៩៩នៃក្រមរដ្ឋប្បវេណី វាមានលក្ខណៈច្បាស់លាស់ថាការផ្ទេរកម្មសិទ្ធិត្រូវបានអនុវត្តដោយមិនមែនតាមការព្រមព្រៀង។ ប៉ុន្តែក្នុងករណីសហសន្តតិជនបានធ្វើការពិភាក្សាគ្នាបែងចែកមតិកដូចមានបញ្ញត្តិនៅក្នុងមាត្រា១២៦៦ នៃក្រមរដ្ឋប្បវេណី វាអាចមានភាពចម្រូងចម្រាសថាតើការផ្ទេរកម្មសិទ្ធិត្រូវបានអនុវត្តតាមការព្រមព្រៀងឬ មិនមែនតាមការព្រមព្រៀង។ ប៉ុន្តែ ដោយសារអានុភាពប្រតិសកម្មនៃការពិភាក្សាបែងចែកមតិកតាម បញ្ញត្តិនៃមាត្រា១២៧៣ កថាខណ្ឌទី ១ នៃក្រម កម្មសិទ្ធិនៃដីត្រូវបានចាត់ទុកថាបានផ្ទេរពីមតកជន ទៅសន្តតិជនដោយផ្ទាល់ នៅពេលមតកជនទទួលមរណភាព មានន័យថា រចនាសម្ព័ន្ធនៃការផ្ទេរកម្មសិទ្ធិគឺដូចគ្នានឹងសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍ ពោលគឺកម្មសិទ្ធិលើអចលនវត្ថុ ត្រូវបានផ្ទេរ ដោយមិនចាំបាច់មានការចុះបញ្ជី ហេតុនេះមាត្រា១៣៥ នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ។ |

(៣) ស្ថានភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនៅកម្ពុជា

ផ្អែកតាមការវាយតម្លៃរបស់មន្ត្រីចុះបញ្ជី ដីធ្លីត្រឹមតែ៥៥ភាគតែប៉ុណ្ណោះដែលត្រូវបានចុះបញ្ជី (មានប័ណ្ណកម្មសិទ្ធិ) ហេតុនេះ យើងឃើញថា នៅកម្ពុជាមានដីធ្លីដែលមិនទាន់បានចុះបញ្ជីនៅមានចំនួនច្រើន ប៉ុន្តែទាំងដីធ្លីដែលបានចុះបញ្ជី និងដីធ្លីដែលមិនទាន់បានចុះបញ្ជី សុទ្ធតែក្លាយជាកម្មវត្ថុនៃការលក់ទិញ។

ចំពោះដីដែលបានចុះបញ្ជី ក្នុងករណីមានការលក់ទិញ ការផ្ទេរកម្មសិទ្ធិតាមរយៈការចុះបញ្ជី ត្រូវបានអនុវត្ត ប៉ុន្តែ ក៏មានករណីមួយចំនួន ដែលគូភាគី ពុំបានធ្វើការផ្ទេរកម្មសិទ្ធិតាមរយៈការចុះបញ្ជីនោះទេ ពោលគឺ គូភាគីព្រមព្រៀងគ្នាផ្ទេរកម្មសិទ្ធិ ត្រឹមអាជ្ញាធរសង្កាត់ ខណ្ឌ ទោះបីជាដឹងថា ការផ្ទេរនេះ ពុំមានអានុភាពតាមផ្លូវច្បាប់ក៏ដោយ។ ចំណែកឯ ដីដែលមិនទាន់បានចុះបញ្ជី ក្នុងករណីមានការលក់ទិញ ការផ្ទេរសិទ្ធិលើដី ធ្វើឡើងត្រឹមអាជ្ញាធរសង្កាត់ ខណ្ឌ ហៅថា ការផ្ទេរសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី។

## ២. លក្ខខណ្ឌក្នុងការផ្ទេរកម្មសិទ្ធិលើអចលវត្ថុដោយការលក់ទិញ

### ២.១ ការព្រមព្រៀងបង្កើតកិច្ចសន្យាលក់ទិញដោយលិខិតយថាភូត

#### ក. ភាពចាំបាច់នៃការបង្កើតកិច្ចសន្យាទិញលក់ដោយលិខិតយថាភូត

⇨ ទិដ្ឋភាពផ្លូវច្បាប់នៃការបង្កើតកិច្ចសន្យាលក់ទិញ

ជាគោលការណ៍ កិច្ចសន្យាមានអានុភាព (កើតឡើង)ដោយសារសំណើ និងស្វីកាត្រូវគ្នា (**មាត្រា៣៣៦ កថាខណ្ឌទី១ នៃក្រម**)។ ប៉ុន្តែក្នុងករណីកិច្ចសន្យាដែលភាគីម្ខាងទទួលករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ <u>នឹងមានអានុភាពលុះត្រាតែបានធ្វើតាមលិខិតយថាភូត</u> (**មាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋវេណី**)។

កិច្ចសន្យាលក់ទិញអចលនវត្ថុ គឺជាប្រភេទនៃកិច្ចសន្យាដែលភាគីម្ខាងទទួលករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ ហេតុនេះ កិច្ចសន្យាលក់ទិញអចលនវត្ថុមានអានុភាពលុះត្រាតែបានធ្វើឡើងដោយលិខិតយថាភូត(**មាត្រា៥១៦នៃក្រមរដ្ឋប្បវេណី**)។

| |
|---|
| បញ្ហា៖ ភាពខុសគ្នារវាងច្បាប់ភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីទាក់ទងនឹងការបង្កើតកិច្ចសន្យាលក់ទិញតាមលិខិតយថាភូត<br><u>ច្បាប់ភូមិបាល</u>៖ ការបង្កើតកិច្ចសន្យាលក់ទិញតាមលិខិតយថាភូត គឺជាលក្ខខណ្ឌតតាំងនឹងតតិយជន ហេតុនេះ គូភាគីអាចបង្កើតកិច្ចសន្យាលក់ទិញតាមលិខិតឯកជនបាន ប៉ុន្តែមានអានុភាពត្រឹមតែគូភាគីតែប៉ុណ្ណោះ ពោលគឺ មិនអាចតតាំងនឹងតតិជនបានទេ (**មាត្រា៦៥**)។ * បញ្ញត្តិនេះត្រូវបាននិរាករណ៍ដោយមាត្រា ៨០ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។<br><u>ក្រមរដ្ឋប្បវេណី</u>៖ ការបង្កើតកិច្ចសន្យាលក់ទិញតាមលិខិតយថាភូត គឺជាលក្ខខណ្ឌបង្កើតអានុភាពនៃកិច្ចសន្យាចំពោះភាគី មានន័យថា ក្នុងករណីកិច្ចសន្យាលក់ទិញធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលិខិតឯកជន កិច្ចសន្យានោះពុំមានអានុភាព(មិនកើតឡើង)ចំពោះភាគីទេ(**មាត្រា៣៣៦ កថាខណ្ឌទី២ និងមាត្រា៥១៦ វាក្យខណ្ឌទី១**)។ |

➩ ការអនុវត្តជាក់ស្តែង

ទោះបីជាក្រមរដ្ឋប្បវេណី ត្រូវបានអនុវត្តអស់រយៈពេលជិត៨ឆ្នាំហើយក៏ដោយ រហូតមកទល់នឹងពេលនេះ ក៏នៅតែមានភាពខ្វែងគ្នារវាងទិដ្ឋភាពផ្លូវច្បាប់ និងការអនុវត្តជាក់ស្តែងទាក់ទងនឹងការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ។ សព្វថ្ងៃ កិច្ចសន្យាទិញលក់ស្ទើរតែទាំងស្រុង ត្រូវបានបង្កើតឡើងតាមរយៈលិខិតឯកជន (កិច្ចសន្យាចែងអំពី កម្មវត្ថុ តម្លៃ និងខចែងផ្សេងទៀតដែលទាក់ទងនឹងសិទ្ធិ និងករណីកិច្ចរបស់អ្នកលក់ និងអ្នកទិញ) បន្ទាប់មក ដើម្បីអាចចុះបញ្ជីផ្ទេរកម្មសិទ្ធិបាន ភាគីនៃកិច្ចសន្យា ត្រូវផ្តិតមេដៃលើលិខិតមួយដែលរៀបចំដោយមន្ត្រីសុរិយោដី ហៅថា **លិខិតលក់ផ្តាច់** បន្ទាប់មក នឹងចាប់ផ្តើមដំណើរការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។ តើកិច្ចសន្យាដែលធ្វើឡើងដោយភាគីនោះមានអានុភាព ដែរឬទេ? តើលិខិតលក់ផ្តាច់ ចាត់ទុកថាជាលិខិតយថាភូតដែរឬទេ? ហេតុនេះ យើងត្រូវស្វែងយល់ថា អ្វីទៅជាលិខិតយថាភូតជាមុនសិន។

## ខ.អត្ថន័យនៃលិខិតយថាភូត

អត្ថន័យនៃលិខិតយថាភូត ត្រូវបានបញ្ញត្តិនៅក្នុងមាត្រា៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីសំដៅលើ៖

(១) លិខិតដែលធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និង ចុះកាលបរិច្ឆេទ និងចុះហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ (**មាត្រា៩ ចំណុចក វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីការអនុវត្តក្រម**)។

តើអ្នកណាជាសារការី?

នៅកម្ពុជា ជនទាំងពីរប្រភេទដូចខាងក្រោមគឺជាសារការី៖

❶ជនដែលត្រូវបានតែងតាំងជាសារការី

❷មន្ត្រីដែលទទួលបន្ទុកកិច្ចការសារការី (**មាត្រា១០ និង១១ នៃច្បាប់ស្តីពីការអនុវត្តក្រម**)។

(២) លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី

តើអ្នកណាជាមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីចុះបញ្ជី ?

ផ្អែកតាមគោលគំនិតនៃក្រមរដ្ឋប្បវេណី មន្ត្រីដែលមានសមត្ថកិច្ចធ្វើលិខិតយថាភូត ត្រូវបានផ្តល់ឲ្យមន្ត្រីសារការីតែប៉ុណ្ណោះ ប៉ុន្តែផ្អែកតាមការអនុវត្តជាក់ស្តែង យើងគ្មានសារការី ហើយទោះបីជាឥឡូវ

យើងមានសារការីក៏ដោយ ការចុះបញ្ជីអាចធ្វើទៅបានលុះត្រាតែ ភាគីបានផ្តិតមេដៃលើលិខិតលក់ផ្តាច់ ហេតុនេះ កិច្ចសន្យាលក់ទិញដែលធ្វើឡើងដោយសារការីមិនអាចក្លាយជាឯកសារដើម្បីចុះបញ្ជីផ្ទេរកម្ម លើអចលនវត្ថុបានទេ។ ម្យ៉ាងវិញទៀត នៅក្នុងលិខិតលក់ផ្តាច់ មានប្រថាប់ត្រារបស់មេឃុំ ចៅសង្កាត់ និងហត្ថលេខារបស់មន្ត្រីសុរិយោដី ហេតុនេះដើម្បីសម្របសម្រួលចំពោះស្ថានភាពបែបនេះ ការផ្តល់សមត្ថកិច្ចក្នុងការធ្វើលិខិតយថាភូតដល់មន្ត្រីផ្សេងទៀត ក្រៅអំពីមន្ត្រីសារការី គឺជាភាពចាំបាច់។

| |
|---|
| តើមេឃុំ ឬ ចៅសង្កាត់ និងមន្ត្រីសុរិយោដី អ្នកណាក្លាយជាមន្ត្រីមានសមត្ថកិច្ចធ្វើលិខិតយថាភូត ក្នុងនាមជាមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីចុះបញ្ជី? |

ផ្អែកលើប្រកាសអន្តរក្រសួងលេខ២១៥ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ **ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំសង្កាត់ក្នុងការចុះបញ្ជីដីធ្លី** មេឃុំ ឬ ចៅសង្កាត់ ត្រូវបានកំណត់ជាមន្ត្រីមានសមត្ថកិច្ចក្នុងការធ្វើលិខិតយថាភូត។ ចំណែកឯ មន្ត្រីសុរិយោដី គឺជាមន្ត្រីដែលមានសមត្ថកិច្ចចុះបញ្ជី មិនមែនមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីចុះបញ្ជីនោះទេ (**ប្រការ៥ នៃប្រកាសអន្តរក្រសួងក្រមរដ្ឋប្បវេណី**)។

ដោយសារតែ នៅក្នុងលិខិតលក់ផ្តាច់មានប្រថាប់ត្រារបស់មេឃុំ ឬចៅសង្កាត់ ហើយមេឃុំ ឬ ចៅសង្កាត់ត្រូវបានចាត់ទុកជាមន្ត្រីដែលមានសមត្ថកិច្ចចេញលិខិតយថាភូត ហេតុនេះ លិខិតលក់ផ្តាច់ ត្រូវចាត់ទុកថា ជាលិខិតយថាភូត។

| |
|---|
| បញ្ហា៖ លិខិតលក់ផ្តាច់ និងកិច្ចសន្យាដែលធ្វើឡើងដោយគូភាគី (លិខិតឯកជន)<br>កិច្ចសន្យាលក់ទិញអចលនវត្ថុ មានអានុភាព លុះត្រាតែបានបង្កើតឡើងតាមទម្រង់យថាភូតតាមបញ្ញត្តិនៃមាត្រា៣៣៦ កថាខណ្ឌទី២ និងមាត្រា៥១៦ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ហេតុនេះ កិច្ចសន្យាលក់ទិញអចលនវត្ថុដែលត្រូវបានបង្កើតឡើងតាមលិខិតឯកជនពុំមានអានុភាពឡើយ ។ ក្នុងករណី កិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវបានបង្កើតឡើងតាមរយៈលិខិតឯកជន បន្ទាប់មក បានធ្វើលិខិតលក់ផ្តាច់ តើកិច្ចសន្យាដែលធ្វើឡើងដោយ លិខិតឯកជន មានអានុភាពដែរឬទេ? |

## ២.៣ ការព្រមព្រៀងផ្ទេរកម្មសិទ្ធិ (ចុះបញ្ជី)

ជាគោលការណ៍ ការព្រមព្រៀងផ្ទេរកម្មសិទ្ធិ មានអានុភាពត្រឹមតែការព្រមព្រៀងរវាងគូភាគីប៉ុណ្ណោះ(**មាត្រា១៣៣ នៃក្រមរដ្ឋប្បវេណី**)។ ប៉ុន្តែ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀងមានអានុភាពលុះត្រាតែបានចុះបញ្ជី ហេតុនេះ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការលក់ទិញ មាន

អានុភាពលុះត្រាតែបានចុះបញ្ជី(**មាត្រា១៣៥ នៃក្រម**)។ ក្នុងករណី ពុំបានធ្វើការចុះបញ្ជីទេ នោះការផ្ទេរកម្មសិទ្ធិក៏មិនកើតឡើងដែរ ហេតុនេះការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌក្នុងការបង្កើតអានុភាព មិនមែនជាល័ក្ខខ័ណ្ឌតតាំងទេ ប៉ុន្តែ បើយើងពិនិត្យមើលមាត្រា១៣៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ការចុះបញ្ជី ក៏ជាល័ក្ខខ័ណ្ឌតតាំងដែរ។

| |
|---|
| បញ្ហា៖ ការចុះបញ្ជី ជាល័ក្ខខ័ណ្ឌបង្កើតអានុភាព (មាត្រា១៣៥) និងការចុះបញ្ជីជាល័ក្ខខ័ណ្ឌតតាំង (មាត្រា១៣៤ កថាខណ្ឌទី១)។ |

➩ក្នុងករណីការចុះបញ្ជីផ្ទេរកម្មសិទ្ធិតាមការព្រមព្រៀង ដូចជាករណីលក់ទិញជាអាទិ៍ ការចុះបញ្ជីគឺជាល័ក្ខខ័ណ្ឌបង្កើតអានុភាព ហេតុនេះ ក្នុងករណី បានចុះបញ្ជីដែលជាល័ក្ខខ័ណ្ឌបង្កើតអានុភាពរួចរាល់ហើយ មិនចាំបាច់ចុះបញ្ជីដើម្បីទទួលបានល័ក្ខខ័ណ្ឌតតាំងទេ ពីព្រោះករណីនេះ ល័ក្ខខ័ណ្ឌបង្កើតអានុភាព និងល័ក្ខខ័ណ្ឌតតាំង គឺ ត្រួតគ្នា ហេតុនេះ ការចុះបញ្ជីបង្កើតអានុភាព នាំឲ្យទទួលបាននូវល័ក្ខខ័ណ្ឌតតាំង។

➩ ក្នុងករណីការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមិនធ្វើឡើងតាមការព្រមព្រៀង ដូចជាករណី សន្តតិកម្មតាមច្បាប់ជាអាទិ៍ ការចុះបញ្ជី បង្កើតអានុភាពមិនមែនជាល័ក្ខខ័ណ្ឌបង្កើតអានុភាពទេ ពីព្រោះ អានុភាពនៃការផ្ទេរត្រូវបានកើតឡើងដោយស្វ័យប្រវត្តិ ប៉ុន្តែដើម្បីអះអាងនូវកម្មសិទ្ធិចំពោះតតិយជន លុះត្រាតែបានចុះបញ្ជី តាមបញ្ញត្តិនៃមាត្រា១៣៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ហេតុនេះ ការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌតតាំង។ ឧទាហរណ៍ Aមតកជន មានដីមួយកន្លែង មានសន្តតិជនពីរនាក់ C&D ហើយAបានធ្វើ អច្ច័យទាននូវដីនោះឲ្យទៅX។ ដីមួយកន្លែងនោះនឹងក្លាយជាកម្មសិទ្ធិរបស់ X ទោះបីជាពុំមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិពីឈ្មោះរបស់Aទៅឈ្មោះរបស់ X ក៏ដោយ នេះដោយសារតែអច្ច័យទាន កើតចេញអំពីឆន្ទៈរបស់មតកជន មិនមែនកើតឡើងដោយការព្រមព្រៀងរវាងមតកជន និងអច្ច័យលាភីនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដើម្បីអះអាងកម្មសិទ្ធិចំពោះតតិយជនដែលបានទិញដីនោះពី C&D ឬ ផ្ទេរកម្មសិទ្ធិរបស់ X នេះបន្តឲ្យតតិយជនតាមរយៈការលក់ទិញជាអាទិ៍ បានលុះត្រាតែបានផ្ទេរកម្មសិទ្ធិពីឈ្មោះA មកឈ្មោះរបស់ X ទើប X អាចផ្ទេរកម្មសិទ្ធិបន្តពីឈ្មោះ X ឲ្យទៅតតិយជនបាន ហេតុនេះ ការចុះបញ្ជី គឺមានភាពចាំបាច់។

➩ចំពោះករណី លុបចោល មោឃភាព ឬរំលាយក៏ជាការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលមិនធ្វើឡើងដោយការព្រមព្រៀងដែរ ហេតុនេះ អានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ នឹងកើតឡើងដោយស្វ័យប្រវត្តិក្នុងករណី មានការបង្ហាញឆន្ទៈលុបចោល មោឃភាព ឬរំលាយ។ តើករណីនេះ តម្រូវឲ្យមានការចុះបញ្ជីដើម្បីទទួលបានល័ក្ខខ័ណ្ឌតតាំងដូចមានចែងនៅក្នុងមាត្រា១៣៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែឬទេ?

| |
|---|
| បញ្ហា៖ A&B បានចុះកិច្ចសន្យាលក់ទិញដី និងបានផ្ទេរកម្មសិទ្ធិរួចរាល់ បន្ទាប់មក A បានបង្ហាញឆន្ទៈលុបចោល កិច្ចសន្យាលក់ទិញ តើត្រូវធ្វើដូចម្តេចដើម្បីឲ្យខ្លួនទទួលបានកម្មសិទ្ធិពេញលេញ? ចុះប្រសិនបើ B លក់ដីនោះបន្តទៅ C តើរវាង A និង C អ្នកណាជាកម្មសិទ្ធិករ? |

សន្និដ្ឋាន៖ បន្ទាប់ពីបាន បង្កើតកិច្ចសន្យាដោយលិខិតយថាភូត និងបានព្រមព្រៀងគ្នាផ្ទេរកម្មសិទ្ធិ ភាគីនៃកិច្ចសន្យា ត្រូវទៅចុះបញ្ជី ដើម្បីឲ្យការព្រមព្រៀងនេះបង្កើតអានុភាព។

តើស្ថាប័នណាមានសមត្ថកិច្ចក្នុងការចុះបញ្ជី តើអ្នកណាជាអ្នកដាក់ពាក្យសុំចុះបញ្ជី តើការចុះបញ្ជីផ្ទេរកម្មសិទ្ធិធ្វើឡើងតាមវិធីបែបណា? នឹងមានពន្យល់នៅក្នុងចំណុចស្តីពីការចុះបញ្ជី។

## ៣- ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដោយផ្អែកលើកិច្ចសន្យាលក់-ទិញ

ប្រតិបត្តិការនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ធ្វើឡើងក្នុងតំណាក់កាលនៃការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា ដែលតាមរយៈនោះ អ្នកលក់មានកាតព្វកិច្ចក្នុងការចុះបញ្ជីផ្ទេរកម្មសិទ្ធិរបស់ខ្លួនទៅឲ្យអ្នកទិញ។ ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលវត្ថុដោយការព្រមព្រៀងនឹងមិនមានអានុភាពនោះទេ បើមិនបានចុះបញ្ជី យោងតាមបញ្ញត្តិនៃមាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ អ្នកទិញ ឬ បុគ្គលដែលមានសិទ្ធិចុះបញ្ជី គឺសំដៅទៅលើបុគ្គលដែលទទួលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជី (មាត្រា ៤ កថាខណ្ឌ៣ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី) និងអ្នកលក់ ឬបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី គឺសំដៅទៅលើបុគ្គលដែលទទួលនូវការប៉ះពាល់ផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជី (មាត្រា ៤ កថាខណ្ឌ៤ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី) ត្រូវដាក់ពាក្យសុំចុះបញ្ជីជាលាយលក្ខណ៍អក្សររួមគ្នា ដោយមានភ្ជាប់មកជាមួយនូវឯកសារភ្ជាប់ដែលចាំបាច់ទៅស្ថាប័នមានសមត្ថកិច្ច។

តើស្ថាប័នណាមួយមានសមត្ថកិច្ចពាក់ព័ន្ធនឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ?

### ៣.១ ស្ថាប័នមានសមត្ថកិច្ច

ស្ថាប័នដែលមានសមត្ថកិច្ចទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ តាមន័យនៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីគឺរដ្ឋបាលសុរិយោដី ថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ (ប្រការ ៥ កថាខណ្ឌ២ នៃប្រកាសអន្តរក្រសួង) ។

ពាក្យសុំចុះបញ្ជីត្រូវធ្វើជាលាយលក្ខណ៍អក្សរ (ប្រការ៦នៃប្រកាស)។ នៅពេលដែលពាក្យសុំត្រូវបានដាក់ទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលជាស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវចុះលេខរៀងទៅតាមលំដាប់នៃការទទួលពាក្យសុំ (ប្រការ ៧ កថាខណ្ឌ១ នៃប្រកាស) ។ សៀវភៅ ទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ គឺត្រូវបង្កើតដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំ ផ្សេងៗទៀត ហេតុដូច្នេះរដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវធ្វើការចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីដែលពាក់ព័ន្ធ (ប្រការ ៦ កថាខណ្ឌ៣ នៃប្រកាស)។

## ៣.២ ការដាក់ពាក្យសុំចុះបញ្ជីរួមគ្នា

### ក. គោលការណ៍នៃការដាក់ពាក្យសុំរួមគ្នា

គោលគំនិតនៃ"គោលការណ៍ដាក់ពាក្យសុំរួមគ្នា" គឺសំដៅទៅលើការទៅដាក់ពាក្យសុំចុះបញ្ជីរួមគ្នារវាងបុគ្គលដែលមានសិទ្ធិចុះបញ្ជី និងបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី(ប្រការ១០កថាខណ្ឌ១ នៃប្រកាស)។ ប្រសិនបើមានការដាក់ពាក្យសុំដាច់ដោយឡែកពីគ្នា មន្ត្រីចុះបញ្ជីត្រូវធ្វើការស្រាវជ្រាវផ្សេងទៀតក្រៅពីឯកសារដែលភាគីអ្នកដាក់ពាក្យសុំបានដាក់ចូលមក ហើយធ្វើការបញ្ជាក់អំពីខ្លឹមសារនៃការដាក់ពាក្យសុំថាត្រឹមត្រូវឬទេ ដែលការស្រាវជ្រាវបែបនេះអាចចំណាយពេលវេលាយូរ ហើយដំណើរការនៃការចុះបញ្ជីនឹងមិនអាចប្រព្រឹត្តទៅដោយឆាប់រហ័ស និងដោយរលូននោះឡើយ។ ហេតុដូច្នេះគោលគំនិតនៃ "គោលការណ៍ដាក់ពាក្យសុំរួមគ្នា" គឺដើម្បីធានាឲ្យបាននូវភាពត្រឹមត្រូវនៃការដាក់ពាក្យសុំរួមគ្នាផង និងដើម្បីអាចធានាបាននូវភាពឆាប់រហ័សដោយការពិនិត្យជាលក្ខណៈទម្រង់នូវឯកសារពាក្យសុំដោយមន្ត្រីចុះបញ្ជីផង

ដែរ។

ការដាក់ពាក្យសុំចុះបញ្ជីក៏អាចធ្វើឡើងដោយអ្នកតំណាងបានដែរ (យោងតាមប្រការ ១០ កថាខណ្ឌ៤ នៃប្រកាស) មានន័យថាអ្នកតំណាងអាចចុះហត្ថលេខា និងដាក់ពាក្យសុំចុះបញ្ជីនោះ ក្នុងនាមអ្នកទិញ

និង/ឬអ្នកលក់បាន។

*តើអ្នកតំណាងក្នុងន័យនេះអាចជាបុគ្គលបែបណាខ្លះ ?*

បើពិនិត្យទៅលើមាត្រា ២៧ នៃប្រកាស យើងឃើញមានអ្នកតំណាងបី (០៣) ប្រភេទ ដូចជាអ្នកតំណាងរបស់នីតិបុគ្គល ដែលអាចជាអភិបាលក្រុមហ៊ុន អ្នកតំណាងដែលច្បាប់បានកំណត់ មានដូចជាអ្នកអាណាព្យាបាលទូទៅ ឪពុកម្ដាយ ឬអាព្យាបាលរបស់អនីតិជន និងអ្នកតំណាងដោយអាណត្តិ ដែល

ក្នុងករណីនេះ អាចជាមេធាវី មិត្តភក្តិ ឬហិតូបត្ថម្ភកៈជាដើម។ ដូច្នេះ បុគ្គលដែលជាអ្នកតំណាងដូចមានរៀបរាប់ខាងលើនេះ អាចដាក់ពាក្យសុំចុះបញ្ជី និងចុះហត្ថលេខាលើលិខិតស្នាមនានាដែលចាំបាច់ក្នុងការសុំចុះបញ្ជី ក្នុងនាម និងក្នុងផលប្រយោជន៍របស់បុគ្គលដែលជាអ្នកទិញ និង/ឬអ្នកលក់នោះបាន។

## ខ. ករណីលើកលែងនៃការដាក់ពាក្យសុំរួមគ្នា

ប្រសិនបើគូភាគីមានការព្រមព្រៀង និងឯកភាពគ្នាក្នុងការទៅចុះបញ្ជីរួមគ្នា នោះបញ្ហានឹងមិនកើតឡើង ផ្ទុយទៅវិញក្នុងករណីដែលភាគីមិនសហការក្នុងការដាក់ពាក្យសុំរួមគ្នាវិញ នោះភាគីម្ខាងទៀតនឹងជួបផលលំបាកក្នុងការដាក់ពាក្យសុំចុះបញ្ជីជាក់ជាមិនខាន។ ដោយហេតុនេះហើយ ទើបមានករណីលើកលែងមួយចំនួន ដែលអនុញ្ញាតឲ្យភាគីម្ខាងអាចទៅធ្វើការសុំចុះបញ្ជីដោយម្នាក់ឯងបាន ដោយយោងតាមមាត្រា ១០ កថាខណ្ឌ២ នៃប្រកាស។

- **ករណីសន្តតិកម្ម (លើកលែងតែអច្ច័យទាន)**

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសន្តតិកម្ម គឺជាការផ្ទេរកម្មសិទ្ធិដោយមិនផ្អែកតាមការព្រមព្រៀងនោះទេ ហេតុដូច្នេះ កម្មសិទ្ធិលើអចលនវត្ថុនឹងត្រូវបានផ្ទេរដោយស្វ័យប្រវត្តិពីមតកជនទៅសន្តតិជនចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព (មាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលមានការពិភាក្សាបែងចែកមតិក សហសន្តតិជនត្រូវភ្ជាប់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរនៃការពិភាក្សាអំពីការបែងចែកមតិកនោះ ដែលចុះហត្ថលេខាដោយសហសន្តតិជនទាំងអស់។

**ឧទាហរណ៍ទី១ (សន្តតិកម្ម)៖**

មតកជន A បានទទួលមរណភាព ដោយបន្សល់ទុកនូវអចលនវត្ថុ និងប្រាក់សុទ្ធក្នុងធនាគារ ហើយមានសន្តតិជនតែ ២នាក់ គឺ B និង C ដែលត្រូវជាកូន។ សន្តតិជនបានធ្វើការពិភាក្សាបែងចែកមតិក ដោយ B ធ្វើសន្តតិកម្មលើដី និងផ្ទះ ហើយ C ធ្វើសន្តតិកម្មលើប្រាក់សុទ្ធ។ នៅក្នុងករណីបែបនេះ B អាចទៅដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន ព្រោះវាជាការផ្ទេរកម្មសិទ្ធិតាមការព្រមព្រៀង ដែលមិនចាំបាច់ត្រូវធ្វើតាមនីតិវិធីបណ្តឹងនោះទេ។

តើករណីដែលសហសន្តតិជនមិនមានការព្រមព្រៀង បញ្ហានឹងទៅជាយ៉ាងណាវិញ? ប្រសិនបើសន្តតិជន B និងC គ្មានការព្រមព្រៀងគ្នាទៅលើការបែងចែកចំណែកមតក ដូច្នេះសន្តតិជនត្រូវដាក់ពាក្យសុំបែងចែកមតកទៅតុលាការ ដែលកម្មវត្ថុនៃពាក្យសុំគឺការបែងចែកមតក[47] របស់មតកជនA។

[47] មូលដ្ឋាននៃដីកាសម្រេច៖

*** ខ្លឹមសារនៃដីកាសម្រេចដែលដើមចោទទាមទារឲ្យតុលាការចេញ គឺ " ធ្វើការបែងចែកដីដែលមានចុះក្នុងឧបសម្ព័ន្ធមតិក ដោយដើមចោទធ្វើលទ្ធកម្មលើដីខាងលើ ...." ។**

**ឧទាហរណ៍ទី២ (អច្ច័យទាន)៖**

មតកជនA បានទទួលមរណភាព ហើយបន្សល់ទុកមតកសាសន៍ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥ ដោយបានប្រគល់ដីមួយកន្លែងទៅឲ្យមិត្តសម្លាញ់របស់ខ្លួនគឺ C។ A មានតែសន្តតិជនតែម្នាក់គត់ គឺ ប្រពន្ធ B។

ក្នុងករណីនេះ ប្រពន្ធអាចធ្វើសន្តតិកម្មទៅលើមតកផ្សេងដែលមតកជនមាន ដូចជាលុយសុទ្ធក្នុងធនាគារ ជាដើម។

ដូច្នេះ នៅពេល C ធ្វើការចុះបញ្ជីដោយមូលហេតុអច្ច័យទាន C ត្រូវធ្វើការដាក់ពាក្យសុំចុះបញ្ជីរួមគ្នាជាមួយនឹង B ព្រោះ C មិនអាចធ្វើការដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបានឡើយ (ប្រការ ១០ កថាខណ្ឌ ២ នៃប្រកាស)។ ក្នុងករណីដែលមានវិវាទ C ត្រូវដាក់ពាក្យបណ្តឹងទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅតុលាការដែលមានសមត្ថកិច្ច។

*** ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ គឺ " បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលមានចុះក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ ដោយមូលហេតុអច្ច័យទាន ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៥ "។**

**ខ)- សាលក្រម ឬសាលដីកាស្ថាពរដែលជាលិខិតអនុវត្តដែលបង្គាប់ឲ្យមាននីតិវិធីចុះបញ្ជី**

ប្រសិនបើសាលក្រម ឬសាលដីកាស្ថាពរសម្រេចឲ្យដើមបណ្តឹងឈ្នះក្តី នោះគេចាត់ទុកថាចុងចម្លើយបានបង្ហាញឆន្ទៈដាក់ពាក្យសុំរួមគ្នា(មាត្រា៥២៩ កថាខណ្ឌ១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ដូច្នេះ ដើមបណ្តឹងអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯង ដោយមានឯកសារភ្ជាប់ជាសាលក្រម ឬសាលដីកាស្ថាពរ (ប្រការ ២៧ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី និងប្រការ ៥០ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី)។

---

-មាត្រា ៣ កថាខណ្ឌ១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង៖ ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗនៃតារាងឧបសម្ពន្ធ័ តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

-មាត្រា ៣ កថាខណ្ឌ ២ ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។ តារាងឧបសម្ព័ន្ធផ្នែក ៥ លេខ ១៧ ស្តីពីការបែងចែកមតកិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌ១ នៃមាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណី ៩ការបែងចែកដោយតុលាការ) ។

ដោយសារតែប្រធានបទនេះ ផ្តោតសំខាន់តែទៅលើការផ្ទេរកម្មសិទ្ធិដោយមូលហេតុលក់ទិញ ដូច្នេះ យើងនឹងសិក្សាទៅលើករណីសិក្សា ២ យ៉ាងដែលជាបញ្ហាទាក់ទងនឹងការចុះបញ្ជី។

១- ករណីដែលភាគីមិនព្រមផ្ទេរកម្មសិទ្ធិ និង

២- ករណីដែលសុំលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលត្រូវបានផ្ទេរកម្មសិទ្ធិរួច

**ឧទាហរណ៍ទី ១៖ កិច្ចសន្យាលក់-ទិញអចលនវត្ថុ តែអ្នកលក់មិនព្រមផ្ទេរកម្មសិទ្ធិទៅឲ្យអ្នកទិញ**

A បានធ្វើកិច្ចសន្យាទិញ-លក់ដីមួយកន្លែងទៅឲ្យ B ក្នុងតម្លៃ ២០ម៉ឺនដុល្លាអាមេរិក នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥ ដោយលិខិតយថាភូត ។ B បានបង់ប្រាក់ថ្លៃទិញគ្រប់ចំនួន តែ A ពុំព្រមធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឲ្យ B នោះទេ។ ដូច្នេះ B បានដាក់ពាក្យបណ្តឹងទៅតុលាការទាមទារឲ្យ A ផ្ទេរកម្មសិទ្ធិនៃដីមកឲ្យខ្លួនយោងតាមកិច្ចសន្យាលក់-ទិញ។

*** ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ គឺ " បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលបានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ ដោយមូលហេតុនៃ ការលក់-ទិញ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥ " ។**

**សូមប្រុងប្រយ័ត្នទៅលើការប្រើប្រាស់ពាក្យពេចន៍ក្នុងខ្លឹមសារនៃការទាមទារ៖**

**ចំណុចត្រូវសរសេរ ៖**

- ដើមចោទត្រូវប្រើពាក្យថា " សុំឲ្យតុលាការបង្គាប់ឲ្យចុងចម្លើយ ដែលជាបុគ្គលមានកាតព្វកិច្ចចុះបញ្ជីធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីដូចមានចុះក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៥ " (ដោយហេតុថា ពាក្យបណ្តឹងទាក់ទងនឹងការចុះបញ្ជីជា "បណ្តឹងទាមទារឲ្យបង្ហាញឆន្ទៈ" ដូច្នេះ ត្រូវបញ្ជាក់ឲ្យច្បាស់ថា តើអ្នកណា "ត្រូវបង្ហាញឆន្ទៈ" ទៅអោយ "អ្នកណា" )។

**ចំណុចដែលមិនត្រូវសរសេរ៖**

- "បញ្ជាក់ថា A គឺជាកម្មសិទ្ធិករនៃដីដែលបានកំណត់ជាក់លាក់ ដូចមានក្នុងឧបសម្ព័ន្ធកម្មវត្ថុ" (ការដែលសរសេរបែបនេះ នាំឲ្យសាលក្រម ឬដីកាសម្រេចដែលចេញមក គឺពុំបានបង្គាប់ឲ្យផ្តល់តាវកាលិកអ្វីតាមការទាមទារនោះឡើយ ដូច្នេះវាជាសាលក្រម ឬសាលដីកាបញ្ជាក់ ដែលមិនមែនជាលិខិតអនុវត្តអាចយកទៅអនុវត្តនោះឡើយ)។

-"មន្ត្រីចុះបញ្ជីត្រូវចុះបញ្ជីផ្ទេរកម្មសិទ្ធិពាក់ព័ន្ធនឹងដីដែលបានកំណត់ជាក់លាក់ មានក្នុងឧបសម្ព័ន្ធកម្មវត្ថុ" (ដោយហេតុថា ការចុះបញ្ជីផ្ទេរកម្មសិទ្ធិគឺជាកម្មវត្ថុចម្បងនៃការទាមទារ ត្រូវធ្វើឡើងដោយមន្ត្រីចុះបញ្ជីទៅតាមពាក្យសុំរបស់បុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី គឺចុងចម្លើយ ពោលគឺចុងចម្លើយ ត្រឹមតែអាចធ្វើ" "នីតិវិធីចុះបញ្ជី" មិនអាចធ្វើ "ការចុះបញ្ជី" នោះទេ)។

**ឧទាហរណ៍ទី២ ការសុំលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលបានផ្ទេរកម្មសិទ្ធិរួច)**

A បានធ្វើកិច្ចសន្យាទិញ-លក់ដីមួយកន្លែងទៅឲ្យ B ដោយលិខិតយថាភូត ក្នុងតម្លៃ ២០ម៉ឺនដុល្លាអាមេរិក នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥។ B បានបង់ប្រាក់ថ្លៃលក់រួចរាល់ ហើយ A ក៏បានបំពេញកាតព្វកិច្ចចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឲ្យ B ចប់សព្វគ្រប់ដែរ។ ក្រោយមក A បានរកឃើញថា B បានឆបោកខ្លួនពេលចុះកិច្ចសន្យា ដែលនាំឲ្យ A មានបំណងសុំលុបចោលកិច្ចសន្យា និងសុំឲ្យ B ធ្វើការលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានឈ្មោះ B មកឲ្យខ្លួនវិញ។ B មិនយល់ព្រមក្នុងការចុះបញ្ជីផ្ទេរ ហើយ A ក៏បានធ្វើពាក្យបណ្ដឹងទៅតុលាការ។

* **ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ គឺ " បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីទាក់ទងនឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះនៅក្នុងឧបសម្ព័ន្ធចុះបញ្ជី លើដីដែលមានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ ដោយមូលហេតុនៃការលុបចោលការលក់ទិញ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៥** (យោងតាមប្រការ ២៦ និង ៣១ នៃប្រកាស)។

តើចំណុចអ្វីខ្លះដែលត្រូវសរសេរនៅក្នុងពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់អ្វីខ្លះដែលទាមទារឲ្យមាននៅពេលដែលដាក់ពាក្យសុំចុះបញ្ជី?

## ៣.៣ ទម្រង់ពាក្យសុំចុះបញ្ជី

ពាក្យសុំចុះបញ្ជី ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដូចមានកំណត់ក្នុងប្រការ ៦ នៃប្រកាស។ យោងតាមប្រកាសនេះ ទម្រង់នៃពាក្យសុំ គឺមានសណ្ឋានជាទម្រង់ពាក្យសុំទូទៅ និងទម្រង់ពាក្យសុំទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជី។

ទម្រង់ពាក្យសុំចុះបញ្ជីទូទៅ ដូចមានកំណត់នៅក្នុងប្រការ ២៦ នៃប្រកាស ហើយទម្រង់នៃពាក្យសុំទាក់ទងនឹងការផ្ទេរកម្មសិទ្ធិមានកំណត់ក្នុងប្រការ ២៨ នៃប្រកាស ដោយត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

- ឈ្មោះប្រទេសជាផ្លូវការ

- បាវចនា

- រដ្ឋបាលសុរិយោដីដែលអចលនវត្ថុតាំងនៅ

- គោលបំណងនៃពាក្យសុំចុះបញ្ជី៖ "ការផ្ទេរកម្មសិទ្ធិទាំងមូល" ឬ "ការផ្ទេរកម្មសិទ្ធិមួយផ្នែក"

- មូលហេតុនៃពាក្យសុំចុះបញ្ជី និងកាលបរិច្ឆេទ៖ "ការលក់" និង "កាលបរិច្ឆេទនៃកិច្ចសន្យាលក់ទិញ"

- ឈ្មោះឬនាមករណ៍ និងអាសយដ្ឋានរបស់បុគ្គលមានសិទ្ធិចុះបញ្ជីនិងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី៖ "ឈ្មោះ ឬ នាមករណ៍, ថ្ងៃខែឆ្នាំកំណើត, ទីកន្លែងកំណើត, អាសយដ្ឋានទីកន្លែងស្នាក់នៅ, និងឈ្មោះ ឬ នាមករណ៍របស់ឪពុកម្តាយរបស់បុគ្គលដែលមានសិទ្ធិចុះបញ្ជី និងបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី"

- អត្តសញ្ញាណនៃអចលនវត្ថុ៖ "អាសយដ្ឋាននៃទីកន្លែង" និង"លេខប័ណ្ណ ឬ លេខក្បាលដី"

- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី

- ឯកសារភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជី (ប្រការ ២៧ នៃប្រកាស)

*សូមធ្វើការកត់ចំណាំថា មានចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំក្រៅពីនេះ ដើម្បីឆ្លើយតបនឹងភាពចាំបាច់នៃការដាក់ពាក្យសុំ។

**ក្នុងករណីដែលពាក្យសុំចុះបញ្ជីធ្វើឡើងដោយមានចំណុចខ្វះខាតដូចខាងក្រោម រដ្ឋបាលសុរិយោដី ថ្នាក់រាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវបង្គាប់ឲ្យកែតម្រូវដោយកំណត់អំឡុងពេលសមរម្យ (ប្រការ ៩ នៃប្រកាស) ៖ សូមមើលតារាងដែលមានភ្ជាប់

- នៅពេលខ្វះខាតឯកសារភ្ជាប់ដែលចាំបាច់
- នៅពេលខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- នៅពេលអត្តសញ្ញាណនៃបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជីនៅក្នុងពាក្យសុំចុះបញ្ជី មិនដូចគ្នានឹងសៀវភៅចុះបញ្ជី
- នៅពេលពុំបានបង់ពន្ធ ឬសោហ៊ុយសេវាផ្សេងៗទាក់ទងនឹងការចុះបញ្ជី

  ក្នុងករណីដែលបុគ្គលដាក់ពាក្យសុំចុះបញ្ជីមិនបានកែតម្រូវតាមការបង្គាប់ ដូចបានកំណត់នៅក្នុងចំណុចខាងលើនេះទេ នោះរដ្ឋបាលសុរិយោដីត្រូវលើកចោលពាក្យសុំចុះបញ្ជីនោះ។

***តើចំណុចអ្វីខ្លះ ដែលត្រូវចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជី ក្នុងករណីចុះបញ្ជីកម្មសិទ្ធិ? (ប្រការ ១៤ កថាខណ្ឌ ១ និង ២ នៃប្រកាស)

- ឈ្មោះ ឬនាមករណ៍របស់បុគ្គលមានសិទ្ធិចុះបញ្ជី
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុនៃការចុះបញ្ជី និងកាលបរិច្ឆេទ

- លេខដែលបង្ហាញពីលំដាប់នៃការចុះបញ្ជី
- ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតរបស់បុគ្គលមានសិទ្ធិចុះបញ្ជី
- ឈ្មោះ ឬ នាមករណ៍របស់ឪពុកម្តាយរបស់បុគ្គលមានសិទ្ធិចុះបញ្ជី

## ៣.៤ ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជី (ប្រការ ២៧ នៃប្រកាស)

នៅពេលសុំចុះបញ្ជី ភាគីត្រូវភ្ជាប់ជាមួយនូវឯកសារសំខាន់ៗដូចជា៖

- ឯកសារដែលបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដែលបានដាក់ពាក្យសុំចុះបញ្ជី (ឧ. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន)

- ឯកសារដែលបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី (ឧ. កិច្ចសន្យាទិញលក់ និងកាលបរិច្ឆេទ)

- សាលក្រម ឬសាលដីកាដែលចូលជាស្ថាពរ (ករណីដែលការដាក់ពាក្យសុំធ្វើឡើងដោយបុគ្គលម្ខាងតែម្នាក់ឯង ) ។

- ប័ណ្ណ

- ឯកសារដែលចាំបាច់ផ្សេងៗទៀត ទៅតាមមូលហេតុ និងអត្ថន័យនៃការដាក់ពាក្យសុំជាអាទិ៍៕

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៩

## ប្រធានបទ៖ កិច្ចសន្យាបញ្ញើ

## ថ្ងៃទី ៣០ កក្កដា ២០១៥

# កិច្ចសន្យាបញ្ញើ

## សញ្ញាណទូទៅ

ទំនាក់ទំនងបុគ្គលក្នុងជីវភាពរស់នៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារសេរី មានទំនាក់ទំនងជាច្រើនដែលបុគ្គលឯកជនបង្កើតឡើង ដើម្បីជួយសម្រួលដល់ការងារ របស់ពួកគេដូចជាទំនាក់ទំនងក្នុងសកម្មភាពចាត់ចែង គ្រប់គ្រង ប្រើប្រាស់ រក្សាទុក នូវកម្មសិទ្ធិជាវត្ថុ ជាអាទិ៍។ ដោយឡែកទំនាក់ទំនងរក្សាទុកកម្មសិទ្ធិឬវត្ថុ ក៏ត្រូវបានបង្កើតឡើងហៅថា"បញ្ញើ"។ បញ្ញើវត្ថុនេះកើតឡើងដំបូងគ្រាន់តែជាសកម្មភាពមួយដែលមនុស្សម្នាក់ជួយយកអាសារក្នុងការជួយរក្សាទុកវត្ថុដល់មនុស្សម្នាក់ទៀត ក្នុងពេលកំណត់មួយដោយមិនយកកម្រៃនោះទេ។ ប៉ុន្តែសកម្មភាពបញ្ញើវត្ថុនេះកាន់តែសកម្មឡើង បញ្ញើខ្លះភាគីបញ្ញើបានយកកម្រៃ បញ្ញើខ្លះផ្តល់ជាផល ជាការប្រាក់។ល។ ហើយក៏បានកំណត់អំពីការទទួលខុសត្រូវក្នុងការរក្សាទុកវត្ថុបញ្ញើផងដែរ។

ជាញឹកញាប់សកម្មភាពបញ្ញើនេះ តែងតែមានកើតនូវវិវាទជាច្រើន អំពីសំណងនៃការខូចខាត ក្នុងករណីវត្ថុជាកម្មវត្ថុនៃបញ្ញើបានបែកបាក់ ឬបាត់។ ដូច្នេះដើម្បីសម្រួលដល់សកម្មភាពនៃទំនាក់ទំនងបញ្ញើនេះ ឲ្យប្រព្រឹត្តទៅដោយរលូន កាត់បន្ថយនូវវិវាទ ច្បាប់កម្ពុជាបានចែងកំណត់អំពីប្រភេទនៃសកម្មភាពបញ្ញើនេះ ដូចមានក្នុងជំពូកទី១០ គន្ថីទី៥ នៃក្រមរដ្ឋប្បវេណី។

តើអ្វីទៅជាបញ្ញើ? ហើយបញ្ញើនេះត្រូវបានបែងចែកប៉ុន្មានប្រភេទ? និង មានការទទួលខុសត្រូវយ៉ាងណាខ្លះ រវាងអ្នកផ្ញើ និងអ្នកទទួលបញ្ញើ?

### ១.និយមន័យ

បញ្ញើគឺជាកិច្ចសន្យាដែលធ្វើឡើងរវាងភាគីម្ខាងហៅថាអ្នកទទួលបញ្ញើ និងភាគីម្ខាងទៀតហៅថាអ្នកផ្ញើ ដែលតាមរយៈកិច្ចសន្យានេះ អ្នកទទួលបញ្ញើយល់ព្រមទទួលយកវត្ថុ ដែលជាកម្មវត្ថុនៃបញ្ញើពីអ្នកផ្ញើ យកមករក្សាទុក ក្នុងអំឡុងពេលបានកំណត់មួយ ហើយត្រូវសងវត្ថុនេះទៅឲ្យអ្នកផ្ញើវិញ នៅពេលអំឡុងពេលកំណត់រក្សាទុកនេះត្រូវបានបញ្ចប់ (*សូមមើលមាត្រា ៦៦៩.១ ក.រ*) ។

### ២.ការបង្កើតកិច្ចសន្យាបញ្ញើ និងអានុភាព

#### ២.១.កម្មវត្ថុនៃកិច្ចសន្យាបញ្ញើ

ជាទូទៅកម្មវត្ថុនៃកិច្ចសន្យាបញ្ញើគឺជា វត្ថុ ហើយវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានេះភាគច្រើនជា **ចលនវត្ថុ**។ អចលនវត្ថុក៏អាចជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើដែរ ប៉ុន្តែក្នុងការអនុវត្តជាក់មិនសូវមានបញ្ញើដែលយកអចលនវត្ថុធ្វើជាកម្មវត្ថុនៃបញ្ញើនោះទេ។ ក្នុងសកម្មភាពរស់នៅជាក់ស្តែងរបស់បុគ្គលឯកជន

ភាគច្រើនគេយកវត្ថុមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើ មានដូច ប្រាក់កាស យានយន្ត សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន គ្រឿងសង្ហារឹម ទំនិញ គ្រឿងឧបភោគបរិភោគ និងសត្វ។ល

**២.២.ប្រភេទនៃកិច្ចសន្យាបញ្ញើ**

យើងអាចបែងចែកកិច្ចសន្យាបញ្ញើជាបួនប្រភេទធំៗ ដែលក្នុងនោះមានកិច្ចសន្យាបញ្ញើធម្មតា (ចាប់ពីមាត្រា៦៦៩ដល់មាត្រា៦៨៨ នៃក.រ)និង កិច្ចសន្យាបញ្ញើដោយរួមបញ្ចូល (មាត្រា៦៨៩ នៃក.រ) កិច្ចសន្យាបញ្ញើបរិភោគ(ចាប់ពីមាត្រា៦៩០ ដល់មាត្រា៦៩១ នៃក.រ) និងកិច្ចសន្យាវិសុណ្ឌាប័ន(ចាប់ពីមាត្រា៦៩២ ដល់មាត្រា៦៩៨ នៃក.រ)។

កិច្ចសន្យាបញ្ញើធម្មតា មានកិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ និងកិច្ចសន្យាបញ្ញើដោយយកកម្រៃ ដែលជាកម្មវត្ថុនៃការលើកយកមកពិភាក្សានៅក្នុងសិក្ខាសាលាពេលនេះចាប់ពីមាត្រា៦៦៩ រហូតដល់មាត្រា៦៨៨ នៃក្រមរដ្ឋប្បវេណី រីឯកិច្ចសន្យាបញ្ញើដោយរួមបញ្ចូលគ្នា កិច្ចសន្យាបញ្ញើបរិភោគ និងកិច្ចសន្យាវិសុណ្ឌាប័ន មិនត្រូវបានលើកមកពិភាក្សា ក្នុងពេលនេះទេ។

**២.៣.កិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ**

កិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ ជាប្រភេទនៃកិច្ចសន្យាបញ្ញើធម្មតា ដែលធ្វើឡើងរវាង អ្នកផ្ញើ និងអ្នកទទួលបញ្ញើ ដែលតាមរយៈកិច្ចសន្យានេះ អ្នកទទួលបញ្ញើយល់ព្រមដោយស្ម័គ្រចិត្តទទួលយកវត្ថុបញ្ញើមករក្សាទុក ដោយមិនយកកម្រៃ ក្នុងអំឡុងពេលមួយកំណត់ ឬមិនកំណត់ ហើយត្រូវសងវត្ថុបញ្ញើនោះទៅអ្នកផ្ញើវិញ នៅពេលមានការទាមទារឲ្យសងពីអ្នកផ្ញើ ឬពេលកំណត់សងបានមកដល់ (*ម.៦៦៩.២ វាក្យខណ្ឌ១ ក.រ*) ។

ឧទាហរណ៍១៖ ករណីដូចជា (ការជួយដោយស្ម័គ្រចិត្តរវាងមិត្តភក្តិ ឬ សាច់ញាតិ)៖ X នឹងទៅសិក្សានៅបរទេសរយៈពេល ១ ឆ្នាំ។ ក្នុងអំឡុងពេល១ ឆ្នាំនេះ X ត្រូវការកន្លែងមួយដើម្បីទុកវ៉ាលីទាំង ៣ របស់គាត់។ ដូច្នេះ X បានផ្ញើវាជាមួយ Y ដែលជាមិត្តភក្តិរបស់ X ដោយមិនគិតថ្លៃ។

ឧទាហរណ៍២៖ (ការពិនិត្យវ៉ាលី)៖ X បានទៅទស្សនានៅសារមន្ទីរ Y។ នៅកន្លែងទទួលភ្ញៀវ X បានពិនិត្យ (ផ្ញើ) វ៉ាលីរបស់គាត់។

ក្នុងករណីខាងលើ កិច្ចសន្យារវាង X និង Y ត្រូវបានហៅថាជាកិច្ចសន្យាបញ្ញើ។ X ត្រូវបានហៅថាជាអ្នកផ្ញើ និង Y ត្រូវបានហៅថា អ្នកទទួលបញ្ញើ។ ជាគោលការណ៍ Y មិនអាចទាមទារប្រាក់កម្រៃពី X បានទេ (មាត្រា ៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក.រ) ព្រោះកិច្ចសន្យាបញ្ញើជាច្រើនគឺផ្អែកលើការជួយដោយស្ម័គ្រចិត្តដូចក្នុងឧទាហរណ៍១ ខាងលើ ឬ ជាសេវាកម្មបន្ទាប់បន្សំនៃសេវាកម្មចម្បងផ្សេងៗ ដូចជាឧទាហរណ៍២ ខាងលើ។

ជាគោលការណ៍កិច្ចសន្យាបញ្ញើត្រូវបង្កើតនិងមានអានុភាពនៅពេលដែល វត្ថុដែលជាកម្មវត្ថុនៃបញ្ញើត្រូវបានទទួលយកដោយអ្នកទទួលបញ្ញើ ដែលត្រូវរក្សាទុកវត្ថុបញ្ញើតាមការព្រមព្រៀងនោះ (*សូមមើលមាត្រា ៦៧០.១ ក.រ*)។

ប្រសិនបើបញ្ញើធ្វើឡើងដោយមិនយកកម្រៃនេះ បង្កើតដោយការព្រមព្រៀងប៉ុណ្ណោះ ប៉ុន្តែការប្រគល់និងទទួលវត្ថុជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើមិនទាន់ត្រូវបានធ្វើឡើងនោះទេ នោះអានុភាពនៃកិច្ចសន្យាបញ្ញើក៏ត្រូវបានបង្កើតឡើងដែរ(*សូមមើលមាត្រា ៦៧១ វាក្យខណ្ឌ១ ក.រ*)។ ប៉ុន្តែភាគីនីមួយៗនៃកិច្ចសន្យាបញ្ញើនេះ អាចដកការព្រមព្រៀងចេញនៅពេលណាក៏បាន ដោយមិនទទួលខុសត្រូវសំណងនៃការខូចខាតនោះទេ។ ព្រោះថាបញ្ញើមិនយកកម្រៃ បើមានតែការព្រមព្រៀងផ្ញើនិងទទួលបញ្ញើនាពេលអនាគត ហើយភាគីនៃកិច្ចសន្យានេះមិនទាន់បានប្រគល់និងទទួលវត្ថុជាកម្មវត្ថុបញ្ញើមករក្សាទុកផងករណីភាគីណាមួយដកការព្រមព្រៀងវិញ មុនពេលកំណត់ដែលត្រូវប្រគល់វត្ថុបញ្ញើនោះ ត្រូវឲ្យភាគីនោះទទួលខុសត្រូវសងការខូចខាត ដោយសារតែមិនអនុវត្តតាមការសន្យាហាក់ដូចជាមិនសូវសមរម្យនោះទេ។

### ២.៤.កិច្ចសន្យាបញ្ញើដោយយកកម្រៃ

កិច្ចសន្យាបញ្ញើដោយយកកម្រៃ ជាប្រភេទនៃកិច្ចសន្យាបញ្ញើធម្មតា ដែលធ្វើឡើងរវាង អ្នកផ្ញើ និងអ្នកទទួលបញ្ញើ ដែលតាមរយៈកិច្ចសន្យានេះ អ្នកទទួលបញ្ញើយល់ព្រមទទួលយកវត្ថុបញ្ញើមករក្សាទុកក្នុងល័ក្ខខ័ណ្ឌដែលទទួលបានកម្រៃអំពីសេវារក្សាទុកវត្ថុបញ្ញើដោយការសន្យាពិសេសនេះ ឬក្នុងនាមអាជីវកម្មរបស់ខ្លួនផ្ទាល់ ក្នុងអំឡុងពេលមួយកំណត់ ហើយត្រូវសងវត្ថុបញ្ញើនោះទៅអ្នកផ្ញើវិញ នៅពេលមានការទាមទារឲ្យសងពីអ្នកផ្ញើ ឬពេលកំណត់សងបានមកដល់ (*ម.៦៦៩.២ វាក្យខណ្ឌ២ ក.រ*) ។

ប្រសិនបើអ្នកផ្ញើ និងអ្នកទទួលបញ្ញើ បានធ្វើកិច្ចសន្យាពិសេសមួយអំពីការបង់ប្រាក់កម្រៃ នោះអ្នកទទួលបញ្ញើអាចទាមទារកម្រៃពីផ្ញើបាន ដោយផ្អែកលើកិច្ចសន្យាពិសេសនោះ (មាត្រា ៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក.រ)។ លើសពីនេះទៀត ប្រសិនបើអ្នកទទួលបញ្ញើបានបើកអាជីវកម្មបញ្ញើមួយនោះអ្នកទទួលបញ្ញើអាចទាមទារកម្រៃក្នុងចំនួនសមរម្យមួយពីអ្នកផ្ញើបាន ទោះបីជាពុំមានកិច្ចសន្យាពិសេសក៏ដោយ (មាត្រា ៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២ ក.រ)។

ឧទាហរណ៍៣៖ (គ្រឿងបរិក្ខារពិសេស)៖ X មានស្រាទំពាំងបាយជូរ និងម្ហូបកកជាច្រើន សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ប៉ុន្តែ X មិនមានគ្រឿងបរិក្ខារសម្រាប់រក្សាទុករបស់ទាំងអស់នេះឲ្យនៅល្អបាន។ ដូច្នេះ X បានផ្ញើវាទុកជាមួយនឹង Y ដែលមានមុខជំនួញបើកឃ្លាំងឥវ៉ាន់ មានគ្រឿងបរិក្ខារពិសេសសម្រាប់រក្សាទុកស្រាទំពាំងបាយជូរ និងម្ហូបកកឲ្យមានសភាពល្អ ក្នុងតម្លៃ ២០ ដុល្លារ ក្នុងមួយខែ។

ឧទាហរណ៍៤៖ករណី (ឃ្លាំង)៖ X មានកម្មសិទ្ធិលើម៉ាស៊ីនធំមួយ និងទំនិញជាច្រើនសម្រាប់មុខជំនួញរបស់គាត់។ ក៏ប៉ុន្តែ គាត់ចង់ផ្អាកមុខជំនួញរបស់គាត់រយៈពេល ២ ឆ្នាំ ព្រោះគាត់នឹងទៅសិក្សានៅបរទេសរយៈពេល២ ឆ្នាំ។ X មិនមានកន្លែងសម្រាប់ទុកឥវ៉ាន់ទាំងនោះក្នុងរយៈពេល ២ ឆ្នាំនេះ។ ដូច្នេះ X បានផ្ញើឥវ៉ាន់ទាំងនោះជាមួយនឹង Y ដែលមានមុខជំនួញបើកឃ្លាំងឥវ៉ាន់ ក្នុងតម្លៃ ២០ ដុល្លារ ក្នុងមួយខែ។

ជាទូទៅអានុភាពនៃកិច្ចសន្យាបញ្ញើកើតមាន នៅពេលមានការប្រគល់វត្ថុបញ្ញើ។ ប៉ុន្តែក្នុងករណីពិសេស ដូចជាគូភាគីនៃកិច្ចសន្យាបញ្ញើដោយយកកម្រៃ បានព្រមព្រៀងគ្នាទុកជាមុនថានឹងធ្វើការប្រគល់ និងទទួលវត្ថុយកមករក្សាទុកនាពេលអនាគតនោះអានុភាពនៃកិច្ចសន្យានេះត្រូវបានកើតឡើងដោយសារការព្រមព្រៀងនេះ (*សូមមើលមាត្រា ៦៧១ វាក្យខណ្ឌ១ ក.រ*)។

ប្រសិនអ្នកទទួលបញ្ញើ បានធ្វើឲ្យខូចខាតដល់ភាគីម្ខាងទៀត ដោយសារការបដិសេធមិនទទួលវត្ថុបញ្ញើផ្ទុយនឹងការសន្យានោះ ភាគីអ្នកទទួលបញ្ញើត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតនោះទៅភាគីម្ខាងទៀត ប្រសិនបើការបដិសេធនោះគ្មានមូលហេតុត្រឹមត្រូវ (*សូមមើលមាត្រា ៦៧១ វាក្យខណ្ឌ ២ ក.រ*) ។ ផ្ទុយទៅវិញប្រសិនបើអ្នកផ្ញើបដិសេធមិនប្រគល់វត្ថុជាកម្មវត្ថុបញ្ញើ នោះអ្នកផ្ញើមិនទទួលខុសត្រូវសងការខូចខាតដល់ភាគីម្ខាងទៀតទេ។

ឧទាហរណ៍៖ X ជាម្ចាស់ឃ្លាំងស្តុកមីកញ្ចប់ បានព្រមព្រៀងទទួលបញ្ញើមីចំនួន៥,០០០កេះ ក្នុង១ខែ ៥០ ដុល្លា ជាមួយ Y ដែលជាម្ចាស់មី នៅក្នុងពេលរដូវវស្សាមកដល់ក្នុងខែកញ្ញា ឆ្នាំ២០១៤។ ដល់ខែកញ្ញា ឆ្នាំ២០១៤ Y បាននាំយកនាំមីមកដល់ ស្រាប់តែ Xប្រាប់ថាឈប់ទទួលបញ្ញើមីនេះ ដោយសារថា X បានទទួលបញ្ញើវត្ថុពី Z បានតម្លៃថ្លៃជាង។ Y មិនអាចរកឃ្លាំងដាក់មីបាន ត្រូវបង្ខំលក់ក្នុងតម្លៃថោ។ ដូច្នេះ Y អាចទាមទារឲ្យ X សងការខូចខាតបានតាម មាត្រា ៦៧១ វាក្យខណ្ឌ២ ក.រ) ដោយសារ តែ X មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យាបញ្ញើនេះ។

ផ្ទុយទៅវិញកិច្ចសន្យាបញ្ញើធ្វើឡើងដោយមិនយកកម្រៃ ប្រសិនបើភាគីបានព្រមព្រៀងថានឹងបង្កើតទំនាក់ទំនងបញ្ញើនាពេលអនាគត ភាគីនីមួយៗ អាចដកការព្រមព្រៀងនោះចេញនៅពេលណាក៏បាន រហូតដល់ពេលដែលបានប្រគល់វត្ថុនៃបញ្ញើនោះហើយការដកការសន្យានេះ ភាគីនីមួយៗមិនទទួលខុសត្រូវសំណងនៃការខូចខាត ដោយសារការបដិសេធនេះទេ(សូមមើលមាត្រា ៦៧១ វាក្យខណ្ឌ១ក.រ)។

ឧទាហរណ៍៖X ជាម្ចាស់ផ្ទះមានទីធ្លាដីធំ បានព្រមព្រៀងទទួលបញ្ញើឡានមួយគ្រឿងពីអ្នកជិតខាង Y ដោយមិនកម្រៃ នៅពេលណាដែល Y ទិញឡានបាន។ Y ក៏ទិញឡានបាន Xឮដំណឹងនេះ ក៏បានប្រាប់ទៅ Yថាឈប់ទទួលបញ្ញើឡាននេះហើយ។

## ២.៥.កិច្ចសន្យាបញ្ញើវត្ថុជាកម្មសិទ្ធិរបស់អ្នកដទៃ

កិច្ចសន្យាបញ្ញើអាចត្រូវបានបង្កើតឡើង ទោះបីវត្ថុជាកម្មវត្ថុនៃបញ្ញើ មិនមែនជាកម្មសិទ្ធិរបស់អ្នកផ្ញើក៏ដោយ ដោយហេតុថាផ្អែកលើគោលការណ៍នៃការសន្មតថាអ្នកណាកាប់កាន់វត្ថុ អ្នកនោះជាម្ចាស់កម្មសិទ្ធិ(ម.២៣៩ក.រ) ដូច្នេះហើយច្បាប់អនុញ្ញាតឲ្យបង្កើតកិច្ចសន្យាបានបើទោះបីវត្ថុជាកម្មវត្ថុនៃបញ្ញើជាកម្មសិទ្ធិរបស់អ្នកដទៃក៏ដោយ ហើយវាមានអានុភាពនៅពេលដែលវត្ថុបញ្ញើនោះត្រូវបានប្រគល់និងបានទទួលយកមករក្សាទុក(សូមមើលមាត្រា៦៧២ វាក្យខណ្ឌ១ ក.រ)។

ក្នុងករណីមានបណ្ដឹងទាមទារឲ្យប្រគល់វត្ថុពីម្ចាស់កម្មសិទ្ធិករចំពោះអ្នកទទួលបញ្ញើក៏ដោយ ក៏អ្នកទទួលបញ្ញើអាចសងវត្ថុនេះទៅអ្នកផ្ញើបានដែរ (ត្រា៦៧២ វាក្យខណ្ឌ២ ក.រ) ព្រោះកាតព្វកិច្ចនៃការសងវត្ថុវិញក្នុងកិច្ចសន្យាបញ្ញើនេះគឺត្រូវសងវត្ថុបញ្ញើទៅអ្នកផ្ញើវិញ (មាត្រា៦៨២.១ ក.រ)។ អ្នកទទួលបញ្ញើមិនមានកាតព្វកិច្ចសងវត្ថុបញ្ញើនេះ ទៅម្ចាស់កម្មសិទ្ធិដែលកំពុងធ្វើបណ្ដឹងទាមទារកម្មសិទ្ធិនោះទេ។ ប៉ុន្តែក្នុងករណីដែលការទាមទារកម្មសិទ្ធិតាមផ្លូវតុលាការត្រូវបានទទួលស្គាល់ ហើយសេចក្ដីសម្រេចនោះបានចូលជាស្ថាពរ អ្នកទទួលបញ្ញើគួរតែសងវត្ថុបញ្ញើនោះទៅកម្មសិទ្ធិករ វិញ (មាត្រា៦៧២ វាក្យខណ្ឌ៣ ក.រ)។ ប្រសិនបើអ្នកទទួលបញ្ញើសងវត្ថុបញ្ញើទៅអ្នកផ្ញើ នោះអ្នក ទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះកម្មសិទ្ធិករនៃវត្ថុបញ្ញើនោះ។

## ២.៦.កិច្ចសន្យាបញ្ញើបន្ត

ជាកិច្ចសន្យាដែលបានធ្វើឡើងរវាងនិងទទួលបញ្ញើ និងអ្នកទទួលបញ្ញើបន្ត ដោយមានការយល់ព្រមពីអ្នកផ្ញើ (ម.៦៧៧.១ ក.រ) តាមរយៈកិច្ចសន្យានេះ វត្ថុដែលជាកម្មវត្ថុបញ្ញើបន្តនេះ ត្រូវបានបន្តកាន់កាប់រក្សាទុកដោយអ្នកទទួលបញ្ញើបន្ត ហើយបញ្ញត្តិនៃជំពូកទី១០ស្ដីពីបញ្ញើនេះត្រូវបានយកមកអនុវត្តផងដែរ រវាងអ្នកទទួលបញ្ញើ និងអ្នកទទួលបញ្ញើបន្ត (ម.៦៧៨.១ក.រ) រីឯអ្នកទទួលបញ្ញើបន្តនេះមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងអ្នកទទួលបញ្ញើចំពោះអ្នកផ្ញើ (ម.៦៧៨៨.២ក.រ)។

ជាគោលការណ៍អ្នកទទួលបញ្ញើមានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើដោយខ្លួនឯងផ្ទាល់ ហើយមិនត្រូវប្រគល់វត្ថុបញ្ញើទៅឲ្យតតិយជនកាន់កាប់រក្សាទុកបន្តបានឡើយ(ម.៦៧៧.១ក.រ)។ ដោយហេតុថា អ្នកផ្ញើបានគិតពិចារណា និងទុកចិត្តទៅលើអ្នកទទួលបញ្ញើថាមានជំនាញនិងបទពិសោធន៍ក្នុងការរក្សាទុកវត្ថុបញ្ញើ ទើបអ្នកផ្ញើសម្រេចចិត្តឲ្យអ្នកទទួលបញ្ញើរក្សាទុកវត្ថុរបស់ខ្លួន បើអនុញ្ញាតឲ្យ អ្នកទទួលបញ្ញើផ្ញើវត្ថុបញ្ញើបន្តទៅឲ្យតតិយជននោះជាការមិនសមហេតុផលទេ។

ប៉ុន្តែដោយសារការវិវត្តរបស់សង្គមសេដ្ឋកិច្ចបច្ចុប្បន្ន សកម្មភាពពាណិជ្ជកម្មមួយចំនួន តម្រូវឲ្យមានសេវាបញ្ញើបន្ត ទើបគោលដៅនៃការជួញដូរអាចសម្រេចបាន ដូចនេះជាញឹកញាប់ភាគីនៃកិច្ចសន្យាបញ្ញើក្នុងស្ថានភាពបែបនេះ មានឆន្ទៈអនុញ្ញាតឲ្យមានបញ្ញើបន្ត។

ទោះបីអនុញ្ញាតពីអ្នកផ្ញើឲ្យអ្នកទទួលបញ្ញើអាចផ្ញើវត្ថុជាកម្មវត្ថុបញ្ញើនេះ បន្តទៅអ្នកទទួលបញ្ញើបន្តក៏ដោយ ក៏អ្នកទទួលបញ្ញើនៅតែទទួលខុសត្រូវចំពោះអ្នកផ្ញើដដែល ដូចជាការទទួលខុសត្រូវក្នុងការជ្រើសតាំងតតិយជនរក្សាទុកបញ្ញើ និងការទទួលខុសត្រូវក្នុងការត្រួតពិនិត្យអ្នកទទួលបញ្ញើ បន្តដែលត្រូវរក្សាទុកវត្ថុជាកម្មវត្ថុនៃបញ្ញើបន្តនេះ (ម.៦៧៧.២ ក.រ)។

## ២.៧.លក្ខណៈនៃការប្រគល់វត្ថុបញ្ញើ

### ក.ការប្រគល់ដោយសង្ខេប

ជាទូទៅកិច្ចសន្យាបញ្ញើតម្រូវឲ្យមានការប្រគល់វត្ថុដើម្បីបង្កើតអានុភាព ហើយការប្រគល់វត្ថុនេះភាគច្រើនគឺត្រូវធ្វើឡើងដោយផ្ទាល់។ ប៉ុន្តែករណីពិសេសដូចជាអ្នកទទួលវត្ថុបញ្ញើបានរក្សាទុកវត្ថុបញ្ញើរួចហើយ នោះមិនចាំបាច់តម្រូវឲ្យអ្នកផ្ញើប្រគល់វត្ថុបញ្ញើដោយផ្ទាល់ទៀតទេ (សូមមើលមាត្រា ៦៧០.២ វាក្យខណ្ឌ១ ក.រ) គ្រាន់តែអ្នកទទួលបញ្ញើយល់ព្រមទទួលបញ្ញើ កិច្ចសន្យាបញ្ញើនោះបង្កើតអានុភាព។ មានន័យថាវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើកំពុងតែកាន់កាប់ដោយអ្នក ទទួលបញ្ញើរួចហើយ វាមិនមានប្រយោជន៍អ្វីដែលត្រូវប្រគល់វត្ថុនោះមកឲ្យអ្នកផ្ញើ រួចហើយអ្នកផ្ញើត្រូវប្រគល់វត្ថុនោះមកឲ្យអ្នកទទួលបញ្ញើវិញនោះទេ ដោយអ្នកទទួលបញ្ញើគ្រាន់តែបន្តកាន់កាប់វត្ថុ នោះ ក្នុងនាមជាអ្នកទទួលបញ្ញើតាមកិច្ចសន្យាបញ្ញើនោះជាការគ្រប់គ្រាន់ហើយ រីឯការប្រគល់វត្ថុ គ្រាន់តែធ្វើឡើងដោយសង្ខេបប៉ុណ្ណោះ ដូចមានចែងក្នុង (ម.២២៩.៣ ក.រ)។

ឧទាហរណ៍៖ ករណី A ម្ចាស់ឃ្លាំងលក់រថយន្ត និងទទួលផ្ញើរថយន្តប្រចាំថ្ងៃ ហើយខ្លួនបានលក់រថយន្តប្រភេទទេសចរណ៍មួយគ្រឿងឲ្យ B ប៉ុន្តែ B មិនទាន់បានយកវាមកប្រើប្រាស់ទេដោយ សារខ្លួនបានជាប់រវល់ទៅបរទេស ហើយក៏បានផ្ញើរថយន្តនោះ នៅឃ្លាំងរបស់ A តទៅទៀត ក្នុង អំឡុងពេល១ខែ ដោយត្រូវបង់កម្រៃឲ្យ A ក្នុងមួយថ្ងៃ១០,០០០រៀល។ ដោយសាររថយន្តនោះនៅក្នុងឃ្លាំរបស់ A ស្រាប់ ដូចនេះ B មិនចាំបាច់ធ្វើការប្រគល់រថយន្តនេះទៀតទេនាំតែខាតពេល ដោយAគ្រាន់តែបន្តការកាន់កាប់រថយន្តនោះក្នុងនាមជាអ្នកទទួលបញ្ញើតាមកិច្ចសន្យាបញ្ញើនោះ វាគ្រប់គ្រាន់ហើយ។

### ខ.ការប្រគល់ដោយបញ្ជា

ចំពោះវត្ថុដែលកាន់កាប់ដោយអ្នកទទួលបញ្ញើ អ្នកផ្ញើបានផ្ទេរកម្មសិទ្ធិវត្ថុនោះទៅជនទីបី ហើយករណីខ្លះជនទី៣(ម្ចាស់កម្មសិទ្ធិថ្មី)នេះបានព្រមព្រៀងផ្ញើវត្ថុនេះជាមួយអ្នកទទួលបញ្ញើជាបន្តទៅទៀត។

ដូច្នេះម្ចាស់កម្មសិទ្ធិថ្មី មិនចាំបាច់យកវត្ថុនោះចេញពីឃ្លាំង ហើយយកវត្ថុនោះមក ផ្ញើនៅឃ្លាំងអ្នកទទួលបញ្ញើវិញឡើយ ដោយអ្នកទទួលបញ្ញើគ្រាន់**តែទទួលការបញ្ជាពីម្ចាស់កម្មសិទ្ធិចាស់ថា៖ម្ចាស់ឃ្លាំងត្រូវកាន់កាប់វត្ថុនេះសម្រាប់ម្ចាស់កម្មសិទ្ធិថ្មី** តាមកិច្ចសន្យាបញ្ញើរវាងអ្នកទទួល បញ្ញើនិងម្ចាស់កម្មសិទ្ធិថ្មីលើវត្ថុនោះអានុភាពនៃបញ្ញើត្រូវបានបង្កើតឡើង(មាត្រា៦៧០.២ វាក្យខណ្ឌ ២ ក.រ) ដោយសារការផ្ទេរការកាន់កាប់ដោយបញ្ជានេះ ដូចមានចែងក្នុង(មាត្រា ២២៩.៤ ក.រ)។

ឧទាហរណ៍៖ A ជាម្ចាស់ឃ្លាំងជាអ្នកទទួលបញ្ញើស្រាបៀអង្គរ១០,០០០កេះ ហើយកំពុង រក្សាទុកឲ្យអ្នកផ្ញើ B (A ជាតតិយជនកាន់កាប់ស្រាបៀអង្គរដោយចំពោះសម្រាប់B) ប៉ុន្តែ B (B អ្នក កាន់កាប់ស្រាបៀអង្គរដោយប្រយោល) ក៏បានលក់ស្រាបៀអង្គរនោះទៅឲ្យ C ហើយ C ក៏បានព្រមព្រៀងផ្ញើស្រាបៀអង្គរនោះជាមួយនឹង A ជាបន្តទៅទៀត។ ប៉ុន្តែដោយសារស្រាបៀអង្គរ១០,០០០កេះនេះ កំពុងតែកាន់កាប់និងរក្សាទុកដោយ A ជាតតិយជន។ ក្នុងករណីនេះកិច្ចសន្យាបញ្ញើរវាង A និង C ត្រូវបានបង្កើតឡើង នៅពេលដែល B បានបញ្ជាទៅ A (Aតតិយជននៃការកាន់កាប់វត្ថុ) ថាត្រូវកាន់កាប់ស្រាបៀអង្គរ១០,០០០កេះនេះសម្រាប់ C ហើយអានុភាពនៃកិច្ចសន្យានេះកើតឡើងក្រោយពេល A បានទទួលបញ្ជាពី B។

## ៣.ការបញ្ចប់កិច្ចសន្យាបញ្ញើ

កិច្ចសន្យាបញ្ញើត្រូវបានបង្កើតនៅពេលដែលវត្ថុបញ្ញើ ត្រូវបានប្រគល់ និងទទួលមករក្សាទុក ក្នុងអំឡុងពេលកំណត់មួយ ហើយកិច្ចសន្យាបញ្ញើនេះត្រូវបានបញ្ចប់នៅអំឡុងពេលកំណត់បានមកដល់ ហើយវត្ថុដែលជាកម្មវត្ថុនៃបញ្ញើត្រូវបានសងមកឲ្យអ្នកផ្ញើវិញ (*សូមមើលមាត្រា ៦៦៩.១ ក.រ*)។

### ៣.១.ពេលវេលានៃការសងវត្ថុ

☞ក្នុងកិច្ចសន្យាបញ្ញើ ប្រសិនបើភាគីបានកំណត់អំឡុងពេលត្រូវសង អ្នកទទួលបញ្ញើមិនអាចសងវត្ថុជាកម្មវត្ថុនៃបញ្ញើមកឲ្យអ្នកផ្ញើមុនពេលកំណត់បានមកដល់បានឡើយ ប្រសិនបើគ្មានមូលហេតុដែលអាចជៀសបាននោះទេ(*សូមមើលមាត្រា៦៨១.២ក.រ*)។ ឧទាហរណ៍ដូចជាឃ្លាំងរក្សាទុកវត្ថុបញ្ញើ ត្រូវទឹកជំនន់លិច ហើយអ្នកទទួលបញ្ញើពុំមានលទ្ធភាពអាចទប់ទល់ឬការពារបាន អ្នកទទួលបញ្ញើ អាចស្នើសុំសងវត្ថុបញ្ញើមុនពេលកំណត់សង ទៅអ្នកផ្ញើវិញបាន។

☞ប៉ុន្តែចំពោះអ្នកផ្ញើវិញអាចទាមទារឲ្យសងវត្ថុជាកម្មវត្ថុនៃបញ្ញើនៅពេលណា ក៏បានដែរ ទោះបីកិច្ចសន្យាបញ្ញើនោះមានកំណត់អំឡុងពេលនៃការសងវត្ថុ ហើយពេលកំណត់សងវត្ថុបញ្ញើនោះមិនទាន់មកដល់ក៏ដោយ(*សូមមើលមាត្រា ៦៨០ ក.រ*) លើកលែងប្រាក់កម្រៃចេញ។ ព្រោះថាការទាមទារឲ្យសងនេះមានលក្ខណៈសមស្របទៅនឹងគោលបំណងនៃកិច្ចសន្យាបញ្ញើ ដែលបង្កើត ឡើងដើម្បីការពារផលប្រយោជន៍របស់អ្នកផ្ញើ ច្រើនជាងផលប្រយោជន៍របស់អ្នកទទួលបញ្ញើ។ ករណីនេះ អ្នកទទួលបញ្ញើមិន

មានប្រយោជន៍អ្វីដែលត្រូវរក្សាទុកវត្ថុបញ្ញើជាបន្តទៅទៀតនោះដែរ លើកលែងតែសោហ៊ុយឬសំណងនៃការខូចខាតនៃការរក្សាទុកវត្ថុនោះ ដែលអ្នកផ្ញើមិនទាន់បានបង់ឲ្យខ្លួនដូច មានចែងក្នុងមាត្រា៦៨៦នៃក.រ (*ករណីយកិច្ចសងសោហ៊ុយវិញរបស់អ្នកផ្ញើ*) និងមាត្រា ៦៨៨ (*សិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើ*) នៃក.រ។

☞ប្រសិនបើកិច្ចសន្យាបញ្ញើ ដែលភាគីមិនបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើនោះទេ អ្នកទទួលបញ្ញើក៏អាចសងវត្ថុនោះ នៅពេលណាក៏បានដែរ (*សូមមើលមាត្រា ៦៨១.១ ក.រ*)។

☞ក្នុងករណីកិច្ចសន្យាបញ្ញើត្រូវបង្កើតដោយវត្ថុបញ្ញើជាកម្មសិទ្ធិរបស់អ្នកដទៃ និងមានអានុភាពដោយសារអ្នកទទួលបញ្ញើបានទទួលវត្ថុបញ្ញើនោះមករក្សាទុក។ ប៉ុន្តែបើមានតតិយជនជាម្ចាស់កម្មសិទ្ធិលើវត្ថុបញ្ញើមកទាមទារឬកំពុងត្រូវបានទាមទារតាមផ្លូវតុលាការ នោះអ្នកទទួលបញ្ញើមិនមានករណីយកិច្ចសងវត្ថុបញ្ញើនោះ ទៅអ្នកតាំងខ្លួនជាកម្មសិទ្ធិករលើវត្ថុនោះឡើយ គឺអ្នកទទួលបញ្ញើមានករណីយសងវត្ថុបញ្ញើនេះទៅអ្នកផ្ញើវិញបើមានការទាមទារឲ្យសងពីអ្នកផ្ញើ(*សូមមើលមាត្រា៦៨០ក.រ*)។ បើអ្នកទទួលបញ្ញើសងទៅអ្នកតាំងខ្លួនជាកម្មសិទ្ធិករលើវត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះអ្នកផ្ញើ(*សូមមើលមាត្រា៦៧២វាក្យខណ្ឌទី២*)។ ករណីមានសេចក្តីសម្រេចពីតុលាការទទួលស្គាល់សិទ្ធិកម្មសិទ្ធិលើវត្ថុបញ្ញើនោះ ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ នោះអ្នកទទួលបញ្ញើមានករណីយកិច្ចសងវត្ថុបញ្ញើនោះទៅម្ចាស់កម្មសិទ្ធិនោះវិញ (*មាត្រា៦៧២វាក្យខណ្ឌទី៣*)។

### ៣.២.ការបង់ប្រាក់កម្រៃ សោហ៊ុយ និងសំណងនៃការខូចខាតក្នុងការសងវត្ថុ

ដើម្បីទទួលបានការសងវត្ថុបញ្ញើមកវិញ អ្នកផ្ញើមានករណីយកិច្ចបង់ប្រាក់កម្រៃ ទៅអ្នកទទួលបញ្ញើតាមការសន្យាពិសេស (សូមមើលមាត្រា ៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក.រ) ឬបង់ប្រាក់កម្រៃតាមការទាមទាររបស់អ្នកទទួលបញ្ញើ (សូមមើលមាត្រា ៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២ ក.រ)។ ដូចជាករណីអ្នកទទួលបញ្ញើបានបើកអាជីវកម្មបញ្ញើមួយ ហើយមិនមានការសន្យាពិសេសណាមួយរវាងអ្នកផ្ញើនិងអ្នកទទួលបញ្ញើទេ នោះអ្នកទទួលបញ្ញើអាចទាមទារកម្រៃក្នុងចំនួនសមរម្យមួយពីអ្នកផ្ញើបាន ហើយអ្នកផ្ញើត្រូវបង់ប្រាក់កម្រៃនេះ។

ក្នុងករណីបញ្ញើមិនយកកម្រៃ អ្នកផ្ញើមានករណីយ និងអ្នកទទួលបញ្ញើមានសិទ្ធិទាមទារឲ្យបង់សោហ៊ុយចាំបាច់នៃការសងវត្ថុបញ្ញើបាន (សូមមើលមាត្រា ៦៨៥ វាក្យខណ្ឌ១ ក.រ) និងបង់សោហ៊ុយចាំបាច់ក្នុងការរក្សាទុកវត្ថុបញ្ញើបាន (សូមមើលមាត្រា៦៨៦ កថាខណ្ឌទី១ ក.រ) ។

ជាគោលការណ៍សោហ៊ុយសម្រាប់ការសងវិញជាបន្ទុករបស់កូនបំណុល (សូមមលើមាត្រា ៤៨៦ ក.រ) ប៉ុន្តែបញ្ញើមិនយកកម្រៃនេះ ប្រសិនបើឲ្យអ្នកទទួលបញ្ញើដែលជាកូនបំណុលទទួលខុសត្រូវចំពោះ

កាតព្វកិច្ចលើសោហ៊ុយសងវិញនៃវត្ថុបញ្ញើ ហាក់ដូចជាមិនសមរម្យនោះទេ។ ដូច្នេះ មាត្រា៦៨៥ វាក្យខណ្ឌ១ ក.រ កំណត់អំពីបញ្ញត្តិពិសេសចំពោះមាត្រា៤៨៦ ក.រ ។

រីឯសោហ៊ុយចាំបាច់ក្នុងការរក្សាទុកវត្ថុបញ្ញើក្នុងកិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ ក៏ត្រូវជាបន្ទុករបស់អ្នកផ្ញើដែរ ពីព្រោះថា"មិនយកកម្រៃ" មានន័យថា មិនបង់លាភសក្ការៈទៅអ្នកទទួលបញ្ញើ ដូច្នេះកម្រៃមិនពាក់ព័ន្ធជាមួយសោហ៊ុយចាំបាច់ក្នុងការចំណាយជាក់ស្តែងសម្រាប់ការរក្សាទុកវត្ថុនោះទេ (សូមមើលមាត្រា ៦៨៦ កថាខណ្ឌ១ ក.រ)។

លើសពីនេះទៅទៀត អ្នកផ្ញើក៏ត្រូវមានករណីយកិច្ចសងការខូចខាត ដល់អ្នកទទួលបញ្ញើ ក្នុងករណីយដែលការខូចខាតនោះបណ្តាលមកពីវត្ថុបញ្ញើ មុនពេលទទួលបានការសងវត្ថុបញ្ញើវិញ (សូមមើលមាត្រា ៦៨៦ កថាខណ្ឌ២ ក.រ)។

ផ្ទុយទៅវិញប្រសិនបើអ្នកផ្ញើ មិនបានបង់សោហ៊ុយនៃការសងវត្ថុបញ្ញើវិញ មិនបានបង់សោហ៊ុយចាំបាច់នៃការរក្សាទុកវត្ថុបញ្ញើ និងមិនបានសងសំណងនៃការខូចខាតដែលបង្កឡើងដោយវត្ថុបញ្ញើ នោះអ្នកទទួលបញ្ញើ មានសិទ្ធិឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយនិងសំណងនៃការខូចខាត ទាំងនោះ (សូមមើលមាត្រា ៦៨៨ ក.រ)។

### ៣.៣.ទីកន្លែងនៃការសងវត្ថុ

ចំពោះទីន្លែងនៃការសងវត្ថុបញ្ញើ ប្រសិនបើមិនបានកំណត់ទីកន្លែងសងទេ ការសងនេះត្រូវធ្វើឡើងនៅទីកន្លែងដែលបានទទួលរក្សាទុកវត្ថុបញ្ញើនោះ (*សូមមើលមាត្រា ៦៨៧ វាក្យខណ្ឌ១ ក.រ*)។ ប៉ុន្តែបើអ្នកទទួលបញ្ញើបានផ្លាស់ប្តូរកន្លែងរក្សាទុកវត្ថុបញ្ញើនោះដោយមានមូលហេតុត្រឹមត្រូវ ការសងអាចធ្វើនៅកន្លែងរក្សាទុកជាក់ស្តែងនាពេលសងបាន(*សូមមើលមាត្រា ៦៨៧ វាក្យខណ្ឌ២ ក.រ*)។

## ៤.សិទ្ធិនិងករណីយកិច្ចរបស់អ្នកទទួលបញ្ញើនិងអ្នកផ្ញើ

### ៤.១.សិទ្ធិរបស់អ្នកទទួលបញ្ញើ

១.<u>កែប្រែឬបដិសេធមិនទទួលវត្ថុបញ្ញើពីអ្នកផ្ញើ បានគ្រប់ពេលវេលា រហូតដល់ពេលប្រគល់វត្ថុបញ្ញើក្នុងករណីដែលកិច្ចសន្យាបញ្ញើត្រូវបង្កើតឡើងដោយមិនយកកម្រៃហើយមានការព្រមព្រៀងថាទទួលផ្ញើវត្ថុដែលជាកម្មវត្ថុបញ្ញើនាពេលអនាគត (*សូមមើលមាត្រា ៦៧១ វាក្យខណ្ឌ១ ក.រ*)។</u>

២.សិទ្ធិកែប្រែឬបដិសេធមិនទទួលវត្ថុបញ្ញើពីអ្នកផ្ញើ ដោយសារមានមូលហេតុត្រឹមត្រូវក្នុងករណីដែលកិច្ចសន្យាបញ្ញើត្រូវបង្កើតឡើងដោយយកកម្រៃ និងមានការព្រមព្រៀងថាទទួលផ្ញើវត្ថុដែលជាកម្មវត្ថុបញ្ញើនាពេលអនាគត ហើយពេលវេលាទទួលយកវត្ថុបញ្ញើមករក្សាទុក បានមកដល់ ប៉ុន្តែមានមូលហេតុ

ដែលបញ្ជាក់ថា មិនអាចទទួលយកវត្ថុបញ្ញើយកមករក្សាទុកបាន (*សូមមើលមាត្រា ៦៧១ វាក្យខណ្ឌ២ ក.រ*)។

៣.សិទ្ធិទាមទារសំណងនៃការខូចខាតពីអ្នកផ្ញើ ដោយសារការខូចខាតបណ្តាលមកពីវត្ថុបញ្ញើ ហើយពុំមែនជាកំហុសរបស់ខ្លួន (*សូមមើលមាត្រា ៦៨៦ កថាខណ្ឌ២ ក.រ*)។

៤.សិទ្ធិទាមទារឲ្យអ្នកផ្ញើបង់សោហ៊ុយដែលចាំបាច់ក្នុងការរក្សាទុកវត្ថុបញ្ញើ (*សូមមើលមាត្រា ៦៨៦ កថាខណ្ឌ១ ក.រ*) និងសោហ៊ុយសងវត្ថុបញ្ញើ (*សូមមើលមាត្រា.៦៨៥ ក.រ*)។

៥.សិទ្ធិឃាត់ទុកវត្ថុបញ្ញើ ក្នុងករណីអ្នកផ្ញើមិនបានបង់សោហ៊ុយ និងសំណងនៃការខូចខាត ដូចមានចែងក្នុងកថាខណ្ឌទី១និងទី២ មេត្រា៦៨៦ នៃក្រមរដ្ឋប្បវេណី រហូតដល់ពេលអ្នកផ្ញើបានបង់សោហ៊ុយ និងសំណងនៃការខូចខាតមកឲ្យខ្លួន (*សូមមើលមាត្រា ៦៨៨ ក.រ*)។

៦.សិទ្ធិសងវត្ថុបញ្ញើ ទៅអ្នកផ្ញើវិញ បានគ្រប់ពេលវេលា ក្នុងករណីកិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយមិនបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើ (*សូមមើលមាត្រា ៦៨១.១ ក.រ*)។

៧.សិទ្ធិអាចសងវត្ថុបញ្ញើទៅអ្នកផ្ញើវិញ ទោះបីក្នុងករណីកិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ ប្រសិនបើភាគីខ្លួនមានមូលហេតុត្រឹមត្រូវ (*សូមមើលមាត្រា ៦៨១.២ ក.រ*)។

### ៤.២.ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

១.ករណីយកិច្ចថែរក្សាទុកវត្ថុបញ្ញើដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រង ដោយសុច្ចរិត (*សូមមើលមាត្រា ៦៧៣.១ ក.រ*) និងករណីយមិនប្រើប្រាស់វត្ថុបញ្ញើ បើគ្មានការយល់ព្រមពីអ្នកផ្ញើនោះទេ(*សូមមើលមាត្រា ៦៧៣.២ ក.រ*)។

២.ករណីយកិច្ចរក្សាទុវត្ថុបញ្ញើដោយខ្លួនឯងផ្ទាល់ ហើយមិនត្រូវប្រគល់វត្ថុបញ្ញើទៅឲ្យតតិយជនកាន់កាប់រក្សាទុកបន្តបានឡើយ(ម.៦៧៧.១ក.រ) បើគ្មានការយល់ព្រមអ្នកផ្ញើ។

៣.ករណីយកិច្ចសងវត្ថុបញ្ញើដដែល(សូមមើលមាត្រា៦៨២ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី "អំពីអត្ថន័យនៃការសង") ដែលបានទទួលពីអ្នកផ្ញើ ទៅអ្នកផ្ញើវិញ នៅពេលណាដែលមានការស្នើសុំឲ្យសងវត្ថុបញ្ញើពីអ្នកផ្ញើ ទោះបីកិច្ចសន្យាបញ្ញើនោះធ្វើឡើងមានកំណត់អំឡុងពេល នៃការសងវត្ថុបញ្ញើក៏ដោយ (*សូមមើលមាត្រា ៦៨០ ក.រ*)។

៤.ករណីយកិច្ចជូនដំណឹងទៅអ្នកផ្ញើឲ្យបានដឹងអំពីករណីមានតតិយជនមកអះអាងអំពីសិទ្ធិ ចំពោះវត្ថុបញ្ញើនោះ បានដាក់ពាក្យបណ្តឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបានរឹបអូស (*សូមមើលមាត្រា ៦៧៩ ក.រ "ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ"*)។

៥.ការទទួលខុសត្រូវក្នុងការជ្រើសតាំង និងត្រួតពិនិត្យអ្នកទទួលបញ្ញើបន្ត ដែលត្រូវបានឲ្យរក្សាទុកវត្ថុបញ្ញើបន្ត ក្នុងករណីដែលអ្នកទទួលបញ្ញើអាចឲ្យតតិយជនរក្សាទុកវត្ថុបញ្ញើនោះ (សូមមើលមាត្រា ៦៧៧ កថាខណ្ឌ២ នៃក.រ)។

៦.ទទួលខុសត្រូវសងការខូចខាតនូវវត្ថុបញ្ញើក្នុងករណីខ្លួនមានកំហុសធ្វើឲ្យបែកបាក់វត្ថុបញ្ញើ (សូមមើលមាត្រា ៦៧៤ កថាខណ្ឌ១ នៃក.រ)។

៧.ទទួលខុសត្រូវក្នុងការសងការខូចខាតវត្ថុបញ្ញើ ប្រសិនបើកម្មសិទ្ធិករនៃសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិល្បៈការផ្សេងៗ បានទទួលបញ្ញើពីភ្ញៀវ ហើយបានធ្វើឲ្យបាត់បង់ ឬបែកបាក់វត្ថុបញ្ញើ ក្នុងករណីដែលគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ (សូមមើលមាត្រា ៦៧៤ កថាខណ្ឌ ៣ នៃក.រ)។

៨.អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវសងការខូចខាត ករណីដូចជានៅសារៈមន្ទីរ ឬកន្លែងផ្សេងទៀត ដែលតម្រូវឲ្យអ្នកផ្ញើត្រូវតែផ្ញើវត្ថុមុនពេលចូលទៅសារៈមន្ទីរឬកន្លែងដែលតម្រូវនោះ ប្រសិន បើអ្នកទទួលបញ្ញើនៅកន្លែងនោះ បានធ្វើបាត់បង់ឬបែកបាក់វត្ថុនោះ ហើយគ្មានការបញ្ជាក់ថាជាករណី ប្រធានសក្តិនោះទេ(សូមមើលមាត្រា ៦៧៤ កថាខណ្ឌ២ នៃក.រ)។

**៤.៣.សិទ្ធិរបស់អ្នកផ្ញើ**

១.សិទ្ធិទាមទារឲ្យសងវត្ថុបញ្ញើ ពីអ្នកទទួលបញ្ញើ បានគ្រប់ពេលវេលា ទោះបីភាគីបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ ហើយទោះបីអំឡុងពេលកំណត់នោះមិនទាន់បានមកដល់ក៏ដោយ (*សូមមើលមាត្រា ៦៨០ ក.រ*)។

២.សិទ្ធិផ្តល់ការយល់ព្រមឬមិនយល់ព្រម ករណីយអ្នកទទួលបញ្ញើត្រូវប្រគល់វត្ថុបញ្ញើទៅឲ្យតតិយជនកាន់កាប់រក្សាទុកបន្ត(ម.៦៧៧.១ក.រ)។

៣.សិទ្ធិទាមទារឲ្យអ្នកទទួលបញ្ញើសងវត្ថុបញ្ញើដដែល(សូមមើលមាត្រា៦៨២ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី "អំពីអត្ថន័យនៃការសង") ដែលខ្លួនបានប្រគល់ទៅឲ្យអ្នកទទួលបញ្ញើ។

៤.សិទ្ធិទាមទារឲ្យអ្នកទទួលបញ្ញើ សងការខូចខាតវត្ថុបញ្ញើ ដែលអ្នកទទួលបញ្ញើបានទទួល ប្រាក់ធានារ៉ាប់រង ឬវត្ថុផ្សេងទៀតជំនួសវត្ថុបញ្ញើដែលត្រូវបាត់បង់ ឬបែកបាក់នោះ ហើយមិនមែនជាកំហុសរបស់អ្នកទទួលបញ្ញើទេ(មាត្រា៦៨២ កថាខណ្ឌ២ ក.រ "អំពីអត្ថន័យនៃការសង")។

៥.សិទ្ធិទទួលបានការជូនដំណឹងពីអ្នកទទួលបញ្ញើ អំពីករណីមានតតិយជនមកអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើនោះ បានដាក់ពាក្យបណ្តឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបានរឹបអូស (*សូមមើលមាត្រា ៦៧៩ ក.រ "ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ"*)។

៦.សិទ្ធិទាមទារសំណងនៃការខូចខាត ពីអ្នកទទួលបញ្ញើ ករណីវត្ថុបាត់បង់ឬបែកបាក់ដោយសារអ្នកទទួលបញ្ញើ ប្រគល់ឲ្យតតិយជនកាន់កាប់ ហើយអ្នកទទួលបញ្ញើមានកំហុសដោយសារធ្វេសប្រហែសក្នុងការជ្រើសតាំងអ្នកទទួលបញ្ញើបន្ត និងមិនបានត្រួតពិនិត្យអ្នកទទួលបញ្ញើបន្ត ដែលត្រូវឲ្យរក្សាទុកវត្ថុបញ្ញើបន្តនោះ (សូមមើលមាត្រា ៦៧៧ កថាខណ្ឌ២ នៃក.រ)។

៧.សិទ្ធិទាមទារឲ្យអ្នកទទួលបញ្ញើសងការខូចខាតនូវវត្ថុបញ្ញើក្នុងករណីអ្នកទទួលបញ្ញើមានកំហុសធ្វើឲ្យបាត់ឬបែកបាក់វត្ថុបញ្ញើ (សូមមើលមាត្រា ៦៧៤ កថាខណ្ឌ១ នៃក.រ)។

៨.សិទ្ធិទាមទារសំណងនៃការខូចខាតវត្ថុបញ្ញើ ប្រសិនបើកម្មសិទ្ធិករនៃសណ្ឋាគារ ផ្ទះសំណាក់ភោជនីយដ្ឋាន កន្លែងងូតទឹក សិល្បៈការផ្សេងៗ បានទទួលបញ្ញើ ហើយបានធ្វើឲ្យបាត់បង់ ឬបែកបាក់វត្ថុបញ្ញើ ក្នុងករណីដែលគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ (មាត្រា ៦៧៤.៣ នៃក.រ)។

៩.សិទ្ធិទាមទារសំណងនៃការខូចខាត ករណីដូចជានៅសារៈមន្ទីរ ឬកន្លែងផ្សេងទៀត ដែលតម្រូវឲ្យអ្នកផ្ញើត្រូវតែផ្ញើវត្ថុមុនពេលចូលទៅសារៈមន្ទីរឬកន្លែងដែលតម្រូវនោះ ប្រសិនបើអ្នកទទួលបញ្ញើនៅកន្លែងនោះ បានធ្វើបាត់បង់ឬបែកបាក់វត្ថុនោះ ហើយគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិនោះទេ(សូមមើលមាត្រា ៦៧៤ កថាខណ្ឌ២ នៃក.រ)។

១០.សិទ្ធិទាមទារឲ្យអ្នកទទួលបញ្ញើសងការខូចខាត ករណីភាគីអ្នកទទួលបញ្ញើដកការសន្យា ក្នុងការទទួលបញ្ញើនាពេលអនាគត ដោយសារការបដិសេធនោះគ្មានមូលហេតុត្រឹមត្រូវ (សូមមើលមាត្រា ៦៧១ វាក្យខណ្ឌ២ នៃក.រ)។

### ៤.៤.ករណីយកិច្ចរបស់អ្នកផ្ញើ

១.ករណីយកិច្ចបង់កម្រៃជូនទៅអ្នកទទួលបញ្ញើ ករណីភាគីខ្លួនបានបញ្ចប់កិច្ចសន្យាបញ្ញើមានកម្រៃ មុនពេលកំណត់ (សូមមើលមាត្រា ៦៨០ ក.រ)។

២.ករណីយកិច្ចបង់សោហ៊ុយចាំបាច់នៃការសងវត្ថុបញ្ញើ ចំពោះអ្នកទទួលបញ្ញើ (សូមមើលមាត្រា ៦៨៥ វាក្យខណ្ឌ១ ក.រ) ក្នុងកិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ។

៣.ករណីយកិច្ចបង់បង់សោហ៊ុយដែលចាំបាច់ក្នុងការរក្សាទុកវត្ថុបញ្ញើ (សូមមើលមាត្រា ៦៨៦ កថាខណ្ឌ១ ក.រ)។

៤.ករណីយកិច្ចបង់សំណងនៃការខូចខាត ក្នុងករណីវត្ថុបញ្ញើបានបង្កការខូចខាតដល់អ្នកទទួលបញ្ញើ ដូចមានចែងក្នុងកថាខណ្ឌទី២ មេត្រា៦៨៦ នៃក្រមរដ្ឋប្បវេណី។

## ៥.ការសម្រាលការទទួលខុសត្រូវសំណងនៃការខូចខាត

ទស្សនៈអំពីសំណងនៃការខូចខាត តាមមាត្រា ៦៧៤ កថាខណ្ឌទី១ ក.រ គឺផ្អែកលើការបំពានលើករណីយកិច្ចរក្សាទុក ដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតរបស់អ្នកទទួលបញ្ញើ(សូមមើលមាត្រា៦៧៣.១ក.រ)។ មាត្រា៦៧៤ ក.រ នេះគឺគ្រាន់តែនិយាយម្តងទៀតពីវិធានដូចគ្នានឹងមាត្រា ៣៩៨ ក.រ "ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវសងសំណងនៃការខូចខាត" ដែលត្រូវសងហើយត្រូវគណនា ដោយផ្អែកលើទំហំនៃសំណងការខូចខាតតាមមាត្រា ៤០១ ក.រ។

យើងបានពិភាក្សាអំពីសិទ្ធិនិងករណីយកិច្ចរបស់ភាគីអ្នកទទួលបញ្ញើ និងភាគីអ្នកផ្ញើ ដោយឃើញថាភាគីនីមួយៗ មានសិទ្ធិនិងករណីយ និងការទទួលខុសត្រូវសងការខូចខាតរាងៗខ្លួន។

ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយអ្នកទទួលបញ្ញើមានកាតព្វកិច្ចទទួលខុសត្រូវសងការខូចខាត ទៅដល់អ្នកផ្ញើច្រើនជាង។ ករណីនេះ អ្នកទទួលបញ្ញើអាចប្តឹងតវ៉ា ដើម្បីឲ្យតុលាការជួយសម្រេចពិចារណាបន្ធូបន្ថយឬសម្រាលអំពីការទទួលខុសត្រូវចំពោះអ្នកផ្ញើ។

ដូចជានៅក្នុងករណីបញ្ញើដោយមិនយកកម្រៃ តុលាការអាចពិចារណាបន្ថយការទទួលខុសត្រូវសំណងនៃការខូចខាត ចំពោះអ្នកទទួលបញ្ញើ មិនយកកម្រៃ ដោយពិចារណាអំពីស្ថានភាពនៃទ្រព្យសម្បត្តិភាគីទាំងសងខាង និងកាលៈទេសៈផ្សេងៗទៀតបាន(ម.៦៧៥ក.រ) ។ ដោយហេតុថាមានករណីខ្លះអ្នកទទួលបញ្ញើត្រូវបានតម្រូវឲ្យទទួលខុសត្រូវមានលក្ខណៈធ្ងន់ធ្ងរពេក ព្រោះថាគាត់មានករណីយកិច្ចក្នុងការប្រុងប្រយ័ត្ននិងជាអ្នកគ្រប់គ្រងដោយសុចរិត ប៉ុន្តែមិនបានទទួលកម្រៃតបស្នងណាមួយផង បើឲ្យគាត់ទទួលខុសត្រូវទាំងស្រុង ហាក់ដូចជាអយុត្តិធម៌សម្រាប់អ្នកទទួលបញ្ញើមិនយកកម្រៃ។ ដូច្នេះច្បាប់ផ្តល់អំណាចឲ្យតុលាការអាចសម្រេចបន្ថយការទទួលខុសត្រូវសំណងនៃការខូចខាត ដោយពិចារណាលើស្ថានភាពនៃទ្រព្យសម្បត្តិនិងកាលៈទេសៈផ្សេងៗទៀតបាន។

ករណីបញ្ញើមិនយកកម្រៃនៅសណ្ឋាគារ ឬនៅសារៈមន្ទីរ ដោយអ្នកផ្ញើបាន ផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និងវត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀត ប្រសិនបើអ្នកផ្ញើមិនបាន រាយការណ៍អំពីប្រភេទនិងតម្លៃនៃវត្ថុនោះទៅឲ្យអ្នកទទួលបញ្ញើឲ្យបានដឹងមុនទេ ហើយករណីមានការបាត់បង់ ឬខូចខាតដោយសារកំហុសរបស់អ្នកទទួលបញ្ញើ មិនបានគ្រប់គ្រងដោយការប្រុងប្រយ័ត្ន ព្រោះគិតថាវត្ថុទាំងនោះមិនសូវសំខាន់។ ក្នុងស្ថានភាពបែបបនេះ បើមានការទាមទារ ឲ្យសម្រាលនូវការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើតុលាការអាចពិចារណាសម្រេចបន្ធូបន្ថយ ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើបាន(ម.៦៧៦ ក.រ) ព្រោះថាជាកំហុសមួយផ្នែករបស់អ្នកផ្ញើ ដែលមិនបានរាយការណ៍អំពីប្រភេទនិងតម្លៃវត្ថុនោះ ឲ្យអ្នក

ទទួលបញ្ញើបានដឹងមុន ដើម្បីឲ្យអ្នកទទួលបញ្ញើកាន់តែចិត្តទុកដាក់បង្កើនការប្រុងប្រយ័ត្នក្នុងការទទួលរក្សាទុកវត្ថុបញ្ញើនេះ។

## ៦.ករណីសិក្សា

ករណី១៖ X បានផ្ញើចូផ្កាបុរាណមួយជាមួយនឹង Y ដែលជាអ្នកមានមុខរបរបើកឃ្លាំងដាក់ទំនិញ។ ដោយសារ Y រវល់ពេក Y បានផ្ញើចូផ្កានោះជាមួយនឹង Z ដោយពុំមានការយល់ព្រមពី X។ Z ដែលជាអ្នកមានមុខរបរបើកឃ្លាំងដាក់ទំនិញដ៏ល្បីឈ្មោះមួយមានជំនាញគ្រប់គ្រាន់ក្នុងការរក្សាទុកចូផ្កាបុរាណ។ ក៏ប៉ុន្តែ Z បានធ្វើឲ្យបែកចូផ្កានោះដោយចៃដន្យ។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬទេ?

ករណី ២៖ X បានផ្ញើចូផ្កាបុរាណមួយជាមួយនឹង Y ដែលជាអ្នកមានមុខរបរបើកឃ្លាំងដាក់ទំនិញដោយសារ Y រវល់ពេក Y បានផ្ញើចូផ្កានោះជាមួយនឹង Z ហើយ X បានយល់ព្រមចំពោះបញ្ញើបន្តនៃចូផ្កាជាមួយនឹង Z។ ក៏ប៉ុន្តែ Z បានធ្វើឲ្យបែកចូផ្កាដោយចៃដន្យ ដោយសារមុខជំនួញរបស់ Z គឺបើកឃ្លាំងដាក់ឡានហើយ Z មិនដែលរក្សាទុកចូផ្កាបុរាណទេ។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬ ទេ?

ករណី ៣៖ X បានផ្ញើចូផ្ការបុរាណមួយជាមួយនឹង Y ដែលជាអ្នកមានមុខរបរបើកឃ្លាំងដាក់ទំនិញ។ ដោយសារ Y រវល់ពេក Y បានបញ្ជាឲ្យ Z ដែលជាបុគ្គលិករបស់ Y ឲ្យថែរក្សាចូផ្កានោះ។ X បានផ្តល់ការយល់ព្រមឲ្យ Z ថែរក្សាចូផ្កានោះ។ Z បាននិងកំពុងធ្វើការឲ្យ Y អស់រយៈពេលជាយូរមកហើយ និងជាបុគ្គលិកដែលពោរពេញដោយបទពិសោធន៍ មានជំនាញគ្រប់គ្រាន់ក្នុងការថែរក្សាចូផ្កា។ ក៏ប៉ុន្តែ Z បានធ្វើឲ្យបែកចូផ្កាដោយចៃដន្យ។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬ ទេ? សូមមើលមាត្រា ៣៩៨ កថាខណ្ឌទី២ ក.រ។

ករណី ៤៖ X មានតុបុរាណដ៏ស្អាតមួយ។ ដោយសារ X ត្រូវការរៀបចំជួសជុលផ្ទះរបស់គាត់រយៈពេល ៣ ខែ X បានសុំឲ្យ Y ដែលជាមិត្តភក្តិរបស់ X និងបើកហាងលក់សៀវភៅមួយ ជួយរក្សាទុកតុនោះក្នុងហាងរបស់ Y រយៈពេល ៣ ខែ ដោយមិនគិតថ្លៃ ហើយ Y បានយល់ព្រម។ នៅពេល X បានយកតុនោះទៅដាក់នៅហាងសៀវភៅរបស់ Y ប៉ុន្តែ Y បានផ្លាស់ប្តូរចិត្ត និងបានបដិសេធទទួលរក្សាទុកតុនោះ ដោយពុំមានមូលហេតុត្រឹមត្រូវ។ X ចង់ទាមទារសំណងនៃការខូចខាតពី Y ដោយសារ X មិនអាចជៀសវាងពីការលក់តុនោះក្នុងតម្លៃទាបបាន។

ករណី ៥៖ X មានតុបុរាណដ៏ស្អាតមួយ។ ដោយសារ X ត្រូវការរៀបចំជួសជុលផ្ទះរបស់គាត់រយៈពេល ៣ ខែ គាត់បានសុំឲ្យ Y រក្សាទុកតុនោះក្នុងឃ្លាំងរបស់ Y រយៈពេល ៣ ខែ ក្នុងតម្លៃ ២០ ដុល្លារ ក្នុងមួយខែ ហើយ Y បានយល់ព្រម។ នៅពេល X បានយកតុនោះទៅដាក់នៅឃ្លាំងរបស់ Y ប៉ុន្តែ Y បានផ្លាស់ប្តូរចិត្ត និងបានបដិសេធទទួលតុនោះ ដោយសារ Y បានទទួលសំណើល្អជាងនេះពី Z ដើម្បីផ្ញើតុមួយ ក្នុងតម្លៃ ៣០ ដុល្លារ ក្នុងមួយខែ។ ឥឡូវ X ចង់ទាមទារសំណងនៃការខូចខាតពី Y ដោយសារ X មិនអាចជៀសវាងពីការលក់តុនោះក្នុងតម្លៃទាបបាន។

ករណី ៦៖ X មានតុបុរាណដ៏ស្អាតមួយ។ ដោយសារ X ត្រូវការរៀបចំជួសជុលផ្ទះរបស់គាត់រយៈពេល ៣ ខែ គាត់បានសុំឲ្យ Y រក្សាទុកតុនោះក្នុងឃ្លាំងរបស់ Y រយៈពេល ៣ ខែ ក្នុងតម្លៃ ២០ ដុល្លារ ក្នុងមួយខែ ហើយ Y បានយល់ព្រម។ ក៏ប៉ុន្តែ X បានផ្លាស់ប្តូរចិត្ត និងបានបដិសេធក្នុងការប្រគល់តុឲ្យ Y ដោយសារ X បានទទួលសំណើដ៏ល្អមួយពី Z ដើម្បីទិញតុក្នុងតម្លៃមួយដ៏ល្អ។ ឥឡូវ Y ចង់ទាមទារលុយ ៦០ ដុល្លារពី X។

ករណី ៧៖ X បានផ្ញើឡានមួយនៅឃ្លាំងរបស់ Y។ Z បានមក និងប្រាប់ Y ថាឡាននោះជាឡានរបស់ Z ដែល X បានលួច ហើយ Z បានទាមទារឲ្យប្រគល់ឡាន។ តើ Y ត្រូវប្រគល់ឡានឲ្យអ្នកណា?

ករណី ៨៖ X បានផ្ញើឡានមួយនៅឃ្លាំងរបស់ Y។ Z ដែលជាម្ចាស់បំណុលរបស់ X បានដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុរបស់ X ហើយអាជ្ញាសាលាបានមកឃ្លាំងរបស់ Y ដើម្បីរឹបអូសឡាននោះ។ តើ Y គួរធ្វើដូចម្តេច? សូមមើលមាត្រា៣៨៦ និង ៣៨៧ ក្រមនីតិវិធី។

ករណី ៩៖ X បានផ្ញើឡានរបស់ X ក្នុងយានដ្ឋានរបស់ Y រយៈពេល ១ ខែដោយមិនគិតថ្លៃ។ Y បានបើកឡាននោះអស់ ១០០ km ដើម្បីកំសាន្តរីករាយនឹងការបើកបរ ដោយពុំបានជូនដំណឹងទៅ X។ Y បានយកឡានមកទុកក្នុងហ្គារាសវិញដោយសុវត្ថិភាព ប៉ុន្តែសាំងឡាននោះត្រូវបានប្រើអស់ ហើយកង់ឡានក៏សឹកបន្តិច។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬ ទេ?

ករណី ១០៖ X បានផ្ញើឡានរបស់ X នៅយានដ្ឋានរបស់ Y រយៈពេល ១ ខែ ដោយមិនគិតថ្លៃ។ Y បានបើកឡាននោះអស់ ១០០ km ដើម្បីកំសាន្តរីករាយនឹងការបើកបរ ដោយពុំបានជូនដំណឹងទៅ X។ Y បានកំពុងបើកបរដោយសុវត្ថិភាពនិងត្រឹមត្រូវ ប៉ុន្តែមានឡានមួយដែលបើកដោយ Z បានមកបុកឡានរបស់ X ហើយឡានរបស់ X ក៏បានខូចខាត។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬ ទេ?

ករណី ១១៖ X បានផ្ញើឡានរបស់ X ក្នុងយានដ្ឋានរបស់ Y រយៈពេល ១ ខែ ដោយមិនគិតថ្លៃ។ Y បានចាក់សោរហ្គារាស និងបានរក្សាទុកឡាន ដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ប៉ុន្តែឡានត្រូវបានគេលួច។ តើX អាចទាមទារសំណងនៃការខូចខាតពីY បានដែរឬ ទេ?

ករណី ១២៖ X បានចូលរួមក្នុងពិធីជប់លៀងមួយដែលប្រារព្ធធ្វើនៅសណ្ឋាគារ Y។ X បានផ្ញើវ៉ាលីរបស់គាត់នៅបន្ទប់ផ្ញើឥវ៉ាន់របស់សណ្ឋាគារ។ បុគ្គលិករបស់សណ្ឋាគារបានដាក់វ៉ាលីក្នុងទូ និងបានរក្សាទុកវាដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ប៉ុន្តែវ៉ាលីនោះត្រូវបានគេលួច។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬ ទេ?

ករណី ១៣៖ X បានផ្ញើគ្រឿងអលង្ការមួយប្រអប់ជាមួយនឹង Y ក្នុងតម្លៃ ១០ ដុល្លារ ក្នុងមួយខែ។ X មិនបានប្រាប់តម្លៃនៃគ្រឿងអលង្ការនោះទៅ Y ទេ។ Y បានគិតមួយភ្លែតថាតម្លៃនៃគ្រឿងអលង្ការនោះគឺប្រហែល ៣.០០០ ដុល្លារ ប៉ុន្តែតម្លៃជាក់ស្តែងគឺ ១០.០០០ ដុល្លារ។ Y បានដាក់គ្រឿងអលង្ការនោះក្នុងប្រអប់សុវត្ថិភាពមួយ។ ក៏ប៉ុន្តែ ដោយសារប្រអប់សុវត្ថិភាពនោះជាប្រភេទចាស់ ចោរបានលួចបើកវា និងបានលួចយកគ្រឿងអលង្ការទាំងអស់។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬ ទេ?

ករណី ១៤៖ X បានផ្ញើគ្រឿងអលង្ការមួយប្រអប់ជាមួយនឹង Y ក្នុងតម្លៃ ១០ ដុល្លារ ក្នុងមួយខែ។ X បានប្រាប់ Y ពីតម្លៃនៃគ្រឿងអលង្ការគឺ ១០.០០០ ដុល្លារ។ កិច្ចសន្យាបញ្ញើមានខចែងមួយដែលចែងថា Y មិនទទួលខុសត្រូវចំពោះការខូចខាត ឬ ការបាត់បង់វត្ថុបញ្ញើទេ ទោះជាក្នុងស្ថានភាពណាមួយក៏ដោយ។ Y បានធ្វេសប្រហែសទុកចោលប្រអប់នោះនៅតុទទួលភ្ញៀវរបស់ហាងគាត់ ហើយវាក៏ត្រូវបានគេលួច។ តើ X អាចទាមទារសំណងនៃការខូចខាតពី Y បានដែរ ឬ ទេ? សូមមើលមាត្រា ៤០៣ កថាខណ្ឌទី២ ក.រ។

ករណី ១៥៖ X បានផ្ញើម៉ូតូមួយជាមួយនឹង Y ក្នុងតម្លៃ១០ ដុល្លារ ក្នុងមួយខែ។ ម៉ូតូត្រូវបានគេលួចដោយសារកំហុសរបស់ Y។ តម្លៃម៉ូតូគឺ ៦០០ ដុល្លារ ប៉ុន្តែមានគ្រឿងអលង្ការដ៏មានតម្លៃថ្លៃមួយ ដែលមានតម្លៃ ១០.០០០ ដុល្លារ ត្រូវបានទុកក្នុងកែបម៉ូតូ ដែល Y មិនបានដឹង។ តើ X អាចទាមទារសំណងនៃការខូចខាតពី Yបានដែរ ឬ ទេ?

ករណី ១៦៖ X បានផ្ញើកប៉ាល់របស់គាត់ក្នុងឃ្លាំងរបស់ Y ក្នុងតម្លៃ ៣០ ដុល្លារ ក្នុងមួយខែ សម្រាប់រយៈពេល ៦ ខែ។ រយៈពេល ២ ខែ ក្រោយមក X បានមកឃ្លាំងរបស់ Y និងបានសុំឲ្យ Y ប្រគល់កប៉ាល់វិញ។ ក៏ប៉ុន្តែ Y បានបដិសេធក្នុងការប្រគល់កប៉ាល់ និងបានអះអាងថាប្រសិនបើ X ចង់បានកប៉ាល់វិញ នោះ X ត្រូវបង់ ១២០ ដុល្លារ សម្រាប់រយៈពេល ៤ ខែ។

ករណី ១៧៖ X បានផ្ញើកប៉ាល់របស់គាត់ក្នុងឃ្លាំងរបស់ Y ក្នុងតម្លៃ ៣០ ដុល្លារ ក្នុងមួយខែ ដោយពុំមានកំណត់ពីអំឡុងពេល។ ថ្ងៃមួយ ដោយសារ Y មានអារម្មណ៍ថាចូលចិត្តនិងចង់ទិញកប៉ាល់មួយផ្ទាល់ខ្លួន Y បានរៀបចំប្រគល់កប៉ាល់នោះវិញ និងសុំឲ្យ X មកយកកប៉ាល់។ ក៏ប៉ុន្តែ X មិនបានមកយកទេ ហើយនិយាយថាប្រសិនបើ Y ចង់ឲ្យ X មកយកកប៉ាល់ Y ត្រូវបង់សោហ៊ុយធ្វើដំណើររបស់ X និងសោហ៊ុយដឹកកប៉ាល់ចេញពីឃ្លាំងរបស់ Y ទៅកាន់កន្លែងដាក់ឥវ៉ាន់របស់ X។ Y បាននិយាយថា X ត្រូវបង់សោហ៊ុយទាំងនោះដោយខ្លួនឯង។ ការប្រកែកគ្នារវាង X និង Y បានបន្តអស់រយៈពេល ២ ខែ ក្នុងអំឡុងពេលនោះ Y បានចំណាយអស់ ២០ ដុល្លារ ក្នុងការថែទាំកប៉ាល់ ហើយទីបំផុតកប៉ាល់ត្រូវបានគេលួចចេញពីឃ្លាំងរបស់ Y។ សូមមើលមាត្រា ៤៥៥, ៤៥៦ ក.រ។

ករណី ១៨៖ X បានផ្ញើកប៉ាល់របស់គាត់ក្នុងឃ្លាំងរបស់ Y ក្នុងតម្លៃ ៣០ ដុល្លារ ក្នុងមួយខែ សម្រាប់រយៈពេល ៦ ខែ។ រយៈពេល ២ ខែ ក្រោយមក Y បាមទទួលសំណើមួយពី Z ដើម្បីផ្ញើកប៉ាល់របស់ Z ក្នុងតម្លៃ ៥០ ដុល្លារ ក្នុងមួយខែ។ Y បានយកកប៉ាល់របស់ X ទៅដាក់នៅកន្លែងរបស់ X វិញ និងបានសុំឲ្យ X ទទួលកប៉ាល់។ ក៏ប៉ុន្តែ X បដិសេធក្នុងការទទួលកប៉ាល់វិញ និងបានអះអាងថា Y គួរតែរក្សាទុកកប៉ាល់សម្រាប់រយៈពេល ៤ ខែ ទៀត ព្រោះពួកគេបានព្រមព្រៀងគ្នាដូច្នេះហើយ។ Y បានរក្សាទុកកប៉ាល់របស់ X ដោយទើសទាល់សម្រាប់រយៈពេល ៤ ខែ ទៀត ក្នុងអំឡុងពេលនោះ Y បានចំណាយអស់ ៤០ ដុល្លារ ដើម្បីថែទាំកប៉ាល់ និងបានបាត់បង់ឱកាសរកស៊ីជាមួយ Z ដោយសារ Z បានដកសំណើ។

ករណី១៩៖ X បានផ្ញើឆ្កែរបស់គាត់ជាមួយនឹង Y រយៈពេល ១ ខែ ដោយមិនគិតថ្លៃ។ ក្នុងអំឡុងពេល ១ ខែ Y បានចំណាយអស់ ៣០ ដុល្លារ សម្រាប់អាហាររបស់ឆ្កែ។ លើសពីនេះទៀត ឆ្កែបានខាំ Y ហើយ Yបានចំណាយអស់ ១០០ ដុល្លារ សម្រាប់ថ្លៃព្យាបាល។ ១ ខែ ក្រោយមក X បានមកយកឆ្កែ ប៉ុន្តែ Yបានបដិសេធ ដោយទាមទារថា Y នឹងឲ្យឆ្កែវិញ ជាការដូរនឹងការបង់ប្រាក់ ១៣០ ដុល្លាររបស់ X។ បន្ទាប់ពីការប្រកែកគ្នារវាង X និងY អស់រយៈពេល ១ ខែ X បានព្រមបង់ ១៣០ ដុល្លារឲ្យ Y។ ក៏ប៉ុន្តែ Y បានបង់ ៣០ ដុល្លារ ទៀតសម្រាប់អាហាររបស់ឆ្កែក្នុងរយៈពេលនៃការប្រកែកគ្នានោះ ហើយ Y បានទាមទារសរុប ១៦០ ដុល្លារ។ សូមមើលមាត្រា ៧៧៧ កថាខណ្ឌទី១ ក.រ។

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី១០

## ប្រធានបទ៖ បណ្ដឹងតវ៉ារបស់តតិយជនក្នុងរឿងអនុវត្តដោយបង្ខំ និងរក្សាការពារ

ថ្ងៃទី ១៧ ធ្នូ ២០១៥

# បណ្ដឹងតវ៉ារបស់តតិយជនក្នុង រឿងអនុវត្តដោយបង្ខំ និងរក្សាការពារ

## ១. គោលគំនិតទូទៅ

សិទ្ធិធ្វើបណ្តឹងជាសិទ្ធិរបស់ភាគីដែលត្រូវបានធានា តាមរយៈសិទ្ធិពឹងពាក់តុលាការដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

ទន្ទឹមនឹងការអនុវត្តនៃសិទ្ធិនេះ ការទាមទារមួយចំនួនរបស់ភាគីបណ្តឹង គឺអាចធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់តតិយជន ដូចជាតាមរយៈស្នើរសុំការចាត់ចែងរក្សាការពារ ឬការអនុវត្តដោយបង្ខំ ជាដើម។

កត្តាទាំងនេះហើយ តតិយជនអាចធ្វើការតវ៉ា ដោយដាក់បណ្តឹងតវ៉ារបស់តតិយជនបាន។

| |
|---|
| <u>ឧទាហរណ៍ទី១</u><br>ក(ម្ចាស់បំណុល) បានដាក់ពាក្យសុំរឹបអូសអចលនវត្ថុ ដែលបានចុះបញ្ជីឈ្មោះ ខ (កូនបំណុល) ។ ប៉ុន្តែតាមពិត ម្ចាស់កម្មសិទ្ធិលើអចលនវត្ថុពិតប្រាកដគឺ គ។ |

| |
|---|
| <u>ឧទាហរណ៍ទី២</u><br>ក(ម្ចាស់បំណុល) បានដាក់ពាក្យសុំរឹបអូសចលនវត្ថុ ដែលស្ថិតក្រោមការកាន់កាប់ឈ្មោះ ខ (កូនបំណុល)។ ប៉ុន្តែតាមពិត ម្ចាស់កម្មសិទ្ធិលើចលនវត្ថុពិតប្រាកដគឺ គ ដែល គ ទើបតែបានជួលវាទៅអោយ ខ។<br>ករណីទាំងនេះគឺ គ អាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនបាន (CCP៣៦៥) |

## ២. អត្ថន័យតតយជន

### *នរណាជាតតិយជន?*

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ពុំមានផ្តល់អត្ថន័យថាតតិយជនជាមនុស្ស បែបណានោះទេ។ នៅក្នុងសន្ទានុក្រមរដ្ឋប្បវេណីបានពន្យល់ពាក្យតតិយជនថា ជនទីបី ឬជនដែលមិនមែនជាភាគី នៅក្នុងទំនាក់ទំនងគតិយុត្ត។ជនដែលមិនមែនជាភាគីនៅក្នុងរឿងក្តីរដ្ឋប្បវេណី។

## ៣- អត្ថន័យបណ្តឹងតវ៉ារបស់តតិយជន

បណ្ដឹងតវ៉ារបស់តតិយជន គឺជាបណ្ដឹងដែលតតិយជនប្ដឹងតវ៉ាប្រឆាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ដោយអះអាងថាកម្មវត្ថុនៃការអនុវត្ត មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវនៅក្រោមច្បាប់សារធាតុ *ហើយទាមទារអោយដកចេញនូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិទាំងនោះ (*CCP *៣៦៥ កថា១)* ។

បណ្ដឹងតវ៉ារបស់តតិយជនជាវិធីមួយដែលក្រមនីតិវិធីបានចែងដើម្បីសង្គ្រោះនូវសិទ្ធិរបស់តតិយជនដែលកម្មវត្ថុនៃការអនុវត្តដោយបង្ខំ មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវ។

បណ្ដឹងតវ៉ារបស់តតិយជនមិនមែនជាវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារ ដែលម្ចាស់បំណុលចង់ឲ្យសម្រេចតាមរយៈការអនុវត្តដោយបង្ខំនោះទេ។

បណ្ដឹងតវ៉ារបស់តតិយជន អាចយកទៅអនុវត្តបាន ចំពោះការអនុវត្តដោយបង្ខំគ្រប់ប្រភេទ ដូចជាការអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារអោយសងជាប្រាក់ សិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិ និងការអនុវត្តដោយបង្ខំអោយប្រគល់វត្ថុ ការអនុវត្តដោយបង្ខំអោយចាកចេញពីផ្ទះ ជាអាទិ៍។

## ៤- ភាគី

**<u>ដើមចោទ</u>** ត្រូវតែជាតតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ទ្រព្យសម្បត្តិ។ ភាគច្រើនសិទ្ធិរបស់តតិយជនគឺ កម្មសិទ្ធិ។

លើសពីនេះទៀតសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ទ្រព្យសម្បត្តិរាប់បញ្ចូលទាំងកម្មសិទ្ធិអវិភាគ និងសិទ្ធិប្រាតិភោគដោយផ្អែកលើសិទ្ធិប្រាតិភោគដោយអនុប្បទាន (CC៨៨៨)។ សិទ្ធិទាំងអស់នោះត្រូវតែជាសិទ្ធិដែលអាចអះអាងចំពោះម្ចាស់បំណុល ដែលបានរឹបអូសទ្រព្យសម្បត្តិ ដែលមានន័យថាត្រូវតែមានការចុះឈ្មោះឬការកាន់កាប់ (CC១៣៩)។

**<u>ចុងចម្លើយ</u>** គឺម្ចាស់បំណុលនៃការអនុវត្ត មិនមែនអាជ្ញាសាលា ឬស្ថាប័នអនុវត្តផ្សេងទៀតទេ។

| |
|---|
| ឧទាហរណ៍ទី៣<br>Z បានលក់ដី និងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិដីមក Y ។ ក៏ប៉ុន្តែ វាមានភាពច្បាស់ណាស់ថា Y បានបោក Z ក្នុងកិច្ចសន្យាជាមួយខ្លួន ហើយ Z លុបចោលកិច្ចសន្យានោះដោយផ្អែកលើការឆបោក (CC៣៤៧-១)។ ក្រោយពីការលុបចោល Z មិនទាន់ទទួលបានការចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យខ្លួនវិញនៅឡើយទេ។ X គឺជាម្ចាស់បំណុលរបស់ Y និងបានរឹបអូសយកដីខាងលើដែលចុះបញ្ជីក្រោមឈ្មោះរបស់ Y។ Z បានដាក់ពាក្យបណ្ដឹជំទាស់ក្នុងនាមជាតតិយជនប្រឆាំងនឹង X ផ្អែកលើកម្មសិទ្ធិរបស់គាត់។<br>តើពាក្យបណ្ដឹងរបស់ Z គួរតែត្រូវទទួលយក ឬលើកចោល? |

ឧទាហរណ៍ ៤

Y បានលក់ពេជ្រមួយគ្រាប់ទៅ Z ហើយបានផ្ទេរការកាន់កាប់ពេជ្រនោះដោយកិច្ចព្រមព្រៀង គឺមិនបានប្រគល់គ្រាប់ពេជ្រជាក់ស្តែងទេ(CC២២៩-២)។ X គឺជាម្ចាស់បំណុលរបស់ Y និងបានរឹបអូសយកពេជ្រដែល Y បានកំពុងកាន់កាប់។ Z បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនចំពោះ X ផ្អែកលើកម្មសិទ្ធិរបស់គាត់។ តើការទាមទាររបស់ Z គួរគប្បីទទួលយកឬលើកចោល?

## ៥. បណ្តឹងតវ៉ារបស់តតិយជនក្នុងករណីអនុវត្តដោយបង្ខំ

### *តើបណ្តឹងតវ៉ារបស់តតិយជន អាចត្រូវបានដាក់ និងទទួលនៅពេលណា?*

ជាគោលការណ៍ ផលប្រយោជន៍ក្នុងការដាក់បណ្តឹង(CCP៧៤) កើតឡើងនៅក្រោយការចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុដែលពាក់ព័ន្ធ។

ក្នុងករណីកម្មវត្ថុនៃការអនុវត្តដោយបង្ខំត្រូវបានបញ្ជាក់ ដូចជាការប្រគល់វត្ថុជាក់លាក់ណាមួយនោះ ប្រសិនបើមានការផ្តល់រូបមន្តអនុវត្ត(CCP៣៥៧) នោះនឹងមានការទទួលស្គាល់ថា ភយន្តរាយនៃការអនុវត្តដោយបង្ខំ លេចចេញយ៉ាងជាក់ស្តែង ហើយពេលនោះផលប្រយោជន៍នៃការដាក់ពាក្យបណ្តឹង ក៏នឹងត្រូវទទួលស្គាល់ផងដែរ។

ដោយសារ បណ្តឹងតវ៉ារបស់តតិយជនត្រូវបានទទួលស្គាល់ថា វាវិធីដែលតតិយជនអាចសង្គ្រោះនូវសិទ្ធិរបស់ខ្លួនពីការអនុវត្តដោយបង្ខំ របស់ម្ចាស់បំណុល។ ដូចនេះនៅពេលដែលការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុដែលពាក់ព័ន្ធនោះ បានបញ្ចប់ហើយ ផលប្រយោជន៍ក្នុងការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ក៏ត្រូវរលត់ដែរ។ ហើយបើតតិយជននៅតែដាក់បណ្តឹងទៀត បណ្តឹងនោះនឹងត្រូវលើចោល។ "នៅពេលដែលការអនុវត្តដោយបង្ខំដែលទាក់ទងទៅនឹងប្រធានបទនេះបានបញ្ចប់" មានន័យថាការបញ្ចប់នៃការបែងចែកចំនែក(ក្នុងករណីអនុវត្តទាមទារបំណុល) ឬការបញ្ចប់នៃការប្រគល់កម្មវត្ថុ (ក្នុងករណីនៃការអនុវត្តទាមទារប្រគល់កម្មវត្ថុជាក់លាក់)។

ឧទាហរណ៍ ៥

Z មានពេជ្រមួយគ្រាប់ ហើយបានជួលពេជ្រនោះទៅឲ្យ Y។ X គឺជាម្ចាស់បំណុលរបស់ Y និងបានរឹបអូសយកពេជ្រដែល Y កំពុងកាន់កាប់។ Z បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយចំពោះ X ទៅសាលាដំបូងរាជធានីភ្នំពេញ ក៏ប៉ុន្តែ Z មិនបានដាក់ពាក្យសុំផ្អាកការអនុវត្តជាបណ្តោះអាសន្នទេ (CCP៣៦៧)។ ខណៈពេលដែលបណ្តឹងតវ៉ាដោយតតិយជនកំពុងចាត់ការ ការអនុវត្តដោយបង្ខំនៅតែបន្ត ហើយត្បូងពេជ្រនេះត្រូវបានលក់ទៅឲ្យ លោក A តាមរយៈការលក់ដោយបង្ខំ រួចលោក A បានបង់ប្រាក់លក់ទិញទៅតុលាការ ហើយទីបំផុត, លុយនេះត្រូវបានចែកទៅម្ចាស់បំណុលរបស់ Y។ ចំណុចនេះ ការអនុវត្តដោយ

បង្ខំបានបញ្ចប់ ពាក្យសុំផ្អាកជាបណ្តោះនូវការអនុវត្តដោយបង្ខំមិនមានប្រសិទ្ធិភាព។ ដូចនេះ បណ្តឹងតវ៉ាដោយតតិយជន បាត់បង់ផលប្រយោជន៍នៃពាក្យបណ្តឹង ហើយបណ្តឹង នោះនឹងត្រូវចលើកចោល។

## ៥.១- លំហូរនីតិវិធីបណ្តឹងតវ៉ារបស់តតិយជន

<u>ក- សមត្ថកិច្ចនៃបណ្តឹងតវ៉ារបស់តតិយជន</u> (CCP៣៦៥ កថា២)

តតិយជនត្រូវដាក់ពាក្យបណ្តឹងទៅតុលាការអនុវត្តដែលក្លាយជាស្ថាប័នអនុវត្ត ឬតុលាការដែលអាជ្ញាសាលាដែលក្លាយជាស្ថាប័នអនុវត្តនោះស្ថិតនៅ។

<u>ខ- ពន្ធដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន</u> ត្រូវកំណត់យកតាមប្រកាសលេខ៥៥៨កយប្រក/០៩ ទំព័រ១៨

<u>គ- ពាក្យបណ្តឹង</u>

ជាគោលការណ៍តុលាការ អាចចេញសាលក្រមបានទាល់តែមានពាក្យបណ្តឹង និងការទាមទារ ហើយតុលាការមិនអាចចេញអ្វីអោយហួសពីការទាមទាររបស់ភាគីនេះឡើយ។ (CCP១៨២-២)

**ពាក្យបណ្តឹងត្រូវតែគោរពតាម មាត្រា៧៥**

<u>ខ្លឹមសារសាលក្រមដែលដើមចោទទាមទារ (CCP៧៥-២-ខ)</u>

ការអនុវត្តដោយបង្ខំដែលចុងចម្លើយ X បានដាក់ដោយផ្អែកលើអនុសារសាលក្រមដែលមានរូបមន្តអនុវត្តក្នុងរឿងក្តី (បញ្ជាក់រឿងក្តីនៃសាលក្រមដែលបានដាក់ពាក្យសុំអនុវត្តដោយ បង្ខំ) ចុះថ្ងៃ ខែ ឆ្នាំ លើទ្រព្យសម្បត្តិ (អត្តសញ្ញាណទ្រព្យសម្បត្តិ)មិនត្រូវបានអនុញ្ញាត។

<u>អង្គហេតុដែលជាមូលហេតុនៃការទាមទារ(CCP ៧៥-៣)</u>

1. ចុងចម្លើយ X បានដាក់ពាក្យបណ្តឹងអនុវត្តដោយបង្ខំ ទៅសាលាដំបូងរាជធានីភ្នំពេញដោយផ្អែកលើសាលក្រម (រឿងក្តីលេខ ឆ្នាំ......... តុលាការដំបូងរាជធានីភ្នំពេញ) និងអាជ្ញាសាលារបស់តុលាការដំបូងរាជធានីភ្នំពេញនៅ ថ្ងៃទី០១ ខែ ធ្នូ ២០១៥ លើអចលនវត្ថុដែលបានរៀបរាប់នៅក្នុងបញ្ជីទ្រព្យសម្បត្តិ។
2. ដើមចោទ Z គឺជាកម្មសិទ្ធិករនៃទ្រព្យដែលបានរៀបរាប់នៅក្នុងបញ្ជីទ្រព្យសម្បត្តិ ។ (នៅក្នុងការអនុវត្តជាក់ស្តែង Z ត្រូវរៀបរាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលគាត់បានទទួលភាពជាកម្មសិទ្ធិករ)

***តើបណ្តឹងតវ៉ារបស់តតិយជន មានអានុភាពផ្អាកការអនុវត្តដោយបង្ខំដែរឬទេ?***

ពាក្យបណ្តឹងតវ៉ារបស់តតិយជន មិនមានអានុភាពផ្អាកដោយស្វ័យប្រវត្តិនូវការអនុវត្តនោះទេ ហើយក៏មិនរាំងការបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំដែរ ។ ក្នុងករណី Z បានដាក់បណ្តឹងនៃការតវ៉ាដោយតតិយជនដោយផ្អែកលើភាពជាម្ចាស់សិទ្ធិរបស់គាត់ ប៉ុន្តែនីតិវិធីនៃការអនុវត្តដោយបង្ខំ នៅតែបន្តតើនឹងមានអ្វីកើតឡើង? ក្នុងករណីនេះការអនុវត្តដោយបង្ខំអាចត្រូវបានបញ្ចប់មុនពេលសាលក្រមបណ្តឹង

នៃតវ៉ាដោយតតិយជនបានចេញ ហើយបណ្តឹងនៃការតវ៉ាដោយតតិយជនគ្មានប្រយោជន៍។ ដូច្នេះដើម្បីការពារ Z , CCP៣៦៧ បានផ្តល់នូវមធ្យោបាយ ឬវិធាននៃការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន។

(CCP៣៦៧) បើតតិយជនធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការតវ៉ា នោះតុលាការអាចបង្គាប់អោយផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬលុបចោលនូវការចាត់ចែងការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ ដោយអោយដាក់ ឬមិនអោយដាក់ប្រាតិភោគ រហូតដល់ពេលចេញសាលក្រម ឬសាលដីកាចុងក្រោយ។

ជារូម Z អាចដាក់ពាក្យសុំផ្អាកឲ្យការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន រួមគ្នាជាមួយនឹងបណ្តឹងនៃការតវ៉ាដោយតតិយជន (ឬអាចដាក់ពាក្យសុំនោះ បន្ទាប់ ឬក្រោយពីដាក់ពាក្យបណ្តឹង មានន័យថាក្នុងអំឡុងពេលដែលបណ្តឹងនៃការតវ៉ាដោយតតិយជនកំពុងចាត់ការ)។ ប្រសិនបើ Z បានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិរបស់ខ្លួន បានជោគជ័យ នោះតុលាការអាចចេញដីកាសម្រេចបង្គាប់ឲ្យផ្អាក ការអនុវត្តដោយបង្ខំជាបណ្តោះអាសន្នបាន។ ដីកាសម្រេចនេះជា ឯកសារមួយដែលនៅក្រោម CCP៣៧០-២-ក។ ដូច្នេះប្រសិនបើ Z ដាក់ដីកាសម្រេចនេះទៅតុលាការអនុវត្ត តុលាការអនុវត្តត្រូវផ្អាកការអនុវត្ត។

- *ដូចបានឃើញខាងលើនេះ នៅពេលដែលមានការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន មេធាវីគប្បីដាក់ពាក្យសុំ ឲ្យផ្អាកការអនុវត្តជាបណ្តោះអាសន្នផងដែរ!*

**<u>ឃ- នីតិវិធីជំនុំជម្រះ</u>**

សម្រាប់នីតិវិធីជំនុំជម្រះលើបណ្តឹងតវ៉ារបស់តតិយជន គឺធ្វើដូចនីតិវិធីនៃការជម្រះក្តីលើកទី១ដែរ។

តុលាការដែលទទួលពាក្យបណ្តឹង ត្រូវពិនិត្យពាក្យបណ្តឹង។

ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងចេញសាលក្រម។

**<u>ង- អានុភាពសាលក្រម</u>**

ក្នុងករណីដែលតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា៖

ការអនុវត្តដោយបង្ខំ ដែលធ្វើឡើងដោយចុងចម្លើយ X ដោយផ្អែកលើឯកសារចម្លងយថាភូតនៃអនុសារសាលក្រមដែលភ្ជាប់ជាមួយរូបមន្តអនុវត្ត (រឿងក្តីលេខ ........... ឆ្នាំ........ឈ្មោះតុលាការ) នៅលើទ្រព្យសម្បត្តិដែលបានរៀបរាប់នៅក្នុងបញ្ជីទ្រព្យសម្បត្តិនឹងមិនត្រូវបានអនុញ្ញាត។ តតិយជនដែលបានសាលក្រមឈ្នះក្តី អាចលុបចោលការអនុវត្តដោយបង្ខំ ឬការអនុវត្តការរឹបអូសជាបណ្តោះអាសន្នដោយគ្រាន់តែដាក់ឯកសារចម្លងយថាភូតនៃអនុសារសាលក្រមទៅតុលាការអនុវត្ត នោះនីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវផ្អាក និងលុបចោល (មាត្រា៣៧០ កថា១-ខ)។

សាលក្រមដែលត្រូវដាក់ទៅតុលាការអនុវត្តត្រូវតែជាសាលក្រស្ថាពរ (មាត្រា១៩៣ និង ១៩៤) ឬត្រូវមានការប្រកាសអោយអនុវត្តជាបណ្ដោះអាសន្ន (មាត្រា១៩៦)។ មិនចាំបាច់មានរូបមន្តអនុវត្តទេ។

***តើសេចក្ដីសម្រេចផ្អាកការអនុវត្តដោយបង្ខំ*** (CCP៣៦៧) ***មានអានុភាពដល់ពេលណា នៅពេលដែលសាលក្រមនៃបណ្ដឹងតវ៉ារបស់តតិត្រូវ បានចេញតែមិនទាន់បានចូលជាស្ថាពរ?***

បញ្ហានេះត្រូវដោះស្រាយដោយ CCP៣៦៨

**មាត្រា៣៦៨ ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយជាអាទិ៍**

នៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយ អំពីបណ្ដឹងតវ៉ាចំពោះការទាមទារ បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ឬបណ្ដឹងតវ៉ារបស់តតិយជន តុលាការដែលទទួលពាក្យបណ្ដឹងអាច បង្គាប់អោយធ្វើការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ និង កថាខណ្ឌទី២ នៃមាត្រា៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារជាអាទិ៍)នៃក្រមនេះ ឬអាចលុបចោល ឬផ្លាស់ប្ដូរឬទទួលស្គាល់នូវសេចក្ដីសម្រេចដែលបានធ្វើរួច ហើយតាមបញ្ញត្តិនៃទី១ ឬកថាខណ្ឌទី២នោះបាន។ ការសម្រេចសេចក្ដីនេះត្រូវមានអានុភាព ចាប់ពីថ្ងៃដែលសាលក្រមឬសាលដីកាចុងក្រោយអំពីបណ្ដឹងដែលបានកំណត់នៅក្នុងមាត្រាត្រូវបានប្រកាស។

ដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃមាត្រា៣៦៧នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបាត់បង់អានុភាពនៅពេលដែលតុលាការចេញសាលក្រមនៃបណ្ដឹតតវ៉ារបស់តតិយជន ជាហេតុនាំឲ្យការអនុវត្តដែលបង្ខំដែលត្រូវបានផ្អាក អាចចាប់ផ្ដើមអនុវត្តដោយបង្ខំឡើងវិញ មុនពេលដែលសាលក្រមនៃបណ្ដឹងតវ៉ារបស់តតិយជនចូលជាស្ថាពរ ហេតុនេះ ដើម្បីរារាំងនូវបញ្ហានេះ មាត្រា៣៦៨ នៃក្រមនីតិវិធីបានបញ្ញត្តិ .................។ មានន័យថា នៅក្នុងសេចក្ដីសម្រេចរបស់តុលាការ ក្រៅអំពីការសម្រេច (a) អំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ តុលាការត្រូវ (b) សម្រេចបន្ថែមដែលមានខ្លឹមសារ (១) ទទួលស្គាល់ដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំ ផ្លាស់ប្ដូរដីកាសម្រេចឲ្យផ្អាកការអនុវត្តដោយបង្ខំ (៣) លុបចោលដីកាសម្រេចឲ្យផ្អាកការអនុវត្តជាបណ្ដោះអាសន្ន ហើយសេចក្ដីសម្រេចបន្ថែមនេះ មានអានុភាពអនុវត្តភ្លាប់បន្ទាប់ពីតុលាការប្រកាសសាលាក្រម។

ឧទាហរណ៍៖ តុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទនៃបណ្ដឹងតវ៉ារបស់តតិយជន ហេតុនេះ តុលាការត្រូវចេញសេចក្ដីសម្រេចដូចខាងក្រោម៖

១-ការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយចុងចម្លើយដោយផ្អែកលើអនុសារៈសាលក្រម ដែលភ្ជាប់មកជាមួយរូបមន្តអនុវត្ត (សំណុំរឿងលេខ ឆ្នាំ ឈ្មោះតុលាការ) ចំពោះទ្រព្យសម្បត្តិដែលបានរៀបរាប់នៅក្នុងបញ្ជីទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាត។

២- ទទួលស្គាល់ដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំ

ក្នុងករណី សេចក្តីសម្រេចទី១ មានអានុភាពលុះត្រាតែសាលាក្រមស្ថាពរ ប៉ុន្តែសេចក្តីសម្រេចទី២ មានអានុភាពភ្លាមបន្ទាប់ពីតុលាការបានធ្វើការប្រកាស(មាត្រា៣៦៨នៃក្រមនីតិវិធី) នេះជាចំណុចពិសេសទាក់ទងនឹងសេចក្តីសម្រេចរបស់តុលាការនៃបណ្តឹងតវ៉ារបស់តតិយជន។ ក្នុងករណីនេះទោះបីជាមានឧបាស្រ័យទៅតុលាការជាន់ខ្ពស់អំពីសេចក្តីសម្រេចនេះក៏ដោយ ការផ្អាកការអនុវត្តដោយបង្ខំតាមរយៈដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំនៅតែបន្ត។ ប៉ុន្តែដើម្បីឲ្យតុលាការអនុវត្តបន្តផ្អាកការអនុវត្តដោយបង្ខំតាមខ្លឹមសារនៃសេចក្តីសម្រេចខាងលើ ភាគីត្រូវផ្ញើសេចក្តីសម្រេចនោះទៅតុលាការអនុវត្ត។

ឧទាហរណ៍៦

Z បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនចំពោះ X ទៅសាលាដំបូងរាជធានីភ្នំពេញ និងបានដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំ។ តុលាការបានចេញដីកាសម្រេចបង្គាប់ឲ្យផ្អាក ការអនុវត្តោយបង្ខំ។ Z បានដាក់ដីកាសម្រេចនេះទៅតុលាការអនុវត្ត ហើយតុលាការអនុវត្តផ្អាកជាបណ្តោះអាសន្ននៃការអនុវត្តដោយបង្ខំ។ បន្ទាប់ពីនោះ Z បានឈ្នះបណ្តឹង តវ៉ារបស់តតិយជន។ ក្នុងករណីនេះសាលាដំបូងរាជធានីភ្នំពេញ ត្រូវបង្គាប់ "ទទួលស្គាល់ដីកាសម្រេចឲ្យផ្អាកការអនុវត្តជាបណ្តោះអាសន្ន (រឿងក្តីលេខ ឆ្នាំ ឈ្មោះសាលាដំបូងរាជធានីភ្នំពេញ )" នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម។ សេចក្តីសម្រេចនេះមានអានុភាពភ្លាមៗ(CCP៣៦៨-វាក្យខ័ណ្ឌ២។ ពេលដែល Z បានដាក់សាលក្រមនេះទៅតុលាការអនុវត្ត តុលាការអនុវត្តត្រូវបន្តផ្អាកការអនុវត្តដោយបង្ខំ។

១.មិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំ

២.ទទួលស្គាល់ដីកាសម្រេចផ្អាក

ឧទាហរណ៍ ៧

Z បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនចំពោះ X ទៅសាលាដំបូងរាជធានីភ្នំពេញ និងដាក់ពាក្យ សុំផ្អាកការអនុវត្តដោយបង្ខំ។ តុលាការបានចេញដីកាសម្រេចបង្គាប់ឲ្យផ្អាកជាបណ្តោះអាសន្ននៃការអនុវត្តដោយបង្ខំ។ Z បានដាក់ដីកាសម្រេចនេះទៅតុលាការអនុវត្ត ហើយតុលាការអនុវត្តផ្អាកជាបណ្តោះអាសន្ននៃការអនុវត្តដោយបង្ខំ។ បន្ទាប់មក Z បានចាញ់ក្តីក្នុងបណ្តឹងនៃការតវ៉ាដោយតតិយជន។ ក្នុងករណីនេះសាលាដំបូងរាជធានី ភ្នំពេញ ត្រូវបង្គាប់ "លុបចោលដីកាសម្រេចឲ្យផ្អាកជាបណ្តោះអាសន្ននៃការអនុវត្តដោយបង្ខំ (រឿងក្តីលេខ ឆ្នាំ ឈ្មោះសាលាដំបូងរាជធានីភ្នំពេញ )" នៅក្នុងសេចក្តីបញ្ចប់។ សេចក្តីសម្រេចនេះមានអានុភាពភ្លាមៗ (CCP368-វាក្យខ័ណ្ឌ2)។ ពេលដែល X បានដាក់សាលក្រមនេះទៅតុលាការអនុវត្ត តុលាការអនុវត្តត្រូវបន្តការអនុវត្តដោយបង្ខំ។

## ៦. បណ្តឹងតវ៉ារបស់តតិយជនក្នុងករណីដីកាសម្រេចរក្សាការពារ

ការចាត់ចែងរក្សាការពារដែលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់តតិយជន គឺការរឹបអូសជាបណ្តោះអាសន្ន។ ការរឹបអូសជាបណ្តោះអាសន្ន ជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងអោយសងជាប្រាក់។

ឧទាហរណ៍៨- លោក ក បានអោយលោក ខ ខ្ចីប្រាក់ចំនួន១០០០០ដុល្លាអាមេរិក រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃ០១- ០១- ២០១៤ និង កំណត់ពេលសង០១- ០១- ២០១៥។ លោក ខ ជាម្ចាស់ហាងលក់ និងជួសជុលកុំព្យូទ័រ។ នៅ ថ្ងៃ ០១ ១២ ២០១៤ លោក គ ជាប្អូនបង្កើត លោក ខ បានយកកុំព្យូទ័រថ្មី១០គ្រឿងទៅផ្ញើនៅហាងលោក ខ អោយជួយលក់។

ថ្ងៃកំណត់សងមកដល់ លោក ក បានដាស់តឿនលោក ខ សងប្រាក់មកខ្លួន តែលោក ខ បដិសេធ។ លោក ក បានដាក់ពាក្យសុំរក្សាការពារសុំរឹបអូសជាបណ្តោះអាសន្នកុំព្យូទ័រថ្មី១០គ្រឿងក្នុងហាងលោក ក។ តុលាការបានចេញដីកាសម្រេចរឹបអូសកុំព្យូទ័រថ្មី១០គ្រឿងនោះ។

តតិយជនអាចធ្វើបណ្តឹងតវ៉ារបស់តតិយជន (CCP៣៦៤ និង៣៦៥) ដូចគ្នានឹងបណ្តឹងតវ៉ារបស់តតិយជនករណីអនុវត្តដោយបង្ខំដែរ(CCP៥៦៤)។

ខណៈពេលដែលបណ្តឹងតវ៉ារបស់តតិយជននៅមិនទាន់បានសម្រេចនៅឡើយ ប្រសិនបើការចាត់ចែងរក្សាការពារបានប្តូរទៅជាការអនុវត្តដោយបង្ខំ ដើមចោទគួរកែប្រែពាក្យបណ្តឹងពីការទាមទារឲ្យផ្អាកការចាត់ចែងរក្សាការពារ ទៅជាការទាមទារឲ្យផ្អាកការអនុវត្តដោយបង្ខំ (CCP៨៤)។

## ៧. ការតវ៉ាចំពោះការអនុវត្ត

យោងតាមខ្លឹមសារនៃមាត្រា ៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា៖ ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យមួយដែលទាមទារឲ្យតុលាការអនុវត្ត ឬសាលាដំបូង កែតម្រូវនូវការចាត់ចែងការអនុវត្តដែលមិនអាចប្តឹងជំទាស់បាន។

- <u>**មូលហេតុនៃការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត**</u>៖ អ្នកតវ៉ាអះអាងថា ការអនុវត្តដោយបង្ខំនោះខុសនឹងបញ្ញត្តិស្តីនីតិវិធីច្បាប់។
- ចំពោះកំឡុងពេលសម្រាប់ធ្វើការតវ៉ាគឺមិនត្រូវបានកំណត់ឡើយ មានន័យថា អ្នកតវ៉ាអាចធ្វើការតវ៉ានៅពេលណាក៏បាន តែទោះជាយ៉ាងណាក៏ដោយអ្នកតវ៉ាត្រូវធ្វើនៅពេលដែលមានផលប្រយោជន៍ក្នុងការតវ៉ា និងនៅមុនពេលបញ្ចប់នៃនីតិវិធីអនុវត្តដោយបង្ខំ។

តាមរយៈមាត្រា ៣៨៤ ខាងលើនេះ មានការកម្រិតនូវសិទ្ធិក្នុងការតវ៉ាចំពោះការអនុវត្តនេះ គឺមានតែការចាត់ចែងអនុវត្តណា ដែលមិនអាចប្តឹងជំទាស់[48]បាន ទើបមានសិទ្ធិអាចប្តឹងតវ៉ាបាន។

[48] មាត្រា ២៥៩ ប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

- <u>**អ្នកដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត**</u>៖ ជាគោលការណ៍ យើងឃើញថាបុគ្គលដែលអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្តបាន គឺអ្នកដែលខូចខាតផលប្រយោជន៍ដោយសារការចាត់ចែងការអនុវត្តខុសច្បាប់នោះ ឬដោយសារការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការអនុវត្ត។ ហេតុនេះ អ្នកដែលខូចផលប្រយោជន៍ ដោយសារការយឺតយ៉ាវ ឬធ្វេសប្រហែស គឺ **មិនត្រឹមតែជា (១) ម្ចាស់បំណុលដែលបានដាក់ពាក្យសុំឲ្យអនុវត្ត ឬ (២)កូនបំណុលដែលត្រូវបានទាមទារឲ្យអនុវត្តប៉ុណ្ណោះទេ នៅអាចមាន(៣)តតិយជនផ្សេងទៀត ដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងអស់នេះ។**
- <u>**ទីកន្លែងដែលត្រូវដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត**</u>៖ (សមត្ថកិច្ចផ្ដាច់មុខ មានចែងក្នុងមាត្រា ៣៩៦) តាមមាត្រា ៣៩៤ នៃក្រមនីតិវិធី (១) ការតវ៉ាចំពោះការចាត់ចែងអនុវត្តដោយតុលាការអនុវត្ត គឺត្រូវធ្វើទៅតុលាការអនុវត្ត (២)ចំណែកឯការតវ៉ា ចំពោះការចាត់ចែងដោយអាជ្ញាសាលា គឺត្រូវធ្វើទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។
- <u>**ការបង់ពន្ធ**</u>៖ ចំពោះពន្ធក្នុងការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត គឺត្រូវបង់ពន្ធ ៥០០០ រៀល (យោងប្រកាសស្ដីការកែសម្រួល លេខ ៥៤ កយប្រក/០៩ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩)
- <u>**អានុភាពនៃការដាក់ពាក្យសុំ**</u>៖ នៅពេលមានការដាក់ពាក្យតវ៉ាចំពោះការអនុវត្ត ការតវ៉ានោះមិនមានអានុភាពផ្អាកការអនុវត្តដោយបង្ខំជាស្វ័យប្រវត្តិឡើយ៣៤៣បញ្ញត្តិនៃមាត្រា)-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះការតវ៉ាចំពោះការអនុវត្តដែលមានចែងក្នុងមាត្រា ៣៩៤។(៣-

ហេតុដូច្នេះហើយតុលាការអនុវត្ត ឬសាលាដំបូងអាចចេញដីកាសម្រេច *(១)-* បង្គាប់ឲ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយដាក់ប្រាតិភោគ ឬមិនឲ្យដាក់ប្រាតិភោគ *(២)- )-* បង្គាប់ឲ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬទាំងមូល ដោយដាក់ប្រាតិភោគ ឬមិនឲ្យដាក់ប្រាតិភោគ (បញ្ញត្តិនៃមាត្រា ៣៤៣-២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

- <u>**ការសម្រេចសេចក្ដីលើពាក្យសុំតវ៉ាចំពោះការអនុវត្ត៖**</u> នៅក្រោយពេលទទួលបានពាក្យសុំតវ៉ាចំពោះការអនុវត្ត នោះតុលាការអនុវត្ត ឬសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅត្រូវសម្រេចសេចក្ដីដោយចេញដីកាសម្រេចដែលដីកាសម្រេចនេះមិនអាចប្ដឹងជំទាស់បានឡើយ កាលណាគ្មានច្បាប់បញ្ញត្តិ)មាត្រា២៥៩នៃក្រមនីតិវិធី(លើកលែងតែមានចែងក្នុងមាត្រា345-1-គ។

ខ្លឹមសារនៃដីកាសម្រេចលើពាក្យសុំតវ៉ាចំពោះការអនុវត្ត គឺអាចជាការទទួលស្គាល់ពាក្យសុំតវ៉ា ឬជាការលើកចោលពាក្យសុំតវ៉ា។

***<u>មានភាពខុសប្លែកគ្នារវាងបណ្តឹងតវ៉ារបស់តតិយជន និងពាក្យតវ៉ាចំពោះការអនុវត្ត៖</u>***

- បណ្តឹងតវ៉ារបស់តតិយជន គឺត្រូវបានធ្វើឡើងដោយតតិយជន ដែលអាចទទួលរងនូវផលប៉ះពាល់ដោយសារនីតិវិធីអនុវត្ត ដែលមានចែងក្នុងក្រមនីតិវិធី ឬដោយសារការបំពានសិទ្ធិដែលមានចែងក្រមនីតិវិធី។
- ពាក្យតវ៉ាចំពោះការអនុវត្ត គឺអាចធ្វើឡើងដោយកូនបំណុល ម្ចាស់បំណុល ឬតតិយជនដែលទទួលរងនូវផលប៉ះពាល់ដោយសារការអនុវត្តនីតិវិធី ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

ដើម្បីងាយស្រួលបង្ហាញពីភាពខុសគ្នាចំពោះបណ្តឹងតវ៉ារបស់តតិយជន និងពាក្យតវ៉ាចំពោះការអនុវត្ត យើងខ្ញុំសូមលើកយកជាឧទាហរណ៍ មកធ្វើការបញ្ជាក់ជូន ដូចតទៅ៖

***<u>ក្នុងករណីការស្នើសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ</u>*** គឺនៅក្នុងពាក្យស្នើសុំរបស់ម្ចាស់បំណុល (X) ត្រូវភ្ជាប់នូវឯកសារចម្លងយថាភូត នៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និងឯកសារដូចខាងក្រោម[49]៖

១. ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចំលងដែលមានបញ្ជាក់ នៃសៀវភៅចុះបញ្ជី និងក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះគឺជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។

២. ចំពោះដីដែលមិនទាន់ចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។

| |
|---|
| ឧទាហរណ៍៩៖<br>ប្រសិនបើនៅពេល X បានដាក់ពាក្យសុំអនុវត្តដោយបង្ខំរឹបអូសដីរបស់ Y តែកម្មសិទ្ធិករដែលបានចុះបញ្ជីលើដីក្នុងសៀវភៅចុះបញ្ជីគឺជា Z ហើយ X មិនបានបញ្ជាក់ពីកម្មសិទ្ធិរបស់ Y លើដីទេ នោះតុលាការមិនត្រូវចេញដីកាសម្រេចអនុវត្តដោយបង្ខំរឹបអូសដីនោះទេ ព្រោះពាក្យសុំអនុវត្តដោយបង្ខំមិនគោរពតាម មាត្រា ៥១៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធី។<br>ប្រសិនបើតុលាការអនុវត្តបានចេញដីកាសម្រេចរឹបអូសដីដោយមានកំហុសនីតិវិធី ហេតុនេះការអនុវត្តគឺខុសច្បាប់ ហើយ Z អាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៩៤ នៃក្រមនីតិវិធី) ហើយក៏ជាការបំពាននូវសិទ្ធិរបស់តតិយជន Z ហេតុនេះ Z អាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន (មាត្រា ៣៦៥ នៃក្រមនីតិវិធី)បាន។ |

[49] កថាខ័ណ្ឌទី៣ មាត្រា ៥១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ឧទាហរណ៍ ១០

ផ្ទុយទៅវិញ ប្រសិនបើកម្មសិទ្ធិករដែលបានចុះបញ្ជីដី គឺជា Y ហើយម្ចាស់បំណុលរបស់ Y គឺ X បានដាក់ពាក្យសុំរឹបអូសដី នោះតុលាការអនុវត្តអាចចេញដីកាសម្រេចអនុវត្តដោយបង្ខំរឹបអូសដីបាន មិនថាអ្នកណាជាកម្មសិទ្ធិករនៃដីនោះទេ។ ក្នុងករណីនេះ ទោះបីជាកម្មសិទ្ធិករពិតប្រាកដមិនមែនជា Y នោះទេ ប៉ុន្តែបែរជា Z ក៏ដោយ ក៏ដីកាសម្រេចនៅតែស្របច្បាប់ដែរ ព្រោះ X បានដាក់នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី មានឈ្មោះរបស់ Y ត្រូវបានចុះបញ្ជីដីធ្លីថាជាកម្មសិទ្ធិករ។ ដូច្នេះ Z មិនអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៩៤ នៃក្រមនីតិវិធី) បានទេ ពីព្រោះមិនមានកំហុសនីតិវិធីក្នុងការអនុវត្ត ប៉ុន្តែអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនបាន (មាត្រា ៣៦៥ នៃក្រមនីតិវិធី) ដោយផ្អែកទៅលើភាពជាម្ចាស់កម្មសិទ្ធរបស់គាត់។

## ៨. ករណីសិក្សា

ក្នុងនេះយើងខ្ញុំសូមលើកយកឧទាហរណ៍មួយចំនួនមកធ្វើការបង្ហាញដោយផ្តោតសំខាន់តែទៅលើសិទ្ធិ និងផលប្រយោជន៍របស់តតិយជនប៉ុណ្ណោះ។

នៅក្នុងករណីដូចខាងក្រោមនេះ X គឺជាម្ចាស់បំណុលនៃការអនុវត្ត, Yគឺជាកូនបំណុលនៃការអនុវត្ត ហើយ Z គឺជាតតិយជន។

- ចំណុចទី១. តើតតិយជន (Z) មានសិទ្ធិដែលរងការប៉ះពាល់ដោយសារការអនុវត្តដោយបង្ខំ ឬការអនុវត្តរក្សាការពារដែរឬទេ?
- ចំណុចទី២. តើសិទ្ធិនោះអាចតតាំងចំពោះម្ចាស់បំណុលដែលបានរឹបអូសទ្រព្យសម្បត្តិ ដែរឬទេ?

**ករណីសិក្សាទី ១៖ ចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល**

Z បានជួលម៉ាស៊ីនកូពីមួយឲ្យទៅ Y។ X ដែលជាម្ចាស់បំណុលរបស់ Y បានដាក់ពាក្យសុំរឹបអូសម៉ាស៊ីនកូពីដែលបានកាន់កាប់ដោយ Y។ អាជ្ញាសាលាបានរឹបអូស និងបានយកម៉ាស៊ីនកូពីនោះចេញ។

***<u>បំណកស្រាយ៖</u>***

ក្នុងឧទាហរណ៍ខាងលើនេះ យើងសន្មតថា X ដែលជាម្ចាស់បំណុលរបស់ Y បានអនុវត្តស្របតាមខ្លឹមសារនៃមាត្រា ៣៨៩នៃក្រមនីតិវិធីរដ្ឋប្បវេណីក្នុងការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។ ដោយសារតែ ម៉ាស៊ីនកូពី គឺជាចលនវត្ថុ ហេតុនេះច្បាប់ពុំបានតម្រូវឲ្យម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់លំអិតនូវវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះឡើយ ដោយគ្រាន់តែបញ្ជាក់អំពីទីកន្លែងដែលចនវត្ថុត្រូវរឹបអូសតែប៉ុណ្ណោះ។ ចំពោះម៉ាស៊ីនកូពីនេះទៀតសោតគឺ Y ជាអ្នកកាន់កាប់ មាន

ន័យថា កាន់កាប់ដោយផ្ទាល់ ដូចនេះនៅពេលអាជ្ញាសាលាបានចូលទៅអនុវត្តរឹបអូស នោះអាជ្ញាសាលាបានយកម៉ាស៊ីនកូពីនោះចេញដើម្បីកាន់កាប់ដោយខ្លួនឯង។
ក៏ប៉ុន្តែបើសិនជាអាជ្ញាសាលាយកម៉ាស៊ីនកូពីនោះចេញ វានឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់តតិយជន (Z) ពីព្រោះថា Y ពុំមែនជាម្ចាស់កម្មសិទ្ធិនោះទេ គាត់ជួលពីតតិយជន (Z)។

ដោយហេតុថា ជាគោលការណ៍ ការរឹបអូសចលនវត្ថុ គឺត្រូវធ្វើឡើងចំពោះតែចលនវត្ថុណាដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តប៉ុណ្ណោះ ក៏ប៉ុន្តែកម្មសិទ្ធិនៃចលវត្ថុពិបាកដឹងណាស់បើសិនមើលតែពីសំបកក្រៅ ម្យ៉ាងទៀតច្បាប់បានសន្មតថា អ្នកដែលកាន់កាប់ក្តាប់ទុកចលនវត្ថុ គឺជាម្ចាស់កម្មសិទ្ធិ ហេតុនេះ បើ Y កាន់កាប់ម៉ាស៊ីនកូពី នោះនឹងត្រូវបានគេគិតថា គាត់គឺជាម្ចាស់កម្មសិទ្ធិ។ បើមានការរឹបអូសមែន នោះតតិយជន (Z) អាចប្រើសិទ្ធិក្នុងនាមជាកម្មសិទ្ធិករលើម៉ាស៊ីនកូពី ដើម្បីប្តឹងតវ៉ាក្នុងឋានៈជាតតិយជន ក្នុងការទាមទារការហាមឃាត់ការអនុវត្តដោយបង្ខំ ដោយផ្អែកលើភស្តុតាងបង្ហាញថា Z គឺជាកម្មសិទ្ធករពិតប្រាកដនៃម៉ាស៊ីនកូពី។

**ករណីសិក្សាទី ២៖ ចលនវត្ថុដែលកាន់កាប់ដោយតតិយជន**

Y បានជួលម៉ាស៊ីនកូពីមួយឲ្យទៅ Z។ X ដែលជាម្ចាស់បំណុលរបស់ Y បានដាក់ពាក្យសុំរឹបអូសម៉ាស៊ីនកូពីដែល Z បានកាន់កាប់ ហើយអាជ្ញាសាលាបានមកកន្លែងរបស់ Z។ ទោះបីជា Z បានបដិសេធមិនឲ្យធ្វើការរឹបអូសម៉ាស៊ីនកូពីរបស់អាជ្ញាសាលាក៏ដោយ ក៏អាជ្ញាសាលាបានរឹបអូសម៉ាស៊ីនកូពី និងបានយកវាចេញហើយដែរ។

***<u>បំណកស្រាយ៖</u>***

ការរឹបអូសដោយអាជ្ញាសាលាគឺជាការខុសច្បាប់ដោយសារតែអាជ្ញាសាលាមិនអាចអនុវត្តការរឹបអូសលើទ្រព្យសម្បត្តិកាន់កាប់ដោយតតិយជនបានទេប្រសិនបើតតិយជនបានបដិសេធមិនប្រគលចលនវត្ថុ (CCP៣៨៦)។ ដូច្នេះ Z អាចដាក់បណ្តឹងតវ៉ាចំពោះការអនុវត្ត (CCP៣៩៤) និងទាមទារឲ្យមានការលុបចោលនៃការអនុវត្តដោយបង្ខំ។

**ករណីសិក្សាទី ៣៖ ការលក់ចលនវត្ថុ**

Y បានលក់ម៉ាស៊ីនកូពីមួយឲ្យ Z។ មុនពេល Y ប្រគល់ម៉ាស៊ីនកូពីទៅឲ្យ Z X ដែលជាម្ចាស់បំណុលរបស់ Y បានដាក់ពាក្យសុំរឹបអូសម៉ាស៊ីនកូពីដែលនៅក្រោមការកាន់កាប់របស់ Y។ អាជ្ញាសាលាបានរឹបអូស និងបានយកម៉ាស៊ីនកូពីចេញ។

*បំណកស្រាយ៖*

តាមស្មារតីនៃមាត្រា១៣៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី បានកំណត់អំពីការធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ ឬការធ្វើអនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុទៅបុគ្គលណាមួយ មិនអាចតតាំងនឹងតតិយជនបានឡើយ បើមិនបានផ្ទេរការកាន់កាប់ចលនវត្ថុទៅបុគ្គលនោះ។ មានន័យថាលទ្ធកម្មកម្មសិទ្ធិលើសិទ្ធិប្រត្យក្សនៃចលនវត្ថុ អាចតតាំងជាមួយតតិយជនបានលុះត្រាតែបានផ្ទេរការកាន់កាប់។

ក្នុងករណីសិក្សាខាងលើនេះ ឃើញថា Y នៅមិនទាន់បានប្រគល់ម៉ាស៊ីនកូពីទៅ Z នៅឡើយ មានន័យថា Y កំពុងកាន់កាប់ម៉ាស៊ីនកូពី។ ហេតុនេះការធ្វើលទ្ធកម្មកម្មសិទ្ធិរបស់ Z មិនអាចតតាំងជាមួយ X បានឡើយ។ ហេតុដូច្នេះ បណ្ដឹងតវ៉ារបស់តតិយជនរបស់ Z នឹងត្រូវបានលើកចោល។

**ករណីសិក្សាទី ៤៖ អចលនវត្ថុដែលបានចុះបញ្ជីក្រោមឈ្មោះរបស់កូនបំណុល**

Z មានដីមួយកន្លែង។ Y បានក្លែងបន្លំឯកសារ និងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិដីពី Z ទៅ Y ដោយពុំឲ្យ Z ដឹង។ X ដែលជាម្ចាស់បំណុលរបស់ Y បានដាក់ពាក្យសុំរឹបអូសដីដែលបានចុះបញ្ជីក្រោមឈ្មោះរបស់ Y ហើយតុលាការអនុវត្តបានចេញដីកាសម្រេចរឹបអូសដីនោះ។

*បំណកស្រាយ៖*

X បានដាក់ឯកសារបញ្ជាក់ចម្លងនៃសៀវភៅចុះបញ្ជីដីធ្លី ដែល Y បានចុះបញ្ជីជាកម្មសិទ្ធិករនៃដីនេះ។ ហេតុនេះហើយបានជាសំណើរបស់ X អនុលោមតាម CCP៥១៧-៣។

ក៏ប៉ុន្តែសិទ្ធិរបស់តតិយជន Z ត្រូវបានទទួលរងផលប៉ះពាល់ដោយសារការដាក់ពាក្យសុំអនុវត្តរបស់ X ពីព្រោះថា ដីនោះត្រូវបាន Y ក្លែងបន្លំឯកសារ និងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិដីពីតតិយជន Z ទៅ Y។ ហេតុនេះ តតិយជន Z អាចដាក់ពាក្យបណ្ដឹងតវ៉ាក្នុងនាមជាតតិយជនបាន ដោយធ្វើការអះអាងអំពីសិទ្ធិកម្មសិទ្ធិរបស់ Z ដែលជាកម្មវត្ថុនៃការប្ដឹងតវ៉ា (មាត្រា៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ តតិយជន Z អាចទាមទារការហាមឃាត់ការអនុវត្តដោយបង្ខំដែលមានមូលដ្ឋានលើកម្មសិទ្ធិនោះ។

ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានអនុវត្តចប់(ឈានដល់ការចែកចំណែក)នោះតតិយជន Z មិនអាចប្ដឹងតវ៉ារបស់តតិយជនបានទេ ពីព្រោះគ្មានផលប្រយោជន៍នៃការធ្វើបណ្ដឹងទេ (មាត្រា ៧៤ នៃក្រមនីតិវិធី) តែតតិយជន Z អាចដាក់បណ្ដឹងទាមទារពី Y ក្នុងនីតិវិធីបណ្ដឹងធម្មតាទាក់ទងនឹងសេចក្ដីចម្រើនឥតហេតុដោយសារទ្រព្យរបស់ Z ត្រូវបាន Yយកទៅសងបំណុល។

**ករណីសិក្សាទី ៥៖ ការលក់អចលនវត្ថុ**

Y បានលក់ដីមួយកន្លែងទៅឲ្យ Z ក៏ប៉ុន្តែ នៅមុនពេល Y បានផ្ទេរការចុះបញ្ជីកម្មសិទ្ធិដីទៅឲ្យ Z X បានដាក់ពាក្យសុំរឹបអូសដី។ តុលាការអនុវត្តបានចេញដីកាសម្រេចរឹបអូសដី ដែលត្រូវបានចុះបញ្ជីក្រោមឈ្មោះរបស់ Y។

*បំណកស្រាយ៖*

បើយោងទៅតាម CC135 Z បានមិនបានទទួលភាពជាម្ចាស់កម្មសិទ្ធនៃដីបានទេ។ ដូច្នេះ Z មិនមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនឡើយ។ បើដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនពេលនោះតុលាការអនុវត្តនឹងលើកចោលពាក្យបណ្តឹងនោះ។

**ករណីសិក្សាទី ៦៖ ហ៊ីប៉ូតែក**

Y មានដីមួយកន្លែង។ Y បានបង្កើតហ៊ីប៉ូតែកលើដីសម្រាប់ Z ហើយហ៊ីប៉ូតែកនោះត្រូវបានចុះបញ្ជី។ X ដែលជាម្ចាស់បំណុលរបស់ Y បានដាក់ពាក្យសុំរឹបអូសដី។ តុលាការអនុវត្តបានចេញដីកាសម្រេចរឹបអូសដី ដែលត្រូវបានចុះបញ្ជីក្រោមឈ្មោះរបស់ Y និងហ៊ីប៉ូតែដែលត្រូវបានចុះបញ្ជីសម្រាប់ Z។

*បំណកស្រាយ៖*

- សិទ្ធិរបស់តតិយជន Z មិនទទួលរងនូវផលប៉ះពាល់ដោយពាក្យស្នើសុំការអនុវត្តដោយបង្ខំឡើយ ដោយសារតែហ៊ីប៉ូតែមានអានុភាពឡើងវិញបន្ទាប់ពីការអនុវត្តដោយបង្ខំ)CCP៤៣១(១-។ ហេតុដូច្នេះហើយបណ្តឹងតវ៉ារបស់តតិយជន Z នឹងត្រូវលើកចោល។

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី១១

## ប្រធានបទ៖ ការរៀបចំពាក្យបណ្ដឹង និងឯកសារត្រៀម

ថ្ងៃទី ០៣ មីនា ២០១៦

# ការរៀបចំពាក្យបណ្ដឹង និងឯកសារត្រៀម

## មាតិកា

I. **ការពន្យល់ទូទៅ**

II. **ការរៀបចំពាក្យបណ្ដឹង**

១-ការស្វែងយល់អំពីអង្គហេតុចម្បង

២-ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

III. **ការរៀបចំឯកសារត្រៀម និងឯកសារចម្លើយ**

១- ការស្វែងយល់អំពីអង្គហេតុចម្បង

២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀមនិងឯកសារចម្លើយ




រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

## លំហូរនីតិវិធីនៃការជំនុំជម្រះលើកទី១




## ២ - ប្រភេទនៃបណ្ដឹង

① **បណ្ដឹងទាមទារឲ្យផ្ដល់តាវការលិក**

② **បណ្ដឹងទាមទារឲ្យបញ្ជាក់**

③ **បណ្ដឹងទាមទារឲ្យបង្កើត កែប្រែ និង រំលត់ទំនាក់ទំនងគតិយុត្ត**

### ① បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក

☞ ជាបណ្ដឹង ដែលទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ ឲ្យចុងចម្លើយផ្ដល់តាវកាលិក កំណត់មួយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារតាមផ្លូវច្បាប់សារធាតុរបស់ដើមចោទ។

☞ បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក មានដូចជា បង់ប្រាក់ ប្រគល់វត្ថុ ឲ្យធ្វើ ឬមិនឲ្យធ្វើសកម្មភាពអ្វីមួយ។

### ① បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក

ឧទាហរណ៍

(១) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន១០០០ដុល្លារឲ្យដើមចោទ

(២) បង្គាប់ឲ្យចុងចម្លើយ ប្រគល់វត្ថុដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធមកឲ្យដើមចោទ

(៣) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីផ្ទេរចុះបញ្ជីទាំងមូលលើដីដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ ដោយមូលហេតុលក់ទិញ នៅថ្ងៃទី ០១ ខែ ០២ ឆ្នាំ ២០១៦ មកឲ្យដើមចោទ

## ① បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

(៤) ហាមឃាត់ចុងចម្លើយមិនត្រូវធ្វើឲ្យមានសម្លេងរំខានដែលធំជាង៨0dBពីម៉ោង៦ ល្ងាច ដល់ម៉ោង ៦ ព្រឹក នៅទីតាំង(អត្តសញ្ញាណនៃអចលនវត្ថុ)របស់ដើមចោទពីខាងក្រៅ។

- ❖ យើងអាចសម្គាល់បណ្តឹងទាមទារឲ្យផ្តល់តាមវកាលិកតាមរយៈ ពាក្យបង្គាប់ឲ្យ /ហាមឃាត់ ដែលត្រូវសរសេរនៅក្នុងបណ្តឹង ។

## ① បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក

❖ ការប្រើពាក្យ

បង្គាប់ឲ្យ

ហាមឃាត់ (ករណីមិនឲ្យធ្វើសកម្មភាពអ្វីមួយ)

ផ្អែកលើគោលគំនិតរបស់ប្រទេសកម្ពុជា ។

❖ នៅប្រទេសជប៉ុន ខ្លឹមសារនៃសាលក្រមចំពោះបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកពុំមានពាក្យថា បង្គាប់ឲ្យ /ហាមឃាត់ទេ គេសរសេរថា ចុងចម្លើយត្រូវបង់ប្រាក់ / ចុងចម្លើយមិនត្រូវធ្វើឲ្យមានសំលេងរំខាន.....។




## ② បណ្តឹងទាមទារឲ្យបញ្ជាក់

☞ ជាបណ្តឹងដែលទាមទារឲ្យតុលាការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិតាមច្បាប់សារធាតុ។

☞ការសំគាល់បណ្តឹងទាមទារឲ្យបញ្ជាក់ ៖

បញ្ជាក់អំពីសិទ្ធិ

បញ្ជាក់អំពីទំនាក់ទំនងគតិយុត្តិ

បញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច

## ② បណ្តឹងទាមទារឲ្យបញ្ជាក់

- **ឧទាហរណ៍៖**

<u>បណ្តឹងទាមទារបញ្ជាក់អំពីសិទ្ធិ</u>

❖បញ្ជាក់ថា ដើមចោទមានកម្មសិទ្ធិលើដីដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធ។

<u>បណ្តឹងទាមទារឲ្យបញ្ជាក់ទំនាក់ទំនងគតិយុត្ត</u>

❖បញ្ជាក់ថា ដើមចោទ មិនមែនជាកូនរបស់ចុងចម្លើយ (មាត្រា១០០២ នៃCC)។

## ② បណ្តឹងទាមទារឲ្យបញ្ជាក់

<u>បណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច</u>

បញ្ជាក់ថា កាតព្វកិច្ចរបស់ចុងចម្លើយ ក្នុងការសងប្រាក់ចំនួន២០០០ដុល្លារ ឲ្យដើមចោទ ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគរវាង ដើមចោទ និងចុងចម្លើយចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៥ ពុំមានអត្ថិភាព។




## ② បណ្តឹងទាមទារឲ្យបញ្ជាក់

☞ សាលក្រមបញ្ជាក់ពុំមានអានុភាពអនុវត្តទេ លើកលែង តែសាលក្រមបញ្ជាក់អំពីសិទ្ធិប្រាតិភោគដែលមានបញ្ញត្តិនៅក្នុងមាត្រា ៤៩៦ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ③ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ និង រំលត់ទំនាក់ទំនងគតិយុត្ត

☞ ជាបណ្តឹង ទាមទារឲ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត ដែលមានកំណត់តាមផ្លូវច្បាប់សារធាតុ ។

❖ <u>បណ្តឹងទាមទារឲ្យបង្កើតទំនាក់ទំនងគតិយុត្តិ</u>

ឧទាហរណ៍ បណ្តឹងទាមទារឲ្យទទួលស្គាល់កូន (មាត្រា១០០១ នៃCC)

ខ្លឹមសារនៃសាលក្រមសរសេរថា *ទទួលស្គាល់ដើមចោទ X ជាកូនរបស់ ចុងចម្លើយ Y* ។

## ③ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ និង រំលត់ទំនាក់ទំនងគតិយុត្ត

❖ <u>បណ្តឹងទាមទារឲ្យកែប្រែទំនាក់ទំនងគតិយុត្តិ</u>

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាមានចែង បណ្តឹងទាមទារឲ្យបង្កើត និង រំលត់ទំនាក់ទំនងគតិយុត្ត ដូចជា លែងលះ (មាត្រា ៩៧៨), កាត់កាល់កូនសុំ (មាត្រា ១០៣១), ទទួលស្គាល់កូន (មាត្រា ១០០១),សិទ្ធិលុបចោលអំពើដែលនាំឲ្យខូចផលប្រយោជន៍ (មាត្រា ៤២៨)។

## ③ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្ត

ចំពោះបណ្តឹងទាមទារឲ្យកែប្រែទំនាក់ទំនងគតិយុត្តពុំមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែមានមាត្រាមួយចំនួនមានលក្ខណៈដូចបណ្តឹងទាមទារឲ្យកែប្រែ ដូចជាមាត្រា ២៤៩(មាត្រានេះ គឺអាស្រ័យទៅលើការបកស្រាយ តែមានមតិភាគច្រើនថាវាជាបណ្តឹងកែប្រែ), មាត្រា ៦០៧។ ប៉ុន្តែ មាត្រានេះ ពុំតម្រូវឲ្យកែប្រែតាមផ្លូវតុលាការនោះទេ ហេតុនេះ វាពុំមែនជាបណ្តឹងទាមទារឲ្យកែប្រែនោះទេ។

## ③ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្ត

❖បណ្តឹងទាមទារឲ្យរំលត់ទំនាក់ទំនងគតិយុត្ត

ឧទាហរណ៍ **បណ្តឹងលែងលះ**

ខ្លឹមសារនៃសាលក្រម សរសេរថា ឲ្យដើមចោទ Xលែងលះ ពីចុងចម្លើយ Y ។

## ③ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ និង រំលត់ទំនាក់ទំនងគតិយុត្ត

☞ លក្ខណៈសំគាល់ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្ត ៖

(១) មិនបង្កើតអានុភាពបើ ពុំធ្វើតាមផ្លូវតុលាការ

ឧទាហរណ៍ ករណីលែងលះ

ហេតុនេះ ករណីដែលអាចទាមទារអនុវត្តសិទ្ធិក្រៅតុលាការបាន នោះវាមិនមែនជាបណ្តឹងទាមទារឲ្យបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្តទេ ដូចជា មាត្រា ៦០៧នៃ CC។

## ③ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ និង រំលត់ទំនាក់ទំនងគតិយុត្ត

(២) បណ្តឹងទាមទារឲ្យបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលដើមចោទត្រូវដាក់ភស្តុតាង និង អះអាងអំពីល័ក្ខខ័ណ្ឌកំណត់មួយ ដូចមានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ មាត្រាខ្លះនៅក្នុងក្រមរដ្ឋប្បវេណី ដូចជាមាត្រា២១២ មើលទៅមានលក្ខណៈដូចជា បណ្តឹងទាមទារឲ្យបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្ត ប៉ុន្តែ មាត្រានេះពុំមានចែងច្បាស់ឲ្យដើមចោទអះអាងល័ក្ខខ័ណ្ឌនឹងដាក់ភស្តុតាងឡើយ។

## ③ បណ្តឹងទាមទារឲ្យបង្កើត កែប្រែ និង រំលត់ទំនាក់ទំនងគតិយុត្ត

ផ្ទុយទៅវិញ មាត្រានេះគឺជាការសម្រេចដោយឆន្ទានុសិទ្ធិរបស់តុលាការ ហេតុនេះ វាមិនមែនជាបណ្តឹងទាមទារឲ្យបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្តឡើយ។




### ③ បណ្ដឹងទាមទារឲ្យបង្កើត កែប្រែ និង រំលត់ទំនាក់ទំនងគតិយុត្ត

☞ បណ្ដឹងបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្ត ភាគច្រើនគឺជាបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។

☞សាលក្រមបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្តពុំមានអានុភាពអនុវត្តទេ។

## ៣ - ទម្រង់នៃពាក្យបណ្ដឹង

**① ទម្រង់ពេញលេញនៃពាក្យបណ្ដឹង**
**② ចំណុចជាច់ខាតនៃពាក្យបណ្ដឹង**
**③ ចំណុចមិនដាច់ខាតនៃពាក្យបណ្ដឹង**

### ① ទម្រង់ពេញលេញនៃពាក្យបណ្ដឹង

☞ ពាក្យបណ្ដឹង ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដាក់ទៅតុលាការ (មាត្រា៧៥ កថាខណ្ឌទី ១ នៃ CCP) ។ ប៉ុន្តែ ចំពោះករណីរឿងក្ដីចំនួនទឹកប្រាក់តិចពាក្យបណ្ដឹងអាចធ្វើដោយផ្ទាល់មាត់បាន (មាត្រា២២៥ កថាខណ្ឌទី១ នៃCCP

☞ ពាក្យបណ្ដឹង ត្រូវសរសេរនូវចំណុចដូចខាងក្រោម៖



## ② ចំណុចដាច់ខាតនៃពាក្យបណ្តឹង

☞ ជាទូទៅ ពាក្យបណ្តឹងគួរតែសរសេរឲ្យបានពេញលេញដូចមានចែងនៅក្នុងមាត្រា៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែនៅក្នុងមាត្រានោះ មិនមែនដាច់ខាតត្រូវតែសរសេរទាំងអស់នោះទេ មានចំណុចខ្លះ ដើមចោទមិនចាំបាច់សរសេរនៅក្នុងពាក្យបណ្តឹងក៏បាន ចាំអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏បាន ហើយក៏មានចំណុចខ្លះដែលតម្រូវឲ្យសរសេរជាដាច់ខាតផងដែរ។

☞ ចំណុចដែលត្រូវសរសេរដាច់ខាត ៖






**③ ចំណុចមិនដាច់ខាតនៃពាក្យបណ្ដឹង**

☞ចំណុចទាំង៣ខាងលើ ក្នុងករណី មិនបានសរសេរនៅក្នុងពាក្យបណ្ដឹងក៏តុលាការមិនបង្គាប់ឲ្យកែតម្រូវដែរ ពីព្រោះមាត្រា៧៥ កថាខណ្ឌទី៣និងទី៤ នៃ CCP មិនតម្រូវដាច់ខាតនោះទេ ។ ប៉ុន្តែដើម្បីឲ្យមានភាពងាយស្រួល ជាពិសេសឲ្យតុលាការ អាចយល់ដឹងបាន គួរតែសរសេរឲ្យបានពេញលេញ។


ដាក់ពាក្យបណ្ដឹង
នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
ការទាញហេតុផលដោយផ្ទាល់មាត់
ប្រកាសសាលក្រម
①
②
③
④
ការទាមទារ
ការអះអាង
ការពិនិត្យភស្តុតាង


ពិនិត្យពាក្យបណ្ដឹងតាមមាត្រា ៧៨ នៃ CCP
ពាក្យបណ្ដឹង
ពាក្យបណ្ដឹង
ឯកសារចម្លើយ
②
ដីកាបង្គាប់ឲ្យកែតម្រូវ
①

# ៤ - ទម្រង់នៃឯកសារត្រៀម និងឯកសារចម្លើយ




## ការរៀបចំពាក្យបណ្តឹង

## II. ការរៀបចំពាក្យបណ្តឹង

**១- ការស្វែងយល់អំពីអង្គហេតុចម្បង**

**២- ការស្វែងយល់អំពីចំណុចនីមួយៗដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹង**

### ១- ការស្វែងយល់អំពីអង្គហេតុចម្បង

☞ អង្គហេតុចម្បង គឺជាអង្គហេតុលំអិតដែលត្រូវនឹងល័ក្ខខ័ណ្ឌច្បាប់ ហើយនាំឲ្យកើតមាននូវអានុភាពគតិយុត្ត។

☞ ប្រភេទនៃអង្គហេតុចម្បង

- អង្គហេតុកើតឡើងសិទ្ធិ
- អង្គហេតុរាំងសិទ្ធិ
- អង្គហេតុរលត់សិទ្ធិ
- អង្គហេតុទប់ស្កាត់សិទ្ធិ




## ២- ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

(១) អត្តសញ្ញាណរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ក នៃ CCP)

ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី

ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

តើពាក្យបណ្ដឹងត្រូវសរសេរអំពីទីកន្លែងបញ្ជូនឬទេ?

## ២- ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

(២) ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ (មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ នៃCCP)

☞ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ គឺជាការដែលដើមចោទសុំឲ្យតុលាការចេញសេចក្តីសម្រេចបញ្ចប់នៃសាលក្រម។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

☞ ឧទារហណ៍

- បង្គាប់ឲ្យចុងចម្លើយ បង់ប្រាក់ចំនួន១០០០ដុល្លារឲ្យដើមចោទ
- បង្គាប់ឲ្យចុងចម្លើយ ប្រគល់អចលនវត្ថុដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធមកឲ្យ
- ដើមចោទ

☞ នៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ មិនត្រូវសរសេរអំពីលក្ខណៈនៃសិទ្ធិជាសារធាតុឡើយ។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

ឧទាហរណ៍៖ បង្គាប់ឲ្យចុងចម្លើយ បង់ប្រាក់ចំនួន១០០០ ដុល្លារឲ្យដើមចោទ ~~ផ្អែកលើកិច្ចសន្យាលក់ទិញ~~ ។

(ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការ

ចេញធ្វើយ៉ាងណាឲ្យខ្លី និងមានភាពងាយស្រួលយល់)។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

ករណីលើកលែង៖

<u>ករណីផ្ទេរចុះបញ្ជី</u>

បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលមានកំណាត់នៅក្នុង ឧបសម្ព័ន្ធឲ្យដើមចោទ *ដោយ*

*មូលហេតុនៃការលក់ទិញ ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៥*។

ប្រការ ២៨ ចំណុច ក នៃប្រកាសអន្តរក្រសួង ស្តីពីការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រម រដ្ឋប្បវេណី

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

<u>ករណីបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច</u>

បញ្ជាក់ថា កាតព្វកិច្ចរបស់ចុងចម្លើយ ក្នុងការសងប្រាក់

ចំនួន២០០០ដុល្លារ ឲ្យដើមចោទ *ផ្អែកលើកិច្ចសន្យា ខ្ចី*

***បរិភោគរវាង ដើមចោទ និងចុងចម្លើយចុះថ្ងៃទី ០៦ ខែ***

***មិថុនា ឆ្នាំ២០១៥*** ពុំមានអត្ថិភាព។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

☞ នៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ មានការទាមទារ ចម្បង និងអាចមានការទាមទារបន្ទាប់បន្សំ ។

☞ ការទាមទារចម្បងអាចមានមួយ ឬ មានច្រើនស្របតាមរឿងក្តីនីមួយៗ ឧទាហរណ៍ ករណី ទាមទារប្រាក់កម្ចី ៖

ការទាមទារចម្បងមានតែមួយចំណុចទេ គឺ ការទាមទារប្រាក់ដើម។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

ករណីការទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ

ការទាមទារចម្បងមានៈ ឲ្យចុងចម្លើយធ្វើនីតិវិធីផ្ទេរចុះ

បញ្ជី និងទាមទារឲ្យប្រគល់វត្ថុ។

☞ ការទាមទារបន្ទាប់បន្សំមានៈ ការទាមទារការប្រាក់ ការ

ប្រាក់យឺតយ៉ាវ។

- ប្រាក់ប្រដាប់ក្តី គឺ ទោះបី ភាគីមិនទាមទារក៏តុលាការត្រូវតែសម្រេចឲ្យដែរ។

- ការប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន គឺភាគីគ្រាន់តែធ្វើការទាមទារ តែវាជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការធ្វើសេចក្តីសម្រេចទៅលើការទាមទារនេះ។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

(៣) អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ (មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ នៃCCP)

☞អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុដែលជាមូលដ្ឋាន ឬ សំអាងចំពោះការទាមទារ ប៉ុន្តែ មិនមែនជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

ឧទាហរណ៍ ទាមទារឲ្យបង់ថ្លៃផ្អែកលើកិច្ចសន្យាលក់ទិញ

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺ

**កិច្ចសន្យាលក់ទិញរថយន្ត Lexus មួយគ្រឿងសេរី**

**ឆ្នាំ ២០១៥ តម្លៃ ៥០០០០ដុល្លារ រវាង Xនិង Yនៅនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦។**

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

ឧទាហរណ៍៖ ទាមទារសំណងនៃការខូចខាតផ្អែកលើអំពើអនីត្យានុកូល អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ៖ គឺ Aបានជិះ ម៉ូតូបុកB បណ្តាលឲ្យB ខូចខាតម៉ូតូ និងរងរបួសក្បាល នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥ វេលាម៉ោង ១០ ពេលព្រឹក។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

នៅក្នុងមាត្រា៧៥ កថាខណ្ឌទី ២ បានបញ្ញត្តិបញ្ចូលគ្នារវាងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ប៉ុន្តែ ជាក់ស្តែង គេមិនសរសេរ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារនៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញទេ ពោលគឺ សរសេរនៅកន្លែងផ្សេងគ្នា ។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

☞ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ស្ទើរតែដូចគ្នានឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហេតុនេះ គេសរសេរចូលជាមួយអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

ពីព្រោះក្នុងករណីបានសរសេរ អង្គហាតុដែលជាមូលហេតុនៃការទាមទារ ជាស្វ័យប្រវត្តិ នឹងមានអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ នាំឲ្យគ្មានប្រយោជន៍ក្នុងការបែងចែក និងសរសេរផ្សេងពីគ្នានោះទេ ផ្ទុយទៅវិញ នាំឲ្យមានការសរសេរដដែលៗ។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

**(៤) អង្គហេតុដែលជាមូលហេតុនៃការទាមទារ (មាត្រា៧៥ កថាខណ្ឌ៣ នៃCCP)**

☞ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុចម្បង

ដែលអះអាងដោយដើមចោទដើម្បីឲ្យកើតឡើងនូវសិទ្ធិទាមទារ។

☞ ឧទាហរណ៍ ករណីខ្ចីប្រាក់

អង្គហេតុដែលកើតឡើងនូវសិទ្ធិទាមទារឲ្យសងវិញ មាត្រា ៥៧៨ និង

៥៩១ នៃCC៖

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

❶ ការព្រមព្រៀង

❷ ការប្រគល់ប្រាក់

❸ កំណាត់ពេលសងបានមកដល់

(អង្គហេតុបង្កើតនូវសិទ្ធិ)

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

☞ ឧទាហរណ៍ <u>ករណីទាមទារសំណងនៃការខូចខាតផ្អែកលើអំពើអនីត្យានុកូល</u>

អង្គហេតុកើតឡើងនូវសិទ្ធិទាមទារសំណងនៃការខូចខាត ផ្អែកតាមមាត្រា ៧៤២ ៧៤៣ ៧៥៧ ៖

❶ អំពើបំពានសិទ្ធិ ឬ ផលប្រយោជន៍របស់ដើមចោទ

❷ កំហុស

❸ ការខូចខាត

❹ ទំនាក់ទំនងហេតុ និងផលរវាង ចំណុច និងចំណុច

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

☞ ឧទាហរណ៍ <u>**ករណីទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយមូលហេតុលក់ទិញ**</u>

អង្គហេតុកើតឡើងនូវសិទ្ធិទាមទារឲ្យផ្ទេរចុះបញ្ជីផ្ទេរកម្មសិទ្ធិ ផ្អែកតាមមាត្រា៣៣៦ កថាខណ្ឌទី២ នៃCC៖

❶ ការព្រមព្រៀងលក់ទិញ

❷ ការព្រមព្រៀងធ្វើឡើងដោយលិខិតយថាភូត

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

**(៥) អង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ (មាត្រា៧៥ កថាខណ្ឌទី៣ នៃCCP)**

☞ ជាអង្គហេតុ ប្រយោលដែលគេប្រើនៅពេលដែលពុំមានភស្តុតាងដោយផ្ទាល់ដើម្បីធ្វើការបញ្ជាក់អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

•

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

☞ ឧទាហរណ៍ <u>ករណីការទាមទារសំណងនៃការខូចខាតផ្អែកលើ អំពើអនីត្យានុកូល</u>

នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដើមចោទត្រូវចុងចម្លើយដាល់មួយដៃចំាមុខ ក្នុងករណីនេះ ពុំមានភស្តុតាងដោយផ្ទាល់ដែលបង្ហាញពីសកម្មភាព ដែលចុងចម្លើយដាល់ដើមចោទនោះទេ ករណីនេះ ដើមចោទអាចអះអាងអង្គហេតុប្រយោលដូចខាងក្រោមដើម្បីបញ្ជាក់ពីអង្គហេតុវាយនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ៖

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

❖ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ចុងចម្លើយមកលេងផ្ទះរបស់ដើមចោទ
❖ ពេលចុងចម្លើយចេញពីផ្ទះរបស់ដើមចោទ មុខរបស់ដើមចោទមានរបួស
❖ នៅពេលដែលចុងចម្លើយមកលេងផ្ទះដើមចោទ ពុំមានអ្នកផ្សេងក្រៅពីដើមចោទ និង ចុងចម្លើយទេ។

## ② ការស្វែងយល់អំពីចំណុចនីមួយៗដែល ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង

### (៦) ភស្តុតាង (មាត្រា៧៥ កថាខណ្ឌទី៤ នៃCCP)

☞ តាមមាត្រា៧៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពុំតម្រូវឲ្យដើមចោទទៅភ្ជាប់ជាមួយនឹងភស្តុតាងទេ ប៉ុន្តែដើម្បីងាយស្រួលឲ្យតុលាការបានយល់ ដើមចោទ គួរតែ ភ្ជាប់ជាមួយ ភស្តុតាង ឬ សរសេរមធ្យោបាយការពារខ្លួននៅក្នុងពាក្យបណ្តឹង ។

☞ ភស្តុតាងដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃ

ការទាមទារៈលិខិតកិច្ចសន្យា វិក្កយប័ត្រជាអាទិ៍ ។



# ការរៀបចំឯកសារត្រៀម និង ឯកសារចម្លើយ

- ① ការស្វែងយល់អំពីអង្គហេតុចម្បង
- ② ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារ ចម្លើយ
- ③ ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារ ត្រៀម

☞ បើតុលាការពិនិត្យទៅ មានភាពត្រឹមត្រូវ តុលាការនឹងបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ ដោយកំណត់កាល

បរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១

ក្នុងអំឡុងពេល៣០ថ្ងៃគិតចាប់ពីថ្ងៃដែលបានទទួលពាក្យ

បណ្តឹង។

☞នៅក្នុងដីកាកោះដែលបញ្ជូនទៅចុងចម្លើយ តុលាការអាចកំណត់កាលបរិច្ឆេទក្នុងការដាក់ឯកសារចម្លើយបាន ក្នុងករណីនេះ ចុងចម្លើយត្រូវតែដាក់ឯកសារចម្លើយតាមការកំណត់របស់តុលាការ ។ ជាក់ស្តែងនៅកម្ពុជា តុលាការពុំដែលកំណត់កាលបរិច្ឆេទដាក់ឯកសារចម្លើយនោះទេ ហេតុនេះ ការដាក់ឯកសារចម្លើយជាមុនមានចំនួនតិចតួច។




**ឯកសារចម្លើយជាឯកសារដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង។**

### ❖ លំដាប់នៃការដាក់ឯកសារ

**★ ការដាក់ឯកសារជាធម្មតា**

ពាក្យបណ្តឹង (ដើមចោទធ្វើការដើមចោទធ្វើការទាមទារ និង អះអាង)

↓

ឯកសារចម្លើយ (ចុងចម្លើយធ្វើការឆ្លើយតបចំពោះពាក្យបណ្តឹង)

↓

ឯកសារត្រៀមលើកទី១ របស់ដើមចោទ (ដើមចោទធ្វើការឆ្លើយតបចំពោះឯកសារចម្លើយ)

↓

ឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ (ចុងចម្លើយធ្វើការឆ្លើយតបចំពោះឯកសារត្រៀមលើកទី១ របស់ដើមចោទ)

↓

ឯកសារត្រៀមលើកទី២ របស់ដើមចោទ (ដើមចោទធ្វើការឆ្លើយតបចំពោះឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ)

↓

ឯកសារត្រៀមលើកទី២ របស់ចុងចម្លើយ (ចុងចម្លើយធ្វើការឆ្លើយតបចំពោះឯកសារត្រៀមលើកទី២ របស់ដើមចោទ)

↓

(បន្ត)

### ❖ លំដាប់នៃការដាក់ឯកសារ

**★ ក្នុងករណីចុងចម្លើយខ្វះខាតក្នុងការដាក់ឯកសារ**

ពាក្យបណ្តឹង (ដើមចោទធ្វើការទាមទារ និង អះអាង)

↓

ឯកសារចម្លើយ (ចុងចម្លើយឆ្លើយតបចំពោះពាក្យបណ្តឹង)

↓

ឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ (ចុងចម្លើយធ្វើការបំពេញនូវខ្លឹមសារនៅក្នុងឯកសារចម្លើយ)

↓

ឯកសារត្រៀមលើកទី១ របស់ដើមចោទ (ដើមចោទធ្វើការឆ្លើយតបចំពោះឯកសារចម្លើយ និង ឯកសារត្រៀមទី១ របស់ចុងចម្លើយ)

↓

ឯកសារត្រៀមលើកទី២ របស់ចុងចម្លើយ(ចុងចម្លើយធ្វើការឆ្លើយបចំពោះឯកសារត្រៀមលើកទី១ របស់ដើមចោទ)

↓

ឯកសារត្រៀមលើកទី២ របស់ដើមចោទ (ដើមចោទធ្វើការឆ្លើយតបចំពោះឯកសារត្រៀមលើកទី២ របស់ចុងចម្លើយ )

↓

(បន្ត)

## ១- ការស្វែងយល់អំពីអង្គហេតុចម្បង

- ☞ ចុងចម្លើយ ត្រូវស្វែងយល់អំពីអង្គហេតុចម្បងដូចគ្នានឹងដើមចោទដែរ ប៉ុន្តែជាអង្គហេតុចម្បងដែលនាំឲ្យសិទ្ធិទាមទារ

របស់ដើមចោទបាត់បង់។ អង្គហេតុ រារាំង រលត់ និងទប់ស្កាត់សិទ្ធិ ជាអង្គហេតុចម្បង ដែលត្រូវអះអាងដោយចុងចម្លើយ ដើម្បីឆ្លើយតបអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

## ១- ការស្វែងយល់អំពីអង្គហេតុចម្បង

ឧទាហរណ៍ អង្គហេតុ ការសង ការលើកលែងបំណុល

ពន្យាពេលសង ការផុតរលត់អាជ្ញាយុកាលនៃសិទ្ធិលើ

បំណុល សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា មោឃភាពកិច្ចសន្យាជាអាទិ៍។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅ ក្នុងឯកសារចម្លើយ

(១) ការឆ្លើយតប ចំពោះការទាមទារនៃខ្លឹមសារនៃសាលាក្រមដែលសរសេរនៅក្នុងពាក្យបណ្តឹង

❖ ករណីមិនទទួលស្គាល់ការទាមទាររបស់ដើមចោទ៖ ត្រូវសរសេរថា ***ច្រានចោលការទាមទាររបស់ដើមចោទ***
(ទាំងអស់)

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅ ក្នុងឯកសារចម្លើយ

❖ ករណីទទួលស្គាល់ការទាមទាររបស់ដើមចោទ៖

ត្រូវសរសេរថា ***ទទួលស្គាល់ការទាមទាររបស់ដើមចោទ***

(ទាំងអស់) ។

❖តុលាការនឹងបញ្ចប់បណ្តឹងដោយកំណត់ហេតុ

ទទួលស្គាល់ការទាមទារដូចមានបញ្ញត្តិនៅក្នុងមាត្រា២២១

នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

(២) ការឆ្លើយតបចំពោះអង្គហេតុដែលមានសរសេរនៅក្នុង

ពាក្យបណ្តឹង

ការទទួលស្គាល់ ឬ មិនទទួលស្គាល់ ៖

១. ទទួលស្គាល់

២. មិនទទួលស្គាល់

៣. មិនដឹង

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

១. ទទួលស្គាល់

ក្នុងករណី ចុងចម្លើយទទួលស្គាល់ចំពោះអង្គហេតុដែលអះអាងដោយដើមចោទ អង្គហេតុនោះ គឺជាអង្គហេតុដែលត្រូវបានសារភាព ហេតុនេះ តុលាការត្រូវទទួលស្គាល់អង្គហេតុនោះដោយមិនចាំបាច់ពិនិត្យភស្តុតាង (មាត្រា ១២៣ កថាខណ្ឌទី២ នៃCCP)។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

២. មិនទទួលស្គាល់

ក្នុងករណីចុងចម្លើយមិនទទួលស្គាល់អង្គហេតុចម្បងដែលអះអាងដោយដើមចោទ នេះជាអង្គហេតុដែលមានវិវាទ ហេតុនេះ តុលាការត្រូវសម្រេចទទួលស្គាល់ ឬមិនទទួល

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

ស្គាល់នូវអង្គហេតុនោះដោយភស្តុតាង (មាត្រា១២៣ កថាខណ្ឌទី១ នៃCCP)។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

៣. មិនដឹង ត្រូវសន្មតថាអង្គហេតុនោះជាចំណុចវិវាទ

មាត្រា៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធី រដ្ឋប្បវេណី ដូច្នេះ

ករណីនេះដូចគ្នានឹងការមិនទទួលស្គាល់ដែរ ហេតុនេះ

តុលាការត្រូវកំណត់អត្ថិភាព ឬ នត្ថិភាព នៃអង្គហេតុដោយ

ភស្តុតាង។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

☞ ករណីមិនធ្វើអ្វីទាំងអស់ មិនឆ្លើយទទួលស្គាល់ ហើយក៏មិនឆ្លើយថាមិនទទួលស្គាល់ចំពោះអង្គហេតុណាមួយភាគីត្រូវចាត់ទុកថា បានសារភាពចំពោះអង្គហេតុនោះ (មាត្រា៩៦កថាខណ្ឌទី១ នៃCCP)។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

(៣) អង្គហេតុតវ៉ា

នៅក្នុងឯកសារចម្លើយ ឆ្លើយតបការទាមទាររបស់ដើមចោទ និងឆ្លើយតបនឹង អង្គហេតុដែលអះអាងដោយដើមចោទ ចុងចម្លើយត្រូវអះអាងនូវ អង្គហេតុតវ៉ាដើម្បីឲ្យរលត់នូវសិទ្ធិទាមទាររបស់ដើមចោទ ។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

**(៤) អង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុតវ៉ា**

☞ ជាអង្គហេតុប្រយោល ដើម្បីបញ្ជាក់អំពី អត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុតវ៉ា ។

ឧទាហរណ៍ ករណីចុងម្លើយអះអាងអង្គហេតុតវ៉ា ចំពោះ ការសង ៖

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

❖ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ចុងចម្លើយបានទូរស័ព្ទទៅដើមចោទនិយាយថា នឹងសងប្រាក់ក្នុងពេលឆាប់ៗនេះ

❖ នៅថ្ងៃដដែល ចុងចម្លើយបានទៅដកប្រាក់ពីគណនេយ្យរបស់ខ្លួន

❖ពេលចុងចម្លើយសងលុយទៅដើមចោទ បានសុំឲ្យដើមចោទធ្វើលិខិតប្រគល់ទទួលប្រាក់ តែដើមចោទថា គ្មានពេលចាំថ្ងៃស្អែក ចុងបញ្ចប់ អត់បានធ្វើលិខិតប្រគល់ទទួលប្រាក់ទេ។

## ២- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ

**(៥) ភស្តុតាង**

☞លិខិតបញ្ជាក់អំពីការសង លិខិតបញ្ជាក់អំពីការលើកលែងបំណុល ជាអាទ៍។

☞ភស្តុតាងប្រយោល ដូចជា លិខិតបញ្ជាក់អំពីការបើកប្រាក់ពីធនាគារ ជាអាទ៍។

## ៣- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម

ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម

(១) សេចក្តីថ្លែងការណ៍ ទទួលស្គាល់ ឬមិនទទួលស្គាល់

អង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត។

## ៣- ការស្វែងយល់អំពីចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម

(២) មធ្យោបាយតទល់ ឬការពារខ្លួន

❶ អង្គហេតុតវ៉ាតប

❷ អង្គហេតុតវ៉ាតបចំពោះអង្គហេតុតវ៉ាតប

❸ អង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុ

❹ ភស្តុតាង

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៦៦៨៨៥ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ ដែលមានអាសយដ្ឋានស្ថិតនៅអាគារ IOC ជាន់ទី៥ បន្ទប់$F_5$-R01 & $F_5$-R02 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ០១៧ ៥២៣២២៩។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ[50]

**ចុងចម្លើយ** ៖ ឈ្មោះ Y អាយុ ៦០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៦៦៨៨៦ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៥ ផ្លូវលេខ ៣៨៥ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

## សូមគោរពចូលមក

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ[51]

### ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ[52] ៖

[50]មាត្រា ២៨៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ទោះបីជាមិនដាក់ពីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏ជាទូទៅគឺត្រូវធ្វើការបញ្ជូនទៅការិយាល័យមេធាវីនៃបណ្តឹង។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់លាស់ពីទីកន្លែងដែលត្រូវបញ្ជូន វាជាការល្អដែលដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។ ជាពិសេស ក្នុងករណីដែលមានមេធាវីច្រើនធ្វើជាអ្នកតំណាងរបស់ដើមចោទ នោះដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការបញ្ជូនទៅការិយាល័យមេធាវីណាមួយ នោះត្រូវដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។

[51] ការដាក់ពាក្យបណ្តឹងត្រូវធ្វើទៅតុលាការដែលមានសមត្ថកិច្ច (សមត្ថកិច្ចសាលាជម្រះក្តី) (មាត្រា ០៨ មាត្រា ០៩ ជាអាទិ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ រឿងក្តីនេះ លំនៅឋានរបស់ចុងចម្លើយស្ថិតនៅខេត្តកណ្តាល ដូច្នេះ តុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងខេត្តកណ្តាល ( ក្រមនីតិវិធិរដ្ឋប្បវេណីមាត្រា ៨ ចំណុច ក)។ ម្យ៉ាងទៀត ដោយសារតែ ទីតាំងនៃអចលនវត្ថុដែលជាកម្មវត្ថុនៃបណ្តឹងស្ថិតនៅ ភ្នំពេញ ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញក៏មានសមត្ថកិច្ចតុលាការដែរ ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩ ចំណុច ឆ និង ជ)។

(១) ចុងចម្លើយ "Y" ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដី B ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០១០ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១០ មានទំហំ ៦០០ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ១ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ រវាង X និង Y ដោយមូលហេតុនៃការលក់-ទិញ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១៤[53] មកឲ្យដើមចោទ"X"

(២) បង្គាប់ឲ្យចុងចម្លើយប្រគល់ដីដែលមានអត្តសញ្ញាណខាងលើមកឲ្យដើមចោទ

(៣) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៦០០ (ប្រាំមួយរយ) ដុល្លារអាមេរិកក្នុងមួយខែគិតចាប់ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ រហូតដល់ពេលប្រគល់ដីខាងលើមកឲ្យដើមចោទ

(៤) ប្រកាសអនុវត្តជាបណ្ដោះអាសន្ន[54]

(៥) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ[55]

## ខ.អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ[56]

១. ដើមចោទ X និង ចុងចម្លើយ Y បានបង្កើតកិច្ចសន្យាលក់ទិញ ដី (លេខក្បាលដី ទីតាំង) (ខាងក្រោមនេះ ហៅថា "ដីនៃរឿងក្ដី") នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ ក្នុងតម្លៃ ៨០,០០០ (ប្រាំបីម៉ឺន)ដុល្លារអាមេរិក (រឿងក្ដីនៃកិច្ចសន្យាលក់ទិញ)។ (ភស្តុតាង ១ និងភស្តុតាង ២)

---

[52] ខ្លឹមសារនៃសាលក្រមគឺមានភាពចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

[53] ការដាក់ពាក្យសុំផ្ទេរកម្មសិទ្ធិត្រូវធ្វើឡើងរួមគ្នារវាងអ្នកមានករណីយកិច្ចចុះបញ្ជីនិងអ្នកមានសិទ្ធិទាមទារឲ្យចុះបញ្ជី ប៉ុន្តែក្នុងករណីមានសេចក្ដីសម្រេចរបស់តុលាការដែលចូលជាស្ថាពរ ភាគីតែម្ខាងអាចដាក់ពាក្យសុំបាន (មាត្រា ១០ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ ចុងចម្លើយមិនមែនជាអ្នកចុះបញ្ជីនោះទេ គឺមន្ត្រីសុរិយោដីជាអ្នកចុះបញ្ជី ហេតុនេះប្រសិនបើចុងចម្លើយចាញ់ក្ដី ត្រូវបានចាត់ទុកថាបានបង្ហាញឆន្ទៈ ហើយការទាមទារបែបនេះអាចអនុវត្តបានលុះត្រាតែសេចក្ដីសម្រេចរបស់តុលាការចូលជាស្ថាពរ មានន័យថា មិនអាចប្រកាសឲ្យអនុវត្តជា បណ្ដោះអាសន្នបានឡើយ (CCP៥២៩)។

[54] ចំពោះចំណុចទី១នៃការទាមទារក្នុងសាលក្រមគឺមិនអាចទាមទារឲ្យប្រកាសអនុវត្តជាបណ្ដោះអាសន្ននោះទេ ប៉ុន្តែចំណុចទី២ និងទី៣ អាចទាមទារឲ្យប្រកាសអនុវត្តបណ្ដោះអាសន្នបាន (មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

[55] តុលាការត្រូវសម្រេចអំពីប្រាក់ប្រដាប់ក្ដី (CCP១៨២-៣) ហើយប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកចាញ់ក្ដី (CCP៦៤-១)

[56] "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ" គឺជាចំណុចចាំបាច់ដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (ក្រមនីតិវិធីរដ្ឋ ប្បវេណី មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ)។ " អង្គហេតុដែលជាមូលហេតុនៃការទាមទារ" គឺជាចំណុចមិនបង្ខំឲ្យសរសេរនៅក្នុងពាក្យបណ្ដឹងទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥ កថាខណ្ឌទី៣) ប៉ុន្តែ ដើម្បីប្រាប់អំពីខ្លឹមសារនៃរឿងក្ដីទៅតុលាការ គប្បីសរសេរ។ ប្រសិនបើ សរសេររួមបញ្ចូលគ្នានូវចំណុចទាំងពីរនេះទៅក្នុងផ្នែកតែមួយ វានឹងមានភាពងាយស្រួលដើម្បីឲ្យមានន័យគ្រប់គ្រាន់។

២. ដើមចោទ X និង ចុងចម្លើយ Y បានបង្កើតកិច្ចសន្យាលក់ផ្តាច់ (Definitive Sale Letter )ចំពោះរឿងក្តីនៃកិច្ចសន្យាលក់ទិញនេះ នៅថ្ងៃដដែលនោះ[57]។ (ភស្តុតាង ៣)

៣. ដើមចោទ X បានបង់ប្រាក់ ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក នៃរឿងក្តីនៃកិច្ចសន្យាលក់ទិញទៅឲ្យចុងចម្លើយ Y នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤។ ( ភស្តុតាង ៤)

៤. ដោយសារតែចុងចម្លើយ Y មិនប្រគល់ដីនៃរឿងក្តីនេះ ទៅដើមចោទ X ហេតុនេះ ទោះបីជានៅក្រោយពេលដែលបានបង់ប្រាក់លើដីនៃរឿងក្តីនេះហើយក៏ដោយ ក៏ដើមចោទ X មិនអាចប្រើប្រាស់ដីនៃរឿងក្តីនេះបានដែរ។ ហេតុនេះ ដើមចោទ X កើតមាននូវការខូចខាតចំពោះថ្លៃឈ្នួលលើដីនៃរឿងក្តីនេះ។

៥. ថ្លៃឈ្នួលលើដីនៃរឿងក្តីនេះ គឺមួយខែ ៦០០ (ប្រាំមួយរយ) ដុល្លារអាមេរិក/ខែ។ (ភស្តុតាង ៥)

***ហេតុនេះដើមចោទទាមទារឲ្យចុងចម្លើយត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដី B ដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ។***

## ក-ភស្តុតាង

១. ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីអចលនវត្ថុ (លិខិតបញ្ជាក់ព័ត៌មានសុរិយោដី)

២. កិច្ចសន្យាលក់ទិញ

៣. លិខិតលក់ផ្តាច់

៤. លិខិតប្រគល់-ទទួលប្រាក់

៥. លិខិតគណនាថ្លៃឈ្នួល

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

[57] " ចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុ ក្នុងករណីបើមិនបង្កើតជាលិខិតយថាភូតទេ កិច្ចសន្យាលក់ទិញនោះនឹងត្រូវមោឃភាព (ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២)។ ខ្លឹមសារនៃលិខិតយថាភូត មានសរសេរនៅក្នុង មាត្រា ៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ រឿងក្តីនេះ លិខិតលក់ផ្តាច់គឺជា "លិខិតដែល មន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើ នីតិវិធីនៃការចុះបញ្ជី" ដូច្នេះ វាជាលិខិតយថាភូត។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤

**ហត្ថលេខា និងត្រា**

P

<u>ឯកសារភ្ជាប់</u>

១.លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២.ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ឯកសារចម្លើយ</u>[58]

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៩ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ ដែលមានអាសយដ្ឋានស្ថិតនៅអាគារ IOC ជាន់ទី៥ បន្ទប់$F_5$-R01 & $F_5$-R02 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ០១៧ ៥២៣២២៩។ ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ

**ចុងចម្លើយ** ៖ ឈ្មោះ Y អាយុ ៦០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៦ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៤ ផ្លូវលេខ ៣៨៤ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

**អ្នកតំណាងដោយអាណត្តិ** "ចុងចម្លើយ" ៖ នាងខ្ញុំ B ជាមេធាវីនៃការិយាល័យមេធាវីអន្តរជាតិ ជេស៊ី ឡ ដែលមានអាសយដ្ឋានស្ថិតនៅបុរីឧទ្យានបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ០៩២ ៨៧៦ ២៥៥។

ទីកន្លែងបញ្ជូន ៖ ការិយាល័យមេធាវីអន្តរជាតិ ជេស៊ី ឡ

[58] ដោយសារតែឯកសារនេះ ជាឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ដូច្នេះ ការបង្កើតត្រូវស្របតាមមាត្រា ១០១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើមើលតាម កថាខណ្ឌ និង មាត្រាដដែលគឺ មានកំណត់ថា "ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារ នៅក្នុងពាក្យបណ្តឹង និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងជាអាទិ៍"។ ច្បាប់របស់ប្រទេសជប៉ុន ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង គឺហៅថា ឯកសារចម្លើយ។

**<u>សូមគោរពចូលមក</u>**

**លោក W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>៖** សុំដាក់ឯកសារចម្លើយដើម្បីឆ្លើយតបនឹងពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ ឧសភា

ឆ្នាំ ២០១៤ របស់ឈ្មោះ X

**<u>យោង</u>៖** -មាត្រា ១០១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥

សេចក្តីដូចមានកំណត់ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ឈ្មោះ X បានដាក់ពាក្យបណ្តឹងមកសាលាដំបូងរាជធានីភ្នំពេញ ដោយទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ ៖

**ទី១** ចុងចម្លើយ "Y" ត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិដី B ដែលមានវិញ្ញាបនបត្រ

សំគាល់ម្ចាស់អចលនវត្ថុលេខ ០០១០ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១០ មានទំហំ

៦០០ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ១ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ

រាជធានីភ្នំពេញ រវាង X និង Y ដោយមូលហេតុនៃការលក់-ទិញ ចុះថ្ងៃទី០២ ខែមេសាឆ្នាំ ២០១៤ មកឲ្យដើមចោទ"X"

**ទី២** បង្គាប់ឲ្យចុងចម្លើយប្រគល់ដីដែលមានអត្តសញ្ញាណខាងលើមកឲ្យដើមចោទ

**ទី៣** បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៦០០ (ប្រាំមួយរយ) ដុល្លារអាមេរិក ក្នុង មួយខែ គិតចាប់ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ រហូតដល់ពេលប្រគល់ដីខាងលើមកឲ្យដើមចោទ

**ទី៤** ប្រកាសអនុវត្តជាបណ្តោះអាសន្ន

**ទី៥** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ

នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ ២០១៤ ខ្ញុំបានទទួលពាក្យបណ្តឹងនេះតាមរយៈការបញ្ជូនរបស់មន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ហេតុនេះខ្ញុំសុំឆ្លើយតបចំពោះពាក្យ បណ្តឹងនេះ ដូចខាងក្រោម ៖

## ក-ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ X

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ X

## ខ-ការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទារ

១.ស្តីពីអង្គហេតុលក់-ទិញ "ខ.១ និងខ.២" របស់ដើមចោទ ៖ ចុងចម្លើយទទួលស្គាល់

២.ស្តីពីអង្គហេតុទទួលប្រាក់ "ខ.៣" របស់ដើមចោទ ៖ ចុងចម្លើយមិនទទួលស្គាល់ដើមចោទ X បានបង់ប្រាក់ឲ្យមកកូនក្តីនាងខ្ញុំ (ចុងចម្លើយ Y) តែ ១០០០០ ដុល្លារតែប៉ុណ្ណោះ។ នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ ដើមចោទ X បានបង់ប្រាក់ ១០០០០ដុល្លារ ដែលជាចំនួនទឹកប្រាក់មួយផ្នែកនៃកិច្ចសន្យាលក់ទិញក្នុងរឿងក្តីនេះតែប៉ុណ្ណោះ (ភស្តុតាង១របស់ចុងចម្លើយ) ហើយដើមចោទX បាននិយាយថា " ប្រាក់នៅសល់ ៧០០០០ ដុល្លារ ទៀត ថ្ងៃស្អែកនឹងបង់ឲ្យ ដូច្នេះក៏ធ្វើលិខិតប្រគល់-ទទួល ចំនួនប្រាក់ ៨០០០០ ដុល្លារ តែម្តងឲ្យហើយទៅ"។ចុងចម្លើយ Y បានជឿទៅលើពាក្យសំដីរបស់ដើមចោទ X ក៏បានធ្វើលិខិតប្រគល់-ទទួលប្រាក់ ដោយសរសេរចំនួនទឹកប្រាក់ ៨០០០០ ដុល្លារ ហើយក៏ប្រគល់ទៅដើមចោទ X រួចរាល់។ (ភស្តុតាង ១)[59]

៣.ស្តីពីអង្គហេតុមិនប្រគល់ដី "ខ.៤" របស់ដើមចោទ ៖ ចុងចម្លើយទទួលស្គាល់ឃ្លាទី១ តែមិនទទួលស្គាល់ឃ្លាទី២ទេ។

៤.ស្តីពីអង្គហេតុថ្លៃឈ្នួលដី "ខ.៥" របស់ដើមចោទ ៖ ចុងចម្លើយមិនទទួលស្គាល់ចំនួនទឹកប្រាក់ថ្លៃឈ្នួលដីនេះគឺ ៣០០ (បីរយ) ដុល្លារអាមេរិក/ខែ។[60]

## គ-អង្គហេតុតវ៉ា ជាអាទិ៍

ស្តីពីសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា គឺចុងចម្លើយ Y បដិសេធក្នុងការប្រគល់ដីនៃរឿងក្តីនេះ រហូតដល់ពេល ដើមចោទ X បង់ប្រាក់ដែលនៅសល់ ៧០,០០០ (ប្រាំពីម៉ឺន) ដុល្លារអាមេរិក ទើបចុងចម្លើយ Y ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីនៃរឿងក្តីនេះ។[61]

[59] នៅក្នុងរឿងក្តីនេះ ចំណុចវិវាទសំខាន់បំផុតនោះគឺ ដើមចោទ X បានបង់ប្រាក់ទៅឲ្យចុងចម្លើយ Y ដូច្នេះ វាមានភាពចាំបាច់ណាស់ដែលត្រូវធ្វើការពន្យល់ឲ្យបានក្បោះក្បាយចំពោះចំណុចនេះ។ ដោយសារតែ អំឡុងពេលដាក់ឯកសារចម្លើយមានរយៈពេលខ្លី ដូច្នេះ នៅថ្ងៃបន្ទាប់ ចុងចម្លើយ Y ត្រូវពន្យល់ឲ្យបានលំអិតបន្ថែមនៅក្នុងឯកសារត្រៀម។

[60] ដើមចោទ X បានដាក់លិខិតគណនាដែលមានចំនួនទឹកប្រាក់ ៦០០ ដុល្លារក្នុង ១ ខែ។ ដូច្នេះ វាជាការល្អដែលចុងចម្លើយ Y គួរតែដាក់ភស្តុតាងដែលជាភស្តុតាងតបទៅដើមចោទវិញ។ ដោយសារតែ អំឡុងពេលដាក់ឯកសារចម្លើយមានរយៈពេលខ្លី ដូច្នេះ នៅថ្ងៃបន្ទាប់ ចុងចម្លើយ Y ត្រូវដាក់ភស្តុតាងដែលជាភស្តុតាងតបនៅពេលដាក់ឯកសារចម្លើយ។

## ឃ-ភស្តុតាង

ទម្រង់បែបបទនៃការផ្ទេរប្រាក់របស់ធនាគារកម្ពុជាសាធារណៈ

សូម **ឯកឧត្តមប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៤

**ហត្ថលេខា និងត្រា**

B

ឯកសារភ្ជាប់

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"

[61] ចុងចម្លើយ Y អាចធ្វើការបដិសេធក្នុងការប្រគល់ដីនៃរឿងក្តីនេះ និងអាចធ្វើការបដិសេធក្នុងការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិផងដែរ (ក្រមរដ្ឋប្បវេណី មាត្រា ៥៥១ កថាខណ្ឌទី១)។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ឯកសារត្រៀមលើកទី១ របស់ដើមចោទ

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៩ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ ដែលមានអាសយដ្ឋានស្ថិតនៅអាគារ IOC ជាន់ទី៥ បន្ទប់$F_5$-R01 & $F_5$-R02 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ០១៧ ៥២៣២២៩។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ

**ចុងចម្លើយ** ៖ ឈ្មោះ Y អាយុ ៦០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៦ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៤ ផ្លូវលេខ ៣៨៤ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

**អ្នកតំណាងដោយអាណត្តិ** "ចុងចម្លើយ" ៖ នាងខ្ញុំ B ជាមេធាវីនៃការិយាល័យមេធាវីអន្តរជាតិ ដេស៊ី ឡ ដែលមានអាសយដ្ឋានស្ថិតនៅបុរីឧឡានបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ០៩២ ៨៧៦ ២៥៥។

ទីកន្លែងបញ្ជូន ៖ ការិយាល័យមេធាវីអន្តរជាតិ ដេស៊ី ឡ

## សូមគោរពចូលមក

## លោក W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ**៖សំណើសុំដាក់ឯកសារត្រៀមលើកទី១របស់ដើមចោទដើម្បីឆ្លើយតបចំពោះឯកសារចម្លើយរបស់ចុងចម្លើយចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៤ របស់ឈ្មោះ Y

**យោង៖** -មាត្រា ១០១ **កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥

សេចក្តីដូចមានកំណត់ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៤ ឈ្មោះ Y បានដាក់ឯកសារចម្លើយមកសាលាដំបូងរាជធានីភ្នំពេញ។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ ខ្ញុំបានទទួលឯកសារចម្លើយនេះ តាមរយៈការបញ្ជូនរបស់មន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ហេតុនេះ ខ្ញុំសុំឆ្លើយតបចំពោះឯកសារចម្លើយនេះ ដូចខាងក្រោម ៖

## ក-ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះឯកសារចម្លើយ

១. ស្តីពីអង្គហេតុធ្វើលិខិតប្រគល់ទទួល-ប្រាក់ចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក "ខ.២" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់

២. ស្តីពីអង្គហេតុអនុវត្តសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា "ខ.៣" នៃឯកសារចម្លើយ ៖

ដើមចោទមិនទទួលស្គាល់

៣. ស្តីពីអង្គហេតុថ្លៃឈ្នួលដី "ខ.៤" នៃឯកសារចម្លើយ ៖ ដើមចោទមិនទទួលស្គាល់

## ខ-ការអះអាងរបស់ដើមចោទ

១. ស្តីពីការបង់ប្រាក់ចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក

នៅថ្ងៃទី០២ ខែ មេសា ឆ្នាំ ២០១៤ ដើមចោទ X និង ចុងចម្លើយ Y បានចុះហត្ថលេខាលើលិខិតកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ ហើយក៏បានបង្កើតលិខិតលក់ផ្តាច់ ( Definitive sale letter) ប៉ុន្តែ មិនទាន់បានធ្វើនីតិវិធីចុះបញ្ជីផ្ទេរនៅឡើយទេ។

បន្ទាប់មក ដើមចោទ X ក៏បានឲ្យចុងចម្លើយ Y មើលប្រាក់ចំនួន ៨០០០០ ដុល្លារ តែដោយសារតែប្រាក់ចំនួនមួយផ្នែកនៃប្រាក់ ៨០០០០ ដុល្លារត្រូវបានប្រលាក់ និង គក្រិច ចុងចម្លើយក៏បាននិយាយថាមិនចង់ទទួលប្រាក់គក្រិចនោះទេ។ ហេតុនេះ ដើមចោទ X ក៏បានស្នើសុំបង់ប្រាក់ទៅចុងចម្លើយ Y តែ ៧០០០០ ដុល្លារ ចំពោះប្រាក់នៅសល់ ១០០០០ដុល្លារ ដើមចោទស្នើសុំបង់តាមរយៈវេរប្រាក់ក្នុងធនាគារ ហើយចុងចម្លើយក៏បានយល់ព្រមដែរ។

ដើមចោទ X និង ចុងចម្លើយ Y បានទៅធនាគារ CAMPU BANK សាខាអូឡាំពិក ជាមួយ

គ្នា។ ដើមចោទ X ក៏បានវេរបញ្ចូលទឹកប្រាក់ចំនួន ១០០០០ដុល្លារ ពីឈ្មោះគណនេយ្យរបស់ X ទៅឈ្មោះគណនេយ្យរបស់ Y។ (ភស្តុតាង១ របស់ចុងចម្លើយ Y)

ចុងចម្លើយ Y បន្ទាប់ពីបានធ្វើការបញ្ជាក់ថាប្រាក់ ១០០០០ដុល្លារ បានវេរបញ្ចូលរួចហើយ ដើមចោទ X ក៏បានប្រគល់ប្រាក់ ៧០០០០ដុល្លារ ទៅឲ្យចុងចម្លើយ Y។

ចុងចម្លើយ Y បន្ទាប់ពីទទួលបានប្រាក់ ៧០០០០ ដុល្លារ ភ្លាមក៏បានធ្វើលិខិតប្រគល់

ទទួលប្រាក់ក្នុងចំនួនទឹកប្រាក់ ៨០០០០ ដុល្លារ ហើយក៏បានប្រគល់មកឲ្យដើមចោទ។ (ភស្តុតាង៤ របស់ដើមចោទ X)

២. ស្តីពីសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា

ដោយសារតែនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ ដើមចោទបានបង់ប្រាក់ ៨០០០០ដុល្លារ ទៅចុងចម្លើយហើយ នាំឲ្យ សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នារបស់ចុងចម្លើយ ត្រូវបានរលត់ ហេតុនេះ ចុងចម្លើយគឺបានយឺតយ៉ាវក្នុងការប្រគល់ដីនៃរឿងក្តីនេះតាំងពីថ្ងៃទី ០២ ខែមេសាឆ្នាំ ២០១៤ មកម្ល៉េះ។

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **លោកចៅក្រម** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤

**ហត្ថលេខា និងត្រា**

P

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៩ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ ដែលមានអាសយដ្ឋានស្ថិតនៅអាគារ IOC ជាន់ទី៥ បន្ទប់$F_5$-R01 & $F_5$-R02 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ០១៧ ៥២៣២២៩។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវីកម្ពុជាអន្តរជាតិ

**ចុងចម្លើយ** ៖ ឈ្មោះ Y អាយុ ៦០ ឆ្នាំ មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៦ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៤ ផ្លូវលេខ ៣៨៤ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

**អ្នកតំណាងដោយអាណត្តិ** "ចុងចម្លើយ" ៖ នាងខ្ញុំ B ជាមេធាវីនៃការិយាល័យមេធាវីអន្តរជាតិ ជេស៊ី ឡ ដែលមានអាសយដ្ឋានស្ថិតនៅបុរីឧទ្យានបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ០៩២ ៨៧៦ ២៥៥។

ទីកន្លែងបញ្ជូន ៖ ការិយាល័យមេធាវីអន្តរជាតិ ជេស៊ី ឡ

## សូមគោរពចូលមក

## លោក W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ**៖សំណើសុំដាក់ឯកសារត្រៀមលើកទី១របស់ចុងចម្លើយ ដើម្បីឆ្លើយតបចំពោះឯកសារត្រៀមលើកទី១របស់ដើមចោទចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨របស់ឈ្មោះ X

**យោង៖** -មាត្រា ១០១ **កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥

សេចក្តីដូចមានកំណត់ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ ឈ្មោះ x បានដាក់ឯកសារត្រៀមលើកទី១របស់ដើមចោទមកសាលាដំបូងរាជធានីភ្នំពេញ។ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ខ្ញុំបានទទួលឯកសារត្រៀមលើកទី១របស់ដើមចោទនេះ តាមរយៈការបញ្ជូនរបស់មន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ហេតុនេះ ខ្ញុំសុំឆ្លើយតបចំពោះឯកសារត្រៀមលើកទី១របស់ដើមចោទនេះ ដូចខាងក្រោម ៖

## ក-ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះឯកសារត្រៀមលើកទី១របស់ដើមចោទ

ស្តីពីអង្គហេតុបង់ប្រាក់ចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក "ខ.១" នៃឯកសារត្រៀមលើកទី១របស់ដើមចោទ ៖ ចុងចម្លើយទទួលស្គាល់អង្គហេតុខាងក្រោម ប៉ុន្តែក្រៅពីនេះចុងចម្លើយមិនទទួលស្គាល់ ៖

១. នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ ដើមចោទ X និង ចុងចម្លើយ Y បានចុះហត្ថលេខាលើលិខិតកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ និងបានបង្កើតលិខិតលក់ផ្តាច់ ( Definitive sale letter) ប៉ុន្តែ មិនទាន់បានធ្វើនីតិវិធីចុះបញ្ជីផ្ទេរនៅឡើយទេ។

២. ដើមចោទ X និង ចុងចម្លើយ Y បានទៅធនាគារ CAMPU BANK សាខាអូឡាំពិកជាមួយគ្នា។ ដើមចោទ X ក៏បានវេរបញ្ចូលទឹកប្រាក់ចំនួន ១០០០០ដុល្លារ ពីឈ្មោះគណនេយ្យរបស់ X ទៅឈ្មោះគណនេយ្យរបស់ Y។

## ខ-ការអះអាងរបស់ចុងចម្លើយ

១. ស្តីពីការបង់ប្រាក់ ៨០០០០ ដុល្លារ

ដើមចោទ X និង ចុងចម្លើយ Y បានចុះហត្ថលេខាលើលិខិតកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ ហើយបន្ទាប់ពីបានបង្កើតលិខិតលក់ផ្តាច់ (Definitive sale letter) រួច ដើម្បីបង់ប្រាក់ ដើមចោទ X និង ចុងចម្លើយ Y បានទៅធនាគារ CAMPU BANK សាខាអូឡាំពិក ជាមួយគ្នា។ ប៉ុន្តែ នៅក្នុងគណនេយ្យធានាគាររបស់ដើមចោទ X មានប្រាក់ប្រហែលតែ ១០០០០ដុល្លារ ជាងបន្តិចប៉ុណ្ណោះ។

ចុងចម្លើយ Y បាននិយាយថា "ប្រសិនបើគ្មានប្រាក់ទេ អញ្ចឹងយើងមិនចាំបាច់បង្កើតកិច្ចសន្យាលក់ទិញក្នុងរឿងក្តីនេះទេ"។ ប៉ុន្តែ ដើមចោទ X បាននិយាយថា "ខ្ញុំនឹងវេរប្រាក់ ១០០០០ ដុល្លារ ចូលទៅ

ក្នុងគណនេយ្យធនាគាររបស់ Y ឥឡូវនេះហើយ ! ប្រសិនបើ ធ្វើលិខិតប្រគល់-ទទួលប្រាក់ ក្នុងចំនួនទឹកប្រាក់ ៨០០០០ ដុល្លារ មកខ្ញុំ នោះនៅថ្ងៃស្អែកខ្ញុំនឹងវេរប្រាក់ ៧០០០០ ដុល្លារដែលនៅសល់ចូលទៅក្នុងគណនេយ្យធនាគាររបស់ Y ។ ខ្ញុំមានប្រាក់នៅផ្ទះច្រើនណាស់”។

ចុងចម្លើយ Y បានជឿទៅលើពាក្យសម្តីរបស់ដើមចោទ X ក៏ធ្វើលិខិតប្រគល់-ទទួលប្រាក់ចំនួន ៨០,០០០ ដុល្លារប្រគល់ទៅឲ្យដើមចោទ។ (ភស្តុតាង៤ របស់ដើមចោទ)

២. ស្តីពីចំនួនទឹកប្រាក់ថ្លៃឈ្នួលសមរម្យ

ចុងចម្លើយ Y បានពឹងពាក់ភ្នាក់ងារអចលនវត្ថុ ឈ្មោះលោក A ឲ្យវាយតម្លៃលើចំនួនទឹកប្រាក់ថ្លៃឈ្នួលសមរម្យនៃដី។

ផ្អែកតាមការវាយតម្លៃ ប្រាក់ថ្លៃឈ្នួលសមរម្យនៃដីគឺតម្លៃ ៣៥០ដុល្លារ ក្នុងមួយខែ។

(ភស្តុតាង២ របស់ចុងចម្លើយ Y)

## គ-ភស្តុតាង

លិខិតវាយតម្លៃរបស់ភ្នាក់ងារវាយតម្លៃអចលនវត្ថុឈ្មោះ A

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **លោកចៅក្រម** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៤

**ហត្ថលេខា និងត្រា**

B

ឯកសារភ្ជាប់

ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ “ចំនួន ០២ ច្បាប់”

# សិក្ខាសាលាគណៈមេធាវី(តូច)លើកទី១២

## ប្រធានបទ៖ ប្រាតិភោគដោយអនុប្បទាន

ថ្ងៃទី ២៤ មីនា ២០១៦

# ប្រាតិភោគដោយអនុប្បទាន

## ១. សញ្ញាណទូទៅ

ប្រាតិភោគ គឺជាមធ្យោបាយមួយដើម្បីធានាកាតព្វកិច្ច ហើយការធានាកាតព្វកិច្ច ត្រូវបានធ្វើតាមទម្រង់ ៣ ជាគោលគឺ ៖

១. ការធានាកាតព្វកិច្ចតាមការកំណត់របស់ច្បាប់

២. ការធានាកាតព្វកិច្ចដោយបុគ្គល

៣.ការធានាកាតព្វកិច្ចដោយវត្ថុ

បច្ចុប្បន្ន ការធានាកាតព្វកិច្ចដោយវត្ថុគឺជារឿងដែលកើតឡើងជាប្រចាំនៅក្នុងសង្គម ជាតិយើងដែលមិនអាចកាត់ផ្តាច់បាន។ ដោយសារតែចង្វាក់ពាណិជ្ជកម្មបានកើនឡើង នោះតម្រូវការនៃលំហូរសាច់ប្រាក់ក៏រឹតតែមានសារៈសំខាន់។ ការដាក់ប្រាតិភោគ គឺជាមធ្យោបាយ មួយដែលធ្វើឲ្យម្ចាស់បំណុលមានលទ្ធភាពខ្ពស់ក្នុងប្រមូលនូវតណទេយ្យរបស់ខ្លួនត្រលប់មកវិញ ដោយយកវត្ថុមកធានា។ តាមក្រមរដ្ឋប្បវេណី ការបង្កើតប្រាតិភោគដោយវត្ថុ អាចបង្កើតតាម រយៈ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និងប្រាតិភោគដោយអនុប្បទាន។

ប្រាតិភោគដោយអនុប្បទាន គឺជាប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សមួយ ដែលត្រូវបាន បង្កើតឡើងតាមការព្រមព្រៀងរបស់ភាគី ដើម្បីបង្កើតនូវវិស័យគតិយុត្តថ្មីមួយដែលមានសារៈ សំខាន់សម្រាប់ជំរុញប្រព័ន្ធឥណទាន ឬហិរញ្ញប្បទាន ឲ្យដំណើរការល្អ។

### ១.១ និយមន័យ

ប្រាតិភោគដោយអនុប្បទាន គឺសំដៅទៅលើការណ៍ដែលកូនបំណុល ឬតតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ទៅឲ្យម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច ហើយកម្មវត្ថុនៃប្រាតិភោគអាចជាចលនវត្ថុ ឬចលនវត្ថុរួមផ្គុំគ្នាតែមួយដែលបានបង្កើតឡើងតាមការព្រមព្រៀងរបស់ភាគី។

- ប្រាតិភោគោ ៖ មធ្យោបាយមួយដើម្បីធានាកាតព្វកិច្ច។
- អនុប្បទាន ៖ សំដៅដល់ការផ្ទេរកម្មសិទ្ធិដើម្បីបង្កើតសិទ្ធិប្រាតិភោគ។
- ម្ចាស់សិទ្ធិលើប្រាតិភោគ ៖ ម្ចាស់បំណុល។
- អ្នកបង្កើតប្រាតិភោគ ៖ កូនបំណុលឬតតិយជន។

- វត្ថុនៃប្រាតិភោគដោយអនុប្បទាន ៖ ត្រូវតែជាចលនវត្ថុឬចលនវត្ថុរួមផ្គុំតែមួយ។
- កម្មសិទ្ធិនៃវត្ថុ ៖ ផ្នែកខ្លះត្រូវបន្តការកាន់កាប់ដោយអ្នកបង្កើតប្រាតិភោគ ហើយផ្នែកខ្លះត្រូវបានផ្ទេរទៅឲ្យ អ្នកមានសិទ្ធិប្រាតិភោគ។
- ការកាន់កាប់វត្ថុដោយផ្ទាល់ ៖ ដោយផ្អែកលើកិច្ចព្រមព្រៀងរបស់ភាគី វត្ថុអាចនឹងត្រូវបានកាន់កាប់ដោយអ្នកណាម្នាក់ដូចខាងក្រោម៖
    - អ្នកបង្កើតសិទ្ធិប្រាតិភោគ
    - ម្ចាស់សិទ្ធិលើប្រាតិភោគ
    - តតិយជនដែលបានទទួលបញ្ជាពីអ្នកបង្កើតសិទ្ធិប្រាតិភោគ
    - តតិយជនដែលបានទទួលបញ្ជាពីម្ចាស់សិទ្ធិប្រាតិភោគ ។

➢ **ការបង្កើតប្រាតិភោគដោយអនុប្បទានដោយចលនវត្ថុ**

ឧទាហរណ៍ទី១ ៖ B ជាម្ចាស់ហាងកាហ្វេមួយកន្លែង។ B បានខ្ចីប្រាក់ចំនួន1000ដុល្លាពី A តែ A បានទាមទារឲ្យ B ដាក់ប្រាតិភោគ។ ដូច្នេះ B បានបង្កើតប្រាតិភោគដោយអនុប្បទាន ជាមួយ A ដោយយកម៉ាស៊ីនឆុងកាហ្វេរបស់គាត់ជាកម្មវត្ថុនៃប្រាតិភោគ។ ដោយ B បានផ្ទេរកម្ម សិទ្ធិឲ្យទៅ A តាមការព្រមព្រៀង ប៉ុន្តែ B នៅតែបន្តកាន់កាប់ម៉ាស៊ីនឆុងកាហ្វេនោះដដែល។



- **ការបង្កើតប្រាតិភោគដោយអនុប្បទានដោយចលនវត្ថុរួមផ្គុំគ្នាតែមួយ**

ភាគីត្រូវកំណត់ទំហំមាត្រដ្ឋាននៃចលនវត្ថុរួមផ្គុំតែមួយ 888-2CC ។

-ចលនវត្ថុទាំងអស់ក្នុងឃ្លាំង Q

-ទាទាំងអស់នៅក្នុងកសិដ្ឋានទាQ

ឧទាហរណ៍១៖ X មានបំណងចង់ពង្រីក កសិដ្ឋានចិញ្ចឹមទា Q របស់គាត់ៗបានខ្ចីប្រាក់ពីY តែ Y តម្រូវឲ្យ X ដាក់ប្រាតិភោគ។ X បានបង្កើតប្រាតិភោគដោយអនុប្បទានលើសត្វទា នៅក្នុងកសិដ្ឋានចំនួន១០០០ក្បាលចំពោះ Y ។ ដូច្នេះ សត្វទាទាំងអស់ដែលមាននៅក្នុងកសិដ្ឋាន Q គឺជាកម្មវត្ថុនៃប្រាតិភោគ បើទោះជា X លក់សត្វទាខ្លះចេញ តែចំនួនសត្វទា ថ្មីដែល X ទិញចូល គឺជាផ្នែកមួយនៃប្រាតិភោគ។






**១ .២.មុខងារ**

ជាការពិតប្រាតិភោគដោយអនុប្បទាន គឺជាឧបករណ៍ថ្មីមួយដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ត្រង់ជំពូក៦ ដែលអនុញ្ញាតឲ្យ **អ្នកបង្កើតសិទ្ធិប្រាតិភោគ ឬ កូនបំណុលបន្តការ កាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ តាមទម្រង់នៃការផ្ទេរកម្មសិទ្ធិ** មាត្រា 889នៃក្រមរដ្ឋប្បវេណី បញ្ញត្តិនេះ អនុវត្តលើតែចលនវត្ថុប៉ុណ្ណោះ។ ពិតមែនតែ សិទ្ធិលើការបញ្ចាំអាចអនុវត្ត បានទាំង ចលនវត្ថុ និង អចលនវត្ថុក៏ដោយ ក៏ផលវិបាកនូវត្រង់ថា ក្រោយពេលដែលបង្កើតសិទ្ធិលើការ បញ្ចាំ តម្រូវឲ្យកូនបំណុលប្រគល់វត្ថុបញ្ចាំឲ្យម្ចាស់សិទ្ធិនៃការបញ្ចាំមាត្រា)818,) រីឯអ្នកបង្កើត សិទ្ធិលើការបញ្ចាំ **មិនត្រូវបានអនុញ្ញាតឲ្យកូនបំណុលនៃការបញ្ចាំបន្តកាន់កាប់ចលនវត្ថុដែល ជាកម្មវត្ថុលើការបញ្ចាំដោយចំពោះឡើយ**(មាត្រា819)។ ប្រាតិភោគដោយអនុប្បទាន គឺជាការ ធានាសិទ្ធិលើបំណុលមួយប្រភេទដែល អនុញ្ញាតឲ្យអ្នកង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្រើប្រាស់ និងបន្តការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ។

ឧទាហរណ៍១៖ X បានខ្ចីប្រាក់ចំនួន1000ដុល្លាអាមេរិកពី Y ដោយ Y ទាមទារឲ្យ X យកទ្រព្យមកដាក់បញ្ចាំដើម្បីធានាសិទ្ធិលើបំណុល។ X បានយកម៉ាស៊ីនកិនស្រូវមកដាក់បញ្ចាំ ជាមួយY។ ដើម្បីបង្កើតសិទ្ធិលើការបញ្ចាំ X ត្រូវតែប្រគល់វត្ថុបញ្ចាំ)ម៉ាស៊ីនកិនស្រូវ(ឲ្យទៅ Y កាន់ កាប់ CC 818, 819។






X ប្រគល់ការកាន់កាប់ដោយចំពោះឲ្យ Y

**ឧទាហរណ៍២៖** Y ដំណើរការរោងចក្រកិនស្រូវមួយកន្លែងនិង ដើម្បីពង្រីកអាជីវកម្ម របស់គាត់ Y ចង់ខ្ចីប្រាក់ពី X។ តែ X បានទាមទារឲ្យ Y ផ្តល់ប្រាតិភោគ។ Y មានម៉ាស៊ីនកិនស្រូវ ដែលមានតម្លៃ ប៉ុន្តែ Y មិនអាចយកម៉ាស៊ីននោះមកដាក់បញ្ចាំទេ ព្រោះគាត់ត្រូវការប្រើម៉ាស៊ីន កិនស្រូវនោះសម្រាប់អាជីវកម្មរបស់គាត់ ។ ក្នុងករណីនេះ Y អាចបង្កើតប្រាតិភោគដោយ អនុប្បទានលើម៉ាស៊ីនសម្រាប់ X ហើយ Y នៅតែបន្តកាន់កាប់ប្រើប្រាស់ម៉ាស៊ីន និងបន្តពង្រីក អាជីវកម្ម។ ប្រសិនបើ Y ខកខានមិនបានសងប្រាក់X នោះX អាចលក់ម៉ាស៊ីន និងទទួលយក ប្រាក់វិញបាន។



Y ផ្ទេរសិទ្ធិកាន់កាប់តាមការព្រមព្រៀងឲ្យទៅ X ដូច្នេះ X ទទួលបានការកាន់កាប់ដោយ ប្រយោលលើម៉ាស៊ីនកិនស្រូវ រីឯ Y កាន់កាប់ដោយចំពោះលើម៉ាស៊ីនកិនស្រូវ។

ឧទាហរណ៍២៖ Y បើកហាងលក់គ្រឿងប្រាក់មួយកន្លែង។ ដើម្បីពង្រីកអាជីវកម្ម Y មានបំណងចង់ខ្ចីប្រាក់ពី X។ X បានទាមទារឲ្យ Y ផ្តល់ប្រាតិភោគ។ Y មានគ្រឿងប្រាក់ជាច្រើននៅក្នុងហាងរបស់គាត់ ប៉ុន្តែ Y មិនអាចប្រគល់គ្រឿងប្រាក់នោះសម្រាប់ការបញ្ចាំនោះទេ ព្រោះ Y ត្រូវការរក្សាគ្រឿងប្រាក់ទាំងអស់នៅក្នុងហាងរបស់គាត់សម្រាប់លក់។ ក្នុងករណីនេះ Y អាចបង្កើតប្រាតិភោគដោយអនុប្បទានលើគ្រឿងប្រាក់ដែលមាននៅក្នុងហាងរបស់Y។ ដោយY អាចបន្តការកាន់កាប់ និងលក់គ្រឿងប្រាក់នោះ។ នៅពេលដែល Y ដាក់បំពេញឡើងវិញនូវគ្រឿងប្រាក់ថ្មីនៅក្នុងហាងរបស់គាត់ គ្រឿងប្រាក់ថ្មីនោះនឹងក្លាយជាផ្នែកមួយដោយ ស្វ័យប្រវត្តិនៃវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។ ប្រសិនបើ Y ខកខានមិនបានសងប្រាក់ដែលបានខ្ចីទៅឲ្យ X នោះ X អាចលក់គ្រឿងប្រាក់ទាំងអស់ និងប្រមូលប្រាក់មកវិញបាន។

## ២.ការបង្កើត និងអានុភាពតតាំង

### ២.១ការបង្កើត

ប្រាតិភោគដោយអនុប្បទាន គឺជាឧបករណ៍ថ្មីមួយដែលត្រូវបានបង្កើតឡើងតាមកិច្ច ព្រមព្រៀងរបស់ភាគីដោយឯកសារលាយលក្ខណ៍មិនត្រូវបានទាមទារ(មាត្រា៨៨៩ក.រ) បើទោះជាឯកសារលាយលក្ខណ៍អក្សរគួតែត្រូវបានធ្វើឡើងជានិច្ចជាកាលក៏ដោយ។

ប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយនូវផលលំបាករវាង សិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក។

ដោយហេតុថាសិទ្ធិលើការបញ្ចាំគឺតម្រូវឲ្យកូនបំណុលប្រគល់វត្ថុបញ្ចាំឲ្យម្ចាស់សិទ្ធិ លើការបញ្ចាំ កូនបំណុលមិនអាចកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ (មាត្រា818, 819ក.រ)។ ចំណែកឯ

ហ៊ីប៉ូតែកវិញ ពិតមែនតែកូនបំណុលមិនផ្ទេរការកាន់កាប់ ហើយអាចប្រើបានច្រើនលើកច្រើនសារ លើអចលនវត្ថុតែមួយ (មាត្រា843, 851 ក.រ) ក៏ដោយ ក៏ នៅតែមានផលលំបាក ព្រោះថាអ្នកប្រើប្រាស់ខ្លះ មិនមានអចលនវត្ថុដើម្បីបង្កើតហ៊ីប៉ូតែក ឡើយ។

ដោយសារតែមូលហេតុទាំងអស់នេះហើយ ទើបប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើង។ ក្នុងករណី អ្នកបង្កើតសិទ្ធិប្រាតិភោគ មានទាំងអចលនវត្ថុ និងចលនវត្ថុ គាត់អាចប្រើប្រាស់អស់តម្លៃនៃវត្ថុដែលគាត់មាន ហើយដែលសំខាន់នោះ គឺថាកូនបំណុលមានលទ្ធភាព ខ្ពស់ក្នុងការប្រើប្រាស់វត្ថុរបស់គាត់ជាប្រាតិភោគដើម្បីខ្ចីប្រាក់ ខណៈពេលដែលគាត់នៅតែបន្តការកាន់កាប់វត្ថុ (កូនបំណុលកាន់កាប់វត្ថុដោយចំពោះ) គឺគ្រាន់តែផ្ទេរកម្មសិទ្ធិតាមកិច្ចព្រមព្រៀងលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានឲ្យទៅម្ចាស់សិទ្ធិ (មាត្រា890 ក.រ ) ។

បញ្ហានៅត្រង់ថាពេលដែលកិច្ចព្រមព្រៀងធ្វើឡើងដោយផ្ទាល់មាត់ តើការអានុភាពតតាំងអាចកើតមានរឺទេ?

## ២.២. អានុភាពតតាំង

ដើម្បីទទួលបានអានុភាពតតាំង ចំពោះប្រាតិភោគដោយអនុប្បទាន ល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្ទេរការកាន់កាន់ ត្រូវបានទាមទារ។ ដើម្បីតតាំង និងតតិយជនបាន ត្រូវមានល័ក្ខខ័ណ្ឌផ្ទេរការកាន់កាប់នៃវត្ថុដែលជាកម្មវត្ថុប្រាតិភោគ។

តើម្ចាស់សិទ្ធិប្រាតិភោគ ទទួលបានការកាន់កាប់លើកម្មវត្ថុប្រាតិភោគតាមវិធីណា?

យោងតាមមាត្រា២២៩នៃក្រមរដ្ឋប្បវេណី បានបញ្ញាតិថា ការផ្ទេរការកាន់កាប់អាចជា៖

- ការប្រគល់ដោយជាក់ស្តែង
- ការប្តូលក្ខណៈនៃការកាន់កាប់
- ការប្រគល់ដោយសង្ខេប
- ការផ្ទេរការកាន់កាប់ដោយបញ្ជា

### ❖ ការប្រគល់ដោយជាក់ស្តែង

ការប្រគល់ដោយជាក់ស្តែង គឺជាការផ្ទេរតាមរយៈការប្រគល់វត្ថុកាន់កាប់ (មាត្រា២២៩កថាខ័ណ្ឌទី ១)។

ឧទាហរណ៍៖ X បានទិញសៀវភៅមួយក្បាលពី Y ហើយបានប្រគល់សៀវភៅ នោះឲ្យទៅ X ដោយផ្អែកលើកិច្ចសន្យាលក់-ទិញ។ ដូច្នេះ X បានកាន់កាប់ដោយចំពោះ លើសៀវភៅនោះ។ នេះជាការផ្ទេរការកាន់កាប់លើចលនវត្ថុ ប្រសិនបើអចលនវត្ថុអាច ជាការចាកចេញពីអចលនវត្ថុនោះ ហើយប្រគល់ដោយផ្ទាល់ទៅអនុប្បទានិក និងការ ប្រគល់ជាក់ស្តែងនូវប័ណ្ណកម្មសិទ្ធិ និងសោផ្ទះជាដើម។

### ❖ ការប្តូលក្ខណៈនៃការកាន់កាប់

គឺជាការកាន់កាប់ដែលអាចធ្វើការផ្ទេរតាមការព្រមព្រៀងរបស់ភាគីដោយមិនចាំបាច់ធ្វើការប្រគល់ជាក់ស្តែងនោះទេ។ ករណីនេះ អនុប្បទានិកនៃការកាន់កាប់ធ្វើលទ្ធកម្មដោយប្រយោលតាមរយៈអនុប្បទាយី (មាត្រា២២៩ កថាខ័ណ្ឌទី២)។

ឧទាហរណ៍៖ X បានលក់រថយន្តឲ្យ Y បន្ទាប់មកទៀត X បានជួលរថយន្តនោះ ពី Y វិញ។ ដោយ នៅតែបន្តការកាន់កាប់ និងប្រើប្រាស់ទៀត បើយើងមើលពីខាងក្រៅឃើញ ថា ការកាន់កាប់នោះមិនបានផ្ទេរទេ ប៉ុន្តែជាក់ស្តែង ការកាន់កាប់បានផ្ទេរទៅ Y តាមការព្រមព្រៀងរបស់ភាគីរួចហើយដោយផ្អែកលើកិច្ចសន្យាលក់-ទិញ និងកិច្ចសន្យាជួល។ ក្នុងករណីនេះ X ជាអ្នកកាន់កាប់ដោយផ្ទាល់ហើយ Y ជាអ្នកកាន់កាប់ដោយប្រយោល។

### ❖ ការប្រគល់ដោយសង្ខេប

ការប្រគល់ដោយសង្ខេបគឺសំដៅដល់ការផ្ទេរការកាន់កាប់តាមរយៈការព្រមព្រៀងរបស់ភាគី ក្នុងករណីអនុប្បទានិកបានក្តាប់ទុកវត្ថុដែលជាកម្មវត្ថុនៃការកាន់កាប់ នោះនៅក្នុងដៃតាមការជាក់ស្តែង ហើយអនុប្បទាយីបានបាត់បង់ការកាន់កាប់ដោយប្រ យោលរបស់ខ្លួនធ្លាប់មាន។

ឧទាហរណ៍៖ X បានជួលរថយន្តពី Y ហើយក្រោយមកទៀត X បានទិញ រថយន្តដែលគាត់ជួលនោះពី Y មក ។ ក្នុងករណីនេះ Y បានបាត់បង់ការកាន់កាប់ ដោយ ប្រយោលរបស់គាត់តាមរយៈ X ព្រោះថា Y មិនបានកាន់កាប់វត្ថុដោយចំពោះតាំងពីដើមមកហើយ លុះដល់ពេលការលក់-ទិញកើតឡើងគាត់មិនមានវត្ថុដែលត្រូវប្រគល់ឲ្យ X ទេ នេះគឺជាការប្រគល់ដោយសង្ខេប។

### ❖ ការផ្ទេរការកាន់កាប់ដោយបញ្ជា

សំដៅទៅលើអ្នកកាន់កាប់ដោយប្រយោលបានបង្កើតនូវកិច្ចព្រមព្រៀងផ្ទេរការកាន់កាប់ទៅឲ្យ តតិយជន និងមានករណីកិច្ចត្រូវជូនដំណឹងអំពីហេតុនោះទៅឲ្យអ្នកកាន់កាប់ដោយចំពោះលើវត្ថុនោះបានដឹង។

ឧទាហរណ៍៖ X ជួលផ្ទះឲ្យ Y ហើយស្ថិតក្នុងកំឡុងពេលជួលនោះ X បានលក់ផ្ទះនោះឲ្យទៅ Z ។ដោយ X និង Z មានការព្រមព្រៀងគ្នាដើម្បីផ្ទេរកម្មសិទ្ធិ ដូច្នេះ X មានករណីកិច្ចត្រូវជូនដំណឹងឲ្យ Y បានដឹងអំពីការផ្ទេរកម្មសិទ្ធិនេះដើម្បីឲ្យ Y ដឹងថា Y កាន់កាប់ដោយចំពោះលើទ្រព្យរបស់អ្នកណា។

ផ្អែកតាមស្ថានភាព 4 ខាងលើយើងឃើញថា ការផ្ទេរការកាន់កាប់ អាចត្រូវមានណា មួយក្នុងចំណោម 4 ប្រភេទដែលបានចែងក្នុង មាត្រា229 នៃក្រមរដ្ឋប្បវេណី។

ទោះបីយ៉ាងណាដើម្បីការពារការធ្វើលទ្ធកម្មនូវកម្មវត្ថុទៅតតិយជនដោយសុចរិត (មាត្រា894-1,193) ដូចជាវិធានការនៃការជូនដំណឹង និង\ឬបិទស្លាកសំគាល់កម្មវត្ថុនៃប្រាតិភោគនឹងមានអត្ថប្រយោជន៍។

ប្រសិនបើចលនវត្ថុមានស្លាកសំគាល់បែបនេះ តតិយជនអាចដឹងថាចលនវត្ថុនោះគឺស្ថិតនៅក្រោមសិទ្ធិប្រាតិភោគដោយអនុប្បទាន។ បើទោះបីជាតតិយជនមិនបានគត់សម្គាល់ឃើញស្លាកសំគាល់ក៏ដោយៗ ម្ចាស់សិទ្ធប្រាតិភោគអាចបង្កាការធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃចលនវត្ថុបានពីការធ្វើលទ្ធកម្មដោយសុចរិត។

វិធីសាស្ត្រនៃ " ការផ្ទេរការកាន់កាប់ដោយកិច្ចព្រមព្រៀង " កិច្ចសន្យានៃប្រាតិភោគដោយអនុប្បទានមានចែងថា" នៅថ្ងៃនៃកិច្ចសន្យានេះ Y ផ្ទេរការកាន់កាប់លើម៉ាស៊ីនដែលជា កម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានឲ្យទៅ X ដោយកិច្ចព្រមព្រៀង" ។ ប្រសិនបើកិច្ចសន្យាមានចែងដូច្នេះ នោះការផ្ទេរការកាន់កាប់ដោយកិច្ចព្រមព្រៀងត្រូវបានបំពេញ។ ម៉ាស៊ីននេះមិនអាចផ្លាស់ទីបានទេ។ ដូច្នេះ Y អាចបន្តការកាន់កាប់ម៉ាស៊ីនដោយចំពោះ ហើយ X បានទទួលការកាន់កាប់ដោយប្រយោលលើម៉ាស៊ីននោះ CC228។



**មាស៊ីននេះស្ថិតនៅក្រោមសិទ្ធិប្រាតិភោគរបស់ B**

យោងតាមបញ្ញាតិនៃមាត្រា៨៩៤ ម្ចាស់សិទ្ធិប្រាតិភោគមិនអាចយកសិទ្ធិប្រាតិភោគដោយអនុប្បទានទៅតតាំងចំពោះតតិយជនបានឡើយ ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងមាត្រា១៩៣។ ត្រង់នេះហើយដែលប្រាតិភោគដោយអនុប្បទាននៅតែមានចន្លោះខ្វះខាត ក្នុងការការពារម្ចាស់សិទ្ធិប្រាតិភោគ។ វិធានការណ៍មួយដែលអាចឲ្យម្ចាស់សិទ្ធិប្រាតិភោគតតាំងនិងតតិយជនបាននោះ គឺមានតែការបិទស្លាកសញ្ញាសំគាល់លើវត្ថុ ដើម្បីឲ្យតតិយជនបានដឹងថា វត្ថុនោះកំពុងស្ថិតក្រោមសិទ្ធិប្រាតិភោគកិច្ចព្រមព្រៀងគួរតែត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ។

**មុនពេលការផ្ទេរការកាន់កាប់**

X Y

កាន់កាប់ដោយចំពោះ

**ក្រោយពេលការផ្ទេរការកាន់កាប់**




**កាន់កាប់ដោយចំពោះ:**




## ៣. អានុភាព

### ៣.១. អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទានមានអានុភាពលើ៖

- វត្ថុភ្ជាប់: វត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និងជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។[62] ឧ. ពូករបស់សាឡុង, គ្រឿងសង្ហារឹមដូចជា កៅអីដែលមានភ្ជាប់ជាមួយនឹងតុ។ វត្ថុភ្ជាប់ត្រូវបានចែកចេញជាពីរគឺ៖

- សមាសភាគនៃវត្ថុ: ចំពោះសមាសភាគនៃវត្ថុអ្វីមួយដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ។[63]

[62] មាត្រា ៨៩១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី
[63] មាត្រា ១២១ នៃក្រមរដ្ឋប្បវេណី

ឧ. កង់ កញ្ចក់ បំពង់ស៊ីមាំង នៃរថយន្ត ...។

- វត្ថុចំនុះ: វត្ថុដែលភ្ជាប់ទៅនឹងវត្ថុចម្បងហើយបង្កើននូវតំលៃនៃវត្ថុចម្បងជាបន្តបន្ទាប់។[64]

ឧ. ចិញ្ចៀនដែលមានដាំត្បូងពេជ្រ, ខ្សែកដែលមានដាំត្បូង...។

<u>**ករណីលើកលែង:**</u> ភាគីអាចដកចេញ "វត្ថុចំនុះ" ពីអានុភាពនៃប្រាតិភោគដោយអនុប្បទានដោយកិច្ចព្រមព្រៀង យោងតាម CC 891-2, 126-2 ។ ប៉ុន្តែ ភាគីមិនអាចដកចេញ "សមាសភាគនៃវត្ថុ" ពីអានុភាពនៃប្រាតិភោគដោយអនុប្បទាន ទោះបីជាភាគីបានយល់ព្រមគ្នាក៏ដោយ យោងតាម CC 121 ដែលជាទូទៅត្រូវបានចាត់ទុកជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

### ៣.២. ផលដែលអាចកើតមានឡើងពីវត្ថុនៃប្រាតិភោគដោយអនុប្បទាន (CC892)

| អ្នកកាន់កាប់ | ផល |
|---|---|
| Y ឬតតិយជនទទួលការបញ្ជាពី Y | ឧ. Y បានបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានលើរថយន្តមួយគ្រឿងជាមួយនឹង X ហើយ Y បានជួលរថយន្តនោះទៅឲ្យ Z។<br>**តើថ្លៃឈ្នួលរថយន្តនោះត្រូវបានទៅលើអ្នកណា?**<br>Y អាចទទួលបានផលនោះ (CC892-1)។ ប៉ុន្តែបើផុតអំឡុងពេលនៃប្រាតិភោគដោយអនុប្បទាន X តម្រូវឲ្យប្រគល់ CC898-2 (ការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានជាស្ថាពរ) Y ត្រូវឲ្យផលនោះទៅឲ្យ X។ |
| X ឬតតិយជនទទួលការបញ្ជាពី X | ឧ. X ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលើរថយន្តមួយគ្រឿងដែល Y បានផ្ទេរការកាន់កាប់ដោយចំពោះ ហើយ X បានជួលរថយន្តនោះទៅឲ្យ Z។<br>**តើថ្លៃឈ្នួលរថយន្តនោះត្រូវបានទៅលើអ្នកណា?**<br>X អាចទទួលបានផលសមរម្យទៅតាមការទាមទាររបស់គាត់ CC892-2, 822 (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព)។ |

* ប្រសិនបើ X ឬតតិយជនទទួលការបញ្ជាពី X កាន់កាប់ដោយផ្ទាល់លើវត្ថុនៃប្រាតិភោគដោយអនុប្បទាន:

- X អាចទទួលបានផលសមរម្យទៅតាមការទាមទាររបស់គាត់ (CC892-2, 822)។

[64] មាត្រា ១២៦ នៃក្រមរដ្ឋប្បវេណី

- X អាចឃាត់ទុកវត្ថុ (CC821) ។
- X ត្រូវទទួលបន្ទុកកាតព្វកិច្ចថែរក្សាជាអ្នកគ្រប់គ្រងដោយសុចរិត (CC823)។
- X អាចទាមទារសំណងនៃការចំណាយសម្រាប់ការគ្រប់គ្រង និងថែរក្សា (CC824)។
- X អាចប្រើប្រាស់វត្ថុ ឬ អត់គឺអាស្រ័យទៅតាមកិច្ចព្រមព្រៀងរវាង X និង Y។ ប្រសិន បើកិច្ចព្រមព្រៀងនេះមិនបានបញ្ជាក់នោះទេ X អាចប្រើប្រាស់វត្ថុនោះបានត្រឹមតែកម្រិតដែលចាំបាច់ក្នុងការថែរក្សាវត្ថុនោះប៉ុណ្ណោះ (CC831)។

## ៣.៣. ការចាត់ចែងប្រាតិភោគដោយអនុប្បទាន

**ករណីទី 1:** Y ធ្វើអាជីវកម្មរោងចក្រមួយ។ វត្ថុនៃប្រាតិភោគដោយអនុប្បទានគឺម៉ាស៊ីនមួយក្នុងរោងចក្ររបស់ Y។ Y បានរក្សាការកាន់កាប់ម៉ាស៊ីនដោយផ្ទាល់ ប៉ុន្តែ Y បានលក់ម៉ាស៊ីននោះទៅឲ្យ Z ដោយគ្មានការយល់ព្រមពី X។




**តើ X អាចប្រើសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់គាត់ចំពោះម៉ាស៊ីនបានដែរឬទេ ដែលបច្ចុប្បន្ននេះត្រូវបានគ្រប់គ្រងនិងកាន់កាប់ដោយ Z?**

ប្រសិនបើ Z បានទទួលការកាន់កាប់ម៉ាស៊ីនដោយសុចរិត និងគ្មានកំហុស:

Z ទទួលបានកម្មសិទ្ធិលើម៉ាស៊ីនដោយគ្មានបន្ទុកសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ X មានន័យថា**សិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ X ត្រូវបានរលត់** (CC894-1) ។

ក្នុងករណីនេះ X មិនអាចទាមទារម៉ាស៊ីនពី Z បានឡើយ។ ដោយឡែក X អាចទាមទារសិទ្ធិលើបំណុល និងសំណងការខូចខាតពី Y ដោយសារតែការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល

(CC331-ខ) និងការបំពានកិច្ចសន្យា (CC398-1) ព្រោះ Y បានធ្វើឲ្យសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ X រលត់។ ដូច្នេះ X អាចទាញយកវិធានការណ៍ដូចខាងក្រោមៈ

1) ទាមទារឲ្យ Y សងជាប្រាក់បំណុល និងសំណងការខូចខាត ឬ

2) អនុវត្តរឹបអូសប្រាក់ថ្លៃទិញម៉ាស៊ីនដែល Z ត្រូវបង់ទៅឲ្យ Y (CC893-1, CCP506)។

ប្រសិនបើ Z បានទទួលការកាន់កាប់ម៉ាស៊ីនដោយទុចរិត និងមានកំហុសៈ

Z អាចទទួលបានកម្មសិទ្ធិលើម៉ាស៊ីនជាបន្ទុកនៃសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ X បាន ប៉ុន្តែ X អាចប្រើសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ខ្លួនទារយកម៉ាស៊ីនបាន (CC894-1) ។ ប្រសិនបើ Y ខកខានក្នុងការសងប្រាក់តាមពេលកំណត់ នោះ X អាចប្រើសិទ្ធិប្រាតិភោគដោយអនុប្បទានតាមរយៈការជូនដំណឹង (CC898-2) ទៅ Z ឲ្យប្រគល់ម៉ាស៊ីននោះមកវិញ។

* CC893-1-2: X ត្រូវអនុវត្តការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្នចំពោះការទាមទារលើប្រាក់ទិញលក់របស់ Y ពី Z មុនពេល Z បានបង់ប្រាក់ទៅឲ្យ Y។ នេះគឺដោយសារតែនៅពេលដែល Z បានបង់ប្រាក់ទៅឲ្យ Y នោះប្រាក់និងលាយឡំគ្នាជាមួយទ្រព្យសម្បត្តិផ្សេងទៀតរបស់ Y ដែលក្លាយទៅជាមិនអាចបែងចែកពីទ្រព្យសម្បត្តិផ្សេងទៀតរបស់ Y។

**ករណីទី 2:** Y ធ្វើអាជីវកម្មបើកហាងលក់រូបភាពមួយ។ វត្ថុនៃប្រាតិភោគដោយអនុប្បទានគឺរូបភាពទាំងអស់នៅក្នុងហាងរបស់ Y ហើយ Y បានរក្សាការកាន់កាប់រូបភាពដោយផ្ទាល់។ Y បានបន្តដំណើរការអាជីវកម្មរបស់ខ្លួនលក់រូបភាពទាំងនោះនិងបានលក់រូបភាពមួយទៅឲ្យ Z (រូបភាពQ)។




**តើ X អាចប្រើប្រាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន របស់ខ្លួនចំពោះរូបភាពQបានដែរឬទេ ដែលឥឡូវនេះត្រូវបានគ្រប់គ្រងនិងកាន់កាប់ដោយ Z?**

ទោះបី Z បានទទួលការកាន់កាប់លើរូបភាពដោយទុចរិត និងមានកំហុសក៏ដោយក៏ Z អាចទទួលបានកម្មសិទ្ធិលើរូបភាព Q ដោយគ្មានបន្ទុកនៃសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ X បាន មានន័យថាសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ X លើរូបភាព Q ត្រូវបានរលត់ (CC 894-2)។ លើសពីនេះទៀត X មិនអាចអនុវត្តសិទ្ធិនៃប្រាតិភោគដោយអនុប្បទានលើការទាមទារប្រាក់ថ្លៃលក់ទិញរបស់ Y ពី Z បានដែរ (CC893-2)។

**ករណីទី3:** Y បានបើកដំណើរការរោងចក្រមួយកន្លែង ប៉ុន្តែត្រូវផ្អាកដំណើរការរោងចក្រមួយរយៈក្នុងគោលបំណងដើម្បីរៀបចំសម្រាប់អាជីវកម្មថ្មី។ Y ខ្ចីប្រាក់ពី X ដើម្បីវិនិយោគក្នុងអាជីវកម្មថ្មី និងប្រគល់ម៉ាស៊ីនចាស់មួយគ្រឿងទៅឲ្យ X សម្រាប់ជាប្រាតិភោគ។ Y បានផ្ទេរការកាន់កាប់ដោយផ្ទាល់លើម៉ាស៊ីនទៅឲ្យ X។ X ត្រូវបានគេសន្មតថាបានរក្សាម៉ាស៊ីនជាមួយគាត់ ប៉ុន្តែគាត់បានលក់ម៉ាស៊ីនទៅ Z។




**តើ Z អាចទទួលបានកម្មសិទ្ធិនៃម៉ាស៊ីននេះដែរឬទេ?**

ប្រសិនបើ Z បានទទួលសិទ្ធិកាន់កាប់ម៉ាស៊ីនដោយសុចរិត និងគ្មានកំហុស

Z ទទួលបានកម្មសិទ្ធិលើម៉ាស៊ីន ហើយ Y បាត់បង់កម្មសិទ្ធិលើម៉ាស៊ីន។ ក្នុងករណីនេះ Y អាចទាមទារសំណងការខូចខាត ដោយផ្អែកលើការបំពាននៃកិច្ចព្រមព្រៀង យោងតាម (CC398) ឬ អំពើអនីត្យានុកូល (CC743) ។

ប្រសិនបើ Z បានទទួលសិទ្ធិកាន់កាប់ម៉ាស៊ីន ដោយទុចរិត និងមានកំហុស

Z មិនទទួលបានកម្មសិទ្ធិលើម៉ាស៊ីននេះទេ។ ក្នុងករណីនេះ Y អាចទាមទារឲ្យ Z ប្រគល់ម៉ាស៊ីនត្រឡប់មកវិញដោយផ្អែកលើកម្មសិទ្ធិរបស់ Y។ លើសពីនេះទៀត Y អាចទាមទារឲ្យរលត់នៃសិទ្ធិប្រាតិភោគដោយអនុប្បទាន (CC 896, 823-2) បាន។

## ៣.៤. ការខូចខាតឬការបាត់បង់វត្ថុនៃប្រាតិភោគដោយអនុប្បទាន

**ករណីទី 1:** នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង និងកំណត់សងប្រាក់រយៈពេល ០១ឆ្នាំ។ ប៉ុន្តែនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៦ ម៉ាស៊ីននោះបានខូចប្រើប្រាស់លែងកើត ។

**តើ X ត្រូវធ្វើដូចម្តេច បើបច្ចុប្បន្ននេះម៉ាស៊ីនខូចទៅហើយ?**




Y បាត់បង់ផលប្រយោជន៍នៃការកំណត់ពេល (CC 331-ខ) ។ ហេតុនេះហើយ X អាចទាមទារការទូទាត់សងសិទ្ធិលើបំណុលពី Y។ លើសពីនេះទៀត ប្រសិនបើ Y បានទទួលសិទ្ធិសម្រាប់ការទូទាត់ធានារ៉ាប់រងទៀតនោះ X អាចអនុវត្តការរឹបអូសការធានារ៉ាប់រងរបស់ Y (CC893-1, CCP506) ។

| |
|---|
| **ករណីទី 2:** នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង និងកំណត់សងប្រាក់រយៈពេល ០១ឆ្នាំ។ ក្រោយពីខ្ចីប្រាក់រួច Y បានព្យាយាមលាក់ទុកម៉ាស៊ីននោះ។<br>**តើ X ត្រូវធ្វើដូចម្តេច បើបច្ចុប្បន្ននេះម៉ាស៊ីនត្រូវបាន Y យកទៅលាក់ទុកបាត់ហើយ?** |




- X អាចដាក់ពាក្យសុំចាត់ចែងរក្សាការពារចំពោះម៉ាស៊ីនដែលជាកម្មវត្ថុនៃវិវាទ ដើម្បីហាមឃាត់ការផ្ទេរការកាន់កាប់របស់ Y (CCP 531-B, 571) ហើយម៉ាស៊ីននោះ ត្រូវបានរក្សាទុកដោយអាជ្ញាសាលា(CCP570, 565-1) ។ ប្រសិនបើម៉ាស៊ីននោះមានហានិភ័យនៃការថយចុះតម្លៃធ្ងន់ធ្ងរ ឬការចំណាយដើម្បីរក្សាទុកម៉ាស៊ីននេះខ្ពស់ពេក អាជ្ញាសាលាអាចលក់ម៉ាស៊ីនបាន (CCP 570, 565-3) ហើយផ្ញើប្រាក់នោះនៅតុលាការដែលអាជ្ញាសាលាស្ថិតនៅ។

- X អាចដាក់ពាក្យសុំចាត់ចែងរក្សាការពារ ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ដើម្បីឲ្យ Y ប្រគល់ម៉ាស៊ីនទៅ X បាន (CCP531-C, 570)។ ក្នុងករណីនេះ X អាចទទួលបានការកាន់កាប់ដោយផ្ទាល់។ ទោះជាយ៉ាងណាការចាត់ចែងរក្សាការពារដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ត្រូវបានទទួលយកដោយតឹងរ៉ឹង (CCP 548-B)។

**ករណីទី3 ៖** នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿងនិងកំណត់សងប្រាក់រយៈពេល០១ឆ្នាំ។ ស្រាប់តែនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ X បានទៅយកម៉ាស៊ីននោះចេញដោយគ្មានការយល់ព្រមពី Y ឡើយ។
**តើ Y អាចទាមទារយកម៉ាស៊ីននោះមកវិញបានដែរឬទេ បើបច្ចុប្បន្ន X កំពុងតែកាន់កាប់ និងគ្រប់គ្រងលើម៉ាស៊ីននេះ?**




Y អាចទាមទារឲ្យ X ប្រគល់ម៉ាស៊ីនមកវិញបានដោយផ្អែកលើភាពជាម្ចាស់កម្មសិទ្ធិរបស់ Y (CC155)។ ម្យ៉ាងទៀត Y អាចទាមទារសំណងការខូចខាត ដោយសារការបំពាននៃកិច្ចព្រមព្រៀងរបស់ X យោងតាម (CC398) ឬ អំពើអនីត្យានុកូល (CC743) ដោយសារតែការរំលោភលើភាពជាកម្មសិទ្ធិរបស់ X ទៅលើ Y។

## ៣.៥. ការរឹបអូសចំពោះវត្ថុនៃប្រាតិភោគដោយអនុប្បទាន

**ករណីទី1:** Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង។ Y បានរក្សាការកាន់កាប់ម៉ាស៊ីនដោយផ្ទាល់ ប៉ុន្តែ Z ដែលជាម្ចាស់បំណុលផ្សេងទៀតរបស់ Y បានធ្វើការអនុវត្តដោយបង្ខំរឹបអូសយកម៉ាស៊ីននោះទៅលក់ដើម្បីសងបំណុល។
**តើ X ត្រូវធ្វើដូចម្ដេច បើពេលនេះ Z កំពុងរឹបអូសយកម៉ាស៊ីននេះ?**




X អាចដាក់ពាក្យបណ្ដឹងតវ៉ាដោយតតិយជន (CCP 365) ដែលមានមូលដ្ឋានលើសិទ្ធិប្រាតិភោគដោយអនុប្បទាន។

**ករណីទី 2:** Y ខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដើម្បីវិនិយោគក្នុងអាជីវកម្មមួយ និងបានប្រគល់ម៉ាស៊ីនមួយគ្រឿងទៅឲ្យ X សម្រាប់ជាប្រាតិភោគ។ Y បានផ្ទេរការកាន់កាប់ដោយផ្ទាល់លើម៉ាស៊ីនទៅឲ្យ X។ ប៉ុន្តែ Z ដែលជាម្ចាស់បំណុលរបស់ X បានមកធ្វើការអនុវត្តដោយបង្ខំរឹបអូសយកម៉ាស៊ីននោះ។
**តើ Y ត្រូវធ្វើដូចម្ដេច បើពេលនេះ Z កំពុងរឹបអូសយកម៉ាស៊ីននេះ?**




Y អាចដាក់ពាក្យបណ្ដឹតវ៉ាដោយតតិយជន (CCP 365) ដោយផ្អែកលើកម្មសិទ្ធិ។

# ៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

នីតិវិធីការអនុវត្តន៍ប្រាតិភោគដោយអនុប្រទានត្រូវបានអនុវត្តនៅខាងក្រៅតុលាការ។

## ៤.១. លំហូរ

1) សេចក្តីជូនដំណឹងពី X ទៅ Y (CC898-1) ។

2) Y ត្រូវប្រគល់វត្ថុទៅ X (CC898-2 ) ។

3) ប្រសិនបើតម្លៃនៃវត្ថុលើសពីទំហំសិទ្ធិលើបំណុលប្រាតិភោគ X ត្រូវប្រគល់ត្រឡប់មកវិញនូវចំនួនទឹកប្រាក់លើសនេះទៅ Y ជាប្រាក់ជម្រះ (CC898-3) ។ ប្រសិនបើតម្លៃនៃវត្ថុនោះមិនលើសពីចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលប្រាតិភោគទេ X ត្រូវផ្តល់ដំណឹងដល់ Y ពីការពិតដែលថាតម្លៃនៃវត្ថុនោះមិនលើសពីចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលប្រាតិភោគឡើយ។

* ជាទូទៅត្រូវបាននិយាយថាចំនួនទឹកប្រាក់ជម្រះ ត្រូវធ្វើឡើងដោយយកចំនួនទឹកប្រាក់នៃតម្លៃត្រឹមត្រូវរបស់វត្ថុដកចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលប្រាតិភោគ។ ក្នុងករណីម្ចាស់សិទ្ធិប្រាតិភោគបានបម្លែងវត្ថុទៅជាសាច់ប្រាក់ តម្លៃត្រឹមត្រូវនៃវត្ថុនឹងត្រូវបានគណនានៅពេលបម្លែង។ ក្នុងករណីម្ចាស់សិទ្ធិប្រាតិភោគធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ នោះតម្លៃត្រឹមត្រូវនៃវត្ថុនឹងត្រូវបានគណនានៅពេលទូទាត់នៃប្រាក់ជម្រះ។

**ករណីទី 1:** Y បានខ្ចីប្រាក់ពី X ដើម្បីវិនិយោគក្រុមហ៊ុនថ្មីមួយ ហើយបានបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង។ Y បានរក្សាការកាន់កាប់ម៉ាស៊ីនដោយផ្ទាល់។ ដោយសារតែ Y មិនបានបំពេញកាតព្វកិច្ចតាមការសន្យា X បានទាមទារឲ្យ Y ប្រគល់ម៉ាស៊ីន ប៉ុន្តែ Y បានបដិសេធមិនប្រគល់។
**តើ X ត្រូវធ្វើដូចម្តេច?**




X អាចដាក់ពាក្យសុំចាត់ចែងរក្សាការពារដែលកំណត់ឋានៈជាបណ្តោះអាសន្ន ដើម្បីឲ្យ Y ប្រគល់នូវម៉ាស៊ីនទៅឲ្យ X បាន (CCP 531-គ)។ ហើយ X អាចដាក់ពាក្យបណ្តឹងទាមទារឲ្យ Y ប្រគល់ម៉ាស៊ីននេះ។

**ករណីទី 2:** ដោយសារតែ Y មិនមានប្រាក់សងបំណុលប្រាតិភោគរបស់ X។ X បានធ្វើការវាយតំលៃទៅលើម៉ាស៊ីនដែលជាប្រាតិភោគនោះ មានតម្លៃលើសពីបំណុល។ ដូច្នេះ X បានបង់ប្រាក់ជម្រះទៅឲ្យ Y ប៉ុន្តែ Y គិតថាចំនួនទឹកប្រាក់នេះគឺមិនទាន់គ្រប់គ្រាន់នៅឡើយ។
**តើ Y ត្រូវធ្វើដូចម្ដេច?**




- Y អាចបដិសេធក្នុងការប្រគល់ម៉ាស៊ីនទៅឲ្យ X បានដោយផ្អែកលើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (CC386) ឬសិទ្ធិឃាត់ទុក (CC 774)។

- Y អាចដាក់ពាក្យបណ្ដឹងចំពោះ X ទាមទារឲ្យមានការទូទាត់ចំនួនទឹកប្រាក់ត្រឹមត្រូវនៃប្រាក់ជម្រះ។

**ករណីទី 3:** Y បានប្រគល់ម៉ាស៊ីនមួយគ្រឿងទៅឲ្យ X ដើម្បីទូទាត់បំណុលប្រាតិភោគ។ ក្រោយពីប្រគល់រួច Y បានឈ្នះឆ្នោតជាតិ ហើយមានប្រាក់គ្រប់គ្រាន់សំរាប់ទូទាត់បំណុល។ ដូច្នេះ Y មានបំណងចង់បានម៉ាស៊ីននោះត្រឡប់មកវិញ។
**តើ Y ត្រូវធ្វើដូចម្ដេច?**




- Y អាចទទួលបានម៉ាស៊ីនដែលជាកម្មវត្ថុនៃប្រាតិភោគវិញដោយផ្អែកលើសិទ្ធិទទួលយកមកវិញ(CC899) ទោះបីជាពេលកំណត់ត្រូវសងកាតព្វកិច្ចបានកន្លងផុតក៏ដោយ។

- Y អាចដាក់ពាក្យបណ្ដឹងចំពោះ X ទាមទារឲ្យ X ប្រគល់ម៉ាស៊ីនជាកម្មវត្ថុនៃប្រាតិភោគទៅ Y វិញ។

* ជាទូទៅសិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើតមិនអាចធ្វើបានឡើយ នៅក្រោយពេលមានការផ្តល់ប្រាក់ជម្រះ (CC 898-3) ឬ នៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគ បានជូនដំណឹងអំពីចំនួនដែលមិនលើសនេះទៅឲ្យអ្នកបង្កើតក្នុងករណីតម្លៃវត្ថុមិនលើសពីចំនួនបំណុលប្រាតិភោគ។

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងប្រាតិភោគ

**ម្ចាស់សិទ្ធិប្រាតិភោគៈ**# លោក............... អាយុ............ ជនជាតិ.......កាន់អត្ត សញ្ញាណប័ណ្ណលេខ.....................ចុះថ្ងៃទី........ខែ......ឆ្នាំ........ មានទីលំនៅស្ថិតនៅ ផ្ទះលេខ......ក្រុមទី........ភូមិ........ ឃុំ .......... សង្កាត់............ ខេត្ត/រាជធានី.................ជាម្ចាស់បំណុលហៅកាត់ ថា ភាគី “ក” ទូរស័ព្ទលេខៈ xxxxxxxx ។#

**និង**

**អ្នកបង្កើតប្រាតិភោគៈ** លោក.................អាយុ............ ជនជាតិ.......កាន់អត្ត សញ្ញាណប័ណ្ណលេខ.....................ចុះថ្ងៃទី........ខែ......ឆ្នាំ........ មានទីលំនៅស្ថិតនៅ ផ្ទះលេខ......ក្រុមទី........ភូមិ........ ឃុំ .......... សង្កាត់............ ខេត្ត/រាជធានី.................ជាកូនបំណុលហៅកាត់ ថា ភាគី “ខ” ទូរស័ព្ទលេខៈ xxxxxxxxxx។#

ភាគីទាំងពីរបានព្រមព្រៀងនិងឯកភាពគ្នាដោយសុឆន្ទៈអនុវត្តន៍តាមប្រការដូចខាងក្រោម៖#

**ប្រការ១៖** ភាគី “ក” បានឲ្យភាគី “ខ” ខ្ចីប្រាក់ចំនួន........... ដុល្លាអាមេរិកគត់ #

**ប្រការ២៖** ភាគី “ខ” បានទទួលប្រាក់ចំនួន. ........... ដុល្លាអាមេរិកគត់ ពីភាគី “ក”នៅថ្ងៃទី......ខែ......ឆ្នាំ......... សម្រាប់រយៈពេល............ គិតចាប់ពីថ្ងៃចុះកិច្ចសន្យារហូត ដល់ថ្ងៃទី......ខែ..........ឆ្នាំ.......... នឹងត្រូវសងប្រាក់ជំពាក់ឲ្យមកភាគី "ក" វិញយ៉ាងយូរត្រឹមថ្ងៃទី...........ខែ..........ឆ្នាំ..........។

**ប្រការ៣៖** ថ្ងៃនេះ ភាគី "ខ" បានផ្ទេរកម្មសិទ្ធនៃទ្រព្យសម្បត្តិដែលបានរៀបរាប់ខាងក្រោម ( ការពណ៌នាពី"លក្ខណៈនៃទ្រព្យសម្បត្តិ") ទៅភាគី"ក" ក្នុងគោលបំណងធានាសិទ្ធិលើ

បំណុលរបស់ភាគី "ក" សម្រាប់ការទូទាត់សងប្រាក់ពីភាគី "ខ" ដែលបានខ្ចីដោយយោងលើមាត្រាទី 1 និងទី 2 នៃកិច្ចសន្យានេះ។

ការពណ៌នាពីលក្ខណៈនៃទ្រព្យសម្បត្តិ

**ប្រការ៤៖** ថ្ងៃនេះ ភាគី"ខ" បានផ្ទេរការកាន់កាប់នៃទ្រព្យសម្បត្តិទៅភាគី "ក" ដោយការប្តូលក្ខណៈនៃការកាន់កាប់។

**ប្រការ៥៖** ភាគី "ក" យល់ព្រមនិងបានអនុញ្ញាតឲ្យភាគី "ខ" បន្តការកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិនោះ ហើយភាគី "ខ" បានយល់ព្រម។

**ប្រការ៦៖** ភាគី"ខ"ត្រូវចាត់វិធានការសមស្របជូនដំណឹងជាសាធារណៈពីទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ភាគី "ក"។ ប្រសិនបើភាគី "ខ" មិនចាត់វិធានការណាមួយទេ នោះភាគី "ក" អាចចាត់វិធានកាជំនួសភាគី "ខ" ហើយនៅក្នុងករណីនេះ ភាគី "ក" អាចទាមទារសំណងនៃការចំណាយក្នុងការចាត់វិធានការនោះពី ភាគី"ខ" ។

**ប្រការ៧៖** ក្នុងអំឡុងពេលខ្ចីប្រាក់ ភាគី "ខ" បានយល់ព្រមបង់ការប្រាក់ ........... ស្មើ ....... % ក្នុងមួយខែនៅលើចំនួនទឹកប្រាក់សរុបទៅភាគី "ក" យ៉ាងយូរនៅថ្ងៃ ..... ... ..... .....

**ប្រការ៨៖** ភាគី"ខ" នឹងបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលនៅក្នុងករណីដូចខាងក្រោមនេះ៖

(1) ភាគី"ខ" បានផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទៅតតិយជនមួយដោយគ្មានការយល់ព្រមពី ភាគី"ក" ។

(2) ភាគី"ខ" ដកយកចេញវិធានការនៃការជូនដំណឹងតាមមាត្រា 6 នៃកិច្ចសន្យានេះ។

**ប្រការ៨៖** ការកែប្រែណាមួយនៃកិច្ចសន្យាឬបន្ថែមខ្លឹមសារផ្សេងៗ អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមនិងកិច្ចព្រមព្រៀងពីភាគីទាំងសងខាង។

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

# ក្រុមការងារ

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# មេរៀន ភាគ ២

# មាតិកា

**គន្លឹះទី៤ ភាតព្វកិច្ច** ........ ១

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ** ........ ១

**ផ្នែកទី៣ លក្ខខណ្ឌ កំណត់ពេល និងអំឡុងពេល** ........ ១

១. និយមន័យនៃលក្ខខណ្ឌ ........ ១

១.១. លក្ខខណ្ឌ ........ ១

១.២. លក្ខខណ្ឌបង្អង់ ........ ១

១.៣. លក្ខខណ្ឌរំលាយ ........ ១

២. ការចាត់ចែងសិទ្ធិដែលភ្ជាប់ជាមួយលក្ខខណ្ឌ ........ ២

៣. ការបំពានសិទ្ធិដែលភ្ជាប់ជាមួយលក្ខខណ្ឌ ........ ២

៣.១. ការទទួលខុសត្រូវក្នុងការមិនគោរពអនុវត្តកាតព្វកិច្ច ........ ២

៣.២. ការទទួលខុសត្រូវលើអំពើអនីត្យានុកូល ........ ២

៤. ការចាត់ទុកថាលក្ខខណ្ឌត្រូវបានបំពេញ ........ ២

៥. និយមន័យនៃការកំណត់ពេល ........ ៣

៥.១. ការកំណត់ពេលពិតប្រាកដ និងការកំណត់ពេលមិនពិតប្រាកដ ........ ៣

ក. ការកំណត់ពេលពិតប្រាកដ ........ ៣

ខ. ការកំណត់ពេលមិនពិតប្រាកដ ........ ៣

៥.២. ការកំណត់ពេលទាក់ទងនឹងអានុភាពនៃកិច្ចសន្យា និងកំណត់ពេលទាក់ទងនឹងពេលអនុវត្ត ........ ៣

ក. ការកំណត់ពេលទាក់ទងនឹងអានុភាពនៃកិច្ចសន្យា ........ ៣

ខ. ការកំណត់ពេលទាក់ទងនឹងពេលអនុវត្ត ........ ៣

៦. ប្រយោជន៍នៃការកំណត់ពេល ........ ៣

៧. ការបោះបង់ផលប្រយោជន៍នៃការកំណត់ពេល ........ ៤

៨. របៀបកំណត់អំឡុងពេល ........ ៥

៩. ការគណនាកំណត់អំឡុងពេលជា ម៉ោង នាទី ឬ វិនាទី ........ ៥

១០. ការគណនាកំណត់អំឡុងពេលជា ថ្ងៃ សប្ដាហ៍ ខែ ឬ ឆ្នាំ ........ ៥

១១. ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ ........ ៦

**ជំពូកទី២ ការបង្ហាញឆន្ទៈ និងកិច្ចសន្យា** ..... ៧
**ផ្នែកទី ១ ការបង្កើតកិច្ចសន្យា** ..... ៧
១. ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ ..... ៧
១.១ គោលការណ៍ ..... ៧
១.២ ករណីលើកលែង ..... ៧
២. និយមន័យនៃសំណើ និងស្វីការ ..... ៧
២.១ និយមន័យនៃសំណើ ..... ៧
២.២ ភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ ..... ៧
២.៣ ពេលដែលបង្កើតអានុភាពនៃសំណើ ..... ៨
២.៤ និយមន័យនៃស្វីការ ..... ៩
២.៥ សំណើខ្វែង ..... ៩
២.៦ ពេលដែលបង្កើតអានុភាពនៃស្វីការ ..... ១០
៣. សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ ..... ១០
៤. សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ ..... ១០
៤.១ ករណីគូភាគីដែលកំពុងនិយាយគ្នា ..... ១០
៤.២ ករណីគូភាគីដែលមិននិយាយគ្នា ..... ១១
៤.៣ ពេលដែលបង្កើតអានុភាពនៃការដកសំណើ ..... ១១
៥. ពេលនៃការបង្កើតកិច្ចសន្យា៖ គោលការណ៍នៃការមកដល់នៃស្វីការ ..... ១២
៦. ការមកដល់យឺតយ៉ាវនៃស្វីការ ..... ១២
៧. ស្វីការដោយមានបន្ថែមការកែប្រែ ..... ១៣
៨. ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្វីការ ..... ១៣
៩. ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់ ..... ១៣
**ផ្នែកទី២ វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា** ..... ១៤
១. ការពិចារណាជាមូលដ្ឋាន ..... ១៤
២. ការបង្ហាញឆន្ទៈដោយមានវិការៈ ..... ១៤
៣. ការភាន់ច្រឡំ ..... ១៥

ក) និយមន័យ ..... ១៥
ខ) ដំណាក់កាលនៃការបង្ហាញឆន្ទៈ ..... ១៥
៣.១ ការភាន់ច្រឡំក្នុងកិច្ចសន្យា ..... ១៦
៣.២ ការភាន់ច្រឡំអង្គហេតុសំខាន់ចំពោះភាគីម្ខាង ..... ១៦
៣.៣ ការភាន់ច្រឡំរួម ..... ១៨
៣.៤ តតិយជន និង ការលុបចោលដោយការភាន់ច្រឡំ ..... ១៩
ក) អានុភាពប្រតិសកម្ម ..... ១៩
ខ) ការសងតាវកាលិក ..... ១៩
គ) ការការពារតតិយជន ..... ១៩
៤. ការឆបោក ..... ២៥
៤.១ ការលុបចោលដោយការឆបោក ..... ២៦
ក) សកម្មភាពបោកបញ្ឆោត ឬ បំភ្លៃការពិត ..... ២៦
ខ) ចេតនានៃការឆបោក ..... ២៧
គ) ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ ..... ២៧
៤.២ ការឆបោកដោយតតិយជន ..... ២៧
៤.៣ ការឆបោក និង តតិយជន ..... ២៨
៥. ព័ត៌មានមិនពិត ..... ៣០
៥.១ ការលុបចោលដោយមូលហេតុព័ត៌មានមិនពិត ..... ៣០
៥.២ សំណងការខូចខាត ..... ៣១
៥.៣ ព័ត៌មានមិនពិត និង តតិយជន ..... ៣១
៦. ការរំលោភបំពានលើស្ថានភាព ..... ៣១
៦.១ ការលុបចោលដោយមូលហេតុការរំលោភបំពានលើស្ថានភាព ..... ៣១
៦.២ ការរំលោភបំពានលើស្ថានភាព និង តតិយជន ..... ៣២
៧. ការគំរាមកំហែង ..... ៣២
៨. ការកេងយកចំណេញហួសហេតុ ..... ៣៣
៩.ឋបនីយផ្លូវចិត្ត ..... ៣៣

៩.១ ករណីភាគីម្ខាងទៀតសុចរិត ............................................................ ៣៣
៩.២ ករណីភាគីម្ខាងទៀតទុច្ចរិត ............................................................ ៣៤
៩.៣ ឋបនីយផ្លូវចិត្ត និង តតិយជន ............................................................ ៣៥
១០. ការបង្ហាញឆន្ទៈមិនពិត ............................................................ ៣៥
១០.១ ទំនាក់ទំនងរវាងគូភាគីនៃការបង្ហាញឆន្ទៈមិនពិត ............................................................ ៣៥
១០.២ ការបង្ហាញឆន្ទៈមិនពិត និង តតិយជន ............................................................ ៣៦
១១. ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អក្នុងអត្ថន័យនៃកិច្ចសន្យា ............................................................ ៣៦
១១.១ ភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ............................................................ ៣៦
១១.២ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ ............................................................ ៣៧
១១.៣ អត្ថន័យនៃកិច្ចសន្យាមួយផ្នែកដែលមានភាពផ្ទុយច្បាប់ ............................................................ ៣៧
១២. អលទ្ធភាពតាំពីដំបូង ............................................................ ៣៧
១២.១ អលទ្ធភាពតាំងពីដំបូង ............................................................ ៣៧
១២.២ ការទទួលខុសត្រូវក្នុងការសងការខូចខាត ............................................................ ៣៨
**ផ្នែកទី ៣ មោឃៈភាព និងការលុបចោល** ............................................................ ៤១
១. ការពិចារណាជាមូលដ្ឋាន ............................................................ ៤១
២. និយមន័យនៃសសកម្មភាព ............................................................ ៤២
៣. អត្ថន័យនៃមោឃភាព ............................................................ ៤២
៤. សកម្មភាពដែលអាចលុបចោលបាន ............................................................ ៤៣
៥. អ្នកមានសិទ្ធិលុបចោល ............................................................ ៤៤
៦. វិធីនៃការលុបចោល ឬសច្ចានុមតិ ............................................................ ៤៤
៧. អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និងលក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ ............................................................ ៤៥
៨. សច្ចានុមតិដែលច្បាប់បានកំណត់ ............................................................ ៤៥
៩. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ............................................................ ៤៧

## គន្លឹះទី៤ ភាតព្វកិច្ច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

## ផ្នែកទី៣ លក្ខខណ្ឌ កំណត់ពេល និងអំឡុងពេល

**១. និយមន័យនៃលក្ខខណ្ឌ**

**១.១. លក្ខខណ្ឌ**

**តាមច្បាប់៖** លក្ខខណ្ឌ គឺជាព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគតហើយដែលមិនទៀងទាត់ (មាត្រា៣២៥)។

**១.២. លក្ខខណ្ឌបង្អង់**

ក្នុងករណីកិច្ចសន្យាដែលមានលក្ខខណ្ឌបង្អង់ លុះត្រាតែលក្ខខណ្ឌត្រូវបានបំពេញ ទើបចាប់ផ្ដើម កើតមាននូវអានុភាពនៃសិទ្ធិ ឬកាតព្វកិច្ច ដែលកើតឡើងពីសកម្មភាពឯកតោភាគី ឬកិច្ចសន្យា។ មានន័យថា មិនអាចកើតមាននូវអានុភាពនៃសិទ្ធិ ឬកាតព្វកិច្ចដែលកើតឡើងពីសកម្មភាពឯកតោភាគី ឬកិច្ចសន្យានោះទេ រហូតដល់លក្ខខណ្ឌត្រូវបានបំពេញ។

ឧទាហរណ៍ទី១៖ ឪពុកបានសន្យាធ្វើប្រទានកម្ម ឲ្យម៉ូតូម៉ាកស្កុបពីឆ្នាំ២០១៥ ចំនួន១គ្រឿងទៅ ឲ្យកូនស្រីរបស់គាត់ ប្រសិនបើនាងប្រឡងជាប់មធ្យមសិក្សាទុតិយភូមិជាប់។ កិច្ចសន្យាប្រទានកម្មនេះ មានអានុភាពនៅពេលដែលនាងប្រឡងជាប់។

ឧទាហរណ៍ទី២៖ លោក សម្បត្តិ និងអ្នកស្រី ស្រីម៉ុម បានសន្យាធ្វើប្រទានកម្មផ្ទះ១ល្វែងទៅឲ្យកូនស្រីពៅរបស់គាត់នៅពេលដែលនាងរៀបការ។ កិច្ចសន្យាប្រទានកម្មនេះ មានអានុភាពនៅពេលដែលនាងរៀបការរួច។

**១.៣. លក្ខខណ្ឌរំលាយ**

លក្ខខណ្ឌរំលាយ គឺជាការព្រមព្រៀងនៃគូភាគីក្នុងការរំលាយលើកាតព្វកិច្ច ឬសិទ្ធិ ដែលកើតឡើងដោយកិច្ចសន្យា។

នៅក្នុងករណីលក្ខខណ្ឌត្រូវបានបំពេញ នោះនឹងនាំឲ្យរលត់នូវអានុភាពនៃសិទ្ធិ ឬកាតព្វកិច្ច ដែលកើតឡើងពីសកម្មភាពឯកតោភាគី ឬកិច្ចសន្យា។ មានន័យថា អានុភាពនៃសិទ្ធិ ឬកាតព្វកិច្ចដែលកើតឡើងពីសកម្មភាពឯកតោភាគី ឬកិច្ចសន្យា នឹងបន្តរហូតដល់លក្ខខណ្ឌត្រូវបានបំពេញ។

ឧទាហរណ៍៖ លោក សំណាង បានបង្កើតកិច្ចសន្យាខ្ចីប្រើផ្ទះជាមួយលោក ឡេង ដោយអនុញ្ញាត ឲ្យលោក ឡេងរស់នៅក្នុងផ្ទះរហូតដល់រៀនចប់ថ្នាក់បរិញ្ញាបត្រ។ កិច្ចសន្យាខ្ចីប្រើនេះនឹងរលត់អានុភាព នៅពេលលោក ឡេង រៀនចប់ថ្នាក់បរិញ្ញាបត្រ។

**២. ការចាត់ចែងសិទ្ធិដែលភ្ជាប់ជាមួយលក្ខខណ្ឌ**

❖ **<u>ករណីសិក្សា៖</u>**

លោក X បានឲ្យលោក Y ខ្ចីប្រាក់ចំនួន១០០០ដុល្លារ ដើម្បីទៅរកការងារធ្វើនៅខេត្តសៀមរាប ដោយភ្ជាប់នូវលក្ខខណ្ឌថា នៅពេលបានការងារធ្វើនឹងសងប្រាក់នោះវិញ។ ប៉ុន្តែ Y បានខិតខំប្រឹងប្រែងស្វែងរកការងារធ្វើណាស់តែរកមិនបាន។ X ត្រូវការលុយបន្ទាន់ ហើយក៏បានយកសិទ្ធិលើបំណុលដែលមានចំពោះ Y ទៅលក់ឲ្យ Z តម្លៃ ៥០០ដុល្លារ។ ក្នុងករណីនេះ នៅពេលដែល Y មានការងារធ្វើ Z អាចទាមទារប្រាក់ចំនួន១០០០ដុល្លារពី Y បាន។

**៣. ការបំពានសិទ្ធិដែលភ្ជាប់ជាមួយលក្ខខណ្ឌ (មាត្រា ៣២៧ កថាខណ្ឌទី ១)**

**៣.១. ការទទួលខុសត្រូវក្នុងការមិនគោរពអនុវត្តកាតព្វកិច្ច**

❖ **ករណីសិក្សាទី១៖**

ករណីសិក្សា ៖ X បានសន្យាជាមួយ Y ថានឹងប្រទានកម្មដី A ប្រសិនបើប្រឡងសាកលវិទ្យាល័យជាប់។ ប៉ុន្តែមុនពេលថ្ងៃ Y ប្រឡង X បានលក់ដី A ទៅឲ្យតតិយជន។ នៅក្នុងករណីនេះ នៅមុនពេលថ្ងៃប្រឡង Y អាចទាមទារសំណងខូចខាតចំពោះ X ដោយផ្អែកលើការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។ ប៉ុន្តែ ដើម្បីគណនាអំពីចំនួនទឹកប្រាក់នៃការខូចខាត ត្រូវពិចារណាអំពីលទ្ធភាព ដែល Y ប្រឡងជាប់។ មានន័យថា ប្រសិនបើ Y មានលទ្ធភាពខ្ពស់ដែលនឹងអាចប្រឡងជាប់ ចំនួនទឹកប្រាក់នៃការខូចខាតនឹងក្លាយទៅជាចំនួនច្រើន ហើយប្រសិនបើមានលទ្ធភាពទាប ចំនួននៃទឹកប្រាក់នៃការខូចខាតនឹងក្លាយទៅជាចំនួនតិច។ ក្រោយមក នៅក្នុងស្ថានភាពជាក់ស្តែង ប្រសិនបើ Y បានប្រឡងជាប់ Y អាចទាមទារសំណងខូចខាតទាំងអស់ ចំពោះ X បាន។ ប្រសិនបើ Y ប្រឡងមិនជាប់នោះ Y មិនអាចទាមទារសំណងខូចខាតបានទេ។

**៣.២.ការទទួលខុសត្រូវលើអំពើអនីត្យានុកូល**

❖ **ករណីសិក្សាទី២៖** លោក X បានសន្យានឹង Y ថាប្រសិនបើប្រឡងសាកលវិទ្យាល័យជាប់ នឹងប្រទានកម្មដីឲ្យ Y ។ ប៉ុន្តែនៅថ្ងៃប្រឡងដោយសារ Z បានរារាំង Y ធ្វើឲ្យ Y មិនអាចទៅប្រឡងបាន។ តើ Y អាចទាមទារ Z ឲ្យសងការសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលបានឬទេ? ករណីនេះ Y អាចទាមទារបាន (មាត្រា៣២៧(២)) ។

**៤. ការចាត់ទុកថាលក្ខខណ្ឌត្រូវបានបំពេញ (មាត្រា៣២៨)**

ករណីសិក្សា៖ X បានពឹងពាក់ Y ក្នុងការចរចារដើម្បីលក់ដីរបស់ខ្លួន ហើយបានសន្យាថា ប្រសិនបើដីនោះអាចលក់បានតម្លៃពី១០ម៉ឺនដុល្លារឡើងទៅ នឹងឲ្យ១ម៉ឺនដុល្លារជាកម្រៃជើងសារ។ Y បានរកឃើញអ្នកទិញ A ដែលឲ្យ

តម្លៃ១០ម៉ឺនដុល្លារ។ ប៉ុន្តែ X បានលក់ដីនោះក្នុងតម្លៃ៩ម៉ឺនដុល្លារឲ្យទៅ B ទៅវិញ ដែលធ្វើឲ្យមិនអាចបង្កើតកិច្ចសន្យាលក់ទិញជាមួយ A បាន។ តើ Y អាចទាមទារកម្រៃជើងសារ១ម៉ឺនដុល្លារពី X បានឬទេ? យោងតាមយុត្តិសាស្ត្រតុលាការកំពូលប្រទេសជប៉ុន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំង១៩៦៤ ករណីខាងលើ Y អាចទាមទារពី X នូវកម្រៃជើងសារ១ម៉ឺនដុល្លារបាន (មាត្រា៣២៨)។

## ៥. និយមន័យនៃការកំណត់ពេល

ការកំណត់ពេល ជាការព្រមព្រៀងអំពីលក្ខខណ្ឌនៃការបង្កើត ឬការរលត់នៃអានុភាពសកម្មភាពគតិយុត្ត ដោយការមកដល់នៃពេលវេលាជាអង្គហេតុជាក់លាក់ **(មាត្រា៣២៩**)។

### ៥.១. ការកំណត់ពេលពិតប្រាកដ និងការកំណត់ពេលមិនពិតប្រាកដ

#### ក. ការកំណត់ពេលពិតប្រាកដ

ការកំណត់ពេលពិតប្រាកដ៖ ការមកដល់នៃពេលវេលាជាអង្គហេតុជាក់លាក់ ហើយធ្វើការកំណត់យកពេលវេលានោះ។

ឧទាហរណ៍ ៖ ប្រសិនបើថ្ងៃទី១ ខែមករា ឆ្នាំក្រោយ បានមកដល់។

#### ខ. ការកំណត់ពេលមិនពិតប្រាកដ

ការកំណត់ពេលវេលាមិនពិតប្រាកដ៖ ការមកដល់នៃពេលវេលាជាអង្គហេតុជាក់លាក់ ប៉ុន្តែការមកដល់នៃពេលវេលានោះនៅពេលណា គឺមិនទាន់ដឹង។

ឧទាហរណ៍៖ ប្រសិនបើនៅពេលក្រោយ មេឃភ្លៀង។

### ៥.២. ការកំណត់ពេលទាក់ទងនឹងអានុភាពនៃកិច្ចសន្យា និងកំណត់ពេលទាក់ទងនឹងពេលអនុវត្ត

**ក. ការកំណត់ពេលទាក់ទងនឹងអានុភាពនៃកិច្ចសន្យា៖** គឺជារយៈពេលរង់ចាំថ្ងៃកំណត់មកដល់ដើម្បីអនុវត្តកិច្ចសន្យា។

**ខ. ការកំណត់ពេលទាក់ទងនឹងពេលអនុវត្ត៖** គឺជាការចាប់ផ្តើមអនុវត្តកាតព្វកិច្ចនៅពេលកំណត់នៃកិច្ចសន្យាមកដល់។

## ៦. ប្រយោជន៍នៃការកំណត់ពេល (មាត្រា ៣៣០)

ក. ការកំណត់ពេលត្រូវបានសន្មតថា បានជាប្រយោជន៍របស់កូនបំណុល។

ខ. ប្រយោជន៍នៃការកំណត់ពេលនេះអាចបោះបង់ចោលបាន លុះត្រាតែមិននាំឲ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត។ ប៉ុន្តែ ប្រសិនបើការបោះបង់ចោលនោះធ្វើឲ្យមានការខូចខាតផលប្រយោជន៍របស់ភាគីម្ខាង

ទៀត ភាគីដែលធ្វើឲ្យមានការខូចខាតនោះ ត្រូវសងការខូចខាតដល់ភាគីម្ខាងទៀត។

〔គោលគំនិតដែលពិចារណាអំពីផលប្រយោជន៍នៃការកំណត់ពេល〕

ភាគីដែលទទួលប្រយោជន៍នៃការកំណត់ពេល នៅពេលដែលធ្វើការបោះបង់ចោលនូវប្រយោជន៍នោះ អាចនាំឲ្យកើតមាននូវអានុភាពនៃសកម្មភាពគតិយុត្តក្នុងអំឡុងពេលនៃការកំណត់ពេល។ ភាគីដែលមិនទទួលប្រយោជន៍នៃការកំណត់ពេល ត្រូវតែរង់ចាំរហូតដល់ពេលដែលកំណត់នោះមកដល់ដោយមិនអាចបោះបង់ចោលបានទេ។ នេះជាចំណុចខុសគ្នាខ្លាំង។

ជាធម្មតា បុគ្គលដែលទទួលផលប្រយោជន៍នៃការកំណត់ពេល គឺជាកូនបំណុល។ ពីព្រោះ ក្នុងករណីដែលភ្ជាប់នូវការកំណត់ពេល កូនបំណុលមិនចាំបាច់អនុវត្តកាតព្វកិច្ចភ្លាមៗនោះទេ ហើយអាចអនុវត្តកាតព្វកិច្ចរហូតដល់ការកំណត់អំឡុងពេលបានមកដល់។ ឧទាហរណ៍ ៖ A ខ្ចីប្រាក់១០០០០ដុល្លារពី B ហើយក្នុងករណីដែលធ្វើការកំណត់១ឆ្នាំក្រោយជាពេលសង A មិនមានកាតព្វកិច្ចក្នុងការសងប្រាក់១០០០០ដុល្លារភ្លាមៗនោះទេ គឺអាចធ្វើការសងរហូតដល់១ឆ្នាំក្រោយ។ A អាចសងប្រាក់នៅ១ឆ្នាំក្រោយដូចតាមការកំណត់ក៏បាន ហើយក៏អាចធ្វើការបោះបង់ចោលនូវប្រយោជន៍នៃការកំណត់ពេលនោះ ដោយសងប្រាក់នៅក្នុងអំឡុងពេល១ឆ្នាំ។

ជាធម្មតា ដោយសារតែម្ចាស់បំណុលត្រូវបានចាត់ទុកថាជាបុគ្គលដែលមិនមានផលប្រយោជន៍ទាក់ទងទៅនឹងការកំណត់ពេល ដូច្នេះហើយម្ចាស់បំណុលមិនអាចបោះបង់ចោលនូវការកំណត់ពេលបានទេ។ នៅក្នុងករណីសិក្សាខាងលើ B មិនអាចធ្វើការទាមទារឲ្យ A សងប្រាក់ពាក់កណ្តាលទីបានទេ (មុនការកំណត់ពេល) គឺត្រូវរងចាំរហូតដល់រយៈពេល ១ឆ្នាំបានកន្លងផុត។

**៧. ការបោះបង់ផលប្រយោជន៍នៃការកំណត់ពេល (មាត្រា ៣៣១)**

ជាធម្មតា ម្ចាស់បំណុលមិនបានទទួលប្រយោជន៍នៃការកំណត់ពេលទេ ហេតុនេះ មិនអាចទាមទារឲ្យកូនបំណុលអនុវត្តកាតព្វកិច្ច រហូតដល់ការកំណត់ពេលបានមកដល់។ ឧទាហរណ៍៖ អ្នកដែលឲ្យគេខ្ចីប្រាក់មិនអាចទាមទារឲ្យសងប្រាក់មុនការកំណត់ពេលមកដល់។ ប៉ុន្តែដោយសារស្ថានភាពរបស់ភាគីកូនបំណុល ដូចជាក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់កូនបំណុលមានការប្រែប្រួលកាន់តែអាក្រក់ទៅៗ ហើយម្ចាស់បំណុលមានការបារម្ភថា មិនអាចទទួលបានសំណងនាពេលអនាគត។ ដូច្នេះ យោងតាមមាត្រា៣៣១ បញ្ញត្តថា ក្នុងករណីស្ថានភាពដ៏ជាក់លាក់នាពេលអនាគតបានកើតឡើងដោយសារស្ថានភាពរបស់ភាគីខាងកូនបំណុល គឺកូនបំណុលត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល។ ដូច្នេះប្រសិនបើកូនបំណុលត្រូវបាត់បង់ប្រយោជន៍នៃការកំណត់ពេល គឺម្ចាស់បំណុលអាចធ្វើការទាមទារឲ្យអនុវត្តនូវការទូទាត់សង ដោយមិនចាំបាច់រង់ចាំការកំណត់ពេលមកដល់នោះទេ មាន

ន័យថាម្ចាស់បំណុល អាចធ្វើការទាមទារឲ្យកូនបំណុលធ្វើការទូទាត់សងមុនការកំណត់ពេលមកដល់។

តើក្នុងស្ថានភាពណាខ្លះដែលម្ចាស់បំណុល អាចធ្វើការទាមទារឲ្យកូនបំណុលធ្វើការទូទាត់សងប្រាក់ មុនការកំណត់ពេលបានមកដល់? ដូចជាស្ថានភាពដែលកូនបំណុលមិនបានអនុវត្តនូវកាតព្វកិច្ច តើកូនបំណុលអាចបាត់បង់ផលប្រយោជន៍នូវការកំណត់ពេលឬទេ? សូមពិចារណាលើគោលគំនិតនៃ មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី ចំពោះស្ថានភាពដែលម្ចាស់បំណុលអាចធ្វើការទាមទារឲ្យកូនបំណុលធ្វើការទូទាត់សងមុនការកំណត់ពេល លើករណីដូចខាងក្រោម៖

-កូនបំណុលត្រូវបានប្រកាសក្ស័យធន (ក)

-កូនបំណុលបានធ្វើឲ្យខូចខាតប្រាតិភោគ (ខ)

-កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែមិនបានបំពេញករណីយកិច្ចនេះ (គ)

-មានហេតុដែលគូភាគីបានព្រមព្រៀងគ្នា បានកើតឡើង (ឃ)

## ៨. របៀបកំណត់អំឡុងពេល

អំឡុងពេលអាចកំណត់ជា ម៉ោង នាទី វិនាទី ថ្ងៃ សប្តាហ៍ ខែ ឬឆ្នាំ បាន (មាត្រា៣៣២)។

បញ្ញត្តិនេះធ្វើការកំណត់ជាទូទៅអំពីអំឡុងពេល។

## ៩. ការគណនាកំណត់អំឡុងពេលជា ម៉ោង នាទី ឬ វិនាទី

ប្រសិនបើបានកំណត់អំឡុងពេលជាម៉ោង នាទី ឬ វិនាទី ត្រូវធ្វើការគណនាពីពេលចាប់ផ្តើមរហូតដល់ពេលចប់នៃអំឡុងពេលនោះ (មាត្រា៣៣៣)។

បញ្ញត្តិនេះធ្វើការកំណត់ជាទូទៅ អំពីរបៀបគណនានៃអំឡុងពេលគិតជាម៉ោង នាទី ឬវិនាទី។

## ១០. ការគណនាកំណត់អំឡុងពេលជា ថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំ

ប្រសិនបើបានកំណត់អំឡុងពេលជាថ្ងៃ សប្តាហ៍ ខែ ឬឆ្នាំវិញ មិនត្រូវគិតបញ្ចូលថ្ងៃដែលចាប់ផ្តើមនៃអំឡុងពេលនេះទេ លើកលែងតែអំឡុងពេលនេះបានចាប់ផ្តើមពីម៉ោងសូន្យទៅ (មាត្រា៣៣៤(១))។

ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី១ខាងលើនេះ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃចុងក្រោយនៃអំឡុងពេលនោះ (មាត្រា៣៣៤(២))។

ករណីសិក្សា

A បានជួប B នៅពេលសម្រាកថ្ងៃត្រង់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ហើយបានឲ្យប្រាក់ B ខ្ចី ១000 ដុល្លារ ដោយបានសន្យាថានឹងសងនៅក្នុងរយៈពេល១ខែ។

នៅពេលគណនាអំពីអំឡុងពេល ត្រូវគណនាចាប់ពីថ្ងៃបន្ទាប់នៃម៉ោងសូន្យ ដោយមិនរាប់បញ្ចូលចាប់ពីថ្ងៃដែលបានឲ្យខ្ចីប្រាក់នោះទេ។ អំឡុងពេលនឹងចាប់ផ្តើមគិតពីម៉ោងសូន្យនៃថ្ងៃទី១១ ខែសីហា។ ដូច្នេះ ថ្ងៃទី១០ ខែកញ្ញា ជាអំឡុងពេលដែលផុតកំណត់សងចុងក្រោយ។ ដោយសារអំឡុងពេលត្រូវបញ្ចប់ទៅតាមការបញ្ចប់នៃពេលផុតថ្ងៃនៃអំឡុងពេលនោះ ហេតុនេះ ថ្ងៃទី១១ ខែកញ្ញា នៃម៉ោងសូន្យ ជាអំឡុងពេលចប់ពេញលេញ។ ដូច្នេះ មុនថ្ងៃទី១១ ខែកញ្ញា នៃម៉ោងសូន្យ B ត្រូវតែសងប្រាក់១០០០ដុល្លារទៅ A។

ប្រសិនបើថ្ងៃទី១០ ខែកញ្ញា ជាថ្ងៃសៅរ៍ នោះថ្ងៃទី១២ ខែកញ្ញា ជាថ្ងៃផុតចុងក្រោយ ហេតុនេះ B ត្រូវតែសងប្រាក់ ១០០០ ដុល្លារ ទៅឲ្យ A មុនថ្ងៃទី១៣ ខែកញ្ញា នៃម៉ោងសូន្យ។

ប្រសិនបើថ្ងៃទី១០ ខែកញ្ញា ជាថ្ងៃអាទិត្យ នោះថ្ងៃទី១១ ខែកញ្ញា ជាថ្ងៃផុតចុងក្រោយ ហេតុនេះB ត្រូវតែសងប្រាក់ ១០០០ដុល្លារ ទៅឲ្យ A មុនថ្ងៃទី១២ ខែកញ្ញា នៃម៉ោងសូន្យ។

**១១. ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ**

ក្នុងករណីដែលធ្វើការគណនាអំឡុងពេលជាសប្តាហ៍ ខែ ឬ ឆ្នាំ ត្រូវធ្វើការគណនាតាមប្រតិទិនសុរិយគតិ (មាត្រា ៣៣៥(១))។

ក្នុងករណីដែលមិនអាចធ្វើការគណនាអំឡុងពេលដោយគិតពីដើមសប្តាហ៍ ដើមខែ ឬ ដើមឆ្នាំ អំឡុងពេលនេះត្រូវចប់ពេញលេញនៅមួយថ្ងៃមុនថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើមរាប់នៃសប្តាហ៍ចុងក្រោយ ខែចុងក្រោយ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេល។ ប៉ុន្តែ ក្នុងករណីដែលត្រូវគណនាអំឡុងពេលជាខែ ឬ ជាឆ្នាំវិញ ប្រសិនបើខែ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេលនោះ គ្មានថ្ងៃដែលត្រូវនឹងថ្ងៃដែលអំឡុងពេលបានចាប់ផ្តើមទេ ថ្ងៃចុងក្រោយនៃខែនោះ ត្រូវជាថ្ងៃដែលអំឡុងពេលត្រូវចប់ពេញលេញ (មាត្រា៣៣៥(២))។

ករណីសិក្សា

A បានជួប B នៅពេលសម្រាកថ្ងៃត្រង់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ ហើយបានឲ្យប្រាក់ B ខ្ចី ១០០០ ដុល្លារ ដោយបានសន្យាថានឹងសងនៅក្នុងរយៈពេល១ខែ។ នៅក្នុងករណីនេះ អំឡុងពេលនឹងចាប់ផ្តើមពីថ្ងៃបន្ទាប់ គឺថ្ងៃទី១ ខែកញ្ញា ហើយបន្ទាប់ពី១ខែ ដែលជាថ្ងៃទី៣១ ខែកញ្ញា ជាថ្ងៃផុតចុងក្រោយ។ ប៉ុន្តែ មិនមានថ្ងៃទី៣១ ខែកញ្ញានោះទេ។ ករណីនេះ ថ្ងៃទី៣០ ខែកញ្ញា ជាថ្ងៃផុតចុងក្រោយ ហេតុនេះ B ត្រូវតែសងប្រាក់ ១០០០ ដុល្លារទៅឲ្យ A រហូតដល់ថ្ងៃទី១ ខែតុលា នៃម៉ោងសូន្យ។

# គន្លឹះទី ៤ ភាគពួកិច្ច
# ជំពូកទី ២ ការបង្ហាញឆន្ទៈ និង កិច្ចសន្យា
# ផ្នែកទី ១ ការបង្កើតកិច្ចសន្យា

**១. ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ (មាត្រា ៣៣៦)**

**១.១ គោលការណ៍**

ជាគោលការណ៍ការបង្កើតកិច្ចសន្យា គឺជាការបង្កើតការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគីពីរ ឬ ច្រើននាក់។ យោងទៅតាម Black's Law Dictionary ពាក្យកិច្ចសន្យាមានន័យថា "ការព្រមព្រៀងរវាងភាគីពីរឬច្រើននាក់ក្នុងការបង្កើតកាតព្វកិច្ចដែលអាចអនុវត្តបានឬក៏ទទួលស្គាល់ដោយច្បាប់។"[1] គោលការណ៍នៃការបង្កើតកិច្ចសន្យា គឺជាគោលការណ៍សេរីភាពរបស់បុគ្គលក្នុងការព្រមព្រៀងធ្វើអ្វីមួយ។ ទោះជាយ៉ាងណាក៏ដោយ គេសន្មតថាកិច្ចសន្យាមួយមានអានុភាពលុះត្រាតែសំណើនិងស្វីការត្រូវគ្នា។[2]

**១.២ករណីលើកលែង**

ចំពោះកិច្ចសន្យាដែលទាក់ទងនឹងការធ្វើអនុប្បទាន ឬ ធ្វើលទ្ធកម្មនៃអចលនវត្ថុ វាអាចមានអានុភាពទៅបានលុះត្រាតែបានធ្វើលិខិតយថាភូត។ លិខិតយថាភូតត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១។

**២. និយមន័យនៃសំណើ និងស្វីការ (មាត្រា ៣៣៧)**

**២.១ និយមន័យនៃសំណើ**

ការស្វែងយល់ពីអត្ថន័យនៃសំណើ និង ស្វីការគឺជាការចាំបាច់ក្នុងការសិក្សាពីកិច្ចសន្យា។ សំណើគឺជា "ការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ"។[3]

**២.២ ភាពខុសគ្នារវាងសំណើ និងការអញ្ជើញឲ្យធ្វើសំណើ**

ទោះបីជាមានចែងច្បាស់ពីនិយមន័យនៃសំណើក៏ដោយ ក៏គេពិនិត្យឃើញមានភាពខុសគ្នារវាងសំណើនិងការ

---

[1]Bryan A Garner, *Black's Law Dictionary*, 8th ed. (St. Paul, Minn: West Group, 2004), 341។

[2]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៣៣៦(១)។

[3]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៣៣៧(១)។

អញ្ជើញឲ្យធ្វើសំណើ។ សំណើគឺជាការបង្ហាញឆន្ទៈថានឹងភ្ជាប់ជាមួយចំណងនៃកិច្ចសន្យាក្នុងករណីដែលភាគីម្ខាងផ្តល់ស្វីការឲ្យស្របគ្នាទៅនឹងសំណើនោះ។ ចំណែកឯការអញ្ជើញឲ្យធ្វើសំណើ គឺជាការអញ្ជើញឲ្យភាគីផ្សេងឲ្យធ្វើសំណើមកកាន់ខ្លួន។

ឧទាហរណ៍ខាងក្រោមបង្ហាញអំពីការអញ្ជើញឲ្យធ្វើសំណើ។

- ហាង A បានបិតប្រកាសជ្រើសរើសបុគ្គលិកចំនួន១នាក់ នៅខាងមុខហាងរបស់ខ្លួន ដោយដាក់លក្ខខណ្ឌជ្រើសរើស។ ការប្រកាសផ្សាយនេះជាការអញ្ជើញឲ្យធ្វើសំណើលើកិច្ចសន្យាការងារ រីឯបុគ្គលដែលមានចំណាប់អារម្មណ៍លើការប្រកាសនោះ ហើយបានដាក់ពាក្យសុំធ្វើការ គឺជាការដាក់សំណើ។ ក្រោយពីហាង A បានពិនិត្យលើពាក្យសុំ ហើយបានសម្រេចយកបុគ្គលណាម្នាក់ជាបុគ្គលិក គឺជាស្វីការទៅលើសំណើ ពេលនោះកិច្ចសន្យាការងារត្រូវបានកើតឡើង។

- លោកសំណាងជាអ្នកលក់សម្លៀកបំពាក់នៅក្នុងហាងមួយ ដោយដាក់តម្លៃនៅលើសម្លៀកបំពាក់នីមួយៗលោកមិនបានធ្វើសំណើទេគ្រាន់តែអញ្ជើញឲ្យភ្ញៀវធ្វើសំណើ។ នៅពេលលោកសម្បត្តិនិយាយទៅកាន់លោកសំណាងថាគាត់នឹងទិញសម្លៀកបំពាក់មួយកំផ្លេនេះ នោះសំណើនឹងកើតឡើងភ្លាម ហើយនៅពេលលោកសំណាងយល់ព្រមលក់សម្លៀកបំពាក់នោះ ពោលគឺ ផ្តល់ស្វីការត្រូវគ្នាទៅនឹងសំណើដែលបានលើកឡើងនោះកិច្ចសន្យាក៏ត្រូវបានបង្កើតឡើងដែរ។

- ក្រុមហ៊ុនធានារ៉ាប់រង A បានប្រកាសផ្សព្វផ្សាយលក់ធានារ៉ាប់រងសុខភាព។ នេះជាការអញ្ជើញឲ្យធ្វើសំណើ។ B ជាអតិថិជនទិញធានារ៉ាប់រងសុខភាពទៅតាមលក្ខខណ្ឌក្រុមហ៊ុនកំណត់។ ករណីនេះ B ជាអ្នកដាក់សំណើ។ នៅពេលក្រុមហ៊ុន A យល់ព្រមលក់ធានារ៉ាប់រងឲ្យ B ពោលគឺផ្តល់ស្វីការត្រូវគ្នាទៅនឹងសំណើរបស់ B នោះកិច្ចសន្យាក៏ត្រូវបានបង្កើតឡើង។

**២.៣ ពេលដែលបង្កើតអានុភាពនៃសំណើ**

សំណើមានអានុភាពទៅបាន លុះត្រាតែសំណើនោះបានទៅដល់ភាគីម្ខាងទៀត (មាត្រា៣៣៧ កថាខណ្ឌទី២ វាក្យខ័ណ្ឌទី១)។ ឧបមា B ជាអ្នកលក់កង់ហើយលោក A និយាយប្រាប់ B ថានឹងទិញកង់ណាមួយពី B។ ដូច្នេះសំណើដែល A ផ្តល់ទៅឲ្យ B មានអានុភាព។

ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬមុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើងឡើយ (មាត្រា៣៣៧ កថាខណ្ឌទី២ វាក្យខ័ណ្ឌទី២)។ ឧទាហរណ៍ A បានស្នើ C ឲ្យជូនដំណឹងទៅ B ថាខ្លួនទិញកង់មួយពី B (សំណើ)។ តែក្រោយមក A បានស្នើ D

ឲ្យជូនដំណឹងទៅ B ថាខ្លួនមិនទិញកង់នោះទេ (ការដកសំណើ)។ករណីនេះប្រសិនបើ Dបានប្រាប់ B ពីការណ៍ដែល A ឈប់ទិញកង់នៅចំពេល ឬមុនពេលដែល Cប្រាប់ B ពីការទិញកង់របស់ A នោះសំណើរបស់ A តាមរយៈ C មិនមានអានុភាពឡើយ។

### ២.៤ និយមន័យនៃស្វីការ

ស្វីការគឺជា "ការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។"[4] ឧទាហរណ៍ បើ A ប្រាប់ B ថានឹងទិញកង់មួយពី B ហើយ B យល់ព្រមលក់កង់នោះ មានន័យថា ការឆ្លើយតបរបស់ B គឺជាស្វីការ។

### ២.៥ សំណើខ្វែង

សំណើខ្វែងគឺជា "សំណើមួយដែលធ្វើឡើងដោយអ្នកណាម្នាក់ដោយមិនបានដឹងថាអ្នកទទួលសំណើក៏បានដាក់សំណើដូចគ្នាមកកាន់អ្នកស្នើ។"[5] ឧទាហរណ៍ A ជូនដំណឹងទៅ B ថានឹងទិញកង់មួយ ។ B ក៏ជូនដំណឹងទៅ A ថានឹងលក់កង់មួយឲ្យ A ដោយមិនបានដឹងពីការជូនដំណឹងរបស់ A ទេ (សំណើខ្វែង)។ ជាគោលការណ៍ទោះអ្នកទាំងពីរបានបង្ហាញឆន្ទៈក៏ដោយ ក៏កិច្ចសន្យាមិនទាន់កើតមានឡើយ ពីព្រោះពួកគេគ្រាន់តែដាក់សំណើឲ្យគ្នាទៅវិញទៅមកប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើមានស្វីការពីភាគីណាមួយម្តងទៀត នោះកិច្ចសន្យានឹងកើតឡើង។ ម្យ៉ាងវិញទៀត មានទស្សនៈថា ដោយសារឆន្ទៈរបស់ភាគីទាំងពីរត្រូវគ្នា ហេតុនេះគួរតែទទួលស្គាល់ថា កិច្ចសន្យានឹងកើតមានបន្ទាប់ពីសំណើក្រោយបានទៅដល់ភាគីម្ខាងទៀត។




---

[4] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៣៣៧(៣)។

[5] Bryan A Garner, *Black's Law Dictionary*, 8th ed. (St. Paul, Minn: West Group, 2004), 405។

### ២.៦ ពេលដែលបង្កើតអានុភាពនៃស្ទីការ

មិនខុសពីអានុភាពនៃសំណើទេ អានុភាពនៃស្ទីការកើតមានឡើង លុះត្រាតែស្ទីការនោះបានទៅដល់អ្នកស្នើ។ ទោះជាយ៉ាងណាក៏ដោយ បើដំណឹងពីការដកស្ទីការបានទៅដល់ក្នុងអំឡុងពេល ឬមុនពេលស្ទីការទៅដល់អ្នកស្នើនាំឲ្យស្ទីការនោះមិនមានអានុភាពទេ។ ឧទាហរណ៍ នៅម៉ោង ២:០០រសៀល A បាននិយាយប្រាប់ C ថានឹងទិញកង់ណាមួយជាក់លាក់ដែល B បានដាក់លក់។ តែនៅម៉ោង៣:០០ បានសម្រេចចិត្តឈប់ទិញកង់នោះវិញ ហើយបានប្រាប់ E ឲ្យជម្រាបជូន B ផង។ C និង E បានជម្រាបជូន B ពីដំណឹងនេះក្នុងពេលជាមួយគ្នា ឬ E បានប្រាប់ B មុនពេលដែល C ជម្រាប B។ ករណីនេះ ស្ទីការរបស់ A មិនមានអានុភាពទេ ដូច្នេះកិច្ចសន្យាទិញលក់កង់ ក៏មិនកើតមានដែរ។

## ៣. សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើនោះ

គេអាចដាក់សំណើដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ (មាត្រា៣៣៨ កថាខណ្ឌទី១)។ ឧទាហរណ៍ A ប្រកាសលក់ឡានម៉ាកកាមរី ២០០៣ តម្លៃ ១៣០០០ដុល្លារ គិតចាប់ពីថ្ងៃជូនដំណឹង រហូតដល់ថ្ងៃទី៣១ ខែឧសភា។ ដូច្នេះ សំណើនេះមានសុពលភាព ចាប់ពីថ្ងៃជូនដំណឹងដល់ថ្ងៃទី៣១ ខែឧសភា ហើយអស់សុពលភាពចាប់ពីថ្ងៃទី១ ខែមិថុនា។ ករណីសំណើមិនបានបញ្ជាក់ពេលច្បាស់លាស់នៃការចាប់ផ្តើមអំឡុងពេលសម្រាប់ស្ទីការត្រូវគិតចាប់ពីថ្ងៃជូនដំណឹង (មាត្រា៣៣៨ កថាខណ្ឌទី១ វាក្យខណ្ឌទី២)។

ក្នុងករណីដែលសំណើបានកំណត់អំឡុងពេលសម្រាប់ស្ទីការ សំណើនេះមិនអាចដកវិញបានទេ ពីព្រោះគោលបំណងរបស់វា គឺដើម្បីបញ្ជាក់ពីឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំស្ទីការ។ ក្នុងករណីអំឡុងពេលសម្រាប់ធ្វើស្ទីការបានផុតកំណត់ សំណើដែលបានកំណត់អំឡុងពេលត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ។ ជាមួយគ្នានេះដែរ បើអ្នកស្នើបានដឹងពីការបដិសេធសំណើ នៅក្នុងអំឡុងពេលសម្រាប់ស្ទីការសំណើនោះក៏អស់អានុភាពដែរ។

## ៤. សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើនោះ

### ៤.១ ករណីគូភាគីដែលកំពុងនិយាយគ្នា

ក្នុងករណីដែលសំណើគ្មានកំណត់អំឡុងពេលរវាងភាគីដែលកំពុងនិយាយគ្នា ហើយភាគីណាមួយអាចឆ្លើយតបទៅនឹងសំណើភ្លាមៗ ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះនឹងបាត់បង់អានុភាព(មាត្រា៣៣៩(១))។

ឧទាហរណ៍ទី១៖ A កំពុងនិយាយទៅកាន់ B ថា "ខ្ញុំលក់ឡាននេះឲ្យអ្នកនូវតម្លៃ១០០០០ដុល្លារ" ហើយ B មិនឆ្លើយតប ឬនៅស្ងៀមស្ងាត់ ដូច្នេះសំណើលក់ឡាន១០០០០ដុល្លារបាត់បង់ អានុភាព។

ឧទាហរណ៍ទី២៖ C និយាយទៅកាន់ D ថា សៀវភៅប្រវត្តិសាស្ត្រមួយក្បាលនេះខ្លួនបានអានចប់ហើយដោយឃើញថាមានខ្លឹមសារល្អក៏ចង់លក់ទៅឲ្យ D នូវតម្លៃ១០ដុល្លារ។ D មិនឆ្លើយតបថាខ្លួនទិញ ឬមិនទិញទេ ដូច្នេះសំណើលក់សៀវភៅនេះបាត់បង់អានុភាព។

**៤.២ ករណីគូភាគីដែលមិននិយាយគ្នា**

ក្នុងករណីដែលសំណើគ្មានកំណត់អំឡុងពេលរវាងភាគីដែលមិននិយាយគ្នា ដូចជាតាមរយៈ ការសរសេរសំបុត្រ ការផ្ញើសារតាមរយៈEmail ជាដើម អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ។ ពាក្យថា "អំឡុងពេលសមរម្យ" ប្រែប្រួលទៅតាមករណីជាក់ស្តែងនៃប្រភេទកិច្ចសន្យានីមួយៗ។ ទោះបីជាអំឡុងពេលសមរម្យនោះបានកន្លងហួសក៏ដោយ ក៏មិនមានន័យថាសំណើនោះបាត់បង់អានុភាពដែរ។ ឧទាហរណ៍ A ជាម្ចាស់ផ្ទះមួយល្វែងបានផ្ញើ Email ទៅ B ជួលផ្ទះមួយល្វែងនោះ ក្នុងតម្លៃ២០០ដុល្លារក្នុងមួយខែ។ ជាធម្មតា A និង B ទាក់ទងគ្នាតាម Email ជារៀងរាល់ថ្ងៃ។

**៤.៣ ពេលដែលបង្កើតអានុភាពនៃការដកសំណើ**

ការដកសំណើមានអានុភាព នៅពេលដំណឹងអំពីការដកសំណើបានទៅដល់ភាគីម្ខាងទៀតមុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ (មាត្រា៣៣៩(៣))។

ឧទាហរណ៍




A បានធ្វើសំណើទៅ B ថាខ្លួននឹងលក់ផ្ទះមួយល្វែងទៅឲ្យ B ក្នុងតម្លៃ៥០០០០ដុល្លារ នៅថ្ងៃទី១០ ខែតុលា។ នៅថ្ងៃទី១១ ខែតុលា A បានជូនដំណឹងអំពីការដកសំណើទៅកាន់ B ហើយ ដំណឹងអំពីការដកសំណើនោះបានទៅដល់ B នៅថ្ងៃទី១៣ ខែតុលា។ ប៉ុន្តែ B បានធ្វើស្ទីការតបវិញ នៅថ្ងៃទី១២ ខែតុលា។ ដូចនេះការដកសំណើមិនមានអានុភាពពីព្រោះ B បានធ្វើស្ទីការមុនពេលដែលការជូនដំណឹងអំពីការដកសំណើរបស់ A បានទៅដល់។

**ករណីសិក្សា**

X បានធ្វើសំណើបង្កើតកិច្ចសន្យាចំពោះ Y។ ១០ឆ្នាំក្រោយ Y បានជូនដំណឹងអំពីស្ទីការទៅ X។ តើកិច្ចសន្យាត្រូវបានបង្កើតឡើងដែរឬទេ?

ការពិភាក្សា៖ ដោយសារសំណើបង្កើតកិច្ចសន្យារបស់ X ចំពោះ Y មិនកំណត់អំឡុងពេលសម្រាប់ស្ទីការ ដូច្នេះការដែល១០ឆ្នាំក្រោយមក Y បានជូនដំណឹងពីស្ទីការ នាំឲ្យមានកិច្ចសន្យាកើតឡើង។

**៥. ពេលនៃការបង្កើតកិច្ចសន្យា៖ គោលការណ៍នៃការមកដល់នៃស្វីការ**

កិច្ចសន្យាមួយកើតឡើង នៅពេលដែលអ្នកស្នើបានទទួលដំណឹងអំពីស្វីការ (មាត្រា៣៤០)។

ឧទាហរណ៍ A បានដាក់សំណើទិញរថយន្តម៉ាកក្សូឡាពី B នូវតម្លៃ១៣០០០ដុល្លារ នៅ ថ្ងៃទី១១ ខែវិច្ឆិកា ហើយ B បានធ្វើស្វីការនៅថ្ងៃទី១២ ខែវិច្ឆិកា។ ដូច្នេះ កិច្ចសន្យាលក់ទិញរថយន្ត កើតមានឡើងនៅថ្ងៃទី១២ ខែវិច្ឆិកា។

**ករណីសិក្សា**

X បានធ្វើសំណើបង្កើតកិច្ចសន្យាចំពោះ Y។ តើអាចទទួលស្គាល់អំពីការបង្កើតកិច្ចសន្យាបានដែរ ឬទេ ក្នុងករណីខាងក្រោម?

១. Y បានយកលិខិតស្វីការនៃការបង្កើតកិច្ចសន្យាទៅដល់ផ្ទះរបស់ X តែX មិននៅផ្ទះ ហេតុនេះ Y បានទុកលិខិតនោះនៅផ្ទះរបស់ X រួចក៏ត្រឡប់មកវិញ។

២. Y បានយកលិខិតស្វីការនៃការបង្កើតកិច្ចសន្យាទៅដល់ផ្ទះរបស់ X តែ X មិននៅផ្ទះ ហេតុនេះ Y បានប្រគល់លិខិតនោះដល់ដៃប្រពន្ធរបស់ X។

៣. Y បានជូនដំណឹងអំពីស្វីការតាមរយៈការផ្ញើសារអេឡិចត្រូនិច ប៉ុន្តែកុំព្យូទ័ររបស់ X ខូច ហេតុនេះ X មិនអាចមើលឃើញសារនោះទេ។

ការពិភាក្សា៖

១. មុនពេល X បានឃើញលិខិតស្វីការ កិច្ចសន្យាមិនទាន់កើតមានទេ។ ក្នុងករណី X មកដល់ផ្ទះ ហើយឃើញលិខិតស្វីការនោះ កិច្ចសន្យារវាង X និង Y កើតមាន។

២. បើប្រពន្ធ X ប្រាប់ពីការប្រគល់លិខិតស្វីការរបស់ Y ទៅដល់ X នាំឲ្យកិច្ចសន្យារវាង X និង Y កើតមាន។

៣. នៅក្នុងអំឡុងពេលកុំព្យូទ័រខូច កិច្ចសន្យាមិនទាន់កើតមានទេ។ ប៉ុន្តែបើកុំព្យូទ័រត្រូវបានជួសជុលរួច ពេល X បើកសារអេឡិចត្រូនិចរបស់ខ្លួន ហើយឃើញស្វីការរបស់ Y កិច្ចសន្យានោះកើតមាន។

**៦. ការមកដល់យឺតយ៉ាវនៃស្វីការ (មាត្រា ៣៤១)**

ក្នុងករណីដែលស្វីការមកដល់អ្នកស្នើយឺតជាងអំឡុងពេលដែលបានកំណត់ ហើយអ្នកស្នើដឹងអំពីស្ថានភាពដែលស្វីការនឹងមកដល់ជាធម្មតាក្នុងអំឡុងពេលកំណត់ តែបែរជាមិនឃើញមកដល់ ហើយអ្នកស្នើក៏បានជូនដំណឹងអំពីការយឺតយ៉ាវ នោះស្វីការមិនមានអានុភាពទេ។ ប៉ុន្តែបើអ្នកស្នើមិនបានជូនដំណឹងអំពីការយឺតយ៉ាវ ដោយសារការធ្វេសប្រហែសរបស់ខ្លួន នោះស្វីការនឹងមានសុពលភាព។ ទោះជាយ៉ាងណាក៏ដោយ ស្វីការដែលអស់សុពលភាពនោះ អាចត្រូវបានចាត់ទុកជាសំណើថ្មីបាន។

**៧. ស្ទីការដោយមានបន្ថែមការកែប្រែ (មាត្រា ៣៤២)**

នៅពេលទទួលបានសំណើ អ្នកធ្វើស្ទីការដាក់លក្ខខណ្ឌបន្ថែមលើសំណើ ឬបានកែប្រែខ្លឹមសារនៃសំណើ ស្ទីការកែប្រែនោះមិនមានសុពលភាពទេ ហើយត្រូវក្លាយជាសំណើថ្មី។ ក្នុងករណីនេះ កិច្ចសន្យានឹងកើតឡើង ប្រសិនបើអ្នកស្នើខាងដើមធ្វើស្ទីការចំពោះសំណើថ្មី។ ឧទាហរណ៍ A ចង់លក់ឡានឲ្យ B នូវតម្លៃ១០០០០ដុល្លារ ហើយ B និយាយតបថា បើឡាននេះបាញ់ថ្នាំថ្មី គាត់នឹងទិញឡាននោះ។ បើ A យល់ព្រមបាញ់ថ្នាំថ្មី នោះកិច្ចសន្យាទិញលក់ឡានរវាង A និង B កើតមាន។

ប្រសិនបើស្ទីការដែលមានដាក់លក្ខខណ្ឌ ឬការកែប្រែទៅនឹងសំណើដោយមិនធ្វើឲ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាពបាន លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការនោះមិនតវ៉ាភ្លាមៗ។ ឧទាហរណ៍ ដូចករណីខាងលើ តែឡានប្រឡាក់ដីច្រើន ដូច្នេះ B ស្នើសុំ ឲ្យ A លាងសម្អាតឡាននោះសិនទើបប្រគល់មកឲ្យខ្លួនជាក្រោយ។

**៨. ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្ទីការ (មាត្រា ៣៤៣)**

ទោះបីជាមិនមានការបង្ហាញឆន្ទៈអំពីស្ទីការចំពោះសំណើក៏ដោយ ប្រសិនបើសកម្មភាពនោះ ត្រូវបានចាត់ទុកថាជាស្ទីការ សំណើដែលបានដាក់នោះមានសុពលភាព នាំឲ្យកិច្ចសន្យាកើតមានឡើង។ ឧទាហរណ៍ A បញ្ជាទិញល្បែងក្មេងលេងជាឡានបញ្ជាតាមរយៈសារអេឡិចត្រូនិចទៅ B ដោយប្រាប់ពីអាសយដ្ឋាននៃការផ្ញើ។ B មិនបានឆ្លើយតបពីការយល់ព្រមទេ តែបានផ្ញើទំនិញនោះទៅអាសយដ្ឋានរបស់ A។ ករណីនេះកិច្ចសន្យាលក់ទិញឡានបញ្ជាកើតមានឡើង។

**៩. ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់**

ចំពោះសំណើដែលផ្សាយជាសាធារណៈទៅកាន់សាធារណជន វាអាចត្រូវបានដកវិញបាន តាមរយៈការផ្សាយជាសាធារណៈដែរ (មាត្រា៣៤៤)។

ឧទាហរណ៍ទី១៖ A បានផ្សាយដំណឹងពីការលក់ដីមួយកន្លែង តម្លៃ២០០០០ដុល្លារ តាមរយៈកាសែតរស្មីកម្ពុជា នៅថ្ងៃទី២ ខែឧសភា។ សន្មតថាការផ្សាយខាងលើ គឺជាសំណើ។ ក្រោយមក A បានប្ដូរចិត្តឈប់លក់ដីនោះវិញ។ A ត្រូវផ្សាយជាសាធារណៈនៅក្នុងកាសែតរស្មីកម្ពុជា អំពីការឈប់លក់ដីនោះវិញ បើពុំដូច្នោះទេ សំណើរបស់ A នៅតែមានសុពលភាព។

ឧទាហរណ៍ទី២៖ ក្រុមហ៊ុនលក់ភីហ្សា បានប្រកាសថាលក់ភីហ្សាមួយថែមមួយ ក្នុងករណីទិញខ្នាតធំមួយ នឹងត្រូវបានថែមខ្នាតកណ្ដាលមួយ។ ក្នុងករណីនេះ ក្រុមហ៊ុនភីហ្សាបានធ្វើសំណើប្រទានកម្មភ្ជាប់ជាមួយកិច្ចសន្យាលក់ទិញ។

បើក្រុមហ៊ុនភីហ្សាឈប់ថែម ត្រូវប្រកាសជូនដំណឹងអំពីការឈប់ថែមនោះ។ ការប្រកាសជូនដំណឹងនេះ ជាការដកសំណើ។

**ករណីសិក្សា**

X បានជ្រុះបាត់កាបូបលុយ ហើយបានផ្សាយជាសាធារណៈនៅលើទំព័រកាសែតថា នឹងជូន ១០០ដុល្លារ ចំពោះអ្នកដែលរកឃើញ និងបានប្រគល់ឲ្យ X វិញ។

១. ប្រសិនបើ X ចង់ដកការផ្សាយជាសាធារណៈនោះ តើគួរប្រើប្រាស់វិធីបែបណា?

២. Y បានរកឃើញកាបូបលុយ ហើយបានបញ្ជូនទៅដល់ X តែ Y មិនបានដឹងអំពីការផ្សាយជាសាធារណៈអំពីការដកសំណើនោះទេ។ តើ Y អាចទាមទារប្រាក់ ១០០ដុល្លារ ពី X បានដែរ ឬទេ?

ការពិភាក្សា៖

១. X ត្រូវផ្សាយជាសាធារណៈអំពីការដកសំណើនៅលើទំព័រកាសែតដដែលនោះវិញ។

២. បើ Y យកកាបូបមកឲ្យ X ក្រោយពីការផ្សាយជាសាធារណៈអំពីការដកសំណើ ដូច្នេះ Y មិនអាចទាមទារប្រាក់១០០ដុល្លារពី X បានទេ។

## ផ្នែកទី ២ វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា

**១.ការពិចារណាជាមូលដ្ឋាន**

-នៅក្នុងរឿងក្តីវិការៈក្នុងការបង្ហាញឆន្ទៈ តើត្រូវពិចារណាលើផលប្រយោជន៍របស់អ្នកណា?

ទិដ្ឋភាពទាំងអស់នៃការលុបចោលកិច្ចសន្យា ដោយរៀបរាប់កិច្ចសន្យាអាចត្រូវបានលុបចោល ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ។ កិច្ចសន្យាមានសុពលភាព នៅពេលការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរស្របគ្នាទៅវិញទៅមក។ ហេតុដូច្នេះហើយ ប្រសិនបើគ្មានការបង្ហាញឆន្ទៈដែលមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទេ កិច្ចសន្យានោះពុំមានចំណងចងភាគីទាំងពីរទេ ទោះបីជាកិច្ចសន្យាហាក់ដូចជាត្រូវបានបង្កើតឡើងបើមើលពីខាងក្រៅក៏ដោយ។ តាមន័យនេះ ការបង្ហាញឆន្ទៈដែលមានសុពលភាព គឺជាលក្ខខ័ណ្ឌដើម្បីឲ្យកិច្ចសន្យាមានអានុភាពចងភាគីទាំងពីរ(៣៤៥)។ ដូច្នេះ គេត្រូវពិចារណាលើផលប្រយោជន៍របស់ភាគីទាំងពីរដែលដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ។

**២.ការបង្ហាញឆន្ទៈដោយមានវិការៈ (មាត្រា ៣៤៥)**

មាត្រានេះត្រូវបានចងក្រងជាមូលហេតុនៃការលុបចោល ដែលត្រូវបញ្ញត្តិពី មាត្រា៣៤៦ ដល់ មាត្រា ៣៥១

ហេតុនេះ ជាដំបូងត្រូវស្វែងយល់ពីមាត្រាទាំងអស់នេះសិន។ ចូរអានមាត្រា៣៤៦ ដល់ មាត្រា៣៥១។

**៣.ការភាន់ច្រឡំ (មាត្រា ៣៤៥)**

**ក) និយមន័យ៖**

**១)** ការភាន់ច្រឡំ មានន័យថា គឺជាការបង្ហាញនូវឆន្ទៈទៅលើកិច្ចសន្យាដោយការយល់ច្រឡំអំពីខ្លឹមសារនៃកិច្ចសន្យា។

**២)** ការយល់ខុសដោយខ្លួនឯងដោយមិនមានអ្នកណាមួយមកបំភាន់ឡើយ។

**៣)** គឺជាស្ថានភាពមួយដែលធាតុអត្តនោម័តខាងក្នុង ខុសពីភាពសត្យានុម័តខាងក្រៅ។

**ខ) ដំណាក់កាលនៃការបង្ហាញឆន្ទៈ**

ប្រភេទនៃការភាន់ច្រឡំ ដូចខាងក្រោម៖

- ការភាន់ច្រឡំទៅលើមូលហេតុ (៣៤៦ (២))
- ការភាន់ច្រឡំទៅលើខ្លឹមសារ (៣៤៦ (១-២))
    - ចំណុចសំខាន់នៃកិច្ចសន្យាមើលពីខាងក្រៅ ( ៣៤៦ (១))
    - ចំណុចនៃកិច្ចសន្យាដែលភាគីម្ខាងយល់ថាសំខាន់ (៣៤៦ (២))
- ការភាន់ច្រឡំទៅលើការបង្ហាញ (៣៤៦ (១-២))
    - ចំណុចសំខាន់នៃកិច្ចសន្យាមើលពីខាងក្រៅ (៣៤៦ (១))
    - ចំណុចនៃកិច្ចសន្យាដែលភាគីម្ខាងយល់ថាសំខាន់ ( ៣៤៦ (២))
- ការភាន់ច្រឡំរួម (៣៤៦ (៣))

**ឧទាហរណ៍១ អំពីការភាន់ច្រឡំទៅលើមូលហេតុ** (ក) បានបង្កើតកិច្ចសន្យាទិញដីពី (ខ) ក្នុងតម្លៃ១០០០០០ដុល្លារអាមេរិក ដោយខ្លួនយល់ថា ទៅថ្ងៃមុខនឹងមានសាងសង់ផ្សារទំនើបនៅជិតទីនោះ។ តាមពិតនៅជិតដីនោះមិនមានគម្រោងសាងសង់ផ្សារទំនើបទេ។ **ករណីនេះជាការភាន់ច្រឡំលើមូលហេតុ។**

**ឧទាហរណ៍២ អំពីការភាន់ច្រឡំលើខ្លឹមសារ** (ក) យល់ថាដីរបស់(ខ)មានទំហំ៥០០០ម៉ែតការ៉េ ក៏បានបង្កើតកិច្ចសន្យាទិញដីនោះ ក្នុងតម្លៃ១០០០០០ដុល្លារអាមេរិក។ តាមពិតដីនោះមានទំហំតែ ៣០០០ម៉ែតការ៉េប៉ុណ្ណោះ។ នេះ**ជាការភាន់ច្រឡំលើខ្លឹមសារ។**

**ឧទាហរណ៍៣ អំពីការភាន់ច្រឡំលើការបង្ហាញ** ភាគី(ក)បានដាក់ស្លាកលក់ដីមួយកន្លែងក្នុងតម្លៃ១០០០០ដុល្លារអាមេរិក។ ក្រោយមកភាគី(ខ)យល់ព្រមទិញដីនោះហើយក៏បានផ្ញើសារមកសុំទិញដីភាគី(ក) ដោយសរសេរច្រឡំ

តម្លៃថា១០០០០០ដុល្លារអាមេរិក។ ភាគី(ក)បានផ្ញើសារត្រឡប់ទៅវិញ ថាយល់ព្រមលក់ដីនោះ។ **នេះជាការភាន់ច្រឡំលើការបង្ហាញ។**

**៣.១ ការភាន់ច្រឡំក្នុងកិច្ចសន្យា**

- លក្ខខណ្ឌនៃការភាន់ច្រឡំ ក្នុងការអនុវត្តមាត្រា៣៤៦ កថាខណ្ឌទី១ ៖

    ក)- ភាគីមានការភាន់ច្រឡំ

    ខ)- ចំណុចដែលភាន់ច្រឡំជាចំណុចសំខាន់ក្នុងកិច្ចសន្យា

    គ)- ភាគីម្ខាងទៀតបានដឹងពី ភាគីដែលមានការភាន់ច្រឡំ

កថាខណ្ឌទី១ ចែងថា ភាគីដែលមានការភាន់ច្រឡំត្រូវបានអនុញ្ញាតឲ្យលុបចោលកិច្ចសន្យា ក្នុងលក្ខខ័ណ្ឌ ដែលមាន «ការភាន់ច្រឡំអំពីចំនុចសំខាន់នៃកិច្ចសន្យា» ហើយភាគីម្ខាងទៀតអាចដឹងថាមានការភាន់ច្រឡំ។

- **តើចំនុចសំខាន់ៗនៃកិច្ចសន្យាជាអ្វី?** វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាចំណុចសំខាន់នៃកិច្ចសន្យាលក់។

**ឧទាហរណ៍** (ក)បានបង្កើតកិច្ចសន្យាទិញដីពី (ខ) ដោយខ្លួនយល់ថា ទៅថ្ងៃមុខនឹងមានសាងសង់ផ្សារទំនើបនៅជិតទីនោះ។ ប៉ុន្តែនៅថ្ងៃបន្ទាប់ ភាគី(ក) បានដឹងថា មិនមានការសាងសង់ផ្សារទំនើបអ្វីទេនៅជិតដីនោះ ទៅថ្ងៃខាងមុខ ដូច្នេះហើយភាគី(ក)បានលុបចោលកិច្ចសន្យា ទិញដីនោះជាមួយភាគី(ខ)។

ដូច្នេះ ដី គឺជាកម្មវត្ថុនៃកិច្ចសន្យាគឺជាចំណុចសំខាន់នៃកិច្ចសន្យា។

**ករណីសិក្សាទី១**

A បានទទួលការណែនាំទៅមើលដី X និងដី Y នៅក្នុងទីក្រុងភ្នំពេញពីអ្នកប្រកបអាជីវកម្មអចលនវត្ថុ B។ នៅពេលនោះ A បាននិយាយទៅកាន់ B ថា "ខ្ញុំចាប់អារម្មណ៍ដី X ប៉ុន្តែខ្ញុំគិតថាទៅពិភាក្សាជាមួយប្រពន្ធសិន"។ A ត្រលប់ទៅផ្ទះវិញក៏បានពិភាក្សាជាមួយប្រពន្ធ ហើយប្រពន្ធក៏បានយល់ព្រមដែរ។ ហេតុដូច្នេះ A បានផ្ញើ Mail ទៅ B ថា "ដោយសារប្រពន្ធរបស់ខ្ញុំក៏បានយល់ព្រមដែរ ខ្ញុំនឹងទិញដី Y តាមគម្រោង"។ នៅពេលនោះ A បានសរសេរច្រឡំនៅត្រង់កន្លែងដី X ទៅជាដី Y ទៅវិញ។ ហើយ A ក៏បានបង្កើតកិច្ចសន្យាជាមួយ B។ ថ្ងៃបន្ទាប់ A បានដឹងខ្លួនថាច្រឡំ តើ A អាចលុបចោលកិច្ចសន្យាលក់ទិញ ដោយមូលហេតុភាន់ច្រឡំបានដែរឬទេ? ក្នុងករណីសិក្សាទី១នេះ A អាចលុបចោលកិច្ចសន្យាលក់ទិញ ដោយមូលហេតុភាន់ច្រឡំបាន **(មាត្រា៣៤៦ កថាខណ្ឌទី១)**។

**៣.២ ការភាន់ច្រឡំអង្គហេតុសំខាន់ចំពោះភាគីម្ខាង**

លក្ខខណ្ឌនៃការភាន់ច្រឡំ ក្នុងការអនុវត្តមាត្រា៣៤៦ កថាខណ្ឌទី២៖

    ក) ភាគីមានការភាន់ច្រឡំ

ខ) ភាគីដែលភាន់ច្រឡំ មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថា សំខាន់ក្នុងការបង្កើតកិច្ចសន្យា។

គ) ភាគីម្ខាងទៀតបានដឹងពីភាគីដែលភាន់ច្រឡំ ហើយក៏ដឹងថា ចំណុចដែលភាគីភាន់ច្រឡំជាចំណុចសំខាន់របស់ភាគីភាន់ច្រឡំ។

កថាខណ្ឌទី២ ចែងអំពីករណីដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំអំពីចំណុចដែលខ្លួនឯងយល់ ដោយអត្តនោម័តថា សំខាន់។

**ត្រូវចែកជាពីរករណីដូចខាងក្រោម៖**

**ករណីទី១** អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំនៅផ្នែកណាមួយនៃកិច្ចសន្យាដែលជាធម្មតាមិនសំខាន់ទេ ទៅតាមប្រភេទនៃកិច្ចសន្យា ប៉ុន្តែ អ្នកបង្ហាញឆន្ទៈនោះយល់ឃើញខ្លួនឯងដោយអត្តនោម័តថា ចំណុចនេះសំខាន់។ ឧទាហរណ៍ ករណីនៃការលក់ទិញរថយន្ត ទោះបីជាពណ៌របស់រថយន្ត ជាធម្មតាមិនមែនជា «ចំណុចសំខាន់នៃកិច្ចសន្យា» ក៏ដោយ ប៉ុន្តែបើអ្នកទិញ ចាត់ទុកថា «ពណ៌» ថាជាចំណុចសំខាន់ ក្នុងការប្រើប្រាស់របស់គាត់ អ្នកទិញអាចអនុញ្ញាតឲ្យលុបចោលកិច្ចសន្យា ដោយហេតុផលនៃការភាន់ច្រឡំអំពីពណ៌បាន។ ប៉ុន្តែ ក្នុងលក្ខខ័ណ្ឌដែលភាគីម្ខាងទៀតអាចដឹងថា «ពណ៌» គឺជាចំណុចសំខាន់សម្រាប់អ្នកទិញ ហើយអាចដឹងបានដែរថា អ្នកទិញមានការភាន់ច្រឡំ។

**ករណីទី២** ជាករណីដែលត្រូវហៅថា «ការភាន់ច្រឡំអំពីមូលហេតុ» ឧទាហរណ៍ (ក) បង្កើតកិច្ចសន្យាជាមួយ (ខ) ដើម្បីទិញភ្នំដែលមានព្រៃឈើ ដោយមានបំណងកាប់ឈើ ប៉ុន្តែ (ក)មិនបានដឹងថា ការកាប់ដើមឈើត្រូវហាមឃាត់ទេ ដោយសារការភាន់ច្រឡំរបស់ខ្លួន។ ក្នុងករណីនេះ (ក)មានការភាន់ច្រឡំអំពីមូលហេតុ (បំណង) នៃការបង្កើតកិច្ចសន្យា ដោយអត្តនោម័ត។ ក្នុងករណីនេះ ការលុបចោលកិច្ចសន្យាត្រូវបានអនុញ្ញាត លុះត្រាតែក្នុងករណីដែលភាគីដែលមានការភាន់ច្រឡំបញ្ជាក់ថា ភាគីម្ខាងទៀត «អាចដឹង» អំពីការភាន់ច្រឡំនោះ(៣៤៦(២))។

- ចំណុចដែលយល់ឃើញថាសំខាន់នៅពេលបង្កើតកិច្ចសន្យា គឺ មូលហេតុ និងគោលបំណង។

**ករណីសិក្សាទី២**

ដូចក្នុងករណីសិក្សាទី១ដែរ A បាននិយាយទៅកាន់ B ថា " ដី X និង ដី Y ជាដីល្អ ប៉ុន្តែខ្ញុំលឺថាឆាប់ៗនេះ នៅជិតដី X នឹងមានការសាងសង់ផ្សារអ៊ីអនដ៏ធំ ហេតុនេះខ្ញុំសម្រេចទិញដី X" ហើយក៏បានបង្កើតកិច្ចសន្យាលក់ទិញ។ តាមការពិត មិនមានគម្រោងសាងសង់ផ្សារអ៊ីអននោះទេ ហើយ B ក៏បានដឹងអំពីចំណុចនេះដែរ ប៉ុន្តែ B មិនបានប្រាប់ A ទេ ហើយបង្កើតកិច្ចសន្យានេះឡើងតែម្តង។ ថ្ងៃបន្ទាប់ A បានដឹងអំពីចំណុចនេះ តើ A អាចលុបចោលកិច្ច

សន្យាដោយមូលហេតុនៃការភាន់ច្រឡំបានដែរឬទេ? ករណីសិក្សាទី២ នេះ A អាចលុបចោលកិច្ចសន្យាដោយមូលហេតុនៃការភាន់ច្រឡំបាន **(មាត្រា៣៤៦ កថាខណ្ឌទី២)**។

**៣.៣ ការភាន់ច្រឡំរួម**

លក្ខខណ្ឌក្នុងការអនុវត្តមាត្រា៣៤៦ កថាខណ្ឌទី៣ ចែងអំពីការភាន់ច្រឡំរួម។

ក) ភាគីទាំងសងខាងមានការភាន់ច្រឡំ

ខ) ចំណុចដែលមានការភាន់ច្រឡំ គឺជាចំណុចសំខាន់ក្នុងកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។

**(ការភាន់ច្រឡំរួម អំពីចំនុចសំខាន់នៃកិច្ចសន្យា) ៖**

**ឧទាហរណ៍១** (ក) ជាអ្នកបើកហាងលក់សម្ភារសិក្សា មានម៉ាកល្បីៗបានតាំងលក់កាតាប ម៉ាក Monblan ដែលមានតម្លៃខ្ពស់ ហើយបានច្រឡំដាក់តាំងកាតាបម៉ាក Monblan ដែលផលិតនៅប្រទេសចិនចូលជាមួយ (ខ) យល់ច្រឡំថាជារបស់ពិត ហើយទិញក្នុងតម្លៃខ្ពស់ ។ ម៉ាក Monblan ពិតផលិតនៅប្រទេស អាល្លឺម៉ង់ Monblan មិនពិតផលិតនៅប្រទេសចិន គឺជាចំណុចសំខាន់ក្នុងកិច្ចសន្យា។ ក្នុងករណីនេះអ្នកលក់ (ក) និងអ្នកទិញ (ខ)មានការភាន់ច្រឡំដូចគ្នា ។ ទោះបីជា(ក) មិនដឹងអំពីការភាន់ច្រឡំរបស់(ខ)ក៏ដោយ ក៏(ខ)អាចលុបចោលកិច្ចសន្យានេះបានដែរ។

**ឧទាហរណ៍២** ប្រសិនបើភាគីទាំងពីមានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា កិច្ចសន្យាអាចលុបចោលបាន ទោះបីភាគីម្ខាងគ្មានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ។ ឧទាហរណ៍ អ្នកលក់ និង អ្នកទិញបានបង្កើតកិច្ចសន្យាលក់ទិញរូបភាពដែលភាគីទាំងពីរជឿជាក់ថា ត្រូវបានគូរដោយវិចិត្រករល្បីឈ្មោះ ប៉ុន្តែក្រោយមកគេបានរកឃើញថា រូបភាពនោះមិនមែនជាស្នាដៃរបស់វិចិត្រករល្បីឈ្មោះទេ គឺជាស្នាដៃរបស់វិចិត្រករធម្មតាតែប៉ុណ្ណោះ។ ករណីនេះបើភាគីណាមួយរកឃើញការពិតបែបនេះហើយចង់លុបចោលកិច្ចសន្យាលក់ទិញវិញ អាចលុបបាន (មាត្រា៣៤៦ កថាខណ្ឌទី៣)។

**ឧទាហរណ៍៣** (ការភាន់ច្រឡំរួម អំពីចំណុចដែលយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា) ៖ A ជាម្ចាស់សណ្ឋាគានៅក្រុងសៀមរាប គាត់គិតថានៅទីក្រុងសៀមរាប នឹងមានការប្រគុំតន្ត្រីអន្តរជាតិល្បីមួយនៅជិតទីក្រុងនេះ ហើយនឹងមានភ្ញៀវច្រើន ដូច្នេះហើយ A ក៏បានឡើងថ្លៃជាងតម្លៃធម្មតា ២ដង។ ក្រោយមកការប្រគុំតន្ត្រីត្រូវបានប្តូរទីតាំង ទៅកន្លែងផ្សេងដែលនៅឆ្ងាយពីទីនោះ។ ដើម្បីចូលរួមមើលតន្ត្រីអន្តរជាតិនោះ B ក៏បានកក់សណ្ឋាគាររបស់ A ។ A និង B មិនបានដឹងពីការផ្លាស់ប្តូរទីតាំងនេះទេ។ ការផ្លាស់ប្តូរទីតាំងនៃការប្រគុំតន្ត្រីបានធ្វើឡើងនៅមុនពេលបង្កើតកិច្ចសន្យា។ ការប្រគុំតន្ត្រីនៅទីក្រុងសៀមរាប ឬ មិននៅទីនោះ មិនមែនជាចំណុចនៃកិច្ចសន្យាទេ ប៉ុន្តែ A

និង B បានគិតថា នេះជាចំណុចសំខាន់ក្នុងការបង្កើតកិច្ចសន្យា ហើយអ្នកទាំងពីរមានការភាន់ច្រឡំអំពីចំណុចនេះ។ ទោះបីជា A មិនដឹងអំពីការភាន់ច្រឡំរបស់ B ក៏ដោយ ក៏ B អាចលុបចោលកិច្ចសន្យាបានដែរ។

**ករណីសិក្សាទី៣**

ដូចក្នុងករណីសិក្សាទី២ដែរ ក្នុងករណីដែល A និង B សុទ្ធតែយល់ច្រឡំថាមានគម្រោងសាងសង់ផ្សារអ៊ីអននៅជិតដី X តើ A អាចលុបចោលកិច្ចសន្យាលក់ទិញដី X ដោយយកមូលហេតុនៃការភាន់ច្រឡំបានដែរឬទេ? ដូច្នេះ A អាចលុបចោលកិច្ចសន្យាលក់ទិញដី X ដោយយកមូលហេតុនៃការភាន់ច្រឡំបាន (**មាត្រា ៣៤៦ កថាខណ្ឌទី៣**) ។

**៣.៤ តតិយជន និង ការលុបចោលដោយការភាន់ច្រឡំ**

**(អានុភាព នៃការលុបចោលដោយសារការភាន់ច្រឡំ)៖**

លក្ខខណ្ឌតតាំងការលុបចោលនូវកិច្ចសន្យាចំពោះតតិយជន ក្នុងករណីដែលមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយនឹងកិច្ចសន្យា ក្នុងការអនុវត្តមាត្រា ៣៤៦ កថាខណ្ឌទី ៤។

**ក) អានុភាពប្រតិសកម្ម៖** កិច្ចសន្យាដែលមានការភាន់ច្រឡំ អាចលុបចោលបាន ហើយសកម្មភាពដែលត្រូវបានលុបចោលនោះ ត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង (មាត្រា៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

**ខ) ការសងតាវកាលិក៖** ក្នុងករណីលុបចោលកិច្ចសន្យា តាវកាលិកដែលទទួលបានពីកិច្ចសន្យានឹងក្លាយជាសេចក្តីចម្រើនឥតហេតុ(មាត្រា ៧៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ បើបុគ្គលដែលទទួលបានផលប្រយោជន៍ មានចេតនា ឬកំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់។ លើសពីនេះ បើបុគ្គលដែលត្រូវបាត់បង់ផលប្រយោជន៍ ទទួលការខូចខាតបុគ្គលដែលបានទទួលផលប្រយោជន៍ ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាត (មាត្រា៧៣៧ កថាខណ្ឌទី២និង៣)។

**គ) ការការពារតតិយជន៖** ការលុបចោលកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ប៉ុន្តែ ប្រសិនបើតតិយជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ នោះមិនអាចអះអាងនូវការលុបចោលចំពោះតតិយជនបានឡើយ(មាត្រា៣៤៦ កថាខណ្ឌទី៤)។

**-តតិយជនមុនការលុបចោល**

(ក) បានលក់វត្ថុអនុស្សាវរីយ៍ឲ្យ (ខ) ហើយ (ខ) បានលក់បន្តទៅឲ្យ (គ) ។ ក្រោយមកកិច្ចសន្យារវាង (ក) និង (ខ) ត្រូវបានលុបចោល។ ករណីនេះ (គ) គឺជាតតិយជនមុនពេលលុបចោលកិច្ចសន្យា។

- **តតិយជនក្រោយការលុបចោល**

(ក) បានលក់វត្ថុអនុស្សាវរីយ៍ឲ្យ (ខ) បន្ទាប់មកកិច្ចសន្យារវាង (ក) និង (ខ) ត្រូវបានលុបចោល។ ក្រោយមក (ខ) បានលក់បន្តទៅឲ្យ(គ) ។ ករណីនេះ (គ) គឺជាតតិយជនក្រោយពេលលុបចោលកិច្ចសន្យា។

ក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤នៃមាត្រា ៣៤៦ មិនមានបែងចែកតតិយជនមុន ឬក៏ ក្រោយការលុបចោលកិច្ចសន្យានោះទេ ហេតុនេះហើយអាចធ្វើការបកស្រាយថា គឺសំដៅទៅលើតតិយជនទាំងមុន និងក្រោយការលុបចោលកិច្ចសន្យាបាន។ ប៉ុន្តែ បើយោងតាមទ្រឹស្តីច្បាប់ ស្ថានភាពរបស់តតិយជនមុនពេលលុបចោលកិច្ចសន្យា និងតតិយជនក្រោយពេលលុបចោលកិច្ចសន្យាមានភាពខុសគ្នា ហេតុនេះហើយ គួរធ្វើការបែងចែកឲ្យដាច់ពីគ្នា។ពាក្យថា (តតិយជន) ក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា៣៤៦ មានគំនិតមួយលើកឡើងថា សំដៅទៅលើតែតតិយជននៅមុនពេលលុបចោលកិច្ចសន្យាតែប៉ុណ្ណោះ។

**ភាពខុសគ្នាតាមគោលជំហរនៃទ្រឹស្តី**

- **តតិយជនមុនពេលលុបចោលកិច្ចសន្យា៖** ទទួលរងការខូចខាតដោយសារតែអានុភាពប្រតិសកម្មនៃការលុបចោល។ ការលុបចោល គឺជាបញ្ហាដាច់ដោយឡែក ដូច្នេះការលុបចោល គួរការពារតាមរយៈបញ្ញត្តិដាច់ដោយឡែកដែលចែងក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤នៃមាត្រា ៣៤៦។
- **តតិយជនក្រោយពេលលុបចោលកិច្ចសន្យា៖** ទទួលរងការខូចខាតដោយសារតែចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ មិនមែនដោយសារតែអានុភាពប្រតិសកម្មនៃការលុបចោលនោះទេ។ ដូច្នេះ អាចពិចារណាថាត្រូវការពារតាមប្រព័ន្ធដែលការពារបុគ្គលដែលចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ ឬ ក៏ជនដែលមិនមានសិទ្ធិពេញលេញតាមរយៈមាត្រា១៣៤ មាត្រា១៩៣ និង មាត្រា៣៥៣ជាដើម។
- តតិយជនមុនពេលលុបចោលកិច្ចសន្យា ឧទាហរណ៍ នៅពេល គ ធ្វើពាណិជ្ជកម្មជាមួយ (ខ) នោះ (ខ) ជាជនដែលមានសិទ្ធិ។ ប៉ុន្តែ ប្រសិនបើក្រោយមក (ក) លុបចោលកិច្ចសន្យានោះ (ខ) នឹងក្លាយជាបុគ្គលគ្មានសិទ្ធិ
- តាំងពីដំបូងតាមអានុភាពប្រតិសកម្ម។
- តតិយជនក្រោយពេលលុបចោលកិច្ចសន្យា ឧទាហរណ៍នៅពេលដែល (គ) ធ្វើពាណិជ្ជកម្មជាមួយ (ខ) នោះ (ខ) គឺជាជនដែលគ្មានសិទ្ធិរួចទៅហើយ។

## ការការពារតតិយជននៅក្នុងការលុបចោលដោយមូលហេតុការភាន់ច្រឡំ

**មាត្រា៣៥៨ កថាខណ្ឌទី២**

ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។

- **ការការពារតតិយជនមុនពេលលុបចោលកិច្ចសន្យា៖**

- ជនដែលសុចរិត និងគ្មានកំហុស (គ) ត្រូវទទួលបានការការពារតាមរយៈ វាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា ៣៤៦។ សុចរិត និងគ្មានកំហុសមានន័យថា ពេលដែល(ខ) និង (គ) ចុះកិច្ចសន្យាជាមួយគ្នា, (គ) មិនបានដឹងអំពីការភាន់ច្រឡំរបស់ (ក) ព្រមទាំងមិនមានកំហុសក្នុងការមិនបានដឹងនោះ។

- **ការការពារតតិយជនក្រោយពេលលុបចោលកិច្ចសន្យា៖**

ក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា៣៤៦ មិនបានបដិសេធច្បាស់លាស់អំពីតតិយជនក្រោយពេលលុបចោលកិច្ចសន្យានោះទេ ហេតុនេះហើយ យើងអាចបកស្រាយថា វាក្យខណ្ឌ២ កថាខណ្ឌ៤នៃមាត្រា ៣៤៦ ក៏ការពារតតិយជនក្រោយពេលលុបចោលលុបចោលកិច្ចសន្យាផងដែរ។ ប៉ុន្តែ តាមរយៈហេតុផលដែលបានពន្យល់ខាងលើ ការការពារតតិយជនក្រោយពេលលុបចោលកិច្ចសន្យា មានទ្រឹស្តីដែលយកតាមប្រព័ន្ធការពារជនដែលបានចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ (ឬក៏ ជនដែលមានសិទ្ធិមិនពេញលេញ)។

**ករណីសិក្សាទី៤**

A បានគិតថានឹងលក់ដី X ទៅឲ្យ B ក្នុងតម្លៃ ១០០០០០ ដុល្លារ។ ហេតុនេះ A បានផ្ញើ mail ទៅឲ្យ B ប៉ុន្តែបានច្រឡំចំនួនទឹកប្រាក់ ដោយបានផ្ញើ mail ថា "ខ្ញុំចង់លក់ដី X ក្នុងតម្លៃ ១០០០០ ដុល្លារ តើចង់ទិញដែរឬទេ?"។ B បានដឹងថា A ច្រឡំចំនួនទឹកប្រាក់ដែរ ប៉ុន្តែ B នៅតែផ្ញើ mail ទៅ A ដោយសរសេរថា "ទិញ" ហើយក៏បានបង្កើតកិច្ចសន្យាលក់ទិញរវាង A និង B។ នៅថ្ងៃនោះ B បានធ្វើសំណើទៅ C ដែលជាអ្នកស្គាល់គ្នា ថាចង់លក់ដី X ក្នុងតម្លៃ ៧០០០០ ដុល្លារ ។ C គិតថាជាតម្លៃថោក ក៏បានសាកសួរទៅ B ហើយ B បានសារភាពថា ខ្លួនអាចទិញដី X ក្នុងតម្លៃ ១០០០០ ដុល្លារ ដោយសារ A បានច្រឡំអំពីចំនួនទឹកប្រាក់។ A បានលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការភាន់ច្រឡំនេះ។ តើ A អាចអះអាងអំពីការលុបចោលដោយមូលហេតុនៃការភាន់ច្រឡំចំពោះ C បានដែរឬទេ?A អាចអះអាងអំពីការលុបចោលដោយមូលហេតុនៃការភាន់ច្រឡំចំពោះ C បាន **(មាត្រា៣៤៦,៤) និង (មាត្រា៩៥នៃក្រមរដ្ឋប្បវេណីជប៉ុន)**

**ករណីសិក្សាទី៥**

ស្រដៀងគ្នានឹងករណីសិក្សាទី៤ដែរ ប៉ុន្តែមានចំណុចខុសគ្នាបន្តិច។ ដោយសារ A បានច្រឡំចំនួនទឹកប្រាក់ A ក៏អះអាងពីការភាន់ច្រឡំ ហើយបានលុបចោលកិច្ចសន្យាលក់ទិញដី X ជាមួយ B។ ប៉ុន្តែ ការចុះបញ្ជីកម្មសិទ្ធិលើដី X គឺ A បានផ្ទេរទៅឲ្យ B រួចហើយ ហើយពុំទាន់បានផ្ទេរត្រលប់ទៅ A វិញទេ។ ហេតុនេះ B បាននិយាយអំពីហេតុការណ៍ទាំងអស់ប្រាប់ C ហើយលក់ដី X និង បានចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឲ្យ C ។ តើ A អាចទាមទារ C ឲ្យប្រគល់ដី និងផ្ទេរការចុះបញ្ជីដី X មកឲ្យខ្លួនវិញ បានដែរឬទេ? ភាពខុសគ្នារវាងករណីសិក្សាទី ៤ គឺ តើកិច្ចសន្យាលក់ទិញរវាង B និង C ធ្វើឡើងនៅមុន ឬ ក្រោយពេល A បានលុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ។ បើកិច្ចសន្យាលក់ទិញរវាង B និង C ធ្វើឡើងនៅមុនពេលAបានលុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ នោះA មិនអាចទាមទារ C ឲ្យប្រគល់ដី និងផ្ទេរការចុះបញ្ជីដី X មកឲ្យខ្លួនវិញទេ។ ប៉ុន្តែបើកិច្ចសន្យាលក់ទិញរវាង B និង C ធ្វើឡើងនៅក្រោយពេលAបានលុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំជាមួយB នោះA អាចទាមទារ C ឲ្យប្រគល់ដី និងផ្ទេរការចុះបញ្ជីដី X មកឲ្យខ្លួនវិញបាន **(មាត្រា៣៤៦,៤) និង (មាត្រា៩៥នៃក្រមរដ្ឋប្បវេណីជប៉ុន)។ ខាងក្រោមនេះជាឧទាហរណ៍ច្រើនទៀតស្តីអំពីការការពារតតិជននៅក្នុងការលុបចោលដោយមូលហេតុភាន់ច្រឡំ៖**

**តតិយជនមុនពេលលុបចោល**




**មាត្រា៣៥៨កថាខណ្ឌទី២**

ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។

**តតិយជនមុនពេលលុបចោល**

①បានលក់ដី ③បានលក់ដី

②បានផ្ទេរការចុះបញ្ជី ④បានផ្ទេរការចុះបញ្ជី

X → Y → Z

⑤បានលុបចោលដោយមូលហេតុនៃការភាន់ច្រឡំ

ការចុះបញ្ជី

ជាលទ្ធផល ក្លាយទៅជារូបរាងនៃការទិញដីពីជនដែលគ្មានសិទ្ធិ។

ទោះបីជានិយាយនៅពេលនេះ ក៏នៅតែមានបញ្ហា។

**តតិយជនមុនពេលលុបចោល**

①បានលក់ដី ③បានលក់ដី

②បានផ្ទេរការចុះបញ្ជី ④បានផ្ទេរការចុះបញ្ជី

X - - → Y → Z

⑤បានលុបចោលដោយមូលហេតុនៃការភាន់ច្រឡំ

ការចុះបញ្ជី

ដូច្នេះ មាត្រា៣៤៦ កថាខណ្ឌទី៤ ការពារតតិយជន Z ដោយយកការគ្មានកំហុស និង សុចរិតភាពជាលក្ខខណ្ឌ។

**តតិយជនក្រោយពេលលុបចោល**

①បានលក់ដី

②បានផ្ទេរការចុះបញ្ជី

X → Y

**តតិយជនក្រោយពេលលុបចោល**

①បានលក់ដី

②បានផ្ទេរការចុះបញ្ជី

X → Y

③បានលុបចោលដោយមូលហេតុនៃការភាន់ច្រឡំ

នៅក្នុងចំណុចពេលនេះ Y ក្លាយទៅជាជនដែលគ្មានសិទ្ធិ។

**តតិយជនក្រោយពេលលុបចោល**




Z ដែលបានទិញដីពីជនដែលគ្មានសិទ្ធិ Y តើត្រូវការពារបែបណា?

**ទ្រឹស្តីA ទ្រឹស្តីភាគតិចរបស់ប្រទេសជប៉ុន**

**តតិយជនក្រោយពេលលុបចោលទ្រឹស្តីA**




មាត្រា៣៤៦ កថាខណ្ឌទី៤ ក៏ត្រូវបានអនុវត្តចំពោះតតិយជនក្រោយពេលលុបចោលដែរ។

ហេតុដូច្នេះ ប្រសិនបើZ ជាជនសុចរិត និង គ្មានកំហុស នោះនឹងត្រូវបានការពារដោយមាត្រា៣៤៦ កថាខណ្ឌទី៤។

**ទ្រឹស្តីB របៀបពិចារណារបស់តុលាការកំពូលប្រទេសជប៉ុន**

**តតិយជនក្រោយពេលលុបចោល ទ្រឹស្តី B**




នៅពេលដែល X បានលុបចោលការភាន់ច្រឡំ③ នោះអាចពិចារណាបានថា កម្មសិទ្ធិបានវិលត្រលប់ពី Y មក X វិញ។

(ជាក់ស្តែង កិច្ចសន្យារវាងXY ក្លាយទៅជាមោឃៈដោយប្រតិសកម្ម មិនមែនបានន័យថាធ្វើដំណើរការ X→Y ,

Y→X នោះទេ ប៉ុន្តែត្រូវពិចារណាបែបនេះ ដើម្បីដោះស្រាយចំណុចពិភាក្សាអំពីតតិយជនក្រោយពេលលុបចោល។ ហេតុដូច្នេះ ប្រសិនបើមើលចំណុចទាំងអស់នេះដោយផ្តោតទៅលើ Y ជាចំណុចកណ្តាល វាក្លាយទៅជារូបរាងដែលដូចគ្នានឹងការធ្វើអនុប្បទានជាន់គ្នាជាមួយ X និង Z ដូចនេះ ដោយផ្អែកលើមាត្រា១៣៤ មាត្រា១៣៥ ដោះស្រាយឲ្យនរណាបានចុះបញ្ជីមុនរវាង X និង Z យោងតាមករណីសិក្សាខាងលើនេះ ដោយសារតែ Z បានចុះបញ្ជីមុន ហេតុនេះ Z ត្រូវបានការពារ។

**ទ្រឹស្តីC របៀបពិចារណាគាំទ្ររបស់អ្នកសិក្សាច្បាប់ជាច្រើននៅប្រទេសជប៉ុន**

**តតិយជនក្រោយពេលលុបចោល ទ្រឹស្តីC**




មាត្រា៣៥៣ កថាខណ្ឌទី២ ត្រូវបានអនុវត្តប្រដូចនឹងបញ្ញត្តិអំពីការបង្ហាញឆន្ទៈមិនពិតរបស់តតិយជន។

គោលគំនិតនៃមាត្រា៣៥៣ កថាខណ្ឌទី២ គឺការពារតតិយជនសុចរិត ដោយឲ្យជនដែលបានបង្កើតរូបភាពខាងក្រៅមិនពិត ជាអ្នកទទួលខុសត្រូវ។

ករណីករណីសិក្សាខាងលើ X ក្រោយពីបានលុបចោលការភាន់ច្រឡំ③ ទោះបីជាអាចត្រលប់ការចុះបញ្ជីមកខ្លួនវិញបានភ្លាមៗក៏ដោយ ក៏ X បានធ្វេសប្រហែសក្នុងការភាន់ច្រឡំនេះដែរ។ ជាលទ្ធផល បង្កើតបានជារូបភាពខាងក្រៅមិនពិត អំពីការចុះបញ្ជីដែលនៅសល់របស់ Y ដែលជាជនគ្មានសិទ្ធិ។ នៅក្នុងចំណុចនេះ ដោយសារអាចវាយតម្លៃបានថា X បានបង្កើតរូបភាពខាងក្រៅមិនពិត ហេតុនេះត្រូវនឹងគោលគំនិតនៃមាត្រា៣៥៣ កថាខណ្ឌទី២។

ហេតុដូច្នេះ Z ត្រូវបានការពារ ប្រសិនបើជាជនសុចរិត ឬក៏មិនមានកំហុសធ្ងន់ធ្ងរ។

**៤. ការឆបោក (មាត្រា ៣៤៧)**

**និយមន័យ**

ការឆបោកគឺជាស្ថានភាពដែលភាគីម្ខាងធ្វើឲ្យភាគីម្ខាងទៀតយល់ច្រឡំទៅលើអង្គហេតុ និងបង្ហាញឆន្ទៈដោយសារសកម្មភាពបំភ្លៃអង្គហេតុ ឬជាសកម្មភាពលាក់បាំងអង្គហេតុពិត។

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ឧទាហរណ៍ បុគ្គលិករបស់ហាងលក់សំលៀកបំពាក់ អមរា បានបញ្ចុះបញ្ចូលអតិថិជនឲ្យជឿលើអង្គហេតុថា សំលៀកបំពាក់នោះផលិតដោយក្រុមហ៊ុនសំលៀកបំពាក់ប្រទេសបារាំង ដែលជាសំលៀកបំពាក់ពេញនិយម ទាំងដឹងថា ការពិតសំលៀកបំពាក់នោះគឺជាផលិតផលរបស់ក្រុមហ៊ុនប្រទេសចិន ហើយអតិថិជនក៏ជឿ និងបានទិញសំលៀកបំពាក់នោះ។ អតិថិជនអាចលុបចោល កិច្ចសន្យាដោយផ្អែកលើការឆបោកបាន។

**៤.១ ការលុបចោលដោយការឆបោក**

មានលក្ខខណ្ឌជាមួយបុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ(មាត្រា៣៤៧(១))។

- **លក្ខខណ្ឌនៃការឆបោក**

**ក)- សកម្មភាពបោកបញ្ឆោត ឬ បំភ្លៃការពិត**

- សកម្មភាពប្រាប់អង្គហេតុមិនពិត ឬសកម្មភាពលាក់អង្គហេតុ ឬបំភ្លៃអង្គហេតុ។ ប៉ុន្តែចាំបាច់ត្រូវស្ថិតនៅក្នុងកម្រិតដែលមិនត្រូវបានអនុញ្ញាតដោយសង្គម។

- ក្នុងករណីតតិយជនក្រៅពីភាគីនៃកិច្ចសន្យាជាអ្នកធ្វើសកម្មភាពឆបោក អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយផ្អែកលើភាគីម្ខាងទៀតនៃកិច្ចសន្យាបានដឹង ឬ អាចដឹងអំពីការឆបោកនោះ (មាត្រា៣៤៧(២))។

ឧទាហរណ៍ (សកម្មភាពអង្គហេតុមិនពិត)៖ នៅពេលលក់ដីមួយកន្លែង គាត់លក់ក្នុងតម្លៃថ្លៃ ដោយប្រាប់អង្គហេតុមិនពិតថា នឹងមានគម្រោងកសាងផ្លូវហៃវេមួយជាប់នឹងដីនេះនៅឆ្នាំក្រោយ។

ឧទាហរណ៍ (សកម្មភាពលាក់អង្គហេតុ)៖ នៅពេលលក់ដី គាត់លក់ក្នុងតម្លៃថ្លៃ ដោយមិនបានប្រាប់ពីរឿងហេតុដែលដីនោះមានជាប់ហ៊ីប៉ូតែក។

- មិនចាត់ទុកជាការឆបោកទេ ចំពោះកម្រិតនៃការកុហកដែលស្ថិតក្នុងទំហំនៃបច្ចេកទេសក្នុងការចចារទាក់ទងនឹង កិច្ចការពាណិជ្ជកម្ម ឬ កិច្ចការផ្សេងទៀត។

ឧទាហរណ៍ទី១៖ អ្នកលក់សំលៀកបំពាក់បានប្រាប់អ្នកទិញថា សំលៀកបំពាក់នេះអ្នកស្លៀកពាក់ទៅ គឺសមហើយ។ អ្នកទិញក៏សម្រេចចិត្តទិញសំលៀកបំពាក់នោះ។ តាមពិតសំលៀកបំពាក់នោះ អ្នកទិញស្លៀកពាក់ទៅមិនសមទេ។

ឧទាហរណ៍ទី២៖ អ្នកលក់ឡានបានប្រាប់អ្នកទិញថា ឡានពណ៌ទឹកមាសពេញនិយមណាស់នាពេលបច្ចុប្បន្ន។ អ្នកទិញក៏បានទិញឡានពណ៌ទឹកមាសនោះ។ តាមពិតឡានពណ៌ទឹកមាសមិនសូវពេញនិយមទេ។

**ខ).ចេតនានៃការឆបោក**

ដើម្បីឲ្យការឆបោកកើតមានឡើង លុះត្រាតែអ្នកឆបោកបានដឹងថា អង្គហេតុដែលខ្លួននិយាយនោះជាអង្គហេតុមិនពិត។ ប៉ុន្តែ ករណីអ្នកដែលបានប្រាប់អង្គហេតុមិនពិតមិនបានដឹងអំពីភាពមិនពិតទេនោះ អ្នកប្រាប់អង្គហេតុនោះមិនមានចេតនាក្នុងការឆបោកទេ។ ហេតុនេះការឆបោកក៏មិនកើតឡើងដែរ។

ឧទាហរណ៍ ករណីលក់នាឡិកាម៉ាកល្បីក្លែងក្លាយ ក្នុងតម្លៃខ្ពស់ដោយអ្នកលក់ជឿថាជារបស់ពិត នោះអ្នកលក់មិនមានចេតនាឆបោកទេ ហេតុនេះការឆបោកក៏មិនកើតឡើងដែរ។ ករណីនេះអាចជាការបង្ហាញព័ត៌មានមិនពិត (មាត្រា៣៤៨) ឬ ជាការភាន់ច្រឡំរួម (មាត្រា៣៤៦(៣))។

**គ). ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ**

អ្នកបង្ហាញឆន្ទៈជឿជាក់ថាសកម្មភាពកុហកនោះ ជាអង្គហេតុពិត។ ឧទាហរណ៍ ករណីអ្នកលក់ទំនិញក្លែងក្លាយនៅក្នុងផ្សារដែលមានលក់ទាំងទំនិញក្លែងក្លាយ និង ទំនិញពិតប្រាកដ បាននិយាយទៅកាន់អ្នកទិញថា ទំនិញនេះជាទំនិញពិតប្រាកដ តែលក់ក្នុងតម្លៃ៥០ដុល្លារ ដែលតម្លៃទំនិញពិតប្រាកដគឺ ១០០ដុល្លារ ហើយតម្លៃទំនិញក្លែងក្លាយគឺ ២០ដុល្លារ។ អ្នកទិញជឿថា ទំនិញនេះ ជាទំនិញពិត។ ករណីនេះជាការឆបោក។

**ករណីសិក្សាទី៦**

B បានគិតថាចង់បានដី X ដែលជាកម្មសិទ្ធិរបស់ A។ ប៉ុន្តែ A ហាក់មិនចង់លក់ដី X នេះទេ។ ហេតុនេះ B បាននិយាយបោកប្រាស់ A ថា" ដី X កាលពីមុនបានសាងសង់រោងចក្រផលិតឱសថ ហើយបច្ចុប្បន្នក៏នៅមានសារធាតុពុលចេញពីដីដែរ"។A បានជឿសម្ដីរបស់ B ហើយក៏លក់ដី X ឲ្យទៅ B។ ថ្ងៃបន្ទាប់ A បានដឹងពីការបោកប្រាស់របស់ B តើ A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការឆបោកបានដែរឬទេ?

A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការឆបោកបាន (**មាត្រា៣៤៧ កថាខណ្ឌទី១**)។

**៤.២ ការឆបោកដោយតតិយជន**

មានលក្ខខណ្ឌខ្លះដើម្បីសម្របសម្រួលនូវការការពារអ្នកបង្ហាញឆន្ទៈដែលត្រូវបានឆបោក ជាមួយនឹងផលប្រយោជន៍របស់ភាគីម្ខាងទៀត។ មាត្រា៣៤៧ កថាខណ្ឌទី២ អនុញ្ញាតឲ្យលុបចោលកិច្ចសន្យា លុះត្រាតែក្នុងករណីភាគីម្ខាងទៀតបានដឹង ឬអាចដឹងអំពីការឆបោក។

**ករណីសិក្សាទី៧**

ដូចករណីសិក្សាទី៦ដែរ B បានពិភាក្សាជាមួយ C ដែលជាមិត្តភក្តិថា "ខ្ញុំកំពុងតែមានបញ្ហា ដោយសារ A មិនព្រមលក់ដី X ឲ្យមកខ្ញុំសោះ"។ C គិតថានឹងជួយ B ហើយបាននិយាយបោកប្រាស់ A ថា "ដី X កាលពីមុនបានសាងសង់រោងចក្រផលិតឱសថ ហើយបច្ចុប្បន្នក៏នៅមានសារធាតុពុលចេញពីដីដែរ"។ ហេតុនេះ A បានសម្រេចលក់ដី X ឲ្យទៅ B។ B មិនបានដឹងអំពីការណ៍ដែល C បោកប្រាស់ A ទេ ប៉ុន្តែស្រាប់តែ A បានប្រាប់ថាព្រមលក់ដី X ឲ្យទៅ B ភ្លាមនោះ B ក៏បានគិតថា C បានជួយអ្វីមួយជាមិនខាន។ តើ A អាចលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការឆបោកបានដែរឬទេ?

ដើម្បីពិភាក្សាទៅលើករណីសិក្សាខាងលើ យើងគប្បីពិនិត្យទៅលើលក្ខខណ្ឌតម្រូវនៅក្នុងមាត្រា ៣៤៧(២) ក្នុងនោះមានៈ

លក្ខខណ្ឌទី១៖ ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន

លក្ខខណ្ឌទី២៖ 1. ករណីភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈបានដឹង ឬ

2. អាចដឹងអំពីការឆបោក

ដូច្នេះក្នុងករណីនេះ យោងតាមមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី យើងត្រូវបញ្ជាក់ថាតើ A អាចដឹងអំពីការឆបោករបស់ C ដែរឬទេ។ យើងឃើញថា A បានសម្រេចចិត្តលក់ដី គឺដោយសារការឆបោករបស់ C មានន័យថា A បានដឹងអំពីការឆបោករបស់ C។ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។ បន្ទាប់មក យើងត្រូវពិនិត្យមើលលក្ខខណ្ឌទី២បន្តទៀត។ តើ B បានដឹងពីការឆបោករបស់ C ដែរឬទេ? តាមអង្គហេតុ B មិនបានដឹងអំពីការឆបោករបស់ C ទេ។ ដូច្នេះ លក្ខខណ្ឌទី២ ចំណុចទី១ មិនបានបំពេញទេ។ យើងត្រូវពិនិត្យមើលចំណុចទី២ ទៀត ថាតើ B អាចដឹងអំពីការឆបោករបស់ C ដែរឬទេ? តាមអង្គហេតុ B បានគិតថា "C បានជួយអ្វីម្យ៉ាងជាមិនខាន"។ មានន័យថា B អាចនឹងដឹងអំពីការឆបោករបស់ C។ ដូច្នេះលក្ខខណ្ឌទី២ ចំណុច២ត្រូវបានបំពេញ។ សរុបសេចក្តីមក A អាចលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការឆបោកបាន។

### ៤.៣ ការឆបោក និង តតិយជន

មាត្រា៣៤៧ កថាខណ្ឌទី៣ ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។

**ករណីសិក្សាទី៨៖** ដូចគ្នានឹងករណីសិក្សាទី៦ បន្ទាប់ពី B បានបោកប្រាស់ A ហើយបានទិញដី X ពី A ហើយ B ក៏បានលក់ដី X នោះទៅឲ្យ C។ C មិនបានដឹងអំពីការណ៍ដែល B បោកប្រាស់ A ទេ ហើយក៏មិនមានកំហុសក្នុងការមិនដឹងនេះដែរ។ ក្រោយមក A បានលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការឆបោក។ តើ A អាចអះអាងពីការលុបចោលដោយការឆបោកចំពោះ C បានដែរឬទេ?

ដំបូងយើងត្រូវពិនិត្យមើលលក្ខខណ្ឌនៃការឆបោកយោងតាមមាត្រា៣៤៧ កថាខណ្ឌទី៣ ដូចខាងក្រោម៖

- តតិយជនជាជនទុច្ចរិត ឬ
- តតិយជនមានកំហុសអំពីការឆបោក

តាមអង្គហេតុខាងលើ យើងឃើញថា C ជាជនសុចរិត ដូច្នេះ លក្ខខណ្ឌទី១មិនត្រូវបានបំពេញទេ។ យើងត្រូវពិនិត្យមើលលក្ខខណ្ឌទី២ទៀត។ តាមអង្គហេតុដដែល C ជាជនគ្មានកំហុសអំពីការឆបោកនេះទេ ដូច្នេះលក្ខខណ្ឌទី២ ក៏មិនត្រូវបានបំពេញទៀត។ សរុបមក យើងអាចសន្និដ្ឋានបានថា A មិនអាចអះអាងអំពីការលុបចោលកិច្ចសន្យាជាមួយ C បានទេ។

**ករណីសិក្សាទី៩៖** ដូចគ្នានឹងករណីសិក្សាទី៦ A បានលុបចោលកិច្ចសន្យាជាមួយ B ដោយមូលហេតុនៃការឆបោក។ ប៉ុន្តែ ការចុះបញ្ជីកម្មសិទ្ធិលើដី បានផ្ទេរពី A ទៅឲ្យ B ហើយមិនទាន់បានផ្ទេរត្រលប់ទៅឲ្យ A វិញទេ។ B ប្រើប្រាស់ការចុះបញ្ជីដីនោះជារបស់ខ្លួន ហើយក៏លក់ដី X ទៅឲ្យ C និងបានផ្ទេរការចុះបញ្ជីទៅឲ្យ C។ C បានដឹងអំពីការណ៍ដែល B បានបោកប្រាស់ A។ តើ A អាចអះអាងពីការលុបចោលដោយការឆបោក ហើយទាមទារ C ឲ្យប្រគល់ដី X និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញ បានដែរឬទេ? A អាចអះអាងពីការលុបចោលដោយការឆបោក ហើយទាមទារ C ឲ្យប្រគល់ដី X និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបាន ព្រោះC បានដឹងអំពីការណ៍ដែល B បានបោកប្រាស់ A (មាត្រា ៣៤៧ កថាខណ្ឌទី៣ អនុញ្ញាតឲ្យលុបចោលកិច្ចសន្យា លុះត្រាតែ ក្នុងករណី«ភាគីម្ខាងទៀតបានដឹង ឬអាចដឹងអំពីការឆបោក)។

- A អាចអះអាងពីការលុបចោលដោយការឆបោក ហើយទាមទារ C ឲ្យប្រគល់ដី X និងផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបាន ព្រោះC បានដឹងអំពីការណ៍ដែល B បានបោកប្រាស់ A (មាត្រា៣៤៧ កថាខណ្ឌទី៣ អនុញ្ញាតឲ្យលុបចោលកិច្ចសន្យា)។ ប្រើបានទាំងតតិយជនក្រោយ និងមុនពេលលុបចោលកិច្ចសន្យាបាន។

-ប្រសិនបើ ប្រើមាត្រា ១៣៤ និងមាត្រា១៣៥ ដើម្បីកំណត់អ្នកឈ្នះអ្នកចាញ់ ទោះ C ជាជនសុចរិត រឺទុច្ចរិតក៏ដោយ C យល់ថា B មានការចុះបញ្ជី ដូច្នេះ C ត្រូវបានការពារ។ បើ C បានចុះបញ្ជីមុន A មិនអាចអះអាងពីការលុបចោល និង មិនអាចទាមទារឲ្យ C ផ្ទេរការចុះបញ្ជីត្រឡប់មកខ្លួនវិញបានទេ។

-បើសិនប្រើ មាត្រា (៣៥៣, ២) C បានទិញដីពីជនដែលមិនមានសិទ្ធិ B ដូច្នេះ A អាចទាមទារការចុះបញ្ជីពី C មកវិញបាន ដោយការអនុវត្តដោយប្រយោល ហើយ C ជាជនទុច្ចរិតមិនត្រូវបានការពារទេ។

### ៥. ព័ត៌មានមិនពិត

### ៥.១ ការលុបចោលដោយមូលហេតុព័ត៌មានមិនពិត

- ក្នុងការអនុវត្តមាត្រា៣៤៨ កថាខណ្ឌទី១ នេះការពារភាគីបង្ហាញឆន្ទៈ ដោយផ្អែកលើព័ត៌មានមិនពិតដែលត្រូវបានបង្ហាញដោយភាគីម្ខាងទៀត។ ប្រសិនបើភាគីម្ខាងទៀតបង្ហាញព័ត៌មានមិនពិតដោយចេតនា សកម្មភាពនេះក្លាយជាការឆបោក ហេតុដូច្នេះ អ្នកបង្ហាញឆន្ទៈត្រូវបានការពារដោយយោងតាមមាត្រា៣៤៧។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀត មិនបានធ្វើដោយចេតនាទេ ការបង្ហាញឆន្ទៈនេះមិនអាចលុបចោលដោយហេតុផលនៃការឆបោកបានទេ។ ម្យ៉ាងទៀត ក្នុងករណីដែលព័ត៌មានមិនពិតត្រូវបានបង្ហាញដោយភាគីម្ខាងទៀត មានករណីច្រើនដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ហេតុដូច្នេះ ការលុបចោលកិច្ចសន្យាអាចអនុញ្ញាតដោយហេតុផលនៃការភាន់ច្រឡំ។ ប៉ុន្តែ ការលុបចោលនូវកិច្ចសន្យាដោយសារការភាន់ច្រឡំតម្រូវថា ការភាន់ច្រឡំត្រូវទាក់ទងនឹងចំណុចសំខាន់ៗនៃកិច្ចសន្យា និងភាគីម្ខាងទៀតត្រូវមានលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំនេះ (មាត្រា៣៤៦ កថាខណ្ឌទី១)។
- ការរក្សាទុកមាត្រា៣៤៨ កថាខណ្ឌទី១ មានគោលគំនិត ការពារភាគីបង្ហាញឆន្ទៈ ដោយផ្អែកលើព័ត៌មានមិនពិត ដែលត្រូវបានបង្ហាញដោយភាគីម្ខាងទៀត។

**ករណីសិក្សាទី១០**

A គិតថានឹងជួលផ្ទះល្វែងនៅក្នុងទីក្រុងភ្នំពេញ ហើយបានពិភាក្សាជាមួយ B ដែលជាអ្នកប្រកបរបរអាជីវកម្មអចលនវត្ថុ។ B បានណែនាំផ្ទះ X ឲ្យទៅ A។ B បានពន្យល់អំពីផលប្រយោជន៍ជាច្រើនដូចជា នៅជិតផ្ទះនោះ មានផ្សារដែលមានភាពងាយស្រួល មានពន្លឺព្រះអាទិត្យចេញចូលល្អ ហើយនៅលើដំបូលមានអាងហែលទឹក កន្លែងហាត់ប្រាណជាដើម។ ដោយសារ A ចូលចិត្តហែលទឹក ហេតុនេះក៏ចាប់អារម្មណ៍អាងហែលទឹកនោះយ៉ាងខ្លាំងបំផុត ហើយសម្រេច ថាជួលផ្ទះ X ដើម្បីស្នាក់នៅ។ ប៉ុន្តែ អាងហែលទឹកនោះ បានខូចកាលពី១ឆ្នាំមុន ហើយមានសភាពដែលមិនអាចប្រើប្រាស់បាន។ B មិនបានដឹងអំពីចំណុចនេះទេ។ ក្នុងករណីនេះ តើ A ត្រូវបានការពារដោយរបៀបណា?

មុនដំបូងយើងត្រូវពិនិត្យនូវលក្ខខណ្ឌចំនួន៣នៃមាត្រា៣៤៨(១) ដូចខាងក្រោម៖

-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត

-ភាគីដែលបង្ហាញឆន្ទៈជឿថាអង្គហេតុនោះជាការពិត

-ប្រសិនបើភាគីដឹងថាអង្គហេតុនោះមិនមែនជាការពិត ភាគីនោះមិនបង្ហាញឆន្ទៈ

[ការបកស្រាយអង្គហេតុ]

ក្នុងករណីសិក្សាខាងលើ B បានប្រាប់ A អំពីការមានអាងហែលទឹកនៅលើដំបូលផ្ទះ។ ប៉ុន្តែ តាមពិត អាងហែលទឹកនោះមិនអាចដំណើរការបាន។ ដូច្នេះ លក្ខខណ្ឌទី១ត្រូវបានបំពេញ។ បន្ទាប់មកយើងបង្ហាញលក្ខខណ្ឌទី ២ ទៀត។ ក្នុងករណីនេះ A នៅពេលបង្កើតកិច្ចសន្យា ជឿថាមានអាងហែលទឹក។ ដូច្នេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។ ចុងក្រោយ យើងពិនិត្យមើលលក្ខខណ្ឌទី៣។ យើងឃើញថា ប្រសិនបើ A ដឹងថាមិនមានអាងហែលទឹកដែលអាចដំណើរការបាន ខ្លួនក៏មិនបង្ហាញឆន្ទៈជួលផ្ទះនោះដែរ។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញទៀត។

សរុបមក A អាចលុបចោលកិច្ចសន្យាជួលផ្ទះនោះបាន។

### ៥.២ សំណងការខូចខាត

គោលបំណងរបស់មាត្រា៣៤៨ កថាខណ្ឌទី២ ចែងថា ប្រសិនបើភាគីដែលបង្ហាញព័ត៌មានមិនពិត មានកំហុសក្នុងការបង្ហាញព័ត៌មានមិនពិតនេះ ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត។ ក្នុងករណីនេះ គួរបកស្រាយថា ភាគីដែលទទួលរងនូវការខូចខាត អាចលុបចោលកិច្ចសន្យា និងទាមទារសំណងនៃការខូចខាតដែលនៅសល់ក្រោយការលុបចោលបាន ឬ ក៏អាចទាមទារសំណងនៃការខូចខាតដោយមិនលុបចោលកិច្ចសន្យាបានដែរ។

### ៥.៣ ព័ត៌មានមិនពិត និង តតិយជន

មាត្រា៣៤៨ កថាខណ្ឌទី៣ មានន័យថា ប្រសិនបើកិច្ចសន្យាត្រូវបានលុបចោលដោយសារហេតុផលនៃព័ត៌មានមិនពិត អានុភាពនៃការលុបចោលកិច្ចសន្យាអាចតតាំងបាន មិនត្រឹមភាគីម្ខាងទៀតប៉ុណ្ណោះទេ ថែមទាំងតតិយជនដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់ផងដែរ។

## ៦. ការរំលោភបំពានលើស្ថានភាព

### ៦.១ ការលុបចោលដោយមូលហេតុការរំលោភបំពានលើស្ថានភាព

- មាត្រា៣៤៩ កថាខណ្ឌទី១ មានន័យថា អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន លុះត្រាតែក្នុងករណីដែលមាន "ការប្រើដោយមិនត្រឹមត្រូវ" នូវស្ថានភាពនេះប៉ុណ្ណោះ។ មាត្រា ៤៤(៤) នៃក្រមរដ្ឋប្បវេណីហូឡង់ ឲ្យនិយមន័យអំពីការរំលោភបំពានលើស្ថានភាពថា "ក្នុងករណីដែលភាគីម្ខាងដឹង ឬគួរដឹងថា ភាគីម្ខាងទៀតត្រូវបាននាំឲ្យធ្វើសកម្មភាពគតិយុត្តដែលជាលទ្ធផលនៃស្ថានភាពពិសេស ដូចជាភាពចាំបាច់ ភាពពឹងពាក់ការធ្វើសកម្មភាពភ្លាមៗដែលខ្វះការពិចារណា ស្ថានភាពខាងប្រាជ្ញាមិនប្រក្រតី ឬភាពខ្វះខាតបទពិសោធន៍ ហើយជំរុញឲ្យភាគីម្ខាងទៀតធ្វើសកម្មភាពបែបនេះ ទោះបីខ្លួនមិនគួរនាំឲ្យភាគីម្ខាងទៀតធ្វើសកម្មភាពក៏ដោយ នោះភាគីនោះប្រព្រឹត្ត

សកម្មភាពរំលោភបំពានលើស្ថានភាព" មាត្រានេះនឹងមានប្រយោជន៍ក្នុងការការពារអ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬសង្គម ជាពិសេស អ្នកប្រើប្រាស់។

- គោលគំនិតនៃមាត្រា៣៤៩ កថាខណ្ឌទី១នេះ នឹងមានប្រយោជន៍ក្នុងការការពារអ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬសង្គម។

ឧទាហរណ៍៖ ក្នុងករណីដែលស្ថានភាពនិយោជកបង្ខំឲ្យនិយោជិតលក់ដីមកឲ្យខ្លួន ប្រសិនបើនិយោជិតមិនយល់ព្រមលក់ដីឲ្យខ្លួនទេ និយោជកអាចនឹងបញ្ឈប់និយោជិតនោះពីការងារ។ ដោយនិយោជិតខ្លាចបាត់បង់ការងារខ្លួន ក៏សម្រេចចិត្តលក់ដីនោះ។

**៦.២ ការរំលោភបំពានលើស្ថានភាព និង តតិយជន**

មាត្រា ៣៤៩ កថាខណ្ឌទី២ចែងអំពីអានុភាពនៃការលុបចោលកិច្ចសន្យាដែលភាគីម្ខាងបានធ្វើដោយហេតុថាភាគីម្ខាងទៀតបានប្រើឋានៈខ្លួនខាងផ្នែកសេដ្ឋកិច្ច ជាអាទិ៍ ចំពោះតតិយជន។ ដើម្បីសម្របសម្រួលជាមួយនឹង ផលប្រយោជន៍របស់តតិយជនដែលជាជនសុចរិតហើយគ្មានកំហុស កថាខណ្ឌនេះចែងថា ការលុបចោលកិច្ចសន្យា ដោយហេតុនៃការរំលោភលើស្ថានភាព មិនអាចតតាំងចំពោះតតិយជនសុចរិតដែលគ្មានកំហុសបានឡើយ។

**៧. ការគំរាមកំហែង (មាត្រា ៣៥០)**

- មានលក្ខខណ្ឌ ក្នុងការអនុវត្តមាត្រា៣៥០នេះចែងអំពីការលុបចោលកិច្ចសន្យាដោយមូលហេតុនៃការគំរាមកំហែង។ ការង្ហាញឆន្ទៈដោយការគំរាមកំហែង ក៏ជាការបង្ហាញឆន្ទៈដែលអ្នកបង្ហាញឆន្ទៈគ្មានបំណងបង្ហាញដែរ ហេតុដូច្នេះ មាត្រានេះការពារអ្នកបង្ហាញឆន្ទៈដោយអនុញ្ញាតឲ្យអ្នកបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា។ ខុសគ្នានឹងករណីនៃការ ឆបោក ក្នុងករណីនៃការគំរាមកំហែងដែលធ្វើដោយតតិយជន ក្រមនេះបានអនុម័តយកជំហរដែលកិច្ចសន្យាអាចលុបចោលបាន ទោះបីជាភាគីម្ខាងទៀតគ្មានលទ្ធភាពដឹងអំពីការគំរាមកំហែងក៏ដោយ។
- ការឆបោក និងការគំរាមកំហែង មានចំណុចដូចគ្នាត្រង់ថា នាំឲ្យអ្នកបង្ហាញឆន្ទៈបង្ហាញខុសឆន្ទៈពិតរបស់ខ្លួន និងនាំឲ្យមានវិការៈ។
- ករណីនៃការឆបោក មានបញ្ញត្តិស្ដីពីការឆបោកដោយតតិយជន (មាត្រា៣៤៧ កថាខណ្ឌទី២) និង បញ្ញត្តិស្ដីពីការកាពារតតិយជន (មាត្រា៣៤៧ កថាខណ្ឌទី៣) ជាដើម ប៉ុន្តែ នៅក្នុងការគំរាមកំហែង ពុំមានបញ្ញត្តិដែលកម្រិតការតតាំងចំពោះអានុភាពនៃការលុបចោល ចំពោះតតិយជនដែលជាជនសុចរិតហើយគ្មានកំហុសទេ។ ហេតុនេះហើយ ផ្អែកតាមគោលការណ៍ទូទៅ អានុភាពនៃការលុបចោលកិច្ចសន្យា ដោយសារការគំរាមកំហែង អាចតតាំង

ចំពោះតតិយជន ដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់បាន។ ការកំណត់បែបនេះ មានគោលបំណងឲ្យជនរងគ្រោះនៃការគំរាមកំហែង ទទួលបាននូវការការពារធំជាងជនរងគ្រោះនៃការឆបោក ជាអាទិ៍។

**ករណីសិក្សាទី១១**

B ចង់ទិញដី X ដែលជាកម្មសិទ្ធិរបស់ A ហើយ B ក៏បានដាក់សំណើទៅ A ប៉ុន្តែ ត្រូវបាន A បដិសេធ។ B បានពិភាក្សាជាមួយ C ដែលជាមិត្តភក្តិ។ C បានដឹងថា A កំពុងតែផិតក្បត់ជាមួយស្រីផ្សេងដែលមិនមែនជាប្រពន្ធ។ ហេតុនេះ C គិតថានឹងជួយ B ដោយបាននិយាយគំរាមទៅ A ថា "ប្រសិនបើមិនលក់ដី X ឲ្យទៅ B ទេ ខ្ញុំនឹងនិយាយអំពីការផិតក្បត់របស់អ្នកប្រាប់ប្រពន្ធរបស់អ្នក"។ ហេតុនេះ A គ្មានវិធីផ្សេង ក៏បានលក់ដី X ឲ្យទៅ B។ ក្រោយមក B បានលក់ដី X ឲ្យទៅ D។ ក្នុងករណីនេះ តើ A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការគំរាមកំហែង ហើយអះអាងចំពោះ D និងឲ្យ D ប្រគល់ ដី X ត្រលប់មកវិញបានដែរឬទេ? A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការគំរាមកំហែង ហើយអះអាងចំពោះ D និងឲ្យ D ប្រគល់ ដី X ត្រលប់មកវិញបាន (មាត្រា៣៥០)។

**៨. ការកេងយកចំណេញហួសហេតុ (មាត្រា ៣៥១)**

- មាត្រា ៣៥១ នេះចែងអំពីការកេងចំណេញហួសហេតុ ចំពោះករណីដែលភាគីម្ខាងទៀតជាអនីតិជន ជាអាទិ៍តែប៉ុណ្ណោះ។
- គោលគំនិតនៃមាត្រា៣៥១ គឺថា មានតែភាគីដែលទទួលការខូចខាតផលប្រយោជន៍ប៉ុណ្ណោះ ដែលអាចលុបចោលកិច្ចសន្យាបាន។
- ករណីខ្លះទៀត ដែលត្រូវយកមាត្រា៣៥១ មកអនុវត្ត គឺករណីដែលភាគីនៃកិច្ចសន្យាជាអាជីវករ ហើយភាគីម្ខាងទៀតគឺជាអ្នកប្រើប្រាស់ ប្រសិនបើអាជីវករបានចំណេញហួសហេតុ ដោយឆ្លៀតឱកាសនៃភាពល្ងង់ ឬ ខ្វះបទពិសោធន៍របស់អ្នកប្រើប្រាស់ អ្នកប្រើប្រាស់នោះអាចលុបចោលកិច្ចសន្យាបាន ដោយយោងមាត្រានេះ។

**៩.ឋបនីយផ្លូវចិត្ត (មាត្រា ៣៥២)**

**៩.១ ករណីភាគីម្ខាងទៀតសុចរិត**

មាត្រា៣៥២ ចែងអំពីឋបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដែលធ្វើដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ។

ឧទាហរណ៍ A បង្ហាញឆន្ទៈ«ធ្វើប្រទានកម្មឲ្យទៅ B» ទោះបីជា A គ្មានបំណងធ្វើបែបនេះក៏ដោយ។ ការបង្ហាញឆន្ទៈដែលមិនពិតគឺជាការបង្ហាញឆន្ទៈដែលមានវិការៈ ហើយតាមគោលការណ៍នៃកិច្ចសន្យាដែលមានការបង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលបាន។ A ហាក់ដូចជាត្រូវអនុញ្ញាតឲ្យលុបចោលកិច្ចសន្យាប្រទានកម្ម ប៉ុន្តែ ការ

អនុញ្ញាតឲ្យលុបចោលក្នុងករណីនេះ ធ្វើឲ្យខូចប្រយោជន៍របស់ B យ៉ាងខ្លាំង ប្រសិនបើ B មិនដឹងថា ការង្ហាញឆន្ទៈរបស់ A មិនពិតទេនោះ។ ដោយដឹងថាការបង្ហាញឆន្ទៈនោះមិនពិត វាមិនចាំបាច់ការពារអ្នកបង្ហាញឆន្ទៈ A ដែលបានធ្វើឋបនីយផ្លូវចិត្តទេ។ ហេតុដូច្នេះ មាត្រានេះចែងថា កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយឋបនីយផ្លូវចិត្តមានសុពលភាព។ តែប្រសិនបើភាគីម្ខាងទៀតដឹងអំពីឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន។

ករណីនេះមិនមែនមានន័យថា ការបដិសេធនូវអានុភាពនៃកិច្ចសន្យាទេ។ ហេតុដូច្នេះហើយ ទោះបីជាភាគីម្ខាងទៀត B មិនអាចទាមទារការអនុវត្តកិច្ចសន្យាចំពោះ A ក៏ដោយ អ្នកធ្វើលទ្ធកម្មបន្ត C អាចធ្វើលទ្ធកម្មនូវសិទ្ធិរបស់ B ដោយមានសុពលភាពបាន ហើយ A មិនអាចអះអាងអ្វីចំពោះ C បានទេ **(មាត្រា ៣៥២)**។

**ករណីសិក្សាទី១២៖** A ជាសង្សាររបស់ B ប៉ុន្តែក្រោយមក A បានស្រលាញ់ C ហើយក៏ទៅនិយាយសុំបែកគ្នាជាមួយ B។ ប៉ុន្តែ B មិនព្រមបែកគ្នាឡើយ។ A បាននិយាយលេងសើចថា " ប្រសិនបើព្រមបែកគ្នា ខ្ញុំឲ្យលុយ ១000 ដុល្លារ "។ B បានលឺបែបនេះហើយ បានជឿថា A និយាយមែន ក៏សម្រេចបែកគ្នាជាមួយ A។ តើ B អាចទាមទារឲ្យ A បង់ប្រាក់ ១000 ដុល្លារ បានដែរឬទេ?

B អាចទាមទារឲ្យ A បង់ប្រាក់ ១000 ដុល្លារ បាន ព្រោះB មិនដឹងថា ការង្ហាញឆន្ទៈរបស់ Aមិនពិតនោះទេ។

**៩.២ ករណីភាគីម្ខាងទៀតទុច្ចរិត**

មាត្រា៣៥២ នេះចែងថា កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយឋបនីយផ្លូវចិត្ត មានសុពលភាព។ ប៉ុន្តែប្រសិនបើភាគីម្ខាងទៀតដឹងអំពីឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន។

គោលគំនិតនៃមាត្រា៣៥២ វាក្យខណ្ឌទី២ គឺការពារឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ ក្នុងករណីដែលភាគីម្ខាងទៀតមានបំណងទុច្ចរិត។

**ករណីសិក្សាទី១៣៖** ដូចនឹងករណីសិក្សាទី១២ A បាននិយាយលេងជាមួយ B ថា "ប្រសិនបើព្រមបែកគ្នា ខ្ញុំឲ្យលុយ១00 លានដុល្លារ"។ B បានដឹងថា A មិនមានលុយច្រើនបែបនេះទេ ហេតុនេះ B ដឹងថា A កំពុងនិយាយលេងសើច។ ក្រោយមក A និង B បានបែកគ្នា ហើយបានកន្លងផុតរយៈពេល១ឆ្នាំ ។ ដោយសារ B ត្រូវបានក្រុមហ៊ុនបណ្តេញចេញ ធ្វើឲ្យមានបញ្ហាជីវភាព ក៏ស្រាប់តែទាមទារលុយ១00លានដុល្លារពី A។ តើ A អាចបដិសេធបានដែរឬទេ? A អាចបដិសេធបាន ព្រោះកិច្ចសន្យានោះមិនមានអានុភាពទៀតទេ នេះជាទុច្ចរិតភាពរបស់ B ព្រោះ B ដឹងថា A បាននិយាយលេងសើចតែប៉ុណ្ណោះ ហើយខ្លួនបានសុខចិត្តបែកគ្នាពី A បានកន្លងផុតរយៈពេល១ឆ្នាំថែមទៀត។

### ៩.៣ ឋបនីយផ្លូវចិត្ត និង តតិយជន

**ករណីសិក្សាទី១៤៖** A ជាសង្សាររបស់ B ប៉ុន្តែក្រោយមក A បានស្រលាញ់ C ហើយក៏ទៅនិយាយសុំបែកគ្នាជាមួយ B ។ ប៉ុន្តែ B មិនព្រមបែកគ្នាឡើយ។ A បាននិយាយលេងសើចថា "ប្រសិនបើព្រមបែកគ្នា ខ្ញុំឲ្យឡាន Lexus នេះ"។ B បានលឺបែបនេះ ដឹងថា A កំពុងនិយាយលេងសើច ហើយគិតថាចង់ធ្វើឲ្យ A មានបញ្ហា ក៏បានបើកឡាន Lexus តាមអំពើចិត្ត និងលក់ទៅឲ្យ D ដែលជាមិត្តភក្តិ ក្នុងតម្លៃ ១០០០០ដុល្លារ។ ប្រសិនបើ A ទាមទារ D ឲ្យប្រគល់ឡាន Lexus តើ D អាចបដិសេធបានដែរឬទេ? ប្រសិនបើ A ទាមទារ D ឲ្យប្រគល់ឡាន Lexus D អាចបដិសេធបាន។

## ១០. ការបង្ហាញឆន្ទៈមិនពិត (មាត្រា៣៥៣)

### ១០.១ ទំនាក់ទំនងរវាងគូភាគីនៃការបង្ហាញឆន្ទៈមិនពិត

- តើមានលក្ខខណ្ឌអ្វីខ្លះ ក្នុងការអនុវត្តមាត្រា៣៥៣ កថាខណ្ឌទី១? ការបង្ហាញឆន្ទៈមិនពិត គឺឧទាហរណ៍ដូចជាករណី (ក) មានគំនិតលាក់បាំងនូវទ្រព្យសម្បត្តិរបស់ខ្លួន ហើយបានពិភាក្សាជាមួយ (ខ) ដែលជាភរិយា ដោយឃុបឃិតគ្នាធ្វើជាប្រទានកម្មទ្រព្យសម្បត្តិរបស់គាត់ទៅ (ខ) ដែលតាមការពិតទៅគាត់គ្មានឆន្ទៈធ្វើប្រទានកម្មបែបនោះឡើយ ពោលគឺជាករណីដែលបានបង្ហាញចេញមក ថ្វីបើគ្មានឆន្ទៈដូចដែលបានបង្ហាញចេញមកក៏ដោយ។ ករណីបែបនេះ គឺមិនមែនតែអ្នកបង្ហាញឆន្ទៈតែម្នាក់ឯងទេ គឺភាគីម្ខាងទៀតក៏បានដឹងដែរថា អ្នកបង្ហាញឆន្ទៈមិនមានឆន្ទៈពិតដូចដែលបានបង្ហាញចេញមកនោះទេ។ការបង្ហាញបែបនេះ គឺជាការបង្ហាញឆន្ទៈមិនពិតរវាងគូភាគី ហើយដែលច្បាប់បញ្ញត្តថាត្រូវទុកមោឃៈ (កថាខណ្ឌទី១ មាត្រា៩៤នៃក្រមរដ្ឋប្បវេណី)។

គោលគំនិតនៃមាត្រា៣៥៣ កថាខណ្ឌទី១ ការពារតតិយជនដែលសុចរិត ក្នុងករណីដែលតតិយជនមិនដឹងអំពីអង្គហេតុស្តីពីការបង្ហាញឆន្ទៈមិនពិតនោះ (មានន័យថាសុចរិត) ដូច្នេះមិនអាចតតាំងដោយផ្អែកលើមោឃភាពបានទេ (មាត្រា៩៤កថាខណ្ឌទី ២)។

**ករណីសិក្សាទី១៥៖** A ជំពាក់បំណុលជាច្រើន ហើយបារម្ភខ្លាចម្ចាស់បំណុលដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់ខ្លួន។ ហេតុនេះ ដើម្បីជៀសផុតពីការអនុវត្តដោយបង្ខំទៅលើដី X ដែលជាកម្មសិទ្ធិរបស់ខ្លួន A ក៏សម្រេចក្លែងធ្វើជាលក់ដីទៅឲ្យ B ដែលជាមិត្តភក្តិ។ ដូចនេះ A បានទៅជាពិភាក្សាជាមួយ B ហើយបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិលើដី X ទៅឲ្យ B។ ក្រោយមក A បានសងបំណុលទាំងអស់ទៅឲ្យម្ចាស់បំណុលរួចរាល់ ហើយលែងមានការបារម្ភពីការអនុវត្តដោយបង្ខំដែរ ក៏បាននិយាយទៅកាន់ B ឲ្យផ្ទេរការចុះបញ្ជីកម្មសិទ្ធិលើដី X មកឲ្យខ្លួនវិញ។ ប៉ុន្តែ B មិនព្រមផ្ទេរការចុះបញ្ជីឲ្យ A វិញទេ។ តើ A អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យារវាង A និង B និង

ទាមទារឲ្យ B ផ្ទេរការចុះបញ្ជីមកខ្លួនវិញ ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតបានដែរឬទេ? A អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យារវាង A និង B និងទាមទារឲ្យ B ផ្ទេរការចុះបញ្ជីមកខ្លួនវិញ ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតបាន (កថាខណ្ឌទី១ មាត្រា៩៤នៃក្រមរដ្ឋប្បវេណី)។

**១០.២ ការបង្ហាញឆន្ទៈមិនពិត និង តតិយជន**

- មានលក្ខខណ្ឌខ្លះ ដើម្បីឲ្យតតិយជនអះអាងអំពីសុពលភាពនៃកិច្ចសន្យាដោយផ្អែកតាមមាត្រា ៣៥៣ កថាខណ្ឌទី២ ចំពោះបុគ្គលដែលធ្វើការបង្ហាញឆន្ទៈមិនពិត។ តែចំពោះ មោឃៈភាពនៃកិច្ចសន្យាដែលបានកំណត់ក្នុងកថាខណ្ឌ១នៃមាត្រា៣៥៣ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ។
- គោលគំនិតនៃមាត្រា ៣៥៣ កថាខណ្ឌទី២ គឺការពារចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ផ្សេងទៀត។

**ករណីសិក្សាទី១៦៖** ដូចគ្នានឹងករណីសិក្សាទី១៥ដែរ B លក់ដី X ទៅឲ្យ C ហើយបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិទៅឲ្យ C។ C មិនបានដឹងថាកិច្ចសន្យាទិញលក់រវាង A និង B ជាការបង្ហាញឆន្ទៈមិនពិតទេ ហើយក៏មិនមានកំហុសចំពោះការមិនដឹងនោះដែរ។ ប្រសិនបើ A ទាមទារឲ្យ C ផ្ទេរការចុះបញ្ជីមកឲ្យ A វិញ តើ C អាចបដិសេធបានដែរឬទេ?

C អាចបដិសេធបាន ព្រោះ C មិនបានដឹងថាកិច្ចសន្យាទិញលក់រវាង A និង B ជាការបង្ហាញឆន្ទៈមិនពិតទេ ហើយក៏មិនមានកំហុសចំពោះការមិនដឹងនោះដែរ (មាត្រា៣៥៣ កថាខណ្ឌទី២) ។

**១១. ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អក្នុងអត្ថន័យនៃកិច្ចសន្យា (មាត្រា ៣៥៤)**

**១១.១ ភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ**

- មាត្រានេះចែងថា ទោះបីជាការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរត្រូវបានធ្វើដោយគ្មានមូលហេតុនៃមោឃភាព ឬ ការលុបចោលក៏ដោយ ក៏កិច្ចសន្យាចាត់ទុកជាមោឃៈដែរ ប្រសិនបើអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។ បញ្ញត្តិដែលអនុវត្តដោយបង្ខំ ជាបញ្ញត្តិដែលបដិសេធអានុភាពនៃសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនេះ។ គំនិតដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺជាកម្រិតទំហំនៃសេរីភាពក្នុងការធ្វើកិច្ចសន្យា។

- កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ។

**១១.២ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ**

- តើសណ្តាប់ធ្នាប់សាធារណៈ **និង ទំនៀមទំលាប់ល្អ** ជាអ្វី? «សណ្តាប់ធ្នាប់សាធារណៈ» ត្រង់ចំណុចនេះគឺសំដៅលើសណ្តាប់ធ្នាប់ប្រទេស ឬ សង្គម រីឯ **«ទំនៀមទំលាប់ល្អ»** សំដៅគោលគំនិតជាសីលធម៌ទូទៅនៅក្នុងសង្គម។

- កិច្ចសន្យាដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ **និង ទំនៀមទំលាប់ល្អ** ជាកិច្ចសន្យាគ្មានសុពលភាព។

**១១.៣ អត្ថន័យនៃកិច្ចសន្យាមួយផ្នែកដែលមានភាពផ្ទុយច្បាប់**

គោលគំនិតនៃមាត្រា៣៥៤ កថាខណ្ឌទី២ ចែងអំពីបញ្ហាថា តើកិច្ចសន្យាមួយផ្នែកដែលមានបញ្ហា ឬ កិច្ចសន្យាទាំងមូលត្រូវទុកជាមោឃៈ ប្រសិនបើអត្ថន័យនៃផ្នែកណាមួយនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។ ចំណុចនេះហៅថា «បញ្ហានៃមោឃភាពមួយផ្នែក»។ មោឃភាពនៃកិច្ចសន្យាធ្វើឲ្យប៉ះពាល់បុគ្គលជាច្រើនដែលមានផលប្រយោជន៍ ដែលធ្វើសកម្មភាពដោយគិតថា កិច្ចសន្យានោះមានសុពលភាព។ ដើម្បីកាត់បន្ថយការប៉ះពាល់នៃបញ្ហាមោឃភាពឲ្យបានច្រើនតាមតែអាចធ្វើបាន វាជាការសមរម្យដែលត្រូវទុកជាមោឃៈតែផ្នែកដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់លល្អប៉ុណ្ណោះ។

**១២. អលទ្ធភាពតាំងពីដំបូង (មាត្រា ៣៥៥)**

**១២.១ អលទ្ធភាពតាំងពីដំបូង**

- តើករណីណាខ្លះ ដែលអត្ថន័យនៃកិច្ចសន្យា មិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យា?

មាត្រានេះចែងថា កិច្ចសន្យាមិនត្រូវចាត់ទុកជាមោឃៈទេ ដោយហេតុផលមួយដែលហៅថា «អលទ្ធភាពតាំងពីដំបូង» អលទ្ធភាពតាំងពីដំបូងមានន័យថា នៅពេលកិច្ចសន្យាត្រូវបានបង្កើត មានភាពច្បាស់លាស់ជាស្ថាពរថា ការអនុវត្តកិច្ចសន្យានេះមិនអាចធ្វើបានទេ។ សព្វថ្ងៃនេះប្រទេសជាច្រើនមាននិន្នាការដែលមិនបានយកអលទ្ធភាពតាំងពីដំបូងធ្វើជាមូលហេតុនៃមោឃភាពនៃកិច្ចសន្យាទេ ហើយប្រសិនបើអលទ្ធភាពតាំងពីដំបូងមិនត្រូវចាត់ទុកជាមូលហេតុនៃមោឃភាពទេ កិច្ចសន្យាត្រូវបង្កើតឡើងដោយមានសុពលភាព ទោះបីជាមានអលទ្ធភាពតាំងពីដំបូងក៏ដោយ។ ក្នុងករណីនេះ អលទ្ធភាពតាំងពីដំបូង ត្រូវបានដោះស្រាយជាបញ្ហាអលទ្ធភាពទូទៅនៃការអនុវត្ត។ ហេតុដូច្នេះហើយ បញ្ហានេះត្រូវបានដោះស្រាយ តាមការរំលាយកិច្ចសន្យាដោយយកអលទ្ធភាពក្នុងការអនុវត្តមកធ្វើជាមូលហេតុ ឬ តាមសំណងការខូចខាត។ ប្រសិនបើភាគីដែលធ្វើកិច្ចសន្យាដោយជឿជាក់ថា ខ្លឹមសារនៃកិច្ចសន្យា

អាចអនុវត្តបាន បំពេញលក្ខខ័ណ្ឌនៃការភាន់ច្រឡំ នោះភាគីអាចលុបចោលកិច្ចសន្យា ដោយហេតុថាមានការភាន់ច្រឡំ។ ឧទាហរណ៍៖ ក្នុងករណីដែល A និង B បានបង្កើតកិច្ចសន្យាដូរ «រូបភាពរបស់វិចិត្រករ X» របស់ A ជាមួយនឹង «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» របស់ B ប្រសិនបើ «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» របស់ B គឺជារូបចម្លាក់ក្លែងក្លាយ ហើយជាងចម្លាក់ Y មិនដែលឆ្លាក់រូបចម្លាក់សេះទេ ការប្រគល់ «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» ពី B ទៅ A គឺជាអលទ្ធភាពតាំងពីដំបូង។ ប្រសិនបើ A បានធ្វើកិច្ចសន្យាដូរនេះដោយជឿជាក់ថា ពិតជាមាន «រូបចម្លាក់សេះរបស់ជាងចម្លាក់ Y» នោះ A មានការភាន់ច្រឡំ ហើយប្រសិនបើ A បានបំពេញលក្ខខ័ណ្ឌសម្រាប់ការលុបចោលកិច្ចសន្យាដោសារភាន់ច្រឡំ A អាចលុបចោលកិច្ចសន្យាដូរនោះបាន។

**១២.២ ការទទួលខុសត្រូវក្នុងការសងការខូចខាត**

- តើករណីណាខ្លះ ដែលអាចទាមទារសំណងការខូចខាត ដោយផ្អែកលើមាត្រា៣៥៥ កថាខណ្ឌទី២បាន?

បន្ថែមពីការទទួលខុសត្រូវទូទៅក្នុងការសងសំណងការខូចខាត ដោយសារការមិនអនុវត្តកាតព្វកិច្ច ដូចដែលបានរៀបរាប់ខាងលើ ភាគីដែលបានដឹងអំពីអលទ្ធភាពតាំងពីដំបូងនៅពេលធ្វើកិច្ចសន្យា ត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ទៅភាគីម្ខាងទៀតដែលបានធ្វើកិច្ចសន្យាគ្មានប្រយោជន៍នេះ។ នេះគឺជាបញ្ហានៃកំហុសក្នុងការបង្កើតកិច្ចសន្យា។

កថាខណ្ឌទី២ ចែងអំពីបញ្ហានេះ។ ការទទួលខុសត្រូវដែលមានចែងក្នុងកថាខណ្ឌទី២ នោះ ខុសពីការទទួលខុសត្រូវចំពោះការបង្កើតមូលហេតុនៃអលទ្ធភាព។ ឧទាហរណ៍ ចំពោះកិច្ចសន្យាលក់ផ្ទះនៅស្រុកស្រែមួយរបស់ A ទៅឲ្យ B ប្រសិនបើផ្ទះនៅស្រុកស្រែនោះ ត្រូវបានឆេះ ដោយសារការដុតរបស់តតិយជននៅមុនថ្ងៃចុះកិច្ចសន្យា អ្នកលក់ A មិនចាំបាច់ទទួលខុសត្រូវពីអលទ្ធភាពក្នុងការអនុវត្ត ប៉ុន្តែ A គួរបានដឹងអំពីការឆេះ ដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមុនកាលបរិច្ឆេតចុះកិច្ចសន្យាដោយទទួលបានព័ត៌មានអំពីផ្ទះនោះ។ ប្រសិនបើ A បានដឹង ហើយបានជូនដំណឹងទៅភាគីម្ខាងទៀត A អាចជៀសវាងមិនឲ្យភាគីម្ខាងទៀតធ្វើកិច្ចសន្យាដែលគ្មានប្រយោជន៍នេះបាន។ កថាខណ្ឌទី២ ចែងអំពីការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅឲ្យភាគីម្ខាងទៀត B ក្នុងករណីបែបនេះ។

**(រូបភាពនៃការភាន់ច្រឡំ ករណីលក់ទិញដី)**

**<u>មូលហេតុដែលនាំឲ្យមានឆន្ទៈខាងក្នុង៖</u>**

(ក) ចង់ទិញដី (ខ) ដោយខ្លួនយល់ថា ទៅថ្ងៃមុខនឹងមានសាងសង់ផ្សារទំនើបនៅជិតទីនោះ។ ពេលនោះ (ក) បានសុំទិញដីនោះពី (ខ) ក្នុងតម្លៃ១០០០០០ដុល្លារអាមេរិក ភាគី(ខ)ក៏យល់ព្រម ក៏ឈានដល់ការកក់លុយ ដើម្បី

បង្កើតកិច្ចសន្យាលក់ទិញមួយនៅថ្ងៃបន្ទាប់។ ប៉ុន្តែនៅថ្ងៃបន្ទាប់ភាគី(ក) បានដឹងថាមិនមានការសាងសង់ផ្សារទំនើបអ្វីទេនៅជិតដីនោះ ទៅថ្ងៃខាងមុខ ដូច្នេះហើយភាគី(ក)មិនព្រមធ្វើកិច្ចសន្យាកក់លុយ ដើម្បីទិញដីនោះជាមួយភាគី(ខ)ឡើយ។ តើភាគី(ក)អាចលុបចោលកិច្ចសន្យានោះបានដែរឬទេ? **យោងមាត្រា៣៤៦ កថាខណ្ឌទី១ក្រមរដ្ឋប្បវេណី ២០០៧ ចែងថា ៖** (ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំនុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ)។ ដូច្នេះភាគី(ក) អាចលុបចោលកិច្ចសន្យានោះបាន។

**<u>ឆន្ទៈទាមទារឲ្យកើតឡើងអានុភាពគតិយុត្តិ៖</u>**

(ក)មានបំណងទិញដីរបស់(ខ)ដែលមានទំហំ ៥០០០ម៉ែតការ៉េ ក្នុងតម្លៃ១០០០០០ដុល្លារអាមេរិក។ តាមពិតទៅ (ខ) មានដីទំហំតែ២០០០ម៉ែតការ៉េតែប៉ុណ្ណោះ តែដោយភាគី(ក)ភាន់ច្រឡំចំនុចសំខាន់នៃកិច្ចសន្យា ដូច្នេះ ភាគី(ខ) អាចលុចចោលកិច្ចសន្យាលក់ទិញនេះបានដោយយោងមាត្រា៣៤៦កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណីខាងលើ។

**<u>សកម្មភាពនៃការបង្ហាញ៖</u>**

ភាគី(ក)បានដាក់ផ្លាកលក់ដីមួយកន្លែងក្នុងតម្លៃ១០០០០០ដុល្លារអាមេរិក។ ក្រោយមកភាគី(ខ)យល់ព្រមទិញដីនោះ ហើយក៏បានផ្ញើសារមកសុំទិញដីភាគី(ក)ក្នុងតម្លៃ១០០០០ដុល្លារអាមេរិក។ ភាគី(ក)យល់ថា ភាគី(ខ)មានការភាន់ច្រឡំចំនុចសំខាន់នៃកិច្ចសន្យា ភាគី(ក)អាចលុបចោលកិច្ចសន្យាទិញលក់ជាមួយភាគី (ខ)បាន ដោយយោងមាត្រាទី៣៤៦ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណី២០០៧ ខាងលើ។ **(ការប្រើប្រាស់មាត្រានីមួយៗ ករណីលក់ទិញរថយន្ត)**

**<u>មូលហេតុដែលនាំឲ្យមានឆន្ទៈខាងក្នុង៖</u>**

ចំណុចដែលភាគីម្ខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។ ភាគី (ក) ទិញរថយន្តមួយពី ភាគី (ខ) ដោយខ្លួនគិតថា រថយន្តនោះជារថយន្តរបស់តារាភាពយន្តល្បីល្បាញហូលីវូដម្នាក់។ ប៉ុន្តែក្រោយពីបានប្រគល់ប្រាក់និងរថយន្តរួចមក ភាគី (ក) បាននិយាយថា ខ្លួនទិញរថយន្តនេះព្រោះរថយន្តនេះជារបស់អតីតតារាភាពយន្តហូលីវូដដែលគាត់ពេញចិត្តតែប៉ុណ្ណោះ។ ពេលនោះភាគី (ខ) បានប្រាប់ថា រថយន្តនេះមិនមែនរបស់តារាភាពយន្តល្បីល្បាញអីទេ គឺជារបស់គាត់តែម្តង។ ភាគី (ក) ស្រង៉ាកចិត្ត ហើយសុំលុបកិច្ចសន្យាលក់ទិញនេះវិញ។ តើភាគី (ក) អាចលុបចោលកិច្ចសន្យានេះបានដែរ ឬទេ? បើយោងតាម **មាត្រា៣៤៦ កថាខណ្ឌទី២ ចែងថាៈ** (ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំនៃចំនុចនៃកិច្ចសន្យាដែលខ្លួនយល់ថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការ

ភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ដូចនេះភាគី (ក) អាចលុបកិច្ចសន្យាបាន។ មួយវិញទៀត បើ**យោងតាមមាត្រា៣៨៦ កថាខណ្ឌទី៣ ចែងថាៈ** (ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ដូច្នេះ ភាគី (ក)ក៏អាចលុបចោលកិច្ចសន្យាបានដែរ ។

**<u>ឆន្ទៈទាមទារឲ្យកើតឡើងនូវអានុភាពគតិយុត្តិៈ</u>**

លោក (ក) បានទូរស័ព្ទសុំទិញរថយន្តឡិចស៊ីសពីលោក (ខ) ក្នុងតម្លៃ១០០០០ដុល្លារ ដែលភាគី (ខ) បានប្រកាសលក់។ តាមពិតលោក (ខ) ប្រកាសលក់រថយន្តស៊ីអរវី ទេក្នុងតម្លៃ១០០០០ដុល្លារនោះ លោក (ខ) មិនមានរថយន្តឡិចស៊ីសដូចដែលលោក (ក) ចង់បាននោះទេ។ ដូច្នេះលោក (ខ) អាចលុបកិច្ចសន្យាលក់ទិញជាមួយលោក(ក) វិញបាន។ នេះបើយោងតាមមាត្រា ៣៨៦ កថាខណ្ឌទី ១ និង កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ខាងលើ។

ក្នុងករណីស្រដៀងគ្នានេះដែរ លោក (ក) បានសុំទិញរថយន្តពីលោក (ខ) ក្នុងតម្លៃ១០០០០ដុល្លារ។ លោក (ក) ចង់ទិញរថយន្តដែលមានស្លាកលេខភ្នំពេញតែប៉ុណ្ណោះ ប៉ុន្តែលោក (ខ) មិនមានរថយន្តដែលមានស្លាកលេខភ្នំពេញទេ គាត់មានតែរថយន្តដែលមានស្លាកលេខខេត្តកណ្ដាល។ តើលោក (ក) អាចលុចចោលកិច្ចសន្យាលក់ទិញជាមួយលោក (ខ) បានដែរឬទេ?

យោងតាមមាត្រា ៣៨៦កថាខណ្ឌទី២ ចែងថាៈ (ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំនៃចំនុចនៃកិច្ចសន្យាដែលខ្លួនយល់ថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ)។ **មាត្រា៣៨៦ កថាខណ្ឌទី ៣ ចែងថា** (ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុច សំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ)។ ដូច្នេះ បើយោងតាមមាត្រា៣៨៦ កថាខណ្ឌ២ និងកថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

លោក (ក) អាចលុបកិច្ចសន្យាលក់ទិញរថយន្តពីលោក (ខ) វិញបាន។

<u>**សកម្មភាពនៃការបង្ហាញ៖**</u>

លោក (ក) ប្រកាសលក់រថយន្តរបស់គាត់ក្នុងតម្លៃ១០០០០ដុល្លារ ជាច្រើនថ្ងៃមកហើយ ។ ក្រោយមកលោក (ខ) បានផ្ញើរសារមកសុំទិញរថយន្តនោះក្នុងតម្លៃប្រកាសលក់ខាងលើ ប៉ុន្តែលោក (ខ) បានផ្ញើរសារច្រឡំតម្លៃ ១០០០ដុល្លារទៅវិញ។ សួរថាតើលោក (ក) អាចលុបកិច្ចសន្យាលក់ទិញនេះវិញបានដែរ ឬទេ? បើយោងតាម មាត្រា ៣៤៦ កថាខណ្ឌទី១ និង កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ លោក (ក) អាចលុបកិច្ចសន្យាលក់ទិញនេះវិញបាន។

លោក (ក) ជាអ្នកលក់រថយន្តនៅភ្នំពេញ លោក (ខ) មានទីលំនៅ នៅខេត្តសៀមរាបបានឡើងមកទិញរថយន្តនៅភ្នំពេញ។ ថ្ងៃមួយលោក (ខ) បានមកជួបលោក (ក) ដើម្បីទិញរថយន្តពីលោក (ក) អ្នកទាំងពីរបានព្រមព្រៀងគ្នាលក់ទិញរថយន្តមួយគ្រឿងក្នុងតម្លៃសមរម្យ ដោយសន្យា៣ថ្ងៃក្រោយប្រគល់រថយន្ត និងប្រគល់លុយ។

ប៉ុន្តែ ៣ថ្ងៃក្រោយលោក (ក) រង់ចាំលោក (ខ) ដើម្បីប្រគល់រថយន្តនៅភ្នំពេញ រីឯលោក (ខ) ក៏រង់ចាំលោក (ក) ដើម្បីប្រគល់ប្រាក់នៅខេត្តសៀមរាបផងដែរ។ អ្នកទាំងពីរបានយល់ច្រឡំពីទីកន្លែងប្រគល់រថយន្ត។ ក្នុងករណីនេះ បើភាគីណាមួយចង់លុបចោលកិច្ចសន្យាលក់ទិញវិញ អាចលុបបាន នេះបើយោងតាមមាត្រា ៣៤៦ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

## ផ្នែកទី ៣ មោឃភាព និងការលុបចោល

### ១. ការពិចារណាជាមូលដ្ឋាន

នៅពេលបង្កើតកិច្ចសន្យា ភាគីទាំងពីរនឹងត្រូវចងដោយអត្ថន័យនៃកិច្ចសន្យានោះ និង មានករណីយកិច្ច។

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់មានករណីយកិច្ចប្រគល់កម្មវត្ថុទៅឲ្យអ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចប្រគល់ប្រាក់។ ប៉ុន្តែ ក្នុងករណីជាក់លាក់មួយចំនួន ចាំបាច់ត្រូវបដិសេធលើអានុភាពរបស់កិច្ចសន្យា។

ឧទាហរណ៍ ករណីដែលអត្ថន័យនៃកិច្ចសន្យានោះប្រឆាំងនឹងផលប្រយោជន៍របស់ប្រជាជាតិ ទាំងមូល និងករណីដែលចាំបាច់ត្រូវការពារភាគី ជាដើម។

បច្ចេកទេសដើម្បីធ្វើការបដិសេធអានុភាពនៃកិច្ចសន្យានៅក្នុងករណីបែបនេះ គឺមោឃភាព និងការលុបចោល។ ជាទូទៅ ករណីភាគច្រើនតម្រូវឲ្យធ្វើការបដិសេធអានុភាពនៃកិច្ចសន្យា តាមមោឃភាព ជាជាង តាមការលុបចោល។

ភាពខុសគ្នារវាងចំនុចទាំងពីរ ត្រូវបានបង្ហាញដោយភាពខុសគ្នាដូចខាងក្រោម៖

- តើអ្នកណាអាចធ្វើការអះអាងបាន?
- អាចផ្តល់សច្ចានុមតិ បានឬទេ?
- មានកម្រិតពេលវេលាដែរឬទេ?

**២. និយមន័យនៃសកម្មភាព (មាត្រា ៣៥៦)**

សកម្មភាពដែលសំដៅដល់មោឃភាព និងការលុបចោល គឺ កិច្ចសន្យា ឬ សកម្មភាពឯកតោភាគី។ សកម្មភាពឯកតោភាគីគឺ ឧទាហរណ៍ ការទូទាត់ ការលើកលែង ជាដើម។

**៣. អត្ថន័យនៃមោឃភាព (មាត្រា ៣៥៧)**

ក្នុងមាត្រានេះមានឧទាហរណ៍អំពី ករណីនៃសកម្មភាពដែលក្លាយជាមោឃភាព មួយចំនួន ត្រូវបានលើកឡើង។

- ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ
- ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ
- ផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារដោយច្បាប់

ក្រៅពីនេះ ក៏មានករណីសកម្មភាពក្លាយជាមោឃភាពផ្សេងទៀតដែរ។

- ការបង្ហាញឆន្ទៈមិនពិត
- ការតំណាងដោយគ្មានសិទ្ធិ

ប្រសិនបើសកម្មភាពជាមោឃភាព មិនត្រឹមតែភាគីប៉ុណ្ណោះទេ បុគ្គលណាក៏អាចអះអាង មោឃភាពបានដែរ។ ផ្ទុយទៅវិញ ចំពោះការលុបចោលវិញ មានតែអ្នកមានសិទ្ធិលុបចោលប៉ុណ្ណោះ ទើបអាចធ្វើការលុបចោលបាន (ម ៣៥៩)។

〔អំពីបញ្ញត្តិដែលអនុវត្តដោយបង្ខំ និងបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត〕

ដើមឡើយក្រមរដ្ឋប្បវេណីគឺ បង្កើតឡើងដើម្បីដោះស្រាយជម្លោះនៃសកម្មភាពសេដ្ឋកិច្ច រវាងប្រជាជន មិនមែនដើម្បីកំណត់ទំនាក់ទំនងរវាងរដ្ឋ និងប្រជាជននោះទេ។ ហេតុនេះ ឧទាហរណ៍ថាទោះជាមានកិច្ចសន្យា ដែលមានអត្ថន័យប្រឆាំងនឹងបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ដោយ ប្រសិនបើភាគីទាំងសងខាងមានការពេញចិត្ត នោះនឹងក្លាយទៅជាគោលការណ៍មានប្រសិទ្ធភាព។

ឧទាហរណ៍៖ ក្នុងមាត្រា ៥១៨ បានចែងថា "អ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញ ដោយសងប្រាក់ស្មើនឹង២ដងនៃប្រាក់កក់ទៅអ្នកទិញ"។ ប៉ុន្តែ ប្រសិនបើភាគីទាំងពីរ អ្នកលក់ និង អ្នកទិញ មានការសន្យាដោយការពេញចិត្ត

ថា "កិច្ចសន្យាអាចរំលាយបានដោយ អ្នកលក់សងប្រាក់ស្មើនឹង៣ដងនៃប្រាក់កក់ទៅអ្នកទិញ" ក៏អាចធ្វើបានដែរ។ ព្រោះទោះបីជាទទួលស្គាល់កិច្ចសន្យាបែបនេះក៏ដោយ ក៏មិនបង្ករការរំខានដល់នរណាម្នាក់ឡើយ។ ការណ៍ដែលភាគីទាំងពីរបដិសេធការអនុវត្ត ដោយការព្រមព្រៀងបែបនេះហៅថា បញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត។

ប៉ុន្តែ មិនមែនមានន័យថា គ្រប់បញ្ញត្តិទាំងអស់របស់ក្រមរដ្ឋប្បវេណី សុទ្ធតែជាបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្តនោះទេ។ នៅក្នុងក្រមរដ្ឋប្បវេណីក៏មានបទបញ្ញត្តិសម្រាប់ជាប្រយោជន៍ដល់ប្រជាជនទាំងអស់ដែរ។ ឧទាហរណ៍ មាត្រា ១៣៥ បានចែងថា "ការផ្ទេរកម្មសិទ្ធិលើ អចលនវត្ថុដោយព្រមព្រៀង មិនមានអានុភាពបើមិនមានការចុះបញ្ជី"។ នេះ ជាការធានាសុវត្ថិភាពនៃរាល់កិច្ចការជំនួញអចលនវត្ថុទាំងអស់ ដោយយកការចុះបញ្ជីមកធ្វើជាល័ក្ខខ័ណ្ឌប្រសិទ្ធភាព។ មានន័យថា បទបញ្ញត្តិនេះ មិនមែនគ្រាន់តែជាលក្ខណៈវិនិច្ឆ័យសម្រាប់ដោះស្រាយជម្លោះរវាងគូភាគីទេ វាគឺជាបញ្ញត្តិមានមុខងារសម្រាប់ការប្រព្រឹត្តិទៅដ៏ត្រឹមត្រូវនៃប្រព័ន្ធរបស់រដ្ឋដែលហៅថា ប្រព័ន្ធចុះបញ្ជី។ ប្រសិនបើមានការបង្កើតកិច្ចសន្យា ដោយផ្អែកលើការព្រមព្រៀងរវាងគូភាគីថា "មិនបាច់ធ្វើការផ្ទេរការចុះបញ្ជី គ្រាន់តែផ្ទេរកម្មសិទ្ធ" នោះការផ្ទេរកម្មសិទ្ធិនឹងមិនត្រូវបានបង្ហាញក្នុងការចុះបញ្ជី ហើយប្រព័ន្ធចុះបញ្ជីនឹងត្រូវបាត់បង់មុខងារ។ មានន័យថា នឹងមានបង្ករការរំខានដល់សាធារណៈជន។ ដូច្នេះ ឧទាហរណ៍៖ បើមានការព្រមព្រៀងរវាងគូភាគីក៏ដោយ មិនអាចបង្កើតកិច្ចសន្យាដែលមានអត្ថន័យប្រឆាំងនឹងមាត្រា ១៣៥ បានទេ។ កិច្ចសន្យាបែបនោះទុកជាមោឃភាព។ បទបញ្ញត្តិបែបនេះ ហៅថា បញ្ញត្តិដែលអនុវត្តដោយបង្ខំ។

ដើម្បីដឹងថា បទបញ្ញត្តិមួយជាបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត ឬ ជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ចាំបាច់ត្រូវធ្វើការវិនិច្ឆ័យដោយអាស្រ័យលើគោលបំណង និង គោលដៅរបស់បទបញ្ញត្តិនោះ។ ជាទូទៅ ក្នុងផ្នែកសិទ្ធិលើបំណុល មានបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្តច្រើន ហើយក្នុងផ្នែកសិទ្ធិប្រត្យក្ស និង ញាតិ មានបញ្ញត្តិដែលអនុវត្តដោយបង្ខំច្រើន។

**៤. សកម្មភាពដែលអាចលុបចោលបាន (មាត្រា ៣៥៨)**

បើសកម្មភាពមួយជាមោឃភាព ទោះជាភាគីមិនអះអាងមោឃភាព ក៏តាមសត្យានុម័តខាងក្រៅ គឺជាមោឃភាព។ ម្យ៉ាងវិញទៀត សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ (ក ១)។

ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានលុបចោល សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។ មានន័យថា ការលុបចោល មានអានុភាពប្រតិសកម្ម (ក ២)។ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិ សកម្មភាពនោះនឹងត្រូវមាន សុពលភាពជាស្ថាពរ (ក ៣)។

### ៥. អ្នកមានសិទ្ធិលុបចោល

អ្នកមានសិទ្ធិលុបចោលមានដូចខាងក្រោម។

ករណីការបង្ហាញឆន្ទៈមានវិការៈ (ការភាន់ច្រឡំ ការឆបោក ជាដើម)

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់
- សន្តតិជន
- អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យា

ករណីកង្វះសមត្ថភាពខាងឆន្ទៈ ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ហិតូបត្ថម្ភកៈ
- សន្តតិជន
- អច្ច័យលាភីសកល

### ៦. វិធីនៃការលុបចោល ឬសច្ចានុមតិ (មាត្រា ៣៦០)

ការលុបចោល និង សច្ចានុមតិ ត្រូវធ្វើឡើងតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀត។ ការជូនដំណឹងធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ជាលិខិតក៏បាន។

អានុភាពនៃការលុបចោល និង សច្ចានុមតិកើតមានឡើង នៅពេលការជូនដំណឹងបានទៅ ដល់ភាគីម្ខាងទៀត។

〔អាច ឬ មិនអាចនៃបណ្តឹងទាមទារលុបចោលកិច្ចសន្យា〕

នៅក្នុងក្រឹត្យច្បាប់លេខ ៣៨ បណ្តឹងទាមទារលុបចោលកិច្ចសន្យាអាចកើតឡើងបានដោយខ្លួនវាផ្ទាល់។

ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីថ្មី និង ក្រមនីតិវិធីរដ្ឋប្បវេណីវិញ បណ្តឹងទាមទារលុបចោលកិច្ចសន្យាមិនអាចលើកឡើងបានដោយខ្លួនវាផ្ទាល់ទេ។ ពីព្រោះ ដោយគ្រាន់តែបានលុបកិច្ចសន្យា គឺមិនអាចសម្រេចគោលបំណងចំបងដែលជាសំណងជាសាច់ប្រាក់ និង សំណងជាកម្មវត្ថុបានទេ។ ដោយសារតែ ចុងក្រោយនៅតែត្រូវដាក់ពាក្យបណ្តឹងដើម្បីទាមទារសំណងជាសាច់ប្រាក់ និង សំណងជាកម្មវត្ថុម្តងទៀត។

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាទិញលក់ដី ក្រោយពេលអ្នកទិញបានបង់ប្រាក់រួច កិច្ចសន្យាក៏ត្រូវលុបចោលដោយមូលហេតុការភាន់ច្រឡំ។ ក្នុងករណីនេះ នៅក្រៅតុលាការ ពេលដែលអ្នកទិញបានជូនដំណឹងពីការភាន់ច្រឡំ

ទៅកាន់អ្នកលក់ អានុភាពនៃការលុបចោលនឹងកើតឡើង។ ប៉ុន្តែប្រសិនបើ អ្នកលក់មិនព្រមទទួលស្គាល់ការលុបចោលរបស់អ្នកទិញ ហើយមិនព្រមសងប្រាក់ នោះអ្នកទិញចាំបាច់ត្រូវដាក់ពាក្យប្ដឹង។ ករណីនេះ អ្នកទិញមិនមែនដាក់ពាក្យបណ្ដឹងទាមទារលុបចោលកិច្ចសន្យានោះទេ គឺចាំបាច់ត្រូវដាក់ពាក្យបណ្ដឹងទាមទារសំនងជាសាច់ប្រាក់។ ការលុបចោលកិច្ចសន្យា គឺជាវិធីសាស្ត្រក្នុងការការពារការវាយប្រហារក្នុងវិវាទ ប៉ុន្តែ មិនមែនជាគោលបំណងនៃពាក្យបណ្ដឹងទេ។

**៧. អ្នកមានសិទ្ធិផ្ដល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្ដល់សច្ចានុមតិ (មាត្រា ៣៦១)**

- ក្នុងករណីការបង្ហាញឆន្ទៈមានវិការៈ អ្នកមានសិទ្ធលុបចោលអាចផ្ដល់សច្ចានុមតិបាន ចាប់ពីពេលបានដឹងអំពីមូលហេតុនៃការលុបចោល (ក ១)។

ករណីសិក្សា

ក ត្រូវបាន ខ បោកបញ្ឆោតថា ដី X ច្បាស់ជាឡើងថ្លៃក្នុងរយៈពេល១ឆ្នាំ។ ក ក៏បានបង្កើតកិច្ចសន្យាទិញ ដី X ពី ខ និង ធ្វើលិខិតយថាភូត។ ខ បានសួរទៅកាន់ ក ថា "អាចលុបចោលកិច្ចសន្យាពីឥឡូវបាន តើគិតយ៉ាងណា?"។ នៅពេលនោះ ក មិនទាន់បានដឹងពីការបោកបញ្ឆោតរបស់ ខ រួចក៏តបថា "ទេ មិនចាំបាច់លុបចោលទេ។"។ ក្រោយមក កន្លងផុតទៅ១ឆ្នាំ តំលៃដី X មិនឡើងថ្លៃ ក គិតថាត្រូវបាន ខ បោកប្រាស់ ក៏បានដាក់ពាក្យបណ្ដឹងលុបចោលកិច្ចសន្យាដោយមូលហេតុឆបោក និង ទាមទារសំនងជាសាច់ប្រាក់ពី ខ។ ក្នុងវិវាទ ខ បានអះអាងថា "ដោយសារតែ ក បានផ្ដល់សច្ចានុមតិថា មិនចាំបាច់លុបចោលកិច្ចសន្យា ហេតុនេះកិច្ចសន្យាមិនអាចលុបចោលបានទេ។" ។ ការអះអាងរបស់ ខ មិនអាចទទួលយកបានទេ។ ពីព្រោះ ពេលដែល ក ឆ្លើយតបទៅ ខ ក មិនបានដឹងថាមានមូលហេតុនៃការលុបចោល ហេតុនេះ សកម្មភាពរបស់ ក មិនក្លាយជាសច្ចានុមតិទេ។

- ករណីកង្វះសមត្ថភាពខាងឆន្ទៈ ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព អាចផ្ដល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោល ត្រូវរលត់ (ក ១)។ ឧទាហរណ៍ ករណីអនីតិជន បើមិនទាន់ក្លាយជាជនគ្រប់អាយុ មិនអាចផ្ដល់សច្ចានុមតិបានទេ។ ប៉ុន្តែ ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ និង ហិតូបត្ថម្ភកៈ ទោះជាអ្នកបង្ហាញឆន្ទៈអសមត្ថភាពខាងឆន្ទៈ ឬ អសមត្ថភាពខាងសកម្មភាពក៏អាចផ្ដល់សច្ចានុមតិបានដែរ (ក ២)។

**៨. សច្ចានុមតិដែលច្បាប់បានកំណត់ (មាត្រា ៣៦២)**

ទោះជាមិនមានការជូនដំណឹងច្បាស់លាស់ក៏ដោយ ប្រសិនមានបើមានអង្គហេតុដូចខាងក្រោម នឹងត្រូវចាត់ទុកថា បានផ្ដល់សច្ចានុមតិរួចហើយ។ ព្រោះថា ប្រសិនមានអង្គហេតុដូចខាងក្រោម ភាគីម្ខាងទៀតនឹងរំពឹងទុកថា

កិច្ចសន្យានឹងមិនត្រូវបានលុបចោលទេ ការរំពឹងទុកបែបនេះចាំបាច់ត្រូវការពារ។

ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ (ចំនុច ក)។

ករណីសិក្សា

ក មានបំណងទិញរថយន្ត Lexus ពីអ្នកស្គាល់គ្នា ខ ប៉ុន្តែបានច្រឡំទិញរថយន្ត CRV ទៅវិញ។ ក បានគិតថាចង់លុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ ប៉ុន្តែមិត្តស្រី របស់គាត់ គ បាននិយាយថា "ខ្ញុំចូលចិត្តរថយន្ត CRV ជាងរថយន្ត Lexus។" ក ក៏មិនបានលុបចោលកិច្ចសន្យាហើយប្រគល់ប្រាក់ឲ្យ ខ។ ប៉ុន្តែក្រោយមក ក បានបែកគ្នាជាមួយ គ ហើយចាប់ផ្តើមសេពគប់ជាមួយ ឃ ជាមិត្តស្រីថ្មី។ ដោយសារតែ មិត្តស្រី ឃ បាននិយាយថា "រថយន្ត Lexus ឡូយជាង រថយន្ត CRV" ក គិតថាទិញរថយន្ត Lexus ក៏បានជូនដំណឹងលុបចោលកិច្ចសន្យាទៅ ខ និង ទាមទារសំណងជាសាច់ប្រាក់។ ករណីបែបនេះ ការបង់ប្រាក់របស់ ក ត្រូវបានចាត់ទុកជាសច្ចានុមតិ ហេតុនេះ ខ អាចបដិសេធមិនសងសំណងជាប្រាក់បាន។

- ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាមទារឲ្យភាគីម្ខាងទៀតអនុវត្ត (ចំនុច ខ)។
- អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។
- ប៉ុន្តែ ករណីដែលបានសំដៅទុកជាមុនថាមិនផ្តល់សច្ចានុមតិ នោះមិនត្រូវបានចាត់ទុកថាបានផ្តល់សច្ចានុមតិទេ។

ករណីសិក្សា

ក មានបំណងទិញរថយន្ត Lexus ពីអ្នកស្គាល់គ្នា ខ ប៉ុន្តែបានច្រឡំទិញរថយន្ត CRV ទៅវិញ។ ក បានគិតថានឹងសួរយោបល់ពីមិត្តស្រីរបស់គាត់ គ ថាគួរតែលុបចោលកិច្ចសន្យាដោយមូលហេតុការភាន់ច្រឡំ ឬទេ រួចទើបធ្វើការសម្រេចចិត្ត។ ហើយនៅពេលដែលត្រូវបាន ខ ទាមទារឲ្យបង់ប្រាក់ ក បាននិយាយថា "ខ្ញុំបង់ប្រាក់ឲ្យជាមុនសិន ប៉ុន្តែ ប្រសិនបើមិត្តស្រីរបស់ខ្ញុំនិយាយថា ចង់ជិះរថយន្ត Lexus កិច្ចសន្យានឹងត្រូវលុបចោល" រួចក៏បានបង់ប្រាក់។ ក្រោយមក បន្ទាប់ពីបានស្តាប់គំនិតមិត្តស្រី គ រួច នាងបានឆ្លើយថា "ចង់ជិះថយន្ត Lexus ជាង រថយន្ត CRV" ។ ពេលនោះ ក ក៏បានជូនដំណឹងលុបចោលកិច្ចសន្យា ទៅ ខ និង ទាមទារសំនងជាប្រាក់។ ករណីនេះ ខ មិនអាចបដិសេធមិនផ្តល់សំនងជាប្រាក់បានទេ។

**៩. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល (មាត្រា ៣៦៣)**

- សិទ្ធិលុបចោលនឹងត្រូវរលត់ ក្នុងរយៈពេល៣ឆ្នាំចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ(ក ១)។ សិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោល ក៏ត្រូវរលត់ដែរ (ក ១)។
- ម្យ៉ាងទៀត ទោះបីជាមិនស្ថិតក្នុងស្ថានភាពអាចផ្តល់សច្ចានុមតិក៏ដោយ ប្រសិនបើហួស អំឡុងពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ (ក ២)។
- ក្នុងករណីដែលមានបុគ្គលច្រើននាក់មានសិទ្ធិលុបចោល បញ្ញត្តិនៃកថាខណ្ឌទី១ និង ទី២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនីមួយៗ (ក ៣)។

ករណីសិក្សា

ក គឺជាអនីតិជន មានអាយុ១៦ឆ្នាំ ហើយ ខ គឺជាអ្នកតំណាងដែលច្បាប់បានកំណត់។ នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៥ ក បានបង្កើតកិច្ចសន្យាទិញលក់រថយន្តជាមួយ គ។ ក បានក្លាយជា ជនគ្រប់អាយុ ១៨ឆ្នាំ នៅថ្ងៃកំណើត ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៦។ ក្នុងករណីជាកូន ដោយសារ ខ ជាឪពុក អាចអនុវត្តសិទ្ធិសច្ចានុមតិចាប់ពីពេលបង្កើតកិច្ចសន្យារបស់ ក សិទ្ធិលុបចោលរបស់ ខ ជាឪពុកនឹងរលត់ រយៈពេល ៣ឆ្នាំ បន្ទាប់ពីថ្ងៃបង្កើតកិច្ចសន្យា នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៨។ ដោយសារតែ ក អាចអនុវត្តសិទ្ធិផ្តល់សច្ចានុមតិ ចាប់ពីថ្ងៃកំនើតអាយុ ១៨ឆ្នាំ នោះសិទ្ធិលុបចោលរបស់ ក នឹងត្រូវរលត់រយៈពេល ៣ឆ្នាំបន្ទាប់ពីថ្ងៃកំណើតអាយុ១៨ឆ្នាំ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៩។

# សិក្ខាសាលា

លើកទី ១ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ

លើកទី ២ រូបវន្តបុគ្គល

លើកទី ៣ លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

# ក្រុមការងារ

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សិក្ខាសាលាលើកទី ១
## ស្តីពី

## សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ

ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥

# សិក្ខាសាលាស្តីពី

# សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ

ក្រុមការងារ
សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

កាលបរិច្ឆេទ៖ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥

1

# មាតិកា

- សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ
  - ✓ សិទ្ធិទាមទារឲ្យប្រគល់វិញ
  - ✓ សទ្ធិទាមទារឲ្យបញ្ឈប់
  - ✓ សិទ្ធិទាមទារឲ្យបង្ការការរារាំង
- សិទ្ធិទាមទារឲ្យការពារចំពោះការកាន់កាប់
  - ✓ សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់
  - ✓ សិទ្ធិទាមទារបញ្ឈប់ការរារាំងការកាន់កាប់
  - ✓ សិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងនូវការកាន់កាប់

2

# អត្ថន័យនៃកម្មសិទ្ធិ

- កម្មសិទ្ធិ "សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត។"

(CC, Art. 138)

3

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (1)

ក្រ/ណី. ម. 155៖

"កម្មសិទ្ធិករអាចទាមទារឲ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកកាន់កាប់នោះមានមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ ចំពោះកម្មសិទ្ធិករ។"

4

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (2)

Case: លោក A បានឲ្យ B ចាំផ្ទះរបស់ខ្លួនក្នុងរយៈពេល2ឆ្នាំ។ ចប់រយៈពេល2ឆ្នាំ B ប្រកែកមិនព្រមចាកចេញ។ តើ A ត្រូវធ្វើដូចម្ដេច?




5

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (3)

Case: តើ A អាចប្រើកម្លាំងដេញ B ចេញពីផ្ទះបានដែរឬទេ?




6

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (4)

Case: តើ A អាចធ្វើរបងព័ទ្ធជុំវិញផ្ទះ នៅពេល B មិននៅផ្ទះដែ ឬទេ?




តើ B មាន សិទ្ធិអ្វីក្នុងការតតាំង?

7

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (5)

Case: A ត្រូវប្តឹងទៅតុលាការដើម្បីចេញសាលក្រម សម្រេចពីសិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ។




8

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (6)

Case: A អាចយកសាលក្រមទៅបង្ហាញ B ដើម្បីឲ្យអនុវត្ត។




9

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (7)

Case: តើ A អាចប្រើកម្លាំងបណ្តេញឲ្យ B ចេញពីផ្ទះបានដែរ ឬទេ?




10

## សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (8)

Case: A ត្រូវប្ដឹងទៅតុលាការដើម្បីឲ្យអនុវត្តសាលក្រម។




11

## សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (1)

ក្រ/ណី. ម. 159(1)៖

"ក្នុងករណីដែលការអនុវត្តកម្មសិទ្ធិរបស់ខ្លួនត្រូវបានរារាំង កម្មសិទ្ធិករអាចទាមទារឲ្យបញ្ឈប់ការរារាំង ចំពោះអ្នករារាំងនោះបាន។"

12

## សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (2)

Case1: A បានជួសជុលផ្ទះរបស់ខ្លួន ដោយបានដាក់សម្ភារៈសំណង់ខ្លះ នៅលើដីរបស់លោក B។ B ចង់ឲ្យគេយកសម្ភារៈនោះចេញពីដី។ តើ B មានសិទ្ធិអ្វី?




13

## សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (3)

តើលោក B អាចប្រើកម្លាំងខ្លួនឯងដើម្បីយកសម្ភារៈនោះចេញពីដីរបស់ខ្លួន ដែរឬទេ?




14

## សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (4)

A បានជួសជុលផ្ទះរបស់ខ្លួន ដោយបានដាក់សម្ភារៈសំណង់ខ្លះ នៅលើដីរបស់លោក B។ B ចង់ឲ្យគេយកសម្ភារៈនោះចេញពីដី។ តើ B មានសិទ្ធិអ្វី?




15

## សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (5)

Case 2: B បានយកគ្រឿងសំណង់ដាក់លើដីរបស់ A ដើម្បីសាងសង់លើដីរបស់ខ្លួន។ A ចង់ឲ្យ B យកគ្រឿងសំណង់ចេញពីដី។ តើ A មានសិទ្ធិអ្វី?




16

## សិទ្ធិទាមទារឲ្យបង្ការការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (1)

ក្រ/ណី. ម. 159(2)៖

"ក្នុងករណីដែលមានការបារម្ភជាក់ស្តែងថា ការអនុវត្តកម្មសិទ្ធិរបស់ខ្លួននឹងទទួលការរារាំង នោះកម្មសិទ្ធិករអាចទាមទារឲ្យបង្ការការរារាំងនោះបាន ចំពោះអ្នកដែលអាចនឹងរារាំងនោះ។"

17

## សិទ្ធិទាមទារឲ្យបបង្ការការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (2)

Case: ដើមឈើរបស់ B ទោរទន់មករកដី A។ A បានបារម្ភអំពីការដួល រលំនៃដើមឈើនេះលើដីរបស់ខ្លួន។ តើ A មានសិទ្ធិអ្វី?




18

## សិទ្ធិទាមទារឲ្យបបង្ការការរារាំងដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (3)

Case 1: ដើមឈើរបស់ B ទោរទន់មករកដី A។ A បានបារម្ភអំពីការដួល រលំនៃដើមឈើនេះលើដីរបស់ខ្លួន។ A អាចធ្វើដូចតទៅ៖




19

## ការហាមឃាត់ការសង្គ្រោះដោយប្រើកម្លាំងខ្លួនឯង

ក្រមរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យកម្មសិទ្ធិករអនុវត្តសិទ្ធិដោយប្រើកម្លាំងខ្លួនឯងបានទេ ពោលគឺអនុវត្តសិទ្ធិត្រឹមតែទាមទារ ចំពោះអ្នកបំពានតែប៉ុណ្ណោះ។ នេះគឺជាគោលការណ៍ហាមឃាត់ការសង្គ្រោះដោយប្រើកម្លាំងខ្លួនឯង។




20

## អ្នកកាន់កាប់ និងផល

ក្រ/ណី. ម. 156៖

1. អ្នកកាន់កាប់ដោយសុចរិត អាចទទួលផលដែលកើតពីវត្ថុកាន់កាប់នោះ។
2. នៅពេលអ្នកកាន់កាប់ដោយសុចរិតបានចាញ់ក្តី ក្នុងបណ្តឹងអំពីមូលហេតុគតិយុត្ត នៃការកាន់កាប់ អ្នកកាន់កាប់នោះ ត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតតាំងពីពេលបានដាក់ពាក្យបណ្តឹងនោះ។
3. ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់វត្ថុកាន់កាប់ឲ្យកម្មសិទ្ធិករវិញ អ្នកកាន់កាប់ទុច្ចរិតនៅពេលដែលផលបានកើតឡើង មានករណីយកិច្ចសងផលដែលខ្លួនបានទទួលនោះវិញ ហើយមានករណីយកិច្ចសងសំណងនូវតម្លៃនៃផលដែលត្រូវ បានខូចខាត ឬធ្វេសប្រហែសក្នុងការទទួលដោយកំហុស។

21

## សិទ្ធិទាមទារឲ្យការពារការកាន់កាប់ (1)

អ្នកកាន់កាប់អាច៖

1. ទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ (CC, Art. 237)
2. ទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ (CC, Art. 238)
3. ទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់ (CC, Art. 240)

22

## សិទ្ធិទាមទារឲ្យការពារការកាន់កាប់ (2)

សិទ្ធិដែលនាំឲ្យមានការកាន់កាប់ត្រឹមត្រូវតាមច្បាប់ រួមមាន៖

- កម្មសិទ្ធិ
- សិទ្ធិជួលអចិន្ត្រៃយ៍
- ផលុបភោគ
- សិទ្ធិលើការបញ្ចាំ
- សិទ្ធិជួល
- សេរភាព . . .

→ សិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្ត

23

## សិទ្ធិទាមទារឲ្យប្រគល់ការកាន់កាប់មកវិញ (1)

ក្រ/ណី. ម. 237៖

1. ប្រសិនបើអ្នកកាន់កាប់ត្រូវបានដកហូតនូវវត្ថុកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឲ្យប្រគល់វត្ថុនោះមកវិញបាន។
2. ការទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ មិនអាចធ្វើចំពោះអ្នកដែលបានទទួលវត្ថុពីអ្នកដកហូតការកាន់កាប់ ចំពោះអ្នកដែលបានទទួលការបង្កើតសិទ្ធិលើការបញ្ចាំ និងចំពោះប្រតិសិទ្ធិដោយឡែកផ្សេងទៀតបានឡើយ។ ប៉ុន្តែ ក្នុងករណីដែលប្រតិសិទ្ធិនោះបានដឹង ឬអាចដឹងនូវការដកហូតការកាន់កាប់នោះ អ្នកដែលបានកាន់កាប់អាចទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ ចំពោះប្រតិសិទ្ធិនោះបាន។
3. បណ្ដឹងទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ ត្រូវធ្វើឡើងក្នុងអំឡុងពេល១ (មួយ) ឆ្នាំ គិតចាប់ពីការដកហូតការកាន់កាប់នោះ។

24

## សិទ្ធិទាមទារឲ្យប្រគល់ការកាន់កាប់មកវិញ (2)

Case 1: A ជួលផ្ទះឲ្យ B រយៈពេល៥ឆ្នាំ។ ជួលបាន៣ឆ្នាំ B ខកខាន មិនបានបង់ថ្លៃឈ្នួល បន្ទាប់មក នៅពេល B មិននៅផ្ទះ A បានធ្វើរបង ដើម្បីកុំឲ្យ B អាចចូលផ្ទះបាន។ តើ B អាចអនុវត្តសិទ្ធិអ្វី?




25

## សិទ្ធិទាមទារឲ្យប្រគល់ការកាន់កាប់មកវិញ (3)

Case 1: B មានសិទ្ធិទាមទារឲ្យ A ប្រគល់ការកាន់កាប់តាមរយៈតុលាការ។




26

# សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ (1)

ក្រ/ណី. ម. 238៖

1. ប្រសិនបើអ្នកកាន់កាប់ត្រូវបានរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់បាន។
2. បណ្តឹងទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ ត្រូវធ្វើឡើងនៅពេលដែលមានការរារាំង ឬក្នុងអំឡុងពេល១ (មួយ) ឆ្នាំ ក្រោយពីការរារាំងនោះបានចប់។ ប៉ុន្តែ ក្នុងករណីដែលវត្ថុកាន់កាប់នោះ បានទទួលនូវការខូចខាត ដោយសារស្ថាបនកម្ម បណ្តឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្តើម ឬបើស្ថាបនកម្មនោះបានចប់។

27

# សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ (2)

Case 1: A ជួលផ្ទះឲ្យ B រយៈពេល៥ឆ្នាំ។ ជួលបាន៣ឆ្នាំ B ខកខានមិនបានបង់ថ្លៃឈ្នួល។ A បានប្រើកម្លាំងធ្វើរបងព័ទ្ធជុំវិញរារាំងការកាន់កាប់របស់ B។ តើ B អាចអនុវត្តសិទ្ធិអ្វី?




28

## សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ (3)

Case 1: B ប្តឹងទៅតុលាការ ដើម្បីឲ្យ A បញ្ឈប់ការប្រើកម្លាំងរារាំង។




29

## សិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់ (1)

ក្រ/ណី. ម. 240៖

1. ប្រសិនបើអ្នកកាន់កាប់ត្រូវបានរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះ អាចទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់បាន។
2. បណ្តឹងទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ ត្រូវធ្វើឡើងនៅពេលដែលមានការរារាំង ឬក្នុងអំឡុងពេល១ (មួយ) ឆ្នាំ ក្រោយពីការរារាំងនោះបានចប់។ ប៉ុន្តែ ក្នុងករណីដែលវត្ថុកាន់កាប់នោះ បានទទួលនូវការខូចខាតដោយសារស្ថាបនកម្ម បណ្តឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្តើម ឬបើស្ថាបនកម្មនោះបានចប់។

30

## សិទ្ធិទាមទារឲ្យបង្គារជាមុននូវការរារាំងការកាន់កាប់ (2)

Case 1: A ជួលផ្ទះឲ្យ B រយៈពេល៥ឆ្នាំ។ នៅពេលចប់៥ឆ្នាំហើយ B មិនព្រមចេញពីផ្ទះ។ A បានមកប្រាប់ B ថា ខ្លួននឹងរុះផ្ទះចាស់ដើម្បីសង់ថ្មី។ តើ B អាចអនុវត្តសិទ្ធិអ្វី?




31

## សិទ្ធិទាមទារឲ្យបង្គារជាមុននូវការរារាំងការកាន់កាប់ (3)

Case 1: A ជួលផ្ទះឲ្យ B រយៈពេល៥ឆ្នាំ។ នៅពេលចប់៥ឆ្នាំហើយ B មិនព្រមចេញពីផ្ទះ។ A បានមកប្រាប់ B ថា ខ្លួននឹងរុះផ្ទះចាស់ដើម្បីសង់ថ្មី។ តើ B អាចអនុវត្តសិទ្ធិអ្វី?




32

# សូមអរគុណ!!!
# Q & A

## ឯកសារពិគ្រោះ

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៩។

33

# សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ
## (សិក្សាអំពីទំនាក់ទំនងរវាងសិទ្ធិកម្មសិទ្ធិលើអចលវត្ថុ និងការកាន់កាប់)

### ជំពូកទី១. តើអ្វីទៅជាសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ?

សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ គឺជាសិទ្ធិដែលផ្តល់ឲ្យកម្មសិទ្ធិករនៃទ្រព្យអាចលើកសំអាងក្នុងនាមជាម្ចាស់សិទ្ធិ ដើម្បីទាមទារឲ្យអ្នកកាន់កាប់ទ្រព្យរបស់ខ្លួនប្រគល់ទ្រព្យនោះត្រឡប់មកវិញបាន។

ជាទូទៅក្នុងនាមជាកម្មសិទ្ធិករ បុគ្គលអាចទទួលបាននូវការធានា និង ការការពារស្របច្បាប់ដោយប្រែប្រួលទៅតាមទំហំនៃសិទ្ធិកម្មសិទ្ធិ មានន័យថា កម្មសិទ្ធិករត្រូវទទួលបាននូវការធានាចំពោះការអនុវត្តសិទ្ធិផ្ទាល់លើទ្រព្យដែលជាកម្មវត្ថុនៃសិទ្ធិកម្មសិទ្ធិរួមមានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និង សិទ្ធិចាត់ចែង។ ម្យ៉ាងទៀត យោងតាមនិយមន័យនៃមាត្រា១៣០នៃក្រមរដ្ឋប្បវេណី សិទ្ធិកម្មសិទ្ធិត្រូវបានចាត់ទុកថាជាសិទ្ធិប្រត្យក្ស គឺជាសិទ្ធិគ្រប់គ្រង និងមានលក្ខណៈដាច់ខាតមិនអាចបំពានបាន។

**ករណីសិក្សាទី១**

បំពង់សម្រាប់បង្ហូរទឹកកាកសំណល់សម្រាប់សណ្ឋាគារ ABC ដែលគ្រប់គ្រងដោយក្រុមហ៊ុន A ត្រូវបានដំឡើងដោយឆ្លងកាត់ដីរបស់ B ដោយគ្មានការអនុញ្ញាត។ ដោយហេតុនេះទើប B ប្តឹងទាមទារឲ្យ A រុះរើយកបំពង់នោះចេញ។ តើការទាមទាររបស់ B ត្រូវទទួលស្គាល់ដែរ ឬទេ? មូលហេតុអ្វី?

កម្មសិទ្ធិករស្របច្បាប់អាចធ្វើការទាមទារដូចខាងក្រោម៖

- ប្រភេទនៃសិទ្ធិទាមទារដោយផ្អែកលើកម្មសិទ្ធិ (ផ្នែកទី១)
- ការហាមឃាត់ការសង្គ្រោះដោយប្រើប្រាស់នូវកម្លាំងខ្លួនឯង (ផ្នែកទី២)
- សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ- ការទទួលបន្ទុកសោហ៊ុយ (ផ្នែកទី៣)
- ការសម្របសម្រួលនូវផលប្រយោជន៍ទាក់ទងនឹងសិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ (ផ្នែកទី៤)

### ផ្នែកទី១. ប្រភេទនៃសិទ្ធិទាមទារដោយផ្អែកលើកម្មសិទ្ធិ

#### កថាភាគទី១.សិទ្ធិទាមទារឲ្យប្រគល់វត្ថុវិញដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ

**មាត្រា១៥៥នៃក្រមរដ្ឋប្បវេណី** ៖ សិទ្ធិទាមទារឲ្យប្រគល់មកវិញដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ កម្មសិទ្ធិករអាចទាមទារឲ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលអ្នកកាន់កាប់នោះមានមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ចំពោះម្ចាស់កម្មសិទ្ធិករ។

យោងតាមគោលគំនិតខាងលើបុគ្គលដែលត្រូវបានចាត់ទុកថាជាកម្មសិទ្ធិករ គឺអាចទាមទារឲ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនត្រឡប់មកវិញបាន។ ប៉ុន្តែសិទ្ធិទទួលបាននូវការការពារ និងការធានាដែលមានលក្ខណៈដាច់ខាតនោះគឺអាចប្រែប្រួលទៅតាមទំនាក់ទំនងគតិយុត្តិ ដោយផ្អែកទៅលើឆន្ទៈសេរីរបស់ម្ចាស់សិទ្ធិ មានន័យថាម្ចាស់សិទ្ធិអាចមានការព្រមព្រៀងបង្កើត កែប្រែសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្រោមរូបភាពជាភតិសន្យា កិច្ចសន្យាបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ហើយប៉ុន្តែក ការ

បញ្ញាំ...។ ដូចនេះដោយសារមូលហេតុនៃទំនាក់ទំនងគតិយុត្តិ ម្ចាស់សិទ្ធិកាន់កាប់អាចធ្វើការរារាំង ចំពោះកម្មសិទ្ធិករក្នុងការអនុវត្តសិទ្ធិទាមទារឲ្យប្រគល់វត្ថុវិញដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ។

## កថាភាគទី២. សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ

**មាត្រា១៥៩** កថាខណ្ឌ១៖ ក្នុងករណីដែលការអនុវត្តកម្មសិទ្ធិរបស់ខ្លួនត្រូវបានរារាំង កម្មសិទ្ធិករអាចទាមទារឲ្យបញ្ឈប់ការរារាំង ចំពោះអ្នករារាំងនោះបាន។

យោងតាមគោលគំនិតនៃមាត្រា១៥៩កថាខណ្ឌ១នៃក្រមរដ្ឋប្បវេណី ក្នុងករណីការអនុវត្តសិទ្ធិកម្មសិទ្ធិត្រូវបានរារាំង ក្រៅពីមូលហេតុនៃការដកហូតការកាន់កាប់ដោយផ្អែកតាមលក្ខណៈជាសិទ្ធិគ្រប់គ្រងនៃសិទ្ធិប្រត្យក្ស (សំដៅដល់មូលហេតុគតិយុត្តផ្សេងទៀតដែលមាននៅលើដី) គឺកម្មសិទ្ធិករនៃដី អាចអនុវត្តសិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងដែលកើតមាន។

ប៉ុន្តែបញ្ហាចោទនៅទីនេះ ថាតើម្ចាស់សិទ្ធិអាចអនុវត្តសិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងបាននូវពេលណា? និងនៅក្នុងករណីណាខ្លះ? សិទ្ធិទាមទារឲ្យបញ្ឈប់ការរាំងដោយផ្អែកទៅលើសិទ្ធិកម្មសិទ្ធិ គឺអាចអនុវត្តបាននូវក្នុងស្ថានភាពដែលម្ចាស់សិទ្ធិទទួលរងនូវការបំពានជាក់ស្តែងទៅលើសិទ្ធិកម្មសិទ្ធិ គឺករណីនោះម្ចាស់សិទ្ធិអាចទាមទារឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើសិទ្ធិកម្មសិទ្ធិបាន (គោលគំនិតនៃមាត្រា១៥៩(១) អនុវត្តនៅពេលការបំពានបានកើតមាន)។

សូមធ្វើការសិក្សាវិភាគដោយផ្អែកលើករណីសិក្សាដូចខាងក្រោម តើអ្នកយល់យ៉ាងណាចំពោះគោលគំនិតនៃមាត្រា១៥៩(១) នៃក្រមរដ្ឋប្បវេណី?

**ករណីសិក្សាទី២**

លោក **ក** និងលោក **ខ** មានដីនៅជាប់គ្នា។ លោក **ក** មានបំណងសាងសង់ផ្ទះខ្ពស់ដែលមានកំពស់២០ជាន់។ នៅពេលកំពុងរៀបចំដំណើការបើកការដ្ឋាន លោក **ក** បានដឹកសម្ភារៈសំណង់ និងសរសគ្រឹះមកទុកនៅលើដីរបស់លោក **ខ** ដោយពុំបានជូនដំណឹងជាមុន និង ធ្វើការស្នើរសុំពីលោក **ខ** ទេ ពីព្រោះគាត់យល់ឃើញថាដីលោក **ខ** ជាដីទំនេរទុកចោលមិនប្រើប្រាស់។ ករណីខាងលើនេះចាត់ទុកជាការបំពានសិទ្ធិ ឬយ៉ាងណា បើដីដែលរបស់លោក **ខ** ជាដីទំនេរទុកចោលមិនប្រើប្រាស់?

**ករណីសិក្សាទី៣**

លោក **ក** និង លោក **ខ** មានលំនៅដ្ឋាននៅជាប់គ្នាស្ថិតនៅក្នុងដីឡូត៍មួយកន្លែងនៃទីក្រុងភ្នំពេញ។ លោក **ក** ជួសជុលផ្ទះ ហើយបានដឹកសម្ភារៈសំណង់យកមកទុកពេញមុខផ្ទះរបស់ខ្លួន និងមុខផ្ទះរបស់ លោក **ខ** ដោយមិនបានជូនដំណឹងអ្វីទាំងអស់។ ការណ៍ដែលលោក **ក** ធ្វើនេះ គឺធ្វើឲ្យលោក **ខ** មិនអាចចត និង ចេញចូលឡានបាន ហើយថែមទាំងមានការពិបាកក្នុងការធ្វើដំណើរចេញចូលផ្ទះរបស់ខ្លួន។ ករណីនេះតើ លោក **ខ** អាចមានសិទ្ធិអ្វីខ្លះដើម្បីទាមទារឲ្យទទួលបាននូវការការពារពីទង្វើរបស់លោក **ក**។

## កថាភាគទី៣. សិទ្ធិទាមទារឲ្យបង្ការការរារាំងដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ

**មាត្រា១៥៩ កថាខណ្ឌ២**
ក្នុងករណីដែលមានការបារម្ភជាក់ស្តែងថា ការអនុវត្តកម្មសិទ្ធិរបស់ខ្លួននឹងទទួលការរារាំង នោះកម្មសិទ្ធិករអាចទាមទារឲ្យបង្ការការរារាំងនោះបាន ចំពោះអ្នកដែលអាចនឹងរារាំងនោះ។

យោងតាមគោលគំនិតនៃមាត្រា១៥៩កថាខណ្ឌ២នៃក្រមរដ្ឋប្បវេណី ក្នុងករណីការអនុវត្តសិទ្ធិកម្មសិទ្ធិ ដែលកម្មសិទ្ធិករខ្លាច ឬបារម្ភថាអាចមានការរារាំងជាក់ស្តែងណាមួយកើតឡើង គឺកម្មសិទ្ធិករអាចទាមទារឲ្យបង្ការនូវការរារាំងនោះបាន។

ជារួម ម្ចាស់សិទ្ធិអាចអនុវត្តសិទ្ធិទាមទារឲ្យបង្ការការរារាំងដោយផ្អែកលើសិទ្ធិកម្មសិទ្ធិបាន នៅក្នុងករណីដែលការបំពានមិនទាន់កើតមាន ប៉ុន្តែម្ចាស់សិទ្ធិមានការបារម្ភថា ការបំពាននឹងអាចកើតមាននាពេលអនាគត ពោលគឺស្ថានភាពដែលនឹងបំពានអាចសន្មតបានថាពិតជាកើតមាន (គោលគំនិតនៃមាត្រា១៥៩(២) អនុវត្តនៅពេលការបំពានមិនទាន់កើតមាន ប៉ុន្តែម្ចាស់សិទ្ធិមានកាបារម្ភថាសិទ្ធិកម្មសិទ្ធិនឹងទទួលរងនូវការបំពាននាពេលអនាគត)។

តើស្ថានភាពបែបណាដែលអាចចាត់ទុកថាជាការបំពានលើសិទ្ធិកម្មសិទ្ធិ ហើយម្ចាស់សិទ្ធិមានការបារម្ភថាសិទ្ធិកម្មសិទ្ធិរបស់ខ្លួនអាចទទួលរងនូវការបំពាននាពេលអនាគត? ដូចនេះយើងអាចធ្វើការសិក្សាវិភាគដោយប្រែប្រួលទៅតាមករណីសិក្សានីមួយៗ។

**ករណីសិក្សាទី៤**

នៅបញ្ចៀងមុខផ្ទះរបស់លោក **ក** មានដើមក្ងោកដ៏ធំមួយដែលមានអាយុកាលរាប់សិបឆ្នាំមកហើយ។ នៅថ្ងៃមួយមានភ្លៀង និងខ្យល់កន្ត្រាក់ខ្លាំងធ្វើឲ្យដើមក្ងោកនោះទ្រេតមករកផ្ទះរបស់ លោក **ក**។ លោក **ក** មានការបារម្ភជាខ្លាំង ហើយបានមកប្រឹក្សាជាមួយអ្នក ថាតើក្នុងនាមគាត់ជាជាកម្មសិទ្ធិករនៃផ្ទះខាងលើនេះ គាត់អាចអនុវត្តសិទ្ធិបែបណាដើម្បីការពារផលប្រយោជន៍របស់ខ្លួន?

**ករណីសិក្សាទី៥**

លោក **ក** និងលោក **ខ**មានលំនៅដ្ឋានដែលមានព្រំដីជាប់គ្នាតាំងពីឆ្នាំ១៩៨៩មក។ នៅឆ្នាំ២០១៥ លោក **ក** បានលក់លំនៅដ្ឋាននោះទៅឲ្យលោក **គ** ដែលជាអ្នកវិនិយោគ ក្នុងការសាងសង់ផ្ទះខ្ពស់ដែលមានកំពស់២៥ជាន់។ ក្រោយមកលោក **គ** បានរៀបចំដំណើការបើកការដ្ឋានដើម្បីកម្ទេចផ្ទះដោយពុំបានរៀបចំការពារគ្រប់គ្រាន់។ លោក **ខ** មានការបារម្ភជាខ្លាំងចំពោះការប្រេះស្រាំលំនៅដ្ឋាននាពេលខាងមុខ។ម្យ៉ាងទៀតដោយភ័យផង ខ្លាចផងព្រោះលោក **គ**ជាអ្នកវិនិយោគដែលមានដើមទុនច្រើន លោក **ក**បានមកប្រឹក្សាជាមួយអ្នក ក្នុងករណីខាងលើនេះតើគាត់អាចធ្វើយ៉ាងណាបានដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

ក្នុងស្ថានភាពខាងលើនេះ តើអ្នកយល់យ៉ាងណាចំពោះទំនាក់ទំនងនៃការអនុវត្តសិទ្ធិកម្មសិទ្ធិក្នុងនាមបុគ្គលមានសិទ្ធិដូចគ្នា?

### កថាភាគទី៤.ស្តង់ដារនៃការបែងចែកអំពីសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សទាំង៣ប្រភេទ

សិទ្ធិទាមទារឲ្យប្រគល់វិញ (មាត្រា១៥៥), សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំង (មាត្រា១៥៩ កថាខណ្ឌទី១), សិទ្ធិទាមទារឲ្យបង្ការការរារាំង (មាត្រា១៥៩ កថាខណ្ឌទី២) គឺត្រូវបានបែងចែងតាមកម្រិត និងបែបយ៉ាងនៃការបំពានចំពោះកម្មសិទ្ធិ។ ទោះបីជាកម្មសិទ្ធិមិនទាន់ត្រូវបានបំពានក៏ដោយ ប៉ុន្តែក្នុងករណីបើខិតទៅជិតនៃគ្រោះថ្នាក់នៃការបំពាន កម្មសិទ្ធិករអាចអនុវត្តសិទ្ធិទាមទារឲ្យបង្ការការរារាំងបាន។ ក្នុងករណីកម្មសិទ្ធិត្រូវបានបំពានដោយវិធីក្រៅពីការបំពានការកាន់កាប់ កម្មសិទ្ធិករអាចអនុវត្តសិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងបាន។ ក្នុងករណីការកាន់កាប់ត្រូវបានដកហូត កម្មសិទ្ធិករអាចអនុវត្តសិទ្ធិទាមទារឲ្យប្រគល់វិញបាន។

**ករណីសិក្សាទី៦**

B មានបំណងចង់សាងសង់អាគារតាមទំនើងចិត្ត នៅលើដីដែល A កំពុងមានកម្មសិទ្ធិ។ B វាស់ទំហំដី ហើយរៀបចំត្រៀមសាងសង់អាគារ ប៉ុន្តែស្ថាបនកម្មមិនទាន់បានចាប់ផ្តើមទេ។ ក្នុងករណីនេះ តើ A អាចអនុវត្តសិទ្ធិបែបណាចំពោះ B?

**ករណីសិក្សាទី៧**

B មានបំណងចង់សាងសង់អាគារតាមទំនើងចិត្ត នៅលើដីដែល A កំពុងមានកម្មសិទ្ធិ។ B ដឹកជញ្ជូនគ្រឿងសំណង់ដូចជាឥដ្ឋជាដើមដាក់នៅដីនេះ។ ក្នុងករណីនេះ តើ A អាចអនុវត្តសិទ្ធិបែបណាចំពោះ B?

**ករណីសិក្សាទី៨**

B បានសាសង់អាគារនិងរស់នៅតាមទំនើងចិត្តនៅលើដីដែល A កំពុងមានកម្មសិទ្ធិ។ ក្នុងករណីនេះ តើ A អនុវត្តសិទ្ធិបែបណាចំពោះ B?

### ផ្នែកទី២.ហាមឃាត់ការសង្គ្រោះដោយប្រើកម្លាំងខ្លួនឯង

មាត្រា១៥៥នៃក្រមរដ្ឋប្បវេណី មិនបានសរសេរថា "កម្មសិទ្ធិករអាចយកវត្ថុនោះវិញបាន" នោះទេ គឺសរសេរថា "អាចទាមទារឲ្យប្រគល់វិញបាន" ។ ម្យ៉ាងទៀត មាត្រា១៥៩ មិនបានសរសេរថា "អាចបញ្ឈប់ការរារាំង" "អាចបង្ការការរារាំង" នោះទេ គឺសរសេថា "អាចទាមទារឲ្យបញ្ឈប់ការរារាំង" "អាចទាមទារឲ្យបង្ការការរារាំង" ។ ពោលគឺ ទោះបីជាកម្មសិទ្ធិត្រូវបានបំពានក៏ដោយ កម្មសិទ្ធិករមិនអាចអនុវត្តសិទ្ធិដោយបង្ខំដោយកម្លាំងខ្លួនឯងនោះទេ គឺគ្រាន់តែអាច "ទាមទារ" ចំពោះអ្នកបំពានតែប៉ុណ្ណោះ។ គោលការណ៍នេះហៅថា "ហាមឃាត់ការសង្គ្រោះដោយកម្លាំងខ្លួនឯង" ។

សូមពិចារណាលើករណីសិក្សាខាងក្រោម និងគោលគំនិតនៃមាត្រា១៥៥នៃក្រមរដ្ឋប្បវេណី ថាតើអ្វីទៅជាប្រព័ន្ធនៃការហាមឃាត់ចំពោះការប្រើប្រាស់នូវកម្លាំងខ្លួនឯង?

**ករណីសិក្សាទី៩**

លោក **ក** និងលោក **ខ** មានលំនៅដ្ឋាននៅជិតគ្នាស្ថិតនៅក្នុងបុរីមួយកន្លែងនៃទីក្រុងភ្នំពេញ។ លោក **ក** បានយកជើងផ្កាតូចមួយ មកទុកនៅពីមុខផ្ទះ លោក **ខ** ដោយមិនដឹងមូលហេតុ។ តើលោក **ខ** អាចអនុវត្តសិទ្ធិដោយយកជើងផ្កានោះចេញពីមុខផ្ទះរបស់ខ្លួនដោយខ្លួនឯងបាន ឬទេ? ឬដោយត តាំងនឹងទង្វើរបស់លោក **ក**, លោក **ខ** គិតថាគ្រាន់ជាជើងផ្កាតូចមួយ និងជាវត្ថុអាចជំនួសបានហើយ មានតម្លៃទាបផង និងចាំសងសំណងនៅពេលក្រោយ ដោយមានអារម្មណ៍ម៉ូម៉ៅផង ខឹងផងលោក **ខ** បានបើកឡានកំទេចជើងផ្កានោះចោល។ តើអ្នកយល់យ៉ាងណាចំពោះទង្វើខាងលើនេះ? តើ លោក **ខ** គួរអនុវត្តសិទ្ធិការពារផលប្រយោជន៍របស់ខ្លួនយ៉ាងដូចម្តេចឲ្យស្របច្បាប់ជាពិសេសគឺឲ្យស្របទៅនឹងគោលគំនិតនៃច្បាប់សារធាតុ?

ចំពោះការទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិរវាងកម្មសិទ្ធិករ និងម្ចាស់សិទ្ធិកាន់កាប់ តើកម្មសិទ្ធិករអនុវត្តសិទ្ធិទាមទារយ៉ាងដូចម្តេចចំពោះម្ចាស់សិទ្ធិកាន់កាប់ និងម្ចាស់សិទ្ធិកាន់កាប់អាចទទួលបាននូវការការពារបែបណាផ្អែកតាមគោលគំនិតនៃក្រមរដ្ឋប្បវេណី?

ជាបឋម កម្មសិទ្ធិករអាចទាមទារឲ្យបញ្ឈប់សកម្មភាពបំពានចំពោះអ្នកបំពាន ដោយផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ។ ប៉ុន្តែ ក៏អាចមានករណីអ្នកបំពានអនុវត្តដោយស្ម័គ្រចិត្ត។ ក្នុងករណីនេះ កម្មសិទ្ធិករចាំបាច់ធ្វើការទាមទារដោយដាក់ពាក្យបណ្តឹងទៅតុលាការ។ ប៉ុន្តែ ឧទាហរណ៍ទោះបីជាឈ្នះបណ្តឹងក៏ដោយ ក៏អាចមានករណីអ្នកបំពាននៅតែមិនអនុវត្តតាម។ ក្នុងករណីនេះ កម្មសិទ្ធិករ ចាំបាច់ត្រូវអនុវត្តដោយបង្ខំស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ហេតុដូច្នេះ ទោះបីជាកម្មសិទ្ធិករក៏ដោយ ក៏មិនអាចបំពេញសិទ្ធិដោយខ្លួនឯងបាននោះទេ គឺចាំបាច់ត្រូវខ្ចីកម្លាំងពីតុលាការ។ គោលការណ៍នេះហៅថា "ហាមឃាត់ការសង្គ្រោះដោយកម្លាំងខ្លួនឯង" ។

**ករណីសិក្សាទី១០**

A បានឲ្យ B ខ្ចីរយៈពេល ៥ ឆ្នាំនូវដីដែលខ្លួនកំពុងមានកម្មសិទ្ធិ។ ប៉ុន្តែ B បានឲ្យ C ជួលបន្តដោយមិនមានការយល់ព្រមពី A។ C បានចាប់ផ្តើមបើកហាងលក់ផ្លែឈើនៅលើអាគារនោះ។

A បានខឹងនៅពេលបានលឺថា C កំពុងប្រើប្រាស់អាគារដោយមិនមានការសម្រេចពីខ្លួន។ ហេតុនេះ A គិតថាចង់យកអាគារនោះពី C វិញ។

តើ A អាចបំផ្លាញសោទ្វារអាគារហើយចូលទៅខាងក្នុងយកផ្លែឈើនិងវត្ថុរបស់ C ចេញ ដោយគ្មានការអនុញ្ញាតពី C បានដែរឬទេ?

ប្រសិនបើមិនអាចធ្វើបាន តើ A អនុវត្តសិទ្ធិបានយ៉ាងដូចម្តេច?

## ផ្នែកទី៣. សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ- ភារៈទទួលបន្ទុកសោហ៊ុយ

ចំពោះសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ និងការទទួលបន្ទុកសោហ៊ុយ គឺយើងអាចធ្វើការសិក្សាវិភាគអំពីទំនាក់ទំនងរវាងកម្មសិទ្ធិករ និងអ្នកកាន់កាប់អចលនទ្រព្យ ដោយផ្អែកទៅលើទ្រឹស្តីនៃការទាមទារឲ្យធ្វើសកម្មភាព និងទ្រឹស្តីនៃការទាមទារឲ្យទទួល។

### កថាភាគទី១. ទ្រឹស្តីនៃការទាមទារឲ្យធ្វើសកម្មភាព

ចំពោះទ្រឹស្តីនៃការទាមទារឲ្យធ្វើសកម្មភាពមានន័យថាបុគ្គលដែលជាអ្នកធ្វើសកម្មភាពគឺជាអ្នកទទួលបន្ទុកសោហ៊ុយ។ យោងតាមយុត្តិសាស្ត្ររបស់ប្រទេសជប៉ុន សំដៅដល់បុគ្គលដែលទទួលខុសត្រូវ គឺជាអ្នកទាមទារឲ្យធ្វើសកម្មភាព ក្នុងនោះយើងអាចសិក្សាអំពីទង្វើដែលបង្ករជាកំហុស និងករណីគ្មានកំហុសគឺមិនអាចធ្វើការទាមទារបានទេ ឬ ដូចជានៅក្នុងស្ថានភាពដែលយើងសន្មតថាអ្នកដាក់ពាក្យប្តឹងមុនគឺជាអ្នកឈ្នះ។ ដូចនេះអ្នកទទួលបន្ទុកសោហ៊ុយ គឺជាភាគីដែលមិនបានដាក់ពាក្យប្តឹង។

### កថាភាគទី២. ទ្រឹស្តីនៃការទាមទារឲ្យទទួល

ទ្រឹស្តីនៃការទាមទារឲ្យទទួល មានន័យថា ប្រសិនបើកម្មសិទ្ធិករអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស កម្មសិទ្ធិករត្រូវតែទទួលបន្ទុកសោហ៊ុយ ហើយភាគីម្ខាងទៀតគ្រាន់តែទទួលនូវការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សពីកម្មសិទ្ធិករ។

**ករណីសិក្សាទី១១**

ចោរម្នាក់បានលួចរថយន្តរបស់B ហើយបានទុករថយន្តនោះចោលនៅក្នុងដីរបស់ A។ ក្នុងករណីដែល A ទាមទារ B ឲ្យបញ្ឈប់ការរារាំងដោយផ្អែកលើការអនុវត្តសិទ្ធិលើកម្មសិទ្ធិលើដីនោះ តើអ្នកណាត្រូវទទួលបន្ទុកសោហ៊ុយក្នុងការយករថយន្តនោះចេញ? នៅពេលដែល B ទាមទារ A ឲ្យប្រគល់រថយន្តវិញដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ តើអ្នកណាត្រូវទទួលបន្ទុកសោហ៊ុយក្នុងការប្រគល់រថយន្ត?

## ផ្នែកទី៤. ការសម្របសម្រួលនូវផលប្រយោជន៍ទាក់ទងនិងសិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើកម្មសិទ្ធិ

តើអ្នកកាន់កាប់អាចទទួលផលពីវត្ថុកាន់កាប់នោះដោយផ្អែកលើមូលហេតុអ្វី និងក្នុងលក្ខខណ្ឌណាខ្លះ? តើអ្នកកាន់កាប់អាចអះអាងយ៉ាងដូចម្តេចចំពោះកម្មសិទ្ធិករ? តើគោលគំនិតនៃមាត្រាខាងលើនេះធ្វើការការពារអ្នកកាន់កាប់ និងកម្មសិទ្ធិករយ៉ាងដូចម្តេច?

ករណីខាងលើនេះ គឺយើងអាចធ្វើការសិក្សាវិភាគអំពីទំនាក់ទំនងគតិយុត្តដែលកើតមានរវាងកម្មសិទ្ធិករ និង អ្នកកាន់កាប់ស្តីពីការប្រើប្រាស់ និងអាស្រ័យផលពីវត្ថុកាន់កាប់ដែលស្តែងឡើងក្រោមរូបភាពជាការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា...ហើយករណីដែលកម្មសិទ្ធិករលើដីបានទាមទារ ឲ្យអ្នកកាន់កាប់តាមទំនាក់ទំនងទាំងអស់នោះប្រគល់វត្ថុកាន់កាប់ត្រឡប់មកវិញ។ ប៉ុន្តែបញ្ហាចោទនៅទីនេះ គឺការទទួលខុសត្រូវចំពោះវត្ថុដែលជាកម្មវត្ថុនៃការកាន់កាប់ ទោះបីជាក្រោមរូបភាពណាក៏ដោយដូចជាការជម្រះបញ្ជីសោហ៊ុយជាអាទិ៍ ដែលការចាំបាច់ក្នុងការកាន់កាប់វត្ថុនោះ គឺ

បានកំណត់ប្រែប្រួលទៅតាមប្រភេទនៃទំនាក់ទំនងគតិយុត្ត។ ផ្ទុយទៅវិញ ករណីមិនបានកំណត់អំពីលក្ខខណ្ឌចាំបាច់ទាំងអស់នោះទេ ថាតើភាគីណាជាអ្នកទទួលខុសត្រូវចំពោះការខូចខាតវត្ថុកាន់កាប់ ឬការបែងចែកផលយ៉ាងណាដែលកើតពីវត្ថុកាន់កាប់។ ហេតុដូចនេះករណីមិនមានការព្រមព្រៀងណាមួយដើម្បីកំណត់អំពីលក្ខខណ្ឌទាំងអស់នោះទេ គឺយើងអាចធ្វើការបកស្រាយដោយផ្អែកទៅតាមច្បាប់សារធាតុ ដើម្បីកំណត់អំពីលទ្ធភាពនៃការបែកចែកផល និងការទទួលខុសត្រូវលើការខូចខាតវត្ថុកាន់កាប់ យ៉ាងណាឲ្យមានតុល្យភាពអាចទទួលយកបានទាំងកម្មសិទ្ធិករ និងអ្នកកាន់កាប់។

## កថាភាគទី១. អត្ថន័យនៃសុចរិតនិងទុច្ចរិត

អ្នកកាន់កាប់សុចរិត ជាអ្នកកាន់កាប់ដែលមានអារម្មណ៍យល់ខុសថាខ្លួនកំពុងតែកាន់កាប់ដោយផ្អែកទៅលើសិទ្ធិអ្វីមួយ ប៉ុន្តែ តាមពិតទៅអ្នកកាន់កាប់នោះជាបុគ្គលដែលគ្មានសិទ្ធិ។ អ្នកកាន់កាប់ទុច្ចរិត ជាអ្នកកាន់កាប់ដែលដឹងថាខ្លួនជាបុគ្គលដែលគ្មានសិទ្ធិ។

**ករណីសិក្សាទី១២**

A បានឲ្យ B ខ្ចីអាគារដែលខ្លួនកំពុងមានកម្មសិទ្ធិ។ B បានឲ្យ C ជួលបន្ត ទោះបីជាគ្មានយល់ព្រមពី A។ យោងតាមក្រមរដ្ឋប្បវេណី មាត្រា៦០៨កថាខណ្ឌទី១ C មិនអាចអះអាងអំពីសិទ្ធិជួលចំពោះ A បានទេ ហេតុនេះ C ជាបុគ្គលគ្មានសិទ្ធិ។ ប៉ុន្តែ C បានគិតថា A បានយល់ព្រមអំពីសិទ្ធិជួលនោះ។

ក្នុងករណីនេះ C ជាអ្នកកាន់កាប់សុចរិត ឬ អ្នកកាន់កាប់ទុច្ចរិត?

## កថាភាគទី២. វិធានការទាក់ទងនឹងផល (មាត្រា១៥៦)

**មាត្រា១៥៦នៃក្រមរដ្ឋប្បវេណី៖** អ្នកកាន់កាប់ និងផល

១. អ្នកកាន់កាប់ដោយសុចរិត អាចទទួលផលដែលកើតពីវត្ថុកាន់កាប់នោះ។

២.នៅពេលដែលអ្នកកាន់កាប់ដោយសុចរិតបានចាញ់ក្ដីក្នុងបណ្ដឹងអំពីមូលហេតុគតិយុត្តនៃការកាន់កាប់ ត្រូវបានចាត់ទុកជាអ្នកកាន់កាប់ដោយទុច្ចរិត គិតតាំងពីពេលបានដាក់ពាក្យបណ្ដឹង។

៣. ក្នុងករណីដែលអ្នកប្រគល់វត្ថុកាន់កាប់ឲ្យកម្មសិទ្ធិករវិញ អ្នកកាន់កាប់ទុច្ចរិតនៅពេលដែលផលបានកើតឡើង មានករណីយកិច្ចសងផលដែលបានទទួលនោះវិញ ហើយមានករណីយកិច្ចត្រូវសងសំណងតម្លៃនៃផលដែលត្រូវបានខូចខាត ឬធ្វេសប្រហែសក្នុងការទទួលដោយកំហុស។

យោងតាមគោលគំនិតនៃមាត្រា១៥៦កថាខណ្ឌ១នៃក្រមរដ្ឋប្បវេណី គឺធ្វើការការពារចំពោះអ្នកកាន់កាប់សុចរិត និងអ្នកកាន់កាប់អាចទទួលផលដែលកើតពីវត្ថុកាន់កាប់បាន។

ម្យ៉ាងទៀត ចំពោះអ្នកកាន់កាប់ដោយសុចរិត ករណីចាញ់ក្ដីត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ទុច្ចរិតដោយគិតចាប់តាំងពីពេលបានដាក់ពាក្យបណ្ដឹង(មាត្រា១៥៦កថាខណ្ឌ២)។ លើសពីនេះទៅទៀតអ្នកកាន់កាប់ទុច្ចរិតនៅពេលប្រគល់វត្ថុកាន់កាប់ទៅឲ្យកម្មសិទ្ធិករវិញ គឺមានករណីយកិច្ច(មាត្រា១៥៦កថាខណ្ឌ៣)ត្រូវសងផលដែលទទួលបានពីវត្ថុកាន់កាប់វិញ និងត្រូវសងតម្លៃនៃផលដែលត្រូវបានខូចខាត ឬធ្វេសប្រហែសក្នុងការទទួលដោយកំហុស។

## កថាភាគទី៣.ការទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតនៃវត្ថុកាន់កាប់(មាត្រា ១៥៧)

**មាត្រា១៥៧នៃក្រមរដ្ឋប្បវេណី៖** ការទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតនៃវត្ថុកាន់កាប់
ក្នុងករណីដែលអ្នកកាន់កាប់មានកំហុសចំពោះការបាត់បង់ ឬការខូចខាតវត្ថុកាន់កាប់ ឬការមិនអាចប្រគល់វត្ថុនោះវិញបាន អ្នកកាន់កាប់ទុច្ចរិតនៅពេលដែលការបាត់បង់ ការខូចខាតដល់វត្ថុ ឬហេតុផ្សេងដែលមិនអាចប្រគល់វត្ថុនោះវិញបាននោះបានកើតឡើង មានករណីកិច្ចសងសំណងខូចខាតត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលប៉ុណ្ណោះ។ ប៉ុន្តែ អ្នកកាន់កាប់ដែលគ្មានឆន្ទៈយកជាកម្មសិទ្ធិ ទោះបីជាក្នុងករណីកាន់កាប់ដោយសុចរិតក៏ដោយ ក៏មានករណីកិច្ចសងនូវការខូចខាតទាំងអស់ដែរ។

ជាទូទៅចំពោះលក្ខខណ្ឌដែលទាមទារឲ្យមានការទទួលខុសត្រូវ គឺយើងត្រូវធ្វើការបកស្រាយទៅលើទ្រឹស្តីនៃកំហុស ដើម្បីកំណត់ថាបុគ្គលណាមានកាតព្វកិច្ចត្រូវរ៉ាប់រងរាល់ការខាតបង់ ឬការខូចខាតនៃវត្ថុកាន់កាប់ មានន័យថា អ្នកដែលបង្កឲ្យមានការខូចខាតដោយកំហុសផ្ទាល់ ឬមិនផ្ទាល់ គឺមានកាតព្វកិច្ចត្រូវទទួលខុសត្រូវ។ អនុវត្តដូចគ្នាចំពោះគោលគំនិតនៃមាត្រា១៥៧ គឺសិក្សាពីទំនាក់ទំនងគតិយុត្តិរវាងកម្មសិទ្ធិករ និងអ្នកកាន់កាប់ស្តីពីការប្រើប្រាស់ និងអាស្រ័យផលពីវត្ថុកាន់កាប់របស់អ្នកកាន់កាប់ ដោយត្រូវធ្វើការបែងចែករវាងអ្នកកាន់កាប់សុចរិត និងអ្នកកាន់កាប់ទុច្ចរិត។ អ្នកកាន់កាប់ទុច្ចរិតមានកាតព្វកិច្ចត្រូវទទួលខុសត្រូវសងសំណងខូចខាតទាំងអស់ និងអ្នកកាន់កាប់សុចរិតមានករណីយកិច្ចត្រូវសងសំណងខូចខាតត្រឹមកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលប៉ុណ្ណោះ ប៉ុន្តែក្នុងករណីអ្នកកាន់កាប់ ដែលគ្មានឆន្ទៈយកជាកម្មសិទ្ធិ ទោះបីជាក្នុងករណីកាន់កាប់ដោយសុចរិតក៏ដោយ ក៏មានករណីយកិច្ចសងការខូចខាតទាំងអស់ដែរ។

## កថាភាគទី៤.ទទាមការទាក់ទងសោហ៊ុយ(មាត្រា១៥៨)

**មាត្រា១៥៨នៃក្រមរដ្ឋប្បវេណី៖** សិទ្ធិរបស់អ្នកកាន់កាប់ក្នុងការទាមទារសងសោហ៊ុយ
១. ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់វត្ថុកាន់កាប់ទៅឲ្យកម្មសិទ្ធិករវិញ អ្នកកាន់កាប់អាចទាមទារឲ្យកម្មសិទ្ធិករសងនូវសោហ៊ុយចាំបាច់ដែលខ្លួនបានចំណាយក្នុងការគ្រប់គ្រង និងថែរក្សាវត្ថុនោះ។ ក្នុងករណីអ្នកកាន់កាប់នោះបានទទួលផលពីវត្ថុកាន់កាប់ អ្នកកាន់កាប់ត្រូវទទួលបន្ទុកនូវសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រង និងថែរក្សាវត្ថុជាធម្មតា។
២. ប្រសិនបើអ្នកកាន់កាប់បានចំណាយប្រាក់ដើម្បីកែលំអវត្ថុកាន់កាប់ ឬចំណាយដើម្បីបង្កើនតម្លៃផ្សេង ចំពោះវត្ថុនោះ កម្មសិទ្ធិករត្រូវសងទៅអ្នកកាន់កាប់វិញនូវសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬតម្លៃប្រាក់ដែលកើននោះតាមការជ្រើសរើសរបស់កម្មសិទ្ធិករ ក្នុងកម្រិតដែលកំណើនតម្លៃនៅតែមាន។ ប៉ុន្តែចំពោះអ្នកកាន់កាប់ទុច្ចរិត តុលាការអាចអនុញ្ញាតឲ្យកម្មសិទ្ធិករមានអំឡុងពេលសមរម្យសម្រាប់ការសងនេះ។
៣. ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់ដីធ្លីឲ្យកម្មសិទ្ធិករវិញ កម្មសិទ្ធិករត្រូវសងនូវសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬកំណើនតម្លៃដែលនៅតែមានចំពោះសំណងដែលអ្នកកាន់កាប់សុចរិតបានសង់

ដំណាំដែលអ្នកនោះបានដាំ តែមិនទាន់បានទទួលផល និងដើមឈើមិនទាន់បានកាប់។ ទោះបីជាមានកថាខណ្ឌទី១ និងកថាខណ្ឌទី២ខាងលើនេះក៏ដោយចំពោះអ្នកកាន់កាប់ទុច្ចរិតវិញ កម្មសិទ្ធិករមានសិទ្ធិជ្រើសរើសឲ្យអ្នកកាន់កាប់ យកសំណង់ដែលបានសង់ ដំណាំដែលបានដាំតែមិនទាន់ទទួលផល និងដើមឈើមិនទាន់កាប់នោះចេញពីដី ឬយកវត្ថុនោះជាកម្មសិទ្ធិរបស់ខ្លួន។ ប្រសិនបើកម្មសិទ្ធិករជ្រើសរើសឲ្យដកយកវត្ថុនោះចេញ អ្នកកាន់កាប់ត្រូវយកត្រូវយកសំណង់ ដំណាំ និងដើមឈើទាំងនោះចេញដោយមិនគិតថ្លៃ។ ប្រសិនបើកម្មសិទ្ធិករជ្រើសរើសយកសំណង់ ដំណាំ និងដើមឈើនោះជាកម្មសិទ្ធិរបស់ខ្លួនវិញ កម្មសិទ្ធិករត្រូវសងសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬតម្លៃប្រាក់ដែលបានកើនឡើង រួមទាំងតម្លៃនៃវត្ថុដែលទទួលយក ដោយមិនគិតពិចារណាពីអធិកលាភដីនោះទេ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យកម្មសិទ្ធិករមានអំឡុងពេលសមរម្យសម្រាប់ការសងនេះ។

ជារួមចំពោះការការពារផលប្រយោជន៍អ្នកកាន់កាប់ដោយសុច្ចរិត គឺបុគ្គលដែលជាអ្នកកាន់កាប់នោះអាចទាមទារសោហ៊ុយចំពោះការគ្រប់គ្រង និងថែរក្សាវត្ថុដូចជាៈ

- អ្នកកាន់កាប់អាចទាមទារឲ្យកម្មសិទ្ធិករសងសោហ៊ុយចាំបាច់ដែលខ្លួនចំណាយក្នុងការគ្រប់គ្រង ថែរក្សាវត្ថុ និងមិនអាចទាមទារបានក្នុងករណីដែលអ្នកកាន់កាប់បានផលពីវត្ថុកាន់កាប់។
- ករណីអ្នកកាន់កាប់បានចំណាយប្រាក់ដើម្បីកែលំអវត្ថុកាន់កាប់ ឬចំណាយដើម្បីបង្កើនតម្លៃផ្សេងចំពោះវត្ថុនោះ កម្មសិទ្ធិករត្រូវសងអ្នកកាន់កាប់វិញ ប៉ុន្តែមិនអនុវត្តចំពោះអ្នកកាន់កាប់ទុច្ចរិត។
- ករណីអចលនវត្ថុ កម្មសិទ្ធិករត្រូវសងនូវសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬកំណើនតម្លៃដែលនៅមានចំពោះសំណង់ដែលអ្នកកាន់កាប់សុច្ចរិតបានសង់ ដំណាំដែលបានដាំតែមិនទាន់បានទទួលផល និងដើមឈើដែលមិនទាន់បានកាប់។

## ជំពូកទី២. សិទ្ធិទាមទារឲ្យការពារការកាន់កាប់

**មាត្រា២៣៦នៃក្រមរដ្ឋប្បវេណីៈ** សិទ្ធិទាមទារឲ្យការពារអ្នកកាន់កាប់
អ្នកកាន់កាប់អាចទាមទារឲ្យប្រគល់វត្ថុដែលត្រូវបានដកហូតមកវិញ ទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ ឬទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់បានដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា២៣៧ (សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ) ដល់មាត្រា២៤១ (ទំនាក់ទំនងសិទ្ធិដែលមានមូលហេតុគតិយុត្តិ) នៃក្រមនេះទោះបីជាការកាន់កាប់នោះ ជាការកាន់កាប់ដោយចំពោះ ឬដោយប្រយោលក៏ដោយ។
មាត្រា២៣៧នៃក្រមរដ្ឋប្បវេណីៈ សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ
១-ប្រសិនបើអ្នកកាន់កាប់ត្រូវបានដកហូតនូវវត្ថុកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឲ្យប្រគល់វត្ថុនោះមកវិញបាន។
២-ការទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ មិនអាចធ្វើ ចំពោះអ្នកដែលបានទទួលវត្ថុពីអ្នកដកហូតការកាន់កាប់ ចំពោះអ្នកដែលបានទទួលការបង្កើតសិទ្ធិលើការបញ្ចាំ និង ចំពោះប្រតិសិទ្ធិដោយឡែកផ្សេងទៀតបានឡើយ។ ប៉ុន្តែ ក្នុងករណីដែលប្រតិសិទ្ធិនោះបានដឹង ឬ អាចដឹងនូវការដកហូតការកាន់កាប់នោះ អ្នកដែលបានកាន់កាប់ អាចទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ ចំពោះប្រតិសិទ្ធិនោះបាន។

៣-បណ្ដឹងទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ ត្រូវធ្វើឡើង ក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការដកហូតការកាន់កាប់នោះ។
មាត្រា២៣៨នៃក្រមរដ្ឋប្បវេណី៖ សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់
១-ប្រសិនបើអ្នកកាន់កាប់ត្រូវបានរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់បាន។
២-បណ្ដឹងទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ ត្រូវធ្វើឡើង នៅពេលដែលមានការរារាំង ឬ ក្នុងអំឡុងពេល១(មួយ)ឆ្នាំ ក្រោយពីការរារាំងនោះបានចប់។ ប៉ុន្តែ ក្នុងករណីដែលវត្ថុកាន់កាប់នោះ បានទទួលនូវការខូចខាត ដោយសារស្ថាបនកម្ម បណ្ដឹងនោះមិនអាចធ្វើបានឡើយ បើអំឡុងពេល១(មួយ)ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្ដើម ឬ បើស្ថាបនកម្មនោះបានចប់។

មាត្រា២៤០នៃក្រមរដ្ឋប្បវេណី៖ សិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់
១-ប្រសិនបើមានការបារម្ភថា អាចមានការរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់អាចទាមទារឲ្យបង្ការការរារាំងនូវការកាន់កាប់បាន។ ប៉ុន្តែ តុលាការអាចឲ្យភាគីម្ខាងទៀត ដាក់ការធានាសមរម្យជំនួសការបង្ការជាមុននូវការរារាំងនោះ។
២-បណ្ដឹងទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់ អាចធ្វើឡើងបាន ក្នុងអំឡុងពេលដែលមានការបារម្ភចំពោះការរារាំង។ ប៉ុន្តែ ក្នុងករណីដែលមានការបារម្ភថាអាចមានការខូចខាតចំពោះវត្ថុកាន់កាប់ ដោយសារស្ថាបនកម្ម បណ្ដឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល១(មួយ)ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្ដើម ឬ បើស្ថាបនកម្មនោះបានចប់។

យោងតាមអត្ថន័យនៃបទប្បញ្ញត្តិខាងលើ តើអ្វីទៅជាសិទ្ធិទាមឲ្យការពារការកាន់កាប់? ហើយសិទ្ធិទាមទារឲ្យការពារការកាន់កាប់កើតមាននៅពេលណា? ក្នុងស្ថានភាពបែបណា?

ដើម្បីធ្វើការសិក្សាស្វែងយល់អំពីអត្ថន័យខាងលើយើងអាចធ្វើការសិក្សាបែងចែកដូចខាងក្រោម៖

- គោលការណ៍ទូទៅ (ផ្នែកទី១)
- ប្រភេទនៃសិទ្ធិទាមទារឲ្យការពារការកាន់កាប់ (ផ្នែកទី២)
- គោលគំនិតនៃសិទ្ធិទាមទារឲ្យការពារការកាន់កាប់ (ផ្នែកទី៣)
- ទំនាក់ទំនងនៃសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិ និងសិទ្ធិទាមទារឲ្យការពារការកាន់កាប់ (ផ្នែកទី៤)

## ផ្នែកទី១ គោលការណ៍ទូទៅ

លើសពីនេះដើម្បីស្វែងយល់អំពីគោលគំនិតខាងលើ យើងអាចធ្វើការសិក្សាវិភាគអំពីទំនាក់ទំនងរវាងកម្មសិទ្ធិករនិងអ្នកកាន់កាប់ (គឺរវាងអ្នកកាន់កាប់មានសិទ្ធិ និងអ្នកកាន់កាប់ដោយគ្មានសិទ្ធិ) ថាតើសិទ្ធិទាមទារឲ្យធ្វើការការពារការកាន់កាប់កើតមាននៅពេលណា? និងមូលហេតុអ្វីបានជាសិទ្ធិទាមទារឲ្យធ្វើការការពារការកាន់កាប់កើតមាន បើធៀបជាមួយនឹងសិទ្ធិទាមទារឲ្យធ្វើការការពារសិទ្ធិកម្មសិទ្ធិ?

ចំពោះទំនាក់ទំនងនៃសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិ និងសិទ្ធិទាមទារឲ្យការពារការកាន់កាប់កើតមាន យោងតាមគោលគំនិតនៃច្បាប់សារធាតុ គឺបានគិតដល់មូលហេតុតុល្យភាពនៃផលប្រយោជន៍របស់បុគ្គលដែលមានសិទ្ធិ និងបុគ្គលដែលបានធ្វើកាន់កាប់លើវត្ថុដោយផ្ទាល់ ឬដោយប្រយោលជាបុគ្គលមានសិទ្ធិឬគ្មានសិទ្ធិ និងគោលគំនិតនៃការហាមឃាត់បុគ្គលចំពោះការសង្គ្រោះដោយប្រើប្រាស់នូវកម្លាំងខ្លួនឯងដើម្បីទាមទាររកយុត្តិធម៌នៅក្នុងសង្គម ទើបបង្កើតឲ្យមានរបបនៃការទាមទារឲ្យធ្វើការការពារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ និង របបនៃការទាមទារឲ្យធ្វើការការពារដោយផ្អែកលើការកាន់កាប់ ទោះបីជាការកាន់កាប់នោះធ្វើឡើងដោយបុគ្គលមានសិទ្ធិ ឬគ្មានសិទ្ធិក៏ដោយ។

## ផ្នែកទី២. ប្រភេទនៃសិទ្ធទាមទារឲ្យការពារការកាន់កាប់

### កថាភាគទី១. ប្រភេទនៃសិទ្ធទាមទារឲ្យការពារការកាន់កាប់

យោងតាមគោលគំនិតនៃមាត្រា២៣៦អ្នកកាន់កាប់មានសិទ្ធិទាមទារឲ្យទទួលបាននូវការការពារករណីមានការបំពានទៅលើការកាន់កាប់។ លើសពីនេះទៅទៀត ផ្អែកតាមច្បាប់សារធាតុអ្នកកាន់កាប់មានសិទ្ធិទាមទារឲ្យទទួលបានការពារទៅតាមប្រភេទនៃការបំពាននៅក្នុងលក្ខខណ្ឌទៅតាមប្រភេទនៃសិទ្ធិទាមទារដូចជា៖

- សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ(មាត្រា២៣៧)
- សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់(មាត្រា២៣៨)
- សិទ្ធិទាមទារសំណងការខូចខាត(មាត្រា២៣៩)
- សិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់(មាត្រា២៤០)

សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់ សិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់ ត្រូវបានបែងចែកទៅតាមកម្រិត និង បែបយ៉ាងនៃការបំពានការកាន់កាប់។ ក្នុងករណីការកាន់កាប់ត្រូវបានដកហូតទាំងស្រុង នោះអាចអនុវត្តសិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ។ ក្នុងករណីការកាន់កាប់ត្រូវបានបំពាន ប៉ុន្តែ មិនទាន់ត្រូវបានដកហូតទាំងស្រុងទេ នោះអាចអនុវត្តសិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់។ ក្នុងករណីការបំពានការកាន់កាប់មិនទាន់ចាប់ផ្តើម នោះអាចអនុវត្តសិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់។

### កថាភាគទី២. គោលគំនិតនៃមាត្រា២៣៧ សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ

គោលគំនិតនៃមាត្រា២៣៧ អនុវត្តនៅពេលដែលវត្ថុកាន់កាប់ត្រូវបានដកហូត គឺអ្នកកាន់កាប់មានសិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់នោះមកវិញតាមរយៈការដាក់ពាក្យប្តឹងទៅតុលាការក្នុងអំឡុងពេលមួយឆ្នាំ គិតចាប់ការដកហូតការកាន់កាប់។ ប៉ុន្តែសិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញមិនអាចអនុវត្តបានចំពោះអ្នកដែលបានទទួលសិទ្ធិលើការបញ្ញាំ និង ចំពោះប្រតិសិទ្ធិដោយឡែកផ្សេងទៀត។

**ករណីសិក្សាទី១៣**

ករណីលោក **ក** កំពុងកាន់កាប់ដីមួយកន្លែងដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ហើយលោក **ខ** បានសង់អាគារក្នុងដីដែលលោក **ក** កំពុងកាន់កាប់ដោយឯកឯង ហើយចាប់ផ្តើមរស់នៅលើដីនោះ។ ករណីខាងលើនេះតើ លោក **ក** គួរធ្វើបែបណាដើម្បីឲ្យលោក ខ ប្រគល់ដីនោះមកខ្លួនវិញបាន?

## កថាភាគទី៣. គោលគំនិតនៃមាត្រា២៣៨ សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងការកាន់កាប់

គោលគំនិតនៃមាត្រា២៣៨ អនុវត្តនៅពេលណា? និងក្នុងស្ថានភាពបែបណា? ករណីការកាន់កាប់ត្រូវបានបំពាន អ្នកកាន់កាប់ ទោះបីជាបុគ្គលមានសិទ្ធិ ឬគ្មានសិទ្ធិ គឺអាចទាមទារឲ្យបញ្ឈប់ការរារាំងនូវការកាន់កាប់តាមរយៈ នីតិវិធីនៃការដាក់ពាក្យប្តឹងទៅតុលាការ។ សូមពិចារណាទៅលើករណីសិក្សាខាងក្រោមៈ

**ករណីសិក្សាទី១៤**

ករណីលោក **ក** កំពុងកាន់កាប់ដីមួយកន្លែងដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ហើយលោក **ខ** បានដឹកជញ្ជូនសម្ភារៈដាក់ពេញក្នុងដីដែលលោក **ក** កំពុងកាន់កាប់ដោយឯកឯង។ ករណីខាងលើនេះតើ លោក **ក** អនុវត្តការរារាំងចំពោះការកាន់កាប់នោះបានយ៉ាងដូចម្តេច?

## កថាភាគទី៤. គោលគំនិតនៃមាត្រា២៤០ សិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់

គោលគំនិតនៃមាត្រា២៤០ អនុវត្តនៅក្នុងករណីដែលការកាន់កាប់ត្រូវបានបំពាន ហើយអ្នកកាន់កាប់មានការបារម្ភថាការកាន់កាប់របស់ខ្លួននឹងត្រូវបានរារាំងពិតប្រាកដនាពេលអនាគត គឺអ្នកកាន់កាប់មានសិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់។ ចំពោះការអនុវត្ត អ្នកកាន់កាប់មិនអាចធ្វើការទាមទារដោយប្រើប្រាស់នូវកម្លាំងខ្លួនឯងទេ គឺត្រូវតែខ្ចីកម្លាំងពីតុលាការ។ មានន័យអ្នកកាន់កាប់ត្រូវដាក់បណ្តឹងទៅតុលាការ ដើម្បីទាមទារឲ្យបង្ការជាមុននូវការរារាំងការកាន់កាប់ក្នុងអំឡុងពេលមួយឆ្នាំដោយគិតចាប់ពីស្ថាបនកម្មបានចាប់ផ្តើម ឬបើស្ថាបនកម្មនោះបានចប់។

**ករណីសិក្សាទី១៥**

ករណី លោក **ក** បានធ្វើការកាន់កាប់ដីមួយកន្លែងដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន។ ថ្ងៃមួយលោក **ខ** បានមកធ្វើការអះអាងចំពោះលោក **ក** ថាគាត់នឹងយកដីនោះវិញដើម្បីសាងសង់ឃ្លាំងផ្ទុកសម្ភារៈសំណង់ដូចនេះ លោក **ក** ត្រូវតែរើចេញពីដីនោះ។ ក្រោយពីការអះអាងរបស់លោក **ខ** ប៉ុន្មានថ្ងៃក្រោយមក គេឃើញមានកម្មករបីនាក់ដឹកសម្ភារៈសំណង់មកទុកនៅខាងមុខជិតដីដែលលោក **ក** កំពុងកាន់កាប់ ហើយបានប្រាប់ទៅលោក **ក** ថាសម្ភារៈទាំងអស់គឺថៅហ្វាយឲ្យដឹកមកទុកមុនដើម្បី

សាងសង់ឃ្លាំងនៅសប្ដាហ៍ក្រោយ។ លោក ក ក្រោយពីបានទទួលដំណឹងនេះហើយបានមកប្រឹក្សាជាមួយអ្នក តើគាត់អាចអនុវត្តសិទ្ធិបែបណាដើម្បីការពារផលប្រយោជន៍របស់ខ្លួន?

## ផ្នែកទី៣. គោលគំនិតនៃសិទ្ធិទាមទារឲ្យការពារការកាន់កាប់

សិទ្ធិទាមទារឲ្យការពារការកាន់កាប់ ជាប្រព័ន្ធមួយផ្សេងពីសិទ្ធិទាមទារដោយផ្អែកលើកម្មសិទ្ធិ។ សិទ្ធិទាមទារដោយផ្អែកលើកម្មសិទ្ធិ ជាប្រព័ន្ធដើម្បីការពារ "សិទ្ធិ" ដែលជា "កម្មសិទ្ធិ" ប៉ុន្តែផ្ទុយមកវិញ សិទ្ធិទាមទារឲ្យការពារការកាន់កាប់ ជាប្រព័ន្ធដើម្បីការពារ "ស្ថានភាព" ដែលជា "ការកាន់កាប់" ។ ហេតុដូច្នេះ មិនមែនមានតែអ្នកកាន់កាប់ដោយផ្អែកលើសិទ្ធិ អាចអនុវត្តសិទ្ធិទាមទារឲ្យការពារការកាន់កាប់ទេ សូម្បីតែអ្នកកាន់កាប់ដែលជាបុគ្គលគ្មានសិទ្ធិ ក៏អាចអនុវត្តសិទ្ធិទាមទារឲ្យការពារការកាន់កាប់បានដែរ។

គោលបំណងដែលទទួលស្គាល់សិទ្ធិទាមទារឲ្យការពារការកាន់កាប់អាចមាន សូម្បីតែអ្នកកាន់កាប់ដែលជាបុគ្គលគ្មានសិទ្ធិ គឺដោយសារតែគោលគំនិតនៃច្បាប់សារធាតុធ្វើការហាមឃាត់ការសង្គ្រោះដោយកម្លាំងខ្លួនឯង។ ឧទាហរណ៍យោងតាមករណីសិក្សាខាងលើ៖ ទង្វើដែល A ដាក់ជួរបង្គោលនៅជុំវិញផ្ទះ គឺជាការសង្គ្រោះដោយប្រើកម្លាំង ហេតុនេះមិនអនុញ្ញាតឲ្យមានទង្វើបែបនេះឡើយ។ ដោយសារតែមានទង្វើសង្គ្រោះដោយប្រើកម្លាំងខ្លួនឯងបែបនេះ សិទ្ធិទាមទារឲ្យការពារការកាន់កាប់ត្រូវបានបញ្ញត្តិដើម្បីការពារអ្នកកាន់កាប់ជា "បណ្ដោះអាសន្ន។

**ករណីសិក្សាទី១៦**

A បានឲ្យ B ខ្ចីផ្ទះដែលខ្លួនកំពុងមានកម្មសិទ្ធិ ដោយកំណត់រយៈពេល ៥ ឆ្នាំ។ ហើយ ៥ ឆ្នាំបានកន្លងផុត ភតិសន្យារបស់ A និង B បានបញ្ចប់។ ហេតុនេះ A បានទាមទារឲ្យ B រើចេញ និងប្រគល់ផ្ទះ។ ប៉ុន្តែ B ធុញទ្រាន់ក្នុងការស្វែងរកផ្ទះផ្សេង ហេតុនេះ B មិនខ្វល់នឹងការទាមទាររបស់ A ទេ ហើយក៏បន្តរស់នៅលើអាគារនោះ។ ដូច្នេះ A បានដាក់ជួរបង្គោលនៅជុំវិញផ្ទះដោយមិនមានការសម្រេចពី B ដើម្បីរារាំងមិនឲ្យ B ចូលក្នុងផ្ទះ។

ក្នុងករណីនេះ B អាចទាមទារអនុវត្តសិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់ពី A បានដែរឬទេ?

## ផ្នែកទី៤. ទំនាក់ទំនងនៃសិទ្ធិដែលនាំឲ្យមានមូលហេតុគតយុត្ត និង សិទ្ធិទាមទារឲ្យការពារការកាន់កាប់

**មាត្រា២៤១នៃក្រមរដ្ឋប្បវេណី៖** ទំនាក់ទំនងនឹងសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្ត

១. សិទ្ធិដែលធ្វើឲ្យការក្តាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់ ដូចជាកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិលើការបញ្ចាំ សិទ្ធិជួល ជាអាទិ៍ ហៅថាសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិ។

២. ចំពោះការអនុវត្តសិទ្ធិទាមទារឲ្យការពារអ្នកកាន់កាប់ ភាគីម្ខាងទៀតមិនត្រូវបានអនុញ្ញាតឲ្យអះអាងសេចក្តីតវ៉ា ដោយផ្អែកលើសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិឡើយ។

៣. បណ្តឹងដែលផ្អែកលើការកាន់កាប់ និងបណ្តឹងដែលផ្អែកលើសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិ

ពុំបានរារាំងគ្នាទៅវិញទៅមកឡើយ។ ចំពោះការអនុវត្តសិទ្ធិប្តឹងទាមទារដោយផ្អែកលើការកាន់កាប់ ភាគីម្ខាងទៀតអាចដាក់ពាក្យបណ្តឹងតបបាន ដោយផ្អែកលើសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិ។
៤. បណ្តឹងដែលផ្អែកលើការកាន់កាប់ មិនត្រូវបានសម្រេចសេចក្តីដោយផ្អែកលើមូលហេតុដែលទាក់ទងនឹងសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិឡើយ។

សិទ្ធិដែលធ្វើឲ្យភ្ជាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់ ដូចជាកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិលើការបញ្ចាំ សិទ្ធិជួល ជាអាទិ៍ ហៅថាសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិ។ យោងតាមករណីសិក្សាខាងលើ នៅក្នុងបណ្តឹងរបស់ B ដែលទាមទារឲ្យ A ប្រគល់វត្ថុកាន់កាប់ A អះអាងថាខ្លួនជាកម្មសិទ្ធិករលើអាគារ ហើយបានទាមទារឲ្យច្រានចោលពាក្យបណ្តឹងរបស់ B។ ប្រសិនបើតុលាការជ្រើសរើសយកការអះអាងរបស់ A ហើយបានច្រានចោលពាក្យបណ្តឹងរបស់ B នោះទង្វើសង្គ្រោះដោយកម្លាំងខ្លួនឯងរបស់ A ដែលបានដាក់ជួរបង្គោលនៅជុំវិញផ្ទះ នឹងត្រូវបានការពារ។ ជាលទ្ធផល ទង្វើសង្គ្រោះដោយកម្លាំងខ្លួនឯង ត្រូវបានទទួលស្គាល់ ហើយការទទួលស្គាល់សិទ្ធិទាមទារឲ្យការពារការកាន់កាប់នឹងលែងមានន័យ។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណី មាត្រា២៤១ កថាខណ្ឌទី២ បញ្ញត្តិថា "ចំពោះការអនុវត្តសិទ្ធិទាមទារឲ្យការពារការកាន់កាប់ ភាគីម្ខាងទៀតមិនត្រូវបានអនុញ្ញាតឲ្យអះអាងសេចក្តីតវ៉ា ដោយផ្អែកលើសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តិឡើយ"។ ម្យ៉ាងទៀត មាត្រា២៤១ កថាខណ្ឌ៤ បញ្ញត្តិថា " បណ្តឹងដែលផ្អែកលើការកាន់កាប់ មិនត្រូវបានសម្រេចសេចក្តីដោយផ្អែកលើមូលហេតុដែលទាក់ទងនឹងសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តឡើយ"។

ហេតុដូច្នេះ យោងតាមករណីសិក្សាខាងលើ A មិនអាចអះអាងកម្មសិទ្ធិរបស់ខ្លួននៅក្នុងសវនាការបានឡើយ ហើយតុលាការក៏មិនអាចច្រានចោលពាក្យបណ្តឹងរបស់ B ដោយមូលហេតុកម្មសិទ្ធិរបស់ A បានទេ នោះនាំឲ្យ B ឈ្នះក្តី។ ហេតុដូច្នេះ A ត្រូវតែរើចេញហើយប្រគល់អាគារទៅឲ្យ B។ ករណីនេះ B ដែលជាអ្នកកាន់កាប់ ត្រូវបានការពារជាបណ្តោះអាសន្ន ដោយផ្អែកលើសិទ្ធិទាមទារឲ្យការពារការកាន់កាប់។ ប៉ុន្តែ ដោយសារតែ A ជាកម្មសិទ្ធិករ ហើយ B ជាបុគ្គលគ្មានសិទ្ធិ ទោះបីជា B ត្រូវបានការពារជាបណ្តោះអាសន្នក៏ដោយ ក៏លទ្ធផលចុងក្រោយ A ចាំបាច់ត្រូវតែទទួលបានការពារ។ *តើ A គួរត្រូវធ្វើយ៉ាងណា? A អាចដាក់ពាក្យបណ្តឹងទាមទារឲ្យ B រើចេញហើយប្រគល់អាគារដោយផ្អែកលើកម្មសិទ្ធិ ឬ ដោយផ្អែកលើការបញ្ចប់ភតិសន្យា*។ ប៉ុន្តែ នៅពេលនេះ A កំពុងតែកាន់កាប់អាគារ ហេតុនេះ A មិនចាំបាច់ទាមទារឲ្យ B រើចេញហើយប្រគល់ឡើយ។ ការទាមទាររបស់ A ចាំបាច់នឹងកើតមានឡើងនៅក្រោយពេល A ចាញ់ក្តី ហើយរើចេញនិងប្រគល់អាគារ នៅក្នុងបណ្តឹងទាមទារឲ្យប្រគល់វត្ថុកាន់កាប់របស់ B។ ហេតុនេះ ប្រសិនបើ A ដាក់ពាក្យប្តឹង B នៅពេលនេះ ចាំបាច់ត្រូធ្វើបណ្តឹងទាមទារឲ្យផ្តល់តាវកាលិកនៅពេលអនាគត (**ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៦**) ដែលមានន័យថា "នាពេលអនាគត ប្រសិនបើ A រើចេញហើយប្រគល់អាគារទៅឲ្យ B នោះ B ត្រូវតែរើចេញហើយប្រគល់អាគារមកឲ្យ A វិញ" ។ ម្យ៉ាងទៀត A អាចដាក់ពាក្យបណ្តឹងទាមទារឲ្យរើចេញហើយប្រគល់អាគារតាមការសរសេរខាងលើ ជាលក្ខណៈបណ្តឹងតបនៅក្នុងនីតិវិធីនៃបណ្តឹងទាមទារឲ្យប្រគល់វត្ថុកាន់កាប់របស់ B។

ក្នុងករណីនេះ ជាបណ្តោះអាសន្ន អ្នកកាន់កាប់ត្រូវបានការពារដោយផ្អែកលើសិទ្ធិទាមទារឲ្យការពារការកាន់កាប់ ហើយកម្មសិទ្ធិករត្រូវបានហាមឃាត់នូវការសង្គ្រោះដោយកម្លាំងខ្លួនឯង ប៉ុន្តែ ជាលទ្ធផលចុងក្រោយ កម្មសិទ្ធិករ នៅតែទទួលបានការពារ។

**ករណីសិក្សាទី១៧**

ករណីលោក **ក** បានបង្កើតទំនាក់ទំនងគតិយុត្តិជាមួយលោក **ខ** លើការកាន់កាប់ផ្ទះ និងដីមួយកន្លែងនៅឆ្នាំ២០០១។ នៅឆ្នាំ២០០៥ លោក **ក** បានទទួលមរណៈភាព។ ហើយលោកស្រី **គ** បានធ្វើសន្តតិកម្មពីលោក **ក**។

១. ទោះបីជាលោក **ក** ទទួលមរណភាពរួចទៅហើយ តើក្នុងករណីបែបណាដែល លោក **ខ** អាចបន្តស្នាក់នៅក្នុងផ្ទះនោះបាន? ផ្ទុយមកវិញ បន្ទាប់ពីមរណភាពលោក **ក** តើក្នុងករណីបែបណាដែលលោក **ខ** ក្លាយជាបុគ្គលដែលគ្មានសិទ្ធិ?

២. លោក **ខ** ដែលជាបុគ្គលដែលគ្មានសិទ្ធិក៏ដោយ នៅតែបន្តរស់នៅក្នុងផ្ទះនោះ។ ពេលនោះ **គ** មានគំនិតចង់បណ្តេញ លោក **ខ** ចេញពីផ្ទះនោះ។ ក្នុងករណីនេះ តើលោកស្រី **គ** គួរតែធ្វើបែបណា?

៣. ទោះបីជាលោកស្រី **គ** បានស្នើសុំ លោក **ខ** ប៉ុន្មានដងក៏ដោយ ក៏ លោក **ខ** មិនព្រមចេញ។ នៅពេលដែលលោក **ខ** បានទៅធ្វើដំណើរកំសាន្តនៅបរទេស លោកស្រី **គ** ក៏បានធ្វើរបងព័ទ្ធជុំវិញផ្ទះដើម្បីកុំឲ្យ លោក **ខ** ចូលរួច។ ក្នុងករណីនេះ តើគួរធ្វើបែបណាដើម្បីការពាលោក **ខ**?

៤. បន្តពីចំនុចទី៣ លោក **ខ** បានដាក់ពាក្យបណ្តឹងប្តឹងទៅលោកស្រី **គ**។ ក្នុងករណីនេះ លោកស្រី **គ** អាចអះអាងអ្វីបាននៅក្នុងតុលាការ? ហើយតើតុលាការគួរធ្វើការវិនិច្ឆ័យបែបណា?

# ក្រុមការងារ

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង
# វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សិក្ខាសាលាលើកទី ២
## ស្តីពី

## រូបវន្តបុគ្គល

ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥

# សិក្ខាសាលាស្តីពី
# រូបវន្តបុគ្គល

ក្រុមការងារ
សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

កាលបរិច្ឆេទ៖ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥

1

## ករណីសិក្សាទី១ ប្រធាននៃសមត្ថភាពទទួលសិទ្ធិ



លោកវាសនា និងប្រពន្ធរបស់គាត់ជាកសិករ រស់នៅខេត្តបាត់ដំបង។ ប្រពន្ធរបស់គាត់បានទទួលមរណភាព។ គាត់មានកូន២នាក់ ប៉ុន្តែកូន២នាក់នោះរស់នៅភ្នំពេញជាមួយសាច់ញាតិ ហើយមិនបានត្រលប់មកបាត់ដំបងវិញរយៈពេល១០ឆ្នាំ។ លោកវាសនា ចិញ្ចឹមឆ្មាដែលមានឈ្មោះថា ចម្រើន។ វាហាក់ដូចជាសមាជិកគ្រួសាររបស់គាត់ និងមានរូបរាងគួរឲ្យស្រលាញ់។ លោកវាសនា ធ្លាក់ខ្លួនម៉ានជំងឺ ហើយគ្រូពេទ្យបាននិយាយថា គាត់អាចរស់នៅបានត្រឹមតែ១ខែទៀតទេ។ ហេតុនេះ លោកវាសនា បានសរសេរពាក្យបណ្តាំថា "ទ្រព្យសម្បត្តិរបស់ខ្ញុំទាំងអស់ ឲ្យទៅឆ្មាឈ្មោះចម្រើន"។ បន្ទាប់មក លោកវាសនា បានទទួលមរណភាព។

នៅពេលនេះ តើចម្រើនអាចធ្វើលទ្ធកម្មកម្មសិទ្ធិទ្រព្យសម្បត្តិរបស់លោកវាសនាបានដែរឬទេ?

2




**ក្រមរដ្ឋប្បវេណី មាត្រា៦**

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។

មាត្រានេះ បញ្ញត្តិអំពីសមត្ថភាពទទួលសិទ្ធិ។
តើសមត្ថភាពទទួលសិទ្ធិ ជាអ្វី?
សមត្ថភាពទទួលសិទ្ធិ គឺជាឋានៈដែលអាចក្លាយទៅជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ បើមិនមានសមត្ថភាពទទួលសិទ្ធិទេ ក៏មិនអាចទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដែរ។ សមត្ថភាពទទួលសិទ្ធិត្រូវបានទទួលស្គាល់តែចំពោះបុគ្គលប៉ុណ្ណោះ។ ឧទាហរណ៍ សត្វឆ្កែ និងសត្វឆ្មាមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ ហេតុនេះហើយមិនអាចធ្វើលទ្ធកម្ម កម្មសិទ្ធិតាមរយៈកិច្ចសន្យា ឬសន្តតិកម្មជាដើម និងមិនអាចទទួលកាតព្វកិច្ចបានទេ។

4

**ករណីសិក្សាទី២ សមត្ថភាពទទួលសិទ្ធិរបស់ជនបរទេស**

លោក Michael ជាជនជាតិអាមេរិច។ គាត់បានទិញ I Phone 6 នៅហាងលក់ទូរស័ព្ទដៃក្នុងទីក្រុងភ្នំពេញ។ ប៉ុន្តែ ១សប្តាហ៍ក្រោយមក បុគ្គលិកហាងលក់ទូរស័ព្ទដៃនោះ បានមក ហើយនិយាយទៅកាន់លោក Michael ថា "អ្នកជាជនបរទេស ហេតុនេះអ្នកមិនអាចបង្កើតកិច្ចសន្យានៅកម្ពុជាបានទេ ហើយមិនអាចមានកម្មសិទ្ធិលើទូរស័ព្ទដៃបានទេ។ ដូច្នេះ សូមប្រគល់ I Phone 6 មកវិញ"។

តើលោក Michael ត្រូវតែប្រគល់ I Phone 6 វិញដែរឬទេ?



**ករណីសិក្សាទី២ សមត្ថភាពទទួលសិទ្ធិរបស់ជនបរទេស**




6

**ក្រមរដ្ឋប្បវេណី មាត្រា៦**

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។

គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ
ក្រមរដ្ឋប្បវេណីទទួលស្គាល់ថា បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ។

ហេតុនេះ ជនបរទេសក៏មានសមត្ថភាពទទួលសិទ្ធិដែរ។

7

**ករណីសិក្សាទី៣**
**ករណីពិសេសនៃសមត្ថភាពទទួលសិទ្ធិរបស់ជនបរទេស**

លោក Michael បានទៅរកភ្នាក់ងារអចលនទ្រព្យ ដើម្បីទិញដីនៅភ្នំពេញ។ ប៉ុន្តែភ្នាក់ងារអចលនទ្រព្យបាននិយាយថា "អ្នកជាជនបរទេស ហេតុនេះមិនអាចទិញដីនៅប្រទេសកម្ពុជាបានទេ។"
តើ លោក Michael អាចទិញដីបានទេ?



8

**ករណីសិក្សាទី៣ ករណីពិសេសនៃសមត្ថភាពទទួលសិទ្ធិរបស់ជនបរទេស**




9

**ក្រមរដ្ឋប្បវេណី មាត្រា៧**

ជនជាតិបរទេស មិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ។

**រដ្ឋធម្មនុញ្ញមាត្រា ៤៤**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។

ហេតុនេះ ជនជាតិបរទេសមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើដីបានទេ។

10

## ករណីសិក្សាទី៤ ពេលចាប់ផ្តើមសមត្ថភាពទទួលសិទ្ធិ

ស្រីពៅមានផ្ទៃពោះ៩ខែ។ កូននៅក្នុងផ្ទៃជាកូនប្រុស ហើយស្រីពៅបានដាក់ឈ្មោះឲ្យកូននោះថា សីហា តាំងពីពេលកូននោះមិនទាន់កើត។ ឪពុកម្តាយរបស់ស្រីពៅបាននិយាយថា "ទិញរបស់នេះឲ្យកូនដែលនៅក្នុងផ្ទៃ" រួចបានទិញសម្ភារៈក្មេងលេងទុកឲ្យសីហា។ សីហាកំពុងនៅក្នុងផ្ទៃរបស់ស្រីពៅ។ នៅពេលនេះ តើសីហាមានសិទ្ធិកម្មសិទ្ធិលើសម្ភារៈក្មេងលេងដែរឬទេ?



11

ករណីសិក្សាទី៤ ពេលចាប់ផ្តើមសមត្ថភាពទទួលសិទ្ធិ




12

**ក្រមរដ្ឋប្បវេណី មាត្រា៨**
រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព។

កូននៅក្នុងផ្ទៃ មិនមានសមត្ថភាពទទួលសិទ្ធិទេ។
ដូចនេះ សីហា មិនអាចទទួលបានប្រទានកម្មនៃសម្ភារៈក្មេងលេងពីឪពុកម្តាយរបស់ស្រីពៅបានទេ។

តើ សីហា អាចទទួលបានកម្មសិទ្ធិលើសម្ភារៈក្មេងលេងយ៉ាងដូចម្តេច?

13

**ករណីសិក្សាទី៥**
**ករណីពិសេសនៃពេលចាប់ផ្តើមសមត្ថភាពទទួលសិទ្ធិ**

នៅពេលដែលសីហានៅក្នុងផ្ទៃនៅឡើយ ខេមដែលជាប្តីរបស់ស្រីពៅមានគ្រោះថ្នាក់ចរាចរណ៍ ហើយទទួលមរណភាពទៅ។ បន្ទាប់មកស្រីពៅបានផ្តល់កំណើតឲ្យសីហា។

ស្រីពៅបានទាមទារសំណងការខូចខាតចំពោះភាគីនៃគ្រោះថ្នាក់ចរាចរណ៍។ នៅពេលនោះ ស្រីពៅមិនត្រឹមតែទាមទារសំណងការខូចខាតដែលខ្លួនទទួលនោះទេ ក្នុងនាមជាអ្នកតំណាងរបស់សីហា តើនាងអាចទាមទាមសំណងការខូចខាតដែលសីហាទទួលរងដែរឬទេ?



14

**ករណីសិក្សាទី៥ ករណីពិសេសនៃពេលចាប់ផ្ដើមសមត្ថភាពទទួលសិទ្ធិ**




**ក្រមរដ្ឋប្បវេណី មាត្រា៩ កថាខណ្ឌ១**

ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបាន។

មាត្រានេះទាក់ទងនឹងការទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ហើយទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់ទារកនៅក្នុងគភ៌។

ហេតុនេះ ឧទាហរណ៍ក្នុងករណីដែលប្រពន្ធកំពុងពរពោះ ប្ដីបានទទួលមរណភាពក្នុងគ្រោះថ្នាក់ចរាចរណ៍ ទារកដែលបានចាប់កំណើតក្រោយពេលគ្រោះថ្នាក់ អាចទាមទារសំណងនៃការខូចខាតជាទ្រព្យសម្បត្តិ និងជាសំណងខាងផ្លូវចិត្តតាមរយៈមរណភាពរបស់ឪពុកចំពោះជនដែលបង្កគ្រោះថ្នាក់បាន។

ប៉ុន្តែ ដោយសារតែមានបញ្ញត្តិថា " មានកំណើតនៅពេលក្រោយ" ហេតុនេះក្នុងករណីដែលទារកកើតមកស្លាប់ នោះមិនអាចធ្វើសន្តតិកម្មការទាមទារសំណងការខូចខាតទៅម្ដាយជាដើមបានទេ ហើយម្ដាយក៏មិនអាចទាមទារសំណងការខូចខាតក្នុងនាមជាអ្នកតំណាងឲ្យទារកនៅក្នុងគភ៌មុនពេលចាប់កំណើតបានដែរ។

16

**ករណីសិក្សាទី៦**
**ករណីពិសេសនៃពេលចាប់ផ្ដើមសមត្ថភាពទទួលសិទ្ធិ**

នៅពេលដែលសីហានៅក្នុងផ្ទៃនៅឡើយ ខេមដែលជាប្ដីរបស់ស្រីពៅមានគ្រោះថ្នាក់ចរាចរណ៍ ហើយទទួលមរណភាពទៅ។ បន្ទាប់មកស្រីពៅបានផ្ដល់កំណើតឲ្យសីហា។

នៅពេលនោះ តើសីហាអាចធ្វើសន្តតិកម្មទៅលើទ្រព្យសម្បត្តិរបស់ ខេម បានទេ?



17

ករណីសិក្សាទី៦ ករណីពិសេសនៃពេលចាប់ផ្ដើមសមត្ថភាពទទួលសិទ្ធិ




18

**ក្រមរដ្ឋប្បវេណី មាត្រា៩ កថាខណ្ឌ២**
ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន។

ក្រមរដ្ឋប្បវេណី ទោះបីជាទាក់ទងនឹងសន្តតិកម្មក៏ដោយ ជាករណីពិសេសគឺទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់ទារកនៅក្នុងគភ៌។ ហេតុនេះ ក្នុងករណីដែលឪពុកទទួលមរណភាពនៅពេលម្តាយកំពុងពរពោះ ទារកដែលមានកំណើតនៅក្រោយ អាចធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ឪពុកបាន។ នៅក្នុងករណីសន្តតិកម្មនេះដែរ ដោយសារតែមានបញ្ញត្តិថា " មានកំណើតនៅពេលក្រោយ" ហេតុនេះក្នុងករណីដែលទារកកើតមកស្លាប់ នោះមិនអាចធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ឪពុកបានទេ ហើយម្តាយដែលកំពុងមានផ្ទៃពោះក៏មិនអាចតំណាងឲ្យទារកនៅក្នុងគភ៌ក្នុងការធ្វើការបែងចែកទ្រព្យសម្បត្តិបានដែរ។

19

**ករណីសិក្សាទី៧ ការប្រកាសអំពីការបាត់ខ្លួន**

សិរីមន្ត ជាអ្នកថតរូបដែលរស់នៅភ្នំពេញ។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៩ គាត់បានទៅប្រទេសអាហ្វ្រិកតែម្នាក់ឯង ដើម្បីថតរូបសត្វ។ ប្រពន្ធរបស់គាត់ រស្មីបានទាក់ទងជាមួយគាត់តាមរយៈFacebook ប៉ុន្តែ១ខែក្រោយមក គឺចាប់ខែកញ្ញា ឆ្នាំ២០០៩ ទៅ នាងមិនអាចទាក់ទងទៅគាត់បានទេ។ បន្ទាប់មក ៥ឆ្នាំបានកន្លងផុតមកដល់ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៤។ សិរីមន្ត មានការិយាល័យ និងដីនៅភ្នំពេញ។ រស្មីគិតថា ដី និងការិយាល័យនោះមិនចាំបាច់ ក៏ចង់លក់ ប៉ុន្តែដី និងការិយាល័យនោះមានចុះបញ្ជីឈ្មោះរបស់ សិរីមន្ត ហេតុនេះមិនអាចលក់បានទេ។ នៅពេលនេះ តើរស្មីគួរធ្វើបែបណា?

ម្យ៉ាងទៀត រស្មីចូលចិត្តបុរសម្នាក់ឈ្មោះ សុវត្ថិ។ តើនាងគួរធ្វើយ៉ាងណាដើម្បីអាចរៀបការជាមួយសុវត្ថិបាន?



20




**ក្រមរដ្ឋប្បវេណី មាត្រា ៤១ កថាខណ្ឌ ១**

ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។

**ក្រមរដ្ឋប្បវេណី មាត្រា ៤៣**

ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤១ (លក្ខខណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន)នៃក្រមនេះ បន្ទាប់ពីពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នោះបានកន្លងផុត និងក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រាដដែល បន្ទាប់ពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថា បានទទួលមរណភាព។ បញ្ញត្តិនេះត្រូវយកមកអនុវត្ត ចំពោះតែទំនាក់ទំនងគតិយុត្តិជុំវិញលំនៅឋាន ឬ ទីសំណាក់កន្លងមករហូតដល់ពេលនោះ។

22

តើការប្រកាសអំពីការបាត់ខ្លួន គឺជាប្រព័ន្ធបែបណា?

ការប្រកាសអំពីការបាត់ខ្លួន គឺជាប្រព័ន្ធដែលចាត់ទុកថា បុគ្គលនោះ បានទទួលមរណភាព ទៅលើទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋានជាដើម តាមរយៈនីតិវិធីដែលបានកំណត់ ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលនោះនៅរស់ ឬស្លាប់ក្នុងអំឡុងពេលកំណត់។ ក្នុងករណីដែលពុំមានដំណឹងរយៈពេលយូរថា បុគ្គលនោះនៅរស់ ឬស្លាប់ ទ្រព្យសម្បត្តិដែលបានបន្សល់ទុកនោះ ទោះដល់ពេលណាក៏ដោយ ក៏មិនអាចធ្វើសន្តតិកម្មបានទេ តែចាំបាច់ត្រូវមានអ្នកគ្រប់គ្រងបន្ត ហើយសហព័ទ្ធក៏មិនអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវប្រព័ន្ធការប្រកាសអំពីការបាត់ខ្លួននេះឡើង ដើម្បីអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិ និង សហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតបាន។

23

តើអ្នកណាអាចដាក់ពាក្យសុំឲ្យធ្វើការប្រកាសអំពីការបាត់ខ្លួនបាន?

- ■សហព័ទ្ធ
- ■អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន
- ■អច្ច័យលាភី
- ■អ្នកទទួលប្រាក់ធានារ៉ាប់រង
- ■អ្នកមានសិទ្ធិអំណាចមេបា
- ■អ្នកអាណាព្យាបាល
- ■ឪពុកម្តាយ
- ■អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន

24

តើដាក់ពាក្យសុំធ្វើការប្រកាសអំពីការបាត់ខ្លួនទៅអ្នកណា?

■ដាក់ពាក្យសុំទៅតុលាការ។

តើអ្នកណាជា អ្នកធ្វើការប្រកាសអំពីការបាត់ខ្លួន?

■តុលាការជាអ្នកធ្វើការប្រកាស។

នៅពេលធ្វើការប្រកាសអំពីការបាត់ខ្លួន តើនឹងក្លាយជាយ៉ាងណា?

■អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថា បានទទួលមរណភាព។
ហេតុនេះ អាចចាប់ផ្តើមធ្វើសន្តតិកម្មបាន ហើយសហព័ទ្ធក៏អាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតបានដែរ។

25

តើនៅពេលណាទើបត្រូវបានចាត់ទុកថា ទទួលមរណភាព?

■នៅពេលដែលពុំមានដំណឹងថា អ្នកបាត់ខ្លួននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ៥ឆ្នាំ។

| | | |
|---|---|---|
| 2009. 8. 10 | បានទៅអាហ្វ្រិក | |
| 2009. 9. 10 | មានអាចទំនាក់ទំនងបាន។ គឺមិនដឹងថា នៅរស់ ឬ ទទួលមរណភាព។ | |
| 2014. 9. 11 0:00am | មិនដឹងថា នៅរស់ ឬ ទទួលមរណភាព បានកន្លងផុតអំឡុងពេល ៥ឆ្នាំ។ | |
| 2014. 10. 10 | បានដាក់ពាក្យសុំប្រកាសអំពីការបាត់ខ្លួន | អានុភាពកើតមានឡើង |
| 2014. 11. 10 | តុលាការបានប្រកាសអំពីកាបាត់ខ្លួន | |

26

## ករណីសិក្សាទី៨ អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន

ការពិត សិរីមន្ត មិនបានទទួលមរណភាពទេ គាត់បានស្គាល់គ្នាជាមួយស្រីជនជាតិអាហ្វ្រិក ហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយនាង។ បន្ទាប់មក សិរីមន្តបាន នាំប្រពន្ធជនជាតិអាហ្វ្រិក ត្រលប់មកកម្ពុជានៅខែមេសា ឆ្នាំ២០១៥។ គាត់មិនបានផ្តល់ដំណឹងថា បានត្រលប់មកប្រទេសវិញដល់រស្មីទេ។ គាត់បានចាប់ផ្តើមរស់នៅក្នុងភូមិមួយនៅមណ្ឌលគិរីជាមួយប្រពន្ធជនជាតិអាហ្វ្រិក នោះ។



27



**ករណីសិក្សាទី៨ អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន**

សិរីមន្តបាននាំប្រពន្ធដែលជាជនជាតិអាហ្វ្រិកនោះទៅដើរលេងនៅសៀមរាប។ បន្ទាប់មកគិតថានឹងទៅទិញសំលៀកបំពាក់នៅផ្សារចាស់។ នៅពេលនៅចៃដន្យ សុខនួន ដែលជាមិត្តរបស់ រស្មី បានឆ្លងកាត់។ សុខនួន បានដឹងអំពីការប្រកាសបាត់ខ្លួនរបស់ សិរីមន្ត ពី រស្មី។ សុខនួន បានឃើញសិរីមន្ត នៅជាមួយស្រីផ្សេង ក៏ភ្ញាក់ផ្អើល ហើយខឹងយ៉ាងខ្លាំង។ បន្ទាប់មក សុខនួនបាននិយាយទៅកាន់ សិរីមន្តថា " អ្នកត្រូវបានគេចាត់ទុកថា ស្លាប់ហើយ។ មនុស្សដែលស្លាប់ មិនអាចទិញសំលៀកបំពាក់បានទេ។"



តើសិរីមន្តអាចទិញសំលៀកបំពាក់បានទេ?

29

នៅពេលធ្វើការប្រកាសអំពីការបាត់ខ្លួន តើនឹងក្លាយជាយ៉ាងណា?

■អ្នកបាត់ខ្លួន ត្រូវបានចាត់ទុកថា បានទទួលមរណភាព ចំពោះតែទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬទីសំណាក់កន្លងមករហូតដល់ពេលនោះ។

ត្រូវចាត់ទុកថា បានទទួលមរណភាពចំពោះតែទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋានប៉ុណ្ណោះ មិនមែនដកហូតនូវសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលនោះទេ ដូច្នេះហើយបើបុគ្គលនោះនៅរស់ ហើយរស់នៅកន្លែងផ្សេង បុគ្គលនោះអាចធ្វើលទ្ធកម្មនូវសិទ្ធិ និង កាតព្វកិច្ចបាន ឧទាហរណ៍ថា បុគ្គលនោះបានបង្កើតកិច្ចសន្យា ក៏មានសុពលភាពដែរ។

30

**ករណីសិក្សាទី៩ ការលុបចោលការប្រកាសអំពីការបាត់ខ្លួន**

ក្រោយពីការប្រកាសអំពីការបាត់ខ្លួនរបស់ សិរីមន្ត រស្មីបាន ត្រៀមរៀបចំអាពាហ៍ពិពាហ៍ជាមួយ សម្បត្តិ ប៉ុន្តែមិនទាន់រៀប អាពាហ៍ពិពាហ៍ជាផ្លូវការណ៍នោះទេ។ នៅក្នុងអំឡុងពេលនោះ សុខនួន បានប្រាប់ពីរឿងដែលសិរីមន្តនៅរស់ដល់រស្មី ថែមទាំងប្រាប់លេខ ទូរស័ព្ទដែលបានសុំពី សិរីមន្ត ទៀតផង។ រស្មី រន្ធត់ជាខ្លាំង នាងបានយំ អស់ពេញ១យប់។ នៅព្រឹកថ្ងៃបន្ទាប់ នាងបានពិភាក្សាជាមួយ សម្បត្តិ។ សម្បត្តិ ភ្ញាក់ផ្អើលរួចនិយាយទៅកាន់ រស្មីថា " កុំបារម្ភពីខ្ញុំអី ធ្វើតាមចិត្ត នាងចង់ទៅចុះ។" បន្ទាប់មក រស្មី ក៏បែកពីសម្បត្តិ។ នាងបានទូរស័ព្ទទៅ រក សិរីមន្ត ហើយនិយាយថា ចង់ជួបគ្នា។



31

**ករណីសិក្សាទី៩ ការលុបចោលការប្រកាសអំពីការបាត់ខ្លួន**

មួយរយៈក្រោយមក ស្ត្រីជនជាតិអាហ្វ្រិកនោះ បានចាប់ផ្តើម និយាយថា ចង់ត្រលប់ទៅអាហ្វ្រិកវិញ។ ហេតុនេះ សិរីមន្ត ក៏បែកពីនាង ហើយឲ្យនាងត្រលប់ទៅវិញ។ បន្ទាប់មក គាត់បាន ត្រលប់ទៅភ្នំពេញ វិញ ហើយបានជួបជាមួយ រស្មី។

ដើម្បីឲ្យសិរីមន្ត និងរស្មី អាចត្រលប់ទៅកាន់ជីវភាពដូចពីមុន វិញ តើគួរធ្វើយ៉ាងណា?



32




**ក្រមរដ្ឋប្បវេណី មាត្រា ៤៤ កថាខណ្ឌ១**

ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ មានការបញ្ជាក់ថាទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) ខាងលើនេះ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍។

ករណីដែលបានប្រកាសអំពីការបាត់ខ្លួនហើយ តាមផ្លូវច្បាប់ត្រូវចាត់ទុកថាបានទទួលមរណភាព ដូច្នេះហើយ ទោះបីជាសាមីខ្លួនបានត្រលប់មកវិញក៏ដោយ ក៏អានុភាពនៃការប្រកាសអំពីការបាត់ខ្លួនមិនបាត់បង់អានុភាពនោះទេ។ ដើម្បីឲ្យអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនបាត់បង់អានុភាព ចាំបាច់ត្រូវធ្វើការលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ។

នៅពេលដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ត្រូវយកមកអនុវត្តដូចការប្រកាសអំពីការបាត់ខ្លួននោះមិនមានតាំងពីដំបូង។

34

**ករណីសិក្សាទី១០ អនុភាពនៃការលុបចោលការប្រកាសអំពីការបាត់ខ្លួន**

ការប្រកាសអំពីការបាត់ខ្លួនរបស់សិរីមន្តត្រូវបានលុបចោល ហើយអ្នកទាំង២ បានចាប់ផ្តើមប្រកបរបរជាមួយគ្នាម្តងទៀត ក្នុងនាមជាប្តីប្រពន្ធ។ សិរីមន្ត បាន គិតថាចង់ប្រើប្រាស់ការិយាល័យនៅភ្នំពេញ ដែលជាទ្រព្យសម្បត្តិដោយឡែក របស់ខ្លួនមានមុនពេលរៀបអាពាហ៍ពិពាហ៍ ដើម្បីធ្វើការងារជាអ្នកថតរូប។ ប៉ុន្តែ នាពេលបច្ចុប្បន្ន ការិយាល័យនោះ កំពុងត្រូវបានប្រើប្រាស់ដោយមនុស្ស ប្រុសម្នាក់ ឈ្មោះថា ដារ៉ា។ ព្រោះ បន្ទាប់ពីការប្រកាសអំពីការបាត់ខ្លួនរបស់ សិរីមន្ត រស្មីបានធ្វើនីតិវិធីសន្តតិកម្ម ហើយបានផ្លាស់ប្តូរការចុះបញ្ជី ការិយាល័យនោះ ជាឈ្មោះរបស់ខ្លួន បន្ទាប់មកបានលក់ទៅឲ្យដារ៉ា ចំនួន ១០០០០០ ដុល្លារ។ នៅពេលនេះ តើសិរីមន្ត អាចទាមទារឲ្យប្រគល់ ការិយាល័យមកខ្លួនវិញបានទេ?



35

**ករណីសិក្សាទី១០**
**អានុភាពនៃការលុបចោលការប្រកាសអំពីការបាត់ខ្លួន**

ការប្រកាសអំពីការបាត់ខ្លួនរបស់សិរីមន្ត

នីតិវិធីសន្តតិកម្ម
ចុះបញ្ជីឈ្មោះ ពីការិយាល័យរបស់សិរីមន្ត ទៅជារបស់រស្មី

រស្មីលក់ការិយាល័យថ្លៃ១០០០០០ (ដប់ម៉ឺន) ដុល្លារឲ្យទៅដារ៉ា។
ចុះបញ្ជីឈ្មោះការិយាល័យ ដោយប្តូរទៅជារបស់ដារ៉ា

លុបចោលការប្រកាសអំពីការបាត់ខ្លួន




36

**មាត្រា៤៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី**
អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ។

នៅពេលដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ត្រូវយកមកអនុវត្តដូចដែរការប្រកាសអំពីការបាត់ខ្លួននោះមិនមានតាំងពីដំបូង។ បើដូច្នេះ មានការព្រួយបារម្ភអំពីការបាត់បង់ផលប្រយោជន៍របស់បុគ្គលដែលបានធ្វើលទ្ធកម្មទ្រព្យសម្បត្តិដោយសារការប្រកាសអំពីការបាត់ខ្លួន បុគ្គលដែលធ្វើពាណិជ្ជកម្មជាមួយបុគ្គលធ្វើលទ្ធកម្មនោះ និងសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ថ្មីក្រោយពីការប្រកាសអំពីការបាត់ខ្លួនជាដើម។ ដូចនេះ ក្រមរដ្ឋប្បវេណីបានបង្កើតឡើងនូវបញ្ញត្តិដើម្បីគ្រប់គ្រងទៅលើផលប្រយោជន៍ និងការខាតបង់នេះ។

37

**ករណីសិក្សាទី១១**
**អានុភាពនៃការលុបចោលការប្រកាសអំពីការបាត់ខ្លួន**

សិរីមន្ត បាននិយាយទៅកាន់រស្មីឲ្យលក់ការិយាល័យ ហើយប្រគល់ប្រាក់ដែលបានទទួលចំនួន ១០០០០០ ដុល្លារមកឲ្យខ្លួនវិញ ដើម្បីទិញការិយាល័យផ្សេង។ ប៉ុន្តែ រស្មី សល់ប្រាក់តែ ៥០០០០ ដុល្លារ នាពេលបច្ចុប្បន្នទេ។ ព្រោះ នៅក្នុងប្រាក់ ១០០០០០ដុល្លារ រស្មី បានដកយក ៥០០០០ ដុល្លារ ទៅសង់ផ្ទះដើម្បីឲ្យឪពុកម្តាយរស់នៅខេត្តកោះកុង។ ករណីនេះ តើ រស្មី ត្រូវតែសងសងប្រាក់ឲ្យទៅសិរីមន្តចំនួនប៉ុន្មាន?



38




**មាត្រា៤៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី**

បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយចំពោះ ដោយសារអនុភាពនៃការប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ។ ប៉ុន្តែ បុគ្គលដែលមិនបានដឹងថា ការប្រកាសបាត់ខ្លួននោះ ផ្ទុយពីការពិត នៅពេលដែលខ្លួនបានទទួលទ្រព្យសម្បត្តិនោះ ត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ។

"បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន" គឺជា សន្តតិជន ឬ អ្នកទទួលប្រាក់ធានារ៉ាប់រង ជាដើម។

"ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍" មានន័យថា ទ្រព្យសម្បត្តិដែលបានប្រើប្រាស់រួច មិនចាំបាច់ឲ្យមានការសងត្រលប់ទៅវិញទេ គឺសងត្រឹមតែទ្រព្យសម្បត្តិដែលនៅសល់។

40

**ករណីសិក្សាទី១២ អានុភាពនៃការលុបចោលការប្រកាសអំពីការបាត់ខ្លួន**

បន្ទាប់ពីការប្រកាសអំពីការបាត់ខ្លួនរបស់សិរីមន្ត ប្រសិនបើ រស្មី រៀប អាពាហ៍ពិពាហ៍ជាមួយសម្បត្តិ ហើយបន្ទាប់មក ប្រសិនបើការប្រកាស អំពីការបាត់ខ្លួន ត្រូវបានលុបចោល តើអានុភាពនៃអាពាហ៍ពិពាហ៍រវាង រស្មី និង សម្បត្តិ ក្លាយទៅជាយ៉ាងណា?



41

**មាត្រា៤៤ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី**

ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ។

ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោលក្រោយពេលសហព័ទ្ធបានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេង ទោះបីជាគូភាគីសុចរិតក៏ដោយ ទុច្ចរិតក៏ដោយ ក៏អាពាហ៍ពិពាហ៍ក្រោយមានសុពលភាព។

42

**ករណីសិក្សាទី១៣ ការបាត់ខ្លួនពិសេស**

ពិសាល បានជិះយន្តហោះរបស់អាកាសចរណ៍ម៉ាឡេស៊ី ពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដើម្បីទៅធ្វើការនៅប៉េកាំង ប្រទេសចិន នៅថ្ងៃទី ៨ ខែមីនា ឆ្នាំ២០១៤។ ជាដំបូង គាត់បានទៅកូឡាឡាំពួរ បន្ទាប់មក គាត់បានចាកចេញពីទីនោះ ហើយជិះយន្តហោះទៅប៉េកាំង។ ប៉ុន្តែ នៅថ្ងៃនោះ យន្តហោះនោះបានបាត់ ហើយនាពេលបច្ចុប្បន្នមិនទាន់ស្វែងរកឃើញទេ។ លក្ខិណា ដែលជាប្រពន្ធរបស់ ពិសាល គិតថា ពិសាល មិនអាចត្រលប់មកវិញបានទេ។ ក្នុងករណីនេះ បើ លក្ខិណា ចង់ធ្វើនីតិវិធីសន្តតិកម្មនូវទ្រព្យសម្បត្តិដោយឡែករបស់ ពិសាល មកខ្លួន

តើលក្ខិណា ត្រូវធ្វើដូចម្តេច?



43

**ករណីសិក្សាទី១៣**
**ការបាត់ខ្លួនពិសេស**




44

**មាត្រា៤១ នៃក្រមរដ្ឋប្បវេណី**

១- ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេប៉ា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឲ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ។

មាត្រា៤១ កថាខណ្ឌទី២ ចែងអំពីការបាត់ខ្លួនពិសេស។ ការបាត់ខ្លួនពិសេស គឺជាប្រព័ន្ធដែលទទួលស្គាល់ការប្រកាសអំពីការបាត់ខ្លួនក្នុងអំឡុពេលយ៉ាងខ្លីដែលខុសពីធម្មតា ក្នុងករណីដែលមានលទ្ធភាពខ្ពស់នៃមរណភាពដោយសារសង្គ្រាម ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរជាដើម ហើយសាកសពនៅមិនទាន់រកឃើញនៅឡើយ។

45

**មាត្រា៤៣ នៃក្រមរដ្ឋប្បវេណី**

ក្នុងករណីដែលការបាត់ខ្លួនបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន)នៃក្រមនេះ បន្ទាប់ពីពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ បានកន្លងផុត និង ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រាដដែល បន្ទាប់ពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាព។ បញ្ញត្តិនេះត្រូវយកមកអនុវត្ត ចំពោះតែទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬ ទីសំណាក់កន្លងមករហូតដល់ពេលនោះ។

ក្នុងករណីនៃការបាត់ខ្លួនពិសេស អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាពចាប់តាំងពីពេលគ្រោះថ្នាក់បានកន្លងផុត។ ក្នុងករណីគ្រោះថ្នាក់យន្តហោះ ត្រូវបានចាត់ទុកថា បានទទួលមរណភាពនៅថ្ងៃដែលបានកើតឡើងនូវគ្រោះថ្នាក់នោះ។

46

**ករណីសិក្សាទី១៤**
**ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា**

លោកសំបូរ រស់នៅជាមួយ ឪពុកម្តាយ ប្រពន្ធ និងកូនម្នាក់។ នៅពេលលោកសំបូរបើកម៉ូតូដោយឌុបកូននៅពីក្រោយ ក៏បានជួបប្រទះគ្រោះថ្នាក់ចរាចរណ៍។ កូន បាន ទទួល មរណភាពភ្លាមៗនៅកន្លែងកើតហេតុ។ លោកសំបូរ ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ប៉ុន្តែ១ម៉ោងក្រោយមក គាត់បានទទួលមរណភាព។
ក្នុងករណីនេះ តើនរណាធ្វើសន្តតិកម្មទ្រព្យសម្បត្តិរបស់លោកសំបូរ?

ករណីសិក្សានេះ ជាករណីសិក្សាដើម្បីរៀបចំការសិក្សាអំពី "ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា" នៃមាត្រា៤៥ ក្រមរដ្ឋប្បវេណី។




47

**ករណីសិក្សាទី១៤ ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា**






48

**ក្រមរដ្ឋប្បវេណី មាត្រា១១៥៩**

១- បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នាត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន។

២- ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា។

49

**ក្រមរដ្ឋប្បវេណី មាត្រា១១៦១**

១- សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។

២- នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ។

**ក្រមរដ្ឋប្បវេណី មាត្រា១១៦២**

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោយនេះ៖

ក- បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗរបស់មតកជននោះនឹងត្រូវទទួលចំណែកមត៌កស្មើគ្នា។

ខ- បើសហព័ទ្ធ និង ឪពុក ម្តាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា១ភាគ៣(មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្តាយ ត្រូវជា២ភាគ៣ (ពីរភាគបី)។ ប៉ុន្តែ បើឪពុក ឬ ម្តាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្តាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា។

50

**ករណីសិក្សាទី១៤ ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា**

$\frac{1}{3}$ ឪពុក — ម្ដាយ $\frac{1}{3}\left(\frac{2}{3} \times \frac{1}{2}\right)$

សំបូរ
១ម៉ោងក្រោយមក បាន
ទទួលមរណភាព — ប្រពន្ធ $\frac{1}{3}$

កូន
បានទទួលមរណភាពភ្លាមៗ



51

**ករណីសិក្សាទី១៥**
**ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា**

សំបូរ រស់នៅជាមួយឪពុកម្ដាយ ប្រពន្ធ និងកូនម្នាក់។ សំបូរ បើកម៉ូតូឌុបកូនរបស់គាត់ពីក្រោយ ហើយបានជួបប្រទះនឹងគ្រោះថ្នាក់ចរាចរណ៍ពេលកំពុងជិះ។ សំបូរ បានស្លាប់នៅនឹងកន្លែង ឯកូនរបស់គាត់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ប៉ុន្តែស្លាប់នៅ ១ សប្ដាហ៍បន្ទាប់។ ក្នុងពេលបែបនេះ តើទ្រព្យសម្បត្តិរបស់ សំបូរ ត្រូវធ្វើសន្តតិកម្មទៅនរណា?

ករណីសិក្សានេះ ក៏ជាករណីសិក្សាសម្រាប់ត្រៀមសិក្សាអំពី "ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា" នៃមាត្រា ៤៥។




52

**ករណីសិក្សាទី១៥ ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា**

ឪពុក — ម្តាយ

សំបូរ
បានទទួលមរណភាពភ្លាមៗ — ប្រពន្ធ

កូន
១ម៉ោងក្រោយមក បាន
ទទួលមរណភាព



53

**ក្រមរដ្ឋប្បវេណី មាត្រា ១១៥៦ កថាខណ្ឌទី១**
កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១។

**ក្រមរដ្ឋប្បវេណី មាត្រា ១១៥៩**
បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នាត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន។
ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា។

54

**ក្រមរដ្ឋប្បវេណី មាត្រា ១១៦១**

សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។

នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តនៃផ្នែកទី១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ។

**ក្រមរដ្ឋប្បវេណី មាត្រា ១១៦២**

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានកំណត់ដូចខាងក្រោមនេះ៖

ក. បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗរបស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា។

**ករណីសិក្សាទី១៥ ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា**

ឪពុក ═ ម្តាយ

សំបូរ
បានទទួលមរណភាពភ្លាមៗ ═ ប្រពន្ធ $\frac{1}{2} + \frac{1}{2} = 1$

កូន
១ម៉ោងក្រោយមក បាន
ទទួលមរណភាព $\frac{1}{2}$



56

**ករណីសិក្សាទី១៦**
**ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា**

សំបូរ រស់នៅជាមួយឪពុកម្តាយ ប្រពន្ធ និងកូនម្នាក់។ សំបូរ បើកម៉ូតូឌុបកូនរបស់គាត់ពីក្រោយ ហើយបានជួបប្រទះនឹងគ្រោះថ្នាក់ចរាចរណ៍ពេលកំពុងជិះ។ មិនដឹងថារវាង សំបូរ និង កូនរបស់គាត់ នរណាស្លាប់មុននោះទេ។

ក្នុងករណីនេះ តើទ្រព្យសម្បត្តិរបស់ សំបូរ ត្រូវធ្វើសន្តតិកម្មទៅនរណា?




57

**ករណីសិក្សាទី១៦ ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា**






58

**ក្រមរដ្ឋប្បវេណី មាត្រា ៤៥**
ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀត បានទទួលមរណភាពទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា។

មាត្រានេះ បញ្ញត្តអំពី ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា។ "ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀត បានទទួលមរណភាពទេ" មានន័យថា មិនដឹងថា តើបុគ្គលណាទទួលមរណភាពមុន។

59

**ក្រមរដ្ឋប្បវេណី មាត្រា ១១៤៩ កថាខណ្ឌទី១**
មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន។

បុគ្គលដែលទទួលមរណភាពព្រមពេលជាមួយគ្នានឹងមតកជន មិនមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ហេតុនេះមិនអាចក្លាយជាសន្តតិជនបានទេ។

60

**ករណីសិក្សាទី១៦ ការចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា**

$\frac{1}{3}$ ឪពុក — ម្តាយ $\frac{1}{3}$

សំបូរ
មិនដឹងថាអ្នកណាម្នាក់
បានទទួលមរណភាព
មុនទេ

— ប្រពន្ធ $\frac{1}{3}$

កូន
មិនដឹងថាអ្នកណាម្នាក់
បានទទួលមរណភាព
មុនទេ



61

# សូមអរគុណ!!!

# Q & A

---

# ឯកសារពិគ្រោះ

## ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

62

## រូបវន្តបុគ្គល

### ១ សមត្ថភាពទទួលសិទ្ធិ

#### ១.១ និយមន័យនៃសមត្ថភាពទទួលសិទ្ធិ

សមត្ថភាពទទួលសិទ្ធិ គឺជាឋានៈដែលអាចក្លាយទៅជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ បើមិនមានសមត្ថភាពទទួលសិទ្ធិទេ ក៏មិនអាចទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដែរ។ សមត្ថភាពទទួលសិទ្ធិត្រូវបានទទួលស្គាល់តែចំពោះបុគ្គលប៉ុណ្ណោះ។ ឧទាហរណ៍ សត្វឆ្កែ និងសត្វឆ្មាមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ ហេតុនេះហើយមិនអាចធ្វើលទ្ធកម្មសិទ្ធិតាមរយៈកិច្ចសន្យាជាដើម និងមិនអាចទទួលកាតព្វកិច្ចតាមតាមរយៈអំពើអនីត្យានុកូលជាដើមនោះទេ។

#### ១.២ គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

តើអ្នកណាជាអ្នកមានសមត្ថភាពទទួលសិទ្ធិ? បុគ្គលត្រូវបែកចែកជា រូបវន្តបុគ្គល និង នីតិបុគ្គល។ រូបវន្តបុគ្គល គឺជាមនុស្ស ហើយនីតិបុគ្គល គឺជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចពិសេសដែលទទួលស្គាល់ដោយច្បាប់។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា « រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចបាន» (មាត្រា ៦)។ មានន័យថា ក្រមរដ្ឋប្បវេណីបានទទួលស្គាល់ថា បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ។

#### ១.៣ ពេលចាប់ផ្តើមនៃសមត្ថភាពទទួលសិទ្ធិ

##### ១.៣.១ គោលការណ៍ (មាត្រា ៨)

ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិ ប៉ុន្តែ តើសមត្ថភាពទទួលសិទ្ធិចាប់មានពីពេលណា? សមត្ថភាពទទួលសិទ្ធិ តើចាប់ផ្តើមពីពេលណា គឺជាបញ្ហា។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីពេលផ្តើមនៃសមត្ថភាពទទួលសិទ្ធិថា «រូបវន្តបុគ្គលទទួលបានសមត្ថភាពទទួលសិទ្ធិនៅពេលដែលចាប់កំណើត»។ និយមន័យនៃការចាប់កំណើតមិនបានបញ្ញត្តច្បាស់លាស់នោះទេក្នុងក្រមរដ្ឋប្បវេណី គឺពឹងផ្អែកទៅលើការបកស្រាយរបស់កម្ពុជា។ នៅប្រទេសជប៉ុន មានការបកស្រាយជាច្រើនដូចជា ពេលដែលខ្លួនទារកទាំងមូលបានកើតផុតពីគភ៌ម្តាយ (ទ្រឹស្តីនៃការកើតផុតខ្លួនទាំងមូល) ពេលដែលទារកកើតបានមួយផ្នែកពីគភ៌ម្តាយ (ទ្រឹស្តីនៃការកើតតែមួយផ្នែក) និង ពេលដែលទារកបានឯករាជ្យពីគភ៌ម្តាយ ហើយចាប់ផ្តើមដកដង្ហើម (ទ្រឹស្តីនៃការដកដង្ហើមឯករាជ្យ) ប៉ុន្តែ ទ្រឹស្តីនៃការកើតផុតខ្លួនទាំងមូល គឺគេទទួលស្គាល់ច្រើន។

##### ១.៣.២ ករណីលើកលែង (មាត្រា ៩)

ដូចដែលបានពិភាក្សាមុននេះ ពេលចាប់ផ្តើមនៃសមត្ថភាពទទួលសិទ្ធិ គឺពេលដែលមានកំណើត។ មានន័យថា ជាគោលការណ៍ ទារកនៅមុនពេលមានកំណើតមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ។ ប៉ុន្តែ ទារកដែលជិតមានកំណើតហើយ បែរជាមិនទទួលស្គាល់សិទ្ធិទាល់តែសោះ ដូចជាសន្តតិកម្មជាដើមនោះ គឺមិនស្មើភាពនោះទេ។ ហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវករណីលើកលែង ដោយទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ដែលទាក់ទង

ទៅនឹង ការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល សន្តតិកម្ម និង អច្ច័យទាន។

### ក. ទារកនៅក្នុងគភ៌ និង អំពើអនីត្យានុកូល

ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា «ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនោះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលបាន» (កថា.១ មាត្រា៩) ទាក់ទងនឹងការទាមទារសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូល ទារកក្នុងគភ៌ត្រូវបានទទួលស្គាល់ថាមានសមត្ថភាពទទួលសិទ្ធិ។ មានន័យថា ឧទាហរណ៍ក្នុងករណីដែលប្តីបានរងគ្រោះថ្នាក់ចរាចរណ៍ស្លាប់ក្នុងពេលដែលប្រពន្ធកំពុងតែមានគភ៌ ទារកដែលនៅក្នុងគភ៌នាពេលដែលមានគ្រោះថ្នាក់កើតឡើង ក្រោយពេលដែលកើតមកអាចទាមទារសំណងការខូចខាតជាការខូចខាតផ្នែកស្មារតី និងទ្រព្យសម្បត្តិដោយសារមរណភាពរបស់ឪពុក ចំពោះចារីបាន។ ប៉ុន្តែ ក្នុងមាត្រាបានបញ្ញត្តថា «បើទារកនោះមានកំណើតនៅពេលក្រោយ» ដូច្នេះហើយ ករណីទារកស្លាប់ពេលសម្រាល ម្តាយជាដើមមិនអាចធ្វើសន្តតិកម្មសិទ្ធិទាមទារសំណងការខូចខាតបានទេ ហើយនៅមុនពេលទារកចាប់កំណើតក៏ម្តាយមិនអាចធ្វើជាអ្នកតំណាងទារកក្នុងផ្ទៃ ដើម្បីទាមទារសំណងការខូចខាតបានដែរ។

### ខ. ទារកនៅក្នុងគភ៌ និង សន្តតិកម្ម

ក្រមរដ្ឋប្បវេណី ក៏បានទទួលស្គាល់ជាករណីលើកលែងចំពោះទារកក្នុងគភ៌នូវសមត្ថភាពទទួលសិទ្ធិ ដែលទាក់ទងនឹងសន្តតិកម្ម ដោយបញ្ញត្តថា «ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌កដោយសន្តតិកម្មនោះបាន»(កថា.២ មាត្រា ៩)។ មានន័យថា ករណីដែលឪពុកបានទទួលមរណភាពនៅពេលដែលម្តាយកំពុងតែមានគភ៌ កូនដែលនៅក្នុងគភ៌នោះ នៅពេលចាប់កំណើតនៅពេលក្រោយ អាចទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិរបស់ឪពុកបាន។ ករណីសន្តតិកម្មក៏ដូចគ្នាផងដែរ ក្នុងមាត្រាបានបញ្ញត្តថា «បើទារកនោះមានកំណើតនៅពេលក្រោយ» ដូច្នេះហើយ បើទារកស្លាប់នៅពេលសម្រាលគឺមិនអាចធ្វើសន្តតិកម្មពីទ្រព្យសម្បត្តិរបស់ឪពុកបានទេ ហើយនៅពេលដែលកំពុងតែមានគភ៌ ម្តាយមិនអាចតំណាងឲ្យទារកក្នុងគភ៌ ហើយទាមទារឲ្យចែកមត៌កបាននោះទេ។

### គ. ទារកនៅក្នុងគភ៌ និង អច្ច័យទាន

ចំពោះអច្ច័យទាន ក៏ទទួលស្គាល់នូវសមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ក្នុងនាមជាករណីលើកលែងផងដែរ ហើយក្រមរដ្ឋប្បវេណីបានបញ្ញត្តថា «ទារកដែលនៅក្នុងគភ៌នាពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្តាំនោះបាន» (កថា.៣ មាត្រា ៩)។ មានន័យថា ឪពុកអាចធ្វើអច្ច័យទានទៅទារកមុនពេលមានកំណើត ក្នុងនាមជាអច្ច័លាភីបាន ហើយបើទារកនោះចាប់កំណើតនៅពេលក្រោយ ទារកនោះអាចធ្វើលទ្ធកម្មទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអច្ច័យទានបាន។

**ករណីសិក្សា**

X ជាប្ដី ហើយ Y ជាប្រពន្ធ។ Y មានគភ៌កូនរបស់ X ។ X បានទទួលមរណភាពដោយសារគ្រោះថ្នាក់ចរាចរណ៍។ តើ Y អាចតំណាងឲ្យទារកក្នុងគភ៌ ហើយទាមទារសំណងការខូចខាតបានឬទេ? (ប្រភព៖ យុត្តិសាស្ត្រតុលាការកំពូលនៅប្រទេសជប៉ុន)

ជាគោលការណ៍ រូបវន្តបុគ្គលទទួលបានសមត្ថភាពទទួលសិទ្ធិតាមរយៈការចាប់កំណើត ដូច្នេះទារកក្នុងគភ៌ គឺមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ ដោយកំរិតក្នុងករណី ៣ យ៉ាងគឺ ការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល សន្តតិកម្ម និង អច្ច័យទាន។ មានន័យថា នៅក្រោយពេលចាប់កំណើត ទារកក្នុងគភ៌អាចទាមទារសំណងការខូចខាតចំពោះចារីនៃគ្រោះថ្នាក់ចរាចរណ៍បាន។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា «បើទារកនោះមានកំណើតនៅពេលក្រោយ» អាចទាមទារសំណងការខូចខាតបាន ដូច្នេះហើយ យើងអាចពិចារណាបានថា នៅដំណាក់កាលមុនពេលមានកំណើត គឺមិនអាចទាមទារសំណងការខូចខាតបានទេ។ ដូចនេះ ក្នុងករណីសិក្សានេះ Y ដែលជាម្ដាយរបស់ទារកក្នុងគភ៌ មិនអាចតំណាងឲ្យទារកក្នុងគភ៌ ហើយទាមទារសំណងការខូចខាតបានទេ។

**១.៤ ពេលបញ្ចប់សមត្ថភាពទទួលសិទ្ធិ**

**១.៤.១ មរណភាព (មាត្រា ៨)**

យើងបានសិក្សាហើយថា ពេលចាប់ផ្ដើមនៃសមត្ថភាពទទួលសិទ្ធិ គឺនៅពេលមានកំណើត។ ចំណែកឯពេលបញ្ចប់សមត្ថភាពទទួលសិទ្ធិវិញ តើនៅពេលណា? ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា «រូបវន្តបុគ្គលបាត់បង់សមត្ថភាពទទួលសិទ្ធិនៅពេលមរណភាព» (មាត្រា ៨) ហើយបានបញ្ជាក់យ៉ាងច្បាស់ថា ពេលបញ្ចប់នៃសមត្ថភាពទទួលសិទ្ធិ គឺនៅពេលមរណភាព។

**១.៤.២ ការប្រកាសអំពីការបាត់ខ្លួន** (មាត្រា ៤១ ~ មាត្រា ៤៤)

ការប្រកាសអំពីការបាត់ខ្លួន គឺជាប្រព័ន្ធដែលចាត់ទុកថាបុគ្គលនោះបានទទួលមរណភាព ទៅលើទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋានជាដើម តាមរយៈនីតិវិធីដែលបានកំណត់ ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលនោះនៅរស់ ឬ ស្លាប់ក្នុងអំឡុងពេលកំណត់។ ក្នុងករណីដែលពុំមានដំណឹងរយៈពេលយូរថា បុគ្គលនោះនៅរស់ ឬ ស្លាប់ ទ្រព្យសម្បត្តិដែលបានបន្សល់ទុកនោះ ទោះដល់ពេលណាក៏ដោយ ក៏មិនអាចធ្វើសន្តតិកម្មបានទេ តែចាំបាច់ត្រូវមានអ្នកគ្រប់គ្រងបន្ត ហើយសហព័ទ្ធក៏មិនអាចរៀបអាពាហ៍ពិពាហ៍ម្ដងទៀតទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវប្រព័ន្ធការប្រកាសអំពីការបាត់ខ្លួននេះឡើង ដើម្បីអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិ និងសហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ម្ដងទៀតបាន។

**ក. និយមន័យនៃការប្រកាសអំពីការបាត់ខ្លួន**

ការប្រកាសអំពីការបាត់ខ្លួន គឺជាប្រព័ន្ធដែលចាត់ទុកថាបុគ្គលនោះបានទទួលមរណភាព ទៅលើទំនាក់ទំនងគតិយុត្តជុំវិញលំនៅដ្ឋានជាដើម តាមរយៈនីតិវិធីដែលបានកំណត់ ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលនោះនៅរស់ ឬ ស្លាប់ក្នុងអំឡុងពេលកំណត់។ ក្នុង

ករណីដែលពុំមានដំណឹងរយៈពេលយូរថា បុគ្គលនោះនៅរស់ ឬ ស្លាប់ ទ្រព្យសម្បត្តិដែលបានបន្សល់ទុកនោះ ទោះដល់ពេលណាក៏ដោយ ក៏មិនអាចធ្វើសន្តតិកម្មបានទេ តែចាំបាច់ត្រូវមានអ្នកគ្រប់គ្រងបន្ត ហើយសហព័ទ្ធក៏មិនអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវប្រព័ន្ធការប្រកាសអំពីការបាត់ខ្លួននេះឡើង ដើម្បីអាចធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិ និងសហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតបាន។

**ខ. លក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួន**

ការប្រកាសអំពីការបាត់ខ្លួនមាន ២ ប្រភេទគឺ ការបាត់ខ្លួនធម្មតា និង ការបាត់ខ្លួនពិសេស ហើយលក្ខខណ្ឌក៏ខុសគ្នាដែរ។ ករណីការប្រកាសអំពីការបាត់ខ្លួនធម្មតា នៅពេលមិនមានដំណឹងច្បាស់លាស់រយៈពេល ៥ឆ្នាំថា បុគ្គលដែលអវត្តមាននោះនៅរស់ ឬ ស្លាប់ តុលាការអាចប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន (កថា.១ មាត្រា ៤១)។ ឧទាហរណ៍៖ ករណីដែលមិនច្បាស់ពីដំណឹងរយៈពេលលើសពី ៧ឆ្នាំ អំពីប្តីដែលចាកចេញពីផ្ទះថានៅរស់ ឬ ស្លាប់ ប្រពន្ធអាចទាមទារឲ្យប្រកាសអំពីការបាត់ខ្លួនបាន។ ការបាត់ខ្លួនពិសេស គឺអនុវត្តទៅលើករណីដែលមិនច្បាស់ថាបុគ្គលដែលជួបប្រទះនឹងករណីគ្រោះថ្នាក់ជាដើម នៅរស់ ឬ ស្លាប់។ បុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឲ្យទទួលមរណភាព ហើយពុំមានដំណឹងថាបុគ្គលនោះនៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់នោះបានកន្លងផុតទៅ តុលាការអាចប្រកាសអំពីការបាត់ខ្លួនបាន តាមពាក្យសុំរបស់អ្នកដែលមានទំនាក់ទំនងផលប្រយោជន៍ដូចខាងលើ (កថា.២ មាត្រា ៤១)។

**គ. អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន**

នៅពេលប្រកាសអំពីការបាត់ខ្លួន អ្នកបាត់ខ្លួនត្រូវចាត់ទុកថាទទួលមរណភាពចំពោះទំនាក់ទំនងគតិយុត្តិជុំវិញលំនៅឋាន ឬ ទីសំណាក់ (មាត្រា ៤៣)។ មានន័យថា សន្តតិកម្មអាចចាប់ផ្តើម ហើយសហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀត។ ប៉ុន្តែ ត្រូវចាត់ទុកថាបានទទួលមរណភាពចំពោះតែទំនាក់ទំនងគតិយុត្តិនៅជុំវិញលំនៅឋានប៉ុណ្ណោះ មិនមែនដកហូតនូវសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលនោះទេ ដូច្នេះហើយបើបុគ្គលនោះនៅរស់ ហើយរស់នៅកន្លែងផ្សេង បុគ្គលនោះអាចធ្វើលទ្ធកម្មនូវសិទ្ធិ និង កាតព្វកិច្ចបាន ឧទាហរណ៍ថា បុគ្គលនោះបានបង្កើតកិច្ចសន្យា ក៏មានសុពលភាពដែរ។ ពេលដែលបង្កើតអនុភាពនៃការប្រកាសអំពីការបាត់ខ្លួន ករណីការបាត់ខ្លួនធម្មតាគឺអំឡុងពេលពេល ៥ឆ្នាំ ហើយករណីការបាត់ខ្លួនពិសេសគឺ ពេលគ្រោះថ្នាក់នោះបានកន្លងផុត។

### ឃ. អានុភាពនៃការលុបចោលការប្រកាសអំពីការបាត់ខ្លួន

ចុះបើករណីដែលអ្នកដែលបានប្រកាសថាបាត់ខ្លួន តាមពិតទៅគឺនៅរស់ ហើយត្រលប់មកទីលំនៅដើមវិញ តើនឹងក្លាយជាយ៉ាងណា? ករណីដែលបានប្រកាសអំពីការបាត់ខ្លួនហើយ តាមផ្លូវច្បាប់ត្រូវចាត់ទុកថាបានទទួលមរណភាព ដូច្នេះហើយ ទោះបីជាសាមីខ្លួនបានត្រលប់មកវិញក៏ដោយ ក៏អានុភាពនៃការប្រកាសអំពីការបាត់ខ្លួនមិនបាត់បង់អានុភាពនោះទេ។ ដើម្បីឲ្យអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនបាត់បង់អនុភាព ចាំបាច់ត្រូវធ្វើការលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបានបាត់ខ្លួននៅរស់ ឬមានការបញ្ជាក់ថាទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់ ក្នុងករណីការប្រកាសអំពីការបាត់ខ្លួនធម្មតា គឺអំឡុងពេល ៥ឆ្នាំ ហើយចំពោះការបាត់ខ្លួនពិសេស គឺអំឡុងពេល ១ឆ្នាំ ក្រោយពីគ្រោះថ្នាក់នោះ បានកន្លងផុត តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ (កថា.១ មាត្រា ៤៤)។ នៅពេលដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ត្រូវយកមកអនុវត្តដូចដែរការប្រកាសអំពីការបាត់ខ្លួននោះមិនមានតាំងពីដំបូង។ បើដូច្នេះ មានការព្រួយបារម្ភអំពីការបាត់បង់ផលប្រយោជន៍របស់បុគ្គលដែលបានធ្វើលទ្ធកម្មទ្រព្យសម្បត្តិដោយសារការប្រកាសអំពីការបាត់ខ្លួន បុគ្គលដែលធ្វើពាណិជ្ជកម្មជាមួយបុគ្គលធ្វើលទ្ធកម្មនោះ និង សហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ថ្មីក្រោយពីការប្រកាសអំពីការបាត់ខ្លួនជាដើម។ ដូចនេះ ក្រមរដ្ឋប្បវេណីបានបង្កើតឡើងនូវបញ្ញត្តិដើម្បីគ្រប់គ្រងទៅលើផលប្រយោជន៍ និង ការខាតបង់នេះ។ ដំបូង បុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះពីបុគ្គលដែលបាត់ខ្លួនដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន គឺត្រូវបាត់បង់សិទ្ធិដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែ បុគ្គលដែលធ្វើលទ្ធកម្មដោយសុចរិត គឺសងត្រឹមតែកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួននៅតែទទួលផលប្រយោជន៍ប៉ុណ្ណោះ (កថា.២ មាត្រា ៤៤)។ ពាក្យថាបុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះដែលប្រើប្រាស់នៅកន្លែងនេះ គឺជាសន្តតិជន ឬ អ្នកទទួលប្រាក់ធានារ៉ាប់រងអាយុជីវិតជាដើម។ <u>ឧទាហរណ៍</u> ក្នុងករណីដែលសន្តតិជនដែលធ្វើសន្តតិកម្មទៅលើទ្រព្យសម្បត្តិរបស់បុគ្គលដែលបានបាត់ខ្លួន ដោយសារការប្រកាសអំពីការបាត់ខ្លួន មិនបានដឹងថា ការប្រកាសអំពីការបាត់ខ្លួននោះ ផ្ទុយពីការពិត គ្រាន់តែសងទ្រព្យសម្បត្តិដែលនៅសល់គឺគ្រប់គ្រាន់ ហើយមិនមានករណីយកិច្ចក្នុងការសងទ្រព្យសម្បត្តិដែលបានប្រើប្រាស់ពីមុននោះទេ។ ប៉ុន្តែ ការប្រើប្រាស់ដើម្បីថ្លៃជីវភាព ចំណែកដែលបានចំណាយចេញទៅត្រូវបានពិចារណាថា ជាផលប្រយោជន៍ដែលនៅសល់។ បន្ទាប់ ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា «អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពលដោយសារការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ (កថា.៣ មាត្រា ៤៤)។ <u>ឧទាហរណ៍</u> ករណីដែលប្តី X បានទទួលការប្រកាសអំពីការបាត់ខ្លួន ហើយប្រពន្ធ Y ក៏បានលក់ដីដែលទទួលពីសន្តតិកម្មទៅឲ្យ Z ក្រោយមក ការប្រកាសអំពីការបាត់ខ្លួន X ត្រូវបានលុបចោល ហើយករណីនេះ

ទាំង Y និង Z មិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននេះផ្ទុយនឹងការពិតនោះទេ ករណីបែបនេះ X មិនអាចទាមទារឲ្យ Z ប្រគល់ដីត្រលប់មកវិញបានទេ។ ចំពោះករណីបែបនេះ តើចាំបាច់ត្រូវឲ្យទាំង Y និង Z ត្រូវតែសុចរិតទាំងពីរ ឬគ្រាន់តែ Z សុចរិតគឺគ្រប់គ្រាន់នោះ មានចំណុចដែលត្រូវធ្វើការបកស្រាយ។ យើងអាចពិចារណាថា ប្រសិនបើផ្តោតសំខាន់ទៅលើផលប្រយោជន៍របស់ X ដែលត្រូវបានប្រកាសអំពីការបាត់ខ្លួន គឺតម្រូវឲ្យទាំង Y និង Z សុចរិត ប៉ុន្តែ ប្រសិនបើផ្តោតសំខាន់ទៅលើសុវត្ថិភាពនៃពាណិជ្ជកម្ម គឺគ្រាន់តែ Z សុចរិតគ្រប់គ្រាន់ហើយ។ ប៉ុន្តែ នៅក្នុងយុត្តិសាស្ត្ររបស់ប្រទេសជប៉ុន គឺតម្រូវឲ្យ ទាំង Y និង Z សុចរិត មានន័យថា មិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននោះផ្ទុយពីការពិតទេ។ បន្ទាប់ ក្រមរដ្ឋប្បវេណីបានបញ្ញត្តទាក់ទងនឹងអានុភាពនៃអាពាហ៍ពិពាហ៍ថា «ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ (កថា.៤ មាត្រា ៤៤)។ <u>ឧទាហរណ៍</u> ក្រោយពីប្តី X ត្រូវបានប្រកាសអំពីការបាត់ខ្លួន ប្រពន្ធ Y បានរៀបអាពាហ៍ពិពាហ៍ជាថ្មីជាមួយ Z ក្រោយមក ករណីដែលការប្រកាសអំពីការបាត់ខ្លួន X ត្រូវបានលុបចោល អាពាហ៍ពិពាហ៍រវាង X និង Y ត្រូវរលាយ ហើយមិនមានឥទ្ធិពលដល់អានុភាពនៃអាពាហ៍ពិពាហ៍របស់ Y និង Z ទេ។ ករណីនេះ ទោះបីជា Y និង Z សុចរិត ឬ ទុច្ចរិតក៏ដោយ ក៏អានុភាពនៃអាពាហ៍ពិពាហ៍ក្រោយមានអានុភាព។

**ករណីសិក្សា**

X ត្រូវបានប្រកាសអំពីការបាត់ខ្លួន ហើយ ប្រពន្ធ Y បានធ្វើសន្តតិកម្មដីរបស់ X ។ Y បានធ្វើអនុប្បទានដីនោះទៅ A ហើយ A បានធ្វើអនុប្បទានបន្តទៅ B ហើយបានផ្ទេរការចុះបញ្ជី។ ក្រោយមក ការប្រកាសអំពីការបាត់ខ្លួន X ត្រូវបានលុបចោល។ តើ X អាចទាមទារឲ្យ B ប្រគល់ដីមកវិញបាន ឬទេ? ដោយសិក្សាបែងចែកករណី A B សុចរិត និង ទុច្ចរិត។ ប៉ុន្តែ Y មិនបានដឹងថាការប្រកាសអំពីការបាត់ខ្លួននេះផ្ទុយពីការពិតនោះទេ។

នៅពេលដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ត្រូវអនុវត្តដូចដែលការប្រកាសអំពីការបាត់ខ្លួននោះមិនមានតាំងពីដំបូង ប៉ុន្តែ មុនពេលលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន សកម្មភាពដែលបានធ្វើឡើងដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន ពុំទទួលឥទ្ធិពលពីការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ (កថា.៣ មាត្រា ៤៤)។ តើតម្រូវឲ្យភាគីទាំងសងខាងនៃកិច្ចសន្យាសុចរិត ឬ គ្រាន់តែបុគ្គលដែលធ្វើលទ្ធកម្មនៃសិទ្ធិនោះសុចរិតប៉ុណ្ណោះគ្រប់គ្រាន់ហើយ គឺមានចំណុចដែលត្រូវបកស្រាយ ប៉ុន្តែ បើឈរលើការបកស្រាយខាងដើម ក្នុងករណីដែល A ទុច្ចរិត ទោះបីជា B សុចរិត ឬ ទុច្ចរិតក៏ដោយ ក៏ X អាចទាមទារចំពោះ B ឲ្យប្រគល់ដីមកវិញបាន។ ម៉្យាងវិញទៀត បើឈរលើការបកស្រាយខាងក្រោយ ប្រសិនបើ B សុចរិត ទោះបីជា A សុចរិត ឬ ទុច្ចរិតក៏ដោយ ក៏ X មិនអាចទាមទារឲ្យ B ប្រគល់ដីមកវិញបានទេ។ ចុះបើ A សុចរិត តែ B ទុច្ចរិត

វិញយ៉ាងម៉េចដែរ? ក្នុងករណីនេះ ទោះបីជាឈរលើការបកស្រាយខាងដើមក៏ដោយ បើ A និង Y សុចរិត នៅពេលនោះ A ត្រូវបានការពារ យើងអាចបកស្រាយបានថាទោះបីជាអ្នកទទួលបន្តក្រោយទុច្ចរិតក៏ដោយ ក៏ត្រូវការពារដែរ (គោលការណ៍សមាសភាពដាច់ខាត)។ ប្រសិនបើទទួលស្គាល់ការទាមទារឲ្យ B ប្រគល់ត្រលប់ ជាហេតុធ្វើឲ្យ B មានសិទ្ធិទាមទារការទទួលខុសត្រូវឲ្យធានាចំពោះ A ដែលសុចរិត ។ ទស្សនៈភាគច្រើននៅជប៉ុន អនុវត្តតាមគោលការណ៍សមាសភាពដាច់ខាត។

### **១.៤.៣ ការសន្មតថាបានទទួលមរណភាពព្រមពេលជាមួយគ្នា**

ប្រសិនបើមិនដឹងថាទទួលមរណភាពមុន ឬ ក្រោយទេនឹងទៅជាយ៉ាងណា? ឧទាហរណ៍ ករណីដែល ប្តី X និង កូន Z បានទទួលមរណភាពនៅពេលជាមួយគ្នា ក្នុងគ្រោះថ្នាក់ចរាចរណ៍ ហើយករណីដែល X មានប្រពន្ធ Y និង ឪពុក A ប្រសិនបើ ប្តី X ទទួលមរណភាពមុន នោះប្រពន្ធ Y និង កូន Z នឹងក្លាយទៅជាសន្តតិជន ហើយ Y នឹងធ្វើសន្តតិកម្មទ្រព្យសម្បត្តិរបស់កូន Z ដូច្នេះ ប្រពន្ធ Y នឹងធ្វើលទ្ធកម្មទ្រព្យសម្បត្តិទាំងអស់។ ម៉្យាងវិញទៀត បើកូន Z ទទួលមរណភាពមុន នោះប្រពន្ធ Y និង ឪពុក A នឹងក្លាយជាសន្តតិជន។

#### **ក. លក្ខខណ្ឌ**

ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា «ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ» (មាត្រា ៤៥)។ មានន័យថា លក្ខខណ្ឌ គឺភាពមិនច្បាស់លាស់នៃទំនាក់ទំនងមុនក្រោយនៃការទទួលមរណភាព។ ឧទាហរណ៍ ទោះបីជាទទួលមរណភាពដោយសារគ្រោះថ្នាក់ក្នុងពេលជាមួយគ្នាក៏ដោយ ប្រសិនបើអាចបញ្ជាក់អំពីទំនាក់ទំនងមុននិងក្រោយនៃការទទួលមរណភាព នោះសន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកទៅលើទំនាក់ទំនងនោះ។

#### **ខ. អានុភាព**

ករណីដែលមិនច្បាស់លាស់អំពីទំនាក់ទំនងមុននិងក្រោយនៃការទទួលមរណភាពទេ ត្រូវយកមាត្រា ៤៥ មកអនុវត្ត។ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីអនុភាពនោះថា «ចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា»។ សន្តតិកម្ម គឺមានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្មប៉ុណ្ណោះ ទើបអាចទទួលសន្តតិកម្មបាន (កថា.១ មាត្រា ១១៤៩)។ ហេតុនេះ ជនដែលបានសន្មតថា បានទទួលមរណភាពព្រមពេលជាមួយគ្នា ដោយផ្អែកលើមាត្រា ៤៥ មិនអាចក្លាយជាសន្តតិជនបានទេ។ មានន័យថា នៅចន្លោះនៃបុគ្គលទាំងពីរដែលបានសន្មតថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ដោយផ្អែកលើមាត្រា ៤៥ មិនបង្កើតឲ្យមាននូវសន្តតិកម្មនោះទេ។

### **ករណីសិក្សា**

X មានប្រពន្ធ Y កូន Z និង ឪពុក A។ X និង Z បានទទួលមរណភាពក្នុងគ្រោះថ្នាក់ចរាចរណ៍ជាមួយគ្នា ហើយមិនច្បាស់លាស់អំពីទំនាក់ទំនងមុននឹងក្រោយនៃការទទួលមរណភាព

របស់បុគ្គលទាំងពីរនេះទេ។ ចូរបកស្រាយ តើទ្រព្យសម្បត្តិរបស់ X នឹងត្រូវធ្វើសន្តតិកម្មដោយរបៀបណា?

ក្នុងករណីសិក្សានេះ គឺមិនមានភាពច្បាស់លាស់នៃទំនាក់ទងមុននិងក្រោយនៃការទទួលមរណភាពរបស់ Z និង X ទេ ដូច្នេះហើយ ផ្អែកតាមមាត្រា ៤៥ ត្រូវសន្មតថាបុគ្គលទាំងពីរបានទទួលមរណភាពព្រមពេលជាមួយគ្នា។ ដូច្នេះ X មិនអាចទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិរបស់ Z បានទេ។ ដូចនេះ ទ្រព្យសម្បត្តិរបស់ X ត្រូវធ្វើសន្តតិកម្មដោយប្រពន្ធ Y និង ឪពុក A (យោង មាត្រា ១១៥៩ និង កថា.១ កថា.២ នៃមាត្រា ១១៦១)។

# ក្រុមការងារ

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង
# វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សិក្ខាសាលាលើកទី ៣
## ស្តីពី

# លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦

# សិក្ខាសាលាស្តីពី

## លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

ក្រុមការងារ
សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

កាលបរិច្ឆេទៈថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦

## មាតិកា

- ទិដ្ឋភាពទូទៅ
- ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ
- ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (មាត្រា ១៩៣)
- ៣. អនុប្បទាននូវវត្ថុលួច ឬបាត់ (មាត្រា ១៩៤)
- ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (មាត្រា១៩៥)
- ៥. អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត (មាត្រា ១៩៦)
- ៦. ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ (មាត្រា១៩៨)
- ៧. ការកែច្នៃចលនវត្ថុ (មាត្រា១៩៩)
- ៨. អានុភាពនៃឧបាគមន៍នៃចលនវត្ថុ (មាត្រា ២០០)
- ៩. ឧបាគមន៍ និងសិទ្ធិទាមទារប្រាក់សំណង (មាត្រា ២០១)




## និដ្ឋភាពទូទៅ

- និយមន័យ លទ្ធកម្មនៃកម្មសិទ្ធិ
  - ការទទួលបាន។
  - ការបានឡើងជាម្ចាស់សិទ្ធិនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួនក្តី ដោយការទិញ ឬដោយការដូរក្តី។

## ទិដ្ឋភាពទូទៅ

- ជាធម្មតា លទ្ធកម្មនៃកម្មសិទ្ធិ អាចត្រូវបានគេធ្វើឡើងតាមច្រើនរបៀប ហើយអ្វីដែលគេឃើញកើតមានជាញឹកញាប់ ដូចជា ការធ្វើលទ្ធកម្មដោយកិច្ចសន្យាលក់ទិញ ឬកិច្ចសន្យាប្រទានកម្ម ជាអាទ៍។
  - ឧទាហរណ៍: ការទិញវត្ថុពីហាងលក់ទំនិញនៅទីផ្សារក្នុងជីវភាពប្រចាំថ្ងៃ និងការទទួលអំណោយផ្សេងៗពីក្រុមគ្រួសារ ឬមិត្តភក្តិ នៅថ្ងៃខួបកំណើត។

## ទិដ្ឋភាពទូទៅ

- មូលហេតុនៃលទ្ធកម្ម (<u>មាត្រា ១៨៧</u>)
  - កិច្ចសន្យា
  - សន្តតិកម្ម
  - ហេតុដែលបានកំណត់ក្នុងផ្នែកទី៤ (លទ្ធកម្មនៃកម្មសិទ្ធិ)
- ប្រភេទនៃមូលហេតុនៃលទ្ធកម្ម
  - លទ្ធកម្មតាំងពីដំបូង
  - លទ្ធកម្មបន្ត

## លទ្ធកម្មតាំងពីដំបូង

- លទ្ធកម្មនៃសិទ្ធិប្រត្យក្សមួយថ្មីដែលមានរួចហើយ ឬអាចនិយាយបានថា កម្មសិទ្ធិករថ្មី បានធ្វើលទ្ធកម្មសិទ្ធិលើចលនវត្ថុដោយឯករាជ្យ មិនទទួលបន្តពីសិទ្ធិរបស់អ្នកផ្សេងឡើយ។
- ឧទាហរណ៍
  - លទ្ធកម្មកម្មសិទ្ធិដោយសុចរិត (ម.១៩៣) ឬ ដោយអាជ្ញាយុកាលជាដើម (ម.១៩៥)
  - ករណី បុគ្គលម្នាក់ចាប់ផ្តើមកាន់កាប់ចលនវត្ថុដែលមិនមែនជា កម្មសិទ្ធិរបស់បុគ្គលណាម្នាក់ផ្សេងទៀត អ្នកកាន់កាប់នោះ អាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុនោះ។ (ម. ១៨៨)

## លទ្ធកម្មបន្ត

- ជាលទ្ធកម្មនៃសិទ្ធិប្រត្យក្សមួយដែលមានរួចហើយ ឬអាចនិយាយបានថា កម្មសិទ្ធិករក្រោយ ទទួលបាននូវសិទ្ធិលើចលនវត្ថុបន្តពីសិទ្ធិរបស់កម្មសិទ្ធិករមុន។
- ឧទាហរណ៍ ការធ្វើលទ្ធកម្មកម្មសិទ្ធិតាមរយៈកិច្ចសន្យាលក់ទិញ ឬសន្តតិកម្មជាដើម។

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ

- ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាព តាមការព្រមព្រៀងរវាងភាគី (មាត្រា១៣៣)។

ឧទាហរណ៍ នៅក្នុងករណីកិច្ចសន្យាលក់ទិញកង់ នៅពេល អ្នកលក់ A និយាយថាចង់លក់ ហើយអ្នកទិញ B និយាយថាចង់ទិញ នាំឲ្យកម្មសិទ្ធិលើកង់ផ្ទេរពីអ្នកលក់ A ទៅអ្នកទិញ B។

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)



## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)

- កករណីអ្នកលក់ A បានលក់កង់ ១ ទៅឲ្យមនុស្ស ២ នាក់ គឺ B និង C តើរវាង B និង C មួយណាធ្វើលទ្ធកម្មកម្មសិទ្ធិលើកង់?

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)



## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)

➨ អនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុទៅបុគ្គលណាមួយ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានផ្ទេរការកាន់កាប់ចលនវត្ថុទៅបុគ្គលនោះទេ (មាត្រា១៣៩(២))។

➨ ដូច្នេះ ក្នុងចំណោម B និង C អ្នកដែលបានទទួលការផ្ទេរការកាន់កាប់កង់ពី A នឹងអាចធ្វើលទ្ធកម្មកម្មសិទ្ធិបាន។

➨ នៅក្នុងការផ្ទេរការកាន់កាប់ មានវិធី ៤ យ៉ាង (មាត្រា២២៩)។

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)

➨ ប្រភេទទាំង ៤ យ៉ាងនៃការផ្ទេរការកាន់កាប់

❖ ការប្រគល់ដោយជាក់ស្តែង (មាត្រា២២៩ កថាខណ្ឌទី១)

❖ ការប្តូរលក្ខណៈនៃការកាន់កាប់ (មាត្រា២២៩ កថាខណ្ឌទី២)

❖ ការប្រគល់ដោយសង្ខេប (មាត្រា២២៩ កថាខណ្ឌទី៣)

❖ ការផ្ទេរការកាន់កាប់ដោយបញ្ជា (មាត្រា២២៩ កថាខណ្ឌទី៤)

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)

- ការកាន់កាប់ត្រូវបានផ្ទេរ ដោយការប្រគល់វត្ថុកាន់កាប់។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការប្រគល់ដោយជាក់ស្តែង (មាត្រា ២២៩(១))។

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)




(ការប្រគល់ដោយជាក់ស្តែង)

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)

- ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់ដោយជាក់ស្តែង។ ក្នុងករណីនេះ អនុប្បទានិកនៃការកាន់កាប់ ត្រូវទទួលការកាន់កាប់ដោយប្រយោល តាមរយៈអនុប្បទាយី។ ការផ្ទេរការកាន់កាប់ បែបនេះ ហៅថា ការប្តូរលក្ខណៈនៃការកាន់កាប់។ (មាត្រា ២២៩(២))។

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)




(ការប្តូរលក្ខណៈនៃការកាន់កាប់)

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)

- បើអ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះ តាមការជាក់ស្តែង ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ។ ដោយសារហេតុនេះ អនុប្បទាយីនៃការកាន់កាប់ ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មានតាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថាការប្រគល់ដោយសង្ខេប។ (មាត្រា២២៩(៣))។

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)




(ការប្រគល់ដោយសង្ខេប)

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)

- អ្នកកាន់កាប់ដោយប្រយោល តាមរយៈអ្នកដទៃ អាចផ្ទេរការកាន់កាប់ទៅឲ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយនឹងតតិយជន និង ដោយការជូនដំណឹងអំពីហេតុនោះ ទៅឲ្យអ្នកកាន់កាប់ដោយចំពោះ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការផ្ទេរការកាន់កាប់ដោយបញ្ជា។ (មាត្រា ២២៩(៤))។

## ១. លទ្ធកម្មបន្តនៃកម្មសិទ្ធិលើចលនវត្ថុ (ត)




(ការផ្ទេរការកាន់កាប់ដោយបញ្ជា)

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (មាត្រា១៩៣)

- ក្នុងករណីបានទិញចលនវត្ថុពីបុគ្គលដែលមិនមានកម្មសិទ្ធិ អ្នកទិញមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះបានទេ។ ប៉ុន្តែ ប្រសិនបើអ្នកទិញ មិនត្រូវបានការពារទាំងស្រុងទេ អ្នកណាក៏ដោយ នឹងមិនអាចទិញចលនវត្ថុដោយភ័យខ្លាចបានទេ។ ហេតុនេះ លទ្ធកម្មដោយសុចរិត គឺជាប្រព័ន្ធដើម្បីការពារអ្នកទិញ នៅក្នុងករណីមួយចំនួន។

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)

- ប្រសិនបើលទ្ធកម្មដោយសុចរិតត្រូវបានបង្កើតឡើង កម្មសិទ្ធិករពិតប្រាកដ នឹងបាត់បង់កម្មសិទ្ធិលើចលនវត្ថុនោះ។ មានន័យថា លទ្ធកម្មដោយសុចរិត គឺជាប្រព័ន្ធដែលនាំមកនូវការលំបាកដល់កម្មសិទ្ធិករពិតប្រាកដ។ ដូច្នេះ ការសម្រួលផលប្រយោជន៍របស់កម្មសិទ្ធិករពិតប្រាកដ និង ផលប្រយោជន៍របស់អ្នកទិញ មានសារៈសំខាន់។

ហេតុនេះ មាត្រា១៩៣ បញ្ញត្តនូវលក្ខខណ្ឌដ៏តឹងរ៉ឹង ដើម្បីធ្វើលទ្ធកម្មដោយសុចរិត។

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)




## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)

- ទោះជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ ឲ្យតែអនុប្បទានិក បានចាប់ផ្ដើមកាន់កាប់ចលនវត្ថុនោះដោយផ្អែកលើកិច្ចសន្យាអនុប្បទានកម្មសិទ្ធិ ដែលមានសុពលភាពដោយសុចរិត និងគ្មានកំហុស នោះអនុប្បទានិកត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ លើកលែងតែអនុប្បទានិកមិនបានចាប់ផ្ដើមកាន់កាប់ចលនវត្ថុនោះ ឬក្នុងករណីដែលអនុប្បទាយីនៅតែបន្តកាន់កាប់ចលនវត្ថុនោះ ដោយចំពោះ។ (<u>មាត្រា ១៩៣</u>)

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)

<u>ដើម្បីធ្វើលទ្ធកម្មដោយសុចរិតលើចលនវត្ថុគេត្រូវគោរពលក្ខខណ្ឌ៖</u>

- ចលនវត្ថុ
- កិច្ចសន្យាអនុប្បទានកម្មសិទ្ធិលើចលនវត្ថុដែលមានសុពលភាព
- អនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុ
- សុចរិត និងគ្មានកំហុស
- ទទួលបាននូវការប្រគល់ចលនវត្ថុ

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)



## ករណីសិក្សា




➨ <u>ករណីសិក្សាទី១</u>

A បានជួលកង់មួយគ្រឿងឲ្យទៅ B។ B បានទុកកង់នោះជារបស់ខ្លួន ហើយលក់កង់នោះឲ្យទៅ C និងបានប្រគល់រួចរាល់។ C បានជឿជាក់ថា B ជាកម្មសិទ្ធិករ ហើយគ្មានកំហុសក្នុងការជឿជាក់ទេ។ តើ A អាចទាមទារ C ឲ្យប្រគល់កង់នោះត្រឡប់មកវិញបានដែរ ឬទេ?

<u>ចម្លើយ?</u>

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)



## ករណីសិក្សា




➨ <u>ករណីសិក្សាទី២</u>

A បានលក់កង់មួយគ្រឿងឲ្យទៅ B ហើយបានធ្វើការប្រគល់នូវកង់នោះរួចរាល់ដែរ។ នៅពេលនោះ A គឺជាអនីតិជន ហើយក៏ពុំមានការយល់ព្រមពីអ្នកមានអំណាចមេបាដែរ។ ក្រោយមក អ្នកមានអំណាចមេបាលើ A បានលុបចោលកិច្ចសន្យាលក់ទិញកង់នោះ ហើយទាមទារឲ្យ B ប្រគល់កង់មកវិញ។ តើ B អាចអះអាងអំពីលទ្ធកម្មដោយសុចរិតលើកង់បានដែរ ឬទេ? <u>ចម្លើយ?</u>

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)



## ករណីសិក្សា

- ករណីសិក្សាទី៣

B បានទិញកង់មួយគ្រឿងពី A ហើយបានឲ្យ A បន្តគ្រប់គ្រងកង់នោះដដែល។ A បានទុកកង់នោះជារបស់ខ្លួន ហើយបានលក់ឲ្យទៅ C ប៉ុន្តែ C ក៏បានឲ្យ A បន្តធ្វើការកាន់កាប់កង់នោះដែរ។ នៅពេលទិញកង់នោះ C បានជឿជាក់ថា A គឺជាកម្មសិទ្ធិករនៃកង់នោះ ហើយគ្មានកំហុសក្នុងការជឿជាក់ទេ។ តើ C អាចធ្វើលទ្ធកម្មកម្មសិទ្ធិកង់នោះបានដែរ ឬទេ? <u>ចម្លើយ?</u>



## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)




## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)

- "អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និង គ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាប់ដោយចំពោះ (មាត្រា១៩៣)។"

## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)




## ២. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (ត)

➨ ការផ្ទេរការកាន់កាប់ ដែលជាលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិត

○ ❖ ការប្រគល់ដោយជាក់ស្តែង

✕ ❖ ការប្តូរលក្ខណៈនៃការកាន់កាប់

○ ❖ ការប្រគល់ដោយសង្ខេប

○ ❖ ការផ្ទេរការកាន់កាប់ដោយបញ្ជា

(២២៩)

## ៣. អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់ (មាត្រា១៩៤)

- ប្រសិនបើកង់របស់អ្នកត្រូវបានចោរលួច ហើយមានបុគ្គលណាម្នាក់ បានធ្វើលទ្ធកម្មដោយសុចរិតទៅលើកង់នោះ នោះអ្នកនឹងពិតជាមានអារម្មណ៍សោកសៅជាមិនខាន។ ក្នុងករណីបែបនេះ ចាំបាច់ត្រូវការពារអ្នក ដែលជាកម្មសិទ្ធិករពិតប្រាកដ ។ ហេតុនេះ មាត្រា១៩៤ នៃក្រមរដ្ឋប្បវេណី បញ្ញត្តពីករណីលើកលែងនៃលទ្ធកម្មដោយសុចរិត អំពីវត្ថុលួច ឬ វត្ថុបាត់។
- ត្រង់ចំណុចនេះ តុល្យភាពនៃផលប្រយោជន៍របស់កម្មសិទ្ធិករពិតប្រាកដ និង ផលប្រយោជន៍របស់អ្នកទិញ ក៏មានសារៈសំខាន់ផងដែរ។

## ៣. អនុប្បទាននូវវត្ថុលួច ឬបាត់ (ត)

មានករណីលើកលែងមួយចំនួនចំពោះវត្ថុលួច ឬ វត្ថុដែលបាត់៖

ក. ករណីដែលកម្មវត្ថុគឺជាវត្ថុលួច ឬវត្ថុបាត់ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់នោះ អាចទាមទារចំពោះជនដែលបានធ្វើលទ្ធកម្មដោយសុចរិតនោះ ឲ្យសងវត្ថុនោះមកវិញបាន

- ចំពោះភាគីម្ខាងទៀតដែលត្រូវបានគេទាមទារ មិនមែនកម្រិតត្រឹមតែអ្នកដែលធ្វើលទ្ធកម្ម ដោយសុចរិតពីដំបូងនោះទេ គឺរាប់បញ្ចូលទាំងអ្នកដែលធ្វើលទ្ធកម្មដោយសុចរិតបន្តបន្ទាប់ ផងដែរ។
- ចំពោះភាគីដែលមានសិទ្ធិទាមទារឲ្យសងវិញ គឺត្រូវបានកម្រិតត្រឹមជនរងគ្រោះនៃវត្ថុដែលត្រូវបានលួច ឬម្ចាស់វត្ថុដែលបាត់តែប៉ុណ្ណោះ។ មានន័យថា ចាំបាច់ការបាត់បង់ការកាន់កាប់នោះ ត្រូវតែផ្ទុយពីឆន្ទៈរបស់ម្ចាស់សិទ្ធិដើម ហើយក្នុងករណីដែលម្ចាស់សិទ្ធិដើមបានបាត់បង់នូវការកាន់កាប់វត្ថុនោះ ដោយការឆបោក ការបន្លំ ឬ ការគំរាមកំហែង មិនអាចអនុវត្តមាត្រានេះបានទេ។

## ៣. អនុប្បទាននូវវត្ថុលួច ឬបាត់ (ត)

ខ. ទោះជាយ៉ាងណាក៏ដោយ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់នោះ ត្រូវធ្វើការទាមទារ ក្នុងអំឡុងពេល ២ឆ្នាំ គិតចាប់ពីពេលបាត់ ឬពេលត្រូវបានលួច។ (<u>មាត្រា១៩៤(១)</u>)

## ៣. អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់ (ត)



## ៣. អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់ (ត)

- ឧទាហរណ៍ អ្នកបានទិញកង់ចាស់នៅហាងលក់កង់ ដែលនៅជិតផ្សារអូឬស្សី។ ប៉ុន្តែ នៅតាមផ្លូវ មានបុគ្គលណាម្នាក់បាននិយាយថា កង់នេះ ជាកង់ដែលចោរលួចពីខ្ញុំ ហេតុនេះសូមប្រគល់មកឲ្យខ្ញុំវិញ។ តើអ្នកយល់ព្រមដែរឬទេ? ក្នុងករណីនេះ គឺត្រូវការពារអ្នកទិញ។ ដោយសារតែមានករណីនេះ ទើបមានបញ្ញត្តនៅក្នុងមាត្រា១៩៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។
- ត្រង់ចំណុចនេះ គុល្យភាពនៃផលប្រយោជន៍របស់កម្មសិទ្ធិករពិតប្រាកដ និង ផលប្រយោជន៍របស់អ្នកទិញ ក៏មានសារៈសំខាន់ផងដែរ។

## ៣. អនុបទាននូវវត្ថុលួច ឬបាត់ (ត)

គ. ក្នុងករណីដែលអ្នកធ្វើលទ្ធកម្មដោយសុចរិតនោះ បានទិញដោយសុចរិត នូវវត្ថុដែលបានបាត់ ឬ វត្ថុដែលលួចនោះតាមរយៈការលក់ដេញថ្លៃ ឬ នៅទីផ្សារសាធារណៈ ឬ ពីពាណិជ្ជករ ឬ អាជីវករដែលលក់វត្ថុប្រភេទដូចគ្នា នោះជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់មិនអាចទាមទារ ឲ្យសងវត្ថុនោះមកវិញបានទេ ប្រសិនបើមិនសងថ្លៃលក់ទៅឲ្យអ្នកដែលបានធ្វើលទ្ធកម្មដោយសុចរិតនោះ។ (មាត្រា១៩៤-២)

## ៣. អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់ (ត)




## ៣. អនុប្បទាននូវវត្ថុលួច ឬបាត់ (ត)

ឧទាហរណ៍ លោក A បានបាត់កង់ ហើយលោក B បានលួចកង់របស់លោក A ហើយយកទៅលក់ឲ្យលោក C ដែលជាអាជីវករលក់កង់។ លោក D បានទិញកង់នោះ ពីលោក C ក្នុងតម្លៃ ៤០០ដុល្លា។ បើយោងតាមមាត្រា១៩៤(២) ប្រសិនបើលោក A មិនបង់ប្រាក់ឲ្យទៅលោក D ចំនួន ៤០០ដុល្លារជាមុនទេ គាត់មិនអាចទាមទារឲ្យប្រគល់កង់នោះមកវិញបានទេ។

## ៣. អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់ (ត)




## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (មាត្រា១៩៥)

- អាជ្ញាយុកាលនៃលទ្ធកម្ម គឺជាប្រព័ន្ធដែលធ្វើលទ្ធកម្មកម្មសិទ្ធិនៃវត្ថុនោះ ក្នុងករណីបុគ្គលដែលមិនមែនជាកម្មសិទ្ធិករ បានបន្តការកាន់កាប់វត្ថុ ក្នុងអំឡុងពេលដែលបានកំណត់។

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)




## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

➨ ប្រសិនបើអាជ្ញាយុកាលនៃលទ្ធកម្មបានបង្កើតឡើង នោះអ្នកកាន់កាប់នឹងមានអារម្មណ៍សប្បាយរីករាយ ដោយសារតែអាចធ្វើលទ្ធកម្មកម្មសិទ្ធិបាន ប៉ុន្តែកម្មសិទ្ធិករពិតប្រាកដនឹងបាត់បង់កម្មសិទ្ធិ ហេតុនេះកម្មសិទ្ធិករពិតប្រាកដ នឹងមានអារម្មណ៍លំបាក។ ដូច្នេះ ការសម្រួលផលប្រយោជន៍របស់កម្មសិទ្ធិករពិតប្រាកដ និង ផលប្រយោជន៍របស់អ្នកកាន់កាប់ មានសារៈសំខាន់។

ហេតុនេះ មាត្រា១៩៥ នៃក្រមរដ្ឋប្បវេណី បញ្ញត្តនូវលក្ខខណ្ឌដ៏តឹងរ៉ឹង អំពីអាជ្ញាយុកាលនៃលទ្ធកម្មលើចលនវត្ថុ។

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)




## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

- លក្ខខណ្ឌអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ អាចមានលក្ខណៈខុសគ្នាដោយផ្អែកទៅអត្ថិភាព ឬនត្ថិភាពនៃភាពសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមការកាន់កាប់។
- ករណីមិនមែនជាជនសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមការកាន់កាប់ (មាត្រា ១៩៥(១)) ៖
  - ក. ត្រូវកាន់កាប់វត្ថុនោះក្នុងរយៈពេល ១០ឆ្នាំ
  - ខ. ត្រូវមានឆន្ទៈយកធ្វើជាកម្មសិទ្ធិ
  - គ. ត្រូវធ្វើឡើងដោយសន្តិវិធី
  - ឃ. ការកាន់កាប់នោះត្រូវមានការដឹងឮជាសាធារណៈ

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

- សុចរិត មានន័យថា ការមិនដឹងថាចលនវត្ថុនោះ មិនមែនជារបស់ខ្លួនឯង។
- គ្មានកំហុស មានន័យថា មិនមានកំហុសអំពីការមិនដឹង។

ដូច្នេះ ការមិនមែនជាជនសុចរិត និងគ្មានកំហុស មានន័យថា ជននោះបានដឹងថាចលនវត្ថុនោះ មិនមែនជារបស់ខ្លួនឯង ឬ ករណីដែលមិនដឹងដោយសារមានកំហុស។

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

**មានឆន្ទៈយកជាកម្មសិទ្ធិ**
មានន័យថា ត្រូវមានការគិតថា ខ្លួនមានកម្មសិទ្ធិ។

**សន្តិវិធី**
មាន័យថា មិនមែនជាដកហូតការកាន់កាប់ដោយហិង្សាទេ គឺត្រូវធ្វើលទ្ធកម្មនូវការកាន់កាប់ដោយសន្តិភាព។

**ដឹងឮជាសាធារណៈ**
មានន័យថា មិនមែនជាការកាន់កាប់ដោយសម្ងាត់ចំពោះមនុស្សដែលនៅជុំវិញទេ គឺត្រូវកាន់កាប់ដោយថ្លៃថ្នូរ ដែលអាចឲ្យមនុស្សនៅជុំវិញដឹងឮបាន។

ករណីទុច្ចរិត ឬ មានកំហុស
អំឡុងពេលអាជ្ញាយុកាល ១០ឆ្នាំ



អ្នកកាន់កាប់

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

➨ករណីសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមការកាន់កាប់ (មាត្រា ១៩៥(២)) ៖

ក. ត្រូវកាន់កាប់ក្នុងរយៈពេល ៥ឆ្នាំ នូវវត្ថុនោះ

ខ. ត្រូវមានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិ

គ. ត្រូវធ្វើឡើងដោយសន្តិវិធី

ឃ. ការកាន់កាប់នោះត្រូវមានការដឹងឮជាសាធារណៈ

ង. ត្រូវតែសុចរិត និងគ្មានកំហុសនៅពេលដែលខ្លួនចាប់ផ្តើមកាន់កាប់

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

➨ចាំបាច់ត្រូវតែការពារអ្នកកាន់កាប់សុចរិត និង គ្មានកំហុស ឲ្យខ្លាំងជាង អ្នកកាន់កាប់ទុច្ចរិត និង មានកំហុស។ ហេតុនេះ ទើបមានបញ្ញត្តិដែលកំណត់អំឡុងពេលអាជ្ញាយុកាលរយៈពេល ៥ ឆ្នាំ ដើម្បីអាចឲ្យអាជ្ញាយុកាលនៃលទ្ធកម្មបង្កើតឡើងបានយ៉ាងងាយស្រួល។

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

**មានឆន្ទៈយកជាកម្មសិទ្ធិ**
មានន័យថា ត្រូវមានការគិតថា ខ្លួនមានកម្មសិទ្ធិ។

**សន្តិវិធី**
មាន័យថា មិនមែនជាដកហូតការកាន់កាប់ដោយហិង្សាទេ គឺត្រូវធ្វើលទ្ធកម្មនូវការកាន់កាប់ដោយសន្តិភាព។

**ដឹងឮជាសាធារណៈ**
មានន័យថា មិនមែនជាការកាន់កាប់ដោយសម្ងាត់ចំពោះមនុស្សដែលនៅជុំវិញទេ គឺត្រូវកាន់កាប់ដោយថ្លៃថ្នូរ ដែលអាចឲ្យមនុស្សនៅជុំវិញដឹងឮបាន។



អ្នកកាន់កាប់

ករណីទុច្ចរិត ឬ មានកំហុស អំឡុងពេលអាជ្ញាយុកាល ១០ឆ្នាំ

ករណីសុចរិត និង គ្មានកំហុស អំឡុងពេលអាជ្ញាយុកាល ៥ ឆ្នាំ

## ករណីសិក្សា

A បានទុកកង់នៅតាមផ្លូវ ហើយបានចូលទៅក្នុងភោជនីយដ្ឋានពិសាអាហារ។ ក្នុងអំឡុងពេលនោះ ចោរបានលួចកង់របស់ A។ ក្រោយមក B បានទុកកង់នៅទីកន្លែងដដែលនោះ។ កង់របស់ A និង B មានពណ៌ និងរូបរាងស្រដៀងគ្នាខ្លាំង។

បន្ទាប់ពី A បានពិសាអាហាររួច ក៏បានចាកចេញពីភោជនីយដ្ឋាន។ ហើយ A បានជិះកង់របស់ B ត្រលប់ទៅវិញ ដោយគិតថាជាកង់របស់ខ្លួន។ A គ្មានកំហុសក្នុងការយកកង់របស់ B នោះទេ។

៧ ឆ្នាំបានកន្លងផុតទៅ។

តើនៅពេលនេះ A អាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលលើកង់របស់ B បានដែរឬទេ?

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

មានឆន្ទៈយកជាកម្មសិទ្ធិ

សន្តិវិធី

ដឹងឮជាសាធារណៈ



អ្នកកាន់កាប់

ករណីទុច្ចរិត ឬ មានកំហុស អំឡុងពេលអាជ្ញាយុកាល ១០ ឆ្នាំ

ករណីសុចរិត និង គ្មានកំហុស អំឡុងពេលអាជ្ញាយុកាល ៥ ឆ្នាំ

## ករណីសិក្សា

A បានទុកកង់នៅតាមផ្លូវ ហើយបានចូលទៅក្នុងភោជនីយដ្ឋានពិសាអាហារ។ ក្នុងអំឡុងពេលនោះ ចោរបានលួចកង់របស់ A។ ក្រោយមក B បានទុកកង់នៅទីកន្លែងដដែលនោះ។ កង់របស់ A និង B មានពណ៌ដូចគ្នា និងរូបរាងខុសគ្នាបន្តិចបន្តួច។

បន្ទាប់ពី A បានពិសាអាហាររួច ក៏បានចាកចេញពីភោជនីយដ្ឋាន និងបានជិះកង់របស់ B ត្រឡប់ទៅវិញ។ A មានកំហុសដោយមិនបានពិនិត្យកង់ច្បាស់លាស់។

ក្រោយមក ៧ ឆ្នាំ បានកន្លងហួស។

**តើនៅពេលនេះ A អាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលលើកង់របស់ B បានដែរឬទេ?**

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

មានឆន្ទៈយកជាកម្មសិទ្ធិ

សន្តិវិធី

ដឹងឮជាសាធារណៈ

អ្នកកាន់កាប់

ករណីទុច្ចរិត ឬ មានកំហុស អំឡុងពេលអាជ្ញាយុកាល ១០ ឆ្នាំ

ករណីសុចរិត និង គ្មានកំហុស អំឡុងពេលអាជ្ញាយុកាល ៥ ឆ្នាំ

## ករណីសិក្សា

A បានទុកកង់នៅតាមផ្លូវ ហើយបានចូលទៅក្នុងភោជនីយដ្ឋានពិសាអាហារ។ ក្នុងអំឡុងពេលនោះ ចោរបានលួចកង់របស់ A។ ក្រោយមក B បានទុកកង់នៅទីកន្លែងដដែលនោះ។

បន្ទាប់ពី A បានពិសាអាហាររួច ក៏បានចាកចេញពីភោជនីយដ្ឋាន។ ប៉ុន្តែ ដោយសារកង់របស់ខ្លួនបានបាត់ A បានគិតថានឹងលួចយកកង់របស់អ្នកដទៃ (B) ជិះត្រលប់ទៅវិញ។ ប៉ុន្តែ កង់របស់ B បានចាក់សោរ ហេតុនេះ A បានវាយបំបែកសោរនោះ ហើយក៏ជិះកង់របស់ B ត្រលប់ទៅវិញ។

១១ ឆ្នាំ បានកន្លងផុត។

តើនៅពេលនេះ A អាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលលើកង់របស់ B បានដែរឬទេ?

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

មានឆន្ទៈយកជាកម្មសិទ្ធិ

សន្តិវិធី

ដឹងឮជាសាធារណៈ

អ្នកកាន់កាប់

ករណីទុច្ចរិត ឬ មានកំហុស អំឡុងពេលអាជ្ញាយុកាល ១០ ឆ្នាំ

ករណីសុចរិត និង គ្មានកំហុស អំឡុងពេលអាជ្ញាយុកាល ៥ ឆ្នាំ

## ករណីសិក្សា

A បានទុកកង់នៅតាមផ្លូវ ហើយបានចូលទៅក្នុងភោជនីយដ្ឋានពិសាអាហារ។ ក្នុងអំឡុងពេលនោះ ចោរបានលួចកង់របស់ A។

បន្ទាប់ពី A បានពិសាអាហាររួច ក៏បានចាកចេញពីភោជនីយដ្ឋាន។ ប៉ុន្តែ កង់របស់ខ្លួនបានបាត់។ ហេតុនេះ A បានខ្ចីកង់នៅភោជនីយដ្ឋាន ហើយក៏ជិះវាត្រលប់ទៅវិញ។

ក្រោយមក A ធុញទ្រាន់នឹងការសងកង់ទៅឲ្យភោជនីយដ្ឋានវិញ ហើយក៏នៅតែបន្តខ្ចីកង់នោះទៀត។

ក្រោយមក ១១ ឆ្នាំ បានកន្លងហួស។

ករណីនេះ តើ A អាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលលើកង់បានដែរឬទេ?

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (ត)

មានឆន្ទៈយកជាកម្មសិទ្ធិ

សន្តិវិធី

ដឹងឮជាសាធារណៈ

អ្នកកាន់កាប់

ករណីទុច្ចរិត ឬ មានកំហុស អំឡុងពេលអាជ្ញាយុកាល ១០ ឆ្នាំ

ករណីសុចរិត និង គ្មានកំហុស អំឡុងពេលអាជ្ញាយុកាល ៥ ឆ្នាំ

## ៥. អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត (<u>មាត្រា ១៩៦</u>)

ជនទាំងឡាយណា ដែលបានប្រើសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ ដូចជាសិទ្ធិលើការបញ្ចាំ សិទ្ធិជួល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដោយសន្តិវិធី និងដោយការដឹងឮជាសាធារណៈ ហើយដោយមានឆន្ទៈប្រើសម្រាប់ខ្លួន ត្រូវតែធ្វើលទ្ធកម្មនូវសិទ្ធិនោះក្រោយពេល ៥ឆ្នាំ ប្រសិនបើសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមកាន់កាប់ និងក្រោយពេល ១០ឆ្នាំ ប្រសិនបើមិនមានចំណុចនេះ ដូចបានបែងចែកនៅក្នុងមាត្រា ១៩៥។

## ៦. ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ

ការជាប់គ្នានៃចលនវត្ថុច្រើនរបស់កម្មសិទ្ធិករផ្សេងគ្នា ហើយដែលមិនអាចបំបែកឲ្យដាច់ពីគ្នាបាន ដោយមិនធ្វើឲ្យចលនវត្ថុនោះបែកបាក់ ឬ អាចជាករណីដែលត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ ដើម្បីធ្វើការបំបែកចលនវត្ថុនោះ កម្មសិទ្ធិនៃវត្ថុភ្ជាប់គ្នានោះ ត្រូវធ្លាក់ទៅកម្មសិទ្ធិករនៃចលនវត្ថុដែលជាចំណែកចម្បង (មាត្រា ១៩៨(១))។

## ៦. ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ (ត)

- ការបែងចែកអំពីចំណែកចម្បង និងចំណែកបន្ទាប់បន្សំ គឺអាស្រ័យទៅលើទស្សនៈសង្គមជាក់ស្តែង ប៉ុន្តែក្នុងករណីដែលមិនអាចបែងចែកឲ្យដាច់ថា ចំណែកណាជាចំណែកចម្បង ចំណែកណាជាចំណែក បន្ទាប់បន្សំ កម្មសិទ្ធិករនៃចលនវត្ថុនីមួយៗនោះ នឹងក្លាយទៅជាម្ចាស់កម្មសិទ្ធិអវិភាគ ដោយគិតទៅតាមសមាមាត្រនៃតម្លៃនីមួយៗនាពេលជាប់គ្នានោះ (មាត្រា ១៩៨(២)) ។

ឧទាហរណ៍៖ ករណីដែលយកម៉ាស៊ីនទៅភ្ជាប់នឹងទូក

## ៦. ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ (ត)

**<u>ករណីទី១</u>**

លោក ក មានទូកមួយ ហើយបានភ្ជាប់ម៉ាស៊ីនដែលជារបស់លោក ខ ទៅនឹងទូកនោះ។ ពុំមានការព្រមព្រៀងជាក់លាក់រវាងលោក ក និងលោក ខ ស្តីពីការភ្ជាប់ម៉ាស៊ីនឡើយ។ តើនរណាជាកម្មសិទ្ធិករនៃទូកនោះ (មាត្រា ១៩៨(១-២))?

<u>ចម្លើយ?</u>

## ៦. ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ (ត)

**<u>ករណីទី២</u>**

លោក សុក ជាជាងសំណង់ គាត់បានលាយខ្សាច់ និង ស៊ីម៉ង់ច្របល់បញ្ចូលគ្នា ក្រោយមកទៀតគាត់រកឃើញថា ខ្សាច់ដែលគាត់យកមកលាយនោះជារបស់លោក សៅ ដែលជាជាងសំណង់ម្នាក់ទៀត។ តើនរណាជាម្ចាស់ស៊ីម៉ង់ដែលបានលាយនោះ (មាត្រា១៩៨(៣))?

<u>ចម្លើយ</u>?

# ៧. ការកែច្នៃចលនវត្ថុ (មាត្រា១៩៩)

សំដៅទៅលើការបង្កើតវត្ថុថ្មីដោយបន្ថែមការកែច្នៃទៅលើវត្ថុអ្នកដទៃ។

- ករណីយកវត្ថុអ្នកដទៃទៅកែច្នៃបង្កើតជាវត្ថុថ្មី តើវត្ថុថ្មីនោះធ្លាក់ទៅលើកម្មសិទ្ធិករនៃធាតុផ្សំ ឬ អ្នកកែច្នៃ?
- មានទស្សនៈ ២ គឺទស្សនៈធាតុផ្សំ ដែលទទួលស្គាល់ថាអ្នកផ្គត់ផ្គង់ធាតុផ្សំគឺជាកម្មសិទ្ធិករ និងទស្សនៈកែច្នៃ ដែលទទួលស្គាល់អ្នកកែច្នៃគឺជាកម្មសិទ្ធិករ

ក្រមរដ្ឋប្បវេណីកម្ពុជា អនុវត្តគោលការណ៍នៃទស្សនៈកែច្នៃ

# ៧. ការកែច្នៃចលនវត្ថុ (<u>មាត្រា១៩៩</u>) (ត)

- ប៉ុន្តែ មានករណីលើកលែង ដែលករណីខាងក្រោម គឺកម្មសិទ្ធិករធាតុផ្សំជាអ្នកធ្វើលទ្ធកម្មលើកម្មសិទ្ធិ។
  - ករណីដែលតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះតិចហួសហេតុជាងតម្លៃវត្ថុធាតុដើម (មាត្រា១៩៩(១) វាក្យខណ្ឌទី២)។
  - ករណីដែលអ្នកកែច្នៃវត្ថុបានផ្តល់វត្ថុធាតុដើមមួយចំណែក ហើយតម្លៃវត្ថុធាតុដើម ព្រមទាំងតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ មិនលើសពីតម្លៃ វត្ថុធាតុដើមនៃអ្នកដទៃ (មាត្រា១៩៩(២))។
- ជាទូទៅ រវាងអ្នកផ្គត់ផ្គង់ធាតុផ្សំ និងអ្នកកែច្នៃ គឺមានទំនាក់ទំនងកិច្ចសន្យាអ្វីមួយ ហើយការកំណត់អំពីកម្មសិទ្ធិ ក៏បានកំណត់នៅក្នុងទំនាក់ទំនងកិច្ចសន្យានោះដែរ។ មាត្រានេះ អនុវត្តចំពោះតែករណីដែលភាគីទាំងពីរពុំមានទំនាក់ទំនងកិច្ចសន្យាតែប៉ុណ្ណោះ។

## ៧. ការកែច្នៃចលនវត្ថុ (ត)

ករណីសិក្សាទី១

B បានយកព្រះពុទ្ធរូបមាសរបស់ A ទៅរំលាយធ្វើជាដុំមាស។ តើ A ឬ B ដែលមានកម្មសិទ្ធិលើដុំមាសនោះ?

ចម្លើយ?

## ៧. ការកែច្នៃចលនវត្ថុ (ត)

ករណីសិក្សាទី២

ជាងចម្លាក់ល្បីឈ្មោះលោក B បានធ្វើការកែច្នៃទៅលើឈើមួយដុំរបស់ A បង្កើតបានជាចម្លាក់ដ៏រឹងមាំមួយ។

តើអ្នកណាមានកម្មសិទ្ធិទៅលើរូបចម្លាក់នោះ? (មាត្រា ១៩៩)

ចម្លើយ?

## ៨. អានុភាពនៃឧបាគមន៍នៃចលនវត្ថុ (មាត្រា ២០០)

- ការជាប់គ្នា ការលាយគ្នា ការច្របល់គ្នា និងការកែច្នៃចលនវត្ថុ ជារួមហៅថា ឧបាគមន៍នៃចលនវត្ថុ។ ករណីដែលមានឧបាគមន៍នៃចលនវត្ថុកើតឡើង តើសិទ្ធិដែលមាននៅលើចលនវត្ថុមុនឧបាគមន៍កើតឡើង នឹងទៅជាយ៉ាងណា? ឧបាគមន៍នេះ បានកំណត់បញ្ហានេះដូចខាងក្រោម ៖
  - ក្នុងករណីដែលកម្មសិទ្ធិលើវត្ថុត្រូវរលត់ ដោយសារការជាប់គ្នា ការលាយច្របល់គ្នា សិទ្ធិដែលមានលើវត្ថុនោះ ក៏ត្រូវរលត់ដែរ (មាត្រា ២០០(១))។
  - សិទ្ធិរបស់អ្នកដទៃដែលមានលើវត្ថុ ដែលធ្លាប់ជាកម្មសិទ្ធិរបស់ជនដែលក្លាយជាកម្មសិទ្ធិករនៃវត្ថុភ្ជាប់គ្នា វត្ថុលាយច្របល់គ្នា ឬវត្ថុកែច្នៃ ត្រូវបន្តអត្ថិភាពលើវត្ថុដែលត្រូវបានធ្វើ លទ្ធកម្មជាថ្មីនេះទៀត។
  - ក្នុងករណីប្រសិនបើ ក្លាយជាកម្មសិទ្ធិអវិភាគ សិទ្ធិនោះត្រូវបន្តអត្ថិភាពលើចំណែកនៃម្ចាស់កម្មសិទ្ធិករអវិភាគនោះ។

## ៩. ឧបាគមន៍ និងសិទ្ធិទាមទារប្រាក់សំណង (មាត្រា ២០១)

- តើបុគ្គលដែលបានបាត់បង់កម្មសិទ្ធិដោយសារឧបាគមន៍នៃចលនវត្ថុ អាចទាមទារប្រាក់សំណងចំពោះបុគ្គលដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិថ្មីបានឬទេ?
- បញ្ញត្តិនេះ ចែងថា ជនដែលបានបាត់បង់សិទ្ធិដោយសារការជាប់គ្នា ការលាយច្របល់គ្នា និងការកែច្នៃនៃចលនវត្ថុ អាចទាមទារសំណងពីជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិនោះ ដោយផ្អែកទៅលើបញ្ញត្តិទាក់ទងនឹងសេចក្ដីចម្រើនឥតហេតុ។
- ការទាមទារឲ្យធ្វើបដិទានគឺ មិនត្រូវបានអនុញ្ញាតនោះទេ ពីព្រោះការដែលទទួលស្គាល់ឲ្យបំបែកវត្ថុ ធ្វើបដិទានឡើងវិញ ក្នុងករណីដែលចលនវត្ថុនោះត្រូវបានទទួលស្គាល់ថាបានភ្ជាប់គ្នាដោយមិនអាចបំបែកបាន ហើយបានបង្កើតនូវវត្ថុថ្មីតាមរយៈឧបាគមន៍ គឺផ្ទុយនឹងគោលបំណងនៃបញ្ញត្តិនីមួយៗទាក់ទងនឹងឧបាគមន៍។


សំណួរ/ចម្លើយ
stefano prada
Prugna.net

# លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

មានវិធីជាច្រើនដែលបុគ្គលម្នាក់អាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុមួយបាន។ ប៉ុន្តែ វិធី ដែលសាមញ្ញដែលបានកើតមានឡើងជាញឹកញាប់បំផុតនោះគឺ លទ្ធកម្មកម្មសិទ្ធិដោយកិច្ចសន្យាលក់ទិញ ឬកិច្ចសន្យាប្រទានកម្ម ជាដើម។ ឧទាហរណ៍ ដូចជាការធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុ តាមរយៈកិច្ចសន្យា នៅពេលដែលយើងទិញវត្ថុពីហាងលក់ទំនិញនៅទីផ្សារក្នុងជីវភាពប្រចាំថ្ងៃ។ ម្យ៉ាងវិញទៀត ការដែលយើងទទួលអំណោយផ្សេងៗពីក្រុមគ្រួសារ ឬមិត្តភក្តិ នៅថ្ងៃខួបកំណើត គឺជាការដែលយើងធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុទាំងនោះតាមរយៈកិច្ចសន្យាប្រទានកម្ម។

វិធីធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ គឺមានវិធីច្រើនយ៉ាងដូចជា តាមកិច្ចសន្យា សន្តតិកម្ម និង លទ្ធកម្មដោយសុចរិតជាដើម។ ហើយវិធីទាំងអស់នេះអាចបែងចែកជាពីរផ្នែកគឺ លទ្ធកម្មបន្ត និង លទ្ធកម្មតាំងពីដំបូង។

- លទ្ធកម្មបន្តៈ គឺជាលទ្ធកម្មនៃសិទ្ធិប្រកត្យក្សមួយដែលមានរួចហើយ ឬអាចនិយាយបានថា កម្មសិទ្ធិករក្រោយ ទទួលបាននូវសិទ្ធិលើចលនវត្ថុដោយផ្អែកលើសិទ្ធិ អ្នកផ្សេង។ អ្នកទិញអាចធ្វើលទ្ធកម្មបាន លុះត្រាតែអ្នកលក់គឺជាកម្មសិទ្ធិករ។ ឧទាហរណ៍ ការធ្វើលទ្ធកម្មកម្មសិទ្ធិតាមរយៈកិច្ចសន្យាលក់ទិញ ឬ សន្តតិកម្មជាដើម គឺជាលទ្ធកម្មបន្ត។

- លទ្ធកម្មតាំងពីដំបូងៈ គឺជាលទ្ធកម្មនៃសិទ្ធិប្រកត្យក្សមួយថ្មីដែលមានរួចហើយ ឬអាចនិយាយបានថា កម្មសិទ្ធិករថ្មីបានធ្វើលទ្ធកម្មសិទ្ធិលើចលនវត្ថុដោយឯករាជ្យ មិនទទួលបន្តពីសិទ្ធិរបស់អ្នកផ្សេងឡើយ។ ឧទាហរណ៍ លទ្ធកម្មកម្មសិទ្ធិដោយសុចរិត ឬដោយអាជ្ញាយុកាលជាដើម គឺជាលទ្ធកម្មតាំងពីដំបូង។

## ១. លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (មាត្រា ១៩៣)

ដើម្បីរក្សាសុវត្ថិភាពក្នុងកិច្ចជំនួញផ្នែកចលនវត្ថុ តាមរយៈការការពារអ្នកដែលបង្កើតកិច្ចសន្យាអនុប្បទានកម្មសិទ្ធិជាមួយអ្នកដែលមិនមែនជាម្ចាស់សិទ្ធិ ដោយជឿថា អ្នកកាន់កាប់ចលនវត្ថុគឺជាអ្នកមានកម្មសិទ្ធិលើចលនវត្ថុនោះ យោងតាមមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ទោះជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ ឲ្យតែអនុប្បទានិកបានចាប់ផ្តើមកាន់កាប់ចលនវត្ថុនោះ ដោយផ្អែកលើកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាពដោយសុចរិត និងគ្មានកំហុសនោះ អនុប្បទានិកត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ លើកលែងតែអនុប្បទានិកមិនបានចាប់ផ្តើមកាន់កាប់ចលនវត្ថុនោះ ឬក្នុងករណីដែលអនុប្បទាយីនៅតែបន្តកាន់កាប់ចលនវត្ថុនោះ។

ដើម្បីធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុដោយផ្អែកលើលទ្ធកម្មដោយសុចរិតបាន ត្រូវគោរព នូវលក្ខខណ្ឌដូចខាងក្រោម:

### ក. ចលនវត្ថុ

កម្មវត្ថុនៃការធ្វើអនុប្បទានជាចាំបាច់ត្រូវតែជាចលនវត្ថុ។ ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ (មាត្រា ១២០ កថាខណ្ឌទី៣) រួមទាំងទ្រព្យសម្បត្តិ ទាំងឡាយណាដែលគ្មានរូបរាងដែលអាចគ្រប់គ្រងបាន ក៏ត្រូវបានចាត់ទុកថាជាចលនវត្ថុ (មាត្រា១២០ កថាខណ្ឌទី៤)។

### ខ. កិច្ចសន្យាអនុប្បទានកម្មសិទ្ធិលើចលនវត្ថុដែលមានសុពលភាព

កិច្ចសន្យាអនុប្បទានកម្មសិទ្ធិ ចាំបាច់ត្រូវតែជាកិច្ចសន្យាដែលមានសុពលភាព។ លទ្ធកម្មដោយសុចរិត គឺជាប្រព័ន្ធដែលទទួលស្គាល់ការធ្វើលទ្ធកម្មកម្មសិទ្ធិរបស់អនុប្បទានិក ដើម្បីការពារកិច្ចការជំនួញ ទោះបីជាអនុប្បទាយីមិនមានកម្មសិទ្ធិក៏ដោយ ហើយមិនមែនជាប្រព័ន្ធដែលជួយសង្គ្រោះអនុប្បទានិក ក្នុងករណីដែលកិច្ចសន្យាមានវិការៈនោះទេ។ ហេតុដូចនេះ ប្រព័ន្ធនេះមិនមែនជាប្រព័ន្ធដែលអនុញ្ញាតឲ្យអនុប្បទានិក ធ្វើលទ្ធកម្មកម្មសិទ្ធិ ដោយការជួសជុលវិការៈនៃកិច្ចសន្យា ក្នុងករណីដែលកិច្ចសន្យាមិនមានសុពលភាពដោយសារហេតុផលមួយចំនួន ដូចជា អនុប្បទាយីពុំមានសមត្ថភាពខាងឆន្ទៈ ឬ សមត្ថភាពក្នុងការធ្វើសកម្មភាព ឬ ក្នុងករណីដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងដោយមានវិការៈ (ការភាន់ច្រឡំ ការឆបោក ការគំរាមកំហែង ជាដើម) ឡើយ (មាត្រា ១៩៣ ក្រមរដ្ឋប្បវេណី)។

### គ. អនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុ

លទ្ធកម្មដោយសុចរិត គឺជាប្រព័ន្ធដែលទទួលស្គាល់ការធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ ក្នុងករណីដែលអនុប្បទានិកបានចាប់ផ្តើមកាន់កាប់ចលនវត្ថុនោះដោយផ្អែកលើកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ទោះបីអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុក៏ដោយ ហេតុនេះ ការណ៍ដែលតម្រូវឲ្យអនុប្បទាយីពុំមានកម្មសិទ្ធិលើចលនវត្ថុនោះ ក្លាយទៅជាលក្ខខណ្ឌមួយផងដែរ។

### ឃ. សុចរិត និងគ្មានកំហុស

ដើម្បីទទួលស្គាល់លទ្ធកម្មដោយសុចរិតបាន តម្រូវឲ្យអនុប្បទានិក គឺជាជនសុចរិត និង គ្មានកំហុសនៅពេលចាប់ផ្តើមកាន់កាប់។ សុចរិត និងគ្មានកំហុសនៅត្រង់នេះ មានន័យថា អនុប្បទានិកជឿជាក់ថា កម្មសិទ្ធិមាននៅអនុប្បទាយី ហើយគ្មានកំហុសក្នុងការជឿជាក់នោះ។ អ្នកកាន់កាប់ត្រូវបានសន្មតថា កាន់កាប់ដោយសុចរិត ដោយសន្តិវិធី និងដឹងលឺជាសាធារណៈ (មាត្រា

២៣៤ កថាខណ្ឌទី ២) ហេតុដូច្នេះ អនុប្បទានិកមិនចាំបាច់ទទួលខុសត្រូវក្នុងការអះអាងពីភាពសុចរិតនោះទេ។ ម៉្យាងទៀត អ្នកកាន់កាប់ត្រូវបានសន្មតថាមានសិទ្ធិត្រឹមត្រូវស្របច្បាប់ក្នុងការកាន់កាប់វត្ថុកាន់កាប់ (មាត្រា ២៣៤ កថាខណ្ឌទី ៤) ហេតុនេះ ជាលទ្ធផល អនុប្បទាយីត្រូវបានសន្មតថាគឺជាម្ចាស់សិទ្ធិ ហើយអនុប្បទានិកដែលបានជឿជាក់ទៅលើចំណុចនេះ ត្រូវបានសន្មតថាគ្មានកំហុស។ ដូចនេះ ដើម្បីបដិសេធការសម្រេចលទ្ធកម្មដោយសុចរិត កម្មសិទ្ធិករពិតប្រាកដ ត្រូវទទួលខុសត្រូវក្នុងការអះអាងអំពីភាពទុច្ចរិត និងមានកំហុសរបស់អនុប្បទានិក (យោងយុត្តិសាស្ត្រតុលាការកំពូលប្រទេសជប៉ុនចេញថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៦៦)។

### ង. ទទួលបាននូវការប្រគល់ចលនវត្ថុ

ការចាប់ផ្តើមការកាន់កាប់ គឺជាលក្ខខណ្ឌចាំបាច់ដែលបានចែងនៅក្នុងមាត្រា ១៩៣។ ការផ្ទេរការកាន់កាប់ រួមមាន ការប្រគល់ដោយជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ (ការផ្ទេរការកាន់កាប់តាមការព្រមព្រៀង) ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា (មាត្រា ២២៩)។ ប៉ុន្តែ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៩៣ បានចែងថា ករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាន់ដោយចំពោះ នោះលទ្ធកម្មដោយសុចរិតមិនសម្រេចឡើយ។ ហេតុនេះ ការប្តូរលក្ខណៈនៃការកាន់កាប់ (ការផ្ទេរការកាន់កាប់តាមការព្រមព្រៀង) គឺមិនបំពេញលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតទេ។

<u>**ករណីសិក្សា**</u>

១. A បានជួលកង់មួយគ្រឿងឲ្យទៅ B។ B បានទុកកង់នោះជារបស់ខ្លួន ហើយលក់កង់នោះឲ្យទៅ C និងបានប្រគល់រួចរាល់។ C បានជឿជាក់ថា B ជាកម្មសិទ្ធិករ ហើយគ្មានកំហុសក្នុងការជឿជាក់ទេ។ តើ A អាចទាមទារ Cឲ្យប្រគល់កង់នោះត្រឡប់មកវិញបានដែរ ឬទេ?

ករណីនេះ កង់នោះគឺជាវត្ថុដែលជាកម្មសិទ្ធិរបស់ A ហើយ B ពុំមានសិទ្ធិក្នុងការលក់កង់នោះទេ ហេតុនេះជាគោលការណ៍ C មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើកង់បានទេ ហើយ A អាចទាមទារឲ្យប្រគល់កង់មកវិញដោយផ្អែកលើកម្មសិទ្ធិបាន (មាត្រា ១៥៥)។ ប៉ុន្តែ C បានទទួលបន្តនូវកង់នោះដោយសុចរិត និងគ្មានកំហុស ហេតុនេះយើងត្រូវធ្វើការសិក្សាទៅលើការសម្រេចនៃលទ្ធកម្មដោយសុចរិត។ ជាដំបូង ដើម្បីសម្រេចលទ្ធកម្មដោយសុចរិតបាន កម្មវត្ថុត្រូវតែជាចលនវត្ថុ ហើយកម្មវត្ថុនៅក្នុងករណីនេះ គឺកង់ ហេតុនេះលក្ខខណ្ឌនេះត្រូវបានបំពេញ។ ម៉្យាងទៀត ចាំបាច់ត្រូវមានកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយ C ទទួលបានការប្រគល់កង់ដោយផ្អែកលើកិច្ចសន្យាលក់ទិញជាមួយ B ហេតុនេះលក្ខខណ្ឌនេះត្រូវបានបំពេញ។ លើសពីនេះ C ទទួលបានការប្រគល់កង់នោះដោយជាក់ស្តែង ហេតុនេះលក្ខខណ្ឌនៃការការផ្ទេរការកាន់កាប់ក៏ត្រូវបានបំពេញ។ ដូចនេះ C ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិនៃកង់តាមរយៈលទ្ធកម្មដោយសុចរិត ហើយជា

លទ្ធផល A ត្រូវបាត់បង់កម្មសិទ្ធិ ហេតុនេះ A មិនអាចទាមទារ C ឲ្យប្រគល់កង់មកវិញបានទេ។ ផ្ទុយទៅវិញ A អាចទាមទារឲ្យ B ប្រគល់នូវតម្លៃកង់ ក្នុងនាមជាសំណងការខូចខាតដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ឬអំពើអនីត្យានុកូល។

២. A បានលក់កង់មួយគ្រឿងឲ្យទៅ B ហើយបានធ្វើការប្រគល់នូវកង់នោះរួចរាល់ដែរ។ នៅពេលនោះA គឺជាអនីតិជន ហើយក៏ពុំមានការយល់ព្រមពីអ្នកមានអំណាចមេបាដែរ។ ក្រោយមក A បានលុបចោលកិច្ចសន្យាលក់ទិញកង់នោះហើយទាមទារឲ្យ B ប្រគល់កង់មកវិញ។ តើ B អាចអះអាងអំពីលទ្ធកម្មដោយសុចរិតលើកង់បានដែរ ឬទេ?

A អាចលុបចោលកិច្ចសន្យាលក់ទិញកង់នោះបាន (មាត្រា ១៨, មាត្រា ៣៥៩ កថាខណ្ឌទី ២) ។ ក្នុងករណីដែលកិច្ចសន្យាត្រូវបានលុបចោល កិច្ចសន្យានោះត្រូវបានចាត់ទុកថាមោឃៈតាំងពីដំបូង (មាត្រា ៣៥៨ កថាខណ្ឌទី ២) ។ ហេតុនេះ A អាចទាមទារឲ្យ Bប្រគល់កង់នោះមកវិញដោយផ្អែកលើកម្មសិទ្ធិ ឬសេចក្តីចម្រើនឥតហេតុ (មាត្រា ១៥៥, មាត្រា ៧៣៦ កថាខណ្ឌទី ២) ។ ករណីនេះ តើ B អាចអះអាងអំពីលទ្ធកម្មដោយសុចរិត ហើយបដិសេធការទាមទារឲ្យប្រគល់វិញរបស់ A បានដែរ ឬទេ? លទ្ធកម្មដោយសុចរិត គឺជាបញ្ញត្តិដើម្បីការពារសុវត្ថិភាពប្រតិបត្តិការចលនវត្ថុ។ ហេតុនេះ លទ្ធកម្មដោយសុចរិត ជាប្រព័ន្ធដែលទទួលស្គាល់ត្រឹមតែករណីដែលកិច្ចសន្យាអនុប្បទានកម្មសិទ្ធិមានសុពលភាពតែប៉ុណ្ណោះ ហើយមិនមែនជាប្រព័ន្ធដែលជួសជុលកិច្ចសន្យាដែលមានវិការៈនោះទេ។ នៅក្នុងករណីសិក្សាខាងលើ កិច្ចសន្យាលក់ទិញត្រូវបានលុបចោលដោយមូលហេតុអ្នកលក់ជាអនីតិជន នាំឲ្យពុំមានការផ្ទេរការកាន់កាប់ដោយផ្អែកទៅលើកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាពនោះទេ ដូចនេះលទ្ធកម្មដោយសុចរិតមិនត្រូវបានទទួលស្គាល់នោះទេ។ ដូច្នេះ B មិនអាចបដិសេធចំពោះការទាមទារឲ្យប្រគល់មកវិញរបស់ A បានទេ។

៣. B បានទិញកង់មួយគ្រឿងពី A ហើយបានឲ្យ A បន្តធ្វើការគ្រប់គ្រងកង់នោះដដែល។ A បានទុកកង់នោះជារបស់ខ្លួន ហើយបានលក់ឲ្យទៅ C ប៉ុន្តែ C ក៏បានឲ្យ A បន្តធ្វើការគ្រប់គ្រងកង់នោះដែរ។ នៅពេលទិញកង់នោះ C បានជឿជាក់ថា A គឺជាកម្មសិទ្ធិករនៃកង់នោះ ហើយគ្មានកំហុសក្នុងការជឿជាក់ទេ។ តើ C អាចធ្វើលទ្ធកម្មកម្មសិទ្ធិកង់នោះបានដែរ ឬទេ?

ការផ្ទេរសិទ្ធិប្រត្យក្សជាអាទិ៍ កើតឡើងតាមរយៈការព្រមព្រៀងរបស់គូភាគី (មាត្រា ១៣៣)។ ប៉ុន្តែ ការបង្កើត ការផ្ទេរ និង ការកែប្រែសិទ្ធិប្រត្យក្ស ចាំបាច់ត្រូវមានលក្ខខណ្ឌតតាំងដើម្បីអាចតតាំងជាមួយតតិយជនបាន ដែលចំពោះអនុប្បទានសិទ្ធិប្រត្យក្សលើចលនវត្ថុ មិនអាចតតាំងជាមួយតតិយជនបានឡើយ ប្រសិនបើពុំមានការផ្ទេរការកាន់កាប់ (មាត្រា ១៣៤ កថាខណ្ឌទី ២)។ នៅក្នុងក្រមរដ្ឋប្បវេណី ការផ្ទេរការកាន់កាប់ មិនកម្រិតត្រឹមតែការប្រគល់ដោយជាក់ស្តែងប៉ុណ្ណោះទេ ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជាក៏ត្រូវបានរាប់បញ្ចូលផងដែរ (មាត្រា ២២៩) ហើយការផ្ទេរការកាន់កាប់ដែលជាលក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យក្សចំពោះចលនវត្ថុនោះ អាចជាទម្រង់ណាមួយក្នុងចំណោម

ការប្រគល់ដោយជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។ ថ្វីត្បិតតែ B មិនទទួលបានការប្រគល់ដោយជាក់ស្តែងក៏ដោយ ប៉ុន្តែ A បានបន្តការកាន់កាប់នោះដោយសារការព្រមព្រៀងរវាង A និង B ហេតុនេះ ការផ្ទេរការកាន់កាប់ដោយការប្តូរលក្ខណៈនៃការកាន់កាប់ត្រូវបានទទួលស្គាល់ (មាត្រា ២២៩ កថាខណ្ឌទី ២)។ ដូចនេះ B បានបំពេញលក្ខខណ្ឌតតាំងសម្រាប់លទ្ធកម្មកម្មសិទ្ធិនៃកង់នោះ។ ផ្ទុយទៅវិញ C ក៏បានបង្កើតកិច្ចសន្យាលក់ទិញជាមួយ A ដោយព្រមព្រៀងថា ឲ្យ A បន្តការកាន់កាប់កង់នោះ ហេតុនេះការផ្ទេរការកាន់កាប់ដោយប្តូរលក្ខណៈនៃការកាន់កាប់ត្រូវបានកើតឡើង នាំឲ្យលក្ខខណ្ឌតតាំងត្រូវបានបំពេញ។ ករណីដែលអនុប្បនិកទាំងអស់សុទ្ធតែបំពេញលក្ខខណ្ឌតតាំង នោះអនុប្បនិកណាដែលបានបំពេញលក្ខខណ្ឌតតាំងមុនគេមានអាទិភាព ហេតុនេះ B អាចអះអាងអំពីកម្មសិទ្ធិនៃកង់ចំពោះ C បាន។ អញ្ចឹង តើ B អាចអះអាងអំពីលទ្ធកម្មដោយសុចរិតបានដែរ ឬទេ? C បានទទួលការផ្ទេរការកាន់កាប់កង់តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ដោយសុចរិត និងគ្មានកំហុស ដោយផ្អែកលើកិច្ចសន្យាលក់ទិញដែលមានសុពលភាព។ ប៉ុន្តែ ករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាប់ដោយចំពោះនោះលទ្ធកម្មដោយសុចរិតមិនអាចសម្រេចបានឡើយ (មាត្រា ១៩៣ វាក្យខ័ណ្ឌទី ២) ។ នេះគឺដោយសារតែពុំមានភាពសមស្របទេ ក្នុងករណីដែលដកហូតកម្មសិទ្ធិពីម្ចាស់សិទ្ធិពិតប្រាកដ ដោយផ្អែកលើទិដ្ឋភាពខាងក្រៅដែលពុំមានការផ្លាស់ប្តូរស្ថានភាពនៃការផ្ទេរការកាន់កាប់នោះ។ នៅក្នុងករណីសិក្សា A នៅតែបន្តការកាន់កាប់ដោយផ្ទាល់ តាមរយៈការព្រមព្រៀងរវាង A និង C ហេតុនេះ មាត្រា ១៩៣ វាក្យខ័ណ្ឌទី ២ ត្រូវយកមកអនុវត្ត។ ដូចនេះ លទ្ធកម្មដោយសុចរិតមិនត្រូវបានសម្រេច ហើយ C មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិបានទេ។

### ២. អនុប្បទាននូវវត្ថុលួច ឬបាត់ (មាត្រា ១៩៤)

មានករណីលើកលែងមួយចំនួនចំពោះវត្ថុលួច ឬ វត្ថុដែលបាត់៖

ក.ករណីដែលកម្មវត្ថុគឺជាវត្ថុលួច ឬវត្ថុបាត់ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់នោះ អាចទាមទារចំពោះជនដែលបានធ្វើលទ្ធកម្មដោយសុចរិតនោះ ឲ្យសងវត្ថុនោះមកវិញបាន។

- ចំពោះភាគីម្ខាងទៀតដែលត្រូវបានគេទាមទារ មិនមែនកំរិតត្រឹមតែអ្នកដែលធ្វើលទ្ធកម្មដោយសុចរិតពីដំបូងនោះទេ គឺរាប់បញ្ចូលទាំងអ្នកដែលធ្វើលទ្ធកម្មដោយសុចរិតបន្តបន្ទាប់ផងដែរ។
- ចំពោះភាគីដែលមានសិទ្ធិទាមទារឲ្យសងវិញ គឺត្រូវបានកំរិតត្រឹមជនរងគ្រោះនៃវត្ថុដែលត្រូវបានលួច ឬម្ចាស់វត្ថុដែលបាត់តែប៉ុណ្ណោះ។ មានន័យថា ចាំបាច់ការបាត់បង់ការកាន់កាប់នោះត្រូវតែផ្ទុយពីឆន្ទៈរបស់អ្នកមានសិទ្ធិដើម ហើយក្នុងករណីដែលអ្នកមានសិទ្ធិដើមបានបាត់បង់នូវការកាន់កាប់វត្ថុនោះ ដោយការឆបោក ការបន្លំ ឬ ការគំរាមកំហែង មិនអាចអនុវត្តមាត្រានេះបានទេ។

ខ. ទោះជាយ៉ាងណាក៏ដោយ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់នោះ ត្រូវធ្វើការទាមទារក្នុងអំឡុងពេល ២ឆ្នាំ គិតចាប់ពីពេលបាត់ ឬពេលត្រូវបានលួច។ (មាត្រា១៩៤-១)

គ. ប៉ុន្តែ ក្នុងករណីដែលអ្នកធ្វើលទ្ធកម្មដោយសុចរិតនោះ បានទិញដោយសុចរិតនូវវត្ថុដែលបានបាត់ ឬ វត្ថុដែលលួចនោះតាមរយៈការលក់ដេញថ្លៃ ឬ នៅទីផ្សារសាធារណៈ ឬ ពីពាណិជ្ជករ ឬ អាជីវករដែលលក់វត្ថុប្រភេទដូចគ្នា នោះជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់មិនអាចទាមទារឲ្យសងវត្ថុនោះមកវិញបានទេ ប្រសិនបើមិនសងថ្លៃលក់ទៅឲ្យអ្នកដែលបានធ្វើលទ្ធកម្មដោយសុចរិតនោះ។ (មាត្រា ១៩៤-២)

ឧទាហរណ៍ លោក A បានបាត់កង់ ហើយលោក B រើសបាន ហើយយកទៅលក់ឲ្យលោក C ដែលជាអាជីវករលក់កង់។ លោក D បានទិញកង់នោះ ពីលោក C ក្នុងតម្លៃ ៤០០ដុល្លា។ បើយោងតាមមាត្រា១៩៤-២ ប្រសិនបើលោក A មិនបង់ប្រាក់ឲ្យទៅលោក D ចំនួន ៤០០ដុល្លារជាមុនទេ គាត់មិនអាចទាមទារឲ្យប្រគល់កង់នោះមកវិញបានទេ។

ដូចបានបកស្រាយខាងលើរួចហើយ យោងតាមមាត្រា ១៩៤ ករណីដែលកម្មវត្ថុនៃលទ្ធកម្មដោយសុចរិតជាវត្ថុលួច ឬវត្ថុបាត់ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់ អាចទាមទារឲ្យធ្វើបដិទាននូវកម្មវត្ថុនោះបានក្នុងអំឡុងពេល ២ឆ្នាំ។ អញ្ចឹង តើក្នុងអំឡុងពេលនេះ តើអ្នកណាគឺជាម្ចាស់កម្មសិទ្ធិនៃកម្មវត្ថុនោះ? ចំណុចនេះ អ្នកមានសិទ្ធិដើម មានកម្មសិទ្ធិ ពោលគឺ ប្រសិនបើឈរលើទស្សនៈថា អំឡុងពេល ២ឆ្នាំនេះ លទ្ធកម្មដោយសុចរិតមិនត្រូវបានទទួលស្គាល់ទេ នោះកម្មសិទ្ធិត្រូវធ្លាក់ទៅលើអ្នកធ្វើលទ្ធកម្មដោយសុចរិត ប៉ុន្តែអាចមានទស្សនៈដែលទទួលស្គាល់នូវសិទ្ធិទាមទារបដិទានពិសេសដោយផ្អែកលើមាត្រា ១៩៤។ ចំនែក យុត្តិសាស្ត្រប្រទេសជប៉ុន បានជ្រើសរើសយកទស្សនៈទីមួយ។

### ៣. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ (មាត្រា១៩៥)

អាជ្ញាយុកាលនៃលទ្ធកម្ម គឺជាប្រព័ន្ធដែលអនុញ្ញាតឲ្យធ្វើលទ្ធកម្មនៃសិទ្ធិតាមរយៈការកន្លងហួសនៃរយៈពេលពិតប្រាកដមួយ។

៣.១ លក្ខខណ្ឌអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ មានដូចខាងក្រោម ដែលខុសគ្នាដោយផ្អែកទៅអត្ថិភាព ឬនត្ថិភាពនៃភាពសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមការកាន់កាប់។

ករណីមិនមែនជាជនសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមការកាន់កាប់ (មាត្រា ១៩៥ កថាខណ្ឌទី ១) ៖

ក. ត្រូវកាន់កាប់វត្ថុនោះក្នុងរយៈពេល ១០ឆ្នាំ

ខ. ត្រូវមានឆន្ទៈយកធ្វើជាកម្មសិទ្ធិ

គ. ត្រូវធ្វើឡើងដោយសន្តិវិធី

ឃ. ការកាន់កាប់នោះត្រូវមានការដឹងឮជាសាធារណៈ

ករណីសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមការកាន់កាប់ (មាត្រា ១៩៥ កថាខណ្ឌទី ២)៖

ក. ត្រូវកាន់កាប់ក្នុងរយៈពេល ៥ឆ្នាំ នូវវត្ថុនោះ

ខ. ត្រូវមានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិ

គ. ត្រូវធ្វើឡើងដោយសន្តិវិធី

ឃ. ការកាន់កាប់នោះត្រូវមានការដឹងឮជាសាធារណៈ

ង. ត្រូវតែសុចរិត និងគ្មានកំហុសនៅពេលដែលខ្លួនចាប់ផ្តើមកាន់កាប់

## ៤. អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត (មាត្រា ១៩៦)

ជនទាំងឡាយណាដែលបានប្រើសិទ្ធិដែលទាក់ទង់នឹងចលនវត្ថុ ដូចជាសិទ្ធិលើការបញ្ចាំ សិទ្ធិជួល និងសិទ្ធិជួលលើទ្រព្យសម្បត្តិផ្សេងទៀត ដោយសន្តិវិធី និង ដោយការដឹងឮជាសាធារណៈ ហើយដោយមានឆន្ទៈប្រើសម្រាប់ខ្លួន ត្រូវតែធ្វើលទ្ធកម្មនូវសិទ្ធិនោះក្រោយពេល ៥ឆ្នាំ ប្រសិនបើសុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមកាន់កាប់ និងក្រោយពេល ១០ឆ្នាំ ប្រសិនបើមិនមានចំណុចនេះ ដូចបានបែងចែកនៅក្នុងមាត្រា១៩៥ នៃក្រមរដ្ឋប្បវេណី។ ឧទាហរណ៍ ករណីបុគ្គលដែលមិនមែនជាកម្មសិទ្ធិករនៃចលនវត្ថុនោះទេ ប៉ុន្តែបានបន្លំខ្លួនធ្វើជាកម្មសិទ្ធិករ ហើយបានយកវត្ថុនោះទៅដាក់បញ្ចាំ អ្នកដែលទទួលយកការបញ្ចាំនោះ អាចធ្វើលទ្ធកម្មនូវសិទ្ធិលើការបញ្ចាំតាមរយៈអាជ្ញាយុកាលបាន។ អាជ្ញាយុកាលនៃលទ្ធកម្មនៃសិទ្ធិទ្រព្យសម្បត្តិផ្សេងទៀត មានដូចជា សិទ្ធិលើបំណុលជាប្រាក់ដែលមានរយៈពេលកំណត់ សិទ្ធិលើបំណុលកម្ចីដែលបង់ការប្រាក់ក្នុងរយៈពេលកំណត់ជាដើម ដែលជាសិទ្ធិលើបំណុលមានកម្មវត្ថុជាការផ្តល់តាវកាលិកជាបន្តបន្ទាប់។

## ៥. ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ (មាត្រា១៩៨)

មាត្រា១៩៨-១ បញ្ញត្តអំពីការជាប់គ្នា នៃចលនវត្ថុច្រើនរបស់កម្មសិទ្ធិករផ្សេងគ្នា បានជាប់គ្នា ហើយដែលមិនអាចបំបែកឲ្យដាច់ពីគ្នាបាន ដោយមិនធ្វើឲ្យចលនវត្ថុនោះបែកបាក់ ឬ អាចជាករណីដែលត្រូវចំណាយសោហ៊ុយច្រើនហួសហេតុដើម្បីធ្វើការបំបែកចលនវត្ថុនោះ កម្មសិទ្ធិនៃវត្ថុភ្ជាប់គ្នានោះ ត្រូវធ្លាក់ទៅកម្មសិទ្ធិករនៃចលនវត្ថុដែលជាចំណែកចម្បង។ ការបែងចែកអំពីចំណែកចម្បង និង ចំណែកបន្ទាប់បន្សំ គឺអាស្រ័យទៅលើទស្សនៈសង្គមជាក់ស្តែង ប៉ុន្តែក្នុងករណីដែលមិនអាចបែងចែកឲ្យដាច់ថា ចំណែកណាជាចំណែកចម្បង ចំណែកណាជាចំណែកបន្ទាប់បន្សំ កម្មសិទ្ធិករនៃ

ចលនវត្ថុនីមួយៗនោះ នឹងក្លាយទៅជាម្ចាស់កម្មសិទ្ធិអវិភាគដោយគិតទៅតាមសមាមាត្រនៃតម្លៃនីមួយៗនាពេលជាប់គ្នានោះ។ ករណីដែលយកម៉ាស៊ីនទៅភ្ជាប់នឹងទូក ឬករណីដែលនិយោជករោងចក្របានយកបរិក្ខាររបស់ខ្លួន ទៅភ្ជាប់នឹងម៉ាស៊ីនដែលមាននៅក្នុងរោងចក្រជាដើមនោះ គឺជាឧទាហរណ៍នៃការជាប់គ្នានៃចលនវត្ថុ។ ករណីដែលវត្ថុរឹងលាយបញ្ចូលគ្នាហើយពិបាកនឹងបំបែកចេញពីគ្នា គឺជាការលាយគ្នា ដូចជាករណីដែលកម្មសិទ្ធិករនៃអង្ករផ្សេងគ្នាបានយកអង្ករនោះមកច្របល់បញ្ចូលគ្នា គឺជាឧទាហរណ៍នៃការលាយគ្នានៃចលនវត្ថុ។ មួយទៀត ករណីដែលវត្ថុរាវលាយបញ្ចូលគ្នា គឺជាការច្របល់គ្នា ដូចជាករណីដែលកម្មសិទ្ធិករនៃប្រេងផ្សេងគ្នាបានយកប្រេងមកលាយបញ្ចូលគ្នាជាដើម គឺជាឧទាហរណ៍នៃការលាយគ្នានៃចលនវត្ថុ។

**ករណីទី១៖** លោក ក មានទូកមួយ ហើយបានភ្ជាប់ម៉ាស៊ីនដែលជារបស់លោក ខ ទៅនឹងទូកនោះ។ ពុំមានការព្រមព្រៀងជាក់លាក់រវាងលោក ក និងលោក ខ ស្តីពីការភ្ជាប់ម៉ាស៊ីនឡើយ។ តើនរណាជាម្ចាស់កម្មសិទ្ធិករនៃទូកនោះ?
ប្រសិនបើលទ្ធផលដែលលោក ខ បានភ្ជាប់ម៉ាស៊ីននោះ ធ្វើឲ្យម៉ាស៊ីននោះមិនអាចបំបែកចេញពីទូកបានដោយមិនធ្វើឲ្យខូចម៉ាស៊ីន ឬ ត្រូវចំណាយសោហ៊ុយហួសហេតុក្នុងការបំបែកទេ ទូក និងម៉ាស៊ីននោះនឹងក្លាយជាវត្ថុភ្ជាប់គ្នាតែមួយ ហើយកម្មសិទ្ធិនឹងធ្លាក់ទៅលើកម្មសិទ្ធិករនៃចលនវត្ថុដែលជាចំណែកចម្បង។ ក្នុងករណីនេះ រវាងទូក និងម៉ាស៊ីន តើមួយណាជាចលនវត្ថុចម្បងនោះត្រូវពិចារណាទៅលើតម្លៃជាអាទិ៍ ហើយត្រូវសម្រេចតាមការយល់ឃើញជាទូទៅនៅក្នុងសង្គម ប៉ុន្តែប្រសិនបើគ្មានស្ថានភាពពិសេសទេ ជាទូទៅ ទូកត្រូវបានគេចាត់ទុកថាជាចលនវត្ថុចម្បង។ ករណីនេះ លោក ក នឹងក្លាយជាកម្មសិទ្ធិករនៃទូកទាំងមូល រួមទាំងម៉ាស៊ីនរបស់លោក ខដែលបានភ្ជាប់នឹងទូកនោះផងដែរ។ ក្នុងករណីដែលលោក ក បានធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុភ្ជាប់គ្នាហើយ លោក ខ អាចទាមទារលោក ក នូវទឹកប្រាក់សមរម្យទៅនឹងតម្លៃម៉ាស៊ីនដែលជាប្រាក់សំណង (មាត្រា ២០១)។

**ករណីទី២៖** លោក សុក ជាជាងសំណង់ គាត់បានលាយខ្សាច់ និង ស៊ីម៉ង់ច្របល់បញ្ចូលគ្នា ក្រោយមកទៀតគាត់រកឃើញថា ខ្សាច់ដែលគាត់យកមកលាយនោះជារបស់លោក សៅ ដែលជាជាងសំណង់ម្នាក់ទៀត។ តើនរណាជាម្ចាស់ស៊ីម៉ង់ដែលបានលាយនោះ?

ករណីនេះ មានការលាយគ្នារវាងស៊ីម៉ង់ និងខ្សាច់ដែលជាវត្ថុរឹង ហេតុនេះជាបញ្ហាពាក់ព័ន្ធនឹងការលាយគ្នានៃចលនវត្ថុ។ ករណីដែលចលនវត្ថុច្រើនបានលាយគ្នា ហើយមិនអាចបំបែកចេញពីគ្នាបាន (មាត្រា ១៩៨ កថាខណ្ឌទី ៣) ត្រូវអនុលោមតាមកថាខណ្ឌទី ១ និងទី ២ នៃមាត្រា ១៩៨។ ហេតុនេះ ត្រូវធ្វើការពិចារណាតម្លៃ និងបរិមាណជាអាទិ៍ ដែលស៊ីម៉ង់ និងខ្សាច់បានលាយគ្នារួច ហើយផ្អែកតាមការយល់ឃើញជាទូទៅរបស់សង្គម ធ្វើការវិនិច្ឆ័យថា វត្ថុមួយណាជាចលនវត្ថុ

ចម្បង ហើយកម្មសិទ្ធិករនោះត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុភ្ជាប់គ្នានោះ។ ក្នុងករណីដែលមិនអាចបែងចែកចំណែកចម្បង និង ចំណែកបន្ទាប់បន្សំបាន កម្មសិទ្ធិករនៃខ្សាច់ និងកម្មសិទ្ធិករនៃស៊ីម៉ង់នឹងក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគទៅតាមសមាមាត្រនៃតម្លៃនៅពេលដែលលាយចូលគ្នានោះ។

## ៦. ការកែច្នៃចលនវត្ថុ (មាត្រា១៩៩)

សំដៅទៅលើការបង្កើតវត្ថុថ្មីដោយបន្ថែមការកែច្នៃទៅលើវត្ថុអ្នកដទៃ។ ឧទាហរណ៍ ករណីដែលយកក្រណាត់ទៅកាត់ធ្វើជាសំលៀកបំពាក់ជាដើម។ ករណីយកវត្ថុអ្នកដទៃទៅកែច្នៃបង្កើតជាវត្ថុថ្មី តើវត្ថុថ្មីនោះធ្លាក់ទៅលើកម្មសិទ្ធិករនៃធាតុផ្សំ ឬអ្នកកែច្នៃ គឺជាបញ្ហា។ ស្តីពីបញ្ហានេះ មានទស្សនៈ ២ គឺទស្សនៈធាតុផ្សំ ដែលទទួលស្គាល់ថាអ្នកផ្គត់ផ្គង់ធាតុផ្សំ គឺជាកម្មសិទ្ធិករ និងទស្សនៈកែច្នៃ ដែលទទួលស្គាល់អ្នកកែច្នៃគឺជាកម្មសិទ្ធិករ ប៉ុន្តែក្រមរដ្ឋប្បវេណីកម្ពុជា អនុវត្តគោលការណ៍នៃទស្សនៈកែច្នៃ។ ប៉ុន្តែ មានករណីលើកលែង ដែលករណីខាងក្រោម គឺកម្មសិទ្ធិករធាតុផ្សំជាអ្នកធ្វើលទ្ធកម្មលើកម្មសិទ្ធិ។

ក. ករណីដែលតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះតិចហួសហេតុជាងតម្លៃវត្ថុធាតុដើម (កថាខណ្ឌទី ១ វាក្យខ័ណ្ឌទី ២)។

ខ. ករណីដែលអ្នកកែច្នៃវត្ថុបានផ្តល់វត្ថុធាតុដើមមួយចំណែក ហើយតម្លៃវត្ថុធាតុដើម ព្រមទាំងតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ មិនលើសពីតម្លៃវត្ថុធាតុដើមនៃអ្នកដទៃ (កថាខណ្ឌទី ២)។

ជាទូទៅ រវាងអ្នកផ្គត់ផ្គង់ធាតុផ្សំ និងអ្នកកែច្នៃ គឺមានទំនាក់ទំនងកិច្ចសន្យាអ្វីមួយ ហើយការកំណត់អំពីកម្មសិទ្ធិ ក៏បានកំណត់នៅក្នុងទំនាក់ទំនងកិច្ចសន្យានោះដែរ។ មាត្រានេះ អនុវត្តចំពោះតែករណីដែលភាគីទាំងពីរពុំមានទំនាក់ទំនងកិច្ចសន្យាតែប៉ុណ្ណោះ។

<u>**ករណីសិក្សា**</u>

១. B បានយកព្រះពុទ្ធរូបមាសរបស់ A ទៅរំលាយធ្វើជាដុំមាស។ តើ A ឬ B ដែលមានកម្មសិទ្ធិលើដុំមាសនោះ?

ដើម្បីអនុវត្តបញ្ញត្តិស្តីពីការកែច្នៃ ចាំបាច់ត្រូវមានការបង្កើតវត្ថុថ្មីដោយផ្អែកលើការកែច្នៃ។ វត្ថុដែលគ្រាន់តែបង្កើតឡើងដោយការកែច្នៃ មិនអាចហៅថាជាវត្ថុថ្មីបានទេ ដោយសារតែកម្មសិទ្ធិច្បាស់ជាធ្លាក់ទៅកម្មសិទ្ធិករនៃធាតុផ្សំ ក្នុងករណីដែលទទួលស្គាល់ថាមានភាពដូចគ្នានឹងធាតុផ្សំ។ ក្នុងករណីសិក្សានេះ B គ្រាន់តែយកព្រះពុទ្ធរូបមាសមករំលាយធ្វើជាដុំមាសតែប៉ុណ្ណោះ ហេតុនេះផ្អែកតាមការយល់ឃើញជាទូទៅរបស់សង្គម មិនអាចទទួលស្គាល់ថាបានបង្កើតវត្ថុថ្មីនោះទេ ហើយបញ្ញត្តិស្តីពីការកែច្នៃក៏មិនអាចអនុវត្តបានដែរ។ ដូចនេះ A មានកម្មសិទ្ធិទៅលើដុំមាស។

២. ជាងចម្លាក់ល្បីឈ្មោះលោក B បានធ្វើការកែច្នៃទៅលើឈើមួយដុំរបស់ A បង្កើតបានជាចម្លាក់ដ៏រឹងមាំមួយ។ តើអ្នកណាមានកម្មសិទ្ធិទៅលើរូបចម្លាក់នោះ?

ករណីនេះ ជាងចម្លាក់ B បានកែច្នៃទៅលើឈើ ហើយបង្កើតជារូបចម្លាក់។ ផ្អែកតាមការយល់ឃើញជាទូទៅរបស់សង្គម ទទួលស្គាល់ថាបានបង្កើតនូវវត្ថុថ្មី ហេតុនេះ បញ្ញត្តិស្តីពីការកែច្នៃត្រូវយកមកអនុវត្ត ហើយ B ដែលជាអ្នកកែច្នៃត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិទៅលើរូបចម្លាក់ដែលបានបង្កើតរួចរាល់នោះ។ ប៉ុន្តែ ករណីការកើនឡើងនៃតម្លៃដោយការកែច្នៃ តិចជាងតម្លៃនៃវត្ថុធាតុផ្សំហួសហេតុពេក កម្មសិទ្ធិនៃវត្ថុកែច្នៃនោះនឹងធ្លាក់ទៅលើកម្មសិទ្ធិករនៃវត្ថុធាតុផ្សំ (កថាខណ្ឌទី ១ វាក្យខ័ណ្ឌទី ២) ហេតុនេះគេត្រូវធ្វើការសិក្សាទៅលើកម្រិតនៃការកើនឡើងនៃតម្លៃដោយផ្អែកទៅលើការកែច្នៃរបស់ B។ ជាទូទៅ ករណីដែលជាងចម្លាក់ល្បីឈ្មោះ B បានបង្កើតរូបចម្លាក់ដ៏រឹងមាំមួយចេញពីធាតុផ្សំ ប្រហែលជាមិនអាចនិយាយថា តម្លៃដែលកើនឡើងដោយការកែច្នៃ តិចជាងតម្លៃនៃវត្ថុធាតុផ្សំហួសហេតុនោះទេ។

## ៧. អានុភាពនៃឧបាគមន៍នៃចលនវត្ថុ (មាត្រា ២០០)

ការជាប់គ្នា ការលាយគ្នា ការច្របល់គ្នា និងការកែច្នៃចលនវត្ថុ ជារួមហៅថា ឧបាគមន៍នៃចលនវត្ថុ។ ករណីដែលមានឧបាគមន៍នៃចលនវត្ថុកើតឡើង តើសិទ្ធិដែលមាននៅលើចលនវត្ថុមុនឧបាគមន៍កើតឡើង នឹងទៅជាយ៉ាងណា? បញ្ញត្តិនៃឧបាគមន៍នេះ បានកំណត់បញ្ហានេះដូចខាងក្រោម ៖

ក. ក្នុងករណីដែលកម្មសិទ្ធិលើវត្ថុត្រូវរលត់ ដោយសារការជាប់គ្នា ការលាយច្របល់គ្នា សិទ្ធិដែលមានលើវត្ថុនោះ ក៏ត្រូវរលត់ដែរ (កថាខណ្ឌទី១)។

ខ.១. សិទ្ធិរបស់អ្នកដទៃដែលមានលើវត្ថុ ដែលធ្លាប់ជាកម្មសិទ្ធិរបស់ជនដែលក្លាយជាកម្មសិទ្ធិករនៃវត្ថុភ្ជាប់គ្នា វត្ថុលាយច្របល់គ្នា ឬវត្ថុកែច្នៃ ត្រូវបន្តអត្ថិភាពលើវត្ថុដែលត្រូវបានធ្វើលទ្ធកម្មជាថ្មីនេះទៀត។

ខ.២. ក្នុងករណីប្រសិនបើក្លាយជាកម្មសិទ្ធិអវិភាគ សិទ្ធិនោះត្រូវបន្តអត្ថិភាពលើចំណែកនៃម្ចាស់កម្មសិទ្ធិករអវិភាគនោះ។

## ៨. ឧបាគមន៍ និងសិទ្ធិទាមទារប្រាក់សំណង (មាត្រា ២០១)

តើបុគ្គលដែលបានបាត់បង់កម្មសិទ្ធិដោយសារឧបាគមន៍នៃចលនវត្ថុ អាចទាមទារប្រាក់សំណងចំពោះបុគ្គលដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិថ្មីបានឬទេ នោះគឺជាបញ្ហា។ បញ្ញត្តិនេះ បានចែងថា ជនដែលបានបាត់បង់សិទ្ធិដោយសារការជាប់គ្នា ការលាយច្របល់គ្នា និងការកែច្នៃ អាចទាមទារ

សំណងពីជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិនោះ ដោយផ្អែកទៅលើបញ្ញត្តិទាក់ទងនឹងសេចក្តីចម្រើនឥតហេតុ។

ការទាមទារឲ្យធ្វើបដិទានគឺ មិនត្រូវបានអនុញ្ញាតនោះទេ ពីព្រោះការដែលទទួលស្គាល់ឲ្យបំបែកវត្ថុ ធ្វើបដិទានឡើងវិញ ក្នុងករណីដែលចលនវត្ថុនោះត្រូវបានទទួលស្គាល់ថាបានភ្ជាប់គ្នាដោយមិនអាចបំបែកបាន ហើយបានបង្កើតនូវវត្ថុថ្មីតាមរយៈឧបាគមន៍គឺផ្ទុយនឹងគោលបំណង នៃបញ្ញត្តិនីមួយៗទាក់ទងនឹងឧបាគមន៍។

ISBN-13: 978-99963-26-10-3

# មេរៀន ភាគ ២

ឧបត្ថម្ភដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ
នៃប្រទេសជប៉ុន (JICA)

ហាមលក់